ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

# របាយការណ៍សង្ខេប

## ស្តីពី

## សមិទ្ធផលសំខាន់ៗរបស់

## រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ឆ្នាំ២០១៧-២០២១

ទីស្តីការគណៈរដ្ឋមន្ត្រី

ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ខែកុម្ភៈ ឆ្នាំ២០២២



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដំបូង
នីតិកាលទី៦នៃរដ្ឋសភា នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨






**សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដំបូង**
**នីតិកាលទី៦នៃរដ្ឋសភា នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨**







កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្នុងដំណាក់កាលជំងឺកូវីដ-១៩
កាលពីថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០២១

# បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភានេះ បានខិតខំបំពេញតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងអនុលោមតាមយុទ្ធសាស្ត្រ គោលនយោបាយសំខាន់ៗដទៃទៀត ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញឱ្យអនុវត្តក្រោមម្លប់នៃសន្តិភាពពេញលេញនៅទូទាំងប្រទេស។

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សមិទ្ធផលជាច្រើនអនេកដែលរាជរដ្ឋាភិបាលសម្រេចបានដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ដោយមើលឃើញពីសមិទ្ធផលទាំងនេះ ទីស្តីការគណៈរដ្ឋមន្ត្រីបានសហការជាមួយក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលរាជធានី ខេត្ត បានប្រមូលនិងរៀបចំចងក្រងអត្ថបទជាសៀវភៅរបាយការណ៍សង្ខេប ស្តីពីសមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រយៈពេល៥ឆ្នាំ(២០១៧-២០២១)នេះឡើង ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រ។

របាយការណ៍នេះ បានឆ្លុះបញ្ចាំងពីសកម្មភាពការងារយ៉ាងមមាញឹក រស់រវើក នៃកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរ ជំនះរាល់ឧបសគ្គនិងបញ្ហាប្រឈម ពិសេសការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជា ក៏ដូចជាសេដ្ឋកិច្ចរបស់ពិភពលោកទាំងមូល។ ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ឈ្លាសវៃ និងម៉ឺងម៉ាត់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជារក្សាបានស្ថានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការធានាបាននូវចីរភាព សមត្ថភាព និងលទ្ធភាពអាចគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ បានល្អប្រសើរ។ ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលផ្តោតលើការបង្កើនល្បឿននៃការកែទម្រង់កាន់តែស៊ីជម្រៅ អភិបាលកិច្ចកាន់តែល្អប្រសើរ បរិស្ថានគ្របដណ្តប់កាន់តែរឹងមាំ និងអំណោយផលសម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល ការផ្តល់អាទិភាពកាន់តែច្រើនជាងមុនដល់ការអភិវឌ្ឍធនធានមនុស្ស ការជំរុញធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យកាន់តែខ្លាំងក្លា ការអនុវត្តគោលនយោបាយ សេដ្ឋកិច្ច សង្គម ឌីជីថល ការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជននិងការងារ និងការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្នក្រោមម្លប់ដ៏ត្រជាក់ត្រជុំនៃសុខសន្តិភាព។

ទីស្តីការគណៈរដ្ឋមន្ត្រី សូមកោតសរសើរនិងថ្លែងអំណរគុណចំពោះក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលរាជធានី ខេត្ត ដែលបានផ្តល់កិច្ចសហការយ៉ាងល្អប្រសើរនាពេលកន្លងទៅក្នុងការផ្តល់ខ្លឹមសារអត្ថបទដើម្បីរៀបចំចងក្រងសៀវភៅ របាយការណ៍សង្ខេបដ៏មានសារៈសំខាន់នេះ។ ទីស្តីការគណៈរដ្ឋមន្ត្រី ជឿជាក់យ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលរាជធានី ខេត្តនឹងបន្តអនុវត្តតួនាទី ភារកិច្ចកាន់តែសស្រាក់សស្រាំ ដោយបន្តសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍និងចូលរួមគាំទ្រកាន់តែមុតមាំជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីសម្រេចបាននូវសមិទ្ធផលធំធេងថ្មីៗថែមទៀត ដែលជាគុណប្រយោជន៍សម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

ទីស្តីការគណៈរដ្ឋមន្ត្រី សូមសម្តែងការគោរពដឹងគុណដ៏ខ្ពង់ខ្ពស់បំផុត ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតនិងឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាស្ថាបនិកសន្តិភាព ដែលបាននិងកំពុងបន្តដឹកនាំនាវាកម្ពុជាឱ្យបោះជំហានទៅមុខឥតឈប់ឈរនិងសម្រេចបាននូវការអភិវឌ្ឍលើគ្រប់វិស័យទាំងផ្ទៃក្នុងជាតិ និងមានកិត្តិសព្ទល្បីរន្ទឺទាំងលើឆាកអន្តរជាតិគួរជាទីមោទនៈបំផុត។

**សូមអរគុណសន្តិភាព**

ថ្ងៃពុធ ១កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២

# មាតិកា


**គួលេខសំខាន់ៗ** ........ ១

**ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**

**ទី១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន** ........ ២

១- ការគ្រប់គ្រងក្របខ័ណ្ឌ និងការអភិវឌ្ឍអាជីពមន្ត្រីរាជការស៊ីវិល ........ ៤

១.១- ការកសាង និងការដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត ........ ៤

១.២- ការគ្រប់គ្រង និងការវិវឌ្ឍអាជីពរបស់មន្ត្រីរាជការស៊ីវិល ........ ៥

២- ការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ........ ៨

២.១- ការកែលម្អសេវាសាធារណៈ ........ ៨

២.២- ការកែទម្រង់ប្រព័ន្ធបៀវត្ស និងលាភការ ........ ៨

៣- ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល ........ ១០

៣.១- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ........ ១០

៣.២- ការធ្វើអធិការកិច្ចក្នុងវិស័យមុខងារសាធារណៈ ........ ១១

**ទី២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ** ........ ១១

១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ........ ១១

១.១- ការអប់រំ ........ ១១

១.២-ការបង្ការទប់ស្កាត់ ........ ១៣

១.៣- ការអនុវត្តច្បាប់បង្ក្រាប ........ ១៤

១.៤- ការបំពេញកាតព្វកិច្ចជាតិនិងអន្តរជាតិ ........ ១៦

២- ការអប់រំ ផ្សព្វផ្សាយ និងអធិការកិច្ច ........ ១៧

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ........ ១៧

២.១- ការងារនីតិកម្ម ........ ១៧

២.២- ការងារអប់រំផ្សព្វផ្សាយច្បាប់ ........ ១៧

២.៣- ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ........ ១៨

២.៤- ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា ........ ១៨

២.៥- ការងារទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ........ ១៨

២.៦- សកម្មភាពការងារអធិការកិច្ច ........ ១៨

**ទី៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ** ........ ២០

១- ការងារវិមជ្ឈការនិងវិសហមជ្ឈការ ........ ២០

១.១- ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ២០

១.២- ការងារវិមជ្ឈការនិងវិសហមជ្ឈការ ........ ២១

ក- ការគាំទ្រ និងតាមដាន ត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ....... ២១
ខ- ការផ្ទេរមុខងារនិងធនធាន ........ ២១
គ-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ២១
២- ការពង្រឹងវិស័យយុត្តិធម៌និងនីតិរដ្ឋ ........ ២២
២.១- ការពង្រឹងវិស័យយុត្តិធម៌ ........ ២២
ក- ការកសាងច្បាប់ ដើម្បីចូលរួមពង្រឹងនីតិរដ្ឋ ........ ២២
ខ- ការងារអប់រំនិងផ្សព្វផ្សាយច្បាប់ ........ ២២
គ- ការចេញព្រឹត្តិបត្រថ្កោលទោសនិងកម្រៃសេវា ........ ២៥
ឃ- ចៅក្រម ........ ២៥
ង- ក្រឡាបញ្ជី ........ ២៥
ច- មេធាវី ........ ២៦
ឆ- សារការី ........ ២៦
២.២- ការពង្រឹងនីតិរដ្ឋ ........ ២៦
៣- យន្តការដោះស្រាយបណ្តឹង ........ ៣៦
៣.១- ក្រសួងមហាផ្ទៃ ........ ៣៦
៣.២- ក្រសួងយុត្តិធម៌ ........ ៣៧
៣.៣- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ........ ៣៩
៣.៤- ក្រសួងធម្មការ និងសាសនា ........ ៤០
៣.៥- ការងារដោះស្រាយវិវាទដីធ្លី ........ ៤០
៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ........ ៤១
៤.១- លទ្ធផលការងាររបស់កងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិ ........ ៤១
ក-ការងារកែទម្រង់កងយោធពលខេមរភូមិន្ទ ........ ៤១
ខ- ការងារនីតិកម្ម ........ ៤២
គ- ការកសាងបណ្តាញផ្លូវគមនាគមន៍ សំណង់អគារ ........ ៤២
ឃ- ការងារអតីតយុទ្ធជន ........ ៤៣
៤.២- លទ្ធផលការងាររបស់កងនគរបាលជាតិនៃក្រសួងមហាផ្ទៃ ........ ៤៤
**ទី៤- ការពង្រឹងអភិបាលកិច្ចវិស័យឯកជន** ........ ៤៥

## បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

**ទី១- សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ** ........ ៤៦
១- កិច្ចការពារជាតិនិងថែរក្សាសន្តិសុខជាតិ ........ ៤៦
២- គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ........ ៤៨
៣- ការងារប្រជាធិបតេយ្យនីយកម្ម ........ ៥០

៣.១- គណបក្សនយោបាយ ..... ៥០
៣.២- ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ..... ៥០
៤- ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន ..... ៥៤
៤.១- ការងារច្រកទ្វារព្រំដែន ..... ៥៤
៤.២- ការការពារដែនអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា ..... ៥៥
៥- ការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ ឃុំ មានសុវត្ថិភាព» ..... ៥៦
៦- លទ្ធផលនៃការបង្ក្រាបបទល្មើស រក្សាសុវត្ថិភាពសង្គម ..... ៥៦
៧- ការងារគ្រប់គ្រងពន្ធនាគារ ..... ៥៧
៧.១-ក្របខ័ណ្ឌគោលនយោបាយច្បាប់ ..... ៥៧
៧.២-អំពីស្ថានភាពជនជាប់ឃុំ ..... ៥៧
៧.៣- ស្ថានភាពជនជាប់ឃុំទទួលបានការអប់រំកែប្រែ និងការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ..... ៥៨
៨-ការងារអត្តសញ្ញាណកម្ម ..... ៥៨
៩- ការងារចុះបញ្ជីអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម ..... ៥៨
១០-ការងារអន្តោប្រវេសន៍ ..... ៥៩

**ទី២- បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ ..... ៦០**

១- ការងារកម្មសិទ្ធិបញ្ញា និងការចុះបញ្ជីម៉ាក និងសេវាពាក់ព័ន្ធ ..... ៦០
២- ការចុះបញ្ជីពាណិជ្ជកម្ម ..... ៦១

**ទី៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ ..... ៦២**

១- ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ និងអធិបតេយ្យ ..... ៦៣
១.១- ការការពារឯករាជ្យ អធិបតេយ្យ និងកិត្តិយសជាតិ ..... ៦៣
១.២- ការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស ..... ៦៣
២- ការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ ..... ៦៤
៣- ការងារសង្គមស៊ីវិល ..... ៦៥
៣.១-ការចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ ..... ៦៥
៣.២- ការចុះឈ្មោះក្នុងបញ្ជីនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ..... ៦៥
៤- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា) ..... ៦៥

**ទី៤- ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ..... ៦៧**

១- ទំនាក់ទំនងទ្វេភាគី ..... ៦៨
២- ទំនាក់ទំនងពហុភាគី ..... ៧២
៣- ការអនុវត្តការងារការទូត សេដ្ឋកិច្ច និងវប្បធម៌ ..... ៧៥

៤- ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងដំណោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក.... ៧៦
៥- ការចូលរួមរបស់កងយោធពលខេមរភូមិន្ទ ក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ............ ៧៧

## ចតុកោណយុទ្ធសាស្ត្រទី១

## ការអភិវឌ្ឍធនធានមនុស្ស

**មុំទី១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** ............ ៧៩
១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស ............ ៧៩
១.១- ការអប់រំចំណេះទូទៅនិងឧត្តមសិក្សា ............ ៨០
១.២- គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរនិងបរទេស ............ ៨២
១.៣- ការអប់រំឌីជីថល ............ ៨២
១.៤- ការងារយុវជន អប់រំកាយ និងកីឡា ............ ៨៤
ក- សមិទ្ធផលសំខាន់ៗនៃការងារយុវជន ............ ៨៤
ខ- សមិទ្ធផលសំខាន់ៗនៃការងារអប់រំកាយ និងកីឡា ............ ៨៥
១.៥- ការងារកីឡានៃក្រសួងការពារជាតិ ............ ៨៧
**មុំទី២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស** ............ ៨៧
១- ការបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ស្ថាប័ន ............ ៨៧
២- ការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ............ ៨៨
២.១- ក្រសួងមហាផ្ទៃ ............ ៨៨
២.២- ក្រសួងការពារជាតិ ............ ៨៩
២.៣- គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ............ ៩០
២.៤- ក្រសួងមុខងារសាធារណៈ ............ ៩០
២.៥- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ............ ៩១
២.៦- ក្រសួងសុខាភិបាល ............ ៩២
២.៧- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ............ ៩៣
២.៨- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ............ ៩៥
២.៩- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ............ ៩៦
២.១០- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ............ ៩៦
២.១១- ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ............ ១០២
២.១២- ក្រសួងផែនការ ............ ១០៣
២.១៣-ក្រសួងអភិវឌ្ឍន៍ជនបទ ............ ១០៣

២.១៤- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ........ ១០៣
២.១៥- ក្រសួងកិច្ចការនារី ........ ១០៥
២.១៦- ក្រសួងធម្មការ និងសាសនា ........ ១០៥
២.១៧- ក្រសួងសាធារណការ និងដឹកជញ្ជូន ........ ១០៦
២.១៨- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ........ ១០៦
២.១៩- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ........ ១០៧

**មុំទី៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហាររូបត្ថម្ភ** ........ ១០៧

១- សមិទ្ធផលសម្រេចបានក្នុងការអនុវត្តគោលនយោបាយអាទិភាព និងសកម្មភាពអន្តរាគមន៍វិស័យសុខាភិបាល ........ ១០៨
២- លើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ ........ ១០៩
២.១- ការលើកកម្ពស់សុខភាពបន្តពូជ ........ ១០៩
២.២- ការលើកកម្ពស់សុខភាពមាតានិងទារក ........ ១០៩
២.៣- ការលើកកម្ពស់សុខភាពកុមារ ........ ១១០
២.៤- ការកែលម្អកង្វះអាហារូបត្ថម្ភ ........ ១១១
៣- ការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩(២០២០-២០២១) ........ ១១២
៣.១- ផែនការជាតិឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ........ ១១២
៣.២- ការចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៃក្រសួងការពារជាតិ ........ ១១៤
៤- ការកាត់បន្ថយការឈឺនិងស្លាប់ដែលបណ្តាលមកពីជំងឺឆ្លងផ្សេងទៀត ........ ១១៤
៤.១- ការបន្ថយបន្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ ........ ១១៤
៤.២- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍(ឆ្នាំ២០១៧-២០២១) ........ ១១៥
៤.៣- ការបន្ថយបន្ទុកជំងឺរបេង ........ ១១៨
៤.៤- ការបន្ថយបន្ទុកជំងឺគ្រុនចាញ់ ........ ១១៩
៥- បង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ ........ ១២០
៥.១- ជំងឺទឹកនោមផ្អែម បេះដូង សរសៃឈាម មហារីក ........ ១២០
៥.២- ជំងឺផ្លូវចិត្តនិងភាពញៀនគ្រឿងញៀន ........ ១២១
៥.៣- សេវាបង្ការនិងគ្រប់គ្រងពិការភាពភ្នែក ........ ១២២
៦- ការពង្រឹងប្រព័ន្ធសុខាភិបាល ........ ១២២
៦.១- ការប្រើប្រាស់សេវាសុខភាពទូទៅ ........ ១២២
៦.២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ ១២៣
៦.៣- ពង្រឹងការបង្ការហានិភ័យហិរញ្ញវត្ថុ ........ ១២៤
៦.៤- ការគ្រប់គ្រងបុគ្គលិក ........ ១២៤
៦.៥- សេវាគាំទ្រជាសារវ័ន្ត ........ ១២៥
៦.៦- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា ........ ១២៥
៦.៧- ការចូលរួមរបស់សហគមន៍និងរដ្ឋបាលមូលដ្ឋានដើម្បីសុខភាព ........ ១២៦

៧- ការលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ............ ១២៧

**មុំទី៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម** ............ ១៣០

១- ការពង្រឹងសមភាពយេនឌ័រ ............ ១៣០

១.១- ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ............ ១៣១

១.២- ការអប់រំស្ត្រីនិងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ ............ ១៣១

១.៣- ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារី និងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ............ ១៣២

១.៤- កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី ............ ១៣៣

១.៥- ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ ............ ១៣៤

១.៦- យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ............ ១៣៥

១.៧- លទ្ធផលការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស.) ............ ១៣៦

១.៨- លទ្ធផលការងារអន្តរវិស័យ ............ ១៣៦

១.៩- ការផលិត ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងជាសាធារណៈ ............ ១៣៩

២- ការលើកកម្ពស់ការគាំពារសង្គម ............ ១៣៩

២.១- ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ............ ១៤០

២.២- ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ ............ ១៥០

៣- ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍន៍ភាពជាដៃគូ ............ ១៥៣

៤- ការអនុវត្តគោលនយោបាយជាតិប្រជាជន ............ ១៥៤

៤.១- ការងារផែនការជាតិនិងគោលនយោបាយ ............ ១៥៤

៤.២- ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ............ ១៥៦

៤.៣- ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ............ ១៥៦

៤.៤- ការងារផែនការថ្នាក់ក្រោមជាតិ ............ ១៥៩

៤.៥- ការងារលើកកម្ពស់អាហារូបត្ថម្ភ ............ ១៥៩

៤.៦- ទិន្នន័យគ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេលជំងឺកូវីដ-១៩ ............ ១៦០

៤.៧- សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ ............ ១៦១

## ចតុកោណយុទ្ធសាស្ត្រទី២

## ការធ្វើពិពិធកម្មសេដ្ឋកិច្ច

**មុំទី១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូនថាមពល និងឌីជីថល** ............ ១៦៨

១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ............ ១៦៨

១.១- ការងារដឹកជញ្ជូនផ្លូវគោក ..... ១៦៨
១.២- ការងារដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ..... ១៧០
១.៣- ការងារផ្លូវដែក ..... ១៧២
១.៤- ការងាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ..... ១៧៣

**សមិទ្ធផលការងារវិស័យអាកាសចរណ៍ស៊ីវិលរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៧-២០២១**

១-ការងារដឹកជញ្ជូនតាមផ្លូវអាកាស ..... ១៧៤
១.១- ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកនិងអន្តរជាតិដែលបានហោះហើរចេញចូល ព្រះរាជាណាចក្រកម្ពុជា ..... ១៧៤
១.២- ការដឹកជញ្ជូនតាមផ្លូវអាកាសក្នុងស្រុកនិងអន្តរជាតិ ..... ១៧៤
១.៣- កិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ..... ១៧៥
១.៤- ដំណើរការគាំទ្រឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស ..... ១៧៥
២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ អន្តរជាតិ ..... ១៧៦
៣- ការពង្រឹងសន្តិសុខអាកាសចរណ៍ស៊ីវិល ..... ១៧៩
៤- សេវាកម្មអាកាសចរណ៍ ..... ១៨៣
២- ថាមពល ..... ១៨៥
១- វិស័យថាមពល ..... ១៨៦
១.១- តម្លៃអគ្គិសនី និងការងារសង្គមកិច្ច ..... ១៨៦
១.២- ការពង្រីកតំបន់គ្របដណ្តប់ ..... ១៨៧
១.៣- ការអភិវឌ្ឍប្រភពអគ្គិសនី ..... ១៨៨
១.៤- ការងារគ្រប់គ្រង បច្ចេកទេសអគ្គិសនី និងបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម ..... ១៨៨
២- វិស័យរ៉ែ ..... ១៨៩
២.១- ការងារពង្រឹងអភិបាលកិច្ចធនធានរ៉ែ ..... ១៨៩
២.២- ការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ..... ១៩០
២.៣- ការការពារបរិស្ថាននិងសង្គម ..... ១៩២
**មុំទី២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ** ..... ១៩៣
១- ការកៀរគរចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ ..... ១៩៣
២- វិស័យប្រេងកាត ..... ១៩៤
២.១- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យប្រេងកាត ..... ១៩៤
២.២- ចំណូលមិនមែនសារពើពន្ធពីវិស័យប្រេងកាត ..... ១៩៦
៣- ការងារចុះបញ្ជីរោងចក្រ ..... ១៩៦
៤- កិច្ចការឧស្សាហកម្ម ..... ១៩៧
៤.១- រោងចក្រ ..... ១៩៧

៤.២- កម្លាំងពលកម្ម ........ ១៩៨
៤.៣- ទុនវិនិយោគ ........ ១៩៨
៤.៤- តម្លៃបរិមាណផលិតផល ........ ១៩៩
៤.៥- កម្រងសេវាសាធារណៈ ........ ១៩៩
៤.៦- ការងារកម្មសិទ្ធិឧស្សាហកម្ម ........ ២០០
៤.៧- ការងារទឹកស្អាត ........ ២០០
៤.៧.១- ការងារផលិតកម្មទឹកស្អាតសាធារណៈរាជធានី-ខេត្ត និងឯកជនទូទាំងប្រទេស ........ ២០១
៤.៧.២- ការងារបញ្ញត្តកម្មទឹកស្អាត ........ ២០២
៤.៧.៣- ការងារគម្រោងនិងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ........ ២០៣
៤.៨- ការងារស្តង់ដារូបនីយកម្ម ........ ២០៨
៤.៩- វិស័យមាត្រាសាស្ត្រជាតិ ........ ២១១
៤.៩.១- ហេដ្ឋារចនាសម្ព័ន្ធ ........ ២១១
៤.៩.២- ការងារកិច្ចការទូទៅ ការងារបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំការងារសហប្រតិបត្តិការ គម្រោងនិងផែនការ ........ ២១១
៥- ការជំរុញវិស័យទេសចរណ៍និងផ្នែកសេវាកម្សាន្ត ........ ២១៥
៥.១- ការអភិវឌ្ឍផលិតផលទេសចរណ៍ ........ ២១៥
៥.១.១- រមណីយដ្ឋានទេសចរណ៍ វប្បធម៌ ធម្មជាតិ និងកែច្នៃ ........ ២១៥
៥.១.២- ការអភិវឌ្ឍតំបន់សមុទ្រ ........ ២១៦
៥.១.៣- ការងាររៀបចំសហគមន៍ទេសចរណ៍ សហគមន៍អេកូទេសចរណ៍ ........ ២១៦
៥.១.៤- ការងាររៀបចំព្រឹត្តិការណ៍ទេសចរណ៍ ........ ២១៧
៥.២- ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ........ ២១៧
៥.២.១- ស្ថិតិឧស្សាហកម្មទេសចរណ៍ ........ ២១៧
៥.២.២- មគ្គុទ្ទេសក៍ទេសចរណ៍គិតត្រឹមឆ្នាំ២០២១ ........ ២១៧
៥.២.៣- ប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ ........ ២១៨
៥.២.៤- ការជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ........ ២១៩
៥.៣- ការងារជំរុញវិស័យទេសចរណ៍ ........ ២១៩
៥.៤- ភ្ញៀវទេសចរជាតិនិងអន្តរជាតិ និងស្ថិតិទេសចរណ៍ និងការបង្កើតការងារ ........ ២២០
៥.៥- ស្ថិតិភ្ញៀវទេសចរអន្តរជាតិទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរសៀមរាប ........ ២២១
៦- ការងារចំណូលពីសេវាវិស័យដីធ្លីនិងសំណង់ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ........ ២២១
៧- ការងារហិរញ្ញវត្ថុ និងថវិកា(រដ្ឋបាលកណ្តាលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍) ........ ២២២

**មុំទី៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤** ........ ២២២

១- វិស័យប្រៃសណីយ៍ ........ ២២៣

១.១- ការងារគ្រប់គ្រងនិងត្រួតពិនិត្យទៅលើប្រតិបត្តិករអាជីវកម្មវិស័យប្រៃសណីយ៍......................២២៣
១.២- សហគ្រាសប្រៃសណីយ៍កម្ពុជា ..............................................................................................២២៤
២- វិស័យទូរគមនាគមន៍ ...................................................................................................................២២៥
៣- វិស័យបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន ...........................................................................២២៥
៤- សហគ្រាសទូរគមនាគមន៍កម្ពុជា.....................................................................................................២២៨
៤.១- ការងារអាជីវកម្ម .....................................................................................................................២២៨
៤.២- ការងារហិរញ្ញកិច្ច និងគណនេយ្យ .........................................................................................២២៩
៥- និយ័តករទូរគមនាគមន៍កម្ពុជា .......................................................................................................២៣០
៥.១- ការងារនិយ័តកម្មទូរគមនាគមន៍ .............................................................................................២៣០
៥.២- ការងារនិយ័តកម្មប្រេកង់វិទ្យុ ..................................................................................................២៣១
**មុំទី៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ**..............................................................២៣២
១- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុសាធារណៈ ..........................................................................២៣២
១.១- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា ..........................................................................................២៣៣
១.២- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកា ...............................................................២៣៥
១.២.១- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ .........................................................................................២៣៥
១.២.២- ការអនុវត្តថវិកា.....................................................................................................................២៣៦
១.៣- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ........................................................................... ២៤០
១.៣.១- វិស័យអភិវឌ្ឍហិរញ្ញវត្ថុ........................................................................................................ ២៤០
១.៣.២- វិស័យអភិវឌ្ឍហិរញ្ញវត្ថុមិនមែនធនាគារ.................................................................................២៤២
១.៤- ការកៀរគរហិរញ្ញវត្ថុពីក្រៅប្រទេស ......................................................................................... ២៤៥
១.៥- វិធានការ និងការអនុវត្តគោលនយោបាយពាក់ព័ន្ធសំខាន់ៗ ...................................................... ២៤៥
២- ការអភិវឌ្ឍវិស័យធនាគារ ...........................................................................................................២៤៦
២.១- វិស័យធនាគារ ....................................................................................................................... ២៤៦
២.១.១- ការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច............................................................................. ២៤៦
២.១.២- ការអភិវឌ្ឍវិស័យធនាគារ ..................................................................................................... ២៤៦
២.២- សមិទ្ធផលសំខាន់ៗនៃប្រព័ន្ធធនាគារ.........................................................................................២៤៧
២.២.១- សមិទ្ធផលសំខាន់ៗនៃវិស័យធនាគារ ..................................................................................... ២៤៨
២.២.២- សមិទ្ធផលសំខាន់ៗនៃវិស័យមីក្រូហិរញ្ញវត្ថុ............................................................................ ២៥០
២.២.៣- វឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់........................................................................ ២៥១

**ចតុកោណយុទ្ធសាស្ត្រទី៣**

**ការអភិវឌ្ឍវិស័យឯកជននិងការងារ**

**មុំទី១- ការអភិវឌ្ឍទីផ្សារការងារ**.......................................................................................................... ២៥៤
១- ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ.............................................២៥៤

២- ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ... ២៥៨
៣- ការរក្សានិងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស ... ២៥៩
៤- ការអភិវឌ្ឍរបបសន្តិសុខសង្គម ... ២៦១
៥- ការពង្រឹងសេវាគាំទ្រទូទៅ ... ២៦៣
**មុំទី២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព** ... ២៦៤
១- ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម ... ២៦៤
១.១- សហគ្រាសធុនតូចនិងមធ្យមនិងសិប្បកម្ម ... ២៦៤
១.២- ការងារស្រែអំបិល ... ២៦៦
២- គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ ... ២៦៧
**មុំទី៣- ការរៀបចំនិងការអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន** ... ២៧០
គណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ... ២៧០
**មុំទី៤- ការពង្រឹងការប្រកួតប្រជែង** ... ២៧២
១- ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ... ២៧២
១.១- ការនាំចេញផលិតផលកសិកម្មសំខាន់ៗ ... ២៧២
១.២- ការនាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វពីឆ្នាំ២០១៧-២០២១ ... ២៧២
២- ទំហំពាណិជ្ជកម្ម ... ២៧៣
៣- ការងារពាណិជ្ជកម្ម ... ២៧៣
៣.១- ស្ថិតិពាណិជ្ជកម្មកម្ពុជាជាមួយដៃគូសំខាន់ៗរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៧-២០២១ ... ២៧៣
៣.២- ការងារកសាង និងផ្សព្វផ្សាយបញ្ញត្តិច្បាប់ពាណិជ្ជកម្ម ... ២៧៤
៣.៣- ការងារអភិវឌ្ឍវិស័យឯកជន ... ២៧៥
៣.៤- ការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច AIMS ... ២៧៦
៣.៥- ការងារសមាហរណកម្មពាណិជ្ជកម្មអន្តរជាតិ ... ២៧៦
៣.៥.១- ការងារចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ... ២៧៦
៣.៥.២- កិច្ចព្រមព្រៀងទូទៅ ពិធីសារ អនុស្សរណៈយោគយល់គ្នា និងការកសាងលិខិតបទដ្ឋានគតិយុត្ត ... ២៧៦
៣.៥.៣- ការងារជំរុញពាណិជ្ជកម្មនិងបើកច្រកទីផ្សារ ... ២៧៧
៣.៥.៤- ក្រុមហ៊ុនហ្គ្រីនត្រេដ ... ២៧៧
៤- ការត្រួតពិនិត្យស្តង់ដា គុណភាព សុវត្ថិភាព និងផលិតផលទំនិញ ... ២៧៨
៤.១- អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ«ក.ប.ប.» ... ២៧៨
៤.២- ការងារមន្ទីរពិសោធន៍ ... ២៧៨

# ចតុកោណយុទ្ធសាស្ត្រទី៤
# ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន


**មុំទី១- ការលើកស្ទួយវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ** ........................................ ២៨០

១- ការលើកស្ទួយវិស័យកសិកម្ម ........................................ ២៨០

២- សមិទ្ធផលក្នុងវិស័យកសិកម្មសម្រេចបានពីឆ្នាំ២០១៧-២០២១ ........................................ ២៨០

២.១- ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច ........................................ ២៨១

២.១.១- ផលិតកម្មដំណាំស្រូវ ........................................ ២៨១

២.១.២- ផលិតកម្មដំណាំសាកវប្បកម្ម ........................................ ២៨១

២.១.៣- ផលិតកម្មដំណាំឧស្សាហកម្មឆ្នាំ២០១៧-២០២១ ........................................ ២៨២

២.១.៤- ការចងក្រងនិងចុះបញ្ជីសហគមន៍កសិកម្ម ........................................ ២៨៣

២.១.៥ ការងារកសិឧស្សាហកម្ម ........................................ ២៨៣

២.១.៦- ការបង្កើនផលិតភាពដំណាំកៅស៊ូ ........................................ ២៨៣

២.១.៧- ការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាកសិកម្ម ........................................ ២៨៤

២.២- ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........................................ ២៨៥

២.២.១- ការជំរុញការចិញ្ចឹមសត្វ និងបង្កើនផលិតភាពសត្វ ........................................ ២៨៥

២.២.២- ការលើកកម្ពស់សុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល ........................................ ២៨៦

២.៣- ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........................................ ២៨៧

២.៣.១- ស្ថិតិផលនេសាទ ........................................ ២៨៧

២.៣.២- ផលវារីវប្បកម្ម ........................................ ២៨៧

២.៣.៣- ការកែច្នៃផល ផលិតផលជលផល ........................................ ២៨៨

២.៣.៤- ការនាំចេញ ផលិតផលជលផល ........................................ ២៨៨

២.៣.៥- ការការពារបង្ក្រាបបទល្មើសជលផល ........................................ ២៨៨

២.៣.៦- ការអភិវឌ្ឍសហគមន៍នេសាទ ........................................ ២៨៨

២.៣.៧- ការងារកិច្ចការជលផល ........................................ ២៨៨

២.៣.៨- ការអភិរក្សធនធានជលផល ........................................ ២៨៨

២.៣.៩- ការសិក្សាស្រាវជ្រាវ ........................................ ២៨៩

៣- ការគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើនិងសត្វព្រៃ ........................................ ២៨៩

៤- លទ្ធផលនៃការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ........................................ ២៩១

៤.១- ការបោសសម្អាតគ្រាប់មីននិងស.ផ.ស. ........................................ ២៩២

៤.២- ការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ........................................ ២៩៣

៤.៣- ការគាំទ្រខាងផ្នែកសម្ភារៈដល់កងទ័ពជើងគោកនិងបោសសម្អាតមីនតាមព្រំដែន ........................................ ២៩៤

៤.៤- ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងអាជ្ញាធរមីន និងក្រសួងពាក់ព័ន្ធ ........................................ ២៩៤

៤.៥- ការកៀរគរនិងតម្រូវការធនធាន ........ ២៩៤
៥- វឌ្ឍនភាពនៃការអនុវត្តលើវិស័យធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ(២០១៧-២០២១) ........ ២៩៤
៥.១- ការស្ដារនិងការសាងសង់ប្រព័ន្ធធារាសាស្ត្រ ........ ២៩៥
៥.២- ការជួសជុល ថែទាំសំណង់សិល្បការ ........ ២៩៦
៥.៣- ការជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រដោយមានប្រជាពលរដ្ឋចូលរួម ........ ២៩៦
៥.៤- ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ........ ២៩៧
៥.៥- ការគ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត ........ ២៩៧
៥.៦- ការគ្រប់គ្រងនិងការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត ........ ២៩៩
៥.៧- ការគ្រប់គ្រងព័ត៌មានស្ដីពីធនធានទឹក និងឧតុនិយម ........ ៣០០
៥.៨- ការងារជលសាស្ត្រ ........ ៣០១
៥.៩- ការងារឧតុនិយម ........ ៣០១
៥.១០- ការការពារនិងការអភិរក្សធនធានទឹក ........ ៣០២
៦- ការអភិវឌ្ឍជនបទ ........ ៣០៣
៦.១- ការងារផ្លូវជនបទ ........ ៣០៣
៦.២- ការផ្គត់ផ្គង់ទឹកជនបទ ........ ៣០៣
៦.៣- ការថែទាំសុខភាពជនបទ ........ ៣០៤
៦.៤- ការអភិវឌ្ឍសហគមន៍ ........ ៣០៥
៦.៥- ការអភិវឌ្ឍសេដ្ឋកិច្ច ........ ៣០៥
៦.៦- ការអភិវឌ្ឍជនជាតិដើមភាគតិច ........ ៣០៥
**មុំទី២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព** ........ ៣០៥
១- ក្រសួងបរិស្ថាន ........ ៣០៥
១.១- ទំនើបកម្មស្ថាប័ន ........ ៣០៦
១.២- កិច្ចគាំពារបរិស្ថាន ........ ៣០៦
១.៣- ការគ្រប់គ្រងធនធានធម្មជាតិ ........ ៣០៨
១.៤- ការងារអប់រំនិងព័ត៌មានបរិស្ថាន ........ ៣០៩
២- វប្បធម៌ សាសនា និងព័ត៌មាន ........ ៣១២
២.១- លទ្ធផលការងារសំខាន់ៗរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ........ ៣១២
២.២- សមិទ្ធផលការងារសំខាន់ៗរយៈពេល៥ឆ្នាំ ........ ៣១៣
ការអភិរក្សវប្បធម៌ជាតិ ........ ៣១៣
២.២.១- ការអភិរក្សវប្បធម៌រូបី ........ ៣១៣
២.២.២- ការអភិរក្សវប្បធម៌អរូបី ........ ៣១៥
២.៣- ការលើកស្ទួយតម្លៃវប្បធម៌ជាតិ ........ ៣១៧
២.៣.១- ការលើកស្ទួយតម្លៃវប្បធម៌រូបី ........ ៣១៧

២.៣.២- ការលើកស្ទួយតម្លៃវប្បធម៌អរូបី ................ ៣១៨
២.៤- ការអភិវឌ្ឍវប្បធម៌ជាតិ ................ ៣២១
២.៤.១- ការអភិវឌ្ឍវប្បធម៌រូបី ................ ៣២១
២.៤.២- ការអភិវឌ្ឍវប្បធម៌អរូបី ................ ៣២២
២.៥- ការងារសាសនា ................ ៣២៤
២.៥.១- ការងារព្រះពុទ្ធសាសនា ................ ៣២៤
២.៥.២- ការងារពាហិរសាសនា ................ ៣២៥
២.៦- ការងារព័ត៌មាន ................ ៣៣១
២.៦.១- សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន ................ ៣៣២
២.៦.២- សូចនាករស្តីពីសមិទ្ធផលសំខាន់ៗ របស់ស្ថាប័នចំណុះក្រសួងព័ត៌មាន ................ ៣៣៤
**មុំទី៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម** ................ ៣៣៨
១- លទ្ធផលការងារសំខាន់ៗរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ................ ៣៣៨
១.១- ការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្ត ................ ៣៣៨
១.២- ការងាររដ្ឋបាលដីធ្លី ................ ៣៣៩
១.៣- ការអភិវឌ្ឍដោយចីរភាព ................ ៣៤៦
២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនៅតាមរាជធានី ខេត្ត ................ ៣៤៧
២.១- រាជធានីភ្នំពេញ ................ ៣៤៧
២.២- ខេត្តកណ្តាល ................ ៣៥៦
២.៣- ខេត្តកំពង់ឆ្នាំង ................ ៣៥៧
២.៤- ខេត្តកំពង់ស្ពឺ ................ ៣៦១
២.៥- ខេត្តព្រះសីហនុ ................ ៣៦៤
២.៦- ខេត្តកោះកុង ................ ៣៦៨
២.៧- ខេត្តកែប ................ ៣៧២
២.៨- ខេត្តកំពត ................ ៣៧៥
២.៩- ខេត្តតាកែវ ................ ៣៨០
២.១០- ខេត្តសៀមរាប ................ ៣៨៣
២.១១- ខេត្តកំពង់ធំ ................ ៣៨៩
២.១២- ខេត្តបាត់ដំបង ................ ៣៩២
២.១៣- ខេត្តប៉ៃលិន ................ ៤០១
២.១៤- ខេត្តបន្ទាយមានជ័យ ................ ៤០៣
២.១៥- ខេត្តពោធិ៍សាត់ ................ ៤០៦
២.១៦- ខេត្តឧត្តរមានជ័យ ................ ៤០៨
២.១៧- ខេត្តមណ្ឌលគិរី ................ ៤១១

២.១៨- ខេត្តរតនគិរី ........................................................................................................ ៤១៣
២.១៩- ខេត្តស្ទឹងត្រែង......................................................................................................៤១៥
២.២០- ខេត្តក្រចេះ...........................................................................................................៤១៦
២.២១- ខេត្តព្រះវិហារ ..................................................................................................... ៤២១
២.២២- ខេត្តត្បូងឃ្មុំ .......................................................................................................៤២៣
២.២៣- ខេត្តកំពង់ចាម..................................................................................................... ៤២៦
២.២៤- ខេត្តព្រៃវែង......................................................................................................... ៤២៧
២.២៥- ខេត្តស្វាយរៀង ..................................................................................................... ៤៣១
៣- ការបែងចែកដីក្នុងគោលដៅសម្បទានដីសង្គមកិច្ចនិងប្រទានកម្ម................................................. ៤៣៥
៤- ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យសំណង់........................................................................... ៤៣៥
**មុំទី៤- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** . ៤៣៦
១- ការធានាចីរភាពបរិស្ថាន ..................................................................................................... ៤៣៦
២- ការរៀបចំលំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុ............................................................៤៣៧
៣- ការសាងសង់ទីលានកប់សំរាម ការសាងសង់ប្រព័ន្ធលូចម្រោះទឹកកខ្វក់ និងទឹកភ្លៀង .....................៤៣៧
សកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ............................................................. ៤៣៩

# គំនូសបំព្រួញស្តីពី «យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤»
# ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព : កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០



# តួលេខសំខាន់ៗ

| | |
|---|---|
| ផ្ទៃដីសរុប : | ១៨១ ០៣៥គ.ម.$^{២}$ |
| ចំនួនរាជធានី : | ១ |
| ចំនួនខេត្ត : | ២៤ |
| ចំនួនស្រុក : | ១៦២ |
| ចំនួនខណ្ឌ : | ១៤ |
| ចំនួនក្រុង : | ២៧ |
| ចំនួនឃុំ : | ១ ៤០៥ |
| ចំនួនសង្កាត់ : | ២៥១ |
| ចំនួនភូមិ : (រួមទាំងភូមិឧបសម្ព័ន្ធ) : | ១៤ ៥៤៥ |
| ប្រជាជនសរុប(ជំរឿន២០១៩) : | ១៥ ៥៥២ ២១១នាក់ |
| ដង់ស៊ីតេប្រជាជន (ក្នុង ១គ.ម.$^{២}$) : | ៨៧ |
| ទំហំបឹងទន្លេសាប : | ៣ ០០០គ.ម.$^{២}$ |
| ភាគរយនៃប្រជាជនអាយុ ០-១៤(ជំរឿន២០១៩) : | ២៩,៤% |
| ភាគរយនៃប្រជាជនអាយុ ១៥-៥៩ (ជំរឿន២០១៩): | ៦១,៧% |
| ភាគរយនៃប្រជាជនអាយុ ៦០ឆ្នាំ : (ជំរឿន២០១៩) | ៨,៩% |
| អត្រាកំណើនប្រជាជនប្រចាំឆ្នាំ : | ១,៤% |
| អត្រាលទ្ធភាពបង្កើតកូនសរុប(ជំរឿនឆ្នាំ២០១៩) : | ២,៥នាក់ |
| ចំនួនគ្រួសារសរុប(ជំរឿនឆ្នាំ២០១៩) : | ៣ ៥៥៣ ០២១ |
| ទំហំគ្រួសារមធ្យម(ជំរឿនឆ្នាំ២០១៩) : | ៤,៣នាក់ |

## ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច

គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច គឺជាការធ្វើទំនើបកម្មស្ថាប័នរដ្ឋនិងការអភិវឌ្ឍប្រកបដោយបរិយាបន្ន សមធម៌និងយុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ចនិងរដ្ឋបាល ក្នុងការដឹកនាំគ្រប់គ្រងនិងចាត់ចែងកិច្ចការប្រទេសជាតិ ពិសេសការធានានិរន្តរភាពនៃតួនាទីនិងដំណើរការរដ្ឋបាលសាធារណៈដោយយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូលនិងការកសាងជាតិ។

**ទី១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន**

អនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា បានរៀបចំសមាសភាពរាជរដ្ឋាភិបាលដោយមានព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃ៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល និងព្រះរាជក្រឹត្យលេខ នស/រកត/១០២១/៧៥៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ស្តីពីការតែងតាំងជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ដែលមានដូចតទៅ៖

**ក- នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

**ខ- ឧបនាយករដ្ឋមន្ត្រី**

១- សម្តេចក្រឡាហោម **ស ខេង**
២- សម្តេចពិជ័យសេនា **ទៀ បាញ់**
៣- ឯកឧត្តម **ហោ ណាំហុង**
៤- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**
៥- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** (ប្រចាំការ)
៦- ឯកឧត្តម **យឹម ឆៃលី**
៧- ឯកឧត្តម **កែ គឹមយ៉ាន**
៨- ឯកឧត្តម **ប្រាក់ សុខុន**
៩- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**
១០- ឯកឧត្តម **ជា សុផារ៉ា**

**គ- ទេសរដ្ឋមន្ត្រី**

១- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**
២- ឯកឧត្តម **ប៉ុល សារឿន** (ទទួលបន្ទុកបេសកកម្មពិសេស)
៣- ឯកឧត្តម **គន់ គីម** (ទទួលបន្ទុកបេសកកម្មពិសេស)
៤- ឯកឧត្តម **មាស សុភា** (ទទួលបន្ទុកបេសកកម្មពិសេស)
៥- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**
៦- ឯកឧត្តម **ស៊ុន ចាន់ថុល**

៧- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឱម យ៉ិនទៀង** (ទទួលបន្ទុកបេសកកម្មពិសេស)
៨- ឯកឧត្តម **អៀង ម៉ូលី** (ទទួលបន្ទុកបេសកកម្មពិសេស)
៩- ឯកឧត្តម **វ៉ា គឹមហុង** (ទទួលបន្ទុកបេសកកម្មពិសេស)
១០- ឯកឧត្តម **យឹម ឈុលឡា** (ទទួលបន្ទុកបេសកកម្មពិសេស)
១១- ឯកឧត្តម **ហ៊ឹម ឆែម** (ទទួលបន្ទុកបេសកកម្មពិសេស) មរណភាព
១២- ឯកឧត្តម **ឋិន ម៉ិនស៊ាន** (ទទួលបន្ទុកបេសកកម្មពិសេស)
១៣- ឯកឧត្តម **ហូ សិទ្ធី** (ទទួលបន្ទុកបេសកកម្មពិសេស)
១៤- ឯកឧត្តម **យុន ហាំង** (ទទួលបន្ទុកបេសកកម្មពិសេស)
១៥- ឯកឧត្តម **លី ធុជ** (ទទួលបន្ទុកបេសកកម្មពិសេស)
១៦- ឯកឧត្តម **អូស្មាន ហាសាន់** (ទទួលបន្ទុកបេសកកម្មពិសេស)
១៧- ឯកឧត្តម **អង្គ វង្សវឌ្ឍនា** (ទទួលបន្ទុកបេសកកម្មពិសេស)
១៨- ឯកឧត្តម **ត្រាំ អ៊ីវតឹក** (ទទួលបន្ទុកបេសកកម្មពិសេស) មរណភាព
១៩- ឯកឧត្តម **ពេជ្រ ម៉ិនធិន** (ទទួលបន្ទុកបេសកកម្មពិសេស)
២០- ឯកឧត្តម **ប៉ា សុជាតិវង្ស** (ទទួលបន្ទុកបេសកកម្មពិសេស)

**ឃ- រដ្ឋមន្ត្រី**

១- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
២- សម្តេចក្រឡាហោម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
៣- សម្តេចពិជ័យសេនា **ទៀ បាញ់** រដ្ឋមន្ត្រីក្រសួងការពារជាតិ
៤- ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
៥- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៦- ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
៧- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
៨- ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
៩- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
១០- ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល
១១- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** រដ្ឋមន្ត្រីក្រសួងផែនការ
១២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
១៣- ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា
១៤- ឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៥- ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន

| | |
|---|---|
| ១៦- ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម |
| ១៧- ឯកឧត្តម **ខៀវ កាញារីទ្ធ** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន |
| ១៨- ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ១៩- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** | រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច |
| ២០- ឯកឧត្តម **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២១- ឯកឧត្តម **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ២២- ឯកឧត្តម **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន |
| ២៣- លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ២៤- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| ២៥- ឯកឧត្តម **ឈិត សុខុន** | រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា |
| ២៦- លោកជំទាវ **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ២៧- ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២៨- ឯកឧត្តម **ព្រុំ សុខា** | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
| ២៩- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល។ |

## ១- ការគ្រប់គ្រងក្របខ័ណ្ឌ និងការអភិវឌ្ឍអាជីពមន្ត្រីរាជការស៊ីវិល

នៅក្នុងរយៈពេល៥ឆ្នាំ(២០១៧-កញ្ញា-២០២១) កន្លងមកនេះ ក្រសួងមុខងារសាធារណៈ បានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្ម និងសម្រេចបាននូវសមិទ្ធផល រួមមាន (១) ការកសាង និងការដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត (២) ការគ្រប់គ្រងការវិវឌ្ឍអាជីពរបស់មន្ត្រីរាជការស៊ីវិល (៣) ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (៣) ការអភិវឌ្ឍធនធានមនុស្សក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល (៤) ការអភិវឌ្ឍស្ថាប័នក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ មានដូចខាងក្រោម៖

### ១.១- ការកសាង និងការដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត

កសាង និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដើម្បីបម្រើដល់ការងារគ្រប់គ្រងមន្ត្រីរាជការ ការអភិវឌ្ឍវិស័យមុខងារសាធារណៈ ការកែទម្រង់បៀវត្ស ការកែលម្អ និងពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈ ក្នុងនោះរួមមានព្រះរាជក្រឹត្យ១ អនុក្រឹត្យ៥៥ សេចក្តីសម្រេច១ ប្រកាស២ សារាចរ១ និងលិខិត៣។ ជាមួយគ្នានេះក្រសួងក៏បានចូលរួមពិភាក្សា ពិគ្រោះយោបល់ និងសហការកសាងលិខិតបទដ្ឋានគតិយុត្តជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជាច្រើនទៀត។

ដោះស្រាយសំណើសុំរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន១១២លិខិត របស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងផែនការ ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងធម្មការ និងសាសនា ក្រសួង

សង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងព័ត៌មាន ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អង្គភាពប្រឆាំងអំពើពុករលួយ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញឬទណ្ឌកម្ម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អង្គការជនពិការកម្ពុជា។

## ១.២- ការគ្រប់គ្រង និងការវិវឌ្ឍអាជីពរបស់មន្ត្រីរាជការស៊ីវិល

- គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ ចំនួនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេសក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាមានសរុប២១៣ ៦៩៤នាក់ ស្មើនឹង១០០%(ស្រី៨៩ ១៥៨នាក់) ក្នុងនោះ ថ្នាក់កណ្តាល៤០ ២៦៨នាក់ ស្មើនឹង១៨,៨៤%(ស្រី១២ ៦៤៤នាក់) និងថ្នាក់រាជធានី ខេត្ត១៧៣ ៤២៦នាក់ ស្មើនឹង៨១,១៦%(ស្រី៧៦ ៥១៤នាក់) និងមន្ត្រីប្រភេទផ្សេងៗ(មិនមែនជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ប៉ុន្តែមានឈ្មោះក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការ ជាអាទិ៍ទីប្រឹក្សា ជំនួយការ...។ល។) នៅថ្នាក់កណ្តាល៨ ៤១៦នាក់ ស្មើនឹង៩៩,៨១%(ស្រី១ ៣៩៨នាក់) និងថ្នាក់រាជធានី ខេត្ត១៦នាក់ ស្មើនឹង០,១៩%(ស្រី៤នាក់)

- បានអនុវត្តផែនការក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា(ឯកតា=នាក់)

| **បរិយាយ** / **ឆ្នាំ** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **សរុប** |
|---|---|---|---|---|---|---|
| ផែនការក្របខ័ណ្ឌ | ៤ ៧៤៥ | ៤ ៣០៤ | ៣ ៦៤៧ | ៣ ៤០១ | ២ ៤៧៧ | **១៨ ៥៧៤** |
| មន្ត្រីជាប់កិច្ចសន្យា | ១៨ ៣៤៤ | ១៨ ១៤៦ | ១៨ ២៩២ | ១៨ ៩២៥ | ១៨ ៩៣៧ | **៩២ ៦៤៤** |
| គ្រូបង្រៀនជាប់កិច្ចសន្យា | ៦ ៧៣០ | ៦ ៧៦៣ | ៨ ១៧៤ | ១០ ០៧៤ | ១០ ០៧៤ | **៤១ ៨១៥** |
| គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | ២ ៤៧២ | ២ ៤៧២ | ២ ៤៧២ | ២ ៤៧២ | ២ ៤៧២ | **១២ ៣៦០** |
| លុបឈ្មោះ | ១ ៣៥៤ | ៩៩៣ | ៧៨៩ | ៩៧៤ | ៨៤៣ | **៤ ៩៥៣** |
| បាត់បង់សម្បទាវិជ្ជាជីវៈ | ៩ | ១១ | ១០ | ២២ | ១០ | **៦២** |
| ចូលនិវត្តន៍ | ៣ ៣៨២ | ៣៣០ | ២ ៨៤៧ | ២ ៤០៥ | ១ ៦៥០ | **១៨ ៥៧៤** |

-បានគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិលនៅក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា(ឯកតា=នាក់)

| **បរិយាយ** / **ឆ្នាំ** | **២០១៧** | | **២០១៨** | | **២០១៩** | | **២០២០** | | **២០២១** | |
|---|---|---|---|---|---|---|---|---|---|---|
| | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** |
| ថ្នាក់កណ្តាល | ៥៧១៣ | ៧៦៥ | ៣៧៣០៧ | ១១៤៥២ | ៣៨២៥០ | ១១៧៨៦ | ៣៩២០១ | ១២០៩២ | ៤០២៦៨ | ១២៦៤៤ |
| ថ្នាក់ក្រោមជាតិ | ១៦៧៤១២ | ៧១៤៩១ | ១៧១៣៦៣ | ៧៤៣៥៨ | ១៧២៨៤៤ | ៧៥៧៣៣ | ១៧២៦៩៥ | ៧៥៨៦៤ | ១៧៣៤២៦ | ៧៦៥១៤ |
| **សរុប** | **១៧៣១២៥** | **៧២២៥៦** | **២០៨៦៧០** | **៨៥៨១០** | **២១១០៩៤** | **៨៧៥១៩** | **២១១៨៩៦** | **៨៧៩៥៦** | **២១៣៦៩៤** | **៨៩១៥៨** |

- បានគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិលតាមប្រភេទក្របខ័ណ្ឌ (ឯកតា=នាក់)

| ឆ្នាំ / បរិយាយ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ក១ | ២ ០២២ | ២៥៧ | ២ ៩០៨ | ៣៦៧ | ៥ ៤៩៧ | ៩០៩ | ៩ ៧៧៦ | ១ ៧១៨ | ១០ ៤៧៨ | ១ ៨៤១ |
| ក២ | ១៧ ៣៤៧ | ៣ ២៩៦ | ១៨ ៧៨៣ | ៣ ៦៧១ | ១៨ ៥៩២ | ៣ ៦៩៩ | ១៧ ១០៥ | ៣ ៦៧៤ | ១៦ ៧០៣ | ៣ ៦២៧ |
| ក៣ | ៣៤ ២៧២ | ១០ ៧៨៤ | ៣៦ ០២៧ | ១១ ៩៦៩ | ៣៧ ៣៩៣ | ១២ ៨៩៧ | ៣៧ ៧៥៨ | ១៣ ៣៥៨ | ៣៨ ៥៣៥ | ១៣ ៧៩៦ |
| ខ១ | ១ ៩៧៥ | ៤៦៧ | ២ ០៤១ | ៥០៤ | ២ ១៣៩ | ៥៣៥ | ៣ ៨៦៧ | ១ ០១៨ | ៣ ៨៧៩ | ៩៩៨ |
| ខ២ | ១៤ ០១៤ | ៤ ៤២៩ | ១៤ ៨៥៩ | ៤ ៦៩៥ | ១៥ ៣២០ | ៤ ៨៩៤ | ២០ ០២១ | ៦ ៩៦៩ | ២០ ០៩៩ | ៦ ៩៥៩ |
| ខ៣ | ៥២ ៣៣០ | ២២ ៩២៩ | ៥៣ ០៥២ | ២៣ ៧៣៩ | ៥៣ ៨៤២ | ២៤ ៤៨៣ | ៤៨ ១៣៧ | ២២ ៦១៧ | ៤៧ ៩៣០ | ២២ ៥៨៦ |
| គ | ៨១ ០៣១ | ៤០ ០៧១ | ៨១ ០០០ | ៤០ ៨៦៥ | ៧៨ ៣១១ | ៤០ ១០២ | ៧៥ ២៣២ | ៣៨ ៦០២ | ៧៦ ០៧០ | ៣៩ ៣៥១ |

- ផ្តល់ទិដ្ឋាការលើ (១) ការតែងតាំងមន្ត្រីរាជការស៊ីវិលចំនួន២០ ៥៣៦នាក់(ស្រី៧ ០៣៩នាក់) (២) ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន១០ ២៣២នាក់(ស្រី៤ ៩២៧នាក់) (៣) ការផ្តល់សលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិល និងបញ្ចូលទិន្នន័យមន្ត្រីក្របខ័ណ្ឌថ្មីបានចំនួន២០ ៨២៧នាក់(ស្រី៩ ៤៧៨នាក់) (៤) ការតាំងស៊ប់ក្នុងក្របខ័ណ្ឌចំនួន៣១ ៥៦៧នាក់(ស្រី១៣ ៩៩២នាក់) និង(៥) ការដំឡើងឋានន្តរសក្តិនិងថ្នាក់ចំនួន ៤០៩ ០១៦នាក់(ស្រី១២៤ ៣៩១នាក់)

| ឆ្នាំ / ប្រភេទស្ថានភាព | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| មន្ត្រីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៧៣៦ | ៥៩៦ | ៧២៧ | ៥៩៧ | ២៩៧ |
| មន្ត្រីចូលបម្រើការងារវិញក្រោយពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ១ ៣២៤ | ៩១២ | ៦៣៧ | ៤៩៩ | ៣៧៩ |
| សលាកប័ត្រព័ត៌មានមន្ត្រីក្របខ័ណ្ឌថ្មីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា | ១១ ៩៨៧ | ៧ ០២២ | ២ ៨៣៣ | ៦ ១៥៤ | ៤៦០ |
| មន្ត្រីក្របខ័ណ្ឌថ្មីបញ្ចូលប្រាក់បៀវត្ស | ៩ ៧៦៣ | ៩ ៥៥០ | ៦ ៣៨៥ | ៤ ៥១១ | ៣ ៤៨០ |
| មន្ត្រីតាំងស៊ប់ | ៥ ៧៦២ | ១០ ១៧៨ | ១១ ៦១៥ | ៧ ២៦៤ | ៣ ៤១០ |
| មន្ត្រីប្តូរក្របខ័ណ្ឌ | ១ ៨១០ | ២ ១៥២ | ៣ ៩៨៦ | ៣ ៦៣០ | ៣៤៧ |
| មន្ត្រីតែងតាំងក្នុងមុខតំណែង | ៨ ៩១១ | ៩ ២០១ | ១១ ៨១០ | ១០ ២៤២ | ៩ ៦៤៩ |
| មន្ត្រីទីប្រឹក្សា និងជំនួយការ | ៣១០ | ៣៩៤ | ១ ៦៨៧ | ៧៤០ | ១៧៤ |
| មន្ត្រីចូលនិវត្តន៍ត្រូវកាត់ចេញពីតារាងបៀវត្ស | ៣ ៦០០ | ៣ ៤៣២ | ២ ៦៣៨ | ២ ៥៦៥ | ៩៣៤ |
| មន្ត្រីលាឈប់ពីការងារ | ៨០០ | ៩០២ | ៨០៧ | ៧២៩ | ៣៨២ |
| មន្ត្រីទទួលមរណភាព | ១៦១ | ២០០ | ២២៩ | ២៧៨ | ២០៣ |
| មន្ត្រីប្តូរឋានន្តរសក្តិ | ២៥៣ | ៣៤៦ | ១៦០៧ | ១២១០ | ១៥៨ |
| មន្ត្រីដំឡើងថ្នាក់ប្រចាំឆ្នាំ និងតាមសញ្ញាបត្រ | ១៥០ ០៨៧ | ៨៩ ៨០២ | ៩៨ ១៤២ | ១៤២ ០៦២ | ១៨ ២៦២ |
| មន្ត្រីឡើងឋានន្តរសក្តិ | ៥១៥ | ៦៣ | ៣៥០ | ១៣០៩ | ២៧៤ |
| មន្ត្រីផ្ទេរចេញ | ៤ ១៤២ | ៣ ០៨២ | ២ ៥៩១ | ២ ២៩៤ | ២ ៥២៥ |
| មន្ត្រីផ្ទេរចូល | ៣ ៧២៨ | ៣ ២៩៩ | ២ ៤៩៤ | ២ ៣៧១ | ២ ៤៩០ |
| មន្ត្រីសុំប្រាក់មុខងារ | ១ ៤៩៧ | ១ ៧៣៣ | ១ ៧៥៨ | ២ ១០៣ | ២០១ |
| មន្ត្រីលំហែមាតុភាព | N/A | N/A | N/A | ១ ៤៧៤ | ១ ៨៤១ |
| បញ្ចូលកូន | ១៣ ៥៩៨ | ១០ ១៤២ | ១១ ៤២៣ | ១២ ១២៥ | ៧ ៥៣៥ |

| ប្រភេទស្ថានភាព \ ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| បញ្ចូលប្រពន្ធ | ៣ ០៥៣ | ២ ២៤២ | ១ ៩៨៩ | ១ ៩៣៥ | ១ ២៩៨ |
| បញ្ចូលប្រាក់តំបន់ | ១៧ ៨២៦ | ២០ ១៤៥ | ៤២ ០៩៧ | ៤១ ៩៤៧ | ៥ ០៨៧ |
| បញ្ចូលប្រាក់ពីរវេន គួប | ១៤ ៦២៧ | ១២ ៥៦៦ | ១៣ ៣៨៧ | ២១ ៩៦៧ | ១៤ ៩៩៥ |
| **សរុប** | **២៥៤ ៤៩០** | **១៨៧ ៩៥៩** | **២១៩ ១៩២** | **២៦៨ ០០៦** | **៧៤ ៣៨១** |

- បានធ្វើការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីនៅក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា(ឯកតា=នាក់)

- បានរៀបចំមុខតំណែងនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន

| មុខតំណែង \ ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ក- ថ្នាក់កណ្ដាល | | | | | |
| អគ្គលេខាធិការនៃក្រសួង ស្ថាប័ន | ៥ | ៥ | ៥ | ៧ | ៦ |
| អគ្គលេខាធិការរងនៃក្រសួង ស្ថាប័ន | ៤១ | ៥១ | ៥៦ | ៤៩ | ៤៧ |
| អគ្គនាយក | ១៥០ | ១៤៤ | ១២៤ | ១១១ | ១១៣ |
| អគ្គាធិការ | ២១ | ១៦ | ១៨ | ១៨ | ១៩ |
| អគ្គនាយករង | ៤៩៥ | ៥២៤ | ៥៥៦ | ៥៦៥ | ៦១៨ |
| អគ្គាធិការរង | ៧៧ | ៨៦ | ១០៣ | ១១៨ | ១១៩ |
| ប្រធាននាយកដ្ឋាន | ៧៣២ | ៧៤៦ | ៧៥៨ | ៧៥៦ | ៨០២ |
| អធិការថ្នាក់កណ្ដាល | ១០៤ | ៩៥ | ១០៦ | ១២៣ | ១២០ |
| អនុប្រធាននាយកដ្ឋាន | ២ ៦០៧ | ២ ៧៨៦ | ៣ ០៧១ | ៣ ១៨៨ | ៣ ៤៨៧ |
| ប្រធានការិយាល័យថ្នាក់កណ្ដាល | ៣ ០៦៦ | ៣ ១៦៣ | ៣ ៣៧៥ | ៣ ៥១១ | ៣ ៦៥២ |
| អនុប្រធានការិយាល័យថ្នាក់កណ្ដាល | ៥ ១៩៤ | ៥ ៤២៦ | ៥ ៨៩៤ | ៦ ៤៤៧ | ៧ ៣១៧ |
| ខ- ថ្នាក់រាជធានី ខេត្ត | | | | | |
| ប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៥៣៧ | ៥៤៧ | ៥៤៥ | ៥៥៥ | ៥៦៧ |
| អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ១ ៣៧១ | ១ ៣៩៦ | ១ ៤៣០ | ១ ៤៦៣ | ១ ៥២២ |
| ប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ២ ១៣៣ | ២ ១៥៨ | ២ ២៨៤ | ២ ៤៥៤ | ២ ៦៧៤ |
| អនុប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ២ ៧៦៥ | ២ ៩៦៥ | ៣ ២៧១ | ៣ ៦១៨ | ៤ ១៣៦ |
| ប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ១ ៤៣៦ | ១ ៤៤៣ | ១ ៤៤០ | ១ ៤៤៩ | ១ ៣៦៣ |
| អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ១ ០៤៣ | ៩៩៦ | ៩៦៣ | ៩៥០ | ៨៩៣ |

- បានគ្រប់គ្រងចំនួនមន្ត្រីរាជការដល់អាយុចូលនិវត្តន៍សរុបចំនួន១៣ ២០៤នាក់(ស្រី៥ ៥៩៦នាក់)

| បរិយាយ \ ឆ្នាំ | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ថ្នាក់កណ្ដាល | ដល់អាយុ | ប្រុស | ៤២៣ | ៤១៧ | ៣៤២ | ២៣០ | ១១៦ | ១ ៥២៨ |
| | | ស្រី | ១៣៨ | ២០៨ | ១៧៨ | ១៩៨ | ១៧៨ | ៩០០ |
| | មុនអាយុ | ប្រុស | ៣២ | ៣១ | ៤៨ | ៣០ | ៣០ | ១៧១ |
| | | ស្រី | ១៣ | ១៩ | ៣២ | ៣២ | ២០ | ១១៦ |
| ថ្នាក់រាជធានី ខេត្ត | ដល់អាយុ | ប្រុស | ១ ៦៥១ | ១ ៤៨៣ | ១ ១៤៧ | ៦៧០ | ៣២០ | ៥ ២៧១ |

| បរិយាយ / ឆ្នាំ | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| | | ស្រី | ៩២៧ | ១ ០៣៩ | ៨៥៥ | ៨៨៨ | ៤៤៤ | ៤ ១៥៣ |
| | មុនអាយុ | ប្រុស | ១១០ | ១២១ | ១១២ | ១៨០ | ១១៥ | ៦៣៨ |
| | | ស្រី | ៨៦ | ៦៧ | ៧៩ | ១១៧ | ៧៨ | ៤ ២៧ |
| សរុបរួម | | ប្រុស | ២ ២១៦ | ២ ០៥២ | ១ ៦៤៩ | ១ ១១០ | ៥៨១ | ៧ ៦០៨ |
| | | ស្រី | ១ ១៦៤ | ១ ៣៣៣ | ១ ១៤៤ | ១ ២៣៥ | ៧២០ | ៥ ៥៩៦ |
| | | សរុប | **៣ ៣៨០** | **៣ ៣៨៥** | **២ ៧៩៣** | **២ ៣៤៥** | **១ ៣០១** | **១៣ ២០៤** |

## ២- ការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ

### ២.១- ការកែលម្អសេវាសាធារណៈ

- រាជរដ្ឋាភិបាល បានផ្តល់ប្រាក់រង្វាន់ចំនួន៣ ១៦០ ០០០ ០០០រៀល ជូនដល់អង្គភាពផ្តល់សេវាសាធារណៈគំរូនៅក្នុងវិស័យអប់រំមាន១០អង្គភាព និងវិស័យសុខាភិបាលមាន៣០អង្គភាព ទៅតាមលំដាប់ថ្នាក់គឺ (ទី១) ចំនួនពីររយលានរៀល (ទី២) ចំនួនមួយរយហាសិបលានរៀល (ទី៣) ចំនួនមួយរយលានរៀល (ទី៤) ចំនួនប៉ែតសិបលានរៀល (ទី៥) ចំនួនហុកសិបលានរៀល (ទី៦ដល់ទី១០) ចំនួនសែសិបលានរៀល

- បានរៀបចំខ្លឹមសារសម្រាប់ផលិតវីដេអូខ្លី និងករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ របស់អង្គភាពជ័យលាភី អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាល

- បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ទាំងថ្នាក់ជាតិ ទាំងថ្នាក់តំបន់ចំនួន១៤លើក ដែលមានអ្នកចូលរួម៤ ៧៨០នាក់(ស្រី៦៤៥នាក់)

- បានចុះ MOU ជាមួយ (១) UNDP ដើម្បីអនុវត្តគម្រោងនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ និងការផ្តល់សេវាតាមប្រព័ន្ធឌីជីថល និងជាមួយ (២) អង្គការតម្លាភាពកម្ពុជា ដើម្បីបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទស្តីពីសេវាសាធារណៈ។

### ២.២- ការកែទម្រង់ប្រព័ន្ធបៀវត្ស និងលាភការ

- បានបង្កើតក្រុមការងាររៀបចំឯកសារគោលនយោបាយស្តីពីបៀវត្សក្នុងវិស័យសាធារណៈ

- បានផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងប្រាក់ឧបត្ថម្ភក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ

- បានកែប្រែ និងដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគា មន្ត្រីនគរបាលជាតិកម្ពុជា និងយោធិននៃកងយោធពលខេមរភូមិន្ទ

- បានកែប្រែ និងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលបានសម្រាលកូនចំនួន៨០០ ០០០រៀល និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាពចំនួន២ ០០០ ០០០រៀល និងកំឡុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារចំនួន៤ ០០០ ០០០រៀល

- បានកម្រិតម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងសម្រាប់ការងារបង្រៀនក្នុងគ្រឹះស្ថានសាធារណៈ

- បានចូលរួមរៀបចំប្រាក់លើកទឹកចិត្តប្រចាំខែសម្រាប់គណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ ដោយផ្តល់ជូនម្នាក់ៗចំនួន១០០ ០០០រៀល និងរៀបចំប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូល

- បានកំណត់បៀវត្សប្រចាំខែ និងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការ និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានទូតតំណាងកម្ពុជានៅបរទេស

- កំណត់ប្រាក់បំណាច់មុខងារប្រចាំខែរបស់ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

- បានដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានរៀបចំប្រាក់បំណាច់មុខងារប្រចាំខែរបស់ប្រធាន អនុប្រធានសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងប្រធាន អនុប្រធានឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ

- បានកែប្រែ និងដំឡើងប្រាក់បំណាច់ចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងបានសុំគោលការណ៍សម្រាប់ការរៀបចំប្រាក់បំណាច់មុខងារជូនអាជ្ញាសាលាដែលបំពេញការងារនៅតាមបណ្តាសាលាដំបូងរាជធានី ខេត្ត

- បានកំណត់ និងដាក់ឱ្យអនុវត្តនីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន និងការបើកផ្តល់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនចំនួន២ដងក្នុងមួយខែ

- បានរៀបចំប្រាក់បំណាច់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ(ឯកតា=រៀល)

| ឆ្នាំ / ឋានៈស្មើ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| នាយករដ្ឋមន្ត្រី | ៣ ៧៥៥ ០០០ | ៣ ៧៥៥ ០០០ | ៣ ៧៥៥ ០០០ | ៣ ៧៥៥ ០០០ | ៣ ៧៥៥ ០០០ |
| ឧបនាយករដ្ឋមន្ត្រី | ២ ៨៨០ ០០០ | ២ ៨៨០ ០០០ | ២ ៨៨០ ០០០ | ២ ៨៨០ ០០០ | ២ ៨៨០ ០០០ |
| ទេសរដ្ឋមន្ត្រី | ២ ៥៣០ ០០០ | ២ ៥៣០ ០០០ | ២ ៥៣០ ០០០ | ២ ៥៣០ ០០០ | ២ ៥៣០ ០០០ |
| រដ្ឋមន្ត្រី | ២ ១៨០ ០០០ | ២ ១៨០ ០០០ | ២ ១៨០ ០០០ | ២ ១៨០ ០០០ | ២ ១៨០ ០០០ |
| រដ្ឋលេខាធិការ | ១ ៨៣០ ០០០ | ១ ៨៣០ ០០០ | ១ ៨៣០ ០០០ | ១ ៨៣០ ០០០ | ១ ៨៣០ ០០០ |
| អនុរដ្ឋលេខាធិការ | ១ ៤៨០ ០០០ | ១ ៤៨០ ០០០ | ១ ៤៨០ ០០០ | ១ ៤៨០ ០០០ | ១ ៤៨០ ០០០ |
| អគ្គនាយក | ៨១៥ ០០០ | ៨១៥ ០០០ | ៨១៥ ០០០ | ៨១៥ ០០០ | ៨១៥ ០០០ |
| អគ្គនាយករង | ៧២៥ ០០០ | ៧២៥ ០០០ | ៧២៥ ០០០ | ៧២៥ ០០០ | ៧២៥ ០០០ |
| ប្រធាននាយកដ្ឋាន | ៧០០ ០០០ | ៧០០ ០០០ | ៧០០ ០០០ | ៧០០ ០០០ | ៧០០ ០០០ |
| អនុប្រធាននាយកដ្ឋាន | ៦២០ ០០០ | ៦២០ ០០០ | ៦២០ ០០០ | ៦២០ ០០០ | ៦២០ ០០០ |
| ប្រធានការិយាល័យ | ១៥៨ ១០០ | ១៥៨ ១០០ | ១៥៨ ១០០ | ១៥៨ ១០០ | ១៥៨ ១០០ |
| អនុប្រធានការិយាល័យ | ១៤១ ៤០០ | ១៤១ ៤០០ | ១៤១ ៤០០ | ១៤១ ៤០០ | ១៤១ ៤០០ |

- បានរៀបចំដំឡើងបៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកម្លាំងប្រដាប់អាវុធ (ឯកតា=រៀល)

| ឆ្នាំ / បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| រដ្ឋបាល បច្ចេកទេស ការទូត | ៨៥៣ ៥០០ | ១ ០១៤ ៤៥០ | ១ ១០០ ១០០ | ១ ១៧២ ៥០០ | ១ ១៧២ ៥០០ |
| អប់រំ | ៩៥៣ ៥០០ | ១ ១១៤ ៤៥០ | ១ ២០០ ១០០ | ១ ២៧២ ៥០០ | ១ ២៧២ ៥០០ |
| សុខាភិបាល | ៩៥៣ ៥០០ | ១ ១១៤ ៤៥០ | ១ ២០០ ១០០ | ១ ២៧២ ៥០០ | ១ ២៧២ ៥០០ |
| នគរបាល | ៩៣៧ ៩៧៧ | ១ ០៩៨ ៩២៧ | ១ ១៨៤ ៥៧៧ | ១ ២៥៦ ៩៧៧ | ១ ២៥៦ ៩៧៧ |
| យោធិន | ៨៨០ ៩៧៧ | ១ ០៣៥ ០២៧ | ១ ១១៤ ៣៧៧ | ១ ១៨១ ៩៧៧ | ១ ១៨១ ៩៧៧ |

- បានរៀបចំដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សាគ្រប់ប្រភេទ និងមន្ត្រីភូមិ (ឯកតា=រៀល)

| ឆ្នាំ / បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| មន្ត្រីជាប់កិច្ចសន្យា | ៥០០ ០០០ | ៦០០ ០០០ | ៦៥០ ០០០ | ៦៧០ ០០០ | ៦៧០ ០០០ |
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ ២១០ ០០០ | ១ ៣៦០ ០០០ | ១ ៤៤០ ០០០ | ១ ៤៤០ ០០០ | ១ ៤៤០ ០០០ |
| សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | ៩៧០ ០០០ | ១០៨ ៥០០ | ១ ១៣៥ ០០០ | ១ ១៣៥ ០០០ | ១ ១៣៥ ០០០ |
| ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៩៣៥ ០០០ | ១០៧ ៥០០០ | ១ ១៥៥ ០០០ | ១ ១៥៥ ០០០ | ១១៥ ៥០០០ |
| សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៧៥០ ០០០ | ៨៦០ ០០០ | ៩១០ ០០០ | ៩១០ ០០០ | ៩១០ ០០០ |
| ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ | ៨៨០ ០០០ | ១ ០៣០ ០០០ | ១ ១១០ ០០០ | ១ ១១០ ០០០ | ១ ១១០ ០០០ |
| ជំទប់ទី១ និងទី២ ចៅសង្កាត់រងទី១ និងទី២ | ៦៥០ ០០០ | ៨០០ ០០០ | ៨៥០ ០០០ | ៨៧០ ០០០ | ៨៧០ ០០០ |
| សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ៥៧០ ០០០ | ៧០០ ០០០ | ៧៤០ ០០០ | ៧៦០ ០០០ | ៧៦០ ០០០ |
| មេភូមិ | ២២៥ ០០០ | ២៥០ ០០០ | ៤០០ ០០០ | ៤៣០ ០០០ | ៤៣០ ០០០ |
| អនុប្រធានភូមិ | ១៨០ ០០០ | ២០០ ០០០ | ២៨០ ០០០ | ៣១០ ០០០ | ៣១០ ០០០ |
| សមាជិកភូមិ | ១៦០ ០០០ | ១៨០ ០០០ | ២៥០ ០០០ | ២៨០ ០០០ | ២៨០ ០០០ |

- បានរៀបចំដំឡើងរបបសន្តិសុខសង្គមអប្បបរមាប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន (ឯកតា=រៀល)

| ឆ្នាំ / បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន | ៤២០ ០០០ | ៤៨០ ០០០ | ៥៦០ ០០០ | ៦៤០ ០០០ | ៦៤០ ០០០ |

- បានរៀបចំដំឡើងតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋាន(ឯកតា=រៀល)

| ឆ្នាំ / បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| សន្ទស្សន៍ | ១ ៩០០ | ២ ១៣០ | ២ ៣៤០ | ២ ៥០០ | ២ ៥០០ |

## ៣- ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល

- បានរៀបចំការពិពណ៌នាមុខតំណែងរបស់ក្រសួង ស្ថាប័នចំនួន២៨

- បានរៀបចំកម្មវិធីចែករំលែកចំណេះដឹង និងវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៤វគ្គ និងក្រៅប្រទេសចំនួន៤វគ្គ ជូនមន្ត្រីរាជការតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតួនាទីពីមន្ត្រី រហូតដល់អគ្គនាយក ឬថ្នាក់ប្រហាក់ប្រហែលចំនួន១ ៥៦៣នាក់។

### ៣.១-ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ

- បានកសាងសេចក្តីព្រាង និងគោលការណ៍ណែនាំស្តីពីប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០២០-២០៣០

- បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលចំនួន៩វគ្គ ដែលមានសមាជិកចូលរួមចំនួន៣ ២១៤ នាក់ ដែលមានតួនាទីពីមន្ត្រី រហូតដល់រដ្ឋលេខាធិការ។

### ៣.២- ការធ្វើអធិការកិច្ចក្នុងវិស័យមុខងារសាធារណៈ

- បានចុះធ្វើអធិការកិច្ចវិស័យមុខងារសាធារណៈចំនួន៩៩ករណី រួមមាន (១) ការគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានចុះអធិការកិច្ច និងដោះស្រាយវិវាទមុខងារសាធារណៈចំនួន១៥ករណី
- បានចុះតាមដានការអនុវត្តអនុសាសន៍អធិការកិច្ចវិស័យមុខងារសាធារណៈចំនួន៤៥ករណី
- បានចុះអធិការកិច្ចករណីបើកបៀវត្សលើសដែលបានរកឃើញចំនួន១ ០៧០ ១៧១ ៤៣៧រៀល ព្រមទាំងបានចាត់វិធានការតាមនីតិវិធីបង្វែរចូលថវិកាជាតិ។

## ទី២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

### ១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

រយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្អែកលើយុទ្ធសាស្ត្រ និងនយោបាយប្រឆាំងអំពើពុករលួយដែលបានដាក់ចេញ ដោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយដំណាក់កាលទី២(២០១៥-២០២០) និងទី៣ (២០២១-២០២៥) ស្របជាមួយនឹងការគាំទ្រ ការផ្តល់នូវកម្លាំងចិត្ត ឆន្ទៈនយោបាយ និងការដាក់ចេញយុទ្ធសាស្ត្រ គោល-នយោបាយ និងផែនការអភិវឌ្ឍជាតិ (ទាំងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ទាំងផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ) ពីសំណាក់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងការដឹកនាំរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយ បានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយការច្នៃប្រឌិត និងបាននាំមកនូវសមិទ្ធផលជាបន្តបន្ទាប់ជូនសង្គមជាតិ។ សមិទ្ធផលទាំងនេះ ត្រូវបានធ្វើឡើងតាមរយៈការងារស្នូលចំនួន៤ រួមមាន(១) ការអប់រំ (២) ការបង្ការទប់ស្កាត់ (៣) ការអនុវត្តច្បាប់ បង្ក្រាបបទល្មើសពុករលួយ និង(៤) ការបំពេញកាតព្វកិច្ចជាតិ និងអន្តរជាតិ។

### ១.១- ការអប់រំ

ការអប់រំអំពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានធ្វើឡើងក្នុងមជ្ឈដ្ឋានសាលា បានបញ្ចូលនូវសៀវភៅសិក្សាស្តីពីការប្រឆាំងអំពើពុករលួយទៅក្នុង៣កម្រិតសិក្សា កម្រិតបឋមសិក្សា (ថ្នាក់ទី៤ ទី៥ និងទី៦) មធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ ទី៨ និងថ្នាក់ទី៩) និងមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២) ដោយបានបោះពុម្ពសៀវភៅអប់រំគាំទ្រការសិក្សា និងការបង្រៀនដល់សិស្សានុសិស្ស និងគ្រូបន្ថែមចំនួន២៤០ ០០០ក្បាល(សរុបចំនួន៨២៥ ០០០ក្បាល) និងបានបណ្តុះបណ្តាលគ្រូបង្គោល ព្រមទាំងបំពាក់បំប៉នការបង្រៀនដល់លោកគ្រូអ្នកគ្រូសរុប១ ០០៧នាក់។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ មានកុមារ និងយុវជនចំនួនជាង២ ០០០ ០០០នាក់ ជារៀងរាល់ឆ្នាំ បានឆ្លងកាត់ការសិក្សាសៀវភៅទាំងនេះ។

ការអប់រំអំពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានធ្វើឡើងក្រៅមជ្ឈដ្ឋានសាលា មានច្រើនបែប ច្រើនរូបភាព ដូចជាការប្រារព្ធទិវាជាតិ អន្តរជាតិប្រឆាំងអំពើពុករលួយ ៩ធ្នូ ការចុះអប់រំផ្សព្វផ្សាយផ្ទាល់តាមក្រសួងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ សាលាវិជ្ជាជីវៈ វិស័យឯកជន អង្គការសង្គមស៊ីវិល វិស័យសារព័ត៌មាន ការផលិត និងផ្សព្វផ្សាយឧបករណ៍អប់រំស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមមធ្យោបាយផ្សេងៗ ការរៀបចំកម្មវិធីបណ្តុះគំនិតស្អាតស្អំផ្សេងៗ ដូចជាយុទ្ធនាការ "ព័ត៌មានស្អាត" ដោយសហការជាមួយសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា បានអនុវត្តស្របគ្នាដើម្បីលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ក្នុងស្មារតីទទួលខុសត្រូវដោយប្រកាន់ខ្ជាប់ថា ការងារអប់រំអំពីការប្រឆាំងអំពើពុករលួយជាភារកិច្ចរបស់អ្នកទាំងអស់គ្នាក្នុងនោះ ក្រសួង ស្ថាប័ន ផ្នែកសិល្បករ ផ្នែកសារព័ត៌មាន ផ្នែកសិក្សាធិការនិងអង្គការសង្គមស៊ីវិល បានសហការយ៉ាងផុលផុសចូលរួមលើកិច្ចការនេះ តាមការស្នើសុំពីអង្គភាពប្រឆាំងអំពើពុករលួយ និងស្ម័គ្រចិត្ត ដែលធ្វើឱ្យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ ការប្រគុំតន្ត្រី ការផ្សាយស្ប៉ត ចម្រៀង សារអប់រំពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមប្រព័ន្ធឃោសនាបណ្តាញទំនាក់ទំនងសង្គម និងសកម្មភាពផ្សេងៗទៀតត្រូវបានពង្រីកយ៉ាងទូលំទូលាយដល់មន្ត្រីរាជការ ធុរជន និងសាធារណជន។

ការអប់រំផ្សព្វផ្សាយទាំងនេះ បានធ្វើឱ្យមហាជន និងមន្ត្រីរាជការ មានការយល់ដឹងច្បាស់លាស់ និងគោរពអនុវត្តនូវ អភិក្រមទាំង៥ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការអនុវត្តការងារប្រចាំថ្ងៃ«**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល វះកាត់**» និងលើកកម្ពស់តម្លាភាពក្នុងកិច្ចការងារ និងការរស់នៅប្រចាំថ្ងៃរបស់ខ្លួន។

**ការងារអប់រំផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើពុករលួយ**

| ល.រ | សកម្មភាពការងារ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចំនួនអ្នកចូលរួមផ្ទាល់ស្តាប់ការផ្សព្វផ្សាយច្បាប់(នាក់) | ៣៦ ២៨២ | ៣១ ២៨២ | ៤ ៩៨៦ | ១ ៣២៦ | ១ ៥១៨ | ៧៥ ៣៩៤ |
| ២ | សៀវភៅច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលបានចែកផ្សាយដល់ដៃ (ក្បាល) | ២០ ០០០ | ២០ ០០០ | - | ៣០ ០០០ | - | ៧០ ០០០ |
| ៣ | បោះពុម្ពសៀវភៅមេរៀនស្តីពីការប្រឆាំងអំពើពុករលួយសម្រាប់បឋមសិក្សាថ្នាក់ទី៤ ទី៥ ទី៦ (ក្បាល) | ២៤០ ០០០ | - | - | - | - | ២៤០ ០០០ |
| ៤ | សម្ភារៈ និងបណ្ណផ្សព្វផ្សាយ poster, sticker (សន្លឹក) | ៣៥ ០០០ | - | - | ១១ ០០០ | - | ៤៦ ០០០ |
| ៥ | ប្រតិទិន (សន្លឹក) | ២០ ០០០ | - | - | - | - | ២០ ០០០ |
| ៦ | ចម្រៀងស្ប៉តអប់រំនិងវីឌីអូខ្លី | ៤ | ៥ | ៣ | ១២ | ៦ | ៣០ |
| ៧ | ផ្ទាំងរូបភាពអបអរសាទរសម្រាប់ព្រឹត្តិការណ៍ផ្សេងៗ | - | - | ៨ | ៣១ | ១៥ | ៥៤ |
| ៨ | -ការផ្សព្វផ្សាយកម្មវិធីដោយឡែក នៃការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមវិទ្យុចំនួន៣ : ១) វិទ្យុជាតិកម្ពុជា ២)វិទ្យុវាយោ និង ៣)វិទ្យុទន្លេ<br>-ការផ្សព្វផ្សាយតាមទូរទស្សន៍ចំនួន១០: ១)ទទក ២)បាយ័ន ៣)អាស៊ីអាគ្នេយ៍ ៤)CTN ៥)ហង្សមាស ៦)អប្សរា ៧)CNC ៨)PNN ៩)PPCTV និង១០)CCTV<br>-ការផ្សព្វផ្សាយតាម LED របស់ក្រុមហ៊ុន ម៉ឹង រួយ គ្រុបចំនួន ១១កន្លែង : ១)ហាងនំប៉័ងABC នៅស្តុបសន្ធម៉ុក ២)ស្ពានជ្រោយចង្វា ៣)បណ្ណាគារIBC នៅស្តុបដេអិន ៤)បណ្ណាគារ | | | - | - | - | - |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | IBC នៅស្តុបត្រសក់ផ្អែម ៥)ស្ថានីយប្រេងឥន្ធនៈ SOKIMEX ក្បាលថ្នល់ ៦)ស្តុបនាងគង្ហីង ៧)ស្តុបអាងទឹកអូឡាំពិក ៨)ស្តុបផ្សារដើមគរ ៩)ផ្សារអូរឫស្សី ១០) ស្តុបផ្សារថ្មី និង១១)រោងកុនអង្គរ | | | | | | |
| ៩ | ចំនួនអ្នកទទួលបានការផ្សព្វផ្សាយតាមគេហទំព័រអ.ប.ព. (នាក់) | ១៧៣ ០០០ | ១៧៩ ០០០ | ១៨៤ ០០០ | ១៨៩ ៩៦៣ | ១៩៥៦០៣ | ១៩៥ ៦០៣ |
| ១០ | បណ្តុះបណ្តាលគ្រូបង្រៀនមេរៀនប្រឆាំងអំពើពុករលួយថ្នាក់ទី៤ ដល់ថ្នាក់ទី១២ (នាក់) | ៣១១ | - | - | - | - | ៣១១ |
| ១១ | ការរៀបចំ និងបណ្តុះបណ្តាលដល់គ្រូ នៃកម្មវិធីមេរៀនប្រឆាំងអំពើពុករលួយ (ចំនួនសិក្ខាកាម និងខេត្ត) | ៨៨៧នាក់/ ៦ខេត្ត | ១២០នាក់/ ១ខេត្ត | - | - | - | ១ ០០៧ នាក់/ ៧ ខេត្ត |
| ១២ | ចុះតាមដានសង្កេតលើការអនុវត្តការបង្រៀន និងរៀនមេរៀនប្រឆាំងអំពើពុករលួយ | ៦សាលារាជធានី-ខេត្ត | - | - | - | - | ៦សាលារាជធានី-ខេត្ត |
| ១៣ | ទិវាជាតិប្រឆាំងអំពើពុករលួយ ៩ធ្នូ (នាក់) | អ្នកចូលរួមផ្ទាល់៣៤៨០ នាក់ និងទស្សនាតាមទូរទស្សន៍ អប្បរាជាង ២លាននាក់ | ចុះផ្សព្វផ្សាយ ៣៧កន្លែង =២៤ ១៤៥ នាក់ | យុទ្ធនាការពិនិត្យសេវាសាធារណៈ សង្កាត់ចំនួន ៤ក្នុងខណ្ឌមានជ័យ | ចូលរួមកិច្ចប្រជុំ ASEAN - PAC និងផ្សព្វផ្សាយតាមបណ្តាញសង្គមដែលអ្នកទស្សនាចំនួនជិត១លាននាក់ | គ្រោងរៀបចំពិធីផ្សព្វផ្សាយដល់សិស្សបឋមសិក្សា នៅសាលាបឋមសិក្សាស្វាយរៀង/ ពហុកីឡដ្ឋានខេត្តស្វាយរៀង | ២៧ ៦២៥ នាក់ |

## ១.២- ការបង្ការទប់ស្កាត់

ការបង្ការទប់ស្កាត់អំពើពុករលួយ ក៏ត្រូវបានអនុវត្តស្របគ្នានឹងការអប់រំ សំដៅរួមចំណែកជាមួយគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលុបបំបាត់ជាបណ្តើរៗកុំឱ្យមានឱកាសប្រព្រឹត្តអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយ បានចូលរួមសង្កេតការណ៍ ដូចមានរៀបរាប់លម្អិតខាងក្រោម៖

- ការងារលទ្ធកម្មរបស់ក្រសួង ស្ថាប័នថ្នាក់ក្រោមជាតិបាន ចំនួន១១៥ ស្មើនឹង២ ៤៧៩គម្រោង
- ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងៗ ចំនួន១០ ស្មើនឹង៣៤លើក
- ការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត នៅតាមសាលាវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សា ចំនួន ៤ ស្មើនឹង១៩លើក
- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន៣លើក
- ការដាក់ចេញ និងកែសម្រួលប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមីផ្តល់សេវាសាធារណៈសរុប ចំនួន១៦ ស្មើនឹង៥១ប្រកាស

- ការស្ទង់មតិ ពិនិត្យ និងផ្តល់យោបល់លើការអនុវត្តការផ្តល់សេវាសាធារណៈ ចំនួន៥ ក្រសួង១២ មន្ទីរ និង៤សង្កាត់

- ការងារទារបំណុលអាជីវកម្មខ្សាច់ និងរ៉ែផ្សេងៗ ចំនួន៤លើក ក្នុងខេត្តចំនួន៤

បន្តការចុះអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីកិច្ចសហការប្រឆាំងអំពើពុករលួយរវាងអង្គភាពប្រឆាំងអំពើពុករលួយ និងវិស័យឯកជន បានកើនដល់១០៤(MoU) ដើម្បីរួមគ្នាទប់ស្កាត់អំពើពុករលួយក្នុងវិស័យឯកជន ដែលមានវិសាលភាពគ្របដណ្តប់លើក្រុមហ៊ុនជាង១ ០០០ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនជាង៣០ និងមានការរៀបចំជាវេទិកាពិគ្រោះយោបល់ និងការដោះស្រាយបញ្ហាប្រឈមនានា ដែលវិស័យឯកជនបានជួបប្រទះក្នុងធុរកិច្ចរបស់ខ្លួន។

រាជរដ្ឋាភិបាលនិងក្រសួងស្ថាប័ននានា ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ បានបង្កើតក្របខ័ណ្ឌគតិយុត្តជាច្រើន ដោយបាននិងកំពុងអនុវត្ត និងបានបង្កើតឱ្យមានយន្តការការគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលបានកាត់បន្ថយនូវឱកាសប្រព្រឹត្តអំពើពុករលួយរវាងមន្ត្រីរាជការដែលជាភ្នាក់ងាររបស់រដ្ឋ និងប្រជាពលរដ្ឋឱ្យបានជាអតិបរមាក្នុងការប្រគល់ ទទួលសេវាកម្មបានទាន់ពេលវេលា មានភាពងាយស្រួល និងសាមញ្ញជាងមុន។ ជាមួយគ្នានេះ អង្គភាពប្រឆាំងអំពើពុករលួយបានចេញលិខិតព្រមានមុខសញ្ញាដែលខកខានមិនបានអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមាន ចំនួន៤៨នាក់។

ការប្រកាសទ្រព្យសម្បត្តិនិងបំណុលលើកទី៣ រយៈពេល៥ឆ្នាំ(២០១៧-២០២១) ក៏នៅតែជាកិច្ចការថ្មីពីព្រោះកន្លងមកក្នុងប្រវត្តិសាស្ត្រ កម្ពុជាយើងមិនធ្លាប់មានការប្រកាសទ្រព្យសម្បត្តិនិងបំណុលនៅឡើយទេ។ ការប្រកាសទ្រព្យសម្បត្តិនិងបំណុល បានរួមចំណែកយ៉ាងសំខាន់ក្នុងការទប់ស្កាត់អំពើពុករលួយនិងបានចូលរួមចំណែកធ្វើឱ្យប្រែប្រួលឥរិយាបទសង្គមលើទ្រព្យសម្បត្តិរបស់ខ្លួន ហើយយើងនៅបន្តការងារប្រកាសទ្រព្យសម្បត្តិនិងបំណុលជាទៀងទាត់តាមរបប២ឆ្នាំ តាមពេលវេលាដែលទទួលតំណែងថ្មី ការលាឈប់ពីការងារចប់អាណត្តិពីការងារចូលនិវត្តន៍ ឬបញ្ឈប់ពីការងារ ដែលការងារទាំងអស់នេះមានភាពស្មុគស្មាញជាច្រើនក៏ដោយក៏យើងនៅតែបានសម្រេចទទួលលទ្ធផលស្ទើរតែ១០០%។

**ការងារប្រកាសទ្រព្យសម្បត្តិ និងបំណុល**

| កាលបរិច្ឆេទ | របប២ឆ្នាំ | តែងតាំងថ្មី | លាឈប់ | បញ្ឈប់ពីមុខតំណែង | ចូលនិវត្តន៍ | ស៊ើបអង្កេត | សរុប (ច្បាប់) |
|---|---|---|---|---|---|---|---|
| **២០១៧** | ២១ ៤៦៨ | ៨ ៤១២ | ៤ ១១៩ | ៩៨៤ | ១៩៦ | - | ៣៥ ១៧៩ |
| **២០១៨** | ៥ ៧២៦ | ៨ ១៧២ | ៤៨៤ | ៣ ៨៩៣ | ៩៩ | - | ១៨ ៣៧៤ |
| **២០១៩** | ២១ ៨៧៥ | ៤ ៥៤៣ | ១ ៤៩៤ | ៤៣ | ៦៥៣ | ២១ | ២៨ ៦២៩ |
| **២០២០** | ១២ ៥០២ | ២ ៩៩៩ | ៣៦០ | ៣០ | ៧១០ | ៣ | ១៦ ៦០៤ |
| **២០២១** | ២៤ ៤១៣ | ១ ០៥៨ | ១៦៥ | ២១ | ៥២៤ | - | ២៦ ១៨១ |
| សរុបរួម | **៨៥ ៩៨៤** | **២៥ ១៨៤** | **៦ ៦២២** | **៤ ៩៧១** | **២ ១៨២** | **២៤** | **១២៤ ៩៦៧** |

## ១.៣- ការអនុវត្តច្បាប់បង្ក្រាប

ការងារអនុវត្តច្បាប់បង្ក្រាបក៏បានដើរទន្ទឹមគ្នាជាមួយនឹងការអប់រំ បង្ការ និងទប់ស្កាត់។ យន្តការទទួល និងដោះស្រាយពាក្យប្តឹងត្រូវបានទទួលការវាយតម្លៃជាវិជ្ជមាន ជាទូទៅពីសំណាក់អ្នកប្តឹងដែលអ.ប.ព. ធ្វើបានរហ័សនិងគ្រប់ជ្រុងជ្រោយ និងបានចុះស្រាវជ្រាវដល់ស្ថាប័ននិងទីកន្លែងមូលដ្ឋាន ហើយមានមូលដ្ឋានគតិយុត្តច្បាស់លាស់។ រាល់ការមកប្តឹងផ្ទាល់ ប្តឹងតាមប្រអប់សំបុត្រស តាមប្រៃសណីយ៍ ទូរសព្ទ អ៊ីមែល និងតាមបណ្តាញ

ទំនាក់ទំនងសង្គម(Facebook Telgram Line WeChat WhatsApp) ព័ត៌មានជាចំហលើសារព័ត៌មាន តាមការប្រមូលព័ត៌មានជាសម្ងាត់របស់(អ.ប.ព.) ត្រូវបានយកមកពិនិត្យនិងដោះស្រាយក្នុងកិច្ចប្រជុំអាហារពេលព្រឹក (ចាប់ផ្តើមម៉ោង៧:៣០នាទី) នៅរៀងរាល់ព្រឹកនៃថ្ងៃធ្វើការដើម្បីពិនិត្យពាក្យប្តឹងដែលបានដាក់មកអង្គភាពប្រឆាំងអំពើពុករលួយ ពាក្យប្តឹងពិសេសដទៃទៀតត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាវិន័យនិងត្រួតពិនិត្យផ្ទៃក្នុង ដើម្បីប្រជុំវិភាគនិងដោះស្រាយ ដោយមានការបើកទ្វារជូនដល់ម្ចាស់បណ្តឹងចូលស្តាប់ការជជែកវែកញែកក៏ដូចជាការផ្តល់នូវជាតុចូលបន្ថែមលើករណីបណ្តឹងរបស់ខ្លួន។

**ការងារទទួលពាក្យប្តឹង**

| យន្តការ នៃការទទួលពាក្យប្តឹង | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | |
| ប្តឹងផ្ទាល់នៅ អ.ប.ព. | ២២៨ | ៣៨,៧៨ | ១៧៤ | ៣៥,៧៣ | ២២៥ | ៣៦,២៣ | ៣២៥ | ៤៩,២៤ | ១៨០ | ៤៣,៧៥ | **១ ១៣២** |
| ប្រអប់សំបុត្រស | ២៧៧ | ៤៧,១១ | ២៤៧ | ៥០,៧២ | ២៤២ | ៣៨,៩៧ | ២៤៧ | ៣៧,៤២ | ១៧០ | ៤៣,១៤ | **១ ១៨៣** |
| អ្នកបញ្ជូនសារ | ៨ | ១,៣៦ | ៣ | ០,៦២ | ១០៤ | ១៦,៧៥ | ២ | ០,៣០ | - | - | **១១៧** |
| ទូរសព្ទ | ១ | ០,១ | ៣ | ០,៦២ | ១ | ០,១៦ | ១ | ០,១៥ | - | - | **៦** |
| អ៊ីមែល | ៣៥ | ៥,៩៥ | ២៨ | ៥,៧៥ | ១៩ | ៣,០៦ | ២៩ | ៤,៣៩ | ១៤ | ៦,២៥ | **១២៥** |
| ប្រៃសណីយ៍ | ១៨ | ៣,២៣ | ៦ | ១,២៣ | ៨ | ១,២៩ | ៧ | ១,០៦ | ៤ | ១,៧០ | **៤៤** |
| Facebook | ២០ | ៣,៤០ | ២៤ | ៤,៩៣ | ១៨ | ២,៩០ | ៤៥ | ៦,៨២ | ១៤ | ១,៧០ | **១២១** |
| តេឡេក្រាម | - | - | ១ | ០,២១ | ៣ | ០,៤៨ | ៣ | ០,៤៥ | - | - | **៧** |
| សារព័ត៌មាន | - | - | ១ | ០,២១ | ១ | ០,១៦ | ១ | ០,១៥ | ១១ | ៤,៥៥ | **១៤** |
| **សរុប** | **៥៨៨** | **១០០** | **៤៨៧** | **១០០** | **៦២១** | **១០០** | **៦៦០** | **១០០** | **៣៩៤** | **១០០** | **២ ៧៥០** |

ឱកាសក្នុងការចូលរួមនិងការមើលឃើញផ្ទាល់នូវសក្ខីភាពនៃកិច្ចប្រឹងប្រែងប្រកបដោយសមត្ថភាព ដោយស្មារតីទទួលខុសត្រូវ វិជ្ជាជីវៈច្បាស់លាស់របស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងការដោះស្រាយបណ្តឹងតែងតែទទួលបាននូវការសាទរពីសំណាក់អ្នកប្តឹង។ យន្តការដោះស្រាយបណ្តឹងនិងស៊ើបអង្កេតក៏ត្រូវបានប្រើប្រាស់សម្រាប់ព័ត៌មានដែលទទួលបានទាំងប្រភពចំហ និងចារកម្ម ក្រោមគោលការណ៍តឹងរ៉ឹង និងមិនអាចដោះដូរបាននៃការរក្សាការសម្ងាត់នៃប្រភពក៏ដូចជាសាក្សីទាំងនៅក្នុងនិងនៅក្រៅអង្គភាពប្រឆាំងអំពើពុករលួយ។

**ការងារចំណាត់ការដោះស្រាយពាក្យប្តឹង**

| ចំណាត់ការ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| រក្សាទុកជាព័ត៌មាន | ៣៥ | ៤២ | ២៤ | ៤៧ | ៣២ | **១៨០** |
| ដោះស្រាយបញ្ចប់ពាក្យប្តឹង (មិនពាក់ព័ន្ធអំពើពុករលួយ) | ២២០ | ២០៧ | ២៦២ | ២៧៤ | ១៥៤ | **១ ១១៧** |
| - អន្តរាគមន៍ | - | ៧ | ១២ | ៨ | ៦ | **៣៣** |
| - ឆ្លើយតប (+ចម្លងជូន) | ១២៦ | ៨៥ | ៨៤ | ១៥២ | ១០៨ | **៥៥៥** |
| - ស្រាវជ្រាវ<br>- សុំការបំភ្លឺ | ៩៤ | ១១៥ | ១៦៦ | ១១៤ | ៤០ | **៥២៩** |
| បញ្ជូនសំណុំរឿងទៅតុលាការ(ករណី) | ៨ | ២ | ៥ | ៧ | ៥ | **២៧** |
| ពាក្យប្តឹងកំពុងបន្តនីតិវិធី | ៣២៥ | ២៣៦ | ៣៣០ | ៣៣២ | ២០៣ | **១ ៤២៦** |

បទពិសោធន៍ បានចង្អុលបង្ហាញពីកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង ស្ថាប័ន ប្រកបដោយភាពវិជ្ជមានក្នុងការដោះស្រាយពាក្យប្តឹងដែលមិនទាន់មាន ឬមិនអាចមាន ឬក៏មានភស្តុតាងដែរ ប៉ុន្តែភស្តុតាងត្រូវបានរលត់ និងមិនអាចយកមកប្រើប្រាស់ដើម្បីបញ្ជូនសំណុំរឿងទៅតុលាការបាន ទន្ទឹមនឹងនោះ ប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹងតាមបែបរដ្ឋបាលនិងវិន័យ ក៏អាចនាំមកនូវឥទ្ធិពលដុំព្រិល(Snowball Effect) ពោលគឺនាំមកលទ្ធផលដែលចង់បាននោះគឺកំហុសដដែលៗមិនអាចកើតឡើងជាថ្មី ហើយការកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលស្អាតស្អំនៅតាមស្ថាប័នសាធារណៈក៏មានសន្ទុះវិជ្ជមានគួរឱ្យកត់សម្គាល់។

កំណើននៃចំណាត់ការរដ្ឋបាលនិងវិន័យ ដែលជាលទ្ធផលនៃកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ព្រមទាំងជាមួយនឹងតម្រូវការនិងភាពចាំបាច់ក្នុងការរកឱ្យបាននូវភស្តុតាងឱ្យបានរឹងមាំ និងច្បាស់លាស់ ដែលជាទូទៅត្រូវការពេលវេលា បទពិសោធន៍និងជំនាញ វិជ្ជាជីវៈគួបផ្សំគ្នា បានធ្វើឱ្យសំណុំរឿងទៅតុលាការត្រូវបានកាត់បន្ថយនិងទទួលបានជោគជ័យ១០០%។

### ១.៤- ការបំពេញភាតព្វកិច្ចជាតិនិងអន្តរជាតិ

អង្គភាពប្រឆាំងអំពើពុករលួយ បានបំពេញភារកិច្ចក្នុងនាមជាស្ថាប័នតំណាងឱ្យរដ្ឋភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(UNCAC) ដោយអង្គភាពប្រឆាំងអំពើពុករលួយ គឺជាស្ថាប័នបង្គោលក្នុងការសម្របសម្រួលលើដំណើរការទទួលការត្រួតពិនិត្យការអនុវត្ត UNCAC ជុំទី២ នៅកម្ពុជា ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរួមមានស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ វិស័យឯកជន អង្គការសង្គម-ស៊ីវិល ដៃគូអភិវឌ្ឍន៍ និងផ្នែកសិក្សាធិការ។ ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ UNCAC នៅជុំទី២ អង្គភាពប្រឆាំងអំពើពុករលួយទទួលការត្រួតពិនិត្យពីសំណាក់ UN នៅប្រទេសថៃ និងអេស្វាទីនី ហើយតំណាងអង្គភាពប្រឆាំងអំពើពុករលួយនៅប្រទេសកម្ពុជា និងUN នឹងទៅត្រួតពិនិត្យការអនុវត្ត UNCAC នៅប្រទេសគិរីបាស និងលីបង់វិញដែរ។

អង្គភាពប្រឆាំងអំពើពុករលួយក៏បានចូលរួមយ៉ាងសស្រាក់សស្រាំក្នុងយន្តការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលកំណត់ដោយអង្គការ FATF។ ការងារគាំទ្រ និងការបំពេញភារកិច្ចពីសំណាក់អង្គភាពប្រឆាំងអំពើពុករលួយ សំដៅរុញច្រានកម្ពុជាចេញពីបញ្ជីប្រផេះ កំណត់ដោយអង្គការ FATF គឺជាអាទិភាពមួយចាំបាច់បំផុត។

អង្គភាពប្រឆាំងអំពើពុករលួយ ស្វាគមន៍ចំពោះកាតព្វកិច្ចអន្តរជាតិទាំងអស់ដែលពាក់ព័ន្ធជាមួយការងារប្រឆាំងអំពើពុករលួយ និងការសម្អាតប្រាក់ ហើយជឿថា កាតព្វកិច្ចទាំងនេះបាននាំមកដល់កម្ពុជានូវឱកាសនៃការអភិវឌ្ឍផ្ទៃក្នុង ទាំងក្នុងក្របខ័ណ្ឌច្បាប់ និងការអនុវត្តតួនាទីរបស់តួអង្គពាក់ព័ន្ធទាំងអស់។

កម្ពុជាបានចាត់ទុកការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម គឺជាការងារសំខាន់ ចាំបាច់ និងបន្ទាន់។ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញឆន្ទៈនិងការប្តេជ្ញាចិត្តខ្ពស់ចំពោះការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម២០១៩-២០២៣ ការកែសម្រួលក្របខ័ណ្ឌច្បាប់និងក្របខ័ណ្ឌស្ថាប័ន ដើម្បីធ្វើឱ្យការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

អង្គភាពប្រឆាំងអំពើពុករលួយ បានចូលរួមកិច្ចប្រជុំកិច្ចការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សរុបចំនួន២លើក នៅឆ្នាំ២០២០ និងចំនួន៥លើក នៅឆ្នាំ២០២១ ដោយផ្តោតសំខាន់លើការត្រួតពិនិត្យវឌ្ឍនភាពការអនុវត្តផែនការសកម្មភាពប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការពិនិត្យលើអនុសាសន៍ដែលកម្ពុជាមិនទាន់ទទួលបានចំណាត់ថ្នាក់ល្អ។

ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ

| ប្រភេទកិច្ចសហប្រតិបត្តិការ(លើក) | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| កិច្ចប្រជុំអាស៊ានផេក ASEAN-PAC | ២ | ២ | ២ | ២ | ២ | **១០** |
| កិច្ចប្រជុំ UNCAC | ៣ | ៣ | ៣ | - | ១ | **១០** |
| កិច្ចប្រជុំ ADB/OECD | ១ | ១ | ១ | ១ | ១ | **៥** |
| សន្និសីទ/កិច្ចប្រជុំ IAACA | - | - | ១ | - | - | **១** |
| កិច្ចប្រជុំ IACA | ១ | ១ | ១ | ១ | ១ | **៥** |
| កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ចសិក្សា សិក្ខាសាលាផ្សេងៗ | ១២ | ២១ | ២៦ | ៦ | ១៥ | **៨០** |
| សរុប | **១៩** | **២៨** | **៣៤** | **១០** | **២០** | **១១១** |

## ២- ការអប់រំ ផ្សព្វផ្សាយ និងអធិការកិច្ច

## ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

### ២.១- ការងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន១០២លើក និងប្រជុំឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចចំនួន២លើក នៅទីស្តីការក្រសួង

- បានចូលរួមការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចក្នុងកិច្ចប្រជុំជំនាញបច្ចេកទេសចំនួន៦លើក និងការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀតចំនួន២លើកនៅទីស្តីការគណៈរដ្ឋមន្ត្រី

- បានបញ្ចូលឯកសារច្បាប់ចំនួន៦១០ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចំនួន១៨៤លិខិត ទៅក្នុងបណ្ណាល័យអេឡិចត្រូនិក

- បានចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ចំនួន៤៥លើក គឺច្បាប់ភូមិបាលចំនួន២៩លើក ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន១២លើក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៤លើក នៅខេត្តចំនួន៨ ដោយមានអ្នកចូលរួមចំនួន៤ ៤៧៤នាក់(ស្ត្រីចំនួន២ ២៩៣នាក់)។

### ២.២- ការងារអប់រំផ្សព្វផ្សាយច្បាប់

បានចុះផ្សព្វផ្សាយច្បាប់ចំនួន៥០០លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន៧៦លើក និងមន្ទីររាជធានី ខេត្តចំនួន៤២៤លើក ក្នុងនោះ ឆ្នាំ២០១៧ ចំនួន៨៦លើក ឆ្នាំ២០១៨ចំនួន១២៤លើក ឆ្នាំ២០១៩ ចំនួន១៤៤លើក ឆ្នាំ២០២០ ចំនួន១០២លើក ឆ្នាំ២០២១ ចំនួន៤៤លើក) គឺច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន២៤០លើក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១៧១លើក ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិចំនួន២លើក ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសងចំនួន១លើក ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន២លើក ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះចំនួន៦លើក ច្បាប់ស្តីពីការបង្ការនិងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ចំនួន៩លើក ច្បាប់ស្តីពីជលផលចំនួន៣លើក ច្បាប់ភូមិបាលចំនួន៣លើក ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយ

គ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចំនួន១២លើក ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៤២លើក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតនិងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចំនួន៩លើក នៅរាជធានី ខេត្តចំនួន២១ ដោយមានអ្នកចូលរួមចំនួន១៥០ ៨៧៣នាក់(ស្រីចំនួន៦១ ៩៧៨នាក់)។

### ២.៣- ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

បានចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីលើ សេចក្តីព្រាងព្រះរាជក្រឹត្យចំនួន១១លើក សេចក្តីព្រាងច្បាប់ចំនួន៩៣លើក សេចក្តីព្រាងអនុក្រឹត្យចំនួន៩០លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន៣៨លើក។

### ២.៤- ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា

- បានចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភាលើសេចក្តីស្នើច្បាប់ចំនួន៧លើក សេចក្តីព្រាងច្បាប់ចំនួន៩៨លើក ការបោះឆ្នោតជ្រើសតាំងចំនួន១៣លើក របាយការណ៍របស់រដ្ឋសភាចំនួន៦លើក ព្រះរាជសារចំនួន៧លើក ការអនុម័តបទបញ្ជាផ្ទៃក្នុងរដ្ឋសភានីតិកាលទី៦ចំនួន១លើក ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន២លើក ការសម្រេចអំពីសុពលភាពចំនួន២លើក និងបានចូលរួមអមដំណើរជាមួយគណៈកម្មការនានានៃរដ្ឋសភាចំនួន១៣លើក

- បានចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភាលើសេចក្តីស្នើច្បាប់ចំនួន៨លើក សេចក្តីព្រាងច្បាប់ចំនួន៩៤លើក ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មីចំនួន៥លើក ការបោះឆ្នោតជ្រើសតាំងចំនួន២លើក ការបោះឆ្នោតជ្រើសរើសចំនួន១លើក របាយការណ៍របស់ព្រឹទ្ធសភាចំនួន១លើក និងបានចូលរួមអមដំណើរជាមួយសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចំនួន២លើក។

### ២.៥- ការងារទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

បានចុះរៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន២៦លើក នៅខេត្តចំនួន៩ ដោយមានអ្នកចូលរួមចំនួន៧ ៧០៩នាក់(ស្រីចំនួន២ ៤០០នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន៨១៥សំណូមពរ។

### ២.៦- សកម្មភាពការងារអធិការកិច្ច

#### ២.៦.១- ការងារអធិការកិច្ច(លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)

- បានចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០១៦ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ អង្គភាព(ក្នុងវិស័យ សេដ្ឋកិច្ច រដ្ឋបាល

ទូទៅ និងសង្គមកិច្ច) បានចំនួន៧០៣មន្ទីរ អង្គភាព ក្នុង២៥រាជធានី-ខេត្ត និងចំនួន១៣ក្រសួង ស្ថាប័ន ក្នុងការិយបរិច្ឆេទ២០១៧ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ អង្គភាព(ក្នុងវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច) បានចំនួន៦៣៤មន្ទីរ អង្គភាព ក្នុង២៥រាជធានី ខេត្ត និងចំនួន១៥ក្រសួង ស្ថាប័ន ក្នុងការិយបរិច្ឆេទ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ អង្គភាព(ក្នុងវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច) បានចំនួន៧៧០មន្ទីរ អង្គភាព ក្នុង២៥រាជធានី ខេត្ត និងចំនួន១៩ក្រសួង ស្ថាប័ន និងក្នុងការិយបរិច្ឆេទ២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋបាលខេត្ត មន្ទីរ អង្គភាព(ក្នុងវិស័យសេដ្ឋកិច្ច និងវិស័យរដ្ឋបាលទូទៅ) បានចំនួន២២៧មន្ទីរ អង្គភាព ក្នុង១៥រាជធានី ខេត្ត

- បានធ្វើលិខិតជូនដំណឹងចំនួន២៨១លិខិត ជូនដល់ក្រសួង ស្ថាប័ន ឱ្យជួយជំរុញកែលម្អចំណុចខ្វះខាតនៅតាមបណ្តាមន្ទីរ អង្គភាព ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន និងបានទទួលលិខិតឆ្លើយតបចំនួន៤០លិខិត

- តាមរយៈការចុះធ្វើអធិការកិច្ច បានពិនិត្យឃើញថាក្រសួង ស្ថាប័ន មន្ទីរ អង្គភាព តាមបណ្តារាជធានី ខេត្ត បានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានបានល្អប្រសើរ។

**២.៦.២- ការងារតាមដានការអនុវត្តច្បាប់**

- បានចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ គោលនយោបាយ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាចំនួន៩៥លើក នៅក្រសួង ស្ថាប័នចំនួន៥ និងចំនួន២៥រាជធានី ខេត្ត រួមមានច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ច្បាប់ស្តីពីគយ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ច្បាប់ស្តីពីបរិស្ថាន ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី អនុក្រឹត្យលេខ២១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ អនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់ អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន អនុក្រឹត្យលេខ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច អនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ អនុក្រឹត្យលេខ០៦អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការកម្រិតកំណត់ទម្ងន់អតិបរមានៃយានយន្តដឹកជញ្ជូនផ្លូវគោក ដែលបើកបរលើបណ្តាញផ្លូវជាតិនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរជាគ្រឹះស្ថាន

សាធារណៈរដ្ឋបាល អនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែង អនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល អនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀប ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល អនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រកាសលេខ២៤៧ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងអាជីវកម្មល្បែងកម្សាន្តស្លុតម៉ាស៊ីន ល្បែងអេឡិចត្រូនិក និងមេកានិចគ្រប់ប្រភេទ ប្រកាសលេខ០៨៧ អ.ន.ស.ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី ប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន សេចក្តីជូនដំណឹងលេខ៣៦៧ សជណ.កមច ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការចុះតាមដាន និងជំរុញឱ្យបណ្តាក្រសួង ស្ថាប័នដែលមានប្រភពចំណូលត្រូវបង់ចូលថវិកាជាតិ កិច្ចសន្យាស្តីពីការបង្កើត និងធ្វើអាជីវកម្មសន្និធិគយបណ្តោះអាសន្ន(ផែស្ងួត) ការអនុវត្តកិច្ចព្រមព្រៀងរបស់ក្រុមហ៊ុនវិនិយោគសិក្សាស្វែងរុករករ៉ែ និងការធ្វើអាជីវកម្មធនធានរ៉ែ និងការអនុវត្តកិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី

- បានធ្វើលិខិតជូនដំណឹងចំនួន២៦លិខិតស្តីពីការជំរុញកែលម្អចំណុចទៅក្រសួង ស្ថាប័នរងអធិការកិច្ច និងបានទទួលលិខិតឆ្លើយតបចំនួន៥លិខិត។

## ទី៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

### ១- ការងាររដ្ឋបាលនិងវិសហមជ្ឈការ

#### ១.១-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្ន(គិតត្រឹមខែតុលា ឆ្នាំ២០២១) ព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន១ ខេត្ត២៤ ក្រុង២៨ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១ ៤០៦ សង្កាត់២៤៦ និងភូមិចំនួន១៤ ៤៤៣។ កត់សម្គាល់កំឡុងពេល៥ឆ្នាំនេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ បានសម្រេចជាគោលការណ៍៖

- កែសម្រួលឡើងវិញនូវព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល រវាងក្រុង ព្រៃវែង និងស្រុកពោធិ៍រៀង ខេត្តព្រៃវែង រវាងក្រុងតាខ្មៅ ជាមួយស្រុកកណ្តាលស្ទឹង និងស្រុកស្អាង ខេត្តកណ្តាល និងរវាងឃុំមួយចំនួននៅក្នុងខេត្តកំពង់ធំ និងខេត្តក្រចេះ

- បង្កើតក្រុងកោះរ៉ុង ចំណុះខេត្តព្រះសីហនុ ក្រុងបូកគោ ចំណុះខេត្តកំពត ខណ្ឌបឹងកេងកង និងខណ្ឌកំបូល ចំណុះរាជធានីភ្នំពេញ ស្រុកតាលោសែនជ័យ ចំណុះខេត្តពោធិ៍សាត់ និងស្រុកបុរីអូរស្វាយសែនជ័យ ចំណុះខេត្តស្ទឹងត្រែង

- បង្កើតឃុំថ្មីចំនួន១ និងភូមិថ្មីចំនួន២១ ក្នុងខេត្តបាត់ដំបង ឃុំថ្មីចំនួន១ ក្នុងខេត្តកំពង់ស្ពឺ ឃុំថ្មីចំនួន១ និងភូមិថ្មីចំនួន៣៧ ក្នុងខេត្តក្រចេះ សង្កាត់ថ្មីចំនួន២ ក្នុងខេត្តបន្ទាយមានជ័យ និងភូមិថ្មីចំនួន២ ក្នុងខេត្តតាកែវ

- បង្កើតនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវនិមិត្តសញ្ញារាជធានី ខេត្តចំនួន២៤(វៀរលែងខេត្តស្ទឹងត្រែង ដែលត្រូវបានអនុញ្ញាតឱ្យកែសម្រួលទម្រង់និមិត្តសញ្ញាចាស់)។

### ១.២- ការងារវិមជ្ឈការនិងវិសហមជ្ឈការ

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ឆ្នាំ២០១០-២០២០) ត្រូវបានអនុវត្តបញ្ចប់នៅដំណាច់ឆ្នាំ២០២០ ជាមួយសមិទ្ធផលសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការផ្ទេរបុគ្គលិក ការកសាងសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់សមភាព សមធម៌យេនឌ័រ ក្នុងដំណើរការកំណែទម្រង់ និងការផ្តល់សេវាសាធារណៈដែលមានការឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះនានា។

#### ក- ការគាំទ្រនិងតាមដាន ត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រសួងមហាផ្ទៃបានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍរាជធានី ខេត្ត សរុបចំនួន១ ៧២៦ គម្រោង។ គម្រោងទាំងនេះ ភាគច្រើនផ្តោតទៅលើការកសាងអគាររដ្ឋបាលសាលា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា។

ក្រោមការសម្របសម្រួលពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេស បានអនុវត្តគម្រោងមូលនិធិក្រុង ស្រុកចំនួន២ ២៧៣គម្រោង និងគម្រោងមូលនិធិឃុំ សង្កាត់ចំនួន៩ ២១១គម្រោង។ មូលនិធិទាំងនេះ ភាគច្រើនផ្តោតទៅលើការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងមធ្យម គម្រោងសេវាសង្គម ការផ្តល់ សេវាសាធារណៈជូនប្រជាពលរដ្ឋ។

#### ខ- ការផ្ទេរមុខងារនិងធនធាន

គិតមកដល់ឆ្នាំ២០២១ មានក្រសួងចំនួន១៨ ដែលបានធ្វើការពិនិត្យមុខងាររបស់ខ្លួន និងបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ ក្រសួងរ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងធម្មការ និងសាសនា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងកិច្ចការនារី និងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

#### គ- ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត អង្គភាពនេះត្រូវបានដាក់ឱ្យដំណើរការនៅពាក់កណ្តាលឆ្នាំ២០១៨។ គិតចាប់ពីពេលដាក់ឱ្យដំណើរការ រហូតដល់ខែកក្កដា ឆ្នាំ២០២១ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង២៥ ផ្តល់សេវាបានចំនួន១ ៤៨៩ ២៣៦សេវា លើ១៤វិស័យ ទទួលបានចំណូលចំនួន ១៨០ ៨២៩ ៦៣៧ ៨០៨រៀល។

ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នមានចំនួន១១៥ការិយាល័យ ក្នុងនោះ គិតពីឆ្នាំ២០១៧ ដល់ខែកក្កដា ឆ្នាំ២០២១ ការិយាល័យទាំងនេះផ្តល់សេវាបាន៥ ៩១២ ១២៦សេវា លើ១៤វិស័យ ទទួលបានចំណូលចំនួន៧២ ៨១៥ ៦៦៣ ៤៦៦រៀល។

## ២- ការពង្រឹងវិស័យយុត្តិធម៌និងនីតិរដ្ឋ

### ២.១- ការពង្រឹងវិស័យយុត្តិធម៌

ក្រសួងយុត្តិធម៌ សម្រេចការងារដូចខាងក្រោម៖

### ក- ការកសាងច្បាប់ ដើម្បីចូលរួមពង្រឹងនីតិរដ្ឋ

ច្បាប់ដែលរាជរដ្ឋាភិបាល(ក្រសួងយុត្តិធម៌) បានក្រាបបង្គំទូលថ្វាយស្នើសុំព្រះករុណា ព្រះមហាក្សត្រ ទ្រង់ព្រះរាជទានព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ ដែលស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តរួចចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ មានដូចខាងក្រោម៖

១- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

២- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៣- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

៤- ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

៥- ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

៦- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

៧- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៨- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី បត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណា-ចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

៩- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។

### ខ- ការងារអប់រំនិងផ្សព្វផ្សាយច្បាប់

ក្រៅពីការកសាងច្បាប់ ក្រសួងយុត្តិធម៌ ក៏មានតួនាទីភារកិច្ចក្នុងការអប់រំនិងផ្សព្វផ្សាយច្បាប់បានទូលំទូលាយជូនប្រជាពលរដ្ឋនិងជាពិសេសចំពោះមន្ត្រីអនុវត្តច្បាប់។ ជាក់ស្តែងចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ ក្រសួងយុត្តិធម៌ បានធ្វើការបណ្តុះបណ្តាលនិងផ្សព្វផ្សាយច្បាប់តាមរយៈវិទ្យុនិងទូរទស្សន៍ ដូចមានរាយក្នុងតារាងខាងក្រោម៖

#### ខ.១- សិក្ខាសាលា នៅតាមរាជធានី-ខេត្ត

| ល.រ. | បរិយាយ | ចំនួន | អ្នកចូលរួមសរុប |
|---|---|---|---|
| ១ | សិក្ខាសាលាផ្សព្វផ្សាយ«**យេនឌ័រដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការជានារី**» | ៥វគ្គ | ១ ០០០នាក់ |
| ២ | សិក្ខាសាលាស្តីពី«**ការសុំកូន**» | ១៩វគ្គ | ១ ៩០០នាក់ |

| | | | |
|---|---|---|---|
| ៣ | សិក្ខាសាលាផ្សព្វផ្សាយស្តីពី«**ច្បាប់ជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងស្ត្រី**» | ៣៣វគ្គ | ៣ ៣០០នាក់ |
| ៤ | សិក្ខាសាលាថ្នាក់ជាតិស្តីពី«**ការអនុវត្តកុមារមេត្រី**» | ៣វគ្គ | ៥០០នាក់ |
| ៥ | សិក្ខាសាលាអំពីកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ | ៤៦វគ្គ | ៥ ៥៨៥នាក់ |
| ៦ | សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី | ៨វគ្គ | ៩៦០នាក់ |
| ៧ | សិក្ខាសាលាផ្សព្វផ្សាយពីទិន្នន័យរឿងក្តីរដ្ឋប្បវេណី | ៤វគ្គ | ៤៨០នាក់ |
| ៨ | សិក្ខាសាលាក្រមរដ្ឋប្បវេណីស្តីពីញាតិនិងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ | ៦វគ្គ | ៥៨០នាក់ |
| ៩ | សិក្ខាសាលាស្តីពីបច្ចេកទេសស្រាវជ្រាវទិន្នន័យ | ១៤វគ្គ | ១ ៣២០នាក់ |
| ១០ | សិក្ខាសាលាបញ្ច្រាបព័ត៌មានមណ្ឌលនិងច្បាប់មូលដ្ឋាន | ១៥វគ្គ | ១ ៩៥០នាក់ |
| ១១ | សិក្ខាសាលារៀបចំនីតិវិធីនៃការសម្រុះសម្រួល | ២វគ្គ | ១២០នាក់ |
| ១២ | សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី អគ្រានុកូលដ្ឋាន | ២វគ្គ | ៣៦០នាក់ |
| ១៣ | សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងកំណត់ពន្យល់<br>នៃក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី | ១វគ្គ | ១២០នាក់ |
| ១៤ | សិក្ខាសាលាថ្នាក់ជាតិផ្សព្វផ្សាយកិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យ<br>រដ្ឋប្បវេណីរវាងកម្ពុជា និងវៀតណាម | ៦វគ្គ | ៥០០នាក់ |
| ១៥ | សិក្ខាសាលាថ្នាក់ជាតិផ្សព្វផ្សាយកិច្ចព្រមព្រៀងស្តីពីការជួយគ្នាផ្នែកយុត្តិធម៌ក្នុងវិស័យ<br>រដ្ឋប្បវេណី | ២វគ្គ | ១៤០នាក់ |
| ១៦ | សិក្ខាសាលាស្តីពីក្រមនីតិវិធីរដ្ឋប្បវេណីដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការថ្នាក់ជាតិ<br>និងថ្នាក់ក្រោមជាតិ | ២៦វគ្គ | ២ ៦០០នាក់ |
| ១៧ | សិក្ខាសាលាផ្សព្វផ្សាយច្បាប់លើវិស័យរដ្ឋប្បវេណី | ៣១វគ្គ | ៤ ៩៨០នាក់ |
| ១៨ | សិក្ខាសាលាពិភាក្សា និងវាយតម្លៃសមិទ្ធផល និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់លើវិស័យ<br>រដ្ឋប្បវេណី | ៨វគ្គ | ៥២០នាក់ |
| ១៩ | សិក្ខាសាលាផ្សព្វផ្សាយអំពីការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌដល់មន្ត្រីអនុវត្តច្បាប់ | ៤វគ្គ | ៨៨០នាក់ |
| ២០ | សិក្ខាសាលាស្តីពី«**ច្បាប់យុត្តិធម៌អនីតិជន**» នៅរាជធានីភ្នំពេញ | ១វគ្គ | ១០០នាក់ |
| ២១ | សិក្ខាសាលាស្តីពី«**ការប្រតិបត្តិការអនុសញ្ញាCITES**» ជូនចៅក្រម តំណាងអយ្យការ និងមន្ត្រី<br>រាជការនៃក្រសួងយុត្តិធម៌ | ១វគ្គ | ៤១នាក់ |
| ២២ | សិក្ខាសាលាស្តីពី«**ច្បាប់យុត្តិធម៌អនីតិជន**» នៅរាជធានីភ្នំពេញ | ១វគ្គ | ១០០នាក់ |
| ២៣ | សិក្ខាសាលាស្តីពីការចែករំលែកបទពិសោធន៍ក្នុងសំណុំរឿងក្តីជួញដូរភ្លុកដំរីនិងកុយរមាស<br>ជូនចៅក្រមនិងតំណាងអយ្យការ | ១វគ្គ | ៦០នាក់ |
| ២៤ | សិក្ខាសាលាស្តីពី«**ការអនុវត្តបែបកុមារមេត្រី ដើម្បីការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់កុមាររងគ្រោះនៃអំពើរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងការអនុវត្តសំណងរដ្ឋប្បវេណីតាមនីតិវិធីតុលាការ**» តាមកម្មវិធីZoom | ១វគ្គ | ៩៨នាក់ |

## ខ.២- ការបណ្តុះបណ្តាល នៅតាមរាជធានី ខេត្ត

| ល.រ. | បរិយាយ | ចំនួន | អ្នកចូលរួមសរុប |
|---|---|---|---|
| ១ | វគ្គបណ្តុះបណ្តាល«**ជនបង្គោលយេនឌ័រ**» | ៥វគ្គ | ៥០០នាក់ |
| ២ | វគ្គបណ្តុះបណ្តាអំពីវិធីសាស្ត្រ បច្ចេកទេសស្រាវជ្រាវ សរសេរអត្ថបទវិភាគផ្នែកច្បាប់ និងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ៩វគ្គ | ៥០០នាក់ |
| ៣ | វគ្គបណ្តុះបណ្តាលការចុះបញ្ជីពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណី | ២០វគ្គ | ២ ២០០នាក់ |
| ៤ | វគ្គបណ្តុះបណ្តាលច្បាប់ក្នុងវិស័យរដ្ឋប្បវេណី | ២វគ្គ | ១៨០នាក់ |
| ៥ | វគ្គបណ្តុះបណ្តាលការចុះបញ្ជីពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណី ដល់មន្ត្រីអនុវត្តច្បាប់ និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ | ២វគ្គ | ១២០នាក់ |
| ៦ | វគ្គបណ្តុះបណ្តាលច្បាប់និងនីតិវិធីដល់មន្ត្រីមណ្ឌល | ១២វគ្គ | ២ ៥២០នាក់ |
| ៧ | វគ្គបណ្តុះបណ្តាលច្បាប់និងនីតិវិធីដល់ជនបង្គោលឃុំ សង្កាត់ | ១៨វគ្គ | ១ ៨០០នាក់ |
| ៨ | វគ្គបណ្តុះបណ្តាលច្បាប់និងនីតិវិធីនៃការដោះស្រាយវិវាទ ដល់អាជ្ញាធរមូលដ្ឋាន | ២វគ្គ | ៣០០នាក់ |
| ៩ | វគ្គបណ្តុះបណ្តាលនីតិវិធីច្បាប់និងជំនាញបច្ចេកទេស សន្ទានកម្ម | ១វគ្គ | ៨០នាក់ |
| ១០ | វគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយកិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកយុត្តិធម៌ក្នុងវិស័យរដ្ឋប្បវេណី រវាងកម្ពុជានិងវៀតណាម | ១វគ្គ | ១១០នាក់ |
| ១១ | វគ្គបណ្តុះបណ្តាលស្តីពី«**ការអនុវត្តក្រមនីតិវិធី នៅក្នុងដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរ និងផលលំបាកនានាក្នុងការអនុវត្ត**» ដល់មន្ត្រីអនុវត្តច្បាប់ | ៤វគ្គ | ២៥១នាក់ |
| ១២ | វគ្គបណ្តុះបណ្តាលច្បាប់ពាក់ព័ន្ធនឹងវិស័យព្រហ្មទណ្ឌដល់មន្ត្រីអនុវត្តច្បាប់ | ៤វគ្គ | ៤០០នាក់ |

## ខ.៣- ការផ្សព្វផ្សាយ តាមវិទ្យុ និងទូរទស្សន៍

| ប្រធានបទ | ការផ្សព្វផ្សាយ | |
|---|---|---|
| **ឆ្នាំ២០១៧-២០២១** | **វិទ្យុ** | **ទូរទស្សន៍** |
| ● រៀបចំផលិតស្ពតអប់រំអំពីច្បាប់ក្នុងវិស័យរដ្ឋប្បវេណី៖ | | |
| - ស្នុំកូនពេញលេញ | ៣ប៉ុស្តិ៍ | ៣ប៉ុស្តិ៍ |
| - កិច្ចសន្យាលក់-ទិញអចលនវត្ថុ និងសុពលភាព អាពាហ៍ពិពាហ៍ | ៣ប៉ុស្តិ៍ | ៣ប៉ុស្តិ៍ |
| - ភតិសន្យាពិសេស | ៣ប៉ុស្តិ៍ | ៣ប៉ុស្តិ៍ |
| - សន្តតិកម្មតាមច្បាប់ | ៣ប៉ុស្តិ៍ | ៣ប៉ុស្តិ៍ |
| ●រៀបចំផលិតស្ពតអប់រំអំពីច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ៖ | | |
| - បទល្មើសជួញដូរសត្វព្រៃ | - | ១ប៉ុស្តិ៍ |

| | | |
|---|---|---|
| ●រៀបចំវេទិកាអប់រំអំពីច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ | | |
| - ការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ | - | ១ប៉ុស្តិ៍ |
| ● រៀបចំផលិតស្ពតស្តីពីកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ | | |
| - ផលិតស្ពតអំពីកម្មវិធីកំណែទម្រង់និងសមិទ្ធផល | ៣ប៉ុស្តិ៍ | ៣ប៉ុស្តិ៍ |

## គ- ការចេញព្រឹត្តិបត្រថ្កោលទោសនិងកម្រៃសេវា

| បរិយាយ | ចេញព្រឹត្តិបត្រថ្កោលទោស | កម្រៃសេវាពីព្រឹត្តិបត្រថ្កោលទោស (រៀល) |
|---|---|---|
| ២០១៧ | ៤៧ ៣០១ | ២ ២៥៣ ៤៩០ ០០០ |
| ២០១៨ | ៤៥ ៣១៥ | ២ ២៧៣ ៤៥០ ០០០ |
| ២០១៩ | ៤៨ ៦៧៦ | ២ ៤៨២ ០៩០ ០០០ |
| ២០២០ | ៤២ ៣៥៩ | ២ ២៤០ ០០០ ០០០ |
| ២០២១ | ១៥ ២៣៨ | ១ ៧៩៤ ៦៦០ ០០០ |
| **សរុប** | **១៩៨ ៨៨៩** | **១១ ០៤៣ ៦៩០ ០០០** |

## ឃ- ចៅក្រម

| បរិយាយ | ចៅក្រមអាសនៈ (នាក់) | ចៅក្រមអយ្យការ (នាក់) |
|---|---|---|
| ២០១៧ | ២៦៦ | ១៧៩ |
| ២០១៨ | ២៦៤ | ១៧៣ |
| ២០១៩ | ៣០០ | ១៨៤ |
| ២០២០ | ៣៣៥ | ២០៤ |
| ២០២១ | ៣២៣ | ២០២ |
| **សរុប** | **១ ៤៨៨** | **៩៤២** |

ចាប់ពីឆ្នាំ២០១៧ ដល់ដំណាច់ឆ្នាំ២០២១នេះ ចៅក្រមសរុបនៅទូទាំងប្រទេស ដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការមានចំនួន១០៩នាក់(ស្រី២៣នាក់) ក្នុងនោះមានចៅក្រមអាសនៈ៦៩នាក់(ស្រី១៨នាក់) ចៅក្រមអយ្យការ៤០នាក់(ស្រី៥នាក់)។ ដោយឡែកចៅក្រម១៥៣នាក់(ស្រី២៨នាក់)ទៀត មិនទាន់ធ្វើការបែងចែក(កំពុងជាប់កម្មសិក្សា)។

## ង- ក្រឡាបញ្ជី

| ល.រ. | ការបណ្តុះបណ្តាល | | ចំនួនសិស្ស |
|---|---|---|---|
| | បរិយាយ | កាលបរិច្ឆេទ | |
| ១ | សិស្សក្រឡាបញ្ជីជំនាន់ទី៥ | ២០១៧-២០១៩ | ១១១នាក់(ស្រី២៦នាក់) |
| ២ | សិស្សក្រឡាបញ្ជីជំនាន់ទី៦ | ២០១៩-២០២០ | ៩៩នាក់(ស្រី៣៧នាក់) |
| ៣ | សិស្សក្រឡាបញ្ជីជំនាន់ទី៧ | ២០២០-បច្ចុប្បន្ន | ១១៧នាក់(ស្រី១១០នាក់) |
| សរុប | | | **៣២៧នាក់(ស្រី១៧៣នាក់)** |

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ក្រឡាបញ្ជីសរុបនៅទូទាំងប្រទេសដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ(ជំនាន់ទី៥ និងជំនាន់ទី៦) មានចំនួនសរុប២១០នាក់(ស្រី៦៣នាក់)។

### ច- មេធាវី

| ល.រ. | ការបណ្តុះបណ្តាល | | ចំនួនសិស្ស |
|---|---|---|---|
| | បរិយាយ | កាលបរិច្ឆេទ | |
| ១ | សិស្សមេធាវី ជំនាន់ទី១៥ | ២០១៧-២០១៨ | ៥៦នាក់(ស្រី១៤ នាក់) |
| ២ | សិស្សមេធាវី ជំនាន់ទី១៦ | ២០១៨-២០១៩ | ៥៥នាក់(ស្រី១៦នាក់) |
| ៣ | សិស្សមេធាវី ជំនាន់ទី១៧ | ២០១៩-២០២០ | ៦១នាក់(ស្រី២៨នាក់) |

ស្ថិតិសរុបសមាជិក សមាជិកាគណៈមេធាវីគិតត្រឹមឆ្នាំ២០២១នេះ មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈសរុបនៅទូទាំងប្រទេសមានចំនួន១ ៩៧៥នាក់(ស្រី៤៧៩នាក់)។

### ឆ- សារការី

| ល.រ. | ការបណ្តុះបណ្តាល | | ចំនួនសិស្ស |
|---|---|---|---|
| | បរិយាយ | កាលបរិច្ឆេទ | |
| ១ | សិស្សសារការីជំនាន់ទី២ | ២០២០-បច្ចុប្បន្ន | ២០នាក់(ស្រី៩នាក់) |

ចាប់ពីឆ្នាំ២០១៧ ដល់ដំណាច់ឆ្នាំ២០២១ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការបានរៀបចំវគ្គបណ្តុះបណ្តាលបន្តរួមមានសិក្ខាសាលា វគ្គបណ្តុះបណ្តាល បាឋកថា ជូនដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា សារការី និងអ្នកអនុវត្តច្បាប់ពាក់ព័ន្ធជាបន្តបន្ទាប់។ ក្រៅពីនេះ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ក៏បានដឹកនាំសិស្សចុះទស្សនកិច្ចសិក្សា និងអ្នកអនុវត្តច្បាប់ មកពីបណ្តាអង្គភាព និងស្ថាប័នពាក់ព័ន្ធនានា ប្រកបដោយគុណភាព ប្រសិទ្ធភាព បច្ចេកទេស និងគុកោសល្យខ្ពស់។ ជាមួយគ្នានេះដែរ ដើម្បីពង្រឹងគុណភាពនៃការបណ្តុះបណ្តាល និងរក្សាបាននូវប្រសិទ្ធភាពការងារសម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានបន្តពង្រឹងការបណ្តុះបណ្តាលគ្រូបង្គោលផ្នែកព្រហ្មទណ្ឌ គ្រូបង្គោលផ្នែករដ្ឋប្បវេណី និងគ្រូបង្គោលពាក់ព័ន្ធ និងជំនាញពិសេសផ្សេងៗទៀត រួមមានគ្រូបង្គោលពាណិជ្ជកម្ម និងគ្រូបង្គោលផ្នែកជួញដូរមនុស្សជាដើម។

## ២.២- ការពង្រឹងនីតិរដ្ឋ

### ទីស្តីការគណៈរដ្ឋមន្ត្រី

### ១- ការងារចូលរួមកសាងច្បាប់និងលិខិតបទដ្ឋានរបស់ក្រុមប្រឹក្សាអ្នកច្បាប់

✡សេចក្តីព្រាងច្បាប់ត្រូវបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិអនុម័ត និងព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| សេចក្តីព្រាងច្បាប់ត្រូវបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិអនុម័ត | ១៣ | ២០ | ៣០ | ៣៦ | ២១ |
| ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ | ២១ | ២១ | ២៤ | ៤៣ | ២១ |

✡ ច្បាប់ដែលរាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយស្នើសូមព្រះករុណា ព្រះមហាក្សត្រទ្រង់ ព្រះរាជទានព្រះរាជក្រមប្រកាសឱ្យប្រើបន្ទាប់ពីស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តរួចចាប់ពីឆ្នាំ១៩៩៣ ដល់ដំណាច់ឆ្នាំ២០២១ សរុបមាន**៥៩៩ច្បាប់**។

✡ ទទួលសំណួរនិងសំណើពីសមាជិករដ្ឋសភា និងស្ថាប័នពាក់ព័ន្ធ

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| សំណួរ ចម្លើយ(ករណី) | ៣ | ១៤ | ១៨ | ៥ | ១០ |

## ២- ការងាររៀបចំកិច្ចប្រជុំ

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| កិច្ចប្រជុំជំនាញបច្ចេកទេស(លើក) | ៧១ | ២៤ | ៨៥ | ២៧ | ៣៣ |
| កិច្ចប្រជុំអន្តរក្រសួង(លើក) | ៤០ | ១៦ | ២៨ | ២០ | ២១ |
| កិច្ចប្រជុំអន្តរក្រសួងចង្អៀត(លើក) | ០ | ០ | ១៨ | ៣៣ | ៩ |
| កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ(លើក) | ០ | ០ | ៧ | ២៧ | ៥ |
| កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី(លើក) | ៧ | ៦ | ៨ | ៧ | ៤ |
| កិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី(លើក) | ០ | ០ | ០ | ១ | ១ |

## ៣- ការងាររបាយការណ៍

ទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំរបាយការណ៍ជាប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ដើម្បីទូលថ្វាយព្រះមហាក្សត្រ និងជម្រាបជូនស្ថាប័ននីតិប្បញ្ញត្តិ ព្រមទាំងចម្លងជូនគ្រប់ក្រសួងស្ថាប័ន។

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ប្រចាំខែ (ក្បាល) | ១ ៤៤០ | ១ ៤៤០ | ១ ៤៤០ | ១ ៤៤០ | ១ ៤៤០ |
| ត្រីមាស (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |
| ឆមាស (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |
| ៩ខែ (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |
| ប្រចាំឆ្នាំ (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |

## ៤- ការងាររដ្ឋបាល

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| សេចក្តីសម្រេច | ១១៩ | ១០១ | ១៨៩ | ១១០ | ១២២ |
| ប្រកាស | ៧០ | ១០៩ | ១២៨ | ៨៥ | ៣២ |
| អនុក្រឹត្យតែងតាំង | ១ ៥០៣ | ១ ២៧៩ | ១ ៥២៦ | ១ ០៨៩ | ៦០៥ |
| អនុក្រឹត្យបង្កើត | ២៥៧ | ១៩៦ | ២៥៣ | ២៤២ | ២៨១ |
| សារាចរ | ៥ | ៧ | ៨ | ៧ | ៨ |
| សារាចរណែនាំ | ៥ | ៨ | ១២ | ៦ | ៧ |
| សេចក្តីណែនាំ | ៣ | ៣ | ២ | ០ | ៦ |

## ៥- ការងាររាជកិច្ច

ផ្នែកប្រមូលនិងចងក្រងឯកសារគតិយុត្តដែលបានបោះពុម្ពរួច គិតចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ រយៈពេល៥ឆ្នាំ ដោយនៅក្នុងឆ្នាំ២០២១ លិខិតបទដ្ឋានគតិយុត្តបានបោះពុម្ពគិតត្រឹមខែវិច្ឆិកា។

| ល.រ. | លិខិតបទដ្ឋាន | ឯកសារគតិយុត្តបោះពុម្ពតាមឆ្នាំនីមួយៗ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| ១ | ព្រះរាជក្រម | ២៣ | ២៣ | ២០ | ៤២ | ២៧ | ១៣៥ |
| ២ | ព្រះរាជក្រឹត្យ | ១ ១៧១ | ១ ៦០៣ | ១ ៧៥៥ | ១ ៦៧០ | ៧១៤ | ៦ ៩១៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ក្រុមប្រឹក្សាធម្មនុញ្ញ | ៣៤ | ៥ | ០ | ១ | ១១ | ៥១ |
| ៤ | ព្រឹទ្ធសភា | ០ | ២ | ០ | ០ | ០ | ២ |
| ៥ | រដ្ឋសភា | ២ | ៣ | ២ | ១ | ១ | ៩ |
| ៦ | អនុសញ្ញា | ១ | ០ | ០ | ០ | ០ | ១ |
| ៧ | អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ | ២២៩ | ២២២ | ១៦០ | ២៧៧ | ២០១ | ១ ០៨៩ |
| ៨ | អនុក្រឹត្យមានលក្ខណៈជាឯកត្តភូត | ១ ៣៧៤ | ១ ៣៥៣ | ១ ៤៣០ | ១ ១៧០ | ៥០៨ | ៥ ៨៣៥ |
| ៩ | សេចក្តីសម្រេច | ១១៦ | ១០០ | ១៧០ | ១២២ | ៨៧ | ៥៩៥ |
| ១០ | សារាចរ | ៥ | ៦ | ៧ | ៧ | ៦ | ៣១ |
| ១១ | សារាចរណែនាំ | ៤ | ៨ | ១០ | ៦ | ៥ | ៣៣ |
| ១២ | សារាចរណែនាំបន្ថែម | គ្មាន | គ្មាន | ១ | គ្មាន | គ្មាន | ១ |
| ១៣ | បទបញ្ជា | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| ១៤ | សេចក្តីណែនាំ | ១ | ៣ | គ្មាន | គ្មាន | ៣ | ៨ |
| ១៥ | សេចក្តីថ្លែងការណ៍ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ |
| ១៦ | សេចក្តីប្រកាស | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| ១៧ | យុទ្ធសាស្រ្ត | គ្មាន | ២ | គ្មាន | គ្មាន | គ្មាន | ២ |
| ១៨ | ទីស្តីការគណៈរដ្ឋមន្ត្រី | គ្មាន | គ្មាន | ១ | គ្មាន | ១ | ២ |
| ១៩ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២៤៣ | ២៤២ | ២៦៥ | ១៤៥ | ៧៧ | ៩៧២ |
| ២០ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ | ១២៧ | ២០៤ | ១៩០ | ១០៣ | ២១០ | ៨៣៤ |
| ២១ | ក្រសួងរ៉ែ និងថាមពល | គ្មាន | គ្មាន | ៥៦ | ៦៥ | ២៣៥ | ៣៥៦ |
| ២២ | ក្រសួងមហាផ្ទៃ | ៥ | គ្មាន | គ្មាន | ៥៣ | ៤២ | ១០០ |
| ២៣ | ក្រសួងការពារជាតិ | ៣ | ៤ | ២ | ១១ | ៧ | ២៧ |
| ២៤ | ក្រសួងយុត្តិធម៌ | គ្មាន | ១ | ១០ | ១៥ | ៣៥ | ៦១ |
| ២៥ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | គ្មាន | ១ | គ្មាន | គ្មាន | គ្មាន | ១ |
| ២៦ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | គ្មាន | គ្មាន | ១ | ២ | ២ | ៥ |
| ២៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣ | ១ | គ្មាន | ១ | គ្មាន | ៥ |
| ២៨ | ក្រសួងពាណិជ្ជកម្ម | ១ | ១ | គ្មាន | គ្មាន | ១ | ៣ |
| ២៩ | ក្រសួងសាធារណការ និងដឹកជញ្ជូន | គ្មាន | គ្មាន | ១ | ១ | គ្មាន | ២ |
| ៣០ | ក្រសួងទេសចរណ៍ | គ្មាន | គ្មាន | ៤ | ៣ | ៦ | ១៣ |
| ៣១ | ក្រសួងអភិវឌ្ឍន៍ជនបទ | គ្មាន | គ្មាន | គ្មាន | ១ | គ្មាន | ១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣២ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | គ្មាន | គ្មាន | ៣ | គ្មាន | គ្មាន | ៣ |
| ៣៣ | ក្រសួងធម្មការ និងសាសនា | គ្មាន | គ្មាន | គ្មាន | គ្មាន | ៧ | ៧ |
| ៣៤ | ក្រសួងកិច្ចការនារី | គ្មាន | គ្មាន | ៣២ | ១៦ | គ្មាន | ៤៨ |
| ៣៥ | ធនាគារជាតិនៃកម្ពុជា | ៧ | ១៣ | ១ | ៤ | គ្មាន | ២៥ |
| ៣៦ | អង្គភាពប្រឆាំងអំពើពុករលួយ | ១ | គ្មាន | គ្មាន | គ្មាន | ១ | ២ |
| សរុប | | ៣ ៣៥០ | ៣ ៧៩៧ | ៤ ១២៣ | ៣ ៧១៦ | ២ ១៨៩ | ១៧ ១៧៥ |

**ការងារផ្នែកបោះពុម្ពរាជកិច្ច**

| ឆ្នាំបោះពុម្ព | ចំនួនសៀវភៅក្នុង១លេខ | ចំនួនសៀវភៅក្នុង១ខែ(៨លេខ) | ចំនួនសៀវភៅក្នុង១ឆ្នាំ(៩៦លេខ) |
|---|---|---|---|
| ២០១៧ | ១ ៧០០ក្បាល | ១៣ ៦០០ក្បាល | ១៦៣ ២០០ក្បាល |
| ២០១៨ | ១ ៧០០ក្បាល | ១៣ ៦០០ក្បាល | ១៦៣ ២០០ក្បាល |
| ២០១៩ | ១ ៧០០ក្បាល | ១៣ ៦០០ក្បាល | ១៦៣ ២០០ក្បាល |
| ២០២០ | ១ ៣២៦ក្បាល | ១០ ៦០៨ក្បាល | ១២៧ ២៩៦ក្បាល |
| ២០២១ | ១ ៣២៦ក្បាល | ១០ ៦០៨ក្បាល | ១២៧ ២៩៦ក្បាល |

- ការផ្សព្វផ្សាយលើគេហទំព័រទីស្តីការគណៈរដ្ឋមន្ត្រី នាយកដ្ឋានរាជកិច្ចបានបញ្ចូលសៀវភៅរាជកិច្ចទៅក្នុងគេហទំព័រដែលអាចស្រាវជ្រាវ និងទាញយកបានគឺសៀវភៅរាជកិច្ចចាប់ពីឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០២១ ដែលក្នុងខែវិច្ឆិកានេះបានបញ្ចូលដល់ត្រឹមលេខ៥៨ (លេខគេហទំព័រ WWW.OCE.GOV.KH)

### ៦- លទ្ធផលការងារសម្រេចបានរបស់នាយកដ្ឋានតម្កល់ឯកសារជាតិ

**ក- ការងារចូលរួមបណ្តុះបណ្តាល សិក្ខាសាលា និងសន្និសីទ**

| ល.រ. | បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ការងារបណ្តុះបណ្តាលក្នុងប្រទេស | ២ | គ្មាន | ២ | ១ | គ្មាន | ៥លើក |
| ២ | ការងារបណ្តុះបណ្តាលក្រៅប្រទេស | ២ | ១ | ១ | គ្មាន | គ្មាន | ៤លើក |
| ៣ | ការងារសិក្ខាសាលាក្នុងប្រទេស | ៣ | ២ | គ្មាន | គ្មាន | ២ | ៧លើក |
| ៤ | ការងារសិក្ខាសាលាក្រៅប្រទេស | ១ | ១ | ៣ | គ្មាន | គ្មាន | ៥លើក |
| ៥ | ការងារសន្និសីទក្រៅប្រទេស | គ្មាន | ២ | គ្មាន | គ្មាន | គ្មាន | ២លើក |
| ៦ | ការងារបណ្តុះបណ្តាលអនឡាញក្នុងប្រទេស | គ្មាន | គ្មាន | គ្មាន | គ្មាន | ២ | ២លើក |
| ៧ | ការងារសន្និសីទ និងសិក្ខាសាលាអនឡាញក្រៅប្រទេស | គ្មាន | គ្មាន | គ្មាន | គ្មាន | ៧ | ៧លើក |

**ខ- ការងារបច្ចេកទេស**

| ល.រ | បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ១ | បកប្រែចំណងសៀវភៅក្នុងកុំព្យូទ័រ | គ្មាន | គ្មាន | ២ ២៤៤ | ២ ៦២៩ | ២ ៣៤៣ | ៧ ២១៦ ចំណងជើង |
| ២ | បោះពុម្ពបញ្ជីស្ថិតិសម្រាប់បម្រើការស្រាវជ្រាវ | គ្មាន | គ្មាន | គ្មាន | គ្មាន | ២ ១១០ | ២ ១១០ទំព័រ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | បញ្ចូលទិន្នន័យសៀវភៅ | ៤៧០ | ៣៩៥ | ៣៥២ | ៤៩១ | ៣៣៦ | ២ ០៤៤ក្បាល |
| ៤ | កែហ្មុងអក្សរចំណងសៀវភៅក្នុងកុំព្យូទ័រ | ២០០ | ៧០ | ៤ ៩៣៩ | ៥០ | ១៥០ | ៥ ៤០៩ ចំណងជើង |
| ៥ | ចំនួនឯកសារសម្អាតនិងចុះលេខ | ៦ ៣៧៩ | | ៨ ២៧៥ | ៣ ៤៨៦ | ១ ៤២០ | ១៩ ៥៦០ទំព័រ |
| ៦ | ចំនួនឯកសារស្កេន | ២ ៤៩៥ | ៣ ៤៥១ | ៣៣ ៥៤៧ | ១៦ ៩៨៣ | ២ ៣៦៦ | ៥៨ ៨៤២ទំព័រ |

ការងារគ្រប់គ្រងទំព័រហ្វេសប៊ុក( Facebook Page ) បណ្ណសារដ្ឋានជាតិនៃកម្ពុជា( National Archive of Cambodia ) ឆ្នាំ២០២១ សារបង្ហោះទៅដល់( Page reach ) មានចំនួន៧៨ ៥៧៧ ចំនួនអ្នកមើលទំព័រ( Page View ) មានចំនួន១ ៥៨៩ ដង ការចូលរួម ( Page enagement ) មានចំនួន៤ ២៧៦ ការចែករំលែក( Shares ) មានចំនួន៦៦ដង ការចូលចិត្តទំព័រ( Page Like ) ចំនួន១ ១២១ និងអ្នកតាមដានទំព័រ( Follower ) ចំនួន១ ៣៧៨នាក់។ បច្ចុប្បន្ន ( Facebook Page ) មានអ្នកចូលចិត្តទំព័រសរុប( Like ) ចំនួន១ ២៨៣នាក់។

**គ- ការងារគ្រប់គ្រងឃ្លាំងបណ្ណសារ**

| ល.រ | បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចំនួនផែនទី ប្លង់ដែលបានជួសជុល | ៤១ | ៧៥ | ៥៨ | ២១ | ១០ | ២០៥ផ្ទាំង |
| ២ | ចំនួនសៀវភៅដែលបានជួសជុល | ២ | ៣ | ១ | ១ | ០២ | ៩ក្បាល |
| ៣ | ចំនួនកាសែតដែលជួសជុល | | ៥០ | គ្មាន | គ្មាន | គ្មាន | ៥០ទំព័រ |
| ៤ | ចំនួនឯកសារក្រុមប្រឹក្សារដ្ឋដែលបានកែសម្រួល | ៤៤ | ២៨ | ៣៦ | ២៩ | ៥ | ១៤២ប្រអប់ |
| ៥ | ចំនួនឯកសារដែលបានត្រួតពិនិត្យ | ៥១ | ២៥ | ៤៩ | ២៨ | ៥ | ១៥៨ប្រអប់ |
| ៦ | ចំនួនឯកសារហ្វីលដែលបានត្រួតពិនិត្យ | គ្មាន | គ្មាន | ៤៥ | គ្មាន | គ្មាន | ៤៥ដុំ |
| ៧ | ចំនួនភ្ញៀវជាតិដែលបានមកស្រាវជ្រាវ | ៥៤ | ៥០ | ១ ១០៨ | ២៦២ | ២៣ | ១ ៤៩៧នាក់ |
| ៨ | ចំនួនភ្ញៀវអន្តរជាតិដែលបានមកស្រាវជ្រាវ | ៥២ | ៣៩ | ៣៣៨ | ៥៥ | ៤ | ៤៨៨នាក់ |
| ៩ | ចំនួនភ្ញៀវជាតិនិងអន្តរជាតិដែលបានមកទស្សនកិច្ច | ៦៧ | ១៤២ | ២៣១ | ៦០ | ៩ | ៥០៩នាក់ |
| ១០ | ចំនួនសៀវភៅដែលទទួលបាន | ១ ៣៥០ | ១ ៦៦០ | ១ ៤៩៩ | ៩១៦ | ២៦០ | ៥៦៨៥ក្បាល |
| ១១ | ចំនួនទស្សនាវដ្ដី ព្រឹត្តិបត្រ កាសែតដែលទទួលបាន | ៦៦១ | ១៩១ | ១៥៨ | ២៦០ | គ្មាន | ១ ២៧០ ច្បាប់ |
| ១២ | ចំនួនឯកសារថតចម្លង | ១៧៨១២ | ៨ ៨២៩ | ១០ ៣២១ | ១៣ ៤១៣ | ១ ៧០១ | ៥២០៧៦ទំព័រ |

## ៧-មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ( ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ) របស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានដូចខាងក្រោម៖

ក- រៀបចំពិធីសម្ពោធមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ ក្រោមអធិបតីភាព **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងឯកឧត្តម **ហ៊ីដេហ៊ីសា ហូរិនួជិ** ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ

ខ- មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលអគារថ្មី ដែលមានទីតាំងស្ថិតនៅអគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។ ការផ្លាស់ប្តូរទីតាំងថ្មីនេះគឺមានសក្តានុពលភាពជាងទីតាំងចាស់ និងបានទទួលការគាំទ្រពីម្ចាស់ជំនួយ គឺរដ្ឋាភិបាលនិងប្រជាជនជប៉ុន

គ- មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ត្រូវបានទទួលស្គាល់ជាសំណាងដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២ ដោយអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

ឃ- ទទួលបានជំនួយ និងការគាំទ្រពីរដ្ឋាភិបាលនិងប្រជាជនជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១៥ ខែតុលាឆ្នាំ២០១៩ បានទទួលការអនុម័តជាផ្លូវការពីរដ្ឋាភិបាលជប៉ុននូវការប្រើប្រាស់ថវិកាចំនួន២៥១ ៩៧០ដុល្លារអាម៉េរិក(ពីររយហាសិបមួយពាន់ប្រាំបួនរយចិតសិបដុល្លារ) ពីមូលនិធិបដិភាគជប៉ុន(Japan V) សម្រាប់ការអនុវត្តគម្រោង**«អនុវត្តអាណត្តិកេរដំណែលរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់(ម.ត.ឯ.ច.) ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»** រយៈពេលបីឆ្នាំ គឺឆ្នាំ២០១៩ ដល់ឆ្នាំ២០២១

ង- ការងារតម្កល់ឯកសារច្បាប់ និងឯកសារពាក់ព័ន្ធដែលទទួលបានមកពី អ.វ.ត.ក. បានធ្វើការសម្របសម្រួលនិងទទួលសំណុំរឿង០០១ ជាឯកសារទន់ និងឯកសាររឹងសរុបចំនួន៧០២៦សំណុំ និង០០២ វគ្គ១ ជាឯកសារទន់ សរុបចំនួន១៧២៦៧សំណុំ ពីអ.វ.ត.ក. មកតម្កល់នៅមជ្ឈមណ្ឌល សម្រាប់បម្រើការស្រាវជ្រាវ៖

- ករណី០០១ បោះត្រាឌីជីថលលើសំណុំរឿងអេឡិចត្រូនិក ករណី០០១ បានចំនួន៧០២៦សំណុំ សរុបចំនួន៧៤ ៣២៤ទំព័រ ធ្វើការកែសម្រួលប្រតិចារឹកបានចំនួន១៤ប្រតិចារឹក ស្មើនឹង១ ២៦៩ទំព័រ និងធ្វើការបន្សុីវីដេអូជាមួយប្រតិចារឹកដែលបានកែសម្រួលរួចបានចំនួន៦៨វីដេអូ

- ករណី០០២ បោះពុម្ពឯកសារសាលាក្ដីខ្មែរក្រហម ករណី០០២ វគ្គ១ សរុបចំនួន៣៤៦០សំណុំ សរុបចំនួន៣១ ៥៨៣ទំព័រ។ បោះត្រាឌីជីថលលើសំណុំរឿងអេឡិចត្រូនិក ករណី០០២ វគ្គ១ បានចំនួន១៧ ២៦៧ សំណុំ សរុបចំនួន១៧៥ ២៤៦ទំព័រ បានទទួលឯកសារសោតទស្សន៍នៃសំណុំរឿង០០២/០១ ពីអ.វ.ត.ក. សរុបមាន៥៥៨សវនាការ និង៣ ៩៤៤វីដេអូ រួមមាន(១) ឯកសារពីផ្នែកអង្គបុរេជំនុំជម្រះមាន២២សវនាការចំនួន៦៧វីដេអូ (២) ឯកសារពីអង្គជំនុំជម្រះសាលាដំបូងមាន៥២៧សវនាការចំនួន៣ ៨០៣វីដេអូ និង(៣) ឯកសារពីអង្គជំនុំជម្រះតុលាការកំពូលមាន៩សវនាការចំនួន៧៤វីដេអូ

- ឯកសារដទៃទៀតធ្វើបញ្ជី ចុះលេខ និងស្កេនឯកសារសំណុំរឿងកាត់ទោសមេដឹកនាំខ្មែរក្រហមឆ្នាំ១៩៧៩ បានចំនួន២៥៧សំណុំស្មើនឹង១ ១១៤ទំព័រ ធ្វើបញ្ជីឯកសារសោតទស្សន៍ចំនួន៨៩ស៊ីឌី ពិនិត្យផ្ទៀងផ្ទាត់សរសេរលេខកូដ ថតចម្លងឯកសារសំឡេងពីកាសែតទៅជាទម្រង់ឌីជីថលបានចំនួន២១កាសែត

- ការងារគ្រប់គ្រងបណ្ណាល័យ បានបញ្ចូលសៀវភៅទៅក្នុងប្រព័ន្ធគ្រប់គ្រងសៀវភៅ និងបណ្ណាល័យញូវជេនលីប សរុបចំនួន១៥៧ចំណងជើង សរុប៨៥ក្បាល បិទកូដសៀវភៅចំនួន៦៧៣ក្បាល ធ្វើតារាងទិន្នន័យចំណងជើងអត្ថបទក្នុងសារព័ត៌មាន(ដែលបានស្កេនរួច) បានចំនួន១៩ ០១៨ចំណងជើង។

ច- ការងារទទួលគារវកិច្ចចំពោះភ្ញៀវទស្សនកិច្ច ភ្ញៀវសិក្សាស្រាវជ្រាវ និងនិស្សិតហាត់ការ ភ្ញៀវស្រាវជ្រាវចំនួន៥០នាក់(អន្តរជាតិ២៩នាក់) ភ្ញៀវទស្សនកិច្ចសិក្សាចំនួន៣៦០២នាក់(អន្តរជាតិ១៦១នាក់) ទទួលនិស្សិតហាត់ការចំនួន១៨នាក់ ក្នុងនោះ និស្សិតខ្មែរចំនួន១៤នាក់ និងបរទេសចំនួន៤នាក់

ឆ- ការងារផ្សព្វផ្សាយដើម្បីឱ្យសាធារណជនយល់អំពីដំណើរការនិងសមិទ្ធផលរបស់អ.វ.ត.ក. បានសហការជាមួយអង្គការដៃគូនានាដើម្បីរៀបចំវេទិកាសំខាន់ៗនៅមជ្ឈមណ្ឌលផ្ទាល់ចំនួន៥លើក ដោយមានការចូលរួមពីសំណាក់អង្គការដៃគូជាតិនិងអន្តរជាតិ ដូចជាអ.វ.ត.ក. ក្រុមបណ្ដាប្រទេសម្ចាស់ផ្ដល់ជំនួយសំខាន់ៗ

១០ប្រទេសរបស់អ.វ.ត.ក. អង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា មជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា សកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចូលរួមធ្វើបទបង្ហាញអំពីមជ្ឈមណ្ឌល នៅក្នុងសន្និសីទជាតិនិងអន្តរជាតិ ព្រមទាំងកម្មវិធីជជែកពិភាក្សាក្រោមប្រធានបទ«**ការតម្កល់បណ្ណសាររបស់សាលាក្ដីខ្មែរក្រហម**» នៅវិទ្យុអេហ្វអឹម១០២ និងស្ថានីយទូរទស្សន៍អប្សរា។ ចុះឧទ្ទេសនាមការងារអំពីតួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌលនៅរាជធានី ខេត្ត តាមគ្រឹះស្ថានសិក្សា និងស្ថាប័នពាក់ព័ន្ធនានា ចំនួន៧៩កន្លែង មានសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិតនិងមហាជនចូលរួម សរុបចំនួន ២៣ ៧១៦នាក់

ជ- បានបង្កើតគេហទំព័រ(www.ldc-eccc.gov.kh) ផ្ទាល់ខ្លួននិងបណ្ដាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) (មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអ.វ.ត.ក LDC) បច្ចុប្បន្នមានអ្នកLike ចំនួន៤ ៥៤៨ នាក់ និងអ្នកតាមដានចំនួន៤ ៦១៩នាក់ ព្រមទាំងបានបោះពុម្ពព្រឹត្តិបត្រប្រចាំឆ្នាំ២០១៧ ឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០ និងខិត្តបណ្ណចំនួន២ប្រភេទ។

### ៨- សកម្មភាពនិងសមិទ្ធផលសំខាន់ៗរយៈពេល៥ឆ្នាំ(២០១៧-២០២១) របស់រាជបណ្ឌិត្យសភាកម្ពុជាមានដូចខាងក្រោម៖

**ក- រយៈពេល៥ឆ្នាំនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរ**បានអនុម័តបច្ចេកសព្ទសរុបចំនួន**១ ៦៩០ពាក្យ**

**ខ- គម្រោងស្ដីពីសិល្បៈចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត** បានធ្វើការថត ស្ទែន និងកំណត់ទីតាំងរូបអប្សរាពីជាន់ទី១ នៃកំពូលប្រាសាទចំនួន៤៣៨រូបនិងបានវិភាគទៅលើលក្ខណៈរចនាបថនៃរូបនីមួយៗយ៉ាងលម្អិត ព្រោះរូបចម្លាក់នៅតាមជញ្ជាំងប្រាសាទកំពុងប្រឈមនឹងការបាក់បែកពុកផុយ។ សៀវភៅដែលកើតចេញពីគម្រោងស្រាវជ្រាវនេះក៏ជាស្នាដៃដំបូងដែលសិក្សាដោយកូនខ្មែរ

**គ- គម្រោងស្ដីពីបន្លែកម្ពុជា ផលិតកម្ម ចរន្តទីផ្សារ និងបញ្ហាប្រឈម** បានចុះសិក្សាស្រាវជ្រាវនៅតាមបណ្ដាច្រកព្រំដែនខេត្តស្វាយរៀង តាកែវ កំពង់ចាម និងខេត្តបន្ទាយមានជ័យ ដើម្បីសិក្សាអំពីបរិមាណនៃការនាំបន្លែចូលមកកម្ពុជា។ ទន្ទឹមនឹងនោះ ក្រុមការងារក៏បានចុះសិក្សានៅតាមទីផ្សារបោះដុំបន្លែនានានៅក្នុងរាជធានី និងតាមបណ្ដាខេត្តមួយចំនួន ព្រមទាំងចុះសិក្សានៅតាមកសិដ្ឋានបន្លែរបស់កសិករ ដើម្បីសិក្សាវាយតម្លៃ និងកំណត់យុទ្ធសាស្ត្រ ដើម្បីលើកស្ទួយការដាំដុះនៅក្នុងស្រុក។ គម្រោងស្រាវជ្រាវនេះបានចងក្រងសៀវភៅលទ្ធផលស្រាវជ្រាវចប់រួចរាល់

**ឃ- គម្រោងស្ដីពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើសង្គមសេដ្ឋកិច្ចកម្ពុជា** សិក្សាអំពីផលប៉ះពាល់របស់ជំងឺកូវីដ-១៩ មកលើសង្គមសេដ្ឋកិច្ចកម្ពុជា ជាពិសេសលើវិស័យទេសចរណ៍ វិស័យកាត់ដេរ អចលនទ្រព្យ ព្រមទាំងមុខរបរនិងការងាររបស់ប្រជាពលរដ្ឋទូទាំងប្រទេស។ ក្រុមការងារចុះសិក្សាស្រាវជ្រាវ ដើម្បីកំណត់ជាយុទ្ធសាស្ត្រ និងដំណោះស្រាយជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីស្ដារសេដ្ឋកិច្ចឡើងវិញ។ គម្រោងស្រាវជ្រាវនេះបានចងក្រងសៀវភៅលទ្ធផលស្រាវជ្រាវចប់រួចរាល់

**ង- គម្រោងស្រាវជ្រាវស្ដីពីអត្តសញ្ញាណបដិមាព្រះបាទជ័យវរ្ម័នទី៧** សិក្សាកំណត់អត្តសញ្ញាណជាក់លាក់នៃអត្តសញ្ញាណបដិមាព្រះបាទជ័យវរ្ម័នទី៧ និងព្រះអគ្គមហេសីព្រះនាងជ័យរាជទេវីនៅប្រាសាទបាយ័ន តំបន់អង្គរ ខេត្តសៀមរាប និងនៅប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ ព្រមទាំងបាននិងកំពុងរៀបចំចុះកូដរូបចម្លាក់របស់ព្រះបាទជ័យវរ្ម័នទី៧ តាមទម្រង់នីមួយៗតាមជញ្ជាំងប្រាសាទ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនឹងសាង

បដិមាព្រះបាទជ័យវរ្ម័នទី៧ ជារូបទោលក្នុងទម្រង់ និងឥរិយាបថបង្ហាញពីអានុភាព អំណាច ពិសេសក្នុងពេលព្រះអង្គចេញធ្វើសង្គ្រាម ឬក្នុងពេលព្រះអង្គចាត់ចែងរាជកិច្ច។ ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ បានរកឃើញរូបចម្លាក់ដែលសង្ស័យថាជារូបរបស់ព្រះបាទជ័យវរ្ម័នទី៧ ឆ្លាក់នៅតាមថែវប្រាសាទបន្ទាយឆ្មារនិងប្រាសាទបាយ័នចំនួន៦៤ព្រះរូប។ ក្រៅពីនេះ នៅមានចម្លាក់នៅតាមប្រាសាទផ្សេងទៀត ប៉ុន្តែជាប្រភេទចម្លាក់លើផ្តែរនិងហោជាងដោយឆ្លាក់រូបព្រះអង្គគ្រងមកុដកំពូលបី ទ្រង់គ្រឿងជាព្រះមហាក្សត្រនិងមានមហេសី២នាក់ហែហមពាក់គ្រឿងជាមហេសី។ គម្រោងស្រាវជ្រាវនេះបានចងក្រងសៀវភៅលទ្ធផលស្រាវជ្រាវចប់រួចរាល់

**ច- គម្រោងស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា** សិក្សាកំណត់គន្លឹះនៃយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ដើម្បីប្រែក្លាយវិស័យទេសចរណ៍ឱ្យដើរតួនាទីជាឆ្អឹងខ្នងសេដ្ឋកិច្ចដ៏សំខាន់មួយក្នុងការអភិវឌ្ឍវិស័យពាក់ព័ន្ធ និងខ្សែចង្វាក់ក្នុងវិស័យពាក់ព័ន្ធ

**ឆ- គម្រោងស្តីពីទំនាក់ទំនងកម្ពុជា ថៃ** ពិនិត្យទៅលើភាពមិនចុះសម្រុងនៃនយោបាយផ្ទៃក្នុងរបស់ថៃ មោទនភាពពូជសាសន៍ និងបញ្ហាប្រជាភិថុតនៃអ្នកនយោបាយថៃដែលជាបច្ច័យនាំឈានទៅឱ្យមានការប្រឈមរវាងកម្ពុជា ថៃ

**ជ- គម្រោងស្តីពីការបណ្តុះនិងដាំកូនឈើ** បានបណ្តុះនិងដាំកូនឈើចំនួនប្រមាណ១ ០០០ដើម នៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោ សែន ឫស្សីត្រឹប

**ឈ- គម្រោងស្តីពីការគាំពារនិងអភិរក្សធនធានធម្មជាតិ** រៀបចំកំណត់ផែនទីព្រៃឈើ និងចុះត្រួតពិនិត្យព្រៃឈើជាប្រចាំនៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោ សែន ឫស្សីត្រឹប ក្នុងនោះ បានទប់ស្កាត់បទល្មើសបំផ្លាញព្រៃឈើ និងបទល្មើសបរបាញ់សត្វព្រៃ និងបានដកហូតរណារយន្តអារឈើ និងឧបករណ៍បរបាញ់សត្វមួយចំនួន

**ញ- គម្រោងស្តីពីការចិញ្ចឹមពពែនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោ សែន ឫស្សីត្រឹប** សង់របងទ្រុងពពែទំហំ៨០០ម.×៦០០ម. និងធ្វើរោងសម្រាប់ពពែ និងកម្មករ ធ្វើរោងពពែចំនួន៣ខ្នង និងនាំយកពពែចំនួន២០៤ក្បាល និងចៀមចំនួន៥១ក្បាល ចូលដល់ទីតាំងកសិដ្ឋានឧទ្យាន។ ដាំស្មៅចំនួន៥ហ.ត.

**ដ- គម្រោងចិញ្ចឹមគោយកទឹកដោះ** ក្រុមការងារបន្ត ការថែទាំង ពង្រីកការដាំស្មៅ និងត្រៀមធ្វើផ្អកស្មៅសម្រាប់ការផ្គត់ផ្គង់នៅរដូវប្រាំង ផ្តល់ជូនទឹកដោះគោតេជោសែនឫស្សីត្រឹបដល់មណ្ឌលកុមារកំព្រា តាំងពិព័ណ៌ទឹកដោះគោតេជោសែន ឫស្សីត្រឹប ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញចូលរួមក្នុងពិធីបើកពិធីបុណ្យទន្លេលើកទី៦ នៅទីរួមខេត្តបាត់ដំបងដែលមានរយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ នៅទីរួមខេត្តបាត់ដំបង ក្រោមប្រធានបទ«**ទន្លេនៃសន្តិភាព និងទន្លេនៃវិបុលភាព**»។ បន្តការស្រោចស្រពស្មៅជាបន្ទាន់ដើម្បីបំពេញតម្រូវការគោទឹកដោះ។ បង្កាត់គោនិងត្រួតពិនិត្យតាមដានសុខភាពគោប្រចាំថ្ងៃ។ តម្លើងឡជីវឧស្ម័នទំហំ៨ម៉ែត្រគូប ដែលឧបត្ថម្ភដោយអគ្គនាយកដ្ឋានផលិតកម្មសត្វ ដោយប្រើប្រាស់លាមកគោ

**ឋ- គម្រោងស្តីពី Smart Library** បានរៀបចំគេហទំព័ររបស់បណ្ណាល័យរាជបណ្ឌិត្យសភាកម្ពុជាដោយបានដាក់បញ្ចូលទិន្នន័យសៀវភៅដែលមាននៅក្នុងបណ្ណាល័យនិងបានរៀបចំតំណភ្ជាប់(Link) ជាមួយគេហទំព័របណ្ណាល័យជុំវិញពិភពលោកដូចជាJstor និងAmazon ដែលអាចអនុញ្ញាតឱ្យអ្នកស្រាវជ្រាវចូលអាននិងទាញយកសៀវភៅទាំងនោះបាន

**ឱ- គម្រោងស្តីពីសេវាសុខភាពសាធារណៈ** ស្វែងយល់អំពីទស្សនៈប្រជាជនលើសេវាសុខាភិបាលសាធារណៈកម្ពុជាលើឥរិយាបថនៃការផ្តល់សេវាលើជំនាញរបស់អ្នកផ្តល់សេវា ការប្រាស្រ័យទាក់ទងរបស់អ្នកផ្តល់សេវា និងភាពងាយស្រួលក្នុងការទទួលបានសេវាលើការពិគ្រោះនិងព្យាបាល

**ឈ- គម្រោងស្តីពីវចនានុក្រមខ្មែរបុរាណ** ទីមួយធ្វើពុម្ពអក្សរខ្មែរបុរាណ ពីស.វ.ទី៩ ដល់ស.វ.ទី១៤ សម្រាប់ប្រើប្រាស់ក្នុងកុំព្យូទ័រ ទីពីរសរសេរប្រតិចារឹកអក្សរ(transliteration) ទីបីសរសេរជាអក្សរខ្មែរទំនើបឱ្យត្រូវជាមួយអក្សរខ្មែរបុរាណ ទីបួនពន្យល់និងបកប្រែពាក្យនីមួយៗ ព្រមទាំងលើកឧទាហរណ៍បញ្ជាក់សរសេរជាអក្សរខ្មែរបុរាណ។ នៅពេលគម្រោងនេះត្រូវបានបញ្ចប់ការបកប្រែអត្ថបទសិលាចារឹកខ្មែរបុរាណមិនមានការពិបាកនោះទេ។ បច្ចុប្បន្ន បានធ្វើដល់មេពាក្យពីអក្សរ«ក» ដល់«រ» ដែលមានចំនួន១ ១៥០ទំព័រ ដែលក្នុងនោះ មានចំនួន២ ៩០០ពាក្យ។ គម្រោងស្រាវជ្រាវនេះបានចងក្រងសៀវភៅលទ្ធផលស្រាវជ្រាវចប់រួចរាល់

**ណ- គម្រោងស្តីពីការយល់ដឹង ការប្រើប្រាស់កាំរស្មីអ៊ីយ៉ុងកម្ម និងវិទ្យុសកម្ម ព្រមទាំងផលប៉ះពាល់សុខភាព** បានចុះស្រាវជ្រាវនៅតាមទីកន្លែងប្រើប្រាស់សារជាតិវិទ្យុសកម្ម និងកាំរស្មីវិទ្យុសកម្មនៅតាមមន្ទីរពេទ្យ រោងចក្រឧស្សាហកម្ម និងកំពង់ផែនៅតាមរាជធានី និងបណ្តាខេត្តមួយចំនួន ដូចជារាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកោះកុង កណ្តាល កំពត និងខេត្តស្ទឹងត្រែងជាដើម

**ត- គម្រោងស្តីពីសំនួនពាក្យ និងសំនួនវោហារសព្ទក្នុងភាសាខ្មែរបច្ចុប្បន្ន** ព្យញ្ជនៈ«យ» ចំនួន៤៣ពាក្យ ព្យញ្ជនៈ «រ» ចំនួន១៤៣ពាក្យ ព្យញ្ជនៈ «ល» ចំនួន៨៩៣ពាក្យ សរុបចំនួន២៧៣ពាក្យ ព្យញ្ជនៈ **«វ»** ចំនួន៣៧ពាក្យ ព្យញ្ជនៈ«ស» ចំនួន១២៧ពាក្យ ព្យញ្ជនៈ «ហ» ចំនួន២៦ពាក្យ ព្យញ្ជនៈ «ឡ» ចំនួន២២ពាក្យ ព្យញ្ជនៈ «អ» ចំនួ១៦០ពាក្យ ស្រៈពេញតួ «ឱ» ចំនួន១២ពាក្យ និងស្រៈពេញតួ «ឪ» ចំនួន១៣ពាក្យ។ សរុបទាំងអស់បាន ៦៦៤ពាក្យ

**ថ- គម្រោងស្តីពីកម្រងទិន្នន័យភាសាខ្មែរសម័យទំនើប** គម្រោងកម្រងទិន្នន័យភាសាខ្មែរសម្រេចលទ្ធផលសរុបចំនួន២ ៤៦៦ទំព័រ

**ទ- គម្រោងស្តីពីទំនាក់ទំនងកម្ពុជាជាមួយប្រទេសជិតខាង** សិក្សា វិភាគលើចំណុចខ្លាំង និងខ្សោយជាមួយប្រទេសជិតខាងមាន ថៃ វៀតណាម និងឡាវ ដើម្បីជាជំនួយដល់រាជរដ្ឋាភិបាល និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងការកំណត់ជំហរនយោបាយការបរទេសរបស់ប្រទេសកម្ពុជា

**ធ- គម្រោងស្តីពីការអភិវឌ្ឍពាណិជ្ជកម្មអនឡាញកម្ពុជា ចិន** ដោយវិស័យកសិកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញវិស័យសេដ្ឋកិច្ចឱ្យមានការរីកចម្រើន យើងបានសិក្សាទៅលើបច្ចេកវិទ្យា និងការធ្វើពាណិជ្ជកម្មអនឡាញ រួមចំណែកក្នុងការទាក់ទងនៃការផលិតផលកសិកម្មតាមប្រព័ន្ធអនឡាញ។ យើងសិក្សាស្រាវជ្រាវទៅលើបច្ចេកវិទ្យាពាណិជ្ជកម្ម និងទៅលើទំនាក់ទំនងនៃការធ្វើពាណិជ្ជកម្មរវាងកម្ពុជា ចិនដោយកំណត់គោលដៅសិក្សាទៅលើការវិនិយោគនៅតំបន់ឆ្នេរ តំបន់ជនបទ តំបន់ប្រជុំជន ច្រកទ្វារអន្តរជាតិ ផ្លូវអាកាស និងផ្លូវគោក និងបណ្តាខេត្តដែលមានមជ្ឈមណ្ឌលវប្បធម៌ចិន

**ន- គម្រោងស្តីពីមាគ៌ារបស់កម្ពុជាសម្រាប់ឆ្ពោះទៅកាន់ការអភិវឌ្ឍពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨** ខ្លឹមសារសៀវភៅចែកចេញជា៣ជំពូក ក្នុងនោះមានបរិយាយអំពី នយោបាយផ្ទៃក្នុង តួនាទីយុវជនក្នុងការអភិវឌ្ឍប្រទេស ដំណើរលទ្ធិប្រជាធិបតេយ្យ តួនាទីរបស់កម្ពុជាលើកិច្ចសហប្រតិបត្តិការតំបន់ និងពិភពលោក តួនាទីកម្ពុជាក្នុងអង្គការអន្តរជាតិនានា វឌ្ឍនភាពសង្គម សេដ្ឋកិច្ច កសិកម្ម ពាណិជ្ជកម្ម អភិវឌ្ឍន៍ជនបទ ការវិនិយោគពីបរទេស ការប្រើប្រាស់ថាមពលអគ្គិសនី ទេសចរណ៍ ធនាគារ និងទំនើបកម្មក្នុងរាជធានីភ្នំពេញ។ គម្រោងស្រាវជ្រាវនេះបានចងក្រងបោះពុម្ពសៀវភៅផ្សព្វផ្សាយចប់រួចរាល់

**ប- គម្រោងស្តីពីបច្ចេកវិទ្យាផលិតជីវធ្យូងអំពីចំបើង និងការអនុវត្តលើវិស័យកសិកម្មនៅកម្ពុជា** អភិវឌ្ឍបច្ចេកវិទ្យាផលិតបាយអូធាសម្រាប់អនុវត្តនៅលើដីកសិកម្ម សម្រាប់បង្កើនគុណភាពដី សមត្ថភាពផ្ទុកទឹក សារធាតុចិញ្ចឹម និងអាចបង្ការទឹកកខ្វក់ក្រោមដី ហើយព្រមទាំងបង្កើននូវផលិតផលកសិកម្ម។ ការផលិតបាយអូធាធ្វើឡើងពីចំបើងដែលសាកល្បងពិសោធន៍លើដំណាំយកស្លឹក ដំណាំពោត និងដំណាំផ្លែថាវ

**ផ- គម្រោងស្តីពីប្រវត្តិអតីតរាជធានីនិងទីក្រុងបុរាណនៃអាណាចក្រខ្មែរ** ចុះស្រាវជ្រាវកំណត់ប្រវត្តិអតីតរាជធានីនិងទីក្រុងបុរាណនៃអាណាចក្រខ្មែរ ដើម្បីចងក្រងជាឯកសារសម្រាប់បង្ហាញទីតាំងឬជាទីកន្លែងដែលក្លាយជាទីតាំង ទីកន្លែង ពេលវេលា និងការកសាងដោយក្សត្រអង្គណា។ ក្រុមការងារបានចុះសិក្សាពីអតីតរាជធានីខ្មែរមុនសម័យអង្គរ សម័យអង្គរ សម័យក្រោយអង្គរនៅតាមបណ្តាខេត្ត ដូចជាតាកែវ សៀមរាប កំពង់ចាម កំពង់ឆ្នាំង ព្រះវិហារ និងខេត្តកំពង់ធំ

**ព- គម្រោងស្តីពីការវិវត្តស្ថានការណ៍នយោបាយ សេដ្ឋកិច្ច និងបញ្ហាចម្បងៗនៅលើពិភពលោកក្នុងឆ្នាំ២០២០** យើងសិក្សាស្រាវជ្រាងចងក្រងអំពី សង្គ្រាមពាណិជ្ជកម្ម ជម្លោះសមុទ្រចិនខាងត្បូង ការរីករាលដាលជំងឺកូវីដ-១៩ បញ្ហាអាវុធនុយក្លេអ៊ែរ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ បញ្ហាសន្តិសុខស្បៀង គោលដៅអភិវឌ្ឍដោយចីរភាព បដិវត្តន៍ឧស្សាហកម្ម៤.០ ជម្លោះរ៉ុយ៉ាល់នៅបស្ទិមបូព៌ា និងការដើរចេញពីសហភាពអឺរ៉ុបរបស់អង់គ្លេស

**ភ- គម្រោងស្តីពីការកែលម្អទៅលើការប្រើភាសាខ្មែរលើស្លាកយីហោ** ស្រាវជ្រាវនិងធ្វើអង្កេតលើស្ថានភាពនៃការប្រើភាសាខ្មែរនៅលើស្លាកយីហោ។ ត្រៀមរៀបចំសិក្ខាសាលាបង្ហាញលទ្ធផលនៃការស្រាវជ្រាវលើស្ថានភាពនៃការប្រើភាសាខ្មែរនៅលើស្លាកយីហោ។ រៀបចំសុសវែរដែលអាចប្រើនៅក្នុងទូរសព្ទប្រព័ន្ធIOS និងប្រព័ន្ធAndroid ដើម្បីថតរូបភាពស្លាក។ រៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការប្រើភាសាខ្មែរនៅលើរូបសញ្ញា

**ម- គម្រោងវចនានុក្រមខ្មែរ** រៀបចំសិក្ខាសាលាពិគ្រោះយោបល់ដើម្បីពិនិត្យកែលម្អគោលការណ៍ក្នុងការរៀបចំធ្វើវចនានុក្រមទាក់ទងនឹង អក្សរកាត់(ន. គុ. ...) និងការប្រើសញ្ញាភ្ជាប់ល្បះ(punctuation)។ បណ្តុះបណ្តាលបន្តទាក់ទងនឹងការពន្យល់ពាក្យ ជ្រើសរើសមេពាក្យនិងកូនពាក្យដើម្បីកំណត់ចំនួនពាក្យនៅក្នុងវចនានុក្រមថ្មី កំណត់សូរអានរបស់ពាក្យ កំណត់និយមន័យពាក្យតាមគោលការណ៍វចនវិទ្យានិងន័យវិទ្យានិងផ្តល់ជាឧទាហរណ៍ រំលេចបរិបទនៃការប្រើប្រាស់ និងដោះស្រាយបញ្ហាទាក់ទងនឹងកម្មវិធីទាញយកទិន្នន័យ(Database) មករៀបចំជាអត្ថបទឬសៀវភៅសម្រាប់បោះពុម្ព

**យ- គម្រោងស្តីពីការរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19)** សិក្សាស្រាវជ្រាវអំពីជំងឺកូវីដ-១៩ នៅលើពិភពលោកដែលបានធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋទូទាំងពិភពលោក។ ក្រុមការងារបានសិក្សាស្រាវជ្រាវវិភាគអំពី ដំណើរការនៃការរីករាលដាលជំងឺតាមលក្ខណៈវេជ្ជសាស្ត្រ យន្តការនៃការទប់ស្កាត់ វិធានការនៃការការពារនិងផលប៉ះពាល់នានាលើវិស័យសេដ្ឋកិច្ច នយោបាយ វប្បធម៌ ពាណិជ្ជកម្ម និងតម្លៃនៃសីលធម៌សង្គម

**រ- ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)** បានអនុម័តមេពាក្យដោយមានសេចក្តីពន្យល់សរុបទាំងអស់ចំនួន១ ៧៨៤ពាក្យ

**ល- រាជបណ្ឌិត្យសភាកម្ពុជា**បានរៀបចំកិច្ចពិភាក្សាតុមូលវេទិកាវិទ្យាសាស្ត្រនិងសន្និសីទកាសែតសរុបចំនួន១១លើក រួមមាន (១) «**ការប្រឈមមុខដាក់គ្នាខាងភូមិសាស្ត្រនយោបាយរវាងចិននិងសហរដ្ឋអាម៉េរិក**»

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (២) «**តើកម្ពុជាត្រៀមខ្លួនអ្វីខ្លះ ដើម្បីស្តារសេដ្ឋកិច្ចក្រោយកូវីដ១៩ បញ្ចប់?**» នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ (៣) «**តើអ្វីជាសារៈប្រយោជន៍នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន?**» នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ (៤) «**តើកម្ពុជាត្រៀមខ្លួនយ៉ាងដូចម្តេចសម្រាប់ថ្ងៃនេះ និងថ្ងៃស្អែក?**» នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ (៥) «**សារៈសំខាន់នៃការជ្រើសរើសជំនាញសិក្សានៅឧត្តមសិក្សានិងក្រោយឧត្តមសិក្សា**» នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ (៦) «**សារៈសំខាន់នៃការសិក្សានៅក្រោយឧត្តមសិក្សា**» នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ (៧) «**ការបណ្តុះបណ្តាលជំនាញគរុកោសល្យថ្នាក់ភាសាចិន**» នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ (៨) «**ការពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការប្រើភាសាខ្មែរនៅលើរូបសញ្ញា និងការផ្សព្វផ្សាយសុសវែរសម្រាប់កំណែកំហុសក្នុងសំណេរលើស្លាកនិងប្រព័ន្ធផ្សព្វផ្សាយ**» នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ (៩) «**ទំនាក់ទំនងកម្ពុជា សហរដ្ឋអាម៉េរិក ការពិនិត្យមើលអតីតកាល រយៈពេល៧០ឆ្នាំកន្លងមក ក្តីរំពឹងទុកសម្រាប់៧០ឆ្នាំបន្ទាប់ និងលើសពីនេះ**» នៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ (១០) «វឌ្ឍនភាពរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា» នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ និង(១១) នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅអនុវត្តការងារប្រចាំឆ្នាំ២០២១។

## ៣- យន្តការដោះស្រាយបណ្តឹង

### ៣.១- ក្រសួងមហាផ្ទៃ

គិតចាប់ពីឆ្នាំ២០១៧ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ ក្រសួងមហាផ្ទៃបានទទួលពាក្យបណ្តឹង និងបានពិនិត្យដោះស្រាយ រួមមាន៖

ការងារទទួលពាក្យបណ្តឹងនិងរបាយការណ៍បំភ្លឺបានទទួលសំណុំរឿងសរុប៣ ០០៧សំណុំរឿង ក្នុងនោះផ្នែករដ្ឋបាល១ ៨៣៧សំណុំរឿង និងផ្នែកនគរបាល១ ១៧០សំណុំរឿង ព្រមទាំងទទួលរបាយការណ៍បំភ្លឺពីអង្គភាពពាក់ព័ន្ធសរុប៥៩៩របាយការណ៍ ក្នុងនោះ ផ្នែករដ្ឋបាល២៨៩របាយការណ៍ និងផ្នែកនគរបាល១១០របាយការណ៍។

ការងារអធិការកិច្ច ចុះធ្វើអធិការកិច្ចសរុប៥០៣សំណុំរឿង ក្នុងនោះ អធិការកិច្ចតាមផែនការសរុប២៤១សំណុំរឿង និងអធិការកិច្ចតាមវត្ថុបំណងសរុបចំនួន២៦២សំណុំរឿង។

ការងារដោះស្រាយពាក្យបណ្តឹង បានដោះស្រាយសំណុំរឿងសរុប**២ ៤១៤សំណុំរឿង** ក្នុងនោះ ដោះស្រាយពាក្យបណ្តឹងបញ្ចប់សរុប៤៧៣សំណុំរឿង បង្វែរពាក្យបណ្តឹងទៅសមត្ថកិច្ចពាក់ព័ន្ធនិងសាមីដើមបណ្តឹងបានសរុប១ ៥៣៥សំណុំរឿង និងរក្សាទុកតាមដានបន្តសរុប៤០៦សំណុំរឿង។ អង្កេតស្រាវជ្រាវសរុប២១៩សំណុំរឿង។

ការងារចុះតាមដានការអនុវត្តសេចក្តីជូនដំណឹង(សជណ) របស់ក្រសួងមហាផ្ទៃ បានចុះតាមដាន និងរៀបចំរបាយការណ៍ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងសរុប៨០គោលដៅ ស្មើនឹង៥៧១សជណ។

លទ្ធផលនៃការពិនិត្យរបាយការណ៍បំភ្លឺ បានពិនិត្យសិក្សា និងសង្ខេបរបាយការណ៍បំភ្លឺសរុប៤៤៣របាយការណ៍។ ចុះអធិការកិច្ចពាក់ព័ន្ធនឹងរបាយការណ៍បំភ្លឺមានផ្នែកនគរបាលសរុប៩គោលដៅ។

## ៣.២- ក្រសួងយុត្តិធម៌

### ក- ការដោះស្រាយបណ្តឹងរបស់ក្រសួងយុត្តិធម៌ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១

- ស្ថិតិពាក្យបណ្តឹងចូលមកអគ្គាធិការដ្ឋានកិច្ចការតុលាការ

| បរិយាយ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៧ | ៤៧ | ៩៨ | ៥៤ | ៩១ |
| ២០១៨ | ៩១ | ៧៩ | ៣៣ | ១៣៧ |
| ២០១៩ | ១៣៧ | ៨១ | ៣២ | ១៨៦ |
| ២០២០ | ១៨៦ | ២១៤ | ២០ | ៣៨០ |
| ២០២១ | ៣៨០ | ១៥០ | ២៥ | ៥០៥ |

- ស្ថិតិពាក្យបណ្តឹងចូលមកអគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ

| បរិយាយ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៧ | ១៥៥ | ៩៦ | ១៥៨ | ៩៣ |
| ២០១៨ | ៩៣ | ៨៤ | ១២១ | ៥៦ |
| ២០១៩ | ៥៦ | ៥៤ | ៨៨ | ២២ |
| ២០២០ | ២២ | ១៩១ | ១៨៧ | ២៦ |
| ២០១៧ | ២៦ | ៧៨ | ៧០ | ៣៤ |

- ស្ថិតិពាក្យបណ្តឹងចូលមកអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

| បរិយាយ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៧ | ៨៤ | ១៨៨ | ២២៣ | ៤៩ |
| ២០១៨ | ៤៩ | ១៧៤ | ១៨១ | ៤២ |
| ២០១៩ | ៤២ | ២២៤ | ២២០ | ៤៦ |
| ២០២០ | ៤៦ | ២៧៧ | ២០២ | ១២១ |
| ២០២១ | ១២១ | ៨៨ | ៤៩ | ១៦០ |

### ខ- ការដោះស្រាយបណ្តឹងរបស់សាលាដំបូងរាជធានី ខេត្តពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១

- ស្ថិតិសំណុំរឿងព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី ខេត្ត

| បរិយាយ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៧ | ៩ ៩២៦ | ១៦ ២៦២ | ៩ ៧៩៦ | ១៦ ៣៩២ |
| ២០១៨ | ១៦ ៣៩២ | ១០ ៤៥៦ | ១១ ០២៣ | ១៥ ៨២៥ |
| ២០១៩ | ១៥ ៨២៥ | ១៨ ០២០ | ១៨ ៥១៤ | ១៥ ៣៣១ |
| ២០២០ | ១៥ ៣៣១ | ៣១ ១១៤ | ៣៦ ៩៦២ | ៩ ៤៨៣ |
| ២០២១ | ៩ ៤៨៣ | ១១ ៥៦៤ | ១១ ០៥៦ | ៩ ៩៩១ |

- ស្ថិតិសំណុំរឿងរដ្ឋប្បវេណីរបស់សាលាដំបូងរាជធានី ខេត្ត

| បរិយាយ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៧ | ៨ ០៥៥ | ១៥ ៤៥១ | ១៣ ៧៨១ | ៩ ៧២៥ |
| ២០១៨ | ៩ ៧២៥ | ១៨ ៣១៩ | ១៧ ១២៦ | ១០ ៩១៨ |
| ២០១៩ | ១០ ៩១៨ | ១៤ ៥៥៤ | ១២ ៩៦៥ | ១២ ៥០៧ |
| ២០២០ | ១២ ៥០៧ | ២៤ ៧៤២ | ២៤ ៨៧៣ | ១២ ៣៧៦ |
| ២០២១ | ១២ ៣៧៦ | ១៤ ៤៥១ | ១៥ ០៩៧ | ១១ ៧៣០ |

## គ- ការងារបន្ធូរបន្ថយទោសនឹងលើកលែងទោស

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ចូលឆ្នាំថ្មីប្រពៃណីជាតិ | ៧២ | ៥០ | ៩៤ | ១៥៧ | ៣៦២ |
| ពិសាខបូជា | ៣៥ | ៣៤ | ៧៧ | ៨៧ | ០០ |
| អុំទូក អកអំបុក សំពះព្រះខែ | ៥០ | ៨៧ | ៩០ | ៦៨៧ | ០០ |
| បុណ្យឯករាជជាតិ | ០០ | ១១០ | ០០ | ០០ | ០០ |
| **សរុប** | **១៥៧** | **២៨១** | **២៦១** | **៩៣១** | **៣៦២** |

## ឃ- ការងារផ្សេងៗទៀត

ក្រោមការដឹកនាំផ្ទាល់របស់ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីឆ្នាំ២០១៩ រហូតដល់បច្ចុប្បន្នក្រសួងក៏បានខិតខំយកចិត្តទុកដាក់ជំរុញ និងអភិវឌ្ឍលើវិស័យយុត្តិធម៌ ទទួលបាននូវសមិទ្ធផលផ្សេងៗទៀតមួយចំនួនដូចខាងក្រោម៖

### ១- ការបើកយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត

យុទ្ធនាការនេះមានរយៈពេល១ឆ្នាំ ១ខែ (គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១) តាមរយៈយុទ្ធនាការនេះ សាលាដំបូងរាជធានី ខេត្តទូទាំងប្រទេសបានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះទាំងដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះមានចំនួនសរុបជាង៣៧ ៩០០រឿង ស្មើនឹង៩១%នៃសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះសរុបជាង៣៩ ៥០០រឿង( សំណុំរឿងដែលត្រូវបានជំនុំជម្រះរួចមានចំនួនជាង១២ ៦០០រឿង ស្មើនឹង៩៧%នៃចំនួនសំណុំរឿងសរុបជាង១៣ ០០០រឿងក្នុងដំណាក់កាលជំនុំជម្រះ)។ បន្ថែមពីនេះ សាលាដំបូងរាជធានី ខេត្ត ទូទាំងប្រទេសក៏បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលចូលថ្មីបានចំនួនជាង៦២ ៨០០រឿង ស្មើនឹងជាង៧៨% នៃចំនួនសំណុំរឿងចូលថ្មីសរុបជាង ៨០ ៤០០រឿង។

### ២- ការបង្កើតសាលាឧទ្ធរណ៍តំបន់ និងសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកែប

- ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ
- ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង
- ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ
- ការដាក់ឱ្យដំណើរការសាលាដំបូងនិងអយ្យការអមសាលាដំបូងខេត្តកែប។

### ៣.៣- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន៥១៦បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១៥៥បណ្តឹង និងមន្ទីររាជធានី ខេត្តចំនួន៣៦១បណ្តឹង ក្នុងនោះឆ្នាំ២០១៧ ចំនួន៧២បណ្តឹង ឆ្នាំ២០១៨ ចំនួន៩២បណ្តឹង ឆ្នាំ២០១៩ ចំនួន១៣៥បណ្តឹង ឆ្នាំ២០២០ ចំនួន១២៩បណ្តឹង ឆ្នាំ២០២១ ចំនួន៨៨បណ្តឹង)៖

- ពាក្យបណ្តឹងកំពុងពិនិត្យចំនួន៣បណ្តឹង(ឆ្នាំ២០២១ ចំនួន៣បណ្តឹង)
- ពាក្យបណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន៩បណ្តឹង(ឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន៨បណ្តឹង)
- ពាក្យបណ្តឹងដែលជាសមត្ថកិច្ចមន្ទីររាជធានី ខេត្តចំនួន៣៥២បណ្តឹង(ឆ្នាំ២០១៧ ចំនួន៤៥បណ្តឹង ឆ្នាំ២០១៨ ចំនួន៥៨បណ្តឹង ឆ្នាំ២០១៩ ចំនួន៨៩បណ្តឹង ឆ្នាំ២០២០ ចំនួន៩៥បណ្តឹង ឆ្នាំ២០២១ ចំនួន៦៥បណ្តឹង)
- ពាក្យបណ្តឹងកំពុងត្រៀមបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន២បណ្តឹង(ឆ្នាំ២០២១ចំនួន២បណ្តឹង)
- ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន៦៨បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៦៣បណ្តឹង និងមន្ទីររាជធានី ខេត្តចំនួន៥បណ្តឹង ក្នុងនោះ ឆ្នាំ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០១៧ ចំនួន១២បណ្តឹង ឆ្នាំ២០១៨ ចំនួន១៦បណ្តឹង ឆ្នាំ២០១៩ ចំនួន១៩បណ្តឹង ឆ្នាំ២០២០ ចំនួន១៥បណ្តឹង ឆ្នាំ២០២១ ចំនួន៥បណ្តឹង)
- ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការចំនួន៨បណ្តឹង (ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៨ ចំនួន២បណ្តឹង ឆ្នាំ២០១៩ ចំនួន១បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង)
- ពាក្យបណ្តឹងដែលមន្ទីររាជធានី ខេត្តសម្រេចតម្កល់ទុកមិនចាត់ការចំនួន៥បណ្តឹង (ឆ្នាំ២០១៩ ចំនួន២បណ្តឹង ឆ្នាំ២០២០ ចំនួន៣បណ្តឹង)។
- ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំដកវិញចំនួន២បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន១បណ្តឹង ក្នុងនោះឆ្នាំ២០១៨ ចំនួន១បណ្តឹង ឆ្នាំ២០២០ ចំនួន១បណ្តឹង)
- ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងបានបោះបង់ចោលចំនួន១បណ្តឹង(មន្ទីររាជធានី ខេត្តឆ្នាំ២០២០ ចំនួន១បណ្តឹង)
- ពាក្យបណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួងចំនួន៣បណ្តឹង(ឆ្នាំ២០២០ ចំនួន២បណ្តឹង ឆ្នាំ២០២១ ចំនួន១បណ្តឹង)
- ពាក្យបណ្តឹងដែលបានចុះជំរុញខ្លឹមសារលិខិតរបស់រាជរដ្ឋាភិបាលចំនួន១បណ្តឹង (ឆ្នាំ២០១៨ ចំនួន១បណ្តឹង)
- ពាក្យបណ្តឹងបានធ្វើរបាយការណ៍គោរពជូនឯកឧត្តមអភិបាលខេត្តកំពង់ស្ពឺ ពិនិត្យសម្រេចចំនួន៨បណ្តឹង(មន្ទីររាជធានី ខេត្តចំនួន៨បណ្តឹង ក្នុងងនោះ ឆ្នាំ២០១៩ ចំនួន២បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង ឆ្នាំ២០២១ ចំនួន២បណ្តឹង)
- ពាក្យបណ្តឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន២បណ្តឹង(ឆ្នាំ២០២១ ចំនួន២បណ្តឹង)
- ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន១៧បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១១បណ្តឹង និងមន្ទីររាជធានី ខេត្តចំនួន៦បណ្តឹង ក្នុងនោះ ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៨ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន៨បណ្តឹង ឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន៦បណ្តឹង)
- ពាក្យបណ្តឹងបានទទួលការឆ្លើយតបចំនួន២៤បណ្តឹង(ឆ្នាំ២០១៤ ចំនួន១បណ្តឹង ឆ្នាំ២០១៥ ចំនួន១បណ្តឹង ឆ្នាំ២០១៦ ចំនួន២បណ្តឹង ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៨ ចំនួន៦បណ្តឹង ឆ្នាំ២០១៩ ចំនួន១២បណ្តឹង ឆ្នាំ២០២០ ចំនួន១បណ្តឹង)

- ពាក្យបណ្ដឹងដែលម្ចាស់បណ្ដឹងសុំជំរុញការដោះស្រាយចំនួន១៧បណ្ដឹង( ឆ្នាំ២០១៦ ចំនួន៥បណ្ដឹង ឆ្នាំ២០១៧ ចំនួន៣បណ្ដឹង ឆ្នាំ២០១៨ ចំនួន១បណ្ដឹង ឆ្នាំ២០១៩ ចំនួន៥បណ្ដឹង ឆ្នាំ២០២០ ចំនួន៣បណ្ដឹង)

- ពាក្យបណ្ដឹងក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយចំនួន១៨បណ្ដឹង( ឆ្នាំ២០១៦ ចំនួន៥បណ្ដឹង ឆ្នាំ២០១៧ ចំនួន៣បណ្ដឹង ឆ្នាំ២០១៨ ចំនួន១បណ្ដឹង ឆ្នាំ២០១៩ ចំនួន៥បណ្ដឹង ឆ្នាំ២០២០ ចំនួន៤បណ្ដឹង)

- ពាក្យបណ្ដឹងដែលបានចុះជំរុញការដោះស្រាយចំនួន១បណ្ដឹង( ឆ្នាំ២០១៨ ចំនួន១បណ្ដឹង )

- ពាក្យបណ្ដឹងបានបញ្ចប់ការដោះស្រាយចំនួន១៧៦បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៥៣ បណ្ដឹង និងមន្ទីររាជធានី ខេត្តចំនួន១២៣បណ្ដឹង ក្នុងនោះឆ្នាំ២០១៤ ចំនួន៨បណ្ដឹង ឆ្នាំ២០១៦ ចំនួន៧បណ្ដឹង ឆ្នាំ២០១៧ ចំនួន២៤បណ្ដឹង ឆ្នាំ២០១៨ ចំនួន៣៥បណ្ដឹង ឆ្នាំ២០១៩ ចំនួន៣៣បណ្ដឹង ឆ្នាំ២០២០ ចំនួន៤៧ បណ្ដឹង ឆ្នាំ២០២១ ចំនួន២២បណ្ដឹង )។

## ៣.៤- ក្រសួងធម្មការ និងសាសនា

- ទទួលពាក្យបណ្ដឹង«**អធិករណ៍**» ក្នុងវិស័យសាសនា៦៧ករណីៈ
  - សម្របសម្រួលដោះស្រាយបញ្ចប់អធិករណ៍៤២ករណី
  - ចាត់បញ្ជូន-បង្វែរអធិករណ៍ទៅអង្គភាព ស្ថាប័នមានសមត្ថកិច្ច១៨ករណី
  - ម្ចាស់ដើមបណ្ដឹងបានសុំដកពាក្យបណ្ដឹង២ករណី
  - មិនចាត់ការពាក្យបណ្ដឹង«**អធិករណ៍**» ១ករណី
  - នៅសល់ពាក្យបណ្ដឹងនៃអធិករណ៍៤ករណី។
- បានទទួលរបាយការណ៍ពីមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ដែលបានធ្វើការសម្របសម្រួលអធិករណ៍រួចរាល់២៥ករណី
- ធ្វើរបាយការណ៍អធិករណ៍និងចម្លងអធិករណ៍ជូនក្រសួងធម្មការ និងសាសនា២៥ករណី
- ចូលបំភ្លឺករណីអធិករណ៍ជូនស្ថាប័នអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងខេត្តកំពង់ស្ពឺ៣ដង
- ចុះសម្រង់ទិន្នន័យករណីទំនាស់ដីធ្លីក្នុងវិស័យសាសនាបាន៧ខេត្ត និងជំរុញពន្លឿនសម្រង់ទិន្នន័យបាន៤ខេត្ត។

## ៣.៥- ការងារដោះស្រាយវិវាទដីធ្លី

១- ការដោះស្រាយរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

| ឆ្នាំ | ករណីទទួលបាន | លទ្ធផល | | |
|---|---|---|---|---|
| | | បង្វែរ | ដោះស្រាយរួច | កំពុងដោះស្រាយ |
| ២០១៧ | - | - | - | - |
| ២០១៨ | ១ ៨១៥ | - | ១ ៧៦៤ | - |
| ២០១៩ | ៨៣ | ២ | ២ | - |
| ២០២០ | ៤៥ | ៣ | ២៨ | - |
| ៩ខែ ឆ្នាំ២០២១ | ៥ | - | ៧ | ១៤២ |
| **សរុប** | **១ ៩៤៨** | **៥** | **១ ៨០១** | **១៤២** |

## ២- ករណីវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី

| ឆ្នាំ | ករណីទទួលបាន | បានដោះស្រាយបញ្ចប់នីតិវិធី | កំពុងដោះស្រាយ | ចំនួនគ្រួសារដោះស្រាយបញ្ចប់ | ចំនួនផ្ទៃដីដោះស្រាយបញ្ចប់ (ហ.ត.) |
|---|---|---|---|---|---|
| ២០១៧ | ២៤៨ | ១៦៣ | - | ៤៤២ | ៥២,២៣ |
| ២០១៨ | ៥៤៤ | ៥១៥ | - | ១៥១២ | ២៤៣,៩៦ |
| ២០១៩ | ៣៤៧ | ៣៥៩ | - | ១១៧៦ | ១៦៤,២៦ |
| ២០២០ | ២៦១ | ២៨០ | - | ៨៧២ | ៣៩,៣៧ |
| ៩ខែ ឆ្នាំ ២០២១ | ៩៥ | ៤២ | ៨០៥ | ៣៥ | ៩,០១ |
| **សរុប** | **១ ៤៩៥** | **១ ៣៥៩** | **៨០៥** | **៤ ០៣៧** | **៥០៨,៨៣** |

## ៣- ករណីវិវាទដីធ្លីដែលប្រជាពលរដ្ឋប្តឹងចូលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ឆ្នាំ | ករណីទទួលបាន | ដោះស្រាយបញ្ចប់ | បង្វែរទៅសមត្ថកិច្ចពាក់ព័ន្ធ និងឆ្លើយទៅសាមីសំណើ | កំពុងដោះស្រាយ |
|---|---|---|---|---|
| ២០១៧ | ៥៣១ | ៣១ | ៩៨ | - |
| ២០១៨ | ៥៧១ | ៥២ | ៧៣ | - |
| ២០១៩ | ៨៧៩ | ៨៤ | ២៥ | - |
| ២០២០ | ៥៦៦ | ៥១ | ១៦ | - |
| ៩ខែ ឆ្នាំ២០២១ | ១១៦ | ២០ | ១២ | ២ ២០១ |
| **សរុប** | **២ ៦៦៣** | **២៣៨** | **២២៤** | **២ ២០១** |

គិតពីចាប់ផ្តើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ ក្រសួងបានទទួលពាក្យបណ្តឹងសរុបចំនួន ១៣ ៧៨២ករណី បានដោះស្រាយបញ្ចប់នីតិវិធីសរុប១០ ៦៣៤ករណី និងកំពុងដោះស្រាយ៣ ១៤៨ករណី។

## ៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

### ៤.១- លទ្ធផលការងាររបស់កងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិ

#### ក- ការងារកែទម្រង់កងយោធពលខេមរភូមិន្ទ

ក្រសួងការពារជាតិបានបន្តយកចិត្តទុកដាក់អនុវត្តការងារកែទម្រង់កងយោធពលខេមរភូមិន្ទ ស្របតាមផែនការនិងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីឆ្លើយតបវិធានការយុទ្ធសាស្ត្រនានាដែលបានដាក់ចេញ ដូចជាបង្កើតក្រុមការងារអ្នកច្បាប់ថ្នាក់ក្រសួង អគ្គបញ្ជាការ ប្រភេទទ័ពនិងថ្នាក់យោធភូមិភាគ បង្កើតកងវរសេនាតូចកាំភ្លើងធំ កងវរសេនាតូចកាំជ្រួចការពារអាកាសរយៈកម្ពស់ទាប កងរុករកនិងសង្គ្រោះគ្រោះមហន្តរាយ ការិយាល័យប្រកទំនាក់ទំនងព្រំដែនកម្ពុជា ឡាវ ការិយាល័យជំនាញនានា សាលាហ្វឹកហ្វឺន បណ្ណាល័យ ផ្នែកទំនាក់ទំនងអន្តរជាតិ និងកងឯកភាពចាំបាច់ផ្សេងទៀតមួយចំនួន។ ធ្វើការកែសម្រួលនិងប្តូរឈ្មោះក្បាលអង្គភាព សាលាហ្វឹកហ្វឺន ព្រមទាំងកែសម្រួលផ្ទៃក្របខ័ណ្ឌអង្គភាពមួយចំនួននិងក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជា ថៃ២៤ច្រក មកចំណុះកងទ័ពជើងគោក។ ក្រៅពីនេះ បានធ្វើការកែសម្រួលរចនាសម្ព័ន្ធនិងក្របខ័ណ្ឌចាត់តាំងចំនួនទ័ពនិងកែសម្រួលទីតាំងចំណុចឈរជើងរបស់បណ្តាកងឯកភាពមួយចំនួន។

ចំពោះការងារគ្រប់គ្រងស្ថិតិកងទ័ព ដោយមានការអនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលក្រសួងការពារជាតិបានធ្វើការជ្រើសទ័ពថ្មីបំពេញក្របខ័ណ្ឌជូនបណ្តាកងឯកភាពមួយចំនួននិងជ្រើសរើសនិស្សិត សិស្សមកទទួល

ការបណ្ដុះបណ្ដាលនិងហ្វឹកហ្វឺនតាមរយៈការប្រឡងប្រជែងតាមផែនការឆ្នាំនីមួយៗ ដើម្បីជំនួសឱ្យយោធិន ចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារនិងយោធិនប្រភេទ២(ពលី មរណៈនិងពិការ) និងយោធិនដែលអវត្តមាន គ្មានមូលហេតុសរុបចំនួន១០ ១២៥នាក់។

ធ្វើការតាមដាននិងសម្រង់ព័ត៌មានប្រចាំថ្ងៃដែលប្រជាពលរដ្ឋសំណូមពរចូលក្នុងទំព័រហ្វេសប៊ុក (Facebook Page) របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សរុបចំនួន៦៨១សំណូមពរ និងបានយកចិត្តទុកដាក់ស្រាវជ្រាវឱ្យបានដាក់លាក់ ដើម្បីឆ្លើយតបបំភ្លឺនិងដោះស្រាយឱ្យបានទាន់ពេលវេលា។

ប្រាក់បៀវត្សរបស់យោធិន រាជរដ្ឋាភិបាលបានបង្កើនជាលំដាប់តាមការកែប្រែតម្លៃឯកតានៃសន្ទស្សន៍ បៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារ ក្នុងនោះបានអាទិភាពបង្កើនកម្រិតសន្ទស្សន៍ថ្នាក់ពីពលទាហានដល់ ថ្នាក់វរសេនីយ៍ នាំឱ្យប្រាក់បៀវត្សប្រចាំខែរបស់ពលទាហានម្នាក់ៗគិតជាមធ្យមនៅឆ្នាំ២០១៧ មាន៨៥៧ ៥០០រៀល រហូតមកដល់ឆ្នាំ២០២០ បានកើនដល់១ ១៥៨ ៥០០រៀលគឺមានកំណើន៣៥% បើប្រៀបធៀបនឹងឆ្នាំ២០១៧ ដោយឡែកឆ្នាំ២០២១ បានរក្សាកម្រិតបៀវត្សនៅដដែលដោយសារវិបត្តិជំងឺកូវីដ-១៩។ ក្រៅពីនេះ ក៏មានការ បង្កើនប្រាក់ហូបជូនយោធិនម្នាក់ៗក្នុងមួយថ្ងៃ៤ ២០០រៀល ការផ្ដល់ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី បុណ្យភ្ជុំបិណ្ឌ ជូនយោធិនគ្រប់រូប និងបានយកចិត្តទុកដាក់បន្តផ្ដល់ប្រាក់ហូបបន្ថែមសមរភូមិមុខ ថែទាំបច្ចេកទេសគ្រឿងបំពាក់ ប្រេងឥន្ធនៈ ឯកសណ្ឋានកងទ័ពនិងថវិកាជំនាញមួយចំនួនផងដែរ។

### ខ-ការងារនីតិកម្ម

១- ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងអង្គការOPCW ស្ដីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អង្គការOPCW(ចូលជាធរមានថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩)។

២- សេចក្ដីព្រាងច្បាប់ ស្ដីពីការរៀបចំតុលាការយោធា(កំពុងបន្តសិក្សានិងពិនិត្យកែសម្រួល)។

៣- សេចក្ដីព្រាងក្រមស្ដីពីបទល្មើសយោធានិងនីតិវិធីបទល្មើសយោធា(ត្រៀមបន្តចូលរួមប្រជុំពិភាក្សា កែសម្រួលជាមួយក្រសួងយុត្តិធម៌)។

### គ-ការកសាងបណ្ដាញផ្លូវគមនាគមន៍ សំណង់អគារ

ក្រៅពីការបំពេញភារកិច្ចស្នូលខាងលើ កងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិក៏មានកាតព្វ កិច្ចនៅក្នុងការចូលរួមចំណែកកសាងនិងជួសជុលបណ្ដាញផ្លូវគមនាគមន៍ ស្ពាន លូ ប្រព័ន្ធធារាសាស្ត្រ ក៏ដូចជា ការកសាងនិងជួសជុលបណ្ដាញផ្លូវ ទីលានបាញ់គ្រាប់ពិត សំណង់អគារ ជំរំជម្រក បន្ទាយ ផ្ទះសម្បែងកងទ័ពនិង គ្រួសារ និងសំណង់ផ្សេងៗ នៅតាមបណ្ដាអង្គភាពទូទាំងកងយោធពលខេមរភូមិន្ទ ព្រមទាំងការសាងសង់វិមាន ឈ្នះ ឈ្នះ នៅរាជធានីភ្នំពេញ ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ នៅខេត្តកោះកុង និងសំណង់ផ្សេងៗនៅ តំបន់កោះថ្ម ឃុំទន្លូង ខេត្តត្បូងឃ្មុំ ផងដែរ។

លទ្ធផលសំខាន់ៗដែលសម្រេចបាន មានដូចជា៖

- កសាងនិងជួសជុលបណ្ដាញផ្លូវគមនាគមន៍ រួមមានផ្លូវបេតុង១៣១ខ្សែ ប្រវែង៩១ ១៣៥ម. ផ្លូវកៅស៊ូ១៦២ខ្សែ ប្រវែង៧២៨ ៣០៥ម. ផ្លូវគ្រួសក្រហម៣៣២ខ្សែ ប្រវែង១ ៧២៣ ៧៥៥ម. ស្ពានបេតុង៦៧ កន្លែង ប្រវែង៣ ៩០៣ម. ស្ពានដែក១កន្លែង ប្រវែង៩៦ម. លូអ៊ុយ៩កន្លែង ប្រវែង៨ ៩៧០ម. ដាឡូ២៤០កន្លែង និងលូមូលគ្រប់ប្រភេទ១ ៩៩០កន្លែង

- កសាងផ្លូវយោធាបានប្រវែង១៣៨ ៥០០ម. ស្ពានយោធាបាន២២៨កន្លែង ប្រវែង១៩០១ម.

- ទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមរយៈអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ចូលរួមកសាងនិងបោះបង្គោលខណ្ឌសីមាព្រំដែនបានចំនួន៩១៧បង្គោល

- កសាងសំណង់អំណោយដ៏ថ្លៃថ្លារបស់**សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** រួមមានផ្សារសាមគ្គីស្ទឹងត្រែងទំហំ៩ ០៦៥,១០ម.២ និងតូបចំនួន១ ៣៥៨តូប ទំហំ៥ ២២០ម.២។ តូបផ្សារអូរឫស្សី ខេត្តក្រចេះចំនួន៥២៣តូប ទំហំ៣ ៩៣៣ម.២។

### ឃ- ការងារអតីតយុទ្ធជន

ការអនុវត្តផែនការបញ្ចេញយោធិនចូលនិវត្តន៍ ចេញពីជួរនិងយោធិនប្រភេទ២ ក្រសួងបានបើកផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយមួយលើកដំបូងជូនបងប្អូន និងផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា សរុបចំនួន១២.៣៩៣នាក់ ដូចមានលម្អិតនៅក្នុងតារាងខាងក្រោម៖

| ឆ្នាំ | សោធននិវត្តន៍ | ចេញពីជួរ | ពលី-មរណៈ | ពិការ | សរុប |
|---|---|---|---|---|---|
| ២០១៧ | ២៩៨នាក់ | | ៤៦២នាក់ | ៨៧២នាក់ | **១ ៦៣២នាក់** |
| ២០១៨ | ៥៤៩នាក់ | | ៤៧៦នាក់ | ៣៧០នាក់ | **១ ៣៩៥នាក់** |
| ២០១៩ | ៣ ៤៩៨នាក់ | ០៧នាក់ | ២៧៨នាក់ | ១២៥នាក់ | **៣ ៩០៨នាក់** |
| ២០២០ | ២ ៣៧៣នាក់ | ១២នាក់ | ៣៣២នាក់ | ៦៥៨នាក់ | **៣ ៣៧៥នាក់** |
| ២០២១ | ១ ២៨៦នាក់ | | ៤៩៨នាក់ | ២៩៩នាក់ | **២ ០៨៣នាក់** |
| សរុប | ៨ ០០៤នាក់ | ១៩នាក់ | ២ ០៤៦នាក់ | ២ ៣២៤នាក់ | ១២ ៣៩៣នាក់ |

សមាគមអតីតយុទ្ធជនកម្ពុជា បានទទួលអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជានិង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នូវការសាងសង់ផ្ទះជូនសមាជិកអតីតយុទ្ធជនកម្ពុជាដែលមានជីវភាពក្រីក្រលំបាក មានជម្រកស្នាក់នៅមិនសមរម្យនិងគ្មានដីគ្មានផ្ទះរស់នៅលើដីសម្បទានសរុបចំនួន២ ៨៩៦ខ្នង។ បច្ចុប្បន្នសមាជិកអតីតយុទ្ធជនកម្ពុជា ដែលកំពុងទទួលរបបឧបត្ថម្ភគោលនយោបាយរៀងរាល់ខែពីរដ្ឋមានចំនួន៨០ ៥២១នាក់ (និវត្តជន៣០ ៧៦៧នាក់ ជនបាត់បង់សមត្ថភាពការងារ១ ៤៤៦នាក់ ជនពិការ២៦ ៨៤១នាក់ គ្រួសារពលី-មរណៈ២១ ៤១៥នាក់និងមន្ត្រីរាជការ៥២នាក់) ដែលមានអ្នកនៅក្នុងបន្ទុក១៤៤ ៥០០នាក់។ ធ្វើការស្រង់ស្ថិតិសមាជិកសមាគមអតីតយុទ្ធជនដែលមានដីគ្មានផ្ទះ គ្មានដីគ្មានផ្ទះ មានផ្ទះមិនសមរម្យនិងរស់នៅលើដីសាធារណៈ សរុបមានចំនួន៦ ៦៩០នាក់។ ទន្ទឹមនេះ បានបើកប្រាក់បេឡាមរណៈសង្គ្រោះជូនគ្រួសារសពសមាជិកសមាគមអតីតយុទ្ធជនបានចំនួន៨ ២៧០សព។

ក្រសួងការពារជាតិមានមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការចំនួន០៣កន្លែង ដែលស្ថិតនៅក្រោមការគ្រប់គ្រង បច្ចុប្បន្នមានយោធិនពិការ គ្រួសារពលី ប៉ូលីស គ្រួសារបញ្ជូនមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា គ្រូបង្រៀននិងគ្រូពេទ្យ រស់នៅសរុបចំនួន១ ១០១គ្រួសារ ក្នុងនោះ៖

១- មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧(កោះស្លា)ចំនួន២៥៥គ្រួសារ សាងសង់ផ្ទះបាន៣៥៧ខ្នង សាងសង់អគារស្នាក់ការ សាលារៀន មន្ទីរពេទ្យ វត្តអារាមនិងអគារអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យសរុប១៥ខ្នង ផ្សារតេជោអភិវឌ្ឍន៍២១០តូប អណ្តូងស្នប់៦៥អណ្តូង

២- មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គូលែន៣១៧ ខេត្តសៀមរាបចំនួន៣០៩គ្រួសារ សាងសង់ផ្ទះបាន២៧២ខ្នង អគាររដ្ឋបាល សិប្បកម្ម មន្ទីរពេទ្យ សាលារៀន វត្តអារាម ស្ថានីយបូមទឹក ស្ថានីយអគ្គិសនីដើរ

ដោយពន្លឺព្រះអាទិត្យនិងអគារស្ថានីយសាកអាគុយ ផ្ទះភ្ញៀវ ផ្ទះប្រចាំការ សរុប២៧ខ្នង រោងម៉ាស៊ីនភ្លើង០៤ខ្នង អណ្ដូងទឹក១៤៨អណ្ដូង

៣- មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧តេជោភ្នំឆត្រ ចំនួន៥៣៧គ្រួសារ សាងសង់ផ្ទះនិងសំណង់អគារផ្សេងៗចំនួន៤៥៩ខ្នង។

## ៤.២- លទ្ធផលការងាររបស់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ សភាពការណ៍សន្តិសុខសកលលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស ប្រកបដោយភាពតានតឹង ស្មុគស្មាញ និងបង្កហានិភ័យនៅគ្រប់តំបន់។ សម្ពាធអវិជ្ជមានដែលកាន់តែធ្ងន់ធ្ងរបន្ថែមទៀតនោះ គឺការផ្ទុះឡើងនូវវិបត្តិសុខភាពសាធារណៈជាសកល ដោយសារការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ និងមេរោគបំប្លែងថ្មីជាច្រើនប្រភេទ បណ្ដាលឱ្យមនុស្សស្លាប់រាប់លាននាក់ និងជះឥទ្ធិពលបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងពិភពលោក។

ស្ថានការណ៍ខាងលើនេះ បានជះឥទ្ធិពលដោយផ្ទាល់ និងប្រយោលដល់បរិយាកាសទូទៅនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសជុំវិញវិបត្តិជំងឺរាតត្បាតសកលកូវីដ-១៩ ស្របពេលដែលសកម្មភាពបដិវត្តន៍ពណ៌នៅតែបន្តជះចំហាយអវិជ្ជមានដល់សន្តិសុខផ្ទៃក្នុង បើទោះបីជាត្រូវទទួលរងបរាជ័យច្រើនលើកច្រើនសាររួចមកហើយក្តី។ ថ្វីបើដូច្នេះមែន ក្នុងរយៈពេល៥ឆ្នាំនេះ កម្ពុជាមានមោទនភាព ដោយនៅតែរក្សាបានសន្តិភាពពេញលេញបរិបូណ៌ទូទាំងប្រទេស និងការឯកភាពផ្ទៃក្នុងជាតិ បញ្ចៀសបាននូវអំពើភេរវកម្ម ព្រមទាំងទប់ស្កាត់បានដោយជោគជ័យនូវឧបាយកល និងសកម្មភាពបដិវត្តន៍ពណ៌ដែលប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ជាមួយនឹងការចាក់គ្រឹះកាន់តែរឹងមាំនៃលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ ខណៈដែលគ្រប់ព្រឹត្តិការណ៍នយោបាយ ព្រឹត្តិការណ៍ជាតិ អន្តរជាតិសំខាន់ៗ ក៏ត្រូវបានដំណើរការដោយរលូននិងមានសុវត្ថិភាពទាំងស្រុង។

ការជំរុញចលនាអនុវត្តគោលនយោបាយ«ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព» បានធ្វើឱ្យបរិយាកាសសន្តិសុខសណ្ដាប់ធ្នាប់សង្គមកាន់តែល្អប្រសើរ។ ជាក់ស្ដែងយើងបានកាត់បន្ថយបទល្មើសដែលជះឥទ្ធិពលដល់ចិត្តសាស្ត្រសង្គមឱ្យថយចុះចំនួន៩% ខណៈដែលកិច្ចប្រតិបត្តិការបង្ក្រាបមានកម្រិតខ្ពស់រហូតដល់៨៩% ធៀបទៅនឹងតួលេខនៃបទល្មើសដែលបានកើតឡើង។ ទន្ទឹមគ្នានេះ កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់ អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ រួមទាំងសកម្មភាពក្មេងទំនើង ក៏ត្រូវបានចាត់អនុវត្តយ៉ាងសកម្ម ផុលផុស និងទទួលលទ្ធផលជាវិជ្ជមានផងដែរ។ រីឯសណ្តាប់ធ្នាប់សាធារណៈនិងរបៀបរៀបរយសង្គមទៀតសោតក៏ត្រូវបានកែលម្អឱ្យកាន់តែប្រសើរជាងមុន ក្នុងនោះបានធ្វើឱ្យគ្រោះថ្នាក់ចរាចរណ៍ថយចុះ២៦% ខណៈអ្នកស្លាប់ថយចុះ១៩% និងអ្នករបួសថយចុះ៣៤%។ ស្ថានភាពនេះ គឺជាចំណែកមួយដ៏សំខាន់ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រផង និងជួយសម្រាលបន្ទុកទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលក្នុងការងាររបបសន្តិសុខសង្គមផង។

ដោយឡែក គ្រោះថ្នាក់អគ្គិភ័យ បើទោះបីមានកំណើន១៤% ប៉ុន្តែនៅឆ្នាំចុងក្រោយនេះ ពិនិត្យឃើញថាតួលេខនៃហេតុការណ៍អគ្គិភ័យមានការថយចុះគួរឱ្យកត់សម្គាល់ ក្នុងខណៈដែលការឧបត្ថម្ភ គាំទ្រ និងការលើកកម្ពស់សមត្ថភាពភ្នាក់ងារពន្លត់អគ្គិភ័យ រួមទាំងការផ្សព្វផ្សាយអប់រំតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព ត្រូវបានចាត់អនុវត្តយ៉ាងទូលំទូលាយនៅទូទាំងប្រទេស។

ស្នាដៃ និងពលិកម្មដ៏ធំធេងមួយទៀតរបស់កងកម្លាំងនគរបាលជាតិ នាដំណាក់កាលចុងក្រោយនេះ គឺដៃម្ខាងពុះពាររួមចំណែកក្នុងការធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមផង និងដៃម្ខាង

ទៀតចូលរួមនៅក្នុងគ្រប់ស្ថានការណ៍ជាមួយអាជ្ញាធរ ស្ថាប័នមានសមត្ថកិច្ច និងយន្តការពាក់ព័ន្ធគ្រប់ថ្នាក់ ដើម្បីប្រយុទ្ធនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងមេរោគបំប្លែងថ្មីផង។

## ទី៤- ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

### ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

**តារាងទី១- ការចុះធ្វើអធិការកិច្ចការងារនិងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់**

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ១ | ការចុះអធិការកិច្ចការងារ | លើក | **៩ ៧១៧** | **៩ ៣៥០** | **៤ ៩២២** | **១ ៨២៤** | **១៣៣** | **២៥ ៩៤៦** |
| ១.១ | ចុះធ្វើអធិការកិច្ចការងារសាមញ្ញ | លើក | ៨ ៦៨៩ | ៨ ៤០២ | ៤ ០៩៥ | ១ ៦៥០ | ៨៧ | **២២ ៩២៣** |
| ១.២ | ចុះធ្វើអធិការកិច្ចតាមដានការដាក់កំហិត | លើក | ៥៩៥ | ៦១៩ | ៥៦១ | ៩០ | ២ | **១ ៨៦៧** |
| ១.៣ | ចុះធ្វើអធិការកិច្ចពិសេស | លើក | ៤៣៣ | ៣២៩ | ២៦៦ | ៨៤ | ៤៤ | **១ ១៥៦** |
| ២ | ដាក់កំហិត | សហ | ៨៩៣ | ៧១៦ | ៩៣៧ | ៣១៨ | ៦០ | **២ ៩៦៤** |
| ៣ | សហគ្រាសត្រូវផាកពិន័យ | សហ | ៦១ | ១០០ | ១៣៦ | ២១ | ២ | **៣២០** |
| ៤ | បានចេញលិខិតផាកពិន័យ | សហ | ៨១ | ១៦ | ៥៥ | ១៩ | ៤ | **១៧៥** |
| ៥ | លើកលែងការផាកពិន័យ | សហ | ០ | ០ | ០ | ០ | ៣ | **៣** |
| ៦ | ប្តឹងទៅតុលាការ | សហ | ៥ | ៤ | ៦ | ១ | ០ | **១៦** |
| ៧ | ដោះស្រាយសំណុំរឿងជាមួយតុលាការ | សហ | ០ | ០ | ០ | ០ | ០ | **០** |

**តារាងទី២- ការចុះបញ្ជិកាពោងចក្រ សហគ្រាស និងចំនួនកម្មករនិយោជិត**

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| វិស័យកាត់ដេរ | សហគ្រាស | ១ ១៤៧ | ១ ១៥៩ | ១ ២០៩ | ១ ១៩២ | ១ ១៣៨ |
| | កម្មករនិយោជិត | ៧៦៣ ៨២០ | ៨២២ ០០៧ | ៨៥៥ ៤១៣ | ៨០២ ៧៦៥ | ៨១៤ ៨៧៥ |
| | ស្រី | ៦៥១ ៤៨៥ | ៦៨៧ ៩៥២ | ៧១៦ ៨២៦ | ៦៦២ ៣១៥ | ៦៥១ ៨៤៥ |
| ក្រៅពីវិស័យកាត់ដេរ | សហគ្រាស | ១០ ២៥០ | ១១ ៦៣៧ | ១២ ៨៥១ | ១២ ៦១៥ | ១២ ១៤៩ |
| | កម្មករនិយោជិត | ៤៤៤ ៥០២ | ៤៩៨ ៥៤០ | ៥៧៨ ៥២២ | ៥៦៧ ៥៥០ | ៥៧៩ ៥៤៧ |
| | ស្រី | ២០៩ ៤៥៧ | ២០៩ ២៧៥ | ២៣១ ០៧៤ | ២៤០ ៣១៨ | ២៤៩ ៥២៤ |
| **សរុប** | **សហគ្រាស** | **១១ ៣៩៧** | **១២ ៧៩៦** | **១៤ ០៦០** | **១៣ ៨០៧** | **១៣ ២៨៧** |
| | **កម្មករនិយោជិត** | **១២០៨៣២២** | **១៣២០៥៤៧** | **១៤៣៣៩៣៥** | **១៣៧០៣១៥** | **១៣៩៤៤២២** |
| | **ស្រី** | **៨៦០ ៩៤២** | **៨៩៧ ២២៧** | **៩៤៧ ៩០០** | **៩០២ ៦៣៣** | **៩០១ ៣៦៩** |

## បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

បរិស្ថានគ្រប់ដណ្តប់ល្អប្រសើរ គឺជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តប្រកបដោយជោគជ័យនូវអាទិភាពគោលនយោបាយតាមផ្នែកនៃចតុកោណយុទ្ធសាស្ត្រទាំង៤ដើម្បីជានាសម្រេចឱ្យបាននូវគោលដៅនៃការអភិវឌ្ឍ។ ជារួមកម្ពុជាត្រូវបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាព និងពង្រឹងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលទ្ធភាពនិងការផ្តល់កាលានុវត្តក្នុងការបន្តដំណើរអភិវឌ្ឍន៍ទៅមុខ។

### ទី១- សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ

#### ១- កិច្ចការពារជាតិនិងថែរក្សាសន្តិសុខជាតិ

ស្ថិតក្រោមម្លប់ដ៏ត្រជាក់នៃ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និងក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសជាតិមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពកាន់តែរឹងមាំបានកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋជាបណ្តើរៗ។ ថ្វីបើនៅក្នុងឆ្នាំ២០២០និង២០២១ កម្ពុជាទទួលរងនូវផលប៉ះពាល់វិស័យមួយចំនួនពីវិបត្តិជំងឺកូវីដ-១៩ ប៉ុន្តែជារួមស្ថិរភាពនយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់សង្គមមានភាពល្អប្រសើរទទួលបាននូវការគាំទ្រពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិនានា។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការនានាជាបន្តបន្ទាប់ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងខិតខំស្វែងរកវ៉ាក់សាំងការពារជំងឺកូវីដ-១៩ មកចាក់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃនៅទូទាំងប្រទេស ព្រមទាំងបានដោះស្រាយនូវផលប៉ះពាល់ដល់វិស័យឯកជន និងដាក់ចេញគោលនយោបាយឧបត្ថម្ភសាច់ប្រាក់ជូនកម្មករ កម្មការិនីដែលបាត់បង់ការងារក្នុងវិស័យកាត់ដេរ ទេសចរណ៍ គ្រួសារក្រីក្រនិងងាយរងគ្រោះ។ រាជរដ្ឋាភិបាលក៏បានចាត់វិធានការតាមផ្លូវច្បាប់ចំពោះរាល់សកម្មភាពទាំងឡាយណាដែលគាំទ្រឱ្យមានការប្រើប្រាស់កម្លាំង ដើម្បីធ្វើរដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់និងបានចាត់ទុកសកម្មភាពរបស់ទណ្ឌិត សម រង្ស៊ី ជនក្បត់ជាតិនិងបក្ខពួកថាជាក្រុមឧទ្ទាមក្រៅច្បាប់។

ព្រះរាជាណាចក្រកម្ពុជាបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ និងបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ដែលព្រឹត្តិការណ៍ទាំងបីបានប្រព្រឹត្តទៅយ៉ាងរលូនប្រកបដោយជោគជ័យត្រូវបានមជ្ឈដ្ឋានជាតិ អន្តរជាតិវាយតម្លៃខ្ពស់មានលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ គ្មានការគំរាមកំហែង គ្មានអំពើហិង្សានិងប្រកបដោយតម្លាភាព។

ប្រាសាទសំបូរព្រៃគុកត្រូវបានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក(UNESCO) សម្រេចដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧។

ក្រោមការដឹកនាំរបស់**សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** កងយោធពលខេមរភូមិន្ទបានប្រមូលផ្តុំយកអស់ពីកម្លាំងកាយចិត្ត អនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់នូវតួនាទីភារកិច្ចរបស់ខ្លួនក្នុងវិស័យការពារជាតិ និងអនុវត្តភារកិច្ចចាំបាច់មួយចំនួនដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ជូនពិសេសការចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩និងការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ ដូសទី២និងដូសជំរុញ ឬដូសទី៣ ជូនកម្មករ កម្មការិនី និយោជកនិងប្រជាពលរដ្ឋក្នុងភូមិសាស្ត្ររាជធានីភ្នំពេញនិងតាមបណ្តាខេត្ត សម្រេចបាននូវលទ្ធផលល្អគួរជាទីមោទនៈ។

នៅក្នុងការអនុវត្តភារកិច្ចការពារជាតិមាតុភូមិ កងយោធពលខេមរភូមិន្ទបានពុះពារជំនះគ្រប់ឧបសគ្គការពារបាននូវអធិបតេយ្យ បូរណភាពទឹកដីតាមខ្សែបន្ទាត់ព្រំដែននៅគ្រប់កាលៈទេសៈដែលមានការរំលោភបំពានពីសំណាក់ប្រទេសជិតខាង។ រីឯបញ្ហាវិវាទព្រំដែនក្នុងភូមិសាស្ត្រអូរអាឡៃនិងអូរតាង៉ាវ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែងជាប់និងខេត្តអាតាពើប្រទេសឡាវ កងយោធពលខេមរភូមិន្ទបានប្រកាន់ខ្ជាប់យកគោលការណ៍ដោះស្រាយដោយសន្តិវិធីដើម្បីបញ្ចៀសការប្រឈមមុខផ្នែកយោធា ពិសេសក្រោយពីមានជំនួបរវាងប្រមុខដឹកនាំប្រទេសទាំងពីរកម្ពុជា-ឡាវ បានដោះស្រាយបញ្ចប់សភាពការណ៍នេះប្រកបដោយជោគជ័យធ្វើឱ្យការប្រឈមផ្នែកយោធាវិលត្រឡប់ទៅរកប្រក្រតីភាពជាធម្មតាឡើងវិញ។ ទន្ទឹមនេះ បើទោះជាមកទល់បច្ចុប្បន្នសភាពការណ៍យោធានៅតាមតំបន់ព្រំដែនមានភាពស្ងប់ស្ងាត់ពុំមានអ្វីជាដុំកំភួន ក៏កងយោធពលខេមរភូមិន្ទចាំបាច់នៅតែបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាព និងត្រៀមខ្លួនជាប់ជានិច្ចដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ណាមួយដែលអាចកើតឡើងជាយថាហេតុ ព្រមទាំងបានពង្រឹងនិងពង្រីកខឿនការពារជាតិដែលមានលក្ខណៈរឹងមាំយូរអង្វែងនៅតាមតំបន់ព្រំដែនគោក និងបណ្តាកោះមួយចំនួន ដូចជាកសាងនិងជួសជុលប្រព័ន្ធលេណដ្ឋានគ្រប់ប្រភេទ ជំរំជម្រក បន្ទាយកងទ័ព ភូមិឋានផ្ទះសម្បែង អណ្តូងទឹក ស្រះទឹក អាងស្តុកទឹក បោសសម្អាតគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះនិងកសាងផ្លូវយុទ្ធសាស្ត្រយោធានៅតាមតំបន់ព្រំដែន។ ក្រៅពីនេះបានធ្វើការកែសម្រួលការគ្រប់គ្រងដឹកនាំបញ្ជា កែសម្រួលកម្លាំង កែសម្រួលទីតាំងឈរជើង តាមដានក្តាប់នូវរាល់សភាពការណ៍ប្រែប្រួលនៅតាមតំបន់ព្រំដែននិងធ្វើល្បាតជាប្រចាំដើម្បីគ្រប់គ្រងត្រួតពិនិត្យការពារភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួននៅតំបន់ព្រំដែនគោក តំបន់សមុទ្របាន៥៨ ៩៤២លើក(បានប្រទះឃើញថ្នាំញៀនប្រភេទ«ខេតាមីន» ចំនួន២៤កេះ ស្មើនឹង៤៦៤ ៥៥៧គ.ក្រ.នៅលើឆ្នេរកោះពូលូវ៉ៃនិងបានប្រគល់ជូនសាលាដំបូងខេត្តព្រះសីហនុ) ព្រមទាំងបានចូលរួមទប់ស្កាត់និងបង្ក្រាបបទល្មើសនៅតាមតំបន់ព្រំដែន សកម្មភាពឆ្លងដែនខុសច្បាប់ទៅវិញទៅមកនៃពលរដ្ឋទាំងសងខាង ចូលរួមពង្រឹងការចេញ-ចូលឆ្លងកាត់ព្រំដែនដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ និងណែនាំការគេចវេះមិនព្រមធ្វើចត្តាឡីស័កពីសំណាក់ប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសជិតខាងនិងដឹកជញ្ជូនទៅកាន់កន្លែងធ្វើចត្តាឡីស័ក និងពីកន្លែងធ្វើចត្តាឡីស័កទៅកាន់លំនៅឋាននៅតាមបណ្តាខេត្តនានាបាន១៣៨ ៣៨២នាក់ ផងដែរ។

ដោយឡែកនៅក្នុងផ្ទៃប្រទេសកងយោធពលខេមរភូមិន្ទ គឺជាកម្លាំងសំខាន់មិនអាចខ្វះបានដែលបានម្ចាស់ការនិងសហការចូលរួមយ៉ាងសកម្មបំផុតនៅក្នុងការគ្រប់គ្រងពង្រឹងការអនុវត្តច្បាប់ កសាងភូមិ ឃុំមានសុវត្ថិភាព ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារស្ថិរភាពនយោបាយ ទប់ស្កាត់និងបង្ក្រាបសកម្មភាពល្មើសគ្រប់ប្រភេទ ភាពអនាធិបតេយ្យផ្សេងៗ ព្រមទាំងការអនុវត្តបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាលក្នុងការបង្ក្រាបសកម្មភាពបំផ្លិចបំផ្លាញធនធានធម្មជាតិ សកម្មភាពគេចពន្ធដើម្បីរួមចំណែកកៀរគរបង្កើនចំណូលថវិកាជាតិជាក់ស្តែង៖

- បានម្ចាស់ការស្រាវជ្រាវនិងបង្ក្រាបបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិមបានចំនួន១០ ៦៧៩លើក ឃាត់ខ្លួនជនសង្ស័យបានចំនួន១៩ ៦៦៨នាក់(ក្នុងនោះរកឃើញជនពាក់ព័ន្ធចំនួន១៧ ៣១៧នាក់និងវត្ថុតាងមួយចំនួនបញ្ជូនទៅតុលាការ បញ្ជូនទៅមណ្ឌលកែប្រែចំនួន៦៦៩នាក់ និងដោះលែងជនមិនពាក់ព័ន្ធចំនួន១ ៦៨២នាក់) ព្រមទាំងរឹបអូសបានថ្នាំញៀនម្សៅICEចំនួន៣០ ៦៣១កញ្ចប់ ស្មើនឹង១០៩ ៩៤១,៧៥ក្រ. ថ្នាំWYចំនួន១៦០ ១៨១គ្រាប់ ស្មើនឹង១៥ ៩២៥,៥៣ក្រ. ថ្នាំអ៊ិចស្តាស៊ី១៧៩កញ្ចប់ និង២ ៣៧៨គ្រាប់ ស្មើនឹង៣ ០៥៥,៣៨ក្រ. ថ្នាំកេតាមីន៦២៧កញ្ចប់ និង២០២គ្រាប់ ស្មើនឹង៥៥ ៨១៦,៩៦ក្រ. ថ្នាំកូកាអ៊ីន១៧កញ្ចប់ ស្មើនឹង៧២៥,៨៤ក្រ.

ថ្នាំហេរ៉ូអ៊ីន២ដុំស្មើ៧០១,៧០ក្រ. កញ្ឆាក្រៀម២៦៣ ៧៦០,៤២ក្រ. កញ្ឆាស្រស់១៨៩ ៧៧២ដើម ដញ្ជីងថ្លឹងថ្នាំញៀន៤៩៦គ្រឿង(បញ្ជូនទៅតុលាការ) ព្រមទាំងសម្ភារៈផ្សេងៗមួយចំនួនទៀត

- ដោះស្រាយពាក្យបណ្តឹងផ្សេងៗបាន៦៣៨បណ្តឹង អនុវត្តដីកាតុលាការបាន១៣ ០៣៦ដីកា

- ជួយសង្គ្រោះប្រជាពលរដ្ឋជួបគ្រោះថ្នាក់ចរាចរណ៍ អគ្គិភ័យ គ្រោះធម្មជាតិ(គ្រោះរាំងស្ងួត ខ្យល់ព្យុះ ទឹកជំនន់...) និងករណីផ្សេងៗបានចំនួន២៤ ៩២៨លើក ដឹកជញ្ជូនជនរងគ្រោះនិងអ្នកជំងឺទៅកាន់មន្ទីរពេទ្យបានចំនួន៣ ៨០៤នាក់ សាកសពទៅកាន់លំនៅឋាននិងវត្តអារាមបានចំនួន៨១សព

- មណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនកងរាជអាវុធហត្ថខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តព្រះសីហនុ និងកងពលតូចលេខ៣១ យោធភូមិភាគទី៣ បានទទួលអ្នកញៀនគ្រឿងញៀនមកធ្វើការអប់រំ និងបន្សាបសារជាតុញៀនជាសះស្បើយត្រឡប់ទៅលំនៅឋានវិញបានចំនួន៣ ៥៥៨នាក់

- ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់ពីគ្រឿងញៀនជូនដល់កងយោធពលខេមរភូមិន្ទនៅតាមបណ្តាអង្គភាព ប្រជាពលរដ្ឋ សិស្ស និស្សិតនៅតាមបណ្តារាជធានី ខេត្តបានចំនួន៥ ០២៤លើក ស្មើនឹង១ ១៣២ ៧០៧នាក់។

ក្រៅពីនេះ កងយោធពលខេមរភូមិន្ទក៏បានចូលរួមយ៉ាងសកម្មជួយប្រជាពលរដ្ឋក្នុងការកសាងនិងជួសជុលផ្ទះសម្បែង ផ្លូវ ស្ពាន បង្គន់អនាម័យ ជីកស្រះទឹក អណ្តូងទឹក ជួយការងារបង្កបង្កើនផល(ភ្ជួររាស់ ដកស្ទូង ច្រូតកាត់ បោកបែន ដាំដុះដំណាំនិងប្រមូលផល លើកភ្លឺស្រែ បូមទឹកដាក់ស្រែ...)ជួយពិនិត្យព្យាបាលជំងឺ និងបានឧបត្ថម្ភជូនបងប្អូនប្រជាពលរដ្ឋដែលខ្វះខាតជួបការលំបាកជាថវិកា សម្ភារៈផ្សេងៗក៏ដូចជាសម្ភារៈសម្រាប់ការពារជំងឺកូវីដ-១៩ ផងដែរ។

### ២- គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម(ល.គ.ជ.ប.ភ.) បានសម្របសម្រួលការរៀបចំបំពេញការងារតាមសូចនាករ ដែលបានគ្រោងទុកកន្លងមកក្នុងនោះរួមមាន ការហ្វឹកហ្វឺន វគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ច ក្នុងស្រុកសរុបចំនួន១៣៥ដង។ អ្នកចូលរួមត្រូវបានអញ្ជើញពីបណ្តាក្រសួង ស្ថាប័ន មន្ទីរពាក់ព័ន្ធរួមមាន ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងការពារជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស កងពលតូចលេខ៧០ អគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ចនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា កំពង់ផែស្វយ័តភ្នំពេញជាដើម។ ចំពោះការចុះបេសកកម្មក្រៅប្រទេស ល.គ.ជ.ប.ភ. បានរៀបចំបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ចូលរួមសរុបចំនួន១១៥ដង(តាមប្រព័ន្ធអនឡាញ ចំនួន១៤ដង) នៅតាមបណ្តាប្រទេសមួយចំនួន ដូចជាសហរដ្ឋអាមេរិក ចិន អូស្ត្រាលី ជប៉ុន ថៃ អាល្លឺម៉ង់ អូទ្រីស អ៊ីតាលី សាធារណរដ្ឋកូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី កេនយ៉ា វៀតណាម សិង្ហបុរី ហ្វីលីពីន ហ្វាំងឡង់ ឥណ្ឌា រុស្ស៊ី ម៉ាល់តា ហុងគ្រី កាណាដា ស្រីលង្កា បេឡារុស អ៊ូបេគីស្ថាន អារ៉ាប់រួម ឆេកូស្លូវ៉ាគី នេប៉ាល់។ ដោយឡែកចំពោះសមយុទ្ធលើតុ ក៏មានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីលេខាធិការដ្ឋាន និងស្ថាប័ននានាដូចជា ក្រសួងការពារជាតិ(អាជ្ញាធរជាតិអាវុធគីមី) ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានកាំកុងត្រូល យោធភូមិភាគពិសេស នាយកដ្ឋានស្រាវជ្រាវចារកិច្ចយោធា ការិយាល័យទី២ នៃអគ្គបញ្ជាការដ្ឋានកងទ័ពជើងគោក។

ក្រៅពីនេះកងកម្លាំងពិសេសប្រឆាំងភេរវកម្ម បានចូលរួមក្នុងការការពារសុវត្ថិភាពជូនថ្នាក់ដឹកនាំ និងឥស្សរជនជាន់ខ្ពស់ក្នុងការចុះបំពេញបេសកកម្ម ការចូលរួមក្នុងព្រឹត្តិការណ៍ជាតិ អន្តរជាតិសំខាន់ៗ ក្នុងស្រុកចំនួន

៥៧២ដង រួមមានការយាង និងអញ្ជើញទៅក្រៅប្រទេសរបស់**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី** និងថ្នាក់ដឹកនាំ កម្មវិធីសំណេះសំណាលផ្សេងៗ កម្មវិធីសម្ពោធសមិទ្ធផលនានា កម្មវិធីបើក បិទសន្និបាត កិច្ចប្រជុំរដ្ឋសភា កិច្ចប្រជុំកំពូលអាស៊ាន ការបំពេញទស្សនកិច្ចជាផ្លូវការ ការចែកអំណោយមនុស្សធម៌កាកបាទក្រហម និងកម្មវិធីបុណ្យជាតិនានា...។

ក្នុងការពង្រឹងផ្នែកច្បាប់ល.គ.ជ.ប.ភ. បានធ្វើបច្ចុប្បន្នភាពសៀវភៅផែនការជាតិប្រឆាំងភេរវកម្ម (ឆ្នាំ២០២១) ដែលសៀវភៅនេះគឺជាឯកសារគោលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ស្ថាប័ននិងភ្នាក់ងារពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជាដើម្បីរៀបចំ បង្ការ និងឆ្លើយតបចំពោះឧបទ្ទវហេតុភេរវកម្មគ្រប់រូបភាពទាំងអស់។ សៀវភៅនេះបានកំណត់មុខងារនិងភារកិច្ចសំខាន់ៗសម្រាប់ស្ថាប័ននិងទីភ្នាក់ងារពាក់ព័ន្ធទាំងអស់ដើម្បីសហការគ្នាប្រកបដោយប្រសិទ្ធភាព។ ល.គ.ជ.ប.ភ.បានបើកវគ្គបណ្តុះបណ្តាលចំណេះដឹងស្តីពីសៀវភៅផែនការជាតិប្រឆាំងភេរវកម្ម ដល់ស្ថាប័ននៅក្នុងខេត្តចំនួន១៦ និងគ្រោងបន្តបើកវគ្គបណ្តុះបណ្តាលនៅទូទាំងប្រទេស (២៥រាជធានី ខេត្ត)។ ទន្ទឹមនេះ ល.គ.ជ.ប.ភ. បាននិងកំពុងចូលរួមក្នុងកិច្ចពិភាក្សាផងដែរលើសេចក្តីព្រាងច្បាប់ស្តីពីថាមពលនុយក្លេអ៊ែររបស់ក្រសួងរ៉ែ និងថាមពល ការរួមចំណែកជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU) ដើម្បីធ្វើការវាយតម្លៃគ្នាទៅវិញទៅមកលើហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

លើសពីនេះទៀតល.គ.ជ.ប.ភ. បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលគម្រោងផ្តួចផ្តើមកំពង់ផែខ្នាតធំដើម្បីតម្លើងម៉ាស៊ីនត្រួតពិនិត្យជាតិវិទ្យុសកម្ម (RPM)នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ និងបំពាក់ឧបករណ៍រាវរកសារធាតុវិទ្យុសកម្ម (RPM) ដែលអាចយួរតាមខ្លួនបានដល់មន្ត្រីគយនៅតាមច្រកត្រួតពិនិត្យព្រំដែនគោក អន្តរជាតិ កំពង់ផែស្ងួត អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប ហើយក៏បានសម្របសម្រួលកម្មវិធីគ្រប់គ្រងការនាំចេញទំនិញយុទ្ធសាស្ត្រ និងការត្រួតពិនិត្យការនាំចេញជាមួយក្រសួងការបរទេសសហរដ្ឋអាមេរិក(DoS) សហភាពអឺរ៉ុបលើគម្រោងP2P។

ក្រៅពីនេះក៏មានការសហការពីភាគីដៃគូលើការងារបង្ការ ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងជាមួយនឹងភេរវកម្ម ដែលមានការសហការទាំងក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ ក៏ដូចជាការសម្របសម្រួលការទទួលភ្ញៀវអន្តរជាតិក្នុងភាពជាដៃគូ ជាមិត្ត ដែលបានចូលមកសហការលើការងារប្រឆាំងភេរវកម្មផងដែរ។

ក្នុងរយៈពេល៥ឆ្នាំកន្លងមក នាយកដ្ឋានទាំងប្រាំចំណុះល.គ.ជ.ប.ភ. រួមទាំងបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្មបានបំពេញការងារតាមសូចនាករនិងការគ្រោងទុកនាពេលកន្លងមក រួមមានការចងក្រង និងបោះពុម្ពសៀវភៅគោលដៅទន់ រឹង បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ល.គ.ជ.ប.ភ. (២០១៩-២០២៣) ផែនការយុទ្ធសាស្ត្របីឆ្នាំរំកិល កិច្ចការផ្សព្វផ្សាយព័ត៌មានភេរវកម្មជុំវិញពិភពលោកចំនួន ៦ ២៩១ព័ត៌មាន ព័ត៌មានសុវត្ថិភាពបច្ចេកវិទ្យាចំនួន៤ ៣៥៤ព័ត៌មាន ដើម្បីផ្សព្វផ្សាយលើគេហទំព័រ www.nctc.gov.kh ការចុះប្រមូលព័ត៌មានចំហនិងព័ត៌មានចារកម្មនៅតាមបណ្តារាជធានី ខេត្ត ក្រុងនានា។

លេខាធិការដ្ឋានគ.ជ.ប.ភ. ក៏បានត្រៀម និងបន្តសកម្មភាពនៅក្នុងបេត់នៃជំងឺកូវីដ-១៩ថ្មី ដើម្បីបន្តការសហការ បង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងភេរវកម្ម ក៏ដូចជាការចូលរួមក្នុងការការពារសុវត្ថិភាពថ្នាក់ដឹកនាំជាបន្តទៀតដោយស្មារតីទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការខ្ពស់។

## ៣- ការងារប្រជាធិបតេយ្យនីយកម្ម

### ៣.១- គណបក្សនយោបាយ

បច្ចុប្បន្ន គណបក្សនយោបាយដែលក្រសួងមហាផ្ទៃទទួលស្គាល់ មានចំនួន៤៧គណបក្ស ក្នុងនោះគណបក្សនយោបាយដែលបានចុះឈ្មោះក្នុងបញ្ជី មានចំនួន៤៤គណបក្ស និងគណបក្សនយោបាយបង្កើតថ្មី តែមិនទាន់បានចុះឈ្មោះក្នុងបញ្ជីមានចំនួន៣គណបក្ស។

គណបក្សនយោបាយទាំង៤៤គណបក្ស រួមមាន(១) គណបក្សប្រជាជនកម្ពុជា (២) គណបក្សហ៊្វុនស៊ិនប៉ិច (៣) គណបក្សកម្ពុជាសេរីឯករាជ្យប្រជាធិបតេយ្យ (៤) គណបក្សកសិករ (៥) គណបក្សចំរើននិយមខ្មែរ (៦) គណបក្សមូលីណាកា (៧) គណបក្សអភិវឌ្ឍន៍កម្ពុជា (៨) គណបក្សភ្លើងទៀន (៩) គណបក្សខ្មែរជួយខ្មែរ (១០) គណបក្សខ្មែរអង្គរ (១១) គណបក្សធម្មាធិបតេយ្យ (១២) គណបក្សស្ត្រីដើម្បីស្ត្រី (១៣) គណបក្សចលនាប្រជាធិបតេយ្យ (១៤) គណបក្សជាតិនិយម (១៥) គណបក្សមហានគរ (១៦) គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (១៧) គណបក្សអំណាចប្រជាពលរដ្ឋ (១៨) គណបក្សសិទ្ធិមនុស្ស (១៩) គណបក្សខ្មែរឈប់ក្រ (២០) គណបក្សខ្មែរសាធារណរដ្ឋ (២១) គណបក្សសង្គមយុត្តិធម៌ (២២) គណបក្សសញ្ជាតិកម្ពុជា (២៣) គណបក្សនគរប្រជាធិបតេយ្យ (២៤) គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច (២៥) គណបក្សខ្មែរឈ្នះ (២៦) គណបក្សយុវជនកម្ពុជា (២៧) គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ (២៨) គណបក្សខ្មែររួបរួមជាតិ (២៩) គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា (៣០) គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (៣១) គណបក្សសាមគ្គីជាតិខ្មែរ (៣២) គណបក្សពន្លឺថ្មី (៣៣) គណបក្សមាតុភូមិយើង (៣៤) គណបក្សខ្មែរតែមួយ (៣៥) គណបក្សរស្មីខេមរា (៣៦) គណបក្សធនធានខ្មែរ (៣៧) គណបក្សប្រជាធិបតេយ្យថ្មី (៣៨) គណបក្សខ្មែរក្រោក (៣៩) គណបក្សបំណងពលរដ្ឋ (៤០) គណបក្សខ្មែរអភិរក្ស (៤១) គណបក្សខ្មែរស្រឡាញ់ជាតិ (៤២) គណបក្សកម្លាំងប្រជាធិបតេយ្យ (៤៣) គណបក្សឯកភាពជាតិខ្មែរ និង(៤៤) គណបក្សកែទម្រង់កម្ពុជា។

គណបក្សនយោបាយបង្កើតថ្មី តែមិនទាន់បានចុះឈ្មោះក្នុងបញ្ជីមានចំនួន៣គណបក្ស រួមមាន គណបក្សបេះដូងជាតិ គណបក្សកម្ពុជានិយម និងគណបក្សសំឡេងសហគមន៍កម្ពុជា។

### ៣.២- ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់

ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់។

**ក- ក្នុងឆ្នាំ២០១៩ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បានបើកកិច្ចប្រជុំចំនួន១៧លើកដើម្បីពិភាក្សាលើ៖**

១- ការចុះសិក្សាដោយផ្ទាល់នៃទស្សនវិស័យស្វ័យសម្រេចរបស់ប្រតិភូគណបក្សសាមីនីមួយៗ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ម៉ម សូណាង់ដូ** ប្រធានគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ជាមួយរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រធានលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩

២-សមិទ្ធផលរបស់ក្រសួងយុត្តិធម៌ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ហ្វូង ជៀមទៀង** ប្រធានគណបក្សខ្មែរសាធារណរដ្ឋ ជាមួយប្រតិភូក្រសួងយុត្តិធម៌ ដឹកនាំដោយឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩

៣- សមិទ្ធផលរបស់ក្រសួងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការទប់ស្កាត់នូវរាល់ការផ្សាយពាណិជ្ជកម្មនៃផលិតផលទំនិញ និងសេវាដែលមានលក្ខណៈភូតកុហកឆបោកក៏ដូចជាមានលក្ខណៈលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ជាពិសេស យុវជនសេពគ្រឿងស្រវឹង ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ពេជ្រ សូជេថ្លា** អនុប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ជាមួយប្រតិភូក្រសួងពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩

៤- ទិដ្ឋភាពជាក់ស្តែងចំពោះប្រសិទ្ធភាពនៃការទប់ស្កាត់ការផ្សាយព័ត៌មានមិនពិត រួមទាំងប្រសិទ្ធភាពនៃការទប់ស្កាត់ការផ្សាយលើកទឹកចិត្តឱ្យប្រជាពលរដ្ឋសេពគ្រឿងស្រវឹង និងបង្កប៉ះពាល់ដល់សន្តិសុខជាតិ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ពេជ្រ សូជេថ្លា** អនុប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ជាមួយប្រតិភូក្រសួងព័ត៌មាន ដឹកនាំដោយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

៥- ទិដ្ឋភាពជាក់ស្តែងពាក់ព័ន្ធនឹងការស្វែងរកការងារជូនប្រជាពលរដ្ឋ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ហួន រាជចំរើន** ប្រធានគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយប្រតិភូក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩

៦- សមិទ្ធផលការងារ ព្រមទាំងបញ្ហាប្រឈមមួយចំនួននៃប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើសនានា និងបរិបទផ្សេងៗក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ហួន រាជចំរើន** ប្រធានគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយប្រតិភូក្រសួងរ៉ែ និងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩

៧- សមិទ្ធផលការងាររបស់ក្រសួងសុខាភិបាល ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ពេជ្រ ស្រស់** ប្រធានគណបក្សយុវជនកម្ពុជា ជាមួយប្រតិភូក្រសួងសុខាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩

៨- សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម(ប.ស.ស.) ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សឆន្ទៈខ្មែរ ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរ ជាមួយប្រតិភូរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩

៩- សេចក្តីព្រាងច្បាប់ស្តីពីសំណង់ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សឆន្ទៈខ្មែរ ជាមួយប្រតិភូក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដឹកនាំដោយឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩

១០- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០២០-២០២៣ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សឆន្ទៈខ្មែរ ជាមួយប្រតិភូក្រសួងផែនការ ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩

១១- សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ ស្តីពីការត្រួតពិនិត្យឡើងវិញនូវការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្ស

ធនធានទឹក ជាមួយប្រតិភូអង្គភាពប្រឆាំងអំពើពុករលួយ ដឹកនាំដោយឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩

១២- ការធានារបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់គម្រោងទិញថាមពលអគ្គិសនីផលិតដោយធ្យូងថ្ម ២៤០០មេហ្គាវ៉ាត់ពីប្រទេសឡាវ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ស្រួយ ខេត** តំណាងគណបក្សជនជាតិដើមប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងរ៉ែនិងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩

១៣- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីសហជីព ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ស្រួយ ខេត** តំណាងគណបក្សជនជាតិដើមប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩

១៤- បរិបទនៃការកំណត់ខណ្ឌសីមា និងដំណើរការនៃការបោះបង្គោលព្រំដែនគោករវាងកម្ពុជានិងវៀតណាម ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **កែម រីទ្ធិសិត** ប្រធានគណបក្សខ្មែរតែមួយ ជាមួយប្រតិភូអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដឹកនាំដោយឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩

១៥- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **កែម រីទ្ធិសិត** ប្រធានគណបក្សខ្មែរតែមួយ ជាមួយប្រតិភូក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី២២ខែតុលា ឆ្នាំ២០១៩

១៦- កិច្ចប្រជុំពិភាក្សាទូទៅដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ឯក សំអុល** តំណាងគណបក្សប្រជាជនកម្ពុជា ជាមួយប្រតិភូក្រសួងធនធានទឹក និងឧតុនិយម ដឹកនាំដោយឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩

១៧- កិច្ចប្រជុំពិភាក្សាទូទៅដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ឯក សំអុល** តំណាងគណបក្សប្រជាជនកម្ពុជា ជាមួយប្រតិភូក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

ក្រៅពីនេះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំប្រជុំចំនួន៣លើកៈ

១- កិច្ចប្រជុំប្រចាំឆមាសលើកទី១នៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ដើម្បីស្តាប់របាយការណ៍សង្ខេបនិងសំណូមពរ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩

២- ដឹកនាំកិច្ចប្រជុំប្រចាំឆមាសលើកទី២នៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ដើម្បីស្តាប់របាយការណ៍សង្ខេប និងសំណូមពរ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩

៣- បិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩។

ខ- ក្នុងឆ្នាំ២០២០ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់បានបើកកិច្ចប្រជុំចំនួន៥លើកដើម្បីពិភាក្សាលើ៖

១- កិច្ចប្រជុំពិភាក្សាលើការងាររបស់ក្រសួងយុត្តិធម៌ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ញឹក ប៊ុនឆៃ** ប្រធានគណបក្សខ្មែររួបរួមជាតិ ជាមួយប្រតិភូក្រសួងយុត្តិធម៌ ដឹកនាំដោយឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០

២- កិច្ចប្រជុំពិភាក្សាលើភាពមិនប្រក្រតីមួយចំនួនរួមទាំងបញ្ហាផ្សេងៗ ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **នួន សុខាទី** ប្រធានគណបក្សពន្លឺថ្មី ជាមួយប្រតិភូក្រសួងសាធារណការនិងដឹកជញ្ជូន ដឹកនាំដោយឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០

៣- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **នួន សុខាទី** ប្រធានគណបក្សពន្លឺថ្មី ជាមួយប្រតិភូ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម រួមទាំងពិភាក្សាលើគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងគម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី២៣០គីឡូវ៉ុល ពីរោងចក្រអគ្គិសនីដុតធ្យូងថ្ម ខេត្តឧត្តរមានជ័យ មកអនុស្ថានីយខាងកើតសៀមរាប របស់ក្រសួងរ៉ែ និងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០

៤- កិច្ចប្រជុំពិភាក្សាអំពីសុក្រឹតភាពការងារជំរឿនប្រជាជនឆ្នាំ២០១៩ ដើម្បីជាស្ថិតិមូលដ្ឋាននៃការរៀបចំផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធផល ឆ្លើយតបនឹងសេចក្តីត្រូវការរបស់សង្គមជាតិ ព្រមទាំងបញ្ហាប្រឈមមួយចំនួននៃប្រសិទ្ធភាពការងារ និងការអនុវត្តច្បាប់ស្ថិតក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងផែនការ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **នួន សុខាទី** ប្រធានគណបក្សពន្លឺថ្មី ជាមួយប្រតិភូក្រសួងផែនការ ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

៥- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងការប្រើប្រាស់និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនិងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ចាន់ យ៉េត** តំណាងប្រតិភូគណបក្សនគរប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០។

ក្រៅពីនេះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំប្រជុំចំនួន២លើក៖

១- កិច្ចប្រជុំប្រចាំឆមាសលើកទី៣ នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ និងបានថ្លែងសារពិសេសជូនជនរួមជាតិស្តីពីវិធានការរបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយនិងកាត់

បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជា ដែលបណ្ដាលមកពីការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួន ក្រោមកម្មវិធីទំនិញគ្រប់មុខ លើកលែងតែអាវុធ (EBA)របស់សហភាពអឺរ៉ុប និងជំងឺកូវីដ-១៩ ព្រមទាំងដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងជួយសម្រាលបន្ទុកប្រជាជនដែលប្រកបមុខរបរក្នុងវិស័យរងផលប៉ះពាល់ ជាអាទិ៍វិស័យទេសចរណ៍ វិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់។ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏បានធ្វើសារផ្សព្វផ្សាយជូនជនរួមជាតិ អំពីវិធានការអនាម័យចាំបាច់មួយចំនួនដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងបើកឱកាសឱ្យប្រធាននិងប្រតិភូតំណាងគណបក្សនយោបាយនីមួយៗ និងអ្នកសារព័ត៌មានលើកជាសំណួរមកទូលព្រះបង្គំជាខ្ញុំបកស្រាយពន្យល់បន្ថែមផងដែរ

២- កិច្ចប្រជុំប្រចាំឆមាសលើកទី៤នៃឧត្ដមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។ ក្នុងឱកាសនោះ**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**បានជម្រាបជូនប្រតិភូគណបក្សនយោបាយលើកយកបញ្ហាទាក់ទងនឹងជំងឺកូវីដ-១៩ ធ្វើជាប្រធានបទនិងរួមយោបល់ចំពោះវិធានការដោះស្រាយរបស់រាជរដ្ឋាភិបាលកន្លងទៅដែលមានផលប៉ះពាល់ដល់វិស័យសេដ្ឋកិច្ច សង្គម ព្រមទាំងជួយលើកបញ្ហាដែលមិនទាន់បានធ្វើការដោះស្រាយ និងបញ្ហាផ្សេងៗមួយចំនួនទៀត។

## ៤- ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន

### ៤.១- ការងារច្រកទ្វារព្រំដែន

**ក- ច្រកទ្វារអន្តរជាតិ** (ស្ថិតនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា)

- អាកាសយានដ្ឋានអន្តរជាតិមាន៣ គឺអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

- កំពង់ផែអន្តរជាតិមាន៣ គឺកំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ និងកំពង់ផែស្វយ័តអន្តរជាតិគ្រីស្ដាល់រ៉ាយ ខេត្តកំពត។

- កំពង់ផែសមុទ្រមាន១០ គឺកំពង់ផែទំនប់រលក ស្ទឹងហាវ ស្រែអំបិល ប៉ាក់ខ្លង កោះស្ដេច ថ្មស កំពង់ផែសមុទ្រទីរួមខេត្តកំពត ត្រពាំងល្ពៅ កោះសេះ និងកំពង់ផែទីក្រុងកែប។

**ខ- បណ្ដាច្រកទ្វារព្រំដែន** (ស្ថិតនៅតាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាង)

| ច្រកទ្វារព្រំដែនអន្តរជាតិ | ច្រកទ្វារព្រំដែនទ្វេភាគី | ច្រកទ្វារតំបន់ព្រំដែន | ឈ្មោះរាជធានី ខេត្ត |
|---|---|---|---|
| ច្រកទ្វារជាប់ព្រំដែនថៃ | | | |
| ចាំយាម | | | កោះកុង |
| ដូង ភ្នំដី | | សួនស៊ុំ អូរវំដួល ភ្នំព្រឹក ច្រក៤០០ ពាមគាស្វាយចេក បានសានចាវ ច្រក២០៣ | បាត់ដំបង |
| ព្រំ | | | ប៉ៃលិន |
| ប៉ោយប៉ែត ស្ទឹងបត់ | | បឹងត្រកួន ម៉ាឡៃ ច្រក៤៣ | បន្ទាយមានជ័យ |
| អូរស្មាច់ ជាំ ជប់គគីរ | | ព្រះប្រឡាយ | ឧត្ដរមានជ័យ |
| អានសេះ | ប្រាសាទព្រះវិហារ | | ព្រះវិហារ |
| ថ្មដា | | ភ្នំឫស្សី ស្ពានជ័យជំនះ | ពោធិ៍សាត់ |

| ច្រកទ្វារជាប់ព្រំដែនវៀតណាម | | | |
|---|---|---|---|
| | ដាក់ដាំ ឡាប៉ាខេ ជីមៀត ណាំលៀ | | មណ្ឌលគិរី |
| អូរយ៉ាដាវ | | | រតនគិរី |
| ត្រពាំងស្រែ | ជ័យឃ្លាំង ស្នួល | | ក្រចេះ |
| ត្រពាំងផ្លុង ដា | ចាន់មូល ទន្លេចាម | ដូនរ័ត្ន ជាំក្រវៀន ទន្លូង | ត្បូងឃ្មុំ |
| បាវិត សំរោង ព្រៃវល្លិ៍ | បុសមន | ស្រែបារាំងដូងព្រៃតាអី ខ្សែវដែក | ស្វាយរៀង |
| ក្អមសំណ ជ្រៃធំ | | ព្រែកជ្រៃ-ព្រែកទន្លា ព្រែកស្បូវ | កណ្តាល |
| បន្ទាយចក្រី កោះរកា ម៉ឺនជ័យ | កោះសំពៅ | ពាមមន្ទា ស្វាយអាដោង | ព្រៃវែង |
| ភ្នំដិន | កំពង់ក្រសាំងបាក់ដៃ | | តាកែវ |
| ព្រែកចាក | តន់ហាន់ | | កំពត |
| ច្រកទ្វារជាប់ព្រំដែនឡាវ | | | |
| ត្រពាំងក្រៀល | | | ស្ទឹងត្រែង |

## ៤.២- ការការពារដែនអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា

**ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សម្រេចការងារដូចខាងក្រោម៖**

ដោយឈរលើស្មារតីជាអ្នកជិតខាងល្អ និងរួមរស់ដោយសន្តិសហវិជ្ជមាន ព្រមទាំងផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ និងគោលការណ៍មិនកែប្រែខ្សែព្រំដែនក្រោយពេលទទួលបានឯករាជ្យពីអាណានិគម ក្រសួងបានសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា និងប្រទេសជិតខាង ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ សំដៅប្រែក្លាយតំបន់ព្រំដែនទៅជាតំបន់សន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ តាមរយៈសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

**ជាមួយឡាវ:** ភាគីទាំងពីរសម្រេចបានការខណ្ឌសីមានិងបោះបង្គោលព្រំដែនចំនួន៨៦% និងមិនទាន់ឯកភាពគ្នាចំនួន១៤%។ ទន្ទឹមនេះ កម្ពុជាក៏បានប្រានចោលនូវ (១) ការទាមទាររបស់ឡាវនៅឆ្នាំ២០១៩ ដែលចង់សើរើតំបន់អូរតាង៉ាវដែលស្ថិតក្រោមអធិបតេយ្យកម្ពុជាផ្អែកលើកិច្ចព្រមព្រៀងក្នុងការទទួលយកផែនទីឆ្នាំ១៩៩៨ (២) ជំហរនិងទឡ្ហីករណ៍របស់ឡាវនៅឆ្នាំ២០២០ ក្នុងសេចក្តីព្រាង TOR ស្តីពីការអញ្ជើញអ្នកជំនាញបារាំងគូសចម្លងខ្សែព្រំដែនពីផែនទីខ្នាត១/១០០ ០០០ មកជាផែនទីUTM ខ្នាត១/៥០ ០០០ នៅកំណាត់ខ្សែព្រំដែនដែលនៅសល់ និង(៣) ការចោទប្រកាន់របស់ឡាវថា កម្ពុជាបានសង់ផ្ទះចូលក្នុងទឹកដីឡាវស្ថិតនៅចន្លោះបង្គោលលេខ០៣៦-០៣៧កាលពីឆ្នាំ២០១៧ និងថាពលរដ្ឋខ្មែររំលោភបំពានចូលទឹកដីឡាវនៅចន្លោះបង្គោលលេខ០០២-០០៤ នៅឆ្នាំ២០២១។ បន្ថែមពីនេះ ក្រសួងក៏បានធ្វើកំណត់ទូតតវ៉ាទៅភាគីឡាវឱ្យបញ្ឈប់សកម្មភាពការដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធឡាវនៅតំបន់អូរអាឡៃនិងអូរតាង៉ាវ និងការសាងសង់ប៉ុស្តិ៍ជុងក្រឡចាស់របស់ឡាវនិងសំណង់ឡាវនៅតំបន់អូរស្វាយ-វ៉ឺនខាំ ដែលស្ថិតនៅខ្សែព្រំដែនមិនទាន់ឯកភាពគ្នានៅឆ្នាំ២០១៧ ព្រមទាំងបានសហការជាមួយអាជ្ញាធរពាក់ព័ន្ធបញ្ឈប់សកម្មភាពឈូសឆាយព្រៃដោយភាគីឡាវនៅចន្លោះបង្គោលព្រំដែន០៣៣ និង០៣៤ ដែលមិនទាន់បានឯកភាពគ្នា នៅឆ្នាំ២០២១។

**ជាមួយវៀតណាម:** ភាគីទាំងពីរសម្រេចបានការខណ្ឌសីមានិងបោះបង្គោលព្រំដែនសរុបចំនួន៨៤% និងនៅមិនទាន់ឯកភាពគ្នាចំនួន១៦%។ នៅឆ្នាំ២០១៩ ភាគីទាំងពីរបានចុះហត្ថលេខាលើសន្ធិសញ្ញាបំពេញ

បន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងពិធីសារខណ្ឌសីមានិងបោះបង្គោលព្រំដែនដែលប្រទេសទាំងពីរបានទទួលស្គាល់សមិទ្ធផល៨៤% នៃការខណ្ឌសីមានិងការបោះបង្គោលព្រំដែនគោកនេះ។ ដោយឡែក ក្នុងចន្លោះឆ្នាំ២០១៧-២០២១ ក្រសួងបានចេញកំណត់ទូតតវ៉ាទៅភាគីវៀតណាមឱ្យបញ្ឈប់ការធ្វើផ្លូវក្រាលកៅស៊ូនៅចន្លោះបង្គោលព្រំដែនលេខ ២៤៥ និង២៥៣ និងការជីកកកាយដីនៅមាត់ព្រែកជ្រៃធំ(ខេត្តកណ្តាល) និងឱ្យរុះរើផ្លូវបេតុង តង់ និងសំណង់រឹង ផ្សេងៗនៅតំបន់ដែលមិនទាន់ឯកភាពគ្នា ព្រមទាំងបានធ្វើការតវ៉ាជាច្រើនលើកថា កោះពោធិ៍ស្ថិតនៅក្នុងដែនអធិបតេយ្យកម្ពុជា ស្របទៅតាមច្បាប់អន្តរជាតិ។

**ជាមួយថៃ:** ភាគីទាំងពីរបានធ្វើការវាស់វែងនិងរុករកបង្គោលព្រំដែនបានចំនួន០២បន្ថែមទៀត គឺបង្គោលលេខ៧២និងលេខ៧៣នៅឆ្នាំ២០១៩ ដែលរហូតមកដល់ពេលនេះបានរកឃើញបង្គោលព្រំដែនសរុបទាំងអស់៧៣ ដែលបោះដោយបារាំងនិងសៀម។ ទន្ទឹមនេះ ភាគីទាំងពីរក៏បានសម្ពោធឱ្យប្រើប្រាស់ស្ពានឆ្លងកាត់ព្រំដែនស្ទឹងបត់(បន្ទាយមានជ័យ) និងបានណងអៀន(ខេត្តសាកែវ) កាលពីឆ្នាំ២០១៩ ផងដែរ។

### ៥- ការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ ឃុំ មានសុវត្ថិភាព»

ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព បាននិងកំពុងជំរុញឱ្យក្លាយទៅជាចលនាជាតិតែមួយ ដើម្បីធ្វើឱ្យសហគមន៍ ភូមិ ឃុំ ទទួលបាននូវសុខសន្តិភាព សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយល្អ ប្រជាពលរដ្ឋរស់នៅនិងប្រកបរបរចញ្ចឹមជីវិតមានភាពកក់ក្តៅទាំងផ្លូវកាយនិងផ្លូវចិត្ត។

រយៈពេលកន្លងទៅនេះ ទាំងការធ្វើវេទិកាសាធារណៈ ទាំងការផ្សព្វផ្សាយគោលនយោបាយនានាត្រូវបានជំរុញកាន់តែសស្រាក់សស្រាំរហូតដល់មូលដ្ឋាននិងខ្នងផ្ទះប្រជាពលរដ្ឋ ដែលធ្វើឱ្យពួកគាត់ទទួលបានព័ត៌មានកាន់តែជាក់លាក់អំពីការផ្តល់សេវាសាធារណៈ សេវាសន្តិសុខ ជាពិសេសគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងឆ្លើយតបនិងដោះស្រាយបានទាន់ពេលវេលានូវសំណើ សំណូមពរ និងបញ្ហាប្រឈមនានា។ ជាមួយគ្នានេះ ការកសាងចលនាប្រជាការពារក្រោមការដឹកនាំរបស់អាជ្ញាធរមូលដ្ឋាន ដោយមាននគរបាលជាតិជាកម្លាំងស្នូលបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម តាមរយៈការធ្វើសកម្មភាពល្បាតយាមកាម ការចូលរួមសម្រួលចរាចរណ៍ និងសណ្តាប់ធ្នាប់នៅតាមទីសាធារណៈ ការជួយសង្គ្រោះប្រជាពលរដ្ឋក្នុងពេលជួបគ្រោះអាសន្ន គ្រោះអគ្គិភ័យ គ្រោះធម្មជាតិ។ល។

### ៦- លទ្ធផលនៃការបង្រ្កាបបទល្មើស រក្សាសុវត្ថិភាពសង្គម

**ក- លទ្ធផលនៃការបង្រ្កាបបទល្មើស ក្មេងទំនើង និងការជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ**

| បរិយាយ/ឆ្នាំ | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| បទល្មើសព្រហ្មទណ្ឌ (ករណី) | បង្រ្កាបរួម | ២ ៤២៤ | ២ ៥៩៨ | ២ ៨៤២ | ២ ៩៤០ | ១ ៧៦៣ | ១២ ៥៦៧ |
| | បទឧក្រិដ្ឋ | ៥៣៤ | ៥២៨ | ៦០៥ | ៥៩៣ | ៣២៦ | ២ ៥៨៦ |
| | បទមជ្ឈិម | ១ ៨៩០ | ២ ០៧០ | ២ ២៣៧ | ២ ៣៤៧ | ១ ៤៣៧ | ៩ ៩៨១ |
| ក្មេងទំនើង(ករណី) | | ៧៩៩ | ៨៨១ | ១ ០៤៦ | ១ ៤៩៥ | ៧៣៥ | ៤ ៩៥៦ |
| ការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ(ករណី) | | ១៥១ | ១០៤ | ១៦៣ | ១៤១ | ២០៦ | ៧៦៥ |

### ខ- លទ្ធផលនៃការបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់

| បរិយាយ/ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| ការបង្ក្រាបបទល្មើសគ្រឿងញៀន(ករណី) | ៥ ៩៤៤ | ៦ ១១១ | ៧ ៦៣៥ | ៨ ៨៦០ | ៤ ០៥១ | ៣២ ៦០១ |
| ចាប់បានជនសង្ស័យ នាក់) | ១២ ៨៧០ | ១១ ៧៩៥ | ១៥ ៦៦១ | ១៧ ៨៤៥ | ៨ ៧៣៥ | ៦៦ ៩០៦ |

កត់សម្គាល់៖

- បង្ក្រាបការជួញដូរចំនួន២១ ០០៨ករណី ឃាត់ខ្លួន៣៩ ៣០៩នាក់(ស្រី៣ ៣១១នាក់)
- បង្ក្រាបការផលិតចំនួន១៧ករណី ឃាត់ខ្លួន៥០នាក់(ស្រី១៣នាក់)
- បង្ក្រាបការដាំដុះចំនួន១៣២ករណី ឃាត់ខ្លួន៣៤នាក់(ស្រី៩នាក់)
- បង្ក្រាបការប្រើប្រាស់ចំនួន១១ ៨៤៤ករណី ឃាត់ខ្លួន២៧ ៥១៣នាក់(ស្រី១ ២៦១នាក់)
- បង្ក្រាបតាមដីកាចំនួន១ ៤៩៧ករណី(ស្រី៦២នាក់)
- វត្ថុតាងគ្រឿងញៀនចំនួន៥ ៣៤៧,៥០គីឡូក្រាម ម៉ូតូ៩ ១៩៨គ្រឿង រថយន្ត៣៨៧គ្រឿង និងអាវុធ១៨៩ដើម។

### គ- លទ្ធផលនៃការបង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ

| បរិយាយ/ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| បង្ក្រាបរួម(លើក) | ៩៦៨ | ៨៦៩ | ៨៧០ | ១ ២៩២ | ១ ០០០ | ៤ ៩៩៩ |
| អនុវត្តវិធានការរដ្ឋបាល(លើក) | ៧៤១ | ៧៤០ | ៨០៧ | ១ ០៩១ | ៨៦៦ | ៤ ២៤៥ |
| អនុវត្តវិធានការច្បាប់(លើក) | ២២៧ | ១២៩ | ៦៣ | ២០១ | ១៣៤ | ៧៥៤ |

### ឃ- ស្ថិតិគ្រោះថ្នាក់ចរាចរណ៍ អគ្គិភ័យ និងអាវុធជាតិផ្ទុះ

| បរិយាយ/ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| គ្រោះថ្នាក់ចរាចរណ៍ (លើក) | ៣ ៥៣១ | ៣ ២៦៧ | ៤ ០៥៦ | ៣ ១៧៩ | ១ ៧០១ | ១៥ ៧៣៤ |
| គ្រោះអគ្គិភ័យ (លើក) | ៥១៤ | ៥៣៤ | ៧១៧ | ៩៣៧ | ៤៧២ | ៣ ១៧៤ |
| គ្រោះថ្នាក់ដោយអាវុធជាតិផ្ទុះ លើក) | ៥១ | ២០ | ៤៧ | ៤២ | ២៣ | ១៨៣ |

## ៧- ការងារគ្រប់គ្រងពន្ធនាគារ

### ៧.១- ក្របខ័ណ្ឌគោលនយោបាយច្បាប់

- ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោសនិងការលើកលែងទោស
- អនុក្រឹត្យស្តីពី ការកែសម្រួលការកំណត់របបជីវភាពជនជាប់ឃុំ។

### ៧.២- អំពីស្ថានភាពជនជាប់ឃុំ

| បរិយាយ/ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ១០.១០.២១ | ធៀបឆ្នាំ២០១៦ |
|---|---|---|---|---|---|---|
| ជនជាប់ឃុំសរុប | ២៨ ៤១៤ | ៣១ ៦៨៦ | ៣៧ ០០៧ | ៣៩ ៣១៧ | ៣៧ ៦១២ | កើន៧១,០៤% |
| ទណ្ឌិត | ៧ ១៧២ | ៩ ១១៥ | ១០ ៦៣៩ | ១២ ៦៦៤ | ១២ ៤០១ | កើន៩១,៧៨% |
| ពិរុទ្ធជន | ១១ ០៣៨ | ១២ ០០៥ | ១១ ៦២០ | ១៦ ៧២១ | ១៤ ៩៥១ | កើន៨៦,២៣% |
| អនុវត្តដីកាឱ្យដោះលែង | ១០ ៩៣៦ | ១២ ៨០៨ | ១៦ ៥៦៩ | ១៩ ៧៦៨ | ១៦ ៧៨១ | កើន៧៩,៤៩% |
| ស្លាប់ | ១០០ | ៩៣ | ១២២ | ២១៣ | ២៥៣ | កើន២៣២,៨៩% |

### ៧.៣- ស្ថានភាពជនជាប់ឃុំទទួលបានការអប់រំកែប្រែនិងការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ

| បរិយាយ/ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ១០.១០.២១ | សរុប |
|---|---|---|---|---|---|---|
| ទទួលបានការអប់រំកែប្រែ | ៩៨ ៥៨៩ | ១៦៧ ១០១ | ១៧៩ ៩២៥ | ១០៣ ៨៩៨ | ១១៤ ៧៦៥ | ៦៥៥ ២៧៨ |
| ទទួលបានការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | ១ ៩១០ | ១ ០១៤ | ៣ ៣៨៨ | ២ ៨៩១ | ១ ៨៨៧ | ១១ ០៩០ |

<u>**កត់សម្គាល់:**</u> ក្នុងជនជាប់ឃុំម្នាក់ អាចមានការចូលរួមកម្មវិធីអប់រំកែប្រែស្តារនីតិសម្បទាជាច្រើនលើកតាមស្ថានភាពជាក់ស្តែង។

## ៨- ការងារអត្តសញ្ញាណកម្ម

ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម២០១៧-២០២៦ គណៈកម្មាធិការជាតិ ដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម គ.ជ.ជ.អ. ត្រូវបានបង្កើតឡើងសម្រាប់ជួយរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួលការចូលរួមសហការ និងការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ផ្នែកឯកជន យន្តការក្នុងតំបន់ និងបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយ ដើម្បីជំរុញនិងអនុវត្តកំណែទម្រង់ប្រព័ន្ធអត្តសញ្ញាណកម្មជាតិ ជាពិសេសការងារអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។

ជាមួយនឹងការបង្កើតគណៈកម្មាធិការខាងលើ ក្រសួងមហាផ្ទៃក៏បាន និងកំពុងរៀបចំតាក់តែងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ព្រមទាំងកំពុងអភិវឌ្ឍប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ប្រព័ន្ធចុះបញ្ជីការស្នាក់នៅ ប្រព័ន្ធគ្រប់គ្រងការងារសញ្ជាតិ ដើម្បីឈានទៅបង្កើតប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជនស្របតាមច្បាប់នេះផងដែរ។

## ៩- ការងារចុះបញ្ជីអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម

| ល.រ. | សកម្មភាពការងារ | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ចំនួនប្រជាពលរដ្ឋដែលបានចុះបញ្ជីគ្រប់ប្រភេទ | សរុប | ៤១៤ ៦១៦ | ៤៦៨ ១៤៦ | ៥០៨៥៨៨ | ៦១៤ ២២៤ | ៤០៣ ៧៩២ | ២ ៤០៩ ៣៦៦ |
| | | ស្រី | ១៩៣ ៨២៣ | ២៣០ ៥៨៦ | ២៤៥៨១៨ | ៣០១ ១៦២ | ១៩៧ ៧៥០ | ១ ១៦៩ ១៣៩ |
| ២ | សំណុំឯកសារស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងបរទេស | សរុប (ច្បាប់) | ១ ៣០៤ | ១ ៩១៨ | ២ ០២០ | ១ ០០៨ | ៤៥២ | ៦ ៧០២ |
| | | សញ្ជាតិ | ៤២ | ៣៩ | ៣៧ | ៣១ | ៩ | ៤២ |

### ក- ការងារគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ

| ល.រ. | សកម្មភាពការងារ | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|---|
| ១ | ផ្តល់សៀវភៅស្នាក់នៅ ក២ (ឯកតាក្បាល) | ផ្តល់ថ្មី | លទ្ធផលក្នុងឆ្នាំ | ១៤៦ ៧១០ | ១២៦ ៧០៨ | ៨៤ ៨០២ | ១២៣ ៥៦៧ | ៧២ ០០៩ |
| | | | បូកយោង | ៣ ០១០ ៥២៦ | ៣ ១៣៧ ២៣៤ | ៣ ២២២ ០៣៦ | ៣៣៤៥៦០៣ | ៣ ៤១៧ ៦១២ |
| | | ទុតិយតា | | ៥៩ ១០៤ | ១៩៧ ៥៧១ | ២៥៤ ៩៦៩ | ៣៥៦ ៣៣៩ | ៤០៩ ៣០៣ |
| ២ | ផ្តល់សៀវភៅគ្រួសារ ក៤ (ឯកតា ក្បាល) | ផ្តល់ថ្មី | លទ្ធផលក្នុងឆ្នាំ | ៩០ ០៨១ | ៧៩ ២៨៩ | ៤៩ ៨៣៥ | ៧៣ ៨៧២ | ៧ ៩១០ |
| | | | បូកយោង | ២ ៨៥៥ ៨៥២ | ២ ៩៣៥ ១៤១ | ២ ៩៨៤ ៩៧៦ | ៣ ០៥៨ ៨៤៨ | ៣ ១១៧ ៦៣៦ |
| | | ទុតិយតា | | ៣៦ ៨២៣ | ១១៨ ៣៣៧ | ១៥២ ៣០៩ | ២១២ ៨២៤ | ២៤៧ ៨៩៦ |

### ខ- ការងារផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

| ល.រ | សកម្មភាពការងារ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ផលិតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបាន (ឯកតា សន្លឹក) | ៤១៩ ៥៣៥ | ៣៩៣ ៥៩១ | ៥០៣ ០០៣ | ៥៨៤ ៧៤១ | ៤៧៩ ០៣០ | ២ ៣៧៩ ៩០០ |
| ២ | ផ្តល់ជូន រាជធានី ខេត្តសម្រាប់ចែកជូនប្រជាពលរដ្ឋ (ឯកតា សន្លឹក) | ៤៣៧ ៥៨៨ | ៣៦៨ ៥២៩ | ៤៧៦ ០៦៣ | ៦១៩ ៣៥៥ | ៤៦៩ ៥៧៨ | ២ ៣៧១ ១១៣ |

### គ- ការងារលិខិតឆ្លងដែន

| ល.រ. | សកម្មភាពការងារ | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | លិខិតឆ្លងដែន (ឯកតា ក្បាល) | ផលិតនិងផ្តល់ជូន | ៣៦៤ ៧៨២ | ៤១០ ៥៩៩ | ៣៥៤ ៥២៨ | ១១៨ ៤១៥ | ២០ ២៤៧ | ១២៦៨ ៥៧១ |
| ២ | លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅក្រៅប្រទេស (ឯកតា ក្បាល) | ផលិតនិងផ្តល់ជូន | ២៩ ៩៦៦ | ៦៦ ៤៩៧ | ៥៣ ៥៦៥ | ២២ ៤០២ | ១០ ១២៩ | ១៨២ ៥៥៩ |

### ឃ- ការងារសញ្ជាតិ

គិតពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ការងារសញ្ជាតិសម្រេចបានដូចតទៅៈ

- បានទទួលព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមរយៈសញ្ជាតូបនីយកម្មសរុបចំនួន១ ៦០៤នាក់ មកពី២៦ប្រទេស
- បានទទួលព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមរយៈការទាមទារសញ្ជាតិសរុបចំនួន៤៥នាក់ មកពី២៣ប្រទេស
- បានទទួលព្រះរាជក្រឹត្យស្តីពីការលះបង់សញ្ជាតិខ្មែរ សរុបចំនួន៥៧នាក់។

## ១០- ការងារអន្តោប្រវេសន៍

### ក- ស្ថិតិអ្នកដំណើរចេញចូលប្រទេស

| បរិយាយ/ឆ្នាំ | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ៩ខែ/២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ជនបរទេស | ចូល | ៥ ៣១២ ៥៨៥ | ៥ ៩០០ ២៨៤ | ៦ ២៩៥ ០៦២ | ១ ៥៨៤ ១៨២ | ១៦៩ ៦២៩ | ១៩ ២៦១ ៧៤២ |
| | ចេញ | ៥ ២៥៣ ៥៦៣ | ៥ ៧៧៩ ៩៦៥ | ៦ ៣០៣ ២៤៦ | ១ ៩២៧ ៦៨៨ | ១៨៨ ០៣៣ | ១៩ ៤៥២ ៤៩៥ |
| ពលរដ្ឋខ្មែរ | ចូល | ១ ៥២៨ ៧៩៤ | ១ ៧១២ ៩២៩ | ២ ០៣៦ ៦៦៨ | ៤៨៦ ១៣៣ | ២១ ៥៨២ | ៥ ៧៨៦ ១០៦ |
| | ចេញ | ១ ៧៦៣ ៦១៣ | ១ ៩៨៥ ៨៥៤ | ២ ១៩៣ ៥៥៨ | ៤៥១ ៤៤០ | ២៧ ៦៣០ | ៦ ៤២២ ០៩៥ |

### ខ- ស្ថិតិការផ្តល់ទិដ្ឋាការចេញចូលនិងការអនុញ្ញាតឱ្យបន្តរយៈពេលស្នាក់នៅ

| បរិយាយ/ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ៩ខែ/២០២១ | សរុប |
|---|---|---|---|---|---|---|
| ទិដ្ឋាការចូល | ២ ២៧១ ៦០៨ | ២ ៨០៤ ៧៦៨ | ២ ៩១២ ៧៥១ | ៥៦២ ៣៣៨ | ៣៨៦ | ៨ ៥៥១ ៨៥១ |
| ទិដ្ឋាការចេញ | ៣ ៥៥០ | ៥ ៨១៥ | ១៥ ១៩៣ | ២ ៨៦២ | ៨៣៧ | ២៨ ២៥៧ |
| បន្តរយៈពេលស្នាក់នៅ | ២៦៥ ០៣៥ | ៤៥៣ ៤៦៦ | ៧៤៣ ៦២៥ | ៣៥៣ ១៥៥ | ២១៥ ៧៥៥ | ២ ០៣១ ០៣៦ |

### គ- ការទប់ស្កាត់ការចេញចូលខុសច្បាប់និងការអនុវត្តនីតិវិធីចំពោះបទល្មើសអន្តោប្រវេសន៍

| បរិយាយ/ឆ្នាំ | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ៩ខែ/២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ផ្អាកដំណើរមិនឱ្យចេញ-ចូលកម្ពុជានិងបញ្ជូនទៅប្រទេសដើមវិញ ( នៅតាមព្រំដែន ) | មនុស្ស | ៧៥១ | ៥៤០ | ១ ៤១៦ | ៤២៨ | ៧៥ | ៣ ២១០ |
| | សញ្ជាតិ | ៦១ | ៦៩ | ៦៩ | ៦៩ | ៣៣ | ៨៥ |
| ការអនុវត្តនីតិវិធីបណ្តេញចេញ ក្រោយស្រាវជ្រាវបង្ក្រាបបទល្មើសអន្តោ-ប្រវេសន៍ ( ក្នុងប្រទេស ) | មនុស្ស | ៤ ០៨២ | ៣ ៣៦៦ | ៣ ២១៨ | ១ ៤៣៦ | ២ ២៦៦ | ១៤ ៣៦៨ |
| | សញ្ជាតិ | ៨៧ | ៨៥ | ៨៣ | ៧៤ | ៤២ | ១០៤ |

## ទី២- បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

### ១- ការពារកម្មសិទ្ធិបញ្ញា និងការចុះបញ្ជីម៉ាក និងសេវាពាក់ព័ន្ធ

| សកម្មភាពការងារ | ឆ្នាំ២០១៧ ( ១មករា-៣១ធ្នូ ) | ឆ្នាំ២០១៨ ( ១មករា-៣១ធ្នូ ) | ឆ្នាំ២០១៩ ( ១មករា-៣១ធ្នូ ) | ឆ្នាំ២០២០ ( ១មករា-៣១ធ្នូ ) | ឆ្នាំ២០២១ ( ១មករា - ៣១កក្កដា ) |
|---|---|---|---|---|---|
| **ក- ការងារចុះបញ្ជីម៉ាក** | | | | | |
| បានទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក<br>- ក្នុងស្រុក<br>- ក្រៅស្រុក | ៥ ៥២៣ម៉ាក<br>២ ០៦៣ម៉ាក<br>៣ ៤៦០ម៉ាក | ៥ ៦៧៨ម៉ាក<br>២ ៣០២ម៉ាក<br>៣ ៣៧៦ម៉ាក | ៦ ៥៤៧ម៉ាក<br>២ ៨១៥ម៉ាក<br>៣ ៧៣២ម៉ាក | ៦ ១១៦ម៉ាក<br>៣ ៥៨៨ម៉ាក<br>២ ៥២៨ម៉ាក | ៣ ១៨៨ម៉ាក<br>១ ៨៤៥ម៉ាក<br>១ ៣៤៣ម៉ាក |
| បានចុះបញ្ជីម៉ាក<br>( តាមប្រព័ន្ធជាតិ )<br>- ក្នុងស្រុក<br>- ក្រៅស្រុក | ៣ ៨៤៧ម៉ាក<br>១ ០៧១ម៉ាក<br>២ ៧៧៦ម៉ាក | ៤ ០៧០ម៉ាក<br>១ ៤៩៦ម៉ាក<br>២ ៥៧៤ម៉ាក | ៤ ២៧៣ម៉ាក<br>១ ៦៤៣ម៉ាក<br>២ ៦៣០ម៉ាក | ៥ ៦២៨ម៉ាក<br>២ ៦៣៥ម៉ាក<br>២ ៩៩៣ម៉ាក | ៤ ១៣៥ម៉ាក<br>២ ០៩៩ម៉ាក<br>២ ០៣៦ម៉ាក |
| **ខ- ការងារចុះបញ្ជីតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ ( Madrid System )** | | | | | |
| ពាក្យស្នើសុំដែលបានដាក់នៅការិយាល័យដើមនៅកម្ពុជា ( Office of Origin ) ដើម្បីចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ | ០ម៉ាក<br>០ជំពូក | ៥ម៉ាក<br>៦ជំពូក | ៦ម៉ាក<br>៩ជំពូក | ១០ម៉ាក<br>១០ជំពូក | ៣ម៉ាក<br>៣ជំពូក |
| ទទួលពាក្យស្នើសុំតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ | ២ ៣៨៣ម៉ាក<br>៥ ៣៩៨ជំពូក | ២ ៦៨ម៉ាក<br>៥ ៧០៩ជំពូក | ៣ ៤៦០ម៉ាក<br>៧ ៧៨៨ជំពូក | ២ ៩៧៨ម៉ាក<br>៥ ៣៨២ជំពូក | ១ ៦៥១ម៉ាក<br>៣ ៦០៧ជំពូក |
| ចុះបញ្ជីម៉ាកតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ | ៨៦៦ម៉ាក<br>១ ៨១៨ជំពូក | ១ ៣៧៦ម៉ាក<br>២ ៩៧៩ជំពូក | ១ ៩០១ម៉ាក<br>៤ ២២១ជំពូក | ២ ៣៦៨ម៉ាក<br>៤ ១៤២ជំពូក | ១ ១២៤ម៉ាក<br>២ ៣៥៧ជំពូក |
| **សរុបការចុះបញ្ជីម៉ាក** | **៨៦៦ម៉ាក<br>១ ៨១៨ជំពូក** | **១ ៣៨១ម៉ាក<br>២ ៩៧៣ជំពូក** | **១ ៩០១ម៉ាក<br>៤ ២២១ជំពូក** | **២ ៣៧៨ម៉ាក<br>៤ ១៥២ជំពូក** | **១ ១២៧ម៉ាក<br>២ ៣៦០ជំពូក** |
| **គ- ការងារក្រោយចុះបញ្ជីម៉ាក** | | | | | |
| បញ្ជាក់អំពីការប្រើប្រាស់ឬមិនប្រើប្រាស់ម៉ាក | ២ ៧០៤ម៉ាក | ៣ ៧៨២ ម៉ាក | ៤ ៤៨១ ម៉ាក | ៣ ៦៧៨ម៉ាក | ២ ១៨៧ម៉ាក |
| ចុះបញ្ជីម៉ាកសាជាថ្មី | ១ ៨១៦ម៉ាក | ១ ៨៤៤ម៉ាក | ១ ៧៧៦ម៉ាក | ២ ៥៤៩ម៉ាក | ១ ៤១២ម៉ាក |
| កត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការនាំចូល | ១០៣ ម៉ាក | ៧៧ម៉ាក | ១៣២ម៉ាក | ១០៦ម៉ាក | ៥៩ម៉ាក |

| | | | | | |
|---|---|---|---|---|---|
| កត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណ ឬ កិច្ចសន្យាផ្តល់សិទ្ធិប្រកប អាជីវកម្ម | ២៣ម៉ាក | ១៤១ម៉ាក | ៣ម៉ាក | ១១១ម៉ាក | ៣០ម៉ាក |
| ការផ្លាស់ប្តូរផ្សេងៗ | ១ ៩៩៦ម៉ាក | ២ ០៣៥ម៉ាក | ២ ០៧២ម៉ាក | ១ ៥៩៦ម៉ាក | ១ ៥៣៩ ម៉ាក |
| ការធ្វើទុតិយតាវិញ្ញាបនបត្រ | ៧២០ ម៉ាក | ៨៥៣ម៉ាក | ៩៩២ម៉ាក | ៥៨៦ម៉ាក | ៤៨៥ម៉ាក |
| ផាកពិន័យចំពោះការស្នើសុំចុះ បញ្ជីម៉ាកសាជាថ្មីយឺត | ០ ម៉ាក | ១២២ម៉ាក | ១៥០ម៉ាក | ២៦២ម៉ាក | ៧៦ម៉ាក |
| **ឃ- ការងារចុះបញ្ជីម៉ាកផ្សេងៗ** | | | | | |
| ចុះម៉ាកសម្គាល់ភូមិសាស្រ្ត ទំនិញ | | ១ម៉ាក | | ១ម៉ាក | ១ម៉ាក |
| ចុះម៉ាកវិញ្ញាតកម្ម | ១ម៉ាក | | | | |
| ចុះបញ្ជីម៉ាកសមូហភាព | | | ១ម៉ាក | | ៣ម៉ាក |
| **ង- កិច្ចការវិវាទម៉ាក** | | | | | |
| ទទួលពាក្យស្នើសុំទប់ស្កាត់ ការរំលោភបំពានម៉ាក | ១៤ករណី | ១៤ករណី | ២១ករណី | ២៨ករណី | ៦ករណី |
| ទទួលពាក្យស្នើសុំលុបម៉ាក | ៣១ករណី | ៣៣ករណី | ៤៤ករណី | ៣១ករណី | ៣២ករណី |
| លទ្ធផលសម្រុះសម្រួល ការរំលោភបំពានម៉ាក | ១៦ករណី | ១០ករណី | ១១ករណី | ២៣ករណី | ៣ករណី |
| **លទ្ធផលលុបម៉ាក** | **២៣ម៉ាក** | **២១ម៉ាក** | **២៥ម៉ាក** | **៤៦ម៉ាក** | **៥ម៉ាក** |

## ២- ការចុះបញ្ជីពាណិជ្ជកម្ម

### តួលេខចុះបញ្ជីពាណិជ្ជកម្មនិងការស្នើសុំវិញ្ញាបនបត្រផ្សេងៗ

| ល.រ. | យថាប្រភេទនៃការចុះបញ្ជីពាណិជ្ជកម្ម | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៧ខែដើម ឆ្នាំ២០២១ |
|---|---|---|---|---|---|---|
| ក- ករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ថ្មី) | | | | | | |
| ១ | ក្រុមហ៊ុនមូលធន | ៥ ៧៨១ | ១២ ២៧៦ | | | ២ ៨២២ |
| ២ | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | ៩៩ | ១៥៩ | ៩ ៣៤៤ | ៥ ៦៧៧ | ២៤ |
| ៣ | ក្រុមហ៊ុនសហកម្មសិទ្ធិ | ០ | ០ | | | ២ |
| ៤ | សហគ្រាសឯកបុគ្គល | ១ ៤៨៨ | ៣ ៦៩៥ | ៣ ៩១៥ | ២ ១៨៣ | ១ ៥៤៨ |
| **សរុបស្នើសុំចុះបញ្ជីពាណិជ្ជកម្ម** | | **៧ ៣៦៨** | **១៦ ១៣០** | **១៣ ២៥៩** | **៧ ៨៦០** | **៤ ៣៩៦** |
| ខ- ករណីស្នើសុំលុបឈ្មោះចេញពីបញ្ជី ពាណិជ្ជកម្ម | | | | | | |
| ១ | ក្រុមហ៊ុនមូលធន | ៧៣ | ១៣១ | | | ៣៤១ |
| ២ | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | ១៤ | ១១ | ១៥៥ | ៤៧៤ | ១៧ |
| ៣ | ក្រុមហ៊ុនសហកម្មសិទ្ធិ | ២ | ៩ | | | គ្មាន |
| ៤ | សហគ្រាសឯកបុគ្គល | គ្មាន | គ្មាន | ១៩ | ២៦ | ១៣ |
| **សរុបស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម** | | **៨៩** | **១៥១** | **១៧៤** | **៥០០** | **៣៧១** |

| | | | | | | |
|---|---|---|---|---|---|---|
| គ- ករណីស្នើសុំចុះបញ្ជី កែប្រែ | | | | | | |
| ១ | ការកែប្រែផ្លាស់ប្ដូរភាគហ៊ុន | ១ ១៩៦ | ១ ៤១៣ | ២ ៧១០ | ២ ៣៦៩ | ១ ២៥៣ |
| ២ | ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ២៤៦ | ៦០៤ | ៨៧៧ | ៥៧៩ | ២៧៦ |
| ៣ | ការកែប្រែផ្សេងៗ(អភិបាល នាមករណ៍ ) | ៧ ៣៨៨ | ៩ ៤៦២ | ១០ ២៨៦ | ៩ ៦៤៥ | ៥ ៨០៣ |
| ៤ | ពិន័យការមិនបានបំពេញបែបបទក្នុងការផ្លាស់ប្ដូរកែប្រែផ្សេងៗ | ៣៧៣ | ៧៤ | ១៤៤ | ២៨៩ | ៥៣ |
| ៥ | ការកែប្រែសហគ្រាសឯកបុគ្គល | ១១១ | ១៦០ | ៤០៨ | ២៨៥ | ៩១ |
| ឃ- ករណីតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | | | | | | |
| ១ | សេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | ៧ ៩៤៧ | ១៣ ០២៩ | ១៨ ១១១ | ២១ ៦៧១ | ១៣ ២២៦ |
| ២ | ការពិន័យលើការមិនតម្កល់ប្រតិវេទន៍តាមកាលកំណត់ | ៤៦៤ | ៥៤៧ | ២ ២៨៤ | ២ ១២៨ | ៨០១ |
| ង- ករណីថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម | | ២ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ច- ការប្ដូរវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | | ១ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ឆ- ករណីស្នើសុំបម្រុងទុកនាមករណ៍ | | | | | | |
| ១ | ការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | ៨ ៤៧៤ | ១៧ ៤៧០ | ១៧ ៧៨៨ | ១១ ៧៧៧ | ៤ ២២៩ |
| ២ | ពន្យារការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | ១៤៦ | ១៨៥ | | | ៣៧៩ |
| ៣ | ការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ១ ៨៦៩ | ៤ ៣៦៤ | | | ១ ៧៧៨ |
| ៤ | ពន្យារការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ៧ | ២៥ | | | ២៨ |
| ជ- ការពិន័យលើការក្លែងបន្លំឯកសារតម្រូវការចុះបញ្ជី | | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ឈ- ការងារពិគ្រោះយោបល់ផ្សេងៗ | | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

## ទី៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សម្រេចការងារបាន៖

ស្ថិតនៅចំពោះមុខការវិវឌ្ឍសភាពការណ៍សកលលោកមិនទៀងទាត់ ប្រកបដោយគ្រោះថ្នាក់ ដែលបង្កឡើងដោយការប្រកួតប្រជែងរវាងប្រទេសមហាអំណាច និងដោយអនុលោមតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានបំពេញតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងលើកកម្ពស់កិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ។ ស្របតាមស្មារតីនេះ និងតាមទិសស្លោក«**បន្តកំណែទម្រង់ផ្ទៃក្នុង និងពង្រីកមិត្តនៅខាងក្រៅ**» ក្រសួងបានខិតខំអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន វាងវៃ និងសម្រេចបាននូវសមិទ្ធផលការងារការទូតសំខាន់ៗ ក្នុងរយៈពេល៥ឆ្នាំនេះ(២០១៧-២០២១) ដូចខាងក្រោម៖

## ១- ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ និងអធិបតេយ្យ

### ១.១- ការការពារឯករាជ្យ អធិបតេយ្យ និងកិត្តិយសជាតិ

ក្រសួង និងស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស បានតស៊ូមតិយ៉ាងស្វិតស្វាញនៅលើសមរភូមិមតិសាធារណៈ និងការទូត បកអាក្រាតរាល់ល្បិចកលពិសពុលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជាក្រោមស្លាក«**ការគោរពសិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ**»។ សកម្មភាពការទូតដ៏មមាញឹកអស់ទាំងនេះ បានធ្វើឱ្យសាធារណជនជាតិ និងអន្តរជាតិ កាន់តែយល់ច្បាស់ពីសភាពការណ៍ពិតដែលបាន និងកំពុងកើតមាននៅលើទឹកដីកម្ពុជា និងទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងការរួមចំណែកការពារអធិបតេយ្យ ឯករាជ្យជាតិ និងបូរណភាពទឹកដីកម្ពុជា។ សកម្មភាពការទូតសំខាន់ៗមានដូចតទៅនេះ៖

- **ទី១** នៅក្នុងជំនួបជាមួយឥស្សរជនបរទេស តំណាងស្ថាប័នអន្តរជាតិ និងសហគមន៍ខ្មែរនៅបរទេស និងតាមរយៈសេចក្តីថ្លែងការណ៍ បានពន្យល់បកស្រាយពី (ក) អាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការរក្សាការពារឱ្យបានដាច់ខាត ទោះក្នុងតម្លៃណាក៏ដោយ នូវសន្តិភាព និងស្ថិរភាពនៅកម្ពុជា ដើម្បីការអភិវឌ្ឍប្រទេសជាតិ (ខ) គតិភាពនិងវឌ្ឍនភាពនៃដំណើរការកសាងនីតិរដ្ឋ និងការលើកកម្ពស់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា (គ) រក្សាសិទ្ធិអធិបតេយ្យរបស់ខ្លួនក្នុងការសម្រេចជ្រើសរើសមធ្យោបាយអភិវឌ្ឍសមត្ថភាពការពារជាតិរបស់ខ្លួន គោរពរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋ ដោយមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅកម្ពុជា និងដាច់ខាតមិនដោះដូរអធិបតេយ្យជាមួយជំនួយបរទេស

- **ទី២** ចងក្រងនិងផ្សព្វផ្សាយនៅក្នុងសហគមន៍អន្តរជាតិ នូវឯកសារសំខាន់ចំនួនពីរ To Tell the Truth (I & II) និង Cambodia Human Rights Situations( I II & III) ពីស្ថានភាពពិតប្រាកដនៅកម្ពុជា និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅក្នុងការពង្រឹងនិងអនុវត្តនីតិរដ្ឋ និងការលើកកម្ពស់ស្ថានភាពសិទ្ធិមនុស្សនិងប្រជាធិបតេយ្យនៅកម្ពុជា

- **ទី៣** បានចូលរួមអនុវត្តសេចក្តីសម្រេចចិត្តដ៏ខ្ពង់ខ្ពស់ប្រកបដោយមនុស្សធម៌របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការអនុញ្ញាតឱ្យនាវាទេសចរណ៍ Westerdam ចូលចតនៅកម្ពុជា និងក្នុងការផ្តល់ជំនួយជាថវិកា វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងគ្រឿងបរិក្ខារវេជ្ជសាស្ត្រ ដល់ប្រទេសឡាវ មីយ៉ាន់ម៉ា ទីម័រខាងកើត វៀតណាម និងនេប៉ាល់

- **ទី៤** គូសបញ្ជាក់និងក្រើនរំលឹកពីអាណត្តិរបស់អ្នករាយការណ៍ពិសេសអ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដោយដាច់ខាតត្រូវអនុវត្តការងារប្រកបដោយវិជ្ជាជីវៈ គណនេយ្យភាព និងទំនួលខុសត្រូវ ដើម្បីជានាបាននូវសហប្រតិបត្តិការដែលមានប្រសិទ្ធភាពក្នុងការលើកកម្ពស់សិទ្ធិមនុស្ស។

### ១.២- ការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស

ការរីករាលដាលនៃជំងឺកូវីដ-១៩នៅដើមឆ្នាំ២០២០ គួបផ្សំនឹងសកម្មភាពជួញដូរមនុស្សដែលកើតមាននៅក្នុងតំបន់និងពិភពលោក បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុវត្ថិភាព សុខមាលភាពនិងសន្តិសុខរបស់ពលរដ្ឋខ្មែរនៅបរទេស។ ស្ថានតំណាងកម្ពុជានៅបរទេសបានបង្កើនការយកចិត្តទុកដាក់ទ្វេដង ដោយសហការជាមួយសមត្ថកិច្ចរដ្ឋម្ចាស់ផ្ទះ និងអង្គការសិទ្ធិមនុស្សនានា ដើម្បីផ្តល់ការជួយឧបត្ថម្ភ និងជួយសម្រួលដោះស្រាយបញ្ហាលំបាកនានាដែលបងប្អូនប្រជាពលរដ្ឋជួបប្រទះ រួមទាំងការធ្វើមាតុភូមិនិវត្តន៍។ រហូតមកដល់ពេលនេះ ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរដែលរងគ្រោះដោយសារបញ្ហាផ្សេងៗ មានដូចខាងក្រោម៖

| ល.រ. | ឆ្នាំ | ប្រុស | ស្រី | សរុប |
|---|---|---|---|---|
| ១ | ២០១៧ | ---- | ---- | ៩៨៦ នាក់ |
| ២ | ២០១៨ | ---- | ---- | ៨ ៤៨៩ នាក់ |
| ៣ | ២០១៩ | ២១ ៦៧២ នាក់ | ១៦ ៨០១ នាក់ | ៣៨ ៤៧៣ នាក់ |
| ៤ | ២០២០ | ៦ ៥៦៤ នាក់ | ៥ ៤១៧ នាក់ | ១១ ៩៨១ នាក់ |
| ៥ | ២០២១ (គិតត្រឹមខែតុលា) | ២ ៩៩៨ នាក់ | ២ ៣៥៤ នាក់ | ៥ ៣៥២ នាក់ |

## ២- ការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ

សប្បុរសជនក្នុងនិងក្រៅប្រទេស ដែលបានចូលរួមថវិកានិងសម្ភារៈក្នុងការកសាងអភិវឌ្ឍមូលដ្ឋានលើគ្រប់វិស័យទាំងផ្នែកអាណាចក្រនិងពុទ្ធចក្រ កសាងរចនាសម្ព័ន្ធនានា ដូចជាផ្លូវ ស្ពាន ប្រព័ន្ធលូទឹក ប្រព័ន្ធទឹកស្អាត ជារាសាស្ត្រទំនប់ប្រឡាយ មន្ទីរពេទ្យ មណ្ឌលសុខភាព កសាងអន្តេវាសិកដ្ឋាន អគារសិក្សា សាលារៀនគ្រប់កម្រិត មណ្ឌលកុមារកំព្រា វត្តអារាម ព្រះវិហារ កុដិ សាលាបាលី សាលាឆាន់ វិហារអ៊ិស្លាម សារ៉ាវ។ល។

| បរិយាយ | ប្រាក់ដុល្លារអាម៉េរិក | ប្រាក់រៀល |
|---|---|---|
| ២០១៧ | ១៩ ៥១៤ ៩២៦ | ៨៨៨ ៧០០ ០០០ |
| ២០១៨ | ១៣ ៩២៩ ១០១ | ២៧១ ១១១ ១០០ |
| ២០១៩ | ១៦ ៧០៩ ០២៩ | ១៩១ ៥០០ ០០០ |
| ២០២០ | ១៨៤ ២០១ ១៩៩,៥០ | គ្មាន |
| ២០២១ | ៧០ ០២៧ ៧៦៨ | គ្មាន |

ដើម្បីសំដែងការដឹងគុណចំពោះសប្បុរសជនក្នុងនិងក្រៅប្រទេស រាជរដ្ឋាភិបាលបានក្រាបបង្គំស្នើសុំព្រះរាជក្រឹត្យនិងចេញអនុក្រឹត្យបំពាក់គ្រឿងឥស្សរិយយសជាបន្តបន្ទាប់មាន៖

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ព្រះរាជក្រឹត្យ(ឯកតា : គិតជាគ្រឿង) | | | | | |
| ព្រះរាជាណាចក្រកម្ពុជា | ៦ ៩៦៥ | ១១ ៩៤៤ | ៨ ៣៤៤ | ៥ ២២៩ | ៣ ២៩៥ |
| ព្រះមហាក្សត្រីយានី | ១៥១ | ៤២៣ | ៧៣ | ០ | ១០ |
| ការពារជាតិ | ៩០ ៨៩១ | ២២០ | ៦ ៣៩៦ | ២៤ | ៦ ៧៨៤ |
| សហាមេត្រី | ៦៧ | ៨៥ | ១១៥ | ៥៦ | ៧ |
| សុវត្ថារា | ៦៦៣ | ៨១៨ | ២៤៣ | ១៩៧ | ១៧៨ |
| មុនីសារាភណ្ឌ | ១ ០១៨ | ១ ១៩៧ | ១ ០៤១ | ៩៤៨ | ៣៤៩ |
| ជាតូបការ | ២៧៧ | ៣៧៣ | ១៤៧ | ១៣១ | ៣៥ |
| សេនាជ័យសិទ្ធ | ២៥៤ | ៣២៤ | ៨៧ | ៨៨ | ៤១ |
| ឯករាជ្យជាតិ | ១ | ០ | ២ | ០ | ០ |
| ឧកញ៉ា | ឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ ចំនួន ២៨៨ | | | | |
| អនុក្រឹត្យ (ឯកតា : គិតជាគ្រឿង) | | | | | |
| សហាមេត្រី | ៣០១ | ២០៦ | ៣៧៧ | ១៧៦ | ៦០ |
| សុវត្ថារា | ២ ៣៥៨ | ១ ២៨៥ | ១ ០៧៩ | ៧៣៨ | ៦១៣ |
| មុនីសារាភណ្ឌ | ៣ ៤៨៤ | ៣ ៨៨៥ | ៤ ៩៤៥ | ១ ៦៧៩ | ៤០៩ |
| ស្ថាបនាជាតិ | ២ ៧០២ | ២ ០៣៥ | ៣ ២០៥ | ២ ២៧៧ | ៧០៧ |

| | | | | | |
|---|---|---|---|---|---|
| ការងារ | ៣១ ១៨៥ | ១៦ ៧៩៩ | ២៦ ៧១៩ | ២៩ ៧៥៨ | ៧ ១៧០ |
| ស្ត្រីវង្វេងនា | ០ | ០ | ៦៥ | ១០៧ | ០ |

## ៣- ការងារសង្គមស៊ីវិល

### ៣.១- ការចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ

គិតត្រឹមខែកក្កដា ឆ្នាំ២០២១ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ សរុបមានចំនួន៥ ៨៥៣(សមាគម២ ៤៤០ អង្គការមិនមែនរដ្ឋាភិបាល៣ ៤១៣)។ កត់សម្គាល់: ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ក្រសួងបានសម្រេចចុះឈ្មោះក្នុងបញ្ជីនូវសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ចំនួន១ ០៩៩(សមាគម៦៣២ អង្គការមិនមែនរដ្ឋាភិបាល៤៦៧) និងលុបឈ្មោះចេញពីបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១៣១(សមាគម៣២ អង្គការមិនមែនរដ្ឋាភិបាល៩៩)។

### ៣.២- ការចុះឈ្មោះក្នុងបញ្ជីនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

កម្ពុជាមានឆន្ទៈក្នុងការបង្កើនបរិយាកាសសុខដុមនីយកម្មចំពោះកិច្ចសហប្រតិបត្តិការ ដោយបើកចំហនិងស្វាគមន៍ ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេសនានា(FNGOs) តាមរយៈ (ក) ការបន្តសុពលភាពMOU ដល់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអ.ស.ប. ប្រចាំនៅកម្ពុជាចំនួន៣លើក សម្រាប់រយៈពេល៦ឆ្នាំ (២០១៧-២០២២) (ខ) រៀបចំកិច្ចពិគ្រោះយោបល់ចំនួន២លើកក្នុងឆ្នាំ២០១៩ និង២០២០ រវាងរាជរដ្ឋាភិបាលកម្ពុជា និងFNGOs ចំនួនជាង២០០ និង(គ) ផ្តល់ភាពស្របច្បាប់ដល់ FNGOs ឱ្យប្រតិបត្តិការការងារនៅកម្ពុជា ដូចខាងក្រោម៖

| ល.រ. | FNGOs | FNGOs ចុះបញ្ជីថ្មី | FNGOs បន្ត MOU | សរុប |
|---|---|---|---|---|
| ១ | ឆ្នាំ ២០១៧ | ៥៨អង្គការ | ៣៤២អង្គការ | ៤០០អង្គការ |
| ២ | ឆ្នាំ ២០១៨ | ៦៥អង្គការ | ៣២១អង្គការ | ៣៨៦អង្គការ |
| ៣ | ឆ្នាំ ២០១៩ | ៨៥អង្គការ | ៣២៩អង្គការ | ៤១៤អង្គការ |
| ៤ | ឆ្នាំ ២០២០ | ៤៣អង្គការ | ៣១៤អង្គការ | ៣៥៧អង្គការ |
| ៥ | ឆ្នាំ ២០២១ (គិតត្រឹមខែតុលា) | ៣៨ អង្គការ | ២៩២អង្គការ | ៣៣០អង្គការ |

## ៤- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា.)

ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ និងអនុវត្តគោលការណ៍ស្តីពីភាពជាដៃគូស្របតាមបរិការណ៍កម្ពុជា ព្រមទាំងអនុវត្តការប្តេជ្ញា និងបទដ្ឋានសកលនានាសម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានសម្រេចជោគជ័យក្នុងការកៀរគរតម្រង់ទិស និងគ្រប់គ្រងធនធានសហប្រតិបត្តិការ អភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រអាទិភាពអភិវឌ្ឍន៍ជាតិ។

### ការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រអាទិភាពជាតិ

តាមរយៈការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ និងដោយឈរលើគោលការណ៍ភាពជាម្ចាស់ និងភាពជាដៃគូប្រកបដោយបរិយាបន្ន គ.ជ.នា./ក.អ.ក. បាននិងកំពុងបន្តអនុវត្តដោយជោគជ័យក្នុងការតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយអាទិភាពជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ជាក់ស្តែង ចាប់ពីឆ្នាំ២០១៧-២០២១ គ.ជ.នា./ក.អ.ក. បានកៀរគរហិរញ្ញប្បទានសរុបប្រមាណ

៩ ៤០១លានដុល្លារអាម៉េរិក ក្នុងនោះវិស័យហេដ្ឋារចនាសម្ព័ន្ធទទួលបានហិរញ្ញប្បទាន ច្រើនជាងគេទំហំ៣៥% នៃហិរញ្ញប្បទានសរុប វិស័យសង្គមកិច្ច២៩% វិស័យសេដ្ឋកិច្ច២០% និងអន្តរវិស័យ១៥%។ ជាការកត់សម្គាល់ ក្នុងឆ្នាំ២០២០ ទំហំហិរញ្ញប្បទានបានកើនដល់២ ៤២៩លានដុល្លារអាម៉េរិក ដោយសារការបើកផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងគាំទ្រការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ពីប្រទេសជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី និងសាធារណរដ្ឋប្រជាមានិតចិន។

**ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ (លានដុល្លារអាម៉េរិក)**

| វិស័យ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ ប៉ាន់ស្មាន | ២០២១ ព្យាករណ៍ | សរុប |
|---|---|---|---|---|---|---|
| វិស័យសង្គមកិច្ច | ៤៣៥,៥ | ៥០៨ | ៥៥២,១ | ៦១០,១ | ៥៧១,៩ | ២ ៧១៧,៦ |
| វិស័យសេដ្ឋកិច្ច | ៣២៩,៦ | ៣១៤,១ | ៤៤៩,២ | ៣២៩ | ៤៨១,៣ | ១ ៩០៣,៣ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធ | ៥១២,១ | ៤៧៩,៥ | ៧៦៨,១ | ៧៩៣,១ | ៧៣៩,៩ | ៣ ២៩២,៧ |
| អន្តរវិស័យ | ១៦៥,២ | ១៩០,៦ | ១៨៦,៨ | ៦៨៧,៤ | ១៦៤,៥ | ១ ៣៩៤,៥ |
| ផ្សេងៗ | ៣៩,៨ | ៥,៨ | ២៤,៧ | ៨,៨ | ១៣,៥ | ៩២,៦ |
| **សរុបរួម** | **១ ៥២២,២** | **១ ៤៩៧,៩** | **១ ៩៨១** | **២ ៤២៨,៥** | **១ ៩៧១,១** | **៩ ៤០០,៧** |

គ.ជ.នា./ក.អ.ក. ក៏បានពង្រឹងយន្តការភាពជាដៃគូ តាមរយៈការអនុវត្តសេចក្តីណែនាំស្តីពីឧបករណ៍ និងយន្តការកិច្ចពិគ្រោះយោបល់ភាពជាដៃគូ ដោយបានបន្តដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗ បន្តពង្រឹងយន្តការក្រុមការងារបច្ចេកទេសចម្រុះ និងយន្តការកិច្ចពិគ្រោះយោបល់ដទៃទៀតនៅកម្រិតវិស័យ និងនៅថ្នាក់ក្រោមជាតិប្រកបដោយជោគជ័យ។ លើសពីនេះក៏បានពង្រឹងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការឱ្យកាន់តែមានសុក្រឹតភាពតាមរយៈការកែសម្រួលប្រព័ន្ធទិន្នន័យ ការធ្វើបច្ចុប្បន្នភាព និងសុពលភាពទិន្នន័យជាប្រចាំ ដើម្បីតាមដានលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ។ ជាលទ្ធផល តាមរយៈការពង្រឹង និងការអនុវត្តយន្តការភាពជាដៃគូខាងលើចាប់ពីឆ្នាំ២០១៧-២០២១ ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានសរុបចំនួន៩ ៤០០,៧ លានដុល្លារអាម៉េរិក សម្រាប់គាំទ្រអាទិភាពអភិវឌ្ឍន៍ជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម។

**ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារអាម៉េរិក)**

| ដៃគូអភិវឌ្ឍន៍ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ ប៉ាន់ស្មាន | ២០២១ ព្យាករណ៍ | សរុប |
|---|---|---|---|---|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី | ១២៥,៧ | ១២២,៨ | ២៣៩,៨ | ៤៤០,៣ | ២៥៩,៣ | ១១៨៨ |
| ធនាគារពិភពលោក | ២១,១ | ៣០,៥៣ | ៧៩,៥ | ៧៦,៧ | ១៦០,៣ | ៣៦៨,៣ |
| ភ្នាក់ងារអង្គការសហប្រជាជាតិ | ៥៩,៣ | ៦២,៧ | ៦១,៧ | ៥៨,២ | ៩១,៩ | ៣៣៤,១ |
| សហភាពអឺរ៉ុប | ៥០,៧ | ៨៨,៨ | ៦៥,៧ | ៨៨,៧ | ១១០,៦ | ៤០៤,៧ |
| សាធារណរដ្ឋប្រជាមានិតចិន | ៤១៥,៧ | ៣៥២ | ៥០៣,៦ | ៤៩១,៨ | ៣២០ | ២ ០៨៣,៤ |
| ជប៉ុន | ១៤៦,៣ | ១៧៥,៤ | ២០៧,៦ | ៥៨០,៦ | ៣៦១,៤ | ១ ៤៧១,៥ |
| បារាំង | ៩០,៧ | ៨០,៦ | ១៩៥,២ | ៨៦,១ | ៧៨ | ៥៣០,៨ |
| សហរដ្ឋអាម៉េរិក | ៩៣,១ | ៩១,៧ | ៩៧,៣ | ៩៨,៤ | ៨៦,៣ | ៤៦៧ |
| សាធារណរដ្ឋកូរ៉េ | ៥៧,១ | ៥៣,៨ | ៧២,៨ | ១០៣,២ | ១១៦,៨ | ៤០៣,៩ |
| អូស្ត្រាលី | ៥៨,២ | ៥០ | ៤០ | ៣០,៥ | ២៥,២ | ២០៥ |
| ដៃគូដទៃទៀត | ៤០៣,៧ | ៣៨៩,២ | ៤១៦,៤ | ៣៧៣,៦ | ៣៦០,៩ | ១ ៩៤៤ |
| **សរុប** | **១ ៥២២,២** | **១ ៤៩៧,៩** | **១ ៩៨១** | **២ ៤២៨,៥** | **១ ៩៧១,១** | **៩ ៤០០,៧** |

**សូចនាករតាមដានរួមគ្នា**

រាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តសូចនាករតាមដានរួមគ្នា ឆ្នាំ២០១៤-២០១៨ និងឆ្នាំ២០១៩-២០២៣ ដើម្បីតម្រង់ទិសសកម្មភាពការងារកិច្ចសហប្រតិបត្តិការ លើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍ និងធានាគណនេយ្យភាពទ្វេទិស។ គ.ជ.នា./ក.អ.ក. បានតាមដាន និងពិនិត្យវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ឆ្នាំ២០១៤-២០១៨ និងឆ្នាំ២០១៩-២០២០ និងសម្របសម្រួលរវាងក្រុមការងារបច្ចេកទេសចម្រុះទាំង២១ និងដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំបញ្ជីសូចនាករតាមដានរួមគ្នាថ្មី សម្រាប់ឆ្នាំ២០២១-២០២៣។ របាយការណ៍វឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២០ បង្ហាញថា ក្នុងចំណោមលទ្ធផលក្នុងឆ្នាំ(Output) ទាំង៦៦ សម្រេចបាន៦៦,៨% (ក្នុងនោះ ៥០%សម្រេចបានទាំងស្រុង និង៥០%ទៀត សម្រេចបាន២/៣ ធៀបនឹងគោលដៅកំណត់)។

**ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា**

គ.ជ.នា/ក.អ.ក បានកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីគាំទ្រការងារអាទិភាព និងវិធានការគន្លឹះនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា(IDP)។ ដៃគូអភិវឌ្ឍន៍សំខាន់ៗដែលបានផ្តល់ការគាំទ្ររួមមាន សាធារណរដ្ឋប្រជាមានិតចិន ជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី បារាំង និងអូស្ត្រាលី។ ចាប់ពីឆ្នាំ ២០១៧-២០២១ ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រការអនុវត្តIDP ចំនួន១ ៣៣២,៥លានដុល្លារអាម៉េរិក ក្នុងនោះ ហិរញ្ញប្បទានទំហំ៩១៧,៦លានដុល្លារអាម៉េរិក បានគាំទ្រវិធានការគន្លឹះបួននៃគោលនយោបាយនេះ។

**ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (លានដុល្លារអាម៉េរិក)**

| វិធានការគោលនយោបាយ និងវិធានការគន្លឹះបួនដាក់ស្តែង | ២០១៧ | ២០១៨ | ២០១៩ | ២០២០ ប៉ាន់ស្មាន | ២០២១ ព្យាករណ៍ | សរុប |
|---|---|---|---|---|---|---|
| ការជំរុញការវិនិយោគ | ១,៨ | ២,៣ | ៤៧,៦ | ១៨,៥ | ៦៥,៥ | ១៣៥,៧ |
| ការពង្រីកសហគ្រាសធុនតូច និងមធ្យម | ៣,៦ | ៣,៩ | ៧,៣ | ៧ | ១៣ | ៣៤,៨ |
| ការកែលម្អបរិយាកាសនិយ័តកម្ម | ២៥,៩ | ៩,២ | ៨,៣ | ៥,២ | ៨,៧ | ៥៧,៣ |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | ២៨,២ | ២៩,៣ | ៣១,៤ | ៥០,១ | ៤៨,១ | ១៨៧,១ |
| វិធានការគន្លឹះបួនដាក់ស្តែង | ១៦២,០ | ១០៤,៨ | ២០១,៩ | ២៦៦ | ១៨២,៩ | ៩១៧,៦ |
| សរុប | **២២១,៥** | **១៤៩,៥** | **២៩៦,៥** | **៣៤៦,៨** | **៣១៨,២** | **១ ៣៣២,៥** |

**ហិរញ្ញប្បទានគាំទ្រការឆ្លើយតបនឹងវិបត្តិនៃជំងឺកូវីដ-១៩**

ក្នុងកិច្ចគាំទ្ររាជរដ្ឋាភិបាលលើការឆ្លើយតបនឹងវិបត្តិនៃជំងឺកូវីដ-១៩ គ.ជ.នា./ក.អ.ក. បានសម្របសម្រួលយន្តការភាពជាដៃគូ ដើម្បីកៀរគរហិរញ្ញប្បទានគាំទ្រទាំងការឆ្លើយតបបន្ទាន់ (Emergency Response) និងការស្តារសង្គម សេដ្ឋកិច្ច(Socio-economic Recovery)។ យោងតាមទិន្នន័យបង្ហាញថា ពីឆ្នាំ២០២០-២០២១ ហិរញ្ញប្បទានចំនួន១៣៦លានដុល្លារអាម៉េរិក ព្រមទាំងវ៉ាក់សាំង ឧបករណ៍ និងសម្ភារៈបរិក្ខារវេជ្ជសាស្ត្រ ត្រូវបានគាំទ្រដល់ការឆ្លើយតបបន្ទាន់ពាក់ព័ន្ធនឹងវិស័យសុខាភិបាល និងហិរញ្ញប្បទានចំនួន៦៨២លានដុល្លារអាម៉េរិក ត្រូវបានបើកផ្តល់ដល់ការស្តារសង្គម សេដ្ឋកិច្ច។

## ទី៤- ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

ការបោះបង់ចោលនូវប្រព័ន្ធផ្អែកលើច្បាប់របស់មហាអំណាចខ្លះ និងស្រវាយកការអនុវត្តប្រព័ន្ធផ្អែកលើអំណាច ការសឹករិចរិលកាន់តែខ្លាំងនៃពហុភាគីនិយម ការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ និងការប្រកួត-

ប្រជែងរវាងមហាអំណាចកាន់តែខ្លាំង បានធ្វើឱ្យសភាពការណ៍ពិភពលោកមានការវិវឌ្ឍស្មុគស្មាញ និងពិបាកប៉ាន់ស្មាន។ ទោះបីជាយ៉ាងនេះក្តី កម្ពុជានៅតែបន្តពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយប្រទេសនានា ក្រោមយន្តការទ្វេភាគី និងពហុភាគី ដែលជាលទ្ធផលសង្ខេប មានដូចតទៅ៖

**១- ទំនាក់ទំនងទ្វេភាគី**

គិតត្រឹមឆ្នាំ២០២១នេះ កម្ពុជាបានបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសចំនួន១៧៥។ ដោយឡែកក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ(២០១៧-២០២១) កម្ពុជាបានភ្ជាប់ទំនាក់ទំនងការទូតជាមួយប្រទេសចំនួន៤ទៀតគឺ Republic of the Marshall Islands បុរីក្សត្រម៉ូណាកូ កោះបាបាដុស និងអ៊ូហ្គង់ដា(Uganda)។ ទន្ទឹមនេះ កម្ពុជាមានស្ថានបេសកកម្មនៅបរទេសសរុបចំនួន៦៦ ហើយស្ថានបេសកកម្មបរទេស ដែលមាននិវេសនដ្ឋាននៅកម្ពុជា មានចំនួន៥៥ នៅពេលបច្ចុប្បន្ននេះ។

**តារាងស្ថានបេសកកម្មកម្ពុជានៅបរទេស និងស្ថានបេសកកម្មបរទេសប្រចាំកម្ពុជា**

| ស្ថានបេសកកម្ម | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ |
|---|---|---|---|---|---|
| ស្ថានទូត/ស្ថានបេសកកម្ម កម្ពុជា នៅបរទេស | ២៨ | ៣០ | ៣១ | ៣១ | ៣១ |
| ស្ថានអគ្គកុងស៊ុលកម្ពុជា | ១០ | ១០ | ១១ | ១២ | ១២ |
| កុងស៊ុលកិត្តិយសកម្ពុជា | ១៩ | ១៩ | ២១ | ២២ | ២៣ |
| **សរុប** | **៥៧** | **៥៩** | **៦៣** | **៦៥** | **៦៦** |
| ស្ថានទូត/ស្ថានបេសកកម្ម បរទេស នៅកម្ពុជា | ៣០ | ៣០ | ៣២ | ៣២ | ៣២ |
| ស្ថានអគ្គកុងស៊ុលបរទេស | ៣ | ៣ | ៣ | ៣ | ៣ |
| ការិយាល័យកុងស៊ុល | ៤ | ៤ | ៤ | ៤ | ៤ |
| កុងស៊ុលកិត្តិយសបរទេស | ១០ | ១០ | ១០ | ១២ | ១៦ |
| **សរុប** | **៤៧** | **៤៧** | **៤៩** | **៥១** | **៥៥** |

ក្នុងរយៈពេល៥ឆ្នាំនេះ បើទោះជាមានការរីករាលដាលជំងឺកូវីដ-១៩ខ្លាំងនៅក្នុងឆ្នាំ២០២០និង២០២១ យ៉ាងណាក៏ដោយ កម្ពុជាបានបន្តរឹតចំណងមិត្តភាពនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយប្រទេសជាច្រើន តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចនិងជំនួបសន្ទនាតាមទូរសព្ទ និងប្រព័ន្ធវីដេអូរវាងថ្នាក់ដឹកនាំកម្ពុជា និងថ្នាក់ដឹកនាំប្រទេសជាមិត្តដែលមានជាអាទិ៍ សាធារណរដ្ឋកូរ៉េ ចិន ជប៉ុន វៀតណាម ថៃ នេប៉ាល់ មីយ៉ាន់ម៉ា ស្រីលង្កា ឡាវ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី ឥណ្ឌា ហុងគ្រី និងអាម៉េរិក។ល។ ឯកសារកិច្ចព្រមព្រៀងប្រមាណ១៤៥ ត្រូវបានចុះហត្ថលេខាសំដៅពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យនយោបាយ សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងវប្បធម៌។ល។ ជាការគួរឱ្យកត់សម្គាល់ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា ចិន និងកម្ពុជា សាធារណរដ្ឋកូរ៉េ ក៏ត្រូវបានចុះហត្ថលេខាផងដែរ។ សកម្មភាពការទូតទ្វេភាគីលេចធ្លោមានដូចខាងក្រោម៖

**ក- កម្ពុជា ចិន**: ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរមានភាពកាន់តែសកម្ម និងមានផ្លែផ្កាគួរឱ្យកត់សម្គាល់ស្របតាមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនិងរឹងមាំដូចដែកថែប។ ក្នុងរយៈពេល៥ឆ្នាំនេះ ដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជា ទៅប្រទេសចិនមានដូចតទៅនេះ៖

**១- ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

- បានយាងទៅបំពេញព្រះរាជទស្សនកិច្ចចំនួន៤លើក និងបានយាងចូលរួម«**វេទិកាអរិយធម៌អាស៊ីលើកទី១**»(ឆ្នាំ២០១៩)

- បានទទួលគ្រឿងឥស្សរិយយស«**មិត្តភាពនៃសាធារណរដ្ឋប្រជាមានិតចិន**» ពីឯកឧត្តមប្រធានាធិបតីចិនផងដែរ(ឆ្នាំ២០២០)

**២- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការចំនួន៤លើក និងបានចូលរួម«**វេទិកាខ្សែក្រវ៉ាត់ និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ**» ចំនួន២(ឆ្នាំ២០១៧ និងឆ្នាំ២០១៩)។ ក្នុងឱកាសទស្សនកិច្ចនោះ កម្ពុជា និងចិនបានចុះហត្ថលេខាលើឯកសារកិច្ចព្រមព្រៀងប្រមាណ៦១ លើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ហិរញ្ញវត្ថុ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទេសចរណ៍ បរិស្ថានសមុទ្រ អគ្គិសនី ហិរញ្ញប្បទានឥតសំណង ឥណទានសម្បទាន ទូរគមនាគមន៍ វេជ្ជសាស្ត្រ ការដោះមីន បរិក្ខារពេទ្យប្រយុទ្ធនឹងជំងឺរាតត្បាតនិងមូលនិធិពិសេសមេគង្គ-ឡានឆាង។

**៣**- ទស្សនកិច្ចផ្លូវការរបស់**ឯកឧត្តម វ៉ាង យី**(Wang Yi) ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិននៅព្រះរាជាណាចក្រកម្ពុជា(២០២០ និង២០២១)

- ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសទាំងពីរកម្ពុជា ចិន និងលើឯកសារសំខាន់ចំនួន៦ ក្នុងវិស័យការបោសសម្អាតមីន និងបរិក្ខាប្រយុទ្ធប្រឆាំងជំងឺរាតត្បាត កិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពីមន្ទីរពេទ្យដៃគូ ការផ្តល់ហិរញ្ញប្បទានឥតសំណង និងមូលនិធិពិសេសមេគង្គ-ឡានឆាង។ ជាមួយគ្នានេះ រដ្ឋាភិបាលចិនបានផ្តល់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ដល់កម្ពុជាប្រមាណ ២៦,៨លានដូស រួមទាំងគ្រឿងបរិក្ខារពេទ្យផ្សេងៗទៀត។

**៤- កម្ពុជា វៀតណាម**: ទំនាក់ទំនងកម្ពុជា វៀតណាម មានភាពរឹងមាំ និងរីកចម្រើនលើគ្រប់វិស័យ។ ឆ្នាំ២០១៧ ជាខួបលើកទី៥០ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា វៀតណាម។

**១- ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

- បានយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសវៀតណាម នៅក្នុងឆ្នាំ២០១៨។

**២- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការចំនួន២លើក ក្នុងឆ្នាំ២០១៨ និង២០១៩ និងបានធ្វើជាសាក្សីនៃពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងចំនួន១៥ លើវិស័យដឹកជញ្ជូន អប់រំ ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហកម្ម វិនិយោគ ការតភ្ជាប់ និងកិច្ចការព្រំដែន

- ពីឆ្នាំ២០១៧ ដល់២០២១កម្ពុជាបានធ្វើជាសហប្រធានរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា វៀតណាម ចំនួន៥លើក។ ជំនួបតាមប្រព័ន្ធវីដេអូ និងទូរសព្ទរវាង **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជា

មួយឯកឧត្តម Nguyen Xuan Phuc ជាប្រធានរដ្ឋវៀតណាម និងឯកឧត្តម Pham Minh Chinh ជានាយករដ្ឋមន្ត្រីវៀតណាម ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០២០ និង២០២១ ដើម្បីអបអរសាទរការឡើងកាន់តំណែងថ្មីរបស់ថ្នាក់ដឹកនាំវៀតណាមទាំងពីរ និងពិភាក្សាអំពីបញ្ហាពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគី

- ភាគីទាំងពីរក៏បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នយោបាយកម្ពុជា វៀតណាមលើកទី៧ តាមប្រព័ន្ធវីដេអូ ដោយបានកត់សម្គាល់ថា ទោះជាមានបញ្ហាប្រឈមនានាបណ្តាលមកពីជំងឺកូវីដ-១៩ ទំនាក់ទំនងជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនៅតែបន្តរីកលូតលាស់លើគ្រប់វិស័យ។

**គ- កម្ពុជា ឡាវ**: កម្ពុជានិងឡាវនៅរក្សាបានទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងល្អប្រសើរ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- បានអញ្ជើញទៅបំពេញទស្សនកិច្ចការងារ និងផ្លូវការ(ឆ្នាំ២០១៧ និង២០១៨) ដើម្បីបន្តលើកកម្ពស់ទំនាក់ទំនងភាតរភាព និងភាពជាអ្នកជិតខាងល្អ

- ឯកឧត្តម **ប៊ុនញ៉ាំង វ៉ូរ៉ាជិត** (Bounnhang Vorachith) ប្រធានរដ្ឋឡាវបានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋចំនួន០២លើកនៅកម្ពុជា(ឆ្នាំ២០១៧ និង២០២០)។ កិច្ចពិភាក្សាបានផ្តោតលើការប្រើប្រាស់ផ្លូវទឹក ផ្លូវគោក កំពង់ផែកម្ពុជា វិស័យអប់រំ ពាណិជ្ជកម្ម គ្រឿងញៀន ការកាប់ឈើខុសច្បាប់ និងការកំណត់ព្រំដែន

- **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបសន្ទនាតាមប្រព័ន្ធវីដេអូ(ឆ្នាំ២០២១) ដើម្បីសម្តែងអំណរសាទរជូនចំពោះឯកឧត្តម **ផនខាំ វីផាវ៉ាន់**(Phankham Viphavanh) ដែលត្រូវបានបោះឆ្នោតជ្រើសតាំងជានាយករដ្ឋមន្ត្រីឡាវថ្មី និងបានពិភាក្សាឯកភាពគ្នាពន្លឿនការបញ្ចប់សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ភាពជាដៃគូ និងការចរចាលើ«កិច្ចព្រមព្រៀងការចៀសយកពន្ធត្រួតគ្នា» ដើម្បីជំរុញការវិនិយោគទ្វេភាគី។

**ឃ- កម្ពុជា ថៃ**: ទំនាក់ទំនងកម្ពុជា ថៃ បានផ្តល់ផ្លែផ្កាល្អប្រសើរគួរឱ្យកត់សម្គាល់ ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម។

**១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

បានជួបពិភាក្សាសន្ទនាតាមប្រព័ន្ធវីដេអូ ជាមួយសមភាគីថៃ(ឆ្នាំ២០២០)។ នៅក្នុងឆ្នាំដដែលនេះមានការប្រារព្ធខួបលើកទី៧០ នៃទំនាក់ទំនងការទូតកម្ពុជា ថៃ។

**២- នាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូចា**(Prayut Chan-o-cha)

បំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា(ឆ្នាំ២០១៧) និងធ្វើជាសហប្រធាននៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះកម្ពុជា ថៃ លើកទី៣។ ភាគីទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការចៀសយកពន្ធត្រួតគ្នានិងការបន្លំប្រាក់ចំណូល ដើម្បីរួមចំណែកដល់ការជំរុញកំណើនពាណិជ្ជកម្មទ្វេភាគី

**៣- ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

បានជួបពិភាក្សាការងារជាមួយឯកឧត្តម **ដន ប្រាម៉ាត់វីណៃ** (Don Pramudwinai) ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសថៃ(ឆ្នាំ២០២១) ក្នុងឱកាសចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសពិសេសអាស៊ាន ចិន និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គឡានឆាងលើកទី៦ នៅទីក្រុងឆុងឈីង ដោយភាគីទាំងពីរបានគូសបញ្ជាក់

ពីសារៈសំខាន់នៃកិច្ចសហការរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងកិច្ចសហការនៅតាមតំបន់ព្រំដែនរវាងប្រទេសទាំងពីរ។

**ង- កម្ពុជា ជប៉ុន**: ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការល្អប្រសើរកម្ពុជា ជប៉ុន មានការរីកចម្រើនប្រកបដោយផ្លែផ្កាឥតឈប់ឈរ។

**១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅជប៉ុន(ឆ្នាំ២០១៧) និងបានធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារចំនួន២ ពាក់ព័ន្ធនឹងហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន

- នៅឆ្នាំ២០១៩ បានអញ្ជើញធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើលិខិតប្តូរសារស្តីពីជំនួយឥតសំណងសម្រាប់គម្រោងសាងសង់ស្ថានីយកុងតឺន័រនៅក្រុងព្រះសីហនុ និងគម្រោងអភិវឌ្ឍន៍ធនធានមនុស្ស។

**២- ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

នៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ២០២១ បានចុះហត្ថលេខាលើលិខិតប្តូរសារចំនួន៤ ជាមួយភាគីជប៉ុនគឺ (១) ការផ្តល់ហិរញ្ញប្បទានឥតសំណងរបស់ជប៉ុន ដើម្បីអនុវត្ត«**គម្រោងអភិវឌ្ឍន៍ចរាចរណ៍នាវានៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ**» (២) គម្រោង«**អាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស**» ដែលមានទឹកប្រាក់ចំនួន ៣៦២លានយ៉េន(ប្រមាណ៣,៣១លានដុល្លារអាម៉េរិក) (៣) ការផ្តល់ឥណទានសម្បទានសម្រាប់ការអនុវត្តគម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតខេត្តសៀមរាប និង(៤) ហិរញ្ញប្បទានឥតសំណងលើគម្រោងចំនួន៥គឺ ផែនការបោសសម្អាតមីន គម្រោងសម្ភារៈបច្ចេកទេសសម្រាប់មន្ទីរពិសោធន៍ជាតិសំណង់ និងសម្រាប់ស្ថានីយវាស់វែងអចិន្ត្រៃយ៍ គម្រោងបំពាក់ឧបករណ៍សម្ភារៈសម្រាប់គ្រឹះស្ថានអប់រំ និងសម្រាប់ឧស្សាហកម្មគ្រឿងយន្តនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ច- កម្ពុជា សាធារណរដ្ឋកូរ៉េ**: ក្នុងឆ្នាំ២០១៧ ភាគីទាំងពីរបានប្រារព្ធខួបលើកទី២០នៃការបង្កើតទំនាក់ទំនង ការទូតរវាងប្រទេសទាំងពីរ ដោយមានការសម្តែងសិល្បៈរួមគ្នាផងដែរ។

**១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

នៅក្នុងឱកាសកិច្ចប្រជុំកំពូលពិភពលោកក្រោមប្រធានបទស្តីពី«**សន្តិភាព សន្តិសុខ និងការអភិវឌ្ឍមនុស្ស**» (ឆ្នាំ២០២០) បានជួបជាមួយឯឧត្តមប្រធានាធិបតី **មូន ចេអ៊ិន**(Moon Jae-in) ដែលនៅក្នុងឱកាសនោះ ភាគីទាំងពីរបានឯកភាពគ្នាជំរុញការចរចាដើម្បីឈានទៅរកការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេរីកម្ពុជា កូរ៉េ។

**២- ប្រធានាធិបតីសាធារណរដ្ឋកូរ៉េ មូន ចេអ៊ិន**

បានមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា(២០១៩)ដែលនៅក្នុងឱកាសនោះមានកិច្ចព្រមព្រៀងចំនួន៧ ពាក់ព័ន្ធនឹងការវិនិយោគ ការផ្តល់ឥណទាន និងថាមពល ត្រូវបានចុះហត្ថលេខា។

**៣- ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

-នៅក្នុងឱកាសចូលរួមកិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំកំពូលមេគង្គ-កូរ៉េ លើកទី១ នៅប៊ូសាន (ឆ្នាំ២០១៩) បានជួបពិភាក្សា ជាមួយលោកជំទាវ **កាង ក្យុងវ៉ា**

(Kang Kyung-wha) រដ្ឋមន្ត្រីការបរទេសកូរ៉េ ដែលនៅក្នុងឱកាសនោះ ភាគីទាំងពីរបានចុះហត្ថលេខាលើឯកសារចំនួន៥ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ កសិកម្ម ពាណិជ្ជកម្ម ទូរគមនាគមន៍ និងពន្ធគយ

- ក្នុងឆ្នាំ២០២១ នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស **មេគង្គ-សាធារណរដ្ឋកូរ៉េ** បានជួបពិភាក្សាជាមួយឯកឧត្តម **ឆុង អ៊ើយយ៉ុង**(Chung Eui-yong) រដ្ឋមន្ត្រីការបរទេសកូរ៉េ ដែលនៅក្នុងឱកាសនោះ ភាគីទាំងពីរមានសុទិដ្ឋិនិយមចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា សាធារណរដ្ឋកូរ៉េ ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២៦ ខែតុលា។

**ឆ- កម្ពុជា តួកគី**

**១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

បានអញ្ជើញទៅបំពេញទស្សនកិច្ចនៅតួកគី ក្នុងឆ្នាំ២០១៨(២០-២២តុលា) ដែលនៅក្នុងឱកាសនោះ **សម្តេចតេជោ** បានសម្រេចឱ្យបើកស្ថានទូតកម្ពុជាប្រចាំតួកគី ហើយកិច្ចព្រមព្រៀងចំនួន៩ ត្រូវបានចុះហត្ថលេខា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ សេដ្ឋកិច្ច កសិកម្ម វប្បធម៌ បោសសម្អាតមីន អប់រំ កីឡា ធនធានទឹក និងការការពារវិនិយោគ។

**២- ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

- បានអញ្ជើញទៅបំពេញទស្សនកិច្ចនៅតួកគី(១-៣ តុលា ឆ្នាំ២០១៨) ដោយភាគីទាំងពីរសម្រេចបាន (១) ពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យវិនិយោគ ពាណិជ្ជកម្ម ការហោះហើរត្រង់ ទេសចរណ៍ អប់រំ កីឡា វប្បធម៌ (២) ជំរុញកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានការទូតទាំងពីរ (៣) ឯកភាពពីតម្រូវការចាំបាច់ឱ្យមានគំនិតផ្តួចផ្តើមច្បាស់លាស់ដើម្បីពង្រីកទំហំពាណិជ្ជកម្មឱ្យដល់៥០០លានដុល្លារអាម៉េរិកនាពេលខាងមុខ និង(៤) ឯកភាពរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី២។

## ២- ទំនាក់ទំនងពហុភាគី

ដើម្បីលើកកម្ពស់ផលប្រយោជន៍និងកិត្យានុភាពជាតិ កម្ពុជាបានចូលរួមយ៉ាងសកម្ម ជាមួយប្រទេសនានា ក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ដូចខាងក្រោម៖

**ក- អង្គការសហប្រជាជាតិ**

- កម្ពុជាបានបំពេញតួនាទីយ៉ាងសកម្ម ជាអនុប្រធានមហាសន្និបាត អ.ស.ប. លើកទី៧៣(ខែកញ្ញា ឆ្នាំ២០១៨-ខែកញ្ញា ឆ្នាំ២០១៩) ប្រធានក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (ប្តូរវេនតាមខែ) និងជាសមាជិកនៃបណ្តាញសុវត្ថិភាពអាស៊ីប៉ាស៊ីហ្វិក នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧

- កម្ពុជាបានចូលរួមជាCo-Sponsor លើសេចក្តីព្រាងសេចក្តីសម្រេច និងសេចក្តីថ្លែងការណ៍នយោបាយមួយចំនួនពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពប្រឆាំងនឹងជំងឺកូវីដ-១៩ ការទទួលបានវ៉ាក់សាំងកូវីដ-១៩ ប្រកបដោយសមធម៌ និងការអភិវឌ្ឍសេដ្ឋកិច្ច។

**ខ- អាស៊ាននិងដៃគូសន្ទនា**

- កម្ពុជាបានធ្វើការងារយ៉ាងសកម្មជាមួយប្រទេសសមាជិកទាំងអស់ ដើម្បីសម្រេចឱ្យបាននូវគោលដៅអាស៊ាន ជាសហគមន៍តែមួយដោយផ្អែកលើវិធានច្បាប់ និងមជ្ឈភាពអាស៊ាន តាមរយៈការចូលរួមកិច្ចប្រជុំអាស៊ាននៅគ្រប់កម្រិត ការអនុម័តឯកសារទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ ប៉ាស៊ីហ្វិក និងការកសាងឯកសារផ្សេងៗ

ដូចជាផែនការសកម្មភាពថ្មីរវាងអាស៊ាន និងប្រទេសដៃគូ(កាណាដា ចិន ឥណ្ឌា សាធារណរដ្ឋកូរ៉េ រុស្ស៊ី អាម៉េរិក និងអ.ស.ប.) ផែនការការងារសមាហរណកម្មអាស៊ានដំណាក់កាលទី៤«**ការព្រមព្រៀងជាឯកច្ឆន្ទលើ៥ចំណុច**» ស្តីពីបញ្ហាមីយ៉ាន់ម៉ា និងឯកសារពាក់ព័ន្ធនឹងការកសាងសសរស្តម្ភសហគមន៍អាស៊ានទាំងបី

- ជំរុញទំនាក់ទំនងរវាងអាស៊ាន និងដៃគូសន្ទនា ជាពិសេសកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ជំងឺរាតត្បាតកូវីដ-១៩ តាមរយៈការផ្តល់វិភាគទាន១០ម៉ឺនដុល្លារអាម៉េរិក ទៅក្នុងមូលនិធិអាស៊ានសម្រាប់ឆ្លើយតបនឹងជំងឺកូវីដ-១៩

- កម្ពុជាក៏បានរួមចំណែកជំរុញផងដែរ (១) ឱ្យមានកិច្ចប្រជុំកំពូលអាស៊ាន អូស្ត្រាលីប្រចាំឆ្នាំជាទៀងទាត់ ចាប់ពីឆ្នាំ២០២១ (២) បារាំង និងអ៊ីតាលីធ្វើជាដៃគូអភិវឌ្ឍន៍ និង(៣) ទំនាក់ទំនងអាស៊ាន សហភាពអឺរ៉ុប ទៅជាដៃគូយុទ្ធសាស្ត្រ

- កម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកម្មវិធីល្បងប្រាជ្ញាពិសេសស្តីពីអាស៊ាន សិក្ខាសាលា/កម្មវិធីស្តីពីការលើកកម្ពស់វិស័យទេសចរណ៍ សារព័ត៌មាន និងទូរទស្សន៍ វេទិកាសហគ្រិនវ័យក្មេងអាស៊ានបូកបី អ្នកស្ម័គ្រចិត្តអាស៊ីបូព៌ា កិច្ចប្រជុំក្រុមការងារស្តីពីការអនុវត្តDOC ការអនុវត្តផែនការទី៣នៃIAI ការផ្សព្វផ្សាយស្តីពី JAIF វេទិកាសហគ្រិនវ័យក្មេងអាស៊ាន-ចិនសិក្ខាសាលាស្តីពីការចូលរួមរបស់ វិស័យសាធារណៈនិងឯកជនអាស៊ាន-សាធារណរដ្ឋកូរ៉េ សិក្ខាសាលាស្តីពីការផ្លាស់ប្តូរទស្សនកិច្ចយុវជនអាស៊ាន សាធារណរដ្ឋកូរ៉េ សិក្ខាសាលាស្តីពីតួនាទីរបស់យុវជនអាស៊ាន-ចិន ក្នុងកិច្ចសហប្រតិបត្តិការនៅសមុទ្រចិនខាងត្បូង នៅឆ្នាំ២០១៧

- ក្នុងនាមជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សាធារណរដ្ឋកូរ៉េ(២០១៥-២០១៨) ដៃគូសន្ទនាអាស៊ាន-នូវែលសេឡង់(២០១៨-២០២១) ដៃគូសន្ទនាASEAN-Gulf Cooperation Council (២០២០) និងដៃគូសន្ទនាអាស៊ាន អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច(២០២១) កម្ពុជាបានខិតខំសម្របសម្រួល និងធ្វើឱ្យសម្រេចបាន៖

- ការឯកភាពឱ្យមានកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ នៅខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ
- កុងសង់ស៊ីសក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-នូវែលសេឡង់ នៅខែមេសា ឆ្នាំ២០២០ នៅវៀតណាម។ការធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន-នូវែលសេឡង់ តាមប្រព័ន្ធ វីដេអូ នៅខែសីហា ឆ្នាំ២០២១ព្រមទាំងដឹកនាំកិច្ចប្រជុំតាក់តែងផែនការសកម្មភាពអាស៊ាន-នូវែលសេឡង់(២០២១-២០២៥) និងសេចក្តីប្រកាសទស្សនវិស័យរួមរបស់ថ្នាក់ដឹកនាំអាស៊ាន-នូវែលសេឡង់
- ជាសហប្រធានដឹកនាំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេសក្រុមប្រទេសសម្ព័ន្ធប៉ាស៊ីហ្វិកលើកទី៦ ជាមួយឈីលី នៅទីក្រុងញូវយ៉ក ឆ្នាំ២០១៩
- កម្ពុជាក៏បានជំរុញឱ្យមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP) ដើម្បីរក្សាទីផ្សារបើកចំហ និងបានត្រៀមលក្ខណៈទទួលធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២២នេះ។

**គ- កិច្ចសហប្រតិបត្តិការក្នុងតំបន់មេគង្គ** កម្ពុជាបានចូលរួមលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងតំបន់មេគង្គយ៉ាងសកម្មតាមរយៈ៖

- **កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង** បានបង្កើតលេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នាឆ្នាំ២០១៧ និងបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-

ឡានឆាងលើកទី២ក្រោមមូលបទ «**ទន្លេរបស់យើងដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព**» ក្នុងឆ្នាំ២០១៨ នៅទីក្រុងភ្នំពេញ ដោយបានអនុម័តឯកសារសំខាន់ចំនួន២ គឺសេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញ និងផែនការសកម្មភាព៥ឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង(ឆ្នាំ ២០១៨-២០២២)។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមូលនិធិពិសេសសម្រាប់គម្រោងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ២០១៧ សម្រាប់ការអនុវត្តក្នុងវិស័យអភិវឌ្ឍន៍ជនបទ កសិកម្ម និងធនធានទឹកជាដើម

- **កិច្ចសហប្រតិបត្តិការមេគង្គ សាធារណរដ្ឋកូរ៉េ** បានគាំទ្រសំណើតម្លើងកម្រិតកិច្ចសហប្រតិបត្តិការមេគង្គ សាធារណរដ្ឋកូរ៉េ ឱ្យទៅជា«**ភាពជាដៃគូយុទ្ធសាស្ត្រ**» ដែលស្របទៅនឹងគំនិតផ្តួចផ្តើមរបស់**សម្តេចតេជោ** កាលពីឆ្នាំ២០១៩ ក្នុងការតម្លើងកម្រិតនៃយន្តការកិច្ចប្រជុំមេគង្គ សាធារណរដ្ឋកូរ៉េ ទៅដល់កម្រិតកិច្ចប្រជុំកំពូល

- **កិច្ចសហប្រតិបត្តិការមេគង្គ ជប៉ុន** បានគាំទ្រសំណើលើកកម្ពស់ភាពជាដៃគូរវាងជប៉ុនជាមួយប្រទេសមេគង្គដល់កម្រិតជាដៃគូយុទ្ធសាស្ត្រនៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ ជប៉ុន ព្រមទាំងស្វាគមន៍យ៉ាងកក់ក្តៅចំពោះគំនិតផ្តួចផ្តើមរបស់ជប៉ុន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា

- **កិច្ចសហប្រតិបត្តិការមេគង្គ គង្គា** កម្ពុជាទទួលបាន«**គម្រោងទទួលបានផលឆាប់រហ័ស**» (Quick Impact Project) សម្រាប់ឆ្នាំ២០១៧-២០១៨ ចំនួន៤គម្រោង(២០ម៉ឺនដុល្លារអាមេរិក)

- **កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី ចៅប្រាយ៉ា មេគង្គ (ACMECS)** កម្ពុជាបានដឹកនាំកិច្ចប្រជុំកំពូល ACMECS លើកទី៩ ក្រោមមូលបទ«**ភាពជាដៃគូដើម្បីការតភ្ជាប់និងភាពរឹងមាំ**» និងបានអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញ។ ក្នុងនាមជាប្រធានក្របខ័ណ្ឌយុទ្ធសាស្ត្រACMECS កម្ពុជាក៏បានសម្របសម្រួលក្នុងការជំរុញការអនុវត្តសកម្មភាពផែនការមេACMECS ឆ្នាំ២០១៩-២០២៣

- **កិច្ចប្រជុំកំពូលអាស៊ី អឺរ៉ុប**(ASEM) កម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី អឺរ៉ុប លើកទី១៣ ដោយជោគជ័យ តាមប្រព័ន្ធវីដេអូ នៅថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានការចូលរួមពីថ្នាក់ដឹកនាំមកពី៥០ប្រទេសនិងស្ថាប័ន។ កិច្ចប្រជុំនេះ បានអនុម័តនូវឯកសារសំខាន់ៗចំនួន៣ គឺ(១) សេចក្តីថ្លែងការណ៍ប្រធានអង្គប្រជុំ ASEM13 (២) សេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញស្តីពីការស្តារសង្គម សេដ្ឋកិច្ចឡើងវិញក្រោយជំងឺកូវីដ១៩ និង(៣) ឯកសារសកម្មភាពអនាគតស្តីពីការតភ្ជាប់ASEM

- **វេទិកាសភាអាស៊ី ប៉ាស៊ីហ្វិក** កម្ពុជាបានធ្វើជាម្ចាស់ផ្ទះ**វេទិកាសភាអាស៊ី ប៉ាស៊ីហ្វិក** លើកទី២៧ និង**កិច្ចប្រជុំកំពូលអាស៊ី ប៉ាស៊ីហ្វិក**លើកទី២

- **អង្គការហ្វ្រង់កូហ្វូន** ក្នុងឆ្នាំ២០២១ ក្រសួងបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការអន្តរជាតិហ្វ្រង់កូហ្វូន(OIF)ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការផ្សព្វផ្សាយអំពីបេសកកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មហ្វ្រង់កូហ្វូនីនៅកម្ពុជា ដែលគ្រោងនឹងប្រព្រឹត្តទៅនាត្រីមាសទី១ ឆ្នាំ២០២២។ ក្នុងនាមជាប្រធាននៃ Réseau des structures et institutions membres de l'OIF en Asie-Pacifique កម្ពុជាបានចេញផ្សាយអត្ថបទអំពីប្រយោជន៍រួមនៃប្រទេសសមាជិកOIF នៅតំបន់អាស៊ី ប៉ាស៊ីហ្វិក នៅក្នុងព្រឹត្តិបត្រ Le Courrier du RESIFAP ចំនួន៣លើក តាមអនឡាញ និងបានផ្សព្វផ្សាយនៅតាមស្ថានតំណាងកម្ពុជា និងបណ្តាស្ថាប័នហ្វ្រង់កូហ្វូនីនៅកម្ពុជា និងបរទេស។ ទន្ទឹមនេះ ក្រសួងក៏បានរៀបចំមហាសន្និបាតលើកទី២ និងទី៣ នៃក្រុមប្រឹក្សាលើកកម្ពស់ការប្រើប្រាស់ភាសាបារាំង នៅទីក្រុងភ្នំពេញ

- **ធនាគារអភិវឌ្ឍន៍អាស៊ី** កម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការដែលមានទឹកប្រាក់សរុបចំនួនប្រមាណ២១៣លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៧ សម្រាប់អនុវត្តគម្រោងចំនួន៨ ក្នុងវិស័យកែលម្អហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ហិរញ្ញវត្ថុ អប់រំ ការទប់ស្កាត់និងបង្ការជំងឺឆ្លង និងគម្រោងផ្គត់ផ្គង់ទឹកស្អាត។

## ៣- ការអនុវត្តការងារការទូត សេដ្ឋកិច្ច និងវប្បធម៌

- កម្ពុជាបាននិងកំពុងជំរុញយុទ្ធសាស្ត្រការទូតអាទិភាពថ្មីមួយ សំដៅប្រែក្លាយការទូតប្រពៃណីទៅជាការទូតដែលផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។ នៅក្នុងទិសដៅនេះ ក្រសួងបានដាក់ឱ្យអនុវត្តជាផ្លូវការនូវ«**យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច២០២១-២០២៣**» ដែលជាផែនទីតម្រង់ទិសដំបូងក្នុងការអនុវត្តការងារការទូតសេដ្ឋកិច្ច នៅឆ្នាំ២០២១។ ជាមួយគ្នានេះដែរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានទទួលជួបសម្តែងការគួរសមជាមួយសមាគមសហគ្រិនវ័យក្មេងកម្ពុជា កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ដែលក្នុងឱកាសនោះ ឯកឧត្តមបានផ្តល់អនុសាសន៍ឱ្យសមាគមនេះផ្សារភ្ជាប់ទំនាក់ទំនងជាមួយស្ថានតំណាងកម្ពុជា ដើម្បីងាយស្រួលចាប់យកកាលានុវត្តភាពធុរកិច្ចពីកិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងៗ

- នៅឆ្នាំ២០១៩ ក្រសួងបានសហការជាមួយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ និងជប៉ុន រៀបចំដំណើរទស្សនកិច្ចរបស់អង្គទូត និងពាណិជ្ជករនៅថៃ និងជប៉ុន មកកម្ពុជា ដើម្បីស្វែងយល់ពីកាលានុវត្តភាពសេដ្ឋកិច្ច និងវិនិយោគរបស់កម្ពុជា ហើយនៅថ្ងៃទី១៥កញ្ញាឆ្នាំ២០២១ ក្រសួងបានសហការជាមួយស្ថានទូតកម្ពុជាប្រចាំតួកគី រៀបចំវេទិកាជំនួបធុរកិច្ចកម្ពុជា តួកគី តាមប្រព័ន្ធវីដេអូផងដែរ

- ស្ថានតំណាងកម្ពុជានៅបរទេសបាននិងកំពុងប្រតិបត្តិជាតួអង្គជួរមុខក្នុងការស្វែងរកផលប្រយោជន៍សេដ្ឋកិច្ច តាមរយៈជំនួបពិភាក្សាជាមួយតំណាងក្រុមហ៊ុនសហគ្រាសបរទេស និងអាជ្ញាធររដ្ឋម្ចាស់ផ្ទះ ក្នុងគោលបំណងផ្សព្វផ្សាយកៀរគរវិនិយោគទុននិងភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា

- ស្ថានតំណាងកម្ពុជា ក៏បានខិតខំការពារផលប្រយោជន៍ពាណិជ្ជកម្មជាតិ តាមរយៈកិច្ចអន្តរាគមន៍ជាច្រើនលើកទប់ស្កាត់ការលួចបន្លំស្លាកសញ្ញាកម្ពុជាខុសច្បាប់ ពីសំណាក់ទំនិញបរទេសមួយចំនួន

- ក្នុងឆ្នាំ២០១៨ ក្រសួងបានសហការជាមួយស្ថានទូតបារាំង និងជប៉ុនប្រចាំកម្ពុជា ព្រមទាំងអង្គការ UNESCO រៀបចំខួបទី២៥នៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ( ICC-Angkor ) ដែលជាការបង្ហាញនូវភាពជោគជ័យក្នុងការការពារ និងអភិរក្សបេតិកភណ្ឌពិភពលោករបស់កម្ពុជា

- នៅឆ្នាំ២០២១ ក្រសួងបានរៀបចំចងក្រងសៀវភៅម្ហូបខ្មែរ ដែលមានចំណងជើងថា«**គេហដំណែលស្នាដៃម្ហូបខ្មែរ The Taste of Angkor**» និងបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយលើឆាកអន្តរជាតិ។ ជាមោទនភាពជាតិកម្ពុជា សៀវភៅមុខម្ហូបនេះ បានទទួលជ័យលាភីជា«**សៀវភៅមុខម្ហូបអាស៊ីដែលល្អផ្តាច់គេ**» ក្នុងចំណោមសៀវភៅមុខម្ហូបចំនួន៤ ០០០ក្បាល មកពី១៩៨ប្រទេស នៅក្នុងការប្រកួតសៀវភៅមុខម្ហូបកម្រិតពិភពលោក Gourmand World Cookbook Award 2021 កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១

- ស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ នៅឆ្នាំ២០២១ បានបើកសម្ពោធគម្រោង«**កម្មវិធីអប់រំភាសា សីលធម៌ និងសុជីវធម៌ខ្មែរសម្រាប់កុមារ**» ជាលើកដំបូងនៅទីក្រុងសុងណាំ។

- គណៈប្រតិភូអចិន្ត្រៃយ៍ប្រចាំUNESCO បានសម្របសម្រួលដាក់បញ្ចូលរមណីយដ្ឋានប្រាសាទសម្បូរព្រៃគុកនៅឆ្នាំ២០១៧ និងល្ខោនខោលចូលជាបេតិកភណ្ឌមនុស្សជាតិនៅឆ្នាំ២០១៨ និងកំពុងសម្របសម្រួលដាក់បញ្ចូលក្បាច់គុនល្បុក្កតោខ្មែរក្នុងបញ្ជីធ្នើមបេតិកភណ្ឌអរូបីយបន្តទៀត

- ស្ថានបេសកកម្មកម្ពុជាប្រចាំអាម៉េរិក និងអ.ស.ប.(ញូវយ៉ក) បានសម្របសម្រួលក្នុងការទទួលនិងបញ្ជូនរូបចម្លាក់បុរាណខ្មែរចំនួន២៧អង្គ ត្រឡប់មកមាតុប្រទេសវិញ។ ក្រៅពីនេះ កម្ពុជាបានដាក់បេក្ខភាពជាសមាជិកនៃគណៈកម្មាធិការបេតិកភណ្ឌអរូបិយសម្រាប់អាណត្តិ២០២២-២០២៦ ដែលនឹងត្រូវបោះឆ្នោតនៅឆ្នាំ២០២២ខាងមុខ ដែលគិតត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ មានប្រទេសចំនួន៦៩ បានសន្យាបោះឆ្នោតគាំទ្រកម្ពុជា។

## ៤- ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងដំណោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក

- កម្ពុជាមានមោទនភាពដែលបានប្រែក្លាយពីប្រទេសទទួលកងកម្លាំងរក្សាសន្តិភាពអ.ស.ប. ទៅជាប្រទេសផ្តត់ផ្គង់កងកម្លាំងនេះដល់អ.ស.ប.

- កម្ពុជាបានចុះហត្ថលេខា (១) លើកិច្ចព្រមព្រៀងរវាងកម្ពុជា និង អង្គការហាមប្រាមអាវុធគីមី (OPCW) ស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិអង្គការនេះ នៅឆ្នាំ២០១៧ (២) ជាមួយអគ្គលេខាធិកា អ.ស.ប. លើកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្តស្តីពីការទប់ស្កាត់និងដោះស្រាយបញ្ហាកេងប្រវ័ញ្ច និងបំពានផ្លូវភេទ នៅឆ្នាំ២០១៨ (៣) លើកិច្ចព្រមព្រៀងហាមឃាត់អាវុធនុយក្លេអ៊ែរ នៅឆ្នាំ២០១៩

- កម្ពុជាបានធ្វើជាសហប្រធានជាមួយប្រទេសចិនរៀបចំកិច្ចប្រជុំអ្នកជំនាញថែរក្សាសន្តិភាពលើកទី៧ និងសន្និសីទវេទិកាតំបន់អាស៊ាន ស្តីពីការកសាងសមត្ថភាពសន្តិសុខនុយក្លេអ៊ែរតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅឆ្នាំ២០១៩

- នៅក្នុងកម្រិតតំបន់ កម្ពុជាក្នុងនាមជាប្រទេសនាំមុខក្នុងការបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន(ARMAC) កាលពីឆ្នាំ២០១៩ បានសម្របសម្រួលរៀបចំសិក្ខាសាលាប្រចាំតំបន់ស្តីពី «**ប្រតិបត្តិការពេញលេញនិងមានប្រសិទ្ធភាព ការលើកកម្ពស់កិច្ចប្រឹងប្រែងតំបន់ក្នុងការដោះស្រាយបញ្ហាសំណល់ជាតិផ្ទុះសង្គ្រាម តាមរយៈវិធីសាស្ត្រចម្រុះ**» ដោយបានពិភាក្សាអំពីការចូលរួមយ៉ាងសកម្មរបស់ប្រទេសសមាជិកឆ្ពោះទៅរកការលុបបំបាត់សំណល់ជាតិផ្ទុះពីសង្គ្រាម

- ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) កម្ពុជាបានចូលជាសមាជិកក្នុងស្ថាប័នអ.ស.ប. និងអន្តរជាតិមួយចំនួន រួមមាន(១) គណៈកម្មាធិការសម្រាប់ការពារសម្បត្តិវប្បធម៌គ្រាមានជម្លោះប្រដាប់អាវុធ ស្តីពីអនុសញ្ញាទីក្រុងឡាអេ១ ៩៥៤ (២) ក្រុមប្រឹក្សាប្រតិបត្តិកម្មវិធីអភិវឌ្ឍន៍អ.ស.ប. មូលនិធិអ.ស.ប. សម្រាប់ប្រជាជន និងការិយាល័យអ.ស.ប. សម្រាប់សេវាកម្មគម្រោង (៣) សមាជិកសហការក្នុងសកម្មភាពក្រុមការងារស្រាវជ្រាវ និងព័ត៌មានស្តីពីសន្តិភាពនិងសន្តិសុខនៃស្ថាប័នសង្កេតការណ៍ប្រតិបត្តិថែរក្សាសន្តិភាពប៊ុត្រូសហ្គាលី (៤) ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអ.ស.ប. សម្រាប់អាណត្តិ២០១៩ (៥) អ្នកជំនាញស្តង់ដារគណនេយ្យ និងការធ្វើរបាយការណ៍ (៦) ក្រុមប្រឹក្សាភិបាល មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ដើម្បីការអភិវឌ្ឍអាស៊ីប៉ាស៊ីហ្វិក (IPCICT) និង(៧) ក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសម្រាប់អភិវឌ្ឍន៍ការគ្រប់គ្រងព័ត៌មានគ្រោះមហន្តរាយអាស៊ី ប៉ាស៊ីហ្វិក(APDIM)

- បច្ចុប្បន្ននេះ កម្ពុជាបាននិងកំពុងស្វែងរកការគាំទ្រជាសមាជិកស្ថាប័នអ.ស.ប. ចំនួន២ទៀត រួមមាន (១) គណៈកម្មាធិការគ្រប់គ្រងនៃគណៈកម្មការកសាងសន្តិភាពអ.ស.ប. សម្រាប់អាណត្តិ២០២៥-២០២៦ និង(២) ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម សម្រាប់អាណត្តិ ២០២៨-២០៣០។

## ៥- ការចូលរួមរបស់កងយោធពលខេមរភូមិន្ទ ក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

សហប្រតិបត្តិការអន្តរជាតិផ្នែកយោធា ត្រូវបានពង្រឹងនិងពង្រីកជាលំដាប់ទាំងនៅក្នុងនិងក្រៅតំបន់ ពិសេសជាមួយប្រទេសដៃគូលើការងារ ដូចជាកិច្ចការប្រឆាំងភេរវកម្ម សន្តិសុខលម្ហសមុទ្រ ការសង្គ្រោះគ្រោះមហន្តរាយ កិច្ចប្រតិបត្តិការរក្សាសន្តិភាព ការផ្លាស់ប្តូរទស្សនកិច្ច ចូលរួមកិច្ចប្រជុំ សិក្ខាសាលានិងការអនុវត្តសកម្មភាពការងារផ្សេងៗ ដែលកិច្ចការទាំងអស់នេះទទួលបាននូវលទ្ធផលល្អគួរជាទីមោទនៈនិងឈរលើស្មារតីគោរពគ្នាទៅវិញទៅមក។ ថ្វីបើរយៈពេល២ឆ្នាំចុងក្រោយនេះពិភពលោកជួបនឹងវិបត្តិជំងឺកូវីដ-១៩ ដែលមានរួមទាំងកម្ពុជាផងនោះ ប៉ុន្តែកងយោធពលខេមរភូមិន្ទនៅតែបន្តរក្សាកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសដៃគូពាក់ព័ន្ធទាំងដោយផ្ទាល់និងតាមប្រព័ន្ធវីដេអូអនឡាញ ប្រព័ន្ធទូរគមនាគមន៍ជាហូរហែ។ ទន្ទឹមនេះ កងយោធពលខេមរភូមិន្ទក៏បានទទួលនូវការជួយឧបត្ថម្ភផ្សេងៗពីបណ្តាប្រទេសដៃគូជាស្មារតី ថវិកា សំណង់អគារ រថយន្ត គ្រឿងចក្រគ្រប់ប្រភេទ វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ឱសថ សម្ភារៈបរិក្ខារពេទ្យ ព្រមទាំងសម្ភារៈផ្សេងៗ រួមទាំងការផ្តល់នូវអាហារូបករណ៍ដល់កងយោធពលខេមរភូមិន្ទទៅសិក្សានៅក្រៅប្រទេសផងដែរ ទាំងនេះ គឺជាសមិទ្ធផលមួយផ្នែកដែលបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍកងយោធពលខេមរភូមិន្ទសមស្របទៅនឹងដំណាក់កាលវិវត្តន៍ថ្មីៗរបស់កម្ពុជាជាបន្តបន្ទាប់។

នៅក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ក្រសួងការពារជាតិបានចាត់តាំងគណៈប្រតិភូនិងនាយទាហានទៅបំពេញទស្សនកិច្ច ចូលរួមប្រជុំ សិក្ខាសាលានិងបំពេញការងារផ្សេងៗក្រៅប្រទេសដោយផ្ទាល់និងតាមប្រព័ន្ធវីដេអូអនឡាញ ប្រព័ន្ធទូរគមនាគមន៍ចំនួន១ ៣៥៥ប្រតិភូ ក្នុងនោះគណៈប្រតិភូដឹកនាំដោយ**សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** អញ្ជើញទៅបំពេញទស្សនកិច្ចនិងចូលរួមប្រជុំផ្ទាល់១៨លើក នៅប្រទេសជប៉ុន ចិន វៀតណាម ហ្វីលីពីន ថៃ កាណាដា សិង្ហបុរី ឡាវ សហរដ្ឋអាម៉េរិកនិងតួកគី។ គណៈប្រតិភូយោធាបរទេសមកបំពេញទស្សនកិច្ច ចូលរួមប្រជុំនិងបំពេញការងារផ្សេងៗជាមួយកងយោធពលខេមរភូមិន្ទដោយផ្ទាល់និងតាមប្រព័ន្ធវីដេអូអនឡាញ ប្រព័ន្ធទូរគមនាគមន៍ចំនួន៣៣០ប្រតិភូ ក្នុងនោះគណៈប្រតិភូដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការពារជាតិឥណ្ឌា វៀតណាម ចិន ថៃ ឡាវនិងឥណ្ឌូណេស៊ី មកបំពេញទស្សនកិច្ចនិងចូលរួមប្រជុំផ្ទាល់៦លើក និងការចូលចតនាវាចម្បាំងចិន រុស្ស៊ី ជប៉ុន នូវែលសេឡង់ ឥណ្ឌា វៀតណាម ថៃ និងអូស្ត្រាលីសរុប១៧លើកស្មើនឹងនាវា២៧គ្រឿង ផងដែរ។

គិតចាប់ពីឆ្នាំ២០០៦មកដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងសរុបចំនួន៧ ៨២៦នាក់(នារី៤៩៤នាក់) ទៅបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិនៅ៩ប្រទេស(ស៊ូដង់ខាងត្បូង ស៊ូដង់ លីបង់ ម៉ាលី អាហ្វ្រិកកណ្តាល ឆាដ ស៊ីប ស៊ីរី និងយេមែន) លើជំនាញបោសសម្អាតគ្រាប់មីន កម្ទេចគ្រាប់មិនទាន់ផ្ទុះ អាវុធហត្ថ មន្ទីរពេទ្យកម្រិត២ វិស្វកម្មសំណង់ វិស្វកម្មព្រលានយន្តហោះ នាយទាហានសេនាធិការ នាយទាហានសង្កេតការណ៍។ បច្ចុប្បន្នកម្លាំងកងយោធពលខេមរភូមិន្ទដែលបាននិងកំពុងបំពេញបេសកកម្មមានចំនួន៧៨៧នាក់

(នារី១០៥នាក់)នៅ៥ប្រទេស(ស៊ូដង់ខាងត្បូង ស៊ូដង់ លីបង់ ម៉ាលីនិងអាហ្វ្រិកកណ្ដាល) ដោយមិនខ្លាចនឿយហត់ក្រោមអាកាសធាតុក្ដៅហួតហែងរហូតដល់៥៣អង្សា នៅទ្វីបអាហ្វ្រិកនិងត្រជាក់ដល់ក្រោមសូន្យអង្សានៅមជ្ឈិមបូព៌ា តំបន់ដែលត្រូវបំពេញភារកិច្ចគ្មានហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ ជាតំបន់ភ្នំ ខ្ពង់រាប ព្រមទាំងប្រឈមនឹងការគំរាមកំហែងផ្នែកសន្តិសុខ ដូចជាការវាយប្រហារអត្តឃាតពីក្រុមភេរវករ ព្យុះខ្យាច់សាហារ៉ា គ្រាប់មីន គ្រឿងផ្ទុះកែច្នៃ ជំងឺឆ្លងEbola ជំងឺគ្រុនចាញ់។ល។ ហើយកម្ពុជាបានបន្តឈរយ៉ាងរឹងមាំ រក្សាបាននូវភាពស្អាតស្អំនិងកេរ្តិ៍ឈ្មោះល្អជាប្រទេសមួយក្នុងចំណោម១៤/១២២ ប្រទេសបរិច្ចាគកងកម្លាំងដែលមិនជាប់ពាក់ព័ន្ធនឹងអំពើហិង្សានិងការជួញដូរផ្លូវភេទ រីឯការបញ្ជូនកម្លាំងនារីទទួលបានលំដាប់លេខ១៣/១២២ប្រទេសបរិច្ចាគកងកម្លាំង និងលំដាប់លេខ២ក្នុងអាស៊ាន។






ពិធីបិទសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៩ លើកទិសដៅការងារឆ្នាំ២០២០
របស់ក្រសួងមហាផ្ទៃ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២០








**ពិធីទទួលដំណើរនិវត្តន៍កងកម្លាំងវិស្វកម្មលេខ ៦៩៣ បញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋលីបង់ កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០**

## ចតុកោណយុទ្ធសាស្ត្រទី១
## ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិភាពនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ នៅគ្រប់ដំណាក់កាល ពិសេសបានក្លាយទៅជាអាទិភាពទី១ នៅដំណាក់កាលទី៣ និងទី៤នេះ សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នាវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពនិងកាយសម្បទារឹងមាំ តួនាទីស្ត្រីនិងកិច្ចគាំពារសង្គម។

### មុំទី១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

**ក្រសួងអប់រំ យុវជន និងកីឡាសម្រេចការងារបានដូចខាងក្រោម៖**

**១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស**

ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤ ដែលសម្រេចបានសមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់លើការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា ក្នុងរយៈពេល៥ឆ្នាំកន្លងមក ដូចខាងក្រោម៖

សាលារៀនគ្រប់កម្រិតសិក្សា បានកើនឡើងជាលំដាប់ ស្ទើរតែគ្រប់ទីតាំងភូមិសាស្ត្រទូទាំងប្រទេស ក្នុងគោលដៅបង្កិតសាលារៀនឱ្យទៅជិតលំនៅឋានរបស់ប្រជាជន ស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។ ជាលទ្ធផលនៅទូទាំងប្រទេសមានសាលាមត្តេយ្យសិក្សា និងសាលារៀនចំណេះទូទៅសរុប**១៧ ៩០៤** ក្នុងនោះ សាលាមត្តេយ្យសិក្សាគ្រប់រូបភាព៨ ០១២សាលា/កន្លែង សាលាបឋមសិក្សា៧ ៨៤៣ អនុវិទ្យាល័យ ១ ៣០៨ និងវិទ្យាល័យ ៧៤១។ គិតមកត្រឹមខែមីនា ឆ្នាំ២០២១ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** មាន៤ ៤៣៥ខ្នង ស្មើនឹង២៨ ២១៨បន្ទប់។

សមិទ្ធផលអប់រំសម្រេចបាន តាមរយៈអន្តរាគមន៍មួយចំនួន ដូចជាការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀន ការផ្តល់ថវិកាដំណើរការសាលារៀន ការផ្តល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ដែលបានបង្កលក្ខណៈឱ្យសិស្សានុសិស្ស និងនិស្សិតមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិត។ ជាក់ស្តែង ក្នុងឆ្នាំសិក្សា២០២០-២០២១ កុមារបានទទួលសេវាអប់រំកុមារតូច សរុប៣៣៨ ៣០៧នាក់(ស្រី១៧០ ៦៥៧នាក់) ស្មើនឹង៥០,៤%។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាពមាន១៩១ ២៨២នាក់ ស្មើនឹង៦១,១%នៃចំនួនប្រជាជនអាយុ៥ឆ្នាំ ស្រី៦២,៣% និងប្រុស ៥៨,៦%។ សិស្សបឋមសិក្សាសរុប២ ១២៨ ៧២២នាក់(ស្រី១ ០២២ ៦៣០នាក់)។ ការចូលរៀននៅបឋមសិក្សារយៈពេល៥ឆ្នាំកន្លងមក សម្រេចបានអត្រាពិតនៃការសិក្សាក្នុងរង្វង់៩៨% ហើយថយចុះមក៩១,៩% នៅឆ្នាំសិក្សា២០២០-២០២១ និងអត្រាបញ្ចប់ការសិក្សា៨៧,៤%។ សិស្សមធ្យមសិក្សាបឋមភូមិសរុប៦៦៨ ៦៣៧នាក់(ស្រី៣៥៤ ៣១៣នាក់) និងសិស្សមធ្យមសិក្សាទុតិយភូមិសរុប៣៧៦ ៦៩២នាក់(ស្រី២០៤ ៥៤៩នាក់)។ ឆ្នាំ២០២០ ចំនួនបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានកើនដល់១២១ ០៧៤នាក់(ស្រី៦៣ ៨៩០នាក់)។ សិស្សបច្ចេកទេស៣ ៣២៤នាក់(ស្រី១ ២៦៩នាក់)។

គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន១២៨ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ៤៨ និងឯកជន ៨០ ដែលមានទីតាំងស្ថិតនៅ២០រាជធានី ខេត្ត។ គ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័នមាន១៦។ និស្សិតកំពុងសិក្សានៅឧត្តមសិក្សាទាំងអស់មាន២០១ ៩០០នាក់(ស្រី១០២ ៥៩៩នាក់) ស្មើនឹង ៥០,៨%។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង១៩ ៧៨២នាក់(ស្រី១០ ២៣៩នាក់) ស្មើនឹង៥១,៧៦% ក្នុងនោះ និស្សិតអាហារូបករណ៍២ ១៩៧ នាក់(ស្រី១ ០៥៩នាក់) ស្មើនឹង៤៨,២%។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ១៧១ ១៨៣នាក់(ស្រី៩២ ២៣៧នាក់) ស្មើនឹង៥៣,៨៨% ក្នុងនោះ និស្សិតអាហារូបករណ៍២៧ ៣៩១នាក់ (ស្រី១៥ ០៥៧នាក់) ស្មើនឹង៥៤,៩៧%។ និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ១០ ៩៤៥នាក់(ស្រី ៣ ១២៣នាក់) ស្មើនឹង២៨,៥៣% ក្នុងនោះ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់៩ ៩៨៤នាក់(ស្រី៣ ០៣៥នាក់) ស្មើនឹង ៣០,៤% និងថ្នាក់បណ្ឌិត៩៦១នាក់(ស្រី៨៨នាក់) ស្មើនឹង៩,១៦%។

ក្រសួងអប់រំ យុវជន និងកីឡាមានបុគ្គលិកអប់រំគ្រប់កម្រិតទូទាំងប្រទេសសរុប១២៣ ២៥០នាក់ (ស្រី៥៧ ៣៦៣នាក់) ស្មើនឹង៤៦,៥៥% ក្នុងនោះ ថ្នាក់ជាតិ៣ ៧៨៦នាក់(ស្រី១ ០៥៧នាក់) ស្មើនឹង២៧,៩% និងថ្នាក់ក្រោមជាតិ១១៩ ៤៦៤នាក់(ស្រី៥៦ ៣០៦នាក់) ស្មើនឹង៤៧,១៣%។ គ្រូមត្តេយ្យសិក្សា៣ ៨២០នាក់ (ស្រី៣ ៧១៨នាក់) ស្មើនឹង៩៧,៣២% គ្រូបឋមសិក្សា៥៣ ២៦៣នាក់(ស្រី២៧ ៨៨២នាក់) ស្មើនឹង៥២,៣៤% គ្រូបង្រៀនកម្រិតមូលដ្ឋាន(ចំណេះទូទៅ) ចំនួន៤៣ ៥០៨នាក់(ស្រី១៨ ៨៥៥នាក់) ស្មើនឹង៤៣,៣៣% គ្រូបង្រៀនកម្រិតមូលដ្ឋាន(អប់រំកាយនិងកីឡា) ចំនួន២ ៥០៣នាក់(ស្រី៥២៥នាក់) ស្មើនឹង២១% គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ) ចំនួន១៨ ២២៤នាក់(ស្រី៥ ៩៥០នាក់) ស្មើនឹង៣២,៦៤% គ្រូបង្រៀនកម្រិតឧត្តមបម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ១ ៦៦២នាក់(ស្រី៣៩៤នាក់) ស្មើនឹង២៣,៧% អធិការបឋម៤០នាក់(ស្រី៦នាក់) ស្មើនឹង១៥% អធិការមធ្យម២៣០នាក់(ស្រី៣៣នាក់) ស្មើនឹង១៤,៣៤%។

ដើម្បីលើកកម្ពស់គុណភាពអប់រំ និងភាពឆ្លើយតប ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេច និងកំពុងអនុវត្តនូវកិច្ចការមួយចំនួន ដូចជាអនុម័តកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាគ្រប់ភូមិសិក្សា កែលម្អការបណ្តុះបណ្តាលគ្រូនិងវិក្រឹតការគ្រូបង្រៀន អភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងរៀបចំផែនការសកម្មភាព ដើម្បីអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត ពង្រីកការអនុវត្តសាលារៀនជំនាន់ថ្មីបាន១១កន្លែង ជំរុញការកែលម្អវិធីសាស្ត្របង្រៀន ជំរុញការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ ក្រសួងកំពុងសាកល្បងនិងពង្រីកការអនុវត្តការគ្រប់គ្រងសាលារៀនឆ្ពោះទៅបង្កើនគណនេយ្យភាព និងស្វ័យភាព និងការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងសាលារៀន អនុវត្តវង្វាយតម្លៃការសិក្សារបស់សិស្ស និងកែលម្អវិធីសាស្ត្របង្រៀន។

## ១.១- ការអប់រំចំណេះទូទៅនិងឧត្តមសិក្សា

| ឆ្នាំសិក្សា | ២០១៦-២០១៧ | ២០១៧-២០១៨ | ២០១៨-២០១៩ | ២០១៩-២០២០ | ២០២០-២០២១ |
|---|---|---|---|---|---|
| **មត្តេយ្យសិក្សា (រដ្ឋ)** | | | | | |
| សាលារៀន/កន្លែង | ៤ ០១៤ | ៤ ១៧៦ | ៤ ៣០១ | ៤ ៤០៩ | ៤ ៤៩៣ |
| សិស្ស (នាក់) | ១៩០ ១៤៨ | ២០៥ ៤៩២ | ២១៧ ៥០៩ | ២៣៣ ១៣២ | ២២៦ ៩៧៩ |
| គ្រូបង្រៀន (នាក់) | ៥ ០៨៤ | ៥ ៣៩៨ | ៥ ៥៥៩ | ៥ ៦៧៨ | ៥ ៧១៧ |

| | | | | | |
|---|---|---|---|---|---|
| **មត្តេយ្យសិក្សា (ឯកជន)** | | | | | |
| សាលារៀន/កន្លែង | ៣៩៣ | ៤៥៦ | ៥០៩ | ៥៩៥ | ៥១៩ |
| សិស្ស (នាក់) | ៣៨ ៤៨៩ | ៤៧ ២៥១ | ៤៨ ៣១៨ | ៥៦ ០០៤ | ៣២ ៤៤៥ |
| **បឋមសិក្សា** | | | | | |
| សាលារៀន (រដ្ឋ) | ៧ ១៤៤ | ៧ ១៨៩ | ៧ ២២៨ | ៧ ២៨២ | ៧ ៣០៤ |
| សាលារៀន (ឯកជន) | ៤១៧ | ៤៣២ | ៤៨៨ | ៥៧៤ | ៥៣៩ |
| សាលារៀន (សរុប) | ៧ ៥៦១ | ៧ ៦២១ | ៧ ៧១៦ | ៧ ៨៥៦ | ៧ ៨៤៣ |
| សិស្ស (រដ្ឋ) | ២ ០២២ ០៦១ | ២ ០២៨ ៦៩៤ | ២ ០៤០ ២៥៧ | ២ ០២៣ ៤៧៣ | ២ ០១០ ២៨៦ |
| សិស្ស (ឯកជន) | ៨៩ ៥៧០ | ១១១ ៧៩៨ | ១២២ ៨៨៦ | ១៣៧ ៦៣៧ | ១១៨ ៤៣៦ |
| សិស្ស (សរុប) | ២ ១១១ ៦៣១ | ២ ១៤០ ៤៩២ | ២ ១៦៣ ១៤៣ | ២ ១៦១ ១១០ | ២ ១២៨ ៧២២ |
| គ្រូបង្រៀន (រដ្ឋ) | ៥៧ ៨៤៤ | ៥៧ ៩១៥ | ៥៧ ៨១១ | ៥៧ ៣៤៧ | ៥៧ ៣០៤ |
| **មធ្យមសិក្សាបឋមភូមិ** | | | | | |
| អនុវិទ្យាល័យ (រដ្ឋ) | ១ ២៤៥ | ១ ២៣៧ | ១ ២៤៦ | ១ ២៤៧ | ១ ២៤៦ |
| អនុវិទ្យាល័យ (ឯកជន) | ៥៥ | ៦៦ | ៧៨ | ៨៧ | ៦២ |
| អនុវិទ្យាល័យ (សរុប) | ១ ៣០០ | ១ ៣០៣ | ១ ៣២៤ | ១ ៣៣៤ | ១ ៣០៨ |
| សិស្ស (រដ្ឋ) | ៥៨៥ ៩៧១ | ៦០៥ ១៧៣ | ៦១០ ២៦១ | ៦១៨ ៩៦៨ | ៦៣២ ៣០៣ |
| សិស្ស (ឯកជន) | ២២ ៩៨៤ | ២៥ ៩២៨ | ២៨ ៤៥១ | ៣៦ ០៨៧ | ៣៦ ៣៣៤ |
| សិស្ស (សរុប) | ៦០៨ ៩៥៥ | ៦៣១ ១០១ | ៦៣៨ ៧១២ | ៦៥៥ ០៥៥ | ៦៦៨ ៦៣៧ |
| គ្រូបង្រៀន (រដ្ឋ) | ៣៣ ៧៦៣ | ៣៣ ១៨១ | ៣៣ ៦៣៨ | ៣២ ៦២០ | ៣៣ ២៧៤ |
| **លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ** | | | | | |
| បេក្ខជនមកប្រឡង (នាក់) | ១២៥ ៩៤៥ | ១៥០ ០៩៩ | ១៥៤ ៦៧៩ | ១៦៤ ៧៥៩ | ១៤៥ ៦៦៨ |
| បេក្ខជនប្រឡងជាប់ (នាក់) | ១១៨ ០៣០ | ១៤១ ៤១០ | ១៤៤ ៣៦៥ | ១៦៤ ៧៥៩ | ១៤១ ០៥៦ |
| **មធ្យមសិក្សាទុតិយភូមិ** | | | | | |
| វិទ្យាល័យ (រដ្ឋ) | ៤៨៦ | ៥១១ | ៥២៥ | ៥៤៤ | ៥៥៤ |
| វិទ្យាល័យ (ឯកជន) | ១២២ | ១២២ | ១៤៧ | ១៧១ | ១៨៧ |
| វិទ្យាល័យ (សរុប) | ៦០៨ | ៦៣៣ | ៦៧២ | ៧១៥ | ៧៤១ |
| សិស្ស (រដ្ឋ) | ២៧៩ ៤៨០ | ៣០៣ ៨៩៣ | ៣២១ ១៤៥ | ៣៣៤ ៧១២ | ៣៥១ ៧៩៤ |
| សិស្ស (ឯកជន) | ១៧ ២៤៤ | ១៨ ១០៧ | ១៨ ៧០២ | ២៣ ៨៤១ | ២៤ ៨៩៨ |
| សិស្ស (សរុប) | ២៩៦ ៧២៤ | ៣២២ ០០០ | ៣៣៩ ៨៤៧ | ៣៥៨ ៥៥៣ | ៣៧៦ ៦៩២ |
| គ្រូបង្រៀន (រដ្ឋ) | ១៤ ៤៥៧ | ១៥ ១៧៦ | ១៥ ៧៦១ | ១៧ ៤៤២ | ១៧ ៨៧៩ |
| **លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | | | | | |
| បេក្ខជនមកប្រឡង (នាក់) | ៩៩ ៧២៨ | ១១៣ ៣៦៥ | ១១៥ ២០៦ | ១២១ ០៧៤ | ១០៩ ៦៩៥ |
| បេក្ខជនប្រឡងជាប់ (នាក់) | ៦៣ ៦៦៨ | ៧៦ ០៣៤ | ៧៩ ០៥២ | ១២១ ០៧៤ | ៧២ ០១៦ |
| **ឧត្តមសិក្សា** | | | | | |
| គ្រឹះស្ថានរដ្ឋ (១) | ៤៨ | ៤៨ | ៤៨ | ៤៨ | ៤៨ |
| គ្រឹះស្ថានឯកជន (២) | ៧៣ | ៧៣ | ៧៧ | ៧៦ | ៨០ |
| សរុប ១+២ | ១២១ | ១២១ | ១២៥ | ១២៤ | ១២៨ |
| និស្សិតបរិញ្ញាបត្ររង (នាក់) | ២៣ ៧៤៦ | ២០ ៥៧០ | ១៩ ៨៧១ | ១៩ ៥៧៥ | ១៩ ៧៨២ |
| និស្សិតបរិញ្ញាបត្រ (នាក់) | ១៧៤ ១៤២ | ១៦៥ ៣៥៩ | ១៦៨ ២៤២ | ១៧៩ ២៥៨ | ១៧១ ១៨៣ |
| និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ (នាក់) | ១៨ ៧២៣ | ២០ ២៧២ | ២២ ០២២ | ២៣ ២៥៦ | ៩ ៩៨៤ |
| និស្សិតថ្នាក់បណ្ឌិត (នាក់) | ៦៣ | ១២២ | ១ ៣៤៩ | ៧៩០ | ៩៦១ |

## ១.២- គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរនិងបរទេស

| គ្រឹះស្ថានសិក្សាឯកជនខ្មែរ និងបរទេស ឆ្នាំសិក្សា២០២០-២០២១ | | | | | |
|---|---|---|---|---|---|
| ប្រភេទសាលា/ភាសា | ខ្មែរ | ចិន | ម៉ូស្លីម | អង់គ្លេស | សរុប |
| សាលាមត្តេយ្យ | ៤០១ | ២១ | ៣ | ៨៩ | ៥១៩ |
| សាលាបឋមសិក្សា | ៤៤៤ | ២៣ | ២៤ | ៤៣ | ៥៣៩ |
| អនុវិទ្យាល័យ | ៥២ | ៧ | ១ | ២ | ៦២ |
| វិទ្យាល័យ | ១៦៨ | ០ | ៥ | ១៣ | ១៨៧ |

## ១.៣- ការអប់រំឌីជីថល

ក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតសំខាន់លើការអប់រំឌីជីថល លើការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាឌីជីថលក្នុងការរៀននិងបង្រៀន ក៏ដូចជាការគ្រប់គ្រងដែរ។ ក្រសួងបានដាក់ចេញនូវវិធានការជា៣ដំណាក់កាលចំពោះការរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិក និងការផ្តល់សេវារៀនពីចម្ងាយ ដំណាក់កាលបន្ទាន់ គឺផលិតវីដេអូបង្រៀនសម្រាប់មុខវិជ្ជាគោលនិងសម្រាប់ថ្នាក់ប្រឡង ព្រមទាំងបង្ហោះនិងផ្សព្វផ្សាយលើវេទិកាឌីជីថលដែលមានស្រាប់ ដំណាក់កាលមធ្យម គឺការលម្អវេទិកាឌីជីថលដែលមានស្រាប់ ឱ្យកាន់តែប្រសើរនិងការផលិតវីដេអូបង្រៀនចាំបាច់បន្ថែមទៀតនិងដំណាក់កាលវែង គឺការរៀបចំកែលម្អនិងអភិវឌ្ឍន៍វេទិកាឌីជីថលសម្រាប់ការផ្តល់សេវាអប់រំ តាមប្រព័ន្ធអេឡិចត្រូនិកដែលមានលក្ខណៈសមស្រប និងគ្រប់ជ្រុងជ្រោយ។

**លទ្ធផលសំខាន់ៗនៃការអប់រំឌីជីថល សម្រេចបានកន្លងមក ដូចជា៖**

ក្រសួងបានចេញសេចក្តីណែនាំស្តីពី ការលើកកម្ពស់ការបង្រៀន និងរៀនពីចម្ងាយ ឬតាមប្រព័ន្ធអេឡិចត្រូនិកដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ មាតាបិតា អាណាព្យាបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមជំរុញការអនុវត្ត និងធានាបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការបង្រៀននិងរៀន និងការវាយតម្លៃ។

ក្រសួងបានបង្កើតវេទិកាឌីជីថលចំនួន៣ ដើម្បីដំណើរការអប់រំអេឡិចត្រូនិក៖

- ✓ បណ្តាញ YouTube ផ្លូវការរបស់ក្រសួង: www.youtube.com/moeys មានវីដេអូបង្រៀនទាំងអស់សម្រាប់សិស្សអាចសិក្សាដោយខ្លួនឯងតាមពេលវេលាជាក់ស្តែង
- ✓ ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង: www.facebook.com/moeys.gov.kh ផ្សព្វផ្សាយរៀងរាល់ថ្ងៃ
- ✓ មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង: www.elearning.moeys.gov.kh សិស្សអាចចូលទៅសិក្សាតាមរយៈការជ្រើសរើសវគ្គសិក្សា ឬមេរៀនដែលត្រូវសិក្សាដោយឥតគិតថ្លៃនិងមិនចាំបាច់ចុះឈ្មោះ។

**- ក្រសួងបានផលិតវីដេអូបង្រៀនសម្រាប់សិស្សគ្រប់កម្រិត៖**

• ជាដំបូង ក្រសួងបានផលិតវីដេអូបង្រៀនសម្រាប់មុខវិជ្ជាគោលចំនួន៦ រួមមានភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យា គីមីវិទ្យា រូបវិទ្យា និងជីវវិទ្យាសម្រាប់ថ្នាក់ទី៩ និងទី១២

• ***មត្តេយ្យសិក្សា*** ផលិតបានខ្សែវីដេអូបង្រៀនសម្រាប់កុមារតូចនៅថ្នាក់មត្តេយ្យសិក្សាចំនួន៥ មុខវិជ្ជា រួមមានចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត និង ភាសាខ្មែរ

• ***បឋមសិក្សា*** ដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធី«**កុមាររៀនកុមារចេះ**» រួមមានកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាកម្រិតថ្នាក់ដំបូងនៅបឋមសិក្សា ដូចជាសៀវភៅណែនាំសម្រាប់គ្រូ និងឯកសារបង្រៀននិងរៀន ព្រមទាំងបានផលិតវីដេអូបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាសម្រាប់ថ្នាក់ទី៤ ដល់ទី៦

• ***មធ្យមសិក្សា*** ផលិតបានខ្សែវីដេអូបង្រៀនសម្រាប់ថ្នាក់ទី៧ ដល់១២ និងជំរុញឱ្យសាលារៀនផ្ដល់លទ្ធភាពឱ្យសិស្សខ្ចីសៀវភៅសិក្សាគោល ដើម្បីស្វ័យសិក្សាបន្ថែមទៀត

• ***ការអប់រំក្រៅប្រព័ន្ធ*** ដាក់ឱ្យដំណើរការកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (BEEP) ដែលជួយឱ្យយុវជនកម្ពុជាបញ្ចប់ការអប់រំមូលដ្ឋាន តាមរយៈការរៀនដោយខ្លួនឯង តាមប្រព័ន្ធពីរបញ្ចូលគ្នាដែលមានភាពបត់បែន និងទន់ភ្លន់

• ***ការអប់រំពិសេស*** ក្រសួងបានរៀបចំផ្សាយផ្ទាល់ការបង្រៀនកម្មវិធីអប់រំពហុភាសា តាមស្ថានីយវិទ្យុផ្សាយសំឡេងរបស់ខេត្តរតនគីរី និងមណ្ឌលគិរី សម្រាប់កម្រិតមត្តេយ្យសិក្សា និងបឋមសិក្សាថ្នាក់ទី១ ដល់ទី៣ ជាភាសាទំពួន និងគ្រឹងក្នុងខេត្តរតនគីរី និងជាភាសាពួងក្នុងខេត្ត មណ្ឌលគិរី

• ***ការអប់រំបច្ចេកទេស*** ក្រសួងបានណែនាំគ្រូជំនាញបច្ចេកទេសឱ្យរៀបចំមេរៀនសង្ខេប ចែកជូនសិស្ស ថតវីដេអូបង្រៀន រៀបចំការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក។ គ្រូជំនាញបានរៀបចំក្រុមសិស្សតាមជំនាញ និងតាមកម្រិតសិក្សា ដោយបានបង្កើតជាបណ្ដាញសម្រាប់ទំនាក់ទំនង ជាមួយសិស្ស និងក្លឹបសិក្សាតាមជំនាញ

• ***គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ*** វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានបង្កើតជាបណ្ដាញទំនាក់ទំនងរវាងគរុសិស្ស គរុនិស្សិតជាមួយនឹងគ្រូឧទ្ទេស។ គ្រូឧទ្ទេសអាចផ្ដល់ឯកសារមេរៀន ឬតំណភ្ជាប់ឯកសារផ្សេងៗទៅឱ្យគរុសិស្ស គរុនិស្សិត ដើម្បីអាចសិក្សាតាមពេលម៉ោងក្នុងកាលវិភាគប្រចាំថ្ងៃ។ គរុសិស្ស គរុនិស្សិត និងគ្រូឧទ្ទេសអាចពិភាក្សា ឆ្លងឆ្លើយគ្នាអំពីខ្លឹមសារមេរៀន ឬអំពីកិច្ចការគ្រូឧទ្ទេសដាក់ឱ្យធ្វើ

• ***គ្រឹះស្ថានឧត្ដមសិក្សា*** គ្រឹះស្ថានឧត្ដមសិក្សាមួយចំនួនបានរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធ អេឡិចត្រូនិក រៀបចំបន្ទប់រៀន ផលិតមេរៀន និងបង្កើតបណ្ដាញទំនាក់ទំនងសម្រាប់និស្សិតនិងសាស្ត្រាចារ្យ។

- ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងព័ត៌មានបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្ដីពីការរៀបចំផលិត និងផ្សព្វផ្សាយកម្មវិធីការសិក្សាពីចម្ងាយនិងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីជានាសេវាអប់រំមានគុណភាពប្រកបដោយសមធម៌ ជាពិសេសសិស្សនៅតំបន់ជនបទ។ មេរៀនគ្រប់មុខវិជ្ជា និងគ្រប់ថ្នាក់ត្រូវបានផ្សាយកម្មវិធីតាមប្រព័ន្ធទូរទស្សន៍ផ្កាយរណប«**តេជោជីវី**» ដែលជាប៉ុស្តិ៍ទូរទស្សន៍អប់រំថ្មី«**ទទក២**»

- ក្រសួងបានសហការជាមួយដៃគូឯកជននានា ដើម្បីធ្វើឱ្យកម្មវិធីអប់រំអេឡិចត្រូនិកកាន់តែ មានភាពសម្បូរបែប។

ដើម្បីអនុវត្តការអប់រំបែបឌីជីថលឱ្យបានកាន់តែប្រសើរ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំកម្មវិធីកំណែទម្រង់វិស័យអប់រំ ដោយដាក់ទុនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធទន់ ជាពិសេសការពង្រឹងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព(SBM) ការបង្កើតសាលាជំនាន់ថ្មី(NGS) ការធ្វើកំណែទម្រង់វិធីសាស្ត្របង្រៀន ការកែលម្អបរិស្ថានសិក្សា និងការលើកកម្ពស់ការសិក្សា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ជាដើម។

ក្នុងឆ្នាំសិក្សា២០២០-២០២១ សាលាជំនាន់ថ្មីកម្រិតមធ្យមសិក្សាមាន៧ គឺវិទ្យាល័យព្រះស៊ីសុវត្ថិ ព្រះយុគន្ធរ ហ៊ុនសែនកំពង់ចាម ហ៊ុនសែនព្រែកលៀប ជាស៊ីមព្រែកអញ្ចាញ ហ៊ុនសែនពាមជីកង និងអនុវិទ្យាល័យ

គោកព្រីង មានសិស្សសរុប៥ ០៤១នាក់(ស្រី២ ៦៩១នាក់)។ ការអនុវត្តកម្មវិធីសាលាជំនាន់ថ្មី រួមមានបង្កើតការគ្រប់គ្រងតាមបែបចម្រុះដោយមានការចូលរួមពីដៃគូពាក់ព័ន្ធ និងគណៈគ្រប់គ្រងសាលារៀន អនុវត្តកម្មវិធីសិក្សាតាមបែបទន់ភ្លន់ ដើម្បីបង្រៀនសិស្សឱ្យមានចំណេះដឹង ជំនាញបច្ចេកទេស បំណិនជីវិត ជំនាញទន់ និងមានអាកប្បកិរិយាល្អ រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូដោយបំប៉នសមត្ថភាពលើវិធីសាស្ត្របង្រៀនតាមបែបរិះរក និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀនសិស្ស រៀបចំឱ្យមានបន្ទប់ពិសោធន៍តាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់គ្រូបង្រៀន និងបណ្ណាល័យសតវត្សទី២១។ សាលារៀនជំនាន់ថ្មីបានអនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តទៅតាមបន្ទប់មុខវិជ្ជា និងពង្រឹងការបង្រៀន និងរៀនការអប់រំបំណិនជីវិត ការអប់រំ STEM ប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន បន្ទប់សង្គ្រោះបឋម និងក្លឹបសិក្សាលើមុខវិជ្ជា គណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា សារព័ត៌មាន បច្ចេកវិទ្យាព័ត៌មាន និងប្រវត្តិវិទ្យា។

និស្សិតបរិញ្ញាបត្រកំពុងសិក្សាជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) មាន៣០,៤%(ស្រី១៧,៥% និងប្រុស ៤៥,៤%)។ ជារួម៥ឆ្នាំកន្លងមក ការសិក្សាជំនាញ STEAM បានកើនពី២២% នៅឆ្នាំសិក្សា២០១៥-២០១៦ ដល់៣០,៤% នៅឆ្នាំសិក្សា២០១៩-២០២០។

## ១.៤- ការងារយុវជន អប់រំកាយ និងកីឡា

### ក- សមិទ្ធផលសំខាន់ៗនៃការងារយុវជន

**ក្រសួងអប់រំ យុវជន និងកីឡាបាន៖**

- ជំរុញចលនាប្រឡងប្រណាំង៣ល្អ«**កូនល្អ សិស្សល្អ មិត្តល្អ**» ចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិ និងបូកសរុបចលនាប្រឡងប្រណាំង៣ល្អនៅថ្នាក់រាជធានី ខេត្ត

- ធ្វើបច្ចុប្បន្នកម្ម និងជំរុញសកម្មភាពក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ឱ្យបានចូលរួមជួយការងារស្វ័យគ្រប់គ្រងសាលារៀន គាំទ្រសកម្មភាពក្លឹប ការងារស្ម័គ្រចិត្ត និងជួយបំប៉នបន្ថែមដល់សិស្សត្រៀមប្រឡងថ្នាក់ទី១២

- ដំណើរការ«**កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(BEEP)**» ដែលផ្តល់ឱកាសដល់យុវជនបោះបង់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ទទួលបានការសិក្សា និងបណ្តុះបណ្តាលជំនាញ។ បច្ចុប្បន្នមានសិស្សចូលរួម៣៥០នាក់(ស្រី៤៧,១%)

- រៀបចំសិក្ខាសាលាអក្ខរកម្មឌីជីថល មានអ្នកចូលរួម៦០០នាក់(ស្រី៥៨,៨%) និងសិក្ខាសាលាស្តីពីជំនាញទន់ មានអ្នកចូលរួម៩០នាក់(ស្រី៦១,១%)

- បណ្តុះបណ្តាលជំនាញរយៈពេលខ្លីដល់យុវជនក្រៅសាលា១ ៣៤៧នាក់(ស្រី៦១%) នៅមជ្ឈមណ្ឌលជាតិយុវជន និងរាជធានី ខេត្ត លើជំនាញរបាំសិល្បៈប្រពៃណី ភ្លេងបុរាណ តន្ត្រីសម័យ ភ្លេង ព្យុហយាត្រា សម្អាងកាយ ភាសាបរទេស តម្រង់ទិសអាជីពមគ្គុទ្ទេសក៍ទេសចរណ៍ កុំព្យូទ័រ រដ្ឋបាល រចនាតាមកុំព្យូទ័រ និងជួសជុលកុំព្យូទ័រ

- ផ្សព្វផ្សាយអប់រំស្តីពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការបង្ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ជំងឺកាមរោគ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់យុវជនកាកបាទក្រហម យុវជនកាយរឹទ្ធិ និងក្រុមប្រឹក្សាយុវជនកម្ពុជា១ ៣០០នាក់(ស្រី៦០%) នៅតាមគ្រឹះស្ថានមធ្យមសិក្សាក្នុងខេត្តស្វាយរៀង ព្រៃវែង តាកែវ កំពង់ចាម ស្ទឹងត្រែង ឧត្តរមានជ័យ មណ្ឌលគិរី ព្រះវិហារ បន្ទាយមានជ័យ និងខេត្តកោះកុង

- ផ្សព្វផ្សាយបន្តផ្ទាល់តាមទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង ស្តីពីការអប់រំចិត្តយុវជនក្នុងបរិបទកូវីដ-១៩ មានអ្នកចូលទស្សនា៥០៨ ០០០នាក់

- លើកកម្ពស់ការស្ម័គ្រចិត្ត និងការចូលរួមរបស់យុវជន តាមរយៈការបើកវគ្គបំប៉នការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ មានអ្នកចូលរួម ៥៧៨នាក់(ស្រី២៨៤នាក់) នៅរាជធានីភ្នំពេញ ខេត្តសៀមរាប រតនគិរី ពោធិ៍សាត់ និងកំពង់ស្ពឺ

- រៀបចំកម្មវិធី«**ការប្រកួតប្រជែងជជែកដេញដោលយុវជនថ្នាក់ជាតិឆ្នាំ២០២០**» មានយុវជនចូលរួមជម្រុះវគ្គ១ ចំនួន៨០នាក់(១៦ក្រុម) ស្រី៧៥,៥% វគ្គទី២ ចំនួន៤០នាក់(៨ក្រុម) វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ ចំនួន២០នាក់(៤ក្រុម) ស្រី៦២,៥% និងវគ្គផ្តាច់ព្រ័ត្រមានយុវជនចូលរួម១០នាក់(២ក្រុម) ស្រី៧៥% ដើម្បីទទួលបានជ័យលាភីពីក្រសួង

- រៀបចំកម្មវិធីការប្រកួតប្រជែងសរសេរផែនការអាជីវកម្មក្រោមប្រធានបទ អាជីវកម្មខ្ញុំ មានយុវជនចូលរួមជម្រុះវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ៩០នាក់(១៥ក្រុម) ស្រី៤៦,៧% និងវគ្គផ្តាច់ព្រ័ត្រ មានយុវជនចូលរួម៣០នាក់(ស្រី៤៣,៣%) ដើម្បីទទួលបានជ័យលាភីពីក្រសួង

- រៀបចំសិក្ខាសាលាស្តីពីការសិក្សានិងការងារ ដល់យុវជន១ ៨០០នាក់(ស្រី៤៥,០%) នៅខេត្តបាត់ដំបង កំពង់ធំបន្ទាយមានជ័យ សៀមរាប រតនគិរី និងមណ្ឌលគិរី

ធ្វើបច្ចុប្បន្នកម្មស្ថិតិសមាជិកកាយរឹទ្ធិជាតិកម្ពុជា ដែលមាន១៦៦ ១៣៥នាក់(ស្រី៤៩%) នៅឆ្នាំសិក្សា២០១៩-២០២០ ស្របជាមួយនឹងសកម្មភាពនានា ក្នុងជំរុញចលនារបស់យុវជន ក្នុងការអភិវឌ្ឍខ្លួនឯង និងការអប់រំខ្លួនឯង«**រៀនបណ្តើរ អនុវត្តបណ្តើរ**» ជាពិសេសលើការអភិវឌ្ឍប្រាជ្ញាស្មារតី និងកាយសម្បទា និងផ្តោតលើការអភិវឌ្ឍសហគមន៍ និងស្រឡាញ់ធម្មជាតិ។

### ខ- សមិទ្ធផលសំខាន់ៗនៃការងារអប់រំកាយ និងកីឡា

ក្រសួងបានរៀបចំការប្រកួតកីឡាជាតិលើកទី២ ឆ្នាំ២០១៨ ចំនួន២៧ប្រភេទកីឡា ស្មើនឹង២៦៨វិញ្ញាសា ចូលរួមដោយក្រសួង៣ និង២៥ ខេត្ត រាជធានី នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កែប និងកំពត មានប្រតិភូកីឡាករ ៤ ១៦៣នាក់(ស្រី១ ០០៤នាក់)។

#### ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ ក្នុងនិងក្រៅប្រទេស

ក្រសួងបានសហការរៀបចំការប្រកួតកីឡាលក្ខណៈអន្តរជាតិក្នុងប្រទេស ហែលទឹក ជ្រើសរើសជើងឯកយុវជនអាស៊ីអាគ្នេយ៍លើកទី៤៣ កីឡាករ៣១៥នាក់(ស្រី១៤៩នាក់) នៅពហុកីឡដ្ឋានមរតកតេជោ។ ប៉េតង់ ជ្រើសរើសជើងឯកពិភពលោកយុវជននិងស្ត្រីលើកទី១៧ ប្រទេសចូលរួម៤៩ កីឡាករ៤៣៣នាក់(ស្រី១១៥នាក់) នៅពហុកីឡដ្ឋានជាតិ ជាលទ្ធផលកម្ពុជាទទួលមេដាយមាស១គ្រឿងនិងសំរឹទ្ធ១គ្រឿង។ បាល់ទាត់វគ្គជម្រុះជម្រើសជើងឯកពិភពលោកឆ្នាំ២០២២ កាតា រវាងកម្ពុជា ប៉ាគីស្ថាននៅពហុកីឡដ្ឋានជាតិ ជាលទ្ធផលកម្ពុជាឈ្នះ២ទល់០។ កីឡាវ៉ូវីណាម ជ្រើសរើសជើងឯកពិភពលោកលើកទី៦ ប្រទេសចូលរួម២៤ កីឡាករ២៧០នាក់(ស្រី៧០នាក់) នៅពហុកីឡដ្ឋានជាតិ ជាលទ្ធផលកម្ពុជាទទួលមេដាយមាស៩គ្រឿង ប្រាក់១០គ្រឿង និងសំរឹទ្ធិ១២គ្រឿង។

ក្នុងឆ្នាំ២០១៩ កម្ពុជាបានបញ្ជូនប្រតិភូ គ្រូបង្វឹក ជំនួយការគ្រូបង្វឹក កីឡាករ ចូលរួមការប្រកួតកីឡាលក្ខណៈអន្តរជាតិ ដែលទទួលបានលទ្ធផលដូចក្នុងតារាងខាងក្រោម។

| ប្រភេទកីឡា | ប្រតិភូ | កីឡាករ | កីឡាការិនី | មេដាយ | | | សរុប |
|---|---|---|---|---|---|---|---|
| | | | | មាស | ប្រាក់ | សំរឹទ្ធិ | |
| ការប្រកួតជើងឯកពិភពលោក | ៥០ | ៧៨ | ៣៩ | ១៤ | ១៣ | ១៥ | ៤២ |
| ការប្រកួតជើងឯកអាស៊ី | ៣៩ | ៥២ | ៣៩ | ១២ | ០៨ | ១២ | ៣២ |
| ការប្រកួតជើងឯកអាស៊ីអាគ្នេយ៍ | ១១ | ២០ | ១៦ | ០០ | ០០ | ០៧ | ០៧ |
| ការប្រកួតកីឡាបើកទូលាយ | ៣៥ | ៧៩ | ៣១ | ០៩ | ០២ | ០៥ | ១៦ |
| ការប្រកួតកីឡាជនពិការ | ០៩ | ៣៤ | ០២ | ០០ | ០១ | ០២ | ០៣ |
| ការប្រកួតកីឡាស៊ីហ្គេម លើកទី៣០ | ១២៣ | ២០៦ | ៧០ | ០៤ | ០៦ | ៣៦ | ៤៦ |
| សរុប | | | | ៣៩ | ៣០ | ៧៧ | ១៤៦ |

ការចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣០ នៅហ្វីលីពីន ទទួលបានមេដាយមាស៤គ្រឿង ប្រាក់៦គ្រឿង និងសំរឹទ្ធិ៣៦គ្រឿង។ ការប្រកួតកីឡាប៉េតង់ជ្រើសរើសជើងឯកពិភពលោកយុវជននិងស្ត្រី កីឡាការិនី **កែ ឡេង** ទទួលបានមេដាយមាសចំនួន៤ដងជាប់ៗគ្នាមុនគេលើពិភពលោក។

**ការលើកកម្ពស់សកម្មភាពរៀននិងបង្រៀន អប់រំកាយក្នុងម៉ោងសិក្សា និងហ្វឹកហាត់កីឡាក្រៅម៉ោងសិក្សា**

ក្រសួងបានអនុវត្តមុខវិជ្ជាអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា ព្រមទាំងចេញសេចក្ដីណែនាំលេខ ២៨២ អកសន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីគោលការណ៍រៀបចំការប្រកួតកីឡាសិស្សថ្នាក់ជាតិនិងការប្រកួតកីឡាសាកលវិទ្យាល័យថ្នាក់ជាតិរៀងរាល់២ឆ្នាំម្ដង។

ក្រសួងបានប្រឡងបញ្ចប់ការសិក្សារបស់គរុសិស្សជំនាន់ទី២៨ ចំនួន១៤៩នាក់(ស្រី១១នាក់) និងរៀបចំកម្មវិធីសិក្សាលម្អិត និងចងក្រងឯកសារមេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រសិល្បៈមនុស្សសាស្ត្រឯកទេស អប់រំកាយឆ្នាំទី២ និងឆ្នាំទី៣។

**ការកសាងលិខិតបទដ្ឋានស្ដីពីការអប់រំកាយនិងកីឡា**

ក្រសួងបានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងអនុវិស័យអប់រំកាយនិងកីឡា។ ក្រសួងបានបង្កើតនាយកដ្ឋានថ្មី២ ចំណុះអគ្គនាយកដ្ឋានកីឡា តាមរយៈអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០។ ក្រសួងបានកែលម្អប្រកាសអន្តរក្រសួងលេខ ៧១៦ ប្រក.សហវ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីគោលការណ៍សម្រាប់ប្រមូលផ្ដុំហ្វឹកហាត់ក្រុមជម្រើសជាតិ និងការប្រកួតលក្ខណៈអន្តរជាតិផ្លូវការប្រចាំឆ្នាំ។

**ការលើកកម្ពស់សមត្ថភាពគ្រូបង្វឹក និងកីឡាករ**

ក្រសួងបានប្រមូលផ្ដុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករថ្នាល៥០៩នាក់(ស្រី១០៨នាក់) លើ៣២ប្រភេទកីឡាមកធ្វើការហ្វឹកហាត់បង្កើនសមត្ថភាពបច្ចេកទេសត្រៀមលក្ខណៈឆ្ពោះទៅស៊ីហ្គេមឆ្នាំ២០២៣ និងប្រមូលផ្ដុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករជម្រើសជាតិ៥០៩នាក់(ស្រី១០៤នាក់) លើ៣៣ប្រភេទកីឡា និង១ប្រភេទកីឡាជនពិការ មកធ្វើការប្រមូលផ្ដុំ ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសសម្រាប់ត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣១ ឆ្នាំ២០២១ នៅវៀតណាម និងចូលរួមការប្រកួតជាលក្ខណៈអន្តរជាតិនានា។

**ការបង្កើនសមត្ថភាពគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនី(ឆ្ពោះទៅស៊ីហ្គេម ២០២៣)**

| ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| សរុប | ១៧២ | ២៩៦ | ៤៦៩ | ៥០០ | ៥០៩ |
| ស្រី | ៣០ | ៦៥ | ៩៦ | ១២០ | ៤០១ |

**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តកីឡា**

ក្រសួងបានជួសជុល កែលម្អ និងថែទាំទីលានកីឡាបាល់ទាត់សាលាតម្រង់ទិស២៥ខេត្ត រាជធានី (ក្នុងមួយរាជធានី ខេត្ត សាលាតម្រង់ទិសមួយវិទ្យាល័យ) ជួសជុលអគាររដ្ឋបាល ប្រព័ន្ធភ្លើង និងបន្ទប់អនាម័យ នៃវិមានពហុកីឡដ្ឋានជាតិ ជួសជុលកែលម្អអគាររដ្ឋបាល ទីលានហ្វឹកហាត់ របងផ្នែកខាងត្បូង រៀបចំប្រព័ន្ធលូបង្ហូរទឹក ចាក់ដីបំពេញទីធ្លា បញ្ចប់ការសាងសង់ផ្លូវបេតុង៤ខ្សែ បន្ទប់អនាម័យ និងថែទាំអាងហែលទឹក នៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា។

### ១.៥- ការងារកីឡានៃក្រសួងការពារជាតិ

ក្រសួងបានចាត់បញ្ជូនកីឡាករ កីឡាការិនីកងយោធពលខេមរភូមិន្ទទៅចូលរួមប្រកួតកីឡាដណ្ដើមពានរង្វាន់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិទូទាំងប្រទេស ប្រកួតដណ្ដើមពានរង្វាន់ផ្សេងៗក្របខ័ណ្ឌជាតិនិងអន្តរជាតិ ថ្នាក់អាស៊ី ថ្នាក់អាស៊ីអាគ្នេយ៍ ថ្នាក់ពិភពលោក។ល។ ជាលទ្ធផលៈ

- ការប្រកួតក្នុងប្រទេសលក្ខណៈជាតិទទួលបាន មេដាយមាស២៤២គ្រឿង មេដាយប្រាក់១៣៤គ្រឿង មេដាយសំរឹទ្ធ៩៨គ្រឿង ពាន៤៣ពាន ខ្សែក្រវាត់១៦ខ្សែ ខ្សែកមាស៣ជីនិងម៉ូតូ២គ្រឿង
- ការចូលរួមប្រកួតថ្នាក់អន្តរជាតិទទួលបាន មេដាយមាស២២គ្រឿង មេដាយប្រាក់២៤គ្រឿង មេដាយសំរឹទ្ធ២៨គ្រឿង ពាន៨ពាន(ពានប៉េតង់ស្ត្រីពិភពលោក១ពាននិងពានប៉េតង់ជើងឯកពិភពលោក១ពាន) ខ្សែក្រវាត់២ខ្សែ ថវិកា២១៦ ០០០ ០០០រៀលនិង១៤ ៥០០ដុល្លារអាម៉េរិក។

## មុំទី២- ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស

### ១- ការបណ្ដុះបណ្ដាលធនធានមនុស្សរបស់ក្រសួង ស្ថាប័ន

| ក្រសួង ស្ថាប័ន | ឆ្នាំ២០១៧ | | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|---|---|---|
| | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្នុងប្រទេស |
| ១- ទីស្ដីការគណៈរដ្ឋមន្ត្រី | ៧២០ | ១៧ | ៥៧២ | ២៣ | ១៨១ | ៦៣ | ១០ | ១ | ២៦ | ២ |
| ២- ក្រសួងមហាផ្ទៃ | ១៨០ | ៩៥ | ៣ ៧៤៦ | ៦៤៥ | ៤ ២៧២ | ៦៧៨ | ២ ១១៦ | ៩៤ | ១៦០ | ០ |
| ៣- ក្រសួងការពារជាតិ | ៩ ៩២៧ | ២ ៧៧២ | ៨ ៣៧០ | ៣១៣៧ | ៩ ៩០៦ | ៣១១៥ | ៨ ៥០៨ | ១១៣៣ | ៨៥០៨ | ២០២១ |
| ៤- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១៤៣ | ៩៨ | ២៥៨ | ១១០ | ៣៥២ | ៧៨ | ១៣៧ | ៣១ | ៩១ | ២ |
| ៥- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៣៥ | ២៧៤ | ៦៦ | | ២១៥ | ២៦៣ | ៧០ | ២៨ | ១៥៧ | ២៩ |
| ៦- ក្រសួងអភិវឌ្ឍន៍ជនបទ | ១ ៥២៧ | ៥០ | ៤ ៣៣១ | ១៨ | ១០៧០ | ៤១ | ៩៥៤ | ៧ | ៨៧ | ១ |
| ៧- ក្រសួងមុខងារសាធារណៈ | ២៦ | ៤៨៦ | ៧២៥ | ៤៧ | ១៧៣១ | ៩៧ | ១៨៥ | ២៣ | ២២៤ | ៥២ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៨- ក្រសួងផែនការ | ៤៨៣ | ៦៤ | ៥០ | ១០ | ៨១ | ២១ | ៦៨ | ១ | ២០៥ | ៣ |
| ៩-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១ ៣៤២ | ២៤០ | ៦ ៧៨០ | ៣០០ | ១០២៩ | ២៨១ | ២ ៣០៦ | ១៣២ | ៥៦៤ | ២៥៦ |
| ១០- ក្រសួងទេសចរណ៍ | ៥៣ | ៦២ | ៤៤ | ៦៦ | ៥០ | ៣៩ | ២៣ | ២៣ | ៣១ | ០ |
| ១១- ក្រសួងធនធានទឹក និងឧតុនិយម | ៣៦១ | ៦០ | ៤៦៥ | ៥០ | ៥៣៣ | ៥១ | ៣២៥ | ១២ | ១៥៩ | ០ |
| ១២-ក្រសួងរ៉ែនិងថាមពល | ១ ៣១៤ | ១៥៦ | ៨៨១ | ១២៨ | ១៩៥៧ | ១៦២ | ១ ៣២៣ | ២៥ | ៤៨៤ | ១៩ |
| ១៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ៣៤៩ | ១៥៣ | ៦៤៦ | ១២៣ | ៥៥៤ | ១៩១ | ១១២ | ១ | ៨០ | ១ |
| ១៤- ក្រសួងបរិស្ថាន | ៩៦៣ | ១៩៤ | ៨២១ | ៩២ | ៩៦៦ | ៨៤ | ៣០៣ | ២៣ | ២៦៥ | ៧ |
| ១៥- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០ | ០ | ២ ២៨០ | ៦៣៦ | ១៣៥២ | ៩១៦ | ២ ៣៤១ | ៣៩៣ | ១០៥១ | ៤៦ |
| ១៦- ក្រសួងកិច្ចការនារី | ២៣ | ១២២ | ២៤ | ២១ | ០ | ០ | ១៣ | ៨ | ៥៤ | ១៦ |
| ១៧- ក្រសួងពាណិជ្ជកម្ម | ១ ០៣៤ | ១៦ | ២៣២ | ៨ | ១០៧ | ៧០ | ៥៥ | ៩ | ៦៩ | ៧ |
| ១៨- ក្រសួងអប់រំ យុវជន និងកីឡា | ១៧៦ | ៨៩ | ១៣៦ | ១២០ | ៣២ | ៧៧ | ៨៤ | ៨៦ | ១២៧ | ៦៤ |
| ១៩- ក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ | ៩៧៩ | ៣៤១ | ៩៨៤ | ៤២៧ | ៥៩៦ | ៤៥១ | ៣ ៤៤៥ | ៦១ | ២៦៤៦ | ៨១ |
| ២០- ក្រសួងយុត្តិធម៌ | ២ ២៥០ | ០ | ២ | ៣ | ២៩ | ២៤ | ០ | ០ | ០ | ០ |
| ២១-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ១៥៩ | ២៨ | ០ | ០ | ៣៤៩ | ៥ | ០ | ០ | ៦៦ | ០ |
| ២២- ក្រសួងវប្បធម៌និង វិចិត្រសិល្បៈ | ៧៨៨ | ៤ | ៥៣៩ | ១៩ | ៧៦៨ | ១១ | ៧៣៦ | ៣ | ៥៦៦ | ៥ |
| ២៣- ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ | ១៩៥ | ៧៣ | ១ ៣៧២ | ៨០ | ១ ២១៧ | ៨៨ | ១ ២១៩ | ៣៤ | ១២២២ | ៣០៣ |
| ២៤- ក្រសួងធម្មការនិង សាសនា | ១៤០ | ០ | ១៥០ | ០ | ២២០ | ០ | ៥៧ | ០ | ១៧០ | ០ |
| ២៥- រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | ៤២៨ | ៧៨ | ២៨៩ | ៤៤ | ៥០៦ | ៩៧ | ២០៥ | ៨ | ៤០ | ០ |

## ២- ការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

### ២.១- ក្រសួងមហាផ្ទៃ

- បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ថ្នាក់ដឹកនាំ គ្រូនគរបាលជាតិ និងមន្ត្រីត្រូវបានអភិវឌ្ឍសមត្ថភាពតាមរយៈការបើកវគ្គបណ្តុះបណ្តាលផ្ទៃក្នុង ការចាត់បញ្ជូនឱ្យចូលរួមក្នុងសិក្ខាសាលាថ្នាក់ជាតិ អន្តរជាតិ វគ្គសិក្សាសំខាន់ៗនៅក្រៅប្រទេសដើម្បីទទួលយកចំណេះដឹងនិងបទពិសោធន៍ថ្មីៗ មកបម្រើឱ្យកិច្ចការដឹកនាំ ចងក្រងឯកសារស្រាវជ្រាវនិងកិច្ចការបង្ហាត់បង្រៀនសរុបចំនួន២ ១៧៨នាក់

- ផ្អែកតាមស្ថិតិ ថ្នាក់ដឹកនាំ គ្រូនគរបាលជាតិ និងមន្ត្រីនគរបាលជាតិនៃរាជបណ្ឌិត្យសភានគរបាលកម្ពុជាមានចំនួនសរុប១ ៧៤២នាក់ ក្នុងនោះកម្រិតគុណវុឌ្ឍិរួមមាន សញ្ញាបត្របណ្ឌិត១៣នាក់ សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់៣៨៤នាក់ សញ្ញាបត្របរិញ្ញាបត្រ៤៨៦នាក់ និងសញ្ញាបត្រផ្សេងៗ២៩៩នាក់។

**លទ្ធផលការងារបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ**

ចាប់តាំងពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១នេះ បណ្ឌិត្យសភានគរបាលកម្ពុជា បានបើកវគ្គបណ្តុះបណ្តាលសរុបចំនួន១៥០វគ្គ ក្នុងនោះមានអ្នកសិក្សាជាមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ សរុបចំនួន១៦ ១៤៨នាក់ (ស្រី២ ៣២៦នាក់)។ លទ្ធផលការងារបណ្តុះបណ្តាលតាមឆ្នាំនីមួយៗមានដូចខាងក្រោម៖

- ឆ្នាំ២០១៧ មានវគ្គសិក្សាសរុប ៥៥វគ្គ សិក្ខាកាមចំនួន៦ ៩៩៥នាក់(ស្រី២ ០៨២នាក់)
- ឆ្នាំ២០១៨ មានវគ្គសិក្សាសរុប ៤២វគ្គ សិក្ខាកាមចំនួន៣ ២៦៦នាក់(ស្រី៣៥៥នាក់)
- ឆ្នាំ២០១៩ មានវគ្គសិក្សាសរុប ៤២វគ្គ សិក្ខាកាមចំនួន៣ ៨៥៧នាក់(ស្រី៤៦៣នាក់)
- ឆ្នាំ២០២០ មានវគ្គសិក្សាសរុប ១០វគ្គ សិក្ខាកាមចំនួន១ ៧៩៦នាក់(ស្រី៣៧៥នាក់)
- ឆ្នាំ២០២១ មានវគ្គសិក្សាសរុប ១វគ្គ សិក្ខាកាមចំនួន២៣៤នាក់(ស្រី៥១នាក់)។

សរុបរយៈពេល៥ឆ្នាំ បានបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាព ចំណេះដឹងវិជ្ជាជីវៈដល់អ្នកសិក្សាបានបញ្ចប់ស្តាពរសរុបចំនួន៦ ៩៩៥នាក់(ស្រី១ ០៨២នាក់)។

## ២.២- ក្រសួងការពារជាតិ

ក្រសួងការពារជាតិ បានលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាពនិងសេចក្តីត្រូវការធនធានមនុស្សនៅក្នុងកងយោធពលខេមរភូមិន្ទ ព្រមទាំងបានបន្តធ្វើការកែសម្រួលពង្រឹងគុណភាពហ្វឹកហ្វឺននិងបានធ្វើការហ្វឹកហ្វឺនបណ្តុះបណ្តាលនិងបំប៉នជំនាញផ្សេងៗ នៅតាមបណ្តាសាលាហ្វឹកហ្វឺនក្នុងប្រទេសបញ្ចប់វគ្គសិក្សាបានចំនួន ១០ ៤៣៧នាក់ និងបានចាត់តាំងហ្វឹកហ្វឺននៅនឹងកន្លែងតាមបណ្តាអង្គភាពស្មើនឹងចំនួន១ ៣១១ ៧៤០លើក/នាក់ ព្រមទាំងចាត់បញ្ជូនទៅបំពេញកម្មសិក្សានៅក្រៅប្រទេសបានចំនួន៦ ៦៧៩នាក់។ ក្រៅពីនេះ បានចាត់តាំងធ្វើលំហាត់ហ្វឹកហ្វឺន៧លើក( ១- នាគមាសឆ្នាំ២០១៨ ឆ្នាំ២០១៩និងឆ្នាំ២០២០ រវាងកងយោធពលខេមរភូមិន្ទនិងកងទ័ពរំដោះប្រជាជនចិន ២- មហាអំរិល២០១៧និង២០១៩ និង៣- ហនុមានមាស២០១៨និង២០១៩) ផងដែរ។

ដោយឡែកការសិក្សាបង់ថ្លៃវគ្គវេជ្ជបណ្ឌិត វគ្គទន្តបណ្ឌិត វគ្គបរិញ្ញាបត្រឱសថ វគ្គបរិញ្ញាបត្ររងគិលានុបដ្ឋាក វគ្គបរិញ្ញាបត្ររងឆ្មប និងវគ្គបរិញ្ញាបត្ររងមន្ទីរពិសោធន៍ នៅវិទ្យាស្ថានសុខាភិបាលខ.ភ.ម. សរុបមានចំនួន១ ៥០២នាក់ ក្នុងនោះ៖

| ឆ្នាំសិក្សា | ២០១៦-២០១៧ | ២០១៧-២០១៨ | ២០១៨-២០១៩ | ២០១៩-២០២០ | ២០២០-២០២១ | សរុប |
|---|---|---|---|---|---|---|
| សិក្ខាកាម | ១៩៦នាក់ | ២៣៥នាក់ | ២៥៧នាក់ | ៣៤៥នាក់ | ៤៦៩នាក់ | ១ ៥០២នាក់ |

កងយោធពលខេមរភូមិន្ទ បានទទួលនូវការបំពាក់បំប៉នជាប្រចាំនូវការអប់រំចិត្តសាស្ត្រ ស្មារតីសតិ-អារម្មណ៍ ច្បាប់ផ្សេងៗនិងសភាពការណ៍ថ្មីៗ ពិសេសច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទសរុប៤០ ៣៧៥លើក ស្មើនឹង ៧ ២៣៦ ៣៦០លើក/នាក់ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការគោរពអនុវត្តច្បាប់ បទបញ្ជានិងទឹកចិត្តស្នេហាជាតិមាតុភូមិ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងការពារនិងស្មោះត្រង់ដាច់ខាតចំពោះរាជរដ្ឋាភិបាល។

## ២.៣- គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម

| ឆ្នាំ | វគ្គហ្វឹកហ្វឺន ការបណ្ដុះបណ្ដាល សិក្ខាសាលា បេសកកម្ម ក្នុងស្រុក | | វគ្គហ្វឹកហ្វឺន ការបណ្ដុះបណ្ដាល សិក្ខាសាលា បេសកកម្ម អន្តរជាតិ | | ការការពារសន្តិសុខសុវត្ថិភាពជូនថ្នាក់ដឹកនាំ និងឥស្សរជនជាន់ខ្ពស់ |
|---|---|---|---|---|---|
| | ចំនួន(ដង) | ចំនួន(នាក់) | ចំនួន(ដង) | ចំនួន(នាក់) | ចំនួន(ដង) |
| ២០១៧ | ៤៣ | ១៧៨ | ៣២ | ៧៣ | ១៦៦ |
| ២០១៨ | ២៥ | ៨៨ | ២១ | ៥៦ | ១៥៤ |
| ២០១៩ | ៣១ | ១០២ | ៣៦ | ១២៥ | ១៥៨ |
| ២០២០ | ២១ | ៧៣ | ១១ | ៣០ | ៨៥ |
| ២០២១ | ១៥ | ៧១ | ១៥ | ៣០ | ៩ |
| **សរុប** | **១៣៥** | **៥១២** | **១១៥** | **៣១៤** | **៥៧២** |

## ២.៤- ក្រសួងមុខងារសាធារណៈ

ក្រសួងបានរៀបចំវគ្គបណ្ដុះបណ្ដាលដោយផ្ទាល់ និងតាមរយៈអនឡាញ(Online) ជូន (១) សិស្សមន្ត្រីជាន់ខ្ពស់ (២) សិស្សមន្ត្រីក្រមការ (៣) វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្រមការ (៤) វគ្គវិក្រឹត្យការ មន្ត្រីគ្រប់គ្រងរដ្ឋបាល និងមន្ត្រីមធ្យម (៥) វគ្គសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មី និង(៦) វគ្គសិក្សាខ្លីៗ ជូនដល់មន្ត្រីរាជការនៅទូទាំងប្រទេសបានចំនួន៥ ៩១១នាក់(ស្ត្រី១ ៧៦១នាក់) ដូចខាងក្រោម៖

ដល់មន្ត្រីរាជការនៅទូទាំងប្រទេសបានចំនួន៥ ៩១១នាក់(ស្ត្រី១ ៧៦១នាក់) ដូចខាងក្រោម៖

| ឆ្នាំ / បរិយាយ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សិស្សមន្ត្រីជាន់ខ្ពស់ (ជំនាន់ទី៩ ១០និង១១) | ៥៦ | ១១ | ០ | ០ | ៦០ | ១៥ | ៩១ | ២៨ | ០ | ០ | ២០៧ | ៥៤ |
| សិស្សមន្ត្រីក្រមការ (ជំនាន់ទី៧ ៨ និង៩) | ១០១ | ៣២ | ០ | ០ | ១១៩ | ៣២ | ០ | ០ | ១២១ | ៤៣ | ៣៤១ | ១០៧ |
| សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មី (២០១៦ ២០១៧ ២០១៨ និង២០១៩) | ៧៨៧ | ៣២១ | ៨៧៥ | ៣២៧ | ៦៨៧ | ២៧៥ | ៣៩៦ | ១៦៦ | ២០៥ | ៧១ | ២ ៩៥០ | ១ ១៦០ |
| មន្ត្រីក្រមការ រដ្ឋបាលក្របខ័ណ្ឌថ្មី២០១៩ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៨៦ | ៣៦ | ៨៦ | ៣៦ |
| វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ | ៣១៣ | ៤១ | ១១៦ | ១០ | ០ | ០ | ១០៦ | ១២ | ១៥៥ | ៣៧ | ៦៨៦ | ១០០ |
| វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល | ០ | ០ | ១៦៦ | ២៤ | ០ | ០ | ១៦៤ | ២៦ | ៥៣៥ | ១៣៤ | ៨៦៥ | ១៨៤ |
| វគ្គវិក្រឹត្យការមន្ត្រីមធ្យម | ១០៧ | ២០ | ២៨ | ៨ | ០ | ០ | ៣៩ | ១១ | ៩០ | ២៧ | ២៦៤ | ៦៦ |
| វគ្គវិក្រឹត្យការមន្ត្រីក្រមការ | ០ | ០ | ៨៦ | ១៦ | ០ | ០ | ៤៣ | ៦ | ៨៨ | ២៤ | ២១៧ | ៤៦ |
| វគ្គបណ្ដុះបណ្ដាលសហការជាមួយកូរ៉េ | | | | | ១៥ | ១ | ១៥ | ៣ | ១៥ | ៤ | ៤៥ | ៨ |

| ឆ្នាំ / បរិយាយ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សិក្ខាសាលាបណ្តុះបណ្តាលសហការជាមួយសិង្ហបុរី សម្រាប់មុខតំណែងចាប់ពីអគ្គ-នាយក អគ្គនាយករង | | | | | | | ៥០ | ០ | | | ៥០ | ០ |
| រៀបចំកម្មវិធីសិក្ខាសាលាស្តីពី«**ការអភិវឌ្ឍភាពជាអ្នកដឹកនាំ**» | | | | | | | | | ២០០ | ០ | ២០០ | ០ |

## ២.៥- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

ការអភិវឌ្ឍធនធានមនុស្ស និងកំណែទម្រង់របៀបរបបការងារ គឺជាការងារអាទិភាពរបស់ក្រសួងក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រីការទូត ដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល៥ឆ្នាំនេះ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស និងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីដូចខាងក្រោម៖

| ល.រ. | បរិយាយ | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (ត្រឹមខែតុលា) | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | បណ្តុះបណ្តាលមន្ត្រី | ក្នុងប្រទេស | ១៩៥នាក់ | ១ ៣៧២នាក់ | ១២១៧នាក់ | ១២១៩នាក់ | ១២២២នាក់ | ៥២២៥នាក់ |
| | | ក្រៅប្រទេស | ៧៣នាក់ | ៨០នាក់ | ៨៨នាក់ | ៣៤នាក់ | ២៨នាក់ | ៣០៣នាក់ |
| ២ | មន្ត្រីក្របខ័ណ្ឌថ្មី | | ១៦នាក់ | ២៥នាក់ | ៦០នាក់ | ៣២នាក់ | គ្មាន | ១៣៣នាក់ |

ក្នុងការធ្វើកំណែទម្រង់ផ្ទៃក្នុង ក្រសួងបានបង្កើតអគ្គនាយកដ្ឋានថ្មីចំនួន៤ នាយកដ្ឋានថ្មីចំនួន១៣ និងអង្គភាពថ្មីចំនួន២ ដើម្បីជានានិរន្តរភាពការងារក្នុងក្រសួង ពង្រឹងពង្រីកទំនាក់ទំនងទ្វេភាគី និងពហុភាគី។ ទន្ទឹមនេះដែរ ក្នុងរយៈពេល៥ឆ្នាំនេះ ក្រសួងបានរៀបចំកិច្ចប្រជុំពាក់កណ្តាលឆ្នាំ និងសន្និបាតបូកសរុបសមិទ្ធផលការងារប្រចាំឆ្នាំ ដើម្បីបង្ហាញពីលទ្ធផលការងារដែលសម្រេចបាន និងពិភាក្សាផ្លាស់ប្តូរយោបល់លើការវិវត្តនៃសភាពការណ៍ក្នុងតំបន់និងអន្តរជាតិ ព្រមទាំងពិភាក្សា ដោះស្រាយអំពីកំណែទម្រង់ផ្ទៃក្នុងក្រសួង បញ្ហាប្រឈមនានា ដើម្បីបង្កើនប្រសិទ្ធភាពការងារផងដែរ។

ក្រៅពីនេះ វិទ្យាស្ថានជាតិការទូតបានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីនិងវគ្គភាសាបរទេសដូចជា ចិន ជប៉ុន ថៃ អាល្លឺម៉ង់ បារាំង អង់គ្លេស និងអេស្ប៉ាញ និងបានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា ព្រមទាំងបានរៀបចំបាឋកថា និងវេទិកាពិភាក្សាជាមួយស្ថាប័នជាតិ អន្តរជាតិ ពាក់ព័ន្ធវិស័យការបរទេស និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតនិងបទល្មើសបច្ចេកវិទ្យា។

ជាមួយគ្នានេះដែរ ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ ក៏បានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគលើប្រធានបទសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងនយោបាយផ្ទៃក្នុងកម្ពុជា និងនយោបាយប្រទេសជិតខាង ក្នុងតំបន់និងពិភពលោកជូនប្រមុខរាជរដ្ឋាភិបាលនិងថ្នាក់ដឹកនាំក្រសួង។

## ២.៦- ក្រសួងសុខាភិបាល

ធនធានមនុស្សគឺជាសមាសភាពដ៏សំខាន់សម្រាប់ប្រតិបត្តិការក្នុងប្រព័ន្ធសុខាភិបាល ជាពិសេសការផ្តល់សេវាសុខាភិបាលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ប្រកបដោយសមធម៌ ដល់ប្រជាពលរដ្ឋគ្រប់រូប។ ការអភិវឌ្ឍធនធានមនុស្សសុខាភិបាល ផ្តោតលើប្រព័ន្ធនិងអភិក្រមនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាលសំដៅលើសមត្ថភាព(ចំណេះដឹង ជំនាញសម្បទា និងចរិយាសម្បទា) ការជ្រើសរើស ការបែងចែកបុគ្គលិក ការពង្រាយបុគ្គលិក ការរក្សាទុកបុគ្គលិកនៅនឹងកន្លែងធ្វើការ ការលើកទឹកចិត្ត ការគ្រប់គ្រងនិងអភិបាលកិច្ច។ រហូតមកដល់បច្ចុប្បន្ននេះ គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលទាំងសាធារណៈនិងឯកជនមាន១៩គ្រឹះស្ថាន។ រូបភាព១១ និងតារាងទី៥ បង្ហាញពីវឌ្ឍនភាពនៃការបណ្តុះបណ្តាលវិស័យសុខាភិបាលពីឆ្នាំ២០១៦-២០២០។

រូបភាពទី១ លទ្ធផលនៃការបញ្ចប់ការសិក្សាមុនពេលបម្រើការងារ ពីឆ្នាំ២០១៦-២០២០




តារាងទី២ ការបណ្តុះបណ្តាលតាមប្រភេទជំនាញនៅគ្រឹះស្ថានសាធារណៈពីឆ្នាំ២០១៦-២០២០

| ប្រភេទជំនាញបច្ចេកទេស | ២០១៦ | | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | |
|---|---|---|---|---|---|---|---|---|---|---|
| | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា |
| វេជ្ជបណ្ឌិតឯកទេស | - | - | - | - | - | - | ៤៨៧ | ១៩៨ | ៤៥៩ | ១៨០ |
| វេជ្ជសាស្ត្រ | ២៥៤១ | ៤១៩ | ២០១៤ | ៤៨៤ | ២៥៣០ | ២៦៨ | ២៤០០ | ២១៨ | ២៥១៤ | ៣១៩ |
| ទន្តសាស្ត្រ | ៤៧២ | ១១៥ | ៥០១ | ១០៥ | ៦១៣ | ៩៨ | ៦៥៧ | ១២២ | ៦១៣ | ១១៨ |
| ឱសថសាស្ត្រ | ៨២៧ | ១៧២ | ៧១៥ | ១៨៤ | ៥៩៣ | ២១៦ | ៧៨៣ | ១៧០ | ៩៩៤ | ១៦២ |
| បរិញ្ញាបត្រសុខភាពសាធារណៈ | ៣៩ | 0 | 0 | ៣១ | ១១ | 0 | ២១ | 0 | ៧ | ១៤ |
| បរិញ្ញាបត្រគិលានុបដ្ឋាក | ២៥៨ | 0 | ១៤៩ | ៧៩ | ១៤៣ | 0 | ២៤៧ | ២៧ | ២១៥ | ៦៥ |
| បរិញ្ញាបត្រឆ្មប | ១៦១ | 0 | ៥៩ | ១២២ | ២៥៨ | 0 | ១៥១ | ១១ | ២៤៥ | ៣៦ |
| បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប | ៥២ | ៧៤ | ៦១ | ៤៣ | ២៧ | ៩៤ | ៥១ | ៥៩ | ៧០ | ២០៨ |
| បរិញ្ញាបត្ររងគិលានុបដ្ឋាក | ២១៦៤ | ៩៨៣ | ២ ០៤៩ | ១ ០៣៩ | ១ ៦០៧ | ១៣៥១ | ១១៤០ | ៨៩៤ | ១៨៨៩ | ៦៧៣ |
| បរិញ្ញាបត្ររងឆ្មប | ១៣០០ | ៨២៧ | ១ ៣០៧ | ៦៧៦ | ៩៩៤ | ៧៥៣ | ៥៧១ | ៦២៧ | ៥៧២ | ៣៨៦ |
| ចក្ខុ-គិលានុបដ្ឋាក | - | - | - | ១៦ | 0 | ៤១ | 0 | 0 | 0 | ២៩ |
| បរិញ្ញាបត្រទន្តគិលានុបដ្ឋាក | - | - | - | - | - | - | ១១ | ១៧ | 0 | 0 |
| បរិញ្ញាបត្រមន្ទីរពិសោធន៍ | - | - | - | - | - | - | - | - | ៦៨ | ៥៦ |
| បរិញ្ញាបត្ររងមន្ទីរពិសោធន៍ | ៣៣៦ | ១៥៧ | ៣០៨ | ១៤៤ | ៨៩ | ១៧១ | ១៣៧ | ៨៧ | ២១៩ | ៩៤ |
| បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក | ៧១ | ៤៧ | ៧៥ | ៤៦ | ១០១ | ២១ | ៦៦ | ៤២ | ១៥៦ | ៤៦ |
| បរិញ្ញាបត្រព្យាបាលចលនា | - | - | - | - | - | - | ២០ | 0 | 0 | ២១ |
| បរិញ្ញាបត្ររងព្យាបាលចលនា | ១៨ | ១១ | ៣១ | ៤ | ៥៣ | ៧ | ៣៦ | ២០ | ៦១ | ១៥ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បរិញ្ញាបត្ររងវិទ្យុសាស្ត្រ | ១៧ | ១៨ | ៩ | ៩ | ០ | ០ | ២១ | ៣ | ៤៥ | ១០ |
| បរិញ្ញាបត្ររងបច្ចេកទេសវិស្វកម្មវេជ្ជជីវសាស្ត្រ | - | - | - | - | - | - | - | - | ១៨ | ០ |
| បរិញ្ញាបត្រគិលានុបដ្ឋាកបែបពាក់កណ្តាលពេល | - | - | - | - | - | - | ៤៩ | ០ | ១០៩ | ០ |
| **សរុប** | **៨២៥៦** | **២ ៨២៣** | **៧ ២៧៨** | **២ ៩៨២** | **៧ ០១៩** | **៣០២០** | **៦៩៤៨** | **២៤៩៥** | **៨២៧២** | **២៤៣២** |

តារាងទី៣ ការបណ្តុះបណ្តាលតាមប្រភេទជំនាញនៅគ្រឹះស្ថានឯកជនពីឆ្នាំ២០១៦-២០២០

| ប្រភេទជំនាញបច្ចេកទេស | ២០១៦ | | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | |
|---|---|---|---|---|---|---|---|---|---|---|
| | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា |
| វេជ្ជបណ្ឌិតឯកទេស | - | - | - | - | - | - | ១២៩ | ០ | ១៩០ | ០ |
| វេជ្ជសាស្ត្រ | ១ ២៥៧ | ១៧២ | ១ ៤៦៧ | ៨៥ | ១៨៦៤ | ៣៦១ | ១៩៦៣ | ៣៤៩ | ១៩៧៤ | ២១៥ |
| ទន្តសាស្ត្រ | ៣០៣ | ១៧ | ៣៤៦ | ៣០ | ២៩៦ | ៤៤ | ៣៨១ | ៧៧ | ៣៥៥ | ៧២ |
| ឱសថសាស្ត្រ | ៧១២ | ៧៤ | ១ ១២៨ | ១៧២ | ១០៩៣ | ១៥២ | ៥៨៦ | ៩៥ | ៦១៥ | ១២៤ |
| ឱសថការីមធ្យម | - | - | - | - | - | ៥៧៦ | ០ | ០ | ០ | ២៤ |
| បរិញ្ញាបត្រឱសថសាស្ត្រ | - | - | - | - | - | - | - | - | ៧៤៤ | ៨២ |
| បរិញ្ញាបត្រគិលានុបដ្ឋាក | ១១៥ | ១៤១ | ២២៦ | ១១៦ | ២២៣ | ៣៧ | ៣០៨ | ១០២ | ២៦៨ | ១៨១ |
| បរិញ្ញាបត្រឆ្មប | ៦៦ | ៤៩ | ៣៩ | ៣០ | ៦០ | ២៨ | ១០៥ | ២ | ៤៤ | ៣៧ |
| បរិញ្ញាបត្រគិលានុបដ្ឋាកឆ្មប | - | - | ២៥ | ១៦ | ១៦ | ៥ | ៤៥ | ២៩ | ៨ | ១៨ |
| បរិញ្ញាបត្រគិលានុបដ្ឋាកពាក់កណ្តាលពេល | - | - | - | - | - | - | - | - | ៦១ | ១៧ |
| បរិញ្ញាបត្ររងគិលានុបដ្ឋាក | ២៣៧២ | ២០០៩ | ១ ៣៧១ | ១ ៨៦០ | ៥៦៤ | ១៣៥២ | ៣១០ | ២៧៧ | ៤៦៤ | ១០៧ |
| បរិញ្ញាបត្ររងឆ្មប | ១១១៩ | ១១៩១ | ៦១៥ | ១ ១៥៨ | ១២៧ | ៧៤៣ | ២៨ | ៧៣ | ៣០ | ២៦ |
| បរិញ្ញាបត្ររងមន្ទីរពិសោធន៍ | ៣៩៤ | ៤៦៨ | ៤០២ | ៥៣៧ | ៧៦ | ២៤០ | ៣៥ | ៤៦ | ៥២ | ១៧ |
| បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក | ១៨៦ | ១៤៨ | ១៨៣ | ១៣៤ | ១១១ | ១៣៨ | ៩៥ | ៦៧ | ១១៨ | ៤៥ |
| សរុប | **៦៥២៤** | **៤២៦៩** | **៥៨០២** | **៤១៣៨** | **៤៤៣០** | **៣៦៣៦** | **៣៩៨៥** | **១១១៧** | **៤៩២៣** | **៩៦៥** |

## ២.៧- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

តារាងទី១ សិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថាន អ.ប.វ. ( ២០១៧-២០២១)

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២០១៦-២០១៧ | | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ៨ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | ០ | ០ | ០ | ០ | ០ | ០ |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ៤៧ | ៤ | ៥១ | ៧ | ២១៣ | ៦១ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ | ៧ ៨៨៤ | ២ ៥៥៣ | ៥ ៥២២ | ២ ២៣១ | ៥ ៨១៨ | ១ ៥៨៣ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | ៤ ១៧៩ | ១ ១៧០ | ៤ ៩០៨ | ១ ៣៣៥ | ៥ ៨៨៤ | ១ ៧៦៤ |
| ៤ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ (CQF4) | ២៦៨ | ៧៨ | ៣៩៨ | ១៥៤ | ៥៩០ | ៩៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ (CQF3) | ៥០៣ | ១៧០ | ៥១៣ | ១៥៦ | ១ ១៤១ | ៣៣៨ |
| ២ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (CQF2) | ១ ៧៣៩ | ៥៧១ | ១ ៩៧៣ | ៥៨៦ | ២ ៥៦៤ | ៧៥២ |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ២២ ៤៣៨ | ១១ ២៦៩ | ៣៨ ៨៨៧ | ១៨ ១២០ | ៤៦១៣៨ | ២៣ ៤០៦ |
| **សរុបរួម** | | **៣៧ ០៥៨** | **១៥ ៨១៥** | **៥២ ២៥២** | **២២ ៥៨៩** | **៦២៣៤៨** | **២៨០០០** |

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ២០១៩-២០២០ | | ២០២០-២០២១ | |
|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី |
| ៨ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | 0 | 0 | 0 | 0 |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ១៧៧ | ៣៥ | ១១៧ | ២៥ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ៥ ១៤៩ | ២ ៥៥១ | ៥ ១១៧ | ១ ៤៦១ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ៤ ៦៧៣ | ១ ៦២៦ | ៤ ៥៩៥ | ១ ០១៥ |
| ៤ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ (CQF4) | ៨៤០ | ២២២ | ៦៨៤ | ១៦៤ |
| ៣ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ (CQF3) | ៩៨៦ | ២៥២ | ២ ១៤៣ | ៧០៣ |
| ២ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (CQF2) | ៣ ២០៥ | ១ ០៣២ | ១២ ៨៤៧ | ៥ ៧៣៣ |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ៣៦ ២២១ | ១៧ ៨១៧ | ២៤ ១៣២ | ១២ ០៥២ |
| **សរុបរួម** | | **៥១ ២៥១** | **២៣ ៥៣៥** | **៤៩ ៦៣៥** | **២១ ១៥៣** |

តារាងទី២ ចំនួនសិក្ខាកាមដែលបានទទួលការបណ្តុះបណ្តាលរយៈពេលខ្លី

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២០១៧ | | ២០១៨ | | ២០១៩ | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ២២ ៤៣៨ | ១១ ២៦៩ | ៣៨ ៨៨៧ | ២១ ២៤៩ | ៤៦ ១៣៨ | ២៣ ៤០៦ |
| ១.១ | កម្មវិធីស្ពានចម្លងបន្តជំនាញ | 0 | 0 | ២ ៥២១ | ៧៩៥ | ២ ៤៦៤ | ១ ០៦៦ |
| ១.២ | កម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ | 0 | 0 | ១១ ៣៣៥ | ៦ ៧០១ | ២៣ ៩៤៧ | ១៣ ៤២៧ |
| ១.៣ | ការបណ្តុះបណ្តាលតាមកម្មវិធីប៊ីប | 0 | 0 | 0 | 0 | 0 | 0 |
| ១.៤ | កម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋនិងឯកជន | 0 | 0 | 0 | 0 | 0 | 0 |
| ១.៥ | កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍, ៤ខែ) | ២២ ៤៣៨ | ១១ ២៦៩ | ២៥ ០៣១ | ១៣ ៧៥៣ | ១៩ ៧២៧ | ៨ ៩១៣ |

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២០២០ | | ២០២១ | |
|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ៣៦ ២២១ | ១៧ ៨១៧ | ២៤ ១៣២ | ១២ ០៥២ |
| ១.១ | កម្មវិធីស្ពានចម្លងបន្តជំនាញ | ៣ ៤០០ | ១ ៥៥០ | ១ ៥៥២ | ៧០៩ |
| ១.២ | កម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ | ១២ ៤០៣ | ៦ ៨៣៨ | ២ ៣១៣ | ១ ៧៥៣ |
| ១.៣ | ការបណ្តុះបណ្តាលតាមកម្មវិធីប៊ីប | ២០៥ | ៧៥ | ១០២ | ៣០ |
| ១.៤ | កម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋ និងឯកជន | ៤៨៦ | ៣៤ | ៤៣៨ | ៤៣ |
| ១.៥ | កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍, ៤ខែ) | ១៩ ៧២៧ | ៩ ៣២០ | ១៩ ៧២៧ | ៩ ៥១៧ |

តារាងទី៣ ការធ្វើអធិការកិច្ចហ្វឹកហ្វឺនកូនជាង

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|
| ១ | ចំនួនសហគ្រាសបានចុះអធិការកិច្ចហ្វឹកហ្វឺនកូនជាង | សហគ្រាស | ០ | ៣៨៣ | ៦៧២ | ០ | ០ |
| ២ | ចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាន | សហគ្រាស | ៥០៤ | ៥៣១ | ៥៨៤ | ៤៣៣ | ៣៤៩ |
| ៣ | ចំនួនកូនជាងត្រូវបានហ្វឹកហ្វឺន | ក្រុមហ៊ុន | ៥០៤ | ៥៣១ | ៥៨៤ | ៤៣៣ | ៣៤៩ |
| | | សរុប | ២៣ ៣០១ | ២៧ ៧០០ | ២៥ ៨៣៥ | ១៨ ៤០៦ | ១៥ ៦៧២ |
| | | ស្រី | ១៨ ៩២៧ | ១៩ ៨៤៦ | ១៩ ៣៥៣ | ១៣ ៨៧៨ | ១១ ៥៣៩ |
| ៤ | ធ្វើតេស្តកូនជាងបានហ្វឹកហ្វឺន ចប់ | ក្រុមហ៊ុន | ៥០៤ | ៥៣១ | ៥៨៤ | ៤៣៣ | ៣៤៩ |
| | | សរុប | ២៣ ៣០១ | ១០ ៨៩៧ | ២៥ ៨៣៥ | ១៨ ៤០៦ | ១៥ ៦៧២ |
| | | ស្រី | ១៨ ៩២៧ | ៧ ៧៥៩ | ១៩ ៣៥៣ | ១៣ ៨៧៨ | ១១ ៥៣៩ |
| ៥ | ផ្តល់វិញ្ញាបនបត្រ និងបានទទួលស្គាល់ជំនាញ | ក្រុមហ៊ុន | ៤៣៣ | ៥០១ | ៥៤៧ | ៥៤៩ | ៣៤៩ |
| | | សរុប | ២២ ៣១២ | ២៥ ៦៣៣ | ២៩ ៦៦៩ | ២២ ៨៦៨ | ១៥ ៦៧២ |
| | | ស្រី | ១៨ ០៤៩ | ១៩ ០៥០ | ២៥ ០៧១ | ១៩ ០៥០ | ១១ ៥៣៩ |

## ២.៨- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងវិស័យវប្បធម៌ ក្នុងគោលបំណងអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ និងការបង្កើតមុខរបរនៅក្នុងវិស័យវប្បធម៌ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងកាត់បន្ថយភាពក្រីក្រ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានបន្តខិតខំបង្កើតនិងបង្កើនធនធានមនុស្សជាច្រើនដោយក្នុងនោះរួមមាន៖

- អប់រំបណ្តុះបណ្តាលធនធានមនុស្សផ្នែកសិល្បៈវប្បធម៌នៅក្នុងប្រព័ន្ធសម្រាប់រយៈពេលវែង( សាលាវិចិត្រសិល្បៈភូមិភាគសៀមរាប សាលាមធ្យមវិចិត្រសិល្បៈ និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ) ដល់សិស្សនិងនិស្សិតសរុបចំនួន១៣ ២៩១នាក់( ស្រី ៥៥៦៤នាក់)

- បណ្តុះបណ្តាលសិល្បៈខ្មែរក្រៅប្រព័ន្ធសម្រាប់រយៈពេលខ្លី(របាំ តន្ត្រី និងចម្លាក់) ដល់សិក្ខាកាមសរុបប្រមាណ២ ៨៩៨នាក់ ដូចជា៖

- សិក្ខាសាលាស្តីពីវគ្គតែងនិពន្ធនិងដឹកនាំរឿង
- សិក្ខាសាលាស្តីពីវគ្គតែងនិពន្ធអត្ថបទភាពយន្ត
- សិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត
- សិក្ខាសាលាថ្នាក់ជាតិស្តីពីការពង្រឹងស្នាដៃតែងនិពន្ធនៅកម្ពុជា
- សិក្ខាសាលាស្តីពីការប្រើប្រាស់កម្មវិធីបណ្ណាល័យតាមប្រព័ន្ធវិទ្យា
- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយផ្តល់សេវាកម្មលេខISBN របៀបបោះពុម្ពសៀវភៅតាមខ្នាតអន្តរជាតិ
- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយពីរបៀបបោះពុម្ពសៀវភៅ
- វគ្គបណ្តុះបណ្តាលក្បាច់ចម្លាក់ខ្មែរនៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង កណ្តាល ព្រៃវែង និងខេត្តពោធិ៍សាត់។ល។

## ២.៩- ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

ការបណ្តុះបណ្តាលវិជ្ជាជីវៈ

| ឆ្នាំ | វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងសុរិយោដី | វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងរៀបចំដែនដី |
|---|---|---|
| ២០១៧ | ១វគ្គ មានសិក្ខាកាម៣១នាក់(ស្រី២នាក់) | - |
| ២០១៨ | ១វគ្គ មានសិក្ខាកាម៣៨នាក់(ស្រី៣នាក់) | ១វគ្គ មានសិក្ខាកាម១៨នាក់(ស្រី១នាក់) |
| ២០១៩ | ១វគ្គ មានសិក្ខាកាម២៤នាក់(ស្រី៣នាក់) | - |
| ២០២០ | ១វគ្គ មានសិក្ខាកាម៣៥នាក់(ស្រី៥នាក់) | - |
| ៩ខែ ២០២១ | - | - |
| សរុប | ៤វគ្គសិក្ខាកាមសរុប១២៤នាក់(ស្រី១៣នាក់) | ១វគ្គ មានសិក្ខាកាមសរុប១៨នាក់(ស្រី១នាក់) |

ការបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសនិងក្រៅប្រទេស

| ឆ្នាំ | ក្នុងប្រទេស (នាក់) | ក្រៅប្រទេស (នាក់) |
|---|---|---|
| ២០១៧ | ១៤៣ | ៩៨ |
| ២០១៨ | ២៥៨ | ១១០ |
| ២០១៩ | ៣៥២ | ៧៨ |
| ២០២០ | ១៣៧ | ៣១ |
| ៩ខែ ឆ្នាំ២០២១ | ៩១ | ២ |
| សរុប | ៩៨១ | ៣១៩ |

## ២.១០- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ១- សាកលវិទ្យាល័យភូមិន្ទកសិកម្ម

តារាងទី១ ស្ថិតិនិស្សិតសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម តាមមហាវិទ្យាល័យ តាមឆ្នាំនីមួយៗ

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៧ | | ២០១៨ | | ២០១៩ | |
| ក. | ថ្នាក់បរិញ្ញាបត្រ | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កសិកម្ម | ៩៦៧ | ៣០០ | ៧០៩ | ២៤៩ | ៨១២ | ២៩៨ |
| ២ | កៅស៊ូ | ៥៧ | ១៥ | ៣៨ | ២០ | ២៩ | ១៩ |
| ៣ | វិទ្យាសាស្ត្រសត្វ | ១៨២ | ៤៦ | ១៦៤ | ៣២ | ១៦២ | ៤០ |
| ៤ | វេជ្ជសាស្ត្រសត្វ | ៨៥៦ | ១៦៩ | ៦២៥ | ១៤២ | ៥៥៩ | ១៤៥ |
| ៥ | ព្រៃឈើ | ៦៩ | ២៨ | ៦៥ | ២៨ | ៨៦ | ៣៥ |
| ៦ | ជលផល | ៨៧ | ៣០ | ១០០ | ៣៦ | ១០៩ | ៤៧ |
| ៧ | វិស្វកម្មកសិកម្ម | ១១៤ | ២១ | ១០៣ | ២៣ | ៩៩ | ២៤ |
| ៨ | កសិឧស្សាហកម្ម | ៤៩៤ | ២៩៩ | ៤៥៦ | ២៨៥ | ៥៤៨ | ៣៤០ |
| ៩ | សេដ្ឋកិច្ចកសិកម្ម-អភិវឌ្ឍន៍ជនបទ | ៣៤០ | ១៣៦ | ២៣៥ | ១១១ | ២១០ | ១០០ |
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ១៨១ | ៥៨ | ២២២ | ៨០ | ៣៣៥ | ១២១ |
| ខ. | ថ្នាក់បរិញ្ញាបត្ររង | ១៥៣ | ៤២ | ១៣៧ | ៣១ | ១៣៥ | ៤២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ. | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ១១១ | ៤០ | ៤៤ | ១៦ | ៤០ | ១៥ |
| ឃ. | ថ្នាក់បណ្ឌិត | ២៧ | ៣ | ២៦ | ៣ | ៣៣ | ៣ |
| **សរុប** | | **៣ ៦៣៨** | **១ ១៨៧** | **៣ ០១៣** | **១ ០៥៦** | **៣ ១៥៧** | **១ ២២៩** |

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | ស្ថិតិនិស្សិតសរុប | |
|---|---|---|---|---|---|---|---|
| | | ២០២០ | | ២០២១ | | | |
| ក. | ថ្នាក់បរិញ្ញាបត្រ | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** |
| ១ | កសិកម្ម | ៨៤៣ | ៣០៦ | ៩៤៩ | ៣៥៩ | ៤ ៣៦៩ | ១ ៥១០ |
| ២ | កៅស៊ូ | ២៦ | ១៨ | ១១ | ៦ | ១៦១ | ៧៨ |
| ៣ | វិទ្យាសាស្ត្រសត្វ | ១៨០ | ៣៧ | ២៧៦ | ៦២ | ៩៦៤ | ២១៧ |
| ៤ | វេជ្ជសាស្ត្រសត្វ | ៥៦៨ | ១៤៩ | ៦៧១ | ១៩៦ | ៣ ២៧៩ | ៨០១ |
| ៥ | ព្រៃឈើ | ៧៣ | ៣៣ | ៥៥ | ៣១ | ៣៤៨ | ១៥៥ |
| ៦ | ជលផល | ១០២ | ៤៧ | ៨៨ | ៣៤ | ៤៨៦ | ១៩៤ |
| ៧ | វិស្វកម្មកសិកម្ម | ៩៨ | ៣៦ | ៧៤ | ១៥ | ៤៨៨ | ១១៩ |
| ៨ | កសិឧស្សាហកម្ម | ៥៣៤ | ៣៤៣ | ៥២១ | ៣៤១ | ២ ៥៥៣ | ១ ៦០៨ |
| ៩ | សេដ្ឋកិច្ចកសិកម្ម-អភិវឌ្ឍន៍ជនបទ | ១៩៤ | ៩៨ | ១៤៦ | ៧៣ | ១ ១២៥ | ៥១៨ |
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ៤៩៧ | ១៩២ | ៥៩១ | ២៣៤ | ១ ៨២៦ | ៦៨៥ |
| ខ. | ថ្នាក់បរិញ្ញាបត្ររង | ១៣៥ | ៥៦ | ៧៤ | ២៧ | ៦៣៤ | ១៩៨ |
| គ. | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ៩០ | ៣០ | ១៦៧ | ៥២ | ៤៥២ | ១៥៣ |
| ឃ. | ថ្នាក់បណ្ឌិត | **៣០** | ២ | ៣៣ | ៦ | ១៤៩ | ១៧ |
| សរុប | | ៣ ៣៧០ | ១ ៣៤៧ | ៣ ៦៥៦ | ១ ៤៣៤ | ១៦ ៨៣៤ | ៦ ២៥៣ |

## តារាងទី២ ស្ថិតិនិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យ តាមមហាវិទ្យាល័យ និងតាមឆ្នាំនិមួយៗ

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៧ | | ២០១៨ | | ២០១៩ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ក. ថ្នាក់បរិញ្ញាបត្រ | | | | | | | |
| ១ | កសិកម្ម | ២២៥ | ៧៣ | ១២០ | ២៥ | ១៧៦ | ៦៩ |
| ២ | កៅស៊ូ | ៣១ | ៤ | ១២ | ៣ | ១ | 0 |
| ៣ | វិទ្យាសាស្ត្រសត្វ | ៣៦ | ១០ | ៣៣ | ៥ | ៣១ | ៨ |
| ៤ | វេជ្ជសាស្ត្រសត្វ | ២០៦ | ៤៩ | ១៣៣ | ៣២ | ១៤២ | ៣២ |
| ៥ | ព្រៃឈើ | ២៦ | ១១ | 0 | 0 | ១៦ | ៨ |
| ៦ | ជលផល | ១៥ | ៦ | ៩ | ៦ | ២២ | ៩ |
| ៧ | វិស្វកម្មកសិកម្ម | ២៥ | ៤ | ១៣ | ៣ | ១៨ | ៣ |
| ៨ | កសិឧស្សាហកម្ម | ៨៥ | ៤៧ | ៦៧ | ៤៤ | ៨៩ | ៥៣ |
| ៩ | សេដ្ឋកិច្ចកសិកម្ម-អភិវឌ្ឍន៍ជនបទ | ៨៥ | ៣៤ | ៤៧ | ១៦ | ៦៤ | ៣៤ |
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ៣៥ | ៥ | ២៦ | ៩ | ២៩ | ១២ |
| ខ. | ថ្នាក់បរិញ្ញាបត្ររង | ៤៣ | ៩ | ៣៦ | ១២ | ២២ | ៦ |
| គ. | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ១៣ | ៣ | ២២ | ៤ | ១៧ | ៦ |
| ឃ. | ថ្នាក់បណ្ឌិត | | | | | | |
| **សរុប** | | **៨២៥** | **២៥៥** | **៥១៨** | **១៥៩** | **៦២៧** | **២៤០** |

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | ស្ថិតិនិស្សិតសរុប | |
|---|---|---|---|---|---|---|---|
| | | ២០២០ | | ២០២១ | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ក. ថ្នាក់បរិញ្ញាបត្រ | | | | | | | |
| ១ | កសិកម្ម | ១៧៩ | ៦១ | ២០២ | ៧៧ | ៩០២ | ៣០៥ |
| ២ | កៅស៊ូ | ៥ | ៤ | ៥ | ៤ | ៥៤ | ១៥ |
| ៣ | វិទ្យាសាស្ត្រសត្វ | ៣០ | ៨ | ៣០ | ៧ | ១៦៩ | ៣៨ |
| ៤ | វេជ្ជសាស្ត្រសត្វ | ១២៤ | ៣៦ | ១៣១ | ៣៥ | ៧៣៦ | ១៨៤ |
| ៥ | ព្រៃឈើ | ១៤ | ៤ | ១៩ | ១១ | ៧៥ | ៣៤ |
| ៦ | ជលផល | ១៤ | ៧ | ១៤ | ៦ | ៧៤ | ៣៤ |
| ៧ | វិស្វកម្មកសិកម្ម | ១៧ | ៥ | ២១ | ៣ | ៩៤ | ១៨ |
| ៨ | កសិឧស្សាហកម្ម | ១១៥ | ៦៧ | ១២៨ | ៧១ | ៤៨៤ | ២៨២ |
| ៩ | សេដ្ឋកិច្ចកសិកម្ម-អភិវឌ្ឍន៍ជនបទ | ៤៧ | ២៥ | ៥៣ | ២៦ | ២៩៦ | ១៣៥ |
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ៦៣ | ២០ | ៧០ | ២១ | ២២២ | ៦៧ |
| ខ. | ថ្នាក់បរិញ្ញារង | ២៨ | ១០ | ២០ | ៦ | ១៤៩ | ៤៣ |
| គ. | ថ្នាក់បរិញ្ញាជាន់ខ្ពស់ | ៤៨ | ២០ | ១៧ | ៨ | ១១៧ | ៤១ |
| ឃ. | ថ្នាក់បណ្ឌិត | ២ | ០ | ៣ | ០ | ៥ | ០ |
| សរុប | | ៦៨៥ | ២៦៧ | ៧១៣ | ២៧៥ | ៣ ៣៦៨ | ១ ១៩៦ |

## ២- វិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

តារាងទី១ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង បច្ចេកទេសកសិកម្ម(អាហារូបករណ៍) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៣១ | ១៧ | ៣៤ | ១៦ | ៤១ | ២០ | ១៦ | ១០ |
| ២ | វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ៤១ | ៩ | ៣៣ | ៧ | ៣៦ | ៩ | ១១ | ៤ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ១៦ | ៦ | ៩ | ៣ | ៣ | ១ | ១ | ១ |
| ៤ | វិទ្យាសាស្ត្រជលផល | ២១ | ១០ | ១០ | ៤ | ៨ | ២ | ២ | ២ |
| ៥ | សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ២៥ | ១០ | ២២ | ៩ | ១៨ | ៦ | ៨ | ៤ |
| សរុបរួម | | ១៣៤ | ៥២ | ១០៨ | ៣៩ | ១០៦ | ៣៨ | ៣៨ | ២១ |

តារាងទី២ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង បច្ចេកទេសកសិកម្ម(បង់ថ្លៃ) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ០ | ០ | ១០ | ៣ | ២ | ១ | ៥ | ៣ |
| ២ | វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ២៣ | ២ | ០ | ០ | ០ | ០ | ៤ | ២ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | វិទ្យាសាស្ត្រជលផល | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **សរុបរួម** | | **២៣** | **២** | **១០** | **៣** | **២** | **១** | **៩** | **៥** |

## តារាងទី៣ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រកសិកម្ម (អាហារូបករណ៍) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៩១ | ៦០ | ១២៧ | ៧៦ | ១៦៦ | ៨៣ | ១៧៤ | ៩៥ |
| ២ | វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ១១៤ | ៤៣ | ១០៥ | ១២ | ១០០ | ២៧ | ១៣០ | ៣៧ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ២២ | ១១ | ១៣ | ៥ | ១១ | ៥ | ៤ | ៣ |
| ៤ | វិទ្យាសាស្ត្រជលផល | ៤២ | ២១ | ៣៤ | ១៧ | ២៧ | ៩ | ២៥ | ១៣ |
| ៥ | សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ៧០ | ៤៣ | ៩១ | ៦២ | ១១៣ | ៦១ | ៧៨ | ៤៨ |
| **សរុបរួម** | | **៣៣៩** | **១៧៨** | **៣៧០** | **១៧២** | **៤១៧** | **១៨៥** | **៤១១** | **១៩៦** |

## តារាងទី៤ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រកសិកម្ម(បង់ថ្លៃ) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ១៧ | ១០ | ៤៤ | ២០ | ៨១ | ៣៧ | ៦០ | ២៨ |
| ២ | វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ៥៩ | ១០ | ៩៧ | ១៨ | ៩០ | ១៦ | ៥៥ | ១២ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៤ | វិទ្យាសាស្ត្រជលផល | ៧ | ៣ | ២១ | ១០ | ២០ | ៩ | ១៥ | ៧ |
| ៥ | សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ៨ | ៦ | ៩ | ៦ | ៣ | ០ | ០ | ០ |
| **សរុបរួម** | | **៩១** | **២៩** | **១៧១** | **៥៤** | **១៩៤** | **៦២** | **១៣០** | **៤៧** |

## តារាងទី៥ ស្ថិតិនិស្សិតបញ្ចប់ការសិក្សាពីឆ្នាំ២០១៧-២០២១

| ល.រ. | កម្រិត | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | និស្សិតថ្នាក់បរិញ្ញាបត្ររង បច្ចេកទេសកសិកម្ម | ៣៣ | ១៥ | ៤៣ | ១៦ | ៤២ | ១៥ | ១៨ | ១១ |
| ២ | និស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម | ១៤១ | ៥៤ | ៧៨ | ២៩ | ៩៧ | ៣៩ | ១៤៣ | ៥៧ |
| **សរុបរួម** | | **១៧៤** | **៦៩** | **១២១** | **៤៥** | **១៣៩** | **៥៤** | **១៦១** | **៦៨** |

### តារាងទី៦ ស្ថិតិមន្ត្រីរាជការ សាស្ត្រាចារ្យ និងគ្រូបង្រៀន ពីឆ្នាំ២០១៧-២០២១

| ល.រ. | មន្ត្រីរាជការ សាស្ត្រាចារ្យ និងគ្រូបង្រៀន | ឆ្នាំបំពេញការងារ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ថ្នាក់ដឹកនាំ/មន្ត្រីរាជការ | ៥៣ | ១៤ | ៥៦ | ១៦ | ៥៧ | ១៦ | ៦០ | ១៦ |
| ២ | មន្ត្រីជាប់កិច្ចសន្យា/ពលករអណ្តែត | ១៦ | ៦ | ២១ | ៧ | ២១ | ៧ | ២១ | ៧ |
| ៣ | សាស្ត្រាចារ្យ/គ្រូបង្រៀនទាំងក្នុងនិងក្រៅអង្គភាព | ១៥៣ | ១៧ | ១៥៤ | ១៩ | ១៥៤ | ១៩ | ១៥៩ | ៤២ |

## ៣- វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

### តារាងទី១ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង (អាហារូបករណ៍) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ក្សេត្រសាស្ត្រ | ២៥ | ៧ | ២៦ | ១៥ | ១៥ | ៦ | ៦ | ២ |
| ២ | ផលិតកម្មនិងបសុព្យាបាល | ២០ | ៥ | ១៤ | ៥ | ៩ | ៥ | ១០ | ៥ |
| ៣ | ជលផល | ១៣ | ៨ | ៥ | ៣ | ១១ | ៦ | ៥ | ៣ |
| ៤ | រុក្ខកម្ម | ១៧ | ៩ | ៩ | ១ | ១ | ០ | ០ | ០ |
| ៥ | សាកវប្បកម្ម | ២ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៦ | សេដ្ឋកិច្ចកសិកម្ម | ៣ | ២ | ១ | ០ | ០ | ០ | ០ | ០ |
| ៧ | កែច្នៃអាហារ | ៣ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៨ | សុរិយោដីនិងការគ្រប់គ្រងដី | ៦ | ២ | ៩ | ៣ | ៧ | ០ | ៥ | ០ |
| ៩ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៦ | ៥ | ៥ | ៤ | ១ | ១ | ០ | ០ |
| ១០ | វិស្វកម្មកសិកម្ម | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **សរុបរួម** | | **៩៦** | **៤២** | **៦៩** | **៣១** | **៤៤** | **១៨** | **២៦** | **១០** |

### តារាងទី២ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង (សិក្សាបង់ថ្លៃ) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ក្សេត្រសាស្ត្រ | ២៨ | ៧ | ២១ | ៦ | ២២ | ៥ | ១៥ | ២ |
| ២ | ផលិតកម្មនិងបសុព្យាបាល | ៥៤ | ៧ | ៥២ | ១០ | ១៦ | ៤ | ៥ | ៣ |
| ៣ | ជលផល | ៤ | ៨ | ១ | ០ | ៣ | ០ | ០ | ០ |
| ៤ | រុក្ខកម្ម | ៤ | ៩ | ២ | ១ | ១ | ១ | ០ | ០ |
| ៥ | សាកវប្បកម្ម | ២ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៦ | សេដ្ឋកិច្ចកសិកម្ម | ៦ | ២ | ៣ | ២ | ០ | ០ | ០ | ០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៧ | កែច្នៃអាហារ | ១ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៨ | សុរិយោដីនិងការគ្រប់គ្រងដី | ១៨ | ៦ | ៤៤ | ១២ | ២០ | ២ | ៥៦ | ១២ |
| ៩ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៤ | ៥ | ៤ | ១ | ១ | ១ | ០ | ០ |
| ១០ | វិស្វកម្មកសិកម្ម | ០ | ០ | ១ | ០ | ០ | ០ | ០ | ០ |
| **សរុបរួម** | | **១២១** | **៣៣** | **១២៨** | **៣២** | **៦៣** | **១៣** | **៨២** | **១៧** |

## តារាងទី៣ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ (អាហារូបករណ៍) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៤៨ | ២១ | ៦២ | ២៩ | ៥២ | ២៩ | ៧៤ | ៤៣ |
| ២ | វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ៤៦ | ១២ | ២៤ | ៩ | ០ | ០ | ១០ | ២ |
| ៣ | វិទ្យាសាស្ត្រសត្វ | ០ | ០ | ១១ | ៥ | ៣៤ | ១២ | ៣៦ | ១៧ |
| ៤ | វេជ្ជសាស្ត្រសត្វ | ០ | ០ | ១៦ | ៧ | ៣០ | ១៥ | ៥២ | ២១ |
| ៥ | វិទ្យាសាស្ត្រជលផល | ៣៥ | ១២ | ៣៩ | ១៩ | ៣៤ | ១៦ | ៣៩ | ១៧ |
| ៦ | វិទ្យាសាស្ត្រព្រៃឈើ | ១៩ | ១០ | ២៤ | ១៣ | ២៩ | ២០ | ២៥ | ១៨ |
| ៧ | សាកវប្បកម្ម | ២១ | ១៣ | ២១ | ១៥ | ១៨ | ៨ | ៣៥ | ១៧ |
| ៨ | សេដ្ឋកិច្ចកសិកម្ម | ៣៧ | ១៨ | ៤៦ | ២០ | ៤៧ | ២៥ | ៤៣ | ២២ |
| ៩ | កែច្នៃអាហារ | ៣៦ | ២៣ | ៤២ | ២៧ | ៦៤ | ៤៥ | ៥០ | ៣៤ |
| ១០ | សុរិយោដីនិងការគ្រប់គ្រងដី | ៤១ | ១៣ | ៦៨ | ២០ | ៨២ | ៣៦ | ៨៦ | ៣០ |
| ១១ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៣៩ | ២១ | ៥០ | ២៩ | ៤៤ | ២៦ | ៣១ | ២១ |
| ១២ | វិស្វកម្មកសិកម្ម | ១២ | ១ | ១០ | ១ | ២៣ | ១០ | ៧ | ១ |
| ១៣ | អាហារូបត្ថម្ភនិងសុខភាព | ១៥ | ១២ | ១០ | ៦ | ៩ | ៦ | ០ | ០ |
| ១៤ | កុំព្យូទ័រ | ១០ | ១ | ៨ | ១ | ១៨ | ៦ | ១៣ | ៣ |
| ១៥ | សេដ្ឋកិច្ចនយោបាយនិងស្បៀង | ៩ | ៣ | ៩ | ៤ | ១១ | ៤ | ៨ | ៣ |
| ១៦ | ភាសាអង់គ្លេស | ៨ | ៧ | ១១ | ១០ | ១២ | ៥ | ៤ | ២ |
| ១៧ | មីក្រូហិរញ្ញវត្ថុ | ៨ | ៣ | ១០ | ៦ | ១១ | ៤ | ២ | ០ |
| ១៨ | ធុរកិច្ចកសិកម្ម | ០ | ០ | ០ | ០ | ៥ | ៣ | ០ | ០ |
| **សរុបរួម** | | **៣៨៤** | **១៧០** | **៤៦១** | **២២១** | **៥២៣** | **២៧០** | **៥១៥** | **២៥១** |

## តារាងទី៤ ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ (សិក្សាបង់ថ្លៃ) ពីឆ្នាំ២០១៧-២០២១

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៨៨ | ៣០ | ៦២ | ២៤ | ៤៤ | ១៤ | ៤៣ | ១៣ |
| ២ | វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ១០៥ | ២២ | ៨២ | ១៦ | ៥២ | ៩ | ៤១ | ៩ |
| ៣ | វិទ្យាសាស្ត្រសត្វ | ០ | ០ | ១ | ០ | ៣០ | ៧ | ៩ | ១ |
| ៤ | វេជ្ជសាស្ត្រសត្វ | ០ | ០ | ៣ | ២ | ៩ | ២ | ២៥ | ៤ |
| ៥ | វិទ្យាសាស្ត្រជលផល | ២ | ១ | ១២ | ៦ | ៧ | ៥ | ៦ | ២ |
| ៦ | វិទ្យាសាស្ត្រព្រៃឈើ | ៥ | ០ | ៩ | ៤ | ១១ | ៤ | ៦ | ១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៧ | សាកវប្បកម្ម | ២ | ១ | ៣ | ២ | ២ | ១ | ៥ | ១ |
| ៨ | សេដ្ឋកិច្ចកសិកម្ម | ១ | ០ | ៤ | ២ | ៦ | ២ | ៤ | ១ |
| ៩ | កែច្នៃអាហារ | ៨ | ២ | ៧ | ៣ | ៦ | ២ | ២ | ០ |
| ១០ | សុរិយោដីនិងការគ្រប់គ្រងដី | ៣៦ | ១០ | ១៥ | ៤ | ៦១ | ១៧ | ៨១ | ២៣ |
| ១១ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៩ | ២ | ៦ | ៣ | ៥ | ២ | ៥ | ៣ |
| ១២ | មីក្រូហិរញ្ញវត្ថុ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១៣ | វិស្វកម្មកសិកម្ម | ០ | ០ | ១ | ០ | ០ | ០ | ១ | ០ |
| **សរុបរួម** | | **២៥៧** | **៦៨** | **២០៥** | **៦៦** | **២៣៣** | **៦៥** | **២២៨** | **៥៨** |

**តារាងទី៥ ស្ថិតិនិស្សិតបញ្ចប់ការសិក្សា ពីឆ្នាំ២០១៧-២០២១**

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | និស្សិតថ្នាក់បរិញ្ញាបត្ររង | ១៥៤ | ៥៦ | ១៤៩ | ៤០ | ៣៦ | ១៦ | ៨៦ | ២៤ |
| ២ | និស្សិតថ្នាក់បរិញ្ញាបត្រ | ២០៦ | ៨១ | ១៩៧ | ៧២ | ១០៣ | ៤៥ | ១២៦ | ៤៩ |
| **សរុបរួម** | | **៣៦០** | **១៣៧** | **៣៤៦** | **១១២** | **១៣៩** | **៦១** | **២១២** | **៧៣** |

## ២.១១- ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា

ក្រសួងបានពង្រឹង និងពង្រីកសកម្មភាពវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការ សមាគម មិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច។វិទ្យាស្ថានបាននិងកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សាដែលសិក្សាលើជំនាញសង្គមកិច្ច ជំនាញសង្គមវិទ្យា ជំនាញកិច្ចគាំពារសង្គម ជំនាញវិស្វកម្មសិប្បនិម្មិតនិងរណប ជំនាញគ្រប់គ្រងសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាញគោលនយោបាយសង្គម ជំនាញគោលនយោបាយសាធារណៈ និងជំនាញអក្សរសាស្ត្រអង់គ្លេសសរុបចំនួន៤៦៣នាក់ និស្សិតបរទេស១៤នាក់។ និស្សិតដែលបានប្រឡងជាប់ជាស្ថាពរថ្នាក់បរិញ្ញាបត្រចំនួន២៦៩នាក់ និស្សិតបរទេស១០នាក់ និងសិក្ខាកាមដែលបានបញ្ចប់ការសិក្សាជំនាញផ្សេងៗរយៈពេលខ្លីចំនួន ៦២៨នាក់ និងបណ្តុះបណ្តាលជំនាញអ្នកជំនួយបច្ចេកទេសឧបករណ៍បច្ចេកទេសសិប្បនិម្មិតនិងរណបចំនួន ២៦នាក់។

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១ | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | ២២១ | ១៦៧ | ៩៦ | ១៣២ | ៩២ | ៧០៨ |
| ២ | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | ៤៣៣ | ៤៨៩ | ៤០០ | ៤៤១ | ៤៦៣ | |
| ៣ | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | ៨៨ | ២០ | ៩១ | ៧០ | - | ២៦៩ |
| ៤ | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | ៦២ | ៧៥ | ២២៥ | ២០៨ | ៥៨ | ៦២៨ |

## ២.១២- ក្រសួងផែនការ

ក្រសួងផែនការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការពង្រឹងសមត្ថភាពរបស់មន្ត្រី ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង និងបានរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ នៅក្នុងប្រទេស និងក្រៅប្រទេស ដោយផ្តោតលើជំនាញការរៀបចំធ្វើផែនការ ការវិភាគស្ថិតិ និងការរៀបចំគោលនយោបាយប្រជាជន ព្រមទាំងវគ្គបណ្តុះបណ្តាលផ្សេងៗទៀតទាក់ទងនឹងការងាររបស់ក្រសួងផែនការ។

ក្រសួងផែនការតាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការស្ថិតិ ដែលជាមជ្ឈមណ្ឌលមួយសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីរាជការមកពីក្រសួង ស្ថាប័ននានា និងសិស្សដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយឆ្លងកាត់ការប្រឡងជ្រើសរើសឱ្យចូលរៀនលើមុខជំនាញឯកទេសពីរគឺផែនការសេដ្ឋកិច្ច និងស្ថិតិសេដ្ឋកិច្ច។ បច្ចុប្បន្នមាននិស្សិតកំពុងសិក្សាចំនួនពីរជំនាន់គឺជំនាន់ទី៣០ និងជំនាន់ទី៣១ ដែលមានសិក្ខាកាម និស្សិតសរុបចំនួន១០៧នាក់(ស្រី ៣៥នាក់)។

## ២.១៣- ក្រសួងអភិវឌ្ឍន៍ជនបទ

ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា កូរ៉េ មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តកំពង់ស្ពឺ តាកែវ ពោធិ៍សាត់ ព្រៃវែង ស្វាយរៀង កំពង់ចាម កំពត កំពង់ធំ បន្ទាយមានជ័យ សៀមរាប និងខេត្តបាត់ដំបងបាននិងបន្តបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដូចជាការអភិវឌ្ឍសហគមន៍ បច្ចេកទេសចិញ្ចឹមមាន់ បច្ចេកទេសចិញ្ចឹមត្រី បច្ចេកទេសដាំត្រសក់ បច្ចេកទេសចិញ្ចឹមកង្កែប អន្ទង់ បច្ចេកទេសកែច្នៃម្ហូបអាហារ បច្ចេកទេសចិញ្ចឹមទា បច្ចេកទេសផលិតសាប៊ូលាងចាន បច្ចេកទេសបណ្តុះផ្សិត បច្ចេកទេសដាំបន្លែតាមបែបទំនើបកម្ម បច្ចេកទេសចិញ្ចឹមនិងភ្ញាស់កូនមាន់ កាត់ដេរសម្លៀកបំពាក់ អ៊ុតសក់និងកែសម្ផស្ស កុំព្យូទ័ររដ្ឋបាល ភាសាអង់គ្លេស បច្ចេកទេសចិញ្ចឹមនិងព្យាបាលជ្រូក បច្ចេកទេសធ្វើជីកំប៉ុស្តិ៍ បច្ចេកទេសចិញ្ចឹមនិងព្យាបាលមាន់ ជួសជុលម៉ូតូគ្រប់ប្រភេទ ជួសជុលគ្រឿងម៉ាស៊ីនខ្នាតតូច ជួសជុលវិទ្យុម៉ាញ៉េ និងទូរទស្សន៍ ផលិតគ្រឿងសង្ហារិមពីឫស្សី បច្ចេកទេសដាំដំណាំស្រូវ បច្ចេកទេសជួសជុលនិងថែទាំអណ្តូងស្នប់ បច្ចេកទេសដាំដំណាំគ្រួសារ កាត់សក់បុរស បច្ចេកទេសបណ្តុះកូនឈើនិងផ្សាំមែក និងបច្ចេកទេសចិញ្ចឹមក្តាមថ្ម ដែលមានសិក្ខាកាមចូលរួមសរុប១៣ ២១៣នាក់(ស្រី ២ ២៥៦នាក់)។

## ២.១៤- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្នុងទិសដៅបង្កើនធនធានមនុស្ស បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(អតីតវិទ្យាស្ថានជាតិ ប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យជំនាញតាមមុខវិជ្ជាដូចតទៅ៖

- បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ(រយៈពេល៥ឆ្នាំ) ផ្តល់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រលើ៣មុខជំនាញដូចតារាងខាងក្រោម៖

| សូចនាករ | ជាក់ស្តែង ២០១៧ | ជាក់ស្តែង ២០១៨ | ជាក់ស្តែង ២០១៩ | ជាក់ស្តែង ២០២០ | ជាក់ស្តែង ២០២១ |
|---|---|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ | | | | | |
| ក-ពាណិជ្ជកម្មអេឡិចត្រូនិក | ១៨ | ២៣ | ២៥ | ៦៧ | ៥៥ |
| ខ-ទូរគមនាគមន៍និងបណ្តាញ | ១៨ | ១៥ | ៥៦ | ៤៣ | ៣៩ |

| គ-វិទ្យាសាស្ត្រកុំព្យូទ័រ | ២១ | ៣៩ | ៤៩ | ៨៣ | ៧០ |
|---|---|---|---|---|---|
| សរុប | ៥៧នាក់ | ៧៧នាក់ | ១៣០នាក់ | ១៩២នាក់ | ១៦៤នាក់ |

- បណ្តុះបណ្តាល រយៈពេលខ្លីក្នុងប្រទេស

ឯកតា: នាក់

| ល.រ. | បរិយាយ | ២០១៧ | | ២០១៨ | | ២០១៩ | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | វគ្គបណ្តុះបណ្តាលជំនាញឌីជីថលចាំបាច់ ( Digital Skill Essential ) | ៥៩៥ | ១២៧ | ៥៤៩ | ១០៥ | ៣៨៥ | ១០៣ |
| ២ | វគ្គបណ្តុះបណ្តាលស្តីពីICTសម្រាប់ការងាររដ្ឋបាល និងកម្មវិធីទូរសព្ទឆ្លាតវៃតាមរយៈកម្មវិធីអ្នកស្ម័គ្រចិត្ត ICTកម្ពុជា | ១ ២២២ | ៨២០ | ១ ៩២៩ | ១ ២១៣ | ១៩០៧ | ១ ៣៧០ |
| ៣ | វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈលើវិស័យ ICT | | | ២៥០ | ២០ | ២៤០ | ៣៥ |
| ៤ | វគ្គបណ្តុះបណ្តាលវិស័យប្រៃសណីយ៍ | ១២០ | ១៨ | ០ | ០ | ០ | ០ |

| ល.រ. | បរិយាយ | ២០២០ | | ២០២១ | | សរុប | | |
|---|---|---|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | ស្ត្រី |
| ១ | វគ្គបណ្តុះបណ្តាលជំនាញឌីជីថលចាំបាច់ ( Digital Skill Essential ) | ៤៧២ | ១១៥ | ១ ០៩៨ | ២៨៥ | ៣ ០៩៩ | ៧៣៥ | ២៣,៧២% |
| ២ | វគ្គបណ្តុះបណ្តាលស្តីពីICTសម្រាប់ការងាររដ្ឋបាល និងកម្មវិធីទូរសព្ទឆ្លាតវៃតាមរយៈកម្មវិធីអ្នកស្ម័គ្រចិត្ត ICTកម្ពុជា | ០ | ០ | ០ | ០ | ៥ ០៥៨ | ៣ ៤០៣ | ៦៧,២៨% |
| ៣ | វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈលើវិស័យ ICT | ០ | ០ | ១២០ | ២០ | ៦១០ | ៧៥ | ១២,៣០% |
| ៤ | វគ្គបណ្តុះបណ្តាលវិស័យប្រៃសណីយ៍ | ០ | ០ | ០ | ០ | ១២០ | ១៨ | ១៥% |

- បណ្តុះបណ្តាលរយៈពេលខ្លីក្រៅប្រទេស

| សូចនាករ | ជាក់ស្តែង ២០១៧ | ជាក់ស្តែង ២០១៨ | ជាក់ស្តែង ២០១៩ | ជាក់ស្តែង ២០២០ | ជាក់ស្តែង ២០២១ | សរុប |
|---|---|---|---|---|---|---|
| អាហារូបករណ៍ទៅប្រទេសឥណ្ឌា(មន្ត្រី) | ៥នាក់ | ៦នាក់ | ១នាក់ | ០០ | ០០ | ១២នាក់ |
| អាហារូបករណ៍ទៅប្រទេសឥណ្ឌា(និស្សិត) | ៥នាក់ | ១៣ នាក់ | ៨នាក់ | ០០ | ០០ | ២៦នាក់ |
| អាហារូបករណ៍ទៅប្រទេសជប៉ុន(គ្រូបង្គោល) | ០០ | ១ នាក់ | ០០ | ០០ | ០០ | ១នាក់ |
| អាហារូបករណ៍ទៅប្រទេសកូរ៉េ(គ្រូបង្គោល) | ០០ | ០០ | ០០ | ១ នាក់ | ០០ | ១នាក់ |
| អាហារូបករណ៍ទៅប្រទេសចិន(គ្រូបង្គោល) | ០០ | ០០ | ២នាក់ | ០០ | ០០ | ២នាក់ |
| អាហារូបករណ៍ទៅប្រទេសបែលហ្សិក(គ្រូបង្គោល) | ០០ | ០០ | ១នាក់ | ០០ | ០០ | ១នាក់ |
| អាហារូបករណ៍ទៅប្រទេសបារាំង(គ្រូបង្គោល) | ០០ | ៣ នាក់ | ៣នាក់ | ៦ នាក់ | ០០ | ១២នាក់ |
| សរុប | ១០នាក់ | ២៣នាក់ | ១៥នាក់ | ៧នាក់ | ០០ | ៥៥នាក់ |

## ២.១៥- ក្រសួងកិច្ចការនារី

១- វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កាត់ដេរ អ៊ុតសក់ សម្អាងការ តម្បាញ ដល់ស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ទណ្ឌិតស្ត្រីបោះបង់ចោលការសិក្សា និងជនជាតិដើមភាគតិច តាមរយៈមន្ទីរកិច្ចការនារី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី ស្ទឹងត្រែង បាត់ដំបង ព្រះសីហនុ រតនគិរី កណ្តាល បន្ទាយមានជ័យ កំពង់ឆ្នាំង ព្រះវិហារ ត្បូងឃ្មុំ កោះកុង ប៉ៃលិន កែប សៀមរាប ក្រចេះ កំពត កំពង់ចាម ព្រៃវែង និងខេត្តឧត្តរមានជ័យ សរុប១៥ ៨៨៧នាក់។

២- វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កែច្នៃចំណីអាហារ និងកែច្នៃផលិតផលកសិកម្ម ដល់ប្រជាពលរដ្ឋក្រីក្រ ជាពិសេសស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ក្មេងស្រីបោះបង់ចោលការសិក្សានិងជនជាតិដើមភាគតិច ដែលប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈមន្ទីរកិច្ចការនារី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី នៅខេត្តស្ទឹងត្រែង បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ព្រះវិហារ ត្បូងឃ្មុំ ប៉ៃលិនក្រចេះ កំពត កំពង់ចាម ព្រៃវែង និងខេត្តឧត្តរមានជ័យ សរុប១៩ ២៨៦នាក់(ស្រី១៥ ៨៤៣នាក់)។

៣- គណៈគ្រប់គ្រងក្នុងមុខតំណែងអគ្គនាយករង អគ្គាធិការរង អគ្គលេខាធិការរងដល់រដ្ឋលេខាធិការជាស្ត្រី២១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល១៣០ម៉ោង មន្ត្រីរាជការ១៣នាក់(ស្រី១០នាក់) ចូលរួមវគ្គបណ្តុះបណ្តាលបន្ត និងមន្ត្រីរាជការក្របខ័ណ្ឌថ្មី៦០នាក់(ស្រី៤២នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល។

## ២.១៦- ក្រសួងធម្មការ និងសាសនា

- ការបណ្តុះបណ្តាលអាចារ្យ-អាចារិនី

| សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ចំនួនអាចារ្យ-អាចារិនី | ៤០៩ | ៥៤៣ | ៦៧២ | ១៧៣ | ០ |

- នាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម

| សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ចំនួនអ្នកចូលរួម | ៥ ០៨៩ | ៦ ៥៧៦ | ៥ ៤៥០ | ៣ ៧៩២ | ១៦ ២០០ |
| ចំនួនស្ថានីយវិទ្យុបានផ្សាយជាស៊ីឌី | ៥៥២ | ៥៥២ | ៥៥២ | ៦៩ | ៦៩ |
| ចំនួនទូរទស្សន៍បានផ្សាយជាឌីវីឌី | ៥៥២ | ៥៥២ | ៥៥២ | ៦៩ | ៦៩ |

- ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលា១៩៤លើក
- រៀបចំកម្មវិធីនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម៩៩លើក ប្រធានបទ២៩៧ប្រធានបទ
- បាននិមន្តធម្មថិកាចារ្យសម្តែងព្រះធម៌ទេសនា២៩៧ព្រះអង្គ ដែលមានអ្នកចូលរួមស្តាប់២០ ៨៥៣អង្គ/នាក់ ក្នុងនោះមានព្រះសង្ឃ១ ៣៦០អង្គ និងស្ត្រី៧ ៨១៣នាក់
- ផលិតDvcam ២៩៧ Dvcam, CD សំឡេង៣ ៤៦៥បន្ទះ និងDVD៤ ៥៥៤ដុំកាស្សែត
- បើកវគ្គបណ្តុះបណ្តាលតួនាទីភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរ សរុប១៣វគ្គ សិក្ខាកាមចូលរួមសរុប១ ៧៩៧អង្គ/នាក់ ក្នុងនោះ មានព្រះសង្ឃ២០៩អង្គ និងស្ត្រី២៩នាក់
- ចេញវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរ ជូនដល់សិក្ខាកាម សរុប១ ៧៩៧អង្គ/នាក់

- ចុះធ្វើកម្មវិធីទស្សនទានព្រះពុទ្ធសាសនា ចំនួន៤៨លើក និងពង្រឹងការផ្សព្វផ្សាយព្រះធម៌៣លើក
- រៀបចំពិធីសំណេះសំណាលជាមួយអាចារ្យ-អាចារិនី៣លើក សរុប៣០០០រូប។

## ២.១៧- ក្រសួងសាធារណការ និងដឹកជញ្ជូន

| ល.រ. | បណ្តុះបណ្តាលមន្ត្រីរាជការ | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|---|
| ១ | ក្នុងប្រទេស | ផ្ទាល់ | ៧៥ | ៩៥(ស្រី១៣) | ២៤(ស្រី២) | ១៦២(ស្រី៣១) | ២០(ស្រី៥) |
| | | អនឡាញ | | | | | ២៤(ស្រី៨) |
| សរុប | | | ៧៥ | ៩៥(ស្រី១៣) | ២៤(ស្រី២) | ១៦២(ស្រី៣១) | ៤៤(ស្រី១៣) |
| ២ | ក្រៅប្រទេស | ផ្ទាល់ | | | | | ២៨(ស្រី៥) |
| | | អនឡាញ | ៨៦ | ៩៧(ស្រី១៤) | ៧៨(ស្រី១៤) | ១០(ស្រី១) | ៤(ស្រី១) |
| **សរុប** | | | **៨៦** | **៩៧(ស្រី១៤)** | **៧៨(ស្រី១៤)** | **១០(ស្រី១)** | **៣២(ស្រី៦)** |

## ២.១៨- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

### ក- ការងារស្រាវជ្រាវ

ក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍វិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រេចបានការងារ រួមមានៈ

- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា
- រចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា
- បញ្ចប់របាយការណ៍អង្កេតអំពី«**ទស្សនៈរបស់យុវជនលើការប្រើប្រាស់បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ ក្នុងវិស័យអប់រំ**» ដែលជាសូចនាករ លេខ២.៤.១.១ សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បញ្ចប់របាយការណ៍អង្កេតអំពី«**តម្រូវការអភិវឌ្ឍន៍បំណិនរបស់និយោជិតអំពីការប្រើប្រាស់ បច្ចេកវិទ្យា និងនវកម្មគំនិតក្នុងវិស័យសហគ្រាសមីក្រូតូច និងមធ្យម និងសាជីវកម្មខ្នាតធំ**» ដែលជាសូចនាករ លេខ២.៤.១.២ សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានចូលរួមចងក្រងសៀវភៅរង្វាស់រង្វាល់ខ្មែរបុរាណនិងសម័យ
- បានចូលរួមរៀបចំរបាយការណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០
- បានធ្វើបច្ចុប្បន្នភាពបញ្ជីធនធានមនុស្ស (បញ្ជីសារពើភណ្ឌ) ជាអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជា ក្នុងនោះ ក្រសួង ស្ថាប័នចំនួន២៤ បានឆ្លើយតប និងផ្តល់ទិន្នន័យៈ
  - ធនធានមនុស្សសរុប១០ ៨៩២នាក់(បុរស៨ ២៨១នាក់ ស្ត្រី២ ៦១១នាក់) កម្រិតបរិញ្ញាបត្រ ៧ ៧៩៥នាក់ បរិញ្ញាបត្រជាន់ខ្ពស់១ ៥៧៦នាក់ វេជ្ជបណ្ឌិត៧៩០នាក់ និងបណ្ឌិត៧៣១នាក់
  - បញ្ចប់ការសិក្សានៅទ្វីបអាស៊ី១០ ៤៥៨នាក់(កម្ពុជា៩ ៥៤៦នាក់) (ទ្វីបអឺរ៉ុប៤០១នាក់ និង ទ្វីបអាម៉េរិក៣៣នាក់)។
- បញ្ចប់ការប្រមូលទិន្នន័យនៃរបាយការណ៍អង្កេតស្តីពី«**ការតាមដាននិងវិភាគអំពីតម្រូវការបណ្តុះបណ្តាលលើជំនាញការប្រើប្រាស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងសហគ្រាសមីក្រូ តូច និងមធ្យម និងសាជីវកម្មខ្នាតធំ ព្រមទាំងស្ថាប័នអប់រំនិងវិស័យផ្សេងៗ**» ដែលជាសូចនាករលេខ ២.៤.៣.១ ដែលបានដាក់ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ខ- ការរៀបចំវគ្គបណ្តុះបណ្តាលដំបូង**

ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលដំបូងជូនសិស្សមន្ត្រី ដែលបានប្រឡងជាប់ជាស្ថាពរចូលបម្រើការងារក្នុងក្របខ័ណ្ឌ ឆ្នាំ២០១៧(២៥រូប) ក្របខ័ណ្ឌឆ្នាំ២០១៨(២០រូប) ក្របខ័ណ្ឌឆ្នាំ២០១៩(២៧រូប) ក្របខ័ណ្ឌពិសេសឆ្នាំ២០២០(៤៥រូប) ក្របខ័ណ្ឌឆ្នាំ២០២១(៨០រូប) សរុបចំនួន១៩៧រូប ដើម្បីស្វែងយល់ពីឋានានុក្រម តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋាន វិទ្យាស្ថាន មជ្ឈមណ្ឌល និងអង្គភាពនានា របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ពិសេសគឺ ដើម្បីយល់ដឹងពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

**គ- ការងារអភិវឌ្ឍធនធានមនុស្ស**

លទ្ធផលទទួលបានពីការបណ្តុះបណ្តាលបន្តតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា ការចុះធ្វើកម្មសិក្សាទស្សនកិច្ចសិក្សាទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលជាការពង្រឹង និងបង្កើនសមត្ថភាព ចំណេះដឹង ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងវិស័យផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាពជូនដល់មន្ត្រីរាជការ ព្រមទាំងធនធានមនុស្សក្នុងវិស័យឯកជន និងគ្រឹះស្ថានសិក្សានានាក្នុងនោះ៖

| ល.រ. | បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប(រូប) |
|---|---|---|---|---|---|---|---|
| ១ | ការបណ្តុះបណ្តាលក្នុងប្រទេស | ៣៥ (ស្រី៣) | ៦៦ (ស្រី៣០) | ២១៥ (ស្រី២៨) | ៧០ (ស្រី២២) | ១៥៧ (ស្រី៤៣) | **៥៤៣** |
| ២ | ការបណ្តុះបណ្តាលក្រៅប្រទេស | ២៧៤ (ស្រី៤៩) | ២៨៣ (ស្រី៣៧) | ២៦៣ (ស្រី៣២) | ២៨ (ស្រី៣) | ២៩ (ស្រី៣) | **៨៧៧** |
| ៣ | ការចុះធ្វើកម្មសិក្សា | ២ (ស្រី១) | ០ | ៤ (ស្រី១) | ១៦ (ស្រី៧) | ២៥ (ស្រី២) | **៤៧** |
| ៤ | ការចូលរួមយន្តការផ្សេងៗ | ០ | ០ | ៤៩០ (ស្រី៥៥) | ១៤០ (ស្រី៣២) | ៥០ (ស្រី១២) | **៦៨០** |
| **សរុបតាមឆ្នាំនីមួយៗ (រូប)** | | **៣១១ (ស្រី៥៣)** | **៣៤៩ (ស្រី៦៧)** | **១ ០០៤ (ស្រី១១៦)** | **២៥៤ (ស្រី៦៤)** | **២៦១ (ស្រី៦០)** | **២ ១៤៧** |

## ២.១៩- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអាកាសចរណ៍ស៊ីវិល គឺជាកិច្ចការចាំបាច់ និងមានសារៈសំខាន់ណាស់ដែលតម្រូវឱ្យមន្ត្រីជំនាញបច្ចេកទេសមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធានាបាននូវសុវត្ថិភាពនិងសន្តិសុខ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ជាពិសេសស្របតាមស្តង់ដារបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ(ICAO)។ គិតត្រឹមខែមិថុនា ឆ្នាំ២០២១នេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបណ្តុះបណ្តាលមន្ត្រីរាជការសរុបចំនួន៨២៩នាក់(ស្រី២៧១នាក់)។

## មុំទី៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ

**ក្រសួងសុខាភិបាល សម្រេចការងារបាន ដូចខាងក្រោម៖**

ក្នុងដំណើរឈានទៅសម្រេចចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០ រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ**

**ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់គោលដៅយុទ្ធសាស្ត្រ៤ នៅក្នុង **«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤»** ដើម្បីតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព នៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង តាមរយៈការលើកកម្ពស់ប្រសិទ្ធភាព និងសក្តិសិទ្ធភាពស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធាន។

ក្នុងការសម្រេចគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាលបាននិងកំពុងអនុវត្តន៍ផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០១៦-២០២០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ក្របខ័ណ្ឌជាតិនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ ដោយមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណ តាមរយៈពង្រឹងការគ្រប់គ្រងប្រព័ន្ធសុខាភិបាល ជាពិសេសការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាពមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងប្រកបដោយសមធម៌ ជូនប្រជាពលរដ្ឋកម្ពុជា នៅក្នុងគ្រប់ភូមិសាស្ត្រទូទាំងប្រទេស ដោយមិនគិតពីលក្ខខ័ណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច។

ផែនការយុទ្ធសាស្ត្រសុខាភិបាល២០១៦-២០២០ ផ្តោតអន្តរាគមន៍ជាចម្បង លើការកាត់បន្ថយការឈឺ និងស្លាប់របស់មាតា ទារក និងកុមារ ការឈឺនិងស្លាប់របស់ប្រជាពលរដ្ឋកម្ពុជាបណ្តាលមកពីជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈសំខាន់ៗ និងពង្រឹងប្រព័ន្ធសុខាភិបាល តាមរយៈ (១) ការពង្រឹងនិងពង្រីកប្រព័ន្ធផ្តល់សេវាថែទាំសុខភាព ដែលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ប្រកបដោយសមធម៌ និង(២) ពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម ដើម្បីកាត់បន្ថយរបាំងហិរញ្ញវត្ថុ ក្នុងការមកប្រើប្រាស់សេវាថែទាំសុខភាព ជាពិសេសដោយប្រជាពលរដ្ឋក្រីក្រ និងគ្រួសារមានប្រាក់ចំណូលទាប។

### ១- សមិទ្ធផលសម្រេចបានក្នុងការអនុវត្តគោលនយោបាយអាទិភាព និងសកម្មភាពអន្តរាគមន៍វិស័យសុខាភិបាល

ការអភិវឌ្ឍក្នុងវិស័យសុខាភិបាលក៏ដូចជាវិស័យនានា ដែលមានឥទ្ធិពលដោយផ្ទាល់លើសុខភាពដូចជាហេដ្ឋារចនាសម្ព័ន្ធ កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ សុទ្ធតែដើរតួនាទីដ៏សំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវិតរំពឹងទុកនៅពេលកើត និងកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ ស្ថានភាពសុខភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា ត្រូវបានធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ តាមរយៈការពង្រឹងនិងពង្រីកប្រព័ន្ធផ្តល់សេវាថែទាំសុខភាពមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព ប្រកបដោយសមធម៌ និងពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម។ ជីវិតរំពឹងទុកនៅពេលកើតក្នុងឆ្នាំ២០១៩ គឺ៧៥,៥ឆ្នាំ(បុរស៧៤,៣ឆ្នាំ ស្ត្រី៧៦,៨ឆ្នាំ) គឺបានកើនឡើងស្ទើរតែ១៧ឆ្នាំខ្ពស់ជាងជីវិតរំពឹងទុក៥៨,៦ឆ្នាំ នៅឆ្នាំ២០០០។

ការចម្លងរាតត្បាតនៃជំងឺកូវីដ-១៩ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ២០២០ បាននាំមកនូវបញ្ហាប្រឈមចម្បងដល់ប្រព័ន្ធសុខាភិបាលប្រទេសយើង។ ទោះជាដូច្នេះក្តី រហូតមកដល់នេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាគ្រប់គ្រងបានល្អ ក្នុងការបង្ការនិងទប់ស្កាត់ការចម្លងរាតត្បាតក្នុងសហគមន៍។

ការវិនិយោគធនធានរបស់រាជរដ្ឋាភិបាលកម្ពុជាលើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ការពង្រឹងប្រព័ន្ធសន្តិសុខ សុខភាពជាតិ (ប្រព័ន្ធអង្កេតតាមដានឆ្លើយតបនឹងជំងឺរាតត្បាត និងគ្រោះអាសន្នសុខភាពសាធារណៈ) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យនិងមណ្ឌលសុខភាព ការរក្សានិរន្តរភាពនៃការផ្តល់សេវាថែទាំសុខភាពសារវ័ន្តជាប្រចាំ នៅក្នុងបរិបទរាតត្បាតនៃជំងឺឆ្លង បានធ្វើឱ្យប្រទេសកម្ពុជាមានសមត្ថភាពឆ្លើយតបនឹងជំងឺកូវីដ-១៩។

## ២- ការលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ

អន្តរាគមន៍កម្មវិធីសុខភាពបន្តពូជ មាតាទារក និងកុមារ និងអាហារូបត្ថម្ភ បានផ្តោតជាចម្បងលើការពង្រីកការគ្របដណ្តប់ និងលើកកម្ពស់គុណភាព សុវត្ថិភាព និងប្រសិទ្ធភាព នៃសេវាពន្យារកំណើត ឬផែនការគ្រួសារ សេវារំលូតដោយសុវត្ថិភាព សុខភាពបន្តពូជយុវវ័យ សេវាថែទាំមុន និងក្រោយសម្រាល ថែទាំទារក សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការផ្តល់វ៉ាក់សាំងបង្ការជំងឺ ការពិនិត្យព្យាបាលជំងឺកុមារ ជាពិសេសជំងឺរលាកផ្លូវដង្ហើម និងជំងឺរាករូស ការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់បន្ថែមជីវជាតិអា និងជីវជាតិដែក (អាស៊ីតហ្វូលិក)។ល។

ជាលទ្ធផល អត្រាមរណភាពមាតាបានបន្តធ្លាក់ចុះពី១៧០ ក្នុងចំណោមទារកកើតរស់១០០ ០០០នាក់ នៅឆ្នាំ២០១៤ មកត្រឹម១៤១ ក្នុងចំណោមទារកកើតរស់១០០ ០០០នាក់ នៅឆ្នាំ២០១៩។ ការធ្លាក់ចុះអត្រាស្លាប់ទារកពី២៨ មក១៨ និងកុមារអាយុក្រោម៥ឆ្នាំពី៣៥ មក២៨ ក្នុងចំណោមទារកកើតរស់១ ០០០នាក់ រវាងឆ្នាំ២០១៤ និង២០១៩ (រូបភាពទី១)។

រូបភាពទី១ និន្នាការអត្រាមរណភាពមាតា ទារក និងកុមារអាយុក្រោម៥ឆ្នាំពីឆ្នាំ២០០៥-២០១៩




### ២.១- ការលើកកម្ពស់សុខភាពបន្តពូជ

ស្ត្រីវ័យបន្តពូជដែលបានរៀបការកំពុងប្រើប្រាស់បន្ទមធ្យោបាយពន្យារកំណើតទំនើបណាមួយ ឆ្នាំ២០២១ មានចំនួន៥៩២ ៦០៨នាក់ ឬស្មើនឹង១៨,៦០% ខ្ពស់ជាងឆ្នាំ២០១៩ ដែលមាន៦៣៣ ៦៤២នាក់ ឬស្មើនឹង ២០,៤៧% និងទាបជាងឆ្នាំ២០១៧ ដែលមានចំនួន៧៤២ ៧៨៦នាក់ ឬស្មើនឹង២៤,៨២%នៃស្ត្រីវ័យបន្តពូជដែលបានរៀបការ។

### ២.២- ការលើកកម្ពស់សុខភាពមាតានិងទារក

ឆ្នាំ២០២១ ការពិនិត្យថែទាំគភ៌លើកទីពីរមានចំនួន២៩៣ ៧៧៩ករណី(ឬស្មើនឹង៨១,៧៤%នៃចំនួនស្ត្រីមានគភ៌រំពឹងទុក) ទាបជាងឆ្នាំ២០១៩ ដែលមានចំនួន៣៦៥ ៧៦៣ករណី(ឬស្មើនឹង៩៩,៨៤%នៃចំនួនស្ត្រីមានគភ៌រំពឹងទុក) និងឆ្នាំ២០១៧ ដែលមានចំនួន៣៦៧ ៦០៨ករណី(ឬស្មើនឹង៩៩,៤២%នៃចំនួនស្ត្រីមានគភ៌រំពឹងទុក)។ ចំពោះការពិនិត្យថែទាំគភ៌លើកទីបួននៅឆ្នាំ២០២១ មានចំនួន២១២ ០៥៤ករណី(ឬស្មើនឹង៥៩%នៃចំនួនស្ត្រីមានគភ៌រំពឹងទុក) ទាបជាងឆ្នាំ២០១៩ និងឆ្នាំ២០១៧(ឆ្នាំ២០១៩ គឺ៧៧,៨១% និងឆ្នាំ២០១៧ គឺ៧៦,៨៤% នៃស្ត្រីមានគភ៌រំពឹងទុក)។

លទ្ធផលឆ្នាំ២០២១ ការសម្រាលនៅមូលដ្ឋានសុខាភិបាលមានអត្រា៨១,៣៩% ក្នុងនោះ៧៨,៧៤% សម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ និង២,៦៥% សម្រាលនៅសេវាឯកជនដែលបានរាយការណ៍។ រីឯការ

សម្រាលដោយបុគ្គលិកសុខាភិបាលមានអត្រា៨៤,៣៦% ក្នុងនោះ៨១,៧០% សម្រាលដោយសុខាភិបាលសាធារណៈ។ គួរកត់សម្គាល់ថា អត្រាសម្រាលនៅមូលដ្ឋានសុខាភិបាលនៅឆ្នាំ២០២១ ទាបជាងឆ្នាំ២០១៩ និងឆ្នាំ២០១៧ រូបភាព២ បង្ហាញពីនិន្នាការនៃការសម្រាលរវាងឆ្នាំ២០១៧-២០២១។

រូបភាពទី២ និន្នាការនៃការសម្រាលពីឆ្នាំ២០១៧-២០២១




នៅឆ្នាំ២០២១ ស្ត្រីក្រោយសម្រាលបានទទួលការពិនិត្យថៃទាំក្រោយសម្រាលលើកទី១ នៅមូលដ្ឋានសុខាភិបាលមានចំនួន២២១ ៣៦០នាក់(ឬ៦១,៥៩%នៃស្ត្រីមានគភ៌រំពឹងទុក)។ លទ្ធផលនេះទាបជាងនៅឆ្នាំ២០១៩ ដែលមានចំនួន២៤៤ ១៩៤នាក់(ឬស្មើនឹង៦៦,៤១%នៃស្ត្រីមានគភ៌រំពឹងទុក) និងទាបជាងនៅឆ្នាំ២០១៧ ដែលមានចំនួន២៥៨ ៥៦៩នាក់(ឬស្មើនឹង៧០%នៃស្ត្រីមានគភ៌រំពឹងទុក)។

### ២.៣- ការលើកកម្ពស់សុខភាពកុមារ

បច្ចុប្បន្ន កម្មវិធីជាតិផ្តល់ថ្នាំបង្ការជាប្រចាំដល់កុមារចំណុចអាយុក្រោមមួយឆ្នាំ រួមមានវ៉ាក់សាំងបង្ការជំងឺរបេង ខាន់ស្លាក់ ក្អកមាន់ តេតាណូស គ្រុនស្វិតដៃជើង កញ្ជ្រឹល រលាកថ្លើម ប្រភេទបេនិងរលាកស្រោមខួរក្បាល រលាកសួត-ស្អូច និងវ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូនលើកុមារីអាយុក្រោម១២ឆ្នាំ។ រូបភាព៣ បង្ហាញពីនិន្នាការនៃការគ្របដណ្តប់ការផ្តល់វ៉ាក់សាំង បង្ការដល់កុមារអាយុក្រោមមួយឆ្នាំពីឆ្នាំ ២០១៧-២០២១។

រូបភាពទី៣ និន្នាការនៃការគ្របដណ្តប់ការផ្តល់វ៉ាក់សាំងបង្ការ DPT-HepB-Hib3(៣ដូស) និងកញ្ជ្រិល ស្អូច (ដូសទី១) ដល់កុមារពីឆ្នាំ២០១៧-២០២១




ឆ្នាំ២០២១ ការពិនិត្យជំងឺក្រៅករណីជំងឺថ្មីកុមារអាយុក្រោមប្រាំឆ្នាំនៅមូលដ្ឋានសុខាភិបាលសាធារណៈ មានចំនួន១ ៨៥៣ ០១១ករណី និងនៅសេវាឯកជនដែលបានរាយការណ៍មានចំនួន៣៧៨ ២៤៤ករណី ដោយគិត

ជាចំនួនលើកនៃការពិនិត្យជំងឺក្រៅករណីថ្មី ក្នុងម្នាក់ក្នុង១ឆ្នាំ គឺ១,២៥លើក។ ចំនួននេះទាបជាងឆ្នាំ២០១៧ ដែលមាន១,៥៥លើក និងទាបជាងឆ្នាំ២០១៩ដែលមាន១,៦១លើក។ រូបភាព៤ បង្ហាញពីនិន្នាការនៃការពិនិត្យពិគ្រោះជំងឺក្រៅកុមារអាយុក្រោម៥ឆ្នាំ ពីឆ្នាំ២០១៧-២០២១។

រូបភាពទី៤ និន្នាការនៃការពិនិត្យពិគ្រោះជំងឺក្រៅកុមារអាយុក្រោម៥ឆ្នាំក្នុងម្នាក់ក្នុង១ឆ្នាំ




## ២.៤- ការកែលម្អកង្វះអាហារូបត្ថម្ភ

ទារកកើតរស់បានទទួលការបំបៅដោយទឹកដោះម្ដាយ នៅក្នុងម៉ោងដំបូងក្រោយកំណើត បានកើនឡើងពីចំនួន១៩៧ ៨៨៣នាក់ ឬស្មើនឹង៦៣%នៃទារកកើតរស់នៅឆ្នាំ២០១៧ ទៅចំនួន២០០ ៥៩៩នាក់ ឬស្មើនឹង៦៥,៣៦% នៃទារកកើតរស់៣០៦ ៨៩១នាក់ នៅឆ្នាំ២០១៩ និងកើនទៅចំនួន២០៥ ៩៦៩នាក់ ឬស្មើនឹង៧២,២៣%នៃទារកកើតរស់២៨៥ ១៧៣នាក់ ដែលបានកើតនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈនៅឆ្នាំ២០២១។

កុមារអាយុពី១២-៥៩ខែ ដែលបានទទួលថ្នាំម៉េបង់ដាហ្សុលជុំទី២ ៦ខែចុងឆ្នាំ២០២១ សម្រេចបានចំនួន៨៨៥ ០៨៤នាក់(លទ្ធផលឆ្នាំ២០១៩ សម្រេចបាន១ ០៧៤ ៥៦២នាក់ និងឆ្នាំ២០១៧ សម្រេចបាន១ ០៤០ ៤០៨នាក់)។

តារាងទី១ លទ្ធផលនៃកម្មវិធីសុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ

| ល.រ. | សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១* |
|---|---|---|---|---|---|---|
| ១ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប (%) | ២៤,៨២ | ២១,៩២ | ២០,៤៧ | ២០,១២ | ១៨,៦០ |
| ២ | សមាមាត្រនៃការសម្រាលដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | ៨៨,៩៩ | ៨៧,២៩ | ៨៩,៤៨ | ៩១,៨១ | ៨៤,៣៦ |
| ៣ | សមាមាត្រការសម្រាលនៅមូលដ្ឋានសុខាភិបាល(%) | ៨៥,៣៧ | ៨៤,០៥ | ៨៦,៧៥ | ៨៩,១៦ | ៨១,៣៩ |
| ៤ | អត្រាសម្រាលដោយវិធីវះកាត់ (%) | ៥,៨៤ | ៦,៧៧ | ៧,១៣ | ៧,៦៧ | ៦,៥៨ |
| ៥ | ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលបួនលើកដោយបុគ្គលិកសុខាភិបាល (%) | ៧៦,៨៤ | ៧៧,២១ | ៧៧,៨១ | ៧៤,១៤ | ៥៩ |
| ៧ | ភាគរយនៃកុមារបានទទួលការបំបៅដោយទឹកដោះម្ដាយក្នុងកំឡុងម៉ោងទីមួយនៃកំណើត | ៦៣,៨៥ | ៦៧ | ៦៥,៣៦ | ៧១,១៤ | ៧២,២៣ |
| ៨ | ភាគរយស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ | ៨៨,៨០ | ៧៩,៩៩ | ៩១,០៥ | ៨៩,៤៧ | ៨២ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | ភាគរយស្ត្រីក្រោយសម្រាលបាន ទទួលគ្រាប់ជីវជាតិដែក/អាស៊ីតហ្វូលិក៤២គ្រាប់ | ៧៨,៣០ | ៧០ | ៧៨,៦៩ | ៨០,៩៦ | ៧៤ |
| ១០ | ភាគរយនៃកុមារអាយុ៦-៥៩ខែបានទទួលគ្រាប់ថ្នាំជីវជាតិអា (ជុំទី២) | ៨១,៩៧ | ៧៨,២០ | ៧៣,០៤ | ៧៤,០ | ៧៣ |
| ១១ | ភាគរយនៃកុមារអាយុ១២-៥៩ខែបានទទួលថ្នាំទម្លាក់ព្រូនមេបង់ដាហ្សុល (ជុំទី ២) | ៨០,០ | ៧៨,០៩ | ៧៥,១៥ | ៧៦,០ | ៦១,៨៦ |
| ១២ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូស បង្ការជំងឺខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកថ្លើមប្រភេទបេ រលាកសួត/លាកស្រោមខួរ (%) | ៩៧,៦៤ | ៩៨ | ៩៩,០ | ១០៦,៦ | ៩៩ |
| ១៣ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូច ដូសទី១ (នៅខែទី៩) (%) | ៩៦ | ១០៣ | ១០២ | ១០៧,៣ | ១០២,៦៨ |
| ១៤ | ពិនិត្យពិគ្រោះជំងឺករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ | ១,៥៥ | ១,៦០ | ១,៦១ | ១,២៨ | ១,២៥ |

ប្រភព៖ - របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៧ ឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០

- * ទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលឆ្នាំ២០២១

### ៣- ការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩(២០២០-២០២១)

រយៈពេលមួយឆ្នាំ ចាប់តាំងពីការរកឃើញនូវការរាតត្បាតនៃជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ អាស្រ័យដោយការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាគ្រប់គ្រងនិងទប់ស្កាត់បានការចម្លងរាតត្បាតនៃកូវីដ-១៩ ក្នុងសហគមន៍ដោយគ្មានការដាក់ប្រទេសក្នុងគ្រាអាសន្ន គ្មានការបិទជាតំបន់ ឬប្រទេសទាំងមូល គ្មានករណីស្លាប់ និងគ្មានការចម្លងដល់គ្រូពេទ្យ និងបុគ្គលិកសុខាភិបាលជួរមុខ។ ការវិនិយោគធនធានរបស់រាជរដ្ឋាភិបាល នៅក្នុងបណ្តាឆ្នាំកន្លងមក រហូតមកដល់បច្ចុប្បន្ននេះ លើការពង្រឹងប្រព័ន្ធសន្តិសុខសុខភាពជាតិ (ប្រព័ន្ធអង្កេតតាមដាន និងឆ្លើយតបជំងឺឆ្លង និងគ្រោះអាសន្នសុខភាពសាធារណៈ) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យនិងមណ្ឌលសុខភាព ការរក្សានិរន្តរភាពនៃការផ្តល់សេវាថែទាំសុខភាពសារវ័ន្តជាប្រចាំ នៅក្នុងបរិបទនៃការរាតត្បាតដោយជំងឺឆ្លង បានធ្វើឱ្យប្រទេសកម្ពុជាមានសមត្ថភាពឆ្លើយតបនឹងជំងឺកូវីដ-១៩។

#### ៣.១- ផែនការជាតិឆ្លើយតបទៅនឹងជំងឺកូវីដ-១៩

នៅព្រះរាជាណាចក្រកម្ពុជា (ខែមិនាឆ្នាំ២០២០ ដល់ខែកុម្ភៈឆ្នាំ២០២១) មានគោលដៅយុទ្ធសាស្ត្រ៣ (១) បង្ការការចម្លងនិងបន្ថយករណីជំងឺធ្ងន់ធ្ងរ និងការស្លាប់ដែលជាប់ទាក់ទងនឹងជំងឺកូវីដ-១៩ (២) ធានាការផ្តល់សេវាសុខភាពជាសារវ័ន្ត និងការត្រៀមបម្រុងសម្រាប់ដំណាក់កាលរាតត្បាតខ្លាំង និង(៣) កាត់បន្ថយផលប៉ះពាល់តាមយន្តការឆ្លើយតបពហុវិស័យគាំទ្រដល់វិធានការសុខភាពសាធារណៈ និងវិធានការទូលាយផ្នែកសង្គមនិងសេដ្ឋកិច្ច។

ការទប់ស្កាត់ការរីករាលដាលកូវីដ-១៩ មានការចូលរួមយ៉ាងសកម្មពីក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច (រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំសង្កាត់ មន្ត្រីភូមិ) កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន គ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ(ធីតា) ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តបទបញ្ជា និងវិធានការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល។

វិធានការជាយុទ្ធសាស្ត្រដែលបានអនុវត្តរួមមាន ស្វែងរកអ្នកប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ជាមួយអ្នកជំងឺកូវីដ-១៩ ឱ្យបានរហ័ស ដាក់អ្នកមានតេស្តជំងឺកូវីដ-១៩ វិជ្ជមានឱ្យនៅដោយឡែកដើម្បីព្យាបាលឱ្យបានទាប់និងដាក់អ្នកសង្ស័យប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ឱ្យធ្វើចត្តាឡីស័កនៅតាមទីតាំងដែលបានកំណត់ដោយក្រសួងសុខាភិបាល និងរដ្ឋបាលមូលដ្ឋាន ពង្រឹងការអនុវត្តវិធានការណែនាំ វិធានការសុខភាពសាធារណៈ និងផ្តល់ព័ត៌មានទាន់ហេតុការណ៍ត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលាអំពីស្ថានការណ៍វិវត្តន៍នៃការចម្លងជំងឺកូវីដ-១៩ ជាប្រចាំដល់សាធារណជន។

ការទប់ស្កាត់ (១) ការរាតត្បាតក្នុងសហគមន៍៣វិច្ឆិកា បានរកឃើញករណីវិជ្ជមានជំងឺកូវីដ-១៩ ចំនួន ៤នាក់ និងបានធ្វើតេស្តអ្នកប៉ះពាល់សរុបជាង៥ ០០០វត្ថុវិភាគ (២) ការរាតត្បាតក្នុងសហគមន៍២៨វិច្ឆិកា បានរកឃើញវិជ្ជមានជំងឺកូវីដ-១៩ ចំនួន៤១នាក់ និងបានធ្វើតេស្តអ្នកប៉ះពាល់សរុប៤១ ៦៨៣វត្ថុវិភាគ (៣) ការរាតត្បាតក្នុងសហគមន៍ក្នុងខេត្តសមុទ្រសាគរប្រទេសថៃ នៅពេលពលករខ្មែរវិលត្រឡប់មកផ្ទះវិញតាមព្រំដែនខេត្តទាំង៧ ខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ និងខេត្តកោះកុង។ រហូតមកដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១ បានធ្វើតេស្ត២០ ៩១៣វត្ថុវិភាគ និងរកឃើញករណីវិជ្ជមាន៦៩នាក់។

គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ការរកឃើញករណីវិជ្ជមានជំងឺកូវីដ-១៩ មានចំនួន១២០ ១៦០ នាក់ ករណីស្លាប់ចំនួន២ ៩៤៤នាក់ និងករណីជាសះស្បើយចំនួន១១៦ ៥២៩នាក់។

គិតមកដល់ខែវិច្ឆិកា ឆ្នាំ២០២១ ព្រះរាជាណាចក្រកម្ពុជា មានវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សរុបចំនួន**៣៧ ៧៩៤ ៨០០ដូស** ក្នុងនោះ រាជរដ្ឋាភិបាលបានទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជាប្រភេទស៊ីណូហ្វាម ចំនួន**៣ ៨០០ ០០០ដូស** និងប្រភេទស៊ីណូវ៉ាក់ ចំនួន**៧ ០០០ ០០០ដូស** ពីសាធារណរដ្ឋប្រជាមានិតចិន ប្រភេទកូវីសែលចំនួន**៣២៤ ០០០ដូស** ជាជំនួយពីមជ្ឈមណ្ឌលកូវ៉ាក់នៃអង្គការសុខភាពពិភពលោក ប្រភេទអាស្ត្រាហ្សេនីកាចំនួន**១ ០០៧ ៥០០ដូស** ពីរដ្ឋាភិបាលជប៉ុន ប្រភេទ Johnson & Johnson ចំនួន**១ ០៦០ ១០០ដូស** ជាជំនួយពីសហរដ្ឋអាម៉េរិក ប្រភេទអាស្ត្រាហ្សេនីកា ចំនួន**៤១៥ ០៤០ដូស** ជាជំនួយពីចក្រភពអង់គ្លេស និងប្រភេទ Moderna ចំនួន**១៨៨ ១៦០ដូស** ជាជំនួយពីអង្គការសុខភាពពិភពលោក ព្រមទាំងធ្វើការបញ្ជាទិញប្រភេទវ៉ាក់សាំងស៊ីណូហ្វាម ចំនួន**៤ ០០០ ០០០ដូស** និងប្រភេទវ៉ាក់សាំងស៊ីណូវ៉ាក់ចំនួន**២០ ០០០ ០០០ដូស** ពីសាធារណរដ្ឋប្រជាមានិតចិន។

គិតត្រឹមថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០២១ អ្នកដែលមានអាយុលើសពី១៨ឆ្នាំ បានទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សរុបនៅទូទាំងព្រះរាជាណាចក្រកម្ពុជាមានចំនួន**១០ ១៦៤ ០២៩នាក់**(ស្រី៥ ១៤០ ៨០៥ នាក់) ស្មើនឹង**១០០,៩២%**នៃផែនការ**១០លាននាក់** ក្នុងនោះ អ្នកចាក់វ៉ាក់សាំងលើកទី២ បានចំនួន**៩ ៧២៦ ៣២៨ នាក់**(ស្រី៤ ៨៩៦ ៦៦១នាក់) អ្នកចាក់វ៉ាក់សាំងដូសជំរុញលើកទី៣ បានចំនួន**២ ២៧២ ៤៧៩នាក់**(ស្រី ១ ០៨៥ ០៧៧នាក់)។ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារ និងយុវជនអាយុ១២ឆ្នាំ ដល់ក្រោមអាយុ ១៨ឆ្នាំ សរុបទូទាំងប្រទេសបានចំនួន**១ ៨០៤ ៩៤៣នាក់**(ស្រី៨៩២ ១១៣នាក់)នៃផែនការប្រមាណ**២លាននាក់** ស្មើនឹង**៩៨,៧៣%** ក្នុងនោះ អ្នកចាក់វ៉ាក់សាំងដូសទី២ បានចំនួន**១ ៧១៨ ៣១៥នាក់**(ស្រី៨៥២ ៧៤៥នាក់)។ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារ និងយុវជន៦ឆ្នាំដល់ក្រោមអាយុ១២ឆ្នាំ សរុបទូទាំងប្រទេស បានចំនួន**១ ៩៨១ ៨៨៥នាក់**(ស្រី៩៧៥ ៥៩១នាក់)នៃផែនការប្រមាណ**២លាននាក់** ស្មើនឹង**១០៤,៤៤%** ក្នុងនោះ អ្នកចាក់វ៉ាក់សាំងដូសទី២ បានចំនួន**១ ៨៥៩ ១១៨នាក់**(ស្រី៩១៨ ២២០នាក់)។ ការចាក់វ៉ាក់សាំង

បង្ការជំងឺកូវីដ-១៩ ជូនកុមារអាយុ៥ឆ្នាំសរុបទូទាំងប្រទេសបានចំនួន**២៦៧ ៨៩២នាក់**(ស្រី១៣៤ ៤០៤នាក់) នៃផែនការប្រមាណ**៣សែននាក់** ស្មើនឹង៨៨,០៣% ក្នុងនោះអ្នកចាក់វ៉ាក់សាំងដូសទី២ បានចំនួន**៤៧ ៧៥៣នាក់**(ស្រី២៣ ៩៣៦នាក់)។

លទ្ធផលសរុបការទទួលចាក់វ៉ាក់សាំងធៀបនឹងប្រជាជនចំនួន**១៦លាននាក់** បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចំនួន**១៤ ២១៨ ៧៤៩នាក់**(ស្រី៧ ១៤២ ៩៣៣នាក់) ស្មើនឹង៨៨,៤១%។

### ៣.២- ការចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៃក្រសួងការពារជាតិ

បណ្តាមន្ទីរពេទ្យ គិលានដ្ឋានទូទាំងកងយោធពលខេមរភូមិន្ទនិងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** ទទួលពិនិត្យពិគ្រោះព្យាបាលជំងឺផ្សេងៗជូនកងទ័ព គ្រួសារកងទ័ពនិងប្រជាពលរដ្ឋបានចំនួន៣២៦ ៩៧៧លើក/នាក់ ពិនិត្យវិភាគវេជ្ជសាស្ត្របានចំនួន៩៩៧ ៩១៤វិភាគ និងទទួលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យជាសះស្បើយចំនួន៨៨ ៥៦៧នាក់។

នៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ កងយោធពលខេមរភូមិន្ទបានចូលរួមយ៉ាងសកម្មក្នុងការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋទូទៅ និងបានពង្រឹងសមត្ថភាពសង្គ្រោះព្យាបាល ការពិសោធន៍រាវរកមេរោគ ការធ្វើចត្តាឡីស័ក ដើម្បីឆ្លើយតបវិធានការនានារបស់រាជរដ្ឋាភិបាលនិងក្រសួងសុខាភិបាលៈ

- គិតត្រឹមថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ មន្ទីរពេទ្យព្រះកេតុមាលាបានយកសំណាកប្រជាពលរដ្ឋនៅខេត្តកំពត ស្វាយរៀង តាកែវ ព្រៃវែង កណ្តាល ក្រចេះ ត្បូងឃ្មុំ ស្ទឹងត្រែង ព្រះវិហារ រតនគិរីនិងខេត្តមណ្ឌលគិរី ធ្វើតេស្តរកមេរោគកូវីដ-១៩ សរុបចំនួន២១៥ ៦៥០នាក់ លទ្ធផលវិជ្ជមានចំនួន៤៧ ២៨៤នាក់
- គិតត្រឹមថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១ កងយោធពលខេមរភូមិន្ទចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកងទ័ពនិងគ្រួសារ កងនគរបាលការពារព្រំដែនគោក ព្រំដែនទឹក អតីតយុទ្ធជន កីឡាករ កីឡាការិនី សមាជិកសមាគមសភាពាណិជ្ជកម្មចិន បុគ្គលិកកម្មករសំណង់វិស្វកម្ម ព្រមទាំងប្រជាពលរដ្ឋ កម្មករ កម្មការិនីនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញនិងតាមបណ្តាខេត្ត ចាក់ដូសទី១បាន២ ៧៥៩ ៨៤៤នាក់(នារី១ ៤០២ ៧២៨នាក់) ដូសទី២បាន២ ៧៣២ ៣៨០នាក់(នារី១ ៣៧២ ១៧៣នាក់) និងដូសទី៣បាន៩២៤ ១៥២នាក់(នារី៤៣៣ ៩០១នាក់)។

ដោយឡែកក្រុមគ្រូពេទ្យស្ម័គ្រចិត្ត**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** បានដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋនៅភូមិសាស្ត្ររាជធានីភ្នំពេញនិងនៅភូមិសាស្ត្រស្រុកស្អាង ខេត្តកណ្តាល ចាក់ដូសទី១បាន១៩៣ ៥២២នាក់(នារី៩៣ ៦១៨នាក់) ដូសទី២បាន១៧០ ៩៤៤នាក់(នារី៨២ ០៩៧នាក់ និងដូសទី៣ឬដូសជំរុញបាន៤៣ ៤៨២(នារី២២ ៦០១នាក់)។

## ៤- ការកាត់បន្ថយការឈឺនិងស្លាប់ដែលបណ្តាលមកពីជំងឺឆ្លងផ្សេងទៀត

### ៤.១- ការបន្ថយបន្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ

ប្រទេសកម្ពុជាបានទទួលជោគជ័យ ក្នុងការកាត់បន្ថយប្រេវ៉ាឡង់នៃការចម្លងមេរោគអេដស៍ពី០,៩% នៅឆ្នាំ២០០៦ មកនៅ០,៥០% នៅឆ្នាំ២០២០។ តាមការប៉ាន់ស្មាន ក្នុងឆ្នាំ២០២០ ករណីឆ្លងថ្មីនៃមេរោគអេដស៍កើតមានលើប្រជាជន១ ១០០នាក់ ឬស្មើនឹង០,០៧% ក្នុងចំណោមប្រជាជន ដែលគ្មានផ្ទុកមេរោគអេដស៍១ ០០០នាក់ (ចាប់ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩ គឺ០,០៣%)។

ឆ្នាំ២០២១ (លទ្ធផល៩ខែ) អ្នកជំងឺសកម្មកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មានចំនួន៦២ ៤០៧នាក់ ស្មើនឹង៩៩,៩១%នៃអ្នកផ្ទុកមេរោគអេដស៍សរុប៦២ ៤៦១នាក់(ឆ្នាំ២០១៩ មាន

ចំនួន៦០ ៦៨៤នាក់ ស្មើនឹង៨៩% និងឆ្នាំ២០១៨ មានចំនួន៥៩ ៥២៦នាក់ ស្មើនឹង៨៧,២២%)។ រីឯមនុស្សពេញវ័យនិងកុមារដែលរស់នៅជាមួយមេរោគអេដស៍ កំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានធ្វើតេស្ត Viral Load និងមានលទ្ធផល Viral Load Suppressed នៅឆ្នាំ២០២១ គឺ៩៧,៣២%(លទ្ធផលឆ្នាំ២០១៧ គឺ ៨០,៧៨% និងឆ្នាំ២០១៩ គឺ៨៩,០%)។

**៤.២- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍(ឆ្នាំ២០១៧-២០២១)**

ប្រទេសកម្ពុជាបានប្តេជ្ញាក្នុងការបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈនៅឆ្នាំ២០២៥ គឺមុន៥ឆ្នាំនៃការកំណត់របស់អង្គការសហប្រជាជាតិដែលបានកំណត់យកឆ្នាំ២០៣០។ ទន្ទឹមនឹងនោះ យើងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ដែលត្រូវសម្រេចគោលដៅ៩០-៩០-៩០ (ដែលមានន័យថា៩០% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩០%នៃអ្នកដែលដឹងស្ថានភាពផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩០% នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន)នៅឆ្នាំ២០២០។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ បានកំណត់ថាត្រូវសម្រេចគោលដៅ៩៥-៩៥-៩៥នៅឆ្នាំ២០២៥ ដោយឈរលើគោលការណ៍ការចូលរួមប្រកបដោយថាមវន្តនៃភាគីពាក់ព័ន្ធ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។ លើសពីនេះ យើងបាននិងកំពុងអនុវត្តនូវវិធានការ៦ចំណុច ដើម្បីធានាចីរភាពក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលតាមសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានឈរលើគោលការណ៍បីមួយ គឺស្ថាប័នសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រជាតិតែមួយ និងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃតែមួយ ដោយគោរពគោលការណ៍មិនទុកនរណាម្នាក់ចោលដោយមិនបានយកចិត្តទុកដាក់ឡើយ។

**សមិទ្ធផលសំខាន់ៗនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឈរលើមូលដ្ឋានគ្រឹះនៃសសរស្តម្ភបី រួមមាន (១) មគ្គុទ្ទេសក៍ភាព និងភាពជាម្ចាស់ (២) ភាពជាដៃគូ និង(៣) ការវិនិយោគ។**

១- មគ្គុទ្ទេសក៍ភាព និងភាពជាម្ចាស់ក្នុងការដឹកនាំ ពង្រឹងការទទួលខុសត្រូវ និងភាពជាម្ចាស់ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទូលំទូលាយនិងពហុវិស័យ ដើម្បីសម្រេចគោលដៅក្នុងការបញ្ចប់អេដស៍នៅឆ្នាំ២០២៥។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ថា«**ទាំងអស់គ្នាចូលរួមជាចន្លដជាតិមួយក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍**»។ ដើម្បីធានាចីរភាពនៃកម្មវិធីនាពេលអនាគត ក្នុងពេលដែលជំនួយអន្តរជាតិកាន់តែមានការថយចុះ រាជរដ្ឋាភិបាលបានខិតខំបង្កើនថវិកាជាតិជួយទិញឱសថព្យាបាលអ្នកជំងឺអេដស៍ ជាមួយនឹងការពង្រីកថវិកាសេវាសង្គមនៅថ្នាក់ជាតិ និងក្រោមជាតិ។ យើងក៏បានរៀបចំនូវផែនទីបង្ហាញផ្លូវសម្រាប់ចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ផងដែរ (Sustainability Road Map)។

២- ភាពជាដៃគូ ការចូលរួមប្រកបដោយថាមវន្ត និងការធ្វើការងារជិតស្និទ្ធពីគ្រប់ដៃគូពាក់ព័ន្ធពីស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងក្រុមប្រជាជនគន្លឹះ។ ក្នុងនោះ យើងបានបញ្ចូលតំណាងក្រុម

ប្រជាជនគន្លឹះទៅក្នុងយន្តការនៃការឆ្លើយតបនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាមួយក្រសួងសុខាភិបាល យើងបានធ្វើការងារសមាហរណកម្មឆ្លើយតបនឹងជំងឺអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល។ ក្រៅពីនោះ ជាមួយក្រសួងផែនការយើងបានធ្វើការងារផ្តល់បណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ ដើម្បីទទួលបានប្រយោជន៍បន្ថែមក្នុងការថែទាំសុខភាព និងការគាំទ្រសង្គម។ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យើងបានធ្វើការងារលើកិច្ចគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍។ ជាមួយក្រសួងមហាផ្ទៃ យើងបានធ្វើការងារលើការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ ទៅក្នុងគោលនយោបាយ«**ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព**» និងដាក់សំណុំសកម្មភាពឆ្លើយតបមេរោគអេដស៍ ការបង្កបរិយាកាសអំណោយផល និងផ្តល់ការគាំទ្រសង្គមដល់គ្រួសារអ្នកផ្ទុកមេរោគអេដស៍ ចូលក្នុងផែនការសកម្មភាពរាជធានី ខេត្ត ប្រឈមខ្ពស់ចំនួន៤(រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប) និងផែនការអភិវឌ្ឍន៍ ព្រមទាំងផែនការវិនិយោគឃុំសង្កាត់។ យើងក៏បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងឡាយបន្តជំរុញការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងការអប់រំបង្ការការឆ្លងមេរោគអេដស៍ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងចំណោមក្រុមប្រជាជនគន្លឹះ ក្រុមយុវវ័យ បុគ្គលិក សហគ្រាស គ្រឹះស្ថាននានា ពលរដ្ឋចំណាកស្រុក និងវិស័យទេសចរណ៍។

៣- ការវិនិយោគ ទាន់ពេលវេលា និងជាបន្តបន្ទាប់ ទាំងធនធានមនុស្ស និងថវិកា សម្រាប់ការឆ្លើយតបមេរោគអេដស៍ ដោយផ្លាស់ប្តូរពីភាពពឹងផ្អែកទៅការឆ្លើយតបប្រកបដោយនិរន្តរភាពចំពោះការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការអនុវត្តវិធានការ៦ចំណុចទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានចែងក្នុងសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។ ផែនការយុទ្ធសាស្ត្រជាតិលើកទី៥ បានបញ្ជាក់ពីការផ្តល់កិច្ចគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ ការងារសមាហរណកម្ម កម្មវិធីអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល និងការងារកិច្ចសន្យាសង្គមលើការងារផ្តល់សេវាឆ្លើយតបមេរោគអេដស៍។ យើងបានសម្របសម្រួល និងចលនាធនធានពីគ្រប់ដៃគូអភិវឌ្ឍន៍រួមមាន មូលនិធិសកល អង្គការសហប្រជាជាតិ ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាម៉េរិក ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី(GF, UN, USAID, DEFAT)។ ចាប់តាំងពីឆ្នាំ២០១៥មក រាជរដ្ឋាភិបាលបានចូលរួមនូវថវិកាជាតិចំនួន**១,៥លានដុល្លារអាម៉េរិក**ក្នុងមួយឆ្នាំ ហើយបានបន្តចូលរួមក្នុងបរិមាណដូចគ្នារហូតដល់ឆ្នាំ២០២០ ព្រមទាំងយល់ព្រមទទួលយកបន្ទុកចំណាយលើបុគ្គលិកកិច្ចសន្យា ក្នុងទំហំទឹកប្រាក់ចំនួនប្រមាណ**១លានដុល្លារអាម៉េរិក**ថែមទៀត។ ជារួមរាជរដ្ឋាភិបាលបានចូលរួមថវិកាបដិភាគចំនួន**៩,៤៥លានដុល្លារអាម៉េរិក**សម្រាប់បីឆ្នាំ(ឆ្នាំ២០១៨-២០២០) និងគ្រោងថវិកាបដិភាគចំនួន**១៣,២៥លានដុល្លារអាម៉េរិក**សម្រាប់បីឆ្នាំ(ឆ្នាំ២០២១-២០២៣)។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានចូលរួមថវិកាបដិភាគលើការឆ្លើយតបមេរោគអេដស៍បាន៣៥%(ឆ្នាំ២០២០) និងប្តេជ្ញាបន្ថែមរហូតដល់៥០%(ឆ្នាំ២០២៣)។ ជាក់ស្តែងបានផ្តល់ថវិកាចំនួន**៨,៣លានដុល្លារអាម៉េរិក** គឺស្មើនឹង២៤% នៅឆ្នាំ២០១៧។

## សមិទ្ធផលទៅតាមសូចនាករ

| | | | | |
|---|---|---|---|---|
| អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុពី១៥ ទៅ៤៩ឆ្នាំ | ០,៦៣% | ០,៦០% | ០,៥៧% | ០,៥៤% |
| ចំនួនអ្នកឆ្លងមេរោគអេដស៍ថ្មី/ឆ្នាំ | ១ ២០០ | ១ ២០០ | ១ ២០០ | ១ ១០០ |
| ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍/ឆ្នាំ | ១ ៥០០ | ១ ៤០០ | ១ ៣០០ | ១ ២០០ |
| អត្រាគ្របដណ្តប់ដោយកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (PMTCT) | ៨៨% | ៨៤% | ៧៩% | ៨៦% |
| អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូន | ១៥% | ១៦,៤% | ១៣,៩% | ១១,៨% |
| ភាគរយនៃបដិភាគថវិកាជាតិសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ | ២៤% | ២៨% | ៣១% | ៣៣% |
| អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុពី១៥ ទៅ៤៩ឆ្នាំ | ០,៦៣% | ០,៦០% | ០,៥៧% | ០,៥៤% |
| ចំនួនអ្នកឆ្លងមេរោគអេដស៍ថ្មី/ឆ្នាំ | ១ ២០០ | ១ ២០០ | ១ ២០០ | ១ ១០០ |
| ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍/ឆ្នាំ | ១ ៥០០ | ១ ៤០០ | ១ ៣០០ | ១ ២០០ |
| អត្រាគ្របដណ្តប់ដោយកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (PMTCT) | ៨៨% | ៨៤% | ៧៩% | ៨៦% |
| អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូន | ១៥% | ១៦,៤% | ១៣,៩% | ១១,៨% |
| ភាគរយនៃបដិភាគថវិកាជាតិសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ | ២៤% | ២៨% | ៣១% | ៣៣% |

១- កម្ពុជាបានសម្រេចបានគោលដៅ៩០-៩០-៩០ នៅឆ្នាំ២០១៧ មុនកាលកំណត់ក្នុងចំណោមប្រទេសចំនួន៧ នៅក្នុងពិភពលោកដែលប្រកាសទទួលស្គាល់ដោយកម្មវិធីអង្គការសហប្រជាជាតិUNAIDS

២- កម្ពុជាសម្រេចបានគោលដៅពីរក្នុងចំណោមគោលដៅទាំងបីនៃគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។ ជាលទ្ធផលនៅឆ្នាំ២០២១ សម្រេចបាន៨៤%(៩៥ទី១) បាន៩៩%(៩៥ទី២) និងបាន៩៧% (៩៥ទី៣)

៣- ការមាក់ងាយ និងរើសអើងពីខាងក្រៅលើអ្នកផ្ទុកមេរោគអេដស៍មានការធ្លាក់ចុះ ជាពិសេសការបដិសេធមិនផ្តល់ការងារគឺមានប្រមាណពី៤៦% នៅឆ្នាំ២០១០ មកនៅត្រឹមតែប្រមាណ២% នៅឆ្នាំ២០១៩។ ការបំពានជាពាក្យសម្តីមានប្រមាណពី១៤% នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩។ ប៉ុន្តែការមាក់ងាយ និងរើសអើងដោយខ្លួនឯង ជាពិសេសអារម្មណ៍ខ្មាស់អៀន នៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភនៅឡើយដោយមានអត្រា៧១,៥% (Stigma Index 2010) និង៦២,៧% (Stigma Index 2019)

៤- តាមរយៈការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល រហូតមកដល់ពេលនេះ អ្នកផ្ទុកមេរោគអេដស៍ប្រមាណ៤៧% បានទទួលការគាំពារសុខភាពសង្គម ដែលក្នុងនោះ៩៨% ទទួលបានមូលនិធិសមធម៌ (HEF) និងមាន៥៤%ទៀត ទទួលបានបណ្ណសមធម៌ (តាមរយៈ Stigma Index 2019)

៥- តាមរយៈការអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះ(មានគ្រួសារអ្នកផ្ទុកមេរោគអេដស៍) ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩(មិថុនា ២០២០-កក្កដា ២០២១) ដែលអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រហូតមកដល់ពេលនេះ គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ចំនួន១ ៩៧៤គ្រួសារ បានទទួលសាច់ប្រាក់ឧបត្ថម្ភសរុបចំនួន៥១៥ ០០៤ ០០០រៀល

៦- ក្រសួងបានដឹកនាំសម្របសម្រួល និងចលនាប្រភពធនធាន បច្ចេកទេស និងថវិកា ក្នុងការឆ្លើយតបមេរោគអេដស៍ ដោយយើងទទួលបានថវិកាពីមូលនិធិសកលចំនួន៤១លានដុល្លារអាមេរិក សម្រាប់រយៈពេលបីឆ្នាំ (ឆ្នាំ២០១៨-២០២០)និង៤១,៦លានដុល្លារអាមេរិក សម្រាប់បីឆ្នាំបន្ត(ឆ្នាំ២០២១-២០២៣)

៧-កម្ពុជានឹងធានាឱ្យបាននូវចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយគណៈ-កម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងទាំងថ្នាក់ក្រោមជាតិធ្វើការបញ្ជ្រាប និងបញ្ចូលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់។

### ៤.៣- ការបន្ថយបន្ទុកជំងឺរបេង

យោងតាមរបាយការណ៍ស្តីពីជំងឺរបេងសកលលោកឆ្នាំ២០២១(Global Tuberculosis report 2021) ដែលចេញផ្សាយដោយអង្គការសុខភាពពិភពលោក(WHO) ពីទីក្រុងហ្សឺណែវបានបញ្ជាក់យ៉ាងច្បាស់ជាថ្មីទៀតថា«**កម្ពុជាបាននិងកំពុងទទួលបានជោគជ័យយ៉ាងល្អប្រសើរក្នុងសកម្មភាពប្រយុទ្ធនឹងជំងឺរបេង**»។

ជាក់ស្តែងតាមរបាយការណ៍ ក្នុងរយៈពេល២០ឆ្នាំ កន្លងមកនេះ អត្រាឈឺ និងអត្រាស្លាប់ដោយជំងឺរបេងនៅកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំង បើប្រៀបធៀបនឹងបណ្តាប្រទេសដទៃទៀត។ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០២០ អត្រាស្លាប់ដោយជំងឺរបេងបានធ្លាក់ចុះ៥២% ពី៤២នាក់ នៅឆ្នាំ២០០០ មកនៅត្រឹម២០នាក់ នៅឆ្នាំ២០២០ ក្នុងចំណោមប្រជាជន១០០ ០០០នាក់។ រីឯអាំងស៊ីដង់ ឬករណីជំងឺរបេងថ្មីបានថយចុះ៥៣% ក្នុងកំឡុងពេលដូចគ្នាពី៥៧៩នាក់ នៅឆ្នាំ២០០០ មកនៅត្រឹម២៧៤នាក់ នៅឆ្នាំ២០២០ ក្នុងចំណោមប្រជាជន១០០ ០០០នាក់ (រូបភាពទី៥)។

រូបភាពទី៥ និន្នាការនៃអាំងស៊ីដង់និងស្លាប់ដោយជំងឺរបេងក្នុងប្រជាជន១០០ ០០០នាក់ ឆ្នាំ២០០០-២០២០




ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) អត្រាព្យាបាលជោគជ័យនៃជំងឺរបេងរក្សាបានខ្ពស់ជាង៩០%។ ជាក់ស្តែងក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ កម្មវិធីជាតិកម្ចាត់រោគរបេងសម្រេចបានអត្រាព្យាបាលជោគជ័យ៩៦% ដែលលើសពីគោលដៅចំណុច៩០%។ ទោះបីជាទទួលបានជោគជ័យយ៉ាងនេះក៏ដោយ ក៏កម្មវិធីជាតិកម្ចាត់រោគរបេងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញទៅថ្ងៃអនាគត ពិសេសដើម្បីរួមចំណែកក្នុងការសម្រេចបានទិសដៅ

នៃវិស័យសុខាភិបាល ក៏ដូចជាសំដៅឆ្ពោះទៅកាន់ការរួមចំណែកក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ២០៣០។ ការស្រាវជ្រាវរកករណីជំងឺរបេងក្នុងឆ្នាំ២០២១ មានចំនួនសរុប១៩ ០០០ករណី ក្នុងនោះ៦ ៧០០ករណី ជារបេងថ្មីវិជ្ជមានបេកាបូក(ឆ្នាំ២០២០ របេងថ្មីវិជ្ជមាន បេកាបូកគឺ១០ ២៤៣ករណី និងរបេងសរុបចំនួន២៩ ១៣៦ករណី)។

### ៤.៤- ការបន្ថយបន្ទុកជំងឺគ្រុនចាញ់

ប្រទេសកម្ពុជាកំពុងស្ថិតនៅលើមាគ៌ាវឌ្ឍនភាពឆ្ពោះទៅកាន់ការលុបបំបាត់ជំងឺគ្រុនចាញ់ នៅឆ្នាំ២០២៥ តាមគោលដៅដែលបានកំណត់ក្នុងផែនការជាតិលុបបំបាត់ជំងឺគ្រុនចាញ់២០១១-២០២៥ ក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ករណីឈឺនៃជំងឺគ្រុនចាញ់បានថយចុះពី៦២ ១៩០ករណី នៅឆ្នាំ២០១១ មកនៅត្រឹម៣ ៥០៤ករណី នៅឆ្នាំ២០២១(គិតត្រឹម១០ខែ) ឬអត្រាអាំងស៊ីដង់០,២១ ក្នុងចំណោមប្រជាជន១ ០០០នាក់។ រីឯករណីស្លាប់ដោយជំងឺគ្រុនចាញ់បានថយចុះពី៩៣ករណី នៅឆ្នាំ២០១១ មកនៅ០ករណី ចាប់ពីឆ្នាំ២០១៨ រហូតមកដល់ឆ្នាំ២០២១(រូបភាពទី៦)។ ១០ខែ ឆ្នាំ២០២១ អាំងស៊ីដង់(ករណីឈឺ)នៃជំងឺគ្រុនចាញ់បានថយចុះ៥៧% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០២០ ពោលគឺថយចុះពី៨ ២២២ករណី មកនៅត្រឹម៣ ៥០៤ករណី និងគ្មានករណីស្លាប់តាំងពីឆ្នាំ២០១៨ គឺជាគជ័យបួនឆ្នាំមុនគោលដៅឆ្នាំ២០២០។

រូបភាពទី៦ ចំនួនករណីឈឺ និងករណីស្លាប់ដោយជំងឺគ្រុនចាញ់ពីឆ្នាំ២០១៧-២០២១




តារាងទី២ សូចនាករនិងលទ្ធផលនៃកម្មវិធីបង្ការនិងគ្រប់គ្រងជំងឺឆ្លង

| ល.រ. | សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| | ករណីឆ្លងថ្មីនៃមេរោគអេសដ៍ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍១ ០០០នាក់ | ០,០៣ | ០,០៣ | ០,០៣ | ០,០៧ | |
| | ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍(មនុស្សពេញវ័យ និងកុមារ) ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressed ក្នុងរយៈពេល១២ខែកន្លងមក | ៨០,៧៨ | ៨៤,៦៣ | ៨៩,០ | ៩៧,០៥ | ៩៧,៣២(៩ខែ) |

| | | | | | | |
|---|---|---|---|---|---|---|
| | ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ (មនុស្សពេញវ័យ និងកុមារ)បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ៥៨ ៣២១ នាក់(មិនមានតួលេខជា%ទេ) | ៨៧,២២ | ៨៩,០ | ៩៩,៨៧ | ៩៩,៩១% (៦២ ៥០៧នាក់ រយៈពេល៩ខែ) |
| | អាំងស៊ីដង់នៃជំងឺរបេងគ្រប់ទម្រង់ | ៣២៦ | មិនមានទិន្នន័យ | ២៨៧ | ២៧៤ | លទ្ធផលចេញនៅចុងឆ្នាំ ២០២២ |
| | អត្រាស្លាប់ដោយជំងឺរបេងក្នុងប្រជាជន១០០ ០០០នាក់ | ១៩ | មិនមានទិន្នន័យ | ១៧ | ២០ | លទ្ធផលចេញនៅចុងឆ្នាំ ២០២២ |
| | អត្រាព្យាបាលជោគជ័យនៃជំងឺរបេង | ៩៣ | ៩៣ | ៩៤ | ៩៦ | ៩៦ |
| | ចំនួនករណីស្រាវជ្រាវជំងឺរបេងដែលបានរាយការណ៍ | ៣៤ ៤៦៧ | មិនមានទិន្នន័យ | ២៩ ៤៥០ | ២៩ ៦៨០ | ១៩ ០០០ |
| | អាំងស៊ីដង់នៃជំងឺគ្រុនចាញ់ (ករណីថ្មី) | ២,៩៦ | ៤ | ១,៩ | ០,៦៥ | ០,៥៩ |
| | អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់ដែល សម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | ០,០១ | ០,០ | ០,០ | ០,០ | ០,០ |
| | អត្រាស្លាប់ដោយជំងឺគ្រុនឈាម | ០,០៥ | ០,០៩ | ០,០៧ | ០,១០ | ០,៤០ (៤៤សប្តាហ៍) |

ប្រភព: - របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៧ ឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០
- របាយការណ៍ប្រចាំឆ្នាំ២០២១ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺអេដស៍និងកាមរោគ មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្រ្ត និងបណកសាស្រ្ត

## ៥- ការបង្ការនិងការគ្រប់គ្រងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ

### ៥.១- ជំងឺទឹកនោមផ្អែម បេះដូងសរសៃឈាម មហារីក

អ្នកជំងឺទឹកនោមផ្អែមដែលបានមកពិនិត្យពិគ្រោះជំងឺបានកើនឡើងពី៥៦ ១៥២នាក់ នៅឆ្នាំ២០១៧ កើនទៅ៧៥ ១៩៤នាក់ នៅឆ្នាំ២០១៩ និងបន្តកើនឡើងនៅឆ្នាំ២០២១ ដែលមានចំនួន៩០ ៧៦៧នាក់។ រីឯអ្នកជំងឺទឹកនោមផ្អែមបានសម្រាកព្យាបាល បានកើនឡើងពី៧ ៤៤៨នាក់ នៅឆ្នាំ២០១៧ កើនទៅ៧ ៦៩០នាក់ នៅឆ្នាំ២០១៩ ប៉ុន្តែថយចុះបន្តិចនៅឆ្នាំ២០២១ ដែលមានចំនួន៥ ៧៤០នាក់(ស្លាប់៦៦នាក់)។

ករណីពិគ្រោះពិនិត្យជំងឺឡើងសម្ពាធឈាមបឋមបានកើនឡើងពី១៩៩ ៦៦៩ករណី នៅឆ្នាំ២០១៧ ទៅ២៣៤ ១០១ករណី(ស្ត្រី១៤៦ ៥៥៥ករណី) នៅឆ្នាំ២០១៩ និងបន្តកើនឡើងនៅឆ្នាំ២០២១ ដែលមានចំនួន ២៣៦ ១៤២ករណី(ស្ត្រី១៤៦ ១១២នាក់)។ រីឯអ្នកជំងឺឡើងសម្ពាធឈាមបឋមដែលបានសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ នៅឆ្នាំ២០២១ មានចំនួន៨ ៥៥៤នាក់ ក្នុងនោះ ស្លាប់៦១នាក់(ឆ្នាំ២០១៧ មាន ២១ ៣០៩ករណី ក្នុងនោះស្លាប់១៦៨នាក់ និងឆ្នាំ២០១៩ មាន១៥ ៣៧៦ករណី ក្នុងនោះ ស្លាប់៦១នាក់)។

ស្ត្រីអាយុក្រោម៣០ឆ្នាំ ដែលបានមកពិនិត្យស្រាវជ្រាវរកមហារីកមាត់ស្បូនមានចំនួនសរុប៣ ១៦០នាក់ ក្នុងនោះមានVIA test វិជ្ជមាន៤១នាក់ និងស្ត្រីសង្ស័យមហារីកមាត់ស្បូន១៨នាក់ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីធ្វើរោគវិនិច្ឆ័យបន្ថែម និងទទួលការព្យាបាល(នៅឆ្នាំ២០១៧ មាន៤ ០៨៧នាក់ ក្នុងនោះស្ត្រី២៨០នាក់ មាន VIA test វិជ្ជមាន និងស្ត្រី២៦៣នាក់ សង្ស័យមហារីកមាត់ស្បូន និងនៅឆ្នាំ២០១៩ មានស្ត្រី១ ៨៤២នាក់ ក្នុងនោះស្ត្រី១៦៥នាក់ មាន VIA test វិជ្ជមាន និងស្ត្រី២៤នាក់ សង្ស័យមហារីកមាត់ស្បូនត្រូវបានបញ្ជូនទៅ មន្ទីរពេទ្យ

ដើម្បីធ្វើរោគវិនិច្ឆ័យបន្ថែម និងទទួលការព្យាបាល)។ ស្ត្រីអាយុ ចន្លោះពី៣០ដល់៤៩ឆ្នាំ បានមកពិនិត្យស្រាវជ្រាវរកមហារីកមាត់ស្បូន មានចំនួន១៣ ៣១៤នាក់ ក្នុងនោះ មានVIA test វិជ្ជមាន ចំនួន១២៧នាក់ និងសង្ស័យមហារីកមាត់ស្បូនចំនួន៥៨នាក់ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីធ្វើរោគវិនិច្ឆ័យបន្ថែម និងទទួលបានការព្យាបាល (នៅឆ្នាំ២០១៧ មានស្ត្រី៣៧ ២៦៧នាក់ ក្នុងនោះស្ត្រី១ ៩៤៩នាក់ មានVIA test វិជ្ជមាន និងស្ត្រី៩០៨នាក់ផ្សេងទៀតមានសង្ស័យមហារីកមាត់ស្បូន និងនៅឆ្នាំ២០១៩ មានស្ត្រី៦ ៧១២នាក់ ក្នុងនោះ ស្ត្រី១៣៩នាក់ មាន VIA test វិជ្ជមាន និងស្ត្រី៣៦១នាក់ សង្ស័យមហារីកមាត់ស្បូនត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីធ្វើរោគវិនិច្ឆ័យបន្ថែម និងទទួលការព្យាបាល)។

### ៥.២- ជំងឺផ្លូវចិត្តនិងភាពញៀនគ្រឿងញៀន

នៅឆ្នាំ២០២១ អ្នកជំងឺផ្លូវចិត្តមកទទួលសេវាពិនិត្យពិគ្រោះ និងព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួន៨៧ ២៨៤នាក់(ប្រុស៣៦ ៦៣១នាក់ ស្រី៥០ ៦៥៣នាក់) ទាបជាងឆ្នាំ២០១៧ ដែលមានចំនួន៩០ ៦៧២នាក់(ប្រុស៣២ ៣០២នាក់ ស្រី៥៨ ៣៧០នាក់) និងទាបជាងឆ្នាំ២០២០ ដែលមានចំនួន១១០ ០១៥នាក់(ប្រុស៤៥ ០៨៦នាក់ ស្រី៦៤ ៩២៩នាក់)។ (រូបភាពទី៧ បង្ហាញពីចំនួនអ្នកជំងឺផ្លូវចិត្តមកទទួលសេវាពិនិត្យពិគ្រោះនិងព្យាបាល រវាងឆ្នាំ២០១៧-២០២១)។

ការប្រើប្រាស់សេវាពិនិត្យពិគ្រោះនិងព្យាបាលភាពញៀនគ្រឿងញៀន មាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ។ នៅឆ្នាំ២០២១ អ្នកញៀនគ្រឿងញៀន ទទួលសេវាពិនិត្យពិគ្រោះ និងព្យាបាលនៅតាមមូលដ្ឋានសុខាភិបាល មានចំនួនសរុប៥ ១២៤នាក់(ប្រុស៣ ៤២២នាក់ និងស្រី១ ៧០២នាក់) ខ្ពស់ជាងឆ្នាំ២០១៧ ដែលមានចំនួន៣ ១០១នាក់(ប្រុស២ ៨៧០នាក់ ស្រី២៣១នាក់) និងទាបជាងឆ្នាំ២០២០ មានចំនួន៦ ៤៣៦នាក់(ប្រុស៥ ៨៥១នាក់ និងស្រី៥៨៥នាក់) (រូបភាពទី៨)។

រូបភាព៧ ចំនួនអ្នកជំងឺផ្លូវចិត្តទទួលសេវាពិនិត្យ ពិគ្រោះ និងព្យាបាលរវាងឆ្នាំ២០១៧-២០២១



រូបភាពទី៨ ចំនួនអ្នកញៀនគ្រឿងញៀនខុសច្បាប់ពិនិត្យពិគ្រោះ និងព្យាបាលសម្រាប់ឆ្នាំ២០១១-២០២១




### ៥.៣- សេវាបង្ការនិងគ្រប់គ្រងពិការភាពភ្នែក

ក្នុងឆ្នាំ២០២១ ករណីពិគ្រោះពិនិត្យជំងឺភ្នែកទូទាំងប្រទេសមានចំនួនសរុប២០១ ៣៥៦ករណី ដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈនិងគ្លីនិកឯកជន( ឆ្នាំ២០១៧ ដែលមានចំនួន២៧០ ២៧៥ករណី និងឆ្នាំ២០១៩ មានចំនួន៤២៨ ៥២២ករណី )។ រីឯការវះកាត់ជំងឺភ្នែកសរុបមានចំនួន២៨ ៨៨២ករណី ក្នុងនោះ វះកាត់ភ្នែកឡើងបាយ២១ ៤០៩ករណី( ឆ្នាំ២០១៧ មានចំនួន៣២ ០៧៩ករណី និងឆ្នាំ២០១៩ ចំនួន៤១ ៨៦៤ករណី ) បើគិតជាអត្រាវះកាត់ភ្នែកឡើងបាយក្នុងប្រជាជន១លាន គឺ១ ៣៤០ករណី។

តារាងទី៣ សូចនាករនិងលទ្ធផលនៃកម្មវិធីបង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង

| ល.រ. | សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| | ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំមានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាល | ៣៣,៨៨ | ៣០ | ២៣,១២ | ២៩,០៧ | ២៤៤ ៦៩៦ ករណី |
| | ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំមានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល | ២៦,៥២ | ៣២ | ២៨,៦ | ៤៣,១៩ | ៩៥ ៥០៧ ករណី |
| | ភាគរយនៃស្ត្រីអាយុ៣០-៤៩ឆ្នាំ បានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន | ១,៨១ | ០,២៦ | ០,៣១ | ០,៥៤ | ១៣ ៣១៤ ករណី |
| | ភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល(%) | ២ | ១,៧១ | ២,២ | ១,៩ | ១,៦% |
| | ចំនួននិងភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល | ៣០,១១% (៣១០១នាក់ ) | ១០០% (៨ ០៩៦នាក់ ) | ៤៥% (៥៣៩៦នាក់ ) | ៥០% (៦៤៣៦នាក់ ) | ៣៩,៤% (៥១២៤នាក់ ) |
| | អត្រាវះកាត់ជំងឺភ្នែកឡើងបាយក្នុងប្រជាជន១លាននាក់ | ១ ៩៥៤ | ២ ២៨៦ | ២ ៥៦២ | ២ ៣៣៤ | ១ ៣៤០ |

ប្រភព: - របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៧ ឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០
- ទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលឆ្នាំ២០២១
- អ្នកញៀនគ្រឿងញៀនមកទទួលសេវាព្យាបាលតាមមូលដ្ឋានសុខាភិបាលក្នុងឆ្នាំ២០២១ មាន ចំនួន៥ ១២៤នាក់។ ផ្អែកលើទិន្នន័យ IBBS ២០១២ ប្រទេសកម្ពុជា អ្នកញៀនគ្រឿងញៀនប្រមាណចំនួន១៣ ០០០នាក់។

## ៦- ការពង្រឹងប្រព័ន្ធសុខាភិបាល

### ៦.១- ការប្រើប្រាស់សេវាសុខភាពទូទៅ

ករណីពិនិត្យពិគ្រោះជំងឺក្រៅសរុប( ករណីជំងឺចាស់និងករណីជំងឺថ្មី ) មានចំនួន១០ ៦២៤ ១២៩ករណី នៅឆ្នាំ២០២១។ ចំណែកករណីថ្មីនៃការពិនិត្យពិគ្រោះជំងឺក្រៅ មានចំនួន៨ ៨១០ ៩១៧ករណី ក្នុងនោះ ពិនិត្យនៅមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួន៨ ៣១២ ០៩៤ករណី និងនៅសេវាសុខាភិបាលឯកជនចំនួន១២២ ៩៩៤ករណី។ បើគិតជាចំនួនលើកមកពិនិត្យជំងឺក្រៅករណីថ្មីដោយប្រជាជនម្នាក់គឺ០,៥២លើក នៅក្នុងឆ្នាំ២០២១ ទាបជាងឆ្នាំ២០១៧( ០,៧១ ) និងឆ្នាំ២០១៩( ០,៧២ ) (រូបភាពទី៩ )។

រូបភាពទី៩ និន្នាការនៃការប្រើប្រាស់សេវាពិនិត្យជំងឺក្រៅពីឆ្នាំ២០១៧-២០២១




នៅឆ្នាំ២០២១ អ្នកជំងឺដែលបានសម្រាកព្យាបាលនៅមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមណ្ឌលសុខភាពមានគ្រែ មានចំនួន៦៥០ ០៨០នាក់ ទាបជាងឆ្នាំ២០១៧ ចំនួន២២២ ៧៩១ នាក់ និងទាបជាងឆ្នាំ២០១៩ ចំនួន៥៥០ ២៨១នាក់។ អត្រាប្រើប្រាស់គ្រែនៅឆ្នាំ២០២១ គឺ៦០,៨៨% នៃចំនួនគ្រែសរុប១៣ ៩៨២គ្រែ(ដោយមិនរាប់បញ្ចូលគ្រែសម្រាប់អ្នកជំងឺរបេង) គឺទាបជាងនៅឆ្នាំ២០១៧(៩៤,៤០% នៃចំនួនគ្រែសរុប១១ ៤០៨គ្រែ) និងទាបជាងនៅឆ្នាំ២០១៩(១០៦,៨២%នៃចំនួនគ្រែសរុប១៣ ៤៦៤គ្រែ) (រូបភាពទី១០)។

រូបភាពទី១០ និន្នាការអត្រាប្រើប្រាស់គ្រែនៅមូលដ្ឋានសុខាភិបាលសាធារណៈឆ្នាំ២០១៧-២០២១




## ៦.២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

គិតត្រឹមខែធ្នូ ឆ្នាំ២០២០ មូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេសមានមណ្ឌលសុខភាព១ ២៥០ កន្លែង(ឆ្នាំ២០១៩ មាន១ ២២២) ប៉ុស្តិ៍សុខភាព១២៩(ឆ្នាំ២០១៩ មាន១២៧) និងមន្ទីរពេទ្យបង្អែក១២៨ (ឆ្នាំ២០១៩ មាន១២៦មន្ទីរពេទ្យ) ក្នុងនោះ មានមន្ទីរពេទ្យជាតិ៩ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត២៥ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ៩៤ នៅក្នុងស្រុកប្រតិបត្តិ១០៣ នៃរាជធានី ខេត្តទាំង២៥។ គួរកត់សម្គាល់ថាចំនួនមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក បានកើនឡើងជារៀងរាល់ឆ្នាំ(តារាងទី៤)។

តារាងទី៤ និន្នាការនៃការអភិវឌ្ឍមូលដ្ឋានសុខាភិបាលសាធារណៈរវាងឆ្នាំ២០១៧-២០២១

| មូលដ្ឋានសុខាភិបាល | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ស្រុកប្រតិបត្តិ | ១០០ | ១០០ | ១០៣ | ១០៣ | ១០៣ |
| មន្ទីរពេទ្យ | ១១៧ | ១២៣ | ១២៦ | ១២៨ | ១២៩ |
| មណ្ឌលសុខភាព | ១១៩០ | ១២០៥ | ១២២២ | ១២៥០ | ១២៦៧ |
| ប៉ុស្តិ៍សុខភាព | ១២១ | ១២៥ | ១២៧ | ១២៩ | ១២៦ |

ឆ្នាំ២០២១ ក្រសួងសុខាភិបាលបានឯកភាពសំណើរបស់រដ្ឋបាលរាជធានី ខេត្ត បង្កើតមន្ទីរពេទ្យបង្អែកចំនួន១កន្លែង មណ្ឌលសុខភាព ១៧កន្លែង(ក្នុងនោះ តម្លើងពីប៉ុស្តិ៍សុខភាព ៥កន្លែង) និងប៉ុស្តិ៍សុខភាព ២កន្លែង និងបានបញ្ជូនសំណើសុំការឯកភាពពីក្រសួងមុខងារ-សាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៦.៣- ពង្រឹងការបង្ការហានិភ័យហិរញ្ញវត្ថុ

រាជរដ្ឋាភិបាលកម្ពុជាបានបន្តវិនិយោគធនធាន លើការពង្រីកការគ្របដណ្តប់កែលម្អគុណភាព សេវាសុខាភិបាល និងបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់ការគាំពារផ្នែកហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាពរបស់ប្រជាពលរដ្ឋជាគោលដៅ តាមយន្តការគាំពារសុខភាពសង្គម ដែលកំពុងត្រូវបានអនុវត្ត ដូចជាកម្មវិធីមូលនិធិសមធម៌ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានគភ៌ និងកុមារអាយុក្រោមពីរឆ្នាំជាដើម។ តាមការប៉ាន់ប្រមាណ នៅឆ្នាំ២០២០ ប្រជាជន៣៩,៥% នៃប្រជាជនកម្ពុជាសរុប(ប្រមាណ១៥,៥លាននាក់) ត្រូវបានគ្របដណ្តប់ដោយមូលនិធិសមធម៌ និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព(មិនរាប់បញ្ចូលការធានារ៉ាប់រងសុខភាពឯកជន) ដោយកើនឡើងពី៣៨,៥% នៅឆ្នាំ២០១៩។

## ៦.៤- ការគ្រប់គ្រងបុគ្គលិក

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ មន្ត្រីរាជការកំពុងបម្រើការក្នុងវិស័យសុខាភិបាលសាធារណៈមានចំនួនសរុប២៩ ៣០៤នាក់(ស្រី១៥ ៥៩៤នាក់) គឺមានចំនួនកើនឡើងលើសឆ្នាំ២០១៧ ដែលមានចំនួន៣ ៨៤៥នាក់ និងលើសឆ្នាំ២០១៩ ដែលមានចំនួន៣ ២១៧នាក់ រូបភាពទី១១ បង្ហាញពីនិន្នាការចំនួនមន្ត្រីរាជការសុខាភិបាលសាធារណៈ រវាងឆ្នាំ២០១០-២០២១។

រូបភាពទី១១ និន្នាការចំនួនមន្ត្រីរាជការសុខាភិបាលសាធារណៈរវាងឆ្នាំ២០១០-២០២១



## ៦.៥- សេវាគាំទ្រជាសារវ័ន្ត

ការផ្គត់ផ្គង់ឱសថបរិក្ខារគ្រប់គ្រាន់ និងទាន់ពេលវេលា រួមជាមួយការប្រើប្រាស់បច្ចេកវិទ្យាវេជ្ជសាស្ត្រ ផ្ដល់នូវមធ្យោបាយប្រកបដោយសក្ដានុពល សម្រាប់ធ្វើអន្តរាគមន៍ក្នុងការបង្ការជំងឺ ធ្វើរោគវិនិច្ឆ័យ ព្យាបាល ថែទាំ និងស្ដារនីតិសម្បទាប្រកបដោយគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពសម្រាប់អ្នកជំងឺ។ ឃ្លាំងឱសថកណ្ដាលនៃក្រសួងសុខាភិបាលបានផ្គត់ផ្គង់និងបែងចែកឱសថបរិក្ខារពេទ្យ ប្រតិករនិងវ៉ាក់សាំងដល់ស្រុកប្រតិបត្តិ (ដើម្បីផ្គត់ផ្គង់បន្តដល់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ) មន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យជាតិ សមស្របតាមតម្រូវការជាក់ស្ដែងនៃការប្រើប្រាស់ ការរៀបចំឯកសារបញ្ជាញ ការវេចខ្ចប់ ការដឹកជញ្ជូនប្រព្រឹត្តទៅយ៉ាងទៀងទាត់រៀងរាល់បីខែម្ដង តាមផែនការបែងចែកដែលបានកំណត់។

ឆ្នាំ២០២១ អំណោយឈាមដែលទទួលបានពីក្រុមគ្រួសារអ្នកជំងឺ(បរិច្ចាគជំនួស) មានចំនួន ៨២ ៩៦៥ប្លោក ឬស្មើនឹង៨៩,៤%នៃអំណោយឈាមសរុប(ឆ្នាំ២០២០ ដែលទទួលបានចំនួន៩៤ ៩៧៣ប្លោក ឬស្មើនឹង៨៦,៨% និងឆ្នាំ២០១៩ ទទួលបាន៧៦ ៧៨៣ប្លោក ឬស្មើនឹង៧៨,៣%)។ អំណោយឈាមស្ម័គ្រចិត្តមានចំនួន៩ ៨៨៤ប្លោក ឬស្មើនឹង១០,៤%នៃអំណោយឈាមសរុប(ឆ្នាំ២០២០ ប្រមូលបាន១៤ ៤៤៥ប្លោក ឬស្មើនឹង១៣,២% និងឆ្នាំ២០១៩ ប្រមូលបាន២១ ២៥៨ប្លោក ឬស្មើនឹង២១,៧%)។

រូបភាពទី១២ និន្នាការនៃអំណោយឈាម(ចំនួនប្លោក) ឆ្នាំ២០១៧-២០២១




## ៦.៦- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា

ការអភិវឌ្ឍប្រព័ន្ធព័ត៌មានសុខាភិបាល និងឌីជីថលសុខាភិបាលឱ្យកាន់តែទូលាយ ក្រសួងសុខាភិបាលបានរៀបចំសេចក្ដីព្រាងយុទ្ធសាស្ត្រឌីជីថលសុខាភិបាល ឆ្នាំ២០២១-២០៣០។ យុទ្ធសាស្ត្រនេះផ្សំដោយសមាសភាព៧ផ្នែក អភិបាលកិច្ច ច្បាប់គោលនយោបាយ បមាណីយកម្មនិងអន្តរប្រតិបត្តិការនៃប្រព័ន្ធយុទ្ធសាស្ត្រ ថវិកាសេវាកម្ម បែបបទនៃការអនុវត្តធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ គោលដៅចំបងនៃយុទ្ធសាស្ត្រឌីជីថលសុខាភិបាលនេះផ្ដោតលើក្របខ័ណ្ឌអភិបាលកិច្ច ឌីជីថលសុខាភិបាល ការប្រើប្រាស់លេខសម្គាល់អត្តសញ្ញាណកម្មអតិថិជនតែមួយ កំណត់ត្រាវេជ្ជសាស្ត្រអេឡិចត្រូនិក និងកសាងសមត្ថភាពស្ថាប័នផ្នែកបច្ចេកវិទ្យាព័ត៌មាន។

## ៦.៧- ការចូលរួមរបស់សហគមន៍និងរដ្ឋបាលមូលដ្ឋានដើម្បីសុខភាព

វិមជ្ឈការនិងវិសហមជ្ឈការៈ ក្រសួងសុខាភិបាលបានអនុវត្តអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលស្តីពីការប្រគល់មុខងារគ្រប់គ្រងនិងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលស្តីពីលក្ខខណ្ឌបច្ចេកទេសនិងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត។ ត្រឹមឆ្នាំ២០២០ ក្រសួងសុខាភិបាលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ២៥ មន្ទីរសុខាភិបាលរាជធានី ខេត្ត១០៣ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ២៥មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ៩៤មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ១ ២៥០មណ្ឌលសុខភាព និង១២៩ប៉ុស្តិ៍សុខភាព និងមន្ត្រីរាជការ សុខាភិបាលថ្នាក់ក្រោមជាតិ សរុបចំនួន១៩ ៩៩៥នាក់។

គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ជាយន្តការជំរុញការប្រើប្រាស់សេវាមណ្ឌលសុខភាព និងអភិវឌ្ឍមណ្ឌលសុខភាព។ គណៈកម្មការនេះ មានសមាសភាពពីក្រុមប្រឹក្សាឃុំ មណ្ឌលសុខភាព និងតំណាងសហគមន៍ និងមានភារកិច្ចចូលរួមអភិវឌ្ឍ ការផ្តល់សេវាសុខាភិបាលនៅមណ្ឌលសុខភាព ដូចជាជួយលើកទឹកចិត្តក្រុមទ្រទ្រង់សុខភាពភូមិ អប់រំនិងផ្សព្វផ្សាយឯកសារសុខភាពដល់ប្រជាជន។ ឆ្នាំ២០២១( ទិន្នន័យ៦ខែដើមឆ្នាំ ) គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពទូទាំងប្រទេស បានដំណើរការមុខងាររបស់ខ្លួនពេញលេញសម្រេចបាន៨៥,៦២%( ៨៧,១២% នៅឆ្នាំ២០១៩ និងឆ្នាំ២០១៧ គឺ៧៥%) យោងតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយក្រសួងសុខាភិបាល។

តារាងទី៥ សូចនាករនិងលទ្ធផលនៃកម្មវិធីពង្រឹងប្រព័ន្ធសុខាភិបាល

| ល.រ. | សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| | ការពិនិត្យពិគ្រោះជំងឺករណីថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ០,៧១ | ០,៧២ | ០,៧២ | ០,៦៧ | ០,៥២ |
| | អត្រាប្រើប្រាស់គ្រែ | ៩៤,៤០ | ១០០,៥ | ១០៦,៨ | ៨៧,៩៧ | ៦០,៨៨ |
| | អត្រាស្លាប់នៅមន្ទីរពេទ្យ | ០,៨៦ | ០,៧២ | ០,៦២ | ០,៧៥ | ១,៤០ |
| | ភាគរយនៃប្រជាជនដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម(មូលនិធិសមធម៌និងធានារ៉ាប់រងសុខភាព) | ៣០ | ៣៥,៧ | ៣៨,៥ | ៣៩,៥ | លទ្ធផលដើមឆ្នាំ២០២២ |
| | ភាគរយនៃការផ្តល់ឈាមដោយស្ម័គ្រចិត្ត | ២៦,៥០ | ២៣ | ២១,៧ | ១៣,២ | ១០,៦ |
| | សន្ទស្សន៍នៃគុណភាពព័ត៌មានសុខាភិបាល | ៩២,៩៤ | ៩៤ | ៩៣,៨៧ | ៩៥,១៣ | ៩៤,៩៧ |
| | ភាគរយ នៃមណ្ឌលសុខភាពនិងមន្ទីរពេទ្យផ្តល់របាយការណ៍ពេញលេញនិងរាយការណ៍ទាន់ពេល (មុនថ្ងៃ១៦មករា) | ៩៥,១០ | ៩៧ | ៩៨,១៤ | ៩៩,០ | ៩៩,២៨ |
| | ភាគរយនៃមណ្ឌលសុខភាពដែលមានគណៈ-កម្មការគ្រប់គ្រងមណ្ឌលសុខភាពដំណើរការពេញលេញ | ៧៥ | ៧៦ | ៨៧,១២ | ៩០,៩៥ | ៨៥,៦២ (៦ខែដើមឆ្នាំ) |

ប្រភពៈ - របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៧ ឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០
- ទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលឆ្នាំ២០២១

## ៧- ការលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សម្រេចលទ្ធផលការងារបានដូចខាងក្រោម៖**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ មានតួនាទីជាគណៈបញ្ជាការឯកភាពមួយជួយរាជរដ្ឋាភិបាលក្នុងកិច្ចសម្របសម្រួលការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន និងមានភារកិច្ចទទួលបន្ទុកចាត់ចែង សម្របសម្រួល តាមដាន វាយតម្លៃ និងផ្តល់យោបល់លើការរៀបចំការអនុវត្តកម្មវិធី និងគោលនយោបាយ ព្រមទាំងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលលើការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ និងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា ស្របតាមគោលដៅអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០៣០ ពិសេសគោលដៅទី២នៃគោលដៅអភិវឌ្ឍន៍ដោយចីរភាពគឺ«**បញ្ចប់ភាពអត់ឃ្លានសម្រេចឱ្យបាននូវសន្តិសុខស្បៀង លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និងកសិកម្មប្រកបដោយចីរភាព**» និងស្របតាមយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពដំណាក់កាលទី៤ ពិសេសចតុកោណទី១ មុំទី៣ ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភនិងចតុកោណទី៤ មុំទី១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។

**សមិទ្ធផលសំខាន់ៗក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) រួមមាន៖**

ក្នុងរយៈពេល៥ឆ្នាំនេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ(ក.ក.ជ.) ដែលជាប្រធានក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ បណ្តាញប្រទេសផ្តល់ជំនួយ បណ្តាញអង្គការសហប្រជាជាតិ បណ្តាញសម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភនៅកម្ពុជា គ្រឹះស្ថានសិក្សា និងវិស័យឯកជន ធ្វើការសម្របសម្រួល និងអនុវត្តការងារជាអាទិភាពលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រេចបានលទ្ធផលសំខាន់ៗ ដូចតទៅ៖

១- ដឹកនាំនិងសម្របសម្រួលរៀបចំវាយតម្លៃពាក់កណ្តាលអាណត្តិ លើការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភឆ្នាំ២០១៤-២០១៨ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីលទ្ធផលនៃការពិនិត្យមើលឡើងវិញពាក់កណ្តាលអាណត្តិ លើការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភឆ្នាំ២០១៤-២០១៨

២- រៀបចំបោះពុម្ពឯកសារលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រលើកាអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ២០១៤-២០១៨ ចំនួន៣ប្រភេទគឺ (១) ឯកសារវឌ្ឍនភាពដែលសម្រេចបានលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (២) ឯកសារបច្ចុប្បន្នភាពវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និង(៣) ឯកសារទិសដៅវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភឆ្នាំ២០៣០ និងបានចុះផ្សព្វផ្សាយឯកសារទាំងនេះតាមបណ្តាលខេត្តនានា

៣- ដឹកនាំនិងសម្របសម្រួលរៀបចំធាតុចូលរបស់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដើម្បីដាក់ជូនក្រសួងផែនការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣

៤- ដឹកនាំកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ជារៀងរាល់ធមាស ដើម្បីដាក់ចេញនូវទិសដៅអនុវត្តលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

៥- កែសម្រួលឈ្មោះ តួនាទី ភារកិច្ច និងសមាសភាពក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅជាក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

វិញ ដើម្បីឱ្យសមស្របទៅនឹងសភាពការណ៍វិវត្តន៍នាពេលបច្ចុប្បន្ន និងបានរៀបចំប្រជុំក្រោមអធិបតីភាព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ជារៀងរាល់ឆមាស

៦- រៀបចំរបាយការណ៍សង្ខេបស្ដីពីវឌ្ឍនភាពរយៈពេល២០ឆ្នាំ លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជាដើម្បីដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអបអរសាទរពិធីប្រារព្ធខួប២០ឆ្នាំនៃគោលនយោបាយឈ្នះឈ្នះរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

៧- ដឹកនាំនិងសម្របសម្រួលអនុវត្តផែនការសកម្មភាពនិងរៀបចំរបាយការណ៍ប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៧ដល់២០២១ របស់ចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភនៅកម្ពុជា ដើម្បីដាក់ជូនចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភពិភពលោក ដែលសម្របសម្រួលដោយតំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការងារសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

៨- ដឹកនាំនិងសម្របសម្រួល និងរៀបចំកិច្ចប្រជុំថ្នាក់ក្រោមជាតិស្ដីពីចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភនៅកម្ពុជា ដើម្បីផ្សព្វផ្សាយពីវឌ្ឍនភាពការងារនៃចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភនៅកម្ពុជា និងពិភាក្សាប្រមូលធាតុចូលដើម្បីរៀបចំយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ឆ្នាំ២០១៩-២០២៣

៩- រៀបចំវេទិកាសន្តិសុខស្បៀង ដើម្បីផ្ដល់ឱកាសឱ្យអ្នកពាក់ព័ន្ធចូលរួមពិភាក្សា ផ្លាស់ប្ដូរយោបល់និងចែករំលែកបទពិសោធន៍លើការងារផ្សេងៗទៀត ដែលទាក់ទងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា

១០- ដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំក្រុមការងារស្ដីពីទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ និងបានរៀបចំសន្និសីទជាតិលើកទី២ ស្ដីពីសមាហរណកម្មវិស័យទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ក្រោមប្រធានបទ **«បទពិសោធន៍នៅកម្ពុជា លទ្ធផលអនុវត្តន៍កម្មវិធីសមាហរណកម្មដើម្បីលើកកម្ពស់អាហារូបត្ថម្ភ»**

១១- ដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំក្រុមការងារអន្តរក្រសួងសម្រាប់វាយតម្លៃការងារគាំពារសង្គម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភដោយប្រើប្រាស់ឧបករណ៍កម្មវិធី Inter-Agency Social Protection Assessment(ISPA) និងបានរៀបចំសិក្ខាសាលាស្ដីពីកិច្ចប្រឹក្សាយោបល់អ្នកពាក់ព័ន្ធ ដើម្បីពិនិត្យមើលរបាយការណ៍នៃការសាកល្បងអនុវត្តឧបករណ៍ ISPA/FSN នៅកម្ពុជា

១២- សហការផលិតនិងចាក់ផ្សាយស្ពតវីដេអូថ្មី (Video Spot) មួយចំនួនស្ដីពីការអប់រំអាហារូបត្ថម្ភជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងនិងការអនុវត្តប្រកបដោយភាពវិជ្ជមានលើវិស័យកសិកម្ម សុខភាព អាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ

១៣- ពង្រឹងយន្តការស្ថាប័នដើម្បីលើកកម្ពស់អភិបាលកិច្ចលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភទាំងថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការចូលរួមអនុវត្តផែនការសកម្មភាពនៃចលនាបង្កើនអាហារូបត្ថម្ភពិភពលោក ដោយបង្កើតបាននូវបណ្ដាញធុរកិច្ច បង្កើនអាហារូបត្ថម្ភនៅកម្ពុជា និងបានកែសម្រួល និងបន្តដំណើរការក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ វេទិកានានា និងបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមខេត្ត

១៤- លើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្តោតលើភាពមានស្បៀង ភាពទទួលបានស្បៀង ការប្រើប្រាស់និងការបើតស្រូបស្បៀង ស្ថិរភាពស្បៀង ដោយផ្តោតការយកចិត្តទុកដាក់លើការសម្របសម្រួលពហុវិស័យ ដូចជារបបអាហារសុខភាព ទឹកស្អាត និងអនាម័យ ដែលគិតគូរដល់អាហារូបត្ថម្ភ ខ្សែច្រវាក់តម្លៃស្បៀង សុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ អាហារូបត្ថម្ភដឹកនាំដោយសហគមន៍ ជំនួយសង្គមនិងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងបរិបទនៃការគ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ

១៥- ពង្រឹងការគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងចំណេះដឹងស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការប្រមូលចងក្រងនិងវិភាគទិន្នន័យដើម្បីបង្ហាញព័ត៌មានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ជូនដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត ដោយបានរៀបចំកែលម្អនិងធ្វើបច្ចុប្បន្នភាពជាប្រចាំលើគេហទំព័រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា(www.foodsecurity.gov.kh) និងបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជាប្រចាំទំព័រហ្វេសប៊ុក (Facebook page): Cambodia Food Security and Nutrition Information System Office (https://web.facebook.com/fsncu2016) និង(Facebook page): អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ព្រមទាំងបានវិភាគពីស្ថានភាពសន្តិសុខស្បៀងជាទៀងទាត់

១៦- កសាងសមត្ថភាពដល់មន្ត្រី និងគ្រូបង្គោល លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការចូលរួមព្រឹត្តិការណ៍ និងកិច្ចប្រជុំអន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបានបណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដល់ក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភថ្នាក់ខេត្ត និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបញ្ជ្រាបការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលឃុំ សង្កាត់ និងបានធ្វើការកែសម្រួលឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

១៧- លើកកម្ពស់បញ្ញាយេនឌ័រ យុវជន និងបរិស្ថានក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការរៀបចំវេទិកាយុវជន ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភតាមគ្រឹះស្ថានសិក្សា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កម្មវិធីបោះជំរំយុវជនអាហារូបត្ថម្ភ និងរៀបចំឱ្យមានក្រុមយុវជនជើងឯកអាហារូបត្ថម្ភ

១៨-រៀបចំទិវាជាតិអាហារូបត្ថម្ភ បានចំនួន៥លើក ក្រោមប្រធានបទ**«ផលិតនិងបរិភោគអាហារចម្រុះសម្បូរជីវជាតិ ដើម្បីសុខភាពល្អមាំមួនក្នុងឆ្នាំ២០១៧» «ផ្តល់អាហារូបត្ថម្ភល្អដល់កូនអ្នក គឺជាការវិនិយោគដ៏ប្រសើរបំផុតក្នុងឆ្នាំ២០១៨» «ការបំបៅកូនដោយទឹកដោះម្តាយ គឺជាជម្រើសដ៏ប្រសើរសម្រាប់អភិវឌ្ឍន៍មូលធនមនុស្ស និងសេដ្ឋកិច្ចជាតិក្នុងឆ្នាំ២០១៩» «ការពង្រឹងប្រព័ន្ធស្បៀង ដើម្បីរបបអាហារសុខភាពក្នុងឆ្នាំ២០២០»** និង **«ការពង្រឹងប្រព័ន្ធស្បៀងដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពក្នុងឆ្នាំ២០២១»** និងបានរៀបចំទិវាអាហារូបត្ថម្ភថ្នាក់ក្រោមជាតិទៅតាមប្រធានបទនីមួយៗនៅតាមបណ្តាលខេត្តមួយចំនួន ដើម្បីផ្សព្វផ្សាយសារលិខិត**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

១៩- សម្របសម្រួលរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ លើកទី២ ឆ្នាំ២០១៩-២០២៣ និងដាក់ឱ្យប្រើប្រាស់និងរៀបចំសូចនាករតាមដានរួមគ្នារបស់ក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដោយផ្តោតលើការធ្វើអន្តរាគមន៍បន្ទុកទ្វេនៃបញ្ហាអាហារូបត្ថម្ភដើម្បីកាត់បន្ថយអត្រាក្រិសក្រិននិងអត្រាស្គមស្គាំង ព្រមទាំងទប់ស្កាត់ការកើនឡើងនៃអត្រាលើសទម្ងន់និងធាត់ជ្រុលរបស់កុមារអាយុក្រោម៥ឆ្នាំនិងស្ត្រីក្នុងវ័យបន្តពូជ

២០- អនុវត្តសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខៈ៩៣៤ស.ជ.ណ. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ស្តីពីអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**សម្រាប់អនុវត្តន៍យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣

២១- រៀបចំកិច្ចសន្ទនាជាតិស្តីពីប្រព័ន្ធស្បៀង តាមរយៈអនឡាញចំនួន៣០លើក ដែលមានអ្នកចូលរួមប្រមាណ២ ០០០នាក់ ដើម្បីប្រមូលធាតុចូលរៀបចំផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀង សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០ និងសម្រាប់កិច្ចប្រជុំកំពូលពិភពលោកស្តីពីប្រព័ន្ធស្បៀង ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១

២២- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួនដូចខាងក្រោមជាមួយៈ

- អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ និងតំណាងស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា លើសេចក្តីថ្លែងការណ៍ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ក្នុងកំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩
- អង្គការជីអាយហ្សីតនៅកម្ពុជា លើកិច្ចព្រមព្រៀងស្តីពីការអនុវត្តគម្រោងពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា(MUSEFO) និងសម្រាប់អនុវត្តគម្រោងចាប់ពីឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាំ២០២២
- កម្មវិធីស្បៀងអាហារពិភពលោកប្រចាំកម្ពុជា លើកិច្ចព្រមព្រៀងស្តីពីការសម្របសម្រួលលើសកម្មភាពរួមពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

២៣- បានរៀបចំគោលនយោបាយ ការវិភាគ និងបោះពុម្ពឯកសាររួមមានៈ

ក- សេចក្តីថ្លែងការណ៍ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងកំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩។

ខ- សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុងបរិបទនៃជំងឺកូវីដ-១៩ សម្រាប់ប្រទេសកម្ពុជា។

គ- ការវាយតម្លៃរហ័សនៃផលប៉ះពាល់កូវីដ-១៩ លើវិស័យកសិកម្មនិងសន្តិសុខស្បៀងនៅកម្ពុជា ដែលឆ្លើយតបទៅនឹងគោលនយោបាយ។

ឃ- ការវិភាគពីគម្លាតគោលនយោបាយដែលទាក់ទងនឹងប្រព័ន្ធស្បៀង សម្រាប់ជាមូលដ្ឋានរៀបចំផែនការសកម្មភាពអនុវត្តផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាពនៅកម្ពុជា ឆ្នាំ២០៣០។

ង- ធ្វើការវិភាគសាកល្បងស្តីពីផលប៉ះពាល់ដោយសារកូវីដ-១៩ នៅថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងនៅក្នុងខេត្តកំពង់ធំនិងខេត្តកំពត ហើយនឹងពង្រីកការប្រើប្រាស់ឧបករណ៍តាមដានត្រួតពិនិត្យនេះ ទៅខេត្តផ្សេងៗទៀត។

## មុំទី៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

### ១- ការពង្រឹងសមភាពយេនឌ័រ

**ក្រសួងកិច្ចការនារីសម្រេចការងារដូចខាងក្រោមៈ**

ក្រសួងកិច្ចការនារី ជាយន្តការថ្នាក់ជាតិ សម្រាប់លើកកម្ពស់ស្ថានភាព ឋានៈតួនាទី របស់ស្ត្រីនៅកម្ពុជា តាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ នារីរតនៈទី៤ និងទី៥ ដោយអនុវត្តតាមគោលនយោបាយ និង

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្រសួងសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

## ១.១- ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

១- បណ្តាញសហគ្រិនស្ត្រីកម្ពុជា (CamWEN) បានបង្កើតនិងដំណើរការដោយប្រមូលផ្តុំពីសមាគមស្ត្រី និងក្រុមស្ត្រីនៅក្នុងវិស័យធុរកិច្ចចំនួន៤(សមាគមសហគ្រិនស្ត្រីកម្ពុជា សមាគមសហគ្រិនវ័យក្មេងកម្ពុជា សមាគមភ្នាក់ងារធ្វើដំណើរកម្ពុជា និងសភាយុវពាណិជ្ជករកម្ពុជា) និងសហគ្រិនស្ត្រីកម្ពុជាឱ្យចូលរួមជាបណ្តាញសហគ្រិនស្ត្រីអាស៊ាន និងទទួលបានពានរង្វាន់សហគ្រិនស្ត្រីផ្ទើមអាស៊ានចំនួន៤៣រូប

២- គម្រោងលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុដល់ស្ត្រីនិងសហគ្រិនស្ត្រី ក្នុងភាពជាដៃគូរវាងក្រសួងកិច្ចការនារី និងធនាគារជាតិនៃកម្ពុជា បានអនុវត្តក្នុងខេត្តគោលដៅចំនួន៤(សៀមរាប ព្រះវិហារ ក្រចេះ និងស្ទឹងត្រែង) និងបានផ្តល់ជាវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងវេទិកានានាក្នុងការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងការអភិវឌ្ឍអាជីវកម្មសម្រាប់ស្ត្រី សិស្សានុសិស្ស និងសហគ្រិនស្ត្រីប្រមាណជាង៩០៣នាក់(ស្រី៧០៣នាក់)

៣- អនុវត្តកម្មវិធីលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងវិស័យទឹកស្អាត និងអនាម័យចំនួន៣២៥នាក់ ក្នុងខេត្តគោលដៅចំនួន៤(រាជធានីភ្នំពេញ កណ្តាល កំពង់ឆ្នាំង និងកំពង់ស្ពឺ)

៤- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី ត្រូវបានដំណើរការនៅឆ្នាំ២០២១ និងផ្តល់វគ្គដល់ស្ត្រីជាអាជីវករចំនួន១០៨នាក់ និងគាំទ្រក្នុងការចាប់ផ្តើមនិងអភិវឌ្ឍអាជីវកម្មរបស់ស្ត្រីតាមរយៈប្រព័ន្ធអនឡាញចំនួន១៨នាក់

៥- គម្រោងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីបានអនុវត្តក្នុងខេត្តចំនួន៥(កំពង់ចាម កំពង់ឆ្នាំង ត្បូងឃ្មុំ កំពង់ធំ និងសៀមរាប) ចំនួន២០ភូមិ ដែលមានប្រជាពលរដ្ឋក្រុមគោលដៅសរុបចំនួន៥៧២នាក់(ស្រី៣៦០នាក់) ទទួលបានការគាំទ្របច្ចេកទេសលើការងារចិញ្ចឹមមាន់ ដាំបន្លែ ធ្វើអំបោស សិប្បកម្មតម្បាញរំពាក់ផ្តៅ និងសេវាកម្មផ្ទះស្នាក់( Homestay) និងសេវាកម្មផ្សេងទៀត

៦- បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រីក្រីក្រ ស្ត្រីរងគ្រោះដោយអំពើហិង្សា ជនជាតិដើមភាគតិច ស្ត្រីជាទណ្ឌិត ក្មេងស្រីបោះបង់ចោលការសិក្សា តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីទាំង១៤ និងមន្ទីរកិច្ចការនារីរាជធានី ខេត្តជាមធ្យមចំនួន៣ ៧៤០នាក់ ក្នុង១ឆ្នាំ។

## ១.២- ការអប់រំស្ត្រីនិងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

១- បង្កើនការយល់ដឹងតាមរយៈការផ្សព្វផ្សាយលើប្រធានបទសំខាន់ៗ ដូចជាយុវវ័យនិងប្រព័ន្ធបច្ចេកវិទ្យា និងខ្ញុំមិនភ័យខ្លាច ដល់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ គ្រឹះស្ថានអប់រំ ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ ការអប់រំសីលធម៌សង្គម និងការអប់រំផ្នែក STEM ដែលជំរុញឱ្យសិស្សស្រីបានចូលរៀនរហូតចប់ថ្នាក់ឧត្តមសិក្សា និងយ៉ាងតិចរៀនចប់ថ្នាក់ទី៩ សរុប៥ ៩៧៣នាក់(ស្រី៣ ៤៩៧នាក់)។

២- យុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមានឆ្នាំ២០១៧-២០២១ បាននិងកំពុងអនុវត្តនៅខេត្តគោលដៅចំនួន៩(រាជធានីភ្នំពេញ ខេត្តកណ្តាល ព្រះសីហនុ សៀមរាប បាត់ដំបង ព្រៃវែង ត្បូងឃ្មុំ ក្រចេះ និងខេត្តរតនគិរី) ក្នុងនោះ កញ្ចប់ឧបករណ៍សម្រាប់បណ្តុះបណ្តាលនិងផ្សព្វផ្សាយចំនួន៣កម្រិត និងសៀវភៅណែនាំចំនួន២ ត្រូវបានដំណើរការអនុវត្តន៍។ មាតាបិតា អាណាព្យាបាល និងអ្នកថែទាំចំនួន១៨ ៦១៥នាក់(ស្រី១៥ ៦១៥នាក់) បានទទួលចំណេះដឹងពីការផ្សព្វផ្សាយនៅតាមសហគមន៍ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមានកម្រិតទី១។

៣- ក្នុងឆ្នាំ២០១៨ ក្រសួងបានបង្កើតទារកដ្ឋានសម្រាប់ទទួលនិងមើលថែកុមារ ជាកូនមន្ត្រីរាជការក្នុងក្រសួងដោយគិតត្រឹមឆ្នាំ២០២០ មានកុមារចំនួន៧២នាក់(កុមារី៤០នាក់) ដែលទទួលបានសេវាពីទារកដ្ឋាន។

៤- សហការជាមួយក្រសួងអប់រំ យុវជននិងកីឡា និងសាកលវិទ្យាល័យចំនួន៤ ក្នុងនោះ បានចុះអនុស្សរណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យចំនួន៣(ភូមិន្ទកសិកម្ម កម្ពុជា និងភូមិន្ទភ្នំពេញ) ព្រមទាំងពង្រឹង និងពង្រីកវិសាលភាពដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជន និងការបញ្ជ្រាបយេនឌ័រក្នុងថ្នាក់ឧត្តមសិក្សាតាមរយៈការរៀបចំ និងដាក់ឱ្យដំណើរការប្រអប់ស្រាវជ្រាវស្តីពីយេនឌ័រជាផ្នែកមួយនៃបណ្ណាល័យ និងការសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យទាំង៤

៥- យុទ្ធនាការទិវានារីអន្តរជាតិ ត្រូវបានរៀបចំជាប្រចាំ បានចំនួន១៥លើក នៅតាមសាកលវិទ្យាល័យ និងវិទ្យាល័យ ដែលមាននិស្សិត និងសិស្សចូលរួមចំនួន៣ ៧៥០នាក់(ស្រី១ ៩៩២នាក់)

៦- មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសរុបចំនួន១ ២៥០នាក់(ស្រី៧៩៦នាក់) បានពង្រឹងសមត្ថភាពស្តីពីសុខុមាលភាពសង្គម ការចិញ្ចឹមកូនបែបវិជ្ជមាន និងការលើកកម្ពស់ជីវិតរស់នៅប្រចាំថ្ងៃ និងសិល្បៈក្នុងការរស់នៅប្រកបដោយសមភាពយេនឌ័រ សិទ្ធិកុមារដើម្បីចៀសឱ្យផុតពីអំពើហិង្សាគ្រប់ទម្រង់

៧- អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**(អនុសាសន៍ទី៨របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី) និងអនុសាសន៍ដ៏ថ្លៃថ្លាទាំង៦ចំណុចរបស់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ(គ.ជ.ស.ស.ខ.) បានជំរុញនិងលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ រិះរកមធ្យោបាយនិងអនុវត្តសកម្មភាពលើកកម្ពស់សីលធម៌សង្គម និងដោះស្រាយបញ្ហាប្រឈមដែលធ្វើឱ្យប៉ះពាល់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈវីដេអូខ្លីលើប្រធានបទសីលធម៌សង្គម បញ្ជ្រាបក្នុងកម្មវិធីវិទ្យុ នាទីអប់រំព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម ការអប់រំផ្លូវចិត្ត យុទ្ធនាការ១៦ថ្ងៃ បញ្ឈប់អំពើហិង្សាលើស្ត្រី ទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាដើម។

### ១.៣- ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារី និងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍

១- ពង្រឹងសមត្ថភាពមន្ត្រីមន្ទីរកិច្ចការនារីរាជធានី ខេត្ត ស្រុក អ្នកទទួលបន្ទុកកិច្ចការនារីឃុំ/សង្កាត់ទាំង២៥រាជធានី ខេត្ត តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីសុខភាពបន្តពូជ អាហារូបត្ថម្ភ អនាម័យ ទឹកស្អាត ការបង្ករោគ ជំងឺកាមរោគ ជំងឺអេដស៍ សុខភាពភ្នែក សរុបចំនួន៧៩វគ្គ មានអ្នកចូលរួមចំនួន២ ៥១៣នាក់ (ស្រី២ ០០៦នាក់)

២- បង្កើនការយល់ដឹងដល់ប្រជាជននៅសហគមន៍ តាមរយៈវេទិកាអប់រំ យុទ្ធនាការអប់រំស្តីពីសុខភាពបន្តពូជ អាហារូបត្ថម្ភ អនាម័យ ទឹកស្អាត ការបង្ករោគ ជំងឺកាមរោគ ជំងឺអេដស៍ សុខភាពភ្នែក សរុបចំនួន២៧៣លើក មានអ្នកចូលរួមចំនួន១២៩ ១០១នាក់(ស្រី១០១ ៩៨៩នាក់) និងបានជំរុញបញ្ជូនប្រជាជនទៅទទួលសេវាសុខាភិបាលយ៉ាងតិច១០%នៃអ្នកចូលរួម

៣- អប់រំផ្សព្វផ្សាយជាសាធារណៈតាមស្ថានីយទូរទស្សន៍ជាតិកម្ពុជា និងMy TV study ស្តីពីយេនឌ័រ និងសុខភាពភ្នែក ចំនួន៥៤លើក និងវេទិកាតុមូល២លើក វេទិកាយុវវ័យជជែកពិភាក្សាជានិស្សិតតាមសាកល-វិទ្យាល័យចំនួន១លើក

៤- សិក្ខាសាលាបូកសរុបលទ្ធផលការងារ ពង្រឹងកិច្ចសហការ ស្វែងរកការគាំទ្រមតិបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រក្រសួងស្ថាប័នពាក់ព័ន្ធចំនួន៥លើក មានអ្នកចូលរួមចំនួន៤១៤នាក់(ស្រី៣០៩នាក់)

៥- ផលិតសម្ភារៈអប់រំ ផ្សព្វផ្សាយស្តីពី យេនឌ័រ និងសុខភាព(សៀវភៅសន្លឹកបិទបើក សៀវភៅគ្រូបង្គោល សៀវភៅណែនាំ អាវយឺត សៀវភៅកត់ត្រា និងបណ្ណបញ្ជូន)

៦- ផលិតស្ពតវីដេអូអប់រំខ្លីចំនួន៣ ស្តីពីការទទួលបានព័ត៌មាន ការទទួលបានសេវា និងសមិទ្ធផលសម្រេចបានរបស់កម្មវិធីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងការថែទាំសុខភាពភ្នែក នឹងចាក់ផ្សាយតាមប្រព័ន្ធហ្វេសប៊ុកក្រសួង។

## ១.៤- កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី

១- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៤-២០១៨ ត្រូវបានអនុវត្តដោយជោគជ័យនិងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការបន្តឆ្នាំ២០១៩-២០២៣ ព្រមទាំងកំពុងអនុវត្តយ៉ាងសកម្មដោយមានការចូលរួមពីភាគីពាក់ព័ន្ធ តាមរយៈក្រុមការងារបច្ចេកទេសស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងយេនឌ័រនៅថ្នាក់ជាតិនិងក្រោមជាតិ

២- ផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ២០១៧-២០២១ កំពុងអនុវត្តដោយក្រសួង ស្ថាប័ពាក់ព័ន្ធនៅថ្នាក់ជាតិនិងក្រោមជាតិ។ ឯកសារគោលការណ៍ពាក់ព័ន្ធអំពើហិង្សាទាក់ទងយេនឌ័រ ត្រូវបានដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌអាស៊ាននិងក្របខ័ណ្ឌជាតិ (១) គោលការណ៍ប្រចាំតំបន់អាស៊ានក្នុងការប្រមូល និងវិភាគទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី (២) គោលការបញ្ជូនស្ត្រីនិងក្មេងស្រីជនរងគ្រោះ គោលការណ៍ប្រមូលទិន្នន័យនិងគ្រប់គ្រងករណីអំពើហិង្សា និង(៣) បទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាយោបល់ជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រី។ សេចក្តីប្រកាសរួមស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី ត្រូវបានដាក់ឱ្យអនុវត្តដោយក្រសួងកិច្ចការនារីនិងក្រសួងព័ត៌មានក្នុងឆ្នាំ២០១៧ និងបន្តផ្សព្វផ្សាយក្នុងចំណោមអ្នកសារព័ត៌មាននិងនិស្សិតសារព័ត៌មាន

៣- កន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័របានអនុវត្តសាកល្បងនៅខេត្តកំពង់ចាមនិងខេត្តស្ទឹងត្រែង និងក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ខេត្តចំនួន៩ គឺខេត្តកំពង់ស្ពឺ ព្រះសីហនុ កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង សៀមរាប ព្រះវិហារ កំពង់ធំ និងខេត្តរតនគិរី និងថ្នាក់ស្រុកចំនួន២៥ ត្រូវបានបង្កើតនិងកំពុងដំណើរការ

៤- សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្ត ដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ និងសម្របសម្រួលបញ្ជូនទៅទទួលសេវាបន្ត(សេវាមេធាវី និងស្នាក់នៅ) ជូនជនរងគ្រោះដោយអំពើហិង្សា មានចំនួន១៨២ករណី

៥- ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ជាមួយឯកអគ្គរដ្ឋទូតអាម៉េរិក ដើម្បីបំភ្លឺលើអនុសាសន៍ទាំង១៧ចំណុច ដែលសហរដ្ឋអាម៉េរិកបានដាក់ចំណាត់ថ្នាក់កម្ពុជាកម្រិតថ្នាក់លេខ២ក្រោមបញ្ជីឃ្លាំ(Tier2 Watchlist) លើរបាយការណ៍វាយតម្លៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ របស់កម្ពុជា

៦- សេចក្តីព្រាងច្បាប់ស្តីពីការពរពោះជំនួស បានបញ្ជូនទៅក្រុមការងារក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ដើម្បីពិនិត្យបន្ត

៧- ផែនការសកម្មភាពស្តីពីអាពាហ៍ពិពាហ៍វ័យកុមារនិងការមានផ្ទៃពោះវ័យជំទង់ខេត្តរតនគីរី បានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៨ និងបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធក្នុងខេត្ត និងដាក់បញ្ចូលទៅក្នុងផែនការវិនិយោគរបស់ខេត្ត ដោយបានបែងចែកកញ្ចប់ថវិកាសម្រាប់អនុវត្តសកម្មភាព

៨- គណៈកម្មការប្រឹក្សាយោបល់ក្នុងការលើកកម្ពស់សិទ្ធិនិងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ត្រូវបានបង្កើតដោយក្រសួងកិច្ចការនារី និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអនុវត្តកម្មវិធីសុវត្ថិភាពនិងយុត្តិធម៌

៩- ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាជួយជនរងគ្រោះដោយអំពើហិង្សាលើស្ត្រីតាមរយៈវគ្គបណ្តុះបណ្តាលចំនួន៥៧វគ្គ និងវេទិកាផ្សព្វផ្សាយចូលរួមទប់ស្កាត់អំពើហិង្សា និងយុទ្ធនាការ១៦ថ្ងៃ បញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីចំនួន៧១លើក ដោយមានអ្នកចូលរួមផ្ទាល់២០ ០៥៧នាក់(ស្រី១៣ ០៦១នាក់) និងផ្សព្វផ្សាយតាមរយៈបណ្តាញសង្គមដោយមានអ្នកចូលរួមមើលប្រមាណ៨០២ ៨៦៦នាក់

១០- ស្ថានភាពស្ត្រីជាទណ្ឌិតនិងពិរុទ្ធជន ចំនួន១ ៧៩៨ នាក់(ទណ្ឌិត ៧៨៩ ពិរុទ្ធជន១ ០០៩នាក់) ក្នុងនោះស្ត្រីមានផ្ទៃពោះ៣០នាក់ មានកូនតូចនៅជាមួយ១១៨នាក់ នៅតាមពន្ធនាគារ ទាំង២៥ រាជធានី ខេត្ត ត្រូវបានចុះសិក្សាស្វែងយល់សម្រាប់រៀបចំរបាយការណ៍ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យនិងសម្រេចលើវិធានការឆ្លើយតបបញ្ហាប្រឈម សម្រាប់ធ្វើការលើកលែង និងបន្ធូរបន្ថយទោស ក្នុងឆ្នាំ២០១៩ ក្នុងនោះបទល្មើសភាគច្រើនពាក់ព័ន្ធនឹងករណីគ្រឿងញៀន ឃាតកម្ម លួច ហិង្សា

១១- សម្របសម្រួលនិងការផ្តល់សេវា ជូនជនរងគ្រោះជាស្ត្រីនិងក្មេងស្រីសរុបចំនួន២ ៧១៥ករណី (អំពើហិង្សាក្នុងគ្រួសារ១ ៤៥៣ករណី រំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ១ ២០២ករណី ការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចនានា៦០ករណី)។

## ១.៥- ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ

១- រាជរដ្ឋាភិបាលកម្ពុជា បានបន្តយកចិត្តទុកដាក់បង្កើនសមាមាត្រស្ត្រីក្នុងការដឹកនាំនិងថ្នាក់ធ្វើសេចក្តីសម្រេចនៅថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីចូលរួមលើកកម្ពស់ពង្រឹងអភិបាលកិច្ចប្រកបដោយបរិយាបន្ន

| ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច | ២០១៧ | ២០២១ |
|---|---|---|
| ស្ត្រីជាសមាជិកព្រឹទ្ធសភា | ៩នាក់(១៤,៧៥%) | ១០នាក់(១៦,១៣%) |
| ស្ត្រីជាសមាជិករដ្ឋសភា | ២៥នាក់(២០,៣២%) | ២៦នាក់(២០,៨០%) |
| ស្ត្រីជារដ្ឋមន្ត្រី | ៣នាក់(១០,៧១%) | ៣នាក់(១០,៣៤%) |
| ស្ត្រីជារដ្ឋលេខាធិការ | ៣៨នាក់ | ៥៩នាក់ |
| ស្ត្រីជាអនុរដ្ឋលេខាធិការ | ៤៨នាក់ | ៧៥នាក់ |
| ស្ត្រីជាអភិបាលខេត្ត | ០១នាក់ | ០២នាក់ |
| ស្ត្រីជាអភិបាលរងខេត្ត រាជធានី | ២៦នាក់ | ២៥នាក់ |
| ស្ត្រីជាអភិបាលស្រុក ក្រុង | ៧នាក់ | ៧នាក់ |
| ស្ត្រីជាអភិបាលរងស្រុក ក្រុង | ១៨៥នាក់ | ១៩៤នាក់ |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាខេត្ត | ៦៤នាក់ | ៩៤នាក់ |
| ស្ត្រីជាប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ២នាក់ | ៥នាក់ |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៤០៤នាក់ | ៦១៧នាក់ |
| ស្ត្រីជាមេឃុំ ចៅសង្កាត់ | ៩៦នាក់(៥,៨%) | ១៣០នាក់(៧,៨៩%) |
| ស្ត្រីជាជំទប់ទី១ | ១៨៩នាក់(១១,៥៧%) | ២៧២នាក់(១៦,៥២%) |
| ស្ត្រីជាជំទប់ទី២ | ១៥១នាក់ (៩,២៤%) | ២៨៥នាក់(១៧,៣១%) |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ | ២ ០៣៨នាក់(១៧,៧៨%) | ១ ៦១១នាក់(១៤%) |
| ស្ត្រីជាចៅក្រម | ៣៨នាក់(១៤,៣៩%) | ៤៦នាក់(១៥,២៨%)(២០១៩) |

| | | |
|---|---|---|
| ស្ត្រីជាព្រះរាជអាជ្ញា | ២៣នាក់(១២,៥%) | ២៥នាក់(១៣,៥១%) |
| ស្ត្រីជាក្រឡាបញ្ជី | ១៦៥នាក់(២៣,១៨%) | ១៨៩នាក់(២២,៧១%) |
| ស្ត្រីជាមន្ត្រីរាជការ | ៤១% | ៤១%(២០២០) |
| ស្ត្រីជាមន្ត្រីរាជការ ដែលមានមុខតំណែងចាប់ពី ថ្នាក់ការិយាល័យតាមស្រុក ដល់ថ្នាក់អគ្គនាយក | ២៤% | ២៦%(២០២០) |

- ក្នុងអង្គនីតិប្បញ្ញត្តិ នៅក្នុងអាណត្តិទី៦ នៃរដ្ឋសភា មានស្ត្រីចំនួន១រូប ជាអនុប្រធានរដ្ឋសភា ស្ត្រីចំនួន២រូប ជាប្រធានគណៈកម្មការ និងស្ត្រីចំនួន៤រូប ជាអនុប្រធានគណៈកម្មការ។ នៅក្នុងអាណត្តិទី៤នៃព្រឹទ្ធសភា មានស្ត្រីជាប្រធានគណៈកម្មការ ចំនួន២រូប ក្នុងចំណោម១០រូប

- នៅលើឆាកអន្តរជាតិ កម្ពុជាជាប់ចំណាត់ថ្នាក់ទី២ ក្នុងសហគមន៍អាស៊ាន និងជាប់ចំណាត់ថ្នាក់លេខទី១៩ ក្នុងចំណោមប្រទេស១២០ ដែលបានបញ្ជូនកងទ័ពជាស្ត្រីចូលរួមប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

២- កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់ស្ត្រីរយៈពេល១៣០ម៉ោង បានរៀបចំ និងអនុវត្តសម្រាប់ស្ត្រីថ្នាក់ដឹកនាំចាប់ពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងអគ្គនាយករង ចំនួន១៦៤រូប តាមរយៈកិច្ចសហការរវាងក្រសួងកិច្ចការនារីនិងសាលាភូមិន្ទរដ្ឋបាល និងស្ត្រីជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ នៅសាលាជាតិរដ្ឋបាលមូលដ្ឋានចំនួន៦១រូប

៣- សហការជាមួយលេខាធិការដ្ឋានគ.ជ.អ.ប. អនុវត្តន៍ផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយស្តីពីសមភាពយេនឌ័រក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ស្ត្រីជាថ្នាក់ដឹកនាំនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៩៣៣នាក់ ត្រូវបានរៀបចំនិងអភិវឌ្ឍសមត្ថភាព

៤- ចុះអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងមុខងារសាធារណៈដើម្បីពង្រីកវិសាលភាពក្នុងការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈនិងការលើកកម្ពស់ស្ត្រីក្នុងវិស័យរដ្ឋបាលសាធារណៈ ព្រមទាំងរៀបចំផែនការសកម្មភាព រួមប្រចាំឆ្នាំដើម្បីអនុវត្តអនុស្សារណៈឱ្យកាន់តែមានប្រសិទ្ធភាព

៥- សហការជាមួយក្រសួងមុខងារសាធារណៈ អគ្គស្នងការដ្ឋាននគរបាលជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងបរិស្ថាន និងក្រសួងការពារជាតិ រៀបចំកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដល់ស្ត្រីក្នុងកម្រិតគ្រប់គ្រង ក្នុងស្ថាប័នខ្លួន ដែលមានចំនួន ៤៩៨នាក់(ស្រី៤១០នាក់)

៦- កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ ឆ្នាំ២០១៩ និងឆ្នាំ២០២១ បានដាក់ឱ្យដំណើរការ ដែលមានការចូលរួមពីយុវជនចំនួន៣៦នាក់(ស្រី២៦នាក់) មកពីក្រសួង ស្ថាប័ន និងតាមសាកលវិទ្យាល័យនានា រួមទាំងការហ្វឹកហាត់អនុវត្តសាកល្បងស្តីពីភាពជាអ្នកដឹកនាំនិងសមភាពយេនឌ័រ និងជំនាញទន់ ដែលអាចឱ្យពួកគេក្លាយជាអ្នកដឹកនាំលើការងារយេនឌ័រ និងអាចប្រើប្រាស់ភាពជាអ្នកដឹកនាំ ក្នុងការលើកកម្ពស់សមភាពយេនឌ័រកាន់តែមានប្រសិទ្ធភាព។

### ១.៦- យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ

អភិវឌ្ឍសមត្ថភាពដល់ថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិកមកពីក្រសួង មន្ទីរកិច្ចការនារី ក្រសួង មន្ទីរ ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការសង្គមស៊ីវិល សមាគមជនពិការ ទាំង២៥ រាជធានី ខេត្តសរុប២៩០

នាក់(ស្រី១៨៩នាក់) ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្រ្តីមានពិការភាពនិងបានចូលរួមជំរុញការងារលើកកម្ពស់សិទ្ធិរបស់ស្ត្រីនិងក្មេងស្រីជនពិការនៅក្នុងដំណើរការរៀបចំ និងអនុវត្តន៍ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ និងកម្មវិធីពាក់ព័ន្ធនានា។

## ១.៧- លទ្ធផលការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.ក.ស.)

ក.ជ.ក.ស. បានអនុវត្តយ៉ាងសកម្មក្នុងការលើកកម្ពស់កិច្ចការពារសិទ្ធិស្ត្រី និងជំរុញការបញ្ជ្រាបយេនឌ័រលើគ្រប់វិស័យ តាមរយៈការអនុវត្តច្បាប់ គោលនយោបាយ ផែនការ កម្មវិធី កំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល អនុសាសន៍គន្លឹះរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីនិងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW) សម្រេចលទ្ធផលដូចខាងក្រោម៖

១- ក្នុងឆ្នាំ២០១៨ បានបញ្ជូននិងទៅការពាររបាយការណ៍លើកទី៦ ស្តីពីការអនុវត្តអនុសញ្ញាCEDAW នៅកម្ពុជានៅគណៈកម្មាធិការCEDAWនៃអង្គការសហប្រជាជាតិ និងទទួលបានមកវិញសេចក្តីសង្កេតសន្និដ្ឋាន ៥៧ចំណុច ដើម្បីអនុវត្តបន្ត។ ក្នុងឆ្នាំ២០២១នេះ ក.ជ.ក.ស.នឹងបញ្ជូនរបាយការណ៍តាមដានការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន ៥៧ចំណុច ផ្តោតលើចំណុច១៩,២៥ (ខ) និង៤៧ (ឃ) ទៅគណៈកម្មាធិការ CEDAW តាមកាលកំណត់

២- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាទៀងទាត់និងកិច្ចប្រជុំសាមញ្ញ វិសាមញ្ញ ដើម្បីបូកសរុបរបាយការណ៍លទ្ធផលការងារសំខាន់ៗជូនរាជរដ្ឋាភិបាលនិងទទួលអនុសាសន៍គន្លឹះ ដើម្បីបន្តការអនុវត្តក្នុងការដោះស្រាយបញ្ហាប្រឈមនានាសម្រាប់ស្ត្រី មានអ្នកចូលរួមសរុប៣ ០៨២នាក់(ស្រី២ ០៤២នាក់)

៣- ចុះតាមដានវាយតម្លៃប្រចាំឆ្នាំ ការផ្តល់វគ្គពង្រឹងសមត្ថភាពនិងការផ្សព្វផ្សាយអំពីការអនុវត្តច្បាប់ជាតិ គោលនយោបាយជាតិពាក់ព័ន្ធ លិខិតបទដ្ឋានគតិយុត្តនានា អនុសាសន៍របស់រាជរដ្ឋាភិបាលនិងអនុសញ្ញា CEDAW បានបង្កើនការយល់ដឹងនិងជំរុញការអនុវត្តបន្ថែមទៀត ដល់មន្ត្រីពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបានចំនួន ៤ ១៥៥នាក់(ស្រី២ ០៦៧នាក់)ក្នុងការលើកស្ថានភាព សិទ្ធិ ឋានៈ និងសុខុមាលភាពស្ត្រី ដើម្បីឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន

៤- ផ្តល់សេវាជំនួយផ្នែកច្បាប់ដោយមិនគិតកម្រៃដល់ស្ត្រីនិងក្មេងស្រីក្រីក្ររងគ្រោះដោយអំពើហិង្សានៅទូទាំង២៥ រាជធានីខេត្ត ចំនួន៤៥២ករណី ក្នុងនោះសេវាមេធាវីការពារក្តីតាមផ្លូវច្បាប់ចំនួន១៤០ករណី ក្រោមកិច្ចសហប្រតិបត្តិការ(MOU) ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

៥- ផលិតនិងផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងអនុសញ្ញាCEDAW និងរបាយការណ៍ជាតិ សរុបចំនួន ៣០ ១៥០ច្បាប់ ក្នុងនោះ ១៦ ៦០០ច្បាប់ ជាព្រះរាជបូត្តម្ភរបស់**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី**។

## ១.៨- លទ្ធផលការងារអន្តរវិស័យ

### ១- ការបញ្ជ្រាបយេនឌ័រ នៅក្នុងគោលនយោបាយនិងផែនការជាតិ

១- រៀបចំនិងតាក់តែងឯកសារសំខាន់ៗដើម្បីលើកកម្ពស់សិទ្ធិស្ត្រីនិងសមភាពយេនឌ័រនៅកម្ពុជា រួមមាន (១) ឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា (២) ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥(២០១៩-២០២៣) (៣) ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី(២០១៩-២០២៣) និង(៤) សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ

២- ការជំរុញការបញ្ជ្រាបយេនឌ័រតាមវិស័យ ក្រសួងបានគាំទ្របច្ចេកទេសក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពក្រសួងចំនួន៩(ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បរិស្ថាន សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការពារជាតិ វប្បធម៌ និងវិចិត្រសិល្បៈ និងអគ្គស្នងការដ្ឋាននគរបាលជាតិ) និងធ្វើបច្ចុប្បន្នភាពលើផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រចំនួន៨ក្រសួង ស្ថាប័ន(ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល ពាណិជ្ជកម្ម ការពារជាតិ មុខងារសាធារណៈ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនធានទឹក និងឧតុនិយម និងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់) បានចូលរួមបញ្ជ្រាបយេនឌ័រក្នុងដំណើរការតាក់តែងនិងអនុវត្តច្បាប់ លិខិតបទដ្ឋាន និងកម្មវិធីតាមវិស័យនិងកម្មវិធីកំណែទម្រង់ រួមទាំងប្រព័ន្ធគ្រប់គ្រងទិន្នន័យជំនួយផ្លូវការដៃគូអភិវឌ្ឍន៍។ ក្នុងក្របខ័ណ្ឌសមាហរណកម្មក្នុងតំបន់ ក្រសួងបានដឹកនាំជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការចូលរួមរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់អាស៊ាន។

៣- ធាតុចូលនៃសមភាពយេនឌ័រត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០១៩-២០៣០) ផែនការសកម្មភាពជាតិស្ដីពីប្រជាជន ២០១៩-២០២១ និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ២០១៩-២០២៣

៤- ផែនការមេស្ដីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ(២០១៨-២០៣០) និងផែនការសកម្មភាពស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ(២០១៩-២០២៣) ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត។ គម្រោងសាកល្បងចំនួន៤ ត្រូវបានអនុវត្តដោយជោគជ័យ។ ក្រុមផលិតស្ត្រីចំនួន៤ក្រុម មានសមាជិកសរុប៨៥នាក់ ទទួលការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាសម្រាប់ដំណើរការអាជីវកម្មខ្នាតតូចចម្រុះ និងផ្នែកកសិកម្ម។

**២- កិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ**

១- ក្នុងនាមជាម្ចាស់ផ្ទះតាមវេនរបស់គណៈកម្មាធិការអាស៊ានស្ដីពីស្ត្រី(ACW) ក្រសួងបានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ លើកទី១៩ តាមរយៈប្រព័ន្ធវីដេអូ និងកិច្ចប្រជុំពាក់ព័ន្ធ រួមមានកិច្ចប្រជុំលើកទី១២របស់ ACW+3 (គណៈកម្មាធិការអាស៊ានស្ដីពីស្ត្រី រួមនឹងប្រទេសចិន ជប៉ុន និងកូរ៉េ) និងកិច្ចប្រជុំរវាងACW និងACWC (គណៈកម្មាធិការអាស៊ាន ដើម្បីការលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ

២-ចូលរួមជាមួយគណៈកម្មាធិការអាស៊ានស្ដីពីស្ត្រី(ACW) និងគណៈកម្មាធិការអាស៊ានដើម្បីលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ(ACWC) ក្នុងការធ្វើផែនការសកម្មភាពរបស់ ACW(2021-2025) និងACWC ដែលបានទទួលការអនុម័តពីរដ្ឋមន្ត្រីស្ដីពីកិច្ចការស្ត្រីអាស៊ាន និងរដ្ឋមន្ត្រីសង្គមកិច្ចទាំង១០ប្រទេស

៣- រៀបចំវេទិកាអាស៊ីអឺរ៉ុបស្ដីពីស្ត្រី សន្តិភាពនិងសន្តិសុខ ក្នុងការសម្របសម្រួលកិច្ចសន្ទនារវាងស្ត្រីនៅអឺរ៉ុបនិងអាស៊ី បង្ហាញវឌ្ឍនភាពរបស់ស្ត្រីក្នុងវិស័យសន្តិភាពនិង រួមទាំងស្ត្រីក្នុងវិស័យបោសសម្អាតមីន យុទ្ធសាស្ត្រទប់ស្កាត់អំពើហិង្សានិងផលប៉ះពាល់នៃជំងឺកូវីដ-១៩

៤- អភិវឌ្ឍសមត្ថភាពមន្ត្រីកិច្ចការនារីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចំនួន៦១៨នាក់(ស្រី៤៨៥នាក់) លើចំណេះដឹងស្ដីពីកិច្ចការស្ត្រីនិងអាស៊ាន និងការចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍

៥- ថ្នាក់ដឹកនាំនិងមន្ត្រីរាជការចំនួន៤៥១នាក់(ស្រី៣៦៩នាក់) បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលពាក់ព័ន្ធស្ត្រី និងសមភាពយេនឌ័រនៅក្រៅប្រទេស

៦- ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MoU) ជាមួយដៃគូពាក់ព័ន្ធចំនួន២០ស្ថាប័ន បានចុះកិច្ចព្រមព្រៀង(LoA) ចំនួន៤ស្ថាប័ន និងផ្ដល់លិខិតគាំទ្រចំនួន៣លើក។

**៣- ការរៀបចំផែនការយុទ្ធសាស្ត្រ និងថវិកា**

១- រៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល (BSP) ផែនការថវិកាប្រចាំឆ្នាំ ផែនការសកម្មភាពរួម ដំណាក់កាលទី៣(MAP3-2020) ផែនការសកម្មភាពដំណាក់កាលទី៣ បូក២(MAP3+2_2021) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលរបស់ក្រសួង បានបញ្ចូលកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលរបស់ជាតិ។

២- របាយការណ៍ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាស និងប្រចាំឆ្នាំ របាយការណ៍សមិទ្ធកម្ម ប្រចាំឆមាសនិងប្រចាំឆ្នាំនៃការអនុវត្តថវិកាកម្មវិធី និងរបាយការណ៍ផ្ទុផ្ទងសម្រេចទូទាត់ប្រចាំឆ្នាំរបស់ក្រសួងនិងមន្ទីររាជធានី-ខេត្ត បានរៀបចំស្របតាមនីតិវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- ថ្នាក់ដឹកនាំ មន្ត្រីថ្នាក់ក្រសួងនិងមន្ទីរកិច្ចការនារីទាំង២៥រាជធានី ខេត្ត ចំនួន៩២៦នាក់(ស្រី៦៨៤នាក់) បានពង្រឹងសមត្ថភាពនិងយល់ដឹងស្តីពីជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៤- ពង្រឹងសមត្ថភាពស្តីពីការរៀបចំផែនការស្ថិតិ ការត្រួតពិនិត្យនិងវាយតម្លៃឆ្លើយតបនឹងយេនឌ័រ ដល់មន្ត្រីក្រសួង មន្ទីរ និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់សរុបចំនួន៨៦៧នាក់(ស្រី៧៣៥នាក់)។

៥- ពង្រឹងសមត្ថភាពស្តីពី គោលការណ៍ណែនាំពីនីតិវិធីសវនកម្ម និងការងារគ្រប់គ្រងហិរញ្ញវត្ថុ ដល់មន្ត្រីក្រសួង មន្ទីររាជធានី ខេត្ត ការិយាល័យកិច្ចការនារី ក្រុង ស្រុក ខណ្ឌ សរុបចំនួន៥០២នាក់(ស្រី៣៧៥នាក់)។

**៤- ការងារអភិវឌ្ឍន៍សមត្ថភាពនិងធនធានមនុស្ស**

១- មន្ត្រីរាជការថ្មី១០៥នាក់(ស្រី៨២នាក់) បានចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី។ បានផ្ទេរក្របខ័ណ្ឌចេញ៤៤នាក់(ស្រី៣០នាក់) ផ្ទេរចូល៧នាក់(ស្រី៦នាក់) ដាក់ឱ្យចូលនិវត្តន៍១៤៥នាក់(ស្រី១៤២នាក់) និងលុបឈ្មោះចេញពីក្របខ័ណ្ឌ១៨នាក់(ស្រី១៣នាក់)។ មន្ត្រីរាជការចំនួន១៨៩នាក់(ស្រី១៤៣នាក់) បានទទួលការតែងតាំងនិងប្រគល់ភារកិច្ចក្នុងការអនុវត្តការងារ។

២- មន្ត្រីរាជការចំនួន៥៣៦នាក់(ស្រី៤០៧នាក់) បានយល់ដឹងអំពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ការតាក់តែងលិខិតបទដ្ឋានគតិយុត្តនិងការងារគ្រប់គ្រងរដ្ឋបាលតាមរយៈវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពចំនួន១០លើក។

៣- ការអនុវត្តកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ ក្រសួងបានផ្ទេរមុខងារចំនួន៣ និងផ្ទេរសមាហរណកម្មមុខតំណែងគ្រប់គ្រង ក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សរុបចំនួន២៧០នាក់(ស្រី២៦១នាក់) និងមន្ត្រីជាប់កិច្ចសន្យាចំនួន១៨នាក់ជាស្ត្រី។

៤- បានធ្វើឌីជីថលូបនីយកម្មតាមរយៈការរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីលើការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការងារប្រចាំថ្ងៃនិងការដាក់ឱ្យដំណើរការទំព័រហ្វេសប៊ុក ប្រព័ន្ធបណ្តាញសង្គម និងគេហទំព័រក្រសួង ក្នុងការផ្តល់ព័ត៌មាន បង្កើនការយល់ដឹង និងការប្រមូលព័ត៌មានត្រឡប់ពីមហាជន តាមរយៈសកម្មភាពមួយចំនួនដូចជាយុទ្ធនាការ១៦ថ្ងៃ ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី ទិវាអន្តរជាតិនារី ៨មីនា ការប្រឹក្សាផ្នែកច្បាប់ តាម Hotline កិច្ចប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ កម្មវិធីពិភាក្សា និងផ្សព្វផ្សាយតាមWebinar កម្មវិធីអប់រំផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម លិខិតរដ្ឋបាល និងឯកសារពាក់ព័ន្ធជាដើម។ ដែលមានអ្នកទទួលនិងចូលរួមសរុបប្រមាណជា២លាននាក់ ក្នុងកំឡុងឆ្នាំ២០១៩-២០២១។

## ១.៩- ការផលិត ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងជាសាធារណៈ

១- ផ្សព្វផ្សាយព័ត៌មានឆ្លើយតបយេនឌ័រ និងផ្លាស់ប្តូរផ្នត់គំនិតបែបអវិជ្ជមានរបស់មហាជនត្រូវបានពង្រីក និងពង្រឹងការអនុវត្ត។ តាមរយៈឯកសារនិងសារអប់រំខ្លីៗខ្លឹមសារលើកកម្ពស់សមភាពយេនឌ័រ ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងពលករចំណាកស្រុក ព្រមទាំងបានធ្វើការផ្សព្វផ្សាយតាមបណ្តាញសង្គម។

២- ផលិតនិងផ្សព្វផ្សាយកម្មវិធីតាមវិទ្យុជាតិនិងវិទ្យុឯកជនចំនួន៣ ៦៤០លើក បោះពុម្ព ព្រឹត្តិបត្រនារីរតនៈ ចំនួនជាង៣០ ០០០ច្បាប់ និងបើកវេទិកាសាធារណៈចំនួន១៨លើក ដែលមានអ្នកចូលរួមចំនួន៧ ៧៤៦នាក់(ស្រី៤១៥៤)។

៣- រៀបចំវេទិកាជជែកពិភាក្សាស្តីពីសមភាពយេនឌ័រ វេទិកាតុមូល ដើម្បីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំនិងមន្ត្រីក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន និស្សិតមកពីសាកលវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញ សរុបចំនួន៨៣៦នាក់(ស្រី៥២៥នាក់) និងបានផ្សព្វផ្សាយតាមបណ្តាស្ថានីយទូរទស្សន៍និងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង(ទំព័រហ្វេសប៊ុក គេហទំព័រ និងYouTube)។

៤- សៀវភៅនិងខិតបណ្ណស្ថិតិយេនឌ័រ បានផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាសាធារណៈ និងបានចែកជូនក្រសួង ស្ថាប័នពាក់ព័ន្ធ សាកលវិទ្យាល័យ អ្នកស្រាវជ្រាវ អ្នករៀបចំផែនការ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ សិស្ស និស្សិតប្រើប្រាស់តាមតម្រូវការ។

## ២- ការលើកកម្ពស់ការគាំពារសង្គម

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចការងារដូចខាងក្រោម៖

ដោយសារការផ្ទុះឡើងនូវជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ និងបន្តអូសបន្លាយដល់ឆ្នាំ២០២១ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតមកលើសេដ្ឋកិច្ចនិងសង្គម នៃបណ្តាប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងដែរ។ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាថមថយសន្ទុះបាត់បង់កំណើន ដែលក្នុងរយៈពេល៥ឆ្នាំ ២០១៧-២០២១ កំណើនសេដ្ឋកិច្ចកម្ពុជាគិតជាមធ្យមកើនឡើងប្រមាណ៤,០៨% ក្នុងមួយឆ្នាំប៉ុណ្ណោះ។

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១«**ការអភិវឌ្ឍធនធានមនុស្ស**» ត្រង់មុំទី៤: ការពង្រឹងសមភាពយេនឌ័រនិងកិច្ចគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គម រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេស ជនរងគ្រោះ និងងាយរងគ្រោះ ឱ្យរួចផុតពីហានិភ័យទាំងឡាយ។ ក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ផ្តោតលើកម្មវិធីសំខាន់ៗចំនួនបីគឺ ១-ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២- ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ និង៣- ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ភាពជាដៃគូ និងអនុកម្មវិធីចំនួន១២ រួមមាន (១) ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះនិងកិច្ចការគ្រួសារ (២) ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា (៣) ការអភិវឌ្ឍសុខុមាលភាពជនពិការ (៤) ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ (៥) ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន (៦) ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត (៧) ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (៨) ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន (៩) ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ (១០) ការ

ពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ (១១) ការអភិវឌ្ឍធនធានមនុស្ស និង(១២) ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ភាពជាដៃគូរាជធានី ខេត្ត។ ជាអាទិ៍ក្នុងរយៈពេល៥ឆ្នាំ២០១៧-២០២១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអនុវត្តសម្រេចបានលទ្ធផលដូចខាងក្រោម៖

## ២.១- ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

### ២.១.១- អភិវឌ្ឍន៍សុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ

- អនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ ដោយសហការជាមួយកាកបាទក្រហមកម្ពុជា និងអង្គការនានា ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាស្បៀងនិងសម្ភារៈផ្សេងៗ ដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ប្រជាជនរងគ្រោះនិងងាយរងគ្រោះ ប្រជាជនក្រីក្រ ទុរគតជន សរុបចំនួន២៨០ ២៩២គ្រួសារ

- ដើម្បីជួយគាំទ្រផ្នែកជីវភាព និងសុខុមាលភាពរបស់ប្រជាជនក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។ ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ប្រជាជនក្រីក្រនិងងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ បានមកចុះឈ្មោះទទួលសេវាសរុបចំនួន៦៨៤ ៧៧១គ្រួសារ ដែលចំណាយថវិកាសរុបចំនួន២ ១២៦ ៦៥៧ ៤១៨ ០០០រៀល(គ្រួសារក្រីក្រកម្រិត១ ចំនួន ២៥៣ ៧៨៥គ្រួសារ និងគ្រួសារក្រីក្រកម្រិត២ ចំនួន៤៣០ ៩៨៦គ្រួសារ) ក្នុងនោះ ចំនួនមនុស្សវ័យចាស់អាយុពី៦០ឆ្នាំទទួលបានការបើកសាច់ប្រាក់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ចំនួន៣៣៨ ០៧៦នាក់ ចំនួនជនមានពិការភាពទទួលបានការបើកសាច់ប្រាក់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចំនួន៦២ ១៧៤នាក់ និងចំនួនគ្រួសារផ្ទុកមេរោគអេដស៍ដែលទទួលបានការបើកសាច់ប្រាក់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចំនួន១ ៩៦៤គ្រួសារ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានការលំបាកផ្នែកជីវភាព ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តការណ៍ ២០កុម្ភៈ ២០២១ ដោយចាប់អនុវត្តពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១។ គិតមកដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ គ្រួសារដែលបានទទួលប្រាក់ឧបត្ថម្ភសរុបចំនួន១២៩ ៦៦៦គ្រួសារ ចំណាយថវិកាសរុបចំនួន៣៤ ៧១៥ ១៨៣ ៦០០រៀល

- ប្រកាសដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។ បើគិតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ៨៧ ០១២នាក់ និងកុមារអាយុក្រោម២ឆ្នាំ ចំនួន៤២ ៩៨៨នាក់ ដែលចំណាយថវិកាសរុបចំនួន៦១ ៧៧៦ ៩៦០ ០០០រៀល

- សង្គ្រោះ អប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ថែទាំសុខភាពជូនជនអនាថាសរុបចំនួន៩ ៤២៧នាក់ ក្រៅពីទទួលបានសេវាខាងលើ ជនអនាថាចំនួន៥ ១៤០នាក់ បានទទួលសេវាស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍។ បានផ្សព្វផ្សាយ អប់រំ បញ្ជ្រាបការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាជន៥៨១នាក់

- មជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលត្រូវបានបង្កើតឡើងនិងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៩ ក្រោមអធិបតីភាពសម្តេច

ក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ មជ្ឈមណ្ឌលនេះបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅចំនួន៦៨នាក់ និងបានសមាហរណកម្មទៅសហគមន៍វិញចំនួន៧នាក់

- ផ្តល់សេវាថែទាំនិងគាំទ្រនៅសហគមន៍ដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗបានចំនួន៩ ២៦៥នាក់ ក្នុងនោះ មានការអប់រំផ្សព្វផ្សាយ វគ្គបំណិនជីវិត អប់រំសុខភាព សេវាប្រឹក្សាយោបល់ និងការបង្កើតមុខរបរខ្នាតតូចដល់គ្រួសារនិងកុមារដែលរងផលប៉ះពាល់ដោយសារជំងឺអេដស៍

- បង្កើតនិងអនុវត្តកម្មវិធី ស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ តាមរយៈការរៀបចំទិវាជាតិ និងអន្តរជាតិ ស្តីពីគ្រួសារ ១៥ឧសភា ជារៀងរាល់ឆ្នាំ និងចុះផ្សព្វផ្សាយទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ឧសភា ដល់សិស្សនិស្សិតនៅតាមវិទ្យាល័យនិងសាកលវិទ្យាល័យផងដែរ។ បានបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការផ្សព្វផ្សាយទស្សនទានយេនឌ័រនិងអនុសញ្ញាស៊ី-ដ(CEDAW) ដល់មន្ត្រីបង្គោលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយការយល់ដឹង ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដល់សហគមន៍

- ផ្សព្វផ្សាយស្តីពីការអប់រំសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរផ្សារភ្ជាប់នឹងទិវានៃក្តីស្រលាញ់ នៅតាមសាលាបឋមសិក្សា វិទ្យាល័យ និងសាកលវិទ្យាល័យ

- រៀបចំអបអរសាទរខួបអនុស្សាវរីយ៍ទិវានារីអន្តរជាតិ៨មីនា ជារៀងរាល់ឆ្នាំ ដល់មន្ត្រីជានារីនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីចិញ្ចឹមកូនបែបវិជ្ជមាន ដល់មន្ត្រីនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ត្រីការិយាល័យសុខុមាលភាពសង្គមទាំង២៥ រាជធានី ខេត្ត

- រៀបចំនិងដាក់ឱ្យអនុវត្តនូវបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្សនិងសង្គ្រោះជនរងគ្រោះ។ តាមរយៈគោលនយោ-បាយនិងបទដ្ឋាន ជនរងគ្រោះដោយអំពើជួញដូរមនុស្ស៤ ៦៩៤នាក់ ត្រូវបានសង្គ្រោះ អប់រំប្រឹក្សាយោបល់ បញ្ជូនទៅស្ថានីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមណ្ឌលរបស់អង្គការ និងជនរងគ្រោះចំនួន១ ២៩៥នាក់ ត្រូវធ្វើសមាហរណកម្មទៅសហគមន៍ និងតាមដានបន្តចំនួន៣៩១នាក់ និងបិទករណីចំនួន ២៤៨នាក់។ ទន្ទឹមនោះ បានកសាងមណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលទុកដាក់ជនរងគ្រោះ និងងាយរងគ្រោះដែលទទួលបានពីអាជ្ញាធរថៃ គិតមកដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ មណ្ឌលសំចតបានទទួលពលករចំណាកស្រុកសរុបចំនួន ១៣១ ៥៩៥នាក់ និងបានសម្ភាសន៍កំណត់អត្តសញ្ញាណរកឃើញជនរងគ្រោះ និងងាយរងគ្រោះចំនួន៦៨៨នាក់

- ទទួលជនរងគ្រោះមាតុភូមិនិវត្តន៍ពីប្រទេសនានាចំនួន១ ៤០២នាក់ និងបានធ្វើមាតុភូមិនិវត្តន៍ដោយអំពើជួញដូរមនុស្សត្រឡប់ទៅប្រទេសកំណើតវិញចំនួន៣៤នាក់។

តារាងទី១- លទ្ធផលសម្រេចបានអនុកម្មវិធីទី១.១

| ល | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ |
| ១ | គ្រួសាររងគ្រោះដោយដាច់ស្បៀងទីទ័ល-ក្រ គ្រោះមហន្តរាយ នៅតាមសហគមន៍ បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសា | ៦២ ៤៧៦ | ៥៦ ១៩៩ | ៣១ ៤២៨ | ១០១ ៤៧៣ | ២៨ ៧១៦ |
| ២ | ប្រជាជនក្រីក្រនិងងាយរងគ្រោះដែលរងផលប៉ះពាល់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ | គ្រួសា | - | - | - | ៦៨១ ៩៩៩ | ៦៨៤ ៧៧១ |
| ៣ | ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញឬបញ្ជូនត្រឡប់ទៅសហគមន៍វិញ | នាក់ | ២៥៤ | ២ ៥០៩ | ១ ២៩១ | ៥៤៥ | ៥៤១ |
| ៤ | ជនអនាថាដែលទទួលបានសេវា | នាក់ | ១២៤៤ | ២ ០៨៥ | ១ ៧៥៨ | ៣០៤៥ | ១ ២៩៥ |
| ៥ | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ដែលទទួលសេវាថែទាំគាំទ្រតាមសហគមន៍ | នាក់ | ២ ៧៥៨ | ៤ ២៨៥ | ១ ៨៦៧ | ៣៣៦ | ១៩ |
| ៦ | ជនវិបល្លាសស្មារតីទទួលបានសេវាព្យាបាលនិងថែទាំក្នុងមជ្ឈមណ្ឌល | នាក់ | - | - | ៤៧ | ៦៥ | ៧០ |
| ៧ | ជនវិបល្លាសស្មារតីទទួលបានការបញ្ជូនត្រឡប់ ឬសមាហរណកម្មទៅគ្រួសារ ឬសហគមន៍ | នាក់ | - | - | - | ០៣ | ០៤ |
| ៨ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | - | - | - | ៤៩ ១៨៦ | ៣៧ ៨២៦ |
| ៩ | កុមារអាយុ០-២ឆ្នាំ នៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | - | - | - | ២៨ ៣៣៣ | ១៤ ៦៥៥ |
| ១០ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទរំលោភបំពានផ្លូវភេទ ទទួលបានការស្តារនីតិសម្បទា | នាក់ | ៧២០ | ៨៤៨ | ៩៦៨ | ៣៧១ | ១ ៧៨៧ |
| ១១ | ជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដែលត្រូវបានគាំពារ និងជួយសង្គ្រោះ | នាក់ | ០ | ០ | ៥៧៩ | ៤៦ | ១៤៣ |
| ១២ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | ៣ | ២ | ៩ | ១៥ | ៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅ | នាក់ | ២៨៨ | ២២២ | ២៩០ | ២២០ | ៣៨២ |
| ១៤ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវទទួលបានការធ្វើសមាហរណកម្ម ទៅតាមសហគមន៍វិញ | នាក់ | ១៤៧ | ៣៤៥ | ៤០៣ | ១០៤ | ២៩៦ |
| ១៥ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានផ្តល់នូវសេវាក្រោយធ្វើ សមាហរណកម្ម | នាក់ | ៩៥ | ១១៧ | ០ | ១២២ | ៥៧ |
| ១៦ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានបិទករណី | នាក់ | ៥៣ | ៦៩ | ២៧ | ២៣ | ៧៦ |

**២.១.២- ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា**

- ក្រសួងបានរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារនិងទិវាកុមារកម្ពុជាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជារៀងរាល់ឆ្នាំ

- ពង្រឹងពង្រីកយន្តការតាមដាននិងអនុវត្តសិទ្ធិកុមារ តាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត និងបានចេញគោលការណ៍ណែនាំស្តីពីការអនុវត្តអនុសាសន៍របស់អង្គការសហប្រជាជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ

- រៀបចំរបាយការណ៍ ស្តីពីស្ថានភាពនៃការអនុវត្តសិទ្ធិកុមារជារៀងរាល់ឆ្នាំនិងរៀបចំរបាយការណ៍ឆ្លើយតបទៅនឹងកម្រងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយការណ៍ជាតិលើកទី១និងទី២ ស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធនិងស្តីពីការជួញដូរកុមារ ការធ្វើពេស្យាចារកុមារនិងរូបភាពអាសអាភាសកុមារ និងរបាយការណ៍ឆ្លើយតបទៅនឹងសេចក្តីសម្រេចចិត្តមហាសន្និបាត អ.ស.ប. លេខ៦៩/១៥៩ ស្តីពីការការពារកុមារពីការសម្លុតគម្រាមកំហែង ដើម្បីផ្ញើទៅតំណាងពិសេសអង្គការសហប្រជាជាតិ និងរបាយការណ៍ជាតិគួបលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ

- ដើម្បីលើកកម្ពស់ការគោរពសិទ្ធិកុមារនិងការពារឧត្តមប្រយោជន៍កុមារ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារត្រូវបានតាក់តែងឡើងនិងពិនិត្យ កែសម្រួលជាបន្តបន្ទាប់តាមរយៈសិក្ខាសាលានិងកិច្ចប្រជុំនានា ក្រៅពីនេះឯកសារមួយចំនួនទៀតក៏ត្រូវបានរៀបចំនិងប្រកាសដាក់ឱ្យអនុវត្ត មានជាអាទិ៍ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍកុមារ ឆ្នាំ២០១៦-២០១៨ គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ ផែនការសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២០២១-២០២៥។ បានពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធតាមរយៈការរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាល និងបានរៀបចំកិច្ចពិភាក្សាតុមូលតាមស្ថានីយវិទ្យុ និងទូរទស្សន៍ សំដៅផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិកុមារឱ្យបានកាន់តែទូលំទូលាយ ជាពិសេស ការបញ្ជ្រាបអំពីតួនាទីគ្រួសារនិងសហគមន៍ ក្នុងការធានានូវឧត្តមប្រយោជន៍របស់កុមារ

- គណៈកម្មាធិការអាស៊ានដើម្បីការលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ(ACWC) ផ្នែកសិទ្ធិកុមារបានអនុវត្តគម្រោង«**យុទ្ធនាការផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រីនិងកុមារក្នុងតំបន់អាស៊ាន**» ដោយផលិតបានសៀវភៅផ្ទត់(Booklet) និងវីដេអូអប់រំជាគំនូរជីវចលស្តីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រីនិងកុមារក្នុងតំបន់អាស៊ាន ព្រមទាំងបានផ្សព្វផ្សាយទៅគ្រប់អង្គភាពអាស៊ាន និងតាមគេហទំព័ររបស់ACWC

- អនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារនិងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ អនុក្រឹត្យលេខ១១៩អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារនិងអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ដោយបានដំឡើងប្រាក់ម្ហូបអាហារពី៤៥ ០០០រៀល/ខែ ទៅ១៥០ ០០០រៀល/ខែ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។ បានទទួលកុមារកំព្រានិងកុមាររងគ្រោះ ឱ្យស្នាក់នៅក្នុងមណ្ឌលថែទាំ ចំនួន១៩៩មណ្ឌល មានកុមារសរុបចំនួន៥ ៤៤០នាក់ កុមារី២ ៥៦៩នាក់ និងយុវជនវ័យក្មេង(អាយុ១៨ឆ្នាំឡើង) ចំនួន១ ៧១៦នាក់(ស្រី ៨៨៧នាក់) ក្នុងនោះ មណ្ឌលថែទាំដែលគ្រប់គ្រងនិងគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលមានចំនួន១៧៨ មណ្ឌលមានកុមារ៤ ៧៣៤នាក់ កុមារី២ ២៧៩នាក់ និងយុវជនវ័យក្មេង(អាយុ១៨ឆ្នាំឡើង) ចំនួន១ ៣៩០នាក់ (ស្រី៧២២នាក់) មណ្ឌលថែទាំរបស់រដ្ឋមានចំនួន២១ មានកុមារចំនួន៧០៨នាក់ កុមារី២៩០នាក់ និងយុវជនវ័យក្មេង(អាយុ១៨ឆ្នាំឡើង) ចំនួន៣២៦នាក់(ស្រី១៦៥នាក់)។ កន្លែងថែទាំបែបសហគមន៍មានចំនួន១០១កន្លែង មានកុមារចំនួន២ ១៨៦នាក់ កុមារី១ ០៤៧នាក់ និងយុវជនវ័យក្មេង(អាយុ១៨ឆ្នាំឡើង) ចំនួន៥២១នាក់(ស្រី ២៧២នាក់)

- ដើម្បីពង្រឹងប្រសិទ្ធភាព និងគុណភាពការគ្រប់គ្រងមណ្ឌលថែទាំកុមារ ក្រសួងបានបង្កើតប្រព័ន្ធនៃអធិការកិច្ចកន្លែងថែទាំកុមារដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងបង្កើតប្រព័ន្ធគ្រប់គ្រងករណីកុមារតាមប្រព័ន្ធបច្ចេកវិទ្យាPrimero និងបានបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកនៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ព្រមទាំងបានធ្វើអធិការកិច្ចមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈពិន្ទុអធិការកិច្ចឆ្នាំ២០១៩ បានបង្ហាញថា មណ្ឌលចំនួន៩៨ ស្មើនឹង៤២,២% អនុវត្តស្របតាមបទដ្ឋាន មណ្ឌលចំនួន៥៩ អនុវត្តមិនស្របតាមបទដ្ឋាន និងមណ្ឌលចំនួន៧៥ អនុវត្តក្រោមបទដ្ឋានអប្បបរមាធ្ងន់ធ្ងរ

- អនុវត្តន៍ផែនការសកម្មភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន៣០% ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាព។ គិតត្រឹមឆ្នាំ២០១៩ មណ្ឌលថែទាំកុមារនៅសល់ចំនួន២៣២មណ្ឌល ដែលមានកុមារសរុបចំនួន៦ ៧៧៨នាក់(ស្រី៣ ៣១៧នាក់) ដូច្នេះ បើធៀបនឹងឆ្នាំ២០១៥ មណ្ឌលថែទាំកុមារបានថយចុះចំនួន១៧៤កន្លែង(៤៣%) និងកុមាររស់នៅក្នុងមណ្ឌលថែទាំបានថយចំនួន៩ ៨០២នាក់(៥៩%)។ ក្នុងចំណោមមណ្ឌលថែទាំកុមារ១៧៤ ដែលថយចុះ ដោយសារមណ្ឌលថែទាំចំនួន៧៧ បានបិទលែងដំណើរការ(ក្នុងនោះមណ្ឌលចំនួន២ បានបិទដោយសារការអនុវត្តមិនស្របតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ មណ្ឌលចំនួន៤៣ បានបិទដោយសារខ្វះមូលនិធិ និងមណ្ឌលចំនួន៣២ផ្សេងទៀត បានបិទដោយសារមូលហេតុផ្សេងៗ មណ្ឌលចំនួន២៤ បានបង្វែរទៅជាសេវាថែទាំតាមសហគមន៍ និងមណ្ឌលចំនួន៧៣ បានផ្លាស់ទៅជាសេវាថែទាំដែលពុំមែនជាមណ្ឌល។ កុមារចំនួន១ ៤១៩នាក់ស្មើនឹង១២% ធៀបនឹងកុមារចំនួន១១ ៧៨៨នាក់ រស់នៅក្នុងមណ្ឌលថែទាំនៅក្នុងរាជធានី ខេត្ត គោលដៅទាំង៥ ត្រូវបានជួយគាំទ្រដើម្បីសមាហរណកម្ម។ ទន្ទឹមនោះ ក្រសួងបានចេញសេចក្តីណែនាំ ស្តីពីតួនាទី ភារកិច្ច របស់មន្ត្រីសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ។

- ក្រសួងបានចេញប្រកាសលេខ១១៩ ស.អ.យ. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិនិងឪពុកម្តាយធម៌។ ក្រសួងសម្របសម្រួលលើការងារសុំកូនក្នុងប្រទេស ដោយតុលាការខេត្តបាត់ដំបងបានចេញដីការសម្រេចអំពីការបង្កើតការសុំកូនពេញលេញបានចំនួន៥នាក់។ ក្រសួងបានទទួលដីការលេខ៦០៧«ជ».ដ.ម. ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ ក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ: ៥៨៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ សម្រេចជ្រើសតាំងប្រធាននាយកដ្ឋានសុខុមាលភាពកុមារជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនចំនួន២៨នាក់ ដែលកំពុងស្នាក់នៅមណ្ឌលបុរីទារកនិងកុមារជាតិ

- ផ្តល់វិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារជូនអង្គការមិនមែនរដ្ឋាភិបាល ចំនួន១០០មណ្ឌល និងបានបណ្តុះបណ្តាលគុណវុឌ្ឍិនៃអង្គការសុវត្ថិភាពនៃកុមារ ដល់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បានចំនួន៦អង្គការ សរុបអ្នកចូលរួមចំនួន១០០នាក់

- ដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ កម្ពុជាបានចូលជាសមាជិកដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ក្រសួងបានរៀបចំផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ បង្កើតយន្តការដឹកនាំការងារនិងបើកយុទ្ធនាការ«**គ្រួសាររឹងមាំ**» នៃយុទ្ធសាស្ត្រ Cambodia Protect ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារនិងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ យុទ្ធនាការនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈវិទ្យុ ទូរទស្សន៍ សារសំឡេងតាមទូរសព្ទ បណ្តាញសង្គមហ្វេសប៊ុក Strong Family និងគេហទំព័រ www.strongfamily.mosvy.gov.kh និងបានរៀបចំសន្និសីទថ្នាក់តំបន់ឆ្ពោះទៅអនុវត្តយុទ្ធសាស្ត្រ INSPIRE (**I** : Implementation and enforcement of laws; **N** : Norms and values; **S** : Safe environments; **P** : Parent and caregiver support; **I** : Income and economic strengthening; **R** : Response and support services; and **E** : Education and life skills) ដែលមានអ្នកចូលរួមចំនួន១៥០នាក់ មកពីប្រទេសចំនួន២១ ដើម្បីសិក្សានិងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក

- បានទទួលរបាយការណ៍តាមដានវឌ្ឍនភាពកូនចិញ្ចឹមចំនួន១ ៩៧៣ករណី មកពីប្រទេសអ៊ីតាលី ១ ៩០១ករណី អូទ្រីស៤៤ករណី ម៉ាល់តា១៩ករណី ហូឡង់១ករណី បារាំង១ករណី បែលហ្ស៊ិក២ករណី អេស្ប៉ាញ១ករណី និងអាម៉េរិក៣ករណី។ តាមរបាយការណ៍ ស្ថានភាពកុមារដែលបានសុំទៅក្រៅប្រទេសមានលក្ខណៈល្អប្រសើរទាំងសុខភាព ការរស់នៅ និងការសិក្សារៀនសូត្រ

- សាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយសារស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ កែវផុស ស្រុកកំពង់សិលា ខេត្តព្រះសីហនុ រហូតមកដល់ពេលនេះ ហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានកសាងរួចរាល់ ហើយកំពុងបានទទួលជនរងគ្រោះដោយសារគ្រឿងញៀនស្នាក់នៅ បន្សាប និងព្យាបាល និងបានចេញប្រកាសអន្តរក្រសួង ស្តីពីលក្ខខណ្ឌនិងទម្រង់បែបបទនៃការស្នើសុំបង្កើតមណ្ឌលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននិងគោលការណ៍ណែនាំ ស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ បានចេញប្រកាសបញ្ចូលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន៣១ ៥៤៣ នាក់ និងចេញប្រកាសបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន៣០ ៣១៩នាក់

- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានផ្សព្វផ្សាយដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដើម្បីជំរុញអនុវត្តច្បាប់នេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិ ២០១៨-២០២០ សាងសង់មណ្ឌលយុវនីតិសម្បទា រៀបចំទម្រង់របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាពនិងស្ថានភាពរបស់អនីតិជន ប្រកាសលេខ១៥៥ ស.អ.យ. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមណ្ឌលយុវនីតិសម្បទា អនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា

ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា តែងតាំង និងទទួលស្គាល់ភ្នាក់ងារសង្គមកិច្ចទាំង ២៥រាជធានី ខេត្ត តាមប្រកាសលេខ ១០១ ស.អ.យ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ សរុបចំនួន៥០នាក់

- បណ្តុះបណ្តាលច្បាប់ស្តីពីយុត្តិធម៌អនីតិជននិងការងារសង្គមដល់មន្ត្រីសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ បានចំនួន១៩៩ ដែមានអ្នកចូលរួមសរុបចំនួន២២៥នាក់ ឆ្នាំ២០១៩

- ផ្សព្វផ្សាយពីការប្រើប្រាស់ទម្រង់របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ ទូទាំង២៥រាជធានី ខេត្ត ដោយមានការចូលរួមពីព្រះរាជអាជ្ញាអមសាលាដំបូង នគរបាលយុត្តិធម៌ ថ្នាក់ដឹកនាំនៃមន្ទីរ ស.អ.យ. និងភ្នាក់សង្គមកិច្ចសរុបចំនួន១៦២នាក់(ស្រី៦១នាក់)

- អប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម រួមចំណែកលើកស្ទួយសីលធម៌ សុជីវធម៌ និងការពារសិទ្ធិកុមារ និងជនរងគ្រោះដែលប្រើប្រាស់គ្រឿងញៀន។ សហការជាមួយក្រសួងមហាផ្ទៃ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ផ្តល់សេវាអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនីតិជនទំនាស់នឹងច្បាប់ និងបានផ្តល់សេវាសង្គមកិច្ចដល់កូនតាមម្តាយក្នុងពន្ធនាគារដែលមានអាយុលើសពី៣ឆ្នាំចំនួន២៥នាក់។

**តារាងទី២ លទ្ធផលសម្រេចបានអនុកម្មវិធី១.២**

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | កុមារកំព្រា និង កុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | ១៦ ៥៧៩ | ៧ ៦៣៤ | ៦ ៧៧៨ | ៦ ៧៧៨ | ៥ ៤៤០ |
| ២ | កុមារកំព្រា និង កុមារងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៧៣៨ | ១ ១៤០ | ១ ៤១៩ | ១ ៤១៩ | ១ ៤៤៧ |
| ៣ | កុមាររងគ្រោះដែលទទួលបានការថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | ៩ ៦០៨ | ១០ ៧៤៨ | ២ ៨០០ | ២ ៨០០ | ២ ១៨៦ |
| ៤ | កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ៥ | ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ៦ | អនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែនិងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | ១ ៤១២ | ១ ៥៦៥ | ១ ៦៨១ | ១ ៦២១ | ១ ៤០៤ |
| ៧ | កូនតាមម្តាយដែលមានអាយុចាប់ពី៣ (បី)ឆ្នាំឡើងទៅនៅក្នុងពន្ធនាគារ ត្រូវបានទទួលសេវាសង្គមកិច្ច | នាក់ | ៥ | ៧ | ៨ | ៧ | ១០ |
| ៨ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | ១០ ១៧៨ | ៨ ០៩៧ | ១១ ៩១៣ | ១១ ៥៣៦ | ១១ ៨៤៣ |
| ៩ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៦ ៧២២ | ៧ ៦៧៧ | ៧ ៩០៥ | ៧ ៥៥១ | ៥ ០៦៧ |

### ២.១.៣- ការអភិវឌ្ឍសុខុមាលភាពជនពិការ

- នឹងកំពុងប្រមូលធាតុចូលក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនមានពិការភាព

- រៀបចំរបាយការណ៍លើកដំបូងនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ

- ប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈផែនការនេះ ក្រសួងបានរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ២០១៥ និងសេចក្តីព្រាងរបាយការណ៍បញ្ចប់អាណត្តិឆ្នាំ២០១៤-២០១៨ និងបានដាក់ឱ្យអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ព្រមទាំងបានផ្សព្វផ្សាយដល់ក្រសួងស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន១៥ រាជធានី ខេត្ត

- ដាក់ឱ្យប្រើប្រាស់ប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌនៃការចេញបណ្ណបើកបរយានយន្តសម្រាប់ជនពិការ រួមទាំងសៀវភៅគោលការណ៍ណែនាំ ស្តីពីជំនួយផ្នែកច្បាប់សម្រាប់ជនពិការ

- អនុវត្តគម្រោងសាកល្បងបរិយាបន្នពិការភាព និងGender ដល់ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្តចំនួន៥ គឺខេត្តបាត់ដំបង សៀមរាប កំពង់ចាម ត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ

- បង្កើតក្រុមការងារសកម្មភាពជនពិការតាមក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាសកម្មភាពជនពិការតាមរាជធានី ខេត្ត និងបានរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងអំពីអនុសញ្ញា ស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញបរិយាប័ន្នពិការភាព របៀបធ្វើបរិយាបន្នពិការភាពដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ស.ជ. ក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន និង ក.ស.ជ. ថ្នាក់រាជធានីខេត្ត យ៉ាងទូលំទូលាយ

- សម្ពោធដាក់ឱ្យប្រើប្រាស់ជម្រាលគំរូក្នុងឃុំចំនួន២២ក្នុងខេត្តចំនួន៥ និងវីដេអូអប់រំ ស្តីពីបទដ្ឋានបច្ចេកទេសហេដ្ឋារចនារូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការ និងបានបណ្តុះបណ្តាលស្តីពីបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការដល់អ្នកពាក់ព័ន្ធ

- ចូលរួមកិច្ចប្រជុំក្រុមការងារក្នុងក្របខ័ណ្ឌអាស៊ានចំនួន៦លើក ស្តីពីការកសាងផែនការមេសម្រាប់ការបញ្ជ្រាបសិទ្ធិជនពិការក្នុងសហគមន៍អាស៊ាន ឆ្នាំ២០២៥

- ចូលរួមសន្និសីទលើកទី១១ នៃរដ្ឋភាគីអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅអង្គការសហប្រជាជាតិការិយាល័យកណ្តាលទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក កាលពីថ្ងៃទី១២ ដល់ទី១៤ ខែមិថុនា ឆ្នាំ២០១៨ ក្រោមប្រធានបទ**«មិនអនុញ្ញាតឱ្យនរណាម្នាក់នៅក្រៅការអនុវត្តយ៉ាងពេញលេញនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ»** ក្នុងនោះកម្ពុជាទទួលបានការគាំទ្រ១៨៣សំឡេង លើ១៨៨សំឡេង ចូលជាសមាជិក ECOSOC នៃអង្គការសហប្រជាជាតិ

- រៀបចំទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ទិវាគ ថ្លង់ និងទិវាអូទីហ្ស៊ីមនិងដោនស៊ីនដ្រូមសម្រាប់ជនពិការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជារៀងរាល់ឆ្នាំ

- បណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តួចផ្តើមបង្កើតមុខរបរនៅតាមសហគមន៍ដល់ជនពិការបាន៤៧នាក់លើជំនាញ កាត់ដេរសម្លៀកបំពាក់និងកាបូប អេឡិចត្រូនិក ជួសជុលម៉ាស៊ីន អ៊ុតសក់ធ្វើមុខនិងសម្អាងការ ចម្លាក់កសិកម្ម ជួសជុលទូរសព្ទ និងជំនាញគ្រប់គ្រងអាជីវកម្មនិងអនាម័យ។ ទន្ទឹមនេះ បានដោះស្រាយការងារ និងមុខរបរជូនជនពិការបាន៣៨៥នាក់

- អនុវត្តតាមអនុក្រឹត្យ ស្តីពីការជ្រើសរើសជនពិការចូលបម្រើការងារ ក្រសួង ស.អ.យ. បានជំរុញក្រសួង ស្ថាប័នរដ្ឋ ក្នុងការជ្រើសរើសជនពិការចូលបម្រើការងារតាមអត្រា បច្ចុប្បន្ន ជនពិការ៣ ៦២១នាក់ កំពុង

បម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋចំនួន៤៣ និងជនពិការ៥ ២៣៥នាក់ កំពុងបម្រើការងារនៅក្នុងរោងចក្រ សហគ្រាសវិស័យឯកជន

- ផ្តល់របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍១៦ ៨០២នាក់ ទៅតាម៣កម្រិត កម្រិត១ឧបត្ថម្ភ១២ខែ កម្រិត២ឧបត្ថម្ភ៦ខែ និងកម្រិត៣ឧបត្ថម្ភ៣ខែ ដោយមួយខែៗឧបត្ថម្ភ២០ ០០០រៀល ដោយក្នុងនោះ កម្រិត១ មាន១១ ១៦៦នាក់ និងកម្រិត២ មាន៥ ៦៣៦នាក់ និងបានលុបឈ្មោះជនពិការចេញពីរបបឧបត្ថម្ភជនពិការក្រីក្រនៅសហគមន៍៩២៩នាក់

- ដើម្បីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ក្រសួងបានកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អត្តសញ្ញាណជនពិការតាមបែបគំរូសង្គមនិងសិទ្ធិជាមូលដ្ឋាន។ បានផលិតវីដេអូណែនាំចំនួន១០ សម្រាប់ណែនាំមន្ត្រីដែលត្រូវចុះអនុវត្តកំណត់អត្តសញ្ញាណកម្មពិការភាពតាមឃុំសង្កាត់ និងបានរៀបចំដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាពិការភាព( DMIS: Disability Management Information System ) និងប្រកាសដាក់ឱ្យដំណើរការអេប( App ) កម្មវិធីចំនួន២ គឺកម្មវិធីអត្តសញ្ញាណកម្មពិការភាព( DIP Cambodia ) និងកម្មវិធីឱកាស ( OAKAS ) ការងារនិងមុខរបរប្រកបដោយបរិយាបន្ន សម្រាប់ជនមានពិការភាព ព្រមទាំង បានបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណកម្មពិការភាព ចំនួន៤ ៩០៦នាក់( ស្រី១ ៧៧៦នាក់ ) និងមេឃុំ ចៅសង្កាត់ ចំនួន១ ៤៩២នាក់

- ផលិតសៀវភៅមគ្គុទ្ទេសក៍គតិយុត្ត ស្តីពីកាតព្វកិច្ចរបស់និយោជកក្នុងការជ្រើសរើសនិយោជិតពិការចូលបម្រើការងារជាបីភាសា( ខ្មែរ អង់គ្លេស និងចិន ) ចំនួន១០ ០០០ក្បាល ដើម្បីចែកជូនដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ទូទាំងប្រទេស

- រហូតមកដល់ពេលនេះ ជនពិការចំនួន២២៥ ២០២នាក់ ត្រូវបានសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណ ជនពិការតាមបែបគំរូសង្គម និងសិទ្ធិជាមូលដ្ឋាននៅតាមឃុំ សង្កាត់ ដោយក្នុងនោះ ជនពិការចំនួន៦៣ ៥៣៨នាក់ ត្រូវបានក្រសួងអនុម័តទទួលស្គាល់

- ចេញប្រកាស ស្តីពីការដាក់ឱ្យប្រើប្រាស់នូវឯកសារណែនាំគោល នីតិវិធីចុះបញ្ជិកា ស្តីពីនីតិវិធីអធិការកិច្ចលើវិស័យពិការភាពនៃព្រះរាជាណាចក្រកម្ពុជា និងបានផ្សព្វផ្សាយទៅតាមរាជធានី ខេត្ត ព្រមទាំង បានចុះពិនិត្យ វាយតម្លៃរោងចក្រ សហគ្រាស និងចុះបញ្ជិកាជូនរោងចក្រ សហគ្រាសសរុបចំនួន១៥០។

**តារាងទី៣ លទ្ធផលសម្រេចបានអនុកម្មវិធី១.៣**

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | ជនពិការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | ១២៣ | ១១៧ | ១១៩ | ៥៣ | ៣៥ |
| ២ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ(២%) | នាក់ | ២ ៧៣៧ | ២ ៨៣៩ | ២ ៨៦០ | ៣ ០៩៥ | ៣ ៦២១ |
| ៣ | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន (១%) | នាក់ | ២ ៩៦២ | ៣ ០៥៥ | ៣ ៣១៥ | ៣ ៨៩១ | ៥ ២៣៥ |
| ៤ | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ | នាក់ | ៦ ៦៥៨ | ១៣ ៤៦៦ | ១៤ ១១៦ | ១៦ ៣៧៣ | ១៦ ៨០២ |

### ២.១.៤- ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់

- រៀបចំ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងបានរៀបចំផែនការសកម្មភាព ២០១៨-២០២០ សម្រាប់អនុវត្តគោលនយោបាយនេះផងដែរ

- ចេញប្រកាសស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំអនុញ្ញាតបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់ និងប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការបង្កើតមជ្ឈមណ្ឌល និងការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់

- រៀបចំទិវាមនុស្សចាស់កម្ពុជានិងមនុស្សចាស់អន្តរជាតិ១តុលា ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរបស់មនុស្សវ័យចាស់

- ដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរ ជំរុញលើកទឹកចិត្តឱ្យមនុស្សចាស់ចេះសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក ក្រសួងបានបង្កើតសមាគមមនុស្សចាស់១ ៦៤៦ មានសមាជិកសរុបចំនួន២៩៤ ៤៤០នាក់ នៅតាមរាជធានីខេត្តទាំង២៥

- ឧបត្ថម្ភសាច់ប្រាក់ជូនមនុស្សចាស់អាយុពី៦០ឆ្នាំឡើង តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនរងគ្រោះនិងរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ចំនួន៣៣៨ ០៧៦នាក់

- សាងសង់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់រាជធានីភ្នំពេញ និងដាក់ឱ្យដំណើរការឆាប់ៗនេះ។ ទន្ទឹមនេះ ក្រសួងបានចេញប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់រាជធានីភ្នំពេញ និងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីកិច្ចគាំពារសង្គមសម្រាប់មនុស្សវ័យចាស់ក្រីក្រគ្មានទីពឹង។

**តារាងទី៤ លទ្ធផលសម្រេចបានអនុកម្មវិធី១.៤**

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២ | ២០២១ |
| ១ | អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | % | | | ០០ | ០០ | ០០ |
| ២ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | | | ០០ | ០០ | ០០ |
| ៣ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានគោលរបបគាំពារសង្គម | នាក់ | | | - | - | ៣៣៨ ០៧៦ |

### ២.១.៥- ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

- បង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់១ ០២៣ មានសមាជិកសរុប ២៤ ៤០៤នាក់ ដែលបានជួយកែលម្អជីវភាពរស់នៅរបស់អតីតយុទ្ធជននិងគ្រួសារឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់

- បណ្តុះបណ្តាលគ្រូបង្គោលស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ ចំនួន៤០០នាក់ នៅខេត្តកែប ស្វាយរៀង ត្បូងឃ្មុំ និងខេត្តកំពត

- រាជរដ្ឋាភិបាលកម្ពុជាបានឧបត្ថម្ភថវិកាចំនួន៤៣ាន់លានរៀល/ឆ្នាំ ជូនដល់សមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីប្រគល់ជូនដល់សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាដែលបានទទួលមរណភាព ចាប់តាំងពីឆ្នាំ២០១៦

- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជារៀបចំប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា២១មិថុនា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ សមាគមអតីតយុទ្ធជនកម្ពុជាបានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះ និងបានចេញសេចក្តីសម្រេចប្រគល់ប្រាក់បេឡាមរណសង្គ្រោះជូនដល់គ្រួសារសព

៧ ៩៨៥សព។ បើគិតពីឆ្នាំ២០០៨ រហូតដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ សមាគមអតីតយុទ្ធជនកម្ពុជាបានចេញសេចក្តីសម្រេចប្រគល់ប្រាក់បេឡាមរណសង្គ្រោះជូនដល់គ្រួសារសព សរុបចំនួន១៧ ៨៨៩សព។ បច្ចុប្បន្ន ស.អ.ក. មានសមាជិកសរុបចំនួន៨០ ៦៩១នាក់

- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា រៀបចំកម្មវិធីបើកមហាសន្និបាតសហព័ន្ធអតីតយុទ្ធជនអាស៊ាន(VECONAC) លើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និងកម្មវិធីបិទមហាសន្និបាតដោយឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** ទេសរដ្ឋមន្ត្រី អនុប្រធានអគ្គលេខាធិការ ស.អ.ក. និងជាប្រធានសហព័ន្ធអតីតយុទ្ធជនអាស៊ានឆ្នាំ២០១៩ និងបានប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា២១មិថុនា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ២.២- ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

### ២.២.១- ការអភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព

- ដើម្បីទ្រទ្រង់ដំណើរការបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលបានបង់ភាគទាន២៤%នៃប្រាក់បៀវត្សរ៍សរុប ដោយក្នុងនោះ បានបង់ភាគទាន៦% ជំនួសមន្ត្រីរាជការស៊ីវិលដែលមានកាតព្វកិច្ចត្រូវបង់។ ទន្ទឹមនឹងការទ្រទ្រង់ទាំងស្រុងដោយថវិកាជាតិលើរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ធ្វើការកែសម្រួលដំឡើងរបបសន្តិសុខសង្គមនេះជាបន្តបន្ទាប់ ដើម្បីឱ្យស្រប តាមការរីកចម្រើននៃសេដ្ឋកិច្ច និងលទ្ធភាពនៃថវិកាជាតិ

- រៀបចំបែបបទផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការដែលត្រូវចូលនិវត្តន៍១៣ ៨៤១នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន១២ ៣០៩នាក់ និងបានផ្ទេរការគ្រប់គ្រងទៅតាមរាជធានី ខេត្ត

- លុបសពនិវត្តជននិងសពជនបាត់បង់សម្បទាវិជ្ជាជីវៈសរុបចំនួន៦ ៦៤៧នាក់ និងបន្តឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកចំនួន៣ ៨២០នាក់

- កែសម្រួលកម្មប្រាក់សោធនជូននិវត្តជន៥០៧នាក់ និងលុបឈ្មោះនិវត្តជន៤៨នាក់ ដែលនៅបន្តបំពេញការងារនៅអង្គភាពដើម ឬប្តូរការទទួលរបបទៅស្ថិតក្រោមស្ថាប័ននីតិប្បញ្ញត្តិ

- ផ្តល់គោលការណ៍រៀបចំបែបបទបើកប្រាក់របបសន្តិសុខសង្គមសម្រាប់សពមន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាព១៥១នាក់ និងទទួលគ្រប់គ្រងកូនសពមន្ត្រីរាជការស៊ីវិល៩២នាក់

- លុបអ្នកនៅក្នុងបន្ទុក៤ ១១១នាក់ និងបើកប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្តជនសពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងកូនក្នុងបន្ទុកមន្ត្រីរាជការស៊ីវិល៤១ ៥០៨នាក់

- បើកប្រាក់របបសន្តិសុខសង្គមចុងក្រោយរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលមរណភាព ៦ ៤៦៤នាក់ និងបើកប្រាក់រំឭកប្រចាំខែជូននិវត្តជន១២ ៩៨៨នាក់

- ផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជំងឺស្នើសុំផ្ទេរសិទ្ធិ៤៤៩នាក់ និងមោឃភាពលិខិតផ្ទេរសិទ្ធិ១២៧លិខិត

- ដំឡើងបន្ថែមប្រាក់សោធនប្រចាំខែតាមកម្រិតជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជារៀងរាល់ឆ្នាំ មកដល់ឆ្នាំ២០២១នេះ ប្រាក់របបសន្តិសុខសង្គមប្រចាំខែទាបបំផុតចំនួន៦៤ម៉ឺនរៀល/ខែ។ គិតជាមធ្យមក្នុងរយៈពេល៥ឆ្នាំនេះ មាននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន៥៦ ៣៨៤នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន៤៤ ៧៨៤នាក់ កំពុងទទួលរបបសន្តិសុខសង្គម

- នៅដើមឆ្នាំ២០១៨ ប.ជ.ស. បានសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស.) ដើម្បីផ្តល់តាវកាលិកថែទាំសុខភាពជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយត្រូវបានដាក់ឱ្យទទួលសេវាថែទាំសុខភាពនៅតាមបណ្តាមូលដ្ឋានសុខាភិបាលដែលមានចុះកិច្ចសន្យាជាមួយប.ស.ស. ចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលព័ត៌មានផ្ទាល់ខ្លួននៅក្នុងសាលាកបត្រព័ត៌មានខុសពីព័ត៌មានក្នុងអត្តសញ្ញាណបណ្ណ ប.ជ.ស. បានចេញវិញ្ញាបនបត្ររដ្ឋបាលបញ្ជាក់ជូនពួកគាត់សរុបចំនួន១ ០៦៩ ដើម្បីប្រើប្រាស់សេវាធានារ៉ាប់រងថែទាំសុខភាព។

តារាងទី៥ លទ្ធផលសម្រេចបានអនុកម្មវិធី២.១

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម | នាក់ | ៩៦ ០៦៩ | ១០០ ៣៨៦ | ១០២ ៤១១ | ១០៥ ៦៦៣ | ១០១ ៣១៣ |
| ២ | និវត្តជនដែលទទួលរបបសោធន | នាក់ | ៥១ ៣៤៥ | ៥៤ ០២៨ | ៥៥ ១៩៣ | ៥៥ ៩៧៥ | ៥៤ ៧៩៥ |
| | ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | ២ ៤៤០ | ២ ៣២៥ | ២ ១០៩ | ២ ០៣៤ | ១ ៦៧៧ |
| | អ្នកនៅក្នុងបន្ទុក | នាក់ | ៤២ ២៨៤ | ៤៤ ០៣៣ | ៤៥ ១០៩ | ៤៧ ៦៥៤ | ៤៤ ៨៤១ |

## ២.២.២- ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ

- ផ្តល់បណ្ណថែទាំសុខភាព៦៨ ៩២៣បណ្ណ ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ និងបណ្ណមូលនិធិសមធម៌៣៣ ០៧៩បណ្ណ ជូនគ្រួសារពលី និងមរណៈ

- បញ្ចូលបន្ទុកអតីតយុទ្ធជនសរុបចំនួន៦៩១នាក់ និងលុបបន្ទុកចំនួន៩ ៦៨៦នាក់

- ផ្តល់ប្រាក់បូជាសព ប្រាក់១លើកដំបូងនិងប្រាក់ធានារ៉ាប់រងសង្គមជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនសរុបចំនួន៦ ៩៧២នាក់

- លុបអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនសរុបចំនួន១៤ ៣៤៨នាក់ និងទទួលស្គាល់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនឡើងវិញ១៥៦នាក់

- កែសម្រួលប្រាក់សោធនជូន ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ រហូតមកដល់ឆ្នាំ២០២១ ប្រាក់សោធនអប្បបរមាត្រូវបានដំឡើងដល់៦៤០ ០០០រៀល/ខែ។ ក្នុងរយៈពេល៥ឆ្នាំនេះ អតីតយុទ្ធជន និងគ្រួសារប្រមាណ៩៣ ៤៨៤នាក់ និងអ្នកនៅក្នុងបន្ទុក១៣៨ ៦០៤នាក់ កំពុងទទួលរបបសន្តិសុខសង្គម តាមប្រព័ន្ធធនាគារ។

**តារាងទី៦ លទ្ធផលសម្រេចបានអនុកម្មវិធី២.២**

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៨៦ ៥១៧ | ៨៨ ៥២៦ | ៩១ ៣១៩ | ៩៨ ៥៧៩ | ១០២ ៦៦៨ |
| ២ | និវត្តជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៦ ៤៧៩ | ២៧ ១០១ | ២៨ ៣៣៨ | ៣៣ ៣៨៨ | ៣៦ ៦៥៧ |
| | ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១ ៥៨៣ | ១ ៥៦៤ | ១ ៥២៧ | ១ ៤៩៩ | ១ ៤៨៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ជនពិការដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៦ ៥០១ | ២៧ ២០៥ | ២៧ ៤៣៧ | ២៨ ៣២៧ | ២៨ ៥៨៤ |
| | ជនពលីដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៥ ៦៤៥ | ២៥ ៧៣២ | ២៦ ២៦៧ | ២៦ ៧៤៣ | ២៦ ៧៨៩ |
| | ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៦ ៣០៩ | ៦ ៩២៤ | ៧ ៧៥០ | ៨ ៦២២ | ៩ ១៥៥ |
| ៣ | អ្នកនៅក្នុងបន្ទុកអតីតយុទ្ធជន | នាក់ | ១៣២៤៦៧ | ១៣០ ៤៤១ | ១៣៥ ៣៨៨ | ១៤៦ ០២៤ | ១៤៨ ៦៩៩ |

**២.២.៣- ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

- មូលនិធិជនពិការបានសហការជាមួយអង្គការដៃគូ ផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិតថ្លៃជូនជនពិការ៣៧៨ ៨៦៨នាក់ ក្នុងនោះ សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ ២៦៧ ៣៧៣នាក់ និងស្តារលទ្ធភាពពលកម្មកាយសម្បទាបាន១១១ ៤៩៥នាក់។ ទន្ទឹមនេះ ជនពិការដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម បានទទួលការឧបត្ថម្ភជាប្រាក់អាហារនិងថ្លៃធ្វើដំណើរទៅមកផងដែរ។ ក្រៅពីការផ្តល់សេវានៅតាមមណ្ឌលស្តារលទ្ធភាពពលកម្ម មូលនិធិជនពិការក៏បានផ្តល់សេវាសហគមន៍ជូនជនពិការ ដូចជាការជួសជុលឧបករណ៍សិប្បនិម្មិតនិងរណប ការសម្របសម្រួលជូនជនពិការទៅទទួលសេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបញ្ជូនទៅសេវាសុខាភិបាលសរុបចំនួន៣៨ ៧៣៨នាក់
- ផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យនិងថែទាំសុខភាព ជូនដល់ជនពិការក្រីក្រនៅតាមសហគមន៍បាន២៩ ២១១នាក់ ដោយម្នាក់ៗទទួលបានថវិកា៣០ ០០០រៀល
- សាងសង់ផ្ទះជូនគ្រួសារជនពិការក្រីក្រចំនួន២៩ខ្នង និងបានផ្តល់កញ្ចប់អំណោយសប្បុរសធម៌របស់មូលនិធិជនពិការជូនជនពិការក្រីក្រសរុបចំនួន២ ៣៥២នាក់
- ទទួលប្រាក់ភាគទានដោយស្ម័គ្រចិត្តពីការមិនបានអនុវត្តតាមអត្រាកំណត់នៃការជ្រើសរើសជនពិការចូលបម្រើការងារពីក្រុមហ៊ុន និងរោងចក្រ សរុបចំនួន២១៣ ២៥២ ៧២៩រៀល និងទទួលបានប្រាក់ពីហិបប្រាក់វិភាគទានសប្បុរសធម៌មូលនិធិជនពិការសរុបចំនួន៨១០ ០៦៩ ៤០០រៀល។

តារាងទី៧ លទ្ធផលសម្រេចបានអនុកម្មវិធី២.៣

| **ល.រ.** | **សូចនាករ** | **ឯកតា** | **លទ្ធផលសម្រេចបានក្នុងឆ្នាំ** | | | | |
|---|---|---|---|---|---|---|---|
| | | | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** |
| ១ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | ២៦ ៣២៥ | ២៨ ០៤៥ | ២៦ ៣១០ | ១៨១៩៨ | ១២ ៦១៧ |
| ២ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | ៨ ០៥១ | ១១ ៨៨៦ | ៩ ៨៨៩ | ៥ ១៣៩ | ៣ ៧៧៣ |
| ៣ | ជនពិការក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភសេវាស្តារនិងពិនិត្យថែទាំសុខភាព | នាក់ | ៥ ១៣០ | ២ ៦៤៤ | ៥ ២៨៧ | ៦ ៨៩៨ | ៩ ២៥២ |
| ៤ | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | ៨២ ៥៩៦ | ៦០ ៤០០ | ៥៩ ០៦៣ | ៤៤ ៦១៣ | ២០ ៧០១ |

### ៣- ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍន៍ភាពជាដៃគូ

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចការងារបានដូចខាងក្រោម៖**

- ចុះអធិការកិច្ច និងសវនកម្ម ដើម្បីពិនិត្យ កែលម្អការបំពេញមុខងារ តួនាទី របៀបរបបការងារ ការដោះស្រាយជម្លោះ ការគ្រប់គ្រងចំណាយថវិការដ្ឋ និងទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត សំដៅលើកកម្ពស់គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ចជូនជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ

- បង្រួមប្រព័ន្ធនៃការផ្តល់សេវារដ្ឋបាល សេវាតម្រូវការ និងសេវាសំណូមពរតាមច្រកចេញចូលតែមួយ កាត់បន្ថយភាពយឺតយ៉ាវ គ្រប់គ្រង និងរក្សាបាននូវការសម្ងាត់ប្រកបដោយភាពគត់ម្មត់ ស្របតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។ បានលើកទឹកចិត្តមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ការដំឡើងថ្នាក់ ឋានន្តរសក្តិ និងការបើកផ្តល់បៀវត្សទាំងពីរលើកបានទាន់ពេលវេលា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

- ពង្រឹងការងារផែនការ និងផ្សព្វផ្សាយ តាមរយៈ ការរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១នៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ ផែនការសកម្មភាពបីឆ្នាំរំកិល ២០២២-២០២៤ ផែនការសកម្មភាពអនុវត្តគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងកម្រងសេវាសាធារណៈរបស់ក្រសួង ដែលមានសេវាជាអាទិភាពសរុបចំនួន២២សេវា

- អនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ«**ការគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ**» ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត «**ការធ្វើអធិការមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល**» ឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមុខងារ«**ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅសហគមន៍**» ឱ្យរដ្ឋបាលរាជធានី និងរដ្ឋបាលឃុំ សង្កាត់ ដោយក្នុងនោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានផ្ទេរមន្ត្រីចំនួន៥៦នាក់ និងផ្ទេរអចលនទ្រព្យរួមមានអគារ សម្ភារៈ អចលនទ្រព្យមួយចំនួនទៀត ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត លើកលែងតែការផ្ទេរការគ្រប់គ្រងដីរបស់មណ្ឌលថែទាំកុមារទាំង២១កន្លែង នៃរាជធានីខេត្តទាំង១៨ កំពុងស្ថិតក្នុងដំណើរការផ្ទេរជាជំហានៗ

- អនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការគ្រប់គ្រងការបើកផ្តល់បានត្រឹមត្រូវនិងទាន់ពេលវេលា។ ការគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការបែងចែកសម្ភារៈប្រកបដោយស័ក្តិសិទ្ធិភាព គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ

- ក្រសួងបានលើកទឹកចិត្ត និងសហប្រតិបត្តិការជាមួយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស និងដៃគូអភិវឌ្ឍន៍នានា ក្នុងស្មារតីសាមគ្គីធម៌ និងកៀរគរប្រភពធនធានទាំងសម្ភារៈ ថវិកា និងបច្ចេកទេស បម្រើឱ្យសំណូមពររបស់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាអាទិ៍បានចុះកិច្ចព្រមព្រៀងគម្រោងការជាមួយអង្គការ១៤៩អង្គការ ដែលមានថវិកាគម្រោងសរុបចំនួន៣២១ ៩៦៨ ៤៤៩,៥០ ដុល្លារអាម៉េរិក។ ទន្ទឹមនេះ ក៏បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងក្របខ័ណ្ឌទ្វេភាគី កម្ពុជា ថៃ ពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលសំចតនិងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលគម្រោងនេះនឹងចាប់ផ្តើមសាងសង់ក្នុងត្រីមាសទី១ នៃឆ្នាំ២០២២ កម្ពុជា វៀតណាម ពាក់ព័ន្ធនឹងការផ្តល់ថវិកាដោយភាគីវៀតណាម ដើម្បីសាងសង់អគារចំនួន៤ នៅក្នុងមជ្ឈមណ្ឌលជាតិព្យាបាល

និងស្ថានីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តនិងផ្អែកលើសហគមន៍កែវផុស ខេត្តព្រះសីហនុ។ ក្នុងក្របខ័ណ្ឌតំបន់អាស៊ាន ពាក់ព័ន្ធនឹងវិស័យសុខុមាលភាពសង្គមនិងការអភិវឌ្ឍ រួមមានសេចក្តីថ្លែងការរួម ស្តីពីការលើកកម្ពស់សិទ្ធិស្ត្រី សន្តិភាព និងសន្តិសុខនៅតំបន់អាស៊ាន ផែនការមេអាស៊ានឆ្នាំ២០២៥ ការបញ្ជ្រាបសិទ្ធិជនមានពិការភាព សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិកុមារក្នុងបរិបទនៃការធ្វើទេសន្តរប្រវេសន៍ សេចក្តីប្រកាសស្តីពីការការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវញ្ចតាមប្រព័ន្ធអ៊ីនធឺណិត និងការរំលោភបំពាននៅអាស៊ាន សេចក្តីថ្លែងការណ៍រួមស្តីពីការបញ្ជាក់ជាថ្មីនៃការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់សិទ្ធិកុមារក្នុងតំបន់អាស៊ាន សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍លើកទី១០ សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានបូកបីស្តីពីសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍លើកទី៦ សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍ ស្តីពីការកាត់បន្ថយផលប៉ះពាល់ដោយកូវីដ-១៩ លើក្រុមជនងាយរងគ្រោះក្នុងអាស៊ាន រៀបចំវេទិកាកុមារអាស៊ានលើកទី៦ ស្តីពីផលប៉ះពាល់នៃកូវីដ-១៩ និងស្ថានភាពបច្ចុប្បន្នចំពោះកុមារ ក្របខ័ណ្ឌថ្នាក់តំបន់និងផែនការសកម្មភាពដើម្បីអនុវត្តសេចក្តីប្រកាសអាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គម សេចក្តីប្រកាសហាណូយ ស្តីពីការពង្រឹងការងារសង្គមឆ្ពោះទៅរកសហគមន៍អាស៊ាន ដែលមានភាពស្អិតរមួត និងមានការឆ្លើយតបរបាយការណ៍លើកទី២ ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការមេអាស៊ានឆ្នាំ២០២៥ ការបញ្ជ្រាបសិទ្ធិជនមានពិការភាពឆ្នាំ២០១៩-២០២០ ផែនការសកម្មភាពថ្នាក់តំបន់ដើម្បីអនុវត្តសេចក្តីប្រកាសកូឡាឡាំពួរ ស្តីពីមនុស្សចាស់ ការផ្តល់សិទ្ធិអំណាចដល់មនុស្សចាស់ក្នុងតំបន់អាស៊ាន និងក្របខ័ណ្ឌប្រតិបត្តិនៃពានរង្វាន់ការងារឆ្នើមលើវិស័យសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍អាស៊ាន។

## ៤- ការអនុវត្តគោលនយោបាយជាតិប្រជាជន

ក្រសួងផែនការ សម្រេចការងារដូចខាងក្រោម៖

### ៤.១- ការងារផែនការជាតិនិងគោលនយោបាយ

- ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៩-២០២៣ ដំណើរការរៀបចំ ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានចាប់ផ្តើមចាប់តាំងពីខែមិថុនា ឆ្នាំ២០១៨។ ផ្អែកលើធាតុចូលដែលទទួលបានពីក្រសួងស្ថាប័ននានា និងដោយផ្អែកលើគោលនយោបាយនិងយុទ្ធសាស្ត្រថ្មីៗរបស់រាជរដ្ឋាភិបាលកម្ពុជា ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជានិងទិន្នន័យពីប្រភពផ្សេងៗ អគ្គនាយកដ្ឋានផែនការបានរៀបចំសេចក្តីព្រាងផ.យ.អ.ជ.២០១៩-២០២៣ និងកែសម្រួលជាបន្តបន្ទាប់ផ្អែកតាមស្មារតីកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេស កិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ និងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សេចក្តីព្រាងផ.យ.អ.ជ.២០១៩-២០២៣ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៩ រដ្ឋសភាជាតិនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ព្រឹទ្ធសភានៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ និងត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាលើប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការអនុម័តយល់ព្រម លើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩។ ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- បន្ទាប់ពីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផ.យ.អ.ជ.២០១៩-២០២៣ ត្រូវបានប្រកាសផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ ដោយបានចែកចេញជាបួនតំបន់ ដែលតំបន់នីមួយៗមានសមាសភាពចូលរួម ពីតំណាងមន្ទីរអង្គភាពជុំវិញខេត្ត សាលាខេត្ត សមាជិកក្រុមប្រឹក្សាខេត្ត សង្គមស៊ីវិល និងមន្ត្រីពី ក្រុង ស្រុក ខណ្ឌ

- សហការជាមួយអង្គការសហប្រជាជាតិ រៀបចំសិក្ខាសាលាជាតិ ដើម្បីធ្វើការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ ស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩។ ផ្អែកតាមស្មារតីនៃអង្គសិក្ខាសាលា អគ្គនាយកដ្ឋានផែនការ បានរៀបចំសេចក្តីព្រាងនៃរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ និងបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ និងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងផ្តល់អនុសាសន៍។ ឯកសារនេះ ត្រូវបានទទួលការឯកភាពពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ និងបានបង្ហាញនៅក្នុងវេទិកានយោបាយកម្រិតខ្ពស់ (High Level Political Forum) នៅបុរីញូវយ៉ក សហរដ្ឋអាម៉េរិក នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ប្រកបដោយជោគជ័យយ៉ាងត្រចះត្រចង់

- បានត្រៀមរៀបចំកែសម្រួលឡើងវិញ សូចនាករ និងចំណុចដៅ របស់គោលដៅនីមួយៗ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៦-២០៣០

- ការរៀបចំកែសម្រួលបញ្ជីសូនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ឆ្នាំ២០១៦-២០៣០ អគ្គនាយកដ្ឋានផែនការ បានរៀបចំកិច្ចប្រជុំអន្តរក្រសួងចំនួន០២លើក ដើម្បីពិនិត្យមើលឡើងវិញនិងកែសម្រួលបញ្ជីចំណុចដៅសូចនាករ និងតម្លៃចំណុចដៅសូចនាករតាមឆ្នាំនីមួយៗនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ និងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១។ បន្ទាប់ពីកិច្ចប្រជុំអន្តរក្រសួង អគ្គនាយកដ្ឋានផែនការ បានបន្តទទួលធាតុចូលពីក្រសួង ស្ថាប័នមួយចំនួន និងកំពុងបន្តសម្របសម្រួលប្រមូលធាតុចូលពីក្រសួង ស្ថាប័នផ្សេងទៀត ដើម្បីបន្តកែសម្រួលបញ្ជីសូចនាករ និងតម្លៃចំណុចដៅតាមសូចនាករ

- រៀបចំ សុន្ទរកថា និងជំនួយស្មារតីជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់ថ្លែងក្នុងកិច្ចប្រជុំកំពូលស្តីពី ផលប៉ះពាល់លើការអភិវឌ្ឍប្រកបដោយចីភាពឆ្នាំ២០២០ ក្រោមប្រធានបទ ការកសាងឆ្ពោះទៅមុខនៅក្នុងប្រទេស ដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន ដែលបានប្រព្រឹត្តទៅ នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០

- បន្ទាប់ពីការរៀបចំកិច្ចប្រជុំក្រុមតូចនៃក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រនៅកម្ពុជា ដើម្បីពិនិត្យ និងពិភាក្សាលើវិធីសាស្ត្រកំណត់ខ្សែបន្ទាត់ភាពក្រីក្រ និងគណនាកម្រិតនៃភាពក្រីក្រនៅកម្ពុជា សម្រាប់ឆ្នាំ២០១៩-២០២០ នាថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២១ អគ្គនាយកដ្ឋានផែនការ បានបន្តរៀបចំរបាយការណ៍ពីលទ្ធផលនៃកិច្ចប្រជុំ ដោយបញ្ចូលនូវឯកសារយោងនានា ផ្ញើជូនថ្នាក់ដឹកនាំក្រសួង និង**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បញ្ចប់ការរៀបចំរបាយការណ៍នៃការអនុវត្តសូចនាករតាមដានរួមគ្នា រវាងក្រសួងផែនការ ជាមួយដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២០ និងសូចនាករតាមដានរួមគ្នារវាងក្រសួងផែនការ (អគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ) ជាមួយដៃគូអភិវឌ្ឍន៍ ឆ្នាំ២០២១-២០២៣ និងផ្ញើទៅគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងបានរៀបចំចុះហត្ថលេខារបស់សហប្រធាន និងសហសម្របសម្រួលក្រុមការងារបច្ចេកទេស ផែនការនិងការកាត់បន្ថយភាពក្រីក្រ

- រៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីណែនាំការរៀបចំធាតុចូលសម្រាប់ការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ តាមប្រព័ន្ធវីដេអូ ក្រោមអធិបតីភាពដ៏

ខ្ពង់ខ្ពស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១។

### ៤.២- ការរៀបចំកម្មវិធីវិនិយោគសាធារណៈ

ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ អគ្គនាយកដ្ឋានផែនការ បានរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ចំនួន៣ដំណាក់កាលៈ

កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១៨-២០២០។

កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១៩-២០២១។

កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២០-២០២២។

កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២១-២០២៣។

កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២២-២០២៤។

### ៤.៣- ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

- ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅតាមរាជធានី ខេត្ត ត្រូវបានអនុវត្តទាំងនីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រនៅទីប្រជុំជន ទាំងនីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រនៅទីជនបទ ចាប់តាំងពីឆ្នាំ២០១៦មក។ ចាប់តាំងពីឆ្នាំ២០១៧ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃអគ្គនាយកដ្ឋានផែនការ បានដំណើរការធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រ តាមជុំចំនួន៥ជុំ។

**តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១០**

| លរ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | បាត់ដំបង | ២៧៤ ៥៤២ | ១៧ ៩៣៥ | ៦,៥៣% | ៣៩ ២៩៥ | ១៤,៣១% | ៥៧ ២៣០ | ២០,៨៥% |
| ២ | កំពង់ឆ្នាំង | ១៤៣ ៦០៧ | ១០ ០១៣ | ៦,៩៧% | ១៤ ៥៥៦ | ១០,១៤% | ២៤ ៥៦៩ | ១៧,១១% |
| ៣ | កណ្តាល | ៣០៦ ៣៨៦ | ៨ ២៣៩ | ២,៦៩% | ១៨ ៦៨១ | ៦,១០% | ២៦ ៩២០ | ៨,៧៩% |
| ៤ | ប៉ៃលិន | ១៩ ១៦២ | ១ ៣៩៣ | ៧,២៧% | ២ ១២៥ | ១១,០៩% | ៣ ៥១៨ | ១៨,៣៦% |
| ៥ | ព្រះវិហារ | ៥៨ ៧០៤ | ៣ ១៦៦ | ៥,៣៩% | ៦ ៤៧១ | ១១,០២% | ៩ ៦៣៧ | ១៦,៤២% |
| ៦ | ពោធិ៍សាត់ | ១២៨ ៧៥៧ | ៩ ៣៤៧ | ៧,២៦% | ១២ ៦០១ | ៩,៧៩% | ២១ ៩៤៨ | ១៧,០៥% |
| ៧ | រតនគិរី | ៤៧ ៨៣៨ | ១ ៩៧២ | ៤,១២% | ៥ ១១៦ | ១០,៦៩% | ៧ ០៨៨ | ១៤,៨២% |
| ៨ | តាកែវ | ២៣០ ៩២៥ | ១០ ៥៩៧ | ៤,៥៩% | ១៩ ០១៣ | ៨,២៣% | ២៩ ៦១០ | ១២,៨២% |
| សរុបជុំទី១០ | | ១ ២០៩ ៩១៩ | ៦២ ៦៦២ | ៥,១៨% | ១១៧ ៨៥៨ | ៩,៧៤% | ១៨០ ៥២០ | ១៤,៩២% |

**តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១១**

| លរ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | កំពង់ស្ពឺ | ១៨៤ ៤៨២ | ៨ ៧៥៥ | ៤,៧៥% | ១២ ៤០៥ | ៦,៧២% | ២១ ១៦០ | ១១,៤៧% |
| ២ | កំពត | ១៥៥ ១០៦ | ៧ ៩៤៣ | ៥,១២% | ១០ ០៧៩ | ៦,៥០% | ១៨ ០២២ | ១១,៦២% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | កោះកុង | ២៩ ៨២៥ | ២ ៤៣៥ | ៨,១៦% | ៣ ៣៥៣ | ១១,២៤% | ៥ ៧៨៨ | ១៩,៤១% |
| ៤ | មណ្ឌលគិរី | ១៧ ៤៤៥ | ៨៤០ | ៤,៨២% | ២ ០៨០ | ១១,៩២% | ២ ៩២០ | ១៦,៧៤% |
| ៥ | ព្រៃវែង | ២៨៩ ១៦១ | ១៨ ៥៩៤ | ៦,៤៣% | ២៨ ៤៩៥ | ៩,៨៥% | ៤៧ ០៨៩ | ១៦,២៨% |
| ៦ | ព្រះសីហនុ | ៣០ ៩៨៥ | ១ ០៤៧ | ៣,៣៨% | ២ ១៨២ | ៧,០៤% | ៣ ២២៩ | ១០,៤២% |
| ៧ | ស្វាយរៀង | ១៤៥ ៩៨៧ | ៥ ៨៦៦ | ៤,០២ | ១១ ៨៥៦ | ៨,១២% | ១៧ ៧២២ | ១២,១៤% |
| ៨ | កែប | ៤ ៥០៥ | ៣១២ | ៦,៩៣% | ៥៧៦ | ១២,៧៩% | ៨៨៨ | ១៩,៧១% |
| **សរុបជុំទី១១** | | **៨៥៧ ៤៩៦** | **៤៥ ៧៩២** | **៥,៤៥%** | **៧១ ០២៦** | **៩,២៧%** | **១១៦ ៨១៨** | **១៤,៧២%** |

## តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១២

| លរ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | បន្ទាយមានជ័យ | ១៥៥ ៧៤៣ | ៦ ៧០២ | ៤,៣% | ១៣ ២២២ | ៨,៥% | ១៩ ៩២៤ | ១២,៨% |
| ២ | កំពង់ចាម | ២៥៣ ៦៨១ | ១៣ ៨៧៩ | ៥,៥% | ២១ ៩៩២ | ៨,៧% | ៣៥ ៨៧១ | ១៤,១% |
| ៣ | កំពង់ធំ | ១៦២ ២៣៦ | ១១ ១៥៥ | ៦,៩% | ១៩ ៤៧៦ | ១២% | ៣០ ៦៣១ | ១៨,៩% |
| ៤ | ក្រចេះ | ៧៨ ៦៦៩ | ៧ ៣៤៨ | ៩,៣% | ៩ ៩៣៤ | ១២,៦% | ១៧ ២៨២ | ២២% |
| ៥ | ភ្នំពេញ(៨ខណ្ឌ) | ១៨៤ ៦៩២ | ៥ ៤២៣ | ២,៩% | ១០ ៧០១ | ៥,៨% | ១៦ ១២៤ | ៨,៧% |
| ៦ | សៀមរាប | ១៨៦ ៤៥៥ | ៩ ៣៤២ | ៥% | ១៧ ០៩៤ | ៩,២% | ២៦ ៤៣៦ | ១៤,២% |
| ៧ | ស្ទឹងត្រែង | ២៧ ៧៩១ | ១ ៩៣៣ | ៧% | ៣ ៩០១ | ១៤% | ៥ ៨៣៤ | ២១% |
| ៨ | ឧត្តរមានជ័យ | ៥៨ ២៤២ | ៣ ០៧៥ | ៥,៣% | ៥ ០១២ | ៨,៦% | ៨ ០៨៧ | ១៣,៩% |
| ៩ | ត្បូងឃ្មុំ | ១៧៩ ០៥៤ | ១០ ១៤៦ | ៥,៧% | ១៩ ៥៦៦ | ១០.៩% | ២៩ ៧១២ | ១៦,៦% |
| **សរុបជុំទី១២** | | **១២៨៦ ៥៦៣** | **៦៩ ០០៣** | **៥,៨%** | **១២០ ៨៩៨** | **១០%** | **១៨៩ ៩០១** | **១៥,៨%** |

## តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១៣

| លរ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | បាត់ដំបង | ២៧៤ ៥៤២ | ១៧ ៩៣៥ | ៦,៥៣% | ៣៩ ២៩៥ | ១៤,៣១% | ៥៧ ២៣០ | ២០,៨៥% |
| ២ | កំពង់ឆ្នាំង | ១៤៣ ៦០៧ | ១០ ០១៣ | ៦,៩៧% | ១៤ ៥៥៦ | ១០,១៤% | ២៤ ៥៦៩ | ១៧,១១% |
| ៣ | កណ្ដាល | ៣០៦ ៣៨៦ | ៨ ២៣៩ | ២,៦៩% | ១៨ ៦៨១ | ៦,១០% | ២៦ ៩២០ | ៨,៧៩% |
| ៤ | ប៉ៃលិន | ១៩ ១៦២ | ១ ៣៩៣ | ៧,២៧% | ២ ១២៥ | ១១,០៩% | ៣ ៥១៨ | ១៨,៣៦% |
| ៥ | ព្រះវិហារ | ៥៨ ៧០៤ | ៣ ១៦៦ | ៥,៣៩% | ៦ ៤៧១ | ១១,០២% | ៩ ៦៣៧ | ១៦,៤២% |
| ៦ | ពោធិ៍សាត់ | ១២៨ ៧៥៧ | ៩ ៣៤៧ | ៧,២៦% | ១២ ៦០១ | ៩,៧៩% | ២១ ៩៤៨ | ១៧,០៥% |
| ៧ | រតនគិរី | ៤៧ ៨៣៦ | ១ ៩៧២ | ៤,១២% | ៥ ១១៦ | ១០,៦៩% | ៧ ០៨៨ | ១៤,៨២% |
| ៨ | តាកែវ | ២៣០ ៩២៥ | ១០ ៥៩៧ | ៤,៥៩% | ១៩ ០១៣ | ៨,២៣% | ២៩ ៦១០ | ១២,៨២% |
| **សរុបជុំទី១៣** | | **១ ២០៩ ៩១៩** | **៦២ ៦៦២** | **៥,១៨%** | **១១៧ ៨៥៨** | **៩,៧៤%** | **១៨០ ៥២០** | **១៤,៩២%** |

## តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១៤

| ល.រ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | កំពង់ស្ពឺ | ១៨៤ ៤៨២ | ៨ ៧៥៥ | ៤,៧៥% | ១២ ៤០៥ | ៦,៧២% | ២១ ១៦០ | ១១,៤៧% |
| ២ | កំពត | ១៥៥ ១០៦ | ៧ ៩៤៣ | ៥,១២% | ១០ ០៧៩ | ៦,៥០% | ១៨ ០២២ | ១១,៦២% |
| ៣ | កោះកុង | ២៩ ៨២៥ | ២ ៤៣៥ | ៨,១៦% | ៣ ៣៥៣ | ១១,២៤% | ៥ ៧៨៨ | ១៩,៤១% |
| ៤ | មណ្ឌលគិរី | ១៧ ៤៤៥ | ៨៤០ | ៤,៨២% | ២ ០៨០ | ១១,៩២% | ២ ៩២០ | ១៦,៧៤% |
| ៥ | ព្រៃវែង | ២៨៩ ១៦១ | ១៨ ៥៩៤ | ៦,៤៣% | ២៨ ៤៩៥ | ៩,៨៥% | ៤៧ ០៨៩ | ១៦,២៨% |
| ៦ | ព្រះសីហនុ | ៣០ ៩៨៥ | ១ ០៤៧ | ៣,៣៨% | ២ ១៨២ | ៧,០៤% | ៣ ២២៩ | ១០,៤២% |
| ៧ | ស្វាយរៀង | ១៤៥ ៩៨៧ | ៥ ៨៦៦ | ៤,០២% | ១១ ៨៥៦ | ៨,១២% | ១៧ ៧២២ | ១២,១៤% |
| ៨ | កែប | ៤ ៥០៥ | ៣១២ | ៦,៩៣% | ៥៧៦ | ១២,៧៩% | ៨៨៨ | ១៩,៧១% |
| សរុបជុំទី១៤ | | ៨៥៧ ៤៩៦ | ៤៥ ៧៩២ | ៥,៤៥% | ៧១ ០២៦ | ៩,២៧% | ១១៦ ៨១៨ | ១៤,៧២% |

- ដើម្បីគាំទ្រដល់កិច្ចអន្តរាគមន៍ជាបន្ទាន់ដល់ប្រជាពលរដ្ឋទាំងអស់ ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ជាពិសេសគ្រួសារក្រីក្រនិងគ្រួសារទទួលរងផលប៉ះពាល់ខ្លាំងជាងគេតាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ អគ្គនាយកដ្ឋានផែនការ បានដំណើរការការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ និងបានផ្តល់ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមជុំ(ជុំទី១២ ទី១៣ និងទី១៤) និងទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំក្នុងកំឡុងពេលកូវីដ-១៩ ចំនួន១៣លើក ដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ដែលមានគ្រួសារក្រីក្រសរុប ចំនួន៦៦៥ ២៩២គ្រួសារ និងទិន្នន័យនៃការដកគ្រួសារក្រីក្រចេញពីបញ្ជីគ្រួសារក្រីក្រ ចំនួន២៧ ៣៧១គ្រួសារ ជូនដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីប្រើប្រាស់ក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ។

## តារាងទិន្នន័យគ្រួសារក្រីក្រតាមជុំ និងតាមការស្នើសុំ ក្នុងកំឡុងពេលកូវីដ-១៩

| ល.រ. | បរិយាយ | ក្រកម្រិត ១ | | ក្រកម្រិត ២ | | សរុប | |
|---|---|---|---|---|---|---|---|
| | | គ្រួសារ | សមាជិក | គ្រួសារ | សមាជិក | គ្រួសារ | សមាជិក |
| ១ | តាមជុំ ជុំទី១២,១៣,១៤ | ១៥៦ ៩៣៨ | ៥៩៣ ២៨១ | ២៩៦ ៥៩៣ | ១២៣០៣៩៤ | ៤៥៣ ៥៣១ | ១៧២៣៦៤៤ |
| ២ | តាមការស្នើសុំលើកទី១ | ២២ ៩៣៤ | ៨២ ៤១១ | ៣០ ២៥២ | ១១៩ ៥១៣ | ៥៣ ១៨៦ | ២០១ ៩២៤ |
| ៣ | តាមការស្នើសុំលើកទី២ | ២១ ៨២៨ | ៨០ ៨៧៣ | ២៩ ០៥០ | ១១៦ ៨៤៣ | ៥០ ៨៧៨ | ១៩៧ ៧១៦ |
| ៤ | តាមការស្នើសុំលើកទី៣ | ២២ ៣២០ | ៧៦ ៩២០ | ៣៣ ៦៩៦ | ១៣១ ១៣៤ | ៥៦ ០១៦ | ២០៨ ០៥៤ |
| ៥ | តាមការស្នើសុំលើកទី៤ | ៨ ៦៥៧ | ៣០ ៤១៥ | ១១ ៧៣៦ | ៤៥ ៦៨១ | ២០ ៣៩៣ | ៧៦ ០៩៦ |
| ៦ | តាមការស្នើសុំលើកទី៥ | ៣ ២២៥ | ១១ ៣៨៣ | ៤ ៣៧៩ | ១៧ ១២១ | ៧ ៦០៤ | ២៨ ៥០៤ |
| ៧ | តាមការស្នើសុំលើកទី៦ | ២ ៥៨១ | ៩ ៥៧០ | ៣ ៩៧៧ | ១៦ ១៨៤ | ៦ ៥៥៨ | ២៥ ៧៥៤ |
| ៨ | តាមការស្នើសុំលើកទី៧ | ១ ៥២០ | ៥ ៤៣១ | ២ ៥០៩ | ១០ ១១៣ | ៤ ០២៩ | ១៥ ៥៤៤ |
| ៩ | តាមការស្នើសុំលើកទី៨ | ១ ១១៨ | ៣ ៩១៥ | ១ ៦៣៨ | ៦ ៥១២ | ២ ៧៥៦ | ១០ ៤២៧ |
| ១០ | តាមការស្នើសុំលើកទី៩ | ១ ២៨៥ | ៤ ៦២៦ | ២ ២៨៦ | ៩ ០២១ | ៣ ៥៧១ | ១៣ ៦៤៧ |
| ១១ | តាមការស្នើសុំលើកទី១០ | ៦៣៩ | ២ ២១៥ | ១ ០៤៥ | ៣ ៩៥៣ | ១ ៦៨៤ | ៦ ១៩៩ |
| ១២ | តាមការស្នើសុំលើកទី១១ | ៧៩៨ | ២ ៨៩៦ | ៨៣៨ | ៣ ២៤១ | ១ ៦៣៦ | ៦ ១៣៧ |
| ១៣ | តាមការស្នើសុំលើកទី១២ | ៣៦៦ | ១ ៣៥៦ | ៥៥៩ | ២ ២៣៩ | ៩២៥ | ៣ ៥៩៥ |
| ១៤ | តាមការស្នើសុំលើកទី១៣ | ១ ០៣៤ | ៣ ៣៧៩ | ១ ៤៩១ | ៥ ៣១៣ | ២ ៥២៥ | ៨ ៦៩២ |
| សរុបរួម | | ២៤៥ ២៤៣ | ៩០៨ ៦៧១ | ៤២០ ០៤៩ | ១៧១៧២៦២ | ៦៦៥ ២៩២ | ២៦២៥៩៣៣ |

### ៤.៤- ការងារផែនការថ្នាក់ក្រោមជាតិ

- ក្នុងគោលបំណងពិនិត្យវឌ្ឍនភាពការងារ បញ្ហាប្រឈមនិងដំណោះស្រាយ និងទទួលបាននូវសំណូមពរ និងអនុសាសន៍នានា លើការងារផែនការថ្នាក់ក្រោមជាតិ មន្ត្រីនាយកដ្ឋានផែនការថ្នាក់ក្រោមជាតិនៃអគ្គនាយកដ្ឋានផែនការ បានចុះតាមដានត្រួតពិនិត្យនិងសិក្សាស្វែងយល់អំពីដំណើរការការងារផែនការនៅថ្នាក់ក្រោមជាតិ

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការពិនិត្យឡើងវិញដំណើរការគ្រប់គ្រងប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) គ្រប់គ្រងគម្រោង (SPD) ការរៀបចំ និងកសាងប្រព័ន្ធផែនការ។

### ៤.៥- ការងារលើកកម្ពស់អាហារូបត្ថម្ភ

- ដើម្បីធានាបានគុណភាពអំបិលអ៊ីយ៉ូដ និងទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក ដែលកំពុងលក់តាមទីផ្សារ និងកំពុងចរាចរ ព្រមទាំងផ្តល់ការណែនាំបច្ចេកទេសដល់ផលិតករ អាជីវករ អគ្គនាយកដ្ឋានផែនការ បានចុះតាមទីផ្សារនិងទីតាំងផលិតកម្ម នៅខេត្តចំនួន១០ ជាពិសេសខេត្តជាប់ព្រំប្រទល់ ប្រទេសវៀតណាម និងខេត្តដែលមានទីតាំងផលិតកម្ម

- យុទ្ធសាស្ត្រចំនួន៣ ក្នុងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ តាមរយៈការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនិងការប្រើប្រាស់គឺ ទី១- ការអប់រំផ្សព្វផ្សាយនិងការប្រើប្រាស់ ទី២- ការជំរុញការផលិត និងការតាមដានត្រួតពិនិត្យ

- បន្តសហការនិងសម្របសម្រួលជាមួយអង្គការHKI/UBC ដើម្បីដំណើរការសាកល្បង និងប្រមូលព័ត៌មានពីការប្រើប្រាស់អំបិលអ៊ីយ៉ូដនិងចំនួនអំបិលដែលត្រូវប្រើប្រាស់ក្នុងមួយថ្ងៃរបស់ស្ត្រីក្នុងមណ្ឌលសុខភាពចំនួន៥ ក្នុងខេត្តកំពង់ធំ ដើម្បីឈានទៅបញ្ចូលវីតាមីនបេ១(B1) ក្នុងអំបិល

- កែសម្រួលនិងបោះពុម្ពសៀវភៅអប់រំសុខភាព ដើម្បីបែងចែកដល់អ្នកចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយ និងគ្រួសារប្រជាពលរដ្ឋ។

**ការងារអាហារូបត្ថម្ភ ២០១៧ -២០២១**

| សមិទ្ធផលសម្រេចបាន | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| បរិមាណផលិផលអំបិលអ៊ីយ៉ូដ (តោន) | ៦៦ ៣០០ | ៥២ ៨២២ | ៣៦ ០០០ | ៣៥ ០៦០ | ១៦ ៨៧៥ |
| បរិមាណផលិផលទឹកត្រី ទឹកស៊ីអ៊ីវជាតិដែក(ពាន់លីត្រ) | ១ ៣០០ | ១ ៥០៥ | ២ ០០៥ | ១ ៤៥៩ | ៧៣៧ |
| ការផ្តល់អង្គបញ្ចូលមីក្រូសារជាតិដល់សិស្សសាលាបឋមសិក្សាចំនួន៨៥២សាលា(ពាន់នាក់) | | | ២២០ | | |
| សៀវភៅអប់រំសុខភាពស្តីពីសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ(ក្បាល) | ២ ០០០ | ១ ៥០០ | ១ ៥០០ | ៨០០ | |
| សៀវភៅអប់រំសុខភាពស្តីពីសារៈសំខាន់នៃការប្រើប្រាស់ចំណីអាហារសម្បូរជាតិដែក (ក្បាល) | ២ ០០០ | ១ ៥០០ | ១ ៥០០ | ៨០០ | |
| សៀវភៅអប់រំសុខភាពស្តីពីសារៈសំខាន់នៃការប្រើប្រាស់ចំណីអាហារសម្បូរជីវជាតិអា (ក្បាល) | ២ ០០០ | | | | |

| សមិទ្ធផលសម្រេចបាន | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| សៀវភៅអនុក្រឹត្យលេខ៦៩ អនក្រ បក.ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ(ក្បាល) | | | ២ ០០០ | | |
| ផ្ទាំងរូបភាពស្តីពីសារៈសំខាន់នៃការប្រើប្រាស់ទឹកត្រីទឹកស៊ីអ៊ីវមានជាតិដែក(ផ្ទាំង) | | | ៧០០ | ៥០០ | ៥០០ |
| ផ្ទាំងរូបភាពស្តីពីសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ | | | ៧០០ | | |
| កូនសៀវភៅបត់ស្តីពីសារៈសំខាន់នៃការប្រើប្រាស់ទឹកត្រីទឹកស៊ីអ៊ីវមានជាតិដែក (ក្បាល) | | | ១ ៥០០ | | |
| ផ្ទាំងរូបភាពស្តីពី ការប្រើប្រាស់អំបិលអ៊ីយ៉ូដដើម្បីការពារជំងឺពកក (ផ្ទាំង) | | | | | ៥០០ |
| ផ្ទាំងរូបភាពស្តីពី ចូរហូបអំបិលអ៊ីយ៉ូដឱ្យបានរៀងរាល់ថ្ងៃដើម្បីបង្កើនប្រាជ្ញា និងការពារជំងឺពកក ក្រេសក្រិន និងឡឺកឺ(ផ្ទាំង) | | | | | ៥០០ |

## ៤.៦- ទិន្នន័យគ្រួសារក្រីក្រតាមការស្នើសុំក្នុងកំឡុងពេលជំងឺកូវីដ-១៩

### តារាងទិន្នន័យគ្រួសារក្រីក្រតាមការស្នើសុំក្នុងកំឡុងពេលជំងឺកូវីដ-១៩

| ល.រ. | ឈ្មោះរាជធានី/ខេត្ត | ចំនួនកំណើននៃការស្នើសុំ | ចំនួនគ្រួសារសម្ភាសន៍ | ចំនួនគ្រួសារក្រីក្រ | | | ភាគរយនៃការសម្ភាសន៍ | ភាគរយគ្រួសារក្រីក្រ |
|---|---|---|---|---|---|---|---|---|
| | | | | ក្រកម្រិត១ | ក្រកម្រិត២ | សរុប | | |
| ១ | បន្ទាយមានជ័យ | ២ ៥៤៩ | ២ ៣៦១ | ៩០១ | ១ ២១៤ | ២ ១១៥ | ៩២,៦២ | ៨២,៩៧ |
| ២ | បាត់ដំបង | ៦ ៤៥៨ | ៦ ៣១៩ | ១ ៨១៧ | ៤ ២៩៦ | ៦ ១១៣ | ៩៧,៨៥ | ៩៤,៦៦ |
| ៣ | កំពង់ចាម | ៤ ៣៨៧ | ៤ ១៧០ | ១ ៥៩០ | ២ ២១៣ | ៣ ៨០៣ | ៩៥,០៥ | ៨៦,៦៩ |
| ៤ | កំពង់ឆ្នាំង | ១ ៥៧៤ | ១ ០១៩ | ៤២៧ | ៥១០ | ៩៣៧ | ៦៤,៧៤ | ៥៩,៥៣ |
| ៥ | កំពង់ស្ពឺ | ៣ ៦៣១ | ៣ ៥០៥ | ១ ៧៣៦ | ១ ៥៨០ | ៣ ៣១៦ | ៩៦,៥៣ | ៩១,៣២ |
| ៦ | កំពង់ធំ | ៣ ៩៦៩ | ៣ ៩០៣ | ១ ៧៩០ | ១ ៨៩៥ | ៣ ៦៨៥ | ៩៨,៣៤ | ៩២,៨៤ |
| ៧ | កំពត | ៣ ០៨៩ | ២ ៩២០ | ១ ៤៩១ | ១ ២៩៥ | ២ ៧៨៦ | ៩៤,៥៣ | ៩០,១៩ |
| ៨ | កណ្តាល | ៥ ៣៦០ | ៥ ១០៦ | ១ ៨៣០ | ២ ៨៣៦ | ៤ ៦៦៦ | ៩៥,២៦ | ៨៧,០៥ |
| ៩ | កោះកុង | ១ ៦៨០ | ១ ៦៥២ | ៨៧៤ | ៧៤៩ | ១ ៦២៣ | ៩៨,៣៣ | ៩៦,៦១ |
| ១០ | ក្រចេះ | ៣ ៧៤៥ | ៣ ៦៥៦ | ១ ៧១៦ | ១ ៨០៨ | ៣ ៥២៤ | ៩៧,៦២ | ៩៤,១០ |
| ១១ | មណ្ឌលគិរី | ៨៨៥ | ៨៧៣ | ២៤២ | ៥៨៧ | ៨២៩ | ៩៨,៦៤ | ៩៣,៦៧ |
| ១២ | រាជធានីភ្នំពេញ | ៥ ៥៧១ | ៥ ៣៧៩ | ២ ០០១ | ២ ៩៥៤ | ៤ ៩៥៥ | ៩៦,៥៥ | ៨៨,៩៤ |
| ១៤ | ព្រះវិហារ | ១ ៥៥៥ | ១ ៣៣៨ | ៤៩៨ | ៦៩៩ | ១ ១៩៧ | ៨៦,០៥ | ៧៦,៩៨ |
| ១៤ | ព្រៃវែង | ៦ ០៧៥ | ៥ ៨០៨ | ៣ ០០៩ | ២ ៤៥៣ | ៥ ៤៦២ | ៩៥,៦០ | ៨៩,៩១ |
| ១៥ | ពោធិ៍សាត់ | ១ ៥០១ | ១ ៤៥៥ | ៦៥៧ | ៦៩៤ | ១ ៣៥១ | ៩៦,៩៤ | ៩០,០១ |
| ១៦ | រតនគិរី | ១ ៤៦៩ | ១ ៥១៨ | ៣៤២ | ៩៣៨ | ១ ២៨០ | ៩៦,៥៣ | ៨៧,១៣ |
| ១៧ | សៀមរាប | ៨២៥ | ៧៩៧ | ៣០៣ | ៤៥០ | ៧៥៣ | ៩៦,៦១ | ៩១,២៧ |

| ល.រ. | ឈ្មោះរាជធានី/ខេត្ត | ចំនួនកំណើន នៃការស្នើសុំ | ចំនួនគ្រួសារ សម្ភាសន៍ | ចំនួនគ្រួសារក្រីក្រ | | | ភាគរយនៃការ សម្ភាសន៍ | ភាគរយ គ្រួសារក្រីក្រ |
|---|---|---|---|---|---|---|---|---|
| | | | | ក្រកម្រិត១ | ក្រកម្រិត២ | សរុប | | |
| ១៨ | ព្រះសីហនុ | ១ ៤៩២ | ១ ៤០៥ | ៦៦៥ | ៦៧១ | ១ ៣៣៦ | ៩៤,១៧ | ៨៩,៥៤ |
| ១៩ | ស្ទឹងត្រែង | ៨២៥ | ៧៩៧ | ៣០៣ | ៤៥០ | ៧៥៣ | ៩៦,៦១ | ៩១,២៧ |
| ២០ | ស្វាយរៀង | ២ ៩៨៣ | ២ ៨១១ | ១ ២៤៣ | ១ ៣២៨ | ២ ៥៧១ | ៩៤,២៣ | ៨៦,១៩ |
| ២១ | តាកែវ | ៣ ៤៤៩ | ៣ ៣៩២ | ១ ៤៤៩ | ១ ៧៤៧ | ៣ ១៩៦ | ៩៨,៣៥ | ៩២,៣៦ |
| ២២ | ឧត្ដរមានជ័យ | ១ ៩៦០ | ១ ៨១៦ | ៤៨២ | ១ ០៤២ | ១ ៥២៤ | ៩២,៦៥ | ៧៧,៧៦ |
| ២៣ | កែប | ១៨៣ | ១៨០ | ៥៥ | ១០៦ | ១៦១ | ៩៨,៣៦ | ៨៧,៩៨ |
| ២៤ | ប៉ៃលិន | ៥០៣ | ៤៣០ | ១៧៦ | ២២៦ | ៤០២ | ៨៥,៤៩ | ៧៩,៩២ |
| ២៥ | ត្បូងឃ្មុំ | ៤ ៧២៦ | ៤ ៦៧៨ | ១ ៦៩៦ | ២ ៧៦១ | ៤ ៤៥៧ | ៩៨,៩៨ | ៩៤,៣១ |
| **សរុប** | | **៧៦ ៧៧៤** | **៧៣ ០៨៩** | **២៩ ៣១៣** | **៣៨ ៨៣៥** | **៦៨ ១៤៨** | **៩៥,២០** | **៨៨,៧៨** |

## ៤.៧- សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

### ក- ចំនួនប្រជាជនពីឆ្នាំ១៩៩៨ ដល់២០៤០




### ខ- ពីរ៉ាមីតប្រជាជនសម្រាប់កម្ពុជា

**ឆ្នាំ១៩៩៦**




*ប្រភព: - វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ១៩៩៦*

**ឆ្នាំ១៩៩៨**




*ប្រភព: - វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០០៩*




*ប្រភព: - វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០០៥*




*ប្រភព: - វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០០៩*




*ប្រភព: - វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ ២០១៣*




*ប្រភព: - CDHS 2014*




*ប្រភព: - វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០២០*

## គ- អត្រាលទ្ធភាពបង្កើតកូនសរុប




## ឃ- អាយុសង្ឃឹមរស់គិតជាមធ្យម




## ង- ផលិតផលក្នុងស្រុកសរុប (គិតតាមថ្លៃបច្ចុប្បន្ន)






## ច- ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់







## ឆ- អត្រាកំណើនតាមសកម្មភាពសេដ្ឋកិច្ច

### គិតតាមថ្លៃថេរឆ្នាំ២០០០( ភាគរយ )

| ឆ្នាំ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ឧស្សាហកម្ម | សេវាកម្ម | ផលិតផលក្នុងស្រុកសរុប |
|---|---|---|---|---|
| ១៩៩៨ | ៤,៤ | ៦,២ | ៥ | ៤,៧ |
| ១៩៩៩ | ៣,៧ | ២១,២ | ១៤,៦ | ១២,៧ |
| ២០០០ | ៤,៤ | ២១,២ | ៨,៩ | ១០,៧ |
| ២០០១ | ១,៧ | ១១,២ | ១១,៩ | ៧,៤ |
| ២០០២ | -២,៥ | ១៧,១ | ៧,៧ | ៦,៦ |
| ២០០៣ | ១០,៥ | ១២ | ៥,៩ | ៨,៥ |
| ២០០៤ | -០,៩ | ១៦,៦ | ១៣,២ | ១០,៣ |
| ២០០៥ | ១៥,៧ | ១២,៧ | ១៣,១ | ១៣,៣ |
| ២០០៦ | ៥,៥ | ១៨,៣ | ១០,១ | ១០,៨ |
| ២០០៧ | ៥ | ៨,៤ | ១០,១ | ១០,២ |
| ២០០៨ | ៥,៧ | ៤ | ៩ | ៦,៧ |
| ២០០៩ | ៥,៤ | -៩,៥ | ២,៣ | ០,១ |

| | | | | |
|---|---|---|---|---|
| ២០១០ | ៤ | ១៣,៦ | ៣,៣ | ៦ |
| ២០១១ | ៣,១ | ១៤,៥ | ៥ | ៧,១ |
| ២០១២ | ៤,៣ | ៩,៣ | ៨,១ | ៧,៣ |
| ២០១៣ | ១,៦ | ១០,៧ | ៨,៧ | ៧,៤ |
| ២០១៤ | ០,៣ | ១០,១ | ៨,៧ | ៧,១ |
| ២០១៥ | ០,២ | ១១,៥ | ៧,១ | ៧ |
| ២០១៦ | ១,៣ | ១០,៦ | ៦,៨ | ៦,៩ |
| ២០១៧ | ១,៧ | ៩,៧ | ៧ | ៧ |
| ២០១៨ | ១,១ | ១១,៦ | ៦,៨ | ៧,៥ |
| ២០១៩ | -០,៥ | ១១,៣ | ៦,២ | ៧,១ |
| ២០២០ | ០,៨ | -២,៨ | -៥,៤ | -៣,១ |






## ជ- អត្រាអតិផរណា




## ឈ- អត្រាប្តូរប្រាក់




## ញ- កម្រិតនៃភាពក្រីក្រនៅកម្ពុជា



## ដ- ស្ថានភាពជំងឺកូវីដ-១៩








ពិធីបិទសន្និបាតអប់រំ យុវជន និងកីឡា
ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៩










**ការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ជូនសម្តេចតេជោ នាយករដ្ឋមន្ត្រី**
**និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន**
**ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១**

# ចតុកោណយុទ្ធសាស្ត្រទី២
# ការធ្វើពិពិធកម្មសេដ្ឋកិច្ច

ការធ្វើពិពិធកម្មសេដ្ឋកិច្ច គឺជាដំណើរការចាំបាច់នៃការបង្កើតជន្ទល់ឱ្យបានច្រើនសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច សំដៅពង្រឹងការនាំចេញ ឬបង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីអាចរក្សាកំណើនសេដ្ឋកិច្ចនៅក្នុងកម្រិតខ្ពស់ ក្នុងរយៈពេលមធ្យមនិងវែងនាពេលខាងមុខ។

## មុំទី១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល

### ១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន

### ១.១- ការងារដឹកជញ្ជូនផ្លូវគោក

សមិទ្ធផលសំខាន់ៗស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន មកទល់នឹងដំណាច់ឆ្នាំ២០២១នេះ មានដូចខាងក្រោម៖

#### ១.១.១- ការងារសាធារណការ

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|
| ផ្លូវជាតិ និងផ្លូវខេត្ត (ឯកតា: គិតជា គ.ម.) | | | | | |
| ផ្លូវជាតិ កម្រិត១(៩ខ្សែ) | ២ ២៥៤ | ២ ២៥៤ | ២ ២៥៤ | ២ ២៥៤ | ២ ២៥៤ |
| ផ្លូវជាតិ កម្រិត២(៦៦ខ្សែ) | ៥ ០០៧ | ៥ ០០៧ | ៥ ០០៧ | ៥ ០០៧ | ៥ ០០៧ |
| ផ្លូវខេត្ត(៦២៧ខ្សែ) | ៩ ០៣១ | ៩ ០៣១ | ៩ ៣០៨ | ១០ ៨៦៣ | ១០ ៨៦៣ |
| សរុបផ្លូវជាតិ និងផ្លូវខេត្ត | ១៦ ២៩២ | ១៦ ២៩២ | ១៦ ៥៦៩ | ១៨ ១២៤ | ១៨ ១២៤ |
| ផ្លូវជាតិដែលបានស្តារដោយក្រាលកៅស៊ូ និងបេតុង ផ្លូវកម្រិត១ និងកម្រិត២ | ៥ ៧៨១ | ៥ ៨៧៥ | ៥ ៩២៩ | ៥ ៩៧៨ | ៦ ០០៣ |
| ផ្លូវដែលបានស្តារដោយក្រាលកៅស៊ូ និងបេតុងផ្លូវកម្រិត១ កម្រិត២ និងផ្លូវខេត្ត | ៨៥២៦ | ៨ ៦២០ | ៩ ២១០ | ៩ ៨៩៥ | ៩ ៩៦៧ |

| ល.រ | ឈ្មោះស្ពាន | ឆ្នាំ | ប្រវែង | ប្រភេទ | ផ្លូវជាតិ | ទីតាំង | ឆ្លងកាត់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ស្ពានធំៗឆ្លងកាត់ទន្លេនិងសមុទ្រ ដែលបានស្ថាបនារួចនិងដាក់ឱ្យប្រើប្រាស់(ឯកតា: គិតជាម៉ែត្រ) | | | | | | | | |
| មុនឆ្នាំ២០១៣ | | | | | | | | |
| ១ | ស្ពានព្រះមុនីវង្សចាស់ | ១៩៦០ | ២៦៩ | បេតុង | ១ | ភ្នំពេញ | ទន្លេបាសាក់ | ជាតិ |
| ២ | ស្ពានជ្រោយចង្វាទី១ | ១៩៦៦ | ៧០០ | បេតុង | ៦ | ភ្នំពេញ | ទន្លេសាប | ជប៉ុន |
| ៣ | ស្ពានគីហ្សូណា | ២០០១ | ១ ៥០០ | បេតុង | ៧ | កំពង់ចាម | ទន្លេមេគង្គ | ជប៉ុន |
| ៤ | ស្ពានកោះកុង | ២០០២ | ១ ៩០០ | បេតុង | ៤៨ | កោះកុង | ដៃសមុទ្រ | ជាតិ |
| ៥ | ស្ពានសេកុង | ២០០៨ | ១ ០៥៧ | បេតុង | ៧ | ស្ទឹងត្រែង | ទន្លេមេគង្គ | ចិន |
| ៦ | ស្ពានព្រះមុនីវង្សថ្មី | ២០០៩ | ២៦៩ | បេតុង | ១ | ភ្នំពេញ | ទន្លេបាសាក់ | ជាតិ |
| ៧ | ស្ពានព្រែកព្នៅ | ២០១០ | ៩៩៦ | បេតុង | ៥ | ភ្នំពេញ | ទន្លេសាប | ជាតិ |
| ៨ | ស្ពានព្រែកក្ដាម | ២០១០ | ៩៨១ | បេតុង | ៥ | កណ្តាល | ទន្លេសាប | ចិន |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៩ | ស្ពានព្រែកតាមាក់ | ២០១១ | ១ ០៦៦ | បេតុង | ៨ | កណ្តាល | ទន្លេមេគង្គ | ចិន |
| ១០ | ស្ពានកោះពស់ | ២០១១ | ៩០០ | បេតុង | | ព្រះសីហនុ | សមុទ្រ | ឯកជន |
| ក្រោយឆ្នាំ២០១៣ | | | | | | | | |
| ១១ | ស្ពានតាខ្មៅ | ២០១៥ | ៨៥៥ | បេតុង | ២១A | កណ្តាល | ទន្លេបាសាក់ | ចិន |
| ១២ | ស្ពានមេគង្គ | ២០១៥ | ១ ៧៣១ | បេតុង | ៩ | ស្ទឹងត្រែង | ទន្លេមេគង្គ | ចិន |
| ១៣ | ស្ពានអ្នកលឿង | ២០១៥ | ២ ២១៥ | ខ្សែកាប | ១ | កណ្តាល-ព្រៃវែង | ទន្លេមេគង្គ | ជប៉ុន |
| ១៤ | ស្ពានជ្រោយចង្វាទី២ | ២០១៥ | ៧១៩ | បេតុង | ៦ | ភ្នំពេញ | ទន្លេសាប | ចិន |
| ១៥ | ស្ពានកោះធំ | ២០១៦ | ៤១៥ | បេតុង | ២១ | កណ្តាល | ទន្លេបាសាក់ | ចិន |
| ១៦ | ស្ពានជ្រៃធំ | ២០១៧ | ២១៦ | បេតុង | ២១ | កណ្តាល | ទន្លេបាសាក់ | វៀតណាម |
| ក្រោយឆ្នាំ២០១៧ | | | | | | | | |
| ១៧ | ស្ទឹងត្រង់-ក្រូចឆ្មារ | ២០២១ | ១ ១៣១ | បេតុង | ៧១សេ | កំពង់ចាម-ត្បូងឃ្មុំ | ទន្លេមេគង្គ | ចិន |

### ១.១.២- ការងារដឹកជញ្ជូនផ្លូវគោក សុវត្ថិភាពចរាចរណ៍ និងដឹកជញ្ជូនសាធារណៈ

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|
| **ការងារចុះបញ្ជីយានយន្ត (ឯកតា៖ គិតជា គ្រឿង)** | | | | | |
| រថយន្តធុនធ្ងន់ | ៦ ៧៦៦ | ៩ ៧៧២ | ១៦ ២៧៥ | ១៥ ៣៤២ | ១០ ៩៦៨ |
| រថយន្តធុនស្រាល | ៥៣ ៦៣៤ | ៦៧ ៤២៣ | ៨៩ ១៧៧ | ៧០ ៦៣១ | ៤៦ ៣៣៨ |
| ម៉ូតូ | ៣៨១ ៤០០ | ៥០២ ៧០១ | ៥៤០ ៦២១ | ៣៧០ ៦០១ | ៣០៦ ៦៦២ |
| **សរុប** | **៤៤១ ៨០០** | **៥៧៩ ៨៩៦** | **៦៤៦ ០៧៣** | **៤៥៦ ៥៧៤** | **៣៦៣ ៩៦៨** |
| បើគិតចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០២១ យានយន្តបានចុះបញ្ជីសរុបមានចំនួន៦ ២១៤ ៣៩៥គ្រឿង (ក្នុងនោះ រួមមានម៉ូតូចំនួន ៥ ២៨១ ១៤៨គ្រឿង រថយន្តធុនស្រាលចំនួន៦៦១ ៤៧១គ្រឿង និងរថយន្តធុនធ្ងន់ចំនួន២៧១ ៧៧៦គ្រឿង) | | | | | |
| ការប្រឡងយកបណ្ណបើកបរ(ឯកតា: គិតជាគ្រឿង) | | | | | |
| រថយន្តគ្រប់ប្រភេទ | ៩១ ០២៤ | ១២៣៣៩១ | ១៥៤ ៩៦៨ | ២១០ ០៦៨ | ៥៨ ៥១៥ |
| ម៉ូតូ | ៤៩២ | ៤៩៥ | ១៤ ២៦១ | ៤២ ០១៥ | ៣ ៥៨១ |
| **សរុប** | ៩១ ៥១៦ | ១២៣៨៨៦ | ១៦៩ ២២៩ | ២៥២ ០៨៣ | ៦២ ០៩៦ |
| បើគិតចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០២១ ការប្រឡងយកបណ្ណបើកបរសរុបមានចំនួន១ ៨៣៥ ៤៩៨គ្រឿង(ក្នុងនោះ រួមមានម៉ូតូចំនួន២២៣ ៦០២គ្រឿង និងរថយន្តគ្រប់ប្រភេទចំនួន១ ៦១១ ៨៩៦គ្រឿង) | | | | | |
| ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ (ផ្លូវគោក) | | | | | |
| ចំនួនគ្រោះថ្នាក់(លើក) | ៣ ៦៨៦ | ៣ ៣៥២ | ៤១១៩ | ៣ ១៧៨ | ២ ១៣១ |
| ស្លាប់(នាក់) | ១ ៩៧៦ | ១ ៨៧១ | ១៩៨២ | ១ ៦៤៥ | ១ ១៩៨ |
| របួសសរុប(នាក់) | ១០ ៨៤៧ | ៩ ៦៤១ | ៦១៣១ | ៤ ៦៨៨ | ២ ៩២៩ |
| អត្រាស្លាប់ក្នុងយានយន្ត១០ ០០០គ្រឿង | ៤,៣០ | ៤,៥ | ៤,២ | ៤,២ | ៦,២១ |
| អត្រាស្លាប់ក្នុងប្រជាជន១០០ ០០០នាក់ | ១១,២០ | ១១,៦ | ១១ | ១១ | ៥,៨ |

- ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោក (ចុះបញ្ជីយានយន្តប្រឡងយកបណ្ណបើកបរយានយន្តនិងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ)

- រៀបចំឱ្យមានការចុះបញ្ជីយានយន្តស្លាកលេខសញ្ញាពិសេសផ្ទាល់ខ្លួននៅថ្ងៃទី៧ ខែមករា ឆ្នាំ២០២០ និងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីស្លាកលេខផ្ទាល់ខ្លួន

- រៀបចំប្រព័ន្ធ QR Code ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារសេវាដឹកជញ្ជូនផ្លូវគោក

- ធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋអាចជ្រើសរើសលេខ និងដាក់ពាក្យ ចុះបញ្ជីយានយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសតាមប្រព័ន្ធអនឡាញ(Online)

| | | | | | |
|---|---|---|---|---|---|
| សាលាបង្រៀនបើកបរយានយន្តទូទាំងប្រទេស | | | | | |
| **ចំនួនសាលា** | ៦ | ៧ | ១១ | ១២ | ១១ |
| **ស្ថិតិមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនិងឆៀកចល័ត តាមឆ្នាំនីមួយៗ** | | | | | |
| **មណ្ឌលសរុប** | ១០ | ១២ | ១៣ | ១៥ | ១៩ |
| **ឆៀកចល័ត** | ២ | ២ | ៣ | ៤ | ៤ |

- ធ្វើសមាហរណកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីផ្តល់បណ្ណសម្គាល់ និងស្លាកលេខយានយន្តជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

## ១.២- ការងារដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១(៩ខែ) |
|---|---|---|---|---|---|
| ☼ការងារអាជីវកម្ម និងហិរញ្ញវត្ថុនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ | | | | | |
| ទំនិញឆ្លងកាត់ផែ(ពាន់តោន) | ៤ ៣៦៥ | ៥ ៣២៨ | ៦ ៥៤៨ | ៦ ៤៤០ | ៥ ២៤៨ |
| នាវាឆ្លងកាត់(គ្រឿង) | ១ ៣០៥ | ១ ៤៥១ | ១ ៦៦១ | ១ ៥៨០ | ១ ០៦៦ |
| កុងតឺន័រឆ្លងកាត់(TEU) | ៤៥៩ ៨៣៩ | ៥៤១ ២២៨ | ៦៣៩ ២១១ | ៦២០ ៥១២ | ៥៦៤ ៥៧៩ |
| ចំណូលអាជីវកម្ម(ពាន់ដុល្លារ) | ៥៦ ៨៤៩ | ៦៨ ៨៩៤ | ៨៣ ៤៧៨ | ៧៧ ០៤៥ | ៦៧ ៣៤៩ |
| ☼ការងារអាជីវកម្ម និងហិរញ្ញវត្ថុនៅកំពង់ផែស្វយ័តភ្នំពេញ | | | | | |
| ទំនិញឆ្លងកាត់ផែ(ពាន់តោន) | ២ ៧៥៨ | ៣ ១៣៥ | ៣៧៨៩ | ៣ ៧៤៤ | ២ ៩១៥ |
| នាវាឆ្លងកាត់(គ្រឿង) | ១ ៦៧៦ | ២ ០២៣ | ២៤០៩ | ២ ៣២៥ | ១ ៧៤៤ |
| កុងតឺន័រឆ្លងកាត់(TEU) | ១៨៤ ៨០៥ | ២១៣ ៥១៧ | ២៨១ ០៤៥ | ២៨៦ ៦៦៦ | ២៥៦ ៤០៧ |
| ចំណូលអាជីវកម្ម(ពាន់ដុល្លារ) | ១៩៦៧៩ | ២២ ៤៣០ | ៣១ ៧១៨ | ២៩ ៤៩១ | ២៥០០៧ |
| ☼ការងារសេវាកម្មដឹកជញ្ជូនផ្លូវទឹក | | | | | |
| ផ្តល់បណ្ណសម្គាល់ជលយានគ្រប់ប្រភេទ(គ្រឿង) | ២១ | ២៥ | ១៣ | ៤៨ | ៩២ |
| ផ្ទេរម្ចាស់កម្មសិទ្ធិ(ច្បាប់) | ៧ | ៧ | ៧ | ១៦ | ៣០ |
| ប្តូរបណ្ណនិងទុតិយតា(ច្បាប់) | ១៣ | ១០ | ៧ | ៦ | ៦ |
| ផ្តល់បណ្ណបើកបរថ្មី(បណ្ណ) | ១១ | ១៦ | ២២ | ៦២ | ០ |
| ផ្តល់បណ្ណបើកបរបន្ត(បណ្ណ) | ៤ | ៨ | ២៣ | ២៣ | ១ |
| ត្រួតពិនិត្យលក្ខណៈបច្ចេកទេស(គ្រឿង) | ៤ | ១០ | ៩ | ៣ | ១ |
| ត្រួតពិនិត្យលក្ខណៈក្នុងស្រុក(គ្រឿង) | ១៥៣ | ១៥៧ | ១៥៩ | ១៨១ | ២០៧ |

| | | | | | |
|---|---|---|---|---|---|
| ត្រួតពិនិត្យលក្ខណៈបច្ចេកទេសដចម្លង(គ្រឿង) | ១៤ | ១៥ | ១៦ | ២៤ | ១៥ |
| ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនទេសចរណ៍(ច្បាប់) | ១១ | ២២ | ១៩ | ៣ | ០ |
| ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូនឆ្លងដែន(ច្បាប់) | ១៣ | ១២ | ១២ | ៣ | ៣ |
| ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូនទំនិញ(ច្បាប់) | ១១១ | ១១៤ | ១២៨ | ១២៨ | ១៦៥ |
| ផ្តល់លិខិតអាជីវកម្មសាឡាងដឹកទំនិញ(ច្បាប់) | ៤ | ៦ | ៤ | ១២ | ១០ |
| ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ(ច្បាប់) | ៤០ | ២០ | ២៥ | ១៤ | ១ |
| ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនដចម្លង(ច្បាប់) | ១២ | ១២ | ១៦ | ២៤ | ១៤ |
| ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូន(ច្បាប់) | ៧ | ៩ | ៥ | ១៣ | ៨ |
| ចំណូលសេវាកម្ម(ពាន់រៀល) | ១១២ ៩៧៣ | ១២៧ ៦៣០ | ១៤០ ១០៥ | ១៤៣ ៥៦៨ | ១៨៩ ១១៦ |
| ☼ការងារសេវាកម្មដឹកជញ្ជូនផ្លូវសមុទ្រ | | | | | |
| ផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក-យន្តការី(ថ្មី)(បណ្ណ) | ០ | ០ | ៣២ | ១៧ | ៤ |
| បន្តសុពលភាពវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក(បណ្ណ) | ១ | ៨ | ១១ | ៧ | ១ |
| ការផ្តល់វិញ្ញាបនបត្របង្ហីលេខសម្រាប់នាវិកលើនាវាឆ្លងកាត់ព្រំដែន(បណ្ណ) | ០ | ០ | ០ | ៣ | ០ |
| ផ្តល់សៀវភៅវិជ្ជាជីវៈនាវិក(ក្បាល) | ០ | ៤៩ | ១១ | ១ | ១៣ |
| ពន្យារពេលប្រើប្រាស់សៀវភៅវិជ្ជាជីវៈនាវិក(ក្បាល) | ២៧ | ២១ | ១៩ | ២ | ០ |
| ទុតិយតាវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក(បណ្ណ) | ០ | ០ | ០ | ២ | ០ |
| ផ្តល់សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា(បណ្ណ) | ០ | ០ | ០ | ៤៣ | ១១ |
| ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មនាវា(ថ្មី)(បណ្ណ) | ០ | ៦ | ២២ | ១៣ | ១ |
| ការផ្តល់បណ្ណសម្គាល់នាវា (លើកដំបូង ផ្ទេរកម្មសិទ្ធិ កែច្នៃលក្ខណៈសម្គាល់នាវា)(បណ្ណ) | ០ | ០ | ២៧ | ១៧ | ០ |
| ច្បាប់អនុញ្ញាតស្ថាបនានាវា(បណ្ណ) | ០ | ០ | ២ | ៥ | ០ |
| បន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការ(បណ្ណ) | ១ | ០ | ០ | ១ | ១ |

| | | | | | |
|---|---|---|---|---|---|
| លិខិតអនុញ្ញាតឱ្យនាវាបរទេស ចូល-ចេញកំពង់ផែ(ទទួលផ្ទាល់ និងអនឡាញ) (គ្រឿង) | ០ | ០ | ០ | ២ ៥៣០ | ០ |
| ចំណូលសេវាកម្ម (ពាន់រៀល) | ២៥ ៣៤៧ | ៤២ ៧៤៩ | ៣៩ ៥៤៩ | ១ ០៤៥ ៣២៤ | ១ ១៨៣ ០៦៧ |

## ១.៣- ការងារផ្លូវដែក

- ផ្លូវដែកមេកម្ពុជាមានចំនួនពីរខ្សែទិសខាងជើងមានប្រវែង៣៨៦គ.ម. និងខាងត្បូងប្រវែង២៦៦គ.ម.
- ខ្សែផ្លូវដែកភ្នំពេញ-បាត់ដំបង-ប៉ោយប៉ែត បានតភ្ជាប់ជាមួយផ្លូវដែកថៃ(ថវិកាជាតិ) ត្រូវបានបញ្ចប់នាខែមេសា ឆ្នាំ២០១៩
- បានសាងសង់ផ្លូវដែកពីរាជធានីភ្នំពេញ ទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ សម្រាប់អ្នកដំណើរដោយមានទូររថភ្លើងចំនួន៣គ្រឿង
- ជប៉ុនកំពុងសិក្សាប្រព័ន្ធរថភ្លើងស្រាលពីរាជធានីភ្នំពេញ ទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ
- បានទិញក្បាលរថភ្លើងចំនួន១០គ្រឿង។

### ក- ផ្លូវដែកទិសខាងជើង

- គម្រោងស្តារនិងសាងសង់ឡើងវិញកំណាត់ផ្លូវដែកពីប៉ោយប៉ែតមកសិរីសោភ័ណសម្រេចបាន១០០%
- គម្រោងស្តារនិងសាងសង់ឡើងវិញកំណាត់ផ្លូវដែកពីសិរីសោភ័ណមកបាត់ដំបងសម្រេចបាន១០០%
- គម្រោងស្តារនិងសាងសង់ឡើងវិញកំណាត់ផ្លូវដែកពីបាត់ដំបងមកពោធិ៍សាត់សម្រេចបាន១០០%
- បានបំពាក់ស្លាកសញ្ញាសុវត្ថិភាពនិងរបារស្វ័យប្រវត្តិផ្លូវដែកភាគខាងជើងបាន(៤កន្លែង) ផ្លូវជាតិលេខ៥ រាងក្រុងសិរីសោភណ័ និងក្រុងបាត់ដំបង
- ការងារជួសជុលស្ថានីយរថភ្លើងប៉ោយប៉ែត គ.ម.៣៨៤+៣០០ សម្រេចបាន១០០%
- បានធ្វើការស្តារឡើងវិញកាលពីឆ្នាំ២០១៥ និងបញ្ចប់ការជួសជុលកាលពីចុងឆ្នាំ២០១៨ ហើយបច្ចុប្បន្នក្រុមហ៊ុនរ៉ូយ៉ាល់ រ៉េលវេ កំពុងធ្វើអាជីវកម្មតាមខ្សែរថភ្លើងមួយនេះ
- បានបំពាក់ស្លាកសញ្ញាសុវត្ថិភាពស្វ័យប្រវត្តិចំនួន១ទីតាំង នៅក្រុងប៉ោយប៉ែត
- បានបញ្ចប់ការងារសាងសង់របងការពារស្ថានីយរថភ្លើងប៉ោយប៉ែតនាដើមខែមិថុនា ឆ្នាំ២០២០
- ធ្វើការពង្រឹង និងលើកម្រិតសមត្ថភាពផ្លូវស្ពាន ដើម្បីទ្រទ្រង់ទម្ងន់រហូតដល់២០តោន/អ័ក្សភ្លៅ(20t /Axle load) បំពាក់ស្លាកសញ្ញា ភ្លើងសញ្ញា ភ្លើងសញ្ញាសុវត្ថិភាពរបារស្វ័យប្រវត្តិ នៅតាមចំណុចផ្លូវឆ្លងកាត់ផ្លូវដែក ដើម្បីធានា សុវត្ថិភាពចរាចរណ៍ខ្សែរថភ្លើង និងសំណង់សិល្បការទាំងអស់
- បានធ្វើការជួសជុលផលប៉ះពាល់ ខូចខាតនូវកំណាត់ផ្លូវដែកខ្លះៗ ដោយសារជំនន់ទឹកភ្លៀងប្រមាណ ២២ ៦១៧ម ក្នុងនោះ មានការខូចខាតជាដំណំ ដោយសារបាក់ទំនប់អូរខែដន ដែលស្ថិតនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានហូរជាច់ទាំងស្រុងអស់ប្រវែង២២៧ម. រួចរាល់ចុងខែធ្នូ ឆ្នាំ២០២០
- គម្រោងសាងសង់ទីតាំងផ្លូវជៀសចំនួន៣កន្លែងបន្ថែមទៀត ដើម្បីសម្រួលក្នុងការបញ្ចៀសចរាចរណ៍ខ្សែរថភ្លើងនិងការផ្ទេរលើក ដាក់ទំនិញ។

### ខ- ផ្លូវដែកទិសខាងត្បូង

- គម្រោងបំពាក់ប្រព័ន្ធសុវត្ថិភាពចរាចរណ៍ផ្លូវឆ្លងកាត់ផ្លូវដែកភាគខាងត្បូងសម្រេចបាន១០០%
- គម្រោងជួសជុលស្ពាន និងពង្រឹងផ្លូវដែកភាគខាងត្បូងសម្រេចបាន១០០%

- បានបញ្ចប់ការជួសជុលស្ពានឡើងវិញកាលពីឆ្នាំ២០១៣ នឹងបានប្រគល់ឱ្យក្រុមហ៊ុនរ៉ូយ៉ាល់ រ៉េលវេ ធ្វើអាជីវកម្មនិងការជួលជុលថែទាំផ្លូវដែកជាបន្ទុករបស់ក្រុមហ៊ុនសម្បទានិក

- បានបំពាក់ស្លាកសញ្ញា និងរបារសុវត្ថិភាពស្វ័យប្រវត្តិចំនួន៩ទីតាំង

- គម្រោងសាងសង់ទីតាំងផ្លូវជៀស៨កន្លែងបន្ថែមទៀត ដើម្បីសម្រួលបានក្នុងការបញ្ចៀសចរាចរ ខ្សែរថភ្លើងនិងការផ្ទេរលើក ដាក់ទំនិញ។

**គ- ផ្លូវដែកថ្មី**

បន្តសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិអន្តរជាតិទាំងផ្នែករដ្ឋ និងផ្នែកឯកជនដើម្បីសិក្សាគម្រោង ផ្លូវដែកថ្មី ផ្លូវដែកក្នុងក្រុង ដើម្បីពង្រីកសក្តានុពលការដឹកជញ្ជូនតាមផ្លូវដែក ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និង តម្លៃប្រកួតប្រជែង ទាំងក្នុងប្រទេស និងក្នុងតំបន់ផងដែរ។

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (៩ ខែ) |
|---|---|---|---|---|---|
| **ការដឹកជញ្ជូនតាមខ្សែផ្លូវដែកភាគខាងត្បូង** | | | | | |
| ការដឹកទំនិញគ្រប់ប្រភេទ(តោន គ.ម.) | ៧៥៩ ៦៧៣ | ៥២៨ ៦០៨ | ៩៤៣ ៤៣១ | ១ ១១០ ២៦០ | ៧៣១ ០៧៧ |
| ការដឹកអ្នកដំណើរ(នាក់ គ.ម.) | ៣៩ ០៥៤ | ១០៩ ០៥៩ | ៦២ ៤៨៥ | ២៤ ៩៩៤ | ៣ ៦១៤ |

## ១.៤- ការងាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

វិស័យអាកាសចរណ៍ស៊ីវិលជាឧស្សាហកម្មមួយដែលកំពុងតែរីកលូតលាស់ឡើងយ៉ាងឆាប់រហ័ស ទាំងនៅលើពិភពលោកនិងក្នុងតំបន់។ ដោយឡែកនៅប្រទេសកម្ពុជាយើងវិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយវានឹងមានការរីកចម្រើនទៅមុខជាលំដាប់ ស្របពេលជាមួយនឹងការអភិវឌ្ឍ លើមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀតផងដែរ។ អាកាសចរណ៍ត្រូវបានគេចាត់ទុកថាជាកត្តាយុទ្ធសាស្ត្រនៃផលិតផល និងជាស្នូលចំពោះដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ ដោយសារតែវិស័យនេះ ដើរតួនាទីសំខាន់ពីរគឺ ទី១- ជាសេវាកម្មពាណិជ្ជកម្ម និងទី២- ជាយានសម្រាប់ពាណិជ្ជកម្មនៅក្នុងវិស័យសេវាកម្ម ដទៃទៀត។ វិស័យអាកាសចរណ៍ដែលមានប្រសិទ្ធភាពមិនត្រឹមតែអាចជួយសម្រួលដល់ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញដោយប្រើប្រាស់ពេលវេលាតិចបំផុតប៉ុណ្ណោះទេ ថែមទាំងជួយជាប្រយោជន៍ក្នុងការបង្កើនផ្នែកពាណិជ្ជកម្ម ទេសចរណ៍ ប្រាក់ចំណូលសម្រាប់ជាតិ និងធ្វើឱ្យកាន់តែប្រសើរនូវបណ្តាញទំនាក់ទំនងសង្គមដែលនាំមកនូវគុណប្រយោជន៍ដល់ប្រទេសនិងតំបន់ថែមទៀតផងដែរ។

ដើម្បីរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាល ទី៦នៃរដ្ឋសភា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានពង្រឹងការលើកកម្ពស់ផ្នែកសុវត្ថិភាព សន្តិសុខ អាកាសចរណ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិនិងអន្តរជាតិ ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការជំរុញឱ្យមានការហោះហើរត្រង់មកកាន់ព្រះរាជាណាចក្រកម្ពុជា និងជំរុញឱ្យមានកំណើនអ្នកដំណើរតាមផ្លូវ អាកាស ជាក់ស្តែងក្នុងឆ្នាំ២០១៩ មានចំនួនអ្នកដំណើរតាមផ្លូវអាកាសមានចំនួនប្រមាណជិត១២លាននាក់ ហើយ កំណើននេះវាមានសារៈសំខាន់ណាស់សម្រាប់ចូលរួមបង្កើនសកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ បង្កើនចំណូល ថវិកាជាតិ លើកកម្ពស់ទំនាក់ទំនងសង្គម ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។

# សមិទ្ធផលការងារវិស័យអាកាសចរណ៍ស៊ីវិលរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៧-២០២១

## ១- ការងារដឹកជញ្ជូនតាមផ្លូវអាកាស

### ១.១- ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកនិងអន្តរជាតិដែលបានហោះហើរចេញ ចូល ព្រះរាជាណាចក្រកម្ពុជា

| ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | |
|---|---|---|---|---|---|---|---|---|---|
| ក្នុងស្រុក (ក្រុមហ៊ុន) | ក្រៅស្រុក (ក្រុមហ៊ុន) | ក្នុងស្រុក (ក្រុមហ៊ុន) | ក្រៅស្រុក (ក្រុមហ៊ុន) | ក្នុងស្រុក (ក្រុមហ៊ុន) | ក្រៅស្រុក (ក្រុមហ៊ុន) | ក្នុងស្រុក (ក្រុមហ៊ុន) | ក្រៅស្រុក (ក្រុមហ៊ុន) | ក្នុងស្រុក (ក្រុមហ៊ុន) | ក្រៅស្រុក (ក្រុមហ៊ុន) |
| ៥ | ៣៦ | ៧ | ៣៨ | ៦ | ៣៩ | ៦ | ៣១ | ៦ | ១៧ |
| ៤១ | | ៤៥ | | ៤៥ | | ៣៧ | | ២៣ | |
| កើន (៣២%) | | កើន (១០%) | | កើន (០%) | | ថយចុះ (-១៨%) | | ថយចុះ (-៣៨%) | |

### ១.២- ការដឹកជញ្ជូនតាមផ្លូវអាកាសក្នុងស្រុកនិងអន្តរជាតិ

#### ក- តារាងទិន្នន័យស្ថិតិដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ឆ្នាំ២០១៧-២០២១

| ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ (៩ខែ) | |
|---|---|---|---|---|---|---|---|---|---|
| ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) |
| ៥៧១ ៦៨៧ | ៧ ៦៦៥ ៧១៧ | ៦៣៦ ៧២៥ | ៩ ៣៧៦ ៣៩៣ | ៦៩៩ ៤៥៣ | ១០ ៣២៥ ៥៣៧ | ២៥៧ ៤៣៣ | ១ ៩១៣ ១៧៦ | ១១ ៧៧៤ | ១៦៩ ៨៧០ |
| ៨ ២៣៧ ៤០៤ | | ១០ ០១៣ ១១៨ | | ១១ ០២៤,៩៩០ | | ២ ១៧០ ៦០៩ | | ១៨១ ៦៤៨ | |
| កើន(២៤%) | | កើន(២២%) | | កើន(១០%) | | ថយចុះ(-៨០%) | | ថយចុះ(-៩១%) | |

#### ខ- តារាងទិន្នន័យស្ថិតិដឹកជញ្ជូនទំនិញតាមផ្លូវអាកាស ឆ្នាំ២០១៧-២០២១

| ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ (៩ខែ) | |
|---|---|---|---|---|---|---|---|---|---|
| **ក្នុងស្រុក (តោន)** | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) |
| **៧៦** | ៦៣ ៨៧៣ | ៣៨៥ | ៧៣ ២០៧ | ២៣៩ | ៦៨ ៤៣៧ | ៧៥ | ៥៥ ២៦៨ | ០ | ៥១ ០២៤ |
| ៦៣ ៩៤៩ | | ៧៣ ៥៩២ | | ៦៨ ៦៧៨ | | ៥៥ ៣៤៣ | | ៥១ ០២៤ | |
| កើន(៣៨%) | | កើន (១៥%) | | ថយចុះ(-៧%) | | ថយចុះ(-១៩%) | | ថយចុះ(-៨%) | |

#### គ- តារាងទិន្នន័យជើងហោះហើរ ឆ្នាំ២០១៧-២០២១

| ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ (៩ខែ) | |
|---|---|---|---|---|---|---|---|---|---|
| **ក្នុងស្រុក (ជើង)** | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) |
| **១៦ ៧៦១** | ៧៦ ៩១០ | ១៦ ៨៧៨ | ៨២ ៣១៩ | ១៣ ៩០៤ | ៩០ ៩២៩ | ៥ ៧២៨ | ២៣ ៥២០ | ៧៦៦ | ៧ ១២៤ |
| ៨៤ ៦៧១ | | ៩៩ ១៩៧ | | ១០៤ ៨៣៣ | | ២៩ ២៤៨ | | ៧ ៨៩០ | |
| កើន(២៣%) | | កើន(១៧%) | | កើន(៦%) | | ថយចុះ(-៧២%) | | ថយចុះ(-៧០%) | |

#### ឃ- តារាងទិន្នន័យជើងហោះហើររំលង ឆ្នាំ២០១៧-២០២១

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (៩ខែ) |
|---|---|---|---|---|
| ៥៨ ៧៣៧ | ៦៦ ០៩២ | ៧២ ០០៨ | ៣១ ៤១២ | ១៦ ៥៥០ |
| កើន(៧%) | កើន(១៣%) | កើន(៩%) | ថយចុះ(-៥៦%) | ថយចុះ(-៣៣%) |

## ១.៣- កិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

ដើម្បីជំរុញកំណើនក្រុមហ៊ុនអាកាសចរណ៍ ជើងហោះហើរ អ្នកដំណើរតាមផ្លូវអាកាស និងការហោះហើរវិលងដែនអាកាសកម្ពុជា នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស កំណត់គោលដៅដ៏ច្បាស់លាស់មួយ លើការពង្រឹង និងពង្រីកកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាមួយបណ្តាប្រទេសសំខាន់ៗ តាមរយៈការចរចាជាលក្ខណៈទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន។ រាល់ការចរចាកិច្ចព្រមព្រៀងទាំងអស់ នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាសបានកំណត់យុទ្ធសាស្ត្រនិងយុទ្ធវិធីច្បាស់លាស់ លើបណ្តាសមាសធាតុសេដ្ឋកិច្ចសំខាន់ៗ ដូចជាការចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ ការកំណត់ចំណុះដឹកជញ្ជូន ការកំណត់ផ្លូវហោះហើរ ការកំណត់បើកចំហ សហការជើងហោះហើរ (Code-Share Flights) ការប្រកួតប្រជែងដោយស្មើភាពនិងការកំណត់សំណាញ់សុវត្ថិភាពនៃប្រតិបត្តិការហោះហើរជាដើម។ មកដល់ឆ្នាំ២០២១នេះ កិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវបានកែសម្រួល ឯកភាពលើខ្លឹមសារនិងបានចុះហត្ថលេខាជាច្រើន ដូចមានសេចក្តីលម្អិតសង្ខេបខាងក្រោម៖

**ក- កិច្ចព្រមព្រៀងទ្វេភាគី:** មកដល់ពេលបច្ចុប្បន្ននេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ចុះហត្ថលេខាអនុស្សរណៈយោគយល់ និងឯកភាពជាគោលការណ៍លើខ្លឹមសារនៃកិច្ចព្រមព្រៀង បានចំនួន៤៧ប្រទេស ដែលរួមមាន៖

- កិច្ចព្រមព្រៀងបានចុះហត្ថលេខាសម្គាល់ចំនួន១៨ប្រទេស
- អនុស្សរណៈយោគយល់បានចុះហត្ថលេខាចំនួន៤៥ប្រទេស
- កិច្ចព្រមព្រៀងបានចុះហត្ថលេខាចំនួន២៩ប្រទេស។

**ខ- កិច្ចព្រមព្រៀងពហុភាគីអាស៊ាន:** នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស ដែលដើរតួនាទីជាអ្នកទទួលបន្ទុកផ្ទាល់រាល់ការចរចាកិច្ចព្រមព្រៀងពាក់ព័ន្ធការងារការដឹកជញ្ជូនតាមផ្លូវអាកាស និងសម្របសម្រួលការងារបច្ចេកទេសពាក់ព័ន្ធនឹងវិស័យអាកាសចរស៊ីវិល បាននាំមកនូវដំណើរការរីកចម្រើនជាលំដាប់ ដោយមានរួមទាំងកិច្ចព្រមព្រៀងបានទទួលសច្ចាប័នរួចពីរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងចុះហត្ថលេខារួចហើយ តែរង់ចាំការផ្តល់សច្ចាប័នពីរដ្ឋសភាជាតិ និងកិច្ចព្រមព្រៀងកំពុងដំណើរការចរចា។

- កិច្ចព្រមព្រៀងពហុភាគីអាស៊ាននិងដៃគូសន្ទនាអាស៊ានចំនួន៤ បានស្នើសុំរដ្ឋសភាជាតិផ្តល់សច្ចាប័នរួច តាមរយៈរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦
- កិច្ចព្រមព្រៀងពហុភាគីអាស៊ាននិងពិធីសារចំនួន៥ បានចុះហត្ថលេខា កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ បានស្នើសុំរដ្ឋសភាជាតិផ្តល់សច្ចាប័នរួច តាមរយៈរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០២១
- កិច្ចព្រមព្រៀងពហុភាគីអាស៊ានយ៉ាងតិចចំនួន៣ និងកិច្ចព្រមព្រៀង រវាងអាស៊ាន និងដៃគូអាស៊ានយ៉ាងតិចចំនួន៤ នឹងត្រូវចុះហត្ថលេខានៅឆ្នាំខាងមុខជាបន្តបន្ទាប់។

## ១.៤- ដំណើរការគាំទ្រឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស

ក្រៅពីដំណើរការការងារជំរុញការហោះហើរ ការអនុញ្ញាតការហោះហើរ ការចរចាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាលក្ខណៈទ្វេភាគីនិងពហុភាគីអាស៊ាន នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស ក៏បានដើរតួនាទីសម្របសម្រួល និងគាំទ្រសហគ្រាស ដឹកជញ្ជូនតាមផ្លូវអាកាស ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

**ក- ការងារធានារ៉ាប់រងវិស័យអាកាសចរណ៍ស៊ីវិល:** រាល់អ្នកធ្វើដំណើរតាមផ្លូវអាកាសទាំងអស់រួមទាំងទំនិញនិងអីវ៉ាន់ ត្រូវបានធានាថា មានធានារ៉ាប់រងត្រឹមត្រូវ តាមរយៈក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ អាកាសយានដ្ឋាននិងចរាចរនាំផ្លូវអាកាស។ បណ្ណធានារ៉ាប់រងរបស់ក្រុមហ៊ុនផ្តល់សេវាកម្មដឹកជញ្ជូនទាំងនេះត្រូវត្រួតពិនិត្យសុពលភាពជាប្រចាំ។

**ខ- ការងារបោះពុម្ពផ្សព្វផ្សាយស្ថិតិដឹកជញ្ជូនតាមផ្លូវអាកាស:** ព្រឹត្តិបត្រស្ថិតិប្រចាំឆ្នាំ ឆមាស ត្រីមាស និងប្រចាំខែ ត្រូវបានបោះពុម្ពផ្សព្វផ្សាយជាប្រចាំជូនថ្នាក់ដឹកនាំនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បណ្តាអាជ្ញាធរ និងស្ថាប័នរដ្ឋពាក់ព័ន្ធ។

**គ- ការងារដោះស្រាយបណ្តឹងនិងវិវាទ:** បណ្តឹងរបស់អ្នកធ្វើដំណើរតាមផ្លូវអាកាស ជាមួយក្រុមហ៊ុនអាកាសចរណ៍ ក្រុមហ៊ុនអាកាសចរណ៍ជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន និងក្រុមហ៊ុនចរាចរដែនអាកាស និងក្រុមហ៊ុនអាកាសចរណ៍ ត្រូវបានដោះស្រាយជាបន្តបន្ទាប់ ដោយឈរលើមូលដ្ឋានសាមគ្គីភាព បង្រួមបញ្ហា និងសុខដុមនីយកម្ម ក្រោមដំបូលឆត្រតែមួយនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ឃ- ទ្រទ្រង់វិស័យឯកជន:** ផ្សព្វផ្សាយលទ្ធផលកិច្ចប្រជុំទ្វេភាគីនិងពហុភាគីអាស៊ាន ស្តីពីចំណុចខ្លាំង និងខ្សោយនៃការអនុវត្តកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសថ្មីៗ ជាទៀងទាត់ជាមួយវិស័យឯកជន និងបើកកិច្ចប្រជុំពិភាក្សាផ្តល់យោបល់ រវាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងវិស័យឯកជន ដើម្បីស្វែងរកលទ្ធភាពជំរុញនិងគាំទ្រដល់ដំណើរការអាជីវកម្មឱ្យមាននិរន្តរភាពនិងតម្លាភាព។

**ង- ការងារសេវាកម្មទ្រទ្រង់ការដឹកជញ្ជូនតាមផ្លូវអាកាស:** បានរៀបចំសេចក្តីប្រកាសស្តីពីការគ្រប់គ្រងប្រតិបត្តិករផ្តល់សេវាកម្មគាំទ្រការដឹកជញ្ជូនតាមផ្លូវអាកាស និងកំពុងដំណើរការតម្រូវឱ្យក្រុមហ៊ុនដែលផ្តល់សេវាកម្មទាំង១៣ប្រភេទ មកចុះបញ្ជីជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ អន្តរជាតិ**

**ក- អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**

- ចុះធ្វើអធិការកិច្ច (Aerodrome Surveillance Inspection) ចំនួន៣លើក
- ចុះត្រួតពិនិត្យផ្លូវបរ(L) ផ្លូវបរ(A) ផ្លូវបរ(C) និងចំណតយន្តហោះ ដែលបានជួសជុលកែលម្អដោយក្រុមហ៊ុន SCA ឱ្យស្របតាមបទប្បញ្ញត្តិអាកាសយានដ្ឋានស្តង់ដា ICAO
- ចុះពិនិត្យបំពង់អគ្គិភ័យ (RFF Surveillance Inspection) ចំនួន២លើក
- ចូលរួមសហការជាមួយមន្ត្រីពាក់ព័ន្ធ(មន្ទីររៀបចំដែនដី និងសំណង់ខណ្ឌពោធិ៍សែនជ័យ មន្ត្រីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ Cambodia Airport) ដើម្បីត្រួតពិនិត្យកម្ពស់សំណង់អគារស្ថិតនៅចុងទិសផ្លូវរត់លេខ៥
- ចូលរួមសហការជាមួយមន្ត្រីពាក់ព័ន្ធ(មន្ទីររៀបចំដែនដី និងសំណង់ខណ្ឌពោធិ៍សែនជ័យ មន្ត្រីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ Cambodia Airport) ដើម្បីត្រួតពិនិត្យកម្ពស់សំណង់ផ្សារទំនើប Centrury អគារស្ថិតនៅចុងទិសផ្លូវរត់លេខ២៣
- ត្រួតពិនិត្យនិងតាមដាននូវរាល់ការសាងសង់សំណង់ខ្ពស់ៗ ជុំវិញអាកាសយានដ្ឋានជាប្រចាំ។

**ខ- អាកាសយានដ្ឋានអន្តរជាតិសៀមរាប**

- ចូលរួមសហការក្នុងការចុះកិច្ចព្រមព្រៀង(MOU) រវាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន(SCA កងកម្លាំងនគរបាល និងកងទ័ពជើងអាកាស)

- ចុះធ្វើអធិការកិច្ច(Aerodrome Surveillance Inspection) ចំនួន៣លើក

- ចុះពិនិត្យបំពង់អគ្គិភ័យ(RFF Surveillance Inspection) ចំនួន២លើក

- ចុះត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នភាពកែប្រែAIP ចាប់ពីថ្ងៃទី៦-១០ ខែមិថុនា ឆ្នាំ២០២១។

**គ- អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ**

- ចុះពិនិត្យនិងវាយតម្លៃផ្លូវរត់ ប្រវែង៣ ៣០០ម. ទីតាំងឧបករណ៍នាំផ្លូវចុះចត និងចំណតយន្តហោះដែលជួសជុលនិងសង់ពង្រីកដោយក្រុមហ៊ុនSCA

- ចុះពិនិត្យមើលការងារពង្រីកចំណត Apron Runway Taxiway

- ចុះធ្វើ Random Inspection ARFFS

- ចុះធ្វើអធិការកិច្ច(Aerodrome Surveillance Inspection) ចំនួន៣លើក

- ចូលរួមត្រួតពិនិត្យប្លង់ជួសជុលកែលម្អនិងសាងសង់ផ្លូវរត់

- ចុះពិនិត្យបំពង់អគ្គិភ័យ(RFF Surveillance Inspection) ចំនួន២លើក។

**ឃ- អាកាសយានដ្ឋានបាត់ដំបង**

- ជួសជុលបញ្ចប់ផ្លូវរត់ទំហំ៩ ២០០ម.² ដោយអ៊ុតកៅស៊ូ(ដំណាក់កាលទី៣)

- ចុះអនុវត្តបោះបង្គោលបេងដែលមានប្រវែង៣៤១៣ម. ស្មើនឹង៨០បង្គោល នៅឆ្នាំ២០២១

- ចូលរួមប្រជុំជាមួយសាលាខេត្តបាត់ដំបង ក្នុងការស្រង់ស្ថិតិ និងជំរឿនលើផលប៉ះពាល់នានារួចដោះស្រាយ និងបន្តអនុវត្តធ្វើប្លង់កម្មសិទ្ធិលើដីអាកាសយានដ្ឋានបាត់ដំបងទាំងមូល។

**ង- អាកាសយានដ្ឋានស្ទឹងត្រែង**

- ចូលរួមប្រជុំជាមួយសាលាខេត្តស្ទឹងត្រែង ដើម្បីកំណត់និយាមការព្រំខណ្ឌ និងពិនិត្យមើលដីមានផលប៉ះពាល់ខាងក្នុងអាកាសយានដ្ឋាន ក្នុងឆ្នាំ២០២០

- ចុះពិនិត្យមើលដំណើរការដីកប្រឡាយព្រំខណ្ឌដីអាកាសយានដ្ឋានខេត្តស្ទឹងត្រែង។

**ច- អាកាសយានដ្ឋានកោះកុង**

បានបញ្ចប់ការតំឡើងត្រង់ស្វូតភ្ជាប់បណ្តាញអគ្គិសនីមេ ចូលអាកាសយានដ្ឋានកោះកុង និងជួសជុលបណ្តាញហើយបំពាក់គ្រឿងអគ្គិសនីនៅក្នុងស្ថានីយអ្នកដំណើរ ។

**ឆ- អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ**

- ចូលរួមសហការត្រួតពិនិត្យ និងផ្តល់ស្តង់ដាបច្ចេកទេសលើប្លង់ ក្នុងការសាងសង់ផ្លូវរត់(Runway) ផ្លូវបរ(Taxiway) ស្ថានីយអ្នកដំណើរ(Terminal) ប៉មបញ្ជា(Tower) ឧបករណ៍នាំផ្លូវអាកាស(Air Navigation Aids) ឧបករណ៍ឧតុនិយម(Meteo) និងអគារស្ថានីយពន្លត់អគ្គិភ័យ(RFF Station)

- បានសិក្សានិងធ្វើសៀវភៅស្តីពីការកំណត់កម្ពស់ឧបសគ្គ (Obstacle Limitation Surface) នៅជុំវិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី

- ចូលរួមសហការត្រួតពិនិត្យ និងផ្តល់កិច្ចសម្របសម្រួលរាល់បទប្បញ្ញត្តិ(Regulations) និងនីតិវិធី(Procedure) ក្នុងការអនុវត្តនៅក្នុងអាកាសយានដ្ឋានភ្នំពេញថ្មី ដើម្បីឱ្យស្របទៅតាមអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិICAO។

**ជ- អាកាសយានដ្ឋានអន្តរជាតិសៀមរាបថ្មី**

- ចុះពិនិត្យមើលវឌ្ឍនភាពនៃការសាងសង់ផ្លូវរត់(Runway) ផ្លូវបរ(Taxiway) ស្ថានីយអ្នកដំណើរ (Terminal) ប៉មបញ្ជា(Tower) និងអគារស្ថានីយពន្លត់អគ្គិភ័យ(RFF Station)

- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់និយាមការរបស់ Airport Refference Point Threshold និងទីតាំងរបស់ឧបករណ៍នាំផ្លូវយន្តហោះ(Air Navigation Facilities)

- ចូលរួមសហការត្រួតពិនិត្យនិងផ្តល់ស្តង់ដាបច្ចេកទេសលើប្លង់ ក្នុងការសាងសង់ផ្លូវរត់(Runway) ផ្លូវបរ Taxiway ស្ថានីយអ្នកដំណើរ(Terminal) ប៉មបញ្ជា(Tower) និងអគារស្ថានីយពន្លត់អគ្គិភ័យ(RFF Station)

- សិក្សានិងធ្វើសៀវភៅស្តីពីការកំណត់កម្ពស់ឧបសគ្គ (Obstacle Limitation Surface) នៅជុំវិញអាកាសយានដ្ឋានអន្តរជាតិសៀមរាបថ្មី

- ចូលរួមសហការត្រួតពិនិត្យនិងផ្តល់កិច្ចសម្របសម្រួលរាល់បទប្បញ្ញត្តិ(Regulations) និងនីតិវិធី (Procedure) ក្នុងការអនុវត្តនៅក្នុងអាកាសយានដ្ឋានសៀមរាបថ្មី ដើម្បីឱ្យស្របទៅតាមអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ICAO

- នឹងកំពុងរៀបចំនីតិវិធីផ្តល់ Aeronautical Information Public (AIP) and Certificate។

**ឈ- អាកាសយានដ្ឋានអន្តរជាតិតារាសាគរ(ខេត្តកោះកុង)**

- រៀបចំទីតាំងសម្រាប់ដំឡើងឧបករណ៍នាំផ្លូវ Airport Reference Point និងឧបករណ៍ទំនាក់ទំនងសម្រាប់អាកាសយានដ្ឋានតារាសាគរ

- ប្រជុំជាមួយក្រុមហ៊ុនសាងសង់អាកាសយានដ្ឋានតារាសាគរ ខេត្តកោះកុង ស្តីពីបទបង្ហាញពីនីតិវិធីសម្រាប់ស្នើសុំវិញ្ញាបនបត្រអាកាសយានដ្ឋានតារាសាគរ មុនពេលដំណើរការប្រតិបត្តិការ

- ចូលរួមសហការត្រួតពិនិត្យនិងផ្តល់ស្តង់ដាបច្ចេកទេសលើប្លង់ ក្នុងការសាងសង់ផ្លូវរត់(Runway) ផ្លូវបរ(Taxiway) ស្ថានីយអ្នកដំណើរ(Terminal) ប៉មបញ្ជា(Tower) និងអគារស្ថានីយពន្លត់អគ្គិភ័យ(RFF Station)

- ចុះពិនិត្យនិងសិក្សាវឌ្ឍនភាពនៃការសាងសង់ផ្លូវរត់(Runway) ផ្លូវបរ(Taxiway) ស្ថានីយអ្នកដំណើរ (Terminal) ប៉មបញ្ជា(Tower) និងអគារស្ថានីយពន្លត់អគ្គិភ័យ(RFF Station)

- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់និយាមការរបស់Airport Refference Point Threshold និងទីតាំងរបស់ឧបករណ៍នាំផ្លូវយន្តហោះ(Air Navigation Facilities)

- សិក្សានិងធ្វើសៀវភៅស្តីពីការកំណត់កម្ពស់ឧបសគ្គ(Obstacle Limitation Surface) នៅជុំវិញអាកាសយានដ្ឋានអន្តរជាតិដារ៉ាសាគរ

- ចូលរួមសហការត្រួតពិនិត្យនិងផ្តល់កិច្ចសម្របសម្រួលរាល់បទប្បញ្ញត្តិ(Regulations) និងនីតិវិធី (Procedure) ក្នុងការអនុវត្តនៅក្នុងអាកាសយានដ្ឋានអន្តរជាតិតារាសាគរ ដើម្បីឱ្យស្របទៅតាមអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិICAO

- រៀបចំនីតិវិធីផ្តល់ Aeronautical Information Public (AIP) and Certificate

- អធិការកិច្ច Aerodrome and RFF Surveillance Inspection សម្រាប់ផ្តល់វិញ្ញាបនបត្រអាកាសយានដ្ឋាន(Aerodrome Certificate) ក្នុងខែតុលា ឆ្នាំ២០២១។

**៣- អាកាសយានដ្ឋានមណ្ឌលគិរីថ្មី**

- ចូលរួមប្រជុំជាមួយសាលាខេត្តមណ្ឌលគិរី ដើម្បីកំណត់និយាមការព្រំខណ្ឌ និងពិនិត្យមើលដីមានផលប៉ះពាល់ខាងក្នុងអាកាសយានដ្ឋាន

- ចុះបោះបង្គោលនិយាមការព្រំដីអាកាសយានដ្ឋានខេត្តមណ្ឌលគិរីថ្មី និងអនុវត្តកាយប្រឡាយ ព្រំខណ្ឌ ពីខែធ្នូ ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០

- សិក្សានិងលើកគម្រោងតាមដានជីកប្រឡាយ៨ ៣៣០ម. និងដាំបង្គោលព្រំចំនួន៨ដើម នៅអាកាសយានដ្ឋានមណ្ឌលគិរី

- ចុះវាស់វែងនិងគូរប្លង់កំណត់និយាមការ ដើម្បីសាងសង់ផ្លូវចូលអាកាសយានដ្ឋានមណ្ឌលគិរីថ្មី មានទទឹងផ្លូវចូលទំហំ៦០ម. និងបណ្តោយប្រវែងជាង៣ ០០០ម.

- ចុះពិនិត្យមើលលទ្ធផលសាងសង់ផ្លូវចូលអាកាសយានដ្ឋានមណ្ឌលគិរីថ្មី និងពិភាក្សាជាមួយមន្ត្រីកសិកម្ម លើផ្ទៃដីចំការស្រស់ដែលបានប៉ះពាល់។

**ង- អាកាសយានដ្ឋានប៉ោយប៉ែត**

- ចុះសហការជាមួយក្រុមស្រង់ចំណុចនិយាមការព្រំដីរបស់អាកាសយានដ្ឋានប៉ោយប៉ែត

- ចុះទៅពិនិត្យនិយាមការរបស់ Airport Refference Point Threshold ផ្លូវរត់ (Runway) ផ្លូវបរ Taxiway ស្ថានីយអ្នកដំណើរ(Terminal)

- ចុះពិនិត្យក្រុមការងារខួងដីអាកាសយានដ្ឋានប៉ោយប៉ែត សម្រាប់ធ្វើតេស្តរក CBR, SPT and DCP ពីថ្ងៃទី២២ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០

- ជួយពិនិត្យនិងសម្របសម្រួលលើគំនូរប្លង់ Apron, Runway, Taxiway នៅអាកាសយានដ្ឋានប៉ោយប៉ែត លើការសិក្សានិងគូរប្លង់មុនពេលបញ្ចប់ការងារ។

**៣- ការពង្រឹងសន្តិសុខអាកាសចរណ៍ស៊ីវិល**

សន្តិសុខអាកាសចរណ៍ស៊ីវិល គឺជាផ្នែកមួយដែលដើរតួនាទីសំខាន់ ដើម្បីធានាសុវត្ថិភាពដល់អ្នកដំណើរ ក្រុមអាកាសយាន បុគ្គលិកបម្រើការងារនៅលើផ្ទៃដី និងសាធារណជនទូទៅ ទប់ទល់នឹងអំពើរំលោភបំពានច្បាប់មកលើអាកាសចរណ៍ស៊ីវិល។ ដើម្បីសម្រេចបាននូវគោលដៅខាងលើ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានអនុវត្តសកម្មភាពការងារឱ្យស្របតាមស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិល និងរៀបចំឱ្យមានច្បាប់ បទប្បញ្ញត្តិ កម្មវិធីថ្នាក់ជាតិ ថ្នាក់ប្រតិបត្តិការអាកាសយាន អាកាសយានដ្ឋាន និងលិខិតបទដ្ឋានបច្ចេកទេសសន្តិសុខមាន៖

- កម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល(National Civil Aviation Security Programme)

- កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរណ៍ស៊ីវិល(National Civil Aviation Quality Control Programme)

- កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរណ៍ស៊ីវិល(National Civil Aviation Security Training Programme)

- កម្មវិធីជាតិសម្រួលសម្រួលដឹកជញ្ជូនផ្លូវអាកាស(National Air Transportation Facilitations Programmed)

- កម្មវិធីសន្តិសុខអាកាសយានដ្ឋាន(Airport Security Programmed)

- កម្មវិធីសន្តិសុខប្រតិបត្តិករអាកាសយាន(Aircraft Operator Security Programmed)

- កម្មវិធីសន្តិសុខប្រតិបត្តិករផ្តល់សេវាកម្មនាំផ្លូវអាកាស(Air Traffic Service Provider Security Programmed)។

ក្រៅពីការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការងារសំខាន់មួយទៀតគឺកិច្ចសហប្រត្តិបត្តិការជាមួយការិយាល័យ ICAO ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកក៏ដូចនៅក្នុងក្របខ័ណ្ឌកម្មវិធីCASP-AP ផងដែរ។ ការងារនេះរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលមានទំនាក់ទំនងនិងសហការបានល្អជាមួយមន្ត្រីសម្របសម្រួលកម្មវិធី (CASP-AP Programmed Coordinator) ដើម្បីស្នើសុំជំនួយបច្ចេសទេសសម្រាប់អនុវត្តការងារសន្តិសុខនៅក្នុងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលតាមរយៈការជ្រើសរើសការងារអាទិភាពមួយចំនួនដែលបានផ្សព្វផ្សាយនៅក្នុងបញ្ជីសកម្មភាពការងារប្រចាំឆ្នាំរបស់កម្មវិធីCASP-AP។

ទោះជារយៈពេល៥ឆ្នាំ(២០១៧ ដល់២០២១)នេះមានផលប៉ះពាល់ ពោពេញទៅដោយការរីករាលដាលនៃជំងឺCovid-19 នៅឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្នយ៉ាងណាក៏ដោយក៏ការងារសន្តិសុខអាកាសចរណ៍ស៊ីវិលបានបំពេញការងាររបស់ខ្លួនប្រចាំថ្ងៃទទួលបានសមិទ្ធផលសំខាន់ៗសម្រេចដូចខាងក្រោម៖

- នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ បានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារUSAP-USOAP-CMA-SSCA ដើម្បីពិនិត្យវឌ្ឍនភាពនៃការឆ្លើយតបចំពោះចំណុចខ្វះខាតដែលរកឃើញដោយក្រុមសវនកម្មនៃអង្គការ ICAO នៅ រ.ល.អ.ស.ទាំងពីផ្នែកUSAP-USOAP

- នៅថ្ងៃទី៦-១៧ ខែមីនា ឆ្នាំ២០១៧ បានទទួលអ្នកជំនាញការ(Expert) មកពិនិត្យកម្មវិធីចំនួន៤៖
  - កម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល
  - កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរណ៍ស៊ីវិល
  - កម្មវិធីជាតិហ្វឹកហ្វឺនសន្តិសុខ
  - កម្មវិធីជាតិសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស។

- នៅថ្ងៃទី៣១ ខែកក្កដា ដល់ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ បានបើកវគ្គបណ្តុះបណ្តាលស្តីពីBasic Security ដល់សន្តិសុខក្រុមហ៊ុនចំនួន១៩នាក់ នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរណ៍ស៊ីវិល

- នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ បានចូលរួមក្នុងពិធីធ្វើបទបង្ហាញអំពីកម្មវិធី និងការបណ្តុះបណ្តាលរបស់បណ្ឌិតសភាអាកាសចរវៀតណាម ក្នុងឱកាសដែលមកបំពេញទស្សនកិច្ច និងពិភាក្សាការងារជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- នៅថ្ងៃទី២១-២៥ ខែសីហា ឆ្នាំ២០១៧ បានបើកវគ្គបង្រៀន Basic Security ដល់កម្លាំងដល់សន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប

- នៅថ្ងៃទី២-១៣ ខែតុលា ឆ្នាំ២០១៧ បានចាត់តាំងមន្ត្រី៥រូបជាគ្រូបង្គោលចុះបំពេញបេសកកម្មនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ដើម្បីបណ្តុះបណ្តាលមន្ត្រីសន្តិសុខបំពេញបន្ថែមចំណុចខ្វះខាតដែល ICAO បានរកឃើញពេលសវនកម្មកាលពីថ្ងៃ២០-២៨ ខែតុលា ឆ្នាំ២០១៦កន្លងមក

- ពិនិត្យកម្មវិធីសន្តិសុខរបស់ក្រុមហ៊ុនអាកាសចរណ៍ Bayon Air បានចប់សព្វគ្រប់

- នៅថ្ងៃទី២០ ខែវិច្ឆិកា ដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ បានបើកវគ្គបណ្តុះបណ្តាលសន្តិសុខ ដើម្បីបំពេញនូវរាល់ចំណុចខ្វះខាត ដែលICAO បានរកឃើញពេលធ្វើសវនកម្មសាកលកាលពីថ្ងៃទី២០ ដល់២៨ ខែតុលា ឆ្នាំ២០១៦កន្លងមក

- នៅថ្ងៃទី៥-១៦ ខែមីនា ឆ្នាំ២០១៨ បានបំពេញការងារនៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ដើម្បីពិនិត្យលើការសិក្សាវាយតម្លៃការបណ្តុះបណ្តាលសន្តិសុខអាកាសចរណ៍ស៊ីវិល និងធ្វើផែនការភាពអាសន្ន និងពិនិត្យលើSOP

- នៅថ្ងៃទី១៩-២៣ ខែមីនា ឆ្នាំ២០១៨ បានវគ្គបណ្តុះបណ្តាលស្តីពី Admin HR Management and Development នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរណ៍ស៊ីវិល

- នៅថ្ងៃទី១-១០ ខែសីហា ឆ្នាំ២០១៨ បានបើកវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសន្តិសុខកម្រិតមធ្យម

- នៅថ្ងៃទី១-០២ ខែវិច្ឆិកា ឆ្នាំ២០១៨ បានចូលរួមអនុវត្តសមហាត់លើតុ ក្នុងសមយុទ្ធទ្រង់ទ្រាយធំ (KOS-EX18) នៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ

- នៅថ្ងៃទី៥-១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ បានបើកវគ្គបណ្តុះបណ្តាល Basic Training For X-Ray Operator Course ដល់ក្រុមហ៊ុន AAS នៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប

- ពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់ ស្តីពីអាកាសចរណ៍ស៊ីវិលកម្ពុជា ដែលមានជំពូក និងមាត្រាពាក់ព័ន្ធនឹងជំនាញ សន្តិសុខអាកាសចរណ៍ស៊ីវិល រួមមានជំពូក១២ នៃមាត្រា៥១ ដល់មាត្រា៥៦

- ធ្វើបច្ចុប្បន្នភាព បទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ផ្នែកសន្តិសុខ(CCAR Part-17) តាមការណែនាំរបស់ ICAO

- ធ្វើវិសោធនកម្ម កម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល ដើម្បីឱ្យស្របទៅតាមការធ្វើវិសោធនកម្ម Annex 17 លើកទី២៧

- ពិនិត្យនិងកែសម្រួលកម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខ

- ពិនិត្យនិងកែសម្រួលកម្មវិធីជាតិ បណ្តុះបណ្តាលសន្តិសុខអាកាសចរណ៍ស៊ីវិល

- ធ្វើសេចក្តីព្រាងកម្មវិធីជាតិកិច្ចសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស តាមការណែនាំរបស់ ICAO

- ចុះធ្វើបច្ចុប្បន្នភាពឧបករណ៍ និងកម្លាំងសន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប

- បើកវគ្គបណ្តុះបណ្តាលរៀបចំផែនការគ្រប់កម្រិត Aviation Security Management Course

- បើកវគ្គបណ្តុះបណ្តាលសម្រាប់អ្នកកាន់ម៉ាស៊ីន X-Ray

- ចុះធ្វើបច្ចុប្បន្នភាពកម្លាំងសន្តិសុខ នៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប

- ចូលរួមពិនិត្យឡើងវិញ ផែនការភាពអាសន្ននៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

- ដឹកនាំក្រុមការងារជំនាញពិនិត្យនិងកែសម្រួលកម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខនៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

- ចុះបំពេញបេសកកម្មពិនិត្យការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី នៅខេត្តកណ្តាល

- ចូលរួមកិច្ចប្រជុំ APAC Contingency and Recovery Planning Group (ACCRPG) ដោយក្នុងនោះ នាយកដ្ឋានសន្តិសុខជាប្រធាន Sub Group Security and Facilitation តាមរយៈ Video Conference ដោយនាយកដ្ឋានសន្តិសុខ ទទួលបាន Council Aviation Recovery Task Force

- ដើរតួនាទីក្នុងនាមជាPoint of Contact (PoC RASG-APAC/APRAST) នៃ ICAO-Asia Pacific (APAC) ក្នុងការសម្របសម្រួលការងារសុវត្ថិភាពអាកាសចរណ៍ស៊ីវិល តាមរយៈការចូលរួមសហការយ៉ាងជិតស្និទ្ធពីសំណាក់នាយកដ្ឋានជំនាញ អង្គភាព មជ្ឈមណ្ឌល អាកាសយាដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធស្ថិតក្រោម

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអង្គការអាកាសចរណ៍ស៊ីវិល អន្តរជាតិ អាស៊ីប៉ាស៊ីហ្វិក (ICAO-APAC) ដោយសម្រេចបាននូវ Safety Tools សម្រាប់កិច្ចការងារសុវត្ថិភាពអាកាសចរណ៍ចំនួន២០ និងបានចូលរួមត្រួតពិនិត្យធ្វើបច្ចុប្បន្នភាពឡើងវិញ ចំនួន១៥ រួមមាន(GEN, CFIT, LOC-I និង RS (RE and RI)

- រៀបចំឱ្យមានបទប្បញ្ញត្តិ ស្តីពីសុវត្ថិភាពអាកាសចរណ៍ CCAR Part 19: Aviation Safety (Issue 1) ដើម្បីឱ្យស្របទៅតាម ICAO Annex 19 Safety Management 1st Edition ហើយបានអនុម័តរួចរាល់ដោយថ្នាក់ដឹកនាំ រលអស នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧

- សម្របសម្រួលរៀបចំបាននូវក្រុមការងារសុវត្ថិភាពផ្លូវរត់(Runway Safety Teams) នៅគ្រប់អាកាសយានដ្ឋានអន្តរជាតិទាំង៣ នៃព្រះរាជាណាចក្រកម្ពុជា ទៅតាមផែនការសុវត្ថិភាពរបស់ ICAO-APAC

- រៀបចំកែសម្រួល ធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិស្តីពីសុវត្ថិភាពអាកាសចរណ៍ CCAR Part 19: Aviation Safety (Issue 2) ដើម្បីឱ្យស្របទៅតាម ICAO Annex 19 2nd Edition (Amendment 1) ហើយបានអនុម័តរួចរាល់ដោយថ្នាក់ដឹកនាំរ.ល.អ.ស. នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១

- ធ្វើការផ្ទៀងផ្ទាល់រវាងបទប្បញ្ញត្តិ ស្តីពីសុវត្ថិភាពអាកាសចរណ៍ CCAR Part 19: Aviation Safety (Issue 2)ជាមួយនឹង SARPs ទាំង៧៤ នៃICAO Annex 19 – Safety Management 2nd Edition

- រៀបចំរួចរាល់នូវសេចក្តីព្រាងកម្មវិធីសុវត្ថិភាពរដ្ឋ State Safety Programme(SSP) ហើយបន្តនីតិវិធីដើម្បីស្នើសុំការឯកភាពពីថ្នាក់ដឹកនាំរ.ល.អ.ស. ដើម្បីបន្តអនុវត្តន៍ឱ្យស្របទៅនឹង ផែនការសុវត្ថិភាពអាកាសចរណ៍សកល GASP ក៏ដូចជា ICAO ដែលតម្រូវឱ្យរដ្ឋជាសមាជិកអនុវត្ត

- រៀបចំធ្វើបច្ចុប្បន្នភាពលើសៀវភៅណែនាំ ស្តីពីសវនកម្មផ្ទៃក្នុង(Internal Audit Manual of Technical) ទាក់ទងទៅនឹងជំនាញបច្ចេកទេសអាកាសចរណ៍ស៊ីវិល ដើម្បីឱ្យស្របតាមតម្រូវការជាក់ស្តែងរបស់អង្គភាព និងចូលរួមលើកកម្ពស់សុវត្ថិភាពអាកាសចរណ៍ឱ្យកាន់តែប្រសើរឡើង

- រៀបចំតម្លើងប្រព័ន្ធគ្រប់គ្រង ត្រួតពិនិត្យសុវត្ថិភាពតាមប្រព័ន្ធ SMIS/SOMS បានរួចរាល់ដោយទទួលបានការសហការក្រុមជំនាញបច្ចេកទេសកម្ពុជា និងការជួយសហការពីក្រសួងរៀបចំដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូននៃសាធារណរដ្ឋកូរ៉េ(MOLIT) រួមជាមួយការបណ្តុះបណ្តាលមូលដ្ឋានដល់មន្ត្រីនៃ រ.ល.អ.ស. ដើម្បីឈានទៅដល់ការអនុវត្តជាផ្លូវការនាពេលឆាប់ៗ

- ធ្វើសេចក្តីព្រាង ស្តីពីផែនការសុវត្ថិភាពអាកាសចរណ៍ជាតិ(National Aviation Safety Plan) ជាបណ្តើរៗដើម្បីឱ្យស្របទៅតាមផែនការសុវត្ថិភាពអាកាសចរណ៍ក្នុងតំបន់ និងសកល

- ធ្វើបច្ចុប្បន្នភាព និងពិនិត្យ Procedures Manual For Aviation Safety Reporting

- បើកវគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីក្នុងនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធតាមប្រព័ន្ធ តាមរយៈថ្នាក់រៀន ក៏ដូចជាតាមរយៈប្រព័ន្ធអនឡាញ(Online Zoom)ក្នុងដំណាក់កាលនៃបរិបទជំងឺកូវីដ-១៩ រួមមានវគ្គដូចខាងក្រោម៖

១- ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព(Safety Management System (SMS) Course)

២- កម្មវិធីសុវត្ថិភាពរដ្ឋ(State Safety Programme(SSP) Course)

៣- ដំណោះស្រាយ ស្តីពីបញ្ហាសុវត្ថិភាព(Resolution of Safety Issue )RSI) Course)

៤- វគ្គបណ្តុះបណ្តាលមួយចំនួនទៀតទាក់ទងទៅនឹងវិស័យអាកាសចរណ៍។

- ចូលរួមផ្សព្វផ្សាយ និងសហការយ៉ាងពេញទំហឹងជាមួយអង្គភាព និងមន្ត្រីក្នុងនាយកដ្ឋាន ស្តីពីករណីការរីករាលដាលជំងឺកូវីដ-១៩ ជាបន្តបន្ទាប់

- ធ្វើបច្ចុប្បន្នភាពសំណួរក្នុងការវិភាគរកចំណុចចន្លោះប្រហោង ស្តីពីកម្មវិធីសុវត្ថិភាពរដ្ឋUpdate Questions in SSP Gap Analysis និងបន្តពិនិត្យការងារ SSP & SMS បន្ថែមទៀត។

- ពង្រាងសេចក្តីព្រាងកិច្ចព្រមព្រៀង កម្ពុជា ឡាវ និងកម្ពុជា ចិន លើការរុករកសង្គ្រោះអាកាសចរណ៍ស៊ីវិល

- ប្រជុំពិភាក្សាជាមួយនាយកដ្ឋានស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស លើការរៀបចំឯកសារគតិយុត្តពាក់ព័ន្ធទៅនឹងប្រតិបត្តិការរបស់មជ្ឈមណ្ឌលសម្របសម្រួលសង្គ្រោះ

- រៀបចំកិច្ចប្រជុំកម្ពុជា ឡាវ វៀតណាម លើប្រព័ន្ធផ្កាយរណប COSPAS-SARSAT Alert Data ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាអ្នកច្បាប់ដើម្បីពិនិត្យ និងពិភាក្សាលើសំណើសុំសិទ្ធប្រទាន ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការរុករក និងសង្គ្រោះ

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ នៅអគ្គលេខាធិការដ្ឋានជាតិសន្តិសុខលម្ហសមុទ្រ

- រៀបចំវគ្គបណ្តុះបណ្តាល COSPAS-SARSAT Alert Data នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល

- សហការជាមួយគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ និងអាជ្ញាធរពាក់ព័ន្ធក្នុងការជួយសង្គ្រោះក្រុមអ្នកទេសចរណ៍ជនជាតិអង់គ្លេសចំនួន១៦នាក់ ដែលបានជួបឧបទ្ទវហេតុពេលធ្វើដំណើរតាមផ្លូវ សមុទ្រពីខេត្តព្រះសីហនុ ទៅកោះថ្មី

- បញ្ជូនមន្ត្រីចំនួន២រូប ចូលរួមសមយុទ្ធមហាអំពិល១៩ នៅខេត្តកោះកុង និងបានចូលរួមសមយុទ្ធទ្រង់ទ្រាយធំ Full Scale Airport Emergency Exercise (REPEX19) នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប

- បញ្ជូនមន្ត្រីចំនួន៥រូប ចូលរួមក្នុងពិធីធ្វើលំហាត់សមយុទ្ធទ្រង់ទ្រាយធំនៅមូលដ្ឋានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

- ចូលរួមកិច្ចប្រជុំរវាងក្រុមការងារបច្ចេកទេសសម្រាប់ការសាងសង់ និងការធ្វើបណ្ណកម្មសិទ្ធិអាកាសយានដ្ឋានក្នុងស្រុកជាមួយក្រុមហ៊ុនឆាយណារ៉េលវេ18THប្ប៊្រូគ្រុប(ខេមបូឌា) ឯ.ក

- ចូលរួមកិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុន CATS ដើម្បីពិនិត្យលើសេចក្តីព្រាងកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការក្នុងវិស័យរុករកសង្គ្រោះ

- រៀបចំចងក្រង និងត្រៀមបោះពុម្ភសៀវភៅ RCC Job Description និង RCC Operation Manual

- សហការនិងទំនាក់ទំនងជាមួយក្រុមហ៊ុន CATS តាមរយៈការធ្វើ Line-Check ជារៀងរាល់ថ្ងៃ

- ទទួលនិងចែកចាយព័ត៌មានតាមរយៈប្រព័ន្ធផ្កាយរណប COSPAS-SASART និង AFTN។

**៤- សេវាកម្មអាកាសចរណ៍**

**ក- ផ្នែកគ្រប់គ្រងចរាចរណ៍ដែនអាកាស**(Air Traffic Control)

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ការបញ្ជាយន្តហោះហោះហើរឡើងចុះនិងហោះឆ្លងកាត់ សរុបមានចំនួន៦៤៣ ៧២៨ជើង

- ក្នុងស្រុកចំនួន៣៧ ៩៣១ជើង ៥៣ ៥៩០ជើង

- អន្តរជាតិចំនួន១០០ ៤៩០ជើង ១៤១ ៥០០ជើង

- ហោះហើរឆ្លងកាត់ចំនួន១៨៣ ៤៤៣ជើង ២៥០ ៥៩៤ជើង។

**ខ- ផ្នែកវិទ្យុទាក់ទង វិទ្យុនាំផ្លូវ និងវិទ្យុឃ្លាំមើល(CNS)**

- តម្លើងឧបករណ៍វិទ្យុឃ្លាំងមើលជំនាន់ចុងក្រោយ ដែលមានឈ្មោះថា Multilateration និង ADS-B Ground Station(MADS) ចំនួន១០ស្ថានីយ ដែលចែកចេញជាពីរចង្កោម(Cluster2) មានដូចជាចង្កោមទី១(cluster1) ស្ថិតនៅរាជធានីភ្នំពេញ មាន៥ស្ថានីយ ដែលមានទីតាំងនៅក្រុមហ៊ុនសេវាកម្មអាកាសចរ(CATS) ចាក់អង្រែលើស្តាតចាស់ អូឌឹម និងកប់ស្រូវ។ ចំណែកឯចង្កោមទី២(cluster2) អាកាសយានដ្ឋានខេត្ត សៀមរាប ស្រុកពួក ភ្នំក្រោម ភូមិលាងដៃ និងស្រុកត្រពាំងស្វាយ។ ចង្កោមទាំងពីរនេះប្រើដើម្បីគ្របដណ្តប់យន្តហោះហើរក្នុងតំបន់ Terminal Area(TMA)នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងខេត្តសៀមរាបដែលមានចម្ងាយអតិបរមា ៥0Nautical Mile

- តម្លើង Satellite Receiver FY-2 ដើម្បីទទួលទិន្នន័យឧតុនិយម ពីផ្កាយរណបនៅអាកាសដ្ឋានអន្តរជាតិភ្នំពេញ១ស្ថានីយ ដែលជាជំនួយរបស់អាកាសចរណ៍ស៊ីវិលចិន

- តម្លើងឧបករណ៍ឧតុនិយម Satellite Distribution System File Transfer Protocol- SADIS-FTP(GST) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ តម្លើងដោយមន្ត្រីជំនាញអាម៉េរិកនិងសហការជាមួយមន្ត្រីនាយកដ្ឋាន(ឧបករណ៍ទិញដោយ SSCA)

- ចុះអនុស្សរណៈយោគយល់គ្នា MOU–Memorandum of Understanding ជាមួយអាកាសចរណ៍ស៊ីវិលចិនក្នុងការសហការការងារផ្តល់សេវាកម្មឧតុនិយមនៅក្នុងប្រទេសកម្ពុជា

- ចូលរួមប្រជុំឧតុនិយម ជាមួយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិInternational Civil Aviation Organization-ICAO ចំនួន១២លើក ដើម្បីពង្រឹងការផ្តល់សេវាកម្មនិងផ្នែកច្បាប់លើវិស័យឧតុនិយម

- ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ មន្ត្រីបច្ចេកទេសចំនួន៣រូប ចូលរួមប្រជុំពិភាក្សាលើករណីវិទ្យុផ្សាយសំឡេងFM 88.7 MHz 95.5 MHz និង107.5 MHz បានសាយភាយស៊ីញ៉ាលើឆ្លងរំខានចូលហ្វ្រេកង់ វិទ្យុទាក់ទងយន្តហោះ VHF Air Band នៅតំបន់ព្រំដែនអាកាសកម្ពុជាថៃ ក្នុងខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ

- ថ្ងៃទី១៦-២០ ខែកក្កដា ឆ្នាំ២០១៨ មន្ត្រីបច្ចេកទេសចំនួន២រូប ចូលរួមប្រជុំនៅទីក្រុង បាងកក(Bangkok) ប្រទេសថៃ ដែលកិច្ចប្រជុំស្តីពីក្រុមការងារ វិទ្យុទាក់ទង នាំផ្លូវ ឃ្លាំមើលលើកទី២២

- ថ្ងៃទី២០-២១ ខែសីហា ឆ្នាំ២០១៨ មន្ត្រីបច្ចេកទេសចំនួន៣រូប ចូលរួមស្តីពីការដោះស្រាយការរំខានហ្វ្រេកង់របស់វិទ្យុបញ្ជាយន្តហោះ និងវិទ្យុយន្តហោះ ជាមួយមន្ត្រីបច្ចេកទេសរបស់ក្រសួងព័ត៌មាន

- បន្តដោះស្រាយបញ្ហាហ្វ្រេកង់ឆ្លងរំខានចូលវិទ្យុទាក់ទងរបស់យន្តហោះ និងវិទ្យុទាក់ទងប៉មបញ្ជាហោះហើររយៈខ្លី មធ្យម និងរយៈឆ្ងាយពីសំណាក់ស្ថានីយផ្សាយសំឡេងវិទ្យុFM ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងព័ត៌មាននិងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បំពាក់ឧបករណ៍វិទ្យុនាំផ្លូវនិងវាស់ចម្ងាយDVOR1150/DME1119ថ្មី នៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ

- បន្តដោះស្រាយបញ្ហាហ្វ្រេកង់ឆ្លងរំខានចូលវិទ្យុទាក់ទងរបស់យន្តហោះ និងវិទ្យុទាក់ទងប៉មបញ្ជាហោះហើររយៈខ្លី មធ្យម និងរយៈឆ្ងាយពីសំណាក់ស្ថានីយផ្សាយសំឡេងវិទ្យុFM ដោយមានកិច្ច សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- ថ្ងៃទី១០-១២ ខែមីនា ឆ្នាំ២០២០ បានចូលរួមប្រជុំស្តី«**ការប្រើប្រាស់ប្រេកង់តាមបណ្តោយព្រំដែនថៃកម្ពុជា**» នៅទីក្រុងបាងកក ប្រទេសថៃ

- ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានចុះហត្ថលេខាអន្តរក្រសួងរវាងមន្ត្រីទទួលបន្ទុកអាកាសចរស៊ីវិល រដ្ឋមន្ត្រីក្រសួងព័ត៌មាននិងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លើប្រកាសរួមស្តីពីវិធានការទប់ស្កាត់ និងលុបបំបាត់ការឆ្លងរំខានចូលប្រេកង់ប្រព័ន្ធឧបករណ៍វិទ្យុនាំផ្លូវអាកាសនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា

- ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ តាមប្រព័ន្ធអនឡាញ។

**គ- ផ្នែកឧតុនិយម** ( Aviation Meteorological Service )

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ ការផ្តល់សេវាកម្មអង្កេត និងព្យាករណ៍អាកាសធាតុ សម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ សរុបមានចំនួន៣២៧ ៣០០ដង។

- ការអង្កេតអាកាសធាតុ( METARs ) ចំនួន២៥៩ ២០០ដង
- ការផ្តល់ព័ត៌មានព្យាការណ៍អាកាសធាតុ ( TAFs ) ចំនួន៦៥ ៧០០ដង
- ការផ្តល់ព័ត៌មានព្យាករណ៍បាតុភូតអាកាសធាតុលើផ្លូវហោះហើរអន្តរជាតិ(SIGMETs) ចំនួន២ ៤០០ដង។

## ២- ថាមពល

**ក្រសួងរ៉ែនិងថាមពល សម្រេចការងារដូចខាងក្រោម៖**

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលតម្រូវឱ្យក្រសួងរ៉ែនិងថាមពលអនុវត្តការងារពាក់ព័ន្ធការអភិវឌ្ឍវិស័យឧស្សាហកម្មនិស្សារណកម្ម ( រ៉ែនិងប្រេងកាត ) ជាមួយនឹងការគ្រប់គ្រងធនធានទាំងនេះប្រកបដោយចីរភាពនិងប្រសិទ្ធភាព និងការគ្រប់គ្រង និងអភិវឌ្ឍវិស័យថាមពល ជាពិសេសថាមពលអគ្គិសនីដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងជាចលករនៃឃ្នាស់សេដ្ឋកិច្ចជាតិទាំងមូល។ ( ១ ) វិស័យថាមពលស្ថិតក្នុងចតុកោណទី២ មុំទី១ អាទិភាពទី៣«**ការបន្តបញ្ចុះថ្លៃអគ្គិសនី ពង្រីកបណ្តាញគ្រប់ដណ្តប់ និងការបង្កើនស្ថិរភាពអគ្គិសនីដោយសាងសង់អនុស្ថានីយបន្ថែមឱ្យដល់តំបន់ប៉ូលសេដ្ឋកិច្ចនិងតំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់**» ក្នុងចតុកោណទី៣ មុំទី១ អាទិភាពទី៧«**ការបន្តពង្រីកការតបណ្តាញអគ្គិសនីដោយតម្លៃទាបជូនកម្មករ និយោជិត សិស្ស និស្សិតនៅតាមផ្ទះជួល**» ក្នុងចតុកោណទី៤ មុំទី១ អាទិភាពទី១០«**ការបន្តជំរុញការអភិវឌ្ឍន៍ជនបទឱ្យរស់រវើក ដោយបន្តពង្រីកការគ្របដណ្តប់ការប្រើប្រាស់អគ្គិសនី**» និងមុំទី៤ អាទិភាពទី៨«**ការបន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើថាមពលស្អាត និងថាមពលកកើតឡើងវិញ ជាពិសេសថាមពលពន្លឺព្រះអាទិត្យទន្ទឹមនឹងការកាត់បន្ថយការ ផលិតថាមពលប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈពេលវែង**»។ រីឯ ( ២ )វិស័យរ៉ែស្ថិតក្នុងចតុកោណទី៤ មុំទី២ អាទិភាពទី១«**ជំរុញការអនុវត្ត(គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨) ដោយពង្រឹងអភិបាលកិច្ចនិងការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន សង្គម និងពង្រឹងការប្រមូលចំណូលថវិកាជាតិ**» និងអាទិភាពទី២«**ការពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មខ្សាច់**

**ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម»**។ ចំពោះ (៣) វិស័យប្រេងកាត ស្ថិតក្នុងចតុកោណទី២ មុំទី២ អាទិភាពទី៦«**ការជំរុញការអភិវឌ្ឍវិស័យប្រេងកាតនិងឧស្ម័នជាពិសេសការដាក់ដំណើរការអណ្តូងប្រេងដំបូងឱ្យបានឆាប់ ទន្ទឹមគ្នានឹងការពង្រឹងការគ្រប់គ្រងចំណូល ដែលបានមកពីធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព»**។

### ១- វិស័យថាមពល

ក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ការអភិវឌ្ឍវិស័យថាមពលរបស់រាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា បានទទួលនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដូចខាងក្រោម៖

#### ១.១- តម្លៃអគ្គិសនី និងការងារសង្គមកិច្ច

**ក- ការបន្ថយថ្លៃ និងការអនុគ្រោះថ្លៃអគ្គិសនី**

ក្នុងរយៈពេល៥ឆ្នាំ ចាប់តាំងពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានខិតខំបន្ថយ និងអនុគ្រោះថ្លៃអគ្គិសនីជាបន្តបន្ទាប់។ តាមរយៈការខិតខំនេះអត្រាថ្លៃអគ្គិសនីដែលត្រូវបានផ្គត់ផ្គង់ឱ្យទៅអ្នកប្រើប្រាស់នៅទូទាំងប្រទេស ត្រូវបានកាត់បន្ថយដូចខាងក្រោម៖

១- ទិញពីទ្វារចរន្តតង់ស្យុងខ្ពស់ ត្រូវបានកាត់បន្ថយពី០,១២៤០$/kWh នៅឆ្នាំ២០១៧ មក០,១១៧០ $/kWh នៅឆ្នាំ២០២១។

២-ទិញពីទ្វារចរន្តតង់ស្យុងមធ្យម ត្រូវបានកាត់បន្ថយពី០,១២៦០$/kWh នៅឆ្នាំ២០១៧ មក ០.១២១០$/kWh នៅឆ្នាំ២០២១។

៣-ឧស្សាហកម្មនិងកសិកម្មភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវបានកាត់បន្ថយពី០,១៦៥០$/kWh នៅឆ្នាំ២០១៧ មក០,១៣៧០$/kWh នៅឆ្នាំ២០២១។

៤- ពាណិជ្ជកម្មនិងរដ្ឋបាលភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវបានកាត់បន្ថយពី០,១៦៥០$/kWh នៅឆ្នាំ២០១៧ មក០,១៥៨០$/kWh នៅឆ្នាំ២០២១។

៥- ឧស្សាហកម្មនិងកសិកម្មភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយ ត្រូវបានកាត់បន្ថយពី០,១៧១៩$/kWh នៅឆ្នាំ២០១៧ មក០,១៤២៤៨$/kWh នៅឆ្នាំ២០២១។

៦- ពាណិជ្ជកម្មនិងរដ្ឋបាលភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយ ត្រូវបានកាត់បន្ថយពី០,១៧១៩$/kWh នៅឆ្នាំ២០១៧ មក០,១៦៤៣$/kWh នៅឆ្នាំ២០២១។

៧-អ្នកប្រើប្រាស់ទូទៅទិញពីខ្សែបណ្តាញចែកចាយតង់ស្យុងទាប ត្រូវបានកាត់បន្ថយពី៧៧០រៀល/kWh នៅឆ្នាំ២០១៧ មក៧៣០រៀល/kWh នៅឆ្នាំ២០២១។

ដើម្បីសម្រេចបានការកាត់បន្ថយថ្លៃអគ្គិសនីខាងលើ រដ្ឋាភិបាលបានចំណាយថវិកា១ ៤៦៥,៨ពាន់លានរៀល ស្មើនឹង៥ ៥២៥,៤លានគីឡូវ៉ាត់ម៉ោង ក្នុងការអនុវត្តឧបត្ថម្ភធនដល់គ្រួសារក្រីក្រនៅតំបន់ជនបទចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០។

**ខ- ការងារសង្គមកិច្ចក្នុងវិស័យថាមពល**

រាជរដ្ឋាភិបាលបានបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ(ម.អ.ជ.) ចំណុះក្របខ័ណ្ឌអគ្គិសនីកម្ពុជា ដើម្បីជួយផ្តល់នូវកម្មវិធីគាំពារសង្គមក្នុងវិស័យថាមពល ដែលក្នុងរយៈពេល៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៧ ដល់

ឆ្នាំ២០២១ ម.អ.ជ.បានអនុវត្តកម្មវិធី រួមមាន ១- ផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ ដើម្បីជួយដល់គ្រួសារក្រីក្របង់ថ្លៃសេវាភ្ជាប់ចរន្តអគ្គិសនី ថ្លៃប្រាក់កក់ឱ្យអ្នកផ្គត់ផ្គង់ ចំណាយលើការទិញនិងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះ និងចំណាយលើការរៀបចំខ្សែបណ្តាញនិងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ប្រាក់កម្ចីនេះគឺមិនលើសពី៤៨០ ០០០រៀល ក្នុងមួយគ្រួសារ ដែលមានគ្រួសារជនបទចំនួន៨៥១គ្រួសារ ស្មើនឹង៣ ៩១៥នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ក្រោមកម្មវិធីនេះ ២- កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់ថវិកាឧបត្ថម្ភធនសម្រាប់ការចំណាយលើសម្ភារៈ និងឈ្នួលពលកម្ម ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ កម្មវិធីនេះ មានគ្រួសារជនបទក្រីក្រ ចំនួន២០ ៣១៩គ្រួសារ ស្មើនឹង៩៣ ៤៩៨នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ ៣- កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ដោយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន១០០ដុល្លារអាម៉េរិក ក្នុងមួយប្រព័ន្ធ ដល់គ្រួសារជនបទដែលបានទិញប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ កម្មវិធីនេះ មានគ្រួសារជនបទចំនួន៦៩ ២៧៤គ្រួសារ(១គ្រួសារ ១ប្រព័ន្ធ) ស្មើនឹង៣១៨ ៦៦០នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់នៅក្នុងភូមិចំនួន៦៩៧ និង៤- កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនី ដើម្បីបូមទឹកធ្វើកសិកម្ម និងអ្នកប្រើប្រាស់ផ្សេងទៀតក្នុងវិស័យកសិកម្ម នូវតម្លៃអនុគ្រោះត្រឹមតែ៤៨០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងសម្រាប់ការប្រើប្រាស់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក។ មកទល់ពេលនេះបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដើម្បីបូមទឹកក្នុងវិស័យកសិកម្មដល់អ្នកកាន់អាជ្ញាបណ្ណចំនួន១៥តំបន់ សរុបបានប្រវែង៥៣៨គ.ម. រួមមានខ្សែបណ្តាញតង់ស្យុងមធ្យម ប្រវែង២៣៣គ.ម. និងខ្សែចែកចាយតង់ស្យុងទាបប្រវែង៣០៥គ.ម. ដែលគ្របដណ្តប់លើខេត្តចំនួន៦បានទទួលផលប្រយោជន៍ដោយផ្ទាល់។

បន្ថែមពីលើនោះរាជរដ្ឋាភិបាល ក៏បានធ្វើការអនុគ្រោះថ្លៃលក់អគ្គិសនីឱ្យលំនៅឋានដែលប្រើប្រាស់ថាមពល មិនលើសពី១០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ឱ្យបង់ថ្លៃ៣៨០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង លំនៅឋានដែលប្រើប្រាស់ពី១១ ដល់៥០គីឡូវ៉ាត់ម៉ោង ក្នុងមួយខែ ឱ្យបង់ថ្លៃ៤៨០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង និងលំនៅឋានដែលប្រើប្រាស់ពី៥១ ដល់២០០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ឱ្យបង់ថ្លៃ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅជនបទឱ្យបង់ថ្លៃត្រឹមតែ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ ដើម្បីរួមចំណែកលើកស្ទួយក្នុងវិស័យការងារ រាជរដ្ឋាភិបាលបានជំរុញការពង្រីកខ្សែបណ្តាញអគ្គិសនីដោយតម្លៃទាបជូនកម្មករនិយោជិត សិស្ស និស្សិត នៅតាមផ្ទះជួល បន្ទប់ជួលដោយគិតមកដល់ត្រឹមចុងឆ្នាំ២០២១ បានចំនួន៣៤៩ ៨៥៨បន្ទប់ជួល។

### ១.២- ការពង្រីកតំបន់គ្របដណ្តប់

#### ក- ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី

ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី(បណ្តាញជាតិ) មានហេដ្ឋារចនាសម្ព័ន្ធសំខាន់ចំនួន៣ គឺបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ អនុស្ថានីយ និងមជ្ឈមណ្ឌលបញ្ជា។ ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានធ្វើឱ្យខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់កម្ពុជាកើនឡើងពី១ ៩៥៧គ.ម. នៅឆ្នាំ២០១៧ រហូតដល់៣ ៥៥៣គ.ម. នៅឆ្នាំ២០២១ កំណើនប្រមាណ៨១,៦% និងធ្វើឱ្យចំនួនអនុស្ថានីយ កើនឡើងពី៣០កន្លែង នៅឆ្នាំ២០១៧ រហូតដល់៥៥កន្លែង នៅឆ្នាំ២០២១ កំណើនប្រមាណ៨៣,៣% ដែលធ្វើឱ្យការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិគ្របដណ្តប់ត្រឹមតែ១៩រាជធានី ខេត្តនៅឆ្នាំ២០១៧ ឡើងដល់២៤រាជធានីខេត្ត នៅឆ្នាំ២០២១(នៅសល់ខេត្តប៉ៃលិនមួយប៉ុណ្ណោះ) ដែលកំណើននេះបានបង្កើនស្ថិរភាព គុណភាព និងនិរន្តរភាព

នៃការផ្គត់ផ្គង់អគ្គិសនី។ តាមរយៈកម្មវិធីជួយទុនសម្រាប់ពង្រីកនិងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ មានអ្នកកាន់អាជ្ញាបណ្ណចំនួន២៥៨ ស្មើនឹង៨៤៦៧,៦៩គ.ម. រួមមានខ្សែបណ្តាញតង់ស្យុងមធ្យមប្រវែង ២៨៨២,៥៩គ.ម. និងខ្សែចែកចាយតង់ស្យុងទាបប្រវែង៥ ៥៨៥,១០គ.ម. ដោយគ្របដណ្តប់ចំនួន២៣ខេត្ត បានទទួលផលប្រយោជន៍ដោយផ្ទាល់។

**ខ- ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនរងនិងប្រព័ន្ធចែកចាយអគ្គិសនី**

ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនរងនិងប្រព័ន្ធចែកចាយអគ្គិសនី ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានធ្វើឱ្យប្រវែងខ្សែបណ្តាញតង់ស្យុងមធ្យមកើនឡើងពី២៨ ៩៧៥គ.ម. នៅឆ្នាំ២០១៧ រហូតដល់៤១ ៤៨៨គ.ម. នៅឆ្នាំ២០២១ និងដែលធ្វើឱ្យប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងទាបកើនឡើងពី២៧ ៨៦២គ.ម. នៅឆ្នាំ២០១៧ រហូតដល់៤៣ ៩៤២គ.ម. នៅឆ្នាំ២០២១។ ការអភិវឌ្ឍខ្សែបណ្តាញបញ្ជូនរងនិងខ្សែបណ្តាញចែកចាយអគ្គិសនីដ៏លឿននេះ បានធ្វើឱ្យការគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិ បានកើនពី១១ ៥៥៨ភូមិ ត្រូវជា ៨១,៥៨% នៃចំនួនភូមិទូទាំងប្រទេស នៅឆ្នាំ២០១៧ ឡើងដល់១៣ ៨១៨ភូមិ ត្រូវជា៩៧,៥៣%នៃចំនួនភូមិទូទាំងប្រទេសនៅឆ្នាំ២០២១នេះ។ ការអភិវឌ្ឍខ្សែបណ្តាញបញ្ជូនរងនិងខ្សែបណ្តាញចែកចាយអគ្គិសនីដ៏លឿននេះក៏បានធ្វើឱ្យការភ្ជាប់ចរន្តឱ្យអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទកើនឡើងពី២ ៤០៩ ៩០៧ទីតាំង នៅឆ្នាំ២០១៧ រហូតដល់៣ ៣១៣ ៦០៧ទីតាំង នៅឆ្នាំ២០២១ ដែលនៅក្នុងនោះការភ្ជាប់ចរន្តឱ្យលំនៅឋានរបស់ប្រជាពលរដ្ឋបានកើនឡើងពី២ ៣១៥ ៩៣០ខ្នងផ្ទះ នៅឆ្នាំ២០១៧ រហូតដល់៣ ១២៣ ០៩៦ខ្នងផ្ទះ នៅឆ្នាំ២០២១។ តាមស្ថិតិចំនួនខ្នងផ្ទះសរុបទូទាំងប្រទេស៣,៦១លានខ្នងផ្ទះ ក្នុងនោះ ខ្នងផ្ទះដែលទទួលបានការផ្គត់ផ្គង់អគ្គិសនីនៅឆ្នាំ២០២១ មានចំនួន៨៦,៤៣%រួចហើយ។

ដោយឡែកភូមិពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីទៅដល់មានចំនួន៣៥០ភូមិ ស្មើនឹង២,៤៧% ជាភូមិដែលដាច់ស្រយាល គ្មានផ្លូវធ្វើដំណើរ ជាតំបន់កោះ ជាភូមិបណ្តែតទឹក និងជាតំបន់លិចទឹកនៅរដូវវស្សា ដែលពិបាកក្នុងការរៀបចំខ្សែបណ្តាញអគ្គិសនី ហើយបើទោះបីជាប្រភពបណ្តាញជាតិពុំទាន់ទៅដល់ ប៉ុន្តែនៅក្នុងភូមិដែលនៅសល់ទាំងនេះ លំនៅឋានប្រជាពលរដ្ឋមួយចំនួនមានអគ្គិសនីប្រើប្រាស់ជាបណ្តោះអាសន្នរួចហើយ តាមរយៈការផ្តល់ប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះ ក្នុងក្របខ័ណ្ឌជំនួយឧបត្ថម្ភនៃកម្មវិធីគាំពារសង្គមរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនិងការវិនិយោគផ្ទាល់ខ្លួន ហើយលំនៅឋានមួយចំនួនទៀត ក៏បានប្រើប្រាស់អាគុយដែលមានកន្លែងសាកអាគុយរួមនៅក្នុងភូមិដែរ។ ក្រសួងរ៉ែនិងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជានឹងរួមគ្នាបន្តដោះស្រាយតាមករណីនីមួយៗរហូតដល់បញ្ចប់។

### ១.៣- ការអភិវឌ្ឍប្រភពអគ្គិសនី

ទំហំប្រភពអគ្គិសនីសរុបដែលបានអភិវឌ្ឍទាំងក្នុងប្រទេស និងការនាំចូលពីប្រទេសជិតខាងបានកើនឡើងពី២ ៣២២មេហ្គាវ៉ាត់ នៅឆ្នាំ២០១៧ រហូតដល់៤ ០១៤មេហ្គាវ៉ាត់ នៅឆ្នាំ២០២១ ដែលស្មើនឹងកំណើន ៧២,៧៤% ធៀបទៅនឹងប្រភពអគ្គិសនីដែលមាននៅឆ្នាំ២០១៧។ ប្រភពអគ្គិសនីសរុបនៅឆ្នាំ២០២១នេះ មាន ៣ ០៣៣មេហ្គាវ៉ាត់ ក្នុងនោះ៧៥,៥៧% ជាប្រភពអគ្គិសនីដែលបានអភិវឌ្ឍក្នុងស្រុក និង២៤,៤៣% ជាប្រភពអគ្គិសនីដែលបាននាំចូលពីប្រទេសជិតខាង។

### ១.៤- ការងារគ្រប់គ្រង បច្ចេកទេសអគ្គិសនី និងបរិមាណវ៉ុលស៊ីវិល រួមទាំងវិទ្យុសកម្ម

ដើម្បីបង្កើនប្រសិទ្ធភាពការគ្រប់គ្រងបច្ចេកទេសអគ្គិសនីនិងប្រសិទ្ធភាពថាមពល ក្រសួងបានរៀបចំបទដ្ឋានបច្ចេកទេសអគ្គិសនី រួមមាន ១- ស្តង់ដារៀបចំខ្សែបណ្តាញនិងសុវត្ថិភាពអគ្គិសនីក្នុងអគារនិងលំនៅឋាន

និងបទដ្ឋាននៃការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលលើឧបករណ៍អគ្គិសនី ២- សេចក្តីណែនាំបច្ចេកទេសផលិតបង្គោលអគ្គិសនីតង់ស្យុងមធ្យមនិងតង់ស្យុងទាប ៣- សេចក្តីណែនាំបច្ចេកទេសនៃការប្រើប្រាស់ប្រភេទបង្គោលតាមទីតាំង និង៤- សេចក្តីណែនាំបច្ចេកទេសប្រើប្រាស់ខ្សែកាបកប់ក្រោមទឹក។ ក្រសួងរ៉ែនិងថាមពល សហការជាមួយADB ពិនិត្យនិងរៀបចំគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល និងរៀបចំការអនុវត្តគម្រោងពាក់ព័ន្ធនឹងប្រសិទ្ធភាព និងសន្សំសំចៃថាមពល។

ដោយឡែកការអភិវឌ្ឍនិងគ្រប់គ្រងការងារបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម ក្រសួងរ៉ែនិងថាមពលបានរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃថាមពលបរមាណូស៊ីវិល រួមមាន (១) ប្រកាសលេខ០១២៦ រថ.វបប.រថ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រងការនាំចូលនិងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម (២) សេចក្តីព្រាងច្បាប់បរមាណូនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាន៥០% និង(៣) សេចក្តីព្រាងបទដ្ឋានបច្ចេកទេសស្តីពីសុវត្ថិភាព វិទ្យុសកម្ម និងសន្តិសុខវិទ្យុសកម្ម សម្រេចបាន៣០%។ ក្នុងការគ្រប់គ្រងលើការងារបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម ក្រសួងបានចុះធ្វើការត្រួតពិនិត្យក៏ដូចជាស្រង់ទិន្នន័យលើការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថាមពលបរមាណូ រួមទាំងវិទ្យុសកម្មនៅតាមទីតាំងនានា ដូចជា ការដ្ឋានរ៉ែ រោងចក្រស៊ីម៉ងត៍ មន្ទីរពេទ្យ មន្ទីរពិសោធន៍ ជាដើម សរុបបានចំនួន៤៣ទីតាំង ហើយបានធ្វើការវាយតម្លៃថាការប្រើប្រាស់ទាំងនោះ គឺមានសុវត្ថិភាព សន្តិសុខ និងក្នុងគោលបំណង សន្តិភាពពិតប្រាកដ។ ទន្ទឹមនេះ ក្រសួងបានដឹកនាំ និងសម្របសម្រួលអនុវត្តគម្រោងបច្ចេកទេសជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិជាដៃគូរួមមានទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ(IAEA) សហគមន៍អឺរ៉ុប សហរដ្ឋអាម៉េរិកជាដើម ដោយទទួលបានជំនួយជាការបណ្តុះបណ្តាល និងឧបករណ៍ សម្ភារៈបច្ចេកទេស ថវិកាសរុបប្រមាណជា៨០០ ០០០ ទៅ១ ០០០ ០០០ អឺរ៉ូក្នុងមួយឆ្នាំ។ ក្នុងបរិបទនៃជំងឺកូវីដ-១៩ ក្រសួងបានស្នើសុំអង្គការជាដៃគូផ្តល់ជំនួយឧបករណ៍និងបរិក្ខារតេស្តមេរោគកូវីដ-១៩ ប្រភេទPCR ចំនួន៥ឈុត ថវិកាសរុប ប្រមាណជា៤០០ ០០០អឺរ៉ូ ជូនវិទ្យាស្ថានសុខភាពសាធារណៈនៃក្រសួងសុខាភិបាល(២ឈុត) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(១ឈុត) មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តសៀមរាប(១ឈុត) និងមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តពោធិ៍សាត់(១ឈុត)។

## ២- វិស័យរ៉ែ

ក្រសួងរ៉ែនិងថាមពលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំផែនការ និងអនុវត្តសកម្មភាពការងារដោយធានាឱ្យបាននូវចីរភាព កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដល់បរិស្ថាននិងសង្គម បង្កើនសុខដុមនីយកម្មរវាងសហគមន៍និងការដ្ឋានរ៉ែ និងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសសម្រេចបានតាមគោលបំណងនិងគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨ ព្រមទាំងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះវិស័យរ៉ែ គឺអភិវឌ្ឍន៍ធនធានរ៉ែដើម្បីជាប្រយោជន៍សេដ្ឋកិច្ចនិងសង្គមប្រកបដោយអភិបាលកិច្ចល្អនិងការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន។

### ២.១- ការពង្រឹងអភិបាលកិច្ចធនធានរ៉ែ

#### ក- ការកសាងលិខិតបទដ្ឋានគតិយុត្ត

ដើម្បីពង្រឹងអភិបាលកិច្ចលើការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានរ៉ែ នៅក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១)នេះ ក្រសួងរ៉ែនិងថាមពលបានកសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនរួមមាន (១) គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៣ (២) ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ (៣) ប្រកាសរួមស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាស

រួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែនិងថាមពល (៤) ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនិងបែបបទសម្រាប់ការនាំចេញផលិតផលរ៉ែ (៥ ) ប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ (៦) ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងនិងការប្រមូលចំណូលសួយសារធនធានរ៉ែពីការប្រើប្រាស់ធនធានរ៉ែសំណង់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ (៧) ប្រកាសអន្តរក្រសួងស្តីពីអត្រាសួយសារលើតម្លៃផលិតផលរ៉ែនិងនីតិវិធីនៃការបង់ថ្លៃសួយសារ (៨) ប្រកាសអន្តរក្រសួងស្តីពីការបង្កើតមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន (៩) ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការរ៉ែ មានលក្ខណៈជាសិប្បកម្មនិងខ្នាតតូចទៅឱ្យរដ្ឋបាលរាជធានី ខេត្ត (១០) ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានធនធានរ៉ែ (១១) ប្រកាសស្តីពីការចាត់តាំងក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើរាល់ប្រតិបត្តិការធនធានរ៉ែនិងសកម្មភាពពាក់ព័ន្ធ (១២) ប្រកាសស្តីពីវិធាននៃអធិការកិច្ចធនធានរ៉ែសម្រាប់ប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ អាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មអាជ្ញាបណ្ណស្វែងរុករករ៉ែ និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ (១៣) ប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី (១៤) ប្រកាសស្តីពីបែបបទនិងនីតិវិធី នៃការធ្វើអធិការកិច្ចធនធានរ៉ែសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី (១៥) ប្រកាសស្តីពីការកំណត់យថាប្រភេទផលិតផលរ៉ែថ្មអារ (១៦) សារាចរស្តីពីការគ្រប់គ្រងផលិតកម្មអាជីវកម្មថ្មអារ សេចក្តីណែនាំស្តីពីការអនុវត្តមុខងារក្នុងការផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែ និងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (១៧) គោលការណ៍ណែនាំស្តីពីគោលការណ៍និងនីតិវិធីនៃការប្រើប្រាស់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន។

**ខ- ការរៀបចំមន្ត្រីនគបាលយុត្តិធម៌**

ដើម្បីជំរុញឱ្យការត្រួតពិនិត្យពង្រឹងភាពអនុលោម និងបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ក្រសួងរ៉ែនិងថាមពល បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការនិងរៀបចំនីតិវិធីផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីអធិការកិច្ចធនធានរ៉ែទាំងថ្នាក់កណ្តាល និងមន្ទីររ៉ែនិងថាមពលរាជធានី ខេត្តចំនួន២៤៥នាក់ តាមរយៈប្រកាសអន្តរក្រសួងលេខ០៤៧ កយ.រថ.ប្រក/២០ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌។

## ២.២- ការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ

**ក- ការគ្រប់គ្រងធនធានរ៉ែ**

ក្រសួងរ៉ែនិងថាមពល បានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការទប់ស្កាត់និងបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យ ព្រមទាំងធ្វើការត្រួតពិនិត្យនិងអធិការកិច្ចជាប្រចាំលើការធ្វើប្រតិបត្តិការធនធានរ៉ែគ្រប់ប្រភេទ ដើម្បីឱ្យការធ្វើប្រតិបត្តិការធនធានរ៉ែមានអនុលោមភាពតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងគោលដៅកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គមឱ្យបានជាអតិបរមា ព្រមទាំងផ្តល់ជាប្រយោជន៍ដល់សេដ្ឋកិច្ចនិងការអភិវឌ្ឍប្រទេស។ ដើម្បីសម្រេចតាមគោលបំណងខាងលើ ក្រសួងរ៉ែនិងថាមពលបានដាក់ចេញនូវយន្តការក្នុងការពង្រឹងភាពអនុលោមក្នុងវិស័យរ៉ែដូចខាងក្រោម៖

- ការពិនិត្យវាយតម្លៃមុននឹងផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ដោយធ្វើការពិចារណា ថ្លឹងថ្លែង និងវាយតម្លៃលើកត្តាសំខាន់ចម្បងចំនួន៣ គឺ ១- សេដ្ឋកិច្ច គឺជាការវាយតម្លៃសក្តានុពលធនធានរ៉ែ ដែលអាចធ្វើអាជីវកម្ម និង

ផលសេដ្ឋកិច្ចពីការធ្វើប្រតិបត្តិការធនធានរ៉ែ ២- បរិស្ថាន កាត់បន្ថយផលប៉ះពាល់បរិស្ថានឱ្យនៅជាអប្បបរមា និងយន្តការការពារទប់ស្កាត់ផលប៉ះពាល់បរិស្ថានឱ្យបានជាអតិបរមា ចាប់ពីដំណាក់កាលការទាញយករ៉ែ រហូតដល់ដំណាក់កាលការបិទការដ្ឋានរ៉ែ និង៣- សង្គម សំដៅដល់ការគិតគូរពីការទប់ស្កាត់ផលប៉ះពាល់សង្គម និងធ្វើយ៉ាងណាឱ្យការធ្វើប្រតិបត្តិការធនធានរ៉ែ បានផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋនៅនឹងមូលដ្ឋាន។

- រៀបចំក្រុមការងារត្រួតពិនិត្យនិងអធិការកិច្ចប្រតិបត្តិការធនធានរ៉ែ ចំនួន៤ក្រុម ទៅតាមប្រភេទនៃការធ្វើអាជីវកម្មរ៉ែដូចជា ការធ្វើអាជីវកម្មធនធានរ៉ែឧស្សាហកម្ម ការធ្វើអាជីវកម្មរ៉ែខ្សាច់តាមដងទន្លេ ស្ទឹង និងសមុទ្រ ការធ្វើអាជីវកម្មរ៉ែអាចម៍ដីនិងខ្សាច់បក និងការធ្វើអាជីវកម្មរ៉ែថ្មសំណង់គ្រប់ប្រភេទ។ ក្រុមការងារនីមួយៗត្រូវបានដឹកនាំដោយរដ្ឋលេខាធិការនិងមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីធ្វើការទប់ស្កាត់ និងបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យ។ ជាលទ្ធផល ក្រុមការងារបានធ្វើការចុះបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែមាសអនាធិបតេយ្យនៅតំបន់ចុងផ្លាស់ខេត្តមណ្ឌលគិរី ភ្នំជីខេត្តកំពង់ធំ និងភ្នំលុងខេត្តព្រះវិហារ។ល។ ជាពិសេសទៅទៀតនោះ សកម្មភាពអាជីវកម្មរ៉ែខ្សាច់តាមដងទន្លេ ដែលកាលពីមុនឆ្នាំ២០១៥ មានស្ទើរតែពេញផ្ទៃទន្លេមេគង្គ ប៉ុន្តែនាពេលបច្ចុប្បន្ននេះ សកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យខ្សាច់តាមដងទន្លេត្រូវបានបង្ក្រាបទាំងស្រុង។

- មន្ត្រីជំនាញ ក្រសួងរ៉ែនិងថាមពល បានចុះត្រួតពិនិត្យការធ្វើប្រតិបត្តិការធនធានរ៉ែជាប្រចាំ ដើម្បីធានាថា ការធ្វើអាជីវកម្មមានភាពអនុលោមតាមបទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តនានា ក្នុងគោលដៅទប់ស្កាត់ផលប៉ះពាល់បរិស្ថាននិងសង្គម និងប្រសិទ្ធភាពនៃការកៀរគរការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១កន្លងទៅ ការចុះត្រួតពិនិត្យភាពអនុលោមបានប្រមូលចំណូលបន្ថែមចំនួនប្រមាណជិត៥លានដុល្លារ និងបានពិន័យជាប្រាក់ចំនួន២០០លានរៀល។

### ខ- អាជីវកម្មធនធានរ៉ែ

ដើម្បីគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសំណង់តូចធំនានា និងចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិនៅក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១)នេះ ការធ្វើអាជីវកម្មរ៉ែសំណង់និងរ៉ែឧស្សាហកម្មបានផលិតបរិមាណផលិតផលរ៉ែដូចខាងក្រោម៖

| ល.រ | ផលិតផលរ៉ែ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|
| ១ | ខ្សាច់សំណង់ | លានម.៣ | ០,៩៨ | ១,៨២ | ២,០១ |
| ២ | ដីល្បាយខ្សាច់ | លានម.៣ | ២,៧៦ | ៦,៣០ | ៧,៧១ |
| ៣ | ខ្សាច់បក | លានម.៣ | ១,៨៩ | ១,៤១ | ១,៧៨ |
| ៤ | ក្រួស | ពាន់ម.៣ | ១៦,៧២ | ៣៨ | ៣៨,៤០ |
| ៥ | ថ្មបំបែក | លានម.៣ | ១,៤៨ | ២,៣៧ | ៤,៧៥ |
| ៦ | អាចម៍ដី | ពាន់ម.៣ | ១ ៤៥៤,៧០ | ៦ ៥៧២,៩៤ | ៨ ១៥២,៥៧ |
| ៧ | ដីក្រហម | ពាន់ម.៣ | ១ ៤៥៤,៧០ | ១ ៣០០,៩៤ | ២ ២០១,៩០ |
| ៨ | ថ្មអារ | ម.៣ | ១៣៧ ៤០០ | ៦៩ ៥៣២ | ១៣៥ ២៣៧ |
| ៩ | ថ្មភក់ | ម.៣ | ៧៦៦ | ១ ១៥០ | ២ ២១១ |
| ១០ | ថ្មកែវ | ម.៣ | ៣៧៥ | ៦០០ | ៥៤២ |
| ១១ | មាស | គ.ក. | - | - | - |
| ១២ | ម្សៅរ៉ែមាស | គ.ក. | - | ៦៣៨,២៤ | ១ ៧៨២ |

| | | | | | |
|---|---|---|---|---|---|
| ១៣ | ធ្យូងថ្ម | តោន | ៥៥ ៩៩១,៨៥ | ៣៤ ១៧២,០៦ | ១៣ ៥៩៨ |
| ១៤ | ថ្មកំបោរ | ពាន់តោន | | ៥ ៤៦២,៥៦ | ៩ ៥៧៥,៤២ |
| ១៥ | ស៊ីម៉ងត៍ | ពាន់តោន | ៣ ៣៩៩,៧០ | ៥ ៩៦៦,៥១ | ៧ ៩០០,៥៣ |
| ១៦ | ថ្មសន្លឹកនាំចេញ | ម.$^{២}$ | ៤៦ ៩០០ | ១២៦ ៨៤៤,៩៦ | ៥១ ៩១៦,៤៤ |
| ១៧ | ថ្មប្លុកនាំចេញ | ម.$^{៣}$ | ១ ០១២ | ២៨៣,៦៧ | ៤ ១៦៣,២២ |

| ល.រ | ផលិតផលរ៉ែ | ឯកតា | ២០២០ | ២០២១ (៩ខែ) | សរុប |
|---|---|---|---|---|---|
| ១ | ខ្សាច់សំណង់ | លានម.$^{៣}$ | ៣,០១ | ២,៨៤ | ១០,៦៧ |
| ២ | ដីល្បាយខ្សាច់ | លានម.$^{៣}$ | ៩,៣១ | ១២,១៨ | ៣៨,២៨ |
| ៣ | ខ្សាច់បក | លានម.$^{៣}$ | ១,៩៥ | ២,៤១ | ៩,៤៥ |
| ៤ | ក្រួស | ពាន់ម.$^{៣}$ | ៣៦,៥០ | ៣៦,៥០ | ១៦៦,១២ |
| ៥ | ថ្មបំបែក | លានម.$^{៣}$ | ៣,៦៧ | ៥,២៣ | ១៧,៥២ |
| ៦ | អាចម៍ដី | ពាន់ម.$^{៣}$ | ៨ ១៨៦ | ១០ ៣៨៦ | ៣៤ ៧៥២,២២ |
| ៧ | ដីក្រហម | ពាន់ម.$^{៣}$ | ១ ១៧៥,២៤ | ១ ៣១១ | ៧ ៤៤៣,៧៩ |
| ៨ | ថ្មអារ | ម.$^{៣}$ | ៤០៨ ៦៤០ | ៤៧៨ ៧២០ | ១ ២២៩ ៥២៩,០០ |
| ៩ | ថ្មភក់ | ម.$^{៣}$ | ៣ ៦៥០ | ៥ ៦០០ | ១៣ ៣៧៧,០០ |
| ១០ | ថ្មកែវ | ម.$^{៣}$ | ២០០ | ២២០ | ១ ៩៣៧,០០ |
| ១១ | មាស | គ.ក. | - | ៧៤៧,២៦ | ៧៤៧,២៦ |
| ១២ | ម្សៅរ៉ែមាស | គ.ក. | ១៦២ | - | ២.៥៨២,២៤ |
| ១៣ | ធ្យូងថ្ម | តោន | ១៩ ០៧៨,២៦ | ១៧ ៥២៨,៧០ | ១៤០ ៣៦៨,៤៧ |
| ១៤ | ថ្មកំបោរ | ពាន់តោន | ១០,៤៧ | ៨ ២៤២,៦២ | ៣៣ ៧៥៥,៤៥ |
| ១៥ | ស៊ីម៉ងត៍ | ពាន់តោន | ៨ ៥០៦,១០ | ៦ ៨៥៥,១៩ | ៣២ ៦២៨,០៥ |
| ១៦ | ថ្មសន្លឹកនាំចេញ | ម.$^{២}$ | ៣៣៦ ០២០,៣៤ | ១៦៨ ២០២,០៨ | ៧២៩ ៨៨៣,៨២ |
| ១៧ | ថ្មប្លុកនាំចេញ | ម.$^{៣}$ | ៥១ ៣៥០,៥៤ | ៣៧៣ ៤៥៩,៨៧ | ៤៣០ ២៦៩,៣០ |

*****ផលិតផលថ្មកំបោរក្នុងឆ្នាំ២០១៧ពុំបានកត់ត្រាទុក ដោយសារក្រុមហ៊ុនបង់លើបរិមាណផលិតផលសម្រេចស៊ីម៉ង់ត៍តែម្តង។**

## ២.៣- ការការពារបរិស្ថាននិងសង្គម

ការទប់ស្កាត់ និងការពារផលប៉ះពាល់បរិស្ថាននិងសង្គម ត្រូវបានពិនិត្យវាយតម្លៃចាប់តាំងពីមុនផ្តល់អាជ្ញាបណ្ណរហូតដល់បិទបញ្ចប់ការដ្ឋាន។ ដើម្បីធានាថាការធ្វើប្រតិបត្តិការធនធានរ៉ែមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមតិចតួចបំផុតនោះ ក្រសួងរ៉ែនិងថាមពល បានតម្រូវឱ្យសម្បទានិកត្រូវធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) និងរៀបចំវេទិការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន មុននឹងផ្តល់អាជ្ញាបណ្ណអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែ។ បន្ថែមលើនេះ ការត្រួតពិនិត្យវាយតម្លៃភាពអនុលោមជាប្រចាំលើការធ្វើប្រតិបត្តិការធនធានរ៉ែ និងការកំណត់អំពីគោលការណ៍នៃការស្តារការដ្ឋានរ៉ែក្រោយបញ្ចប់ការធ្វើប្រតិបត្តិការធនធានរ៉ែក៏ជាការងារអាទិភាព ដែលក្រសួងរ៉ែនិងថាមពល បានយកចិត្តទុកដាក់និងអនុវត្តយ៉ាងសកម្មផងដែរ ដើម្បីធានាអំពីប្រសិទ្ធភាពនៃការទប់ស្កាត់ផលប៉ះពាល់បរិស្ថាននិងសង្គម។ ទន្ទឹមនឹងយន្តការទាំងអស់ខាងលើនេះ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល បានផ្តួចផ្តើមបង្កើតមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន(មូលនិធិរ៉ែ) នៅក្នុងឆ្នាំ២០១៥ ក្នុងគោលដៅប្រើប្រាស់ជាប្រយោជន៍

ដល់ការអភិវឌ្ឍសហគមន៍មូលដ្ឋានដែលបានទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលពីការធ្វើប្រតិបត្តិការធនធានរ៉ែ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១នេះ ចំនួន៧ ០៦៣ ១០៥,៤៧(ប្រាំពីរលានហុកសិបបីពាន់មួយរយប្រាំកៀសសែសិបប្រាំពីរ)ដុល្លារអាមេរិក ហើយបានបញ្ចប់ការអភិវឌ្ឍសហគមន៍មូលដ្ឋានចំនួន២៧គម្រោង និងអនុម័តគម្រោងស្នើសុំអភិវឌ្ឍន៍សហគមន៍ចំនួន២៤គម្រោងបន្ថែម សរុបចំនួន៥១គម្រោងត្រូវបាននិងកំពុងបន្តអនុវត្ត ដែលមានថវិកាចំណាយនិងគ្រោងសរុបចំនួន២ ៦៨១ ០៩៩,៣១(ពីរលានប្រាំមួយរយប៉ែតសិបមួយពាន់កៅសិបប្រាំបួនកៀសសាមសិបមួយ)ដុល្លារអាមេរិក។

## មុំទី២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ

### ១- ការកៀរគរចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ

#### ការពង្រឹងការប្រមូលចំណូល

ក្រសួងរ៉ែនិងថាមពល បានកៀរគរចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែបាន៥៨ ២៥០,៩៨លានរៀល ក្នុងឆ្នាំ២០១៧ កើនដល់៩៨ ៤៦០ លានរៀលនៅឆ្នាំ២០២១(៩ខែ) កំណើន២៥% ធៀប៥ឆ្នាំ២០១៣-២០១៧។




**ចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែរយៈពេល៥ឆ្នាំ(២០១៣ ដល់២០១៧) ធៀបជាមួយនឹង៥ឆ្នាំ(២០១៧ ដល់៩ខែឆ្នាំ២០២១)**

**ឯកតា:លានរៀល**

| ល.រ. | បរិយាយ | អនុវត្តជាក់ស្តែង២០១៣-២០១៧ | អនុវត្តជាក់ស្តែង២០១៧-៩ខែ ដើមឆ្នាំ២០២១ | ធៀប |
|---|---|---|---|---|
| | | ១ | ១ | ៣=២/១ |
| ១ | សួយសារធនធានរ៉ែ | ១០៤ ៩០៩,៦៣ | ៣៥០ ១៥៧,៨១ | ៣៣៤% |
| ២ | កម្រៃអាជ្ញាបណ្ណ | ៨ ១០១,១៨ | ១៤ ១៣៤,៥៥ | ១៧៤% |
| ៣ | កម្រៃចុះបញ្ជី | ១៥៩,១៩ | ៨៩ | ៥៦% |
| ៤ | ថ្លៃផ្ទេរសិទ្ធិអាជ្ញាបណ្ណធនធានរ៉ែ | ១ ៥០៣ | ២ ៤៤០ | ១៦២% |
| ៥ | ចំណូលពីការទទួលស្គាល់សមាសភាពភាគហ៊ុន | ៧៩០ | ១ ១២៥ | ១៤២% |
| ៦ | ចំណូលពីសេវាពិនិត្យ រៀបចំនឹងដំណើរការឯកសារ | ១៨៥,១០ | ៤៦៣,១៥ | ២៥០% |
| ៧ | ចំណូលពីការចេញលិខិតបញ្ជាក់ | ៧៩ | ៦៤៩ | ៨២២% |

| | | | | |
|---|---|---|---|---|
| ៨ | លិខិតអនុញ្ញាតបុរេនា | ១២ | ៨៨ | ៧៣៣% |
| ៩ | ឈ្នួលផ្ទៃក្រឡា | ២០ ៤៩៥,៤៧ | ១៨ ០៥៣,៥៥ | ៨៨% |
| ១០ | ចំណូលបំណុល(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) | ២៦ ១៣៨,១០ | ១៦ ៩៥៥,៥៤ | ៦៥% |
| ១១ | ចំណូលពីការពិន័យ | ៧ ៣៦៨,៧៨ | ២១ ៥៩៦,៦០ | ២៩៣% |
| | **សរុប** | **១៦៩ ៦៩១,៤៥** | **៤២៥ ៧៥២,២០** | **២៥១%** |

## ២- វិស័យប្រេងកាត

ក្រសួងរ៉ែនិងថាមពលបានអនុវត្តការងារដោយឈរលើសរសរស្តម្ភចំនួន៣គឺ ទី១- បង្កើតបន្ថែមឧស្សាហកម្មនិស្សារណកម្មពីវិស័យប្រេងកាត ដោយផ្តោតសំខាន់លើការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ វាយតម្លៃសេដ្ឋកិច្ចនិងការរកឃើញធនធានប្រេងកាត ការផ្សព្វផ្សាយព័ត៌មាន និងការទាក់ទាញការវិនិយោគក្នុងវិស័យប្រេងកាត ការជំរុញប្រសិទ្ធិភាពប្រតិបត្តិការប្រេងកាត ការលើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋាននិងការលើកស្ទួយការប្រើប្រាស់ទំនិញសេវាកម្មនិងពលកម្មក្នុងស្រុក និងការងារដោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នា។ ទី២- បង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រងលំហូរចំណូលជាតិពីវិស័យប្រេងកាត ដោយផ្តោតសំខាន់លើការពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធប្រមូលចំណូល និងការកសាងសមត្ថភាពជាតិក្នុងការគ្រប់គ្រងចំណូលប្រកបដោយប្រសិទ្ធភាព។ និងទី៣- ការការពារបរិស្ថាននិងសង្គមក្នុងប្រតិបត្តិការប្រេងកាត ដោយផ្តោតសំខាន់លើការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងនិងត្រួតពិនិត្យសកម្មភាពផ្នែកដោនស្ទ្រីម ការពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងសម្បទានប្រេងកាតនិងការងារអធិការកិច្ចក្នុងវិស័យប្រេងកាត។

### ២.១- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យប្រេងកាត

ក្រសួងបានយកចិត្តទុកដាក់ខ្ពស់ជំរុញអភិវឌ្ឍន៍វិស័យប្រេងកាតឱ្យមានការរីកចម្រើនដូចបណ្តាប្រទេសនានាក្នុងតំបន់និងសកលលោក ដោយបានខិតខំផ្សព្វផ្សាយនិងទាក់ទាញអ្នកវិនិយោគឱ្យមកបណ្តាក់ទុនរកស៊ីក្នុងវិស័យប្រេងកាតនៅកម្ពុជា។ ជាក់ស្តែង បន្ទាប់ពីការចរចាដ៏ស្វិតស្វាញ ក្រសួងបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយក្រុមហ៊ុន KrisEnergy និងបានសហការសម្របសម្រួលឱ្យក្រុមហ៊ុននេះធ្វើការអភិវឌ្ឍគម្រោងប្រេងកាតប្លុកA រហូតទទួលបានការដាក់ឱ្យដំណើរការផលិតកម្មប្រេងលើកដំបូងរបស់កម្ពុជា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ និងផលិតប្រេងបានចំនួន២៩០ ២៥៤បារ៉ែល គិតត្រឹមខែឧសភា ឆ្នាំ២០២១។ ទន្ទឹមនេះសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ក្រសួងបានផ្តល់អាជ្ញាបណ្ណចំនួន៦៣ លិខិតអនុញ្ញាតដំណើរការចំនួន១៧ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្ថានីយចំនួន៣៤៤ និងលិខិតអនុញ្ញាតដំណើរការស្ថានីយចំនួន១ ៩៣១ ដែលធ្វើឱ្យចំនួនស្ថានីយដែលបានដាក់ពាក្យនិងមានច្បាប់កើនឡើងពី១១% ទៅ៦៧%។

- តារាងសង្ខេបការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតដំណើរការពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្មៈ

| ល.រ. | ប្រភេទ | អាជ្ញាបណ្ណ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១ | មណ្ឌលសន្និធិប្រេងឥន្ធនៈ | ១ | ៣ | ២ | ៣ | ១ | ១០ |
| ២ | មណ្ឌលសន្និធិឧស្ម័នឥន្ធនៈ | ១ | - | ២ | ៣ | ១ | ៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | មណ្ឌលសន្និធិរួមប្រេងនិងឧស្ម័នឥន្ធនៈ | - | - | - | ១ | - | ១ |
| ៤ | ការនាំចូលប្រេង និងឧស្ម័នឥន្ធនៈ | ១ | - | - | ១ | ៣ | ៥ |
| ៥ | ការដឹកជញ្ជូនឧស្ម័នឥន្ធនៈ | ២ | - | - | ១ | - | ៣ |
| ៦ | ការផ្គត់ផ្គង់និងការចែកចាយឧស្ម័នឥន្ធនៈ (ឧស្ម័នធម្មជាតិ) | ២៥ | - | - | - | - | ២៥ |
| ៧ | ការវេចខ្ចប់ឧស្ម័នអិលភីជី | - | - | - | ៧ | ៥ | ១២ |
| សរុប | | ៣០ | ៣ | ៤ | ១៦ | ១០ | ៦៣ |

| ល.រ. | ប្រភេទ | លិខិតអនុញ្ញាតដំណើរការ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១ | មណ្ឌលសន្និធិប្រេងឥន្ធនៈ | ១ | ២ | ១ | ៥ | - | ៩ |
| ២ | មណ្ឌលសន្និធិឧស្ម័នឥន្ធនៈ | - | - | ១ | ៣ | - | ៤ |
| ៣ | មណ្ឌលសន្និធិរួមប្រេងនិងឧស្ម័នឥន្ធនៈ | - | - | - | ១ | - | ១ |
| ៤ | ការនាំចូលប្រេងនិងឧស្ម័នឥន្ធនៈ | - | - | - | - | - | - |
| ៥ | ការដឹកជញ្ជូនឧស្ម័នឥន្ធនៈ | - | - | - | - | - | - |
| ៦ | ការផ្គត់ផ្គង់និងការចែកចាយឧស្ម័នឥន្ធនៈ (ឧស្ម័នធម្មជាតិ) | - | - | - | - | - | - |
| ៧ | ការវេចខ្ចប់ឧស្ម័នអិលភីជី | - | - | - | ២ | ១ | ៣ |
| សរុប | | ១ | ២ | ២ | ១១ | ១ | ១៧ |

| ល.រ. | ប្រភេទ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| ១ | វិញ្ញាបនបត្របញ្ជាក់បច្ចេកទេស | ៣៥ | ១០០ | ៨៧ | ៤២ | ៨០ | ៣៤៤ |
| ២ | លិខិតអនុញ្ញាតដំណើរការ | ១៣ | ៩២ | ១១៥ | ៧៥៨ | ៩៥៣ | ១៩៣១ |
| សរុប | | ៤៨ | ១៩២ | ២០២ | ៨០០ | ១ ០៣៣ | ២ ២៧៥ |

- តារាងសង្ខេបការផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេស និងលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈ៖

- តារាងសង្ខេបចំនួនស្ថានីយដែលបានដាក់ពាក្យនិងមានច្បាប់៖

| ឆ្នាំ | ចំនួនស្ថានីយសរុប | បានដាក់ពាក្យស្នើសុំច្បាប់ | មិនទាន់មានច្បាប់ | ភាគរយបានដាក់ពាក្យនិងមានច្បាប់ |
|---|---|---|---|---|
| ២០១៧ | ៣ ៥១៩ | ៣៧២ | ៣ ១៤៧ | ១១% |
| ២០១៨ | ៣ ៧៧៨ | ៥៦៩ | ៣ ២០៩ | ១៥% |

| | | | | |
|---|---|---|---|---|
| ២០១៩ | ៤ ២០០ | ៨៥៧ | ៣ ៣៤៣ | ២០% |
| ២០២០ | ៤ ៧៥២ | ២ ៦៥៧ | ២ ០៩៥ | ៥៦% |
| ២០២១ | ៥ ០៣៤ | ៣ ៣៩៦ | ១ ៦៣៨ | ៦៧% |

- តារាងសង្ខេបពីការបណ្ដាក់ទុនវិនិយោគសម្រាប់ផ្នែកអាប់ស្រ្ទីមៈ

(ឯកតាៈ លានដុល្លារអាម៉េរិក)

| ក្រុមហ៊ុន | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (គិតត្រឹមត្រីមាសទី៣) | សរុប |
|---|---|---|---|---|---|---|
| ក្រុមហ៊ុន គ្រីសអេនើជី(អប្សរា) ឯ.ក (KrisEnergy Apsara) Company Limited) (ប្លុក A) | ២,៥៦ | ៥,១៨ | ១៩,១៧ | ៥៩,២៧ | ២៩,៦៧ | ១១៥,៨៥ |
| ក្រុមហ៊ុន ខេមបូឌាន រីសសស៍ អេនើជី ឌីវីឡុបមិន ឯ.ក (Cambodian Resource Energy Development Co.,Ltd) (ប្លុក D) | ០ | ០ | ០ | ១,០៣ | ០,៣៥ | ១,៣៨ |
| **សរុប** | **២,៥៦** | **៥,១៨** | **១៩,១៧** | **៦០,៣០** | **៣០,០២** | **១១៧,២៣** |

## ២.២- ចំណូលមិនមែនសារពើពន្ធពីវិស័យប្រេងកាត

ចំណូលពីវិស័យប្រេងកាតក៏ត្រូវបានពង្រឹងតាមរយៈការផ្ដល់សេវាសារធារណៈ និងការជំរុញឱ្យអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតអនុវត្តកាតព្វកិច្ចហិរញ្ញវត្ថុតាមការតម្រូវដោយច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

- ចំណូលពីវិស័យប្រេងកាតដែលប្រមូលបានពីឆ្នាំ២០១៧ ដល់២០២១ រួមមានៈ

(ឯកតាៈលានរៀល)

| ២០១៣-២០១៧ | ២០១៧-២០២១ | % ធៀបឆ្នាំ២០១៣-២០១៧ |
|---|---|---|
| ៧០ ៤៣៧,៣៧ | ៦៧ ៣៤៥,១០ | ៩៦% |

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|
| ៨ ២១៥,៨៨ | ២៤ ១៦៧,៤៩ | ១១ ៧៣៣,០២ | ២១ ០៤៣,៣៦ | ២ ១៨៥,៣៥ | ៦៧ ៣៤៥,១០ |

## ៣- ការងារចុះបញ្ជីពេងចក្រ

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រេចការងារបានដូចខាងក្រោមៈ**

បានបន្តយកចិត្តទុកដាក់អនុវត្តគោល នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងគោលបំណងធ្វើការអភិវឌ្ឍវិស័យឧស្សាហកម្ម នៅកម្ពុជា ប្រែក្លាយទៅជាប្រទេសឧស្សាហកម្មភាវូបនីយកម្ម នាឆ្នាំ២០២៥ ឬជាឧស្សាហកម្មប្រើប្រាស់ជំនាញនិងបច្ចេកវិទ្យា ដែលមានខ្សែសង្វាក់បង្កើតតម្លៃបន្ថែមខ្ពស់ ស្របតាមចរន្តនៃការរីកចម្រើនវិទ្យាសាស្រ្តនិងបច្ចេកវិទ្យា ដែលហៅថាបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដោយ

ឈរលើមូលដ្ឋានអភិវឌ្ឍន៍ពិពិធកម្មឧស្សាហកម្មមានចរិតច្នៃប្រឌិតខ្ពស់ និងមានចរិតជាយុទ្ធសាស្ត្រប្រកួតប្រជែងយូរអង្វែង។ ប៉ុន្តែ ជាអកុសលការឆ្លងរីករាលដាលជាសាកលនៃជំងឺកូវីដ-១៩ ដែលបានបង្កជាបញ្ហាញាំញីរំខាន និងបង្អាក់ដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍នានា និយាយជារួម នឹងប៉ះពាល់ដល់សកម្មភាពការងារចរន្ត ព្រមទាំងទិសដៅការងារដែលត្រូវសម្រេចឱ្យបានរបស់ក្រសួង និយាយដោយឡែក ដែលតម្រូវឱ្យមានការចេះបត់បែនទៅតាមរបៀបធម្មតាបែបថ្មីឬប្រក្រតីកម្ម( new normal ) ទាំងក្នុងជីវភាពរស់នៅនិងការបំពេញកិច្ចការផ្សេងៗ។

ប៉ុន្តែទោះបីជាជួបបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរដូចខាងលើនេះក៏ដោយ ក៏ថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅតែពង្រឹងស្មារតីនិងពូនផ្តុំកម្លាំងសាមគ្គី ក្រោមការដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី** បំពេញភារកិច្ចដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយទទួលបាននូវលទ្ធផលសំខាន់ៗតាមវិស័យនីមួយៗ ដូចខាងក្រោម៖

## ៤- កិច្ចការឧស្សាហកម្ម

### ៤-១- រោងចក្រ

គិតត្រឹមដំណាច់ខែតុលា ឆ្នាំ២០២១នេះ ការងារគ្រប់គ្រងទិន្នន័យ ស្ថិតិរោងចក្រ មានដូចខាងក្រោម៖

១- រោងចក្រដំណើរការមានចំនួន១ ៨៤៩រោងចក្រ ស្ថិតនៅក្នុង២៥រាជធានី ខេត្ត មានការកើនឡើងចំនួន៣២៧រោងចក្រ ស្មើនឹង២១,៤៨% បើធៀបទៅនឹងរយៈពេល៥ឆ្នាំកន្លងមក ដែលនៅក្នុងឆ្នាំ២០១៧ រោងចក្រដំណើរការមានចំនួន១ ៥២២រោងចក្រ។

២- រោងចក្រកើតថ្មីក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ(២០១៧-តុលា២០២១) មានចំនួន៩៦២រោងចក្រ។

៣- រោងចក្របិទទ្វារឈប់ដំណើរការក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ(២០១៧-តុលា២០២១) មានចំនួន៦៩២រោងចក្រ។



### ៤-២- កម្លាំងពលកម្ម

កម្លាំងពលកម្មសរុបគិតត្រឹមដំណាច់ខែតុលា ឆ្នាំ២០២១នេះ មានចំនួន៩៧០ ៤៨៧នាក់ ក្នុងនោះ មានស្រីចំនួន៧៤៧ ៧០០នាក់ ស្មើនឹង៧៧,០៤% មានការថយចុះចំនួន១១ ៧១៦នាក់ ស្មើនឹង១,១៩% បើធៀបទៅនឹងរយៈពេល៥ឆ្នាំកន្លងមក ដែលនៅក្នុងឆ្នាំ២០១៧ កម្លាំងពលកម្មសរុបមានចំនួន៩៨២ ២០៣នាក់។




### ៤-៣- ទុនវិនិយោគ

ទុនវិនិយោគសរុបគិតត្រឹមដំណាច់ខែតុលា ឆ្នាំ២០២១នេះ មានចំនួនជាង១៣,៤៧៤លានដុល្លារអាមេរិក មានការកើនឡើងចំនួនជាង៤ ០៦៤លានដុល្លារអាមេរិក ស្មើនឹង៤៣,១៩% បើធៀបទៅនឹងរយៈពេល៥ឆ្នាំកន្លងមក ដែលនៅក្នុងឆ្នាំ២០១៧ ទុនវិនិយោគសរុបមានចំនួនជាង៩ ៤១០លានដុល្លារអាមេរិក។



## ៤.៤- តម្លៃបរិមាណផលិតផល

តម្លៃបរិមាណផលិតផលសរុបពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១នេះ មានចំនួនជាង៥ ៩៣៣លាន ដុល្លារអាម៉េរិក ក្នុងនោះមាន៖

- តម្លៃបរិមាណផលិតផលបម្រើទីផ្សារក្នុងស្រុកមានចំនួនជាង១ ៥៦០លានដុល្លារអាម៉េរិក
- តម្លៃបរិមាណផលិតផលនាំចេញមានចំនួនជាង៤ ៣៧៣លានដុល្លារអាម៉េរិក។




## ៤.៥- កម្មវិធីសេវាសាធារណៈ

ការផ្តល់សេវាសាធារណៈពីខែមករា ដល់ខែតុលា ឆ្នាំ២០២១ នេះ មានចំនួន៥៣៤ឯកសារ។ ក្នុងរយៈពេល៥ឆ្នាំ(២០១៧-តុលា២០២១) ការផ្តល់សេវាសាធារណៈមានចំនួន៣ ០៨៥ឯកសារ។






### ៤.៦- ការងារកម្មសិទ្ធិឧស្សាហកម្ម

គិតចាប់ពីឆ្នាំ២០១៧ ដល់ត្រឹមខែតុលា ឆ្នាំ២០២១នេះ បានធ្វើការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម រួមមានដូចខាងក្រោម៖

- ទទួលសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មសរុបបានចំនួន១ ៥៧០សំណុំលិខិត និងបានផ្តល់ប្រកាសនីយបត្រតក្កកម្មចំនួន៣៥១សំណុំលិខិត
- ទទួលសំណុំលិខិតស្នើសុំផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ចំនួន៥៧សំណុំលិខិត និងបានផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ចំនួន៦សំណុំលិខិត
- ទទួលសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មចំនួន៥៦២សណុំលិខិត និងបានចុះបញ្ជីចំនួន ៤៣៦សំណុំលិខិត
- ទទួលសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មសារឡើងវិញចំនួន២៦១សំណុំលិខិត និងបានចុះបញ្ជីចំនួន២៦១សំណុំលិខិត។

### ៤.៧- ការងារទឹកស្អាត

អគ្គនាយកដ្ឋានទឹកស្អាតជាសេនាធិការឱ្យក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ លើវិស័យទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយជំរុញការអភិវឌ្ឍនិងគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត សម្រាប់បម្រើឱ្យជីវភាពរស់នៅរបស់ប្រជាជន តាមរយៈផលិតកម្មនិងសេវាកម្ម ដើម្បីលើកកម្ពស់សុខមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជន ដែលរស់នៅក្នុងតំបន់ទីប្រជុំជន ជាយក្រុង និងជនបទ។ គោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត គឺឆ្នាំ២០២៥ ប្រជាជនចំនួន៩០% ដែលរស់នៅតំបន់ទីប្រជុំជនបានទទួលសេវាទឹកស្អាតប្រើប្រាស់និងនៅឆ្នាំ២០៣០ ប្រជាជនចំនួន១០០% បានទទួលសេវាទឹកស្អាតប្រើប្រាស់ ដែលមានគុណភាពល្អនិងថ្លៃសមរម្យ តាមរយៈការពង្រីកសមត្ថភាពផលិត និងលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជនក្នុងការវិនិយោគ លើវិស័យផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងប្រទេស។

ជាគោលដៅយុទ្ធសាស្ត្រនៃការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជន ដែលរស់នៅតំបន់ទីប្រជុំជន នឹងទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់ប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យឱ្យបានចំនួន៩០% គឺឆ្នាំ២០២៥ និងឱ្យបាន១០០% នៅឆ្នាំ២០៣០ តាមរយៈការពង្រីកសមត្ថភាពផលិត និងការលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងប្រទេស។

ដើម្បីឆ្លើយតបទៅនឹងកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានទឹកស្អាតសម្រេចបាននូវសមិទ្ធផលក្នុងវិស័យទឹកស្អាតបានកាន់តែល្អប្រសើរឡើង ដោយអនុវត្តតាមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **កិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ បានធ្វើការណែនាំឱ្យអគ្គនាយកដ្ឋានទឹកស្អាត គិតគូរដល់ការបង្កើនសមត្ថភាពផលិតនិងពង្រីកផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាត នៅគ្រប់ទីប្រជុំជននានា។ ជាមួយគ្នានេះដែរ ក៏បានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ចំពោះប្រជាជនក្រីក្រ ដែលមានចំណូលទាប ហើយមានការប្រើប្រាស់ទឹកស្អាតក្នុងកម្រិតទាប ដែលបញ្ហានេះ ថ្នាក់ដឹកនាំក្រសួងបានពិចារណានិងពិនិត្យកែសម្រួលថ្លៃដើម ផលិតទឹកស្អាតឡើងវិញ ដោយបានកំណត់ថ្លៃលក់ទឹកស្អាតទៅតាមបរិមាណប្រើប្រាស់ទឹកជាក់ស្តែង សំដៅធានាជួយដល់ប្រជាជនក្រីក្រអាចទទួលបាននូវសេវាទឹកស្អាតប្រកបដោយគុណភាព និងតម្លៃសមរម្យ ស្របតាមកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ។

ក្នុងឆ្នាំ២០១៧-២០២១កន្លងមកនេះ សមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ ដែលអគ្គនាយកដ្ឋានទឹកស្អាត សម្រេចបានគិតក្នុងរយៈពេល៥ឆ្នាំ ត្រូវបានឆ្លុះបញ្ចាំងដោយសង្ខេបដូចខាងក្រោម៖

### ៤.៧.១- ការងារផលិតកម្មទឹកស្អាតសាធារណៈរាជធានី-ខេត្ត និងឯកជនទូទាំងប្រទេស

ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) សកម្មភាពផលិតទឹកស្អាតសាធារណៈរាជធានី ខេត្ត និងឯកជននៅទូទាំងប្រទេសបានចំនួន១ ៦៣២ ០២៤ ៥៤៨ម.$^{៣}$ គឺមានការកើនឡើង៤៥,០៨% ធៀបទៅនឹងអាណត្តិទី៥ (១ ១២៤ ៩២៧ ២០០ម.$^{៣}$)នៃរាជរដ្ឋាភិបាល ដោយមានគម្រោងរបស់បណ្តាដៃគូអភិវឌ្ឍន៍នានា ជាពិសេសការពង្រីកប្រព័ន្ធនិងបណ្តាញចែកចាយ និងការពង្រឹងនិងពង្រីកសមត្ថភាពផលិតទឹកស្អាតពីអង្គភាពរដ្ឋាករទឹកសាធារណៈ និងឯកជនផងដែរ។

ជាមួយគ្នានេះដែរ ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជនបានកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងកំឡុងពេល៥ឆ្នាំក្នុងអាណត្តិទី៦នៃរាជរដ្ឋាភិបាលនេះ។ អត្រាគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាតតាមប្រព័ន្ធបណ្តាញក្នុងតំបន់ទីប្រជុំជនបានកើនឡើងដល់៦៥,៧៩% មកដល់ឆ្នាំ២០២១ ដែលគិតជាចំនួនគ្រួសារដែលទទួលបានទឹកស្អាតប្រើប្រាស់ គឺកើនដល់ចំនួន១ ៩៦១ ៣៣៣គ្រួសារ។

ទន្ទឹមនឹងនេះ ក្រសួងបានយកចិត្តទុកដាក់អនុវត្តគោលនយោបាយឧបត្ថម្ភធន សម្រាប់ប្រជាពលរដ្ឋក្រីក្រដែលមានប្រាក់ចំណូលទាប ដើម្បីទទួលបានការប្រើប្រាស់ទឹកដែលមានតម្លៃថោកក្នុងកម្រិតអប្បបរមា ក្នុងនោះ ប្រជាពលរដ្ឋក្រីក្រចំនួន៧៧ ៣៨២គ្រួសារ បានទទួលនូវការឧបត្ថម្ភធនសម្រាប់ការតភ្ជាប់បណ្តាញទឹកស្អាត។ លើសពីនេះទៀត ក្រសួងបានកំណត់ថ្លៃលក់ទឹកស្អាតនៅក្នុងរាជធានីភ្នំពេញ និងចុះកិច្ចសន្យាជាមួយម្ចាស់ផ្ទះជួល៧០០រៀល/ម$^{៣}$ ហើយម្ចាស់ផ្ទះជួលលក់ឱ្យកម្មករ កម្មការិនី សិស្ស និស្សិត ក្នុងតម្លៃ៨០០រៀល/ម$^{៣}$។ បច្ចុប្បន្ន សម្រេចតភ្ជាប់បណ្តាញទឹកស្អាតបានចំនួន៤,៩៩០ផ្ទះ និងអគារ ដែលមានបន្ទប់ជួលចំនួន១០៧ ៨៦៩បន្ទប់។ ក្នុងបរិមាណផលិតកម្មទឹកស្អាតរយៈពេល៥ឆ្នាំ មានឆ្លុះបញ្ចាំងក្នុងតារាងទិន្នន័យផលិតកម្ម ដូចខាងក្រោម៖

| បរិយាយ | ឆ្នាំ ២០១៧ (ម.$^{៣}$) | ឆ្នាំ២០១៨ (ម.$^{៣}$) | ឆ្នាំ២០១៩ (ម.$^{៣}$) |
|---|---|---|---|
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ១៩៤ ៦០១ ៣០៦ | ២០៧ ៧៨៧ ៩៤៩ | ២២១ ៥០៩ ២១៤ |
| រដ្ឋាករទឹកស្វយ័តសៀមរាប | ៥ ៩១១ ៧៩៤ | ៦ ១២៨ ៥១០ | ៦ ៩៧២ ០១០ |
| រដ្ឋាករទឹកសាធារណៈ | ២៦ ៧៤៩ ០៧២ | ៣១ ៧០៥ ១៤៤ | ៣៧ ៣៥១ ៣៥៨ |
| ក្រុមហ៊ុនទឹកស្អាតឯកជន | ៥៣ ៥៥០ ៩៦៥ | ៦៣ ៣០១ ១៣១ | ៨១ ០៨៨ ៤៣៤ |
| អត្រា%ចំនួនប្រជាជនទទួលបានការផ្គត់ផ្គង់ទឹកស្អាត | ៤៤,២១% | ៥១,០៤% | ៥៤,៣៩% |
| សរុប | **២៨០ ៨១៣ ១៣៧** | **៣០៨ ៩២២ ៧៣៤** | **៣៤៦ ៩២១ ០១៦** |

| **បរិយាយ** | **ឆ្នាំ២០២០ (ម.$^{៣}$)** | **ឆ្នាំ២០២១ (ម.$^{៣}$)** | **សរុប៥ឆ្នាំ(ម.$^{៣}$)** |
|---|---|---|---|
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ២៣២ ៦៩១ ៦៤៣ | ២២៥ ៩៣២ ៣៥១ | ១ ០៨២ ៥២២ ៥៦៣ |
| រដ្ឋាករទឹកស្វយ័តសៀមរាប | ៦ ៣៦២ ៨១០ | ៥ ៩៣៤ ១៧០ | ៣១ ៣០៩ ២៩៤ |
| រដ្ឋាករទឹកសាធារណៈ | ២៩ ៣៤៩ ៩៧៦ | ៣០ ៨២២ ៨៣៨ | ១៥៥ ៩៧ ៣៨៨ |
| ក្រុមហ៊ុនទឹកស្អាតឯកជន | ១០៨ ៦២៧ ៨៩២ | ១១៨ ៩៤៧ ០១២ | ៣៦២ ២១៤ ៣០៣ |
| អត្រា%ចំនួនប្រជាជនទទួលបានការផ្គត់ផ្គង់ទឹកស្អាត | ៥៥,៤១% | ៥៦,៦២% | |
| **សរុប** | **៣៧៨ ០៥៥ ៩៤០** | **៣៨១ ៦៣៦ ៣៧១** | **១ ៦៣២ ០២៤ ៥៤៨** |

គិតត្រឹមឆ្នាំ២០២១ បណ្ដាញចែកចាយទឹកស្អាតសរុបទូទាំងប្រទេសមានប្រវែង២២ ៩១៩គ.ម. ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងទី២ ប្រវែងបណ្ដាញសរុបតាមបណ្ដាឆ្នាំនីមួយៗ**

| ប្រតិបត្តិករ | ឆ្នាំ២០១៧ (គ.ម.) | ឆ្នាំ២០១៨ (គ.ម.) | ឆ្នាំ២០១៩ (គ.ម.) | ឆ្នាំ២០២០ (គ.ម.) | ឆ្នាំ២០២១ (គ.ម.) |
|---|---|---|---|---|---|
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ២ ៨៤៥ | ៣ ១០២ | ៣ ៣៨៤ | ៣ ៥៦៤ | ៣ ៨៤៤ |
| រដ្ឋាករទឹកស្វយ័តសៀមរាប | ១៦២ | ១៨៣ | ២៤០ | ២៦៩ | ៣០២ |
| រដ្ឋាករទឹកសាធារណៈចំនួន១០ | ១ ៣៧១ | ១ ៦១៨ | ១ ៧៦៦ | ១ ៦៨៤ | ២ ១០៥ |
| ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯជន | N/A | N/A | ៩ ៩៦១ | ១៥ ៩៦០ | ១៦ ៦៦៨ |
| **ប្រវែងបណ្ដាញសរុប** | | | **១៥ ៣០៩** | **១៩ ៤១៧** | **២២ ៩១៩** |

## ៤.៧.២- ការងារបញ្ញត្តកម្មទឹកស្អាត

បានពង្រឹងការងារបញ្ញត្តកម្ម ដោយបានចុះដោះស្រាយទំនាស់លើករណីជាន់តំបន់សេវាកម្ម និងការដោះស្រាយកង្វល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធគុណភាពទឹក ថ្លៃទឹក កាផ្សព្វផ្សាយពីថ្លៃទឹក តាមរយៈការចុះពិនិត្យផ្ទាល់ ការជួបជាមួយរដ្ឋបាលខេត្ត អាជ្ញាធរមូលដ្ឋាន ក៏ដូចជាជួបជាមួយប្រជាពលរដ្ឋផ្ទាល់ ក្នុងទិសដៅពង្រឹងប្រសិទ្ធភាពការអនុវត្តលក្ខខណ្ឌនៃការប្រកាសអនុញ្ញាត ក៏ដូចជាការពិគ្រោះយោបល់ជាសាធារណៈ តាមរយៈសេចក្ដីជូនដំណឹងមុនពេលផ្ដល់ប្រកាសអនុញ្ញាតជូនប្រតិបត្តិករ។

ក្នុងរយៈពេល៥ឆ្នាំមកនេះ គោលការណ៍សិក្សាសមិទ្ធិលទ្ធភាព និងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលបានផ្ដល់ជូនប្រតិបត្តិកររួមមាន៖

- គោលការណ៍សិក្សាសមិទ្ធិលទ្ធភាព ចំនួន២២៦ទីតាំង
- ប្រកាសអនុញ្ញាតផ្ទាល់ឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន១១៧ទីតាំង
- ប្រកាសអនុញ្ញាតជំនួសឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន១០៥ទីតាំង
- ប្រកាសអនុញ្ញាតអចិន្ត្រៃយ៍ឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន៨ទីតាំង

**តារាងទី៣ ទិន្នន័យចេញប្រកាសអនុញ្ញាត និងគោលការណ៍សិក្សាសមិទ្ធិលទ្ធភាពធៀបក្នុងឆ្នាំ២០១៧-២០២១**

| បរិយាយសកម្មភាព | អនុវត្តឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ |
|---|---|
| គោលការណ៍សិក្សាសមិទ្ធិលទ្ធភាព | ២២៦ |
| ចេញប្រកាសអនុញ្ញាត | ១១៧ |
| ចេញប្រកាសប្រកួតប្រជែង | ១៥ |
| ចេញប្រកាសជំនួស | ១០៥ |
| ចេញប្រកាសអចិន្ត្រៃយ៍ | ៨ |

### ក្រាហ្វិកកំណើនចំនួនប្រកាសអនុញ្ញាតសរុប

**តារាងទី៤ ស្ថិតិប្រកាសអនុញ្ញាតធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតសរុប**

| ប្រភេទនៃប្រកាសអនុញ្ញាតធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត | ចំនួនសរុប |
|---|---|
| ១- ប្រកាសអនុញ្ញាតអចិន្ត្រៃយ៍ | ១០ |
| ២- ប្រកាសអនុញ្ញាតផ្ទាល់ | ១៤៥ |
| ៣- ប្រកាសអនុញ្ញាតជំនួស | ១១៦ |

| | |
|---|---|
| ៤- ប្រកាសអនុញ្ញាតប្រកួតប្រជែង | ១៦ |
| ៥- ប្រកាសអនុញ្ញាត ០៣ឆ្នាំ និងប្រកាសពីអតីតMIME | ២១ |
| **សរុប (ត្រឹមខែវិច្ឆិកា ឆ្នាំ២០២១)** | ៣០៨ |

## ៤.៧.៣- ការងារគម្រោងនិងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

គម្រោងពាក់ព័ន្ធវិស័យទឹកស្អាតទាំងអស់ដែលកំពុងអនុវត្តមានចំនួន១៧គម្រោង ដែលក្នុងនោះ គម្រោងកសាងសមត្ថភាពមានចំនួន៤គម្រោង និងគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធមានចំនួន១៣គម្រោង។ សរុបថវិកាហិរញ្ញប្បទានរបស់គម្រោងទាំង១៧ មានចំនួនប្រមាណ៧៣១,០៤លានដុល្លារអាមេរិក ដែលក្នុងនោះ ហិរញ្ញប្បទានឥតសំណងមានចំនួនប្រមាណ៣៦០,០៤លានដុល្លារអាមេរិក និងហិរញ្ញប្បទានសម្បទានមាន ចំនួនប្រមាណ៣៧១លានដុល្លារអាមេរិក។ ក្រសួងបានខិតខំយកចិត្តទុកដាក់អនុវត្តគម្រោង និងទទួលបានលទ្ធផល ដូចខាងក្រោម៖

### ក- កិច្ចសហប្រតិបត្តិការជាមួយកម្មវិធី 3i

- ឆ្នាំ២០១៩ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យប្រើប្រាស់បទដ្ឋានបច្ចេកទេស អប្បបរមាសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខ្នាតតូច ចំនួន៣លើក នៅរាជធានីភ្នំពេញ បាត់ដំបង និងខេត្តកំពង់ចាម
- បានផ្តល់វគ្គបណ្តុះបណ្តាលជំនាញអគ្គិសនី មេកានិក និងជំនាញផ្នែកដំណើរការ និងការថែរក្សា ប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតចំនួន១៤លើក។

**១- កិច្ចសហប្រតិបត្តិការជាមួយUNICEF**

- បានចុះត្រួតពិនិត្យឡើងវិញការអនុវត្តន៍ផែនការសុវត្ថិភាព
- បានចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសរបស់អាជីវករទឹកស្អាតឯកជន ដើម្បីជាមូលដ្ឋានក្នុងការ ចេញវិញ្ញាបនបត្រប្រតិបត្តិការ។

**២- គម្រោងធ្វើបច្ចុប្បន្នភាពផែនការមេ(២០២១-២០៣០ )របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

ហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន តាមរយៈJICA : **១ លានដុល្លារអាមេរិក**

- ពេលវេលាអនុវត្តគម្រោង: ឆ្នាំ២០២០ ដល់ឆ្នាំ២០២២
- វឌ្ឍនភាព:
  - កំពុងរៀបចំសេចក្តីព្រាងលើកទី១
  - លទ្ធផលបឋម:
    - តម្រូវការប្រើប្រាស់ទឹកស្អាត នៅឆ្នាំ២០២៥ ចំនួន១,២លានម.$^{៣}$/ថ្ងៃ
    - តម្រូវការប្រើប្រាស់ទឹកស្អាត នៅឆ្នាំ២០៣០ ចំនួន១,៧លានម.$^{៣}$/ថ្ងៃ
    - តម្រូវការទុនដើម្បីវិនិយោគសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតបន្ថែម(រោងចក្រនិងបណ្តាញ)។

### ខ- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត

**១. គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតខេត្តកំពង់ធំ**

- ហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុនចំនួន៣ ២៧១លានយ៉េន ឬប្រមាណ២៨,៥លាន ដុល្លារអាមេរិក

- ទំហំគម្រោង:

o ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹក ចំនួន៧ ៥០០ម.៣/ថ្ងៃ

o បណ្តាញទឹកស្អាតចំនួន១៥១គ.ម.

- ក្រុមហ៊ុនសាងសង់: KTP Consortium

- ពេលវេលាសាងសង់: ខែមីនា ឆ្នាំ២០១៩ ដល់ខែកុម្ភៈ ឆ្នាំ២០២២

- វឌ្ឍនភាព: **៩២,៦%**

- ការគ្រប់គ្រង: ក្រុមហ៊ុនរបស់ជប៉ុនSPC(Special Purpose Company) និងគ្រប់គ្រងដំណើរការថែទាំប្រព័ន្ធផលិតកម្ម និងលក់ទឹកដុំឱ្យរដ្ឋាករទឹកខេត្តកំពង់ធំ ក្នុងរយៈពេល៥ឆ្នាំក្រោយបញ្ចប់ការសាងសង់។

**២- គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តពោធិ៍សាត់**

**ព័ត៌មានគម្រោង**:

- ហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុនតាមរយៈJICA: ២ ៤០៥លានយ៉េន ឬប្រមាណ ២១,៨៦លានដុល្លារអាម៉េរិក

- ទំហំគម្រោង:

o ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹកចំនួន៦ ៦០០ម.៣/ថ្ងៃ

o បណ្តាញទឹកស្អាតចំនួន៧៥,៤គ.ម.

- ពេលវេលាអនុវត្តគម្រោង: ខែសីហា ឆ្នាំ២០២១ ដល់ខែសីហា ឆ្នាំ២០២៣

- វឌ្ឍនភាព: ៣,៣%

**៣- គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តស្វាយរៀង**

- ហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន តាមរយៈJICA

- វឌ្ឍនភាព: កំពុងសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំឯកសារស្នើសុំហិរញ្ញប្បទានឥតសំណង។

**៤- គម្រោងសងសង់ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតទឹកខ្នាតតូច(បច្ចេកវិទ្យា** High-Rate Fiber Filtration System)

- ហិរញ្ញប្បទានឥតសំណងតាមរយៈJICA

- គោលដៅគម្រោង: រដ្ឋាករទឹកខេត្តពោធិ៍សាត់ និងរដ្ឋាករទឹកស្វយ័តសៀមរាប

- វឌ្ឍនភាព: កំពុងធ្វើការសិក្សាលម្អិត។

**៥- គម្រោងផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន** (ADB **លេខ ៣២៣២**)

- ហិរញ្ញប្បទានសរុប៣៧,៤លានដុល្លារអាម៉េរិក

- បដិភាគរបស់រាជរដ្ឋាភិបាល៣,៤លានដុល្លារអាម៉េរិក

- ហិរញ្ញប្បទានសម្បទានរបស់ADBចំនួន៣៤លានដុល្លារអាម៉េរិក

- គោលដៅគម្រោងរដ្ឋាករទឹកខេត្តកំពង់ចាម ពោធិ៍សាត់ កំពត ស្វាយរៀង កំពង់ធំ សៀមរាប ស្ទឹងត្រែងព្រះសីហនុ និងរដ្ឋាករទឹកស្ទោង

- ពេលវេលាអនុវត្តគម្រោង: ឆ្នាំ២០១៥ ដល់ឆ្នាំ២០២២

- ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

- កែលម្អប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតទឹក នៅទីប្រជុំជនក្នុងខេត្តចំនួន៧ គឺខេត្តកំពង់ចាម ស្វាយរៀង កំពង់ធំ កំពត ព្រះសីហនុ និងខេត្តពោធិ៍សាត់

- វឌ្ឍនភាពបានបញ្ចប់ការសាងសង់
- ពង្រីកបណ្តាញទឹកស្អាត
- រដ្ឋាករទឹកគោលដៅ កំពង់ចាម ពោធិ៍សាត់ សៀមរាប កំពង់ធំ(ស្ទោង) ស្វាយរៀង
- ប្រវែងបណ្តាញទឹកស្អាតសរុប ២២៥គ.ម.
- វឌ្ឍនភាពបានបញ្ចប់ការសាងសង់
- រដ្ឋាករទឹកខេត្តស្ទឹងត្រែង(សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតថ្មី)
  - ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹកចំនួន១២ ០០០ម.$^{៣}$/ថ្ងៃ
  - បណ្តាញទឹកស្អាតចំនួន២៨៦គ.ម.
  - ពេលវេលាអនុវត្តអនុគម្រោង ខែធ្នូ ឆ្នាំ២០១៩ ដល់ខែធ្នូ ឆ្នាំ២០២១
  - វឌ្ឍនភាពចំនួន៩៨%
- រដ្ឋាករទឹកស្ទោង (សាងសង់ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹកថ្មី)
  - សមត្ថភាព: ១ ៣០០ម.$^{៣}$/ថ្ងៃ
  - វឌ្ឍនភាព: បញ្ចប់ការសាងសង់ និងកំពុងដំណើរការសាកល្បង
- រដ្ឋាករទឹកខេត្តស្វាយរៀង (សាងសង់ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតទឹកថ្មី)
  - សមត្ថភាពចំនួន៩ ០០០ម.$^{៣}$/ថ្ងៃ
  - គ្រោងបញ្ចប់ការសាងសង់នៅខែមីនា ឆ្នាំ២០២២
  - វឌ្ឍនភាពចំនួន៣២%

**៦- គម្រោងទឹកស្អាតនិងអនាម័យខេត្ត(ADB លេខ៣ ៦៣០)**

- ហិរញ្ញប្បទានសរុបចំនួន១១៩,១៧លានដុល្លារអាម៉េរិក
  - បដិភាគរបស់រាជរដ្ឋាភិបាលចំនួន១០,៥៤លានដុល្លារអាម៉េរិក
  - ហិរញ្ញប្បទានឥណទានសម្បទានរបស់ADBចំនួន៥០លានដុល្លារអាម៉េរិក
  - ហិរញ្ញប្បទានឥណទានសម្បទានរបស់AFDចំនួន៤៣,៥៤លានដុល្លារអាម៉េរិក
  - ហិរញ្ញប្បទានឥតសំណងរបស់JFJCMចំនួន១០លានដុល្លារអាម៉េរិក(សម្រាប់ផ្នែកអនាម័យ)
  - ហិរញ្ញប្បទានឥតសំណងរបស់EU-AIFចំនួន៥,០៩លានដុល្លារអាម៉េរិក(សម្រាប់ផ្នែកអនាម័យ)
  - ហិរញ្ញប្បទានសម្រាប់ផ្នែកទឹកស្អាតចំនួន៤៥,៧លានដុល្លារអាម៉េរិក
- គោលដៅគម្រោង: រដ្ឋាករទឹកខេត្តបាត់ដំបង និងរដ្ឋាករទឹកខេត្តកំពង់ចាម
- រដ្ឋាករទឹកខេត្តបាត់ដំបង
  - ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹកចំនួន៥០ ០០០ម.$^{៣}$/ថ្ងៃ
  - បណ្តាញទឹកស្អាតចំនួន៩៥គ.ម.
  - កំពុងអនុវត្តនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់
- រដ្ឋាករទឹកខេត្តកំពង់ចាម
  - ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹកចំនួន១១ ៦០០ម.$^{៣}$/ថ្ងៃ
  - បណ្តាញទឹកស្អាតចំនួន៨០,៨៣គ.ម.

o ត្រៀមអនុវត្តនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់

- ពេលវេលាអនុវត្តគម្រោង៖ ឆ្នាំ២០១៨ ដល់ឆ្នាំ២០២៤។

**៧- គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ(WB លេខ៦ ៣៨៦)**

- ហិរញ្ញប្បទានសរុបចំនួន៥៧,៥លានដុល្លារអាម៉េរិក
  - o បដិភាគរបស់រាជរដ្ឋាភិបាលចំនួន២,៥លានដុល្លារអាម៉េរិក
  - o ហិរញ្ញប្បទានសម្បទានរបស់WBចំនួន៥៥លានដុល្លារអាម៉េរិក
  - o ហិរញ្ញប្បទានសម្រាប់ផ្នែកទឹកស្អាតចំនួន៣០,៥លានដុល្លារអាម៉េរិក
- គោលដៅគម្រោង: អនុគម្រោងខេត្តមណ្ឌលគិរី(រដ្ឋាករទឹកខេត្តមណ្ឌលគិរី) អនុគម្រោងខេត្តកំពង់ធំ (រដ្ឋាករ ទឹកស្ទោង និងតាំងក្រសាំង) អនុគម្រោងខេត្តសៀមរាប(ស្រុកប្រាសាទបាគងនិងស្រុកសូទ្រនិគម) អនុគម្រោងខេត្តបាត់ដំបង(ស្រុកភ្នំព្រឹង) និងអនុគម្រោងខេត្តកំពង់ឆ្នាំង(ស្រុកសាមគ្គីមានជ័យ និងស្រុកទឹកផុស)
- ពេលវេលាអនុវត្តគម្រោង: ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤
- អនុគម្រោងខេត្តមណ្ឌលគិរី ដំហាន១
  - o ទំហំការងារ:
    - ពង្រីកបណ្តាញទឹកស្អាតចំនួន៦០គ.ម.
    - សាងសង់អាងស្តុកទឹកស្អាតចំនួន២ ស្មើនឹង១៥០ម.៣
    - ប្រព័ន្ធលូទឹកភ្លៀងចំនួន៧៥០ម.
  - o វឌ្ឍនភាព: បានបញ្ចប់ការងារសាងសង់។
- អនុគម្រោងផ្សេងៗទៀត:
  - o សាងសង់រោងចក្រប្រព្រឹត្តិកម្មសម្អាតទឹក និងបណ្តាញទឹកស្អាត
  - o សម្រាប់អនុគម្រោងខេត្តសៀមរាបនឹងអនុវត្តតាមរូបភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន(PPP)
  - o កំពុងសិក្សាសមិទ្ធិលទ្ធភាពនិងកំពុងជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស
- គ្រោងធ្វើការសិក្សានិងធ្វើបច្ចុប្បន្នគោលនយោបាយជាតិស្តីពីការផ្គត់ផ្គត់ទឹកស្អាត និងអនាម័យ
- គ្រោងអនុវត្តការឧបត្ថម្ភធនដល់គ្រួសារក្រីក្រ
- កំពុងអនុវត្តកម្មវិធីគណនេយ្យសង្គម(ISAF) នៅអនុគម្រោងខេត្តមណ្ឌលគិរី។

**៨- គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

- ហិរញ្ញប្បទានឥតសំណងតាមរយៈJICA: ៣ ៤២១លានយ៉េន ឬប្រមាណ៣១,១លានដុល្លារអាម៉េរិក
- ទំហំគម្រោង:
  - o ស្ថានីយបូមទឹកឆៅចំនួន៣៣ ០០០ម.៣/ថ្ងៃ
  - o ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹកចំនួន៣០ ០០០ម.៣/ថ្ងៃ
- ពេលវេលាអនុវត្តគម្រោង: ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤
- វឌ្ឍនភាព: គ្រោងចុះកិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់ក្នុងត្រីមាសទី១ ឆ្នាំ២០២២

**៩- គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ជំហានទី១ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

- ហិរញ្ញប្បទានសរុបចំនួន២៤៧លានដុល្លារអាម៉េរិក

០បដិភាគរបស់រាជរដ្ឋាភិបាលៈ ដោយពន្ធ និងអារកផ្សេងៗជាបន្ទុករដ្ឋ
០បដិភាពរបស់រ.ទ.ស.ភចំនួន៤៧លានដុល្លារអាម៉េរិក
០ហិរញ្ញប្បទានឥណទានសម្បទានរបស់EIBចំនួន១០០លានដុល្លារអាម៉េរិក
០ហិរញ្ញប្បទានឥណទានសម្បទានរបស់AFDចំនួន៨៥លានដុល្លារអាម៉េរិក
០ហិរញ្ញប្បទានឥណទានសម្បទានរបស់EUចំនួន១៥លានដុល្លារអាម៉េរិក
- ទំហំគម្រោងៈ
០ស្ថានីយបូមទឹកឆៅចំនួន៤០៦ ០០០ម$^{៣}$/ថ្ងៃ
០ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹកចំនួន១៩៥ ០០០ម$^{៣}$/ថ្ងៃ
០បណ្តាញទឹកស្អាត បំពង់មេទំហំចំនួន២ ០០០ម.ម. ប្រវែង៨,២គ.ម.
- ពេលវេលាអនុវត្តគម្រោងៈ ឆ្នាំ២០២០ ដល់ឆ្នាំ២០២២
- វឌ្ឍនភាពៈ ប្រមាណ៤០%

**១០- គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតភូមិព្រែក ក្រុងភ្នំពេញ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
- ហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន តាមរយៈ JICA
- ហិរញ្ញប្បទានប៉ាន់ស្មានសម្រាប់គម្រោងប្រមាណ៣ ២៤៣លានយ៉េន ឬប្រមាណ២៩ ៤៨១ លានដុល្លារអាម៉េរិក
- ទំហំគម្រោងៈ
០បង្កើនសមត្ថភាពរោងចក្រៈ ពី១៥០ ០០០ម$^{៣}$/ថ្ងៃ ដល់១៩៥ ០០០ម$^{៣}$/ថ្ងៃ
- វឌ្ឍនភាពៈ កំពុងសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំឯកសារស្នើសុំហិរញ្ញប្បទាន។

**១១- គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ជំហានទី២ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
- ហិរញ្ញប្បទានសរុបចំនួន១៣៤,៤លានដុល្លារអាម៉េរិក
០បដិភាគរបស់រាជរដ្ឋាភិបាលៈ ដោយពន្ធ និងអារកផ្សេងៗជាបន្ទុករដ្ឋ
០បដិភាគរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញចំនួន៣៣លានដុល្លារអាម៉េរិក
០ហិរញ្ញប្បទានសម្បទានរបស់AFDចំនួន១០១,៤លានដុល្លារអាម៉េរិក
- ពេលវេលាអនុវត្តគម្រោងៈ ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣
- វឌ្ឍនភាពៈ គ្រោងនឹងចាប់ផ្តើមសាងសង់នៅចុងឆ្នាំ២០២១។

**១២- គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តសៀមរាប**
- ហិរញ្ញប្បទានសម្បទានរបស់JICAចំនួនប្រមាណ១២៣លានដុល្លារអាម៉េរិក
- ទំហំគម្រោងៈ
០ស្ថានីយបូមទឹកឆៅ សមត្ថភាពចំនួន៦៦ ០០០ម.$^{៣}$/ថ្ងៃ
០រោងចក្រផលិតទឹកស្អាត សមត្ថភាពចំនួន៦០ ០០០ម.$^{៣}$/ថ្ងៃ
០បណ្តាញនាំទឹកឆៅចំនួន១៨,៤គ.ម.
០បណ្តាញមេនាំទឹកចំនួន២៣,៤គ.ម.
០បណ្តាញចែកចាយទឹកចំនួន១៩១គ.ម.

- ពេលវេលាអនុវត្តគម្រោង: ឆ្នាំ២០១២ ដល់ឆ្នាំ២០២៣

- វឌ្ឍនភាពចំនួន៦៥%។

**១៣- គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យការពារជំងឺកូវីដ-១៩ របស់រដ្ឋាករទឹកស្វយ័តសៀមរាប**

- ហិរញ្ញប្បទានឥតសំណងតាមរយៈJICAចំនួន៦៣៨ ២២០ដុល្លារអាម៉េរិក

- ទំហំគម្រោង:

  ០ ការផ្គត់ផ្គង់សារធាតុគីមីសម្អាតទឹក

  ០ បណ្តាញទឹកស្អាតចំនួន២០គ.ម.

  ០ សម្ភារៈតំណ(fittings)

  ០ សម្ភារៈបណ្តាញចូលផ្ទះចំនួន២ ៥០០តំណ

- ពេលវេលាអនុវត្តគម្រោង: ឆ្នាំ២០២១ ដល់ឆ្នាំ២០២២

- វឌ្ឍនភាព: JICA បានស្នើបញ្ចូលក្នុងបញ្ជីគម្រោង ឆ្នាំសារពើពន្ធ ២០២១។

## ៤.៨- ការងារស្តង់ដារូបនីយកម្ម

ដោយឈរលើគោលការណ៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម ដើម្បីបង្កើនសមត្ថភាព ក្នុងការប្រកួតប្រជែងទាំងទីផ្សារក្នុងស្រុកនិងបរទេស តាមរយៈការពង្រឹងគុណភាពនិងសុវត្ថិភាព ប្រសិទ្ធភាព ផលិតកម្ម និងសេវាកម្ម ស្របទៅតាមស្តង់ដាជាតិនិងអន្តរជាតិ ក៏ដូចជាចូលរួមចំណែកក្នុងការការពារសុវត្ថិភាពនិងសុខុមាលភាពអ្នកប្រើប្រាស់សាធារណៈ បរិស្ថាន និងសេដ្ឋកិច្ចនោះ ក្នុងរយៈពេល៥ឆ្នាំ (២០១៧-២០២១) កន្លងមកនេះ ស្តង់ដាចំនួន៩៨៨ ត្រូវបានអនុម័ត គឺមានការកើនឡើងខ្លាំងជិតដល់ទៅ **២៦**ដង ធៀបនឹងមុនឆ្នាំ២០១៧ ដែលមានតែ៣៨ស្តង់ដាប៉ុណ្ណោះ ក្នុងនោះរួមមាន៖

- ស្តង់ដាផលិតផលផ្នែកម្ហូបអាហារនិងម្ហូបអាហារវេចខ្ចប់ជាមុនចំនួន៣៨២ស្តង់ដា
- ស្តង់ដាផលិតផលផ្នែកឧបករណ៍អគ្គិសនី និងអេឡិចត្រូនិកចំនួន២០៦ស្តង់ដា
- ស្តង់ដាផ្នែកវិធីសាស្ត្រធ្វើតេស្តចំនួន១៧២ស្តង់ដា
- ស្តង់ដាផ្នែកសារធាតុគីមីចំនួន២៣ស្តង់ដា
- ស្តង់ដាផលិតផលផ្នែកសម្ភារៈសំណង់ចំនួន៣១ស្តង់ដា
- ស្តង់ដាផលិតផលផ្នែកយានយន្តចំនួន២៣ស្តង់ដា
- ស្តង់ដាផលិតផលផ្នែកផលិតផលពីកៅស៊ូចំនួន៥៤ស្តង់ដា
- ស្តង់ដាផលិតផលផ្នែកគ្រឿងសង្ហារិមផលិតពីឈើចំនួន៥៧ស្តង់ដា
- ស្តង់ដាពីក្រុមអនុវត្តល្អចំនួន៨ស្តង់ដា
- ស្តង់ដាផ្នែកវាក្យស័ព្ទបច្ចេកទេសចំនួន១ស្តង់ដា
- ស្តង់ដាផ្នែកប្រព័ន្ធគ្រប់គ្រងចំនួន២៤ស្តង់ដា
- ស្តង់ដាផ្នែកផលិតផលគ្រឿងសម្អាងចំនួន២ស្តង់ដា
- ស្តង់ដាផ្នែកឌីជីថលចំនួន៥ស្តង់ដា

ជាមួយគ្នានេះដែរ ការរៀបចំប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ទៅលើគុណភាព និងសុវត្ថិភាពផលិតផល និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងរបស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម ឱ្យស្របទៅតាមស្តង់ដាជាតិ ស្តង់ដា តំបន់ និងអន្តរជាតិ ក្នុងការធានាផលិតផល និងផលិតកម្មនៅកម្ពុជា ក៏បានប្រព្រឹត្តទៅស្របតាមស្តង់ដា ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ហើយកិច្ចការនេះសម្រេចបានដូចខាងក្រោម៖

**ក- ការងារជំរុញវិញ្ញាបនបត្រកម្មបាន៖**

- រៀបចំប្រជុំគណៈកម្មការវិញ្ញាបនបត្រកម្មផលិតផលចំនួន២៦១លើក
- ប្រជុំគណៈកម្មការវិញ្ញាបនបត្រកម្មប្រព័ន្ធចំនួន៣៨លើក
- រៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញតួនាទីជាមន្ត្រីច្រកចេញចូលជួរក្រោយរបស់វិទ្យាស្ថានស្តង់ដាកម្ពុជា ក្នុងនាមមន្ត្រីច្រករបស់នាយកដ្ឋានវិញ្ញាបនបត្រកម្ម
- រៀបចំបែបបទនិងនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ដោយសេរី
- រៀបចំបែបបទនិងនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់អនាម័យ
- ចេញវិញ្ញាបនបត្រដាក់លក់ផលិតផលលើទីផ្សារដោយសេរីចំនួន១មូលដ្ឋាន។

**ខ- ការងារវិញ្ញាបនបត្រកម្មផលិតផលបាន៖**

- ចុះយកគំរូផលិតផលបញ្ជូនទៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ត្រួតពិនិត្យគុណភាព ក្នុងការវាយតម្លៃភាពអនុលោមចំនួន១ ១៩២គំរូផលិតផល
- ចេញលិខិតបញ្ជាក់គុណភាពសរុបចំនួន៤៥៧វិញ្ញាបនបត្រ
- ចេញសេចក្តីជូនដំណឹងស្តីពីភាពមិនអនុលោមសរុបចំនួន១២៣ដើម្បីឱ្យធ្វើការកែលម្អ
- ចុះត្រួតពិនិត្យខ្សែចង្វាក់ផលិតកម្មរោងចក្រ សិប្បកម្ម ដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ អនាម័យ កម្រិតបឋម វិញ្ញាបនបត្រអនាម័យកម្រិតមធ្យម និងវិញ្ញាបនបត្រផលិតផលបានសរុបចំនួន២៧៩ មូលដ្ឋាន
- ចេញវិញ្ញាបនបត្រអនាម័យកម្រិតបឋមដែលបានផ្តល់ជូនរោងចក្រ សិប្បកម្ម សរុបចំនួន**២៩**វិញ្ញាបនបត្រ
- ចេញវិញ្ញាបនបត្រអនាម័យកម្រិតមធ្យមដែលបានផ្តល់ជូនរោងចក្រ សិប្បកម្ម សរុបចំនួន២៧វិញ្ញាបនបត្រ
- ចេញវិញ្ញាបនបត្រផលិតផល ដែលបានផ្តល់ជូនរោងចក្រ សិប្បកម្ម សរុបចំនួន២៨៩ វិញ្ញាបនបត្រ
- ចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោម(CoC) ដែលបានផ្តល់ជូនក្រុមហ៊ុន រោងចក្រ សរុបចំនួន ៣៣វិញ្ញាបនបត្រ
- ចេញអាជ្ញាបណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផលសម្រាប់រោងចក្រសិប្បកម្ម សរុបចំនួន៣៧០ អាជ្ញាបណ្ណ។

**គ- ការងារវិញ្ញាបនបត្រកម្មប្រព័ន្ធ**

- បានចេញនិងបន្តវិញ្ញាបនបត្រប្រព័ន្ធសរុបចំនួន៣៨ ចាប់ពី២០១៧-២០២១ សម្រាប់ប្រព័ន្ធដូច ខាងក្រោម៖
  - វិញ្ញាបនបត្រប្រព័ន្ធការអនុវត្តផលិតកម្មល្អ(GMP)
  - វិញ្ញាបនបត្រប្រព័ន្ធសុវត្ថិភាពម្ហូបអាហារ(HACCP)

- ចេញវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងគុណភាព( ISO 9001:2015 )
- វិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ( ISO 22000: 2018 )
- វិញ្ញាបនបត្របញ្ជាក់អនាម័យ

**បានចេញអាជ្ញាបណ្ណចុះទិដ្ឋាការបញ្ជាក់វិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងបានចំនួន៤១ទិដ្ឋាការ**

**តារាងសង្ខេបការចេញទិដ្ឋាការ**

| អាជ្ញាបណ្ណ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| ទិដ្ឋាការ | ៤ | ១៤ | ៨ | ១១ | ៤ | ៤១ |

### ឃ- ការងារចុះបញ្ជីផលិតផល

ដើម្បីចូលរួមទប់ស្កាត់ផលិតផលដែលគ្មានគុណភាពនិងក្លែងបន្លំផលិតផល ក៏ដូចជាការជំរុញលើកទឹកចិត្តដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ធុនតូច និងមធ្យម ឱ្យចូលរួមអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធដែលបានចូលជាធរមាន ក្រសួងបានរៀបចំបទប្បញ្ញត្តិបច្ចេកទេសបានចំនួន១៤៨ សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាព ឧបករណ៍អគ្គិសនីនិងអេឡិចត្រូនិក ផលិតផលយានយន្ត ផលិតផលម្ហូបអាហារ ដែលមានហានិភ័យចំពោះសុខភាពដល់អ្នកប្រើប្រាស់។ បន្ថែមពីនេះទៅទៀត ក្រសួងក៏បានរៀបចំប្រព័ន្ធចុះបញ្ជីផលិតផលដើម្បីឱ្យស្របទៅតាមគោលការណ៍អន្តរជាតិនិងកិច្ចសម្របសម្រួលទទួលស្គាល់ទៅវិញទៅមកនៅក្នុងអាស៊ាន ក្នុងការបញ្ជាក់ពីសុវត្ថិភាពដល់អ្នកប្រើប្រាស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ចេញអាជ្ញាបណ្ណចុះបញ្ជីផលិតផល ប្រភេទម្ហូបអាហារ«ចបផ» បានចំនួន៣ ៩៩០អាជ្ញាបណ្ណ
- ចេញអាជ្ញាបណ្ណចុះបញ្ជីសុវត្ថិភាពឧបករណ៍អគ្គិសនី និងអេឡិចត្រូនិក បានចំនួន៣ ៥៨៥អាជ្ញាបណ្ណ
- ចេញអាជ្ញាបណ្ណចុះបញ្ជីសុវត្ថិភាពផលិតផលរបស់យានយន្តបានចំនួន២៨២អាជ្ញាបណ្ណ
- ចេញលិខិតទទួលស្គាល់ក្រុមហ៊ុនចំនួន១៥ក្រុមហ៊ុន
- ចេញលិខិតបញ្ជាក់ការផ្លាស់ប្តូរផ្នែកណាមួយនៃផលិតផលយានយន្តបានចំនួន១៤លិខិត

**តារាងសង្ខេបការចេញលិខិត/អាជ្ញាបណ្ណ**

| លិខិត/អាជ្ញាបណ្ណ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| ច.ប.ផ. | ៤៧៩ | ៧៣០ | ៧២៧ | ១១០២ | ៩៥២ | ៣,៩៩០ |
| អគ្គិសនីនិងអេឡិចត្រូនិក | ៥៥០ | ៦៩៨ | ៦៨៩ | ៨៥៧ | ៧៩១ | ៣,៥៨៥ |
| យានយន្ត | 0 | 0 | ៥៦ | ១៦០ | ៦៦ | ២៨២ |
| តំណាងក្រុមហ៊ុន | 0 | 0 | 0 | ១០ | ៥ | ១៥ |
| លិខិតកែតម្រូវ | 0 | 0 | 0 | ២ | ១២ | ១៤ |

កត្តាចម្បងនៃការរៀបចំប្រព័ន្ធចុះបញ្ជីផលិតផលនិងចុះបញ្ជីសុវត្ថិភាពផលិតផល គឺផ្តោតទៅលើអត្ថប្រយោជន៍ ដូចខាងក្រោម៖

- កាត់បន្ថយការកេងប្រវ័ញ្ចលើការធ្វើពាណិជ្ជកម្មមិនស្របច្បាប់
- ការពារសុខុមាលភាពសាធារណៈ តាមរយៈការប្រើប្រាស់ផលិតផលមិនមានសុវត្ថិភាព
- កាត់បន្ថយហានិភ័យឬគ្រោះមហន្តរាយ តាមរយៈការប្រើប្រាស់ឧបករណ៍អគ្គិសនី និងអេឡិចត្រូនិកដែលមិនមានសុវត្ថិភាព ដូចជាការឆក់ចរន្តអគ្គិសនីឬអគ្គិភ័យដែលបណ្តាលមកពីឧបករណ៍ទាំងនេះមិនមានគុណភាពនិងសុវត្ថិភាព។ល។

បន្ថែមពីនេះ ក្រសួងក៏បានចូលរួមសកម្មភាពការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការបញ្ចូលសារអប់រំក្នុងស្លាកផលិតផលនូវពាក្យស្លោក«គ្រឿងញៀននាំមកនូវគ្រោះថ្នាក់ដល់សុខភាព»។

### ៤.៩- វិស័យមាត្រាសាស្ត្រជាតិ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានជំរុញឱ្យសមត្ថកិច្ចគ្រប់គ្រង និងដឹកនាំអនុវត្តលើវិស័យមាត្រាសាស្ត្រ ប្រកបដោយភាពត្រឹមត្រូវ យុត្តិធម៌ និងភាពជឿជាក់ ដោយមានការទទួលស្គាល់សមត្ថភាពនៃមន្ទីរពិសោធន៍ព្យាសកម្មកម្រិតអន្តរជាតិ។ ដើម្បីធ្វើសុខដុមនីយកម្មជាមួយស្ថាប័នមាត្រាសាស្ត្រក្នុងតំបន់និងអន្តរជាតិ ម.ម.ជ. បានពង្រឹងសមត្ថភាពរហូតបានចូលជាសមាជិករបស់អង្គការអន្តរជាតិនានា។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលមានមន្ទីរពិសោធន៍ព្យាសកម្មនៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រត្រូវបានទទួលការវាយតម្លៃទទួលស្គាល់ ដោយជោគជ័យក្រោមកិច្ចសហការរវាង DAនិងBoA ឆ្លើយតបតាមតម្រូវការបទប្បញ្ញត្តិនិងលក្ខណវិនិច្ឆ័យសមត្ថភាពរបស់មន្ទីរពិសោធន៍ អនុលោមតាមស្តង់ដា ISO/IEC 17025:2005 និងច្បាប់ស្តីពីស្តង់ដាកម្ពុជា។ ការងារមាត្រាសាស្ត្រផ្តល់នូវការធានាឱ្យការធ្វើពាណិជ្ជកម្ម មានភាពយុត្តិធម៌ សមធម៌ និងត្រឹមត្រូវ ជានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ផលិតផលទំនិញ និងសេវាកម្ម ធ្វើឱ្យមានជំនឿនិងទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និងបរិស្ថាន។ ជាមួយគ្នានេះដែរ ការងារមាត្រាសាស្ត្រ គឺជាធាតុចូលមួយបន្ថែមទៀត រួមចំណែកក្នុងការរក្សានិរន្តរភាពនិងសន្ទុះកំណើននៃសេដ្ឋកិច្ចជាតិ ដោយបានធ្វើឱ្យសម្រេចនូវសមិទ្ធផលជាច្រើន សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ឈានដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិបានសម្រេចនូវសមិទ្ធផលការងារដូចមានខាងក្រោម៖

#### ៤.៩.១- ហេដ្ឋារចនាសម្ព័ន្ធ

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានប្តូរទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាមួយការកែសម្រួលតួនាទីភារកិច្ចឱ្យបានសមស្របទៅនឹងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

#### ៤.៩.២- ការងារកិច្ចការទូទៅ ការងារបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំការងារសហប្រតិបត្តិការគម្រោងនិងផែនការ

**ក- ការងារកិច្ចការទូទៅបាន៖**

- រៀបចំកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.)៣ឆ្នាំរំកិល(ចាប់ពីឆ្នាំ២០១៧-២០២១) របស់ម.ម.ជ.

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីឆ្នាំ២០១៧-២០២១(សូចនាករ ចំណូល និងចំណាយ) របស់ ម.ម.ជ.

- បានអនុវត្តវិធានការគោលនយោបាយ២៤ចំណុចក្នុងតារាង(MTR) និងបានធ្វើរបាយការណ៍វឌ្ឍនភាពពាក់កណ្តាលអាណត្តិ(២០១៥-២០២១)នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥

- រៀបចំនិងបំពេញព័ត៌មានសមិទ្ធកម្មស្តីពី ការអនុវត្តម៉ាទ្រីសសកម្មភាពរបស់យុទ្ធសាស្ត្រសមាហរណកម្ម ពាណិជ្ជកម្មកម្ពុជា(Cambodia Trade Integration Strategy) ២០១៩-២០២៣ របស់ម.ម.ជ.

- បានរៀបចំលិខិតស្នើសុំថវិកាជារូបិយបណ្ណអន្តរជាតិ សម្រាប់បង់វិភាគទានសមាជិកភាពជារៀងរាល់ឆ្នាំ ជូនអង្គការអន្តរជាតិនិងតំបន់ ផ្នែកមាត្រាសាស្ត្រ សម្រាប់ប្រទេសកម្ពុជាដូចខាងក្រោម៖

- បង់ជូនអង្គការវេទិកានីត្យានុកូលមាត្រាសាស្ត្រតំបន់អាស៊ីប៉ាស៊ីហ្វិក(APLMF) ចំនួន៦៧៥ដុល្លារ/១ឆ្នាំ
- បង់ជូនអង្គការនីត្យានុកូលមាត្រាសាស្ត្រអន្តរជាតិ(OIML)ចំនួន១ ៤០០អឺរូ ស្មើនឹង១ ៧២៨,៩៦ ដុល្លារអាម៉េរិកក្នុង១ឆ្នាំ
- បង់ជូនអង្គកា កម្មវិធីមាត្រាសាស្ត្រអាស៊ីប៉ាស៊ីហ្វិក(APMP) ចំនួន៦០០ដុល្លារអាម៉េរិកក្នុង១ឆ្នាំ
- បង់ជូនការិយាល័យទម្ងន់និងរង្វាស់រង្វាល់(International Bureau of Weights and Measures BIPM) ចំនួន១២ ៤៨០Eurosក្នុង១ឆ្នាំ

- បានរៀបចំលើករណីស្នើផ្តល់នូវទិន្នន័យគម្រោងស្រាវជ្រាវ ដែលបានអនុវត្តដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រ ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១ ដើម្បីជាធាតុចូលក្នុងការរៀបចំទស្សនាវដ្តី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានចំនួន៦គម្រោង ដូចជា ១. Technical Regulation for Verification of Electricity Meters for Measuring Alternating Current Electrical Energy ២. Development of Metrological Sector Strategic Planning for 5years ៣. Digitalization: A global challeng in Metrology ៤.OIML Certification System ៥.Measurement Uncertainties and Measurement Errors ៦. Roadmap Initiative for Sustainable Metrology Development

- ចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលនៃមន្ទីរពិសោធន៍សំណង់ និងសាធារណការនៃក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់អាណត្តិទី៥

- ទទួលឧបករណ៍ស្តង់ដាម៉ាសចំនួន២គ្រឿង តាមរយៈកិច្ចសហការទ្វេភាគី ម.ម.ជ. និងNIM, China ក្រោមគម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡាងឆាង ដែលឧបករណ៍ស្តង់ដាម៉ាស់ទាំងនេះ ត្រូវប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ ម.ម.ជ. ដើម្បីបម្រើសេវាកម្មជូនអតិថិជន និងសិក្សាស្រាវជ្រាវ មានដូចជា ១. Mass Comparator MCM 10K3 ២. Microbalance MY A21.4Y។

**ខ- ការផ្តល់សេវាសាធារណៈបាន៖**

- ផ្តល់វិញ្ញាបនបត្រព្យាសកម្មឧបករណ៍មាត្រាសាស្ត្រជូនក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាព បានចំនួនសរុប២ ៩១៥គ្រឿង

- ធ្វើព្យាសកម្មលើឧបករណ៍មាត្រាសាស្ត្រជូនមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត បានចំនួន៨៨៣គ្រឿង

- ត្រួតពិនិត្យផ្ទៀងផ្ទាត់ស៊ីទែនរថយន្តបានចំនួន៥១៧គ្រឿង និងត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងថ្លឹងរថយន្ត បានចំនួន៤២៤គ្រឿង

- ចេញអាជ្ញាបណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ជូនក្រុមហ៊ុន ចំនួន១៧(អាជ្ញាបណ្ណថ្មី៦ និងបន្តអាជ្ញាបណ្ណ១១)

- ចេញអាជ្ញាបណ្ណផលិត ជួសជុលឧបករណ៍មាត្រាសាស្ត្រ ជូនក្រុមហ៊ុនចំនួន៩(អាជ្ញាបណ្ណថ្មី៤ និងបន្តអាជ្ញាបណ្ណ៥)

-ចេញវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រចំនួន១ ២១៤មូលដ្ឋាន និងបន្តវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រចំនួន១ ១៦៩មូលដ្ឋាន សរុបចំនួន២ ៣៨៣មូលដ្ឋាន ជូនក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងមូលដ្ឋានធ្វើអាជីវកម្ម ដែលពាក់ព័ន្ធវិស័យមាត្រាសាស្ត្រ ដោយបែងចែកតាមប្រភេទអាជីវកម្មដូចខាងក្រោម៖

- ចុះបញ្ជីមាត្រាសាស្ត្រ(ចុះបញ្ជីថ្មីនិងបន្តសុពលភាពចុះបញ្ជី) លើផ្នែកស្ថានីយ ដេប៉ូប្រេងឥន្ធនៈ ហ្គាស ចំនួន២ ០៧៨មូលដ្ឋាន
- ចុះបញ្ជីមាត្រាសាស្ត្រ(ចុះបញ្ជីថ្មីនិងបន្តសុពលភាពចុះបញ្ជី) លើផ្នែកពាក់ព័ន្ធឧបករណ៍មាត្រាសាស្ត្រ ចំនួន៣០២មូលដ្ឋាន
- ចុះបញ្ជីមាត្រាសាស្ត្រ(ចុះបញ្ជីថ្មីនិងបន្តសុពលភាពចុះបញ្ជី) លើផ្នែកទំនិញផលិត និងទំនិញវេចខ្ចប់ ចំនួន២០៨មូលដ្ឋាន។

**តារាងទី១ ការផ្តល់សេវាសាធារណៈព្យាសកម្មឧបករណ៍មាត្រាសាស្ត្រ**

| ល.រ. | បរិយាយ | ចំនួនសេវាដែលបានផ្តល់តាមឆ្នាំ | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (គិតត្រឹមខែតុលា) |
| ១ | ក្រុមហ៊ុន រោងចក្រ សហគ្រាស | ៥៣៥គ្រឿង | ៥៣១គ្រឿង | ៥៦៤គ្រឿង | ៧២៥គ្រឿង | ៥៦០គ្រឿង |
| ២ | មន្ទីរ ឧ.វ.ប.ន រាជធានី ខេត្ត | ៦០គ្រឿង | ១២១គ្រឿង | ៣៧១គ្រឿង | ២០៣គ្រឿង | ១២៨គ្រឿង |
| **សរុប** | | **៥៩៥គ្រឿង** | **៦៥២គ្រឿង** | **៩៣៥គ្រឿង** | **៩២៨គ្រឿង** | **៦៨៨គ្រឿង** |

**ការធ្វើព្យាសកម្មឧបករណ៍មាត្រាសាស្ត្ររបស់ក្រុមហ៊ុន**
**រោងចក្រ សហគ្រាស(ពីឆ្នាំ២០១៧ ដល់ខែតុលា ឆ្នាំ២០២១)**



## ការធ្វើព្យាសកម្មឧបករណ៍មាត្រាសាស្ត្ររបស់មន្ទីរ ឧ.វ.ប.ន. រាជធានី ខេត្ត
## (ពីឆ្នាំ២០១៧ ដល់ខែតុលា ឆ្នាំ២០២១)




## តារាងទី២ ការផ្តល់សេវាសាធារណៈត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ

| ល.រ. | បរិយាយ | ចំនួនសេវាដែលបានផ្តល់តាមឆ្នាំនីមួយៗ | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | ដៃបាញ់ប្រេង | ៧៩២៤ដៃ | ១៨២៩០ដៃ | ២៤៤៧៩ដៃ | ២៧៧៤២ដៃ | ១៦៦៩៦ដៃ |
| ២ | រថយន្តស៊ីទែន | ៨៩គ្រឿង | ១១៨គ្រឿង | ១០១គ្រឿង | ១២៣គ្រឿង | ៨៦គ្រឿង |
| ៣ | ជញ្ជីងថ្លឹងរថយន្ត | ៧១គ្រឿង | ៦១គ្រឿង | ១៦១គ្រឿង | ៧៧គ្រឿង | ៥៤គ្រឿង |
| ៤ | ឧបករណ៍ផ្សេងៗ | ២៧គ្រឿង | - | - | - | - |
| ៥ | ទំនិញវេចខ្ចប់ | ១០៩ផលិតផល | ២៩ផលិតផល | ៣៧៤ផលិតផល | ៤៧៦ផលិតផល | ៣៨០ផលិតផល |
| ៦ | ជញ្ជីងមេកានិកតាមផ្សារ | ៧៨ជញ្ជីង | ៨៧៧ជញ្ជីង | ១០៩៥ជញ្ជីង | ៤៧៦ជញ្ជីង | ៣៦១ជញ្ជីង |

## ដ្យាក្រាមការផ្តល់សេវាសាធារណៈតាមឆ្នាំនីមួយៗ




## តារាងទី៣ ការផ្តល់សេវាសាធារណៈចុះបញ្ជីមាត្រាសាស្ត្រ
## ស្ថិតិចុះបញ្ជីមាត្រាសាស្ត្រ(ថ្មី និងបន្តសុពលភាពចុះបញ្ជី) ចាប់ពីឆ្នាំ២០១៧-២០២១






## ៥- ការជំរុញវិស័យទេសចរណ៍និងផ្នែកសេវាកម្មានា

### ៥.១- ការអភិវឌ្ឍផលិតផលទេសចរណ៍

#### ៥.១.១- រមណីយដ្ឋានទេសចរណ៍ វប្បធម៌ ធម្មជាតិ និងកែច្នៃ

រយៈពេល៥ឆ្នាំ(២០១៧-២០២១) រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងទេសចរណ៍ជាសេនាធិការ បានខិតខំប្រឹងប្រែងជំរុញការអភិរក្ស និងការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍នៅគ្រប់រាជធានីខេត្តទូទាំងប្រទេស។ បច្ចុប្បន្ន យើងមានរមណីយដ្ឋានទេសចរណ៍ដែលត្រូវបានចុះបញ្ជីផ្លូវការប្រមាណ៥៥៧កន្លែង រួមមានរមណីយដ្ឋានទេសចរណ៍១៨១កន្លែង រមណីយដ្ឋានទេសចរណ៍កែច្នៃ៤២កន្លែង រមណីយដ្ឋានទេសចរណ៍ធម្មជាតិកែច្នៃ២៧កន្លែង រមណីយដ្ឋានទេសចរណ៍វប្បធម៌២៥កន្លែង រមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រ៦១កន្លែង រមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ១២៤កន្លែង រមណីយដ្ឋានកសិទេសចរណ៍១៤កន្លែង រួមជាមួយកន្លែងដែលមានសក្តានុពលទេសចរណ៍ជាច្រើនទៀតក្នុងការទទួលភ្ញៀវទេសចរ។

ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍បានរៀបចំការប្រឡងប្រណាំងរមណីយដ្ឋានទេសចរណ៍គំរូបានចំនួន៣លើក ដោយជ្រើសរើសបានរមណីយដ្ឋានទេសចរណ៍ដែលមានលក្ខណៈស្តង់ដា ក្នុងនោះ ឆ្នាំ២០១៧ មានរមណីយដ្ឋានជ័យលាភីចំនួន២២កន្លែង ឆ្នាំ២០១៨ មានរមណីយដ្ឋានជ័យលាភីចំនួន២៦កន្លែង និងឆ្នាំ២០១៩ មានរមណីយដ្ឋានជ័យលាភីចំនួន២៦កន្លែង។ ដោយឡែក ក្នុងបរិបទជំងឺកូវីដ-១៩ ក្រសួងទេសចរណ៍បានដាក់ចេញវិធានសុវត្ថិភាពទេសចរណ៍និងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា(SOP) សម្រាប់រមណីយដ្ឋានទេសចរណ៍ដើម្បីធានាចរន្តភ្ញៀវទេសចរផ្ទៃក្នុងមិនឱ្យការរីករាលដាលនៃជំងឺកូវីដ-១៩។

ព្រមជាមួយនេះ តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ក្រសួងទេសចរណ៍បានរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប(២០២១-២០៣៥) ផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប(២០២១-២០៣៥)។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់ផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប(២០២១-២០៣៥) កាលពីខែមីនា ឆ្នាំ២០២១ និងផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី(២០២១-២០៣៥) កាលពីខែសីហា ឆ្នាំ២០២១។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការដឹកនាំអនុវត្តន៍ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី តាមរយៈអនុក្រឹត្យលេខ២១៤ អនុក្រ.បក ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២១ ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន។

### ៥.១.២- ការអភិវឌ្ឍតំបន់សមុទ្រ

បន្ទាប់ពីបានជាប់ជាអនុប្រធានក្លឹបទទួលបន្ទុកតំបន់អាស៊ី-ប៉ាស៊ីហ្វិកសម្រាប់អាណត្តិទី១ កម្ពុជាបានបន្តជាប់ឆ្នោតជាអនុប្រធានក្លឹបទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់អាណត្តិទី២ (២០១៥-២០១៨)។ បន្ទាប់មកកម្ពុជាបានបន្តឈានមកកាន់អគ្គនាយករងក្លិប(Directeur-Général Adjoint) សម្រាប់អាណត្តិទី៣(២០១៨-២០២១)តាមរយៈអង្គមហាសន្និបាតក្លឹបលើកទី១៤ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨។

ទន្ទឹមនឹងនេះ នាឱកាសប្រារព្ធពិធីបុណ្យសមុទ្រលើកទី៧ ឆ្នាំ២០១៨ នៅខេត្តកោះកុង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអនុញ្ញាតឱ្យលោកប្រ៊ូយណូ បូដាដ(Bruno Bodard) អគ្គនាយកក្លឹបបានជួបសំដែងការគួរសម និងពិភាក្សាការងារ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨ នៅខេត្តកោះកុង។ ជាលទ្ធផលនៃជំនួបនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានឯកភាពជាគោលការណ៍តាមសំណើរបស់លោក ប្រ៊ូយណូ បូដាដ(Bruno Bodard) រៀបចំមហាសន្និបាតក្លិបលើកទី១៨ ឆ្នាំ២០២២ នៅឆ្នេរសមុទ្រកម្ពុជា។

### ៥.១.៣- ការខារៀបចំសហគមន៍ទេសចរណ៍ សហគមន៍អេកូទេសចរណ៍

រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍(ក.គ.អ.អ.) តាមរយៈសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ១០០ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ដែលមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថានជាអនុប្រធានអចិន្ត្រៃយ៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអនុប្រធាន និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានីខេត្តជាសមាជិក។ ក្រោមកិច្ចខិតខំប្រឹងប្រែងបំពេញការងារក្នុងក្របខ័ណ្ឌនៃក្រុមការងារអន្តរក្រសួងនេះ ការងារជាច្រើនត្រូវបានរៀបចំនិងដាក់ចេញ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់គោលនយោបាយជាតិអេកូទេសចរណ៍(២០១៩-២០៣០) កាលពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី១៩ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំប្រារព្ធវេទិកាជាតិអេកូទេសចរណ៍ក្នុងនោះ វេទិកាជាតិអេកូទេសចរណ៍លើកទី១ អមជាមួយពិធីប្រកាសដាក់ឱ្យប្រើប្រាស់គោលនយោបាយជាតិអេកូទេសចរណ៍ ត្រូវបានរៀបចំឡើងក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចតេជោនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ហើយវេទិកាជាតិអេកូទេសចរណ៍លើកទី២ ត្រូវបានរៀបចំឡើងនាថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០២១ នៅខេត្តសៀមរាប ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងារអន្តរក្រសួង(ក.គ.អ.អ.) តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចតេជោនាយករដ្ឋមន្ត្រី។

ជាលទ្ធផលការងារសំខាន់ៗនៃក្រុមការងារអន្តរក្រសួងនេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ តាមរយៈអនុក្រឹត្យលេខ១២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ដោយមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថានជាអនុប្រធានអចិន្ត្រៃយ៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអនុប្រធាន និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ រួមជាមួយអភិបាលនៃគណៈអភិបាលខេត្តជាសមាជិក។

ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍បានរៀបចំការប្រឡងប្រណាំងសហគមន៍ទេសចរណ៍គំរូបានចំនួន ២លើក ដោយជ្រើសរើសបានរមណីយដ្ឋានទេសចរណ៍ដែលមានលក្ខណៈស្តង់ដា ក្នុងនោះ ឆ្នាំ២០១៨មាន សហគមន៍ជ័យលាភីចំនួន១៥ កន្លែង និងឆ្នាំ២០១៩ មានសហគមន៍ជ័យលាភីចំនួន១៥កន្លែង។ ព្រមជាមួយនេះ ក្រសួងទេសចរណ៍បានដាក់ចេញវិធានសុវត្ថិភាពទេសចរណ៍និងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា(SOP) សម្រាប់ សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ ដើម្បីធានាចរន្តភ្ញៀវទេសចរផ្ទៃក្នុងមិនឱ្យការរីករាលដាលនៃជំងឺកូវីដ-១៩។

#### ៥.១.៤- ការងាររៀបចំព្រឹត្តិការណ៍ទេសចរណ៍

ក្នុងគោលដៅជំរុញចលនាទេសចរណ៍ក្នុងស្រុក ក៏ដូចជាការទាក់ទាញទេសចរអន្តរជាតិមកកាន់កម្ពុជា ឱ្យកាន់តែច្រើនថែមទៀត ចាប់ពីឆ្នាំ២០១៧ដល់ឆ្នាំ២០២១ ក្រសួងបានរៀបចំឱ្យមានព្រឹត្តិការណ៍ទេសចរណ៍ធំៗ ជាច្រើន រួមមានពិធីបុណ្យអង្គរសង្ក្រាន្តនៅពេលបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ នៅរមណីយដ្ឋានអង្គរ ពិធីបុណ្យ សមុទ្រចំនួន៣លើក នៅតាមបណ្តាខេត្តជាប់មាត់សមុទ្រទាំង៤ រួមមានខេត្តកែប កំពត កោះកុង ដោយឡែកនៅ ខេត្តព្រះសីហនុក្នុងឆ្នាំ២០២០ ត្រូវបានលើកពេលដោយសារបញ្ហាការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ប៉ុន្តែត្រូវបាន គ្រោងមកប្រារព្ធឆ្នាំ២០២១វិញ និងពិធីបុណ្យទន្លេចំនួន៤លើក ក្នុងនោះ រួមមានខេត្តស្ទឹងត្រែង ខេត្តកណ្តាល កំពង់ឆ្នាំង ខេត្តបាត់ដំបង និងត្រៀមរៀបចំនៅខេត្តកំពង់ធំក្នុងឆ្នាំ២០២១ ព្រមទាំងព្រឹត្តិការណ៍ទេសចរណ៍ជា ច្រើនទៀតដែលបានទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិរាប់សិបម៉ឺននាក់មកទស្សនា។

### ៥.២- ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

#### ៥.២.១- ស្ថិតិឧស្សាហកម្មទេសចរណ៍

គិតត្រឹមឆ្នាំ២០២០នេះ នៅព្រះរាជាណាចក្រកម្ពុជាមានសណ្ឋាគារសរុប១ ០២៨ទីតាំង ស្មើនឹង ៤៤ ៤២៨បន្ទប់ ផ្ទះសំណាក់មាន២ ៧៥៥ទីតាំង ស្មើនឹង៣៥ ៧៩១បន្ទប់ ភោជនីយដ្ឋានមាន៣ ៣៥៩ទីតាំង ម៉ាស្សាមាន៦៥១ទីតាំង សេវាកម្សាន្តទេសចរណ៍មាន១ ២៧៨កន្លែង ក្នុងនោះ(អាជីវកម្មខារ៉ាអូខេមានចំនួន ៩៦៧អាជីវកម្ម អាជីវកម្មរង្គសាលមានចំនួន១៣អាជីវកម្ម អាជីវកម្មឌីស្កូតែកមានចំនួន១២៥អាជីវកម្ម អាជីវកម្ម បៀរហ្គាឌិនមានចំនួន១៧៣អាជីវកម្ម) អាជីវកម្មកីឡាទេសចរណ៍មានចំនួន៣១អាជីវកម្ម។

ទីភ្នាក់ងារទេសចរណ៍មាន៦៨៦កន្លែង ក្រុមហ៊ុនដឹកជញ្ជូនភ្ញៀវទេសចរ២៧ក្រុមហ៊ុន និងមគ្គុទេសក៍ ទេសចរមាន៦ ៤៩២នាក់។

#### ៥.២.២- មគ្គុទ្ទេសក៍ទេសចរណ៍គិតត្រឹមឆ្នាំ២០២១

| ល.រ. | ភាសា | សៀមរាប-អង្គរ | ភ្នំពេញ | ព្រះវិហារ | តំបន់ផ្សេរ |
|---|---|---|---|---|---|
| ១ | ចិន | ១ ២៥០នាក់ | ២៦៦នាក់ | - | ៥នាក់ |
| ២ | អង់គ្លេស | ១ ៧០៥នាក់ | ៣៨៦នាក់ | - | ៣៣នាក់ |
| ៣ | បារាំង | ៣២៤នាក់ | ១៤៧នាក់ | - | - |
| ៤ | អាល្លឺម៉ង់ | ១១២នាក់ | ៥៤នាក់ | - | - |
| ៥ | អ៊ីតាលី | ២៩នាក់ | ១៣នាក់ | - | - |
| ៦ | ជប៉ុន | ៨៣៥នាក់ | ៨៧នាក់ | - | - |
| ៧ | កូរ៉េ | ២៦១នាក់ | ១២នាក់ | - | - |
| ៨ | ម៉ាឡេស៊ី | ៥នាក់ | ១០នាក់ | - | - |

| | | | | | |
|---|---|---|---|---|---|
| ៩ | រុស្ស៊ី | ៨១នាក់ | ២៧នាក់ | - | - |
| ១០ | អេស្ប៉ាញ | ១៥៣នាក់ | ២៩នាក់ | - | - |
| ១១ | ថៃ | ៤៣៤នាក់ | ១៥នាក់ | - | ១នាក់ |
| ១២ | វៀតណាម | ១២៣នាក់ | ៨៤នាក់ | - | ១២នាក់ |
| **សរុប** | | **៥ ៣១២នាក់** | **១ ១៣០នាក់** | **-** | **៥១នាក់** |

## ៥.២.៣- ប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍

ប្រព័ន្ធចំណាត់ថ្នាក់នេះដាក់ឱ្យអនុវត្តដោយអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍។

គិតត្រឹមឆ្នាំ២០២០ មានសណ្ឋាគារសរុបទូទាំងប្រទេសចំនួន១៧០សណ្ឋាគារ ត្រូវបានចាត់ថ្នាក់តាមលំដាប់ផ្កាយ ក្នុងនោះ សណ្ឋាគារផ្កាយ៥ មានចំនួន៤២ទីតាំង ស្មើនឹង១១ ៥១៥បន្ទប់ សណ្ឋាគារផ្កាយ៤ មានចំនួន៤២ទីតាំង ស្មើនឹង៤ ៨៨៧បន្ទប់ សណ្ឋាគារផ្កាយ៣ មានចំនួន៣៦ទីតាំង ស្មើនឹង២ ៨៨៧បន្ទប់ សណ្ឋាគារផ្កាយ២ មានចំនួន១៩ទីតាំង ស្មើនឹង៩៦៩បន្ទប់ និងសណ្ឋាគារផ្កាយ១ មានចំនួន៣៤ទីតាំង ស្មើនឹង១ ៥១២បន្ទប់។

**✰ ស្ថិតិចំណាត់ថ្នាក់សណ្ឋាគារនិងសេវាស្នាក់នៅទេសចរណ៍**

ស្ថិតិផលធៀបកំណើន ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍តាមលំដាប់ផ្កាយនៅទូទាំងរាជធានី ខេត្តឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០

| ល.រ. | រាជធានី ខេត្ត | ឆ្នាំ២០១៨ | ស្ថិតិឆ្នាំ២០១៨ធៀបនឹងឆ្នាំ២០១៩ | | ស្ថិតិឆ្នាំ២០១៩ធៀបនឹងឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | | ចំនួន | ឆ្នាំ២០១៩ | ធៀប% | ឆ្នាំ២០២០ | ធៀប% |
| ១ | រាជធានីភ្នំពេញ | ៣៣ | ៤៥ | ៣៦,៣% | ៥២ | ១៥,៥% |
| ២ | ខេត្តសៀមរាប | ៦៣ | ៥៤ | -១៤,២% | ៥៥ | ១,៨% |
| ៣ | ខេត្តព្រះសីហនុ | ៦ | ១៩ | ២១៦,៦% | ២២ | ១៥,៧% |
| ៤ | ខេត្តកំពត | ៤ | ៥ | ២៥% | ៥ | 0 |
| ៥ | ខេត្តកណ្តាល | ២ | ២ | 0 | ៣ | ៥0% |
| ៦ | ខេត្តបាត់ដំបង | ៨ | ៩ | ១២,៥% | ៩ | 0 |
| ៧ | ខេត្តកំពង់ធំ | ២ | ២ | 0 | ២ | 0 |
| ៨ | ខេត្តស្វាយរៀង | ១ | ១ | 0 | ១ | 0 |
| ៩ | ខេត្តមណ្ឌលគិរី | ៥ | ៥ | 0 | ៥ | 0 |
| ១០ | ខេត្តពោធិ៍សាត់ | ៣ | ២ | -៣៣,៣% | ២ | 0 |
| ១១ | ខេត្តកំពង់ចាម | ៨ | ១០ | ២៥% | ១៥ | ៥0% |
| ១២ | ខេត្តកែប | ៤ | ៤ | 0 | ៤ | 0 |
| ១៣ | ខេត្តបន្ទាយមានជ័យ | 0 | ២ | ១00% | ៣ | ៥0% |
| **សរុប** | | **១៣៩** | **១៦0** | **៥១,១%** | **១៧៨** | **១១,២៥%** |

ស្ថិតិសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ដែលមានចំណាត់ថ្នាក់តាមលំដាប់ផ្កាយនៅទូទាំងរាជធានី ខេត្ត

| | | 1 STAR | | 2 STAR | | 3 STAR | | 4 STAR | | 5 STAR | | GRAND TOTAL | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| No. | CAPITAL/ PROVINCE | TOTAL | ROOMS | TOTAL | ROOMS | TOTAL | ROOMS | TOTAL | ROOMS | TOTAL | ROOMS | TOTAL | ROOMS |
| ១ | SIEM REAP | ២ | ៧៥ | ២ | ៧៧ | ៦ | ៣១០ | ២៣ | ២ ៣៧៥ | ២២ | ៤ ៧៨១ | **៥៥** | **៧ ៦១៨** |
| ២ | PHNOM PENH | ៨ | ៤១០ | ៨ | ៤៧៧ | ១៥ | ១ ៤៤៦ | ១០ | ១ ៧១៧ | ៨ | ៣ ៤៥១ | **៤៩** | **៧ ៥០១** |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣ | SIHANOUKVILLE | ៧ | ២២៨ | ២ | ៥២ | ៣ | ២០៦ | ៥ | ៤០០ | ៦ | ១ ៥២៦ | **២២** | **២ ៤១២** |
| ៤ | BATTAMBANG | ៣ | ១២៥ | ១ | ៥៦ | ៤ | ៤១៤ | ១ | ១២៨ | 0 | 0 | **៩** | **៧២៣** |
| ៥ | KAMPOT | ១ | ៤០ | 0 | 0 | ១ | ៤៣ | ២ | ១៧៣ | ១ | ៥៦៤ | **៥** | **៨២០** |
| ៦ | KEP | 0 | 0 | 0 | 0 | ១ | ១០០ | ១ | ១២ | ២ | ៣៤ | **៤** | **១៤៦** |
| ៧ | KANDAL | 0 | 0 | ១ | ២៥ | ២ | ៧៣ | 0 | 0 | 0 | 0 | **៣** | **៩៨** |
| ៨ | K.CHAM | ៨ | ៤០២ | ៣ | ១៨៥ | 0 | 0 | 0 | 0 | 0 | 0 | **១១** | **៥៨៧** |
| ៩ | SVAY RIENG | 0 | 0 | 0 | 0 | 0 | 0 | ១ | ១៨៤ | 0 | 0 | **១** | **១៨៤** |
| ១០ | MONDULKIRI | ១ | ៤៧ | ១ | ៧៣ | ៣ | ១៥១ | 0 | 0 | 0 | 0 | **៥** | **២៧១** |
| ១១ | K.THOM | ២ | ១០៣ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **២** | **១០៣** |
| ១២ | B.MEANCHEY | ១ | ៤២ | ១ | ៥៨ | 0 | 0 | 0 | 0 | 0 | 0 | **២** | **១០០** |
| ១៣ | PURSAT | ១ | ៤០ | 0 | 0 | ១ | ១៤៤ | 0 | 0 | 0 | 0 | **២** | **១៨៤** |
| **TOTAL** | | **៣៤** | **១ ៥១២** | **១៩** | **១ ០០៣** | **៣៦** | **២ ៨៨៧** | **៤៣** | **៤ ៩៨៩** | **៣៩** | **១០៣៥៦** | **១៧០** | **២០៧៤៧** |

តារាងនេះបានបង្ហាញស្ថិតិនៅតាមបណ្តាររាជធានីខេត្តត្រឹមចំនួន១៣ មានន័យថាខេត្តចំនួន១២ផ្សេងទៀតដែលពុំមានរំលេចក្នុងតារាងនេះគឺនៅពុំទាន់មានសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដែលមានចំណាត់ថ្នាក់នៅឡើយទេ។

យោងតាមទិន្នន័យក្នុងតារាងខាងលើ យើងសង្កេតឃើញបច្ចុប្បន្នមានសណ្ឋាគារប្រមាណ១៦% ប៉ុណ្ណោះដែលបានឆ្លងកាត់ការវាយតម្លៃនិងផ្តល់ចំណាត់ថ្នាក់ផ្កាយ។

### ៥.២.៤- ការជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍

ដាក់ចេញវិធានសុវត្ថិភាពទេសចរណ៍ ក្នុងជំហានទី១ មានចំនួន៨សេវាកម្ម រួមមាន (១) រមណីយដ្ឋានទេសចរណ៍ (២) សហគមន៍ទេសចរណ៍ (៣) ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ (៤) សេវាកម្មស្នាក់នៅទេសចរណ៍ (៥) ដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក (៦) ដឹកជញ្ជូនទេសចរណ៍ផ្លូវគោក (៧) ការីទេសចរណ៍ក្នុងស្រុក និង(៨) មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត និងក្នុងជំហានទី២ មាន៦សេវាកម្ម រួមមាន(១) សេវាមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ(បៀហ្គាឌិន ខារ៉ាអូខេ រង្គសាល និងឌីស្កូតែក) និង(២) សេវាកម្មស្ប៉ា និងម៉ាស្សា។

វិធានសុវត្ថិភាពទេសចរណ៍ គឺជាសូចនាករគន្លឹះជួយតម្រង់ទិសអនុវត្តរបស់អាជីវកម្មទេសចរណ៍ក្នុង **«គន្លងប្រក្រតីភាពថ្មី»** ជាពិសេសការអនុវត្តវិធានការ**«៣ការពារ និង៣កុំ»**។

បន្ថែមលើនេះ ក្រសួងទេសចរណ៍បានដាក់ចេញនូវ នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា សម្រាប់សេវាកម្មនីមួយៗ ក្នុងទិសដៅសម្រួលដល់អាជីវកម្មអាចប្រើប្រាស់ឯកសារទាំងនេះជាឧបករណ៍ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់បុគ្គលិក។

## ៥.៣- ការខារជំរុញវិស័យទេសចរណ៍

### ក្រសួងទេសចរណ៍

#### ក- ការសិក្សានិងផ្សព្វផ្សាយទេសចរណ៍ផ្ទៃក្នុង

ក្នុងគោលដៅជំរុញចលនាទេសចរណ៍ផ្ទៃក្នុង និងផ្សព្វផ្សាយបញ្ញាបការយល់ដឹងអំពីទេសចរណ៍ឱ្យបានកាន់តែទូលំទូលាយ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ក្រសួងបានដាក់ចេញនូវយន្តការ និងការរៀបចំនិងផលិតឯកសារផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈជាច្រើនដែលមានដូចខាងក្រោម៖

### ១- ការផ្សព្វផ្សាយទេសចរណ៍ផ្ទៃក្នុងតាមប្រព័ន្ធឌីជីថល

ក្រសួងទេសចរណ៍បានដាក់ចេញនូវយន្តការផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍ក្នុងស្រុក សំដៅជំរុញចលនាទេសចរណ៍និងផ្តល់ភាពងាយស្រួលសម្រាប់ភ្ញៀវទេសចរ ដែលមានដូចជាកម្មវិធីទូរសព្ទចល័ត(Mobile App) Visit Cambodia និងគេហទំព័រVisitcambodia.com។ ទន្ទឹមនេះ ក្រសួងបានចងក្រងនិងផលិតឯកសារអប់រំឌីជីថល ដែលមានដូចជាE-journal សម្រាប់ផ្សព្វផ្សាយអំពីព័ត៌មាន និងចំណេះដឹងអំពីវិស័យទេសចរណ៍។ ជាងនេះទៅទៀត ក្រសួងបានសហការផ្សព្វផ្សាយកម្មវិធីទេសចរណ៍ជាមួយស្ថានីយទូរទស្សន៍ក្នុងស្រុកដែលមានដូចជាកម្មវិធីTourism Talk Show និងកម្មវិធីខ្ញុំស្រឡាញ់កម្ពុជា ជាមួយស្ថានីយទូរទស្សន៍ និងវិទ្យុអាស៊ីអាគ្នេយ៍SEATV កម្មវិធី«ផ្លូវទៅស្រុកវត្ត៣» ជាមួយក្រុមហ៊ុនសប្បាយ កម្រងវីដេអូផ្សព្វផ្សាយទេសចរណ៍កម្ពុជាក្រោមប្រធានបទ «**កម្ពុជាអស្ចារ្យ Amazing Cambodia**» ជាមួយក្រុមហ៊ុន Amazing Trip Planner និងស្ប៉ុតវីដេអូផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍ដែលមានសក្តានុពលទេសចរណ៍នានាជាច្រើនទៀត។

### ២- ការជំរុញទេសចរណ៍ផ្ទៃក្នុង

ដើម្បីជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនិងបង្កើនភាពទាក់ទាញនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងបានរៀបចំនូវ«**វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣**» ដើម្បីជំរុញ និងស្តារវិស័យទេសចរណ៍ផ្ទៃក្នុងឡើងវិញក្រោយរងវិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាបានសិក្សានិងរៀបចំ«**ស្តង់ដាមណ្ឌលព័ត៌មានទេសចរកម្ពុជា**» និងធ្វើការចុះផ្សព្វផ្សាយនិងសិក្សា និងពង្រឹងការគ្រប់គ្រងនៅតាមមណ្ឌលព័ត៌មានទេសចរកម្ពុជានៅតាមបណ្តាខេត្ត។ ជាងនេះទៅទៀត ក្រសួងធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌតំបន់សក្តានុពលទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានសក្តានុពលទេសចរណ៍ដែលបានធ្វើបច្ចុប្បន្នភាពចប់រួចរាល់មានចំនួន ១ ០៩៩កន្លែង ដើម្បីជំរុញចលនាទេសចរណ៍ទេសចរណ៍ផ្ទៃក្នុង។ ទន្ទឹមនេះ ក្រសួងបានរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ សម្រាប់រមណីយដ្ឋានតេទឹកពុះ ទំនប់ស្ទឹងតាសាល និងអន្លង់ភេតាពយ ដោយផ្តោតលើទេសចរណ៍ផ្ទៃក្នុងនិងក្រៅស្រុក ការធានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍតាមសហគមន៍មូលដ្ឋាន ការគ្រប់គ្រងវិស័យទេសចរណ៍គ្រប់ជ្រុងជ្រោយ និងសមាហរណកម្មជាមួយផែនការអភិវឌ្ឍនានា។ ក្រសួងក៏បានបង្កើតគំរូផែនការទេសចរណ៍ទីក្រុងសម្រាប់សង្កាត់គំរូ និងបង្កើតគំរូមគ្គុទ្ទេសក៍ទេសចរណ៍វៃឆ្លាតសម្រាប់ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

## ៥.៤- ភ្ញៀវទេសចរជាតិនិងអន្តរជាតិ និងស្ថិតិទេសចរណ៍ និងការបង្កើតការងារ

| សូចនាករ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | លាននាក់ | ៥,៦០ | ៦,២០ | ៦,៦១ | ១,៣១ |
| ទេសចរជាតិ | លាននាក់ | ១០,៨៦ | ១១,០៦ | ១១,៣២ | ៧,២៣ |
| ទេសចរជាតិចេញក្រៅ | លាននាក់ | ១,៧៥ | ១,៩៩ | ២,០៤ | ០,៣៣ |
| មូលដ្ឋានអាជីវកម្មទេសចរណ៍ | អាជ្ញាបណ្ណ | ១៥ ៥៧៤ | ១៥ ៨៣៩ | ១៦ ២២១ | ១៥ ៣៣១ |
| សេវាកម្មស្នាក់នៅ | បន្ទប់ | ៧៤ ៥៥៦ | ៨១ ៥៣៦ | ៨៤ ៥២៨ | ៨០ ២១៩ |
| មុខរបរ និងការងារទេសចរណ៍ | ពាន់នាក់ | ៥៥០ | ៦២០ | ៦៣០ | ៣០០ |
| ចំណូលទេសចរណ៍អន្តរជាតិ | លានដុល្លារ | ៣ ៦៣៨ | ៤ ៣៧៥ | ៤ ៩១៩ | ១ ០២៣ |

## ៥.៥- ស្ថិតិភ្ញៀវទេសចរអន្តរជាតិទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរសៀមរាប

<table>
<tr><td colspan="5">ផ្នែកទី១១ ចំនួនភ្ញៀវនិងចំណូលពីការលក់សំបុត្រចូលទស្សនាទីតាំងវប្បធម៌</td></tr>
<tr><td colspan="5">ក- រមណីយដ្ឋានអង្គរ</td></tr>
<tr><th>ល.រ.</th><th>ប្រភេទភ្ញៀវ</th><th colspan="2">ចំនួនភ្ញៀវ</th><th>ចំណូលពីការលក់សំបុត្រ<br>(គិតជាដុល្លារអាម៉េរិក)</th></tr>
<tr><td colspan="5">១.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ</td></tr>
<tr><td rowspan="10">១</td><td rowspan="10">ភ្ញៀវទេសចរអន្តរជាតិ<br>(បង់ថ្លៃចូលទស្សនា)</td><td colspan="3">២០១៧</td></tr>
<tr><td colspan="2">២ ៤៥៧ ០២៣នាក់</td><td>១០៧ ៩៧៦ ៤៣៩ដុល្លារអាម៉េរិក</td></tr>
<tr><td colspan="3">២០១៨</td></tr>
<tr><td colspan="2">២ ៥៩០ ៨១៥នាក់</td><td>១១៦ ៦៤៦ ៦៨៥ដុល្លារអាម៉េរិក</td></tr>
<tr><td colspan="3">២០១៩</td></tr>
<tr><td colspan="2">១ ៦៦២ ៥១៣នាក់</td><td>៧៤ ៣៤០ ១៨១ដុល្លារអាម៉េរិក</td></tr>
<tr><td colspan="3">២០២០</td></tr>
<tr><td colspan="2">៣៩៦ ២៤១ នាក់</td><td>១៨ ៤៥៦ ៣០៧ដុល្លារអាម៉េរិក</td></tr>
<tr><td colspan="3">២០២១ (មករា - ខែតុលា ឆ្នាំ២០២១)</td></tr>
<tr><td colspan="2">៧ ២៨៦នាក់</td><td>២៩៩ ៧៧៧ដុល្លារអាម៉េរិក</td></tr>
<tr><td rowspan="11">២</td><td rowspan="11">ភ្ញៀវអន្តរជាតិ<br>(ទស្សនាដោយឥតបង់ថ្លៃ)</td><td>អ្នកស្រាវជ្រាវ</td><td>ប្រតិភូអន្តរជាតិ</td><td rowspan="12"></td></tr>
<tr><td colspan="2">២០១៧</td></tr>
<tr><td>៩៥៨នាក់</td><td>៦២១នាក់</td></tr>
<tr><td colspan="2">២០១៨</td></tr>
<tr><td>៤៦៩នាក់</td><td>៥៧៣នាក់</td></tr>
<tr><td colspan="2">២០១៩</td></tr>
<tr><td>៤៨៨នាក់</td><td>៦៥៥នាក់</td></tr>
<tr><td colspan="2">២០២០</td></tr>
<tr><td>១៤៥នាក់</td><td>៣៣នាក់</td></tr>
<tr><td colspan="2">២០២១</td></tr>
<tr><td>៥០នាក់</td><td>៤នាក់</td></tr>
<tr><td>៣</td><td>ភ្ញៀវជាតិ</td><td colspan="2"></td></tr>
</table>

## ៦- ការងារចំណូលពីសេវាវិស័យដីធ្លីនិងសំណង់ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឯកតា៖រៀល

| ឆ្នាំ | សេវាសុរិយោដី | សេវាសំណង់ | ការជួលទីតាំងរោងចក្រ | ពន្ធលើការផ្ទេរអចលនវត្ថុ |
|---|---|---|---|---|
| ២០១៧ | ៤២ ៤៧១ ១៥៨ ១១៥ | ១៣ ១៧៧ ៩០៥ ៣៩៧ | ២៧៧ ០៣៦ ០៩០ | ៣១៥ ០៩៥ ៣៧៩ ០០៣ |
| ២០១៨ | ៥៨ ៤៦៦ ១៩៦ ៧២៦ | ៣៨ ១២២ ៦៩៩ ៧៧២ | ២៨១ ៦៤៨ ៨៨៨ | ៥៣៣ ៨៣៧ ៧៧៤ ៥១៣ |
| ២០១៩ | ៥៩ ០០០ ៥៨៥ ៦៧៧ | ៦៩ ៦២២ ៥៧៨ ៥៧១ | ២៨០ ៤៦៦ ៦១៦ | ៣៦២ ៧៥៨ ៦៨៦ ៤០៥ |
| ២០២០ | ៥៩ ១២២ ៨០៩ ៧៨១ | ៥៨ ៨២២ ៨៥៦ ២០១ | ២៨៣ ៣៩៦ ៥៣៩ | ៣៦១ ៥៩៥ ១០៦ ៨៤១ |

| ៩ខែ ឆ្នាំ ២០២១ | ៤៤ ៦៤២ ៨៦៩ ៥៤១ | ៣៤ ៧៩៨ ៨៣៦ ៣២៥ | ១១ ២៥៩ ៨៦៤ | ៩៩ ៦៥៨ ៤២៩ ៣១៥ |
|---|---|---|---|---|
| សរុប | ២៦៣ ៧០៣ ៦១៩ ៨៤០ | ២១៤ ៥៤៤ ៨៧៦ ២៦៦ | ១ ១៣៣ ៨០៧ ៩៩៧ | ១ ៦៧២ ៩៤៥ ៣៧៦ ០៧៧ |

**៧- ការងារហិរញ្ញវត្ថុ និងថវិកា(រដ្ឋបាលកណ្តាលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)**

ចំណូលរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៧ ដល់៩ខែ ដើមឆ្នាំ២០២១) ដូចក្នុងតារាងខាងក្រោមនេះ៖

| ឆ្នាំអនុវត្ត | ផែនការ | អនុវត្ត | | | ប្រៀបធៀប ផែនការឆ្នាំ(%) |
|---|---|---|---|---|---|
| | KHM(រៀល) | KHMER(រៀល) | USD(ដុល្លារ) | សរុបគិតជារៀល | |
| | ១ | ២ | ៣ | ៤ | ៥=៤/១ |
| ឆ្នាំ២០១៧ | ១៦៦ ៨៥០ ០០០ ០០០ | ២៤៥ ១៩៦ ៥៣០ | ២៩ ១៦៨ ១៣៨,៣៦ | ១១៨៥០១៣០៨៣៥៣ | ៧១,០២% |
| ឆ្នាំ២០១៨ | ១៩៨ ៣៦៧ ០០០ ០០០ | ១២០៨៨២៨២៧៣ | ៣៩ ៧៨៦ ៤៩៧,៥៩ | ១៦២៥៧០៨២៤៧៥០ | ៨១,៩៥% |
| ឆ្នាំ២០១៩ | ២០៧ ៧៨៤ ០០០ ០០០ | ៦ ६៧៣ ៨៨៦ ៥៣៤ | ៥៣ ០៣៥ ០៥៣,៦៧ | ២២២១១៧២០២២៦ | ១០៦,៩០% |
| ឆ្នាំ២០២០ | ១៩០ ២៤១ ០០០ ០០០ | ៦ ២៤១ ០៨០ ៧២២ | ៤៥ ៨៣៥ ៨៤២,៥៨ | ១៩២៣៩២៦១៨៨១៤ | ១០១,១៣% |
| ៩ខែដើម ឆ្នាំ២០២១ | ៣១៤ ៦៨៩ ០០០ ០០០ | ១ ៥៩៩ ៧១១ ១៥០ | ៥៩ ២៩៧ ៨៤៨,៦៧ | ១៩៣៦៥៦៣៦៨៣៩៤ | ៦១,៥៤% |

- ចំណាយថវិការដ្ឋរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៧ ដល់៩ខែដើម ឆ្នាំ២០២១) ដូចក្នុងតារាងខាងក្រោមនេះ៖

ឯកតា: រៀល

| ឆ្នាំអនុវត្ត | ផែនការ | | អនុវត្ត | ប្រៀបធៀប(%) |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | ឥណទានថ្មី | | |
| ឆ្នាំ២០១៧ | ៤៥ ១៩៤ ៣០០ ០០០ | ៨១ ៨៣៧ ៩៧១ ០០០ | ៧៤ ៥៨៣ ៧៩៣ ២៥៩ | ៩១,១៤% |
| ឆ្នាំ២០១៨ | ៥០ ៩៥៨ ១០០ ០០០ | ៦៧ ៤៤៩ ៧០០ ០០០ | ៦៤ ៣៩១ ៧៩៦ ៦៣៧ | ៩៥,៤៧% |
| ឆ្នាំ២០១៩ | ៥៦ ៩៤០ ១០០ ០០០ | ៩៨ ១៦៩ ១០០ ០០០ | ៩៥ ៥០៣ ៦៣៥ ២៨៩ | ៩៧,២៨% |
| ឆ្នាំ២០២០ | ៥៩ ៨២២ ៤០០ ០០០ | ៨៥ ៩៤១ ៩០០ ០០០ | ៨០ ៧៥៧ ៦៩១ ១៨៤ | ៩៣,៩៧% |
| ៩ខែ ដើមឆ្នាំ២០២១ | ៦០ ៦១៦ ០០០ ០០០ | ៩៥ ២២៨ ១៣៧ ៥០០ | ៧៦ ២៦៨ ៤៣៧ ៥៨៣ | ៨០,០៩% |

**មុំទី៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤**

**ក្រសួងប្រៃណីយ៍និងទូរគមនាគមន៍ សម្រេចការងារដូចខាងក្រោម៖**

ក្នុងការកិច្ចបន្តអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនទៅមុខ រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ នៅតែដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍ សេដ្ឋកិច្ចឌីជីថល។ ការបន្តរៀបចំប្រព័ន្ធប្រៃសណីយ៍ឱ្យមានលក្ខណៈទំនើបទាន់សម័យ មានគុណភាពខ្ពស់តាមស្តង់ដា អន្តរជាតិជាតម្រូវការចាំបាច់ សម្រាប់លើកកម្ពស់ចំណូលចិត្តរបស់ប្រជាជនឱ្យកាន់តែនិយមប្រើប្រាស់សេវាប្រៃសណីយ៍។ ទន្ទឹមនេះ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃវិស័យទូរគមនាគមន៍បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តាមទំនើបកម្មនៃបច្ចេកវិទ្យាស្របតាមស្តង់ដាជាសកល នៅដំណាក់កាលផ្លាស់ប្តូរថ្មី គឺបដិវត្តន៍ឧស្សាហកម្មទី៤ បានជំរុញឱ្យក្រសួងត្រូវយកចិត្តទុកដាក់ខ្ពស់ធ្វើកំណែទម្រង់ ដោយផ្តោតជាអាទិភាពអំពីគុណភាព អំពីតម្លៃប្រកួតប្រជែង អំពីសេវាគ្របដណ្តប់ទូទាំងប្រទេស ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនទូទៅអាចប្រើប្រាស់បានគ្រប់ទីកន្លែង គ្រប់ពេលវេលា មានតម្លៃសមរម្យ។ សកម្មភាពទាំងនេះ គឺជាចលករជួយជំរុញ

បន្ថែមទៀត ដើម្បីធ្វើយ៉ាងណាលើកកម្ពស់ជីវភាពគ្រួសារនិងសហគមន៍ក្នុងទិសដៅជួយកាត់បន្ថយចម្ងាយផ្លូវ ពេលវេលានិងការចំណាយដែលធ្លាប់មានពីមុនរបស់ប្រជាជន ដែលបច្ចុប្បន្ននេះរាជរដ្ឋាភិបាលមានទិសដៅពង្រីក ការកសាងបណ្តាញហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍តភ្ជាប់រហូតដល់ភូមិ ឃុំ ទីជនបទ ដើម្បីជួយកាត់បន្ថយគម្លាត ឌីជីថល។ ដូចនេះ សមិទ្ធផលដែលទទួលបានពីការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦ នៃរដ្ឋសភា ពី(ឆ្នាំ២០១៧ ដល់ ៩ខែឆ្នាំ២០២១) សង្ខេបដូចតទៅៈ

## ១- វិស័យប្រៃសណីយ៍

### ១.១- ការងារគ្រប់គ្រងនិងត្រួតពិនិត្យទៅលើប្រតិបត្តិករអាជីវកម្មវិស័យប្រៃសណីយ៍

- បានប្រមូលព័ត៌មានពាក់ព័ន្ធនឹងថ្លៃសេវាប្រៃសណីយ៍ពីបណ្តាប្រតិបត្តិករ ដើម្បីសិក្សាថ្លៃដើម និង កំណត់ថ្លៃ សេវាប្រៃសណីយ៍

- បានប្រជុំដើម្បីតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពនៃការគ្រប់គ្រងការធ្វើអាជីវកម្មសេវាប្រៃសណីយ៍ ជាមួយមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តទាំងអស់

- បានរៀបចំរបាយការណ៍បរិមាណផលិតផលរបស់បណ្តាប្រតិបត្តិករប្រៃសណីយ៍ដូចតារាងខាងក្រោមៈ

ឯកតា: បញ្ញើ

| បញ្ញើ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១(ត្រឹមខែកញ្ញា) |
|---|---|---|---|---|---|
| -បញ្ជូនចេញ | ៨១៣ ៥២៩ | ៤០៧ ៩១២ | ៤២១ ០១៩ | ៥៨៣ ៦១៨ | ១៨៨ ៨៦៦ |
| -ទទួលបាន | ១៧១ ១៨២ | ៥៧៧ ៥២៩ | ៥៣៩ ០៦៦ | ៤៩៧ ៥៦០ | ៨០៤ ៣៦៧ |
| **សរុប** | **៩៨៤ ៧១១** | **៩៨៥ ៤៤១** | **៩៦០ ០៨៥** | **១ ០៨១ ១៧៨** | **៩៩៣ ២៣៣** |

- ចូលរួមដោះស្រាយវិវាទរវាងប្រតិបត្តិករនិងអតិថិជននិងប្រតិបត្តិករនិងស្ថាប័នពាក់ព័ន្ធបាន៧ករណី

- ចុះត្រួតពិនិត្យ និងរៀបចំរបាយការណ៍ក្រុមហ៊ុន១៥៣ ដែលគ្មានអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័ស អន្តរជាតិ

- ចុះតាមដាននិងត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌនៃអាជ្ញាបណ្ណបញ្ញើឆាប់រហ័សអន្តរជាតិ របស់ ប្រតិបត្តិករប្រៃសណីយ៍បានចំនួន៥២ក្រុមហ៊ុន

- បន្តសុពលភាពអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិជូនក្រុមហ៊ុនចំនួន២១

- ចេញអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិជូនក្រុមហ៊ុនថ្មីចំនួន១២

- ចុះត្រួតពិនិត្យក្រុមហ៊ុនបានចំនួន៣៣ មុនចេញអាជ្ញាបណ្ណ

- ចេញលិខិតអនុញ្ញាតបើកសាខាថ្មីចំនួន២ នៅរាជធានីភ្នំពេញ(សម្រាប់សាខាចំនួន១១០ នៅតាម បណ្តាខេត្ត ចេញលិខិតអនុញ្ញាតដោយមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត)

- ចូលរួមប្រជុំស្តីពីការបង្កើតក្រុមការងារ និងលេខាធិការដ្ឋានចំណុះអនុកម្មាធិការទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបញ្ញើប្រៃសណីយ៍

- ចុះទៅត្រួតពិនិត្យបញ្ញើប្រៃសណីយ៍ដែលមានគ្រឿងញៀននៅតាមក្រុមហ៊ុនបានចំនួន៦លើក។

- ចូលរួមបើកកញ្ចប់សេវាប្រៃសណីយ៍ ដែលសង្ស័យមានសារធាតុញៀននៅសាលាដំបូងរាជធានី ភ្នំពេញបានចំនួន៥លើក

- ចូលរួមបើកកញ្ចប់សេវាប្រៃសណីយ៍ ដែលសង្ស័យមានសារធាតុញៀននៅនាយកដ្ឋានសន្តិសុខផ្ទៃ ក្នុងនៃអគ្គស្នងការនគរបាលជាតិបានចំនួន៥លើក

- ជំនួបពិភាក្សាជាមួយធនាគារប្រៃសណីយ៍កម្ពុជានិងក្រុមហ៊ុនវីង ដើម្បីពិនិត្យលទ្ធភាពសហការសម្រាប់ប្រៃសណីយ៍សញ្ញ័យ ការបើកគណនីសន្សំខ្នាតតូច និងធានារ៉ាប់រង។

**១.២- សហគ្រាសប្រៃសណីយ៍កម្ពុជា**

ប្រៃសណីយ៍កម្ពុជា បាននឹងកំពុងបន្តការអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅទាំងផ្នែករចនាសម្ព័ន្ធរដ្ឋបាល ផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស។ សមិទ្ធផលដែលសម្រេចបានរយៈពេល៥ឆ្នាំ(២០១៧-២០២១)៖

- បានអភិវឌ្ឍឱ្យប្រសើរប្រព័ន្ធគ្រប់គ្រងអាជីវកម្ម Counter Automation ដោយបន្ថែម(Core Post Mana- gement System, Office Exchange Management and Stock Delivery Management)

- អភិវឌ្ឍឱ្យប្រសើរប្រព័ន្ធគណនេយ្យ PeachTree ទៅ Sage 50

- តាមដានបញ្ញើក្នុង និងក្រៅប្រទេសតាមរយៈប្រព័ន្ធ International Postal System (IPS)

- បង្កើតសេវាថ្មី E-Commerce , E Solution ដោយសហការជាមួយក្រុមហ៊ុន Tinh Tinh

- បំពាក់ Mobile Scanner ឱ្យគ្រប់កន្លែងចែកសេវា EM

- រថយន្តចែកបញ្ញើចំនួន ៥២គ្រឿង(បច្ចុប្បន្ន) និងម៉ូតូចែកបញ្ញើចំនួន ៧៣គ្រឿង(បច្ចុប្បន្ន)

- បង្កើតសេវា Logistic តាមរយៈរថយន្តប្រៃសណីយ៍

- សាងសង់អគារសាខាប្រៃសណីយ៍កម្ពុជានៅស្រុកមោងឫស្សី ខេត្តបាត់ដំបង(ឆ្នាំ២០១៧) ស្រុកបាកាន ខេត្តកំពង់ឆ្នាំង(ឆ្នាំ២០១៨) ស្រុករតនៈមណ្ឌលខេត្តបាត់ដំបង(ឆ្នាំ២០១៨) ស្រុកជីក្រែង ខេត្តសៀមរាប (ឆ្នាំ២០១៨) និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ(ឆ្នាំ២០១៨) អគារប្តូរបញ្ញើទីស្នាក់ការកណ្តាល(ឆ្នាំ២០១៩)

- បានបង្កើនប្រាក់បៀវត្ស(ឆ្នាំ២០១៧)ចំនួន១ ៤៩៩ ៧២៧ដុល្លារអាម៉េរិក (ឆ្នាំ២០១៨)ចំនួន ២ ១៩៨ ៦៥១ដុល្លារអាម៉េរិក(ឆ្នាំ២០១៩)ចំនួន២ ២៩៣ ៩៧២ដុល្លារអាម៉េរិក(ឆ្នាំ២០២០) ចំនួន ២ ៥៧៨ ៧៥៧ដុល្លារអាម៉េរិក(គម្រោងផែនការថវិកា ឆ្នាំ២០២១ ចំនួន២ ៤៤៩ ៤៧៧ដុល្លារអាម៉េរិក)។

ឯកតាគិត : ដុល្លារអាម៉េរិក

| **សូចនាករ<br>ចំណូល** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **មករា-មិថុនា<br>២០២១** | **សរុប៥ឆ្នាំ** |
|---|---|---|---|---|---|---|
| ១- បញ្ញើឆាប់រហ័ស | ៤ ៦៦៥ ៩២៩ | ៥ ៧៧៦ ៣៨០ | ៥ ៧៣៤ ១៨០ | ៤ ៥១៩ ៣៨៥ | ២៦៦៨៥១៩ | ២៣៣៦៤៣៩៣ |
| ២- ប្រៃសណីយ៍កណ្ឌ | ១ ២០០ ៧៤៩ | ១ ២៧១ ៥៥៨ | ១ ០២៨ ១៧៦ | ២៩៦ ៦៧៩ | ៣ ៨២៧ | ៣ ៨០០ ៩៨៩ |
| ៣- បញ្ញើកញ្ចប់ និងលិខិត | ៣៨៦ ៧០០ | ៣៩២ ៤២៩ | ២៥៤ ៨៣៨ | ១២៣ ១៣៩ | ២៧ ០៩៩ | ១ ១៨៤ ២០៥ |
| ៤- បែងចែកបញ្ញើអន្តរជាតិ | ១ ៣៦៧ ៣០៣ | ៤ ៩៧៥ ៩៨២ | ៤ ១៧៣ ៦៧៦ | ១ ១២០ ២២៣ | ៥ ១៣១ | ១១ ៦៤១ ៣១៥ |
| ៥- ផលិតផលប្រៃសណីយ៍ | ២៨២ ៦៨៣ | ២០៩ ១៨៩ | ១៨៧ ៦៨៧ | ៨១ ៤៨០ | ៣៣ ២២៦ | ៧៩៤ ២៥៦ |
| ៦-សេវាអាណត្តិ<br>ប្រៃសណីយ៍ | ២០ ៩៩១ | ២៨ ៨៩៦ | ២៣ ៨៦៥ | ៣២ ៧៨៦ | ៩ ៥០៤ | ១៣១ ០៤២ |
| ៧- រថយន្តដឹកអ្នកដំណើរ | ១៦០ ៣៤១ | ១៥៤ ២៣៩ | ១៣៩ ៣៥៩ | ៦០ ១០៦ | ៨ ១៥៧ | ៥២២ ២០២ |
| ៨- ចំណូលផ្សេងៗ | ៤១២ ៧១៦ | ៤៩១ ៤១៧ | ២០៤ ៥៦៦ | ២៩៧ ៣៥៤ | ២២៣៦៧២ | ១៦២៩៧២៥ |
| **សរុបចំណូល** | **៨ ៤៩៧ ៤១២** | **១៣៣០០០៩០** | **១១៧៦០៣៤៧** | **៦ ៥៣១ ១៥២** | **២៩៧៩១៣៤** | **៤៣ ០៦៨ ១៣៥** |

## ២- វិស័យទូរគមនាគមន៍

សមិទ្ធផលរយៈពេល៥ឆ្នាំ(២០១៧-២០២១) ដែលសម្រេចបាន ឬបានរួមចំណែកក្នុងសកម្មភាពការងារដូចខាងក្រោម៖

- ចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ពិសេសលិខិតបទដ្ឋានដែលចង្អុលបង្ហាញ ដោយច្បាប់ស្ដីពីទូរគមនាគមនាគមន៍ ក្នុងនោះ លិខិតបទដ្ឋាន ដើម្បីដាក់ឱ្យដំណើរការយន្តការកាតព្វកិច្ចសេវាសកល ទូរគមនាគមន៍(USO)

- រៀបចំទាំងការងារបទប្បញ្ញត្តិ និងការងារបច្ចេកទេសដែលពាក់ព័ន្ធនឹងការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា(DMC)។ ជាលទ្ធផលទិន្នន័យ ដែលផលិតដោយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ សេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា(DMC) ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្របតាមប្រកាសរួមលេខ១៣៥ បទ.ប្រក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨ រួមចំណែកក្នុងការបង្កើនប្រសិទ្ធភាពនៃការកៀរគរចំណូលនៅក្នុងវិស័យទូរគមនាគមន៍

- បណ្ដាញខ្សែកាបក្រោមបាតសមុទ្រចំនួន២ខ្សែ បានដាក់ឱ្យដំណើរការជាផ្លូវការ រួមមានMCT (Malaysia-Cambodia-Thailand)។ ក្រុមហ៊ុន TelcoTech តំណាងកម្ពុជានៅក្នុងបណ្ដាញខ្សែកាបក្រោមបាតសមុទ្រនេះ ក្នុងនោះ ប្រវែង៤៧០គ.ម.នៃប្រវែងខ្សែកាបសរុប១ ៣០០គ.ម. ស្ថិតក្នុងដែនទឹកកម្ពុជា និងតភ្ជាប់ពីស្ថានីយឡើងគោក(CLS) ខេត្តព្រះសីហនុ(កម្ពុជា) Rayong(ថៃ) និងCherating(ម៉ាឡេស៊ី) ព្រមទាំងធ្វើប្រតិបត្តិការផ្លូវការចាប់ពីឆ្នាំ២០១៧ ក្នុងល្បឿន៤៨០Gbps ហើយចំណុះសមត្ថភាពអាចដំណើរការបានរហូតដល់៣០Tbps។ ចំណែកខ្សែកាប ក្រោមបាតសមុទ្រមួយខ្សែទៀតគឺAAE-1 (Asia-Africa-Europe 1) ក៏បានដាក់ឱ្យដំណើរការចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៧។ ខ្សែកាបក្រោមបាតសមុទ្រAAE-1 មានប្រវែងសរុប២៥ ០០០គ.ម. តភ្ជាប់ ២០ប្រទេស និងមានចំណុះសមត្ថភាពដំណើរការរហូតដល់៤០Tbps ក្រុមហ៊ុនតំណាងកម្ពុជា គឺក្រុមហ៊ុន CFOCN

- ការកសាងហេដ្ឋារចនាសម្ព័ន្ធក្រោមក្របខ័ណ្ឌនៃមូលនិធិកាតព្វកិច្ចសេវាសកល ដែលផ្ដោតលើតំបន់ជនបទ មិនទាន់មានសេវាទូរគមនាគមន៍ ឬសេវាគ្របដណ្ដប់នៅមានកម្រិត នៅតែជាអាទិភាពត្រូវបានយកចិត្តទុកដាក់ខ្ពស់ និងបន្តអនុវត្តជាបន្តបន្ទាប់។ គិតតាំងពីពេលចាប់ផ្ដើមដំណើរការនៅក្នុងឆ្នាំ២០១៧ រហូតមកដល់ឆ្នាំ២០២១ នៅទូទាំងប្រទេសទាំង ស្ថានីយទូរសព្ទចល័ត ដែលត្រូវបន្ថែមសមត្ថភាព និងការសាងសង់ថ្មី ដើម្បីផ្ដល់សេវាអ៊ីនធឺណិតបានមានប្រមាណជិត៣០០ស្ថានីយ(BTS)។ តាមរយៈការពង្រីកហេដ្ឋារចនាសម្ព័ន្ធនេះអាចសម្រួលដល់ការតភ្ជាប់សេវាទូរគមនាគមន៍ដល់ប្រជា ពលរដ្ឋប្រមាណជិត៥០ម៉ឺននាក់បន្ថែមទៀត។

## ៣- វិស័យបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន

បានផ្ដោតការយកចិត្តទុកដាក់លើកិច្ចការចម្បងៗ ដូចជាការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល ការជំរុញរដ្ឋាភិបាលអេឡិចត្រូនិក ការគ្រប់គ្រងសន្តិសុខព័ត៌មាន បន្តការគ្រប់គ្រង និងការអភិវឌ្ឍកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន ជូនក្រសួង ស្ថាប័ន ព្រមទាំង បន្តរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀត។

- រៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានខ្លីៗ ជូនក្រសួង ស្ថាប័ន បណ្ដាអង្គភាពពាក់ព័ន្ធ មន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងតំបន់ជនបទ អ្នកចូលរួមសរុបចំនួន ១០ ៨៨៧នាក់(ស្រី២ ៤០៣នាក់ ស្មើនឹង ២២,០៧%)

- រៀបចំកម្មវិធីប្រគួតប្រជែងពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានបាន ចំនួន១២លើក

- រៀបចំអនុក្រឹត្យចំនួន២(អនុក្រឹត្យលេខ ១១០អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគនាគមន៍និងព័ត៌មាន និងអនុក្រឹត្យលេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីហត្ថលេខាឌីជីថល)

- រៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឆ្នាំ២០២០ និងផែនការមេ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជាឆ្នាំ២០២០

- ផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតចំនួន៣០៩ ជូនក្រុមហ៊ុនប្រកបអាជីវកម្មវិស័យបច្ចេកវិទ្យាគមនា គមន៍និងព័ត៌មាន

- អភិវឌ្ឍប្រព័ន្ធកម្មវិធីសុសវែរចំនួន១១ និងកំពុងសិក្សាចំនួន៤ ជូនក្រសួង ស្ថាប័ន

- តភ្ជាប់និងជួសជុលខ្សែកាបអុបទិកប្រវែង១០២ ៤៩៧គ.ម. ជូនក្រសួង ស្ថាប័នសម្រាប់ប្រើប្រាស់អ៊ីនធឺណិត

- ផ្សាយបន្តផ្ទាល់ និងបញ្ជូនឯកសារតាមប្រព័ន្ធបញ្ជូន ទទួល(doc.cambodia.gov.kh) និងតេឡេក្រាម (Telegram) ទៅកាន់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធអំពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងកិច្ចប្រជុំឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់របស់រាជរដ្ឋាភិបាលតាមរយៈប្រព័ន្ធវីដេអូនៃសន្និសីទចំនួន៣៣ លើក និងសម្របសម្រួលបច្ចេកទេសសម្រាប់កិច្ចប្រជុំ GMS 7th Summit កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៨ លើកទី៣៩ កិច្ចប្រជុំប្រធានគណៈកម្មាធិការក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន និងសន្និសីទកំពូលផ្សេងៗទៀត ចំនួន១៤លើក តាមប្រព័ន្ធវីដេអូនៃសន្និសីទជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

- ចុះពិនិត្យ ថែទាំបណ្តាញ និងឧបករណ៍បច្ចេកទេសប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលនៅបណ្តាខេត្តទាំង២៤ ស្មើនឹង៧៦លើក

- បង្កើតដំណភ្ជាប់(Link) សម្រាប់ការប្រជុំ និងសិក្ខាសាលាតាមប្រព័ន្ធអនឡាញចំនួន៣ ១៧៣លើក

- ផ្តល់អាសយដ្ឋានអ៊ីនធឺណិតសាធារណៈ(Public IP Address) ចំនួន១៦៩ ជូនក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចំនួន៤៥

- ត្រួតពិនិត្យចំណុចខ្សោយ ឬភាពងាយរងគ្រោះរបស់វេបសាយចំនួន៧៥ ដែលកំពុងដំណើរការលើម៉ាស៊ីនមេរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- ផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានបានឆ្លើយតបរបាយការណ៍អំពីឧប្បទេវហេតុ (Incident Reports) ចំនួន២៤៥ករណី ភាគច្រើនទទួលបានពីក្រសួង ស្ថាប័ន ក្រុមហ៊ុន ធនាគារ នៅក្នុងប្រទេសកម្ពុជា និងក្រុមឆ្លើយតបបន្ទាន់នៃបញ្ហាកុំព្យូទ័រ(Computer Emergency Response Team-CERT) របស់ប្រទេសក្នុងតំបន់និងពិភពលោក ដូចជាប្រទេសថៃ អេស្ប៉ាញ ហ្វាំងឡង់ គុយបា កាហ្សាក់ស្ថាន ព័រទុយហ្គាល់ ជប៉ុន រុស្ស៊ី អេស្តូនី ហ្វីលីពីន លីទុយអានី អំពីករណីវាយប្រហារ Distribute Denial of Service (DDoS) អ៊ីមែល និង ហ្វេសប៊ុកបោកបញ្ឆោតលក់ទំនិញតាមអនឡាញ វេបសាយផ្ទុកតំណភ្ជាប់ក្លែងបន្លំ (fraud) មេរោគ "Emotet" និងមេរោគ "Avalanche" រាលដាលក្នុងប្រទេសកម្ពុជាជាដើម

- ចេញផ្សាយនៅលើគេហទំព័រ www.camcert.gov.kh នូវព្រឹត្តិបត្រ និងអត្ថបទគន្លឹះសន្តិសុខព័ត៌មាន ៣២០ច្បាប់ពាក់ព័ន្ធនឹងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត វេបសាយឆបោក( Phishing ) ចំណុចខ្សោយធ្ងន់ធ្ងរជាច្រើនមាននៅក្នុងផលិតផល Microsoft, Vmware, Apple, Cisco និងកម្មវិធី Zoom Chat, Google, Chrome, Firefox, Window, Thunderbird, DNS Serve និងDrupal ដែលអាចចម្លងមេរោគ សុវត្ថិភាពទិន្នន័យ និងបច្ចុប្បន្នភាពសន្តិ សុខព័ត៌មានប្រចាំខែ

- រៀបចំម៉ាស៊ីនមេវេបសាយ ម៉ាស៊ីនមេអ៊ីមែល និងម៉ាស៊ីនមេគ្រប់គ្រងអាសយដ្ឋានអ៊ីនធឺណិត ដោយផ្តល់សេវាបង្ហោះវេបសាយចំនួន៩០ ប្រព័ន្ធគ្រប់គ្រងវេបសាយចំនួន៥២ ប្រព័ន្ធអ៊ីមែលចំនួន៣៨ ចុះឈ្មោះអាសយដ្ឋានវេបសាយចំនួន៤៥ ជូនក្រសួង ស្ថាប័ន និងកំពុងបន្តអភិវឌ្ឍប្រព័ន្ធវេបសាយជាតិផងដែរ

- ផ្តល់សេវាប្រឹក្សាយោបល់បច្ចេកទេសថែទាំ និងធ្វើបច្ចុប្បន្នភាពវេបសាយនៅលើម៉ាស៊ីនមេរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ចំនួន១២៦វេបសាយ

- រៀបចំមុខងារគ្រប់គ្រងព័ត៌មានសេវាសាធារណៈ និងបញ្ចូលកម្រងសេវាសាធារណៈចំនួន៤៦០សេវាតាមវេបផត ថល ( Web Portal ) រដ្ឋបាលរាជធានី ខេត្ត។

**- ស្ថិតិវិស័យ ICT រយៈពេល៥ឆ្នាំ(២០១៧-២០២១)**

| ល.រ. | សូចនាករ | ឯកតា | សរុប |
|---|---|---|---|
| ១ | ចេញការអនុញ្ញាតប្រកបអាជីវកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (អាជ្ញាបណ្ណលិខិតអនុញ្ញាត វិញ្ញាបនបត្រ)។ | ចំនួន | ៣០៩ |
| ២ | ផ្សាយបន្តផ្ទាល់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងកិច្ចប្រជុំឧត្តមក្រុមប្រឹក្សា ពិគ្រោះនិងផ្តល់យោបល់តាមប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលទៅកាន់ ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធទូទាំង ប្រទេស។ | លើក | ៣៣ |
| ៣ | ជួសជុល និងតភ្ជាប់បណ្តាញខ្សែកាបអុបទិកជូនក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធចំនួន២៧។ | គ.ម. | ៣៣ |
| ៤ | ផ្តល់អាសយដ្ឋានអ៊ីនធឺណិតសាធារណៈ ( Public IP Address ) ជូនក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចំនួន៤៤។ | IP Address | ១៦៩ |
| ៥ | ថែទាំវេបសាយរបស់ក្រសួង ស្ថាប័ន និងសាលាខេត្តដែលកំពុងដំណើរការលើ ម៉ាស៊ីនមេរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ | វេបសាយ | ១២៦ |
| ៦ | អភិវឌ្ឍកម្មវិធីសុសវែរជូនក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។ | កម្មវិធី | ១១ |
| ៧ | ចេញផ្សាយនៅលើគេហទំព័រ www.camcert.gov.kh នូវអត្ថបទគន្លឹះ និងព្រឹត្តិបត្រសន្តិសុខព័ត៌មាន។ | ច្បាប់ | ៣២០ |
| ៨ | ទប់ស្កាត់ការវាយប្រហារមកលើម៉ាស៊ីនមេផ្ទុកវេបសាយរបស់ក្រសួងស្ថាប័ននានា | ដង | ១៤១៤៨៥៧២៦ |
| ៩ | បង្កើតប្រព័ន្ធគ្រប់គ្រងអ៊ីមែលនិងប្រព័ន្ធបង្ហោះវេបសាយជូនក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្ត។ | អង្គភាព | ១២៨ |
| ១០ | ចុះឈ្មោះអាសយដ្ឋានវេបសាយជូនក្រសួង ស្ថាប័ន។ | អង្គភាព | ៤៥ |
| ១១ | រៀបចំមុខងារគ្រប់គ្រងព័ត៌មានសេវាសាធារណៈតាមវេបផតថល (Web Portal) រដ្ឋបាលរាជធានី ខេត្ត | សេវា | ៤៦០ |

**សម្គាល់** : អង្គភាព ជា( ក្រសួង ស្ថាប័ន រាជធានី-ខេត្ត ឬជាអង្គភាពក្រោមចំណុះក្រសួង )។

- ការពង្រឹងសមត្ថភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

| ល.រ | សកម្មភាព | ចំនួន(នាក់) | | សរុប (នាក់) |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ១ | រៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងនិងបណ្តុះបណ្តាលជំនាញព័ត៌មានវិទ្យាខ្លីៗជូនដល់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងតំបន់ជនបទ។ | ៨ ៤៨៤ | ២ ៤០៣ ស្មើនឹង២២,០៧% | ១០ ៨៨៧ |
| ២ | រៀបចំកម្មវិធីប្រកួតប្រជែងពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានចំនួន១២លើក។ | ០ | ១៧២ | ១៧២ |

- **គម្រោងមូលនិធិ ស.អ.(ការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន)**

គម្រោងបំពាក់កុំព្យូទ័រ និងសម្ភារៈបច្ចេកទេសគាំទ្រការបង្រៀនបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅកម្រិតមធ្យមសិក្សាទុតិយភូមិ(សរុបចំនួន២០ វិទ្យាល័យ ដោយវិទ្យាល័យនិមួយៗទទួលបានៈ កុំព្យូទ័រ២៥គ្រឿង LCD Projector ចំនួន១គ្រឿង តុចំនួន១៣ កៅអីចំនួន៥០ និងកង្ហារចំនួន៧)។

| ល.រ. | រាជធានី ខេត្ត | ចំនួនវិទ្យាល័យ | ឧបករណ៍សម្ភារៈបំពាក់ | | | | |
|---|---|---|---|---|---|---|---|
| | | | កុំព្យូទ័រ (គ្រឿង) | LCD projector | តុ | កៅអី | កង្ហារ |
| ១ | កំពង់ឆ្នាំង | ៤ | ១០០ | ៤ | ៥២ | ២០០ | ២៨ |
| ២ | តាកែវ | ៣ | ៧៥ | ៣ | ៣៩ | ១៥០ | ២១ |
| ៣ | សៀមរាប | ២ | ៥០ | ២ | ២៦ | ១០០ | ១៤ |
| ៤ | ព្រៃវែង | ២ | ៥០ | ២ | ២៦ | ១០០ | ១៤ |
| ៥ | កំពង់ស្ពឺ | ២ | ៥០ | ២ | ២៦ | ១០០ | ១៤ |
| ៦ | ក្រចេះ | ១ | ២៥ | ១ | ១៣ | ៥០ | ៧ |
| ៧ | ឧត្តរមានជ័យ | ១ | ២៥ | ១ | ១៣ | ៥០ | ៧ |
| ៨ | បាត់ដំបង | ១ | ២៥ | ១ | ១៣ | ៥០ | ៧ |
| ៩ | ត្បូងឃ្មុំ | ១ | ២៥ | ១ | ១៣ | ៥០ | ៧ |
| ១០ | កំពត | ១ | ២៥ | ១ | ១៣ | ៥០ | ៧ |
| ១១ | កណ្តាល | ១ | ២៥ | ១ | ១៣ | ៥០ | ៧ |
| ១២ | រាជធានីភ្នំពេញ | ១ | ២៥ | ១ | ១៣ | ៥០ | ៧ |
| សរុប | | ២០ | ៥០០ | ២០ | ២៦០ | ១ ០០០ | ១៤០ |

## ៤- សហគ្រាសទូរគមនាគមន៍កម្ពុជា

### ៤.១- ការងារអាជីវកម្ម

- នៅចំពោះមុខទីផ្សារប្រកួតប្រជែង ទូរគមនាគមន៍កម្ពុជាបានរៀបចំធ្វើផែនការអាជីវកម្មរយៈពេល ៥ឆ្នាំ សម្រាប់រំកិលមកអនុវត្តតាមឆ្នាំនីមួយៗជាក់ស្តែងការអនុវត្តន៍ផែនការឆ្នាំជាបន្តបន្ទាប់មកនេះគឺបានភ្ជាប់គ្នាទៅវិញទៅមក(Link)ជាមួយនឹងផែនការយុទ្ធសាស្ត្រ មានសេវាទូរសព្ទអចល័ត សេវាអ៊ីនធឺណិត និងTransmission ដែលកំពុងផ្តល់ជូនអតិថិជនប្រើប្រាស់ ដូចមានក្នុងតារាងខាងក្រោមៈ

| ទូរសព្ទភ្នំពេញ និងខេត្ត(Line) | | | | |
|---|---|---|---|---|
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| ៣០ ៧៣២ | ៣០ ៧០៣ | ២៩ ៥០៣ | ២៨ ៨០៦ | ២៧ ៣៨៦ |

| សេវា Internet ភ្នំពេញ និងខេត្ត(Users) | | | | | |
|---|---|---|---|---|---|
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ | |
| | | | | Users | Mbps |
| ៧ ៤៦៥ | ៧ ៧១៣ | ៧ ២៤៤ | ៧ ១៨៩ | ៣ ៥១៩ | ៤ ៣១៩ |

| Transmission ភ្នំពេញ និងខេត្ត(Users ) | | | | | | | |
|---|---|---|---|---|---|---|---|
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ | | | |
| | | | | Mbps | E1 | Core | Pairs |
| ៥២ | ៧២ | ៧៣ | ៨៦ | ៧៣៩ | ៤៥ | ១៤១ | ៧ |

- ចរន្តទូរសព្ទតភ្ជាប់ចេញ-ចូល fix to fix និងMobile to fix ក្នុងនោះមានCamintel, CamGSM LATEZ, Viettel, Sea Tel & XINWEI។

| ចរន្តទូរសព្ទតភ្ជាប់ចូល (Fix to Fix) &(Mobile to Fix)(គិតជានាទី) | | | | |
|---|---|---|---|---|
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| ៨ ១៦១ ៣៥៦ | ៦ ៦៩១ ២៨៤ | ៦ ១១៦ ១១១ | ៥ ២៧៤ ៥៨៣ | ៤ ១៨២ ៨៥៧ |
| ចរន្តទូរសព្ទតភ្ជាប់ចេញ (Fix to Fix) &(Mobile to Fix)(គិតជានាទី) | | | | |
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| ១៩ ៥៤៤ ៥៨១ | ១៥ ៥៨០ ២០១ | ១១ ០១៣ ៤០៤ | ៧ ២៤៥ ៥៥៨ | ៥ ០៤១ ៣៥២ |

- ចរន្តទូរសព្ទអន្តរជាតិចេញ-ចូល

| Outgoing to International (គិតជានាទី) | | | | |
|---|---|---|---|---|
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| ៨៤២ ៥៨៦ | ១ ១១៤ ២៧៧ | ៧២១ ១៣៨ | ៦៣៦ ៨៤៨ | ២១៥ ៧៦៨ |
| Incoming from International (គិតជានាទី) | | | | |
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| ១០៥ ៨៣០ ០១២ | ៨០ ៥៩៣ ៤២៧ | ៦៤ ១៥៦ ២១៩ | ៣៧ ៤៦៦ ១៨៩ | ២០ ៩៤៧ ២៩៣ |

## ៤.២- ការងារហិរញ្ញកិច្ច និងគណនេយ្យ

បានអនុវត្តការងារចំណូល-ចំណាយ និងចំណេញ-ខាត ដូចក្នុងតារាងខាងក្រោម៖

| ចំណូល(គិតជាដុល្លារអាម៉េរិក) | | | | |
|---|---|---|---|---|
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| ១៥ ៦៦៥ ១៨១,៨៤ | ១១ ៤៣៤ ៦៥២,៩៥ | ១០ ១៩២ ១៥៧,៦១ | ១០ ១១៦ ០០៧,២៥ | ៥ ៥៧៣ ៤៨៧,៦៧ |
| ចំណាយ (គិតដុល្លារអាម៉េរិក) | | | | |
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| ១៨ ៣៥៩ ៦៣៧,២០ | ១៦ ៦៤៦ ៤៥៥,៣៨ | ១៣ ៩៣៤ ៨៧៤,៩១ | ១៦ ៦៩០ ០៤៧,៨៨ | ៦ ២៩៦ ៧៦៣,៨៨ |
| ចំណេញ-ខាត (គិតដុល្លារអាម៉េរិក) | | | | |
| ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៩ខែ ឆ្នាំ២០២១ |
| -២ ៦៩៤ ៤៥៥,៣៦ | -៥ ២១១ ៨០២,៤៣ | -៣ ៧៤២ ៧១៧,៣០ | -៦ ៥៧៤ ០៤០,៦៣ | -៧២៣ ២៧៦,២១ |

## ៥- និយ័តករទូរគមនាគមន៍កម្ពុជា

### ៥.១- ការងារនិយ័តកម្មទូរគមនាគមន៍

- ស្ថិតិអាជ្ញាបណ្ណផ្តល់សេវាទូរគមនាគមន៍៖ បានអនុញ្ញាតផ្តល់ជូនទៅបណ្តាប្រតិបត្តិករទូរគមនាគមន៍ទៅតាមប្រភេទ ដូចក្នុងតារាងខាងក្រោម៖

ឯកតា៖ អាជ្ញាបណ្ណ

| ល.រ. | ប្រភេទអាជ្ញាបណ្ណ | គិតត្រឹមខែកញ្ញា ឆ្នាំ២០២១(ប្រតិបត្តិករកំពុងដំណើរការ) | | | | |
|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ |
| ១ | អាជ្ញាបណ្ណមាត់ច្រកអន្តរជាតិ (International Gateway) | ២ | ២ | ២ | ២ | ២ |
| ២ | អាជ្ញាបណ្ណសេវាទូរសព្ទចល័ត | ៧ | ៧ | ៧ | ៥ | ៥ |
| ៣ | អាជ្ញាបណ្ណសេវាទូរសព្ទអចល័តមានខ្សែ និងគ្មានខ្សែ | ៧ | ៧ | ៧ | ៦ | ៦ |
| ៤ | អាជ្ញាបណ្ណ VoIP | ១៩ | ១៦ | ១៧ | ១១ | ១០ |
| ៥ | អាជ្ញាបណ្ណ ISP | ៣៦ | ៣៧ | ៤២ | ៤៨ | ៤០ |
| ៦ | អាជ្ញាបណ្ណ Telecom Tower Sharing | ១ | ៣ | ៣ | ៣ | ២ |
| ៧ | អាជ្ញាបណ្ណ Submarine Optical Cable Network | ១ | ២ | ២ | ២ | ២ |
| ៨ | អាជ្ញាបណ្ណ Optical Cable Network | ៣ | ៣ | ៣ | ៣ | ២ |
| ៩ | អាជ្ញាបណ្ណPosition and Navigation | ១ | ១ | ១ | | |
| ១០ | អាជ្ញាបណ្ណ Value Added Network | ១ | ១ | ១ | ១ | ១ |
| ១១ | អាជ្ញាបណ្ណ Toll Free | ១ | ១ | ១ | ១ | ១ |
| ១២ | អាជ្ញាបណ្ណ Directory Service | ១ | ១ | ១ | | |
| **សរុប** | | **៨០** | **៨១** | **៨៧** | **៨២** | **៧១** |

**- ទិន្នន័យអតិថិជនប្រើសេវាទូរសព្ទចល័ត-អចល័តនិងអ៊ីនធឺណិតចល័ត-អចល័ត**

| ប្រតិបត្តិករ | ឯកតា | គិតត្រឹមខែកក្កដា ឆ្នាំ២០២១ | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ទូរសព្ទចល័ត | ស៊ីមកាត | ១៨ ៥៧២ ៩៨៣ | ១៩ ៤១៧ ១២៣ | ២១ ៦៧៥ ៥២៣ | ២០ ៨២៧ ៨៣៥ | ២០ ៩៩៣ ៨៥៧ |
| ទូរសព្ទអចល័ត | នាក់ | ១៣២ ៩១១ | ៩៦ ២៦១ | ៥៧ ៤៣៨ | ៤៩ ៣៨១ | ៤២ ១៩៥ |
| អ៊ីនធឺណិតចល័ត | នាក់ | ១០ ៧០៣ ០៥៦ | ១៣ ៤៥៨ ០៥០ | ១៦ ១២៦ ៣៥៦ | ១៦ ៣៣១ ៣២៨ | ១៧ ៩៩៨ ៨៣៧ |
| អ៊ីនធឺណិតអចល័ត | នាក់ | ១៣៨ ៦៧២ | ១៥១ ៧៥៣ | ២២៤ ១០៤ | ២៨៣ ៥០៨ | ៣០៩ ២៤២ |

- លិខិតទទួលស្គាល់ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ

ឯកតា: ច្បាប់

| ល.រ. | ប្រភេទលិខិត | គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | វិញ្ញាបនបត្រទទួលស្គាល់ជាភ្នាក់ងារនាំចូលបរិក្ខារទូរគមនាគមន៍ | | ៤ | ៤ | ៥ | |
| ២ | លិខិតអនុញ្ញាតនាំចូលបរិក្ខារទូរគមនាគមន៍ | ៥៩ | ៧៣ | ៩៣ | ៧០ | ២៥ |
| ៣ | ទទួលស្គាល់បរិក្ខារទូរគមនាគមន៍ | ១៨០ | ៦១ | ៤២ | ៣៤ | ១៤៧ |
| ៤ | ចុះឈ្មោះដែនជាតិ | ៣ ២១០ | ៣ ៤៥៨ | ៣ ៧១៨ | ៣ ៨៧២ | ៣ ០៣១ |
| ៥ | អ៊ីនធឺណិតកាហ្វេ | ២៥១ | ១៥២ | ១១១ | ៣៦ | ៤ |
| សរុប | | ៣ ៧០០ | ៣ ៧៤៨ | ៣ ៩៦៨ | ៤ ០១៧ | ៣ ២០៧ |

- ទិន្នន័យបណ្តាញខ្សែកាបអុបទិក

| ល.រ | ប្រតិបត្តិករ | គិតត្រឹមខែកក្កដា ឆ្នាំ២០២១ | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | CFOCN | ១៣ ០៣១គ.ម. | ១៦ ០៥៩គ.ម. | ១៦ ៨៤១គ.ម. | ១៧ ០៩៩គ.ម. | ១៧ ០៩៩គ.ម. |
| ២ | Telecom Cambodia | ១ ៦០០គ.ម. | ២ ៣២២គ.ម. | ២ ២៩១,៦គ.ម. | ២ ១៨០គ.ម. | ២ ១៨០គ.ម. |
| ៣ | Viettel Cambodia | ២២ ០០០គ.ម. | ២២ ០០០គ.ម. | ២២ ០០០គ.ម. | ២៦ ៦៥៤,៣គ.ម. | ២៦ ៦៥៤,៣គ.ម. |
| Total | | ៣៦ ៦៣១គ.ម. | ៤០ ៣៨១គ.ម. | ៤១ ១៣២,៦គ.ម. | ៤៥ ៩៣៣,៣គ.ម. | ៤៥ ៩៣៣,៣គ.ម. |

៥.២- ការងារនិយ័តកម្មប្រេកង់វិទ្យុ

- អាជ្ញាបណ្ណប្រេកង់វិទ្យុៈ

ឯកតា: អាជ្ញាបណ្ណ

| ល.រ | ប្រភេទលិខិត | គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | អាជ្ញាបណ្ណប្រេកង់វិទ្យុមិនគិតកម្រៃ | ៤២២ | ៤១៩ | ១១៤ | ៩៤ | ៩៧ |
| ២ | អាជ្ញាបណ្ណប្រេកង់វិទ្យុគិតកម្រៃ | ៣ ២៤៧ | ២ ៩៦៩ | ៣ ២០៣ | ៣ ១១១ | ១១ |
| ៣ | វិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ (TA) | ១៧៣ | ២៧៣ | ៣២៤ | ៣៦០ | ៣០៥ |
| ៤ | លិខិតអនុញ្ញាតនាំចូលបរិក្ខារវិទ្យុគមនាគមន៍ | ១៨ | ៣០ | ២៥ | ២១ | ៤ |
| ៥ | លិខិតអនុញ្ញាតបើកលក់ និង/ឬជួសជុលបរិក្ខារវិទ្យុគមនាគមន៍ | ៩ | ៩ | ៨ | ១១ | |
| ៦ | វិញ្ញាបនបត្រគុណវុឌ្ឍិជាភ្នាក់ងារនាំចូលផ្គត់ផ្គង់ និងចែកចាយបរិក្ខារវិទ្យុគមនាគមន៍ | | ១ | ៦ | ១ | ១០ |
| សរុប | | ៣ ៨៦៩ | ៣ ៧០១ | ៣ ៦៨០ | ៣ ៥៩៨ | ៤២៧ |

- ការងារដោះស្រាយបណ្តឹងបង្គោលអង់តែន : ដោះស្រាយបណ្តឹងប្រជាពលរដ្ឋអំពីការព្រួយបារម្ភផលប៉ះពាល់សុខភាពបណ្តាលមកពីបង្គោលអង់តែនទូរសព្ទចល័តបានចំនួន២៦ករណី ក្រុមហ៊ុនសាងសង់បានឯកភាពធ្វើការសម្របសម្រួលជាមួយប្រជាពលរដ្ឋ

- ការងារដោះស្រាយការឆ្លងរំខានប្រេកង់វិទ្យុ :

+ ការងារដោះស្រាយការឆ្លងរំខានប្រេកង់វិទ្យុក្នុងស្រុកចំនួន៣៦ករណី និងបានដោះស្រាយរួចរាល់។

+ ការងារដោះស្រាយការឆ្លងរំខានប្រេកង់វិទ្យុជាមួយប្រទេសជិតខាងមានចំនួន៧ករណីនិងបានដោះស្រាយរួចរាល់បានចំនួន៥ករណី។

- ការងារចំណូល-ចំណាយនិងបំណុល

ឯកតា : រៀល

| បរិយាយ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១(ប៉ាន់ស្មាន) |
|---|---|---|---|---|---|
| ចំណូល | ១៣ ៨៦៩ ៨៨០ ២១៥ | ១១ ៣៩៩ ៨៨៩ ៥១៥ | ៩ ៣៤១ ៩៥១ ៨៧៦ | ៩ ៥៨០ ២៤១ ៩០០ | ៧ ៥៤៨ ៩៦៦ ៥៦២ |
| ចំណាយ | ១០ ៨២០ ៣៨៨ ៥៥៣ | ១៤ ៦១៣ ២០៣ ៤៦៣ | ១១ ៥២២ ៣២៩ ៦១៩ | ៩ ៥៨០ ២៤១ ៩០០ | ៩ ៦៩១ ១០៦ ៤៦៨ |
| បំណុល | ២០ ៩៣១ ៨០០ ៩២២ | ២០ ៩២២ ៥៤៣ ៣៣៤ | ១៨ ៩៩៥ ៣៨៣ ៧៣៦ | ១៤ ៧០០ ២៥២ ៦០០ | ១០ ៣៥១ ២២៧ ៣៧៦ |

## មុំទី៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

### ១- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុសាធារណៈ

សម្រាប់អាណត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភានេះ ក៏មិនខុសគ្នាពីអាណត្តិមុនៗដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាលើបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំបំពេញតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ស្របតាមគោលបំណងគោលនយោបាយចំនួន២ និងកម្មវិធីទាំង៥ ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ដោយឈរលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាគោល និងអនុលោមតាមយុទ្ធសាស្ត្រសំខាន់ៗដទៃទៀត ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញឱ្យអនុវត្ត។

ចំពោះការគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់រយៈពេល៣ឆ្នាំដំបូង ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ កម្ពុជានៅតែរក្សាបាននូវឯតទគ្គកម្មយ៉ាងល្អប្រសើរបន្តពីអាណត្តិមុន គឺការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមក្នុងរង្វង់៧% ក្នុងមួយឆ្នាំ តែនៅក្នុងឆ្នាំ២០២០ និង២០២១ កំណើននេះត្រូវបានធ្លាក់ចុះមកវិញ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជា ក៏ដូចជាសេដ្ឋកិច្ចរបស់ពិភពលោកទាំងមូល។ ជាក់ស្តែង នៅក្នុងបរិការណ៍ឆ្នាំ២០២១ ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ដ៏កាចសាហាវបាននិងកំពុងបន្តនាំមកនូវផលប៉ះពាល់អវិជ្ជមាន បញ្ហាប្រឈម និងហានិភ័យជាច្រើន ដែលមិនធ្លាប់មានពីមុនមកចំពោះតំបន់ និងពិភពលោកទាំងមូល ដោយគ្មានការលើកលែងចំពោះប្រទេសណាមួយឡើយ ជាពិសេសគឺបានធ្វើឱ្យមនុស្សរាប់លាននាក់បាត់បង់ការងារ ធ្លាក់ចុះនូវប្រាក់ចំណូល ហើយប្រជាជនមួយចំនួនធំនៅលើពិភពលោកត្រូវធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ ហើយកម្ពុជាក៏មិនអាចគេចរួចពីវិបាកអាក្រក់ទាំងនេះផងដែរ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គមសេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ តែថែមទាំងអាចទាញបង្អង់ល្បឿននៃកិច្ចដំណើរការអភិវឌ្ឍន៍ឈានឡើងរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេលនៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ ផងដែរ។

ឆ្លងកាត់ដំណាក់កាលដ៏លំបាកនេះ ទោះបីកម្ពុជាជាប្រទេសតូច ហើយធនធានក៏នៅមានកម្រិតក្តី ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានៅរក្សាបាន

ស្ថានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការធានាបានចីរភាពនៃការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងការរីកដុះឡើងវិញនូវចំណាយក្នុងឆ្នាំ រាជរដ្ឋាភិបាលមានសមត្ថភាព និងលទ្ធភាពអាចគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ បានល្អប្រសើរ ឆ្លើយតបបានទៅនឹងកិច្ចការអាទិភាព ដែលកើតមានថ្មីៗ ដោយផ្អែកលើមូលដ្ឋានគ្រឹះរឹងមាំនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលយើងខិតខំកសាងបាននៅក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមក ជាពិសេសក្នុងរយៈពេល៧ឆ្នាំចុងក្រោយ ព្រមជាមួយនឹងការចូលរួម យ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ផ្លូវការ វិស័យឯកជន ព្រមទាំងអង្គការ និងសង្គមស៊ីវិលផងដែរ។ លើសពីនេះ ជាមួយនឹងកិច្ចប្រឹងប្រែងតស៊ូជម្នះនឹងវិបត្តិនៃជំងឺកូវីដ-១៩ សំដៅកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះមកលើសុខភាពជីវភាពរស់នៅរបស់ប្រជាជន និងសង្គមសេដ្ឋកិច្ចទាំងមូល។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏បានគិតគូររៀបចំនូវ**«ផែនការស្តារសេដ្ឋកិច្ចឡើងវិញ»** សម្រាប់ឆ្នាំ២០២១-២០២៣ ដែលជាការត្រៀមខ្លួនសម្រាប់ដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩(Post Covid-19) ដើម្បីឈានទៅបង្កើតបាននូវភាពធន់ (Resiliency) របស់កម្ពុជាទៅនឹងវិបត្តិសម្រាប់រយៈពេលវែងខាងមុខ រួមបញ្ចូលនូវវិបត្តិសេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ និងការរាតត្បាតនៃជំងឺឆ្លងនានាផងដែរ។

ជាកត្តាសត្យានុម័ត ដោយសារតែមានការដាក់ចេញនូវវិធានការសេដ្ឋកិច្ចបន្ទាន់ៗជាបន្តបន្ទាប់បានទាន់ពេលវេលា និងមានប្រសិទ្ធភាពដោយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតួអង្គប្រតិបត្តិផ្ទាល់ និងបូករួមការធ្វើវិចារណកម្មចំណាយថវិកាចំនួន២លើក ដើម្បីយកធនធានទៅប្រើប្រាស់លើមុខសញ្ញាអាទិភាពចំពោះមុខមួយចំនួនបន្ថែមទៀតនោះ បានធ្វើឱ្យផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដោយសារជំងឺកូវីដ-១៩ មកលើប្រទេសកម្ពុជា ស្ថិតក្នុងកម្រិតមួយអាចគ្រប់គ្រងបាន និងឈានដល់ការសម្រេចបើកដំណើរការប្រទេសឡើងវិញលើគ្រប់វិស័យស្របតាមគន្លងប្រក្រតីភាពថ្មី នាចុងឆ្នាំ២០២១នេះ ជាមួយនឹងការរំពឹងទុកខ្ពស់ជាវិជ្ជមានលើកំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២២ និងឆ្នាំខាងមុខៗ។

### ១.១- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ | គ្រោង ២០២២ |
|---|---|---|---|---|---|---|
| កំណើនសេដ្ឋកិច្ច (%) | ៧ | ៧,៥ | ៧,១ | -៣,១ | ៣ | ៥,៦ |
| ទំហំសេដ្ឋកិច្ច(ប៊ីលានរៀល) | ៨៩ ៨៣១ | ៩៩ ៥៤៤ | ១១០ ០១៤ | ១០៥ ៨៥៧ | ១១០ ៩៧២ | ១២០ ២៧៦ |
| ផលិតផលក្នុងស្រុកសរុប (ផសស)ក្នុងមនុស្សម្នាក់ | ១ ៤៣០ | ១ ៥៦៣ | ១ ៧០០ | ១ ៦០៤ | ១ ៦៦៧ | ១ ៧៨៤ |
| អត្រាអតិផរណា | ២,៩ | ២,៥ | ១,៨ | ២,៩ | ២,៩ | ៣ |

ក្នុងរយៈពេលបីឆ្នាំចុងក្រោយ(មុនវិបត្តិកូវីដ-១៩) កម្ពុជាបន្តរក្សាបានកំណើនរឹងមាំ ក្នុងរង្វង់៧% ក្នុងមួយឆ្នាំ ផលិតផលក្នុងស្រុកសរុប(ផសស) ក្នុងមនុស្សម្នាក់បានកើនពី១ ៤៣០ ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៧ ដល់ប្រមាណ១ ៧០០ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩ គម្លាតនៃប្រាក់ចំណូលរបស់ប្រជាជនក៏មានការធ្លាក់ចុះជាលំដាប់ ស្របពេលដែលអត្រាភាពក្រីក្រក៏បានបន្តការធ្លាក់ចុះ អត្រាអតិផរណានៅកម្ពុជាស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ដោយអត្រាអតិផរណាមធ្យមប្រចាំឆ្នាំស្ថិតក្រោម៥%។ ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងអត្រាអតិផរណាទាប ខាងលើបានធ្វើឱ្យជីវភាពរបស់ប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់បន្តមានភាពប្រសើរឡើង តាមរយៈការទទួលបានឱកាសការងារ និងការបង្កើនប្រាក់ចំណូល ដោយ

ក្នុងនោះមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ទទួលបាននូវគោលនយោបាយដំឡើងប្រាក់បៀវត្សក្នុងគោលដៅជាង១លានរៀលនៅឆ្នាំ២០១៨។ ស្របជាមួយគ្នានេះ បុគ្គលិក និងកម្មករនិយោជិត ដែលកំពុងបម្រើការក្នុងវិស័យឯកជនក៏ទទួលបាននូវឱកាសក្នុងការបង្កើនប្រាក់ចំណូលរបស់ខ្លួនផងដែរ។

ទោះជាយ៉ាងនេះក្តី វិបត្តិជំងឺកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចសកល តំបន់ និងកម្ពុជាទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ក្នុងន័យនេះ សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០ បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ក្នុងប្រវត្តិសាស្ត្រទំនើបរបស់ខ្លួនក្នុងអត្រា-៣,១% ផលិតផលក្នុងស្រុកសរុប(ផសស) ក្នុងមនុស្សម្នាក់បានធ្លាក់ចុះមកត្រឹម១ ៦០៤ ដុល្លារអាមេរិកក្នុងឆ្នាំ២០២០ ពី១ ៧០០ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។ ស្ថានភាពការងារ និងចំណូលរបស់ប្រជាជនបានទទួលរងផលប៉ះពាល់ ជាពិសេស វិស័យដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ រួមមានវិស័យទេសចរណ៍ កាត់ដេរ លក់ដុំលក់រាយ និងសេវាកម្មផ្សេងៗទៀត។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍ប្រកបដោយបុរេសកម្ម ពោលទាំងវិធានការសុខាភិបាល និងរដ្ឋបាលនានា សំដៅកាត់បន្ថយនិងកាត់ផ្តាច់ប្រភពចម្លង និងវិធានការអន្តរាគមន៍ផ្សេងទៀត សំដៅកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះមកលើសង្គមសេដ្ឋកិច្ច។ ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការចំនួន១០ជុំ ក្នុងគោលដៅទ្រទ្រង់ និងស្តារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាពអាជីវកម្មដែលទទួលរងនូវផលប៉ះពាល់ ដែលក្នុងនោះ វិធានការចំពោះមុខគឺទប់ស្កាត់ឱ្យបាននូវការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងរក្សាលំនឹងជីវភាពប្រជាជន រួមមានជនក្រីក្រ ជនងាយរងគ្រោះនិងកម្មករនិយោជិត ក្នុងស្ថានភាពដ៏លំបាកនេះ តាមរយៈការអនុវត្តនូវកម្មវិធី និងវិធានការមួយចំនួន រួមមាន៖

- ការអនុវត្តកម្មវិធី«**សាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករសម្រាប់ឆ្នាំ ២០២០-២០២២**»។
- ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។
- ការផ្តល់ប្រាក់ឧបត្ថម្ភចំនួន៤០ដុល្លារអាមេរិក ក្នុង១ខែ សម្រាប់កម្មករនិយោជិតមួយនាក់ ដែលធ្វើការក្នុងវិស័យកាត់ដេរ(រោងចក្រវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូប) និងវិស័យទេសចរណ៍(សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍) ដែលត្រូវបានព្យួរការងារ។
- ការផ្តល់កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ។
- ការផ្តល់សេវាជួយរកការងារឱ្យកម្មករធ្វើ តាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ។

ទន្ទឹមនឹងវិធានខាងលើ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តគោលនយោបាយជាតិគាំពារសង្គមដែលមានស្រាប់ ដើម្បីលើកកម្ពស់សុខុមាលភាព និងសាមគ្គីភាពសង្គម ព្រមទាំងកាត់បន្ថយភាពក្រីក្រជាអតិបរមា។ ក្នុងនោះ រាជរដ្ឋាភិបាលផ្តល់នូវ (១) ប្រព័ន្ធជំនួយសង្គម ដែលផ្តល់ការគាំពារដល់ប្រជាជនដែលរស់នៅក្រោម និងក្បែរបន្ទាត់ភាពក្រីក្រ ដោយផ្តោតជាពិសេសលើកុមារ ស្ត្រីមានផ្ទៃពោះ ជនពិការ និងជនចាស់ជរាគ្មានទីពឹង និង (២) ប្រព័ន្ធសន្តិសុខសង្គម ដែលផ្តល់ការគាំពារហានិភ័យលើផ្នែកសោធន ថែទាំសុខភាព ហានិភ័យការងារ និកម្មភាពនិងពិការភាពដល់ក្រុមប្រជាជននៃវិស័យសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រព័ន្ធ។

ផ្អែកលើវិធានការអន្តរាគមន៍នានា គួបផ្សំនឹងការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំង សំដៅបង្កើតឱ្យមានភាពស៊ាំសហគមន៍បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញ ក្នុងអត្រា៣,០% ក្នុងឆ្នាំ២០២១ ហើយអាចឆ្លោះទៅកាត់ផ្តាច់ ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ដោយជោគជ័យកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ កន្លង

ទៅនេះ។ ជាមួយគ្នានេះ ផលិតផលក្នុងស្រុកសរុប(ផសស) ក្នុងមនុស្សម្នាក់ កើនឡើងពី១ ៦០៤ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២០ ដល់១ ៦៦៧ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២១។ ទន្ទឹមនេះ សកម្មភាពសេដ្ឋកិច្ចបានវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ ក្រោមការប្រកាសបើកប្រទេសឡើងវិញជាផ្លូវការ ដែលបានធ្វើឱ្យស្ថានភាពការងារ និងចំណូលជារួម ចាប់ផ្ដើមមាននិន្នាការទៅរកភាពល្អប្រសើរឡើងវិញ ស្របនឹងការអនុវត្ត«**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣**»។

## ១.២- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកា

### ១.២.១- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ ដោយប្រកាន់ខ្ជាប់តាមអភិក្រមជាខឿន(Platform Approach) និងបែងចែកជាបួនដំណាក់កាល រួមមានដំណាក់កាលទី១«**ការបង្កើនភាពជឿទុកចិត្តនៃថវិកា**» ដោយផ្តល់អាទិភាពបន្ទាន់លើការងារពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ នៅក្នុងដំណាក់កាលទី១ រាជរដ្ឋាភិបាលបានដាក់ចេញនិងជំរុញការអនុវត្តវិធានការជាច្រើន ដែលនាំឱ្យយើងសម្រេចដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ។ ចំពោះដំណាក់កាលទី២ គោលដៅចម្បង គឺ«**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**» ដោយផ្តោតជាសំខាន់លើការរៀបចំ ការកែលម្អ ការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដាអន្តរជាតិ តាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជា«**ស្នូលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល**» ដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិការហិរញ្ញវត្ថុ និងពិនិត្យតាមដាន កែលម្អចំណាត់ថ្នាក់ថវិកា វាយតម្លៃ ប្រមូលផ្តុំ និងផ្ទៀងផ្ទាត់ និងវិភាគសម្រាប់រៀបចំផែនការ ការរៀបចំថវិកា ការធ្វើសេចក្តីសម្រេចចិត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍។ សម្រាប់ដំណាក់កាលទី៣«**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**» កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានបោះជំហានដ៏សំខាន់មួយថ្មីទៀត គឺការចាប់ផ្តើមធ្វើការផ្លាស់ប្តូរប្រព័ន្ធថវិកាបច្ចុប្បន្ន ព្រមទាំងការចាប់ផ្តើមពង្រឹង និងពង្រីកប្រព័ន្ធថវិកាកម្មវិធីសាកល្បងពេញលេញ ជាជំហានៗ ទៅក្នុងចំណោមក្រសួង ស្ថាប័ន គ្រប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមពីឆ្នាំ២០១៥ ទៅរហូតដល់ឆ្នាំ២០២១ ស្របតាម«**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥**» និង«**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥**»។

សម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានពង្រីក និងដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្តទាំង២៥ ព្រមទាំងដាក់ឱ្យទាំងដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ថវិកាទាំង៧(សេដ្ឋកិច្ច រដ្ឋបាល កម្មវិធី មុខងារ គម្រោង ភូមិសាស្ត្រ និងមូលនិធិ) និងមុខងារស្នូលទាំង៦(មុខងារវិភាជន៍ថវិកា មុខងារគណនីត្រូវសង មុខងារគណនីត្រូវទារ មុខងារគ្រប់គ្រងសាច់ប្រាក់ មុខងារទិញ និងមុខងារសៀវភៅធំ) ដែលអនុវត្តក្នុងជំហានទី១ និងជំហានទី២។ ផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី៣ ឆ្នាំ២០២១-២០២៥ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០២១ ដែលមានវិសាលភាព

គ្រប់ដណ្ដប់ការពង្រីកការអនុវត្តលើមុខងារស្នូលទៅរដ្ឋបាលរាជធានី ខេត្តទាំង២៥ មន្ទីរជំនាញអាទិភាពនៅទូទាំងប្រទេស អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាលរួមមទាំងថ្នាក់មូលដ្ឋានថ្មីៗ បន្ថែមទៀត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ការពង្រីកការអនុវត្តមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្ម និងការគិតគូររៀបចំនិងអភិវឌ្ឍបន្ថែមលើមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងសន្និធិនៅក្នុង FMIS។

ដោយឡែក ការអនុវត្តថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន ឆ្នាំ២០១៥-២០១៨ និងគ្រប់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០១៧-២០២១។ នៅឆ្នាំ២០២០ អង្គភាពថវិកាមានចំនួនសរុប៩១៤ ដែលក្នុងនោះរដ្ឋបាលកណ្ដាលមានចំនួន៣១១ និងថ្នាក់មូលដ្ឋាន(មន្ទីរជំនាញរាជធានី ខេត្ត) ចំនួន៦០៣។ សម្រាប់ថ្នាក់កណ្ដាល អង្គភាពថវិកាចំនួន៣១១ ក្នុងនោះ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមានចំនួន៦១ និងមិនទាន់ផ្ទេរសិទ្ធិ២៥០ និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន៦៦៤។ ក្រសួង ស្ថាប័នចំនួន៤ បានឈានមុខក្នុងការបង្កើតអង្គភាពថវិកានិងបានប្រគល់សិទ្ធិជូនអង្គភាពក្រោមឱវាទកាន់តែច្រើនឱ្យទៅជាអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ ក្នុងនោះរួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានចំនួន១២ ក្រសួងអប់រំ យុវជននិងកីឡា មានចំនួន១០ ក្រសួងសុខាភិបាលមានចំនួន១០ និងក្រសួងបរិស្ថានមានចំនួន៦។ ទន្ទឹមនេះ ដើម្បីបង្កើនគុណភាពនៃការរៀបចំផែនយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី រាជរដ្ឋាភិបាលក៏បានដេញចេញនូវ (១) សម្រាប់ថ្នាក់ជាតិ ក្របខ័ណ្ឌថវិការយៈពេលមធ្យម ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងចាប់តាំងពីឆ្នាំ២០១៩ ធ្វើសមាហរណកម្មចំណាយថវិកាសម្រាប់ថ្នាក់ទាំងថវិកាចរន្ត និងមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស និងក្រៅប្រទេស សម្រាប់ក្រសួង ស្ថាប័នចំនួន៩ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធនសម្រាប់ក្រសួង ស្ថាប័នចំនួន៣(ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម) ជា២កម្រិត គឺនៅកម្រិតផែនការយុទ្ធសាស្ត្រថវិកា និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយមានភ្ជាប់នៅតារាងសង្ខេបគម្រោងវិនិយោគក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីការរៀបចំថវិកាព័ត៌មានសមិទ្ធកម្ម និង (២) សម្រាប់ក្រោមជាតិ គោលការណ៍ណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ការតម្រឹម និងធ្វើសមាហរណកម្មបណ្ដើរៗ ផែនការរដ្ឋបាលថ្នាក់ក្រោមជាតិរហូតសម្រេចបានពេញលេញនៅឆ្នាំ២០២៣ (មន្ទីរជំនាញ ក្រុង ស្រុក និងឃុំ សង្កាត់) គោលការណ៍ណែនាំស្ដីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត និងគោលការណ៍ណែនាំស្ដីពីការអនុវត្តថវិកាកម្មវិធី។

### ១.២.២- ការអនុវត្តថវិកា

#### ក- ការអនុវត្តចំណូល

ការប្រមូលចំណូលថវិកាជាតិដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ ទទួលបានលទ្ធផលល្អប្រសើរលើសផែនការកំណត់ដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ដោយមានអត្រាកំណើន ជាមធ្យមប្រចាំឆ្នាំប្រមាណ១១,៦%។ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ការប្រមូលចំណូលថវិកាជាតិដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាសម្រេចបានតែប្រមាណ៨៤% ប៉ុណ្ណោះនៃផែនការក្នុងឆ្នាំ២០២០ និងបានប្រមាណ៩៧% ក្នុងឆ្នាំ២០២១។ ដោយឡែក លទ្ធផលគ្រប់គ្រងប្រមូលចំណូលពន្ធគឺមានស្ថានភាពល្អប្រសើរ និងលើសផែនការប្រចាំឆ្នាំ ហើយនៅបន្តរក្សាបាននូវកំណើនជាបន្តបន្ទាប់សម្រាប់រយៈពេល៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ដដែល ជាក់ស្ដែង ក្នុងឆ្នាំ២០១៩ ប្រមូលបានចំនួន១២៣,២០% និង២០២០ មានការថយថយចុះបន្តិច ដោយសម្រេចបានចំនួន១០១,៣៦% ធៀបនឹងផែនការប្រចាំឆ្នាំ។

- តារាងអនុវត្តចំណូល

ឯកតា : ប៊ីលានរៀល

| បរិយាយ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | គ្រោងឆ្នាំ២០២១ |
|---|---|---|---|---|---|
| សរុបរួមចំណូលថវិកា (I+II) | ២១ ៦៤៦,០០ | ២៤ ៩៩០,៤៨ | ៣១ ០៥២,១២ | ២៨ ៥០០,៣៧ | ២៦ ២៥០,៣៤ |
| I.សរុបចំណូលអនុវត្តឆ្លងកាត់រតនាគារជាតិ (ក+ខ) | ១៧ ៤២៦,៤៩ | ២០៦៦៨,២៧ | ២៦ ០២៥,០៣ | ២៣ ៣១២,៦៣ | ២០ ៧៨៤,៦៩ |
| ក.ចំណូលចរន្តថ្នាក់ជាតិ (ឆ្លងរតនាគារ) | ១៦ ៩៦៦,៦៩ | ២០ ១៤៦,៧៤ | ២៥ ៣៩៥,០២ | ២១ ៤២០,៩៩ | ១៩ ៧០៥,៩៨ |
| +ចំណូលសារពើពន្ធ | ១៤ ៥២០,៦៨ | ១៧ ២៩៦,០៧ | ២២ ០៥២,៩៣ | ១៩ ៣២៩,៥១ | ១៧ ៥២០,០០ |
| -ចំណូលពន្ធគយនិងរដ្ឋាករ | ៧ ៦៣៤,៤៩ | ១០ ១០២,២៣ | ១២ ៨៩៧,៤១ | ៩ ៦៧២,២២ | ៩ ៤៩៦,០០ |
| -ចំណូលពន្ធដារ | ៦ ៨៨៦,២០ | ៧ ១៩៣,៨៤ | ៩ ១៥៥,៥៣ | ៩ ៦៥៧,២៩ | ៨ ០២៤,០០ |
| +ចំណូលមិនមែនសារពើពន្ធ | ២ ៤៤៦,០១ | ២ ៨៥០,៦៧ | ៣ ៣៤២,០៩ | ២ ០៩១,៤៨ | ២ ១៨៥,៩៨ |
| **ខ.ចំណូលមូលធន** | **៤៥៩,៨១** | **៥២១,៥៣** | **៦៣០,០១** | **១ ៨៩១,៦៤** | **១ ០៧៨,៧០** |
| +ចំណូលមូលធនក្នុងប្រទេស | ១៤២,២៤ | ១៩៤,៧៤ | ១៨១,៤៣ | ១៨៥,២៤ | ២២១,២០ |
| +ចំណូលមូលធន (មូលនិធិទ្រទ្រង់ថវិកា) | ៣១៧,៥៧ | ៣២៦,៧៩ | ៤៤៨,៥៨ | ១ ៧០៦,៤០ | ៨៥៧,៥០ |
| **II. សរុបចំណូលអនុវត្តមិនឆ្លងកាត់រតនាគារជាតិ** | **៤ ២១៩,៤៩** | **៤ ៣២២,២១** | **៥ ០២៧,០៩** | **៥ ១៨៧,៧៤** | **៥ ៤៦៥,៦៥** |

## ខ- ការអនុវត្តចំណាយ

ការអនុវត្តចំណាយនៅរដ្ឋបាលថ្នាក់ជាតិ រយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៧-២០២១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសម្រេចនូវលទ្ធផលយ៉ាងច្រើន ដោយអនុវត្តស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការសកម្មភាពស្របតាមគោលបំណងគោលគោលនយោបាយរបស់ក្រសួងដូចខាងក្រោម៖

- បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ NRMIS ដោយបានពង្រីកវិសាលភាពអនុវត្តជាបន្តបន្ទាប់ដល់ក្រសួង ស្ថាប័ន ចំនួន២៣ នៅរដ្ឋបាលកណ្តាល មន្ទីរ អង្គភាពជំនាញ ចំនួន១៨ នៅតាមបណ្តារាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្ត និងបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័ន ចំនួន១៣ សម្រាប់ជំហានទី១ និងជំហានទី២

- បានអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ជាបន្តបន្ទាប់ ចាប់ពីត្រីមាសទី២ ឆ្នាំ២០២០ ដោយអនុវត្តការទូទាត់ទាំងស្រុងក្នុងប្រព័ន្ធFMIS តាមរយៈការស្កេនបញ្ចូលនូវលិខិតយុត្តិការចំណាយក្នុងប្រព័ន្ធFMIS និងមិនមានបោះផ្សាយអាណត្តិបើកប្រាក់ សម្រាប់ចំណាយបើកផ្តល់បៀវត្ស ចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានរបបកំណត់ច្បាស់លាស់ និងមុខសញ្ញាចំណាយមួយចំនួនដែលមានហានិភ័យទាបដែលមិនមានការស្នើសុំជានា

ចំណាយដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជាថ្លៃប្រើប្រាស់ទឹកស្អាត អគ្គិសនី ប្រាក់អាហារូបករណ៍ជាដើម

•បានធ្វើសន្ធានកម្មជាមួយប្រព័ន្ធខាងក្រៅ ជាច្រើន ដូចជាNRMIS, ASYCUDA, DMFAS និងឈានទៅបញ្ចប់ការសន្ធានកម្មជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ដើម្បីបង្កើតអាណត្តិបៀវត្សដោយស្វ័យប្រវត្តិក្នុងFMIS

•បានធ្វើសន្ធានកម្មជាមួយរបាយការណ៍ធនាគារដៃគូទាំងអស់ចូលក្នុង FMIS ដើម្បីកត់ត្រាកិច្ចបញ្ជិកាគណនេយ្យ ដូចជាNBC, ACLEDA, CANADIA, J TRUST, CAMPU Bank, ធនាគារវឌ្ឍនៈ ធនាគារស្ថាបនា, ធនាគារ ABA, FTB Bank, CHIP MONG Bank និងធនាគារ POST Bank

•បានសម្របសម្រួលរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ក្នុងរយៈពេល៥ឆ្នាំបន្តបន្ទាប់គ្នា ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ (ឆ្នាំ N-1) ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិពិនិត្យនិងអនុម័តទាន់ពេលវេលាក្នុងឆ្នាំថវិកាបន្ទាប់ ដំណាលគ្នានឹងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់ (N+1)។

ដោយឡែកការងារបើកបៀវត្សតាមប្រព័ន្ធធនាគារក៏បន្តរក្សាបានប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល យោធិន កងកម្លាំងនគរបាលជាតិ និងការបើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូន ប.ជ.ស និងប.ជ.អ បានទាន់ពេលវេលានៅក្នុង១ខែ ចំនួនពីរលើក ដែលលើកទី១ នៅសប្តាហ៍ទី២ និងលើកទី២ នៅសប្តាហ៍ទី៤ នៃខែនីមួយៗ ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ដោយក្នុងនោះ៖

•មន្ត្រីរាជការស៊ីវិលទាំងអស់(រាប់បញ្ចូលទាំងមន្ត្រីក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលស៊ីវិល) បានបើកបៀវត្សតាមប្រព័ន្ធធនាគារពេញលេញ១០០%។ ចំពោះមន្ត្រីជាប់កិច្ចសន្យាក៏បានអនុវត្តតាមប្រព័ន្ធធនាគារ។

•ចំពោះក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ ក៏អនុវត្តបានចំនួន៥៨ ១៩១នាក់(ក្នុងចំណោមកងកម្លាំងចំនួន៦១ ៨៨២នាក់ ដែលបានអនុវត្ត តាមប្រព័ន្ធធនាគារ។ ក្រៅពីនេះ មានមន្ត្រីចំនួន១ ០៩៤នាក់ ដែលមិនទាន់បានបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ។ ក្រសួងការពារជាតិ(ក្នុងផែនការជំហានដំបូងចំនួន ១០ ០០០នាក់) ទើបអនុវត្តបានចំនួន៤ ៤០៨នាក់

•ក្នុងការអនុវត្តការបើកបៀវត្សតាមប្រព័ន្ធធនាគារកន្លងមក បានរកឃើញមន្ត្រីមានភាពមិនប្រក្រតី សរុបចំនួន៣ ៦៣១នាក់ ក្នុងនោះបានលុបចេញពីក្របខ័ណ្ឌចំនួន២ ៨៩៥នាក់ និងបានដាក់ឱ្យព្យួរចំនួន៧៣៦នាក់។

- **តារាងការអនុវត្តចំណាយ**

ឯកតា : ប៊ីលានរៀល

| បរិយាយ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | គ្រោងឆ្នាំ២០២១ |
|---|---|---|---|---|---|
| ចំណាយចរន្តថ្នាក់ជាតិ | ១៣ ២៣៦,៦៣ | ១៤ ៩៧២,៥០ | ១៧ ៨៨៩,៥៩ | ១៧ ៣៤៥,៣៤ | ១៧ ៤៤៦,៨០ |
| ចំណាយមូលធនថ្នាក់ជាតិ | ២ ៥៥៩,៨៩ | ៣ ២៥៦,៦១ | ៤ ៤៤០,២៧ | ៦ ៩៦៩,៦៦ | ៧ ៥៧៨,៨៥ |
| គម្រោងវិនិយោគ (ប៊ីលានរៀល) | ១ ៣៨៦,៩៤ | ១ ៧៧១,៧៣ | ២ ៨៩២,០៦ | ៤ ៩៨៤,០៩ | ៤ ៨៧៤,៦៦ |
| បដិភាគវិនិយោគ (ប៊ីលានរៀល) | ៤៨៩,៩៣ | ៥៣៦,០៧ | ៥១៨,៦៨ | ៦៥៥,៩៩ | ៦៦១,៥០ |
| មូលនិធិទ្រទ្រង់ថវិកា (ប៊ីលានរៀល) | ១១៦,៧៩ | ២១២,២៤ | ១០៥,០៦ | ២៤៧,៣៤ | ៨៥៧,៥០ |
| ការទូទាត់ការខ្ចី | ៥៦៦,២៤ | ៧៣៦,៥៧ | ៨៨៤,៤៨ | ១ ០៨២,២៤ | ១ ១៨៥,១៩ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ២១៩,៤៩ | ៣២២,២១ | ៥ ០២៧,០៩ | ៥ ១៨៧,៧៤ | ៥ ៤៦៥,៦៥ |

### គ- ការវិភាជថវិកាសរុបសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានកំណើនគួរឱ្យកត់សម្គាល់។ ក្នុងបរិការណ៍ពិភពលោកទាំងមូល ក៏ដូចជាប្រទេសកម្ពុជា បានជួបប្រទះនឹងវិបត្តិសុខភាពសាធារណៈជាសកល ដែលបណ្ដាលមកពីការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានការថមថយគួរឱ្យកត់សម្គាល់។ ជាក់ស្ដែងនៅឆ្នាំ២០២១ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានការថមថយប្រមាណ២៣% ធៀបនឹងឆ្នាំ២០២០។ ដោយឡែកនៅឆ្នាំ២០២២ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានគ្រោងកើនប្រមាណ៣២% ធៀបនឹងឆ្នាំ២០២១។

**- ការវិភាជថវិកាសរុបសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ឯកតា : លានរៀល

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| រាជធានី ខេត្ត | ១ ០៨៥ ២៣៩ | ១ ០៩០ ២៣៣ | ១ ៤៧៦ ៩៤៦ | ២ ២៧៨៦៩១ | ១ ៥១៣ ១៨៥ | ២ ១១៣ ៨៣៣ |
| ក្រុង ស្រុក | ១៤៥ ០៧២ | ១៦០ ៤០០ | ១៩៨ ៨៩០ | ២៤៧ ២២៨ | ៣៥៦ ១២៣ | ៤៣៣ ៦២៤ |
| ឃុំ សង្កាត់ | ៣៧៥ ៤០៣ | ៤៣៤ ០៤១ | ៥២៣ ៨០០ | ៨០៣ ៣១៧ | ៧០៩ ៥៤៨ | ៨៤៧ ៣៥៦ |
| **សរុបរួម** | **១ ៦០៥ ៧១៤** | **១ ៦៨៤ ៦៧៤** | **២ ១៩៩ ៦៣៦** | **៣ ៣២៩ ២៣៦** | **២ ៥៧៨ ៨៥៦** | **៣ ៣៩៤ ៨១៣** |

ទន្ទឹមនេះ ផ្នែកគ្រប់គ្រងចំណាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រយៈពេលពេល៥ឆ្នាំ ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រេចនូវសមិទ្ធផលគួរឱ្យកត់សម្គាល់មួយចំនួនផងដែររួមមាន៖

- ដាក់ឱ្យរដ្ឋបាលរាជធានី ខេត្ត រៀបចំផែនការយុទ្ធសាស្ត្រថវិកានិងអនុវត្តថវិកាកម្មវិធី រួមទាំងការផ្ដល់ធន្ទានុសិទ្ធិជាបណ្ដើរៗជូនរដ្ឋបាលរាជធានី ខេត្តក្នុងការចាត់ចែងធនធាន

- បង្កើនធនធានមូលនិធិក្រុង ស្រុក តាមរយៈកំណើនចំណូលចរន្តជាតិជារៀងរាល់ឆ្នាំ និងការបង្កើនអត្រាវិភាជន៍ប្រចាំឆ្នាំ ដល់មូលនិធិក្រុង ស្រុកពី១,០% នៅឆ្នាំ២០១៨ ដល់១,៥% នៅឆ្នាំ២០២៣ និងនិងការបែករំលែកចំណូលសារពើពន្ធ៤% នៃចំណូលសារពើពន្ធខេត្តសម្រាប់អភិវឌ្ឍមូលដ្ឋាន

- បង្កើនធនធានមូលនិធិឃុំ សង្កាត់ តាមរយៈកំណើនចំណូលចរន្តជាតិជារៀងរាល់ឆ្នាំ និងការបង្កើនអត្រាវិភាជន៍ប្រចាំឆ្នាំ ដល់មូលនិធិឃុំ សង្កាត់ពី២,៨% នៅឆ្នាំ២០១៨ ដល់៣,៤% នៅឆ្នាំ២០២៣ ការផ្ដល់ធនធានបន្ថែម១%នៃចំណូលចរន្តថវិកាជាតិ សម្រាប់ការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់ និងការបែករំលែកចំណូលសារពើពន្ធ៤%នៃចំណូលសារពើពន្ធរដ្ឋបាលរាជធានី ខេត្ត ដែលនឹងត្រូវបង្កើន០,៥% ជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣។ តាមរយៈការបង្កើនធនធាននេះ តាមការប៉ាន់ស្មាន នៅឆ្នាំ២០២៣ រដ្ឋបាលឃុំ សង្កាត់នីមួយៗ នឹងទទួលបានថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋានជាមធ្យមសម្រាប់ឃុំ សង្កាត់នីមួយៗទទួលបានប្រមាណដប់ម៉ឺនដុល្លារអាម៉េរិក ខណៈដែលឆ្នាំ២០១៩ មានត្រឹមតែជាងបីម៉ឺនដុល្លារអាម៉េរិក ដើម្បីបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កាន់តែមានលទ្ធភាពអាចចូលរួមដោះស្រាយតម្រូវការជាអាទិភាពនានារបស់មូលដ្ឋាននីមួយៗ

- បង្កើនការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងការអនុវត្តយន្តការនៃការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន ទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសការធ្វើសមាហរណកម្ម

ការិយាល័យជំនាញមន្ទីរវិស័យចំនួន២០ ទៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ការផ្ទេរមុខងារអប់រំកុមារតូច បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធទៅរដ្ឋបាលក្រុងស្រុកនៃខេត្តបាត់ដំបង ការផ្ទេរមុខងារមន្ទីរសុខាភិបាលទៅរដ្ឋបាលរាជធានី ខេត្ត ទន្ទឹមគ្នានឹងយន្តការនៃការវិភាជ គ្រប់គ្រង និងប្រើប្រាស់ធនធានសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង សំដៅជានាថា រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ មានលទ្ធភាពផ្តល់សេវាសាធារណៈ និងអភិវឌ្ឍនៅមូលដ្ឋានប្រកបដោយ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងនិរន្តរភាព និងបានពង្រីកវិសាលភាពនៃការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ឃ- ការអនុវត្តថវិកាតាមវិស័យ**

រយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ការអនុវត្តថវិកាតាមវិស័យ ត្រូវបានកត់ត្រា និងមានវឌ្ឍនភាពដូចបានបង្ហាញដូចក្នុងតារាងខាងក្រោម៖

ឯកតា : លានរៀល

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | គ្រោងឆ្នាំ២០២១ |
|---|---|---|---|---|---|
| I-ចំណាយថវិកាថ្នាក់ជាតិ (ក+ខ) | ១៥ ៧៩៦ ៥២១ | ១៨ ២២៩ ១១១ | ២២ ២៨៩ ៧៦៦ | ២៤ ៣១៥ ០០៣ | ២៥ ០២៥ ៧០០ |
| ក-ចំណាយចរន្ត (១+២+៣+៤+៥) | ១៣ ២៣៦៦២៩ | ១៤ ៩៧២ ៥០១ | ១៧ ៨៨៩ ៤៩៣ | ១៧ ៣៤៥ ៣៤៤ | ១៧ ៤៤៦ ៨០០ |
| ១.វិស័យរដ្ឋបាលទូទៅ | ២ ៥៣៦ ០៥១ | ២ ៤៧១ ២១០ | ៣ ២៣៩ ៣១០ | ២ ៦៩០ ៩១០ | ១ ៨១៥ ៩២០៣ |
| ២.វិស័យការពារជាតិ និងសន្តិសុខ | ៣ ៤០៤ ៥៥០ | ៣ ៩៨៩ ២៩០ | ៤ ៤១៥ ៤៤០ | ៤ ៧៣៧ ៣៦០ | ៤ ៧១៥ ៨៧០ |
| ៣.វិស័យសង្គមកិច្ច | ៤ ៨៤០ ៥១៥ | ៥ ៧៥៦ ៣៦០ | ៦ ២៨០ ០០០ | ៦ ៨០០ ២៣០ | ៦ ០៤៨ ៦៨០ |
| ៤.វិស័យសេដ្ឋកិច្ច | ១ ៣២៣ ៣៥៤ | ១ ៣៨៧ ២០០ | ១ ៥២២ ០០០ | ១ ៤៨១ ០៤០ | ១ ៤៥៩ ៧៦០ |
| ៥.ចំណាយមិនទាន់បែងចែក | ១ ១៣២ ១៥៩ | ១ ៣៦៨ ៤៤០ | ២ ៤៣២ ៧៣០ | ១ ៦៣៥ ៨១០ | ៣ ៤០៦ ៦២០ |
| ខ.ចំណាយមូលធន | ២ ៥៥៩ ៨៩២ | ៣ ២៥៦ ៦១០ | ៤ ៤០០ ២៧៣ | ៦ ៩៦៩ ៦៥៩ | ៧ ៥៧៨ ៨៥០ |
| II-ចំណាយថវិកាថ្នាក់ក្រោមជាតិ | ១ ៦៧៥ ៧៧០ | ២ ៤៩៦ ៩៥៧ | ៣ ១៣២ ៦២១ | ២ ៨៥៧ ៧២៣ | ៣ ៤០២ ៩៣៧ |

## ១.៣- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

### ១.៣.១- វិស័យអភិវឌ្ឍហិរញ្ញវត្ថុ

**ក- ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ និងបញ្ចាំ ដែលទទួលបានអាជ្ញាបណ្ណ**

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ក្រុមហ៊ុនវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ | - | ២១ | ៤១ | ៥៧ | ២៣ |
| ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ( គិតជាចំនួនក្រុមហ៊ុន) | - | ៣៥ | ៤៥ | ៣០ | ៣១ |
| ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ (គិតជាចំនួនគម្រោងទទួលបានអាជ្ញាបណ្ណ) | - | ៥៥ | ៥៩ | ៤២ | ៤៦ |
| ក្រុមហ៊ុនបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន | - | ៧៩ | ៥៩ | ៤៨ | ៥៦ |

### ខ- ទីផ្សារធានារ៉ាប់រង

ចាប់តាំងពីឆ្នាំ២០១២ មកដល់បច្ចុប្បន្ន ទំហំទីផ្សារធានារ៉ាប់រងកម្ពុជា រីកចម្រើនយ៉ាងឆាប់រហ័សដោយបុព្វលាភធានារ៉ាប់រងដុលសរុបមានកំណើនប្រមាណ២៨% ជាមធ្យមប្រចាំឆ្នាំ។ ទោះបីជាមានវិបត្តិកូវីដ-១៩ ក៏ដោយក៏បុព្វលាភធានារ៉ាប់រងកម្ពុជាក្នុងឆ្នាំ២០២០ កើនឡើងដល់២៧២លានដុល្លារអាម៉េរិក ដោយមានកំណើនប្រមាណ ៨% បានធានាបន្ទុកហិរញ្ញវត្ថុ ចំនួនប្រមាណ២៤៥ប៊ីលានដុល្លារអាម៉េរិក ចំពោះហានិភ័យទាំងអស់ និងបង្កើតការងារបានចំនួនប្រមាណ៣ ៥០០កន្លែង។




ជាមួយនិងការកើនឡើងនៃទំហំទីផ្សារធានារ៉ាប់រងកម្ពុជា ក្នុងឆ្នាំ២០២០ វិស័យធានារ៉ាប់រងបានរួមភាគទានក្នុងសេដ្ឋកិច្ច(Insurance Penetration Rate) ជាអត្រា១,០៤% ជាមួយដង់ស៊ីតេធានារ៉ាប់រង (Insurance Density) ១៧,២៦ដុល្លារអាម៉េរិក។ ទោះជាយ៉ាងណា បើប្រៀបធៀបនឹងប្រទេសក្នុងតំបន់ អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច(Insurance Penetration Rate) និងដង់ស៊ីតេធានារ៉ាប់រង (Insurance Density) របស់កម្ពុជាទាបជាងបណ្តាប្រទេសនានាក្នុងតំបន់លើកលែងប្រទេសមីយ៉ាម៉ា និងឡាវ។ នេះបញ្ជាក់ថាទីផ្សារធានារ៉ាប់រងកម្ពុជានៅមានសក្តានុពលធំធេងសម្រាប់ការអភិវឌ្ឍ ដែលជាកត្តាទាក់ទាញវិនិយោគិនក្នុងវិស័យធានារ៉ាប់រង។



ក្នុងការធានាបន្ទុកហិរញ្ញវត្ថុទាំងអស់នេះ ក្រុមហ៊ុនធានារ៉ាប់រងបានរៀបចំបង្កើតផលិតផលធានារ៉ាប់រងគ្រប់ប្រភេទសម្រាប់អតិថិជនមានដូចជាផលិតផលធានារ៉ាប់រងលើទ្រព្យសម្បត្តិ ឬអគ្គីភ័យ ផលិតផលធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ផលិតផលធានារ៉ាប់រងវិស្វកម្ម ផលិតផលធានារ៉ាប់រងការដឹកជញ្ជូនទំនិញ ផលិតផលធានារ៉ាប់រងយានយន្ត ផលិតផលធានារ៉ាប់រងសុខភាព ផលិតផលធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល ផលិតផលធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ ផលិតផលធានារ៉ាប់រងអាយុជីវិតមួយជីវិតកាល ផលិតផលធានារ៉ាប់រងទាយជ្ជទាន និងផលិតផលធានារ៉ាប់រងខ្នាតតូចជាដើម។

ទន្ទឹមនឹងនោះ ផលតិផលធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន ផលិតផលធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ និងផលតិផលធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ត្រូវបានដាក់ជាកាតព្វកិច្ចដោយច្បាប់ស្តីពីការធានារ៉ាប់រងឆ្នាំ២០០០ និងប្រកាសអន្តរក្រសួងសម្រាប់អនុវត្តក្នុងឆ្នាំ២០០២ ប៉ុន្តែការអនុវត្តមានកម្រិតតិចតួចបំផុត។

### គ- ក្រុមហ៊ុនធានារ៉ាប់រង

ទីផ្សារធានារ៉ាប់រងបច្ចុប្បន្ន មានក្រុមហ៊ុនធានារ៉ាប់រងផ្ទាល់ចំនួន៣៨ ដែលក្នុងនោះក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន១៨ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន១៤ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៦ កំពុងធ្វើប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំនួនក្រុមហ៊ុនធានារ៉ាប់រងមានការកើនឡើងយ៉ាងគំហុកចាប់តាំងពីឆ្នាំ២០១២ ដែលជាដំណាក់កាលឈានចូលទីផ្សារកម្ពុជារបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត។ ថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើត«**សាជីវកម្មធានាឥណទានកម្ពុជា**» ដោយអនុក្រឹត្យចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ជាសហគ្រាសសាធារណៈក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់ផលិតផលធានារ៉ាប់រងលើការធានាឥណទានក្នុងព្រះរាជាណាចក្រកម្ពុជា។




ក្រុមហ៊ុនទាំងនេះ មានទាំងប្រភេទក្រុមហ៊ុនបរទេសចំនួន២៣ ក្រុមហ៊ុនក្នុងស្រុក១៥ និងក្រុមហ៊ុនចំរុះរដ្ឋ២។ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់មានទ្រព្យសកម្ម ចំនួនប្រមាណ៧៤១លានដុល្លារអាមេរិក និងមូលនិធិភាគហ៊ុនិកចំនួនប្រមាណជាង ៣៤២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០។

### ១.៣.២- វិស័យអភិវឌ្ឍហិរញ្ញវត្ថុមិនមែនធនាគារ

ទីផ្សារមូលបត្រត្រូវបានដាក់ឱ្យដំណើរការ ដោយមាននិយ័តករមូលបត្រកម្ពុជា ជាបញ្ញត្តិករគ្រប់គ្រងវិស័យមូលបត្រ និងក្រុមហ៊ុនផ្សារមូលបត្រជាកម្ពុជា ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជាធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។ ដើម្បីចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងពង្រឹងកិច្ចសហប្រតិបត្តិការ មានការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុរបស់កម្ពុជា

ទៅក្នុងតំបន់អាស៊ាន និងអាស៊ានបូក៣ តាមរយៈការផ្តល់សច្ចាប័នលើ«**ពិធីសារដើម្បីអនុវត្តកញ្ចប់ទី ៦ នៃការប្តេជ្ញាបើកចំហរសេវាហិរញ្ញវត្ថុនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ អាស៊ានស្តីពីសេវា**» និង«**កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣**»។

**ក- ក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងទិន្នន័យទីផ្សារ**

| បរិយាយ | | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|
| **ទីផ្សារមូលបត្រកម្មសិទ្ធិ** | | | | | | | |
| ចំនួនបុគ្គលចុះបញ្ជីមូលបត្រសកម្មសិទ្ធិ | | ១ | - | ១ | ១ | ១ | ១ |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីបោះផ្សាយ | រៀល(លាន) | ៨២ ១៨៩,៦៤ | - | ៧៧ ១២០ | ២១ ១៨០,៧៩ | ៣៣ ១០៤,៥០ | ១០៨០៧២,៦៨ |
| | ដុល្លារ(លាន) | ២០,៥៥ | - | ១៩,២៨ | ៥,៣០ | ៨,៣០ | ២៧,០២ |
| មូលធនូបនីយកម្មទីផ្សារ | រៀល(លាន) | ៥៣៩ ២៣៤ | ៤៦៦ ១៧៦ | ៦៥៨ ៦៨២ | ៧១៦ ៣៨៨ | ៨០៤ ៥៣៩ | ១២៣០៦៧៩ |
| | ដុល្លារ(លាន) | ១៣៤,៨៩ | ១១៦,៦៩ | ១៦១,៦៤ | ១៧៦,៨៩ | ២០៤,៤៦ | ៣០៧,៦៧ |
| ទំហំជួញដូរសរុប(ភាគហ៊ុន) | | ៦ ៩២៨ ៣៨៨ | ២ ២២១ ៩៩៩ | ១ ៧៨៦ ៩៣៩ | ១ ៤២២ ០៦៣ | ២ ៦១៤ ៤៤០ | ៣៦២៣៥១៧ |
| តម្លៃជួញដូរសរុប(លានរៀល) | | ៥៣ ៥៩០,៥០ | ១៣ ៦៥២,៥៩ | ១២ ១១៣,០៤ | ៧ ០៣៩,៨៣ | ១០ ០២៣,៧១ | ១២ ៥៧០,១៣ |
| ទំហំជួញដូរជាមធ្យម(ភាគហ៊ុន) | | ៤៣ ០៣៣ | ៩ ៦៥៩ | ៧ ៩០៧ | ៦ ០៧៧ | ១០ ៨៤៨ | ១៥ ១៦១ |
| ទំហំជួញដូរជាមធ្យម(លានរៀល) | | ៣៣២,៨៦ | ៥៩,៣៦ | ៥៣,៦០ | ៣០,១០ | ៤១,៥០ | ៥២,៥៩ |
| ចំនួនថ្ងៃជួញដូរ | | ១៦១ | ២៣០ | ២២៦ | ២៣៤ | ២៤១ | ២៣៩ |
| សន្ទស្សន៍ ផ.ម.ក. | | ៦៦៦,៦៧ | ៥៧៦,៣៤ | ៤៣២,៣៨ | ៣៩៩,១០ | ៣៥៦,៣១ | ៣៤៤,៥៦ |
| **ទីផ្សារមូលបត្របំណុល** | | | | | | | |
| ចំនួនបុគ្គលចុះបញ្ជីមូលបត្របំណុល | | - | - | - | - | - | - |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ(លានរៀល) | | - | - | - | - | - | - |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ(លានដុល្លារ) | | - | - | - | - | - | - |
| ទំហំជួញដូរសរុប(ឯកតា) | | - | - | - | - | - | - |
| តម្លៃជួញដូរសរុប(លានរៀល) | | - | - | - | - | - | - |
| ចំនួនថ្ងៃជួញដូរ | | - | - | - | - | - | - |
| តម្លៃជួញដូរមធ្យម(លានរៀល) | | - | - | - | - | - | - |

| បរិយាយ | | ២០១៨ | ២០១៩ | ២០២០ | ខែវិច្ឆិកា ២០២១ | សរុបគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ |
|---|---|---|---|---|---|---|
| **ទីផ្សារមូលបត្រកម្មសិទ្ធិ** | | | | | | |
| ចំនួនបុគ្គលចុះបញ្ជីមូលបត្រសកម្មសិទ្ធិ | | - | - | ២ | ១ | ៨ |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីបោះផ្សាយ | រៀល(លាន) | ៤០ ០៤០ | - | ៨២ ៦៩៥,២១ | ១៥៣៧៨,៤៦ | ៤៥៩ ៧៨១,២៩ |
| | ដុល្លារ(លាន) | ១០ | - | ២០,៥៩ | ៣,៨៤ | ១១៤,៨៧ |

| | | | | | | |
|---|---|---|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ | រៀល(លាន) | ១ ៧៧១ ៦៧៨ | ២ ៨០៥ ៨០៧ | ៩ ៨២៧ ៧៤៦ | ៧ ៣០៨ ០៦២ | - |
| | ដុល្លារ(លាន) | ៤៤២,៩២ | ៧០១,៤៥ | ២ ៤៥៦,៩៤ | ១ ៧៩៦,០៣ | - |
| ទំហំជួញដូរសរុប(ភាគហ៊ុន) | | ៣ ៧៨១ ២៣១ | ១៥ ៤៨៩ ៩០៥ | ១១ ៣៤៥ ២៨៥ | ២២ ៧៤៧ ៧២២ | - |
| តម្លៃជួញដូរសរុប(លានរៀល) | | ២៤ ៩០២,៣២ | ១៤៨ ៧៧៨,៦៤ | ១១៣ ៧២៦,៧៥ | ១៨០ ៥៧០,៥០ | - |
| ទំហំជួញដូរជាមធ្យម(ភាគហ៊ុន) | | ១៦ ២២៨ | ៦៥ ៣៥៨ | ៤៧ ២៧២ | ១០៣ ៩១៦,៥៤ | - |
| ទំហំជួញដូរជាមធ្យម(លានរៀល) | | ១០៦,៨៨ | ៦២៨,១៨ | ៤៧៣,៨៦ | ៨២៤,៥២ | - |
| ចំនួនថ្ងៃជួញដូរ | | ២៣៣ | ២៣៧ | ២៤០ | ២១៩ | - |
| សន្ទស្សន៍ ផ.ម.ក. | | ៤៨០,៩៨ | ៧៦១,៧៣ | ៦៤៧,៩៨ | ៤៨០,៨៨ | - |
| **ទីផ្សារមូលបត្របំណុល** | | | | | | |
| ចំនួនបុគ្គលចុះបញ្ជីមូលបត្របំណុល | | ១ | ២ | ៣ | ១ | ៧ |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ(លានរៀល) | | ១២០ ០០០ | ១៦៤ ៨២១ | ២៨៧ ២០០ | ៨០ ០០០ | ៦៥២ ០២១ |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ(លានដុល្លារ) | | ៣០ | ៤១,២០ | ៧១,៨០ | ២០ | ១៦៣ |
| ទំហំជួញដូរសរុប(ឯកតា) | | - | - | ៤៦០ ៥១២ | ៦០ | - |
| តម្លៃជួញដូរសរុប(លានរៀល) | | - | - | ៤៦ ៣៦២,៦៣ | ៦,០៣ | - |
| ចំនួនថ្ងៃជួញដូរ | | ២៣៣ | ២៣៧ | ២៤០ | ២១៩ | - |
| តម្លៃជួញដូរមធ្យម(លានរៀល) | | - | - | ១៩៣,១៨ | ០,០៣ | - |

## ខ- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត និង/ឬការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា

| ល.រ. | ប្រភេទអាជីវកម្ម | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| **អាជីវកម្មមូលបត្រ** | | | | | | |
| ១ | ក្រុមហ៊ុនធានាទិញមូលបត្រ | - | - | - | - | ១ |
| ២ | ក្រុមហ៊ុនពាណិជ្ជករមូលបត្រ | - | - | - | - | - |
| ៣ | ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ | - | - | - | ១ | - |
| ៤ | ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ | - | ១ | - | ២ | - |
| ៥ | ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ | - | - | - | - | - |
| ៦ | ក្រុមហ៊ុនចែកចាយលក់មូលបត្រ | - | - | ១ | ១ | - |
| ៧ | ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ | - | - | ២ | ១ | - |
| ៨ | ភ្នាក់ងារបញ្ជិការ ភ្នាក់ចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ | ១ | - | - | - | - |
| ៩ | ក្រុមហ៊ុនផ្តល់សេវាសវនកម្ម | ១ | ១ | ១ | - | - |
| ១០ | ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ | ៣ | ១ | ២ | ១ | |
| ១១ | ក្រុមហ៊ុនផ្តល់សេវាបកប្រែក្នុងវិស័យមូលបត្រ | - | - | - | - | - |
| ១២ | ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ | - | - | - | - | - |
| ១៣ | ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល | - | ១ | - | - | - |

| | | | | | | |
|---|---|---|---|---|---|---|
| **អាជីវកម្មឧបករណ៍និស្សន្ទ** | | | | | | |
| ១៤ | ក្រុមហ៊ុនសមភាគីកណ្តាល | - | - | ១ | - | ១ |
| ១៥ | ក្រុមហ៊ុនឈ្មួញជើងសារឧបករណ៍និស្សន្ទ | ៥ | ១៣ | ៨ | ៤ | ៤ |
| **អាជីវកម្មគម្រោងវិនិយោគរួម** | | | | | | |
| ១៦ | ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ | - | - | ៥ | ៤ | ៥ |
| ១៧ | ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស | - | - | ៤ | ៦ | ២ |
| ១៨ | ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង | - | - | ១ | ២ | - |
| ១៩ | ក្រុមហ៊ុនអភិបាលមូលនិធិ | - | - | - | ១ | - |

## ១.៤- ការកៀរគរហិរញ្ញវត្ថុពីក្រៅប្រទេស (ចុះហត្ថលេខាតាមវិស័យ)

| វិស័យ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ៦១៣ ៥៧០ ៦៥៧ | ៨២៧ ៩៦២ ៧៨៨,៣ | ២៣៩ ៣១៨ ៣០០,៩ | ៧៦០ ៥០៣ ២០៤,៩ | ៣៣៥ ៨២៩ ៨៥៥,១ |
| អគ្គិសនី | ១១៦ ៦២០ ១២០ | ២៦០ ៤១៦ ១៦២,៤ | ៨០ ៥៥៧ ១៧៧,៩ | ៣១៧ ៩៤៦ ៧៨៩ | - |
| ធារាសាស្ត្រ | ១៣២ ៦២៧ ៥៧៣,៧ | ១០០ ១៦០ ៤១៨,១ | ២៣៩ ៦៧១ ៥០៤,៣ | ៩៨ ៦២០ ៥១៩,១ | ១៦៣ ៣២០ ៣១៥,៩ |
| ស្ថានីយច្រោះទឹកកខ្វក់ | - | ៦៣ ៨៨៦ ០០០ | - | - | ៩៧ ៩៦៣ ៧៣៦,៨ |
| ផ្គត់ផ្គង់ទឹកស្អាត | ៥ ០៤០ ៦២៤,២ | ២២៤ ៨៣៤ ៥៦៤,៤ | ២៧១ ៨០១ ៦៣១,៩ | - | ៥៥ ៦៨៣ ០៦៤,១ |
| កសិកម្ម | - | ១១២ ០៦០ ០០០ | - | - | - |
| ហិរញ្ញវត្ថុ | - | - | ៤០ ០០០ ០០០ | ១៣៥ ១៦៨ ៩១២,២ | ២២៨ ៣៦៨ ៤៧៥,៣ |
| អប់រំ | - | ១៣៦ ៣៧៨ ៤៩៦,៨ | ៨២ ៤២៥ ២៧៦,១ | - | - |
| សុខាភិបាល | - | - | ៨១ ៥៧៩ ៦៨៧,១ | ៥៩៤ ៧០១ ៩៧៧,៧ | ២៥ ០០០ ០០០ |
| ទេសចរណ៍ | - | - | ៥០ ៧២៣ ៨០៣,៧ | - | - |
| ពហុវិស័យ | ១០៩ ៩៧៩ ៥៦៤,១ | ១១៧ ៧៣០ ០០០ | ២០២ ១៨៧ ៩០១,៨ | ១១៥ ៥២២ ៨៣៦,៨ | - |
| **សរុប** | **៩៧៧ ៨៣៨ ៥៣៨,៩** | **១ ៨៤៣ ៤៦៨ ៤៣០** | **១២៨៨២៦៥២៨៣,៥** | **២០២២៨៦៤២៣៩,៧** | **៩០៦ ១៦៥ ៤៤៧,២** |

## ១.៥- វិធានការ និងការអនុវត្តគោលនយោបាយពាក់ព័ន្ធសំខាន់ៗ

ក្រៅពីសម្រេចបាននូវសមិទ្ធផលគន្លឹះៗខាងលើ ស្របពេលមានការលេចឡើងនូវជំងឺកូវីដ-១៩ រយៈពេលពីរឆ្នាំចុងក្រោយក្តី ក៏ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលលើវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ បានរៀបចំ និងដាក់ចេញនូវឯកសារគោលនយោបាយជាយុទ្ធសាស្ត្រមួយចំនួនពាក់ព័ន្ធតាមវិស័យរួមមាន យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៩-២០២៣ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ នីតិវិធីប្រតិបត្តិនៃការគ្រប់គ្រងគម្រោងវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ យុទ្ធសាស្ត្រគយស្តីពីអនុលោមភាពនិងការអនុវត្តច្បាប់ឆ្នាំ២០២០-២០២៣ យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

បន្ថែមពីនេះ ច្បាប់សំខាន់ៗមួយចំនួនត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខា និងប្រកាសដាក់ឱ្យអនុវត្ត ក្នុងនោះរួមមានច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ច្បាប់ស្តីពីមូលបត្ររដ្ឋ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។

## ២- ការអភិវឌ្ឍវិស័យធនាគារ

### ២.១- វិស័យធនាគារ

ក្នុងនាមអាជ្ញាធរត្រួតពិនិត្យវិស័យធនាគារ និងអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានបន្តបេសកកម្មក្នុងការកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ និងបានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

#### ២.១.១- ការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

**ក- ការរក្សាស្ថិរភាពថ្លៃ** អត្រាអតិផរណាត្រូវបានរក្សាឱ្យស្ថិតក្នុងកម្រិតទាប ស្របតាមក្របខ័ណ្ឌគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងបានអំណោយផលដល់ការលើកស្ទួយសកម្មភាពផលិតកម្មនិងពាណិជ្ជកម្ម ព្រមទាំងបានរួមចំណែកដ៏សំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដោយក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ (២០១៧-២០២១) អត្រាអតិផរណាមានកម្រិតទាបជាមធ្យម២,៦%។

**ខ- ស្ថិរភាពអត្រាប្តូរប្រាក់** ដូចគ្នានេះដែរតម្លៃប្រាក់រៀលត្រូវបានរក្សាឱ្យមានស្ថិរភាពល្អ ប្រសើរដោយអត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាម៉េរិកមានកម្រិតជាមធ្យមត្រឹម**៤ ០៧១រៀល** ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ជាមួយនឹងការប្រែប្រួលតិចតួចទៅតាមតម្រូវការនៃរដូវកាលនៃការប្រើប្រាស់ប្រាក់រៀល។ ជាក់ស្តែងនៅឆ្នាំ២០២១នេះ អត្រាប្រាក់រៀលមានកម្រិតជាមធ្យម**៤ ១០០រៀល** ក្នុងមួយដុល្លារអាម៉េរិក កើនឡើង**១%**(ធៀបនឹងអត្រាជាមធ្យម៥ឆ្នាំចុងក្រោយ)។

**គ- ការគរពូនទុនបម្រុងអន្តរជាតិ** ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបានផ្តល់នូវបរិយាកាសអំណោយផលសម្រាប់ការវិនិយោគផ្ទាល់បរទេស ការពង្រីកអាជីវកម្មក្នុងស្រុក និងពាណិជ្ជកម្មឆ្លងដែនជាដើម។ ក្នុងបរិការណ៍នេះ កម្ពុជាអាចរក្សាបាននូវកំណើនអតិរេកនៃសមតុល្យជញ្ជីងទូទាត់ជាបន្តបន្ទាប់ និងបានគរពូនទុនបម្រុងអន្តរជាតិជាលំដាប់។ ជាលទ្ធផល ជញ្ជីងទូទាត់កម្ពុជា មានអតិរេកជាមធ្យមប្រមាណ៥,២% នៃផ.ស.ស. ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ហើយទុនបម្រុងអន្តរជាតិកើនដល់២០,៤ប៊ីលានដុល្លារអាម៉េរិក គិតត្រឹមចុងឆ្នាំ២០២១ ដែលស្មើនឹងប្រមាណ៩ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតកំណត់អប្បបរមាចំនួន៣ខែ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ កម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិបានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ ផ្គត់ផ្គង់តម្រូវការសន្ទនីយភាពក្នុងស្រុក ដើម្បីរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ គរពូនទ្រព្យសម្បត្តិជាតិ និងបង្កើនជំនឿទុកចិត្តមកលើប្រទេស។

#### ២.១.២- ការអភិវឌ្ឍវិស័យធនាគារ

វិស័យធនាគារមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងបានដើរតួនាទីកាន់តែសំខាន់ក្នុង ការជំរុញកំណើនសកម្មភាពសេដ្ឋកិច្ច ដោយបានកេណ្ឌប្រមូល និងផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគ និងការប្រើប្រាស់។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ទ្រព្យសកម្មក្នុងវិស័យធនាគារបានកើនឡើងដល់១៤៩%នៃផ.ស.ស. ពីត្រឹម៩៥%

ក្នុងឆ្នាំ២០១៧ ហើយភាពស៊ីជម្រៅនៃផ្នែកហិរញ្ញវត្ថុ(M2/GDP) បានកើនដល់ប្រមាណ១៣៩% ពី៨៨%។ ទន្ទឹមនេះ វិស័យធនាគារក៏បានទាក់ទាញវិនិយោគបរទេសចូលមកកម្ពុជាប្រមាណជាង៤ប៊ីលានដុល្លារអាម៉េរិក (សមមាត្រនឹង២១%នៃវិនិយោគបរទេសសរុបមកកម្ពុជា) កើនពីត្រឹម១,៨ប៊ីលានដុល្លារអាម៉េរិក។ ដូច្នេះវិស័យធនាគារ បានកេណ្ឌប្រមូលមូលនិធិទាំងក្នុងស្រុក និងក្រៅប្រទេស ដើម្បីបែងចែកការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគក្នុងវិស័យផលិតកម្មនានា ដែលគាំទ្រដល់និរន្តរភាពនៃកំណើន និងការបង្កើតការងារ។

## ២.២- សមិទ្ធផលសំខាន់ៗនៃប្រព័ន្ធធនាគារ

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រព័ន្ធធនាគារកម្ពុជាបន្តរក្សាបាននូវវឌ្ឍនភាព ភាពរឹងមាំ និងជំនឿទុកចិត្តពីសាធារណជន ក៏ដូចជារួមចំណែកគាំទ្រយ៉ាងសកម្មដល់សកម្មភាពនានានៃសេដ្ឋកិច្ចជាតិ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ប្រព័ន្ធធនាគារកម្ពុជាមានសន្ទុះនៃការអភិវឌ្ឍខ្លាំងគួរកត់សម្គាល់។ គិតត្រឹមឆ្នាំ២០២១ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន១៦,០% ដល់២៧៨,៦ទ្រីលានរៀល(៦៨,២ប៊ីលានដុល្លារអាម៉េរិក) ក្នុងនោះឥណទានអតិថិជនបានកើនឡើង២០,៣% ដល់១៨៦,៤ទ្រីលានរៀល(៤៥,៧ប៊ីលានដុល្លារអាម៉េរិក)។ ទន្ទឹមនេះ ប្រាក់បញ្ញើអតិថិជនមានកំណើន១៥,៤% ដល់១៥៧,១ទ្រីលានរៀល(៣៨,៥ ប៊ីលានដុល្លារអាម៉េរិក) និងដើមទុនមានកំណើន១៧,៣% ដល់៥៥,៧ទ្រីលានរៀល(១៣,៦ប៊ីលានដុល្លារអាម៉េរិក)។ គណនីឥណទាន និងប្រាក់បញ្ញើអតិថិជន បន្តកើនឡើងជាបន្តបន្ទាប់ រហូតដល់៣,៣លានគណនី និង១២,១ លានគណនី រៀងគ្នា។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏បានពង្រីកបណ្តាញប្រតិបត្តិការហិរញ្ញវត្ថុរហូតដល់ចំនួន២ ៦០០ទីតាំង និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ(ATM) ចំនួន៣ ៥១២ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ។ ដើម្បីរួមចំណែកអនុវត្តតាមវិធានការរបស់ធនាគារជាតិនៃកម្ពុជាក្នុងការជួយសម្រាលបន្ទុកប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរៀបចំឥណទានឡើងវិញចំនួន៣៧០ ៧៨៥គណនី ស្មើនឹង២២,៤ទ្រីលានរៀល(ស្មើ៥,៥ប៊ីលានដុល្លារអាម៉េរិក)។ ស្របគ្នានឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីសម្រួលដល់ការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់អតិថិជន តាមរយៈបណ្ណឥណពន្ធនិងបណ្ណឥណទាន ការផ្តល់សេវាផ្ទេរប្រាក់ និងការទូទាត់សងប្រាក់តាមអេឡិចត្រូនិក ជាពិសេសប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានធ្វើទំនើបកម្មកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ។

ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការជាផ្លូវការ«**ប្រព័ន្ធបាគង**» នៅខែតុលា ឆ្នាំ២០២០ ដែលប្រព័ន្ធនេះនឹងរួមចំណែកក្នុងការជំរុញការទូទាត់មិនប្រើសាច់ប្រាក់ បរិយាបន្នហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រាក់រៀលក្នុងការទូទាត់សំដៅអភិវឌ្ឍសេដ្ឋកិច្ច ឆ្ពោះទៅរកសេដ្ឋកិច្ចផ្នែកឌីជីថល ស្របតាមបដិវត្តឧស្សាហកម្មទី៤ និងការអភិវឌ្ឍក្នុងតំបន់។ ទន្ទឹមនេះ ការកើនឡើងនៃការប្រើប្រាស់ និងការបញ្ចូលព័ត៌មានឥណទានរបស់ឯកត្តជន និងក្រុមហ៊ុនទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន បានឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងហានិភ័យ ជាពិសេសការវិភាគគុណភាពឥណទានកាន់តែប្រសើរឡើង។ បន្ទាប់

ពីយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ត្រូវបានអនុម័ត ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តតាមផែនការសកម្មភាព និងគំនិតផ្តួចផ្តើមផ្សេងៗក្រោមកិច្ចសហការជាមួយភាគីជាដៃគូពាក់ព័ន្ធនានា។ ធនាគារជាតិនៃកម្ពុជា បានបន្តការផ្សព្វផ្សាយយុទ្ធនាការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជួយដោះស្រាយចម្ងល់និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី**«វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា»** និងការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុ ទៅក្នុងកម្មវិធីសិក្សាទូទៅពីថ្នាក់ទី១-១២ និងក្រសួងកិច្ចការនារី ក្នុងការរៀបចំសិក្ខាសាលាស្តីពី **«ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ សម្រាប់ស្ត្រី និងសហគ្រិន ភាពស្ត្រី»**។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការ Good Return ដើម្បីបន្តកិច្ចសហប្រតិបត្តិការ ក៏ដូចជាការអនុវត្តគម្រោងយុទ្ធនាការប្រើប្រាស់លុយដោយឆ្លាតវៃ ដែលមានឈ្មោះថាយុទ្ធនាការ**«តោះ! និយាយពីលុយៈ តក់ៗពេញបំពង់»** បន្តពីយុទ្ធនាការ**«តោះ! និយាយពីលុយ»** ដែលមានស្រាប់។

### ២.២.១- សមិទ្ធផលសំខាន់ៗនៃវិស័យធនាគារ

ទោះបីជាស្ថិតក្នុងបរិការណ៍នៃវិបត្តិសុខភាពពិភពលោក ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារនៅតែបន្តកើនឡើងក្នុងកម្រិតល្អប្រសើរ១៥,៩% ដល់ ២៣៦,៧ ទ្រីលានរៀល(៥៨,0ប៊ីលានដុល្លារអាម៉េរិក)។ ឥណទានអតិថិជនបានកើនឡើង២០,៣% ដល់១៥០,៤ទ្រីលានរៀល (៣៦,៨ប៊ីលានដុល្លារអាម៉េរិក) ចំណែកទំហំនៃប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារបានកើនឡើង១៤,៩% ហើយគណនីប្រាក់បញ្ញើ បានកើនដល់៩,២លានគណនី។

#### ក- ការវិវឌ្ឍក្នុងវិស័យធនាគារ

| ការវិវឌ្ឍក្នុងវិស័យធនាគារ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ២០,១% | ២១,៤% | ២១,៥% | ១៤,៧% | ១៥,៩% |
| កំណើនឥណទានអតិថិជន | ១៧,២% | ២៤,៣% | ២៣,៩% | ១៦,១% | ២០,៣% |
| កំណើនប្រាក់បញ្ញើ | ២៥,១% | ២៧,៩% | ១៥,១% | ១៤,៥% | ១៤,៩% |
| ទ្រព្យសកម្មធៀបផ.ស.ស. | ១៤២,០% | ១៤៣,៦% | ១៥៥,១% | ១៨៦,១% | ២២៨,៤% |
| ឥណទានធៀបផ.ស.ស. | ៨០,៧% | ៨៣,៥% | ៩២,០% | ១១៤,៨% | ១៤៥,១% |
| ប្រាក់បញ្ញើធៀបផ.ស.ស. | ៨៥,៦% | ៩១,១% | ៩៣,៣% | ១១០,៩% | ១៣៤,៥ |

ឥណទានដែលជាប្រភពទុនយ៉ាងសំខាន់ក្នុងការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ត្រូវបានបែងចែកទៅតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច រួមមានការជួញដូររាយ១៥,៥% ការជួញដូរដុំ៩,៦% ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន១៣,៣% សំណង់៩,៧% ការឱ្យខ្ចីជាបុគ្គល១០,២% ការជួញដូរអចលនទ្រព្យ៨,៣% កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៧,២% សេវាកម្មមិនមែនហិរញ្ញវត្ថុ៥,១% កម្មន្តសាលកម្ម៤,១% សណ្ឋាគារនិងភោជនីយដ្ឋាន៤,៩% និងវិស័យផ្សេងៗ១២,១%។

## ខ- ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច




កំណើនប្រាក់បញ្ញើពីសាធារណជនបានឆ្លុះបញ្ចាំងពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើរាជរដ្ឋាភិបាល និងប្រព័ន្ធធនាគារកម្ពុជា តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពនយោបាយ និងធនាគារជាតិនៃកម្ពុជាក្នុងការរក្សាស្ថិរភាពថ្លៃ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់វិស័យធនាគារបន្តអភិវឌ្ឍជាលំដាប់ តាមរយៈការពង្រីកបណ្តាញប្រតិបត្តិការថ្មីបន្ថែម ដោយការបើកសាខាចំនួន១ ៣៤៩សាខា និងការដាក់ឱ្យប្រើប្រាស់នូវម៉ាស៊ីនATM ចំនួន៣ ២៣៥។ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងភាពល្អប្រសើរនៃកម្រិតជីវភាពរស់នៅរបស់ប្រជាជន ការប្រើប្រាស់បណ្ណជំនួសសាច់ប្រាក់ មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយបណ្ណឥណទាន និងបណ្ណឥណពន្ធបានកើនដល់១៤៨ ១២០បណ្ណ និង៣ ៨៥៩ ៣៧២បណ្ណ រៀងគ្នា។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារភាគច្រើនបាននិងកំពុងអភិវឌ្ឍសេវាហិរញ្ញវត្ថុឌីជីថល ដូចជាការប្រើប្រាស់សេវាធនាគារតាមរយៈ ប្រព័ន្ធអ៊ីនធឺណិត និងទូរសព្ទដៃជាដើម ដែលឆ្លើយតបនឹងការកើនឡើងនៃតម្រូវការរបស់អតិថិជន។ ជារួមគ្រឹះស្ថានធនាគារមានសុខភាពល្អប្រសើរ និងអាចធន់នឹងហានិភ័យនានា ដែលឆ្លុះបញ្ចាំងតាមរយៈអភិបាលកិច្ចល្អ ការត្រួតពិនិត្យផ្ទៃក្នុងម៉ឺងម៉ាត់ និងភាពរឹងមាំនៃគុណភាពទ្រព្យសកម្ម ក៏ដូចជាការអនុលោមតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន ដូចជាអនុបាតសាធនភាព និងអនុបាតសន្ទនីយភាព ដែលរក្សាបានក្នុងកម្រិត២៤,៤% និង១៥០,០% រៀងគ្នា។ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនៅបន្តមានភាពល្អប្រសើរ ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) មាន១,៨% និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុន(ROE) មាន៩,៤%។ ស្របពេលដែលសេដ្ឋកិច្ចសកល ក៏ដូចជាប្រទេសកម្ពុជាកំពុងប្រឈមនឹងវិបត្តិសុខភាពពិភពលោក អនុបាតឥណទានមិនដំណើរការបានកើនឡើងពីចំនួន២% ដល់២,៣%។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការសំខាន់ៗមួយចំនួនដូចជាការរៀបចំឥណទានរៀបចំឡើងវិញ និងការលើកទឹកចិត្តឱ្យមានការអនុគ្រោះ និង/ឬ ការលើកលែងចំពោះការផាកពិន័យផ្សេងៗលើឥណទានជាដើម ក្នុងន័យរួមចំណែកកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ មកលើអតិថិជនដែលកំពុងជួបប្រទះបញ្ហាហិរញ្ញវត្ថុ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

គ្រឹះស្ថានធនាគារ បានអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងរក្សាបានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ។ គ្រឹះស្ថានធនាគារ បន្តពង្រឹងរចនាសម្ព័ន្ធ និងអភិបាលកិច្ចរបស់ខ្លួន ដូចជាលក្ខខណ្ឌមុខងារភារកិច្ចនិងការប្រតិបត្តិរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាល មុខងារប្រតិបត្តិតាម និងការគ្រប់គ្រង

ហានិភ័យជាដើម។  ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តន៍ផែនការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ដែលក្នុងនោះបានរៀបចំកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យឡើងវិញ ដើម្បីជំរុញការងារត្រួតពិនិត្យកាន់តែមានប្រសិទ្ធភាព។

### ២.២.២- សមិទ្ធផលសំខាន់ៗនៃវិស័យមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុនៅតែបន្តការរីកចម្រើនដែលឆ្លុះបញ្ចាំងតាមរយៈជំនឿទុកចិត្តរបស់សាធារណជន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពីប្រជាជននៅតាមជនបទនៅតែបន្តកើនឡើង។ ទំហំទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង១៧,០% ដល់៤០,១ទ្រីលានរៀល(៩,៨ប៊ីលានដុល្លារអាម៉េរិក) ក្នុងនោះឥណទាន កើនឡើង២៤,៩% ដល់៣៤,៣ទ្រីលានរៀល (៨,៤ប៊ីលានដុល្លារអាម៉េរិក) ដែលគាំទ្រដោយ កំណើនមូលនិធិភាគទុនិក៣៦,៧% ដល់៩,៤ទ្រីលានរៀល(២,៣ប៊ីលានដុល្លារអាម៉េរិក) និងកំណើនប្រាក់បញ្ញើ១៩,០% ដល់១៧,៧ទ្រីលានរៀល(៤,២ប៊ីលានដុល្លារអាម៉េរិក)។

#### ក- មីក្រូហិរញ្ញវត្ថុ-ឥណទាន និងប្រាក់បញ្ញើ




កំណើនឥណទានរបស់វិស័យមីក្រូហិរញ្ញវត្ថុ បន្តគាំទ្រដល់សកម្មភាពសេដ្ឋកិច្ចធុនតូច និងមធ្យមនៅមូលដ្ឋាន ដូចជាជំនួញលក្ខណៈគ្រួសារ៣៣,៧% ពាណិជ្ជកម្មនិងជំនួញ២១,៥% កសិកម្ម១៩,៦% សេវាកម្ម១៣,៣% ដឹកជញ្ជូន៥,៣% សំណង់៣,៨% និងវិស័យផ្សេងៗ២,៩%។

#### ខ- មីក្រូហិរញ្ញវត្ថុ-ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច



ឆ្លើយតបនឹងការជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា វិស័យមីក្រូហិរញ្ញវត្ថុបានចូលរួមលើកទឹកចិត្តឱ្យអតិថិជនប្រើប្រាស់សេវាហិរញ្ញវត្ថុ ក្នុងនោះមានការដាក់ប្រាក់បញ្ញើនិងការខ្ចីឥណទានចំនួន២,៨លានគណនី និង២,០លានគណនី រៀងគ្នា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅបន្តអនុវត្តបានតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានារបស់ធនាគារជាតិនៃកម្ពុជា ដូចជាអនុបាតសាធនភាព២៣,៦% និងអនុបាតសន្ទនីយភាព១២២,០% ជាដើម។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅបន្តរក្សាបាននូវប្រាក់ចំណេញរបស់ខ្លួនតាមរយៈអនុបាតROA៣,២% និងROE១៣,៥% ដោយឡែក អនុបាតឥណទានមិនដំណើរការមានការកើនឡើងដល់២,៦% ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងការបាត់បង់ចំណូលចម្បងរបស់អ្នកខ្ចីប្រាក់។ ការទទួលបាននូវសេវាហិរញ្ញវត្ថុចម្បងៗក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅតាមជនបទនៅតែបន្តកើនឡើង ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានពង្រីកសក្តានុពល និងវិសាលភាពនៃសេវាកម្មរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការ។ ជាក់ស្តែង បណ្តាញប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានគ្របដណ្តប់ទូទាំង២៥ខេត្ត ក្រុង ជាមួយ១ ១៩៩ការិយាល័យ ហើយសេវាហិរញ្ញវត្ថុត្រូវបានបន្តធ្វើទំនើបកម្មនិងពិពិធកម្មជាបន្តបន្ទាប់។ ការណ៍នេះបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ជីវភាពរស់នៅតាមមូលដ្ឋាន តាមរយៈការផ្តល់សេវាឥណទានសម្រាប់ការប្រើប្រាស់ និងការប្រកបអាជីវកម្មខ្នាតតូចនិងមធ្យម។

សិក្ខាសាលាផ្សព្វផ្សាយស្តីពី«**វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា**» ត្រូវបានបន្តផ្សព្វផ្សាយនៅថ្នាក់ខេត្តនិងក្រុង។ សិក្ខាសាលាផ្សព្វផ្សាយនេះ ជាវេទិកាដ៏មានប្រសិទ្ធភាពមួយ ដើម្បីពង្រឹងការយល់ដឹងចំពោះវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាជូនដល់អាជ្ញាធរនិងប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ព្រមទាំងផ្តល់ឱកាសដល់អ្នកចូលរួមលើកឡើងពីបញ្ហាប្រឈម សំណូមពរ និងចម្ងល់នានាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា អាជ្ញាធរមានសមត្ថកិច្ច និងតំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានទទួលនិងផ្តល់ជាដំណោះស្រាយ ឬអនុសាសន៍ភ្លាមៗនៅនឹងកន្លែង ព្រមទាំងបង្កើនទំនាក់ទំនងនិងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងអាជ្ញាធរមូលដ្ឋាននិងភាគីពាក់ព័ន្ធនានា ដើម្បីបន្តទទួលបានព័ត៌មានជាក់ស្តែងនៃការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ និងបញ្ចៀសការកេងប្រវ័ញ្ច តាមរយៈការប្រើប្រាស់សេវាកម្មី ដែលមិនមានអាជ្ញាបណ្ណត្រឹមត្រូវ។

### ២.២.៣- វឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

ប្រព័ន្ធទូទាត់សងប្រាក់ជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុកន្លោងមួយដែលមានតួនាទីជាសារវន្ត ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្លាយជាសមាស ជាតុយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ ជាពិសេសការសម្រួលដល់ការទូទាត់ជាអេឡិចត្រូនិកក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ដើម្បីឆ្លើយតបទៅនឹងវឌ្ឍភាពនេះ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍនិងដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់តាមដំណាក់កាល រួមមានប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធOnline Banking ប្រព័ន្ធខេមបូឌានស្វ៊ីច ប្រព័ន្ធវីធែលផេ និងប្រព័ន្ធបាគង ដើម្បីសម្រួលការទូទាត់អន្តរធនាគារប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។ ប្រព័ន្ធទាំងនេះមានមុខងារសម្រួលប្រតិបត្តិការផ្ទេរប្រាក់ ឆ្លងគ្រឹះស្ថាន ជាពិសេសការទូទាត់តាមយូអរកូដ ការប្រើប្រាស់បណ្ណទូទាត់ និងសេវាធនាគារចល័ត។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តដាក់ឱ្យអនុវត្តស្តង់ដាឧបករណ៍ទូទាត់ជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់អន្តរប្រតិបត្តិការនិងសុវត្ថិភាពក្នុងការទូទាត់។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើមូលប្បទានបត្រស្តង់ដា គំរូបញ្ជាទូទាត់សងប្រាក់សម្រាប់ការផ្ទេរឥណទាន ស្តង់ដាEMV CHIP សម្រាប់បណ្ណទូទាត់ឥណពន្ធ និងខេអេចយូអរកូដ

ដែលជាស្តង់ដាឃ្យូអរកូដដើម្បីសម្រួលដល់ការទូទាត់សងប្រាក់ និងឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងតម្រូវការទីផ្សារលើសេវានិងឧបករណ៍ទូទាត់ថ្មីៗ។ ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសមួយចំនួនរួចមកហើយ និងកំពុងបន្តរៀបចំប្រកាស និងសេចក្តីណែនាំថ្មីៗបន្ថែមទៀត ដើម្បីគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ ការផ្តល់សេវា និងឧបករណ៍ទូទាត់សងប្រាក់។ កាលពីឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក្នុងគោលបំណងរួមចំណែកធានាសុវត្ថិភាពនិងភាពរឹងមាំ ជំរុញការប្រកួតប្រជែងដោយស្មោះត្រង់ លើកកម្ពស់គំនិតច្នៃប្រឌិត និងផ្តល់ជំនឿទុកចិត្តដល់សាធារណជនលើសេវាទូទាត់សងប្រាក់ ក៏ដូចជាពង្រឹងបទបញ្ញាប្រុងប្រយ័ត្នពាក់ព័ន្ធការការពារមូលនិធិរបស់អតិថិជន វិធានការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការគ្រប់គ្រងហានិភ័យដែលមានភាពចាំបាច់សម្រាប់ជំរុញស្ថិរភាពនិងសុចរិតភាព នៅក្នុងទីផ្សារទូទាត់សងប្រាក់។ ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក្នុងគោលដៅធានាបានស្ថិរភាព បង្កើនជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធទូទាត់ និងជំរុញការទូទាត់ជាអេឡិចត្រូនិកក្នុងសេដ្ឋកិច្ច។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់ផ្តោតសំខាន់លើប្រសិទ្ធភាពនិងសុវត្ថិភាពនៃប្រតិបត្តិការប្រព័ន្ធទូទាត់។ ចំណែកឯការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដោយយកចិត្តទុកដាក់លើការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសការវាយតម្លៃផ្អែកលើបទប្បញ្ញត្តិប្រុងប្រយ័ត្ន។ បច្ចុប្បន្ន គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលទទួលបានអាជ្ញាបណ្ណផ្តល់សេវាទូទាត់សងប្រាក់មានចំនួន២៩គ្រឹះស្ថាន និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានលិខិតអនុញ្ញាតផ្តល់សេវាទូទាត់សងប្រាក់មានចំនួន២គ្រឹះស្ថាន ព្រមទាំងភ្នាក់ងារសរុបមានចំនួន៥៥,៤៣ន់ទីតាំង។ ចំពោះប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់ឆ្លងដែន អ្នកប្រើប្រាស់អាចអនុវត្តបានតាមរយៈគ្រឹះស្ថានធនាគារ អ្នកដំណើរការតតិយភាគី និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដោយប្រើប្រាស់ប្រព័ន្ធស្វីស(SWIFT) ឬដៃគូសហការក្រៅប្រទេសនានា។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងផ្តួចផ្តើមភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់ ជាពិសេសតំបន់អាស៊ានដែលរួមមានការភ្ជាប់ការទូទាត់តាមរយៈឃ្យូអរកូដជាមួយប្រទេសថៃ និងការតភ្ជាប់ប្រព័ន្ធបាគងជាមួយធនាគារមេយប៊ែង ដើម្បីសម្រួលការផ្ទេរប្រាក់រវាងប្រទេសកម្ពុជា និងម៉ាឡេស៊ីជាដើម។ ជារួម ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់និងបទប្បញ្ញត្តិជាច្រើននាប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងគោលបំណងគាំទ្រប្រតិបត្តិការទូទាត់អេឡិចត្រូនិក និងដើម្បីរួមចំណែកគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលប្រកប ដោយប្រសិទ្ធភាព និងបរិយាបន្ន។

✡✡**ធនាគារជាតិនៃកម្ពុជា**

| **បរិយាយ** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** |
|---|---|---|---|---|---|
| ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច | | | | | |
| អតិផរណា | ២,៩ | ២,៥ | ១,៩ | ២,៩ | ២,៨ |
| អត្រាប្តូរប្រាក់រៀល/ដុល្លារអាម៉េរិក | ៤ ០៥១ | ៤ ០៥១ | ៤ ០៦១ | ៤ ០៩៣ | ៤ ១០០ |
| ការរីកចម្រើនប្រព័ន្ធធនាគារ | | | | | |
| ធនាគារជាតិនៃកម្ពុជា | ១ | ១ | ១ | ១ | ១ |
| សាខាធនាគារជាតិនៃកម្ពុជា | ២១ | ២១ | ២១ | ២១ | ២១ |
| ធនាគារពាណិជ្ជ | ៣៩ | ៤៣ | ៤៧ | ៥១ | ៥៣ |

| | | | | | |
|---|---|---|---|---|---|
| សាខាធនាគារពាណិជ្ជបរទេស | ១១ | ១៣ | ១៣ | ១២ | ១២ |
| បុគ្គលសម្ព័ន្ធធនាគារបរទេស | ១៦ | ១៧ | ១៧ | ១៨ | ១៨ |
| ធនាគារពាណិជ្ជក្នុងស្រុក | ១២ | ១៣ | ១៧ | ២១ | ២៣ |
| សាខាធនាគារពាណិជ្ជរាជធានី ខេត្ត | ៨២៧ | ៨៧៦ | ៩៤១ | ១ ២៨៩ | ១ ៣១៨ |
| ការិយាល័យតំណាងធនាគារបរទេស | ៦ | ៥ | ៦ | ៦ | ៦ |
| ធនាគារឯកទេស | ១៥ | ១៤ | ១៥ | ១២ | ១០ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៧ | ៧ | ៧ | ៦ | ៦ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ៦៩ | ៧៤ | ៧៦ | ៧៥ | ៧៩ |
| ប្រតិបត្តិការផែណាទានជនបទ | ៣១៣ | ២៧៣ | ២៤៥ | ២៤៥ | ២៣៤ |
| ក្រុមហ៊ុនភតិសន្យា | ១១ | ១៥ | ១៥ | ១៥ | ១៧ |

✡✡ ស្ថាប័នធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជាមិនមែនជារបស់រដ្ឋ សូមប្រជាពលរដ្ឋកុំយល់ច្រឡំ។







ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវជាតិលេខ៥៥ នៅខេត្តពោធិ៍សាត់
នៅថ្ងៃទី ៩ ខែមីនា ឆ្នាំ២០២០








ពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការចំណតផែពហុបំណងនៃកំពង់ផែស្វយ័ត
ក្រុងព្រះសីហនុថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨







**សកម្មភាពការដឹកជញ្ជូននៅផែពហុបំណង**
**នៃកំពង់ផែស្វយ័តខេត្តព្រះសីហនុ**
**កាលពីថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨**







សកម្មភាពការងារដឹកជញ្ជូននៅកំពង់ផែរាជធានីភ្នំពេញ
កាលពីថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២១





**អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ**
**កាលពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២០**






**ពិធីបុណ្យសមុទ្រលើកទី៨ វគ្គទី២**

**ថ្ងៃទី២០-២២ ខែធ្នូ ឆ្នាំ ២០១៩**









**វារីអគ្គិសនីសេសានក្រោម២ ខេត្តស្ទឹងត្រែង**
**៤០០ មេហ្គាវ៉ាត់ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨**








**ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាលគយ សាលាជាតិគយ និងសារមន្ទីរគយ**
**របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**កាលពីថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០២១**







**ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤០ នៃការបង្កើត**
**ធនាគារជាតិនៃកម្ពុជាឡើងវិញ**
**(១០ តុលា ១៩៧៩ - ១០ តុលា ២០១៩)**
**ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩**

## ចតុកោណយុទ្ធសាស្ត្រទី៣
## ការអភិវឌ្ឍវិស័យឯកជននិងការងារ

ការអភិវឌ្ឍវិស័យឯកជន នៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងអភិក្រមអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារ និងមានតួនាទីគន្លឹះ ក្នុងការជំរុញកំណើននិងអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។ ក្នុងស្មារតីនេះ ការអភិវឌ្ឍវិស័យឯកជន នឹងត្រូវអនុវត្តតាមវិធានការជាកញ្ចប់និងគ្រប់ជ្រុងជ្រោយ។

### មុំទី១- ការអភិវឌ្ឍទីផ្សារការងារ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៤-២០១៨ និងបានបន្តអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣និងទី៤ ដែលរាជរដ្ឋាភិបាលបានដាក់ចេញកន្លងមក ក្រសួងបានខិតខំអនុវត្តភារកិច្ចការងាររបស់ខ្លួន ដោយគិតពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១(ត្រឹមខែវិច្ឆិកា) ក្រសួងបានសម្រេចនូវលទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម៖

#### ១- ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

ពង្រឹងយន្តការក្រុមអធិការកិច្ចការងារនិងចុះធ្វើអធិការកិច្ចក្នុងពេលតែមួយ សំដៅកាត់បន្ថយបន្ទុករបស់ម្ចាស់រោងចក្រ សហគ្រាស និងធានាប្រសិទ្ធភាពនិងអនុលោមភាពតាមច្បាប់ និងចុះអធិការកិច្ចដោយផ្តោតលើចំណាត់ថ្នាក់នៃកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាសនីមួយៗ។ ជាក់ស្តែងចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ ក្រសួងបានចុះអធិការកិច្ចការងារ សរុបចំនួន២៥ ៩៤៦លើក ក្នុងនោះ អធិការកិច្ចការងារសាមញ្ញចំនួន២២ ៩២៣លើក ការចុះអធិការកិច្ចតាមដានការដាក់កំហិត ចំនួន១ ៨៦៧លើក ការចុះធ្វើអធិការកិច្ចពិសេសចំនួន១ ១៥៦លើក ដោយពិនិត្យឃើញថា រោងចក្រ សហគ្រាស បានអនុវត្តដោយអនុលោមតាមច្បាប់ស្តីពីការងារ។ ក្រសួងបានចុះបញ្ជិការោងចក្រ សហគ្រាស បើគិតរហូតដល់ឆ្នាំ២០២១នេះ សរុបបានចំនួន១៣ ២៨៧រោងចក្រមានកម្មករនិយោជិត សរុបចំនួន១ ៣៩៤ ៤២២នាក់(ស្រី៩០១ ៣៦៩នាក់)។ ក្រសួងបានខិតខំទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនិងការងារដោយបង្ខំ ដោយបានអនុវត្តកិច្ចអន្តរាគមន៍ស្នូល ដកហូតទប់ស្កាត់ ពលកម្មកុមារ សរុបចំនួន១ ២០០នាក់(ស្រី៦៣៧នាក់) ព្រមទាំងបានផ្តល់សេវាពិនិត្យកាយសម្បទាជូនកម្មករនិយោជិតខ្មែរ-បរទេស សរុបចំនួន១ ៤៤៥ ១៤៣នាក់(ស្រី៨៥៦ ៣៥៨នាក់)។

ក្នុងបរិបទនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងវិធានការដ៏មុតស្រួច និងចក្ខុវិស័យច្បាស់លាស់ជួយសង្គ្រោះនិងការពារអាយុជីវិតប្រជាពលរដ្ឋ និងកម្មករនិយោជិតរាប់ម៉ឺនសែននាក់ឱ្យរួចផុតពីការរាតត្បាតដ៏កាចសាហាវនៃជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាល បានខិតខំស្វែងរកប្រភពវ៉ាក់សាំងច្បាស់លាស់ រឹងមាំ និងសម្បូរបែបមកចាក់ជូនប្រជាពលរដ្ឋ កម្មករនិយោជិតនិងកុមារដោយឥតគិតថ្លៃ ហើយមកទល់បច្ចុប្បន្ននេះកម្ពុជាក្លាយជាប្រទេសមួយចាក់វ៉ាក់សាំងកូវីដ-១៩ បានលឿននិងច្រើនជាងគេក្នុងតំបន់អាស៊ាន។ តាមរយៈនេះ ក្រសួងក៏បានចូលរួមក្រោមឆត្រនៃគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងកងយោធពលខេមរភូមិន្ទ បានចុះចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់កម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស និងចាក់ជូនប្រជាពលរដ្ឋ សរុបចំនួនប្រមាណ៥៩ម៉ឺននាក់ ក្នុងនោះ ក្នុងនាមអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកម្មករនិយោជិតចំនួន

ប្រមាណ១៣ម៉ឺននាក់ និងក្រោមឆត្រកងយោធពលខេមរភូមិន្ទចំនួនប្រមាណ៤៦ម៉ឺននាក់។ បន្ថែមលើនេះទៀត ក្រសួងក៏បានពង្រឹងវិធានសុខាភិបាល ពង្រឹងលក្ខខណ្ឌការងារ និងកែសម្រួលលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ(OSH) នៅតាមរោងចក្រ សហគ្រាស បានខិតខំវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ សម្ភារ បរិក្ខារ និងសមត្ថភាពព្យាបាលរបស់មន្ទីរពេទ្យនិងគ្រូពេទ្យ និងបានខិតខំចុះយកសំណាកពិនិត្យជំងឺកូវីដ-១៩ ទាន់ពេលវេលា ដែលបានជួយកាត់បន្ថយការឆ្លងពីកម្មករនិយោជិតម្នាក់ទៅម្នាក់ទៀត និងធ្វើឱ្យរោងចក្រ សហគ្រាសភាគច្រើនអាចដំណើរការជាប្រក្រតី និងជួយកាត់បន្ថយនូវការបាត់បង់ការងារធ្វើ និងចំណូលរបស់កម្មករនិយោជិត។

- ពង្រឹងនិងប្រើប្រាស់យន្តការត្រីភាគីក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ ដោយមុនឆ្នាំ២០១៩ តាមរយៈការបង្កើត និងការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសត្រីភាគីនៃគណៈកម្មាធិការប្រឹក្សាការងារ និងចាប់ពីឆ្នាំ២០១៩ តាមរយៈក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលទទួលបានលទ្ធផលនៃការដំឡើងប្រាក់ឈ្នួលអប្បបរមាប្រកបដោយសុខដុម ស្របតាមកាលវិភាគ ទទួលបានពីគ្រប់ភាគី និងជៀសបាននូវការតវ៉ាតាមផ្លូវសាធារណៈ។ ជាលទ្ធផលចាប់តាំងពីឆ្នាំ២០១៧មក ក្រសួងបានបើកកិច្ចប្រជុំពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងបានកំណត់ប្រាក់ឈ្នួលអប្បបរមាប្រកបដោយភាពសុខដុម និងស្របតាមកាលវិភាគ ដោយបានដំឡើងប្រាក់ឈ្នួលអប្បបរមាពី១៥៣ដុល្លារអាមេរិក/ខែ នៅឆ្នាំ២០១៧ ដល់១៩២ដុល្លារអាមេរិក/ខែ នៅឆ្នាំ២០២១នេះ ហើយប្រសិនបើបូកនឹងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់អាចទទួលប្រាក់ឈ្នួលពី២០៩ ដល់២២០ដុល្លារអាមេរិក/ខែ។ សម្រាប់ឆ្នាំ២០២២ ខាងមុខនេះ ប្រាក់ឈ្នួលអប្បបរមានឹងឡើងដល់១៩៤ដុល្លារអាមេរិក/ខែ

- លើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីសហជីព និងលិខិតបទដ្ឋានពាក់ព័ន្ធ ដោយគិតពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ បានចុះបញ្ជិកាអង្គការវិជ្ជាជីវៈ សរុបចំនួន២ ០៨៣ ក្នុងនោះ សហភាពសហជីពចំនួន២២ សហព័ន្ធសហជីពចំនួន១៤៦ សហជីពមូលដ្ឋានចំនួន១ ៩០៩ និងសមាគមនិយោជកចំនួន៦។ បើគិតសរុបរួមរហូតមកត្រឹមឆ្នាំ២០២១នេះ មានអង្គការវិជ្ជាជីវៈ សរុបចំនួន ៥ ៧០៧ ក្នុងនោះ សហភាពសហជីពចំនួន៤០ សហព័ន្ធសហជីពចំនួន២៤៩ សហជីពមូលដ្ឋានចំនួន៥ ៤០៦ និងសមាគមនិយោជកចំនួន១២។ ការកើនឡើងនៃចំនួនចុះបញ្ជិកានៅក្រសួងបានស្តែងឱ្យឃើញនូវការអនុវត្តសិទ្ធិសេរីភាព អង្គការវិជ្ជាជីវៈ ត្រូវបានលើកកម្ពស់គ្មានការរឹតត្បិត ឬរើសអើងចំពោះការចូលរួមដោយសេរី និងស្មើភាពរបស់កម្មករនិយោជិត។ បន្ថែមលើនេះទៀត ក្រសួងបានកែលម្អលក្ខខណ្ឌការងារនិងលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិតតាមរយៈការដំឡើងប្រាក់ឈ្នួលអប្បបរមានិងបន្ថយចំណាយរបស់កម្មករនិយោជិត ដោយបានពង្រីកបណ្តាញអគ្គិសនីនិងទឹកស្អាតដែលមានតម្លៃទាបនៅតាមផ្ទះជួល ផ្តល់ការធ្វើដំណើរតាមរថយន្តក្រុងរបស់រដ្ឋដោយមិនបង់ប្រាក់ ដំឡើងកម្រិតអប្បបរមានៃបៀវត្សជាប់ពន្ធ បន្តលើកលែងពន្ធលើប្រាក់អត្ថប្រយោជន៍បន្ថែមនានា និងផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីសម្រាលកូន

- ជំរុញអនុវត្តយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ជាពិសេស តាមរយៈយន្តការនាយកដ្ឋានវិវាទការងារ ដោយបានដោះស្រាយវិវាទការងារសរុបចំនួន៣ ៤៥២ករណី(វិវាទបុគ្គលមានចំនួន ២ ៥២២ករណី និងវិវាទការងាររួមមានចំនួន៩៣០ករណី) ក្នុងនោះ ដោះស្រាយសះជា១ ៨៦១ករណីមិនសះជា ១ ៣៤៣ករណី មោឃៈ២៤៨ករណី។ ជាមួយគ្នានេះ ដោយបានបញ្ជូនសំណុំរឿងវិវាទការងារទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយ សរុបចំនួន៣៥៨សំណុំរឿង ក្នុងនោះ សំណុំរឿងចំនួន២៧៧ ត្រូវបានដោះស្រាយ

ដោយចេញសេចក្តីបង្គាប់ សំណុំរឿងមិនចេញសេចក្តីបង្គាប់(កិច្ចព្រមព្រៀង) សះជាដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំនួន៥២ បើពិនិត្យសំណុំរឿងមិនចេញសេចក្តីបង្គាប់ (កិច្ចព្រមព្រៀង) សះជាដោយភាគីទាំងពីរ ចំនួន២៩សំណុំរឿង។ អត្រាវិវាទការងារដែលបានដោះស្រាយសះជានៅកម្រិតមន្ត្រីផ្សះផ្សាគឺមានប្រមាណ៥៤% និងនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលមានប្រមាណ៤០%។ ក្រសួងបានអន្តរាគមន៍ដោះស្រាយកូដកម្មមានចំនួន៤១១ករណី ដោយអន្តរាគមន៍បានដោះស្រាយសះជាចំនួន៣៩២ករណី និងបានធ្វើអន្តរាគមន៍ដោះស្រាយបាតុកម្មមានចំនួន១៣៧ករណី ដោយអន្តរាគមន៍បានដោះស្រាយសះជាចំនួន១១៦ករណី។ បន្ថែមលើនេះទៀត បានដោះស្រាយករណីថៅកែរត់ចោលមិនទូទាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ សរុបចំនួន៩១រោងចក្រ មានកម្មករនិយោជិតសរុបចំនួន៣៨ ៥២០នាក់ ក្នុងនោះ ដោះស្រាយក្រៅប្រព័ន្ធតុលាការមានចំនួន៦៩ករណី នីតិវិធីក្ស័យធនមានចំនួន២ករណី បន្តដោះស្រាយតាមប្រព័ន្ធតុលាការចំនួន៥ករណី និងប្រាក់បុរេប្រទានពីរាជរដ្ឋាភិបាលចំនួន១៥ករណី

- បង្កើតក្រុមការងារដោះស្រាយការរីករាលដាលនៃជំងឺកូវីដ-១៩ តាមបណ្តារោងចក្រ សហគ្រាសនានា ក្នុងរាជធានី ខេត្ត ក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយកំណត់លក្ខណវិនិច្ឆ័យក្នុងការផ្អាក និងបើកឡើងវិញនូវសកម្មភាពអាជីវកម្ម/ផលិតកម្មដោយវិធានការរដ្ឋបាល។ ព្រមជាមួយនេះ ក្រសួងក៏បានដាក់ចេញនូវវិធានការចាំបាច់នានា ពេលបើកដំណើរការរោងចក្រ សហគ្រាសឡើងវិញ ដោយអនុវត្តវិធានការការពារការរីករាលដាលជំងឺកូវីដ-១៩ ក្រសួងបានចុះវាយតម្លៃអំពីកម្រិតហានិភ័យនៃការផ្អាកសកម្មភាពអាជីវកម្មផលិតកម្មរបស់រោងចក្រសហគ្រាសទាំងស្រុង ឬផ្នែកខ្លះនៃរោងចក្រ សហគ្រាស សរុបចំនួន២៧៧ ត្រូវជា៤៣០លើក ដែលក្នុងនោះ បានអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ ចំនួន៦៨រោងចក្រ សហគ្រាសផ្អាកដោយផ្នែកៗ ចំនួន១៧៣ និងផ្អាកទាំងស្រុង ចំនួន៣៦។ គិតមកត្រឹមថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ នេះ បានអនុញ្ញាតឱ្យបើកដំណើរការរោងចក្រ សហគ្រាសឡើងវិញទាំងស្រុង ចំនួន២៧៧

- រៀបចំកម្មវិធីសំណេះសំណាលរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាមួយកម្មករនិយោជិត ដោយគិតចាប់ពីថ្ងៃអាទិត្យ ទី២០ ខែសីហា ឆ្នាំ២០១៧ ដល់ថ្ងៃពុធ ទី១ ខែឧសភា ឆ្នាំ២០១៩ បានចំនួន៧៧លើក មានកម្មករនិយោជិត សរុបចំនួន៩៦៦ ៣១៧នាក់(ស្រី៧៧១ ៣៩១នាក់) ដោយ**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ទាំង១០ចំណុច ហើយក្រសួងបានយកចិត្តទុកដាក់អនុវត្ត ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល

- យកចិត្តទុកដាក់លើកម្មវិធីកំណែទម្រង់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងគោលដៅពង្រឹងប្រសិទ្ធភាព ការការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត ធានាការទុកចិត្តពីសំណាក់វិនិយោគិន និងធុរកិច្ច។ ក្រសួងបានរៀបចំច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា(២០១៨) ច្បាប់ស្តីពីរបបសន្តិសុខសង្គម(២០១៩) និងព្រមទាំងបានធ្វើវិសោធនកម្មច្បាប់ស្តីពីការងារចំនួនពីរលើក ដោយលើកទី១ ត្រង់មាត្រា៨៧ ចំណងជើង«គ» ផ្នែកទី៣នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ ត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ និងលើកទី២ ត្រង់មាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា២៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ ត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ក្នុងគោលបំណងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ ការការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត ធានាការទុកចិត្តពីសំណាក់វិនិយោគិន និងធុរកិច្ច។

## តារាងទី១ ការវិវត្តនៃប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅកម្ពុជា( ជាដុល្លារអាម៉េរិក)

| កាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្ត | ប្រាក់ឈ្នួលអប្បបរមា | ប្រាក់រង្វាន់ធ្វើការទៀងទាត់ | ប្រាក់សោហ៊ុយធ្វើដំណើរនិងស្នាក់នៅ | ប្រាក់ថែទាំសុខភាព | ប្រាក់ឧបត្ថម្ភជីវភាព | ប្រាក់រង្វាន់អតីតភាពការងារ | ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | តិចបំផុត | ច្រើនបំផុត |
| ១ មករា ២០២២ | ១៩៤ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ២១១ | ២២២ |
| ១ មករា ២០២១ | ១៩២ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ២០៩ | ២២០ |
| ១ មករា ២០២០ | ១៩០ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ២០៧ | ២១៨ |
| ១ មករា ២០១៩ | ១៨២ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ១៩៩ | ២១០ |
| ១ មករា ២០១៨ | ១៧០ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ១៨៧ | ១៩៨ |
| ១ មករា ២០១៧ | ១៥៣ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ១៧០ | ១៨១ |
| ១ មករា ២០១៦ | ១៤០ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ១៥៧ | ១៦៨ |
| ១ មករា ២០១៥ | ១២៨ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ១៤៥ | ១៥៦ |
| ១ កុម្ភៈ ២០១៤ | ១០០ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ១១៧ | ១២៨ |
| ១ ឧសភា២០១៣ | ៨០ | ១០ | ៧ | ម.អ. | ម.អ. | ពី០ទៅ១១ | ៩៧ | ១០៨ |
| ១ កញ្ញា ២០១២ | ៦១ | ១០ | ៧ | ៥ | ម.អ. | ពី០ទៅ១១ | ៨៣ | ៩៤ |
| ១ មករា ២០១២ | ៦១ | ៧ | ម.អ. | ៥ | ម.អ. | ពី០ទៅ១១ | ៧៣ | ៨៤ |
| ១ មីនា ២០១១ | ៦១ | ៧ | ម.អ. | ម.អ. | ម.អ. | ពី០ទៅ១១ | ៦៨ | ៧៩ |
| ១ តុលា ២០១០ | ៦១ | ៥ | ម.អ. | ម.អ. | ម.អ. | ពី០ទៅ៥ | ៦៦ | ៧១ |
| ១ មេសា ២០០៨ | ៥០ | ៥ | ម.អ. | ម.អ. | ៦ | ពី០ទៅ៥ | ៦១ | ៦៦ |
| ១ មករា ២០០៧ | ៥០ | ៥ | ម.អ. | ម.អ. | ម.អ. | ពី០ទៅ៥ | ៥៥ | ៦០ |
| ១ សីហា ២០០០ | ៤៥ | ៥ | ម.អ. | ម.អ. | ម.អ. | ពី០ទៅ៥ | ៥០ | ៥៥ |
| ១៩៩៧ | ៤០ | ម.អ. | ម.អ. | ម.អ. | ម.អ. | ពី០ទៅ៥ | ៤០ | ៤០ |

## តារាងទី២ ការដោះស្រាយវិវាទការងារ

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| | **១. វិវាទបុគ្គល** | | | | | | | |
| ១ | ចំនួនវិវាទបុគ្គល | ករណី | ៤៧៦ | ៤១៧ | ៥៧១ | ៥៥២ | ៥០៦ | **២ ៥២២** |
| ២ | សះជា | ករណី | ២២៨ | ១៩៧ | ២៨៧ | ៣២៩ | ២៩៥ | **១ ៣៣៦** |
| ៣ | មិនសះជា | ករណី | ១៩១ | ១៦៣ | ២៥៤ | ១៨២ | ១៦៩ | **៩៥៩** |
| ៤ | មោឃៈ | ករណី | ៥៧ | ៥៧ | ៣០ | ៤១ | ៤២ | **២២៧** |
| | **២. វិវាទការងាររួម** | | | | | | | |
| ១ | ចំនួនវិវាទការងាររួម | ករណី | ១២៧ | ១៦៣ | ២៥៧ | ២៤៧ | ១៣៦ | **៩៣០** |
| ២ | សះជា | ករណី | ៥៦ | ៩៩ | ១២៨ | ១៥៦ | ៨៦ | **៥២៥** |
| ៣ | មិនសះជា | ករណី | ៧០ | ៦១ | ១២៣ | ៨៦ | ៤៤ | **៣៨៤** |
| ៤ | មោឃៈ | ករណី | ១ | ៣ | ៦ | ៥ | ៦ | **២១** |

## តារាងទី៣ ការដោះស្រាយកូដកម្ម និងបាតុកម្ម

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| **១. ការដោះស្រាយករណីកូដកម្ម** | | | | | | | | |
| ១ | ចំនួនកូដកម្ម | ករណី | ៩៧ | ៤៧ | ៧៥ | ១៣៦ | ៥៦ | **៤៤១** |
| ២ | អន្តរាគមន៍ | លើក | ៩៧ | ៤៧ | ៧៥ | ១៣៦ | ៥៦ | **៤១១** |
| ៣ | សះជា | ករណី | ៩០ | ៤៧ | ៦៩ | ១៣២ | ៥៤ | **៣៩២** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | មិនសះជា | ករណី | ៧ | ០ | ៦ | ៤ | ២ | **១៩** |
| **២. ការដោះស្រាយករណីបាតុកម្ម** | | | | | | | | |
| ១ | ចំនួនបាតុកម្ម | ករណី | ៨៩ | ៥ | ១១ | ១៩ | ១៣ | **១៣៧** |
| ២ | អន្តរាគមន៍ | លើក | ៨៩ | ៥ | ១១ | ១៩ | ១៣ | **១៣៧** |
| ៣ | សះជា | ករណី | ៧៤ | ៥ | ៨ | ១៧ | ១២ | **១១៦** |
| ៤ | មិនសះជា | ករណី | ១៥ | ០ | ៣ | ២ | ១ | **២១** |

## ២- ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

- ដាក់ចេញនូវគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងយន្តការមួយចំនួនទៀត សំដៅពង្រឹង និងពង្រីកការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈបន្តជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ផែនការយុទ្ធសាស្ត្រសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ ផែនការមេសម្រាប់អភិវឌ្ឍន៍គ្រឹះស្ថាន អ.ប.វ. រយៈពេល៥ឆ្នាំ(២០២១-២០២៥) និងបានដាក់ឱ្យដំណើរការប្រព័ន្ធជាតិ អ.ប.វ. ពីចម្ងាយ ឬតាមអនឡាញ(National TVET E-Learning Platform) ដើម្បីជានា«យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត»។ ក្រសួងបានដាក់ឱ្យអនុវត្តគម្រោងសាកល្បងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ ដើម្បីបង្កើនជំនាញទប់ស្កាត់ ចំណាកស្រុក និងចំណាកប្រទេស បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពរបស់ប្រជាជននៅទីជនបទ និងបង្កើនការបណ្តុះបណ្តាល ជំនាញបច្ចេកទេសវិជ្ជាជីវៈរយៈពេលវែង តាមវិស័យអាទិភាពទាំង៥ រួមមានសំណង់ អគ្គិសនី មេកានិករថយន្ត កម្មន្តសាល និងធុរកិច្ច ព័ត៌មានវិទ្យា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម។ ជាមួយគ្នានេះ ក្រសួងបានអភិវឌ្ឍន៍ និងដាក់ឱ្យប្រើប្រាស់កញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព(ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត១ ២ ៣ ៤ ៥) ក្នុងវិស័យសំណង់ អគ្គិសនី និងថាមពល មេកានិក កម្មន្តសាល បរិក្ខារត្រជាក់ និងកម្តៅ និងធុរកិច្ច និងព័ត៌មានវិទ្យា សរុបចំនួន៧៣គុណវុឌ្ឍិ លើ៣៣មុខរបរ និងកញ្ចប់ស្តង់ដាអ្នកវាយតម្លៃសមត្ថភាពចំនួន១។

- បន្តយកចិត្តទុកដាក់លើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ នេះ ក្រសួងបាន៖

• បណ្តុះបណ្តាលសិក្ខាកាម សិស្ស និស្សិត ដែលស្ថិតនៅតាមគ្រឹះស្ថាន អ.ប.វ. សាធារណៈ ឯកជន និងអង្គការសមាគមបាន ចំនួន២៥២ ៥៤៤នាក់(ស្រី១១៤ ២២១នាក់) ក្នុងនោះ វគ្គវែងបាន៨៤ ៧២៨នាក់ (ស្រី ២៨ ៤២៨នាក់) និងវគ្គខ្លីបាន១៦៧ ៨១៦នាក់(ស្រី៨៥ ៧៩៣នាក់)។

• ធ្វើតេស្តកូនជាងបានហ្វឹកហ្វឺនចប់ ចំនួន១១០ ៩១៤នាក់(ស្រី៨៣ ៥៤៣នាក់) បានបន្តជំរុញការចុះតាមដាន និងត្រួតពិនិត្យការបណ្តុះបណ្តាល ការបញ្ច្រាបយេនឌ័រ និងមូលនិធិជាតិបង្កើតមុខរបរដោយខ្លួនឯងផងដែរ។

• ទទួលចុះបញ្ជីវិស្វករ សរុបចំនួន៤ ៣៥១នាក់(ស្រី១៦៩នាក់) ក្នុងនោះ ចំនួនវិស្វករជាតិដែលបានចុះបញ្ជី សរុបចំនួន៤ ២៧៧នាក់(ស្រី១៦៧នាក់) និងវិស្វករបរទេសដែលបានចុះបញ្ជី សរុបចំនួន៧៤នាក់ (ស្រី២នាក់)។ បើបច្ចុប្បន្នភាពត្រឹមឆ្នាំ២០២១នេះ បានទទួលចុះបញ្ជីវិស្វករ សរុបចំនួន៥ ៩១៨នាក់(ស្រី២៣៦នាក់)។

- រៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ( National TVET DAY ) ចំនួន៣លើក មានអ្នកចូលរួម សរុបចំនួន២២៨ ១២៥នាក់(ស្រី៧៣ ៦៤៣នាក់ ) ព្រមជាមួយគ្នានេះ បានពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងប្រព័ន្ធ អ.ប.វ.។

## ៣- ការរក្សានិងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស

- បន្តយកចិត្តទុកដាក់គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ និងបន្ត យកចិត្តទុកដាក់លើការរក្សានិងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស ដោយការបង្កើនឱកាស ការងារសមរម្យនិងផលិតភាពការងារខ្ពស់ ការពង្រីកយន្តការ វិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរនិង ការងារឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា។ ក្រសួងបន្តពង្រឹងយន្តការវេទិកាការងារ និង បង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានទីផ្សារការងារ ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំង ពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ ការបង្កើនផលិតភាពកម្លាំងពលកម្ម ដែលកំពុងស្ថិត ក្នុងទីផ្សារការងារ

- ពង្រឹង និងពង្រីកយន្តការ«**វេទិកាការងារ**» ដោយគិតចាប់ពីឆ្នាំ២០១៧-២០២១នេះ បានរៀបចំ ពិព័រណ៍ការងារទិវាជ្រើសរើសកម្លាំងពលកម្មថ្នាក់ជាតិនិងនៅតាមមូលដ្ឋាន សរុបចំនួន១ ៣២៦លើក មានអ្នក ចូលរួមសរុប៣៨១ ០៥៧នាក់ ដែលមានការកើនឡើងជាបន្តបន្ទាប់ដោយសារការបង្កើនការផ្សព្វផ្សាយកាន់តែ ទូលំទូលាយនិងការជឿទុកចិត្តលើគុណភាពសេវា ព្រមទាំងបានពង្រីកការផ្តល់សេវាការងារទូទាំងប្រទេសដោយ បានចុះជួបនិយោជក រោងចក្រ សហគ្រាស ចំនួន៦ ៥០៤សហគ្រាស បានប្រមូលផ្សព្វផ្សាយព័ត៌មានអំពីឱកាស ការងារ ចំនួន៥៣៩ ៨៤៧កន្លែង បានចុះឈ្មោះអ្នកស្វែងរកការងារ ចំនួន៧២ ០៥៣នាក់ និងបានជួយស្វែងរក ការងារជូនប្រជាពលរដ្ឋ ចំនួន៩៨ ០០៦នាក់ និងរកកន្លែងកម្មសិក្សាការងារដល់សិស្ស និស្សិត ចំនួន៤ ២៥៣នាក់ ដោយសារការពង្រីកសេវាមជ្ឈមណ្ឌលការងាររហូតដល់ ចំនួន១៤ និងមជ្ឈមណ្ឌលការងារចល័ត ចំនួន៣ និងការ កើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការផ្តល់សេវា ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវា។ តាមរយៈកិច្ចខិតខំនេះ ក្រសួងបានផ្តល់ឱកាសការងារជូនប្រជាពលរដ្ឋទាំងក្នុង និងក្រៅប្រទេស សរុបចំនួន ១ ០៨៤ ៤៣៩នាក់(ស្រី៦៦៧ ៧៨៨នាក់) ក្នុងនោះ បានផ្តល់ឱកាសការងារក្រៅប្រទេសកាន់តែច្រើនសម្រាប់ ប្រជាជន បានចំនួន២៩៥ ១៨៧នាក់(ស្រី១១៨ ៣៨៤នាក់) ហើយបើគិតចាប់ពីការបញ្ជូនពលករទៅធ្វើការ នៅបរទេសមកទល់បច្ចុប្បន្ននេះ ពលករកម្ពុជា សរុបចំនួន១ ៣០១ ៨០៥នាក់(ស្រី៥២៨ ៨២៦នាក់) ដែល កំពុងស្នាក់នៅ និងធ្វើការងារនៅក្រៅប្រទេស ហើយអ្នកទាំងនោះ បានផ្តល់នូវប្រាក់បញ្ញើវិលត្រឡប់ជូនគ្រួសារ ក្នុងប្រទេស ដោយបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋបានកាន់ តែប្រសើរឡើង

- ដោះស្រាយការព្យួរកិច្ចសន្យាការងាររបស់រោងចក្រ សហគ្រាស វិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងក្នុងវិស័យទេសចរណ៍ និងការបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់ រាជរដ្ឋាភិបាលដែលបណ្តាលមកពីការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ដោយកន្លងមកបានបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់ រាជរដ្ឋាភិបាល ជូនដល់កម្មករនិយោជិត ដែលព្យួរកិច្ចសន្យាការងារបាន សរុបចំនួន៣៤៧ ៨៤៤នាក់ ដែលស្មើនឹង ថវិកាចំនួន១១៤,៥ប៊ីលានរៀល(ប្រមាណ២៨លានដុល្លារអាម៉េរិក) និងបានបើកផ្តល់សាច់ប្រាក់ក្រោមកម្មវិធីជំនួយ សង្គម ជូនបងប្អូនកម្មករនិយោជិត ដែលស្ថិតនៅតំបន់បិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ ដើម្បីជួយដោះស្រាយ

ជីវភាព របស់កម្មករនិយោជិតបាន សរុបចំនួន៣៤១ ៦៤២នាក់ ដែលស្មើនឹងថវិកាសរុបប្រមាណ ៥៤,៦៦ប៊ីលានរៀល(ប្រមាណ១៣,៣៣លានដុល្លារអាម៉េរិក) និងបានបណ្តុះបណ្តាលជំនាញឡើងវិញ ជូនដល់កម្មករនិយោជិតដែលរងផលប៉ះពាល់ដោយសារវិបត្តិជំងឺកូវីដ-១៩ ចំនួន៦ ៥០០នាក់(ស្រី៣ ៣៣៥នាក់)។ ចំពោះបងប្អូនកម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារ ក៏ទទួលបានឱកាសបណ្តុះបណ្តាលជំនាញទន់ពីគ្រូឧទ្ទេសជំនាញ ដែលរួមមានជំនាញនៃទំនាក់ទំនងនិងសិល្បៈនៃការចរចា ការបំពេញការងារជាក្រុម មូលដ្ឋានច្បាប់ស្តីពីការងារ នីតិវិធីដោះស្រាយវិវាទការងារ សិទ្ធិជាមូលដ្ឋានរបស់កម្មករនិយោជិត អត្ថប្រយោជន៍ ប.ស.ស. សុវត្ថិភាព និងសុខភាពការងារ និងវិធានការបង្ការជំងឺកូវីដ-១៩។

### តារាងទី១ ការផ្តល់សេវាមុខរបរនិងការងារ

| ល.រ. | សកម្មភាព | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ១ | អ្នកចុះឈ្មោះស្វែងរកការងារ | ជនពិការ | ២៩ | ៤ | ៣៦ | ២៣ | ១២ | **១០៣** |
| | | ស្រី | ៧ ៥៨៨ | ៨ ៩៦៣ | ១០ ៤៩១ | ១២ ៤៨៤ | ២ ៩៧៣ | **៤២ ៤៩៩** |
| | | **សរុប** | **១៥ ១៣១** | **១៦ ៥២៧** | **១៨ ៦៥៦** | **១៧ ២០១** | **៤ ៥៣៦** | **៧២ ០៥៣** |
| ២ | ផ្ដល់ផ្គងនិងបញ្ជូនអ្នកស្វែងរកការងារទៅនិយោជក | ជនពិការ | ១៨ | ៤ | ១១ | ១០ | ១២ | **៥៥** |
| | | ស្រី | ៨ ៣៥០ | ១២ ៨១០ | ១៥ ៥៨៣ | ១០ ០៩៩ | ៦ ៧៨៩ | **៥៣ ៦៣១** |
| | | **សរុប** | **១៦ ០៧២** | **២៤ ៤៥២** | **២៧ ៦៦៩** | **១៧ ៣០៣** | **១២ ៥១០** | **៩៨ ០០៦** |
| ៣ | អ្នកទទួលបានការងារធ្វើ | ជនពិការ | - | ៤ | ៩ | ៤ | ០ | **១៧** |
| | | ស្រី | ១ ៩២៣ | ៣ ១៧៦ | ៣ ៨៧៥ | ២ ៦៧៣ | ៩០៤ | **១២ ៥៥១** |
| | | **សរុប** | **៣ ៤១២** | **៥ ៦៥០** | **៧ ១២៦** | **៤ ៨១៤** | **១ ៧៥៥** | **២២ ៧៥៧** |

### តារាងទី២ ការចុះបញ្ជីការងារថ្មី

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|
| បានការងារធ្វើក្នុងប្រទេសដោយខ្លួនឯង | សរុប | ១៥១ ៩៤៩ | ១៣៩ ៨៤០ | ១៤៣ ៩៥៦ | ២៣៤ ៧៤៤ | ១១៨ ៧៦៣ | **៧៨៩ ២៥២** |
| | ស្រី | ១០២ ៨៤៩ | ៨៩ ២៧៨ | ៩៤ ១៦៧ | ១៧៩ ៤៥១ | ៨៣ ៦៥៩ | **៥៤៩ ៤០៤** |
| បានការងារធ្វើនៅក្រៅប្រទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងគ.ប.ប.ព.ប. | សរុប | ៩៦ ៣៥៤ | ១០៤ ៩៨១ | ៦៨ ០៤០ | ២២ ៨៤៥ | ២ ៩៦៧ | **២៩៥ ១៨៧** |
| | ស្រី | ៣៨ ២១៨ | ៤១ ៦១៦ | ២៨ ២០១ | ៩ ៤៤០ | ៩០៩ | **១១៨ ៣៨៤** |
| សរុប | សរុប | **២៤៨ ៣០៣** | **២៤៤ ៨២១** | **២១១ ៩៩៦** | **២៥៧ ៥៨៩** | **១២១ ៧៣០** | **១០៨៤៤៣៨** |
| | ស្រី | **១៤១ ០៦៧** | **១៣០ ៨៩៤** | **១២២ ៣៦៨** | **១៨៨ ៨៩១** | **៨៤ ៥៦៨** | **៦៦៧ ៧៨៨** |

### តារាងទី៣ ចំនួនពលករពលការិនីខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេស

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ១ | ប្រទេសថៃ | សរុប | ៨៧ ៩០៩ | ៩៦ ៦៩៩ | ៥៧ ៨២៣ | ១៨ ៦២៥ | ០ | ២៦១ ០៥៦ |
| | | ស្រី | ៣៥ ១៦៤ | ៣៨ ៦៨០ | ២៤ ៩៨៩ | ៧ ៩១៩ | ០ | ១០៦ ៧៥២ |
| ២ | សាធារណរដ្ឋកូរ៉េ | សរុប | ៥ ៩៦៧ | ៤ ៨៧០ | ៥ ៩៣៨ | ៩៩៥ | ២ ៤១០ | ២០ ១៨០ |
| | | ស្រី | ១ ៦៣១ | ១ ១៤២ | ១ ១៧០ | ២១១ | ៦១៦ | ៤ ៧៧០ |
| ៣ | ប្រទេសជប៉ុន | សរុប | ២ ២៩៦ | ៣ ០០២ | ៣ ៩៤៥ | ៣ ១០៩ | ៤៩០ | ១២ ៨៤២ |
| | | ស្រី | ១ ២៤១ | ១ ៤១៧ | ១ ៧៤៤ | ១ ២១១ | ២២៦ | ៥ ៨៣៩ |
| ៤ | ប្រទេសសិង្ហបុរី | សរុប | ១៣៨ | ២៨៧ | ១៣៥ | ៣៩ | ២ | ៦០១ |
| | | ស្រី | ១៣៨ | ២៨៧ | ១៣៥ | ៣៩ | ២ | ៦០១ |
| ៥ | តំបន់រដ្ឋបាលពិសេសហុងកុង | សរុប | ៥ | ៥៤ | ៧២ | ៥១ | ៦៥ | ២៤៧ |
| | | ស្រី | ៥ | ៥៤ | ៧២ | ៥១ | ៦៥ | ២៤៧ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦ | ប្រទេសម៉ាឡេស៊ី | សរុប | ២៧ | ៥៣ | ៦៩ | ២៦ | ០ | ១៧៥ |
| | | ស្រី | ២៧ | ២០ | ៣៣ | ៩ | ០ | ៨៩ |
| ៧ | ប្រទេសអារ៉ាប់ប៊ីសាអូឌីត | សរុប | ១២ | ១៦ | ៥៨ | - | ០ | ៨៦ |
| | | ស្រី | ១២ | ១៦ | ៥៨ | - | ០ | ៨៦ |
| សរុប | | **សរុប** | **៩៦ ៣៥៤** | **១០៤ ៩៨១** | **៦៨ ០៤០** | **២២ ៨៤៥** | **២ ៩៦៧** | **២៩៥១៨៧** |
| | | **ស្រី** | **៣៨ ២១៨** | **៤១ ៦១៦** | **២៨ ២០១** | **៩ ៤៤០** | **៩០៩** | **១១៨៣៨៤** |

## ៤- ការអភិវឌ្ឍរបបសន្តិសុខសង្គម

- បន្តពង្រឹងការអនុវត្តរបបសន្តិសុខសង្គម ដោយបានចុះបញ្ជិកាសមាជិកផ្នែកហានិភ័យការងារ សម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ ដោយគិតចាប់ពីឆ្នាំ២០១៧-២០២១នេះ ប.ស.ស. បានចុះបញ្ជិកា រោងចក្រ សហគ្រាស និងក្រសួង ស្ថាប័ន សរុបចំនួន៨ ៧១៧ និងមានសមាជិក ចំនួន៨២៤ ០៧៣នាក់(ស្រី ៣៣៣ ៤៦០នាក់) និងបានផ្តល់តាវកាលិកហានិភ័យការងារ សរុបចំនួន៦៣ ២២៧នាក់(ស្រី៤០ ៨៨៤នាក់) និងបានចំណាយតាវកាលិកហានិភ័យការងារ ចំនួន៩៤,២៥ប៊ីលានរៀល។ បើគិតចាប់ពីតាំងការអនុវត្តនៅឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០២១នេះ ប.ស.ស. បានចុះបញ្ជិការោងចក្រ សហគ្រាស និងក្រសួង ស្ថាប័ន សរុបចំនួន១៧ ០០៩ សហគ្រាស មានសមាជិក សរុបចំនួន២ ៤៩១ ៩០៨នាក់(ស្រី១ ៥៧៨ ៤៥៣នាក់) និងបានផ្តល់តាវកាលិក ហានិភ័យការងារ សរុបចំនួន១៦៧ ២១២នាក់(ស្រី៦៥ ១១០នាក់) និងបានចំណាយតាវកាលិកហានិភ័យការងារ ចំនួន១៥១,៣៧ប៊ីលានរៀល

- ជាមួយគ្នានេះ ក្រសួងបានបន្តផ្តល់ការពិនិត្យព្យាបាលជំងឺដោយមិនបង់ប្រាក់តាមរយៈការពង្រឹង ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដោយបានពង្រីកសមាជិកដល់ចំនួនប្រមាណ២ ៧៥៤ ៣៧៨នាក់ (ស្រី១ ៦២០ ៥៦៣នាក់) និងមានអ្នកទៅប្រើប្រាស់សេវាកើនដល់៨ ៩០៤ ០៦៧ដង/នាក់(ស្រី៦ ៤៦០ ៦៨៤ ដង/នាក់) និងចំណាយថវិកាអស់ប្រមាណ១ ១៥១,៥៣ប៊ីលានរៀល ព្រមទាំងបានកំពុងរៀបចំដាក់ឱ្យដំណើរការ អនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននាពេលខាងមុខនេះផងដែរ។ ក្រសួងបានពង្រឹងការអនុវត្តរបបសន្តិសុខ សង្គមផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន៩៤៤សហគ្រាស មានចំនួនកម្មករនិយោជិតចំនួន៩៤ ៣៧៨នាក់(ស្រី ២០ ៣៦៥នាក់) និងបានអនុវត្តការផ្តល់ប្រាក់ឈ្នួលជូនដល់កម្មការិនី១២០% និងឈប់សម្រាករយៈពេល៣ខែ ក្នុងពេលសម្រាលកូន ដោយបានផ្តល់ប្រាក់ឈ្នួលដល់កម្មការិនីសម្រាលកូន មានកម្មការិនីសរុបចំនួន២៣៧ ៨២២ នាក់ ដែលគិតជាទឹកប្រាក់អស់ចំនួន៤៨៤,៦០ប៊ីលានរៀល និងបានបន្តផ្តល់ប្រាក់ឧបត្ថម្ភ និងថវិកាបន្ថែមរបស់ **សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ផ្ទាល់ដល់កម្មការិនីសម្រាលកូន មានកម្មការិនីសរុបចំនួន២៧៦ ១១៧ នាក់ មានកូនសរុបចំនួន២៧៨ ០១៨នាក់ ដែលស្មើនឹងថវិកាចំនួន១១១,២១ប៊ីលានរៀល។ បន្ថែមលើនេះទៀត ក្រសួងបានរៀបចំបង្កើតឱ្យមានរបបប្រាក់សោធន សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន បង្ហាញឱ្យឃើញនូវ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដែលគ្រោងនឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០២២ខាងមុខ។

**តារាងទី១ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ**

| **សមាជិកចុះបញ្ជិកាថ្មី** | | | | | | | |
|---|---|---|---|---|---|---|---|
| **បរិយាយ** | **ឯកតា** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **សរុបរួម** |
| សមាជិកផ្នែកហានិភ័យការងារ | សហគ្រាស | ៩៩៣ | ៣ ១០៤ | ២ ១០៧ | ១ ៥១៣ | ១ ០០០ | ៨ ៧១៧ |
| | សមាជិក | ៥០ ១៨២ | ៣០៥ ៦៩១ | ៨៤ ០៨១ | ៤៤ ៥០៨ | ៣៣៩ ៦១១ | ៨២៤ ០៧៣ |
| | ស្រី | ២៩ ៧១៩ | ៧២ ០៤០ | ៥២ ៧២៥ | ២៣ ៦៦៨ | ១៥៣ ៣០៨ | ៣៣១ ៤៦០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កម្មករនិយោជិត | សហគ្រាស | ៩៩៣ | ៣ ១០៤ | ២ ១០៧ | ១ ៥១៣ | ៩៦៥ | ៨ ៦៨២ |
| | សមាជិក | ៥០ ១៨២ | ៣០៥ ៦៩១ | ៨៤ ០៨១ | ៤៤ ៥០៨ | ៩០ ៨៥៧ | ៥៧៥ ៣១៩ |
| | ស្រី | ២៩ ៧១៩ | ៧២ ០៤០ | ៥២ ៧២៥ | ២៣ ៦៦៨ | ៥០ ០៣២ | ២២៨ ១៨៤ |
| មន្ត្រីរាជការសាធារណៈ | សហគ្រាស | - | - | - | - | ៣៥ | ៣៥ |
| | សមាជិក | - | - | - | - | ២៤៨ ៧៥៤ | ២៤៨ ៧៥៤ |
| | ស្រី | - | - | - | - | ១០៣ ២៧៦ | ១០៣ ២៧៦ |
| ការផ្តល់តាវកាលិកហានិភ័យការងារ | | | | | | | |
| ការផ្តល់តាវការលិកសរុប(ឯកសារ) | ឯកសារ | ៤០ ២៧០ | ៣២ ៣២៦ | ១៧ ០៦៨ | ១៣ ៨២៦ | ៨ ៥២៣ | ១១២០១៣ |
| កម្មករនិយោជិត | ឯកសារ | ៤០ ២៧០ | ៣២ ៣២៦ | ១៧ ០៦៨ | ១៣ ៨២៦ | ៨ ៥២៣ | ១១២០០៩ |
| មន្ត្រីរាជការសាធារណៈ | ឯកសារ | - | - | - | - | ៤ | ៤ |
| ជនរងគ្រោះទទួលតាវកាលិកហានិភ័យការងារ | | | | | | | |
| អ្នកទទួល (ជនរងគ្រោះ) បានតាវកាលិក | សរុប | ២១ ២៦៧ | ១៧ ៣៨៦ | ១០ ៥៥៥ | ៨ ៦២២ | ៥ ៣៩៧ | ៦៣ ២២៧ |
| | ស្រី | ១៥ ៣០២ | ១២ ១៩៩ | ៦ ០៥១ | ៤ ៥៥១ | ២ ៧៨១ | ៤០ ៨៨៤ |
| កម្មករនិយោជិត | សរុប | ២១ ២៦៧ | ១៧ ៣៨៦ | ១០ ៥៥៥ | ៨ ៦២២ | ៥ ៣៩៣ | ៦៣ ២២៣ |
| | ស្រី | ១៥ ៣០២ | ១២ ១៩៩ | ៦ ០៥១ | ៤ ៥៥១ | ២ ៧៨១ | ៤០ ៨៨៤ |
| មន្ត្រីរាជការសាធារណៈ | សរុប | - | - | - | - | ៤ | ៤ |
| | ស្រី | - | - | - | - | ០ | ០ |
| ការចំណាយតាវកាលិក និងស្តារនីតិសម្បទា (លានរៀល) | | | | | | | |
| ការចំណាយតាវកាលិក និងស្តារនីតិសម្បទា | លានរៀល | ១៩ ៥៣៤,៣៤ | ២០ ១៦៦,២៦ | ១៩ ៧៨០,០៨ | ១៨ ៩៥០,២៧ | ១៥ ៨១៦,៣០ | ៩៤ ២៤៧,២៥ |

# តារាងទី២ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

| សមាជិកចុះបញ្ជិកាថ្មី | | | | | | | |
|---|---|---|---|---|---|---|---|
| **បរិយាយ** | **ឯកតា** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **សរុបរួម** |
| សមាជិកផ្នែកថែទាំសុខភាព | សហគ្រាស | - | ៣ ១៤០ | ២ ១០៧ | ១ ៥១៤ | ៩៦៦ | ៧ ៧២៧ |
| | សរុប | - | ៦១៩ ៣៤២ | ១០៨ ៩៣៨ | ៩៥ ៦០២ | ១១៥ ៤៩៩ | ៩៣៩ ៣៨១ |
| | ស្រី | - | ១៧១ ៤៣២ | ៦១ ០២២ | ៣១ ៣២០ | ៥៨ ៧៣១ | ៣២២ ៥០៥ |
| កម្មករនិយោជិត | សហគ្រាស | - | ៣ ១០៤ | ២ ១០៧ | ១ ៥១៣ | ៩៦៥ | ៧ ៦៨៩ |
| | សរុប | - | ៣០៥ ៦៩១ | ៨៤ ០៨១ | ៤៤ ៥០៨ | ៨៨ ២៥៥ | ៥២២ ៥៣៥ |
| | ស្រី | - | ៧២ ០៤០ | ៥២ ៧២៥ | ២៣ ៦៦៨ | ៤៩ ០៥១ | ១៩៧ ៤៨៤ |
| មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន | សហគ្រាស | - | ៣៦ | ០ | ១ | ១ | ៣៨ |
| | សរុប | - | ៣១៣ ៦៥១ | ២៤ ៨៥៧ | ៥១ ០៩៤ | ២៧ ២៤៤ | ៤១៦ ៨៤៦ |
| | ស្រី | - | ៩៩ ៣៩២ | ៨ ២៩៧ | ៧ ៦៥២ | ៩ ៦៨០ | ១២៥ ០២១ |
| **អ្នកប្រើប្រាស់សេវាថែទាំសុខភាព** | | | | | | | |
| ការប្រើប្រាស់សេវា សរុប | ដង/នាក់ | ២៩២២៣២ | ១៣៧៣១៣៨ | ២៤៩៤៧៣១ | ២៧២១០៥០ | ២០២២៩១៦ | ៨៩០៤០៦៧ |
| | ស្រី | ២០៤៥៦២ | ៩៥៤ ៧៣៣ | ២០៤០៣៥៣ | ១៩០៥៥៩១ | ១៣៥៥៤៤៥ | ៦៤៦០៦៨៤ |
| កម្មករនិយោជិត (OPD,IPD) | ដង/នាក់ | ២៩២២៣២ | ១៣៤៧២៨៧ | ២៣៩៩៤២៦ | ២៤០៦៨៩៧ | ១៧៨០៥២៩ | ៨២២៦៣៧១ |
| | ស្រី | ២០៤៥៦២ | ៩៤៣ ១០០ | ១៩៩៧៧១០ | ១៧៦៤២២១ | ១២៤៦៣៧០ | ៦១៥៥៩៦៣ |
| មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន | ដង/នាក់ | - | ២៥ ៨៥១ | ៩៥ ៣០៥ | ៣១៤ ១៥៣ | ២៤២ ៣៨៧ | ៦៧៧ ៦៩៦ |
| | ស្រី | - | ១១ ៦៣៣ | ៤២ ៦៤៣ | ១៤១ ៣៧០ | ១០៩ ០៧៥ | ៣០៤ ៧២១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កម្មករនិយោជិតទទួលតាវកាលិកថែទាំសុខភាព | | | | | | | |
| កម្មករនិយោជិតទទួលតាវកាលិកថែទាំសុខភាព | សរុប | ៥ ២៧០ | ៥១ ៣៦៣ | ៨៤ ១២៣ | ៨៩ ៤៦២ | ៩៦ ៧៣៧ | ៣២៦ ៩៥៥ |
| | ស្រី | ៤ ៨៨២ | ៤៩ ៥០៩ | ៨០ ៧១២ | ៨៥ ៩០១ | ៨៣ ៨៧៩ | ៣០៤ ៨៨៣ |
| ការចំណាយតាវកាលិក និងស្ពានីតិសម្បទា (លានរៀល) | | | | | | | |
| ការចំណាយតាវកាលិក និងស្ពានីតិសម្បទា | លានរៀល | ១៨ ៧៧៤ | ១៥៥ ២២៥ | ២៩៧ ៥២៧,៨៣ | ៣៦៦៦៨៩,១៧ | ៣១៣៣១២,៧៣ | ១១៥១៥២៨,៧៣ |

## តារាងទី៣ ការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីសម្រាលកូន

| បរិយាយ | | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ចំនួនស្ត្រីសម្រាលកូនក្នុងប្រព័ន្ធ | ស្ត្រីសម្រាលកូន | នាក់ | - | ៥៧ ៤៥៨ | ៧៦ ១៥១ | ៨១ ៨៣៦ | ៥៩ ៨២៣ | ២៧៥ ២៦៨ |
| | ចំនួនកូនសរុប | នាក់ | - | ៥៧ ៨៨៩ | ៧៦ ៥៦៥ | ៨២ ៣៧២ | ៦០ ២៤៤ | ២៧៧ ១៦១ |
| | ចំនួនទឹកប្រាក់ | លានរៀល | - | ២៣១៥៥,៦០ | ៣០ ៦៦២,៤០ | ៣២ ៩៤៨,៨០ | ២៤ ០៩៧,៦០ | ១១០ ៨៦៤,៤០ |
| ចំនួនស្ត្រីសម្រាលកូនក្រៅប្រព័ន្ធ | ស្ត្រីសម្រាលកូន | នាក់ | - | ៣៧៣ | ២៣០ | ១៥៤ | ៩២ | ៨៤៩ |
| | ចំនួនកូនសរុប | នាក់ | - | ៣៧៦ | ២៣៣ | ១៥៥ | ៩៣ | ៨៥៧ |
| | ចំនួនទឹកប្រាក់ | លានរៀល | - | ១៥០,៤០ | ៩៣,២០ | ៦២ | ៣៧,២០ | ៣៤២,៨០ |
| សរុប(១+២) | ស្ត្រីសម្រាលកូនសរុប | នាក់ | - | ៥៧ ៨៣១ | ៧៦ ៣៨១ | ៨១ ៩៩០ | ៥៩ ៩១៥ | ២៧៦ ១១៧ |
| | ចំនួនកូនសរុបរួម | នាក់ | - | ៥៨ ២៦៥ | ៧៦ ៨៨៩ | ៨២ ៥២៧ | ៦០ ៣៣៧ | ២៧៨ ០១៨ |
| | ចំនួនទឹកប្រាក់ | លានរៀល | - | ២៣ ៣០៦ | ៣០ ៧៥៥,៦០ | ៣៣ ០១០,៨០ | ២៤ ១៣៤,៨០ | ១១១ ២០៧,២០ |

## ៥- ការពង្រឹងសេវាគាំទ្រទូទៅ

បានបញ្ជូនមន្ត្រីទៅចូលរួមបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងក្នុងនិងក្រៅប្រទេសសរុបចំនួន ១០ ០១១នាក់(ស្រី២ ០៧៥នាក់) ក្នុងនោះ ក្នុងប្រទេសចំនួន៨ ៦៥០នាក់(ស្រី១ ៨៣៣នាក់) និងក្រៅប្រទេស ១ ៣៦១នាក់(ស្រី២៤២នាក់)។

### តារាងទី១ ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ

| ល.រ. | បរិយាយ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ការបណ្តុះបណ្តាលរដ្ឋបាល ហិរញ្ញវត្ថុ និងផែនការ | ២០៧ | ១១៨ | ០ | ០ | ២៧៧ | ៩៦ | ២ | ២ | ១៨ | ៦ |
| ២ | ចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស | ៦៣៦ | ៨៧ | ៩៨០ | ១១២ | ៣១៩ | ៥២ | ៣៤២៨ | ៦៨៤ | ២៦០៦ | ៦៦៦ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣ | ចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស | ២៥៥ | ៣១ | ៣៣០ | ៦១ | ៣៩៦ | ៨២ | ៣៩ | ១២ | ៨១ | ២៤ |
| ៤ | ចូលរួមទស្សនកិច្ចសិក្សាក្នុងប្រទេស | ១៣៦ | ៨ | ៤ | ០ | ០ | ០ | ១៥ | ២ | ២២ | ០ |
| ៥ | ចូលរួមទស្សនកិច្ចសិក្សាក្រៅប្រទេស | ៨៦ | ៦ | ៩៧ | ១៥ | ៥៥ | ៥ | ៣៣ | ៦ | ០ | ០ |
| សរុប | | ១៣២០ | ២៥០ | ១៤១១ | ១៨៨ | ១០៤៧ | ២៣៥ | ៣៥០៦ | ៧០៦ | ២៧២៧ | ៦៩៦ |

## មុំទី២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព

### ១- ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម

#### ១.១- សហគ្រាសធុនតូចនិងមធ្យមនិងសិប្បកម្ម

លទ្ធផលការងារសរុប៥ឆ្នាំ(២០១៧-២០២១) របស់អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម មានដូចខាងក្រោម៖

ក្នុងបរិបថនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្របខ័ណ្ឌតំបន់និងពិភពលោកមានការរីកចម្រើនខ្លាំង តាមរយៈការធ្វើទំនើបកម្មឧស្សាហកម្ម ការអភិវឌ្ឍន៍បច្ចេកវិទ្យាទំនើបៗ ដូចនេះរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុក**វិស័យសហគ្រាសធុនមីក្រូតូច និងមធ្យម** ជាមូលដ្ឋានដ៏សំខាន់មួយសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនិងសង្គម ពីព្រោះវិស័យនេះមានលក្ខណៈអន្តរសកម្មភាពច្រើនងាយបត់បែន និងសម្របខ្លួនបានយ៉ាងឆាប់រហ័សទៅតាមកាលៈទេសៈនៃការអភិវឌ្ឍបច្ចេកវិទ្យា។ ក្នុងន័យនេះក្រសួង ស្ថាប័នទទួលបន្ទុកសហគ្រាសធុនតូចនិងមធ្យម ត្រូវពិនិត្យការពង្រឹងក្របខ័ណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសឡើងវិញ ពិសេសបន្ទុកអនុលោមភាពរបស់សហគ្រាស និងការរៀបចំការចុះបញ្ជី ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះទទួលបានព័ត៌មានពីឥណទាន ការផ្ទេរបច្ចេកវិទ្យា ទីផ្សារ និងការពិគ្រោះយោបល់ ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្ម និងការវិយោគលើវិស័យនេះ ព្រមទាំងពង្រឹង ការគ្រប់គ្រងនិងការតាមដានវឌ្ឍនភាពនៃវិស័យនេះ។

នៅក្នុងរយៈពេល៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១(គិតត្រឹមខែតុលា) មូលដ្ឋានបង្កើតថ្មីមានចំនួន៣ ៩៥៣មូលដ្ឋាន ដែលបានបង្កើតការងារចំនួន៥២ ៦០២នាក់ និងបានផ្តល់វិញ្ញាបនបត្របន្តដំណើរការចំនួន២ ៧១២មូលដ្ឋាន។ ដូច្នេះគិតមកដល់ខែតុលា ឆ្នាំ២០២១នេះ មូលដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្មសរុបមានចំនួន៤៣ ២៧៦មូលដ្ឋាន និងពលកម្មមានចំនួន៤៣៥ ៩០៥នាក់។




ចំនួនមូលដ្ឋានសរុបបែងចែកតាមផ្នែក គិតត្រឹមខែតុលា ឆ្នាំ២០២១
917
1,643
5,270
2,093
1,250
195
286
3,317
28,305
សរុប ៤៣,២៧៦ មូលដ្ឋាន
១០-១២.ផ្នែកអាហារ ភេសជ្ជៈ និងថ្នាំ
១៣-១៥.ផ្នែកឧស្សាហកម្មសម្លៀកបំពាក់ កាត់ដេរ ជាក់កាបូប និងស្បែកជើង
១៦-ផ្នែកឧស្សាហកម្មឈើ និងផលិតផលពីឈើ
១៧-១៨.ផ្នែកផលិតផលពីក្រដាស និងក្រដាស និងបោះពុម្ពផ្សេងៗ
១៩-២២.ផ្នែកឧស្សាហកម្មគីមី កៅស៊ូ និងប្លាស្ទិក
២៣.ផ្នែកផលិតកម្មពីមិនមែនលោហៈ
២៤-៣០.ផ្នែកឧស្សាហកម្មកែច្នៃលោហៈ
៣១-ផ្នែកគ្រឿងសង្ហារិម
៣២-ផ្នែកឧស្សាហកម្មផ្សេងៗ


ចំនួនពលកម្មសរុប បែងចែកតាមផ្នែក គិតត្រឹមខែតុលា ឆ្នាំ២០២១
4,631
5,724
20,407
30,189
11,646
4,433
2,075
164,750
192,050
ចំនួនពលកម្មសរុប: ៤៣៥,៩០៥
១០-១២.ផ្នែកអាហារ ភេសជ្ជៈ និងថ្នាំ
១៣-១៥.ផ្នែកឧស្សាហកម្មសម្លៀកបំពាក់ កាត់ដេរ ជាក់កាបូប និងស្បែកជើង
១៦-ផ្នែកឧស្សាហកម្មឈើ និងផលិតផលពីឈើ
១៧-១៨.ផ្នែកផលិតផលពីក្រដាស និងក្រដាស និងបោះពុម្ពផ្សេងៗ
១៩-២២.ផ្នែកឧស្សាហកម្មគីមី កៅស៊ូ និងប្លាស្ទិក
២៣.ផ្នែកផលិតកម្មពីមិនមែនលោហៈ
២៤-៣០.ផ្នែកឧស្សាហកម្មកែច្នៃលោហៈ
៣១-ផ្នែកគ្រឿងសង្ហារិម
៣២-ផ្នែកឧស្សាហកម្មផ្សេងៗ


ចំនួនមូលដ្ឋាន បែងចែកតាមរាជធានី-ខេត្ត គិតត្រឹមខែតុលា ឆ្នាំ២០២១
សរុបចំនួន ៤៣,២៧៦ មូលដ្ឋាន




## ១.២- ការងារស្រែអំបិល

ទាក់ទងនឹងការងារស្រែអំបិល ការផលិតនិងកែច្នៃអំបិល ក្រសួងបាន៖

- ចេញវិញ្ញាបនបត្រប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិលដែលបានបញ្ចូលជាតិអ៊ីយ៉ូដ ដល់សិប្បកម្មកែច្នៃ និងវេចខ្ចប់អំបិលចំនួន២៥ទីតាំង
- ចុះពិនិត្យទីតាំងចាក់ដីលុបផ្លូវទឹកសម្រាប់ផលិតអំបិលនៅខេត្តកំពត និងពិនិត្យទីតាំងបោះបង្គោលកំណត់ព្រំដីព្រៃលិចទឹករបស់មន្ត្រីជលផលជាប់លើដីស្រែអំបិលនៅខេត្តកែប
- ទទួលប្រកាសរួមលេខ០៨៥MIH/2018 ស្តីពីការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិលដែលបានបញ្ចូលជាតិអ៊ីយ៉ូដ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨
- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីនីតិវិធី និងបែបបទសម្រាប់ការផ្តល់អាជ្ញាបណ្ណប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិលដែលបានបញ្ចូលជាតិអ៊ីយ៉ូដ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩
- រៀបចំសិក្ខាសាលាស្តីពីការគ្រប់គ្រងនិងការបញ្ចូលរបាយការណ៍ផលិតកម្មអំបិលអ៊ីយ៉ូដ តាមប្រព័ន្ធបច្ចេកវិទ្យា
- ប្រជុំពិភាក្សាជាមួយតំណាងអនុគណៈកម្មការជាតិលុបបំបាត់ជាតិអ៊ីយ៉ូដស្តីពី ការបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិល និងបញ្ចូលជាតិដែកក្នុងទឹកត្រី ទឹកស៊ីអ៊ីវ
- ប្រជុំស្តីពីបញ្ហាអំបិល នៅទីស្តីការក្រសួង កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩
- រៀបចំផែការសកម្មភាពសម្រាប់ការងារស្រែអំបិលនិងផលិតកម្មអំបិល
- រៀបចំសេចក្តីព្រាងលិខិត ជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកែប ករណីស្នើសុំធ្វើផ្លូវព័ទ្ធជុំវិញ និងកាត់ពាក់កណ្តាលដីស្រែអំបិលស្ថិតនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។

តារាងផ្ទៃដី និងទិន្នផលស្រែអំបិលរយៈពេល៥ឆ្នាំ (២០១៧-២០២១)

| ឆ្នាំ | ទិន្នផល (តោន) | ផ្ទៃដីផលិតជាក់ស្តែង (ហ.ត.) | តម្លៃ/តោន (រៀល) | កម្លាំងពលកម្ម | ផ្សេងៗ |
|---|---|---|---|---|---|
| ខេត្តកែប | | | | | |
| ២០១៧ | ៣៨ ០០០ | ៩៩៥,១២ | ២៨០ ០០០រៀល | ៤១៨នាក់ | |
| ២០១៨ | 0.00 | ៩៩៥,១២ | ៣៦០ ០០០រៀល | ៣២០នាក់ | ភ្លៀងធ្លាក់ច្រើន |
| ២០១៩ | ៨ ៥០០ | ៩៩៥,១២ | ២៤០ ០០០រៀល | ២៣៦នាក់ | |
| ២០២០ | ១២ ៨១៥ | ៧៤៧ | ១៨ ៥០០រៀល | ២១៦នាក់ | |
| ២០២១ | ១០ ១៣៣ | ៧៤៤ | ២២០ ០០០រៀល | ១៧៥នាក់ | |
| ខេត្តកំពត | | | | | |
| ២០១៧ | ៣០ ៩៨០ | ៣ ១៧២,១៤ | ២៨០ ០០០រៀល | ១ ៨៤០នាក់ | |
| ២០១៨ | ៣ ០០០ | ៣ ០៤១,៣៧ | ៣៦០ ០០០រៀល | ១ ៧៦៤នាក់ | |
| ២០១៩ | ១៩ ៨០០ | ៣ ០៤១,៣៧ | ២៤០ ០០០រៀល | ១ ៧៦៤នាក់ | |
| ២០២០ | ៨៣ ៩៦៩,០៥ | ២ ៨៧៥ | ១៨ ៥០០រៀល | ១ ៦៥០នាក់ | |
| ២០២១ | ៦៥ ១៩២,៣៧ | ២ ៨៤៧ | ២២០ ០០០រៀល | ១ ៦៥០នាក់ | |

ក្រាហ្វិកប្រៀបធៀបទិន្នន័យនៃការផលិតអំបិលរយៈពេល៥ឆ្នាំ(គិតជាតោន)




## ២- គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១

រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ តាមរយៈព្រះរាជក្រឹត្យលេខនស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធាន និងសម្តេចវិបុលបញ្ញា **សុខ អាន** ជាអនុប្រធាន។ នៅឆ្នាំ២០១៣ ការងារជំរុញចលនាភូមិ១ផលិតផល១ ត្រូវបានធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ដោយមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី**យឹម ឆៃលី** ជាប្រធាន។ ជាបន្តបន្ទាប់ព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិនេះក៏ត្រូវបានធ្វើវិសោធនកម្មដោយកែសម្រួលមាត្រា១និងមាត្រា២ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ក្រោយពីគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិ១ផលិតផល១ ឆ្នាំ២០១៦ ដល់ឆ្នាំ២០២៦ ត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦។

## សមិទ្ធផលការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានក១.ផ១ រយៈពេល៥ឆ្នាំ(ឆ្នាំ២០១៧-២០២៣)

### ក- ការងាររៀបចំឯកសារគតិយុត្ត ឯកសារគោលនយោបាយ និងឯកសារយុទ្ធសាស្ត្រនានា

បានរៀបចំកែសម្រួលនិងបង្កើតឯកសារគតិយុត្តិមួយចំនួនឱ្យស្របតាមស្ថានភាពការងារប្រចាំថ្ងៃ

- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រាទី១ និងមាត្រាទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១
- អនុក្រឹត្យលេខ១៨៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១
- សេចក្តីសម្រេចលេខ៩៩ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១
- សេចក្តីសម្រេចលេខ០៥ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១
- ប្រកាសលេខ៥២ ប្រក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១
- ដឹកនាំនិងបង្កើតក្រុមការងារបច្ចេកទេសជំរុញចលនាភូមិ១ផលិតផល១ ចំនួន១០ក្រសួង រួមមានក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ ក្រសួងព័ត៌មាន ក្រសួងផែនការ និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- ដឹកនាំនិងបង្កើតគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១ រាជធានី ខេត្ត ចំនួន២៥ខេត្ត រាជធានី
- ដឹកនាំ និងបង្កើតក្រុមការងារដឹកនាំ សម្របសម្រួលការងារចងក្រងសមាជិកចលនាភូមិ១ផលិតផល១ ចំនួន៤ក្រសួង រួមមានក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- រៀបចំឯកសារគោលនយោបាយជាតិស្តីពី ការជំរុញចលនាភូមិ១ផលិតផល១ ឆ្នាំ២០១៦ ដល់ឆ្នាំ២០២៦
- រៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការជំរុញចលនាភូមិ១ផលិតផល១ ចំនួន៥ឆ្នាំ លើកទី១ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣
- រៀបចំគោលការណ៍ណែនាំស្តីពីការចងក្រងសមាជិកចលនាភូមិ១ផលិតផល១។

### ខ- ការងាររៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ

រៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ ថ្ងៃទី៩ ខែមេសា ជារៀងរាល់ឆ្នាំ បានចំនួន ៤លើក និងរៀបចំឱ្យមានគោលការណ៍រួមស្តីពីការរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ នៅទូទាំងប្រទេស។

- លើកទី១ ឆ្នាំ២០១៨ ក្រោមប្រធានបទ«**យើងនាំប្រើប្រាស់ផលិតផលខ្មែរ**»
- លើកទី២ ឆ្នាំ២០១៩ ក្រោមប្រធានបទ«**យើងនាំគ្នាគាំទ្រ និងប្រើប្រាស់ផលិតផលខ្មែរ**»

- លើកទី៣ ឆ្នាំ២០២០ ក្រោមប្រធានបទ«**លើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ គឺលើកកម្ពស់ការផលិតវត្ថុធាតុដើមកែច្នៃ និងទិញផលិតផលខ្មែរ**»

- លើកទី៤ ឆ្នាំ២០២១ ក្រោមប្រធានបទ«**រួមគ្នាទិញនិងប្រើប្រាស់ផលិតផលខ្មែរ គឺរួមគ្នាលើកកម្ពស់កិត្យានុភាពជាតិ**»។

**គ- ការងារចងក្រងផលិតផលភូមិ១ផលិតផល១**

សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១ រាជធានី ខេត្ត ក្នុងការងារប្រមូលចងក្រងសមាជិកចលនាភូមិ១ផលិតផល១ នៅទូទាំងប្រទេស ដោយគិតនៅឆ្នាំ២០២១នេះ គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ បានចងក្រងផលិតផលភូមិ១ផលិតផល១ បានចំនួន ១២០មុខ ដែលក្នុងនោះជាផលិតផលិតរបស់ខេត្តចំនួន១០ រួមមានខេត្តស្វាយរៀង ខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកំពត ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តព្រៃវែង និងខេត្តសៀមរាប។

**ឃ- ការងាររៀបចំព្រឹត្តិការណ៍កម្រិតជាតិ អន្តរជាតិ និងពិព័រណ៌ផលិតផលខ្មែរ**

សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្ម វិស័យឯកជននានា ក្នុងការរៀបចំតាំងពិព័រណ៌ ផលិតផលខ្មែរ ផលិតផលភូមិ១ផលិតផល១ នៅតាមបណ្ដារាជធានី ខេត្តទូទាំង២៥រាជធានី ខេត្ត ព្រមទាំង ចូលរួមព្រឹត្តិការណ៍ពិព័រណ៍កម្រិតថ្នាក់ជាតិ និងអន្តរជាតិជាច្រើនផងដែរ។

**ង- ការងារកសាងសមត្ថភាពនិងបណ្ដុះបណ្ដាល**

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល និងវិស័យឯកជន ក្នុងការរៀបចំវគ្គបណ្ដុះ-បណ្ដាលជំនាញនិងសហគ្រិនភាពដល់អាជីវករ សិប្បករ កសិករ សេវាករ នៅតាមបណ្ដារាជធានី ខេត្តទាំង២៥

- រៀបចំបញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋានក១.ផ១ ទៅចូលរួមសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល វេទិកាជាតិ និងអន្តរជាតិនានា ជារៀងរាល់ឆ្នាំ។

**ច- ការងារកិច្ចសហប្រតិបត្តិការបរទេស វិស័យឯកជន និងសង្គមស៊ីវិល**

- សហការជាមួយទីភ្នាក់ងារសហប្រតិបត្តការអន្តរជាតិថៃ(TICA) លើគម្រោងសាងសង់មជ្ឈមណ្ឌលភូមិភាគលើកកម្ពស់ចលនាក១.ផ១ នៅខេត្តកំពង់ចាម ដែលគ្រោងនឹងចាប់ផ្ដើមដំណើរការសាងសង់នាពេលឆាប់ៗខាងមុខនេះ

- សហការ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹងវិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នសិក្សាស្រាវជ្រាវ ក្នុងគោលបំណងរួមគ្នាលើកកម្ពស់ចលនាភូមិ១ផលិតផល១នៅកម្ពុជាៈ

- កិច្ចព្រមព្រៀងទ្វេភាគីជាមួយសមាគមពាណិជ្ជករដឹកជញ្ជូនទំនិញ
- កិច្ចព្រមព្រៀងទ្វេភាគីជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- កិច្ចព្រមព្រៀងទ្វេភាគីជាមួយរាជបណ្ឌិត្យសភាកម្ពុជា។

**ឆ- ការងារផ្សព្វផ្សាយ ចែករំលែកព័ត៌មាន និងចំណេះដឹង**

- បង្កើតវេបសាយរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ អាស័យដ្ឋាន www.ovopnationalcommittee.gov.kh

- បង្កើតទំព័រហ្វេសប៊ុក(Page Facebook) របស់អគ្គលេខាធិការដ្ឋានក១.ផ១ ដែលមានឈ្មោះOVOP National Committee Cambodia ដែលបច្ចុប្បន្នមានអ្នកចូលLike ចំនួន១ ៨០២នាក់ និងអ្នកFollow ចំនួន ១ ៨៤៣នាក់ និងមានអ្នកចូលមើលចំនួនចាប់ពីខ្ទង់រយដល់ពាន់View ក្នុងមួយPost

- បង្កើតChanel telegram ដែលមានឈ្មោះ OVOP National Committee Cambodia ដែលមានចំនួនសមាជិក២៣២ subscribers និងមានអ្នកចូលមើលចំនួនចាប់ពីខ្ទង់រយដល់ពាន់View ក្នុងមួយPost

- បង្កើតក្រុមការងារភ១.ផ១ អន្តរក្រសួងតាមរយៈគ្រុបTelegram ដើម្បីងាយស្រួលទំនាក់ទំនង និងចែករំលែកព័ត៌មាន

- បង្កើតក្រុមការងារលេខាធិការដ្ឋានភ១.ផ១ រាជធានីខេត្ត តាមរយៈគ្រុប Telegram ដើម្បីងាយស្រួលទំនាក់ទំនង និងចែករំលែកព័ត៌មាន

- បង្កើតបណ្តាញក្រុមការងារជាច្រើនទៀតជាមួយក្រុមអាជីវករ សិប្បករ សមាគមន៍ សហគមន៍ អ្នកផ្តល់សេវា និងក្រុមការងារនិស្សិតជាដើម។

## ចំណុចទី៣- ការរៀបចំនិងការអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន

រាជរដ្ឋាភិបាល បានសម្រេចបង្កើតក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជនដើម្បីដោះស្រាយសំណើនានា រួមមាន (១) ក្រុមការងារផ្នែកកសិកម្ម កសិឧស្សាហកម្ម ដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២) ក្រុមការងារផ្នែកទេសចរណ៍ ដឹកនាំដោយឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ (៣) ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា ដឹកនាំដោយឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម (៤) ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៥) ក្រុមការងារផ្នែកសេវាធនាគារនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា (៦) ក្រុមការងារផ្នែកដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ ដឹកនាំដោយឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន (៧) ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញនិងកិច្ចសម្រួលពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម (៨) ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (៩) ក្រុមការងារផ្នែកស្រូវ អង្ករ ដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (១០) ក្រុមការងារផ្នែកថាមពលនិងធនធានរ៉ែ ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល (១១) ក្រុមការងារផ្នែកអប់រំ ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (១២) ក្រុមការងារផ្នែកសុខាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង(១៣) ក្រុមការងារផ្នែកសំណង់និងអចលនទ្រព្យ ដឹកនាំដោយឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## គណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

### ការពង្រឹងវិស័យឯកជន និងជំរុញការវិនិយោគ និងធុរកិច្ច

| វិស័យ | ឆ្នាំ២០១៧ | | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ (គិតត្រឹមខែតុលា) | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនគម្រោង | ទុនវិនិយោគ (លានដុល្លារ) | ចំនួនគម្រោង | ទុនវិនិយោគ (លានដុល្លារ) | ចំនួនគម្រោង | ទុនវិនិយោគ (លានដុល្លារ) | ចំនួនគម្រោង | ទុនវិនិយោគ (លានដុល្លារ) | ចំនួនគម្រោង | ទុនវិនិយោគ (លានដុល្លារ) |
| កសិកម្ម និង កសិឧស្សាហកម្ម | ១០ | ៣៩៦,២ | ១៨ | ៤៥៧,៧ | ១១ | ១៧២,៥ | ១៣ | ១៤៧,១ | ១២ | ១១៧,៣ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ឧស្សាហកម្ម | ក្រៅ SEZ | ១១២ | ៧៨៤,៩ | ១៣៤ | ១ ១០៦,៦ | ១៧៥ | ៩២២,០ | ១៦៦ | ១.២៣៤,៤ | ៨៨ | ៩៩៥,៧ |
| | ក្នុង SEZ | ៤៧ | ៤៨៤,០ | ៧៩ | ៤៤២,១ | ៩៩ | ១ ០១២,៣ | ៤១ | ២៣៦,២ | ៣៥ | ៧៥១,៤ |
| | **សរុប** | ១៥៩ | ១ ២៦៨,៩ | ២១៣ | ១ ៥៤៨,៧ | ២៧៤ | ១ ៩៣៤,៣ | ២០៧ | ១.៤៧០,៦ | ១២៣ | ១ ៧៤៧,១ |
| ទេសចរណ៍ | | ៩ | ៣ ១៦៦,៦ | ១៣ | ១ ៦១២,៥ | ២០ | ៦ ៣១១,១ | ៧ | ៣៨៦០,១ | ២ | ១២៧,៨ |
| ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ | | ៥ | ១៤៩៩,៤ | ១១ | ២ ៨៣២,៦ | ១០ | ៩៧៩,៧ | ១១ | ២៧៧៣ | ៩ | ១ ៤៨០,១ |
| **សរុប** | | **១៨៣** | **៦៣៣១,១** | **២៥៥** | **៦ ៤៥១,៥** | **៣១៥** | **៩ ៣៩៧,៦** | **២៣៨** | **៨២៥០,៨** | **១៤៦** | **៣ ៤៧២,៣** |

គិតចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ខែតុលា ឆ្នាំ២០២១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈគណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា បានអនុម័តឱ្យក្រុមហ៊ុនក្នុងស្រុក និងមកពីបរទេសធ្វើការវិនិយោគលើគម្រោងថ្មី និងគម្រោងពង្រីកផលិតកម្ម សរុបចំនួន១ ១៣៧គម្រោង ក្នុងទុនវិនិយោគចំនួនប្រមាណ៣៤ប៊ីលានដុល្លារអាម៉េរិក ពោលគឺប្រមាណជិត៧ប៊ីលានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ដែលអាចបង្កើតការងារជូនប្រជាពលរដ្ឋបានចំនួនជាមធ្យមប្រមាណ២០៣ពាន់នាក់ក្នុងមួយឆ្នាំ។ ក្នុងចំណោមគម្រោងវិនិយោគទាំង១ ១៣៧គម្រោង មានគម្រោងវិនិយោគ ចំនួន៩៧៦ ស្ថិតនៅក្នុងវិស័យឧស្សាហកម្ម ដែលមានទុនវិនិយោគចំនួនប្រមាណ៨ប៊ីលានដុល្លារអាម៉េរិក ស្មើនឹង២៣%នៃទុនវិនិយោគសរុប គម្រោងវិនិយោគចំនួន៦៤ ស្ថិតនៅក្នុងវិស័យកសិកម្មនិងកសិឧស្សាហកម្ម ដែលមានទុនវិនិយោគប្រមាណ១,៣ប៊ីលានដុល្លារអាម៉េរិក ស្មើនឹង៤%នៃទុនវិនិយោគសរុប គម្រោងវិនិយោគចំនួន៥១ ស្ថិតនៅក្នុងវិស័យទេសចរណ៍ ដែលមានទុនវិនិយោគប្រមាណ១៥,១ប៊ីលានដុល្លារអាម៉េរិក ស្មើនឹង៤៥%នៃទុនវិនិយោគសរុប និងគម្រោងវិនិយោគចំនួន៤៦ ស្ថិតនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ ដែលមានទុនវិនិយោគប្រមាណ៩,៦ប៊ីលានដុល្លារអាម៉េរិក ស្មើនឹង២៨% នៃទុនវិនិយោគសរុប។

ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១)នេះ រាជរដ្ឋាភិបាលបានឯកភាពឱ្យមានការបង្កើតតំបន់សេដ្ឋកិច្ចពិសេស(SEZ)ចំនួន៨តំបន់ ដែលធ្វើឱ្យចំនួនតំបន់សេដ្ឋកិច្ចពិសេសសរុបកើនដល់ចំនួន៣៩តំបន់។ តំបន់សេដ្ឋកិច្ចពិសេសកំពុងដំណើរការសរុបមានចំនួន២៤តំបន់ ដែលក្នុងនោះមានរោងចក្រចំនួន៥៧៤ កំពុងមានសកម្មភាពផលិត មានទុនវិនិយោគសរុបប្រមាណ៦,៩ប៊ីលានដុល្លារអាម៉េរិក ដោយប្រើប្រាស់កម្លាំងពលកម្មចំនួនជាង១៦ម៉ឺននាក់។ ជាការកត់សម្គាល់ នៅតាមបណ្ដាតំបន់សេដ្ឋកិច្ចពិសេសទាំងនោះ មានការបណ្ដាក់ទុនលើគម្រោងវិនិយោគតាមមុខសញ្ញាផលិតកម្មថ្មីៗជាច្រើនក្រៅពីផ្នែកឧស្សាហកម្មកាត់ដេរ មានជាអាទិ៍ការដំឡើងរថយន្ត ម៉ូតូ កង់ ការផលិតគ្រឿងបង្គុំរថយន្តនិងកង់ ការផលិតម៉ូទ័រខ្នាតតូច ម៉ាស៊ីន ក្រឡឹងគ្រប់ប្រភេទ ឧបករណ៍អគ្គិសនី សម្ភារៈបរិក្ខារពេទ្យ សម្ភារៈក្មេងលេង សម្ភារៈកីឡា សម្ភារៈប្រើប្រាស់ក្នុងផ្ទះ គ្រឿងសង្ហារិម ក្ដារបន្ទះ និងចំណីសត្វ។

# មុំទី៤- ការពង្រឹងការប្រកួតប្រជែង

## ១- ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស

### ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

#### ១.១- ការនាំចេញផលិតផលកសិកម្មសំខាន់ៗ(គិតជាតោន)

| ការនាំចេញផលិតផលកសិកម្មសំខាន់ៗ (គិតជាតោន) | | | | | |
|---|---|---|---|---|---|
| ផលិតផល | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ចំណិតដំឡូងមីក្រៀម | ២ ៨៣៧ ៦៤២ | ១ ៥៩០ ៣២៧ | ១ ៦២៦ ១៦៥ | ១ ៥១៦ ៤៧៦,០៦ | ១ ៤៣៨ ១៧១,៦៨ |
| ដំឡូងមីស្រស់ | ៩៣៦ ៩៨៤ | ៩០៧ ២១០ | ១ ៦០៨ ៤៥០ | ៧២៣ ៥៩០ | ៨៨៧ ៧២០ |
| ម្សៅដំឡូងមី | ៧៦ ០៩៣ | ៩៥ ៤៤៤,១៩ | ៥៦ ៨៧៤,៤៩ | ៣៤ ៩៣៥,១៤ | ៣០ ៤៧១,៧៤ |
| អង្ករ | ៦៣៥ ៦៧៩ | ៦២៦ ២២៥ | ៦២០ ១០៦ | ៦៩០ ៨២៩ | ៥៣២ ១៧៩ |
| ដើមអំពៅស្រស់ | - | - | - | - | |
| គ្រាប់ស្វាយចន្ទី | ៧៣ ១៧៩,០៦ | ១០១ ៩៧៣,២៥ | ២០២ ៣១៨,២៧ | ២១៨ ៩៨០,៦៥ | ៩២១ ០៦១,៤៧ |
| ពោតក្រហម | ១៦៨ ៦៨៥,១៣ | ២០៤ ១៨៤,៧២ | ១១៩ ៩៩៣,១៧ | ១៩៤ ៦២៥,២៨ | ១៧៨ ០៦៩,៣៤ |
| សណ្តែកសៀង | ៣០ ០៧៣,៩៥ | ៣៨ ៩០០ | ៥៧ ២៥០ | ២៩ ០០៥ | ៨៨ ១៦៥,០៤ |
| ល្ង | ២ ៩៤៨,៦៤ | ៧២០ | ៤ ២៦៤,៤៦ | ៥ ៨៨៩,៩២ | ៧ ៤៩៨,៣១ |
| ម្រេច | ២ ៦៩៨,៦៤ | ២ ៤១១,២០ | ៣ ៦៩៣,២៥ | ៥ ០៧៩,៣៦ | ២៧ ៧៣០,០៧ |
| ផ្លែចេកស្រស់ | ១៨ ០០០,១០ | ៣២ ៨២១,៦៤ | ១៥៧ ៨១២,៦១ | ៣៣៣ ១៤២,៧៥ | ៣៩៥ ៨៦៣,៧៨ |
| ផ្លែស្វាយស្រស់ | ៧៧ ៤២១,៧៥ | ១០២ ៤៥៧,១៣ | ៥៨ ១៦២,១៦ | ៩៧ ៦២៧,៦០ | ២២៦ ៥៧៧,៧១ |
| ម្ទេសស្រស់/ម្ទេសបង្កក | ១ ៧៥០ | ១៥ ៤៩៤ | ៥៥ ៥១៣,៥៤ | ៧០ ៥៤៦,៣៨ | ៨៩ ៣៥៧,១២ |
| ដូងប្រេងឆៅ | ៤៤ ៧៣២,៦៩ | ៥៧ ៣៣៩,៨៣ | ៦៣ ៩៤០ | ៥៤ ៤៧០ | ៥៥ ៥១៦,៦៩ |
| សន្លឹកថ្នាំជក់ | ៨ ០៤០,៩៧ | ៦ ៨៣៩,៩៦ | ៦ ៧៦៩,៩៧ | ៥ ៨២០,៨២ | ៤ ២៩៤,០៥ |
| ដំណាំផ្សេងៗ | ២៦៥ ៨៨៧,២១ | ៥០៨ ៥២៤,៤២ | ២៣៥ ៦៤០,៤៦ | ៨៩២ ៤៤៣,១៦ | ២ ២៥៩ ២៣៩,០៤ |
| **សរុប** | **៥ ១៧៩ ៨១៧,១៤** | **៤ ២៩០ ៨៧២,៣៤** | **៤ ៨៧៦ ៩៥៣,៣៨** | **៤ ៨៧៣ ៤៦១,១២** | **៧ ១៣១ ៩១៥,០៤** |

#### ១.២- ការនាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វពីឆ្នាំ២០១៧-២០២១

| ប្រភេទសត្វ និង ផលិតផល | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (មករា-ឧសភា) | សរុប |
|---|---|---|---|---|---|---|---|
| គោ ក្របី | ក្បាល | ១១ ២៤០ | ៦ ៧៨៦ | ៥៦ ២១៨ | ៩ ៧៤២ | ១ ៨៩០ | ៨៥ ៨៧៦ |
| ជ្រូកពូជ(មេ បា) | ក្បាល | ១ ១៤០ | ៥០៥ | ២០០ | ២០០ | ២០០ | ២ ២៤៥ |
| ជ្រូកពូជ(កូន) | ក្បាល | - | ៥ ០០០ | - | - | - | ៥ ០០០ |
| ស្វាក្តាម | ក្បាល | ៦ ៩៣៤ | ១០ ៤៧២ | ១៦ ១៩៦ | ២៣ ៧៧០ | ៨ ៦៦០ | ៦៦ ០៣២ |
| សាច់គោ ក្របី | តោន | ៧ | ១២ ០៧៦ | - | - | - | ១២ ០៨៣ |
| ទឹកដោះគោ | តោន | ៤៥១ | ៧ ៥៥៨ | ៣ ៩៨៤ | - | - | ១១ ៩៩៣ |

| ប្រភេទសត្វ និងផលិតផល | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (មករា-ឧសភា) | សរុប |
|---|---|---|---|---|---|---|---|
| ចំណីឆ្កែ | តោន | ១ ៣៦៥ | ១ ៤៩៤ | ១ ០១១ | ២ ២៧៦ | - | ៦ ១៤៦ |
| រោមសត្វ | តោន | ២៨ | ២៤ | ៨ | ២,៨ | - | ៦២,៨ |
| ស្បែកគោ ក្របីសើម | តោន | ១ ៩៧២ | ១ ២៧៥ | ១ ៤៤០ | ១ ៥៥៤ | - | ៦ ២៤១ |

## ២- **ទំហំពាណិជ្ជកម្ម** (១ដុល្លារអាមេរិក= ៤ ០៧១រៀល)

(តាមតួរលេខគយនិងរដ្ឋាករកម្ពុជា ចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ខែតុលា ឆ្នាំ២០២១)

| |
|---|
| ១- **ការនាំចេញ**មានតម្លៃប្រមាណ២៨៧ ១៩៧,១៥ប៊ីលានរៀល ស្មើនឹងប្រមាណ៧០ ៥៤៧,០៨លានដុល្លារអាមេរិក ក្នុងនោះ ការនាំចេញផលិតផលឈើកែច្នៃមានទំហំទឹកប្រាក់ចំនួន២២១,២១ប៊ីលានរៀលការនាំចេញក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ១៩០ ៧២៤,០១ប៊ីលានរៀល ផលិតផលវាយនភណ្ឌនិងស្បែកជើង ១៦៩ ០៤០,២០ផលិតផលនេសាទ១ ៨១៩,៩៤ពាន់តោននិងកៅស៊ូ៨៩៨,៧២ពាន់តោន។ |
| ២- **ការនាំចូល**មានតម្លៃប្រមាណ៣៧១ ៧២៦,៦៤ប៊ីលានរៀល ស្មើនឹងប្រមាណ៩១ ៣១០,៨៩លានដុល្លារអាមេរិក ក្នុងនោះ ការនាំចូលប្រេងឥន្ធនៈមានចំនួន១៣ ៤៨៩,៨៤ ពាន់តោន ដែកសំណង់២ ៥៣០,៣៦ ពាន់តោន ស៊ីម៉ងត៍៦ ២១៣,៥៦ពាន់តោន ស្រូវសាលី៣៦៨,៤៥ពាន់តោន ត្រាក់ទ័រនិងគោយន្ត ២០២ ៥៣០គ្រឿង រថយន្ត៣៨០ ៤២២គ្រឿង និងការនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ១១២ ៥៥០,៣០ ប៊ីលានរៀល។ |
| ៣- ប្រតិបត្តិការជញ្ជីងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាមានឱនភាព៨៤ ៥២៩,៤៩ប៊ីលានរៀល ស្មើនឹងប្រមាណ ២០ ៧៦៣,៨១លានដុល្លារអាមេរិក។ |

## ៣- **ការងារពាណិជ្ជកម្ម**

### ៣.១- **ស្ថិតិពាណិជ្ជកម្មកម្ពុជាជាមួយដៃគូសំខាន់ៗរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៧-២០២១**

| ល.រ | ទិសដៅ | ២០១៧ | | | ២០១៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| ១ | ពិភពលោក | ១១ ២២២ | ១៤ ២២០ | ២៥ ៤៤២ | ១២៦២៩ | ១៧ ២៦៥ | ២៩ ៨៩៤ | ១៤៧៤៩ | ២០ ១៧២ | ៣៤ ៩២១ |
| ២ | អាម៉េរិក | ២ ៤០៧ | ១៩៤ | ២ ៦០១ | ៣ ០៤២ | ២៦៥ | ៣ ៣០៧ | ៤ ៤០២ | ៣១១ | ៤ ៧១៤ |
| ៣ | ជប៉ុន | ៨៤៨ | ៥៧៩ | ១ ៤២៧ | ១ ០៧៤ | ៧៣៥ | ១ ៨១០ | ១ ១៣៧ | ៨៨២ | ២ ០១៩ |
| ៤ | ចិន | ៧៤៤ | ៥ ២៨៩ | ៦ ០៣៣ | ៨៥៥ | ៦ ១២២ | ៦ ៩៧៧ | ១ ០០៥ | ៧ ៥៥៩ | ៨ ៥៦៣ |
| ៥ | ចក្រភពអង់គ្លេស | ១ ០១៤ | ២៩ | ១ ០៤៣ | ១ ០១៥ | ៥៩ | ១ ០៧៤ | ៩៧៨ | ៨០ | ១ ០៥៧ |
| ៦ | កាណាដា | ៦៨៨ | ៥៧ | ៧៤៦ | ៧៧៦ | ៩៨ | ៨៧៤ | ៨៣៧ | ១២១ | ៩៥៨ |
| ៧ | កូរ៉េ | ១៦៧ | ៤៨៩ | ៦៥៦ | ១៩៩ | ៥៦៤ | ៧៦៣ | ២១២ | ៦៧០ | ៨៨២ |
| ៨ | អូស្ត្រាលី | ១០៦ | ២១ | ១២៦ | ១០៦ | ៤១ | ១៤៨ | ១៣៤ | ៧២ | ២០៦ |
| ៩ | ឥណ្ឌា | ៣៥ | ៩៣ | ១២៨ | ៥០ | ១៥៧ | ២០៧ | ៦៥ | ១៩២ | ២៥៦ |
| ១០ | នូវែលសេឡង់ | ៩ | ៧ | ១៦ | ៩ | ៨ | ១៧ | ១២ | ៩ | ២១ |
| ១១ | អាស៊ាន | ១ ១០៧ | ៥ ៤៩០ | ៦ ៥៩៦ | ៩០៤ | ៦ ៨២៩ | ៧ ៧៣៣ | ១ ៣០៣ | ៧ ៩៥១ | ៩ ២៥៥ |
| ១២ | ថៃ | ៤២៤ | ២ ៤០៣ | ២ ៨២៧ | ៣០៥ | ៣ ១២៩ | ៣ ៤៣៤ | ៥០២ | ៣ ២២២ | ៣ ៧២៥ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៣ | វៀតណាម | ៣២០ | ១ ៦៨៥ | ២ ០០៥ | ៣២៤ | ២ ២១៤ | ២ ៥៣៨ | ៣៣៦ | ២ ៧១៨ | ៣ ០៥៤ |
| ១៤ | អឺរ៉ុប | ៣ ៤១៤ | ៥៦៥ | ៣ ៩៧៩ | ៣ ៨២២ | ៦៥៦ | ៤ ៤៧៨ | ៣ ៨៩៤ | ៧០១ | ៤ ៥៩៥ |
| ១៥ | EAEU | ៣៨ | ២៣ | ៦១ | ៤១ | ៧០ | ១១២ | ៥២ | ៥ | ៥៧ |
| ១៦ | ផ្សេងៗ | ៦៤៥ | ១ ៣៨៤ | ២ ០២៩ | ៧៣៥ | ១ ៦៥៩ | ២ ៣៩៤ | ៧១៩ | ១ ៦១៨ | ២ ៣៣៧ |

| ល.រ. | ទិសដៅ | ២០២០ | | | ២០២១ (មករា-កក្កដា) | | |
|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| ១ | ពិភពលោក | **១៧ ២១៥** | **១៨ ៥៩០** | **៣៥ ៨០៦** | **៩ ៣៤៤** | **១ ៦១២** | **២៥ ៨៥៦** |
| ២ | អាម៉េរិក | ៥ ២៥៩ | ២៥១ | ៥ ៥១០ | ៣ ៨៦៧ | ១៩១ | ៤ ០៥៨ |
| ៣ | ជប៉ុន | ១ ០៥៦ | ៦៣៧ | ១ ៦៩៣ | ៥៩៨ | ៣៨១ | ៩៧៩ |
| ៤ | ចិន | ១ ០៨៦ | ៧ ០៣២ | ៨ ១១៨ | ៨២៥ | ៥ ២០៧ | ៦ ០៣២ |
| ៥ | ចក្រភពអង់គ្លេស | ៨២៦ | ៥១ | ៨៧៨ | ៣៦៩ | ៣១ | ៤០០ |
| ៦ | កាណាដា | ៧៤៥ | ៥៥ | ៨០០ | ៥២១ | ២២ | ៥៤៤ |
| ៧ | កូរ៉េ | ១៨៥ | ៥៤៤ | ៧២៩ | ១១៣ | ៣២៩ | ៤៤២ |
| ៨ | អូស្ត្រាលី | ១៣៤ | ៨០ | ២១៤ | ៧៦ | ៦៥ | ១៤១ |
| ៩ | ឥណ្ឌា | ៦១ | ១២៩ | ១៩០ | ៦៦ | ១០១ | ១៦៧ |
| ១០ | នូវែលសេឡង់ | ១៣ | ១៥ | ២៨ | ៧ | ៨ | ១៥ |
| ១១ | អាស៊ាន | ៣ ៧២៣ | ៧ ៦០៧ | ១១ ៣៣០ | ៧០៤ | ៧៧៩៧ | ៨ ៥០១ |
| ១២ | ថៃ | ៦៥១ | ២ ៨៣៦ | ៣ ៤៨៦ | ២០៦ | ១ ៧៩៥ | ២ ០០១ |
| ១៣ | វៀតណាម | ៣៨៦ | ២ ៦៣៤ | ៣ ០២០ | ២៨៨ | ១ ៨០០ | ២ ០៨៨ |
| ១៤ | អឺរ៉ុប | ៣ ២០៤ | ៦៥៩ | ៣ ៨៦៣ | ១ ៧៣៩ | ៦៨៥ | ២ ៤២៤ |
| ១៥ | EAEU | ៥២ | ១៥ | ៦៧ | ៣៤ | ៣២ | ៦៦ |
| ១៦ | ផ្សេងៗ | ៨៧១ | ១ ៥១៥ | ២ ៣៨៦ | ៤២៥ | ១ ៦៦៣ | ២ ០៨៨ |

## ៣.២- ការងារកសាង និងផ្សព្វផ្សាយបញ្ញត្តិច្បាប់ពាណិជ្ជកម្ម

| សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត | រៀបចំសេចក្តីព្រាងច្បាប់៣ | បន្តពិនិត្យសេចក្តីព្រាងច្បាប់ទាំង៣នេះ | -សម្រេចបានការអនុម័តច្បាប់២ (១-ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និង២-ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក)<br>-រៀបចំសេចក្តីព្រាងច្បាប់២(១-ច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម និងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម) | -បន្តពិនិត្យសេចក្តីព្រាងច្បាប់ដែលមិនទាន់បានអនុម័ត៣<br>-រៀបចំអនុក្រឹត្យ២<br>-ប្រកាស១ | -សម្រេចបានការអនុម័តច្បាប់១គឺច្បាប់ស្តីពីកិច្ចការប្រកួតប្រជែង<br>-បន្តពិនិត្យសេចក្តីព្រាងច្បាប់ដែលនៅសល់២ទៀត |
| ការងារតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា | ១៦៣០លិខិត | ២ ៧៩២លិខិត | ៧ ៨៥៤លិខិត | ៨ ០១៥លិខិត | ១២ ៧១៣លិខិត |

| | | | | | |
|---|---|---|---|---|---|
| ការងារផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម | ៣ខេត្ត | | | ២ដង | ១ដង |
| ការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) បានចូលរួមកិច្ចប្រជុំ ASEAN-OECD GRPN តាមប្រព័ន្ធវីដេអូ conference | ២លើក | ១លើក | ១លើក | ៣លើក | |

## ៣.៣- ការងារអភិវឌ្ឍវិស័យឯកជន

| សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| បានចេញវិញ្ញាបនបត្រទទួលស្គាល់ការតម្កល់លក្ខន្តិកៈជូនសមាគមអាជីវកម្មក្នុងស្រុក និងបរទេស | ៨សមាគមអាជីវកម្មក្នុងស្រុក៥ សមាគមអាជីវកម្មបរទេស | ១០សមាគមអាជីវកម្មក្នុងស្រុក២សមាគមអាជីវកម្មបរទេស | | | |
| រៀបចំបោះឆ្នោតសមាគមអាជីវកម្ម និងសម្ព័ន្ធសមាគមអាជីវកម្ម | ៥សមាគមអាជីវកម្ម ២សម្ព័ន្ធសមាគម | ៤សមាគមអាជីវកម្ម | | | |
| បានរៀបចំបោះឆ្នោតសភាពាណិជ្ជកម្មរាជធានី ខេត្តសម្រាប់អាណត្តិថ្មីនិងអាណត្តិបន្ត | | ២សភាពាណិជ្ជកម្ម | ១៦សភាពាណិជ្ជកម្ម | | |
| បានរៀបចំប្រកាសទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា | ២សភាពាណិជ្ជកម្ម | | ១៨សភាពា-ណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា | | |
| បានរៀបចំអនុក្រឹត្យស្តីពីការបង្កើតសភាពាណិជ្ជកម្មថ្មី | | | ៥សភាពាណិជ្ជកម្ម | | |
| បានរៀបចំអនុក្រឹត្យស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានី ខេត្តសម្រាប់អាណត្តិថ្មី និងអាណត្តិបន្ត | | | | ១៨សភាពាណិជ្ជកម្មរាជធានី ខេត្ត | |
| បានចុះពង្រឹងការងារសភាពាណិជ្ជកម្ម និងសមាគមអាជីវកម្ម | ៤សមាគមអាជីវកម្ម ៧សភាពាណិជ្ជកម្ម | | | | |
| បានចុះត្រួតពិនិត្យនិងវាយតម្លៃបរិមាណសន្និធិប្រេងឥន្ធនៈ និងហ្គាសលើកទី១ និងលើកទី២ | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន |
| បានចេញសេចក្តីជូនដំណឹងស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយប្រេងឥន្ធនៈចំនួន ២ដងក្នុងមួយខែ | ៣ដងក្នុងមួយខែ | ៣ដងក្នុងមួយខែ | ២ដងក្នុងមួយខែ | ២ដងក្នុងមួយខែ | ២ដងក្នុងមួយខែ |
| ចុះស្រាវជ្រាវផលិតផលសក្តានុពល | ១២មុខ | ៤មុខ | ៨មុខ | | |
| បានរៀបចំសិក្ខាសាលាស្តីពីផ្សព្វផ្សាយយុទ្ធសាស្ត្រវិស័យសូត្រកម្ពុជា២០១៦-២០២០ | | ៣ខេត្ត | ១ខេត្ត | ១ខេត្ត | |

| | | | | | |
|---|---|---|---|---|---|
| បានចុះស្រាវជ្រាវប្រមូលទិន្នន័យផលិត-ផលសួត្រនិងធ្វើបច្ចុប្បន្នភាពកីតម្បាញ | | | ៣ខេត្ត | ៤ខេត្ត | |
| បានរៀបចំសិក្ខាសាលាស្តីពីការឆ្លើយតបរបាំងបច្ចេកទេសពាណិជ្ជកម្ម សុវត្ថិភាពចំណីអាហារ ការវេចខ្ចប់ ការដាក់ស្លាកសញ្ញា និងកស្តុការ | ៣ខេត្ត | ៣ខេត្ត | ២ ខេត្ត | | |
| បានជួយសម្របសម្រួលប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍ស្តីពីទិន្នន័យនៃការដឹកជញ្ជូនទំនិញតាមការបញ្ជាទិញអនឡាញជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ក្រហម | | | | | ៥សង្កាត់ |

## ៣.៤- ការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច AIMS

| សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| ការកៀរគរកសិករចូលគម្រោង | | ៧ ១៥៥ | ១៧ ៨៦១ | ៣១ ៧៣៣ | ១៨ ៨៦៩ | ៧៥ ៦២៦ គ្រួសារ |
| ការចងក្រុមជាក្រុមកសិករផលិត | | ១៤៩ | ៣៧៧ | ៨៤៦ | ៥៣៣ | ១ ៩០៦ ក្រុម |
| ការសម្របសម្រួលកិច្ចសន្យាទិញ-លក់ | | ២២ | ១២៤ | ៥៨៣ | ៥៣៧ | ១ ២៦៦ កិច្ចសន្យា |
| ការផ្តល់មូលនិធិអភិវឌ្ឍន៍តាមវិស័យ (SDF) | | | | ៣៣៣ | ១៥២ | ៤៨៥សំណើ |
| មូលនិធិនវានុវត្តន៍ VCIF | | | ៣៦សំណើ | ៤៧៤សំណើ | ៥៩៣សំណើ | ១ ១០៣សំណើ |
| បានចុះអនុស្សរណៈនៃការយោគយល់គ្នាក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃផលិតផលកសិ-ពាណិជ្ជកម្ម រវាងក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុន | | ២ | | ២ | ២ | ៦ក្រុមហ៊ុន |
| ការផ្តល់ចំណេះដឹងជំនាញបច្ចេកទេស ជូនក្រុមកសិករ | | ១៦៦ | ៨១៥ | ៣ ៧៣៩ | ៥ ៦៨៤ | ១០ ៤០៥ គ្រួសារ |

## ៣.៥- ការងារសមាហរណកម្មពាណិជ្ជកម្មអន្តរជាតិ

### ៣.៥.១- ការងារចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី | ០ | ០ | ០ | ១ | ១ |
| កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី | ០ | ០ | ០ | ១ | ០ |

### ៣.៥.២- កិច្ចព្រមព្រៀងទូទៅ ពិធីសារ អនុស្សរណៈយោគយល់គ្នា និងការកសាងលិខិតបទដ្ឋានគតិយុត្ត

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| កិច្ចព្រមព្រៀងទូទៅ | | ៣ | ៤ | ៣ | |
| ពិធីសារ | ២ | | ២ | ១ | |
| អនុស្សរណៈយោគយល់គ្នា | ១ | | ១ | ១ | ១ |
| ការកសាងលិខិតបទដ្ឋានគតិយុត្ត | ១ | | | | |

ក្នុងអាណត្តិនេះ ក្រសួងពាណិជ្ជកម្មសម្រេចបានការចុះហត្ថលេខាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីចំនួន២គឺ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា ចិន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ហើយ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគីចំនួន១ គឺកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ (RCEP)។ ទន្ទឹមនឹងនេះដើម្បីបើកច្រកទីផ្សារថ្មីៗ ជំរុញនិងពង្រីកការនាំចេញទំនិញ និងសេវាកម្មបន្ថែមទៀត ក្រសួងកំពុងសិក្សាលទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយប្រទេសជាដៃគូបន្ថែមទៀតមាន ជាអាទិ៍ អង់គ្លេស អាម៉េរិក ជប៉ុន ម៉ុងហ្គោលី ឥណ្ឌា សហភាពសេដ្ឋកិច្ចអាស៊ីអឺរ៉ុប (EAEU) ស្របតាមគោលនយោបាយចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

### ៣.៥.៣- ការងារជំរុញពាណិជ្ជកម្មនិងបើកច្រកទីផ្សារ

| ល.រ. | បរិយាយ | លទ្ធផល សម្រេចបាន |
|---|---|---|
| ១ | រៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស | ៣៨លើក |
| ២ | រៀបចំពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិកក្រមិតអន្តរក្រសួងដោយមានពន្លាជាតិ | ១៨លើក |
| ៣ | ដឹកនាំវិស័យឯកជនចូលរួមពិព័រណ៍ និងកិច្ចប្រជុំពាក់ព័ន្ធ | ១១៩លើក |
| ៤ | រៀបចំចូលរួមពិព័រណ៍អន្តរជាតិ និងពិព័រណ៍ពិភពលោក | ២លើក |
| ៥ | រៀបចំវេទិកាផ្សព្វផ្សាយដើម្បីបញ្ជូនផលិតផលកម្ពុជាទៅក្រៅប្រទេស | ២៣លើក |
| ៦ | សាងសង់ផ្សារគំរូព្រំដែនកម្ពុជា (ផ្សារដារ ខេត្តត្បូងឃ្មុំ) | ១ |
| ៧ | រៀបចំមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស | ១១ទីតាំង |
| ៨ | បង្កើតស្ថានទីប្រឹក្សាពាណិជ្ជកម្មកម្ពុជាអមស្ថានទូតក្រៅប្រទេស | ១៩ទីតាំង |
| ៩ | បង្កើតស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាទទួលកិច្ចការសេដ្ឋកិច្ចពាណិជ្ជកម្មនៅហ្សឺណែវ | ១ទីតាំង |
| ១០ | សម្រេចបានគោលនយោបាយជាតិជំឡូងមី ២០២០-២០២៥ | ១ឯកសារ |
| ១១ | កំពុងរៀបចំគោលនយោបាយជាតិស្វាយចន្ទី | ១ឯកសារ |
| ១២ | កំពុងរៀបចំគោលនយោបាយម្រេចកម្ពុជា | ១ឯកសារ |
| ១៣ | បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ករត្នោតកម្ពុជានៅកំពង់ឆ្នាំង | ១ទីតាំង |
| ១៤ | បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ចម្លាក់ប្រាក់-ស្ពាន់កម្ពុជានៅខេត្តកណ្តាល | ១ទីតាំង |
| ១៥ | បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ចម្លាក់ថ្មកម្ពុជានៅខេត្តពោធិ៍សាត់ | ១ទីតាំង |

### ៣.៥.៤- ក្រុមហ៊ុនហ្គ្រីនត្រេដ

#### ៣.៥.៤.១- សកម្មភាពផ្នែកអាជីវកម្ម

សកម្មភាពទិញ-លក់អង្ករសរុបចំនួន **: ២៤ ៨៧៥ ត ២៦៣ គក្រ** ក្នុងនោះ៖

| សកម្មភាព ទិញ-លក់អង្ករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១(៦ខែ) | សរុប |
|---|---|---|---|---|---|---|
| ក្រៅប្រទេស | ១០ ៩៥០(តោន) | ១ ០០០(តោន) | ២៤០០(តោន) | 0 | 0 | ១៤៣៥០(តោន) |
| ក្នុងប្រទេស | ២ ៥៤២(តោន) ៥៦៣(គ.ក្រ.) | ៣ ៧៤៦(តោន) ៥០០(គ.ក្រ.) | ២០២២(តោន) ៥០០(គ.ក្រ.) | ២ ០២៥ តោន | ១៨៨(តោន) ៧០០(គ.ក្រ.) | ១០ ៥២៥តោន ២៦៣(គ.ក្រ.) |

#### ៣.៥.៤.២- សកម្មភាពផ្នែកសន្និធិស្តុកស្បៀងត្រៀមបម្រុងរដ្ឋ

ក្រុមហ៊ុនទទួលខុសត្រូវស្តុកសន្និធិបម្រុងរដ្ឋជាអង្ករ។ ស្តុកដើមគ្រាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ មានចំនួន ១៦ ៨២៥តោន ៨៣៣គីឡូក្រាម។ កន្លងមកក្នុងកាលៈទេសៈកូវីដ-១៩ បានបំពេញបន្ថែមទំនិញមួយចំនួនដូចជាទឹកត្រី ទឹកស៊ីអ៊ីវ មីកញ្ចប់ ទឹកបរិសុទ្ធ ត្រីខកំប៉ុង ហើយបានបញ្ចេញប្រើប្រាស់ដូចខាងក្រោម៖

| ល.រ. | ទំនិញ | កូវីដ-១៩ | គ្រោះមហន្តរាយទឹកជំនន់ | សរុប |
|---|---|---|---|---|
| ១ | អង្ករចំនួន | ៦ ០០៦តោន | ១ ០០០តោន | ៧ ០០៦តោន |
| ២ | ទឹកបរិសុទ្ធចំនួន | ១០១ ៦០០កេស | ៥០ ០០០កេស | ១៥១ ៦០០កេស |
| ៣ | មីកញ្ចប់ចំនួន | ៤៣២ ៣០០កេស | ៤០ ០០០កេស | ៤៧២ ៣០០កេស |
| ៤ | ទឹកត្រីចំនួន | ១ ៥១២ ៦០០ដប | ២៤០ ០០០ដប | ១ ៧៥២ ៦០០ដប |
| ៥ | ទឹកស៊ីអ៊ីវចំនួន | ១ ៦៨០ ៦០០ដប | ២៤០ ០០០ដប | ១ ៩២០ ៦០០ដប |
| ៦ | ត្រីខកំប៉ុងចំនួន | ៣៧៧ ៥៣០កេស | | ៣៧៧ ៥៣០កេស |

#### ៣.៥.៤.៣- សកម្មភាព ចំណូល និងចំណាយ

-សរុបចំណូល : ៧៩ ៨៨៨ ១៥៥ ៣២៩រៀល

-សរុបចំណាយ : ៧៥ ៤១៧ ៦៧៨ ៧៦០រៀល

-សរុបចំណេញដុល : ៤ ៤៧០ ៤៧៦ ៥៦៩រៀល

## ៤- ការត្រួតពិនិត្យស្តង់ដា គុណភាព សុវត្ថិភាព និងផលិតផលទំនិញ

### ៤.១- អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ«ក.ប.ប.»

| ឆ្នាំ | លទ្ធផលត្រួតពិនិត្យ | | លទ្ធផលត្រួតពិនិត្យតាមច្រកព្រំដែន | កម្រៃសេវាត្រួតពិនិត្យ និងប្រាក់ពិន័យអន្តរការណ៍(រៀល) |
|---|---|---|---|---|
| | ចំនួនផ្សារបានត្រួតពិនិត្យ | រកឃើញទំនិញខូចគុណភាព(គ.ក្រ.) | រកឃើញទំនិញខូចគុណភាព(គ.ក្រ.) | |
| ២០១៧ | ១ ៧៣៩ | ២៦ ២២៤,១១ | ៥១ ៧២៦ | ១១២ ២០០ ៣៩២ ២៦២ |
| ២០១៨ | ១ ៧៧៦ | ៥១ ៨៧៩ | ៤៤ ២៩៧ | ១២៧ ១២១ ៦០១ ៩៦៩ |
| ២០១៩ | ៥៤៩ | ១៥ ៧៩៩,២២ | 0 | ១៤ ៦១៨ ៦៥៨ ០០០ |
| ២០២០ | ១ ៣០២ | ១០ ៨៥០,៧៦ | 0 | ៨៨ ៦៦៨ ០០០ |
| ២០២១ | ២៧៦ | ៩ ១៥០ | 0 | ៤៩១ ៥៨០ ០០០ |
| សរុប | ៥ ០៤២ | ១១៣ ៩០៣,០៩ | ៩៦ ០២៣ | ២៥៤ ៥២០ ៩០០ ២៣១ |

**តារាងត្រួតពិនិត្យប្រេងឥន្ធនៈ និងការងារមន្ទីរពិសោធន៍**

| ល.រ. | បរិយាយសកម្មភាព | លទ្ធផលសម្រេចបាន |
|---|---|---|
| ១ | ត្រួតពិនិត្យស្ថានីយប្រេងឥន្ធនៈ១ ១៤៨ ស្ថានីយ | ៦៩៤ស្ថានីយ គ្មានអនុលោមភាពតាមគោលការណ៍ច្បាប់។ បានធ្វើការណែនាំឱ្យកែប្រែ និងផាកពិន័យ |
| ២ | វិភាគគុណភាពទំនិញ២៤ ២៣១គំរូ | ៤ ៨៦៩គំរូ មិនសមស្របតាមស្តង់ដាតម្រូវ។ បានធ្វើការណែនាំឱ្យកែប្រែ |
| ៣ | ចុះអប់រំ ផ្សព្វផ្សាយការយល់ដឹងអំពីសុវត្ថិភាពម្ហូបអាហារនៅតាមបណ្តាសាលារៀន និងទីសាធារណៈ១៤៩លើក | សរុបអ្នកចូលរួមចំនួន៣៩ ៣៨៦នាក់ ហើយបានបិទផ្ទាំងរូបភាពនិងខិត្តបណ្ណផ្សព្វផ្សាយពីសុវត្ថិភាពម្ហូបអាហារចំនួន១៦ ០៦២ផ្ទាំង |

### ៤.២- ការងារមន្ទីរពិសោធន៍

មន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៃវិទ្យាស្ថានជាតិសម្រេចបានការផ្តល់នូវសេវាធ្វើតេស្ត វិភាគគុណភាពផលិតផល បានសរុបគំរូផលិតផលចំនួន១៧ ១០០(គិតពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ដល់ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១) គំរូផលិតផល រួមមាន៖

**ក-** ផ្នែកមីក្រូជីវសាស្ត្រចំនួន៥ ៩៩១ គំរូផលិតផល ដោយអនុលោមតាមស្តង់ដា ចំនួន៤ ០០៣គំរូផលិតផល មិនអនុលោមតាមស្តង់ដាចំនួន១ ៩១៤ គំរូផលិតផល និងពុំទាន់ចេញលទ្ធផលចំនួន៧៤គំរូផលិតផល។

**ខ-** ផ្នែកមន្ទីរពិសោធន៍រូប គីមីសាស្ត្រទឹកចំនួន៦ ១៤៩គំរូផលិតផល ដោយអនុលោមតាមស្តង់ដាចំនួន៤ ០៦៥គំរូផលិតផល មិនអនុលោមតាមស្តង់ដាចំនួន២ ០៣២ គំរូផលិតផល និងពុំទាន់ចេញលទ្ធផលចំនួន៥២គំរូផលិតផល។

**គ-** ផ្នែកមន្ទីរពិសោធន៍រូប គីមីសាស្ត្រម្ហូបអាហារចំនួន៣ ៩៧៨គំរូផលិតផល ដោយអនុលោមតាមស្តង់ដាចំនួន២៦៤១គំរូផលិតផល មិនអនុលោមតាមស្តង់ដាចំនួន១ ២៦៦ គំរូផលិតផល និងពុំទាន់ចេញលទ្ធផលចំនួន៧១គំរូផលិតផល។

**ឃ-** ផ្នែកមន្ទីរពិសោធន៍រូប គីមីសាស្ត្រមិនមែនម្ហូបអាហារចំនួន៩៨២គំរូផលិតផល ដោយអនុលោមតាមស្តង់ដាចំនួន៧៧២គំរូផលិតផល មិនអនុលោមតាមស្តង់ដាចំនួន២០០គំរូផលិតផល និងពុំទាន់ចេញលទ្ធផលចំនួន១០គំរូផលិតផល។







**ពិធីសំណេះសំណាលជាមួយកម្មករនិយោជិត នៅខេត្តកណ្តាល**

**ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៨**





ពិធីសំណះសំណាលជាមួយកម្មករនិយោជិត នៅខេត្តកណ្ដាល
ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៨

## ចតុកោណយុទ្ធសាស្ត្រទី៤
## ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

ទន្ទឹមនឹងការជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន ជាពិសេសផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

### មុំទី១- ការលើកស្ទួយវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ

### ១- ការលើកស្ទួយវិស័យកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត«**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣**» ដែលនៅតែចាត់ទុកវិស័យកសិកម្ម ជាវិស័យអាទិភាពក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ជានាសមធម៌ ជានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថាការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានដី ព្រៃឈើ និងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

អនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួន រួមមានការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនដីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាងនិងពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់លើការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់និងវិធានការបច្ចេកទេសសមស្រប ក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ ព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជកម្ម និងការបង្កើនចំណូលថវិកាជាតិ។

ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តកម្មវិធីជាយុទ្ធសាស្ត្រ ដែលបានបង្ហាញសមិទ្ធផលដូចខាងក្រោមះ

### ២- សមិទ្ធផលក្នុងវិស័យកសិកម្មសម្រេចបានពីឆ្នាំ២០១៧-២០២១

តម្លៃបន្ថែមសរុប(គិតតាមតម្លៃបច្ចុប្បន្ន)នៃវិស័យកសិកម្ម(Agricultural Gross Value Added-GVA) គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី២០ ៩៨៦ពាន់លានរៀលនៅឆ្នាំ២០១៧ និងបានបន្តកើនដល់២៣ ៦៣៩ពាន់លានរៀលនៅឆ្នាំ២០២០។

## ២.១- ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

### ២.១.១- ផលិតកម្មដំណាំស្រូវ

ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានលើផ្ទៃដីចំនួន៣,២១លានហ.ត.នៅឆ្នាំ២០១៧ និងបានកើនឡើងដល់៣,៥៥លានហ.ត.នៅឆ្នាំ២០២១ ពោលគឺកើនប្រមាណ២,៥៦%។ ផ្ទៃដីដាំដុះដំណាំស្រូវវស្សាសម្រេចបានចំនួន២,៦៦លានហ.ត.នៅឆ្នាំ២០១៧ នឹងកើនដល់ចំនួន២,៩០លានហ.ត.នៅឆ្នាំ២០២១។ ដោយឡែក ផ្ទៃដីដាំដុះដំណាំស្រូវប្រាំងសម្រេចបានចំនួន០,៥៥លានហ.ត.នៅឆ្នាំ២០១៧ នឹងកើនដល់ចំនួន០,៦៥លានហ.ត. នៅឆ្នាំ២០២១។

ទិន្នផលស្រូវមធ្យមបានកើនពី៣,៣០តោន/ហ.ត. នៅឆ្នាំ២០១៧ ដល់៣,៣៧តោន/ហ.ត. នៅឆ្នាំ២០២១ ដោយមានអត្រាកំណើនជាមធ្យមចំនួន០,៦%ក្នុងមួយឆ្នាំ ក្នុងនោះ ទិន្នផលស្រូវវស្សាបានពី៣,០៥តោន/ហ.ត. នៅឆ្នាំ២០១៧ ដល់៣,១១តោន/ហ.ត. នៅឆ្នាំ២០២១។ នៅពេលដែលទិន្នផលស្រូវប្រាំងទទួលបានពី៤,៥១តោន/ហ.ត. ទៅ៤,៥៣តោន/ហ.ត. ក្នុងរយៈពេល៥ឆ្នាំនេះ។

បរិមាណស្រូវសរុបប្រចាំឆ្នាំបានកើនពី១០,៥២លានតោននៅឆ្នាំ២០១៧ ដល់១១,៧៩លានតោននៅឆ្នាំ២០២១ ដោយមានអត្រាកំណើនជាមធ្យមចំនួន២,៩%ក្នុងមួយឆ្នាំ ក្នុងនោះ បរិមាណផលស្រូវវស្សាបានកើនពី៨,០៥លានតោននៅឆ្នាំ២០១៧ ដល់៨,៨៦លានតោននៅឆ្នាំ២០២១ និងបរិមាណស្រូវរដូវប្រាំងទទួលបានកើនពី២,៤៧លានតោននៅឆ្នាំ២០១៧ ដល់២,៩៣លានតោននៅឆ្នាំ២០២១។

អតិរេកស្រូវបានកើនពី៥,៥៦លានតោននៅឆ្នាំ២០១៧ នឹងកើនដល់៦,៦៦លានតោននៅឆ្នាំ២០២១ ឬគិតជាអង្ករមានចំនួន៣,៥៥លានតោននៅឆ្នាំ២០១៧ នឹងកើនដល់៤,២៧លានតោននៅឆ្នាំ២០២១ អត្រាកំណើនមធ្យមនៃអតិរេកស្រូវ អង្ករ មានចំនួន២,១២%ក្នុងមួយឆ្នាំ។

**តារាងទី១ ផលិតកម្មដំណាំស្រូវឆ្នាំ២០១៧-២០២១**

| ឆ្នាំ/រដូវ | ២០១៧ | | ២០១៨ | |
|---|---|---|---|---|
| | ផ្ទៃដីដាំដុះ(ហ.ត.) | បរិមាណផល(តោន) | ផ្ទៃដីដាំដុះ(ហ.ត.) | បរិមាណផល(តោន) |
| រដូវប្រាំង | ៥៤៨ ៧៥៥ | ២ ៤៦៩ ៥៤២ | ៥៩៦ ៤៨៣ | ២ ៦៧៨ ៨៤២ |
| រដូវវស្សា | ២ ៦៥៧ ៧៦៨ | ៨ ០៤៨ ៧៩៧ | ២ ៧៣៩ ៤៤៦ | ៨ ២១២៨៩៣ |
| **សរុប** | **៣ ២០៦ ៥២៣** | **១០ ៥១៨ ៣៣៩** | **៣ ៣៣៥ ៩២៩** | **១០ ៨៩១ ៧៣៥** |

| ឆ្នាំ/រដូវ | ២០១៩ | | ២០២០ | | ២០២១(ប៉ាន់ស្មាន) | |
|---|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) |
| រដូវប្រាំង | ៥៩៧ ៥០៨ | ២ ៦១៦ ២៥៣ | ៥៩៧ ៥០៨ | ២ ៦១៦ ២៥២ | ៦៤៩ ៥៣៩ | ២ ៩៣១ ៨៤១ |
| រដូវវស្សា | ២ ៧៣១ ៣៣៨ | ៨ ២៦៩ ៤៨០ | ២ ៨០៦ ៦២៣ | ៨ ៣១៩ ៣៦៥ | ២ ៩០១ ៦០៥ | ៨ ៨៥៧ ៨៦៨ |
| **សរុប** | **៣ ៣២៨ ៨៤៦** | **១០ ៨៨៥ ៧៣៣** | **៣ ៤០៤ ១៣១** | **១០ ៩៣៥៦១៨** | **៣ ៥៥១ ១៤៤** | **១១ ៧៨៩ ៧០៩** |

### ២.១.២- ផលិតកម្មដំណាំសាកវប្បកម្ម

ក្នុងរយៈពេល៥ឆ្នាំកន្លងមក ផ្ទៃដីដាំដុះដំណាំសាកវប្បកម្មរយៈពេលខ្លី(ដូចជា ពោត ដំឡូងជ្វា បន្លែគ្រប់មុខ ម្ទេស និងឪឡឹក) បានកើនពី៨១,៤៤ពាន់ហ.ត. នៅឆ្នាំ២០១៧ និងកើនដល់១០៥,៥៨ពាន់ហ.ត. នៅឆ្នាំ២០២១ ក្នុងអត្រាកំណើនជាមធ្យម៦,៧០%ក្នុងមួយឆ្នាំ។ បរិមាណផលសរុបបានកើនឡើងពី០,៥៩លានតោននៅឆ្នាំ២០១៧ ដល់១,១៣លានតោន នៅឆ្នាំ២០២១ ក្នុងកម្រិតកំណើនមធ្យម១៧,៦៣%ក្នុងមួយឆ្នាំ។

ដំណាំសាកវប្បកម្មរយៈពេលវែងមានដូចជាម្នាស់ ចេក ស្រកានាគ ស្វាយ មៀន មៀនប៉ៃលិន ទុរេន ខ្នុរ ក្រូចពោធិ៍សាត់ ក្រូចថ្លុង សារ៉ម៉ាវ ត្របែក ទៀប ទឹកដោះ ល្មុត មានផ្ទៃដីដាំដុះកើនឡើងពីចំនួន១៥១,៦៤ ពាន់ហ.ត. នៅឆ្នាំ២០១៧ ដល់២៦៥,៣០ពាន់ហ.ត. នៅឆ្នាំ២០២១ ដែលមានកំណើនជាមធ្យម១៦% ក្នុងមួយឆ្នាំ និងបរិមាណផលទទួលបានចំនួន១,៣លានតោន នៅឆ្នាំ២០១៧ កើនដល់៣,៣លានតោន ឆ្នាំ២០២១ ក្នុងកំណើនជាមធ្យម២៦% ក្នុងមួយឆ្នាំ។

**តារាងទី២ ផលិតម្មដំណាំសាកវប្បកម្មឆ្នាំ២០១៧-២០២១**

| ឆ្នាំ/រដូវ | ២០១៧ | | ២០១៨ | | ២០១៩ | |
|---|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) |
| រដូវប្រាំង | ៣២ ៧២៧ | ២៦០ ៨៤០ | ៣៤ ៩១១ | ៣៥៩ ៧៨៧ | ៣៧ ៦២៦ | ៣៦៧ ១២០ |
| រដូវវស្សា | ៤៨ ៧១៣ | ៣៣១ ៧៥០ | ៥០ ៤៣៤ | ៤៣៧ ៧៧២ | ៥៦ ៩១៥ | ៥១២ ៧០១ |
| **សរុប** | **៨១ ៤៤០** | **៥៩២ ៥៩០** | **៨៥ ៣៤៥** | **៧៩៧ ៥៥៩** | **៩៤ ៥៤១** | **៨៧៩ ៨២១** |

| ឆ្នាំ/រដូវ | ២០២០ | | ២០២១(ប៉ាន់ស្មាន) | |
|---|---|---|---|---|
| | ផ្ទៃដីដាំដុះ(ហ.ត.) | បរិមាណផល(តោន) | ផ្ទៃដីដាំដុះ(ហ.ត.) | បរិមាណផល(តោន) |
| រដូវប្រាំង | ៣៧ ២៦២ | ៣៦៧ ១១៨ | ៤៥ ៤៣៦ | ៤៧២ ៤៨៩ |
| រដូវវស្សា | ៦៧ ៦៦៥ | ៦៥៨ ៩៧២ | ៦០ ១៤០ | ៦៦២ ១៨៥ |
| **សរុប** | **១០៥ ២៩១** | **១ ០២៦ ០៩០** | **១០៥ ៥៧៦** | **១ ១៣៤ ៦៧៣** |

## ២.១.៣- ផលិតកម្មដំណាំឧស្សាហកម្មឆ្នាំ២០១៧-២០២១

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលខ្លីមានដូចជា ពោតក្រហម ដំឡូងមី សណ្តែកដី សណ្តែកសៀង អំពៅ ក្រចៅ ល្ង និងថ្នាំជក់ ថយចុះពី៩៦៥,៤៩ពាន់ហ.ត. នៅឆ្នាំ២០១៧ មកត្រឹម៩១៩,៩៧ពាន់ហ.ត. នៅឆ្នាំ២០២១ ក្នុងអត្រាថយចុះជាមធ្យម១,២០%ក្នុងមួយឆ្នាំ។ បរិមាណផលសរុបថយចុះពី១៥,៧៩លានតោន នៅឆ្នាំ២០១៧ មកត្រឹម១៣,៨៥លាន នៅឆ្នាំ២០២១ ក្នុងអត្រាថយចុះជាមធ្យម ៣,២២%ក្នុងមួយឆ្នាំ។ ការថយចុះខាងលើនេះ បណ្តាលមកពីមុខដំណាំឧស្សាហកម្មសំខាន់ៗចំនួន៤មុខ(ពោតក្រហម សណ្តែកបាយ សណ្តែកសៀង សណ្តែកដី) បានថយចុះ បើធៀបពីឆ្នាំ២០១៧-២០២០។

ដំណាំឧស្សាហកម្មរយៈពេលវែងមានដូចជា ស្វាយចន្ទី ដូងប្រេង ដូង កាហ្វេ ម្រេច មានផ្ទៃដីដាំដុះកើនឡើងពីចំនួន២៨៣,០២ពាន់ហ.ត. នៅឆ្នាំ២០១៧ ដល់ ៤៨២,៧១ពាន់ហ.ត. នៅឆ្នាំ២០២១ ដែលមានកំណើនជាមធ្យមប្រមាណ១៤%ក្នុងមួយឆ្នាំ។ បរិមាណផលដំណាំឧស្សាហកម្មរយៈពេលវែងមានចំនួន៥៧៣ ៦៤៤ តោន នៅឆ្នាំ២០១៧ កើនដល់១,១៤លានតោន នៅឆ្នាំ២០២១(កើនឡើងប្រមាណ១៩%ក្នុងមួយឆ្នាំ)។

**តារាងទី៣ ផលិតម្មដំណាំឧស្សាហកម្មរយៈពេលខ្លី ឆ្នាំ២០១៧-២០២១**

| ឆ្នាំ/រដូវ | ២០១៧ | | ២០១៨ | | ២០១៩ | |
|---|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) |
| រដូវប្រាំង | ១៣៧ ៩៣០ | ១ ៤៧៩ ៩២៣ | ៨៨ ៨៣៩ | ៩៧៥ ៤៩២ | ៧៩ ២៤៥ | ៨៦១ ៥៧១ |
| រដូវវស្សា | ៨២៧ ៥៦៤ | ១៤ ៣១០ ៥៦៨ | ៩១៧ ៧០៣ | ១៤ ៨៧២ ៣០៩ | ៨៨៥ ៣៧៣ | ១៤២៧៧៩២១ |
| **សរុប** | **៩៦៥ ៤៩៤** | **១៥ ៧៩០ ៤៩១** | **១ ០០៦ ៥៤២** | **១៥ ៨៤៧ ៨០១** | **៩៦៤ ៦១៨** | **១៥១៣៩៤៩២** |

| ឆ្នាំ/រដូវ | ២០២០ | | ២០២១(ប៉ាន់ស្មាន) | |
|---|---|---|---|---|
| | ផ្ទៃដីដាំដុះ(ហ.ត.) | បរិមាណផល(តោន) | ផ្ទៃដីដាំដុះ(ហ.ត.) | បរិមាណផល(តោន) |
| រដូវប្រាំង | ៧៩ ២៤៥ | ៨៦២ ៧៨២ | ១០៤ ២៥៤ | ១ ១៣១ ២៤៥ |
| រដូវវស្សា | ៨៣៣ ៧៣០ | ១៣ ៣៤២ ៣០១ | ៨១៥ ៧២០ | ១២ ៧២១ ២១៣ |
| **សរុប** | **៩១២ ៩៧៥** | **១៤ ២០៥ ០៨៣** | **៩១៩ ៩៧៤** | **១៣ ៨៥២ ៤៥៨** |

**២.១.៤- ការចងក្រងនិងចុះបញ្ជីសហគមន៍កសិកម្ម**

នៅទូទាំងប្រទេសមានសហគមន៍កសិកម្មកើនឡើងសរុបចំនួន១ ២០០សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន១៤៤ ១៨២នាក់ ក្នុងនោះមានសមាជិកនារីចំនួន៩០ ៥៦២នាក់ ស្មើនឹង៦៣% មានប្រាក់ភាគហ៊ុនសរុបចំនួនជាង៤២ ៨៤១លានរៀល ស្មើនឹងជាង១០លានដុល្លារអាម៉េរិក និងដើមទុនសរុបចំនួនជាង៩៣ ៧៦៩លានរៀល ស្មើនឹងជាង២៣,៤លានដុល្លារអាម៉េរិក។ ទន្ទឹមនឹងនេះ ក្រសួងបានចងក្រងសហគមន៍កសិកម្ម ទៅជាសហភាពសហគមន៍កសិកម្ម រហូតមកដល់បច្ចុប្បន្នមានចំនួនសរុប១១ និងមានសហគមន៍កសិកម្មជាសមាជិកមានចំនួន២១៥សហគមន៍ មានដើមទុនសរុបចំនួនជាង២ ៩១៥លានរៀល។

**២.១.៥- ការងារកសិឧស្សាហកម្ម**

ក្រសួងបានរៀបចំបង្កើតអនុគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មថ្នាក់រាជធានីខេត្ត បានចំនួន២៥រាជធានី/ខេត្ត និងបានរៀបចំផែនការយុទ្ធសាស្ត្រកសិឧស្សាហកម្មឆ្នាំ២០១៩-២០៣០។ ឆ្នាំ២០២០ សហគមន៍កសិកម្មចំនួន២៩២សហគមន៍ ក្រុមកសិករ និងក្រុមបណ្តុំអាជីវកម្មផ្សេងទៀតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន៩៣៦កិច្ចសន្យា និងឆ្នាំ២០២១ មានសហគមន៍កសិកម្មចំនួន១១សហគមន៍ ក្រុមកសិករ និងក្រុមបណ្តុំអាជីវកម្មផ្សេងទៀតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនបានចំនួន១៣៦កិច្ចសន្យា។ ទន្ទឹមនឹងនេះ ក្រសួងក៏បានពង្រឹងការងារមន្ទីរពិសោធន៍ ដោយបានរៀបចំកម្រៃសេវាកម្មវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ដើម្បីទទួលបានអនុលោមភាពក្នុងកម្រិតស្តង់ដា១៧ ០២៥។

**២.១.៦- ការបង្កើនផលិតភាពដំណាំកៅស៊ូ**

ផ្ទៃដីកៅស៊ូកម្ពុជាសរុបបានថយចុះពី៤៣៦,៣ពាន់ហ.ត. នៅឆ្នាំ២០១៧ មកត្រឹម៤០៤,១ពាន់ហ.ត. នៅឆ្នាំ២០២១(ថយចុះប្រមាណ៨,៦២%) ដែលក្នុងនោះផ្ទៃដីកៅស៊ូកសិឧស្សាហកម្ម(ផ្ទៃដីរបស់អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) មានចំនួន៦០% និងកៅស៊ូគ្រួសារមានចំនួន៤០%។ ការថយចុះផ្ទៃដីនេះបណ្តាលមកពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួនបានផ្លាស់ប្តូរមុខដំណាំពីដំណាំកៅស៊ូទៅដាំដំណាំផ្សេងៗ ដោយសារដីមានលក្ខណៈមិនសមស្របនឹងដំណាំកៅស៊ូ ការគ្រប់គ្រងនិងថែទាំកៅស៊ូ របស់ក្រុមហ៊ុនមួយចំនួនមិនបានល្អ និងកត្តាភ្លើងឆេះនៅរដូវប្រាំង។

ផ្ទៃដីកៅស៊ូចៀរជ័រមានការកើនឡើងពី១៧០,២ពាន់ហ.ត. នៅឆ្នាំ២០១៧ ដល់៣១៤,៣ពាន់ហ.ត. នៅឆ្នាំ២០២១ ស្មើនឹង៧៧,៧៧%នៃផ្ទៃដីសរុប។ បរិមាណផលិតផលកៅស៊ូមានការកើនឡើងពី១៩៣,៣ពាន់តោនឆ្នាំ២០១៧ ដល់២៧១ពាន់តោនឆ្នាំ២០២១(កើនឡើងប្រមាណ២៩%)។

**តារាងទី៤ ផលិតកម្មដំណាំកៅស៊ូពីឆ្នាំ២០១៧ដល់ឆ្នាំ២០២១**

| ផលិតកម្មកៅស៊ូ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ១- ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហ.ត.) | ៤៣៦,៣ | ៤៣៦,៦ | ៤០៥,៦ | ៤០៣,៩ | ៤០៤,១ |

| | | | | | |
|---|---|---|---|---|---|
| ២- ផ្ទៃដីចៀរជ័រ (ពាន់ហ.ត.) | ១៧០,២ | ២០១,៩ | ២៥០,៤ | ២៩២,៦ | ៣១៤,៣ |
| ៣- ផលិតផលកៅស៊ូ (ពាន់តោន) | ១៩៣,៣ | ៩៧,១ | ១២៦,៩ | ១៤៥,២ | ២៧១ |

ជាមួយគ្នានេះ ការនាំចេញជ័រកៅស៊ូប្រមាណ២៦៦ ៧៦៥តោន ស្មើនឹងទឹកប្រាក់ប្រមាណ៤៤៣,៧៩ លានដុល្លារអាម៉េរិក បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ដែលការនាំចេញមានចំនួន២៤៣ ១២៥តោន គិតជាទឹកប្រាក់សរុប៣១៨,៥៩លានដុល្លារអាម៉េរិក គឺបរិមាណនាំចេញកើនឡើងប្រមាណ២៣ ៦៤០តោន ស្មើនឹង ៩,៧% និងប្រាក់ចំណូលកើនប្រមាណ១២៥,២លានដុល្លារអាម៉េរិក ស្មើនឹង៣៩,៣%។ តម្លៃកៅស៊ូនាំចេញជាមធ្យមថ្លៃ១ ៦៦៤ដុល្លារអាម៉េរិក/តោន បើធៀបនឹងឆ្នាំ២០២០ តម្លៃមធ្យមស្មើនឹង១ ៣១០ដុល្លារអាម៉េរិក/តោន ឃើញថា កើនឡើងចំនួន៣៥៤ដុល្លារអាម៉េរិក/តោន។ ការនាំចេញឈើកៅស៊ូបានចំនួន៥ ១២៨ម៣ ទទួលបានទឹកប្រាក់ចំនួន១,២១លានដុល្លារអាម៉េរិក។ ចំណូលសរុបបានមកពីការនាំចេញជ័រនិងឈើកៅស៊ូមានប្រមាណ ៤៤៥លានដុល្លារអាម៉េរិក។

**២.១.៧- ការងារស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាកសិកម្ម**

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានអនុវត្តសកម្មភាពការងារបានលទ្ធផលសម្រេចបានលេចធ្លោចម្បងៗ មានដូចខាងក្រោម៖

ក- ការងារសមូហកម្មនិងអភិរក្សកម្មពូជដំណាំ ពូជដំណាំចំនួន៧៤០សំណាកត្រូវបានប្រមូលបន្ថែមលើពន្ធុដំណាំដែលបាន និងកំពុងអភិរក្សក្នុងធនាគារពន្ធុដំណាំកើនឡើងដល់៩ ១១៦បញ្ជិក។ ទន្ទឹមនេះ ពូជស្រូវកម្ពុជាចំនួន៤ ៨៩៧បញ្ជិក បាននិងកំពុងរក្សាទុករយៈពេលយូរនៅធនាគារពន្ធុ នៃវិទ្យាស្ថានអន្តរជាតិស្រាវជ្រាវដំណាំស្រូវដែលមានមូលដ្ឋាននៅឯប្រទេសហ្វីលីពីន និងមួយផ្នែកទៀតចំនួន២១៤បញ្ជិក ដែលបានអភិរក្សនៅធនាគារពន្ធុនៅប្រទេសកូរ៉េខាងត្បូង។

ខ- ការងារអភិវឌ្ឍពូជថ្មីនៃដំណាំ និងការបញ្ចេញឱ្យកសិករ និងគ្រប់អ្នកពាក់ព័ន្ធប្រើប្រាស់ ពូជស្រូវផ្កាមាលតី ពូជស្រូវសែនក្រអូប០១ និងពូជសណ្តែកដីខេប០១ត្រូវបានបញ្ចេញជាផ្លូវការ។

គ- ការងារផលិតកម្មគ្រាប់ពូជស្រូវតាមចំណាត់ថ្នាក់បរិសុទ្ធភាព ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ផលិតកម្មគ្រាប់ពូជស្រូវ រួមមានគ្រាប់ពូជគ្រឹះ គ្រាប់ពូជវិញ្ញាបនបត្រ និងគ្រាប់ពូជសុទ្ធល្អនៃពូជស្រូវ ផ្ការំដួល សែនពិដោរ រាំងជ័យ ផ្ការមៀត ផ្ការំដេង ផ្កាច័ន្ទសែនសរ អ៊ីអ៊ែ៦៦ ជលសារ ដំណើបស្បៃមង្គល ខា៨ ខា១៤ ខា១៥ ខា១៦ ផ្កាមាលតី និងសែនក្រអូប០១ សរុបចំនួន២៨២តោន ត្រូវបានផលិតនិងប្រើប្រាស់នៅទូទាំងប្រទេស។

ឃ- ការងារផ្សព្វផ្សាយរបកគំហើញបច្ចេកទេសវិទ្យាសាស្ត្រកសិកម្ម កសិករសរុប៨ ៩៩៨នាក់ត្រូវបានបណ្តុះបណ្តាលទេពកោសល្យផ្នែកផលិតភាពកសិកម្ម តាមរយៈការធ្វើពិសោធន៍ ការធ្វើទិវាស្រែបង្ហាញការចែកផ្សាយព្រឹត្តិបត្រព័ត៌មានកសិករ និងការប្រឹក្សាក្នុងគេហទំព័ររបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា។

ង- ការងារធ្វើវិភាគសមាសភាគជីវជាតិមានគុណប្រយោជន៍ផ្នែកចំណីអាហារនៅក្នុងគ្រាប់អង្ករបស់ប្រភេទពូជស្រូវមួយចំនួន អង្ករសម្រិត និងអង្ករសម្រូបរបស់ពូជស្រូវផ្ការំដួល ផ្ការមៀត ផ្ការំដេង សែនពិដោរ និងផ្កាច័ន្ទសែនសរ និងអង្ករសម្រិតរបស់ពូជស្រូវដំណើបស្បៃមង្គលត្រូវបានយកទៅធ្វើការវិភាគផ្នែកអាហារូបត្ថម្ភ (Nutrition value) នៅមន្ទីរពិសោធន៍បរទេសស្តង់ដាអន្តរជាតិ។ លទ្ធផលនេះត្រូវបានបង្ហោះនៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន(www.cardi.org.kh) សម្រាប់អ្នកពាក់ព័ន្ធយកទៅប្រើប្រាស់។

## ២.២- ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើតការងារ សន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់បញ្ចូលវិស័យកសិកម្ម ក្នុងចតុកោណទី៤ មុំទី១ ចំណុចអាទិភាពទី៧ ចែងពីការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វឱ្យកាន់តែមានលក្ខណៈទូលំទូលាយថែមទៀតតាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយ ផ្ដែកលើខ្សែច្រវាក់តម្លៃ និងដោះស្រាយជាកញ្ចប់នូវឧបសគ្គដល់ការអនុវត្តអនុវិស័យនេះ ជាមួយការគិតគូរដល់បញ្ហាសុវត្ថិភាពចំណីអាហារលើកទឹកចិត្តដល់ការវិនិយោគពេងចក្រផលិតចំណីសត្វ កែលម្អការគ្រប់គ្រងសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ ដំណើរការទីផ្សារ ជាពិសេសអនាម័យ និងភូតគាមអនាម័យ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ បានកំណត់នូវទិសដៅជំរុញផលិតផលសាច់ក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ តាមរយៈការគ្រប់គ្រង និងអភិវឌ្ឍន៍ការចិញ្ចឹមសត្វ កាត់បន្ថយហានិភ័យជំងឺឆ្លងសត្វ ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ។

### ២.២.១- ការជំរុញការចិញ្ចឹមសត្វនិងបង្កើនផលិតភាពសត្វ

#### ក- ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ឆ្នាំ២០១៧ ការចិញ្ចឹមសត្វលក្ខណៈគ្រួសារសរុបមានចំនួន៣៤,៤៧លានក្បាល កើនដល់៣៦,២៥លានក្បាល នៅឆ្នាំ២០២១ ដែលក្នុងនោះមានគោចំនួន២,៨៦លានក្បាល ក្របីចំនួន៤២៥ពាន់ក្បាល ជ្រូកចំនួន១,១៥លានក្បាល និងបក្សីចំនួន៣១,៧៧លានក្បាល។

បើប្រៀបធៀបឆ្នាំ២០២០ និងឆ្នាំ២០២១ ស្ថិតិសត្វចិញ្ចឹមលក្ខណៈគ្រួសារសរុបកើនឡើងចំនួន៣,៦៥% ក្នុងនោះគោកើនចំនួន១% ក្របីកើនចំនួន០,៥% ជ្រូកកើនចំនួន២% និងបក្សីកើនចំនួន៤%។

#### ខ- ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពី៨,៣៥លានក្បាលនៅឆ្នាំ២០១៧ ដល់២០,៧៥លានក្បាលនៅឆ្នាំ២០២១។ ក្នុងឆ្នាំ២០២១នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានកំណើន៩,៧០% ក្នុងនោះផលិតកម្មជ្រូកមានកំណើន៦% និងផលិតកម្មបក្សីមានកំណើន១០%។ អត្រានៃកំណើនផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមាន ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចឱ្យកាន់តែល្អប្រសើរឡើង។

#### គ- ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារ និងលក្ខណៈពាណិជ្ជកម្ម)

ផលិតកម្មសត្វគ្រប់ប្រភេទមានការកើនឡើងពី៤២,៨៣លានក្បាលនៅឆ្នាំ២០១៧ ដល់៦១,២៧លានក្បាល នៅឆ្នាំ២០២១ ដែលក្នុងនោះគោមានចំនួន២,៨៧លានក្បាល ក្របីចំនួន៤២៥ពាន់ក្បាល ជ្រូក២,៦២លានក្បាល បក្សីចំនួន៥១,០៣លានក្បាល សេះចំនួន២,៩៧ពាន់ក្បាល ចៀមចំនួន១,៧៦ពាន់ក្បាល ពពែចំនួន៣០,៩១ពាន់ក្បាល ដំរីចំនួន៥១ក្បាល ស្វាចំនួន១៧,២២ពាន់ក្បាល និងទន្សាយចំនួន៣១១ក្បាល។

បើប្រៀបធៀបឆ្នាំ២០២០ និងឆ្នាំ២០២១ ផលិតកម្មសរុបកើនដល់៥,៤០% ក្នុងនោះគោកើន១,៥០% ក្របីកើន០,៥៥% ជ្រូកកើន៤,១៩% បក្សីកើន៦,១៨% ចៀមកើន២,០២% និងពពែកើន២,០៨%។

## តារាងទី៥ ស្ថិតិផលិតកម្មសត្វសរុបតាមបែបផែនផលិតកម្មពីឆ្នាំ២០១៧-២០២១

| ល.រ. | បែបផែនផលិតកម្មសត្វ | ផលិតកម្មសត្វសរុបតាមបែបផែនផលិតកម្ម (២០១៧-២០២១) | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | លក្ខណៈគ្រួសារ | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៨ ៨៩១ ៤៤៣ | ៤០ ៥១៩ ៥០៧ |
| ២ | លក្ខណៈពាណិជ្ជកម្ម | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ១៨ ៩២០ ០៧៧ | ២០ ៧៥៤ ៤៦៤ |
| សរុប | | ៤២ ៨៣៤ ១៦៨ | ៤៤ ៣៧៥ ៣៩៥ | ៤៥ ៨៥៥ ១៤៣ | ៥៧ ៨១១ ៥២០ | ៦១ ២៧៣ ៩៧១ |

### ឃ- តម្រូវការសត្វនិងសាច់

តាមរបាយការណ៍របស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិបញ្ជាក់ថា ការបរិភោគសាច់សត្វនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៧,៦០គ.ក្រ. ក្នុងនោះ សាច់គោ ក្របី៥គ.ក្រ. សាច់ជ្រូក៩,២៩គ.ក្រ សាច់បក្សី៣,៣គ.ក្រ. និងសាច់សត្វផ្សេងៗទៀត០,០១គ.ក្រ.។

ដោយសារតែកំណើនប្រជាពលរដ្ឋក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់បរិភោគមានការកើនឡើងពី២៨៥ពាន់តោនក្នុងឆ្នាំ២០១៨ ដល់៣០១ពាន់តោន ក្នុងឆ្នាំ២០២០។ ជាក់ស្តែង ផលិតកម្មសត្វក្នុងស្រុកមានលទ្ធភាពផ្គត់ផ្គង់បានក្នុងរង្វង់៨១% ទៅ៨៥% គឺ២៣១ពាន់តោន នៅឆ្នាំ២០១៨ ដល់ ២៦៤ពាន់តោន ក្នុងឆ្នាំ២០២១។

### ង- ការនាំចេញសត្វនិងផលិតផលសត្វ

លទ្ធភាពការនាំចេញសត្វគោ ក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលសត្វ ចំណីអាហារ និងទឹកដោះគោមួយចំនួនទៅបរទេស។ ជារួមក្នុងរយៈពេល៥ឆ្នាំនេះ កម្ពុជាបាននាំចេញគោ ក្របីចំនួន៩០ ២២១ក្បាល ជ្រូកពូជ(មេ បា កូន)ចំនួន៤២ ៤៩៥ក្បាល ស្វាក្តាមចំនួន១០៨ ៩០២ក្បាល សាច់គោចំនួន៨៧តោន ទឹកដោះគោចំនួន១១ ៩៩៣តោន ចំណីថ្លៃចំនួន៧ ៥១៦តោន រោមសត្វចំនួន១១២,៨តោន និងស្បែកគោ ក្របីចំនួន៧,៧ពាន់តោន។ ដោយឡែកនៅឆ្នាំ២០២០បាននាំចេញគោ ក្របីចំនួន៩,៧ពាន់ក្បាល ស្វាក្តាមចំនួន ២៤ពាន់ក្បាល ចំណីថ្លៃចំនួន២ ២៧៦តោន រោមសត្វចំនួន២,៨តោន និងស្បែកគោ ក្របីប្រឡាក់ចំនួន៧ ៧២៤ តោន។

### ច- អំពីចំណីសត្វ

ដើម្បីបង្កើនផលិតកម្មសត្វ អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ បានរៀបចំកម្មវិធីកែលម្អចំណីសត្វ ដោយធ្វើការផ្សព្វផ្សាយពូជស្មៅដែលសំបូរទៅដោយសារជាតុចិញ្ចឹមនិងផ្តល់ទិន្នផលខ្ពស់។ គិតត្រឹមរយៈពេល៩ខែដើមឆ្នាំ២០២១នេះ បានពង្រីកកម្មវិធីដំណាំចំណីសត្វ នៅទូទាំងរាជធានី ខេត្ត មានកន្លែងធ្វើបង្ហាញសរុបចំនួន២ ៨៩៩កន្លែង លើផ្ទៃដីចំនួន២ ១៣១,០៧ហ.ត.។

បច្ចុប្បន្ន ក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វមានចំនួន១៩ក្រុមហ៊ុន ដែលមានរោងចក្រផលិតចំណីសត្វចំនួន២១រោងចក្រ ហើយអាចមានសមត្ថភាពផលិតចំណីសត្វបានប្រមាណ២,១៦ លានតោន/ឆ្នាំ។

### ២.២.២- ការលើកកម្ពស់សុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល

### ក- ការលើកកម្ពស់សុខភាពសត្វ

ក្រសួងបានធ្វើយុទ្ធនាការចាក់ថ្នាំការពារជំងឺឆ្លងសំខាន់ៗលើសត្វគោ ក្របី ជ្រូក មាន់ ទា និងសត្វចិញ្ចឹមផ្សេងៗទៀតនៅទូទាំងប្រទេស។ ដោយឡែកសត្វគោ ក្របីបានចាក់ថ្នាំការពារជំងឺឆ្លងមួយចំនួនដូចជា ជំងឺ

អុតក្ដាម បូសខ្យល់ និងជំងឺសារទឹក។ ក្នុងរយៈពេល៩ខែដើមឆ្នាំ២០២១នេះ បានចាក់ថ្នាំការពារជំងឺសត្វចំនួន ៣៣,៧៨លានក្បាល ដែលក្នុងនោះមានសត្វគោ ក្របីចំនួន៨១៩ ៤១៧ក្បាល។

**ខ- ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល**

គិតត្រឹមឆ្នាំ២០២១នេះ សត្តឃាតដ្ឋានមានចំនួន២២៥កន្លែង ក្នុងនោះសត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨ មានចំនួន១២៥កន្លែង សត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យលេខ១០៨ និងវិនិយោគមានចំនួន ៦០កន្លែង និងសត្តឃាតដ្ឋានវិនិយោគទុនសុទ្ធមានចំនួន៤០កន្លែង។ ទោះបីជាសត្តឃាតដ្ឋានមានការកើនឡើងជាលំដាប់ក៏ដោយ ក៏អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានខិតខំរៀបចំសត្តឃាតដ្ឋានទាំងនោះឱ្យអនុវត្តអនាម័យស្របតាមបទដ្ឋានបច្ចេកទេស។

## ២.៣- ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចយ៉ាងសកម្មទៅលើការងារគ្រប់ផ្នែកលើអនុវិស័យជលផល ក្នុងនោះ ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងកន្លែងអភិរក្សជលផល ការគ្រប់គ្រងដែននេសាទ ការបង្ក្រាបបទល្មើសជលផល ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយ។ ទន្ទឹមនឹងនេះ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**២.៣.១- ស្ថិតិផលនេសាទ**

**ក- ស្ថិតិផលនេសាទទឹកសាប**

ការនេសាទទឹកសាបសម្រេចបានចំនួន៥២៧ ៧៩៥តោន ស្មើនឹង១០៥,៥៦%នៃផែនការឆ្នាំ២០១៧ និងសម្រេចបានចំនួន៣៨៣ ០៥២តោន ស្មើនឹង៧០,៦៧%ក្នុងឆ្នាំ២០២១។

**ខ- ស្ថិតិផលនេសាទសមុទ្រ**

ការនេសាទសមុទ្រសម្រេចបានចំនួន១២១ ០២៥តោន ស្មើនឹង១១០,០២%ក្នុងឆ្នាំ២០១៧ និងសម្រេចបានចំនួន១២៥ ០០០តោន ស្មើនឹង៩៤,៤៦%ក្នុងឆ្នាំ២០២១។

**២.៣.២- ផលវារីវប្បកម្ម**

ក្នុងឆ្នាំ២០១៧ វារីវប្បកម្មសម្រេចបាន ដូចខាងក្រោម៖

- ការចិញ្ចឹមត្រី បង្គា សម្រេចបានចំនួន២០៧ ៤៤៣តោន ស្មើនឹង១០០,០៤%
- ការចិញ្ចឹមក្រពើ សម្រេចបានចំនួន៣៩២ ៧៧៧ក្បាល ស្មើនឹង១៣០,៩០%
- ការភ្ញាស់កូនត្រី សម្រេចបានចំនួន២០៥ ០០០ ០០០កូន ស្មើនឹង១០២,៥០%។

នៅឆ្នាំ២០២១នេះ វារីវប្បកម្មសម្រេចបាន ដូចខាងក្រោម៖

- ការចិញ្ចឹមត្រី បង្គា សម្រេចបានចំនួន៣៨៣ ០៥២តោន ស្មើនឹង៦៤,៣៨%
- ការចិញ្ចឹមក្រពើ សម្រេចបានចំនួន២៧១ ១០០ក្បាល ស្មើនឹង៨២,១៥%
- ការភ្ញាស់កូនត្រី សម្រេចបានចំនួន៣២៣ ៨០៦ ០០០កូន ស្មើនឹង១១៩,៩៣%។

តារាងទី៥ ផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្មពីឆ្នាំ២០១៧-២០២១(តោន)

| ល.រ. | បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ១ | ផលនេសាទទឹកសាប | ៥២៧ ៧៩៥ | ៥៣៥ ០០៥ | ៤៧៨ ៨៩០ | ៤១៣ ២០០ | ៣៨៣ ០៥២ |
| ២ | ផលនេសាទសមុទ្រ | ១២១ ០២៥ | ១២១ ១០០ | ១២២ ២៥០ | ១២២ ៧០០ | ១២៥ ០០០ |
| ៣ | ផលវារីវប្បកម្ម | ២០៧ ៤៤៣ | ២៥៤ ០៤៨ | ៣០៧ ៤០៨ | ៤០០ ៤០០ | ៣៤៨ ៣៤៨ |
| | សរុប | ៨៥៦ ២៦៣ | ៩១០ ១៥៣ | ៩០៨ ៥៤៨ | ៩៣៦ ៣០០ | ៨៥៦ ៤០០ |

**២.៣.៣- ការកែច្នៃផល ផលិតផលជលផល**

ក្នុងឆ្នាំ២០១៧ ការកែច្នៃផល ផលិតផលជលផលសម្រេចបានចំនួន៨២ ៦០០តោន ស្មើនឹង៩០,៧៧% និងផលិតទឹកត្រីសម្រេចបានចំនួន៥៧ ០០០ ០០០លីត្រ ស្មើនឹង១១៤% និងឆ្នាំ២០២១ ការកែច្នៃផល ផលិតផលជលផលសម្រេចបានចំនួន៥៦ ៨១០តោន ស្មើនឹង៦១,៧៥% និងផលិតទឹកត្រីសម្រេចបានចំនួន៤៩,៥លានលីត្រ ស្មើនឹង៩០%។

**២.៣.៤- ការនាំចេញ ផលិតផលជលផល**

ក្នុងឆ្នាំ២០១៧នេះ ការនាំចេញផល ផលិតផលជលផលសម្រេចបានចំនួន១៣ ០០០តោន ស្មើនឹង ៦៥% និងឆ្នាំ២០២១នេះ ការនាំចេញផល ផលិតផលជលផលសម្រេចបានចំនួន៣ ០៦៦តោន ស្មើនឹង៣០,៦៦%។

**២.៣.៥- ការការពារបង្ក្រាបបទល្មើសជលផល**

ក្នុងឆ្នាំ២០១៧ ការការពារបង្ក្រាបបទល្មើសជលផលសម្រេចបាន៣ ៩២៥ករណី និងឆ្នាំ២០២១ ការការពារបង្ក្រាបបទល្មើសជលផលសម្រេចបាន២ ៧៦០ករណី។

**២.៣.៦- ការអភិវឌ្ឍសហគមន៍នេសាទ**

ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ សហគមន៍នេសាទទូទាំងប្រទេសមានចំនួនសរុប៥១៦សហគមន៍ ក្នុងនោះ សហគមន៍នេសាទទឹកសាបចំនួន៤៧៥ និងសហគមន៍នេសាទសមុទ្រចំនួន៤១ ដែលមានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់(ស្ត្រី៣៥%)។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន ៤៣៥ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំពោះសហគមន៍នេសាទដែលផុតអាណត្តិមានចំនួន២០០ ត្រូវបានបោះឆ្នោតជ្រើសរើសគណៈកម្មការឡើងវិញ និងបានរៀបចំផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ និងសារៈសំខាន់នៃវិស័យជលផលដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធបានចំនួន៣៧៩វគ្គ មានអ្នកចូលរួមចំនួន២៤ ២៤១នាក់។

**២.៣.៧- ការងារកិច្ចការជលផល**

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ ការងារកិច្ចការជលផលបានបោះបង្គោលបេតុងកំណត់ព្រំប្រទល់ការពារព្រៃលិចទឹកកម្ពស់៨ម. បានចំនួន២៤០បង្គោល និងធ្វើជំរឿននាវានេសាទ និងបាញ់ស្លាកសម្គាល់នាវានេសាទបានចំនួន៧ ៥៥២គ្រឿង និងបានប្រជុំផ្សព្វផ្សាយប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ពីសារៈសំខាន់នៃព្រៃលិចទឹក និងច្បាប់ពាក់ព័ន្ធបានចំនួន៤២វគ្គ មានអ្នកចូលរួមចំនួន៥ ៨៣០នាក់។

**២.៣.៨- ការអភិរក្សធនធានជលផល**

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ ការងារអភិរក្សជលផលបានរៀបចំកន្លែងអភិរក្សបានចំនួន ៦៦កន្លែង សង់បង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សបានចំនួន៣៨៨បង្គោល ទម្លាក់ប្រអប់បេតុងការពារកន្លែងអភិរក្សជលផលសមុទ្របានចំនួន១ ១៥០បង្គោល សាងសង់ស្នាក់ការល្បាតការពារកន្លែងអភិរក្សបានចំនួន៤៤ខ្នង

ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន២ ៥២០ហ.ត. កែលម្អទីជម្រកផ្កាថ្មនិងស្មៅសមុទ្របានចំនួន៨ ៥០០ ហ.ត. និងការពារអភិរក្សសត្វផ្សោតទន្លេមេគង្គបានចំនួន៨៩ក្បាល។

ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមយ៉ាងសកម្មជាមួយក្រុមការងារអន្តរក្រសួង ដែលដឹកនាំដោយ ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការចុះពិនិត្យ និងមានវិធានការបង្ក្រាបការទន្រ្ទានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៅតំបន់បឹងទន្លេសាបមួយចំនួនដោយជំរុញឱ្យរដ្ឋបាលខេត្តជុំវិញបឹងទន្លេសាបចេញលិខិតណែនាំដល់អាជ្ញាធរស្រុក ឃុំ បញ្ឈប់ការពិនិត្យបញ្ជាក់លើលិខិតសុំកាន់កាប់ដី និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីក្នុងដែនព្រៃលិចទឹកព្រមទាំងចេញលិខិតបដិសេធលើរាល់លិខិតដែលបានចេញរួចពីពេលមុន និងចាត់វិធានការបញ្ឈប់ការចូលទន្រ្ទានដីដែនព្រៃលិចទឹកបន្តទៀត ធ្វើអត្តសញ្ញាណអ្នកដែលបានចូលទន្រ្ទាន ដើម្បីធ្វើការដកហូតដីនិងចាត់វិធានការតាមផ្លូវច្បាប់ ដោយត្រូវកសាងអង្គហេតុ និងដាក់បណ្តឹងអាជ្ញាទៅតុលាការ។

### ២.៣.៩- ការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាដូចជា EU, UNIDO, FAO, WB, MRC, WWF, IUCN, World Fish Center ជាដើម។ល។ ដោយអនុវត្តន៍លើសកម្មភាពមួយចំនួន ដូចជាការសិក្សាស្រាវជ្រាវជីវសាស្ត្រវារីសត្វ សិក្សាតាមដានផលនេសាទតាមដាយត្រី សិក្សាតាមដានប្រភេទកូនត្រី សិក្សាស្រាវជ្រាវការធ្វើចរាចរណ៍នឹងការពងកូនរបស់ត្រីនៅតំបន់មេគង្គលើ សិក្សាតាមដានសុខភាពអេកូឡូស៊ីនៅកម្ពុជា និងសិក្សាតាមដានស្ថានភាពនេសាទសមុទ្រ។ល។ និងលទ្ធផលស្រាវជ្រាវត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល។

## ៣- ការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើនិងសត្វព្រៃ

ធនធានព្រៃឈើ បានផ្តល់សារប្រយោជន៍យ៉ាងច្រើនក្រៃលែងដល់សង្គមជាតិយើងតាំងពីដើមរហូតមកដល់បច្ចុប្បន្ននិងទៅអនាគត។ ព្រៃឈើពុំគ្រាន់តែមានតម្លៃសម្រាប់រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់តម្លៃខ្ពស់មិនអាចប៉ាន់ប្រមាណបានលើផ្នែកថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិ ធ្វើឱ្យធាតុអាកាសមានភាពកាន់តែប្រសើរឡើងនិងខ្យល់បរិសុទ្ធ រក្សាបាននូវនិយ័តភាពប្រភពទឹកសម្រាប់ការធ្វើកសិកម្ម ការពារទីជម្រាលនិងជីវចម្រុះ ទ្រទ្រង់និងលើកកម្ពស់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋដែលពឹងអាស្រ័យផលទៅលើផល អនុផលព្រៃឈើ និងជាប្រភពការពារភេពផែនដីយើង ជីវិតយើង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តកម្មវិធីកែទម្រង់វិស័យព្រៃឈើជាបន្តបន្ទាប់ ជាពិសេសបានដាក់ចេញនូវយុទ្ធសាស្ត្រច្បាស់លាស់ក្នុងគោលដៅដើម្បីលើកកម្ពស់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃឱ្យមាននិរន្តរភាព។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងអាចសម្រេចបានគឺអាស្រ័យដោយមានការគ្រប់គ្រងផ្អែកលើចក្ខុវិស័យច្បាស់លាស់ និងការអនុវត្តនូវបេសកកម្មចំបងៗចំនួនបីគឺ (១) គ្រប់គ្រងធនធានព្រៃឈើ សត្វព្រៃប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន (២) ផ្តល់សេវាកម្មបច្ចេកទេសមានភាពទំនើប វិទ្យាសាស្ត្រ នវានុវត្តន៍ និងវិធានសមស្រប ដើម្បីអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយប្រសិទ្ធផលខ្ពស់ និង(៣) អភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ ក្នុងនោះផ្តោតសំខាន់លើការបង្កើនការដាំឈើ និងឧស្សាហកម្មឈើ។

ទោះបីស្ថិតក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានអូសបន្លាយរហូតដល់ពេលបច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលព្រៃឈើជាអង្គភាពប្រតិបត្តិផ្ទាល់ បានខិតខំបន្តអនុវត្តន៍ផែនការសកម្មភាពជាច្រើនដើម្បីរួមចំណែកដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗរួមមាន៖

**ក- គម្របព្រៃឈើនិងសហគមន៍ព្រៃឈើ**

នៅឆ្នាំ២០១៨ ផ្ទៃដីគម្របព្រៃឈើមានទំហំសរុប៨ ៥២៩ ៣៧២ហ.ត. ស្មើនឹង៤៦,៩៧%នៃផ្ទៃដីសរុប។ គិតពីឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១នេះ ក្រសួងបានចេញប្រកាសបង្កើតសហគមន៍ព្រៃឈើថ្មីចំនួន៣៣សហគមន៍ គ្របដណ្តប់លើផ្ទៃដី១៥ ៦៧២ហ.ត.។ សូមបញ្ជាក់ថា នាពេលបច្ចុប្បន្ននេះ សហគមន៍ព្រៃឈើសរុបមានចំនួន៦៤៣សហគមន៍ គ្របដណ្តប់លើផ្ទៃដី៥២២ ២៧៣ហ.ត. ក្នុងនោះក្រសួងបានចេញប្រកាសចំនួន៥៣៦សហគមន៍ លើផ្ទៃដី៤៤៩ ៤៧៥ហ.ត. និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៤៤៩សហគមន៍ លើផ្ទៃដី៣៧២ ១៧៥ហ.ត. លើសពីនេះបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១០៦សហគមន៍ គ្របដណ្តប់លើផ្ទៃដីទំហំ៧២ ៦២១ហ.ត.។ ជាមួយគ្នានេះ បាននិងកំពុងយកចិត្តទុកដាក់លើការបង្កើតមុខរបរបន្ថែមដល់ប្រជាសហគមន៍ក្នុងការបង្កើនចំណូលលើកកម្ពស់ជីវភាពរស់នៅតាមរយៈការអនុវត្តប្រព័ន្ធកសិរុក្ខកម្ម និងការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យផលលើផល និងអនុផលព្រៃឈើ។

**ខ- ការងារដាំឈើ**

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះគឺ បានថែទាំចម្ការឈើចាស់ទំហំ៦៥៤ហ.ត. ចម្ការពូជឈើទំហំ៩៤ហ.ត.និងឡូតិ៍បង្ហាញកសិរុក្ខកម្មទំហំ៤៤ហ.ត. និងបានដាំឈើជាចម្ការថ្មីទំហំ៣៨ ៧៩៤ហ.ត. និងបានដឹកប្រឡាយការពារចម្ការឈើគ្រញូង និងតំបន់ប្រភពគ្រាប់ពូជឈើគ្រញូងប្រវែងសរុប៥១ ៥៧៨ម. នៅក្នុងខេត្តកំពង់ធំ ព្រះសីហនុ ស្វាយរៀង និងខេត្តសៀមរាប។ ជាមួយគ្នានេះ បានរៀបចំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ដោយគិតមកទល់នឹងពេលបច្ចុប្បន្នមានចំនួន៨០ទីតាំង លើផ្ទៃដីសរុបចំនួន៤៩៩ ០១៣ហ.ត. ក្នុងនោះ ១៦ទីតាំងមានបណ្ណកម្មសិទ្ធិលើផ្ទៃដីទំហំ១០៦ ៥២២ហ.ត. ដើម្បីត្រៀមរៀបចំ និងជំរុញនូវការចូលរួមវិនិយោគរបស់វិស័យឯកជន និងដៃគូពាក់ព័ន្ធនានា លើការងារដាំដុះព្រៃឈើធានាបាននូវនិរន្តរភាពការប្រើប្រាស់ក្នុងស្រុក និងផ្គត់ផ្គង់ដល់ការនាំចេញឈើដាំនាពេលអនាគត។ សព្វថ្ងៃនេះមានការដាំឈើជាលក្ខណៈក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារលើផ្ទៃដីសរុបចំនួន១០២ ១០៨ហ.ត. និងគម្រោងដាំឈើក្នុងសម្បទានដីសេដ្ឋកិច្ចមានចំនួន១៧ក្រុមហ៊ុន លើផ្ទៃដីចុះកិច្ចសន្យាទំហំ២៨០ ៨៧០ហ.ត.។ លើសពីនេះបានបន្តជំរុញការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យមានការចូលរួមដាំឈើតាមទីតាំងផ្សេងៗដូចជា ទីសាធារណៈ សាលារៀន វត្តអារាម លំនៅឋាន។ល។ ពិសេសបានធ្វើការរៀបចំនូវពិធីរុក្ខទិវាថ្នាក់ជាតិ និងតាមបណ្តារាជធានី ខេត្ត។

**គ- ការងារគ្រប់គ្រងផល អនុផលព្រៃឈើ និងឧស្សាហកម្មឈើ**

រដ្ឋបាលព្រៃឈើបានយកចិត្តទុកដាក់ខ្ពស់លើការផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្ត ព្រមទាំងបានពិនិត្យយ៉ាងហ្មត់ចត់លើការផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ផ្តល់ការអនុញ្ញាតបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ការពិនិត្យ និងអនុញ្ញាតបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ ឡធ្យូង និងការផ្តល់ទិដ្ឋាការអាជ្ញាបណ្ណ នាំចេញ នាំចូល ផងដែរ។ បច្ចុប្បន្ននេះ រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ចំនួន២៦កន្លែង រោងម៉ាស៊ីន

អារកែច្នៃឈើ ផលិតគ្រឿងសង្ហារិម និងឡធ្យូង ដែលបានបង្កើតនិងពន្យារសុពលភាពមានចំនួន៣៤កន្លែង និង រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងរោងសន្និធិលក់គ្រឿងសង្ហារិមប្រភេទតូចទទួលបានការអនុញ្ញាត ពីខណ្ឌរដ្ឋបាលព្រៃឈើរាជធានី ខេត្ត មានចំនួន៦៧៥កន្លែង។ លើសពីនេះ បានបន្តកិច្ចខិតខំប្រឹងប្រែងពង្រឹងការ អនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសការត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្ម ឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងចាត់វិធានការ មឺងម៉ាត់ចំពោះការទប់ស្កាត់ និងលុបបំបាត់ការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានយកដីព្រៃធ្វើជាកម្មសិទ្ធិ និងការនាំចេញ ឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទ ដែលគ្មានការអនុញ្ញាត។

**ឃ- ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃ**

បានចុះអន្តរាគមន៍ទប់ស្កាត់និងបង្ក្រាបការជួញដូរសត្វព្រៃ ការដោះអន្ទាក់សត្វព្រៃ ការចុះសិក្សា ស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃ និងជំរុញការចុះបញ្ជិកាថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារ។ ចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ បានធ្វើការចុះបញ្ជិកាការចិញ្ចឹមសត្វត្រចៀកកាំបានចំនួន២៥០ទីតាំង និងការ ចិញ្ចឹមសត្វព្រៃផ្សេងៗបានចំនួន៦២ទីតាំង។ លើសពីនេះបាននិងកំពុងថែរក្សា និងសង្គ្រោះសត្វព្រៃដែលទទួល បានពីតំបន់នានា ព្រមទាំងធ្វើការស្តារលទ្ធភាពជីវសាស្ត្ររួចលែងទៅព្រៃធម្មជាតិវិញ។ តាមទិន្នន័យចាប់ពីឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១នេះ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ បង្ហាញថា បានទទួលសត្វព្រៃយកមកសង្គ្រោះ និងព្យាបាលចំនួន៧ ០៥៧ក្បាល និងបានធ្វើការបង្កាត់ពូជប្រភេទសត្វព្រៃ ងាយរងគ្រោះបានកូនចំនួន៥៤៣ក្បាល ព្រមទាំងស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃនិងលែងទៅព្រៃធម្មជាតិវិញនូវ សត្វព្រៃចំនួន៦ ២៥១ក្បាល។

ទន្ទឹមនឹងការវិវត្តទៅមុខឥតឈប់ឈរស្របតាមនិន្នាការជាសកលនៃការគ្រប់គ្រងព្រៃឈើ និងការ អភិវឌ្ឍនូវបច្ចេកទេសថ្មីៗ ក្នុងដំណាក់កាលនៃសកលភាវូបនីយកម្ម រដ្ឋបាលព្រៃឈើបានបន្តពង្រឹងកិច្ចសហ- ប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ កិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីក្នុងការរៀបចំគម្រោងសម្រាប់អនុវត្ត ជាច្រើន(បច្ចុប្បន្នមាន១២គម្រោង) សំដៅបង្កើនការសិក្សាស្រាវជ្រាវ និងការបញ្ចូលនូវបច្ចេកទេសថ្មីក្នុងការអភិវឌ្ឍ វិស័យព្រៃឈើ និងសត្វព្រៃ។

**ង- ការងារពង្រឹងការអនុវត្តច្បាប់**

គិតចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃ ទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុប មានចំនួន៥ ៨០៣ករណី ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន២ ៧៨៩ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន៣ ០១៤ករណី។ ចំពោះវត្ថុតាងនៃបទល្មើស ព្រៃឈើដែលបានចាប់ឃាត់ និងដកហូត រួមមានឈើមូល-ជ្រុងសរុបមានចំនួន១ ៤០១ម.៣ ឈើអារសរុបចំនួន ១៤ ៥៦៧ម.៣ ឈើគ្រាក់គ្រញូងសរុបចំនួន៧៩,៥ម.៣ និង៣ ១០៨គ.ក្រ. សត្វព្រៃចម្រុះប្រភេទសរុបចំនួន១៦ ៧៧៦ ក្បាល និង ៦ ៦៨៣គ.ក្រ. និងផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ១០ ១២៨ហ.ត.។

## ៤- លទ្ធផលនៃការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម

ប្រទេសកម្ពុជាបានរងគ្រោះដោយសារសង្គ្រាមក្នុងប្រទេសនិងក្នុងតំបន់ ដែលបានអូសបន្លាយចាប់ ពីដើមទស្សវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅខែមករា ឆ្នាំ១៩៧៩

ជម្លោះប្រដាប់អាវុធផ្ទៃក្នុងបានបន្តរហូតដល់ចុងឆ្នាំ១៩៩៨។ ក្នុងកំឡុងពេលសង្គ្រាម ភាគីជម្លោះ ទាំងអស់សុទ្ធតែបានដាក់ពង្រាយគ្រាប់មីន ជាពិសេសនៅខេត្តភាគខាងលិចនិងភាគពាយព្យដែលតាមការប៉ាន់ស្មានគ្រាប់មីនប្រមាណពី៤ ទៅ ៦លានគ្រាប់ ត្រូវបានគេដាក់ពង្រាយលើផ្ទៃប្រទេស។ ចំណែកនៅខេត្តភាគខាងកើតនៃប្រទេសកម្ពុជា មានគ្រាប់បែកចង្កោមនិងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) ផ្សេងទៀតដែលជាលទ្ធផលនៃការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់ក្នុងកំឡុងពេលនៃសង្គ្រាមវៀតណាម។ យោងតាមព័ត៌មានពីក្រសួងការបរទេសសហរដ្ឋអាម៉េរិកបានឱ្យដឹងថា ចាប់ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៣ អាម៉េរិកបានទម្លាក់គ្រាប់បែកចំនួន២,៧៥លានតោន ក្នុងនោះមានគ្រាប់បែកចង្កោមផងដែរ។

ចាប់ពីឆ្នាំ១៩៩២ ដល់ខែកញ្ញា ឆ្នាំ២០២១ ផ្ទៃដីប្រមាណ២ ២៨១គ.ម.$^2$ ត្រូវបានបោសសម្អាត ព្រមទាំងបានរកឃើញនិងកម្ទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន១ ១១២ ៣៤០គ្រាប់ មីនប្រឆាំងរថក្រោះចំនួន២៥ ៦៩៥គ្រាប់ និងស.ផ.ស. ចំនួន២ ៩៣៦ ៣១៥គ្រាប់។ ទោះបីជាកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ធំធេងលើការបោសសម្អាតមីននិងស.ផ.ស. ក៏ដោយក៏កម្ពុជានៅតែប្រឈមនឹងបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងគ្រាប់មីននិងស.ផ.ស. ដែលនៅតែមានលក្ខណៈស្មុគស្មាញ។ ខេត្តភាគពាយព្យនៅតែបន្តទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារមីននិងស.ផ.ស. ខេត្តភាគកណ្តាលទទួលរងផលប៉ះពាល់ក្នុងកម្រិតមធ្យមដោយសារមីននិង ស.ផ.ស. ចំណែកខេត្តភាគខាងកើតទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារគ្រាប់បែកចង្កោម រួមទាំង ស.ផ.ស. ផ្សេងទៀត។ លទ្ធផលនៃការស្រាវជ្រាវចម្ការមីនមូលដ្ឋានបានបង្ហាញថា ផ្ទៃដីចំនួន២ ០៥៧គ.ម.$^2$ នៅមានការគំរាមកំហែងដោយសារមីននិងស.ផ.ស.។

ដើម្បីបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួន រាជរដ្ឋាភិបាលបានបង្កើតគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមួយទៀតរបស់កម្ពុជា គឺគោលដៅទី១៨ ស្តីពីការបញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់គ្រាប់មីននិងស.ផ.ស. និងជំរុញការសង្គ្រោះជនរងគ្រោះ (CSDG18)។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលក៏មានចក្ខុវិស័យច្បាស់លាស់ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលគ្មានគ្រាប់មីននៅត្រឹមឆ្នាំ២០២៥ ហើយការគំរាមកំហែងពី ស.ផ.ស. ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ដើម្បីការអភិវឌ្ឍមនុស្សនិងសេដ្ឋកិច្ចសង្គមប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ កម្ពុជាត្រូវបោសសម្អាតតំបន់ទាំងអស់ដែលដឹងថាមានមីននិងគ្រាប់បែកចង្កោមជាអាទិភាព និងកាត់បន្ថយហានិភ័យដែលនៅសេសសល់បណ្តាលមកពីស.ផ.ស. ផ្សេងទៀតនៅកម្ពុជា និងធ្វើការតស៊ូមតិលើសិទ្ធិនិងផ្តល់សេវាកម្មសម្រាប់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីន និង ស.ផ.ស. ក៏ដូចជាជនរងគ្រោះដោយប្រយោល។

### ៤.១- ការបោសសម្អាតគ្រាប់មីននិងស.ផ.ស.

គិតចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ខែកញ្ញា ឆ្នាំ២០២១ ផ្ទៃដីដែលសង្ស័យមានមីននិងស.ផ.ស. ទំហំ៧១៦គ.ម.$^2$ ត្រូវបានបោសសម្អាតដើម្បីគាំទ្រការអភិវឌ្ឍនិងផ្តល់សុវត្ថិភាពដល់សហគមន៍ ព្រមទាំងបានរកឃើញនិងកម្ទេចចោលគ្រាប់មីនចំនួន៨០ ១០៣គ្រាប់ និងផ.ស.ផ. ចំនួន៣២៩ ៨៧៧គ្រាប់។ ក្នុងរយៈពេល៥ឆ្នាំនេះ ៨៧,២៣% នៃផ្ទៃដីសរុបដែលបានបោសសម្អាតរួច ស្មើនឹង៦២៥គ.ម.$^2$ ត្រូវបានប្រើប្រាស់សម្រាប់វិស័យកសិកម្មដែលមានអ្នកទទួលផលចំនួន៨០៣ ៥៧៨គ្រួសារ ស្មើនឹងប្រជាជនសរុបចំនួន២ ៩៤៣ ១៣៧នាក់ ក្នុងនោះមានស្ត្រីចំនួន១ ៤៤៥ ០៤៤នាក់។ សមិទ្ធផលសំខាន់សរុបសម្រាប់រយៈពេល៣ឆ្នាំនេះ ត្រូវបានពិពណ៌នាលម្អិតដូចខាងក្រោម៖

| សូចនាករសំខាន់ៗ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| ផ្ទៃដីមានមីននិងស.ផ.ស. បានបោសសម្អាត(គ.ម.២) | ១៦៣ | ១៤១ | ១២៧ | ១៥៣ | ១៣២* | **៧១៦** |
| ភាគរយផ្ទៃដីសម្រាប់ធ្វើកសិកម្ម(%) | ៨៥,៥៦% | ៧៩,៧៥% | ៩២,៧៣% | ៩០,៧៣% | ៨៧,៩៦% | **៨៧,២៣%** |
| អ្នកទទួលផលសរុប(នាក់) | ៣៨០ ៧១២ | ៦៦៦ ៨៥៣ | ៨៨០ ២៧៤ | ៥៧៣ ៣៧០ | ៤៤១ ៩២៨ | **២ ៩៤៣ ១៣៧** |
| គ្រាប់មីនរកឃើញនិងកម្ទេចចោល (ចំនួនគ្រាប់) | ១៣ ១០០ | ១៦ ៧៤១ | ១៥ ៧៦៣ | ១៧ ៧០៩ | ១៦ ៧៩០* | **៨០ ១០៣** |
| ស.ផ.ស. រកឃើញ និងកម្ទេចចោល(ចំនួនគ្រាប់) | ៥៨ ៧៤៥ | ៧៧ ៥៦២ | ៧៤ ៤៨៨ | ៦៩ ៣២២ | ៤៩ ៧៦០* | **៣២៩ ៨៧៧** |

សម្គាល់៖(*) គិតពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១

ផ្ទៃដីដែលត្រូវបានបោសសម្អាតទាំងនោះភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ធ្វើកសិកម្មសាងសង់លំនៅឋាន និងបម្រើឱ្យគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានការសាងសង់សាលារៀន មណ្ឌលសុខភាព ផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រព។ ការបោសសម្អាតមីននិងស.ផ.ស. បានផ្តល់អត្ថប្រយោជន៍ ដោយផ្ទាល់ដល់គ្រួសារជាច្រើនដែលរស់នៅក្នុងសហគមន៍ជនបទដាច់ស្រយាល ដែលនេះជាការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច។

### ៤.២- ការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស.

ក្រៅពីការបោសសម្អាតមីននិងស.ផ.ស. ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. នៅតែជាសកម្មភាពចាំបាច់ក្នុងការរួមចំណែកទប់ស្កាត់ការកើនឡើងនៃអត្រាគ្រោះថ្នាក់។ តាមរបាយការណ៍របស់ CMVIS សម្រាប់រយៈពេល៥ឆ្នាំ គិតចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ខែតុលា ឆ្នាំ២០២១ ជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ស្លាប់និងរបួសមានចំនួនសរុប៣០០នាក់ ក្នុងនោះមានស្ត្រីចំនួន២២នាក់ និងកុមារចំនួន៨០នាក់។

| ជនរងគ្រោះដោយសារមីន និង ស.ផ.ស. (ស្លាប់/របួស) | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| បុរស | ៣៥ | ៣៦ | ៥៥ | ៤២ | ៣០* | **១៩៨** |
| ស្ត្រី | ៥ | ៦ | ៦ | ៤ | ១* | **២២** |
| កុមារ | ១៨ | ១៦ | ១៦ | ១៩ | ១១* | **៨០** |
| សរុប | ៥៨ | ៥៨ | ៧៧ | ៦៥ | ៤២* | **៣០០** |

**សម្គាល់៖** (*) គិតចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២១

ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ក៏ជាសកម្មភាពមួយយ៉ាងសំខាន់ក្នុងការកាត់បន្ថយគ្រោះថ្នាក់គិតចាប់ខែមករា ឆ្នាំ២០១៧ ដល់ខែតុលា ឆ្នាំ២០២១ ប្រជាពលរដ្ឋចំនួន៣ ៣០៤ ៧០៨នាក់ បានទទួលសារអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ពីប្រតិបត្តិករបណ្តាញអប់រំតាមសហគមន៍ និងអាជ្ញាធរមានសមត្ថកិច្ច។ ជាមួយគ្នានេះ អាជ្ញាធរមីនបានសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ជ្រាបការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ទៅក្នុងកម្មវិធីសិក្សាថ្នាក់ទី៧ និងថ្នាក់ទី៨ និងបន្តពិភាក្សាអំពីលទ្ធភាពដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី៩ បន្ថែមទៀត។

### ៤.៣- ការគាំទ្រខាងផ្នែកសម្ភារៈដល់កងទ័ពជើងគោកនិងបោសសម្អាតមីនតាមព្រំដែន

ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មអន្តរជាតិ កម្ពុជាបានបង្កើតតំបន់សេដ្ឋកិច្ចពិសេសមួយចំនួននៅតាមតំបន់បណ្តោយព្រំដែនជាមួយប្រទេសជិតខាង ដែលនាំឱ្យមានកំណើនប្រជាជននិងការពង្រីកសហគមន៍នៅក្នុងតំបន់នោះ។ ដោយហេតុថាតំបន់ដែលមានមីនភាគច្រើនស្ថិតនៅតាមបណ្តោយព្រំដែនភាគពាយព្យ គួបផ្សំនឹងកំណើនប្រជាជននិងសកម្មភាពអភិវឌ្ឍន៍ នាំឱ្យមានហានិភ័យខ្ពស់នៅក្នុងតំបន់នោះ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ អាជ្ញាធរមីននឹងបន្តស្វែងរកជំនួយដើម្បីបំពាក់សម្ភារៈនិងផ្តល់ការហ្វឹកហ្វឺនដល់កងយោធពលខេមរភូមិន្ទចំនួន២ ០០០នាក់ ឱ្យចូលរួមបោសសម្អាតមីនតាមតំបន់ព្រំដែន។ ប៉ុន្តែការងារនេះនៅមិនទាន់សម្រេចបានតាមផែនការនៅឡើយ។

### ៤.៤- ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងអាជ្ញាធរមីន និងក្រសួងពាក់ព័ន្ធ

អាជ្ញាធរមីននឹងជួបជាលក្ខណៈទ្វេភាគី ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងបរិស្ថាន ដើម្បីពិភាក្សាពីការបោសសម្អាតចម្ការមីន និងស.ផ.ស. នៅក្នុងតំបន់ដែលគ្រប់គ្រងដោយបណ្តាក្រសួងទាំងនោះ ក្នុងគោលបំណង ប្រែក្លាយកម្ពុជាជាប្រទេសដែលគ្មានមីនត្រឹមឆ្នាំ២០២៥។

### ៤.៥- ការកៀរគរនិងតម្រូវការធនធាន

ដើម្បីសម្រេចបានតាមគោលបំណងកម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥ វិស័យមីនកម្ពុជាត្រូវការថវិកាប្រមាណ៥២លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ។ ប៉ុន្តែជាក់ស្តែង ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ វិស័យនេះទទួលបានថវិកាប្រមាណ៣០លានដុល្លារអាម៉េរិកតែប៉ុណ្ណោះក្នុងមួយឆ្នាំ ឬប្រមាណ៦០%នៃតម្រូវការថវិកាប្រចាំឆ្នាំ។ ដើម្បីសម្រេចនូវគោលបំណងត្រឹមឆ្នាំ២០២៥ គិតចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ វិស័យមីនត្រូវការថវិកាចំនួន ៦៦,៦៥ លានដុល្លារអាម៉េរិក ក្នុងមួយឆ្នាំៗ ដែលក្នុងនោះថវិកាចំនួន៤៥លានដុល្លារអាម៉េរិក ដើម្បីបោសសម្អាតផ្ទៃដីដែលមានមីន១៥លានដុល្លារអាម៉េរិក សម្រាប់បោសសម្អាតផ្ទៃដីដែលមានគ្រាប់បែកចង្កោមនិង០,៦៥លានដុល្លារអាម៉េរិកសម្រាប់ដោះស្រាយបញ្ហាស.ផ.ស. ផ្សេងទៀត ហើយ៦លានដុល្លារអាម៉េរិក សម្រាប់កិច្ចការគ្រប់គ្រង សម្របសម្រួល និងត្រួតពិនិត្យទូទាំងវិស័យ។ ហេតុនេះ អាជ្ញាធរមីននឹងបង្កើនកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលមានស្រាប់ដៃគូអភិវឌ្ឍន៍ថ្មីៗវិស័យឯកជននិងសមាគមនានា ដើម្បីកៀរគរធនធានតាមផែនការពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។ ជាមួយគ្នានេះ យើងនឹងបន្តពិភាក្សាជំរុញការបន្ថែមថវិកាចូលរួមរបស់រាជរដ្ឋាភិបាលតាមលទ្ធភាពដែលអាចធ្វើទៅបាន។

## ៥- វឌ្ឍនភាពនៃការអនុវត្តលើវិស័យធនធានទឹកនិងឧតុនិយម ក្នុងឆ្នាំ(២០១៧-២០២១)

ដើម្បីពង្រឹងស្ថាប័ននិងសមត្ថភាពចំណេះដឹងថ្មីៗដល់មន្ត្រីរាជការ ក្រសួងធនធានទឹក និងឧតុនិយមបញ្ជូនមន្ត្រីរាជការចូលរួមក្នុងសិក្ខាសាលា និងបានបណ្តុះបណ្តាលដល់មន្ត្រីគ្រប់លំដាប់ថ្នាក់នូវមុខវិជ្ជាពាក់ព័ន្ធដល់កិច្ចអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយមទាំងក្នុងប្រទេសនិងក្រៅប្រទេស ដោយមានការយកចិត្តទុកដាក់និងលើកទឹកចិត្តដល់មន្ត្រីជាស្ត្រីឱ្យចូលរួមផងដែរ។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | បណ្តុះបណ្តាល(នាក់) | | | សិក្ខាសាលា(នាក់) | | |
|---|---|---|---|---|---|---|
| | ក្នុងប្រទេស | ក្រៅប្រទេស | សរុប | ក្នុងប្រទេស | ក្រៅប្រទេស | សរុប |
| ២០១៧ | ១៥៥ | ២៥ | ១៨០ | ២០៦ | ៣៥ | ២៤១ |
| ២០១៨ | ១៩១ | ១៧ | ២០៨ | ២៧៤ | ៣៣ | ៣០៧ |

| | | | | | | |
|---|---|---|---|---|---|---|
| ២០១៩ | ២៣៧ | ១៩ | ២៥៦ | ២៩៦ | ៣២ | ៣២៨ |
| ២០២០ | ១៦៩ | ៥ | ១៧៤ | ១៥៦ | ៧ | ១៦៣ |
| ២០២១ | ៩៤ | ០ | ៩៤ | ១៣៣ | ០ | ១៣៣ |
| **សរុប** | **៨៤៦** | **៦៦** | **៩១២** | **១ ០៦៥** | **១០៧** | **១ ១៧២** |

ក្រៅពីនេះក្រសួងបានបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា មានដូចខាងក្រោម៖

| ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| ចំនួន | ១៣លើក | ២៤លើក | ២៩លើក | ១១លើក | ២លើក | ៧៩លើក |

## ៥.១- ការស្តារនិងការសាងសង់ប្រព័ន្ធធារាសាស្ត្រ

**ក្រសួងធនធានទឹក និងឧតុនិយមសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖**

**ក- ជួសជុល ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ដើម្បីបង្កើនលទ្ធភាពស្រោចស្រព**

បានធ្វើការជួសជុល-ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រទាំងតូចទាំងធំនៅទូទាំងប្រទេស ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) ហើយសម្រេចបាន២៦៧គម្រោង ដែលបានបង្កើនលទ្ធភាព ស្រោចស្រព លើផ្ទៃដីដំណាំស្រូវសរុប ចំនួន១៤៥ ៥១៦ហ.ត. ក្នុងនោះ (ស្រូវវស្សា៩៩ ៧២៨ហ.ត. និងស្រូវប្រាំង ៤៥ ៧៨៨ហ.ត.) និងស្រោចស្រពដំណាំរួមផ្សំបាន៣ ២២៣ហ.ត. ចំណាយថវិកា សរុបចំនួន៧២០ ៥៤៣ ៥០៦ ០០០ រៀល និង២៣៧ ៦៥៨ដុល្លារអាមេរិក។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ថវិកាចំណាយ | | បង្កើនលទ្ធភាពស្រោចស្រព (ហ.ត.) | | | |
|---|---|---|---|---|---|---|---|
| | | ជារៀល | ជាដុល្លារ | វស្សា | ប្រាំង | សរុប | ដំណាំ |
| ២០១៧ | ៥៣ | ១៣៥ ១២៥ ៥១១ ០០០ | ៩៧ ៦៥៨ | ២៥ ៨០៩ | ៩ ៩៥៩ | ៣៥ ៧៦៨ | ៥៦៤ |
| ២០១៨ | ៦៦ | ១៥២ ៨៨៦ ៤០៥ ០០០ | | ១៦ ៧០២ | ៦ ២៩៣ | ២២ ៩៩៥ | ៤៥១ |
| ២០១៩ | ៥២ | ១៦១ ០៤០ ៩៥៨ ០០០ | | ២២ ៣១៥ | ១០ ៧៤៨ | ៣៣ ០៦៣ | ៤១២ |
| ២០២០ | ៥៩ | ១៥០ ៧៥៨ ១៣២ ០០០ | ១៤០ ០០០ | ១៩ ៣០១ | ១១ ៨០១ | ៣១ ១០២ | ៥៣៥ |
| ២០២១ | ២៧ | ១២០ ៧៣២ ៥០០ ០០០ | | ១៥ ៦០១ | ៦ ៩៨៧ | ២២ ៥៨៨ | ១ ២៦១ |
| **សរុប** | **២៥៧** | **៧២០ ៥៤៣ ៥០៦ ០០០** | **២៣៧ ៦៥៨** | **៩៩ ៧២៨** | **៤៥ ៧៨៨** | **១៤៥ ៥១៦** | **៣ ២២៣** |

**ខ- កិច្ចដំណើរការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំនិងខួប ដើម្បីរក្សានិរន្តរភាពស្រោចស្រព**

បានអនុវត្តកិច្ចដំណើរការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំនិងខួបទាំងតូចទាំងធំនៅទូទាំងប្រទេសក្នុង រយៈពេល៥ឆ្នាំ(២០១៧-២០២១) លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ថវិកាចំណាយ | | រក្សានិរន្តរភាពនៃលទ្ធភាពស្រោចស្រព (ហ.ត.) | | | |
|---|---|---|---|---|---|---|---|
| | | ជារៀល | ជាដុល្លារ | វស្សា | ប្រាំង | សរុប | ដំណាំ |
| ២០១៧ | ១៧៥ | ៣២ ៧៤១ ៣៧៨ ០០០ | | ២៤២ ០០៧ | ៧១ ៨៩៣ | ៣១៣ ៩០០ | ១ ០៦៩ |
| ២០១៨ | ១៩២ | ៤១ ៧៣៥ ៤៤០ ០០០ | | ៣៩៥ ២៣៩ | ៩០ ៤៥៩ | ៤៨៥ ៦៩៨ | ១ ៥៥៦ |
| ២០១៩ | ១៩៩ | ៥៨ ៤០៤ ៨៧៣ ០០០ | | ៤០៩ ២៦៧ | ៩០ ៤៧៣ | ៤៩៩ ៧៤០ | ១ ៩២៤ |
| ២០២០ | ១៦៥ | ៦៣ ០៤០ ៦៨៧ ០០០ | | ៤៣៣ ០៩៥ | ៨៨ ៦៧២ | ៥២១ ៨៥៧ | ២ ៣១៩ |
| ២០២១ | ២០៥ | ១០៤ ១៨៦ ៩៩៣ ០០០ | | ៥៧៥ ៧៦៥ | ១១៥ ៤៥៦ | ៦៩១ ២២១ | ៣ ៦៤៦ |
| សរុប | ៩៣៦ | ៣០០ ១០៩ ៣៧១ ០០០ | | | | | |

## ៥.២- ការជួសជុល ថែទាំសំណង់សិល្បការ

ក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយមរាជធានី ខេត្ត បានធ្វើការជួសជុល ថែទាំ សំណង់សិល្បការតាមបណ្ដាប្រព័ន្ធធារាសាស្ត្រ ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) សម្រេចបាន រួមមានសំណង់ទ្វារទឹកសរុបចំនួន ១៤៦កន្លែង សំណង់លូទឹក សរុបចំនួន៩៧កន្លែង សំណង់ស្នាក់ទឹក សរុបចំនួន៤៨កន្លែង និងសំណង់បង្ហៀរទឹក សរុបចំនួន១៤កន្លែង ថវិកាចំណាយ១ ២៣៤ ១១៩ ៥០០រៀល។លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ទ្វារទឹក (កន្លែង) | លូទឹក (កន្លែង) | ស្នាក់ទឹក (កន្លែង) | បង្ហៀរ (កន្លែង) | ថវិកាចំណាយ | |
|---|---|---|---|---|---|---|
| | | | | | ជារៀល | ជាដុល្លារ |
| ២០១៧ | ៤២ | ១០ | ៥ | ១ | | |
| ២០១៨ | ២២ | ២៥ | ២ | ៥ | ៩៣២ ៥៦៦ ០០០ | |
| ២០១៩ | ៣៤ | ៤២ | ៣៧ | ៣ | ២៩១ ៥០០ ៥០០ | |
| ២០២០ | ៤០ | ៥ | ៣ | ១ | ១០ ០៥៣ ០០០ | |
| ២០២១ | ៨ | ១៥ | ១ | ៤ | - | |
| សរុប | ១៤៦ | ៩៧ | ៤៨ | ១៤ | ១ ២៣៤ ១១៩ ៥០០ | |

## ៥.៣- ការជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រដោយមានប្រជាពលរដ្ឋចូលរួម

### ៥.៣.១- ការជួសជុល ថែទាំទំនប់

បានធ្វើការជួសជុលថែទាំទំនប់ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) នៅតាមបណ្ដាខេត្តសរុបចំនួន ៩២កន្លែង ប្រវែង៩៨ ៧៦៨ម សាច់ដីសរុបចំនួន៣ ៤៨១ម៣ ប្រើប្រាស់គ្រឿងចក្រ ចំណាយថវិកា៦ ២៥៧ ០០០ រៀល និង៩២ ៩៥៨ដុល្លារ។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួន កន្លែង | ប្រវែង(ម.) | សាច់ដី(ម.៣) | គ្រឿងចក្រ/ពលករ(នាក់) | ថវិកាចំណាយ | |
|---|---|---|---|---|---|---|
| | | | | | ជារៀល | ជាដុល្លារ |
| ២០១៧ | ១៦ | ១២ ៤៥៧ | ២ ០៣៣ | គ្រឿងចក្រ | ៥ ០០០ ០០០ | ៨០០ |
| ២០១៨ | ៩ | ៨ ៩៨០ | | គ្រឿងចក្រ | | |
| ២០១៩ | ១៥ | ២៦ ៧២៤ | ១ ០៤៤ | គ្រឿងចក្រ | ១ ២៧៥ ០០០ | ២ ០០០ |
| ២០២០ | ៣១ | ៣៩ ៨៤០ | - | គ្រឿងចក្រ | - | - |
| ២០២១ | ២១ | ១០ ៧៦៧ | ៤០៤ | គ្រឿងចក្រ | - | ៩០ ១៥៨ |
| សរុប | ៩២ | ៩៨ ៧៦៨ | ៣ ៤៨១ | | ៦ ២៥៧ ០០០ | ៩២ ៩៥៨ |

### ៥.៣.២- ការងារជីក ស្ដារប្រឡាយ

បានធ្វើការងារជីក ស្ដារប្រឡាយក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) នៅតាមបណ្ដាខេត្តសរុបចំនួន២៦៥ខ្សែ ប្រវែង៥៨៨ ៧៣៥ម. សាច់ដីសរុបចំនួន៩៧៥ ១១៨ម.៣ ប្រើប្រាស់គ្រឿងចក្រ បានចំណាយថវិកា ៤៣១ ៧៩០ ០០០រៀល និង៨ ៥០០ដុល្លារអាម៉េរិក។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនខ្សែ | ប្រវែង(ម.) | សាច់ដី(ម.៣) | ពលករ (នាក់) | ថវិកាចំណាយ | |
|---|---|---|---|---|---|---|
| | | | | | ជារៀល | ជាដុល្លារ |
| ២០១៧ | ២៧ | ៥១ ០៣៨ | ៣៦ ៤៦០ | | | |
| ២០១៨ | ៧២ | ១៧៧ ០៣៨ | ១២៥ ៥៣៤ | | ៣២៣ ៤៩៤ ០០០ | ៨ ៥០០ |
| ២០១៩ | ៥២ | ៩៨ ៦០៧ | ២៦ ៧២៤ | គ្រឿងចក្រ | ៤៣ ៥៦៨ ០០០ | |

| | | | | | | |
|---|---|---|---|---|---|---|
| ២០២០ | ៧១ | ១៤១ ៩៦៨ | ២៨៦ ០៤៣ | គ្រឿងចក្រ | ៦៤ ៧២៨ ០០០ | |
| ២០២១ | ៤៣ | ១២០ ០៨៤ | ១០០ ៣៥៧ | គ្រឿងចក្រ | - | |
| **សរុប** | **២៦៥** | **៥៨៨ ៧៣៥** | **៥៧៥ ១១៨** | | **៤៣១ ៧៩០ ០០០** | **៨ ៥០០** |

## ៥.៤- ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក

### ៥.៤.១- រៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

ក្រសួងនិងមន្ទីរបានរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមប្រព័ន្ធធារាសាស្ត្រ ក្នុងរយៈពេល៥ឆ្នាំ (២០១៧-២០២១)នៅតាមបណ្តាលខេត្ត ហើយសម្រេចបានសរុបចំនួន១១១សហគមន៍ ដែលមានផ្ទៃដីស្រូវសរុប២៩៤ ០២០ហ.ត. ក្នុងនោះ(ផ្ទៃដីស្រូវវស្សា២១៤ ៦៥៣ ហ.ត. ស្រូវប្រាំង៧៩ ៣៦៧ហ.ត. និងមាន៧៣ ៥៥៤ គ្រួសារ)។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនសហគមន៍ | ផ្ទៃដីដំណាំស្រូវ | | | ចំនួនគ្រួសារ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ស្រូវវស្សា(ហ.ត.) | ស្រូវប្រាំង(ហ.ត.) | សរុប(ហ.ត.) | | |
| ២០១៧ | ៣៧ | ៧៤ ៧៤៣ | ១៩ ៣៩៩ | ៩៤ ១៤២ | ៣១ ៩៣៣ | |
| ២០១៨ | ២៧ | ៣២ ៣៧៧ | ១៣ ៩៧៧ | ៤៦ ៣៥៤ | ១៤ ០៣៦ | |
| ២១០៩ | ១៣ | ២៨ ៩៥៥ | ៤ ៤០៣ | ៣៣ ៣៥៨ | ២១ ៣០៨ | |
| ២០២០ | ២២ | ២១ ៥២៧ | ៣ ៥៣១ | ២៥ ០៥៨ | ៥ ៨៣៧ | |
| ២០២១ | ១២ | ៥៧ ០៥១ | ៣៨ ០៥៧ | ៩៥ ១០៨ | ៤៤០ | |
| **សរុប** | **១១១** | **២១៤ ៦៥៣** | **៧៩ ៣៦៧** | **២៩៤ ០២០** | **៧៣ ៥៥៤** | |

### ៥.៤.២- ការងារចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកដែលបានបង្កើតរួច

មន្ទីរធនធានទឹកនិងឧតុនិយម តាមបណ្តារាជធានី ខេត្តបានធ្វើការចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមប្រព័ន្ធធារាសាស្ត្របានសរុបចំនួន១៣៥កន្លែង ក្នុងនោះ ខេត្តស្វាយរៀង៦កន្លែង ខេត្តព្រៃវែង៨កន្លែង ខេត្តត្បូងឃ្មុំ៧កន្លែង ខេត្តកំពង់ចាម១០កន្លែង ខេត្តកណ្តាល៧កន្លែង រាជធានីភ្នំពេញ២កន្លែង ខេត្តតាកែវ៥កន្លែង ខេត្តកំពត៨កន្លែង ខេត្តកំពង់ស្ពឺ១១កន្លែង ខេត្តកែប៣កន្លែង ខេត្តព្រះសីហនុ៤កន្លែង ខេត្តកោះកុង២កន្លែង ខេត្តកំពង់ឆ្នាំង១០កន្លែង ខេត្តពោធិ៍សាត់៩កន្លែង ខេត្តបាត់ដំបង១១កន្លែង ខេត្តប៉ៃលិន២កន្លែង ខេត្តបន្ទាយមានជ័យ៤កន្លែង ខេត្តឧត្តរមានជ័យ៤កន្លែង ខេត្តកំពង់ធំ៥កន្លែង ខេត្តព្រះវិហារ២កន្លែង ខេត្តក្រចេះ៣កន្លែង ខេត្តស្ទឹងត្រែង២កន្លែង ខេត្តរតនគិរី៣កន្លែង ខេត្តមណ្ឌលគិរី៣កន្លែង និងខេត្តសៀមរាប៤កន្លែង។

## ៥.៥- ការគ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត(ក្នុងយុទ្ធសាស្ត្រទី៣របស់ក្រសួង)

ក្រសួងសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖

### ៥.៥.១- ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ទឹកប្រៃ

ទឹកជំនន់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានបណ្តាលឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេដ្ឋកិច្ចសង្គមជាច្រើន ដោយសារការប្រែប្រួលអាកាសធាតុ។ ក្រសួងធនធានទឹក និងឧតុនិយមបានធ្វើការជួសជុលទំនប់ទប់ស្កាត់**ទឹកជំនន់ និងទឹកប្រៃ** ដូចមានខាងក្រោម៖

### ៥.៥.២- ទប់ស្កាត់ទឹកជំនន់

#### ក- ការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកជំនន់(ដើម្បីបង្កើនលទ្ធភាពការពារ)

បានធ្វើការជួសជុលទំនប់ការពារទប់ស្កាត់ទឹកជំនន់ស្រុកពញាឮខេត្តកណ្តាលក្នុងរយៈពេល៥ឆ្នាំ (២០១៧-២០២១) បានចំនួន១គម្រោង ដែលមានលទ្ធភាពការពារផ្ទៃដីសរុបចំនួន១០០ហ.ត. ដែលបានចំណាយថវិការាជរដ្ឋាភិបាលសរុបចំនួន៧០០ ៥០០ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ចំណាយ | | រក្សានិរន្តរភាពលទ្ធភាពការពារ(ហ.ត.) | | | |
|---|---|---|---|---|---|---|---|
| | | រៀល | ដុល្លារ | លំនៅឋាន | ស្រូវ | ដំណាំ | សរុប |
| ២០១៧ | ០ | - | | - | - | - | - |
| ២០១៨ | ០ | - | | - | - | - | - |
| ២០១៩ | ១ | ៧០០ ៥០០ ០០០ | | ១០០ | - | - | ១០០ |
| ២០២០ | ០ | - | | - | - | - | - |
| ២០២១ | ០ | - | | - | - | - | - |
| សរុប | ១ | ៧០០ ៥០០ ០០០ | | ១០០ | | | ១០០ |

**ខ- ការជួសជុល ថែទាំទំនប់ជាប្រចាំ(ដើម្បីរក្សានិរន្តរភាពនៃការពារទប់ស្កាត់ទឹកជំនន់)**

បានធ្វើការជួសជុល ថែទាំ ទំនប់ការពារទប់ស្កាត់ទឹកជំនន់ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១)បានចំនួន៦គម្រោង ដែលបានចំណាយថវិការបស់រាជរដ្ឋាភិបាល សរុបចំនួន ២ ៨៦០ ០៥២ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ចំណាយ | | រក្សានិរន្តរភាពលទ្ធភាពការពារ(ហ.ត) | | | |
|---|---|---|---|---|---|---|---|
| | | រៀល | ដុល្លារ | លំនៅឋាន | ស្រូវ | ដំណាំ | សរុប |
| ២០១៧ | ១ | ៣៧៧ ៣៦៤ ០០០ | | ២ ៣២០ | ១ ៤៨១ | ០ | ៣ ៨០១ |
| ២០១៨ | ១ | ៥៧៤ ៥៦០ ០០០ | | ២ ៣២០ | ១ ៤៨១ | ០ | ៣ ៨០១ |
| ២០១៩ | ២ | ៩៣២ ៣២១ ០០០ | | ៣ ៤២០ | ១ ៤៨១ | ០ | ៤ ៩០១ |
| ២០២០ | ១ | ៥២៦ ៨៣០ ០០០ | | ២ ៣២០ | ១ ៤៨១ | ០ | ៣ ៨០១ |
| ២០២១ | ១ | ៤៤៨ ៩៧៧ ០០០ | | ២ ៣២០ | ១ ៤៨១ | ០ | ៣ ៨០១ |
| សរុប | ៦ | ២ ៨៦០ ០៥២ ០០០ | | | | | |

**គ- ការការពារច្រាំងទន្លេ ដើម្បីការពារទប់ស្កាត់ទឹកជំនន់**

ក្រសួងបានអនុវត្តការងាររៀបចំការពារច្រាំងទន្លេនៅក្នុងខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១)សម្រេចបានសរុបចំនួន២៤គម្រោង ដែលសរុបមាន ប្រវែង ២៦ ៩២៦ម ហើយបានចំណាយថវិការាជរដ្ឋាភិបាលសរុបចំនួន ១៧៣ ០៦១ ០០០ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ចំណាយថវិកា(រៀល) | លទ្ធផលសម្រេចបានប្រវែង(ម) | ផ្សេងៗ |
|---|---|---|---|---|
| ២០១៧ | ១ | ៩៤៧ ០០០ ០០០ | ៣៨ | |
| ២០១៨ | ១ | ២ ២៤៨ ០០០ ០០០ | ១៤៨ | |
| ២០១៩ | ៣ | ៨៤ ០៦២ ០០០ ០០០ | ១៣ ៥៩៥ | |
| ២០២០ | ៨ | ៤៤ ៣៤៩ ០០០ ០០០ | ៧ ២៦០ | |
| ២០២១ | ៣ | ៤១ ៤៥៥ ០០០ ០០០ | ៥ ៨៤៥ | |
| សរុប | ២៤ | ១៧៣ ០៦១ ០០០ ០០០ | ២៦ ៩២៦ | |

**៥.៥.៣- ទប់ស្កាត់ទឹកប្រៃ៖**

**ក- ការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃ**

ក្រសួងបានធ្វើការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃ ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) បានចំនួន៦គម្រោង នៅខេត្តកោះកុង ចំណាយថវិកាសរុបចំនួន១៥ ៤៦៣ ០០០ ០០០រៀល ហើយការពារ

ទប់ស្កាត់ទឹកប្រៃ កុំឱ្យប៉ះពាល់ផ្ទៃដី សរុបចំនួន២ ៥៩៥ហ.ត. ក្នុងនោះ(លំនៅឋាន៩៧ហ.ត. ស្រូវវស្សា២ ៣៨១ ហ.ត. ស្រូវប្រាំង៣០ហ.ត. និងដំណាំ៨៧ហ.ត.)។ លទ្ធផលសម្រេចបានរួមមានតាម បណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួន គម្រោង | ចំណាយ | បង្កើនលទ្ធភាពការពារ(ហ.ត.) | | | | |
|---|---|---|---|---|---|---|---|
| | | រៀល | លំនៅឋាន | ស្រូវវស្សា | ស្រូវប្រាំង | ដំណាំ | សរុប |
| ២០១៧ | ១ | ២ ០០១ ៥០០ ០០០ | | ២៨២ | | | ២៨២ |
| ២០១៨ | ១ | ២ ៥២៩ ០០០ ០០០ | | ៧៨ | | | ៧៨ |
| ២០១៩ | ២ | ៦ ៦៣៩ ០០០ ០០០ | ០ | ៦២៥ | ៣០ | ២០ | ៦៧៥ |
| ២០២០ | ១ | ២ ១៨២ ០០០ ០០០ | ០ | ៤៦៣ | ០ | ៧ | ៤៧០ |
| ២០២១ | ១ | ២ ១១១ ៥០០ ០០០ | ៩៧ | ៩៣៣ | ០ | ៦០ | ១ ០៩០ |
| **សរុប** | **៦** | **១៥ ៤៦៣ ០០០ ០០០** | **៩៧** | **២ ៣៨១** | **៣០** | **៨៧** | **២ ៥៩៥** |

**ខ- ការជួសជុល ថែទាំទំនប់ជាប្រចាំ ដើម្បីរក្សានិរន្តរភាពនៃការពារទប់ស្កាត់ទឹកប្រៃ**

បានធ្វើការជួសជុល និងថែទាំជាប្រចាំនូវបណ្តាទំនប់ការពារទប់ស្កាត់ទឹកប្រៃក្នុងរយៈពេល៥ឆ្នាំ (២០១៧-២០២១) បានចំនួន៧០គម្រោង នៅខេត្តកោះកុង និងខេត្តព្រះសីហនុ ចំណាយថវិការបស់រាជរដ្ឋាភិបាល សរុបចំនួន១១ ៣០៥ ៩១១ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួន គម្រោង | ចំណាយ | រក្សានិរន្តរភាពនៃលទ្ធភាពការពារ(ហ.ត.) | | | | |
|---|---|---|---|---|---|---|---|
| | | រៀល | លំនៅឋាន | ស្រូវវស្សា | ស្រូវប្រាំង | ដំណាំ | សរុប |
| ២០១៧ | ១៤ | ១ ២៤១ ៩៦៨ ០០០ | | ១២ ០៧៤ | | | ១២ ០៧៤ |
| ២០១៨ | ១៦ | ១ ២៥៩ ២០០ ០០០ | ៣៨៦ | ១៥ ៤០៣ | ០ | ១១០ | ១៥ ៨៩៩ |
| ២០១៩ | ១៦ | ១ ២៦៨ ២៨០ ០០០ | ៣៨៦ | ១៥ ៤០៣ | ០ | ១១០ | ១៥ ៨៩៩ |
| ២០២០ | ១២ | ៥ ៨១៧ ២៤០ ០០០ | ៣៨៦ | ១៤ ០៥៦ | ៣០ | ១២០ | ១៤ ៥៩២ |
| ២០២១ | ១២ | ១ ៧១៩ ២២៣ ០០០ | ០ | ១៣ ៧២៨ | ០ | ៣៥ | ១៣ ៧៦៣ |
| **សរុប** | **៧០** | **១១ ៣០៥ ៩១១ ០០០** | | | | | |

## ៥.៦- ការគ្រប់គ្រងនិងការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត

គ្រោះរាំងស្ងួតតែងកើតមានឡើង ដោយការប្រែប្រួលអាកាសធាតុ និងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ ផលិតផលកសិកម្ម ដែលជាហេតុបណ្តាលឱ្យទិន្នផលស្រូវធ្លាក់ចុះ ធ្វើឱ្យប្រជាកសិករមានចំណូលទាប។ ក្នុងន័យនេះ ការអន្តរាគមន៍ដោយម៉ាស៊ីនបូមទឹក ដែលជួយដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើរតួយ៉ាងសំខាន់ ក្នុងការសង្គ្រោះ បន្ធូរបន្ថយ និងកែលម្អដំណាំកសិកម្មដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត។

### ៥.៦.១- ការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត

ក្រសួងធនធានទឹក និងឧតុនិយម បានប្រមូលផ្តុំនូវម៉ាស៊ីនបូមទឹក និងមធ្យោបាយចាំបាច់នានា ក្នុង ការអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ ដែលប៉ះពាល់ពីគ្រោះរាំងស្ងួតក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១)បាន ចំណាយប្រេងម៉ាស៊ូតសរុបចំនួន៤ ៩៣៤ ៧០០លីត្រ និងប្រេងម៉ាស៊ីនសរុបចំនួន៤១ ៦៤០លីត្រ ។ លទ្ធផល សម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ការប្រើប្រាស់ប្រេង | | ផ្ទៃដីស្រូវសង្គ្រោះបាន | | |
|---|---|---|---|---|---|
| | ប្រេងម៉ាស៊ូត(ល) | ប្រេងរំអិល(ល) | ប្រាំង(ហ.ត.) | វស្សា(ហ.ត.) | សរុប |
| ២០១៧ | ៦៨៩ ០០០ | ៦ ៨៤០ | ៣១ ៥១៩ | ២២ ៩៣១ | ៥៤ ៤៥០ |
| ២០១៨ | ១ ០៦០ ០០០ | ៨ ៩០០ | ៣៧ ៥៦៨ | ៥៥ ៧១៩ | ៩៣ ២៨៧ |
| ២០១៩ | ១ ១៤០ ០០០ | ៥ ៦០០ | ៤៧ ៨៩២ | ៤២ ២៩៧ | ៩០ ១៨៩ |
| ២០២០ | ១ ១៥០ ៧០០ | ១១ ៣៥០ | ៥៨ ៧៣៩ | ៣៤ ៤៤៥ | ៩៣ ១៨៤ |
| ២០២១ | ៨៩៥ ០០០ | ៨ ៩៥០ | ៥០ ២៧៣ | ៣៣ ០៥៥ | ៨៣ ៣២៨ |
| **សរុប** | **៤ ៩៣៤ ៧០០** | **៤១ ៦៤០** | | | |

ក្រៅពីការងារអន្តរាគមន៍សង្គ្រោះស្រូវ ដោយម៉ាស៊ីនបូមទឹក ក៏មានការងារសង្គ្រោះស្រូវដោយប្រព័ន្ធធារាសាស្ត្រ (បង្ហូរ) មានដូចបណ្តាឆ្នាំខាងក្រោម៖

| ឆ្នាំ | លទ្ធផលបង្ហូរសង្គ្រោះ | | | ផ្សេងៗ |
|---|---|---|---|---|
| | ប្រាំង(ហ.ត.) | វស្សា(ហ.ត.) | សរុប | |
| ២០១៧ | ៨៤៩ | ១ ២៣៨ | ២ ០៨៧ | |
| ២០១៨ | ២ ៥៣២ | ៩០០ | ៣ ៤៣២ | |
| ២០១៩ | ៥៨២ | ៨៣៩ | ១ ៤២១ | |
| ២០២០ | ៥៤៩ | ១ ២៥៧ | ១ ៨០៦ | |
| ២០២១ | ៨៩៧ | ៦៥០ | ១ ៥៤៧ | |

### ៥.៦.២- ការដំឡើង ជួសជុល ស្ថានីយបូមទឹក និងម៉ាស៊ីនបូមទឹក

ដើម្បីឱ្យការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវបានសម្រេច ក្រសួងបានធ្វើការ៖

សាងសង់ស្ថានីយបូមទឹកបានចំនួន២កន្លែង ជួសជុលស្ថានីយបូមទឹកបានចំនួន១៧កន្លែង និងធ្វើការជួសជុលម៉ាស៊ីនបូមទឹកចល័តបានចំនួន១៤៣គ្រឿង ដោយចំណាយថវិការបស់រាជរដ្ឋាភិបាល សរុបចំនួន ៣ ៤៨៩ ៧៩៨ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | សាងសង ស្ថានីយ (កន្លែង) | ជួសជុល ស្ថានីយ (កន្លែង) | ជួសជុល ម៉ាស៊ីន (កន្លែង) | ចំណាយថវិកា | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | រៀល | ដុល្លារ | |
| ២០១៧ | | ៣ | ២៧ | ៦៩៦ ៥០០ ០០០ | | |
| ២០១៨ | | ២ | ២១ | ៦៧៤ ៥០០ ០០០ | | |
| ២០១៩ | | ៣ | ៤៩ | ៧២៧ ៥៥៨ ០០០ | | |
| ២០២០ | ២ | ៦ | ២៣ | ៦៨១ ៧៤០ ០០០ | | |
| ២០២១ | | ៣ | ២៣ | ៧០៩ ៥០០ ០០០ | | |
| **សរុប** | **២** | **១៧** | **១៤៣** | **៣ ៤៨៩ ៧៩៨ ០០០** | | |

## ៥.៧- ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹក និងឧតុនិយម(ក្នុងយុទ្ធសាស្ត្រទី៤របស់ក្រសួង)

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការប្រែប្រួលអាកាសធាតុបានបណ្តាលឱ្យកើតមានឡើងនូវគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលជាគ្រោះធម្មជាតិដ៏ធំ បានធ្វើឱ្យបាត់បង់ដល់អាយុជីវិតមនុស្ស សត្វ ខូចខាតទ្រព្យសម្បត្តិសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន។ ដើម្បីទប់ទល់ និងកាត់បន្ថយនូវគ្រោះមហន្តរាយធម្មជាតិនេះ

ទាមទារឱ្យមានការដំឡើងស្ថានីយឧតុនិយមនិងស្ថានីយជលសាស្ត្រ នៅតាមទន្លេ ដងទន្លេ និងស្ទឹងសំខាន់ៗ ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់ កម្រិតកម្ពស់ទឹក និងទិន្នន័យធារទឹក សម្រាប់ធ្វើការព្យាករណ៍ស្ថានភាពឧតុនិយមនិងស្ថានភាពជលសាស្ត្រឱ្យបានទៀងទាត់ សុក្រឹត និងផ្សព្វផ្សាយជូនដំណឹងទាន់ពេលជូនដល់សាធារណជន ឱ្យបានមុនពេលគ្រោះមហន្តរាយពីធម្មជាតិកើតឡើង ដូចជាភាពរាំងស្ងួត ខ្យល់ព្យុះ រន្ទះ និងទឹកជំនន់។ សមិទ្ធផលការងារខាងលើក្រសួងសម្រេចបានដូចខាងក្រោម៖

### ៥.៨- ការងារជលសាស្ត្រ

- សាងសង់ស្ថានីយជលសាស្ត្រ១១កន្លែង ជួសជុលស្ថានីយជលសាស្ត្រ៤៧កន្លែង ដំឡើងក្តារម៉ែត្រវាស់កម្ពស់ទឹកចំនួន៥កន្លែង ជួសជុលក្តារម៉ែត្រវាស់កម្ពស់ទឹកចំនួន៥កន្លែង និងបំពាក់ឧបករណ៍ស្វ័យប្រវត្តិនៅតាមស្ថាននីយជលសាស្ត្របាន៨កន្លែង ដោយបានចំណាយថវិកាសរុបចំនួន៣ ៥៣៨ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ស្ថានីយជលសាស្ត្រ(កន្លែង) | | ក្តារម៉ែត្រវាស់កម្ពស់ទឹក(កន្លែង) | | ឧបករណ៍ស្វ័យប្រវត្តិ កន្លែង | ថវិកា(រៀល) |
|---|---|---|---|---|---|---|
| | ដំឡើង | ជួសជុល | ដំឡើង | ជួសជុល | | |
| ២០១៧ | ១ | ៥ | | | | |
| ២០១៨ | | ៣ | | ៤ | ៨ | |
| ២០១៩ | | ១ | ១ | ១ | | ៣ ៥៣៨ ០០០ |
| ២០២០ | ១ | ៥ | ១ | | | |
| ២០២១ | ៩ | ៣៣ | ៣ | | | |
| **សរុប** | **១១** | **៤៧** | **៥** | **៥** | **៨** | **៣ ៥៣៨ ០០០** |

### ៥.៩- ការងារឧតុនិយម

- សាងសង់ដំឡើងស្ថានីយឧតុនិយមបានចំនួន ៣៣កន្លែង ជួសជុលកែលម្អស្ថានីយឧតុនិយមបានចំនួន៥៥កន្លែង ដំឡើងប៉ុស្តិ៍តម្រងទឹកភ្លៀងចំនួន៨០កន្លែង ជួសជុលប៉ុស្តិ៍តម្រងទឹកភ្លៀង បានចំនួន២២កន្លែង និងបំពាក់ឧបករណ៍ស្វ័យប្រវត្តិបានចំនួន១៨កន្លែង ដែលបានចំណាយថវិកាសរុបចំនួន២ ៩៥៥ ៣៥៦ ០០០ រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ស្ថានីយឧតុនិយម (កន្លែង) | | ប៉ុស្តិ៍តម្រងទឹកភ្លៀង (កន្លែង) | | បំពាក់ឧបករណ៍ស្វ័យប្រវត្តិ កន្លែង | ថវិកាចំណាយ | |
|---|---|---|---|---|---|---|---|
| | ដំឡើង | ជួសជុល | ដំឡើង | ជួសជុល | | រៀល | ដុល្លារ |
| ២០១៧ | | ៤ | ១៤ | | ៧ | ២៤៧ ០០០ ០០០ | |
| ២០១៨ | | ៦ | ២ | ១០ | ៤ | ២២០ ០០០ ០០០ | |
| ២០១៩ | | ៧ | ២០ | ៥ | | ៨៥៣ ០០០ ០០០ | |
| ២០២០ | ៤ | ១១ | ១៩ | ៤ | ៧ | ១ ០៧៩ ១៥៦ ០០០ | |
| ២០២១ | ២៩ | ២៧ | ២៥ | ៣ | | ៥៥៦ ២០០ ០០០ | |
| **សរុប** | **៣៣** | **៥៥** | **៨០** | **២២** | **១៨** | **២ ៩៥៥ ៣៥៦ ០០០** | |

## ៥.១០- ការការពារនិងការអភិរក្សធនធានទឹក(ក្នុងយុទ្ធសាស្ត្រទី៥របស់ក្រសួង)

ដើម្បីអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានរៀបចំដោយស្ថាប័ននៃរាជរដ្ឋាភិបាល ហើយត្រូវបានព្រះករុណាឡាយព្រះហត្ថលេខា ប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ បន្ទាប់ពីព្រឹទ្ធសភាប្រជុំអនុម័តនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ និងរដ្ឋសភាប្រជុំអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧នោះៈ

ក្រសួងបានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅតាមរាជធានី ខេត្ត និងតាមសហគមន៍កសិករប្រើប្រាស់ទឹក។

ជាមួយនេះដែរ បានចុះកំណត់ផ្ទៃដីអាងទឹក បោះបង្គោលកំណត់ព្រំអាងទឹកនិងបឹងធម្មជាតិដើម្បីធ្វើការអភិរក្សធនធានទឹកនៅតាមបណ្តា រាជធានី ខេត្ត ហើយសម្រេចលទ្ធផលបានសរុបចំនួន៩៩កន្លែង លទ្ធផលសម្រេចបាន រួមមានតាមបណ្តាឆ្នាំដូចខាងក្រោមៈ

**- នៅឆ្នាំ ២០១៩ បាន១៣កន្លែង**

**- នៅឆ្នាំ ២០២០ បាន៥២កន្លែង**

**- នៅឆ្នាំ ២០២១ បាន៣៤កន្លែង**

**សរុប បានចំនួន៩៩កន្លែង**

ក្រសួងបានធ្វើការតាមដាន និងវាស់កម្រិតនីរ៉ូស្តាទិចទឹកអណ្តូង នៅខេត្តព្រៃវែង១៩កន្លែង នៅខេត្តស្វាយរៀង១២កន្លែង និងខេត្តកំពង់ស្ពឺ៥កន្លែង។

ជាមួយនេះដែរ ក្រសួងបានខួងអណ្តូងទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់ នៅតាមបណ្តាខេត្ត សម្រេចបានចំនួន៣០អណ្តូង ខួងអណ្តូងពិសោធន៍ទឹកក្រោមដីបានចំនួន២អណ្តូង និងជីកស្រះយកទឹកជូនប្រជាពលរដ្ឋប្រើប្រាស់សម្រេចបានចំនួន១១៨ស្រះ ដោយបានចំណាយថវិកាសរុបចំនួន១៨៣ ៦០០ ០០០ រៀល។ លទ្ធផលសម្រេចបានរួមមានតាម បណ្តាឆ្នាំដូចខាងក្រោមៈ

| ឆ្នាំ | ខួងអណ្តូងទឹកស្អាត(អណ្តូង) | ខួងអណ្តូងពិសោធន៍ទឹក(អណ្តូង) | ជីកស្រះទឹក(ស្រះ) | ចំណាយ(រៀល) |
|---|---|---|---|---|
| ២០១៧ | 0 | 0 | 0 | |
| ២០១៨ | 0 | 0 | 0 | |
| ២០១៩ | ២៩ | 0 | ១០៣ | |
| ២០២០ | ១ | ១ | ៨ | ៩៥ ០០០ ០០០ |
| ២០២១ | 0 | ១ | ៧ | ៨៩ ៦២០០ ០០០ |
| **សរុប** | **៣០** | **២** | **១១៨** | **១៨៣ ៦០០ ០០០** |

## ៦- ការអភិវឌ្ឍជនបទ

### លទ្ធផលការងារសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទ៖

### ៦.១- ការងារផ្លូវជនបទ

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|
| -ការជួសជុល ថែទាំផ្លូវជនបទជាលក្ខណៈខួប(គ.ម.) | | | | | |
| ៥០២,៥៦ | ៤៩១,៨៩ | ៣៩៥,៦៣ | ៤៧៧,៥២ | ៤២៦,៣២ | ២ ២៩៣,៩២ |
| -ការជួសជុល ថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ(គ.ម.) | | | | | |
| ១ ៥៧២, ៦១ | ១ ៥៦៧,៦០ | ២ ៨១១,២៣ | ២ ៩៦៦,៣៤ | ៣ ០៧២,៣៨ | ១១ ៩៩០,១៥ |
| - ការជួសជុលបន្ទាន់ផ្លូវជនបទក្រោយទឹកជំនន់(ថវិកាជំពូក៦១) (គ.ម.) | | | | | |
| ២៧៣ ,០៧ | ២៦៧, ៩៥ | ២៨៣,២១ | ៣២៩ ៥៩៦ | ០ | ៨២៤,២៣ |
| - ការជួសជុល និងថែទាំសំណង់សិល្បការ(លូមូល) (ថវិកាជំពូក៦១) (កន្លែង) | | | | | |
| ១៤៧ | ១៦៨ | ៨៥ | ៧៤ | ៥២ | ៥២៦ |
| - ការជួសជុល និងថែទាំសំណង់សិល្បការ (លូជ្រុង) (ថវិកាជំពូក៦១) (កន្លែង) | | | | | |
| | ១ | ១ | ២ | ៩ | ១៣ |
| - ការជួសជុលសំណង់សិល្បការ (ស្ពាន) (ថវិកាជំពូក៦១) (កន្លែង) | | | | | |
| ២ | ១ | ៨ | ៣ | ០ | ១៤ |
| - ការដំឡើងស្លាកសញ្ញាចរាចរណ៍ (ថវិកាជំពូក៦១) (ចំនួន) | | | | | |
| ១ ០៦៧ | ១ ៣៣៤ | ១ ៤៤៥ | ២ ១៥២ | ២ ៥២៤ | ៨ ៥២២ |
| - ការសាងសង់ផ្លូវក្រាលបេតុង(ថវិកាជំពូក២១ និងគម្រោង) (គ.ម.) | | | | | |
| ១០,០៣ | ៧,៣៦ | ៦៧,៤០ | ៧៣,២៣ | ១៥ ៧៩៨ | ១៧៣ ៨២២ |
| - ការសាងសង់ផ្លូវក្រាលបេតុង (ថវិកាជំពូក២១ និងគម្រោង) (គ.ម.) | | | | | |
| ១០,០៣ | ៧,៣៦ | ៦៧,៤០ | ៧៣,២៣ | ១៥,៨០ | ១៧៣,៨២ |
| - ការសាងសង់ និងពង្រីកផ្លូវថ្មីផ្លូវក្រាលក្រួស (ថវិកាជំពូក២១ និងគម្រោង) (គ.ម.) | | | | | |
| ៣៦១,៦១ | ៣៨៦,៩១ | ៣៩៣,៣៦ | ៣១០,០៦ | ១០៥,៨៤ | ១ ៥៥៧,៧៩ |
| - ការកែលម្អផ្លូវពីក្រាលក្រួសក្រហមទៅកៅស៊ូពីរជាន់ (ថវិកាជំពូក២១) (DBST) (គ.ម.) | | | | | |
| ៤០,២៥ | ៨២,៣៥ | ២៦៨,៨៦ | ៣១២,០៣ | ១២៣,៣៥ | ៨២៦,៨៤ |
| - ការសាងសង់សំណង់សិល្បការថ្មី (ថវិកាជំពូក២១) (លូមូល) (កន្លែង) | | | | | |
| ៤១២ | ៥០១ | ៤៩៣ | ៥៩៩ | ៣៦៤ | ២ ៣៦៩ |
| - ការសាងសង់សំណង់សិល្បការថ្មី (ថវិកាជំពូក២១) (លូជ្រុង) (កន្លែង) | | | | | |
| ៥៧ | ៦៣ | ៨០ | ១០១ | ៤១ | ៣៤២ |
| - ការសាងសង់សំណង់ស្ពាន (ថវិកាជំពូក២១) (កន្លែង) | | | | | |
| ២៥ | ២៦ | ២៤ | ១៩ | ៥២ | ១៤៦ |
| - ការសាងសង់សំណង់ទំនប់បង្ហៀរ (ថវិកាជំពូក២១) (កន្លែង) | | | | | |
| ១ | ៣ | ០ | ៣៩ | ២ | ៤៥ |
| - ការស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពផ្លូវជនបទ(គ.ម.) | | | | | |
| ១ ០២៥,៥០ | ១ ០០៩,៧១ | ១ ១០២,៨០ | ៩៨៩,៣០ | ៩៧៦,៩៥ | ៥ ១០៤,២៦ |
| **៦.២- ការផ្គត់ផ្គង់ទឹកជនបទ** | | | | | |
| - ចំនួនអណ្តូងស្នប់ អណ្តូងលូ និងអណ្តូងចម្រុះសាងសង់ថ្មីគ្រប់ប្រភេទ(អណ្តូង) | | | | | |
| ២ ៥៤៦ | ៣ ២៣២ | ៣ ៧៥៣ | ៣ ៤២៩ | ១ ២៥៣ | ១៤ ២១៣ |

| | | | | | |
|---|---|---|---|---|---|
| -ចំនួនអណ្តូងគ្រប់ប្រភេទដែលបានជួសជុលឡើងវិញ ហើយកំពុងដំណើរការ(អណ្តូង) | | | | | |
| ១ ៥៣៥ | ២៩៩ | ៥២៨ | ៧០៦ | ២៩ | ៣ ០៩៧ |
| - ស្រះសហគមន៍ ស្រះគ្រួសារដែលបានស្តារ និងសាងសង់ថ្មី(ស្រះ) | | | | | |
| ១១៦ | ១៧៩ | ២១៧ | ២៨៥ | ៥៨១ | ១ ៣៧៨ |
| - ចំនួនអាងត្រងទឹកភ្លៀងដែលបានសាងសង់(៣ម.៣,៥ម.៣)(ចំនួន) | | | | | |
| ១១២ | ១ ០៧៤ | ៨៣២ | ១០៨ | ៧៣ | ២ ១៩៩ |
| - ចំនួនពាងត្រងទឹកភ្លៀងដែលបានសាងសង់ (ចំនួន) | | | | | |
| ១៥ ៦៥២ | ៣២ ០៦៣ | ៦០ ២៣០ | ៤៦ ៥៤១ | ៦៧៥ | ១៥៥ ១៦១ |
| - ចំនួនប្រព័ន្ធចែកចាយទឹកតាមទុយោដែលបានសាងសង់/ចំនួនភូមិ(ប្រព័ន្ធ) | | | | | |
| ៦ | ៣៨ | ១៤ | ១៣១ | ១២ | ២១០ |
| - សាងសង់ស្ថានីយទឹកផឹកដាក់ពីដុងចំណុះ២០លីត្រ | | | | | |
| | | | ១១ | ១១ | ៣៣ |
| - ប្រព័ន្ធធារាសាស្ត្រខ្នាតតូចដែលបានស្តារ និងជួសជុល(ទំនប់/ប្រឡាយ) (គ.ម.) | | | | | |
| ២,៦៥ | ២៥,៤១ | ៣,២ | ១,៦៦ | ២,៩៧ | ៣៥,៨៩ |
| - សាងសង់ស្ថានីយទឹកស្អាត | | | | | |
| | | ២៩២ | ៣៧ | | ៣២៩ |
| - សាងសង់ប្រព័ន្ធចម្រោះទឹកស្អាត | | | | | |
| ៥ ១០៣ | ៧ ៨៦៧ | ២ ៣៨៥ | ១១០ | ១០៨ | ១៥ ៥៧៣ |
| សាងសង់ធុងចម្រោះ | | | | | |
| | ២៦ ៤០៥ | ១៨ ៨០២ | ៣៦ ៤០៦ | | ៨១ ៦១៣ |
| ចែកធុងទឹក | | | | | |
| | | ៧ ៥៤៧ | ១៥ ៣៦៥ | | ២២ ៩១២ |
| ស្ថានីយបូមទឹកស្រោចស្រពកសិកម្ម(កន្លែង) | | | | | |
| | ១៣ | | | | ១៣ |
| សាងសង់ស៊ីទែនទឹក ២០០០លីត្រ | | | | | |
| | ២៤ | ៩ | | | ៣៣ |
| សាងសង់ប្រព័ន្ធស្រោចស្រពទឹកកសិកម្ម(កន្លែង) | | | | | |
| | ១២៨ | | | | ១២៨ |
| - ប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាតជនបទ (ទូទាំងប្រទេស) (នាក់) | | | | | |
| ២១៧ ៦៩០ | ៣៦២ ៩០០ | ៧៣៥ ៤៣៨ | ៨៩៦ ៤៩៤ | ៦៨៥ ៨៧២ | ៣ ១៩៨ ៣៩៤ |
| **៦.៣- ការថែទាំសុខភាពជនបទ** | | | | | |
| - បង្គន់អនាម័យជនបទដែលបានសាងសង់រួច(បង្គន់) | | | | | |
| ៤ ៤១៩ | ៤ ៤៥១ | ២ ៩៥៩ | ៣ ៤២០ | ២ ១៨៧ | ១៧ ៤៣៦ |
| - ប្រជាពលរដ្ឋដែលយល់ដឹងពីបញ្ហាអនាម័យ(នាក់) | | | | | |
| ១៧ ៦៧៦ | ១៧ ៨០០ | ១១ ៨៣៥ | ១៧ ១០០ | ១០ ៩៣០ | ៧៥ ៣៤១ |
| - ប្រជាពលរដ្ឋទទួលបានសេវាអនាម័យ(%) | | | | | |
| ៧១,២ | 0 | ៧៨,៣ | 0 | 0 | ៧៨,៣ |
| - ជំរុញឱ្យប្រជាជនមានបង្គន់ប្រើប្រាស់(បង្គន់) | | | | | |
| ៤ ៩១០ | ៥ ០៥៨ | ៣ ៣៥៦ | ៣ ៧៨៦ | ២ ៥៧៦ | ១៩ ៦៨៦ |

| | | | | | |
|---|---|---|---|---|---|
| - សាងសង់កន្លែងលាងដៃតាមសាលារៀន(កន្លែង) | | | | | |
| ០ | ០ | ០ | ០ | ០ | ០ |
| - សង់ឡដុតសំរាម និងចែកធុងសំរាម(កន្លែង) | | | | | |
| ០ | ០ | ០ | ០ | ០ | ០ |
| - វគ្គផ្សព្វផ្សាយអំពីទឹកស្អាត និងសុខភាពអនាម័យ(វគ្គ) | | | | | |
| ៦០ | ៦៥ | ៦៨ | ៤០ | ៣ | ២៣៦ |
| - សម្រេចបានស្រុកបញ្ឈប់បន្ទោបង់ពាសវាលពាសកាល(ស្រុក) | | | | | |
| ៥ | ២ | ២ | ៤ | ២ | ១៥ |
| **៦.៤- ការអភិវឌ្ឍសហគមន៍** | | | | | |
| - ចំនួនគណៈកម្មាធិការអភិវឌ្ឍន៍ភូមិដែលទទួលបានការបណ្តុះបណ្តាល (ភូមិ) | | | | | |
| ៧០៧ | ៧៧៧ | ៥៧៦ | ៣៩២ | មិនទាន់អនុវត្ត | ២ ៤៥២ |
| - ចំនួនភូមិដែលធ្វើការអភិវឌ្ឍចម្រុះ(ភូមិ) | | | | | |
| ៥ | ៤ | ៥ | ៥ | មិនទាន់អនុវត្ត | ១៩ |
| - ប្រជាពលរដ្ឋដែលបានបញ្ជ្រាបការយល់ដឹងពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយ(នាក់) | | | | | |
| ៥២៥ | ៤៥៥ | ៤៥៥ | ២៤៥ | មិនទាន់អនុវត្ត | ១ ៦៨០ |
| - ចំនួនប្រជាពលរដ្ឋដែលបានបណ្តុះបណ្តាលដីកំប៉ុស និងពូជបន្លែចម្រុះ(នាក់) | | | | | |
| ៣២០ | ៦៦០ | ៣០០ | ២៤៥ | មិនទាន់អនុវត្ត | ១ ៥២៥ |
| **៦.៥- ការអភិវឌ្ឍសេដ្ឋកិច្ច** | | | | | |
| - ក្រុមសន្សំ/សហគមន៍ទទួលសេវាឥណទានជនបទ(នាក់) | | | | | |
| ៥ ៩៣៣ | ៥ ០៩០ | ៤ ២៥២ | ៤ ២២៩ | ៣ ៣២១ | ៤ ៥៦៥/ឆ្នាំ |
| - ការងារតាំងពិព័រណ៍ផលិតផលជនបទ«ភូមិខ្ញុំ ផលិតផលខ្ញុំ»(លើក) | | | | | |
| ២ | ២ | ១ | ០ | ០ | ៥ |
| - ការងារសាងសង់ផ្សារជនបទ(ចំនួន) | | | | | |
| ០ | ០ | ១ | ៤ | ០ | ៥ |
| - ការងារបង្កើតគំនិតអាជីវកម្ម សិប្បកម្មផលិតសាប៊ូ(លើក) | | | | | |
| ៦ | ៦ | ២៧ | ១០ | ៦ | ៥៥ |
| **៦.៦- ការអភិវឌ្ឍជនជាតិដើមភាគតិច** | | | | | |
| - ចេញលិខិតទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិច(ក្រុម) | | | | | |
| ១១ | ១៣ | ១១ | ១ | ០ | ៣៦ |
| - ចុះរៀបចំបទបញ្ជាផ្ទៃក្នុង (ភូមិ) | | | | | |
| ៣ | ១៣ | ១៤ | ០ | ០ | ៣០ |
| - ចូលរួមរៀបចំអបអរសាទរទិវាជនជាតិដើមភាគតិចពិភពលោក (លើក) | | | | | |
| ១ | ១ | ១ | ០ | ០ | ៣ |

## មុំទី២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព

### ១- ក្រសួងបរិស្ថាន

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ព្រមទាំងយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ក្រសួងបរិស្ថានបាននិង

កំពុងអនុវត្តការងារកំណែទម្រង់ និងសម្រេចបានការងារជាច្រើនក្នុងដំណើរឆ្ពោះទៅកសាងឱ្យបាននូវរដ្ឋបាលទំនើបមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងការវិវឌ្ឍរបស់សង្គម ក៏ដូចជាបរិការណ៍តំបន់និងពិភពលោក សំដៅជានាសម្រេចបាននូវបេសកកម្មរបស់ខ្លួនតាមសសរស្តម្ភទាំង៤ គឺ (១) ការធ្វើទំនើបកម្មស្ថាប័ន (២) កិច្ចគាំពារបរិស្ថាន (៣) ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ និង(៤) ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រ ដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព ដោយសំឡឹងឆ្ពោះទៅកចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង២០៥០។

### ១.១- ទំនើបកម្មស្ថាប័ន

- **ការលើកទឹកចិត្តមន្ត្រីរាជការ** បាន (១) រៀបចំដំឡើងឋានន្តរសក្តិនិងថ្នាក់ ជូនដល់មន្ត្រីរាជការនៅទីស្តីការក្រសួងបរិស្ថានចំនួន៣៩៤នាក់ និងមន្ទីរបរិស្ថានរាជធានីខេត្តចំនួន១ ៥៩៦នាក់ និង(២) រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការនៅសាលាភូមិន្ទរដ្ឋបាលចំនួន២២៣នាក់ បណ្តុះបណ្តាលមន្ត្រីមុខងារសាធារណៈជាឧទ្យានុរក្ស ស្តីពីវិធីសាស្ត្រល្បាតក្នុងតំបន់ការពារធម្មជាតិនៅសាលានាយទាហានសកម្មចំនួន៤២៧នាក់ និងបណ្តុះបណ្តាលមន្ត្រីរាជការនៅវិទ្យាស្ថានទំនាក់ទំនងការទូតចំនួន២៥នាក់

- បំពាក់សម្ភារៈបច្ចេកទេសមានដូចជាកុំព្យូទ័រដៃ(Laptop Computer) ចំនួន២៩គ្រឿងកុំព្យូទ័រលើតុ (Desktop Computer) ចំនួន២១គ្រឿង ម៉ាស៊ីនព្រីនធ័រ(Printer) ចំនួន២៤គ្រឿង និងម៉ាស៊ីនថតចម្លងចំនួន៦គ្រឿង

- ផ្តល់យានយន្តចំនួន១៩៤គ្រឿង និងម៉ូតូចំនួន១ ២០០គ្រឿង

- ក្រសួងបរិស្ថាន បានយកចិត្តទុកដាក់លើកិច្ចគាំពារមន្ត្រីរាជការ លើកទឹកចិត្តមន្ត្រីសកម្ម និងគិតគូរជាចម្បងដល់ជីវភាពនិងទុក្ខលំបាករបស់មន្ត្រីរាជការ ដូចជាឧបត្ថម្ភដល់មន្ត្រីរៀបអាពាហ៍ពិពាហ៍ មន្ត្រីសម្រាលបុត្រ មន្ត្រីទទួលមរណភាព មន្ត្រីដែលមានជីវភាពខ្វះខាត មន្ត្រីសម្រាកព្យាបាលជំងឺតាមសភាពជាក់ស្តែង ប្រាក់រង្វាន់ និងផ្តល់របបប្រេងប្រចាំខែដល់មន្ត្រីរាជការសម្រាប់បំពេញការងារជូនក្រសួង

- **ការឆ្លើយតបនឹងពាក្យបណ្តឹង** បាន (១) ធ្វើការឆ្លើយតប ចុះធ្វើអធិការកិច្ច អង្កេតស្រាវជ្រាវតាមបណ្តឹង អនាមិកសរុបចំនួន៣៥ករណី (២) អង្កេតស្រាវជ្រាវលើករណីបទល្មើសព្រៃឈើនិងការកាប់រុករានទន្ទ្រានដីព្រៃ សរុបចំនួន១៦ករណី និង(៣) ចុះពង្រឹងការងារដឹកនាំ គ្រប់គ្រង តាមដានការអនុវត្តច្បាប់ និងភាពអសកម្មក្នុងការអនុវត្តភារកិច្ចរបស់មន្ត្រី មន្ទីររាជធានី ខេត្ត និងតាមតំបន់ការពារធម្មជាតិ សរុបចំនួន៦០ករណី។

### ១.២- កិច្ចគាំពារបរិស្ថាន

- ចុះពិនិត្យតាមដានគុណភាពទឹកសាធារណៈ ទឹកក្រោមដី ទឹកកខ្វក់ និងតំបន់ងាយរងការបំពុលនៅតាមរាជធានី ខេត្តគោលដៅចំនួន១៩១ទីតាំង និងបានយកសំណាកទឹកចំនួន១ ៣៦១សំណាក

- ចុះពិនិត្យទីតាំងនិងវាយតម្លៃសមត្ថភាពអាងប្រព្រឹត្តកម្មសំណល់រាវរោងចក្រចំនួន១ ២៦៥ទីតាំង គិតជាបរិមាណសំណល់រាវបញ្ចេញ៥១ ២១៥ ២៤១ម.៣

- តាមដានគុណភាពខ្យល់សាធារណៈជាប្រចាំនៅតាមរាជធានីខេត្តចំនួន៤១ទីតាំង និងបានប្រើប្រាស់រថយន្ត«**វិស្ណុត្រួតពិនិត្យគុណភាពខ្យល់**» ចំនួន២០លើក

- ចុះត្រួតពិនិត្យវាយតម្លៃគុណភាពខ្យល់និងសំឡេងដល់ក្រុមហ៊ុនចំនួន៣៧០ទីតាំង

- ចុះត្រួតពិនិត្យទីតាំងស្នើសុំបញ្ចេញសំណល់គ្រោះថ្នាក់១៥៥ទីតាំង

- រៀបចំផ្ទាំងផ្សព្វផ្សាយនិងធុងប្រមូលសំណល់ថ្មពិល ក្នុងរាជធានីភ្នំពេញចំនួន៣០ទីតាំង

- ចុះប្រមូលព័ត៌មាន វាស់សារធាតុវិទ្យុសកម្ម និងសំណល់វេជ្ជសាស្ត្រ នៅតាមមន្ទីរពេទ្យរដ្ឋ និងឯកជននៅរាជធានី ខេត្តចំនួន៣៨ទីតាំង និងប្រភពសាយភាយសារធាតុPOPs ចំនួន១២ទីតាំង

- ចុះប្រមូលព័ត៌មានទីតាំងប្រមូលទិញនិងកែច្នៃសំណល់សំបកកង់រថយន្តចំនួន១៥ទីតាំង

- ចុះតាមដាននិងវាយតម្លៃការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យនៅមន្ទីរបរិស្ថានខេត្តចំនួន២៦

- ចុះពង្រឹងប្រសិទ្ធភាពសេវាប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនរាជធានី ក្រុង ស្រុកចំនួន៧៣ក្រុង ស្រុក

- ប្រមូលទិន្នន័យនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមខេត្តចំនួន២៤ និងស្រុក១៦២

- ប្រមូលទិន្នន័យទីតាំងទិញសំណល់អេតចាយ៦៩២និងទីតាំងកែច្នៃសំណល់៣៨ទីតាំង

- ប្រមូលទិន្នន័យសំរាម សំណល់រឹង តាមមណ្ឌលចត្តាឡីស័ក និងមណ្ឌលសម្រាកព្យាបាលជំងឺកូវីដ-១៩ នៅទូទាំង២៥រាជធានី ខេត្ត(២០២១)

- ចុះផ្សព្វផ្សាយស្តីពីការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកតាមផ្សារទំនើបចំនួន៣ទីតាំង

- ពិនិត្យនិងផ្តល់យោបល់លើទីតាំងគ្រោងបង្កើតទីលានចាក់សំរាម សំណល់រឹងទីប្រជុំជននៅ២៥រាជធានី ខេត្តចំនួន៣១ទីតាំង

- ចុះពិនិត្យ វាយតម្លៃ និងបំពាក់ឡដុតសំរាម សំណល់រឹងខ្នាតតូច និងមធ្យម ចំនួន៥៥ឡ ដល់រាជធានី ខេត្ត ចំនួន២៥

- ចុះត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ តាមបណ្តារោងចក្រសហគ្រាស អាជីវកម្ម សេវាកម្ម ដែលងាយរងការបំពុលបរិស្ថានចំនួន១ ០៥៤ទីតាំង និងបានបំពាក់ឧបករណ៍ស្វ័យប្រវត្តិចំនួន១ទីតាំង

- ចុះអធិការកិច្ចប្រភពបំពុល ក្នុងករណីកើតមានបណ្តឹងអំពីបញ្ហាបំពុលបរិស្ថានចំនួន៦២ករណី និងតាមដានអនុវត្តបញ្ជាកែប្រែលើប្រភពបំពុលចំនួន៩៨ករណី

- ពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមចំនួន៣៨៩គម្រោង

- ជំរុញម្ចាស់គម្រោងចំនួន៩៧២ ឱ្យមករៀបចំកិច្ចសន្យាការពារបរិស្ថាន

- ចុះអង្កេតតាមដានការអនុវត្តកិច្ចសន្យាការពារបរិស្ថាននិងផែនការគ្រប់គ្រងបរិស្ថានចំនួន៨៦៣គម្រោង

- វិភាគសំណាកទឹក ដី ភក់ ខ្យល់ អាស៊ីតបរិយាកាសចំនួន១ ៤៦៤សំណាក និងវិភាគរកវត្តមានសារពាង្គកាយកែច្នៃរស់(GMOs & LMOs) ចំនួន១៦សំណាក។

| ល.រ. | សូចនាករ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|
| ១ | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការទប់ស្កាត់ កាត់បន្ថយការបំពុលបរិស្ថាន ទឹក ដី ខ្យល់ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖ | | | | | | |
| | ព្រះរាជក្រម | ច្បាប់ | - | - | - | ២ | - |
| | គោលនយោបាយ | ច្បាប់ | - | - | - | - | ១ |
| | អនុក្រឹត្យ | ច្បាប់ | - | - | - | - | ៤ |
| | សារាចរ | ច្បាប់ | - | - | - | ១ | - |
| | ប្រកាសក្រសួង-អន្តរក្រសួង | ច្បាប់ | ១ | ៥ | ៥ | ៣ | ១៣ |

| ល.រ. | សូចនាករ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|
| | គោលការណ៍ណែនាំ | ច្បាប់ | - | ២ | - | ១ | - |
| | សៀវភៅណែនាំ | ច្បាប់ | - | - | - | ១ | ១ |
| ២ | ការងារត្រួតពិនិត្យតាមដានគុណភាពបរិស្ថាន ៖ | | | | | | |
| | តាមដានគុណភាពទឹកសាធារណៈ និងតំបន់ងាយរងការបំពុល | សំណាក | ២៩០ | ៤២៦ | ៣២០ | ២២២ | ១១៧ |
| | ពិនិត្យទីតាំង និងវាយតម្លៃសមត្ថភាពអាងប្រព្រឹត្តកម្មសំណល់រាវរោងចក្រ | ទីតាំង | ១៨៣ | ១៥៧ | ១៦០ | ៣៩៧ | ៣០៣ |
| | ពិនិត្យតាមដានគុណភាពខ្យល់សាធារណៈនៅតាមរាជធានីខេត្ត | ទីតាំង | ១ | ១ | ៣០ | ៤១ | ៤១ |
| | ចុះត្រួតពិនិត្យវាយតម្លៃគុណភាពខ្យល់ និងសំឡេងតាមប្រភពបំពុល | ទីតាំង | ៤០ | ៦០ | ៧៨ | ៨០ | ១១១ |
| | ត្រួតពិនិត្យទីតាំងស្នើសុំបញ្ចេញសំណល់គ្រោះថ្នាក់ | ទីតាំង | ២ | ១២ | ៣០ | ៦៣ | ៤៨ |
| | ចុះត្រួតពិនិត្យនិងអធិការកិច្ចប្រភពបំពុល | ទីតាំង | ទីតាំង | ២១៦ | ២៣៩ | ៣២១ | ១៤៩ |
| | ការអនុញ្ញាតឱ្យបង្កើតទីលានថ្មី | ទីលាន | ០ | ៦ | ១១ | ៧ | ៧ |
| | ការតម្លើងឡថ្មីសម្រាប់ដុតសំរាម | ឡ | ០ | ០ | ១៩ | ៧ | ២៨ |
| | ការនាំចេញសំណល់អេតចាយ | តោន | ៣២ ៥១០,៥ | ១១ ២០៧,៧ | ១០ ៩២១ | ៩ ១៥០ | ៩ ៥៣២ |
| | ពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | គម្រោង | ៨៣ | ៥៥ | ១១៧ | ៦៣ | ៧១ |
| | ធ្វើកិច្ចសន្យាការពារបរិស្ថាន | គម្រោង | ១៣៣ | ១៣១ | ២៧៦ | ២៨១ | ១៥១ |
| | ចុះអង្កេតតាមដានការអនុវត្តកិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន | គម្រោង | ២៤៨ | ១៣១ | ១២៦ | ២៦២ | ៩៦ |

## ១.៣- ការគ្រប់គ្រងធនធានធម្មជាតិ

- រៀបចំនិងបង្កើនចំនួនតំបន់ការពារធម្មជាតិ ពី២៣តំបន់ ដែលមានផ្ទៃដីទំហំ៣,២លានហ.ត. ស្មើនឹង ១៨%នៃផ្ទៃប្រទេស កើនឡើងរហូតដល់៧៥តំបន់ ដែលមានផ្ទៃដីទំហំសរុបជាង៧លានហ.ត. ស្មើនឹង៤១%នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា ដែលក្នុងនោះរួមមាន ក- ឧទ្យានជាតិចំនួន១២តំបន់ ខ- ដែនជម្រកសត្វព្រៃចំនួន១៩តំបន់ គ- តំបន់ការពារទេសភាពចំនួន១៤តំបន់ ឃ- តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៩តំបន់ ង- តំបន់រ៉ាមសារចំនួន៥តំបន់ ច- តំបន់បេតិកភណ្ឌធម្មជាតិចំនួន១៣តំបន់ និងឆ- របៀងអភិរក្សជីវៈចម្រុះចំនួន៣តំបន់

- រៀបចំលិខិតបទដ្ឋានគតិយុត្ត រួមមានអនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនានា ក្នុងគោលដៅពង្រឹងការងារគ្រប់គ្រងតំបន់ការពារធម្មជាតិឱ្យមានចីរភាព

- គាំទ្រលើមធ្យោបាយ សម្ភារៈនិងឧបករណ៍ សម្រាប់គាំទ្រដល់ការងារល្បាតមន្ត្រីជំនាញ ក្នុងការចុះណែនាំនិងអនុវត្តច្បាប់ លើការទប់ស្កាត់បទល្មើសធនធានធម្មជាតិ និងប្រើប្រាស់ក្នុងតំបន់ការពារធម្មជាតិ ដូចជា ឯកសណ្ឋានប៉ាវ៉ាចំនួន៦ ១០៥កំប្លេ កាំភ្លើងCKC ចំនួន១ ២១០ដើម និងគ្រាប់កាំភ្លើងចំនួន៥៨ ០៨០គ្រាប់ កាំបិតស្នៀតនិងស្រោមស្បែកចំនួន១ ១៧២កាំបិត ម៉ូតូចំនួន១ ០៩៧គ្រឿង(ម៉ូតូរដ្ឋចំនួន៩១៨គ្រឿង និងម៉ូតូ

ដៃតូចចំនួន១៧៩គ្រឿង) និងទូកម៉ាស៊ីនសំបកស្មាច់វែងចំនួន៣២គ្រឿង ធុងទឹកជ័រចំណុះ២២០លីត្រចំនួន២១៨ ធុង សាក់កាដូចំនួន៤ ៨៩៣ អង្រឹងចំនួន៥ ០៨៤ តង់កៅស៊ូចំនួន៤ ៦៧៨ អាវភ្លៀងចំនួន៤ ៩៨៨ អាវងារចំនួន ២ ៦៥០ មុងចំនួន១ ៣៥០ កាមែលចំនួន១ ១៧៨ និងស្បែកជើងជ័រកវែងចំនួន១ ១១៩គូ ថ្នាំពេទ្យ(ចិន)ចំនួន ៣ ៨២២បន្ទះ វីតាមីនចម្រុះចំនួន៤ ០៦០គ្រាប់ វីតាមីនCចំនួន២ ០០៦ប្រអប់ ម៉ាស់ចំនួន៨៥ ០០០ម៉ាស់ និង ឱសថ(សង្គ្រោះបឋម)ចំនួន១ ៥៩០កាបូប (១កាបូប/១៧មុខ) និងសម្ភារៈផ្សេងៗទៀត រួមមានកែវឆ្លុះ ម៉ាស៊ីនថត ម៉ាស៊ីនGPS វិទ្យុទាក់ទង

- បង្កើតតំបន់បេតិកភណ្ឌធម្មជាតិចំនួន១២កន្លែង រួមមានភ្នំយ៉ាត ក្នុងខេត្តប៉ៃលិន ភ្នំប្រាំពីរ ភ្នំគិរីយ៉ង់ ភ្នំទាក់ទ្រាំង ក្នុងខេត្តបាត់ដំបង ភ្នំជញ្ជាំង ភ្នំយាយសំ ភ្នំបាក់ ភ្នំព្រះ ភ្នំវែង ភ្នំព្រះនេត្រព្រះ ភ្នំស្វាយ ក្នុងខេត្ត បន្ទាយមានជ័យ និងភ្នំគុហ៊ាហ្លួង ភ្នំទទុង-ភ្នំតូច ក្នុងខេត្តកំពត បានចុះសិក្សាប្រមូលទិន្នន័យទីតាំងស្លដែកបុរាណ និងបុរាណស្ថានចំនួន១២ទីតាំង បានបោះពុម្ពសៀវភៅផ្សព្វផ្សាយការយល់ដឹងអំពីបេតិកភណ្ឌធម្មជាតិ រៀបចំស្លាក ព័ត៌មាន បោះបង្គោលព្រំ និងបានចុះទៅសិក្សាស្រាវជ្រាវ និងពិនិត្យទីតាំងផូស៊ីល ខ្យង គ្រុំ ងាវចំនួន២៩ទីតាំង

- គ្រប់គ្រងគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ កសិទេសចរណ៍ តំបន់សេដ្ឋកិច្ចពិសេស និងគម្រោង អភិរក្សព្រៃឈើ និងសត្វព្រៃសរុបចំនួន១៨គម្រោង ដែលមានផ្ទៃដីសរុប១ ៣៩៩,៩១ហ.ត.។ ក្នុងចំណោម គម្រោងទាំង១៨គម្រោង ចំនួន៩បានដំណើរការល្អប្រសើរ និងគម្រោងចំនួន៩ទៀត កំពុងបន្តនីតិវិធីច្បាប់ តាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងបរិស្ថាន

- គ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូច(ក្រោម១០ហ.ត. ចំនួន២០៦គម្រោង ដែលមានផ្ទៃដីសរុបទំហំ១ ៨៦២,២៦ហ.ត.។ ក្នុងចំណោមគម្រោងទាំង២០៦មានគម្រោងចំនួន១៧៧ បាន បោះបង្គោលព្រំប្រទល់រួចរាល់ និងគម្រោងចំនួន២៥ទៀតបានរៀបចំប្លង់មេ ក្នុងនោះ មានចំនួន៥គម្រោងត្រូវបាន អនុម័ត

- បង្កើតសហគមន៍ទេសចរណ៍ធម្មជាតិចំនួន២៦សហគមន៍ បានសម្របសម្រួលនិងសហការជាមួយ សហគមន៍តំបន់ការពារធម្មជាតិ និងបានបញ្ចប់សេចក្តីព្រាងកិច្ចសន្យា សិទ្ធប្រទាន និងអនុប្រយោគ ដើម្បីដាក់ការ ស្នើសុំការពិភាក្សាផ្ទៃក្នុងក្រសួងមុនរៀបចំកិច្ចប្រជុំអន្តរក្រសួង។

## ១.៤- ការងារអប់រំនិងព័ត៌មានបរិស្ថាន

**ការងារព័ត៌មានភូមិសាស្ត្រ** បានបញ្ចប់ការកសាងរបាយការណ៍ស្ថានភាពបរិស្ថានចំនួន២ គឺរបាយការណ៍ ស្ថានភាពបរិស្ថានលើកទី៣ និងលើកទី៤ និងបានបោះពុម្ពសរុបចំនួន៧៦២ក្បាល បានធ្វើការវាយតម្លៃធនធាន គម្របព្រៃឈើជាតិ ដោយផលិតជាទិន្នន័យនិងបានបោះពុម្ពជាសៀវភៅសរុបចំនួន១ ៥០០ក្បាល បានផលិត ផែនទីសហគមន៍តំបន់ការពារធម្មជាតិចំនួន៥៣ផ្ទាំង ផែនទីតំបន់ទេសចរណ៍ធម្មជាតិចំនួន១៩៦ផ្ទាំង ផែនទី បេតិកភណ្ឌវប្បធម៌និងធម្មជាតិចំនួន១៦ផ្ទាំងនិងផែនទីកំណត់និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ចំនួន២ផ្ទាំង

| សូចនាករ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| កសាងរបាយការណ៍ស្ថានភាពបរិស្ថាន | លើក | - | លើកទី៣ | - | - | លើកទី៤ |
| វាយតម្លៃធនធានគម្របព្រៃឈើជាតិ | Dataset | - | - | - | ១ | - |
| បោះពុម្ពរបាយការណ៍ស្ថានភាពបរិស្ថាន | ក្បាល | - | ៣០០ | - | - | ៤៦២ |

| | | | | | | |
|---|---|---|---|---|---|---|
| បោះពុម្ពសៀវភៅធនធានគម្របព្រៃឈើជាតិ | ក្បាល | - | - | - | ១៥០០ | - |
| ផលិតផែនទីសហគមន៍តំបន់ការពារធម្មជាតិ | ផ្ទាំង | ១៣ | ៦ | ៣០ | ២ | ២ |
| ផលិតផែនទីតំបន់ទេសចរណ៍ធម្មជាតិ | ផ្ទាំង | ៤ | ២៧ | ៥៨ | ៧២ | ៣៥ |
| ផលិតផែនទីបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ | ផ្ទាំង | ៧ | - | - | ០៩ | - |
| រៀបចំផែនទីកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ | ផ្ទាំង | ១ | - | ១ | - | - |

**ការងារអប់រំបរិស្ថាន** បានផ្សព្វផ្សាយនិងជំរុញការអនុវត្តសាលាមេត្រីបរិស្ថាននិងវត្តអារាមមេត្រីបរិស្ថានចំនួន៤៩៦សាលា និងវត្តអារាមសរុបចំនួន៥០វត្ត បានបោះពុម្ពសៀវភៅគោលការណ៍សាលាមេត្រីបរិស្ថានចំនួន ៤ ០០០ក្បាល និងសៀវភៅគោលការណ៍វត្តអារាមមេត្រីបរិស្ថានចំនួន១ ០០០ក្បាល បានរៀបចំវេទិកាយុវជនជជែកពិភាក្សាអំពីបរិស្ថាន ដោយមានសិស្សចូលរួមសរុបចំនួន១ ៨៨៥នាក់ បានបញ្ចូលមេរៀនអប់រំបរិស្ថានក្នុងប្រព័ន្ធសរុបចំនួន២៥មេរៀន ផលិតវីដេអូអប់រំបរិស្ថានសរុបចំនួន២ និងបោះពុម្ពសម្ភារៈអប់រំបរិស្ថានដូចជា posters calendar សរុបចំនួន៤០០ និងបានចូលរួមផ្តល់ធាតុចូលជាមេរៀនអប់រំបរិស្ថាន សម្រាប់គ្រប់កម្រិតសិក្សាក្នុងកម្មវិធីសុខភាពសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាបានចំនួន១៨មេរៀន រួមមានមេរៀនស្តីពីការថែរក្សាបរិស្ថាននៅផ្ទះ ការថែរក្សាបរិស្ថាននៅសាលារៀន សុវត្ថិភាពពេលទឹកជំនន់ សារៈសំខាន់នៃព្រៃឈើចំពោះសុខភាព គ្រោះថ្នាក់នៃការប្រើប្រាស់បរិក្ខាអេឡិចត្រូនិក គ្រោះថ្នាក់ដោយសារមីននិងអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ ការបំពុលបរិស្ថាននិងផលប៉ះពាល់សុខភាពការបំពុលដោយសំឡេង និងរំញ័រមកលើសុខភាព គ្រោះថ្នាក់នៃការប្រើផលិតផលបង្កើនសម្ផស្ស ផលប៉ះពាល់នៃសំណល់សារជាតុគីមី ផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ សំណល់រឹង ប្លាស្ទិកនិងផលប៉ះពាល់សុខភាព មនុស្សនិងបរិស្ថាន។

| សូចនាករ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| កម្មវិធីសាលាមេត្រីបរិស្ថាន | សាលា | - | ២០៨ | ១១០ | ៧០ | ១០៨ |
| កម្មវិធីអារាមមេត្រីបរិស្ថាន | វត្ត | - | - | - | - | ៥០ |
| បោះពុម្ពសៀវភៅគោលការណ៍សាលាមេត្រីបរិស្ថាន | ក្បាល | - | ១០០០ | ១០០០ | ១០០០ | ១០០០ |
| បោះពុម្ពសៀវភៅគោលការណ៍វត្តអារាមមេត្រីបរិស្ថាន | ក្បាល | - | - | - | ១០០០ | - |
| វេទិកាយុវជនជជែកពិភាក្សាអំពីបរិស្ថាន | សិស្ស | ៤០២ | ៥៥៨ | ៥២០ | ២៤០ | ១៦៥ |
| ដាក់បញ្ចូលមេរៀនអប់រំបរិស្ថានក្នុងប្រព័ន្ធ | មេរៀន | - | - | - | ១៨ | ៧ |
| ផលិតវីដេអូអប់រំបរិស្ថាន | ចំនួន | ២ | - | - | - | - |
| បោះពុម្ពសម្ភារៈអប់រំបរិស្ថានផ្សេងៗ | ចំនួន | - | - | - | - | ៤០០ |

**ការងារព័ត៌មានបរិស្ថាន** បានរៀបចំទិវាបរិស្ថាន ដូចជាទិវា១ម៉ោងនៃភពផែនដី ទិវាភពផែនដី ទិវាបរិស្ថានជាតិនិងបរិស្ថានពិភពលោក ៥ មិថុនា និងទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា ជារៀងរាល់ឆ្នាំ។ ផលិតព័ត៌មានបរិស្ថានប្រចាំថ្ងៃនិងប្រចាំសប្តាហ៍បានចំនួន២ ១២២អត្ថបទ វីដេអូឯកសារនិងវីដេអូខ្លីៗចំនួន ១២វីដេអូ និងបទចម្រៀងបរិស្ថានចំនួន២៥បទ។ ផលិតកម្មវិធីនិងបទយកការណ៍បរិស្ថានសម្រាប់ផ្សព្វផ្សាយតាមរយៈ

ទូរទស្សន៍ វិទ្យុ និងតាមបណ្ដាញសង្គមក្រសួងសរុបចំនួន៨៨ប្រធានបទ បោះពុម្ពផ្សាយទស្សនាវដ្ដីបរិស្ថានប្រចាំឆ្នាំចំនួន៥ ៧៥០ច្បាប់ បោះពុម្ពសៀវភៅវឌ្ឍនភាពបរិស្ថានចំនួន៦២០ច្បាប់ បកប្រែអត្ថបទនិងវីដេអូអប់រំបរិស្ថានពីភាសាបរទេសចំនួន៦០អត្ថបទ និងគូរគំនូររូបភាពនិងរូបគំនូរអំពីសារអេប់រំបរិស្ថាននៅតាមជញ្ជាំងសាលារៀនចំនួន១២២ផ្ទាំង។

| សូចនាករ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| រៀបចំទិវាបរិស្ថានដូចជា ទិវា១ម៉ោងនៃភពផែនដី ទិវាភពផែនដី ទិវាបរិស្ថានជាតិនិងបរិស្ថានពិភពលោក៥មិថុនា និងទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា | លើក | ៤ | ៤ | ២ | ១ | ១ |
| ផលិតព័ត៌មានបរិស្ថានប្រចាំថ្ងៃប្រចាំសប្ដាហ៍ | អត្ថបទ | - | ៦០០ | ៤៥០ | ៥២៤ | ៥៤៨ |
| ផលិតវីដេអូឯកសារ និងវីដេអូខ្លីៗ ស្ដីពីបញ្ហាបរិស្ថាន និងសក្ដានុពល នៃតំបន់ការពារធនធានធម្មជាតិ ផ្សាយតាមបណ្ដាញសង្គមរបស់ក្រសួង | វីដេអូ | ៤ | ២ | ១ | ១ | ៤ |
| ផលិតបទចម្រៀងបរិស្ថាន | ចំនួន | - | - | - | - | ២៥ |
| ផលិតកម្មវិធី និងបទយកការណ៍បរិស្ថានសម្រាប់ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ និងតាមបណ្ដាញសង្គមក្រសួង | ប្រធានបទ | ២៤ | ១៨ | ១៨ | ២៨ | - |
| បោះពុម្ពផ្សាយទស្សនាវដ្ដីបរិស្ថានប្រចាំឆ្នាំ | ច្បាប់ | ១ ១០០ | ១ ០៥០ | ១ ២០០ | ១ ២០០ | ១ ២០០ |
| បោះពុម្ពសៀវភៅវឌ្ឍនភាពបរិស្ថាន | ច្បាប់ | ៣២០ | ៣០០ | - | - | - |
| បកប្រែអត្ថបទ និងវីដេអូអប់រំបរិស្ថានពីភាសាបរទេស | អត្ថបទ | - | - | - | - | ៦០ |
| គូរគំនូរអំពីសារអេប់រំបរិស្ថាននៅតាមជញ្ជាំងសាលារៀន (រូបភាពនិងរូបគំនូរលើជញ្ជាំង) | ផ្ទាំង | ២ | ១១០ | - | ១០ | - |

**ការងារវង្វាន់ និងលើកទឹកចិត្ត** បានរៀបចំលិខិតបទដ្ឋានគតិយុត្ត ដូចជា អនុក្រឹត្យ ស្ដីពីការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន ប្រកាសស្ដីពីបមាណីយមេត្រីភាពបរិស្ថាន សេចក្ដីណែនាំ ស្ដីពីការវាយតម្លៃគុណវុឌ្ឍិ និងការផ្ដល់បណ្ណសរសើរមេត្រីភាពបរិស្ថានដល់រូបវន្តបុគ្គលនិងនីតិបុគ្គលប្រតិបត្តិមេត្រីភាពបរិស្ថានសម្រាប់មន្ទីរបរិស្ថានរាជធានី ខេត្ត និងលិខិតបទដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងការផ្ដល់វង្វាន់និងលើកទឹកចិត្តមេត្រីភាពបរិស្ថានបានចំនួន៥ច្បាប់។ បានផ្ដល់បណ្ណសរសើរនិងលិខិតថ្លែងអំណរគុណដល់នីតិបុគ្គល រូបវន្តបុគ្គល ព្រមទាំងមន្ត្រីឧទ្យានុរក្សដែលបានចូលរួមបំពេញការងារយ៉ាងសកម្មសរុបចំនួន១ ៣៩៣បណ្ណ បានប្រគល់សម្ភារៈគាំពារបរិស្ថានដល់សាលារៀនចំនួន១២២ធុង បានផលិតវីដេអូផ្សព្វផ្សាយមេត្រីភាពបរិស្ថានចំនួន១២ បានផលិតបទចម្រៀងមេត្រីភាពបរិស្ថានចំនួន១៥ និងបានសម្របសម្រួលផ្ដល់បណ្ណក្នុងកម្មវិធីប្រឡងប្រណាំងនានាចំនួន៩៤បណ្ណ។

| សូចនាករ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| រៀបចំបទដ្ឋានគតិយុត្ត | ច្បាប់ | - | ១ | ១ | ១ | ២ |
| កម្មវិធីប្រតិបត្តមេត្រីភាពបរិស្ថាន | បណ្ណ | ៨៨ | ១៨ | ៤៩៨ | ៤៨៤ | ៣០៥ |
| ប្រគល់សម្ភារៈគាំពារបរិស្ថានដល់សាលារៀន និងទីកន្លែងផ្សេងៗ | ធុង | - | - | - | ១២២ | - |
| ផលិតវីដេអូផ្សព្វផ្សាយមេត្រីភាពបរិស្ថាន | វីដេអូ | ១ | ១ | ១ | ១ | ៨ |
| ផលិតបទចម្រៀងមេត្រីភាពបរិស្ថាន | បទ | ៣ | ៣ | ៣ | ៣ | ៣ |
| សម្របសម្រួលផ្តល់បណ្ណក្នុងកម្មវិធីប្រឡង-ប្រណាំងនានា | បណ្ណ | - | - | - | - | ៩៤ |

## ២- វប្បធម៌ សាសនា និងព័ត៌មាន

### ២.១- លទ្ធផលការងារសំខាន់ៗរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ស្របតាមចក្ខុវិស័យ«**អភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម**» ដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ និងគោលបំណង គោលនយោបាយ«**ការអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ**» នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលជាបន្តបន្ទាប់។ ក្នុងរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៧ រយៈពេល៩ខែ ឆ្នាំ២០២១) ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានខិតខំអនុវត្តការងារគ្រប់មុខព្រួញទាំងអស់នៃយុទ្ធសាស្ត្រនិងសម្រេចបានលទ្ធផលការងារជាច្រើនគួរជាទីមោទនៈ ដោយអនុលោមទៅតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

នៅក្នុងផ.យ.អ.ជ.២០១៩-២០២៣ ការងារវប្បធម៌និងវិចិត្រសិល្បៈស្ថិតនៅ«**ផ្នែកទី៤**» ត្រង់ចំណុចទី៤.២.«**ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ**» (ការធ្វើពិពិធកម្មសេដ្ឋកិច្ច) និងចំណុចទី៦.២. «**ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព**» (ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន)។ ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗនៅក្នុងវិស័យវប្បធម៌និងវិចិត្រសិល្បៈ គឺផ្តោតសំខាន់លើការជំរុញការអភិវឌ្ឍវិស័យកម្សាន្ត អក្សរសិល្ប៍ សិល្បៈ គំនូរជីវចល ភាពយន្ត និងទំនិញវប្បធម៌ជាច្រើនផ្សេងទៀត ដើម្បីរួមចំណែកបង្កើតការងារ សហគ្រិនភាព តម្លៃបន្ថែម និងភាពសម្បូរបែបនៃផលិតផលក្នុងស្រុក ពិសេសនៅក្នុងសេដ្ឋកិច្ចច្នៃប្រឌិតរបស់ប្រទេសកម្ពុជា។ ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព គឺផ្តោតលើការអភិរក្ស និងលើកស្ទួយតម្លៃវប្បធម៌ជាតិ តាមរយៈការជួសជុលអភិរក្ស ការពង្រឹងការគ្រប់គ្រង ការជំរុញការចុះបញ្ជីសារពើភណ្ឌ ការសិក្សាស្រាវជ្រាវនិងការចងក្រងឯកសារ និងការបង្កើនការផ្សព្វផ្សាយវប្បធម៌ជាដើម។

ចំពោះវឌ្ឍនភាពការងារសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា និងផ.យ.អ.ជ. ២០១៩-២០២៣ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ ក៏ដូចជាទិសដៅការងារបន្តសម្រាប់រយៈពេលអាណត្តិដែលនៅសល់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានអនុវត្ត និងគ្រោងបន្តអនុវត្តនូវសកម្មភាពការងារសំខាន់ៗ រួមមានដូចខាងក្រោម៖

## ២.២- សមិទ្ធផលការងារសំខាន់ៗរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៧-រយៈពេល៩ខែ ឆ្នាំ២០២១)

## ការអភិរក្សវប្បធម៌ជាតិ

### ២.២.១- ការអភិរក្សវប្បធម៌រូបី

#### ក- ការជួសជុលនិងអភិរក្សសំណង់បុរាណ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានជួសជុលនិងអភិរក្សសំណង់បុរាណសរុបប្រមាណ១៧៧សំណង់ (ប្រាសាទបុរាណ ព្រះវិហារបុរាណ ស្ពានបុរាណ និងសំណង់បុរាណផ្សេងៗ) រួមមាន៖

- **ប្រាសាទបុរាណចំនួន១២១** ប្រាសាទឯកភ្នំ ប្រាសាទបាសែត ប្រាសាទត្រពាំងប្រាសាទ ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព ប្រាសាទព្រះសម្ពី ប្រាសាទចតុម្មុខ ប្រាសាទសែនភូវាំង ប្រាសាទតាព្រហ្មទន្លេបាទី ប្រាសាទព្រះថ្កោល ប្រាសាទបាកាន ប្រាសាទព្រះធាតុតូច ប្រាសាទព្រះធាតុធំ ប្រាសាទភ្នំជីសូរ្យ ប្រាសាទក្លប្ញ(ប្រាសាទប្រុស) ប្រាសាទទន្លេស្ងួត ប្រាសាទក្រហម ប្រាសាទខ្លាឃ្មុំ ប្រាសាទកណ្តាលស្រះស្រង់ ប្រាសាទផ្ទឹ ប្រាសាទមេបុណ្យខាងលិច ប្រាសាទចៅស្រីវិបុល ប្រាសាទលលៃ ប្រាសាទបាតជុំ ប្រាសាទតានៃ ប្រាសាទប្រី ប្រាសាទបន្ទាយសម្រេ ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទព្រះខ័ន ប្រាសាទភ្នំបាខែង ប្រាសាទតាព្រហ្ម ប្រាសាទព្រះពិធូរ ប្រាសាទអកយំ ប្រាសាទបាគង ក្រុមប្រាសាទយាយព័ន្ធ(S3, S5, S7, S8, S9, S10, និង S11) ក្រុមប្រាសាទសំបូរ(N1, N11, និង N27) ប្រាសាទដើមចន្ទ(N15, N16, និង N16ស្ងួន) ប្រាសាទអាស្រមមហាឫសី (N17 និង N19) ប្រាសាទសណ្តាន់(N21) ប្រាសាទស្រង់ព្រះ(N22) ប្រាសាទបុះរាម(N24) ប្រាសាទដូនមោង (D2) ក្រុមប្រាសាទតាម៉ម(T1) ប្រាសាទត្រពាំងរពាក់(Y) ប្រាសាទគក់ទ្រូង(W) ក្រុមប្រាសាទរបងរមាស(K2 និងK7) ប្រាសាទស្រីគ្រប់ល័ក្ខ(L5, L6, និង L7) ប្រាសាទព្រះវិហារ ប្រាសាទបន្ទាយពីរជាន់ ប្រាសាទប្រាង្គ ប្រាសាទឥដ្ឋ ប្រាសាទគោកគ្រង ប្រាសាទក្រចាប់ ប្រាសាទរាមកេ្តី ប្រាសាទខ្នា និងប្រាសាទដងទង់។ល។

- **ព្រះវិហារបុរាណចំនួន១៤** នៅវត្តខ្សាច់ពោយ វត្តទួលខ្សាច់(វត្តកោះផ្ដៅ) វត្តជន្លឹង វត្តអង្គរស្បូវ វត្តទស្សពិត វត្តស្លែង វត្តចិនដំដែក វត្តរាជបូណ៌ វត្តព្រែកអំបិល វត្តកោះតេជោ វត្តស្រីទួល វត្តស្វាយសាច់ភ្នំ វត្តកោជន្លឹង និងវត្តកំពង់ព្រះ

- **ខ្លោងទ្វារចំនួន៤** ខ្លោងទ្វារខាងលិចប្រាសាទនគរបាជ័យ ខ្លោងទ្វារខាងលិចប្រាសាទឯកភ្នំ ខ្លោងទ្វារខាងលិចនៃប្រាសាទចៅស្រីវិបុល និងខ្លោងទ្វារខាងលិចនៃប្រាសាទតាព្រហ្មទន្លេបាទី

- **កំពង់ទឹកចំនួន១** កំពង់ទឹកនៅបារាយណ៍មេបុណ្យនៃប្រាសាទបន្ទាយឆ្មារ

- **ស្ពានបុរាណចំនួន៥** ស្ពានទ័ព ស្ពានហាលខាងកើតប្រាសាទបាកាណ ស្ពានតាអោង ស្ពានហាលខាងលិចនៅប្រាសាទអង្គរវត្ត និងស្ពានហាលនៅមុខខ្លោងទ្វារប្រាសាទព្រះខ័ន

- **សំណង់ផ្សេងៗចំនួន៣២** កុដិបុរាណ សារមន្ទីរជាតិ បណ្ណាល័យជាតិ។ល។

#### ខ- ការអភិរក្សនិងគ្រប់គ្រងវត្ថុបុរាណ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានធ្វើការអភិរក្សនិងគ្រប់គ្រងវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រ ដូចជា៖

- ជួសជុលនិងអភិរក្សវត្ថុបុរាណនិងវត្ថុសិល្បៈសរុបប្រមាណ៩ ២៣០វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង/គ្រាប់
- ជួសជុលនិងអភិរក្សវត្ថុជាតិពន្ធុសាស្ត្រសរុបប្រមាណ៥០៩មុខ

- រកឃើញនិងទទួលបានវត្ថុបុរាណ វត្ថុសិល្បៈថ្មីៗពីគ្រប់ប្រភពសរុបប្រមាណ៣៤ ១៧៨វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង/គ្រាប់ ក្នុងនោះរួមមាន៖

- •រកឃើញថ្មីសរុបប្រមាណ២ ៦២៤វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង/គ្រាប់
- •ទទួលបានពីប្រជាពលរដ្ឋសរុបប្រមាណ៤ ៥៤១វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង
- •ទទួលបានពីសមត្ថកិច្ចសរុបប្រមាណ២ ១៤៦វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង
- •ទទួលបានពីបរទេសឬពីជនបរទេសសរុបប្រមាណ១៦៥វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង និង
- •ទទួលបានពីប្រភពផ្សេងៗសរុបប្រមាណ១០៨៣វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង។

- ចុះបញ្ជីវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រសរុបប្រមាណ២៥ ៣៩២វត្ថុ/រូប/ដុំ/ផ្ទាំង/បំណែក/គ្រាប់(វត្ថុបុរាណនិងវត្ថុសិល្បៈចំនួន២២ ៨៦៦វត្ថុ/រូប/ដុំ/ផ្ទាំង/បំណែក/គ្រាប់ និងវត្ថុជាតិពន្ធុសាស្ត្រចំនួន២ ៥២៦មុខ)

- បញ្ចូលទិន្នន័យវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋាន (Database) សរុបប្រមាណ១២ ៨៣៩វត្ថុ/រូប/ដុំ/ផ្ទាំង/បំណែក

- សិក្សាវិភាគវត្ថុបុរាណ និងវត្ថុសិល្បៈ សរុបប្រមាណ១ ៦៨០វត្ថុ/រូប/ដុំ/ផ្ទាំង/បំណែក។ល។

**គ- ការងារបុរាណវិទ្យា**

ចំពោះការងារបុរាណវិទ្យាសំខាន់ៗ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានអនុវត្តសកម្មភាពការងារសំខាន់ៗដូចជា៖

- សម្អាតនិងរៀបចំសណ្តាប់ធ្នាប់នៅតាមបុរាណដ្ឋានសំខាន់ៗសរុបប្រមាណ២០៩បុរាណដ្ឋាន
- រកឃើញបុរាណដ្ឋានថ្មីសរុបប្រមាណ១ ៣៧២បុរាណដ្ឋាន
- ធ្វើការបោះបង្គោលតម្រុយតាមបុរាណដ្ឋានសរុបប្រមាណ៦០៧បុរាណដ្ឋាន
- បោះបង្គោលព្រំឬបង្គោលសម្គាល់ទីតាំងបុរាណដ្ឋានសរុបប្រមាណ៣៨៧បុរាណដ្ឋាន
- បោះបង្គោលតាមបុរាណដ្ឋានសរុបប្រមាណ១ ០៧២បង្គោល
- ផ្ទៀងផ្ទាត់និយាមការ ទំហំ និងដែនការពារបុរាណដ្ឋានសរុបប្រមាណ៤ ៨៧៨បុរាណដ្ឋាន
- ធ្វើសាលាកបត្រកាន់កាប់បុរាណដ្ឋានសរុបប្រមាណ៩១៤បុរាណដ្ឋាន
- ធ្វើប្លង់ឬបណ្ណកម្មសិទ្ធិរដ្ឋកាន់កាប់បុរាណដ្ឋានសរុបប្រមាណ៤៧៦បុរាណដ្ឋាន
- ធ្វើបច្ចុប្បន្នភាពបុរាណដ្ឋានសរុបប្រមាណ១ ៩០៤បុរាណដ្ឋាន
- ធ្វើកំណាយបុរាណវិទ្យាសរុបប្រមាណ៩៨បុរាណដ្ឋាន
- អនុវត្តការងារបុរាណវិទ្យាផ្សេងៗសរុបប្រមាណ៧៥បុរាណដ្ឋាន។ល។

**ឃ- ការងារនីតិកម្ម**

ដើម្បីពង្រឹងក៏ដូចជាបង្កើនប្រសិទ្ធភាពក្នុងការអភិរក្សសម្បត្តិវប្បធម៌រូបី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានអនុវត្តសកម្មភាពការងារនីតិកម្មសំខាន់ៗដូចជា៖

- ប្រជុំឆ្លងសេចក្តីព្រាងឯកសារគតិយុត្តសំខាន់ៗចំនួន៥រួមមាន៖
  - •សេចក្តីព្រាងច្បាប់ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ជាតិ (វិសោធនកម្ម)
  - •សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ
  - •សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងគ្រប់គ្រងរមណីយដ្ឋានប្រាសាទកោះកេរ

•ប្រកាសស្តីពីការគ្រប់គ្រងសំណង់សម័យក្រោយអង្គរ
•សេចក្តីណែនាំស្តីពីនីតិវិធីក្នុងការស្នើសុំជួសជុលឬសាងសង់សំណង់គ្រប់ប្រភេទក្នុងតំបន់រមណីយដ្ឋានប្រាសាទបន្ទាយឆ្មារ។

- បញ្ចប់ការសិក្សាស្រាវជ្រាវអំពីប្រសិទ្ធភាពនិងផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តលើការគ្រប់គ្រងសំណង់បេតិកភណ្ឌសម័យអាណានិគមបារាំងនៅខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តកំពង់ឆ្នាំង។

**ង- ការងារស្រាវជ្រាវនិងស្ថិតិ**

សកម្មភាពសិក្សាស្រាវជ្រាវនិងចងក្រងស្ថិតិដែលក្រសួងបានអនុវត្តកន្លងទៅ មានចំនួនសរុបប្រមាណ៦៤០សកម្មភាព ដោយការសិក្សាស្រាវជ្រាវនិងចងក្រងស្ថិតិក្នុងផ្នែកវប្បធម៌រូបីមានចំនួនប្រមាណ១៣៣សកម្មភាព ដូចជាៈ

- ស្រង់ទិន្នន័យទួលឡផលិតភាជន៍នៅស្ថានីយឡទ្វារជីផ្ទាំងនៃរាជធានីអង្គរធំ
- សិក្សាស្រាវជ្រាវវត្ថុបុរាណនៅខេត្តចំនួន៨ រួមមានខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តស្ទឹងត្រែង ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ
- ប្រមូលនិងរៀបចំទិន្នន័យវត្ថុបុរាណក្នុងសារមន្ទីរ
- សិក្សាពាក្យបច្ចេកទេសសម្រាប់កុលាលភាជន៍ប្រពៃណី
- សិក្សាស្រាវជ្រាវទួលនៅខាងលិចខ្លោងទ្វារជីផ្ទាំងនៃរាជធានីអង្គរធំ( ឡដុតភាជន៍)
- សិក្សាស្រាវជ្រាវនៅប្រាសាទអកយំ
- សិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យាអំពីផ្លូវបុរាណពីអង្គរទៅបាគង
- សិក្សាស្រាវជ្រាវឡដុតកុលាលភាជន៍គោកជីផ្ទាំងប្រាសាទកោះកេរ
- សិក្សាស្រាវជ្រាវស្ថានីយបុរាណវិទ្យានៅរមណីយដ្ឋានប្រាសាទកោះកេរ
- សិក្សាស្រាវជ្រាវកុលាលភាជន៍លើផ្ទៃដីក្នុងកំពែងរាជធានីឥសានបុរៈ
- សិក្សាស្រាវជ្រាវប្រព័ន្ធបង្ហូរទឹកបុរាណ នៅអមសងខាងស្ពានហាលចន្លោះគោបុរៈទី៣ និងទី៤ ប្រាសាទព្រះវិហារ
- សិក្សាស្រាវជ្រាវក្រុងអង្គរធំ។ល។

**២.២.២- ការអភិរក្សវប្បធម៌អរូបី**

**ក- ការស្តារនិងពង្រឹងសិល្បៈវប្បធម៌របស់សហគមន៍**

ចំពោះការងារអភិរក្សសិល្បៈវប្បធម៌អរូបីរបស់សហគមន៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានយកចិត្តទុកដាក់និងសហការជាមួយសហគមន៍ក្នុងការបណ្តុះបណ្តាលនិងរៀបចំការសម្តែងសិល្បៈដោយក្នុងនោះក្រសួងបានស្តារឱ្យល្ខោនវត្តកៀនស្វាយក្រៅរស់រានឡើងវិញ ព្រមទាំងបានពង្រឹងការថែរក្សាវប្បធម៌របស់សហគមន៍សំខាន់ៗ រួមមានៈ

- សហគមន៍ជនជាតិដើមភាគតិចចំនួន៨ខេត្ត( ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តព្រះវិហារ និងខេត្តកំពង់ស្ពឺ)
- សហគមន៍ទាញព្រ័ត្រនៅខេត្តចំនួន៣( ខេត្តកណ្តាល ខេត្តកំពង់ធំ និងខេត្តសៀមរាប)
- សហគមន៍សិល្បៈវប្បធម៌នៅខេត្តចំនួន៨( ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តតាកែវ ខេត្តកំពង់ធំ និងខេត្តសៀមរាប)។ល។

**ខ- ការសិក្សាស្រាវជ្រាវនិងចងក្រងឯកសារ**

សកម្មភាពសិក្សាស្រាវជ្រាវនិងចងក្រងស្ថិតិដែលក្រសួងបានអនុវត្តកន្លងមកមានចំនួនសរុបប្រមាណ ៦៤០សកម្មភាព(ផ្នែកវប្បធម៌អរូបីមានចំនួន៤៩១សកម្មភាព និងផ្នែកផ្សេងៗចំនួន១៦សកម្មភាព)។

ដើម្បីមានឯកសារគ្រប់គ្រាន់សម្រាប់ធ្វើជាក្បួនខ្នាត សម្រាប់ផ្សព្វផ្សាយ និងសម្រាប់សិក្សាស្រាវជ្រាវនាពេលអនាគត ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានរៀបចំសិក្សាស្រាវជ្រាវ ចងក្រង និងបោះពុម្ពសៀវភៅ ក៏ដូចជាឯកសារអំពីសិល្បៈវប្បធម៌ខ្មែរសំខាន់ៗ រួមមានដូចជា៖

- ស្រាវជ្រាវចងក្រងចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី
- ស្រាវជ្រាវចងក្រងឯកសារល្ខោនខោល
- ស្រាវជ្រាវចងក្រងឯកសារមរតកមនុស្សរស់
- ស្រាវជ្រាវចងក្រងឯកសារល្បែងទាញព្រ័ត្រ
- ស្រាវជ្រាវចងក្រងឯកសារស្មារតីចងចាំពិភពលោក
- ស្រាវជ្រាវនិងចងក្រងឯកសារនំបញ្ចុកក្នុងសង្គមខ្មែរ
- ស្រាវជ្រាវនិងចងក្រងឯកសារដណ្ដាំស្លក្នុងសង្គមខ្មែរ
- ស្រាវជ្រាវនិងចងក្រងរបាយការណ៍ចាប៉ីអនុសញ្ញាអង្គការយូណេស្កូ២០០៣
- ស្រាវជ្រាវនិងចងក្រងរបាយការណ៍អនុសញ្ញាអង្គការយូណេស្កូ២០០៥
- សិក្សាស្រាវជ្រាវនិងចងក្រងឯកសាររបាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យ
- សិក្សាស្រាវជ្រាវនិងចងក្រងសៀវភៅស្ដីពីស្បែកធំ
- សិក្សាស្រាវជ្រាវអំពីចម្លាក់ស្បែក តម្បាញសូត្រ និងសម្ភារៈប្រើប្រាស់ផ្ទះខ្មែរ
- សិក្សាស្រាវជ្រាវនិងស្រង់ទិន្នន័យសាស្ត្រាស្លឹករឹត
- សិក្សាស្រាវជ្រាវនិងចងក្រងតម្បាញសូត្រខ្មែរ
- សិក្សាស្រាវជ្រាវនិងចងក្រងឯកសារ«ភ្លេងមហោរី និងពិណពាទ្យ»
- សិក្សាស្រាវជ្រាវនិងចងក្រងឯកសារ«ហ្វូនបាសាក់»
- ប្រែសម្រួលពីភាសាបារាំងមកជាភាសាខ្មែរនូវសៀវភៅនារីរបាំកម្ពុជា។ល។

**គ- ការអភិរក្សឯកសារបុរាណនិងឯកសារចាស់ៗ**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានបន្តថែទាំ និងអភិរក្សឯកសារបុរាណ និងឯកសារចាស់ៗសំខាន់ៗ ដូចជា៖

- ត្រួតពិនិត្យនិងសម្អាតសាស្ត្រាស្លឹករឹតចំនួន៣០ ៩៧២ខ្សែ
- ថតសាស្ត្រាស្លឹករឹតចំនួន១៣១ ៦៦៣ប៉ុស្តិ៍
- ស្កេនសៀវភៅចាស់ៗចំនួន៥៩០ក្បាល
- ស្កេនកាសែតចាស់ៗចំនួន៧២ក្បាល
- បិទបាកូដសៀវភៅចំនួន៧ ៧២៥ក្បាល
- ត្រួតពិនិត្យនិងសម្អាតកាសែត SPK ចំនួន១ ៤២៥ក្បាល
- ថតកាសែត SPK ចំនួន៩ ៤៧៥ប៉ុស្តិ៍។ល។

## ២.៣- ការលើកស្ទួយតម្លៃវប្បធម៌ជាតិ

### ២.៣.១- ការលើកស្ទួយតម្លៃវប្បធម៌រូបី

**ក- ការចុះបញ្ជីបេតិកភណ្ឌវប្បធម៌រូបីជាបេតិកភណ្ឌវប្បធម៌អន្តរជាតិ**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបាន៖

- «**ប្រាសាទសំបូរព្រៃគុក**» បានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧

- រៀបចំចងក្រងឯកសារដើម្បីត្រៀមស្នើសុំចុះ«**ប្រាសាទកោះកេរ**» ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ

- រៀបចំបញ្ជីត្រៀម(Tentative List) ដើម្បីគ្រោងស្នើសុំចុះសម្បត្តិវប្បធម៌រូបីដែលមានសក្តានុពលក្នុងបញ្ជីបេតិកភណ្ឌរបស់អង្គការយូណេស្កូ រួមមានក្រុមប្រាសាទបន្ទាយឆ្មារ រមណីយដ្ឋានអង្គរបុរីនិងភ្នំដា រមណីយដ្ឋានគូលែន ក្រុមប្រាសាទបេងមាលា ក្រុមប្រាសាទព្រះខ័នកំពង់ស្វាយ រមណីយដ្ឋានឧដុង្គ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក និងអតីតមន្ទីរឃុំឃាំង«ម-១៣»។

**ខ- ការងារនីតិកម្ម**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបាន៖

- រៀបចំព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិព្រះវិហារជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

- ផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ លិខិតបទដ្ឋានគតិយុត្ត សីលធម៌សង្គម ការគ្រប់គ្រងដីធ្លីក្នុងតំបន់បេតិកភណ្ឌ និងការផ្សព្វផ្សាយផ្សេងៗដល់ប្រជាពលរដ្ឋ និងអាជីវករ សរុបប្រមាណ ៥៩ ៧៩៥អង្គ/នាក់

- ផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិនៅខេត្តចំនួន៧(ខេត្តកែប ខេត្តព្រៃវែង ខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង

- ចុះលើកស្លាកសញ្ញា និងផ្ទាំងប៉ាណូ ដើម្បីអប់រំផ្សព្វផ្សាយប្រយុទ្ធប្រឆាំងពាក់ព័ន្ធនឹងកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិនៅខេត្តចំនួន១៦(ខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តកណ្តាល) ក្នុងនោះមានស្រុកក្រុងចំនួន៧ រួមមាន ស្រុកជាំក្សាន្ត ស្រុកឆែប ស្រុករំដួល ស្រុកកំពង់រោទិ៍ ក្រុងបាវិត ស្រុកកោះធំ និងស្រុកលើកដែកដែលជាគោលដៅមួយនៃការអនុវត្តគម្រោងមេគង្គ-ឡានឆាង។

**គ- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

ចំពោះកិច្ចសហប្រតិបត្តិការវប្បធម៌អន្តរជាតិដើម្បីរួមចំណែកក្នុងការងារលើកស្ទួយតម្លៃវប្បធម៌ជាតិ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបាន៖

- រៀបចំនិងប្រកាសទីក្រុងសៀមរាបរបស់កម្ពុជា ជា"**ទីក្រុងវប្បធម៌អាស៊ាន**" សម្រាប់ឆ្នាំ២០២១-២០២២ នៅក្នុងកិច្ចប្រជុំលើកទី៩ របស់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកផ្នែកវប្បធម៌និងសិល្បៈដែលប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ

- បន្តរៀបចំនិងត្រៀមអនុវត្តន៍ផែនការសកម្មភាព ដើម្បីអបអរនិងលើកស្ទួយតម្លៃទីក្រុងសៀមរាប ជាទីក្រុងវប្បធម៌អាស៊ានសម្រាប់ឆ្នាំ២០២១-២០២២

- រៀបចំផ្សព្វផ្សាយឱ្យសាធារណជនបានដឹងនិងស្គាល់ទីតាំងវប្បធម៌សំខាន់ៗ តាមរយៈការរៀបចំព្រឹត្តិការណ៍ និងការបង្កើនការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមហ្វេសប៊ុក

- បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសយន្តការ អាយស៊ីស៊ី-អង្គរ និងអាយស៊ីស៊ី-ព្រះវិហារ ដើម្បីលើកកម្ពស់ការអភិរក្ស ការលើកស្ទួយតម្លៃ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់បេតិកភណ្ឌពិភពលោក។ល។

### ២.៣.២- ការលើកស្ទួយតម្លៃវប្បធម៌អរូបី

#### ក- ការចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីជាបេតិកភណ្ឌវប្បធម៌អន្តរជាតិ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបាន៖

- "**ល្ខោនខោល**" បានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨

- បន្តរៀបចំឯកសារដើម្បីស្នើសុំចុះ «**នំបញ្ចុក**» និង «**ក្បាច់គុនល្បុក្កតោ**» ទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ

- បន្តរៀបចំបញ្ជីត្រៀម (Tentative List) នៃមរតកវប្បធម៌សំខាន់ៗផ្សេងទៀតរបស់កម្ពុជា ដើម្បីត្រៀមស្នើសុំចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ (សម្រាប់មរតកវប្បធម៌អរូបី គឺព្រះរាជពិធីបុណ្យអុំទូក)។

#### ខ- ការរៀបចំព្រឹត្តិការណ៍វប្បធម៌អរូបីសំខាន់ៗ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបាន៖

- រៀបចំមហោស្រពសំខាន់ៗដូចជា៖

- មហោស្រពសិល្បៈដណ្តាំស្លម្ហូបអាហារខ្មែរ នៅរាជធានីភ្នំពេញ
- មហោស្រពបង្ហាញទម្រង់សម្លៀកបំពាក់ប្រពៃណីខ្មែរ នៅរាជធានីភ្នំពេញ
- មហោស្រពបង្អើរខ្លែងខ្មែរនៅខេត្តចំនួន៣ (ខេត្តស្វាយរៀង ខេត្តកោះកុងនិងខេត្តបាត់ដំបង)
- មហោស្រពសិល្បៈអាយ៉ៃ ចាប៉ី និទានរឿង និងចម្រៀងខ្សែដៀវ ទូទាំងប្រទេស ឆ្នាំ២០១៧
- មហោស្រពល្ខោនស្បែកធំ នៅខេត្តសៀមរាប
- មហោស្រពសិល្បៈជាតិ«ល្ខោនយីកេ» លើកទី១ (ខេត្តតាកែវ)
- មហោស្រពសិល្បៈតន្ត្រីគងជនជាតិដើមភាគតិច នៅខេត្តរតនគិរី
- មហោស្រពចាប៉ីដងវែង
- មហោស្រពសិល្បៈជាតិស្តីពីតម្បាញសូត្រ
- មហោស្រពសិល្បៈជាតិស្តីពីសិល្បៈខ្មុកស្មាច់
- មហោស្រពសិល្បៈជាតិស្តីពីសិល្បៈចម្លាក់ស្បែក (ព្រះរាមផ្លែងសរ)។ល។

- រៀបចំពិព័រណ៍សិល្បៈសំខាន់ៗដូចជា៖

- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីសិល្បៈគំនូរបុរាណ

- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីសិល្បៈគំនូរសហសម័យ
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីសិល្បៈហូលពិតានខ្មែរ
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីស្ថាបត្យកម្មខ្មែរសម័យទំនើបនិងប្រទេសជប៉ុន
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីស្នាដៃសិល្បៈសូនរូប
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីអ្នករាំល្ខោនហ្លួងក្រុងកម្ពុជាធិបតី
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីកម្ពុជា និងសង្គ្រាមលោកលើកទី១ បេតិកភណ្ឌក្រោមទឹក
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីវត្ថុបុរាណដែលបាត់បង់ពីសារមន្ទីរវត្តពោធិ៍វាល និងសារមន្ទីរខេត្តបាត់ដំបង
- ពិព័រណ៍ស្តីពីគ្រឿងអលង្កាសម្រាប់ព្រះបដិមា និងមនុស្ស : មាស និងប្រាក់នៃសារមន្ទីរជាតិកម្ពុជា
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីពេលវេលា
- ពិព័រណ៍ស្តីពីថ្មពីឋានព្រះចន្ទនៅកម្ពុជា
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីរបាំព្រះរាជទ្រព្យ
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីសិលាចារឹកមុនសម័យអង្គរ សិលាចារឹកដែលមានលេខសញ្ញាសូន្យដំបូងគេ
- ពិព័រណ៍អចិន្ត្រៃយ៍ស្តីពីវត្ថុសម័យបុរេប្រវត្តិសាស្ត្រ
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីប្រវត្តិសារមន្ទីរជាតិ
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីការរៀបការដោយបង្ខំ
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីជីវិតជនរងគ្រោះ តឹក សេងអេង
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីគំនូរការចងចាំ
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពី៤០ឆ្នាំ : ការចងចាំជនរងគ្រោះស-២១
- ពិព័រណ៍ចល័តស្តីពីអគារបីពណ៌
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីការចងចាំថ្ងៃ២០ឧសភា
- ពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពីខុសឆ្ងាយពីក្តីរំពឹង និង
- ពិព័រណ៍រូបថតស្តីពីស្ថាបនិក ប្រធាន និងបុគ្គលិកសារមន្ទីរ ។ល។

- រៀបចំសិក្ខាសាលាសំខាន់ៗដូចជា៖

- សិក្ខាសាលាស្តីពីទម្រង់សម្លៀកបំពាក់ក្នុងសង្គមខ្មែរ
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសិល្បៈតម្បាញសូត្រ
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសិល្បៈខ្ចុកស្នាច់
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសិល្បៈចម្លាក់ស្បែក
- សិក្ខាសាលាស្តីពីល្ខោនស្បែកធំ នៅខេត្តសៀមរាប
- សិក្ខាសាលាស្តីពីល្ខោនយីកេ។ល។

**គ- ការសម្តែងសិល្បៈនិងប្រគំតន្ត្រី**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបាន៖

- រៀបចំនិងសហការរៀបចំការសម្តែងសិល្បៈសរុបប្រមាណ៤ ២៦៩លើក(ក្រៅប្រទេសចំនួន៣៩លើក) ដោយមានអ្នកទស្សនាប្រមាណជាង៤៦៦ ៣២៧នាក់

- ចាត់ក្រុមសិល្បៈរបស់នាយកដ្ឋានសិល្បៈទស្សនីយភាពនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈចេញសម្តែងសរុបចំនួន២៣២លើក(ក្នុងប្រទេស២០០លើក និងក្រៅប្រទេសចំនួន៣២លើក ដោយមានអ្នកចូលរួមទស្សនាសរុបប្រមាណ៦១ ៧១២នាក់) រួមមាន៖

- សម្តែងសិល្បៈទស្សនីយភាពនិងប្រគំភ្លេងបុរាណក្នុងព្រឹត្តិការណ៍ជាតិសំខាន់ៗដូចជា៖
  - ពិធីបុណ្យចម្រើនព្រះជន្មរបស់ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**
  - ព្រះរាជពិធីបួងសួង នៅព្រះបរមរាជវាំង
  - ពិធីគ្រិស្តសង្ក្រាន្ត នៅព្រះបរមរាជវាំង
  - ពិធីបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា
  - កម្មវិធី«រាត្រីចងចាំ» ដើម្បីអបអរសាទរខួបនៃការដាក់បញ្ចូលមរតកវប្បធម៌ខ្មែរ ក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ
  - ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
  - ទិវាវប្បធម៌ជាតិ
  - ពិធីបុណ្យទន្លេ
  - ពិធីបុណ្យសមុទ្រ
  - ពិធីអបអរសោទរ«ល្ខោនខោល» ដែលត្រូវបានដាក់បញ្ចូលជាសម្បត្តិវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ
  - ពិធីដង្ហែទូកងវែងជាងគេលើលោក នៅខេត្តព្រៃវែង
  - ពិធីអភិសេករូបសំណាកដាវដែកកំពង់ស្វាយ នៅខេត្តកំពង់ធំ។ល។
- សម្តែងសិល្បៈទស្សនីយភាពក្នុងកម្មវិធីអន្តរជាតិក្នុងនិងក្រៅប្រទេស (នៅបរទេសចំនួន១០ប្រទេសរួមមាន ចិន រុស្ស៊ី បេឡារុស វៀតណាម ថៃ កូរ៉េ ជប៉ុន ហ្វីលីពីន សិង្ហបុរី និងឥណ្ឌា) ដូចជា៖
  - ពិធីបដិសណ្ឋារកិច្ចទទួលស្វាគមន៍គណៈប្រតិភូបរទេសជាន់ខ្ពស់សំខាន់ៗ ក្រោមការដឹកនាំរបស់៖
    - គណៈប្រតិភូជាន់ខ្ពស់នៃប្រទេសសិង្ហបុរី
    - គណៈប្រតិភូជាន់ខ្ពស់នៃមីយ៉ាន់ម៉ា
    - គណៈប្រតិភូជាន់ខ្ពស់នៃប្រទេសឡាវ
    - គណៈប្រតិភូជាន់ខ្ពស់នៃប្រទេសវៀតណាម
    - គណៈប្រតិភូទីប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន
    - គណៈប្រតិភូជាន់ខ្ពស់នៃប្រទេសថៃ
    - គណៈប្រតិភូជាន់ខ្ពស់នៃប្រទេសបង់ក្លាដេស
    - ឯកឧត្តម **លីវ យុងសាន** សមាជិកគណៈអចិន្ត្រៃយ៍នៃការិយាល័យនយោបាយបក្សកុម្មុយនិស្តនៃសាធារណរដ្ឋប្រជាមានិតចិន
    - ឯកឧត្តម **ថងលុន ស៊ីសុលីត** (Thongloun Sisoulith) នាយករដ្ឋមន្ត្រីនៃប្រទេសឡាវ
    - ឯកឧត្តម **យ៉ាណូស អាឌ័រ** (JANOS ADER) ប្រធានាធិបតីនៃប្រទេសហុងគ្រី

- o ឯកឧត្តម **ប៊ុនញ៉ាំ វរជិត** (BOUNNHANG VORACHITH) អគ្គលេខាធិការមជ្ឈិមបក្សប្រជាជនបដិវត្តឡាវ និងជាប្រធានរដ្ឋនៃប្រទេសឡាវ
- o ឯកឧត្តម **ម៉ៃទ្រីប៉ាឡា ស៊ីរីសេនា** (Maithripala Sirisena) ប្រធានាធិបតីនៃប្រទេសស្រីលង្កា
- o លោកជំទាវ **អោង សានស៊ូជី** ទីប្រឹក្សារដ្ឋនៃប្រទេសមីយ៉ាន់ម៉ា
- o ឯកឧត្តម **ខេ ភី សាម៉ា អូលី** នាយករដ្ឋមន្ត្រីនៃប្រទេសនេប៉ាល់
- o ឯកឧត្តម **NGUYEN PHU TRONG** អគ្គលេខាធិការបក្សកុម្មុយនិស្តវៀតណាម និង
- o ឯកឧត្តម **សុង ថៅ** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិ មជ្ឈិមបក្សកុម្មុយនិស្តចិន

- ▪ របាំបុប្ផាអាស៊ានសម្រាប់ផ្សាយផ្ទាល់ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកវប្បធម៌លើកទី៩ កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីអាស៊ានទទួលបន្ទុកវប្បធម៌លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ
- ▪ កម្មវិធីសម្តែងសិល្បៈរួមគ្នាកម្ពុជា-ចិន
- ▪ ព្រឹត្តិការណ៍ប្រកួតប្រជែងបវរកញ្ញាភពផែនដី (Miss Planet International)
- ▪ កម្មវិធីប្រកាសក្រុមប្រឹក្សាវប្បធម៌អាស៊ីជាផ្លូវការ នៅព្រលានជល់ដំរី ខេត្តសៀមរាប
- ▪ កម្មវិធីខួបទី២៥ឆ្នាំ នៃការបង្កើត ICC-Angkor នៅខេត្តសៀមរាប
- ▪ កម្មវិធីខួប៦០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងចិននិងកម្ពុជា
- ▪ កម្មវិធីបុណ្យផ្កា នៅស្ថានទូតថៃ
- ▪ កិច្ចប្រជុំលើកទី១៥ នៃរដ្ឋមន្ត្រីក្រសួងបរិស្ថានអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ។ល។

## ២.៤- ការអភិវឌ្ឍវប្បធម៌ជាតិ

### ២.៤.១- ការអភិវឌ្ឍវប្បធម៌រូបី

#### ក- ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់បេតិកភណ្ឌវប្បធម៌

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានខិតខំកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងលើកកម្ពស់សោភណ្ឌភាពតំបន់បេតិកភណ្ឌវប្បធម៌ ដើម្បីបង្កើនភាពទាក់ទាញសម្រាប់វិស័យទេសចរណ៍ និងជានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់បេតិកភណ្ឌវប្បធម៌ ដូចជា៖

គម្រោងរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងលើកកម្ពស់សោភណ្ឌភាពក្នុងរមណីយដ្ឋានអង្គរ ដែលជាដួងព្រលឹងជាតិនិងជាបេតិកភណ្ឌវប្បធម៌ពិភពលោក រួមមាន៖

- បង្កើនភាពបៃតងគ្រប់រដូវ តាមរយៈការដាំស្មៅ ផ្កា និងដើមឈើក្នុងតំបន់អង្គរ
- រៀបចំប្រព័ន្ធស្រោចស្រពស្មៅ ផ្កា និងដើមឈើ
- ជួសជុលនិងកែលម្អទីលានមុខប្រាសាទបុរាណសំខាន់ៗក្នុងតំបន់អង្គរ
- សាងសង់និងបង្កើនគុណភាពផ្លូវធ្វើដំណើរក្នុងតំបន់អង្គរ។ល។

គម្រោងកែលម្អ លើកកម្ពស់ដំណើរការ និងភាពទាក់ទាញរបស់សារមន្ទីរនៅខេត្តសៀមរាប មានសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ សារមន្ទីរកុលាភាជន៍ នៅភូមិតានី។ល។

**ខ- ការផ្តល់សេវាសាធារណៈ**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានផ្តល់សេវាសាធារណៈផ្នែកវប្បធម៌និងវិចិត្រសិល្បៈសរុបប្រមាណ ៦៥ ០២៥សេវា ដោយក្នុងនោះសេវាសាធារណៈនៅក្នុងផ្នែកវប្បធម៌រូបី មានចំនួនប្រមាណ១៦ ១៥៩សេវា (យោងតាមទិន្នន័យដែលកត់ត្រាបាន) ដូចជា៖

សេវាពិនិត្យវត្ថុសិល្បៈនាំចេញទៅក្រៅប្រទេសសរុបចំនួន១២ ៤១៧វត្ថុ/រូប និងសេវាពិនិត្យវត្ថុសិល្បៈនាំចូលមកកម្ពុជាចំនួន៣ ៧៤២វត្ថុ/រូប។

**គ- ភ្ញៀវចូលទស្សនាទីតាំងវប្បធម៌**

ភ្ញៀវចូលទស្សនាទីតាំងវប្បធម៌សំខាន់ៗ មានចំនួនសរុបប្រមាណ១២ ៩៥៩ ៨៨៦នាក់ រួមមាន៖

- ភ្ញៀវអន្តរជាតិសរុបប្រមាណ៩ ៧២៩ ២៥៦នាក់
- ភ្ញៀវបង់ថ្លៃចូលទស្សនាសរុបប្រមាណ៩ ៧៣៣ ៦២១នាក់។

ចំពោះទីតាំងវប្បធម៌សំខាន់ៗ ដែលមានភ្ញៀវទៅទស្សនា រួមមាន៖

- **រមណីយដ្ឋានបេតិកភណ្ឌពិភពលោក** រមណីយដ្ឋានអង្គរ រមណីយដ្ឋានប្រាសាទព្រះវិហារ និងរមណីយដ្ឋានតំបន់ប្រាសាទសំបូរព្រៃគុក

- **សារមន្ទីរនៅថ្នាក់ជាតិ** សារមន្ទីរជាតិ និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

- **បុរាណដ្ឋានមួយចំនួននៅតាមរាជធានី ខេត្ត** ប្រាសាទកោះកេរ មណ្ឌលវត្តភ្នំ សារមន្ទីរនៅតាមបណ្តាខេត្ត ភ្នំសន្ទុក ភ្នំជីសូរ្យ ប្រាសាទតាព្រហ្មទន្លេបាទី ប្រាសាទភ្នំជីតាពេជ្រ ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព ប្រាសាទភ្នំជាតុ ប្រាសាទភ្នំប្រាសាទ ប្រាសាទព្រះគោ និងប្រាសាទគូរ។ល។

**២.៤.២- ការអភិវឌ្ឍវប្បធម៌អរូបី**

**ក- ការស្រាវជ្រាវនិងបង្កើតថ្មី**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈគឺជាតួអង្គមួយនៅក្នុងវិស័យសាធារណៈដែលបានរួមចំណែក នៅក្នុងដំណើរការនៃការបង្កើតនិងបង្កើនទំនិញនិងសេវាវប្បធម៌ថ្មីៗ ដើម្បីជំរុញឧស្សាហកម្មវប្បធម៌និងសេដ្ឋកិច្ចច្នៃប្រឌិត ដោយក្នុងនោះក្រសួងបានស្រាវជ្រាវ ដំឡើង និងផលិតស្នាដៃថ្មីៗជាច្រើន ដូចជា៖

ស្រាវជ្រាវនិងដំឡើងស្នាដៃសិល្បៈទស្សនីយភាពថ្មីៗចំនួន ២២ស្នាដៃ រួមមាន៖

- ចាប៉ីដងវែងរឿង«សុបិន្តកុមារ»
- ល្ខោនពោលស្រី«រឿងជ័យជេត»
- ល្ខោនយីកេរឿង«ពុទ្ធិសែននាងកង្រី»
- ល្ខោនអាប៉េរឿង«អាសព្វជាតិនាងពៅទៅរកអុស» និងរឿង«ក្អែកមាស»
- ល្ខោនស្បែកពណ៌រឿង«ចៅគីង្គក់»
- ល្ខោនស្បែកតូច«ប្រាប់ហើយនៅតែមិនជឿ»
- ល្ខោនភ្លេងការរឿង«ម៉ែអឺយ កូនផ្សេាត»
- ល្ខោនរឿង«ពុទ្ធប្រវត្តិ»
- ល្ខោនមហោរីរឿង«ធម្មបាលកុមារ»
- ល្ខោនបាសាក់រឿង«បក្សីចាំក្រុង»
- ល្ខោនបរិយាកាសរឿង«មេទ័ពកក្កី»

- ល្ខោននិយាយរឿង«ព្រះជិនវង្ស»
- ល្ខោនបុរាណរឿង«ជ័យសែន»
- របាំប្រពៃណី«សម្រស់មច្ឆាជាតិ ប៉ាសេអ៊ី»
- របាំបុរាណ«សម្លៀកបំពាក់ស្ត្រីខ្មែរ ៧ពណ៌»
- របាំបុរាណ«សំពះកុលបុត្រខ្មែរ»
- របាំបុរាណ«សម្លៀកបំពាក់ស្ត្រីខ្មែរ ៧ពណ៌»
- របាំក្លាយសួយ
- របាំស្ទូនឆ្មាំង
- របាំអបអរសាទរខួបលើកទី៤២ នៃទិវាជ័យជម្នះ៧មករា
- ទស្សនីយភាពចម្រុះដើម្បីអបអរទេវតាឆ្នាំថ្មី។ល។

ផលិតភាពយន្តនិងវីដេអូផ្សព្វផ្សាយវប្បធម៌ចំនួន៩ចំណងជើង រួមមាន៖

- ភាពយន្តឯកសារចំនួន៤ចំណងជើង
- នាទីវប្បធម៌ចំនួន៥ចំណងជើង។

### ខ- ការគាំទ្រដល់ការបង្កើតថ្មី

ដើម្បីគាំទ្រនិងជំរុញដល់តួអង្គផ្សេងៗនៅក្នុងវិស័យឯកជននិងអង្គការសង្គមស៊ីវិលឱ្យមានតួនាទីកាន់តែផុសផុលឡើងនៅក្នុងឧស្សាហកម្មវប្បធម៌និងសេដ្ឋកិច្ចច្នៃប្រឌិត ក្រសួងបានអនុវត្តសកម្មភាពការងារសំខាន់ៗដើម្បីគាំទ្រនិងជំរុញដល់ការបង្កើតនិងបង្កើនទំនិញនិងសេវាវប្បធម៌ថ្មីៗ ដោយសកម្មភាពទាំងនោះ រួមមាន៖

បានរៀបចំព្រឹត្តិការណ៍សំខាន់ៗ ដូចជា៖

- ការប្រឡងជ្រើសរើសស្នាដៃតែងនិពន្ធប្រលោមលោកនិងកំណាព្យរឿងមានចំនួន៥លើក
- ពិព័រណ៍សៀវភៅថ្នាក់ជាតិចំនួន៥លើក(អនឡាញ២លើក)
- មហោស្រពភាពយន្តជាតិខ្នាតខ្លី
- មហោស្រពភាពយន្តជាតិខ្នាតវែង
- មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី៩ និងលើកទី១០។ល។

បានរៀបចំកម្មវិធីផ្សព្វផ្សាយនិងលើកកម្ពស់ការចូលរួមក្នុងកិច្ចសន្ទនាវប្បធម៌ ដូចជា៖

- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសិល្បៈចម្លាក់ស្បែក
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសិល្បៈគំនូរបុរាណ
- សិក្ខាសាលាស្តីពីរបាំក្បាច់បុរាណខ្មែរ
- សិក្ខាសាលាស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលនិងកិច្ចពិភាក្សាពិគ្រោះយោបល់ដែលពាក់ព័ន្ធសន្និសញ្ញាផ្សេងៗ
- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយសិទ្ធិអ្នកនិពន្ធនិងអង្គភាពគ្រប់គ្រងសិទ្ធិរួមតន្ត្រីកម្ពុជា
- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់និងអនុសញ្ញាទីក្រុងប៊ែនស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈឆ្នាំ១៨៨៦ និងវិសោធនកម្មឆ្នាំ១៩៧៩

- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយលិខិតបទគតិយុត្តទាក់ទងនឹងច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងផលប្រយោជន៍នៃការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម(សិក្ខាសាលាថ្នាក់ភូមិភាគនៅបាត់ដំបង)
- សិក្ខាសាលាស្តីពីការបញ្ជ្រាបចំណេះដឹងស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងអនុសញ្ញាសន្ធិសញ្ញាពាក់ព័ន្ធនានា(សិក្ខាសាលាថ្នាក់ភូមិភាគនៅខេត្តកំពត)
- សិក្ខាសាលាស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល (សិក្ខាសាលាថ្នាក់ភូមិភាគនៅខេត្តកំពង់ចាម)
- សិក្ខាសាលាស្តីពីច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ
- សិក្ខាសាលាស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម
- សិក្ខាសាលាស្តីពីអត្ថប្រយោជន៍នៃការចូលជាសមាជិកសន្ធិសញ្ញាទីក្រុងប៉េកាំង
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តសិទ្ធិអ្នកនិពន្ធ និងបទដ្ឋានគតិយុត្តផ្សេងៗជាមួយអន្តរក្រសួង និងវិស័យឯកជន
- សិក្ខាសាលាស្តីពីការផ្តល់សេវាសាធារណៈលើវិស័យវប្បធម៌និងវិចិត្រសិល្បៈ នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត
- សន្និសីទបណ្ណារក្សអាស៊ីអាគ្នេយ៍(CONSAL)។ល។

**គ- ការផ្តល់សេវាសាធារណៈ**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានផ្តល់សេវាសាធារណៈផ្នែកវប្បធម៌និងវិចិត្រសិល្បៈសរុបប្រមាណ ៦៥ ០២៥សេវា ដោយក្នុងនោះសេវាសាធារណៈនៅក្នុងផ្នែកវប្បធម៌អរូបីមានដូចជា៖

បានផ្តល់សេវាគាំទ្រដល់ការអភិវឌ្ឍចំណេះដឹងនិងការបង្កើតថ្មី ដូចជា៖

- ផ្តល់លេខISBNចំនួន២ ៩៨៧លេខ ដល់អ្នកនិពន្ធ រោងពុម្ព និងអ្នកដែលមានតម្រូវការធ្វើការបោះពុម្ពផ្សាយសៀវភៅនិងឯកសារនានា
- អនុញ្ញាតឱ្យភ្ញៀវចូលអានសៀវភៅក្នុងបណ្ណាល័យជាតិសរុបចំនួន១៨៥ ០៥១នាក់
- អនុញ្ញាតឱ្យភ្ញៀវខ្ចីសៀវភៅនិងឯកសារចេញពីបណ្ណាល័យចំនួន៨ ៩០៦ក្បាល
- ផ្តល់សេវាសាធារណៈផ្នែកវប្បធម៌និងវិចិត្រសិល្បៈសរុបប្រមាណ៣៧ ៥៣៣សេវា ដោយក្នុងនោះសេវាផ្នែកភាពយន្តនិងវីដេអូសរុបមានចំនួន៥ ៦៧៧សេវា(អាជ្ញាបណ្ណថ្មី បន្តសុពលភាពអាជ្ញាបណ្ណ ចុះបញ្ជីសុំផលិតភាពយន្ត ការចុះបញ្ជីស្នើសុំនាំចូលភាពយន្តពីបរទេស។ល។)

## ២.៥- ការងារសាសនា

### ២.៥.១- ការងារព្រះពុទ្ធសាសនា

**ស្ថិតិវត្តអារាម និងព្រះសង្ឃ**

| សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ចំនួនវត្តអារាម | ៤ ៩២៥ | ៤ ៩៨៥ | ៥ ០២៤ | ៥ ០៤៥ | ៥ ០៥៥ |
| ចំនួនព្រះសង្ឃ | ៦៨ ៣៥៤ | ៧០ ៨៥៣ | ៦៨ ៧១៦ | ៦៨ ៩៤០ | ៦៨ ៩៤០ |

- រៀបចំអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស៤លើក(ឆ្នាំ២០១៧-២០១៨-២០១៩-២០២១)
- រៀបចំទិវាព្រះពុទ្ធសាសនាអន្តរជាតិ៨ មេសា ចំនួន៣លើក(ក្នុងឆ្នាំ២០១៨)
- ជូននិងទទួលព្រះរាជដំណើរសម្តេចសង្ឃទាំងពីរគណៈយាងបំពេញបេសកកម្មក្រៅប្រទេស១៦៧លើក

- អនុញ្ញាតឱ្យធ្វើបុណ្យបញ្ចុះខណ្ឌសីមា ៥៩វត្ត
- រៀបចំពិធីបុណ្យចូលព្រះវស្សា ១៦លើក
- រៀបចំនិងចេញប្រកាសអនុញ្ញាតឱ្យបង្កើតវត្ត ១៣០វត្ត
- រៀបចំនិងចេញប្រកាសអនុញ្ញាតឱ្យប្រែក្លាយពីអាស្រម ទៅជាវត្ត ១១វត្ត
- អនុញ្ញាតឱ្យរុះរើឧបដ្ឋានសាលាចាស់ក្នុងវត្ត ៣វត្ត
- អនុញ្ញាតឱ្យរុះរើព្រះវិហារចាស់ និងកសាងព្រះវិហារថ្មី ១៤វត្ត
- ចងក្រងស្ថិតិវត្តល្បីៗ នៅទូទាំងប្រទេស ១៤៤វត្ត
- ចុះស្រង់ស្ថិតិវត្តដែលបានចុះបញ្ជីជីវត្តទូទាំងប្រទេស
- ស្រង់ស្ថិតិព្រះសង្ឃទូទាំងប្រទេស ដែលមានព្រះជន្ម១៨ ដល់៥៩វស្សា ជូនអនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សរុប៦៤ ៨៦៤អង្គ
- រៀបចំសេចក្តីណែនាំផ្សេងៗ៤០លើក ក្នុងនោះរួមមាន បុណ្យមាឃបូជា៥លើក បុណ្យវិសាខបូជា ៥លើក បុណ្យចម្រើនព្រះជន្ម ព្រះមហាក្សត្រ៥លើក បុណ្យចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី៥លើក ទិវាប្រកាសរដ្ឋធម្មនុញ្ញ៥លើក បុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ៥លើក ពិធីគោរពព្រះវិញ្ញាណក្ខន្ធ«**ព្រះបរមរតនកោដ្ឋ**» ៥លើក និងពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះមហាក្សត្រ៥លើក។

### ២.៥.២- ការងារពាហិរសាសនា

**ស្ថិតិពាហិរសាសនា**

**ក- អ៊ិស្លាមសាសនា**

| សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ចំនួនវិហារ | ៤៩៩ | ៥១៦ | ៥៦៨ | ៥៧០ | ៥៨១ |
| ចំនួនស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ៥៨០ | ៦៧៥ | ៧៦២ | ៧៩២ | ៨០៣ |
| ចំនួនសាលារៀនសាសនា | ៤៣៨ | ៥១៨ | ៥២៩ | ៥៤១ | ៥៤៩ |
| ចំនួនអង្គការ សមាគម | ១៥ | ១៥ | ២១ | ២៣ | ២៥ |
| **ខ-គ្រិស្តសាសនា** | | | | | |
| **កាតូលិក** | | | | | |
| ចំនួនបរិស័ទ | ៤០៦ ២៩០រូប | ៤៤៧ ៩៨៧រូប | ៤១៤ ៧៥៤រូប | ៥០៧ ៨៥១រូប | ៥១០ ៤៨២រូប |
| ចំនួនវិហារ | ៦៧ | ៦៤ | ៦៨ | ៦២ | ៦១ |
| ចំនួនស្នាក់ការថ្វាយបង្គំ | ៤២ | ៤៤ | ៣៩ | ៤១ | ៤៤ |
| ចំនួនសាលារៀនសាសនា | ៥០ | ៦០ | ៦១ | ៦០ | ៥៧ |
| ចំនួនអង្គការ សមាគម | ៩៣ | ១១៧ | ១១៥ | ១៣១ | ១២៩ |
| ចំនួនបរិស័ទ | ១៣ ៥៤១ | ១២ ៣៤០ | ១៣ ០៤៧ | ១៣ ៤៤៦ | ១៣ ៣៥៣ |
| **ប្រូតេស្តង់** | | | | | |
| ចំនួនវិហារ | ៦៨២ | ៥៨៩ | ៦២៦ | ៦៧៥ | ៦១២ |
| ចំនួនស្នាក់ការថ្វាយបង្គំ | ១ ១៤២ | ១ ៣៤៧ | ១ ៣៤០ | ១ ៤១២ | ១ ៤៨៣ |
| ចំនួនសាលារៀនសាសនា | ៦៦៩ | ៧៦៧ | ៨២៩ | ៨៦៩ | ៨៤៣ |
| ចំនួនបរិស័ទ | ៩៨ ៧០៥ | ៩៧ ៣៧៤ | ៩៦ ៥៩២ | ៩៨ ៩៧០ | ៩៨ ១៨៤ |

| មហាយាន | | | | | |
|---|---|---|---|---|---|
| ចំនួនវិហារ | ១៦៩ | ១៤៨ | ១៤៩ | ១៥៣ | ១៤៩ |
| ចំនួនស្នាក់ការថ្វាយបង្គំ | ១៨ | ៣៦ | ២៩ | ៤៨ | ៤៩ |
| ចំនួនសាលារៀនសាសនា | ២១ | ៣៦ | ៤៥ | ៤០ | ៤២ |
| ចំនួនអង្គការ សមាគម | - | - | - | - | - |
| ចំនួនបរិស័ទ | ២១ ៨០៩ | ១៦ ៩៦៩ | ១៧ ៩៨៦ | ២២ ៩៦៥ | ២២ ៧៩៦ |
| **បាហៃ** | | | | | |
| ចំនួនវិហារ | ៣១ | ៥ | ៣ | ៥ | ៤ |
| ចំនួនស្នាក់ការថ្វាយបង្គំ | ១ | ១៥ | ១៥ | ១៤ | ១៤ |
| ចំនួនសាលារៀនសាសនា | ១ | ៤ | ៣ | ៨ | ៧ |
| ចំនួនអង្គការ សមាគម | - | - | - | - | - |
| ចំនួនបរិស័ទ | ៨ ០៦៩ | ៤ ០០៣ | ២ ៦៥៥ | ៥ ៤១៧ | ៥ ៣៤៣ |
| **កៅដាយ** | | | | | |
| ចំនួនវិហារ | ៣ | ៣ | ២ | ៣ | ២ |
| ចំនួនស្នាក់ការថ្វាយបង្គំ | - | - | ១ | - | ១ |
| ចំនួនសាលារៀនសាសនា | ១ | ១ | - | - | - |
| ចំនួនអង្គការ សមាគម | - | - | - | - | - |
| ចំនួនបរិស័ទ | ១ ៨៥៣ | ១ ៨២៨ | ៤៨៩ | ៥០៥ | ៥០៥ |

- រៀបចំសិក្ខាសាលាស្តីពីកិច្ចសន្ទនាអន្តរជំនឿសាសនា ដើម្បីសុខដុមនីយកម្មសាសនានៅកម្ពុជា៣លើក

- សហការរៀបចំពិធីសំណេះសំណាល និងពិសារអាហារសាមគ្គីរវាង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជាមួយថ្នាក់ដឹកនាំគ្រីស្ទបរិស័ទនៅកម្ពុជា៣លើក

- សហការរៀបចំពិធីសំណេះសំណាល និងពិសារអាហារស្រាយបួស«**ខែរ៉ាម៉ាឌន**» រវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជាមួយសាសនិកអ៊ិស្លាមនៅកម្ពុជា៣លើក

- បញ្ឈប់ការចុះបញ្ជី និងតម្កល់លក្ខន្តិកៈសមាគម និងអង្គការមិនមែនរដ្ឋាភិបាល គ្រប់ប្រភេទនៅក្រសួង និងបានណែនាំឱ្យទៅចុះបញ្ជីស្របតាមច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- រៀបចំសារាចរណែនាំស្តីពីការចុះបញ្ជីពាហិរសាសនា ដើម្បីពង្រឹងការគ្រប់គ្រង ជានាសេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃ ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ

- រៀបចំសេចក្តីសម្រេចអនុញ្ញាតឱ្យចុះបញ្ជីស្នាក់ការថ្វាយបង្គំ៣៣៣កន្លែង ក្នុងនោះ អ៊ិស្លាម៤កន្លែង គ្រិស្ត៣១២កន្លែង និងមហាយាន១៧កន្លែង។ បើគិតតាមឆ្នាំ២០១៧ ចំនួន១៦៤កន្លែងឆ្នាំ២០១៨ ចំនួន៤៦កន្លែង ឆ្នាំ២០១៩ ចំនួន៧៤កន្លែង ឆ្នាំ២០២០ ចំនួន២៣កន្លែង និងឆ្នាំ២០២១ ចំនួន២៦កន្លែង

- រៀបចំសេចក្តីសម្រេចអនុញ្ញាតឱ្យចុះបញ្ជីបន្តសុពលភាព ចំនួន៨៤៩កន្លែង ក្នុងនោះ អ៊ិស្លាម ចំនួន២៩កន្លែង គ្រិស្តចំនួន៧៣២កន្លែង មហាយានចំនួន៥៧កន្លែង បាហៃចំនួន២៥កន្លែង កៅដាយចំនួន២កន្លែង និងផ្សេងៗ ចំនួន៤កន្លែង។ បើគិតតាមឆ្នាំ២០១៧ ចំនួន៣០៩កន្លែង ឆ្នាំ២០១៨ ចំនួន១៦០កន្លែង ឆ្នាំ២០១៩ ចំនួន១២៤កន្លែង ឆ្នាំ២០២០ ចំនួន១៨៧កន្លែង និងឆ្នាំ២០២១ ចំនួន៦៩កន្លែង

- រៀបចំសេចក្តីសម្រេចអនុញ្ញាតឱ្យសាងសង់វិហារសាសនា៥កន្លែង ក្នុងនោះ អ៊ិស្លាម១កន្លែង គ្រិស្ត ៣កន្លែង និងមហាយាន១កន្លែង

- សម្របសម្រួលទទួលអំណោយមនុស្សធម៌ និងការនាំចូលគម្ពីរ ឯកសារ និងសម្ភារៈសាសនា សរុបចំនួន៣៦លើក ក្នុងនោះ អ៊ិស្លាម៧លើក គ្រិស្ត២៣លើក មហាយាន៦លើក។ បើគិតតាមឆ្នាំ២០១៧ ចំនួន១លើក ឆ្នាំ២០១៨ ចំនួន៨លើក ឆ្នាំ២០១៩ ចំនួន១៥លើក ឆ្នាំ២០២០ ចំនួន៨លើក និងឆ្នាំ២០២១ ចំនួន៤លើក

- បើធៀបនឹងរយៈពេល៥ឆ្នាំ កន្លែងថ្វាយបង្គំសរុបរួម៣ ៧៦៥កន្លែង កើនឡើង៦៣១កន្លែង សាលាចំនួន១ ៥១៦សាលា កើនឡើង៣៣៦សាលា បរិស័ទថ្វាយបង្គំ ចំនួនសរុបរួម៦៤៩ ១៩៣នាក់ កើនឡើង៩៨ ៩២៦នាក់ ក្នុងនោះ (១) អ៊ិស្លាមសាសនា មានកន្លែងថ្វាយបង្គំចំនួន១ ៣៦៣កន្លែង កើនឡើងចំនួន២៨៤កន្លែង សាលា ចំនួន៥៤៦សាលា កើនឡើងចំនួន១០៨កន្លែង មានបរិស័ទថ្វាយបង្គំ ចំនួន៥០៧ ៩៥៦នាក់ កើនឡើងចំនួន១០១ ៦៦៦នាក់ (២) គ្រិស្តសាសនា មានកន្លែងថ្វាយបង្គំចំនួន២ ១៧៩កន្លែង កើនឡើងចំនួន២៤៦កន្លែង សាលាចំនួន៩២០សាលា កើនឡើងចំនួន២០១សាលា មានបរិស័ទថ្វាយបង្គំចំនួន១១២ ៣៥៥នាក់ កើនឡើងចំនួន១០៩នាក់ និង(៣) មហាយាន និងសាសនាផ្សេងៗ ចំនួន២២៣កន្លែង កើនឡើងចំនួន១កន្លែង បរិស័ទថ្វាយបង្គំចំនួន២៨ ៨៨២នាក់ ថយចុះចំនួន២ ៨៤៩នាក់ សាលាចំនួន៥០សាលា កើនឡើងចំនួន២៧សាលា។

### គ- ការងារពុទ្ធសាសនបណ្ឌិត្យ និងបណ្ណាល័យ

- រៀបចំការប្រឡងប្រជែងស្នាដៃពានរង្វាន់អក្សរសិល្ប៍ពុទ្ធសាសនបណ្ឌិត្យ៤លើក មានប្រធានបទ៤ រួមមាន (១) សុខដុមនីយកម្មក្នុងសង្គមតាមរយៈសាសនា (២) ពុទ្ធទស្សនៈ ក្នុងការអភិវឌ្ឍសង្គមខ្មែរ (៣) ទោសនៃសុរា និង(៤) ការមិនមានរោគ ជាលាភដ៏ប្រសើរ

- រៀបចំបាឋកថាប្រចាំខែ ៤៧ខែ វាគ្មិន៤៧រូប និងប្រធានបទ៤៧ ផ្សេងៗគ្នា

- បោះពុម្ពសៀវភៅ ប្រជុំរឿងព្រេងខ្មែរភាគ១០ ប្រជុំរឿងព្រេងបរទេសភាគ១ ប្រជុំរឿងព្រេងបរទេសភាគ២ ពិធីស្លដៃកនៃជនជាតិកួយ ប្រវត្តិសង្ខេបពុទ្ធសាសនបណ្ឌិត្យ ប្រវត្តិវត្តមហាលាភ របៀបសរសេរអក្សរទេវនាគរី របរធ្វើស្រែ របរធ្វើចម្ការ កម្រងឯកសារស្តីពី«អ្នកតា» សេចក្តីរាយការណ៍ដំណឹងសាសនាភាគ១

- រៀបចំសិក្ខាសាលាប្រពៃណីទំនៀមទម្លាប់២លើក សិក្ខាសាលា«**ការអភិរក្សសាស្ត្រាស្លឹករឹត-ក្រាំង នៃព្រះរាជាណាចក្រកម្ពុជា**» ១លើក និងសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការងារពុទ្ធិក បណ្ណាល័យ១លើក

- រៀបចំសន្និសីទព្រះពុទ្ធសាសនា ក្រោមប្រធានបទ«គំហើញក្នុងអតីតកាល» ១លើក និងសន្និសីទក្រោមប្រធានបទ«ព្រះពុទ្ធសាសនា និងប្រវត្តិសាស្ត្រខ្មែរ» ១លើក

- ប្រារព្ធពិធីបុណ្យខួប៩០ឆ្នាំ នៃការបង្កើតពុទ្ធសាសនបណ្ឌិត្យ១លើក

- រៀបចំពិធីប្រគល់ជ័យលាភីប្រកួតប្រជែងស្នាដៃពានរង្វាន់អក្សរសិល្ប៍ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ២០១៨ និងឆ្នាំ២០១៩

- បញ្ចូលអត្ថបទទៅក្នុងគេហទំព័ររបស់ពុទ្ធសាសនបណ្ឌិត្យ www.budinst.gov.kh បាន៤៣៩ចំណងជើង

- អ្នកទស្សនាក្នុងគេហទំព័រពុទ្ធសាសនបណ្ឌិត្យមាន១៦៣ ៧៥៨ដង និងមានអ្នកចុចឡៃក(Like) ផេកហ្វេសប៊ុកពុទ្ធសាសនបណ្ឌិត្យ មានចំនួនជាង២៤ ០០០ដង

- អ្នកចូលអានក្នុងបណ្ណាល័យសរុប៨ ៥៦៥អង្គ/នាក់

- ទទួលអំណោយសៀវភៅពីសប្បុរសជន និងស្ថាប័ននានា៥៩៣ក្បាល

- ទទួលទស្សនាវដ្ដីនានា១៩១ក្បាល

- ទិញសៀវភៅថ្មី១ ៦៨១ក្បាល ស្មើនឹង៨៥៣ចំណងជើង ដើម្បីដាក់ជូនសាធារណជនអាន

- បញ្ចូលកូដសៀវភៅក្នុងប្រព័ន្ធ koha database បាន៣៩ ៩៩២ក្បាល

- ចម្លងអត្ថបទ និងបោះពុម្ពទស្សនាវដ្ដីកម្ពុជសុរិយា១៨លេខ

- សហការជាមួយក្លឹបអ្នកកាសែតកម្ពុជាក្នុងការធ្វើកម្មវិធីបណ្ដុះបណ្ដាល ដោយមានការចូលរួមពីអ្នកកាសែតជើងចាស់៣លើក

- ចែកសៀវភៅតាមក្រសួង-ស្ថាប័ន និងបណ្ដាខេត្តនានា សរុប១៨ ៥០០ក្បាល។

## ឃ- ការងារពុទ្ធិកសិក្សា

**▪ ស្ថិតិសាលាពុទ្ធិកសិក្សា និងសមណសិស្ស និស្សិត**

| ធម្មវិន័យ | | | | | |
|---|---|---|---|---|---|
| **សូចនាករ** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** |
| ចំនួនសាលា | ៥៣៨ | ៥៤៣ | ៤៩១ | ៤៥៦ | ៥៣៦ |
| ចំនួនសមណសិស្ស | ១៧ ៥២៧ | ១៧ ៥៦៥ | ១៩ ៨២៩ | ១៩ ០៧៦ | ១១ ០១៧ |
| ចំនួនសមណសិស្សប្រឡងជាប់ | ១២ ៥៨៤ | ១៣ ០២៦ | ១៤ ៥៦០ | ១៣ ៥១៧ | មិនទាន់បានប្រឡង |
| **ពុទ្ធិកបឋមសិក្សា** | | | | | |
| ចំនួនសាលា | ៧៦៥ | ៧២៣ | ៧៩៦ | ៩១៥ | ១,០០៥ |
| ចំនួនសមណសិស្សរៀនទាំង៣ថ្នាក់ | ១៩ ៥១៦ | ២១ ០៧៦ | ២២ ៩៣០ | ២៤ ២០៩ | ២៤ ៩១៩ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ១៦៩រូប<br>កិច្ចសន្យា១៦៩រូប<br>គ្រូជួល៣៥៩រូប | ក្របខ័ណ្ឌ១៦៩រូប<br>កិច្ចសន្យា១ ៦៩រូប<br>គ្រូជួល៥៣៧រូប | ក្របខ័ណ្ឌ១៨៦រូប<br>កិច្ចសន្យា១ ៣៥០រូប<br>គ្រូជួល ៥៥៣រូប | ក្របខ័ណ្ឌ១៨៨រូប<br>កិច្ចសន្យា១ ៧២៩រូប<br>គ្រូជួល៥៤១រូប | ក្របខ័ណ្ឌ១៨៨រូប<br>កិច្ចសន្យា១ ៧២៩រូប<br>គ្រូជួល៥៤១រូប |
| ចំនួនសមណសិស្សប្រឡងនិងប្រឡងជាប់សម្រាប់ថ្នាក់ទី៣ | បេក្ខសមណសិស្ស ចំនួន ៣ ៦៧៤អង្គ ប្រឡងជាប់ចំនួន ៣ ១៦៩អង្គ | បេក្ខសមណសិស្ស ចំនួន៤ ៣៨៣អង្គ ប្រឡងជាប់ចំនួន ៣ ២៥១អង្គ | បេក្ខសមណសិស្ស ចំនួន៤ ៣៨១អង្គ ប្រឡងជាប់ចំនួន ២ ៧៣៧អង្គ | បេក្ខសមណសិស្ស ចំនួន៤ ១៩០អង្គ ប្រឡងជាប់ចំនួន ២ ៨២១អង្គ | បេក្ខសមណសិស្ស ចំនួន ៤ ១៨៩អង្គ ប្រឡងជាប់ចំនួន ៤ ១៨៩អង្គ |
| **ពុទ្ធិកមធ្យមសិក្សាបឋមភូមិ** | | | | | |
| **សូចនាករ** | **២០០៨** | **២០០៩** | **២០១០** | **២០១១** | **២០១២** |
| ចំនួនសាលា | ៣៧ | ៤១ | ៤០ | ៤០ | ៣៨ |
| ចំនួនសមណសិស្ស | ៥ ០៤៣ | ៥ ២៧១ | ៥ ៥៥១ | ៥ ៦៤២ | ៥ ៦៣៣ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ១៤០រូប<br>កិច្ចសន្យា១១៣<br>គ្រូជួល៤៦៨ | ក្របខ័ណ្ឌ១៣២<br>កិច្ចសន្យា១៣៤<br>គ្រូជួល៥១៣ | ក្របខ័ណ្ឌ១៣៣<br>កិច្ចសន្យា៩៥<br>គ្រូជួល៤២១ | ក្របខ័ណ្ឌ១២៥<br>កិច្ចសន្យា៥២<br>គ្រូជួល៣៨៨ | ក្របខ័ណ្ឌ១៣៦<br>កិច្ចសន្យា៥៤<br>គ្រូជួល២៥៧ |
| ចំនួនសមណសិស្សប្រឡង និងប្រឡងជាប់សម្រាប់ថ្នាក់ទី៣ | បេក្ខសមណសិស្សចំនួន ១ ០៩០អង្គ ប្រឡងជាប់ ចំនួន៩៩៩អង្គ | បេក្ខសមណសិស្ស ចំនួន៩៩៣អង្គ ប្រឡងជាប់ ចំនួន៨៨០អង្គ | បេក្ខសមណសិស្ស ចំនួន១ ០១៩អង្គ ប្រឡងជាប់ ចំនួន៨០៨អង្គ | បេក្ខសមណសិស្ស ចំនួន១ ២០០អង្គ ប្រឡងជាប់ ចំនួន១ ០០៥អង្គ | បេក្ខសមណសិស្ស ចំនួន១ ២៥៤អង្គ ប្រឡងជាប់ ចំនួន១ ២៥៤អង្គ |

| | | | | | |
|---|---|---|---|---|---|
| **ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ** | | | | | |
| ចំនួនសាលា | ១៤ | ១៤ | ១៤ | ១៤ | ១៤ |
| ចំនួនសមណសិស្ស | ១ ៦៤៤ | ១ ៨២១ | ១ ៨៧២ | ១ ៧២៧ | ១ ៩៣៧ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ៤១ កិច្ចសន្យា១៨ គ្រូជួល២២៤ | ក្របខ័ណ្ឌ៣៣ កិច្ចសន្យា២៧ គ្រូជួល២៤០ | ក្របខ័ណ្ឌ២៥ កិច្ចសន្យា១៧ គ្រូជួល២១០ | ក្របខ័ណ្ឌ៤០ កិច្ចសន្យា១៥ គ្រូជួល២០២ | ក្របខ័ណ្ឌ៣៦ កិច្ចសន្យា១៦ គ្រូជួល១២៩ |
| ចំនួនសមណសិស្សប្រឡង និងប្រឡងជាប់សម្រាប់ថ្នាក់ទី៣ | បេក្ខសមណសិស្ស ចំនួន៣៨៥អង្គ ប្រឡងជាប់ចំនួន៣៥១អង្គ | បេក្ខសមណសិស្សចំនួន៤៦៤អង្គ ប្រឡងជាប់ចំនួន៤១០អង្គ | បេក្ខសមណសិស្សចំនួន៤១៥អង្គ ប្រឡងជាប់ចំនួន៣៧២អង្គ | បេក្ខសមណសិស្សចំនួន៤៤៥អង្គ ប្រឡងជាប់ចំនួន៣២៥អង្គ | បេក្ខសមណសិស្ស ចំនួន៤៨៩អង្គ ប្រឡងជាប់ចំនួន៤៨៩អង្គ |
| **ពុទ្ធិកឧត្តមសិក្សា(ថ្នាក់បរិញ្ញាបត្រ)** | | | | | |
| សាកលវិទ្យាល័យព្រះសីហនុរាជ | ១ | ១ | ១ | ១ | ១ |
| ចំនួនសមណនិស្សិត | ១ ១៧៨អង្គ/នាក់ | ១ ០៧៣អង្គ/នាក់ | ១ ០៨៥អង្គ/នាក់ | ១ ៣៥៥អង្គ/នាក់ | ១ ៨៤៩អង្គ/នាក់ |
| ចំនួនគ្រូ | បរិញ្ញាបត្រ៤៦រូប បរិជាន់ខ្ពស់(គ្មាន) | បរិញ្ញាបត្រ៤៣រូប បរិ.ជាន់ខ្ពស់(គ្មាន) | បរិញ្ញាបត្រ៤៨រូប បរិ.ជាន់ខ្ពស់(គ្មាន) | បរិញ្ញាបត្រ៥៥រូប បរិ.ជាន់ខ្ពស់(គ្មាន) | បរិញ្ញាបត្រ៥០រូប បរិ.ជាន់ខ្ពស់៧រូប |
| ចំនួនសមណនិស្សិតបានបញ្ចប់បរិញ្ញាបត្រ | ២៤៥អង្គ/នាក់ | ២៩៨អង្គ/នាក់ | ១៩០អង្គ/នាក់ | ២០០អង្គ/នាក់ | ៣៤៣អង្គ/នាក់ |
| ចំនួនសាលាពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា | ១ | ១ | ១ | ១ | ១ |
| ចំនួនសមណនិស្សិត | ៧៥៨អង្គ/នាក់ | ៨៩៧អង្គ/នាក់ | ៨៣០អង្គ/នាក់ | ១ ៦២៤អង្គ/នាក់ | ១ ៦២៤អង្គ/នាក់ |
| ចំនួនគ្រូ | គ្រូក្របខ័ណ្ឌ៧រូប គ្រូជួល១២៦រូប | គ្រូក្របខ័ណ្ឌ(គ្មាន) គ្រូជួល៩១រូប | គ្រូក្របខ័ណ្ឌ(គ្មាន) គ្រូជួល៩១រូប | គ្រូក្របខ័ណ្ឌ៦រូប គ្រូជួល៨៨រូប | គ្រូក្របខ័ណ្ឌ៦រូប គ្រូជួល១៣៨រូប |
| ចំនួនសមណនិស្សិតបានបញ្ចប់បរិញ្ញាបត្រ | ១៣៤អង្គ/នាក់ | ១៣៤អង្គ/នាក់ | ១៣៨អង្គ/នាក់ | ២០៣អង្គ/នាក់ | ២០៩អង្គ/នាក់ |
| សាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | ១ | ១ | ១ | ១ | ១ |
| ចំនួនសមណនិស្សិត | ២៣៨អង្គ/នាក់ | ៤៤៥អង្គ/នាក់ | ៨៩២អង្គ/នាក់ | ៦៣៤អង្គ/នាក់ | ៥១០អង្គ/នាក់ |
| ចំនួនគ្រូ | ១២រូប | ១៩រូប | ៥រូប | ៥រូប | ៥រូប |
| ចំនួនសមណនិស្សិតបានបញ្ចប់បរិញ្ញាបត្រ | ៣៥រូប | ៣៧រូប | ៣០៣រូប | ១៤៧រូប | ១៤៤រូប |
| **ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់** | | | | | |
| សាកលវិទ្យាល័យព្រះសីហនុរាជ | ១ | ១ | ១ | ១ | ១ |
| ចំនួនសមណនិស្សិត | ៤២អង្គ/នាក់ | ៦៤អង្គ/នាក់ | ៦៣អង្គ/នាក់ | ៦៦អង្គ/នាក់ | ៣៤៥អង្គ/នាក់ |

| | | | | | |
|---|---|---|---|---|---|
| ចំនួនគ្រូ | ក្របខ័ណ្ឌ(គ្មាន) ជួល១១រូប | ក្របខ័ណ្ឌ(គ្មាន) ជួល១២រូប | ក្របខ័ណ្ឌ(គ្មាន) ជួល១១រូប | ក្របខ័ណ្ឌ(គ្មាន) ជួល១១រូប | ក្របខ័ណ្ឌ៧រូប ជួល១៩រូប |
| ចំនួនសមណនិស្សិតបានបញ្ចប់ថ្នាក់អនុបណ្ឌិត | ៧អង្គ/នាក់ | ១៤អង្គ/នាក់ | (គ្មាន) | ១០អង្គ/នាក់ | (គ្មាន) |
| សាកលវិទ្យាល័យព្រះសីហមុនីរាជា | ១ | ១ | ១ | ១ | ១ |
| ចំនួនសមណនិស្សិត | (គ្មាន) | (គ្មាន) | (គ្មាន) | ៥៧ | ៧៧ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ(គ្មាន) ជួល(គ្មាន) | ក្របខ័ណ្ឌ(គ្មាន) ជួល(គ្មាន) | ក្របខ័ណ្ឌ(គ្មាន) ជួល(គ្មាន) | ក្របខ័ណ្ឌ(គ្មាន) ជួល៣២រូប | ក្របខ័ណ្ឌ(គ្មាន) ជួល១៦រូប |
| ចំនួនសមណនិស្សិតបានបញ្ចប់ | ៦៩អង្គ/នាក់ | ៨៤អង្គ/នាក់ | ១៥៣អង្គ/នាក់ | (គ្មាន) | (គ្មាន) |
| **ថ្នាក់បណ្ឌិត (គ្មាន)** | | | | | |

❖ **ផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ**

- លិខិតចូល១២ច្បាប់ និងលិខិតចេញ៦៣៣ច្បាប់
- រៀបចំប្រកាសតែងតាំងគណៈគ្រប់គ្រង៧៨រូប
- ប្រកាសបើកសាលា១១៤សាលា
- ផលិតវិញ្ញាបនបត្រធម្មវិន័យ៥៣ ៩៨៩សន្លឹក
- ផលិតវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា៩ ០៩៣សន្លឹក
- រៀបចំវគ្គវិក្រឹត្យការគ្រូបង្រៀនពុទ្ធិកបឋមសិក្សា៣លើក សិក្ខាកាមចូលរួម២៧១រូប
- ចុះធ្វើអធិការកិច្ច១២ខេត្ត
- ចុះធ្វើអធិការកិច្ចបច្ចេកទេស និងធ្វើបទបង្ហាញស្តីពីការសិក្សាពីចម្ងាយ និងតាមប្រព័ន្ធអនឡាញ(ZOOM) ១៧ទីតាំង ស្មើនឹង២៣រាជធានី ខេត្ត
- បង្កើតស្ទូឌីយ៉ូ(STUDIO) ដើម្បីផលិតវីដេអូ និងការចាក់ផ្សាយបន្តផ្ទាល់តាមរយៈគេហទំព័រហ្វេសប៊ុក និងប្រព័ន្ធយូធូបផ្លូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- ផលិតបានវីដេអូសរុប២៤២ឃ្លីប លើមុខវិជ្ជា៦ គឺភាសាបាលី ភាសាខ្មែរ គណិតវិទ្យា ពុទ្ធវិន័យ ពុទ្ធប្បវត្តិ និងពុទ្ធសាសនា
- បែងចែកសៀវភៅភាសាបាលី ពុទ្ធវិន័យ ពុទ្ធប្បវត្តិ ពុទ្ធសាសនា ទាំងបីថ្នាក់ សរុប១ ៦៤៩ក្បាល សៀវភៅសិក្ខាគារិក១ ៥៥៧ក្បាល និងសៀវភៅតាមដានការសិក្សា១១ ១២៦ក្បាល ដល់សាលាពុទ្ធិកបឋមសិក្សាតាមរាជធានី-ខេត្ត។

❖ **ផ្នែកពុទ្ធិកមធ្យមសិក្សា**

- លិខិតចូល៣៧៤ច្បាប់ និងលិខិតចេញ៨៩ច្បាប់
- រៀបចំប្រកាសតែងតាំងគណៈគ្រប់គ្រង៥៣រូប
- ចែកសៀវភៅសិក្ខាគារិកពុទ្ធិកមធ្យមសិក្សាបឋមភូមិ១២ ៩៩២ក្បាល និងមធ្យមសិក្សាទុតិយភូមិ ៤ ៤២០ក្បាល

- ចែកសៀវភៅតាមដានការសិក្សាពុទ្ធិកមធ្យមសិក្សាបឋមភូមិ២ ៩២១០ក្បាល និងពុទ្ធិកមធ្យមសិក្សាទុតិយភូមិ៩ ៩៥៨ក្បាល

- ចែកសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ៣ ៨៥៦សន្លឹក និងមធ្យមសិក្សាទុតិយភូមិ២ ៨៣៨សន្លឹក

- សមណសិស្សដែលចូលរៀននៅតាមពុទ្ធិកសិក្សា ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ រួមមាន៖

- ពុទ្ធិកមធ្យមសិក្សាបឋមភូមិ សរុប១៤ ៦៦៤ ២៨៨៦អង្គ និងប្រឡងជាប់១៣ ១៧៤អង្គ។
- ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ សរុប២ ៥២៥អង្គ និងប្រឡងជាប់២ ២៤១អង្គ។
- ដោយឡែកដោយសារស្ថានភាពនៃជំងឺកូវីដ-១៩ ឆ្នាំ២០២០ មានសមណសិស្ស ៩២១អង្គ និងឆ្នាំ២០២១ មានសមណសិស្ស១ ១៤៨អង្គ មិនបានប្រឡងទេ គឺសំណើសុំគោលការណ៍ជាប់ដោយស្វ័យប្រវត្តិ។

- ចុះធ្វើអធិការកិច្ចនៅគ្រប់ពុទ្ធិកមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិទៅតាមរាជធានី ខេត្តនីមួយៗទៅតាមផែនការដែលបានដាក់ចេញជារៀងរាល់ឆ្នាំ

- បានបង្កើតស្ទូឌីយ៉ូ(STUDIO)ដើម្បីផលិតវីដេអូចាក់ផ្សាយសម្រាប់ទូរសិក្សា ក្នុងវិបត្តិនៃជំងឺកូវីដ-១៩ ផលិត២១៧ឃ្លីប លើមុខវិជ្ជា៤ រួមមាន (១) ភាសាបាលី (២) ភាសាសំស្ក្រឹត (៣) ពុទ្ធសាសនា និងព្រះអភិធម្ម និង(៤) ពុទ្ធវិន័យសម្រាប់ពុទ្ធិកមធ្យមសិក្សាបឋមភូមិ៤មុខវិជ្ជាទៀត ក្នុងនោះ ១- ភាសាបាលី ២- ភាសាសំស្ក្រឹត ៣- ពុទ្ធសាសនាប្រៀបធៀប និង៤- ព្រះអភិធម្ម។

❖ **ផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា**

- លិខិតចូល១៥០ច្បាប់ និងលិខិតចេញ៨៤០ច្បាប់
- ចេញលិខិតបញ្ជាក់ការសិក្សា សរុប២០៦ច្បាប់
- ចេញវិញ្ញាបនបត្រថ្នាក់មូលដ្ឋាន សរុប៧៩៣ច្បាប់
- រៀបចំធ្វើសិក្ខាសាលា និងបាឋកថា សរុប៣០លើក
- ចូលរួមប្រជុំទាំងថ្នាក់ជាតិ និងអន្តរជាតិ សរុប២៦០លើក
- ចុះអនុស្សារណៈនៃការយោគយល់(MOU) ជាមួយសាកលវិទ្យាល័យ២ រួមមាន៖
  - សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
  - សាកលវិទ្យាល័យនៃប្រទេសវៀតណាម
- រៀបចំប្រឡងជ្រើសរើសគ្រូបង្រៀនពុទ្ធិកសិក្សាទាំងបីកម្រិត សរុប៥០រូប។
- ចុះចែកអំណោយដល់គ្រួសារក្រីក្រ១ ៥៥៦គ្រួសារ និងនិស្សិតក្រីក្រ៣០នាក់។

## ២.៦- ការងារព័ត៌មាន

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណទាំងបីដំណាក់កាលរួចមកហើយ ដោយទទួលបានលទ្ធផលកំណើនការងារ សមធម៌សង្គម អនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍប្រកបដោយចីរភាពដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចជាង៧% ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (គិតត្រឹមឆ្នាំ២០១៩) ព្រមទាំងរក្សាបាននូវសុខសន្តិភាព នាំឱ្យកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មីនៅលើឆាកអន្តរជាតិគួរជាទីមោទនៈ។

ស្ថិតនៅក្នុងបរិបទនៃវិបត្តិឆ្លងរាលដាលជាសកលនូវជំងឺកូវីដ-១៩ នៅចុងឆ្នាំ២០១៩ រហូតដល់ចុងឆ្នាំ២០២១ នេះបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចរបស់ប្រទេសជាតិ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចថយក្រោយក្រោមសូន្យគឺ(-២%) នៅក្នុងឆ្នាំ២០២០ និងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ គ្រប់ជាន់ថ្នាក់ ជាពិសេសស្ត្រី-កុមារ កម្មករ និងប្រជាកសិករ ។ ប៉ុន្តែក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយទេពកោសល្យរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី បានដឹកនាំនាវាកម្ពុជា ឆ្លងផុតពីគ្រោះមហន្តរាយនៃវិបត្តិកូវីដ-១៩ និងជាបណ្តើរៗនាំមកនូវស្ថិរភាពសង្គម ការរីកចំរើននូវវិស័យសំខាន់ៗមួយចំនួនក្នុងការជំរុញសេដ្ឋកិច្ចជាតិឈានដល់២% នៅត្រឹមដំណាច់ឆ្នាំ២០២១នេះ។

នីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់អនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ក្នុងការអភិវឌ្ឍប្រទេសជាតិលើវិស័យជាអាទិភាព និងវិធានការដាក់ស្តែង បានដើរតួនាទីជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព និង ជាត្រីវិស័យសម្រាប់តម្រង់ទិសសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការបន្តបំពេញភារកិច្ចបម្រើជាតិសំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋ ព្រមទាំងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅគោលដៅចក្ខុវិស័យរបស់កម្ពុជាឆ្នាំ២០៣០និងឆ្នាំ២០៥០។ ដោយឡែកចំពោះក្រសួងព័ត៌មាន ការងារជាសារវន្តសម្រាប់អាណត្តិនេះ គឺធ្វើឱ្យបានសំរេចចេញជារូបរាងនូវច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។

ផ្អែកលើមូលដ្ឋាននៃការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា និងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលខ្លួនទៅនឹងការវិវត្តនៃបដិវត្តឧស្សាហកម្មសកល តម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាប់យកកាលានុវត្តភាពនៃការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល និងត្រៀមខ្លួនឆ្លើយតបនឹងបញ្ហាប្រឈមដោយមានប្រសិទ្ធភាព។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលទាក់ទងនឹងវិស័យព័ត៌មាន មុំទី៣ : ទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងឆ្លើយតបបញ្ហាប្រឈមនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។

### ២.៦.១- សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន

#### - ការផ្លាស់ប្តូរប្រព័ន្ធទូរទស្សន៍ពីអាណាឡូក ទៅឌីជីថល

កិច្ចប្រជុំរដ្ឋមន្ត្រីព័ត៌មានអាស៊ានលើកទី១៤ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី បានឯកភាពកំណត់កាលបរិច្ឆេទនៃការបិទការផ្សាយទូរទស្សន៍អាណាឡូកត្រឹមឆ្នាំ២០២០ ស្របតាមស្មារតីកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអាស៊ីបាស៊ីហ្វិក ដើម្បីសុខដុមនីយកម្មនៃការអភិវឌ្ឍបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយឌីជីថល ទាំងនៅក្នុងតំបន់ និងនៅលើសកលលោក។ ដោយឡែកព្រះរាជាណាចក្រកម្ពុជាបានពន្យារពេលបិទការផ្សាយទូរទស្សន៍អាណាឡូករហូតដល់ដំណាច់ឆ្នាំ២០២៣។

យោងតាមស្មារតីកិច្ចប្រជុំអាស៊ានលើកទី១៤ រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពសម្រេចឱ្យក្រសួងព័ត៌មានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន ដើម្បីរៀបចំផែនការបង្កើតហេដ្ឋារចនាសម្ព័ន្ធថ្នាលទូរទស្សន៍ឌីជីថលជាតិ (National Digital TV Platform) និងបង្កើតស្ថាប័នសាធារណៈរដ្ឋបាល ដើម្បីគ្រប់គ្រងប្រតិបត្តិការថ្នាលទូរទស្សន៍ឌីជីថលជាតិ ដែលគ្រោងនឹងចាប់ផ្តើមអនុវត្តចាប់ពីដើមឆ្នាំ២០២១ និងបញ្ចប់ត្រឹមដំណាច់ឆ្នាំ២០២៣ ក្នុងគោលដៅធ្វើសមាហរណកម្មនិងសុខដុមនីយកម្មប្រព័ន្ធទូរទស្សន៍ឌីជីថលនៅក្នុងតំបន់និងពិភពលោក។

**- ការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន**

បន្តការកសាងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងសារព័ត៌មានតាមបែបប្រពៃណី ទាំងប្រព័ន្ធផ្សព្វផ្សាយតាមរលកអាកាសវិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញរបស់ស្ថាប័នរដ្ឋ និងស្ថាប័នឯកជន ព្រមទាំងពង្រីកវិសាលភាពការផ្សាយឱ្យបានទូលំទូលាយគ្រប់ដណ្ដប់ទូទាំងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និងនៅលើសលកលោក ដើម្បីផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល ការអភិវឌ្ឍប្រទេសជាតិ កម្មវិធីអប់រំ សេដ្ឋកិច្ច វប្បធម៌ កម្មវិធីកម្សាន្តផ្សេងៗ និងការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋបានរហ័សទាន់ពេលវេលាទៅគ្រប់ច្រកល្ហកទូទាំងព្រះរាជាណាចក្រកម្ពុជា តាមទិសស្លោក ប្លែក លឿន ទុកចិត្តបានពេលណាទីណាក៏បាន ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននាពេលបច្ចុប្បន្ន។

ទន្ទឹមនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រីកវិសាលភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ យើងត្រូវបង្កើនល្បឿនផ្សព្វផ្សាយព័ត៌មានឱ្យបានលឿនទាន់សភាពការណ៍ទាំងនៅក្របខ័ណ្ឌជាតិ និងនៅលើពិភពលោក ព្រមទាំងបង្កើននូវភាពជឿជាក់តាមរយៈការផ្សាយព័ត៌មានពិតដោយមានការទទួលខុសត្រូវលើវិជ្ជាជីវៈ។

**- ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអភិវឌ្ឍធនធានមនុស្ស**

ការវិវត្តនៃបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយឌីជីថលតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធយកចិត្តទុកដាក់លើកកម្ពស់ការបណ្តុះបណ្តាលធនធានមនុស្សទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិឱ្យមានសមត្ថភាពជំនាញច្បាស់លាស់ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ និងអាចដើរទាន់នូវការវិវត្តបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយទំនើប។ ស្ថិតនៅក្នុងបរិបទនេះ ក្រសួងព័ត៌មាននឹងបន្តកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ និងស្ថាប័នសារព័ត៌មានរៀបចំបើកសិក្ខាសាលា និងបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន និងជំនាញបច្ចេកទេសដល់មន្ត្រីរាជការទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកសារព័ត៌មាន ដើម្បីឱ្យពួកគេមានសមត្ថភាពបំពេញភារកិច្ចប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវ ព្រមទាំងមានសមត្ថភាពវិភាគព័ត៌មានស៊ីជម្រៅទាំងក្របខ័ណ្ឌជាតិ និងអន្តរជាតិ និងមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការបញ្ជូនទិន្នន័យនិងការផ្សព្វផ្សាយព័ត៌មានបានទាន់ពេលវេលា។

**- ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ**

ការរីកចម្រើននៃបច្ចេកវិទ្យាយុគសម័យបដិវត្តឧស្សាហកម្មជំនាន់ទី៤ បានធ្វើឱ្យមានការរីកលូតលាស់នៃបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងវិស័យផ្សេងៗទៀត ជាមួយនឹងកាលានុវត្តភាពនិងអត្ថប្រយោជន៍យ៉ាងច្រើនដល់សកលលោកយើងទាំងមូល។ ជាមួយគ្នានេះដែរ ក៏ធ្វើឱ្យយើងមានបញ្ហាប្រឈមជាច្រើនដូចជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការអភិវឌ្ឍធនធានមនុស្ស និងបញ្ហាប្រឈមនឹងព័ត៌មានក្លែងក្លាយជាសកលដែលទាមទារឱ្យយើងទាំងអស់គ្នាចូលរួមទប់ស្កាត់និងលុបបំបាត់រាល់ព័ត៌មានក្លែងក្លាយ បំភិតបំភ័យ ញុះញង់ឱ្យកើតមានការរើសអើងប្រកាន់ពូជសាសន៍ បង្កឱ្យមានការបែកបាក់សាមគ្គីភាពជាតិ ការបង្កទំនាស់ជាមួយប្រទេសជិតខាង ការបង្កចលាចលសង្គមជាដើម។ គោលដៅចំពោះមុខ ក្រសួងព័ត៌មាននឹងបន្តសហការជាមួយស្ថាប័នព័ត៌មានទាំងអស់ដើម្បីទប់ស្កាត់និងលុបបំបាត់រាល់ព័ត៌មានក្លែងក្លាយ ដោយជំរុញឱ្យស្ថាប័នព័ត៌មានទាំងអស់ផ្សាយព័ត៌មានពិត ដើម្បីបន្សាបព័ត៌មានមិនពិត និងបន្តសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ ដែលគ្រប់គ្រងបណ្តាញទំនាក់ទំនងសង្គម ដើម្បីរាំងខ្ទប់និងបិទចោលនូវគេហទំព័រឬគណនីហ្វេសប៊ុកដែលផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីចាត់វិធានការចំពោះជនល្មើសតាមនីតិវិធីច្បាប់។

- ពង្រឹងនិងបង្កើនប្រសិទ្ធិភាពច្បាប់សារព័ត៌មាន

ក្រសួងព័ត៌មានត្រូវបានរាជរដ្ឋាភិបាលសម្រេចប្រគល់ភារកិច្ចឱ្យដឹកនាំរៀបចំធ្វើសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិទទួលព័ត៌មាន នៅក្នុងនីតិកាលទី៥ នៃរដ្ឋសភាជាតិ និងសម្រេចប្រគល់សិទ្ធិឱ្យដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីឆ្លងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ កន្លងមក ក្រសួងព័ត៌មានបានឆ្លងអន្តរក្រសួងនូវសេចក្តីព្រាងច្បាប់នេះប្រកបដោយជោគជ័យ ហើយបន្តសហការជាមួយក្រសួងយុត្តិធម៌ឆ្លងទោសប្បញ្ញត្តិសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលគ្រោងនឹងបញ្ចប់នៅក្នុងខែមីនា ដើម្បីដាក់ជូនរាជរដ្ឋាភិបាល និងស្ថាប័ននីតិប្បញ្ញត្តិឱ្យបានរួចរាល់នៅក្នុងឆ្នាំ២០២២នេះ។ ជាមួយគ្នានេះដែរ ក្រសួងព័ត៌មាន កំពុងសិក្សាធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីឱ្យបទប្បញ្ញត្តិច្បាប់នេះ មានសង្គតិភាពទៅនឹងបទប្បញ្ញត្តិច្បាប់ដែលមានជាធរមាន និងស្របតាមតម្រូវការជាក់ស្តែងនាពេលបច្ចុប្បន្ន ដើម្បីជំរុញឱ្យស្ថាប័នព័ត៌មានទាំងអស់ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានប្រកបដោយការទទួលខុសត្រូវ។ ជាមួយគ្នានេះដែរ ក្រសួងព័ត៌មានបន្តខិតខំកសាងបទដ្ឋានគតិយុត្តថ្មីៗ តាមតម្រូវការជាក់ស្តែង ដើម្បីគ្រប់គ្រងវិស័យព័ត៌មាននិងសោតទស្សន៍ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិសេរីភាពសារព័ត៌មានក្នុងក្របខ័ណ្ឌប្រទេសដែលកាន់របបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

- ការចូលរួមក្នុងការប្រយុទ្ធប្រឆាំងនៃការរីករាលដាលជំងឺកូវីដ-១៩

ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋទាំងអស់នៅទូទាំងប្រទេសមាន អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា អគ្គនាយកដ្ឋានព័ត៌មានសោតទស្សន៍ និងអ៊ែបក្រសួងព័ត៌មាន និងមន្ទីរព័ត៌មានរាជធានី ខេត្តទាំង២៥ ក៏ដូចជាសភាពសហព័ន្ធយុវជនកម្ពុជាវិស័យព័ត៌មាន ព្រមទាំងសាខាសមាគមនារីកម្ពុជា ដែលជាសេនាធិការក្នុងការផ្សព្វផ្សាយរបស់រដ្ឋ ស្ថាប័នទាំងនោះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពាំនាំនូវការជូនដំណឹង សុន្ទរកថា សេចក្តីសម្រេច សេចក្តីណែនាំ សេចក្តីថ្លែងការណ៍ ប្រកាស សេចក្តីប្រកាស សេចក្តីប្រកាសព័ត៌មាន សេចក្តីជូនព័ត៌មាន លិខិតជូនដំណឹង លិខិតគោរពជូន សេចក្តីអំពាវនាវ លិខិតជម្រាបជូន លិខិតជម្រាបមក សារលិខិត លិខិតស្រាយបំភ្លឺ សារាចរណែនាំ វិធានការរបាយការណ៍ អនុក្រឹត្យ និងច្បាប់ដើម របស់រដ្ឋាភិបាលកម្ពុជា ជាពិសេសរបស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ពាក់ព័ន្ធការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

ការចូលរួមចាក់វ៉ាក់សាំងជូនមន្ត្រីរាជការនិងគ្រួសារមន្ត្រីទាំងអស់ នៅទូទាំងក្រសួងព័ត៌មាន បានសម្រេចលទ្ធផល១០០ភាគរយ។

### ២.៦.២- សូចនាករស្តីពីសមិទ្ធផលសំខាន់ៗ របស់ស្ថាប័នចំណុះក្រសួងព័ត៌មាន

#### ក- ការងារព័ត៌មាននិងសោតទស្សន៍

ក្នុងរយៈពេលពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ កន្លងទៅនេះ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍បានដំណើរការការងារតាមប្រក្រតី ដោយបានធ្វើការសម្របសម្រួលលិខិតស្នាមផ្សេងៗ ជូនអ្នកសារព័ត៌មានក្នុងការចុះបំពេញការងារតាមមូលដ្ឋាន និងជូនព័ត៌មានអំពីកម្មវិធីនានា ព្រមទាំងចាត់មន្ត្រីឱ្យទៅសម្របសម្រួលអ្នកសារព័ត៌មានក្នុងកម្មវិធីនានា។ ជាមួយនេះ ក៏បានអនុញ្ញាតឱ្យសារព័ត៌មានដំណើរការបោះពុម្ពផ្សាយបន្តអាជ្ញាបណ្ណប្តូរឈ្មោះសារព័ត៌មាន និងធ្វើការផ្អាកការចេញផ្សាយរបស់សារព័ត៌មានដែលផ្ទុយនឹងច្បាប់និងក្រមសីលធម៌។ ទន្ទឹមនឹងនេះក៏នៅបានធ្វើការតាមដានជាប្រចាំនូវរាល់ព័ត៌មានដែលចេញផ្សាយតាមទំព័រសារព័ត៌មាន តាមវិទ្យុ

ទូរទស្សន៍ និងតាមដានការវិវាទនានារបស់អ្នកសារព័ត៌មាន ព្រមទាំងធ្វើការបញ្ជូនមន្ត្រីចូលរួមវគ្គជំនាញផ្សេងៗ និងបញ្ចូលព័ត៌មានទៅក្នុងគេហទំព័ររបស់ក្រសួងថែមទៀត ។

**ចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ អគ្គនាយកដ្ឋាន សម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម**

កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ចំនួន៦៧២លើក ទទួលលិខិតចូលចំនួន២ ០៧៧លិខិត បញ្ជូនលិខិតចេញចំនួន២ ២០៣លិខិត ទទួលកាសែត ទស្សនាវដ្តី ព្រឹត្តិបត្រពីអង្គភាពសារព័ត៌មានជាតិ និងអន្តរជាតិចំនួន៤៩ ៨៥២ច្បាប់ ផ្នែកចេញអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតបន្តចំនួន៩៧៣អាជ្ញាបណ្ណ ចេញបណ្ណអ្នកសារព័ត៌មានជាតិ និងអន្តរជាតិចំនួន១០ ០៣៣បណ្ណ ស្រង់និងថតរូបផ្ទាំងប៉ាណូរាជធានីភ្នំពេញចំនួន១៥៤ស្លាក អង្គភាពសារព័ត៌មានបានចុះបញ្ជីគេហទំព័រTVOnlineចំនួន៦៦៩អង្គភាព (គេហទំព័រ៥៨៨ និងTV Onlineចំនួន៨១អង្គភាព និងចាងហ្វាងជាជនបរទេស១៩អង្គភាព និងចាងហ្វាងជាស្ត្រី៦៨នាក់) កាសែតចំនួន៤៥០អង្គភាព(ក្នុងនោះ មានចាងហ្វាងជាជនបរទេស២៨អង្គភាព និងចាងហ្វាងជាស្ត្រី២១នាក់) សមាគមសារព័ត៌មានចំនួន៥១អង្គភាព(ក្នុងនោះ មានចាងហ្វាងជាជនបរទេស១អង្គភាព និងចាងហ្វាងជាស្ត្រី១នាក់) ទស្សនាវដ្តីចំនួន១៩៦អង្គភាព(ក្នុងនោះ មានចាងហ្វាងជាជនបរទេស៣១អង្គភាព និងចាងហ្វាងជាស្ត្រី៣៧នាក់) ព្រឹត្តិបត្រចំនួន២២អង្គភាព(ក្នុងនោះ មានចាងហ្វាងជាជនបរទេស៧អង្គភាព និងចាងហ្វាងជាស្ត្រី៥នាក់) រោងពុម្ពចំនួន១១៧អង្គភាព(ក្នុងនោះ មានចាងហ្វាងជាស្ត្រី៣៩នាក់ លុប១អង្គភាព) សៀវភៅ២២អង្គភាព(ក្នុងនោះ មានចាងហ្វាងជាជនបរទេស៥អង្គភាពនិងចាងហ្វាងជាស្ត្រី៣នាក់) ទីភ្នាក់ងារសារព័ត៌មានបរទេស២៤អង្គភាព(អ្នកឆ្លើយឆ្លងព័ត៌មាន១អង្គភាព) ភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម១អង្គភាព ក្នុងឆ្នាំ២០២០ស្ថានីយវិទ្យុFM ចំនួន៨៣ស្ថានីយ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត១៣៧ស្ថានីយ និងវិទ្យុAM១ស្ថានីយនៅរាជធានីភ្នំពេញ ទូរទស្សន៍អាណាឡូក១៩ស្ថានីយ ទូរទស្សន៍Digital៨ស្ថានីយ ទូរទស្សន៍ខ្សែកាបនៅភ្នំពេញ២ស្ថានីយ និងនៅតាមខេត្ត២១០ស្ថានីយ ប្រព័ន្ធOTT ៧ក្រុមហ៊ុន ទូរទស្សន៍ផ្សាយតាមប្រព័ន្ធSatellite ២(DTV SKYOne) សេចក្តីប្រកាសព័ត៌មានបិទគេហទំព័រ/ទំព័រហ្វេសប៊ុក(Facebook Page) ចំនួន៤៧ បន្តសុពលភាពអាជីវកម្មរោងពុម្ពពីមន្ទីរព័ត៌មានរាជធានីភ្នំពេញ២១រោងពុម្ព ការងារផ្សព្វផ្សាយព័ត៌មានជូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិចំនួន៥៧លើក។

**ខ- ការងារទូរទស្សន៍ជាតិកម្ពុជា**

ក្នុងរយៈពេលពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ កន្លងទៅនេះ អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជាបានយកចិត្តទុកដាក់អនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការចុះយកព័ត៌មានមកផ្សព្វផ្សាយ និងផលិតកម្មវិធីសំបូរបែប បានយ៉ាងរស់រវើកលើគ្រប់វិស័យនិងទាន់ហេតុការណ៍ មានការអប់រំចំណេះដឹង កម្មវិធីកម្សាន្តសប្បាយជូនទូរទស្សនិកជនគ្រប់មជ្ឈដ្ឋានទាំងក្នុងនិងក្រៅប្រទេសទទួលបានលទ្ធផលគួរជាទីមោទនៈ។

ជាក់ស្តែង អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជាបានទទួលជោគជ័យធំៗ ក្នុងការផ្សព្វផ្សាយរាល់ព្រឹត្តិការណ៍ជាតិធំៗ សំខាន់ៗ ដោយពុំមានខកខាន និងរាំងស្ទះឡើយ។

ចាប់ពី ឆ្នាំ២០១៧ ដល់ ឆ្នាំ២០២១ នេះ អគ្គនាយកដ្ឋាន សម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម៖

ការងារផលិតផ្សព្វផ្សាយព័ត៌មានជាតិ អន្តរជាតិ : ៧៨១ព័ត៌មាន ៧៩៣ដង ២៧០៣០អត្ថបទ ការផលិតកម្មវិធីនិងចាក់ផ្សាយចំនួន៥ ៦១៨កម្មវិធី ៦ ៩១៧អត្ថបទ ការងារផ្សព្វផ្សាយទៅក្រៅប្រទេសចំនួន៤ ៣៩១អត្ថបទ។

ការងារបច្ចេកទេសនិងប្រព័ន្ធផ្សព្វផ្សាយ : រថយន្តចល័តទំនើប១គ្រឿង សម្ភារៈចល័តតាមថ្នាក់ដឹកនាំ ១ឈុត ម៉ាស៊ីនផ្សាយផ្ទាល់ចល័តតូច៤គ្រឿង រថយន្តចល័តតូច១គ្រឿង ម៉ាស៊ីនCamara ២៧គ្រឿង ម៉ាស៊ីន Computer ១៨គ្រឿង Studio ៣ឈុត ម៉ាស៊ីនចាក់ផ្សាយ៣ឈុត។

ការចេញប្រព័ន្ធផ្សព្វផ្សាយ ទូរទស្សន៍ជាតិកម្ពុជាប៉ុស្តិ៍ទទក២ ដែលមានគោលដៅលើការអប់រំ ដែលជាជំហានៗផ្តោតលើការងារច្បាប់ និងការងារស្រាវជ្រាវ។

**គ- ការងារវិទ្យុជាតិកម្ពុជា**

រយៈពេល៥ឆ្នាំ(២០១៧-២០២១) កន្លងមកនេះ ថ្នាក់ដឹកនាំមន្ត្រីរាជការនៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា បានយកចិត្តទុកដាក់បំពេញការងារទទួលបានលទ្ធផលល្អគួរឱ្យកត់សម្គាល់។ ដើម្បីរួមចំណែកការអនុវត្តន៍នូវគោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាអនុវត្តឱ្យបានសមស្របតាមទិសស្លោកដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដែលបានលើកឡើងថា«**ប្លែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន**» វិទ្យុជាតិកម្ពុជា បានផ្សព្វផ្សាយនូវព័ត៌មាន ដូចជាទិវាជាតិ អន្តរជាតិផ្សេងៗ និងព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើងនៅព្រះរាជាណាចក្រកម្ពុជាក្នុងតំបន់ និងនៅលើសកលលោក ទន្ទឹមនេះក៏បានរៀបចំកម្មវិធីអប់រំ និងកម្សាន្តដើម្បីបម្រើអារម្មណ៍ប្រិយមិត្តអ្នកស្តាប់ទៀតផង។

**វិទ្យុជាតិកម្ពុជាធ្វើការផ្សាយតាមប្រព័ន្ធវិទ្យុ៖**

១- វិទ្យុ AM ៩១៨KHz ថាមពលផ្សាយ៦០០KW

២- វិទ្យុ FM វត្តភ្នំ១០៥.៧0MHz ថាមពលផ្សាយ៣0KW

៣- វិទ្យុ FM ជាតិ៩៦MHz ថាមពលផ្សាយ២0KW

៤- ផ្សាយតាមគេហទំព័រវិទ្យុជាតិកម្ពុជា (www.rnk.gov.kh) និងតាមរយៈទំព័រហ្វេសបុកផេក Facebook Page: Radio National of Kampuchea (RNK) និងផ្សាយតាមរលកជាតុអាកាស DTV។

៥- ផ្សាយតាម Chanel Telegram អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា។

ក្នុងរយៈពេលប្រាំឆ្នាំចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ វិទ្យុជាតិកម្ពុជាបានផ្សព្វផ្សាយនូវគ្រប់ជុំវិញព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមាននៅក្នុងប្រទេសនិងតំបន់តាមរយៈការងារបច្ចេកទេស ការផ្សាយសំឡេងផ្ទាល់ ព័ត៌មានភាសាជាតិ ភាសាបរទេស បទយកការណ៍ នាទីកម្សាន្ត បទវិចារណកថា និងតាមមធ្យោបាយផ្សេងៗថែមទៀតផង។

ចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១នេះ អគ្គនាយកដ្ឋាន សម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម៖

ការងារផ្សព្វផ្សាយព័ត៌មានក្នុងនិងក្រៅប្រទេសចំនួន២៥កម្មវិធី ការងារផលិតព័ត៌មាន ចំនួន៣៦ ២២៥ ព័ត៌មាន ១ ៣១៤អត្ថបទ ១ ៤៤០កម្មវិធី ការងារផ្សព្វផ្សាយទៅបរទេស ភាសាជាតិ អង់គ្លេស និងបារាំង ចំនួន ៩ ៤២៨អត្ថបទ និង១២ ៤៩៥ព័ត៌មាន ការងារផលិតកម្មវិធីចំនួន៨ ២០៨កម្មវិធី ៦៧អត្ថបទ ការងារបច្ចេកទេស ចំនួន១ ៩៧៥លើក ២៤ ០៤៩ម៉ោង និង៤៥នាទី ការងារមន្ទីរចំនួន៥ ២៥៤ច្បាប់ ការងារផលិតផ្សព្វផ្សាយព័ត៌មានជាតិ អន្តរជាតិចំនួន១១០ ៤៨៩អត្ថបទ និង៥ ៤០០កម្មវិធី។

**ឃ- ការងារទីភ្នាក់ងារសារព័ត៌មានកម្ពុជា**

រយៈពេល៥ឆ្នាំកន្លងមកនេះ អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា(AKP) បានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ ដោយបានចាត់បញ្ជូនមន្ត្រីយកព័ត៌មាន

និងថតរូប តាមបណ្ដាក្រសួង/ស្ថាប័ននានា នៅបណ្ដារាជធានី/ខេត្តជិតឆ្ងាយក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្សព្វផ្សាយព័ត៌មាន/រូបថត ជាភាសាជាតិ អន្តរជាតិ( ខ្មែរ អង់គ្លេស និងបារាំង ) រូបថតប្រចាំសប្ដាហ៍( ខ្មែរ អង់គ្លេស និងបារាំង ) បទវិចារណកថា បទយកការណ៍ជាអត្ថបទ/វីដេអូ Poster និង Infographic តាមរយៈព្រឹត្តិបត្រព័ត៌មានប្រចាំថ្ងៃ គេហទំព័រ( WWW.akp.gov.kh ) / AKP Gallery ( www.akpgallery.gov.kh ) ទំព័រហ្វេសប៊ុកផ្លូវការ ( ទីភ្នាក់ងារសារព័ត៌មានកម្ពុជា-AKP ) Youtube ( Agence Kampuchea Presse ) Twitter ( Agence Kampuchea Presse ) Channel Telegram ( AKP News ) និងទស្សនាវដ្ដីកម្ពុជាប្រចាំខែផងដែរ បើទោះបីជាស្ថិតក្នុងស្ថានភាពខ្វះខាត ដូចជាមធ្យោបាយចុះយកព័ត៌មាន ប្រេងឥន្ធនៈ សម្ភារៈបច្ចេកទេស និងថវិកាដើម្បីផ្គត់ផ្គង់នៅក្នុងអគ្គនាយកដ្ឋានក៏ដោយ។

ចាប់ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០២១ នេះ អគ្គនាយកដ្ឋាន សម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម៖

ព័ត៌មានជាតិនិងអន្តរជាតិជាភាសាខ្មែរចំនួន៣៦ ៦១៥ដំណឹង ភាសាអង់គ្លេសចំនួន១២ ៣២១ដំណឹង ភាសាបារាំងចំនួន៨ ៧១១ដំណឹង ព័ត៌មានរូបថតជាភាសាខ្មែរ៨៣ ១៤៧ដំណឹង ភាសាអង់គ្លេស៥៧ ៦១៤ដំណឹង ភាសាបារាំងចំនួន៤៦ ៧១៦ដំណឹង ទស្សនាវដ្ដីចំនួន៥៧ក្បាល ព្រឹត្តិបត្រព័ត៌មានចំនួន៦៥ ៤៥៩ច្បាប់ បទវិចារណកថាចំនួន២១អត្ថបទ បទយកការណ៍ជាវីដេអូចំនួន៥៤រឿង បទយកការណ៍ជាអត្ថបទចំនួន១១៦រឿង Poster ចំនួន៥៨រឿង Infographic ចំនួន៧៣រឿង រូបថតប្រចាំសប្ដាហ៍ចំនួន១៩២រឿង។

**ង- មន្ទីរព័ត៌មានរាជធានី ខេត្ត ប្រចាំឆ្នាំ២០១៧-២០២១**

មន្ទីរព័ត៌មានរាជធានី ខេត្ត បានដំណើរការចុះយកព័ត៌មាន ថតរូបភាពយកមកតែងនិពន្ធ ចងក្រងអត្ថបទព័ត៌មានផលិតកម្មវិធីផ្សេងៗ និងស្ពតអប់រំខ្លីៗ ដើម្បីផ្សព្វផ្សាយតាមបណ្ដាញវិទ្យុFM ទូរទស្សន៍ជាតិរាជធានី ខេត្ត ទូរទស្សន៍ខ្សែរកាបឯកជននៅក្នុងរាជធានី ខេត្តរបស់ខ្លួន និងបានបញ្ជូនខ្លឹមសារមកវិទ្យុ និងរូបភាពមកទូរទស្សន៍ជាតិកម្ពុជា និងឯកជននៅរាជធានីភ្នំពេញ ឱ្យជួយផ្សព្វផ្សាយផងដែរ។ ទន្ទឹមនេះគ្រប់មន្ទីរព័ត៌មានរាជធានី ខេត្ត ក៏បានយកចិត្តទុកដាក់ខ្ពស់ក្នុងការចាក់ផ្សាយបន្តពីវិទ្យុ ទូរទស្សន៍ជាតិកម្ពុជាជាប្រចាំ តាមរយៈវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែរកាប នៅក្នុងរាជធានី ខេត្ត នូវរាល់ព្រឹត្តិការណ៍ និងព័ត៌មាន សំខាន់ៗស្ដីពីព្រះរាជសកម្មភាព និងសកម្មភាពព្រះមហាក្សត្រ ព្រឹទ្ធសភា រដ្ឋសភា ប្រមុខរាជរដ្ឋាភិបាល ព្រមទាំងបានរាយការណ៍នូវព័ត៌មានប្លែកៗទាន់ហេតុការណ៍ និងព្រឹត្តិការណ៍ដែលកើតមានក្នុងមូលដ្ឋានរបស់ខ្លួនមកក្រសួងបានទាន់ពេលវេលា និងធ្វើការត្រួតពិនិត្យជាប្រចាំគ្រប់ប្រព័ន្ធផ្សព្វផ្សាយក្នុងរាជធានី ខេត្តផងដែរ។

មន្ទីរព័ត៌មានរាជធានី ខេត្ត ជាសេនាធិការរបស់ក្រសួងព័ត៌មាន ដែលបំពេញតួនាទីទ្រទ្រង់ផ្នែកបច្ចេកទេសសម្រាប់ការងារព័ត៌មាននៅថ្នាក់ក្រោមជាតិដោយបាននូវលទ្ធផលដូចខាងក្រោម៖

ស្ថានីយទូរទស្សន៍ជាតិ ស្ថានីយវិទ្យុជាតិ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ព័ត៌មាននិងសោតទស្សន៍ប្រចាំរាជធានី ខេត្ត បានផលិតកម្មវិធី ចំនួនសរុប១០៥ ៦៦៦អត្ថបទ ៦៥ ៩១៨លើក ៤៧ ៧៩៩ម៉ោង ២០០វីដេអូ ២៤កម្មវិធី៤ ៤០៥សន្លឹក ១ ១៥៨ទីតាំង និងការងារផ្សព្វផ្សាយព័ត៌មានចំនួនសរុប១៧៩ ៨០១អត្ថបទ ៥៩៦ ៣៣៦លើក ១០៣ ៩៩៦ម៉ោង ១៨ ៧៩៤ព័ត៌មាន ២០វីដេអូ ៤២០អាដ្ឋាបណ្ណ ១ ០២៧ទីតាំង។

កិច្ចការរដ្ឋបាល បានចំនួនសរុប៥ ៥៣០លិខិតចូល ៧ ០០៥លិខិតចេញ តាក់តែងលិខិត២ ១១៥លិខិត ការងារតម្កល់ឯកសារ៣ ៦១២លិខិត លិខិតបេសកកម្ម១ ៨៧៦លិខិត ការងារបណ្ដុះបណ្ដាល៣៧ដង។

## មុំទី៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

### ១- លទ្ធផលការងារសំខាន់ៗរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖

### ១.១- ការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្ត

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ៩ខែ ឆ្នាំ២០២១ |
|---|---|---|---|---|---|
| គោលនយោបាយ | ១ | - | - | - | - |
| ច្បាប់ | - | - | ១ | - | - |
| ព្រះរាជក្រឹត្យ | - | ១ | - | - | - |
| អនុក្រឹត្យ | - | ៣ | ២ | ៣ | ១ |
| ប្រកាសអន្តរក្រសួង | ២ | ១ | ៤ | - | ៣ |
| ប្រកាស | - | ២ | ២ | ១ | ១ |
| សេចក្តីសម្រេច | - | ៦ | ៥ | ៨ | ៣ |
| សារាចរណែនាំ | - | ១ | ២ | ១ | ១ |
| សរុប | ៣ | ១៤ | ១៦ | ១៣ | ៩ |

(តារាងឧបសម្ព័ន្ធលិខិតបទដ្ឋានគតិយុត្តដែលសម្រេចបានរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៧ រយៈពេល៩ខែ ឆ្នាំ២០២១)

គិតពីចាប់ផ្តើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានអនុម័តក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តសរុប២៤៨ ក្នុងនោះគោលនយោបាយចំនួន១១ ច្បាប់ចំនួន៤ ព្រះរាជក្រឹត្យចំនួន៨ អនុក្រឹត្យចំនួន៤៤ ប្រកាសអន្តរក្រសួងចំនួន១៧ ប្រកាសចំនួន២៨ បទបញ្ជាចំនួន៤ សារាចរណែនាំចំនួន១៩ សេចក្តីសម្រេចចំនួន៣៤ សេចក្តីណែនាំចំនួន២៥ សេចក្តីជូនដំណឹងចំនួន៨ សេចក្តីប្រកាសចំនួន១ គោលការណ៍ណែនាំចំនួន១ និងលិខិតណែនាំអនុវត្តចំនួន៤៥។

#### ក- ការអភិវឌ្ឍរដ្ឋបាលឌីជីថល

បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការតាមព័ត៌មានវិទ្យា បានបង្កើតសារអេឡិកត្រូនិក(Email) ជូនមន្ត្រីរាជការនៅទីស្តីការក្រសួងចំនួន៨៤៨រូប(ស្ត្រី១៨៧រូប) ប្រព័ន្ធព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈ Scan QR Code បានបង្កើតកម្មវិធី«**សំណង់នៅកម្ពុជា**» ដែលត្រូវបានដាក់ឱ្យប្រើប្រាស់នៅលើប្រព័ន្ធទូរសព្ទចល័ត iOS និង Android និងទទួលបានពានរង្វាន់«**សេវារដ្ឋបាលសាធារណៈអេឡិចត្រូនិកល្អបំផុតប្រចាំឆ្នាំ២០១៩**» ក្នុងព្រឹត្តិការណ៍ពិព័រណ៍បច្ចេកវិទ្យាឌីជីថលកម្ពុជាឆ្នាំ២០១៩ ដែលរៀបចំដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងទទួលបាន«ការទទួលស្គាល់ពិសេសផ្នែកនវានុវត្តឌីជីថល» ក្នុងព្រឹត្តិការណ៍ Cambodia Property Award 2019 រៀបចំដោយ Cambodia Guru Property Award។

#### ខ- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្រសួង

-ការសាងសង់អគារទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានបញ្ចប់រួចរាល់១០០%។ អគារនេះត្រូវបានធ្វើពិធីបញ្ចុះបឋមសិលាបើកការដ្ឋានកាលពីថ្ងៃទី២៨ ខែមករាឆ្នាំ២០២០ លើផ្ទៃដីទំហំ៤,៥ហ.ត. មានក្រឡាផ្ទៃសំណង់សរុប៦១ ៦៤២ម. និងសាងសង់ប្រើរយៈពេល១ឆ្នាំ ១ខែ និង២០ថ្ងៃ

- ការសាងសង់អគារមន្ទីរពិសោធន៍ជាតិសំណង់សម្រេចបានប្រមាណ៤៥% ហើយនឹងត្រូវបញ្ចប់ក្នុងដើមឆ្នាំ២០២២។

## ១.២- ការងាររដ្ឋបាលដីធ្លី

### ១.២.១- ការចុះបញ្ជីដីធ្លី

#### ១- ការចុះបញ្ជីដីធ្លីដំបូង

| ឆ្នាំ | ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ | ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ | | | សរុប |
|---|---|---|---|---|---|
| | | ដីរដ្ឋ | ដីរបស់បុគ្គលឯកជន | ដីសហគមន៍ជនជាតិដើមភាគតិច | |
| ២០១៧ | ២២៦ ៥៦១ | ៨៨៩ | ២ ៣១២ | ៦០ | ២២៩ ៨២២ |
| ២០១៨ | ២៣២ ១១៩ | ១៣៧ | ២ ២៨៤ | ១៦៥ | ២៣៤ ៧០៥ |
| ២០១៩ | ៤៩៦ ១៦២ | ៨៥ | ១ ៤៨០ | ១៣៥ | ៤០៧ ៨៦២ |
| ២០២០ | ៤៤៨ ០៤៨ | ១១១ | ៣ ០៥៨ | ៧៥ | ៤៥១ ២៩២ |
| ៩ខែ ឆ្នាំ២០២១ | ១៩៨ ៤៧០ | ៦៨ | ២ ១៦៨ | - | ២០០ ៧០៦ |
| **សរុប** | **១ ៦០១ ៣៦០** | **១ ២៩០** | **១១ ៣០២** | **៤៣៥** | **១ ៦១៤ ៣៨៧** |

គិតពីចាប់ផ្ដើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានចុះបញ្ជីនិងចេញបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប៦ ២៧៧ ៥៩៩បណ្ណ ស្មើនឹង៨៩,៧%នៃក្បាលដីប៉ាន់ស្មានសរុបចំនួន៧លានក្បាលដី ក្នុងនោះ (១) ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធចំនួន៥ ៦៥៤ ៦២៣បណ្ណ (២) ចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំចំនួន ៦២២ ៩៧៦បណ្ណ(ដីសហគមន៍ជនជាតិដើមភាគតិចបាន៣៣សហគមន៍ ស្មើនឹង៨៥៦បណ្ណ)។

បញ្ជាក់ : ការចុះបញ្ជីដីគុរុកណ្ឌរបស់វត្តបានចំនួន១ ៩៣៣វត្ត ស្មើនឹង២ ៤០០បណ្ណ (ការចុះបញ្ជីជាប្រព័ន្ធចំនួន២ ០៨១បណ្ណ និងការចុះបញ្ជីដាច់ដោយដុំចំនួន៣១៩បណ្ណ)។

#### ២- ការចុះបញ្ជីដីធ្លីតាមប្រភេទទ្រព្យ

គិតជាភាគរយតាមប្រភេទទ្រព្យ ក្នុងនោះមានទ្រព្យខាងប្ដី១០% ទ្រព្យខាងប្រពន្ធ១៨% ទ្រព្យលីវ១២% ទ្រព្យរួមប្ដីប្រពន្ធ៥៣% និងទ្រព្យផ្សេងៗ ៧%។

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ៩ខែឆ្នាំ២០២១ | គិតជា% |
|---|---|---|---|---|---|---|
| ទ្រព្យរួមប្ដីប្រពន្ធ | ១៩៧ ១៤៥ | ១៩៩ ៣១៦ | ៣៨២ ៣៦៣ | ៣៨៧ ២៤៣ | ២៤៦ ៦៤៩ | ៥៣% |
| ទ្រព្យខាងប្ដី | ៣១ ១០២ | ៣៣ ៩៥២ | ៧០ ៣១៨ | ៧៩ ០៨៤ | ៤៦ ១៩០ | ១០% |
| ទ្រព្យខាងប្រពន្ធ | ៦៦ ៨០៣ | ៦០ ៥៣៦ | ១២៩ ៣៣៤ | ១២២ ២៨៣ | ៨០ ៤០៣ | ១៨% |
| ទ្រព្យលីវ | ៣០ ៩៥៩ | ៣២ ៩៦៥ | ៧០ ៦៩២ | ៨០ ២៩៦ | ៥៦ ៦៧៨ | ១២% |
| ទ្រព្យផ្សេងៗ | ៩ ៤៧៦ | ៩ ៦៦០ | ២៥ ៣៣៥ | ៥១ ៧៩៣ | ៣៣៩៤០ | ៧% |
| **សរុបគ្រប់ប្រភេទទ្រព្យ** | **៣៣៥ ៤៨៥** | **៣៣៦ ៤២៩** | **៦៧៨ ០៤២** | **៧២០ ៦៩៩** | **៤៦៣ ៨៦០** | **១០០%** |

#### ៣- ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

| ឆ្នាំ | ចុះបញ្ជីនិងចេញវិញ្ញាបនបត្រ | | | ចុះបញ្ជីផ្ទេរសិទ្ធិ | | |
|---|---|---|---|---|---|---|
| | រាជធានីភ្នំពេញ | ខេត្តព្រះសីហនុ | ខេត្តសៀមរាប | ខ្មែរ | ជនបរទេស | ក្រុមហ៊ុន |
| ២០១៧ | ១២ ០៥០ | ៥១ | - | ២៨៦ | ៨៨៥ | - |
| ២០១៨ | ៤ ៦៦២ | ៣២ | - | ៣៩០ | ១ ១៣៧ | - |
| ២០១៩ | ៣ ២៦៤ | ៤១ | - | ៤៣១ | ២ ៥២២ | ៨៥ |
| ២០២០ | ៧ ៥១៣ | ៦ ២៦២ | ១៣ | ៣៧៩ | ២ ១៤៨ | ១៦៥ |
| ៩ខែឆ្នាំ២០២១ | ១ ០២០ | | - | ២៣២ | ៦៦៨ | ៣៨ |
| **សរុប** | **២៨ ៥០៩** | **៦ ៣៨៦** | **១៣** | **១ ៧១៨** | **៧ ៣៦០** | **២៨៨** |

គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០១១ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិចំនួន៣៨ ០៩៨បណ្ណ (រាជធានីភ្នំពេញចំនួន៣១ ៦៩៩បណ្ណ ខេត្តព្រះសីហនុចំនួន៦ ៣៨៦បណ្ណ និងខេត្តសៀមរាប១៣បណ្ណ) និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចំនួន១០ ៨១១បណ្ណ(ខ្មែរចំនួន២ ៦១១បណ្ណ ជនបរទេសចំនួន៧ ៩១២បណ្ណ និងក្រុមហ៊ុនចំនួន២៨៨បណ្ណ)។

### ១.២.២- ការគាំទ្រដល់ការងាររដ្ឋបាលដីធ្លី

១- ការជំរុញការជម្រះ ការកកស្ទះឯកសារពន្ធប្រថាប់ត្រាសូន្យដែលទាក់ទងនឹងការផ្ទេរកម្មសិទ្ធិរវាងញាតិជាមួយអង្គភាពពន្ធដារសម្រេចបាន៖

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ៩ខែ ឆ្នាំ២០២១ |
|---|---|---|---|---|---|
| បញ្ជូនសំណុំឯកសារទៅសាខាពន្ធដារ | - | - | - | ១១៧ ៩៣៥ | ១១០ |
| ចែកបណ្ណ | - | - | - | ១១៣ ៧៨៤ | ៣៨៧ |
| សំណុំឯកសារសល់នៅពន្ធដារ | - | - | - | ៥៦៧ | ៥៧២ |
| ម្ចាស់កាន់ទៅប្រថាប់ត្រា(សំណុំឯកសារ) | - | - | - | ១ ៣១៦ | ១ ៣១៦ |
| សល់នៅមន្ទីរ (សំណុំឯកសារ) | - | - | - | ២ ១៨១ | ២ ១៨១ |

ការជំរុញការជម្រះការកកស្ទះឯកសារពន្ធប្រថាប់ត្រាសូន្យ ដែលទាក់ទងនឹងការផ្ទេរកម្មសិទ្ធិរវាងញាតិជាមួយអង្គភាពពន្ធដារសម្រេចបាន គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០២០ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ មន្ទីរបានបញ្ជូនសំណុំឯកសារទៅសាខាពន្ធដារបានចំនួន១១៨ ០៤៥សំណុំឯកសារ ហើយសាខាពន្ធដាបានប្រថាប់ត្រារួចចំនួន១១៧ ៣២៣សំណុំឯកសារ មន្ទីរដ.ន.ស.ស.រាជធានី ខេត្ត បានរៀបចំឯកសារសម្រេចនិងបានចែកបណ្ណបានចំនួន១១៤ ១៧៤បណ្ណ។ សំណុំឯកសារដែលសល់នៅសាខាពន្ធដារមានចំនួន៥៧២សំណុំឯកសារ ម្ចាស់កាន់ទៅប្រថាប់ត្រាផ្ទាល់ចំនួន១ ៣១៦សំណុំឯកសារ និងសល់នៅមន្ទីរចំនួន២ ១៨១សំណុំឯកសារ។

២- គាំទ្រការអនុវត្តការងារចុះបញ្ជីដីរដ្ឋ ចុះបញ្ជីដីឯកជនរបស់ប្រជាពលរដ្ឋ ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដោះស្រាយវិវាទដីធ្លី និងកសាងផែនការប្រើប្រាស់ដីខេត្តមណ្ឌលគិរី នៃក្រុង ស្រុកគោលដៅចំនួន៥ គឺក្រុងសែនមនោរម្យ ស្រុកកែវសីមា ស្រុកកោះញែក ស្រុកអូររាំង និងស្រុកពេជ្រាដា ដើម្បីចុះស្រង់និងប្រមូលទិន្នន័យក្បាលដីចំនួន១២ភូមិ ដែលមានក្រុមការងារចុះបញ្ជីដីធ្លីចំនួន១២ក្រុម ស្មើនឹង១២០នាក់។ សរុបលទ្ធផលពីចាប់ផ្តើមអនុវត្តថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានធ្វើការវាស់វែងបានចំនួន៧ ២៥៦ក្បាលដី បំពេញទម្រង់ បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចំនួន៦ ១៩០ក្បាលដី គូសបានចំនួន៧ ២៥៦ក្បាលដី បញ្ចូលទិន្នន័យបានចំនួន៤ ៧៧៦ក្បាលដី។ បានប្រគល់ទិន្នន័យក្បាលដីដែលវាស់វែង និងផែនទី(Hard Copy និង Soft Copy) ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់មកក្រសួង។ បានទទួលការឆ្លើយតបពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន និងកំពុងបន្តអនុវត្តនីតិវិធី។

៣- ការងារភូមិសាស្ត្រនិងវាស់វែង

- ការងារចុះបង្គោះជ្រូន ដើម្បីថតរូបភាពផលិតជាផែនទីរូបថតអ័រតូហ្វូតូ និងវីដេអូបាន២៨ទីតាំង ដែលបានផលិតជាផែនទីរូបថតអ័រតូហ្វូតូបានចំនួន៧៤ ៦៣០ហ.ត.

- បានផលិតអ័រតូហ្វូតូមាត្រដ្ឋាន១:៤ ០០០ ចំនួន៥ ៦៧២សន្លឹក ទំហំ២២ ៥៨៨គ.ម.២ គាំទ្រដល់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធទូទាំងប្រទេស

- បានបោះពុម្ពប្លង់សុរិយោដី រូបថតអ័រតូហ្វូតូ និងបញ្ជីឈ្មោះម្ចាស់ដីទំហំA0 បានចំនួន៨ ៥៧៥សន្លឹក

- បានរៀបចំទិន្នន័យភូមិសាស្ត្រជាទម្រង់ឌីជីថល ដោយបានស្កេនផែនទីនិងរូបថតផែនទី ដែលផលិតដោយកងទ័ពយោធាអាម៉េរិកក្នុងទសវត្សរ៍ទី៦០ បានចំនួន២៨០សន្លឹក មាត្រដ្ឋាន១:៥ ០០០ និងផែនទីឋានលេខាព្រំដែនគោកកម្ពុជា វៀតណាម មាត្រដ្ឋាន១:២៥ ០០០ចំនួន៩២ផ្ទាំង

- បានកសាងស្ថានីយវាស់វែងអចិន្ត្រៃយ៍ចំនួន៦០ស្ថានីយ នៅក្នុងទូទាំងប្រទេសនិងបង្គោលបណ្តាញប្រឹថពីវិភាគចំនួន១១១បង្គោល( លំដាប់ទី២ ចំនួន៥២បង្គោល និងលំដាប់ទី៣ ចំនួន៥៩បង្គោល។

៤- ប្រគល់ភារកិច្ចជូនមេឃុំ ចៅសង្កាត់ មានសមត្ថកិច្ចពេញលេញចុះហត្ថលេខាបញ្ជាក់លើលិខិតផ្សេងៗ ដូចជាលិខិតលក់ផ្តាច់ អំណោយផ្តាច់ ហ៊ីប៉ូតែក កិច្ចសន្យាបង្កើតសេវភាព ផលុបភោគ ដោយមិនតម្រូវឱ្យអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចុះហត្ថលេខា។

៥- បានណែនាំអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ឱ្យឈប់បញ្ជាក់លើឯកសារផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីណាដែលពុំមានភ្ជាប់គំនូសប្លង់ទីតាំង មាននិយាមការច្បាស់លាស់ដោយមានការបញ្ជាក់ទទួលស្គាល់ពីរដ្ឋបាលសុរិយោដី។

### ១.២.៣- ការងាររៀបចំដែនដីនិងនគររូបនីយកម្ម

| រយៈពេល | ថ្នាក់រាជធានី ខេត្ត | ថ្នាក់ក្រុង ស្រុក ខណ្ឌ និងទីប្រជុំជន | ថ្នាក់ឃុំ សង្កាត់ |
|---|---|---|---|
| ២០១៧ | - | ១ | ២ |
| ២០១៨ | ២ | ៣ | ២ |
| ២០១៩ | - | ៦ | ២ |
| ២០២០ | - | ៣ | ៣៥ |
| ៩ខែ ឆ្នាំ២០២១ | - | ១ | ៦០ |
| **សរុប** | **២** | **១៤** | **១០១** |

គិតពីចាប់ផ្តើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ ក្រសួងសម្រេចលទ្ធផលបានដូចខាងក្រោម៖

**១- បានអនុម័តផែនការរូបវន្ត៖**

- ថ្នាក់រាជធានី ខេត្តចំនួន៣ ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ផែនការរៀបចំដែនដីខេត្តបាត់ដំបង និងខេត្តព្រះសីហនុ

- ថ្នាក់ក្រុង ស្រុក ខណ្ឌ និងទីប្រជុំជនចំនួន១៨ : ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនទីរួមខេត្តត្បូងឃ្មុំ ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបង ក្រុងតាខ្មៅ ក្រុងកំពត ក្រុងបូកគោ ក្រុងកែប ក្រុងខេមរភូមិន្ទ ក្រុងសៀមរាប ក្រុងប៉ោយប៉ែត ក្រុងបាវិត ក្រុងស្ទឹងត្រែង ស្រុកបរិបូណ៌ ខណ្ឌជ្រោយចង្វា ខណ្ឌសែនសុខ ក្រុងព្រះសីហនុ ទីប្រជុំជនកោះរ៉ុង ទីប្រជុំជនជ្រៃធំនៃស្រុកកោះធំ និងទីប្រជុំជនស្រុកស្វាយអន្ទរ

- ថ្នាក់ឃុំ សង្កាត់ : ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន១៧៧ឃុំ ក្នុង១៤ខេត្ត។

**២- បានរៀបចំផែនទីព្រំប្រទល់រដ្ឋបាល ផែនទីហេដ្ឋារចនាសម្ព័ន្ធ និងផែនទីប្រើប្រាស់ដីបច្ចុប្បន្ននៃក្រុង** ស្រុក ខណ្ឌចំនួន១៧៦ ស្មើ៨៦% នៃចំនួនក្រុង ស្រុក ខណ្ឌ សរុប២០៣ នៅទូទាំងប្រទេស។

## ៣- ការអភិវឌ្ឍនិងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រកម្ពុជា

### ៣.១- ការកសាងផែនការរូបវន្ត

| ឆ្នាំ | បរិយាយការងារ |
|---|---|
| ២០១៧ | - រៀបចំនិងសម្រេចប្លង់គោលប្រើប្រាស់ដីកោះរ៉ុង |
| ២០១៨ | - រៀបចំប្លង់គោលប្រើប្រាស់ដីកោះចំនួន៣កោះ |
| ២០១៩ | - រៀបចំប្លង់គោលប្រើប្រាស់ដីកោះចំនួន៣កោះ<br>- រៀបចំផែនទីដីចំណីឆ្នេរសមុទ្រកម្ពុជា<br>- បង្ហោះផ្សព្វផ្សាយវីដេអូស្ថានភាពជាក់ស្តែងនៃតំបន់ឆ្នេរសមុទ្រកម្ពុជា ខេត្តកំពត ខេត្តកែប និងខេត្តព្រះសីហនុ |
| ២០២០ | - រៀបចំប្លង់គោលប្រើប្រាស់ដីកោះចំនួន១កោះ<br>- រៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រក្រុងព្រះសីហនុ |
| ៩ខែ ២០២១ | - រៀបចំនិងសម្រេចដាក់ឱ្យប្រើប្រាស់នូវគម្រោងកែលម្អឆ្នេរកក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់ប្រវែង ២ ៧០០ម. ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប<br>- រៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីតំបន់បឹងធំកង្កែប ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ |

### ៣.២- ការសាងសង់

| ឆ្នាំ | បរិយាយការងារ |
|---|---|
| ២០១៧ | - បោះបង្គោលប្រឹថពីវិភាគនិងរៀបចំផែនទីរូបថតពីលើអាកាសចំនួន៤កោះ<br>- សាងសង់ខ្លោងច្រកចូលឆ្នេរសមុទ្រចំនួន១១ ទីតាំងនៅខេត្តព្រះសីហនុ |
| ២០១៨ | - សាងសង់បង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រកម្ពុជាចំនួន១០បង្គោល<br>- បោះបង្គោលប្រឹថពីវិភាគនិងរៀបចំផែនទីរូបថតពីលើអាកាសចំនួន៤កោះ |
| ២០១៩ | - សាងសង់បង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រកម្ពុជាចំនួន១៥បង្គោល<br>- អនុវត្តគម្រោងសាងសង់ស្ថានីយបូមទឹកកខ្វក់ទំនើបចំនួន៤កន្លែង នៅឆ្នេរឯករាជ្យ ឆ្នេរសុខា អូរសម្ពាត និងនៅឆ្នេរអូរឈើទាល រៀបចំបណ្តាញលូបេតុងបានប្រវែង៧៦០ម. និងទុយោជ័រស្វិត ***HDPE*** បានប្រវែង៥ ៧៨១ម. ស្តារព្រែកអូរឈើទាលបានប្រវែង២ ៤០០ម. និងអូរសម្ពាតបានប្រវែង១ ២២៤ម. ដាំដើមនាងនួនតាមដងវិថីចំនួន១០ បានចំនួន២ ៤៥៨ដើម និងដាំដើមកោងកាងនៅព្រែកអូរឈើទាលបានចំនួន១០ ០០០ដើម |
| ២០២០ | - សាងសង់បង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រកម្ពុជាចំនួន១៥បង្គោល<br>- អនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែ មានប្រវែង៨៤ ៥០៥ម. ចែកចេញជាបីប្រភេទ រួមមានមហាវិថីមានចំនួន៣ខ្សែ មានប្រវែង២២ ៧៣១ម. មានទទឹង៥០ម. វិថីមានចំនួន១៦ខ្សែ មានប្រវែង៤៩ ៩៥៧ម. មានទទឹងពី២០ទៅ៤០ម. អនុវិថីមានចំនួន១៥ខ្សែ មានប្រវែង១១ ៨១៧ម. មានទទឹងពី១៥ទៅ៤៥ម. និងស្ពានចំនួន៨ទីតាំងមានប្រវែង២៧២ម. ព្រមទាំងរង្វង់មូលមានចំនួន៥ទីតាំង មានរង្វង់មូលព្រះថោងព្រះនាងនាគ អង្កត់ផ្ចិត៩៩ម. រង្វង់មូលព្រះឧមាហេស្វរៈអង្កត់ផ្ចិត៩៩ម. រង្វង់មូលសីហារាជមុខបី(ត្រីកោណផ្លូវប្រសព្វ) រង្វង់មូលព្រះស្គន្ធគង់លើក្ងោក(ត្រីកោណផ្លូវប្រសព្វ) និងកែលម្អរង្វង់មូលនាគកងកេង<br>- រៀបចំកែលម្អឆ្នេរអូរត្រេះ ឆ្នេរអូរឈើទាល II ឆ្នេរលំហែកាយ ឆ្នេរឯករាជ្យ បឹងព្រែកទប់ និងពយកំពេញ ដោយបានសម្របសម្រួលរុះរើសំណង់បណ្តោះអាសន្នចំនួន១៥៦ទីតាំងនៅឆ្នេរអូរត្រេះ ១២៦ទីតាំងនៅឆ្នេរអូរឈើទាល II និង ១២ទីតាំងនៅឆ្នេរលំហែកាយ |
| ៩ខែ ២០២១ | - អនុវត្តគម្រោងសាងសង់បង្គន់សាធារណៈតាមបណ្តោយឆ្នេរសមុទ្រក្រុងព្រះសីហនុសម្រាប់សាធារណជន និងទេសចរ ចំនួន១៤ទីតាំង |

| | |
|---|---|
| | - អនុវត្តគម្រោងអភិវឌ្ឍស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទំនើបទី១( *WWTP1* ) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ ៥ ២០០ម. គូបក្នុងមួយថ្ងៃ ស្ថិតនៅឆ្នេរឯករាជ្យ និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទំនើបទី២ ( *WWTP2* ) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ៧ ២០០ម. គូបក្នុងមួយថ្ងៃ ស្ថិតនៅអូរសម្អាតនៃឆ្នេរសុខា ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប MABR<br>- កំពុងអនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងថ្មីចំនួន៣ខ្សែបន្ថែមប្រវែង៣១៣៤ម. ដើម្បីតភ្ជាប់ឆ្នេរសមុទ្ររួមមានវិថីតេជោប្រវែង១ ០៣៤ម. វិថីពយអូរឈើទាល ប្រវែង២៥០ម. និងវិថីឆ្នេរពយជំទាវម៉ៅប្រវែង១ ៨៥០ម.<br>-កំពុងអនុវត្តគម្រោងអភិវឌ្ឍស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទំនើបទី៣( WWTP3 ) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ២០ ០០០ម.[៣] ក្នុងមួយថ្ងៃ ស្ថិតនៅព្រែកអូរឈើទាល ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប MABR |

### ៣.៣- ការណែនាំនិងផ្សព្វផ្សាយ

| ឆ្នាំ | បរិយាយការងារ |
|---|---|
| ២០១៧ | - ជំរុញអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រ<br>- លើកប៉ាណូផ្សព្វផ្សាយអំពីការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាចំនួន៥៤ផ្ទាំង នៅខេត្តព្រះសីហនុ |
| ២០១៨ | - ចុះត្រួតពិនិត្យនិងវាយតម្លៃឆ្នេរខ្សាច់កម្សាន្តនៅខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តកែប និងបានរៀបចំប្រឡងប្រណាំងឆ្នេរខ្សាច់កម្សាន្តស្អាតចំនួន១លើក<br>- រៀបចំយុទ្ធនាការសម្អាតទីក្រុងនិងសម្អាតឆ្នេរសមុទ្រកម្ពុជាចំនួន៤លើក នៅខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង<br>- ចែកផែនទីមគ្គុទេសចរណ៍ (Guide Map) សម្រាប់ទេសចរណ៍ខេត្តកែបចំនួន១ ៧៥០ច្បាប់ |
| ២០១៩ | - ធ្វើលិខិតណែនាំម្ចាស់សណ្ឋាគារ អគារពាណិជ្ជកម្ម អគារកាស៊ីណូ ផ្ទះសំណាក់ អគារស្នាក់នៅរួម អគារស្នាក់នៅរបស់បុគ្គល និងម្ចាស់ភោជនីយដ្ឋាន ស្នើរៀបចំបំពាក់ប្រព័ន្ធ និងម៉ាស៊ីនប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងបណ្តាញលូទឹកកខ្វក់ និងលូទឹកភ្លៀង ស្ថិតនៅក្រុងព្រះសីហនុ បានចំនួន ១៤០ទីតាំង<br>- ចុះត្រួតពិនិត្យនិងវាយតម្លៃឆ្នេរខ្សាច់កម្សាន្តនៅខេត្តព្រះសីហនុ ខេត្តកោះកុងនិងខេត្តកែប និងបានរៀបចំប្រឡងប្រណាំងឆ្នេរខ្សាច់កម្សាន្តស្អាតចំនួន១លើក<br>- រៀបចំយុទ្ធនាការសម្អាតទីក្រុងនិងសម្អាតឆ្នេរសមុទ្រកម្ពុជាចំនួន៤លើក នៅខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង<br>- ចែកខិតបណ្ណផ្សព្វផ្សាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាចំនួន៥ ០០០ច្បាប់ |
| ២០២០ | - |
| ៩ខែ ២០២១ | - |

## ១.២.៤- ការអភិវឌ្ឍវិស័យលំនៅឋាន

### ១- លំនៅឋានតម្លៃសមរម្យ

| ឆ្នាំ | ចំនួនគម្រោង | ចំនួនលំនៅឋាន | | ចំនួនចំណែកឯកជន | |
|---|---|---|---|---|---|
| | | តម្លៃក្រោម ៣០ ០០០ដុល្លារ | តម្លៃចាប់ពី ៣០ ០០០ដុល្លារ | តម្លៃក្រោម ៣០ ០០០ដុល្លារ | តម្លៃចាប់ពី ៣០ ០០០ដុល្លារ |
| ២០១៧ | ៣ | ២ ៨០៧ | ៤ ៩៩០ | ១ ៥២០ | ១ ៤៤០ |
| ២០១៨ | ១ | ៥៣៤ | - | - | - |
| ២០១៩ | ១ | - | - | ៤ ១៤០ | ១៥៦ |

| | | | | | |
|---|---|---|---|---|---|
| ២០២០ | - | - | - | - | - |
| ៩ខែ ២០២១ | - | - | - | - | - |
| **សរុប** | **៥** | **៣ ៣៤១** | **៤ ៩៩០** | **៥ ៦៦០** | **១ ៥៩៦** |

គិតពីចាប់ផ្ដើមអនុវត្តឆ្នាំ២០១៧ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ មានគម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យមានចំនួន៥គម្រោង សាងសង់លំនៅឋានចំនួន៨ ៣៣១ខ្នង និង៧ ២៥៦ចំណែកឯកជន។

## ២- ការផ្ដល់វិញ្ញាបនបត្រប្រកបអាជីវកម្មក្នុងវិស័យសំណង់

| រយៈពេល | ក្រុមហ៊ុន | ចំនួនក្រុមហ៊ុន | ប្រភេទ៣ | ប្រភេទ២ | ប្រភេទ១ | សរុបរួម |
|---|---|---|---|---|---|---|
| ២០១៧ | ក្រុមហ៊ុនសាងសង់ | ២៨៦ | ២២១ | ១៧ | ៤៨ | ២៩៩ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ១៣ | ៩ | ១ | ៣ | |
| ២០១៨ | ក្រុមហ៊ុនសាងសង់ | ៣២១ | ២១២ | ៤៧ | ៦២ | ៣៣៤ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ១៣ | ៩ | ៣ | ១ | |
| ២០១៩ | ក្រុមហ៊ុនសាងសង់ | ៥២៤ | ៣៤៩ | ៦៩ | ១០៦ | ៥៥១ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ២៧ | ២០ | ១ | ៦ | |
| ២០២០ | ក្រុមហ៊ុនសាងសង់ | ៤៤០ | ៣៣៧ | ៣៨ | ៦៥ | ៤៧២ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ៣២ | ២៤ | - | ៨ | |
| ៩ខែ ឆ្នាំ២០២១ | ក្រុមហ៊ុនសាងសង់ | ២៣៨ | ១៦៥ | ២៩ | ៤៤ | ២៥២ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | **១៤** | **១៣** | **១** | - | |
| សរុប | | **១ ៩០៨** | **១ ៣៥៩** | **២០៦** | **៣៤៣** | **១ ៩០៨** |

គិតពីចាប់ផ្ដើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានផ្ដល់វិញ្ញាបនបត្រប្រកបអាជីវកម្មក្នុងវិស័យសំណង់ដល់ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់បានចំនួន៣ ១២៦ក្រុមហ៊ុន ប៉ុន្តែនៅមានសុពលភាពចំនួន១ ៣២៥ក្រុមហ៊ុន។

## ៣- ការផ្ដល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈសិក្សាគម្រោងប្លង់

| ឆ្នាំ | ចំនួនអ្នកវិជ្ជាជីវៈ | វិស្វករ | | ស្ថាបត្យករ | |
|---|---|---|---|---|---|
| | | ខ្មែរ | បរទេស | ខ្មែរ | បរទេស |
| ២០១៧ | ៤៥ | ១៨ | - | ២៦ | ១ |
| ២០១៨ | ៣២ | ៧ | ១ | ២៤ | - |
| ២០១៩ | ១១២ | ៥១ | ១ | ៥៩ | ១ |
| ២០២០ | ១៥១ | ៩៣ | ១ | ៥៧ | - |
| ៩ខែ ឆ្នាំ២០២១ | ៨១ | ៥២ | ៣ | ២៥ | ១ |
| **សរុប** | **៤២១** | **២២១** | **៦** | **១៩១** | **៣** |

គិតពីចាប់ផ្ដើមអនុវត្តឆ្នាំ២០០៩ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានផ្ដល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈសិក្សាគម្រោងប្លង់ដល់អ្នកវិជ្ជាជីវៈចំនួន៤៧៥រូប ក្នុងនោះ មានស្ថាបត្យករចំនួន២៣៨រូប( ស្ថាបត្យករសញ្ជាតិបរទេស៥រូប) និងវិស្វករ២៣៧រូប (វិស្វករសញ្ជាតិបរទេស៦រូប) ប៉ុន្តែនៅមានសុពលភាពចំនួន៣៥២រូប។

### ៤- ការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់និងបិទការដ្ឋានសំណង់ដែលជាសមត្ថកិច្ចក្រសួង

| ឆ្នាំ | លិខិតអនុញ្ញាត បើកការដ្ឋានសំណង់ | លិខិតបិទការដ្ឋានសំណង់ | លិខិតអនុញ្ញាតជួសជុល |
|---|---|---|---|
| ២០១៧ | ១៥២ | ១០០ | ១១ |
| ២០១៨ | ១៤៨ | ៨៣ | ១២ |
| ២០១៩ | ២៦៨ | ១០១ | ២៨ |
| ២០២០ | ១៣៩ | ៨២ | ១៩ |
| ៩ខែ ឆ្នាំ២០២១ | ៦៦ | ៤២ | ៥ |
| **សរុប** | **៧៧៣** | **៤០៨** | **៧៥** |

គិតពីចាប់ផ្តើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ ផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់បានចំនួន២ ១៩៧គម្រោង ផ្តល់លិខិតបិទការដ្ឋានសំណង់ចំនួន៨៩២គម្រោង និងផ្តល់លិខិតអនុញ្ញាតជួសជុលចំនួន២១៩គម្រោង។

### ៥- ការងារគណៈស្ថាបត្យករកម្ពុជា

| ឆ្នាំ | ចំនួនស្ថាបត្យករ | ស្ថាបត្យករ | | ស្ថាបត្យករ | |
|---|---|---|---|---|---|
| | | ខ្មែរ | បរទេស | អាជីព | អាស៊ាន |
| ២០១៧ | ៩៥ | ៨០ | ៤ | ៧ | ៤ |
| ២០១៨ | ៩៨ | ៩៦ | ២ | - | - |
| ២០១៩ | ១០៦ | ១០៥ | ១ | - | - |
| ២០២០ | ៣៩៦ | ៣០៥ | ១ | ៦៥ | ២៥ |
| ៩ខែ ឆ្នាំ២០២១ | ៦៦ | ៦៣ | ៣ | - | - |
| **សរុប** | **៧៦១** | **៦៤៩** | **១១** | **៧២** | **២៩** |

គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០១៤ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ ស្ថាបត្យករចុះបញ្ជីសរុបចំនួន ១ ៣២៧នាក់(ស្ត្រី១៧២នាក់) ក្នុងនោះ ស្ថាបត្យករបរទេសចុះបញ្ជីមានចំនួន១៧នាក់ ស្ថាបត្យករអាជីពមានចំនួន៧២នាក់(ស្ត្រី៧នាក់) និងស្ថាបត្យករអាស៊ានមានចំនួន២៩នាក់(ស្ត្រី២នាក់)។

## ១.២.៥- ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

- កំពុងចុះអនុវត្តនូវគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុង៣៨ខ្សែ ក្នុងខេត្តសៀមរាប។ គិតពីចាប់ផ្តើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១សម្រេចបាន៨៣,០២%

- កំពុងចុះអនុវត្តគម្រោងសាងសង់អគារសារមន្ទីរប្រវត្តិសាស្ត្រកោះថ្មនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយសម្រេចបាន៨០%

- កំពុងចុះអនុវត្តគម្រោងសាងសង់អគារមន្ទីរបង្អែកស្រុកក្រូចឆ្មារ(អគារទី១) នៅភូមិខ្សាច់ប្រឆេះលើ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដោយសម្រេចបាន៩០% និងគ្រោងបញ្ចប់ការសាងសង់នៅដំណាច់ឆ្នាំ២០២១នេះ។

## ១.៣- ការអភិវឌ្ឍដោយចីរភាព

### ក្រសួងបរិស្ថាន សម្រេចបានការងារដូចខាងក្រោម៖

- **អនុម័តជាផ្លូវការនិងកំពុងបន្តអនុវត្ត** ១- ផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ២- ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ៣- ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ៤- យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីប្រភេទទន្រ្ទានរាតត្បាត ៥- យុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ៦- ផែនការយុទ្ធសាស្ត្រជេដប្លុកជាតិ ៧- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs localization) សម្រាប់វិស័យបរិស្ថាននិងការអភិវឌ្ឍដោយចីរភាព ៨- ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាព២០១៨-២០២៣ ៩- ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៦-២០៣០ ១០- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព២០២០-២០៣០ សម្រាប់ក្រុងគោលដៅ៧ រួមមានក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម សួង និងក្រុងបាវិត ១១- គោលការណ៍ណែនាំស្តីពីការិយាល័យបៃតងនិងព្រឹត្តិការណ៍បៃតង ១២- ឯកសារក្រមសីលធម៌សិក្សាស្រាវជ្រាវនិងរបៀបវារៈស្រាវជ្រាវ ១៣- របាយការណ៍ជាតិលើកទី៦ សម្រាប់អនុសញ្ញាសហប្រជាជាតិ ស្តីពីជីវៈចម្រុះសម្រាប់ការផ្សព្វផ្សាយ ១៤- គោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិរបស់ស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង(NDA) ១៥- របាការណ៍កម្មវិធីប្រទេសសម្រាប់មូលនិធិអាកាសធាតុបៃតង ១៦- របាយការណ៍ការវាយតម្លៃលទ្ធភាពក្រសួងបរិស្ថានក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់ និង១៧- ប្រព័ន្ធតាមដានការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (NDC Tracking system)

- **បញ្ចប់ការសិក្សាស្រាវជ្រាវសម្រាប់ការរៀបចំគោលនយោបាយនិងផ្សព្វផ្សាយជាផ្លូវការនូវ៖** ១- របាយការណ៍ស្តីពីការកាត់បន្ថយហានិភ័យការវិនិយោគ ក្នុងថាមពលកកើតឡើងវិញនៅកម្ពុជា ២- របាយការណ៍ស្តីពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាននៃការជំរុញវិស័យឧស្សាហកម្មបៃតងនៅកម្ពុជា ៣- ការវាយតម្លៃពីសក្តានុពលនៃការអភិវឌ្ឍបៃតងករណីសិក្សានៅប្រទេសកម្ពុជា ៤- ការវាយតម្លៃសេដ្ឋកិច្ចលើសក្តានុពលថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា ៥- សិក្សាវាយតម្លៃពីលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាទាញយកសារធាតុឆេះពីសំណល់រឹង និងការប្រើប្រាស់សំណល់ពីវិស័យឧស្សាហកម្មកាត់ដេរទៅជាប្រភពឥន្ធនៈសម្រាប់ឧស្សាហកម្មស៊ីម៉ងត៍ ៦- ឯកសារសិក្សាស្រាវជ្រាវលើកទី៣ ស្តីអំពីការស្វែងយល់ទស្សនៈសាធារណជន ចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា ចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAP3) ៧- របាយការណ៍ស្តីពីការចូលរួមរបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និង៨- របាយការណ៍ស្តីពីការសិក្សាលើប្រសិទ្ធភាពទោចក្រយានយន្តអគ្គិសនី

- ដំឡើងស្ថានីយផលិតថាមពលដើរដោយពន្លឺព្រះអាទិត្យ៣២គីឡូវ៉ាត់ ជាមួយប្រព័ន្ធផ្ទុកថាមពល (អាគុយ) ៨៧គីឡូវ៉ាត់ម៉ោង នៅលើ២ទីតាំងគឺមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូល **សុខ អាន** ភ្នំគូលែន ខេត្តសៀមរាប និងសហគមន៍ស្រែអំពិល ឃុំក្តុល ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង

- បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល **សុខ អាន** ភ្នំគូលែន និងបានប្រមូល និងចងក្រងព័ត៌មានស្តីពីកេសរកូលព្រៃចំនួន១៩អំបូរ ដែលមានចំនួន៤៤ប្រភេទ ក្នុងនោះ ១៩ប្រភេទ បានមកពីតំបន់ភ្នំគូលែន ២៥ប្រភេទពីបរិវេណឧទ្យានជាតិព្រះមុនីវង្សបូកគោ ក្នុងតំបន់ទឹកធ្លាក់វាលស្រែ៥០០ទំនប់ទឹក និងខេត្តព្រះវិហារ ប្រមូលកេសរកូលព្រៃចំនួន៣៨ប្រភេទ បណ្តុំជាតិ៥ប្រភេទ បំពង់ក្រឡោម១ប្រភេទ និងរុក្ខជាតិលម្អ






**ពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៨ - ២០១៩ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៩ - ២០២០ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩**

ផ្សេងៗទៀតជាច្រើន ព្រមទាំងបានរៀបចំសំណាកសត្វប្រឡាំងកាសនិងកាចរ ដែលជាប្រភេទសត្វកម្រ ពីខេត្តមណ្ឌលគិរី កោះកុង និងព្រះវិហារ

- បោះពុម្ពផ្ទាំងរូបភាពធំបង្ហាញអំពីប្រភេទនិងលក្ខណៈសំខាន់ៗរបស់រុក្ខជាតិ និងសត្វរាតត្បាតនៅកម្ពុជាចំនួន៥ផ្ទាំង សៀវភៅស្តីពីយុទ្ធសាស្រ្តនិងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ(NBSAP)ចំនួន៥០០ក្បាល ឯកសាររបាយការណ៍ជាតិលើកទី៦ ចំនួន២៥០ក្បាល ឯកសារផ្ទាំងផ្ទត់អប់រំស្តីពីយេនឌ័រនិងការអភិរក្សជីវៈចម្រុះចំនួន១៥០ផ្ទាំង ខិតបណ្ណព័ត៌មាន ស្តីពីកេសរកូល៨ប្រភេទ ចំនួន១០០សន្លឹក សៀវភៅណែនាំរុក្ខជាតិមានតម្លៃផ្នែកសេដ្ឋកិច្ចក្នុងឧទ្យានជាតិភ្នំគូលែនចំនួន១០០ក្បាល សៀវភៅបច្ចេកទេសនិងថែរក្សាទុកក្លៀងនៃប្រទាលថ្លើមផ្ទៃ ឬខ្លាយខ្មៅ ចំនួន៣០០ក្បាល សៀវភៅរបាយការណ៍ជាតិលើកទី៦ សម្រាប់អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ជាភាសាខ្មែរចំនួន៥០ក្បាល។

## ២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនៅតាមរាជធានី ខេត្ត

### ២.១- រាជធានីភ្នំពេញ

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗដែលរដ្ឋបាលរាជធានីភ្នំពេញ សម្រេចបាន៖**

រាជធានីភ្នំពេញ គឺជារាជធានីមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ដែលមានព្រំប្រទល់ខាងលិចទល់នឹងស្រុកអង្គស្នួល ខាងកើតទល់នឹងស្រុកកៀនស្វាយ ស្រុកល្វាឯម ខាងជើងទល់នឹងមុខស្រុកមុខកំពូល ស្រុកពញាឮ ខាងត្បូងទល់នឹងស្រុកកណ្តាលស្ទឹង ក្រុងតាខ្មៅ ខេត្តកណ្តាល។

រាជធានីភ្នំពេញ មានផ្ទៃដីសរុប៦៩ ២៤៦គ.ម.$^{២}$ មានខណ្ឌ១៤ សង្កាត់១០៥ ភូមិ៩៥៣ ចំនួនគ្រួសារ ៤៩៩ ២៩៩ ចំនួនប្រជាពលរដ្ឋសរុប២ ២៨១ ៩៥១នាក់(ស្រី១ ១៧៦ ១៧៨នាក់)។

**ក- ការងារសាធារណការ**

| | | | |
|---|---|---|---|
| ២០១៧ | **ជួលជុល និងស្ថាបនាផ្លូវបេតុងឆ្អឹងដែកកម្រាស់១៥សម-២០សម** | **៣៤ខ្សែ** | **៦៦១ ៨០៦ម.$^{២}$** |
| | ជួសជុលផ្លូវចាក់អ៊ិតកៅស៊ូ AC | ៥៦ខ្សែ | ៦១២ ៤៨៧ម.$^{២}$ |
| | ជួសជុលផ្លូវចាក់ក្រាលថ្មម៉ិក | ១ខ្សែ | ១៧ ៥០០ម.$^{២}$ |
| | ដាក់លូមូលទំហំ០.៦ម. ទៅ ១.៥ម. | ៤៣៩២២ម. | - |
| | ស្តារប្រឡាយ | ៣៥ ១៦៣ម. | - |
| | តម្លើងខឿនបេតុងបែងចែកចរាចរណ៍ប្រភេទថ្មី | ១៦ ៦៧២ម. | - |
| | ស្ថាបនាជញ្ជាំងបេតុងប្រឡាយ | ២ ៧៦២ម. | - |
| | ពង្រីកបណ្តាញចែកចាយទឹក | ១៨៥គ.ម. | - |
| | ស្ថាបនាតម្លើងបង្គោលភ្លើងស្តុបថ្មី និងចាស់ | ៦៣កន្លែង | |
| | សាងសង់អគាររដ្ឋបាលផ្សេងៗ | ១៥អគារ | |
| | សាងសង់ផ្ទះសហគមន៍ភូមិអណ្តូងនិងហេដ្ឋារចនាសម្ព័ន្ធ | ១៦០ខ្នង | |
| | ពង្រីកផ្លូវ និងកែលម្អប្រព័ន្ធចរាចរណ៍ចំណុចភ្លើងស្តុប | ១កន្លែង | |
| | តម្លើងស្លាកសញ្ញាឈ្មោះផ្លូវនិងស្លាកសញ្ញាចរាចរណ៍ថ្មី | ៨ ០០០ស្លាក | |
| | ជួសជុលកែលម្អសួនច្បារនានា | ១៣កន្លែង | |
| | តម្លើងបង្គោលភ្លើងព្រែកនិងទោល តាមដងផ្លូវនានា | ១០ ៤៨ដើម | |
| | តម្លើងទូបញ្ជាភ្លើងថ្មី | ៤៤៧ឈុត | |
| | សាងសង់ស្ថានីយបូមទឹក | ២កន្លែង | |

| | | | | |
|---|---|---|---|---|
| | ស្ថាបនាស្ពានបេតុង | | | ២កន្លែង |
| | ផលិតទឹកបាន | | | ១៩៤ ៦០១ ៣០៦ម.$^{៣}$ |
| | ការតបណ្តាញចូលផ្ទះ | | | ២០ ៤៨៤បណ្តាញ |
| | ការតបណ្តាញទឹកជូនប្រជាពលរដ្ឋដែលមានចំណូលទាប | | | ៨២៣បណ្តាញ |
| | **ការងារសាធារណការ** | | | |
| | លុបសំបុកមាន់តាមផ្លូវ(អ៊ុតបេទីម) | | ៥ខ្សែ | ៧១៣ម.$^{២}$ |
| | អ៊ុតគំនូសចរាចរណ៍ | | | ៣ ១៧២,២៨ម.$^{២}$ |
| | ស្តារលូ | | ៧៥ខ្សែ | ៥៨ ៦៧១ម. |
| | ស្តារអណ្តូងលូ | | | ៧ ៩៥០អណ្តូង |
| | ស្តារប្រឡាយ | | ៥ខ្សែ | ៦ ៣៧០ម. |
| | ស្តារអាងស្តុកស្ពានីយបឹងទំពុន | | ១កន្លែង | ៣២០ម.$^{៣}$ |
| | លាងសម្អាតផ្លូវ និងលាបកំបោរស និងស្លេត្រូ | | | ៤០ ៩០០ម |
| | ដាក់លូថ្មីគ្រប់ប្រភេទ | | | ២ ៧០២ម. |
| | រៀបអណ្តូលូថ្មីគ្រប់ប្រភេទ | | | ២០២អណ្តូង |
| | បូមទឹកបញ្ចេញក្រៅក្រុង | | ២៥ ២៨២ម៉ោង | ២១៤១២៧៣០០ម.$^{២}$ |
| | កាត់តម្រឹមស្មៅតាមសួនសាធារណៈ | | | ១៥៣៤៣០៦២ម.$^{២}$ |
| | កាត់សម្អាតផ្កាតាមសួនសាធារណៈ | | | ២៥០ ១២៥ម.$^{២}$ |
| | តម្លើងភ្លើងស្តុបចរាចរណ៍ថ្មី | | ១៥ទីតាំង | |
| | ជួសជុលប្តូរអំពូល LED ភ្លើងស្តុបចរាចរណ៍ | | | ១ ៩៧០អំពូល |
| | **ការងារធនធានទឹក** | | | |
| ២០១៨ | សាងសង់លូភ្លោះរំដោះទឹកទំហំមុខកាត់១ម ពីរជួរ | | ១កន្លែង | ៨ម. |
| | ស្តារប្រឡាយ | | | ១៩ ២២៩ម. |
| | សាងសង់លូប្រអប់ទំហំមុខកាត់២ម ៣ជួរ បណ្តោយ៦ម | | ៤កន្លែង | |
| | ជួសជុលទំនប់កៅស៊ូ | | | ៩ ៩៤២ម. |
| | ជួសជុលទំនប់គ្រួសក្រហម | | | ២ ៣៨៨ម. |
| | **ការងារអភិវឌ្ឍន៍ជនបទ** | | | |
| | ថែទាំសុពលភាពផ្លូវជាលក្ខណៈខួប | | ៣ខ្សែ | ៣០ ៤៦០ម. |
| | ថែទាំផ្លូវជាលក្ខណៈប្រចាំ | | ១០ខ្សែ | ៣៨ ៩០០ម. |
| | ជួសជុលផ្លូវក្រាលថ្មមិច | | ១ខ្សែ | ១ ៥២០ម. |
| | ជួសជុលផ្លូវក្រាលគ្រួសក្រហម | | ១ខ្សែ | ១ ៥២៣ម. |
| | សាងសង់អណ្តូងស្នប់ប្រភេទ Afridev | | ៣អណ្តូង | |
| | ស្តារស្រះសហគមន៍ ទំហំ (៥០ម x ២០ម x ៤ម) | | ១កន្លែង | |
| | **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី** | | | |
| | ការងាររដ្ឋបាលដែនដី | ចុះបញ្ជីលក្ខណៈជាប្រព័ន្ធ | ១២ ៦២៤បណ្ណ | ១៣ ៣៧១បណ្ណ |
| | | ចុះបញ្ជីលក្ខណៈដាច់ដោយដុំ | ៧៤៧បណ្ណ | |
| | ការងារចុះបញ្ជីដីបន្ត | ចុះបញ្ចុះបញ្ជីផ្ទេរសិទ្ធិ | ១៩ ៨៧៩បណ្ណ | ៣៨ ២៦៣បណ្ណ |
| | | ចុះបញ្ជីប្រាតិភោគ | ១៨ ៣៨៤បណ្ណ | |
| | ការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យសំណង់ | | ១ ០២៥គម្រោង | ៥ ១១២ ០០៧ម.$^{២}$ |

| | | | | |
|---|---|---|---|---|
| | **ការងារទេសចរណ៍** | | | |
| | ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលទស្សនា តាមទីតាំងសំខាន់ៗ រួមមាន | ទេសចជាតិ | ២៦៥៦៨៦៩នាក់ | ៥ ៨០១ ៧៤៤នាក់ |
| | | ទេសចអន្តរជាតិ | ៣១៤៤៨៥៧នាក់ | |
| | **ការងាររដ្ឋាករទឹក** | | | |
| | ផលិតទឹកស្អាតបាន | | | ២០៦ ៦១៧ ៤៧៧ម.$^{៣}$ |
| | ជួសជុលបណ្តាញទឹកធ្លុះធ្លាយ | | ១ ៤៤៦កន្លែង | |
| | ពង្រីកបណ្តាញចែកចាយបានប្រវែង | | | ២៥៧ ០០០ម. |
| | ផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជនមានចំណូលទាប | | ៣៥ ០០៦ បណ្តាញ | |
| | ផ្គត់ផ្គង់ទឹកស្អាតជូនកម្មករ និយោជិក សិស្ស និស្សិតស្នាក់នៅផ្ទះជួល | | ១២២ ២៩១ បន្ទប់ | |
| | **ការងាររដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ រថយន្តក្រុង** | | | |
| | អ្នកជិះរថយន្តក្រុង | អ្នកបង់ប្រាក់ | ២៨៨៣០៧១នាក់ | ៧ ២៧៩ ២៥៥នាក់ |
| | | អ្នកឥតបង់ប្រាក់ | ៤៣៩៦ ១៨៤នាក់ | |
| | ចំនួនអ្នកជិះកាណូត សរុបចំនួន | | ៥៧ ៨៣៥នាក់ | |
| | រដ្ឋាករបានដាក់ឱ្យដំណើរការខ្សែរត់ | | ១៣ខ្សែ | ២៣៥គ្រឿង |
| ២០១៩ | **ការងារសាធារណការ** | | | |
| | តម្លើងស្លាកសញ្ញាបង្គោលមួយនិងបង្គោលមួយស្លាកពីរ | | ៧៤០បង្គោល | |
| | តម្លើងស្លាកសញ្ញាក្បាលបេតុងទ្រូងផ្លូវ | | ៩០គោម | |
| | ដាក់ស្លាកសញ្ញាចរាចរណ៍ | | ២៣ស្លាក | |
| | អ៊ុតគំនូសចរាចរ | | | ៦ ៣២៣,៥១ម.$^{២}$ |
| | លុបសំបុកមាន់ | | | ៣៦៥ម.$^{២}$ |
| | ស្តារលូគ្រប់ប្រភេទ ចំនួន៥៨ផ្លូវ (សំរាមនិងភក់) | | ២៥ ១៦៩ម. | ៣ ១០៦,៨០ម.$^{៣}$ |
| | ស្តារអណ្តូងលូគ្រប់ប្រភេទ១០៤ផ្លូវ (សំរាមនិងភក់) | | ២ ១២៤អណ្តូង | ១ ៣៦៤,២០ម.$^{៣}$ |
| | ស្តារប្រឡាយ(សំរាមនិងភក់) | | ៣ ៣៧៤ម. | ១៨៥ ៦២៥ម.$^{៣}$ |
| | ស្តារក្រោមដី(សំរាមនិងភក់) | | | ១ ៥៣៩ម.$^{៣}$ |
| | ដាក់លូនិងរៀបអណ្តូងលូថ្មីគ្រប់ប្រភេទ | លូថ្មីគ្រប់ប្រភេទ | ១ ២៥២ម. | |
| | | អណ្តូងលូថ្មីគ្រប់ប្រភេទ | ៣៣អណ្តូង | |
| | បារសំរាមតាមស្ថានីយបូមទឹក | | ៥ស្ថានីយ | ៧៤៨ម.$^{៣}$ |
| | បូមទឹកបញ្ចេញក្រៅក្រុង | | ២១ ១៨៥ម៉ោង | ១៧២ ៦១៤ ០៤៥ម.$^{៣}$ |
| | ថែទាំសួនច្បារ | កាត់ស្មៅតាមសួនច្បារសាធារណៈ | | ១២ ៤៨៧ ៣១០ម.$^{២}$ |
| | | កាត់សម្អាតផ្កាតាម សួនច្បារសាធារណៈ | | ២៧៦ ១៤៨ម.$^{២}$ |
| | | រថយន្តស៊ីទែនដឹកទឹកលាយជីស្រោចសួនច្បារ | ៩៧២ឡាន | |
| | តម្លើងភ្លើងស្តុបចរាចរណ៍ថ្មី | | ៤ទីតាំង | |
| | ជួសជុលទូរបញ្ជាភ្លើងស្តុបចរាចរណ៍ | | ១៩៩លើក | |
| | ប្តូរអំពូល LED ភ្លើងស្តុបចរាចរណ៍ | | ១ ១៣៥អំពូល | |
| | ជួលជុលគោមភ្លើងស្តុបចរាចរណ៍ | | ៣០៣គ្រឿង | |
| | ជួសជុលនាឡិកាភ្លើងស្តុបចរាចរណ៍ | | ២១គ្រឿង | |
| | ភ្លើងស្តុបចរាចរណ៍ | | ៣បង្គោល | |

| | | | | |
|---|---|---|---|---|
| | **ការងារធនធានទឹក** | | | |
| | លើកទំនប់កាត់ទទឹងព្រែកតាអេវ | | ៣៥ម. | |
| | បោះបង្គោលបេតុងការពារព្រំដី អាងស្តុកទឹក | | ២៤ដើម | |
| | ស្តារប្រឡាយមេស្រោចស្រព ស្ថិតក្នុងសង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ | | ៥ ៥៧០ម. | |
| | សាងសង់លូប្រអប់ទំហំ ២មx២ម ២ជួរ | | ១កន្លែង | |
| | ជួសជុលផ្លូវកៅស៊ូ ស្ថិតក្នុងខណ្ឌដង្កោ | | ៩ ៩៤២ម. | |
| | ជួសជុលខ្នងទំនប់ ប្រព័ន្ធធារាសាស្ត្រប្រទះឡាង | | ២ ៣៨៨ម. | |
| | **ការងារអភិវឌ្ឍន៍ជនបទ** | | | |
| | ថែទាំសុពលភាពផ្លូវជាលក្ខណៈខួប | | ៤ខ្សែ | ១៤ ៨៦០ម. |
| | អនុវត្តគម្រោងថែទាំផ្លូវជាលក្ខណៈប្រចាំ | | ២៩ខ្សែ | ៨២ ១៧០ម. |
| | បានអនុវត្តការងារជួសជុលផ្លូវបន្ទាន់ដោយក្រាលថ្មម៉ិច១ខ្សែ | | ១ខ្សែ | ១ ១០០ម. |
| | បានអនុវត្តការងារសាងសង់អណ្តូងស្នប់ប្រភេទ Afridev | | ៥អណ្តូង | |
| | បានអនុវត្តការងារជីកស្តារស្រះទឹក ទំហំ (៥០ម. x ៣០ម. x ៤ម.) | | ១កន្លែង | |
| | **ការងាររដ្ឋាករទឹក** | | | |
| | ផលិតទឹកស្អាត | | | ២១៥ ៧១២ ៩៣៩ម.$^{៣}$ |
| | ជួសជុលបណ្តាញទឹកធ្លុះធ្លាយ | | ១ ៩០៣កន្លែង | |
| | តបណ្តាញចូលផ្ទះ | | | ២៦ ១២២បណ្តាញ |
| | បណ្តាញទឹកស្អាត តជូនប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលទាប | | ១ ៣៦៥គ្រួសារ | |
| | ផ្គត់ផ្គង់ទឹកស្អាតជូនបងប្អូនកម្មករ និយោជិត សិស្ស និស្សិតស្នាក់នៅតាមផ្ទះជួល និងបន្ទប់ជួល | | ៩៤ ៦៨៥បន្ទប់ | |
| | អនុវត្តការងារដាក់បំពង់មេ | | | ២៤២ ៥៦១,៩៩ម. |
| | **ការងារទេសចរណ៍** | | | |
| | ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលទស្សនា តាមទីតាំងសំខាន់ៗ រួមមាន | ទេសចជាតិ | ២៣៥៤២៤០នាក់ | ៥ ៩៦៤ ៥០២នាក់ |
| | | ទេសចអន្តរជាតិ | ៣៦១០២៦២នាក់ | |
| | **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី** | | | |
| | ការងាររដ្ឋបាលដែនដី | ចុះបញ្ជីលក្ខណៈជាប្រព័ន្ធ | ៣៥ ៧៥៨បណ្ណ | ៣៦ ២៩៦បណ្ណ |
| | | ចុះបញ្ជីលក្ខណៈដាច់ដោយដុំ | ៥៣៨បណ្ណ | |
| | ការងារចុះបញ្ជីដីបន្ត | ចុះបញ្ជីផ្ទេរសិទ្ធិ | ១៨ ១៨៧បណ្ណ | ៣៣ ៧៥៥បណ្ណ |
| | | ចុះបញ្ជីប្រាតិភោគ | ១៥ ៥៦៨បណ្ណ | |
| | ការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យសំណង់ | | ១ ០៣០គម្រោង | ៦ ៦១០ ០១៥ម.$^{២}$ |
| | **ការងាររដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ រថយន្តក្រុង** | | | |
| | អ្នកជិះរថយន្តក្រុង | អ្នកបង់ប្រាក់ | ២៦៩១ ១១៩នាក់ | ៨ ៧៦៧ ៨៣៥នាក់ |
| | | អ្នកឥតបង់ប្រាក់ | ៦០៧៦ ៧១៦នាក់ | |
| | អ្នកជិះកាណូត | អ្នកបង់ប្រាក់ | ៥ ០០៧នាក់ | ១២ ១៨៦នាក់ |
| | | អ្នកឥតបង់ប្រាក់ | ៧ ១៧៩នាក់ | |
| | រដ្ឋាករបានដាក់ឱ្យដំណើរការខ្សែរត់ | | ១៣ខ្សែ | ២៣៥គ្រឿង |
| ២០២០ | **ការងារសាធារណការ** | | | |
| | ផលិតខ្ទោះអណ្តូងលូទឹកភ្លៀង + ខ្ទោះលើអណ្តូងលូ | | ១៣២ | |
| | ផលិតខ្ទោះបាតអណ្តូងលូ + ជើងបន្ទះអណ្តូងលូ | | ១៩៥ | |
| | ផលិតគំរបលូគ្រប់ប្រភេទ | | ៤៥៨ | |

| | | | | |
|---|---|---|---|---|
| | ដាក់បំពង់លូថ្មីគ្រប់ប្រភេទ | | ២ ២៣២កង់ | |
| | រៀបអណ្តូងលូថ្មីគ្រប់ប្រភេទ | | ១៧៣អណ្តូង | |
| | ស្តារ និងថែទាំប្រឡាយដោយគ្រឿងចក្រ(សំរាម) | | | ៦ ០០០ម.$^{៣}$ |
| | ស្តារដីក្នុងបំពង់លូដោយ  រថយន្តបូម | | | ១២៤ ៦៥០ម. |
| | ស្តារ និងថែទាំអណ្តូងលូដោយគ្រឿងចក្រ | | ៤ ៤២៥អណ្តូង | |
| | បូមទឹកបញ្ចេញក្រៅក្រុង | | | ២២៤ ៣៤១ ៩៨២ម.$^{៣}$ |
| | តម្លើងភ្លើងស្តុបចរាចរណ៍នៅទីតាំងថ្មី | | ៥កន្លែង | |
| | ជួសជុលប្តូរអំពូល LED ភ្លើងស្តុបចរាចរណ៍ | | ១ ៤៩០អំពូល | |
| | ជួសជុលគោមភ្លើងស្តុបចរាចរណ៍ | | ៤១៩គ្រឿង | |
| | ជួសជុលនាឡិកាភ្លើងស្តុបចរាចរណ៍ | | ២៥គ្រឿង | |
| | ដាំដើមឈើតាមដងវិថី និងលើសួនច្បារ | | ៧ដើម | |
| | កាត់តម្រឹមស្មៅតាមសួនច្បារ | | | ១០ ១៧២ ៣៥៨ម.$^{២}$ |
| | កាត់សម្អាតផ្កាតាមសួន | | | ២៧៥ ៤៤៦ម.$^{២}$ |
| | ដឹកទឹកស្រោចស្មៅ ស្រោចផ្កា ដោយរថយន្ត | | ៥០០ឡាន | |
| | **ការងារធនធានទឹក** | | | |
| | លើកទំនប់ដីគ្រួសក្រហមបន្ថែមកម្ពស់១ម (ទំនប់ប្រទះឡាង) | | ២ ៣៨៨ម. | |
| | ស្តារប្រឡាយ | | ១៦ ៩៩០ម. | |
| | **ការងារអភិវឌ្ឍន៍ជនបទ** | | | |
| | ប្រគល់ទទួលបញ្ចប់គម្រោងថែទាំសុពលភាពផ្លូវជាលក្ខណៈខួប | | ៣ខ្សែ | ១១ ៥០០ម. |
| | សាងសង់លូមុខពីរ ទំហំ 80cm x 8m | | ២កន្លែង | |
| | ជួសជុលផ្លូវក្រាលថ្មម៉ិច | | ១ខ្សែ | ១ ០០០ម. |
| | សាងសង់អណ្តូងស្នប់ | | ១២អណ្តូង | |
| | ជីកស្រះទឹក ទំហំ (៤០ម.x៣០ម.x៤ម.) | | ១កន្លែង | |
| | **ការងាររដ្ឋាករទឹក** | | | |
| | ផលិតទឹកស្អាតបានចំនួន | | | ២៣២ ៦៩១ ៦៤៣ម.$^{៣}$ |
| | ជួសជុលបណ្តាញទឹកធ្លុះធ្លាយបាន | | ២ ៣៩៧កន្លែង | |
| | តបណ្តាញចូលផ្ទះបាន | | ២១ ៥២១ បណ្តាញ | |
| | តបណ្តាញទឹកស្អាត ជូនប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលទាប | | ៩៤៤គ្រួសារ | |
| | ផ្គត់ផ្គង់ទឹកស្អាតជូនបងប្អូនកម្មករ និយោជិត សិស្ស និស្សិតស្នាក់នៅតាមផ្ទះជួល និងបន្ទប់ជួល | | ៤ ៧១២ផ្ទះ | ១០២ ៩៤១បន្ទប់ |
| | អនុវត្តការងារដាក់បំពង់មេបានប្រវែងសរុប | | | ២១១ ៦៤០ម. |
| | **ការងារទេសចរណ៍** | | | |
| | ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលទស្សនា តាមទីតាំងសំខាន់ៗ រួមមាន | ទេសចជាតិ | ១ ៨៣៥ ៤១៤នាក់ | ២ ៧៤០ ៦៦៨នាក់ |
| | | ទេសចអន្តរជាតិ | ៩០៥ ២៥៤នាក់ | |
| | **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី** | | | |
| | ការងាររដ្ឋបាលដែនដី | ចុះបញ្ជីលក្ខណៈជាប្រព័ន្ធ | ៣៨ ៥៤២បណ្ណ | ៣៨ ៨៧៥បណ្ណ |
| | | ចុះបញ្ជីលក្ខណៈដាច់ដោយដុំ | ៣៣៣បណ្ណ | |
| | ការងារចុះបញ្ជីដីបន្ត | ចុះបញ្ជីផ្ទេរសិទ្ធិ | ២៩ ១៨៥បណ្ណ | ៥២ ៧០៦បណ្ណ |
| | | ចុះបញ្ជីប្រាតិភោគ | ២៣ ៥២១បណ្ណ | |

| | | | | |
|---|---|---|---|---|
| | ការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យសំណង់ | | ១ ៣៥០គម្រោង | ៧ ៨៤៨ ៨៥៥ម.$^{២}$ |
| | **ការងាររដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ រថយន្តក្រុង** | | | |
| | អ្នកជិះរថយន្តក្រុង | អ្នកបង់ប្រាក់ | ៤៦៤ ៩៤១នាក់ | ១ ៧៤៩ ៣៧៩នាក់ |
| | | អ្នកឥតបង់ប្រាក់ | ១២៨៤៤៦៥នាក់ | |
| | អ្នកជិះកាណូត | អ្នកបង់ប្រាក់ | ១ ៩២៤នាក់ | ៤ ៦១០នាក់ |
| | | អ្នកឥតបង់ប្រាក់ | ២ ៦៨៦នាក់ | |
| | រដ្ឋាករបានដាក់ឱ្យដំណើរការខ្សែរត់ | | ១៣ខ្សែ | ១៨១គ្រឿង |
| ២០២១ | **ការងារសាធារណការ** | | | |
| | មហាវិថី វិថី និងផ្លូវថ្នល់ដែលបានស្ថាបនាថ្មី | | ៣៨ខ្សែ | ៥៨០គ.ម. |
| | ស្ពានបេតុងស្ថាបនាថ្មី | | ១៣កន្លែង | |
| | ស្ពានអាកាស និងផ្លូវក្រោមដី | | ៦កន្លែង | ៥,១៧២គ.ម. |
| | ស្ពានអាកាសថ្មើរជើង | | ៥កន្លែង | |
| | ស្ថានីយបូមទឹកស្ថាបនាមានចំនួន | | ១៤កន្លែង | |
| | ប្រឡាយជញ្ជាំងបេតុង | | ៨ខ្សែ | ៩០១,២គ.ម. |
| | សួនច្បារសាងសង់ថ្មី និងកែលម្អឡើងវិញ | | ១១៥កន្លែង | |
| | កាត់តម្រឹមស្មៅតាមសួនច្បារ | | | ៩ ៧១៩ ៧៧៧ម.$^{២}$ |
| | កាត់តម្រឹមផ្កាតាមសួនច្បារ | | | ៤ ១៦៩ ០៣២ម.$^{២}$ |
| | ដាំដើមឈើតាមដងវិថី និងលើសួនច្បារ | | ១៤៣ដើម | |
| | កាត់លះដើមឈើតាមដងវិថី និងលើសួនច្បារ | | ៣ ០៤៧ដើម | |
| | ដឹកទឹកស្រោចស្មៅផ្កាដោយរថយន្ត | | ១ ៩៩០ឡាន | |
| | តម្លើងភ្លើងបំភ្លឺផ្លូវ | | ១៥២ដើម | |
| | តម្លើងភ្លើងបំភ្លឺសួន | | ២៦ដើម | |
| | តម្លើងស្តុបចរាចរណ៍ | | ៤ទីតាំង | |
| | ជួសជុលទូបញ្ជាភ្លើងស្តុបចរាចរណ៍ | | ១១៤លើក | |
| | ជួសជុលខ្សែភ្លើងប៉ះភ្លើងស្តុបចរាចរណ៍ | | ១៧៨លើក | |
| | ប្តូរអំពូល LED ភ្លើងស្តុបចរាចរណ៍ | | ២ ០៩០គ្រាប់ | |
| | ជួសជុលគោមភ្លើងស្តុបចរាចរណ៍ | | ២១០គ្រឿង | |
| | ជួសជុលនាឡិកាភ្លើងស្តុបចរាចរណ៍ | | ៣១គ្រឿង | |
| | ជួសជុលបង្គោលភ្លើងស្តុបចរាចរណ៍ | | ២ដើម | |
| | កាប់មែកឈើបាំងភ្លើងស្តុបចរាចរណ៍ | | ៥៦ទីតាំង | |
| | ការងាររៀបអណ្តូងលូថ្មី | | ៦អណ្តូង | |
| | ការងារដាក់បំពង់លូថ្មី | | ១១៥ម. | |
| | ការងារជួសជុលអណ្តូងលូ | | ៧៨អណ្តូង | |
| | ការងារជួសជុលបំពង់លូ | | ៨៤ម. | |
| | ការងារជួសជុលគំរបលូ | | ១៧០គំរប | |
| | ដាក់ជុំអ៊ី | | ៤២ជុំ | |
| | ក្បាលខ្ទោះ | | ១៣ខ្ទោះ | |
| | ផលិតអណ្តូងទឹកភ្លៀង+ខ្ទោះលើអណ្តូងលូ | | ៨២ | |
| | ផលិតខ្ទោះបាតអណ្តូងលូ+ជើងបន្ទះអណ្តូងលូ | | ១៣៥ | |

| | | | | |
|---|---|---|---|---|
| | ផលិតគំរបលូ | | ៤៥០គំរប | |
| | ស្តារបំពង់ | | ៧ ៦៩០ម. | ៧៩០,៥០ម.$^{៣}$ |
| | ស្តារអណ្តូងលូ | | ៩៧២អណ្តូង | ២៨៩,១០ម.$^{៣}$ |
| | ស្តារប្រឡាយ | | ៧ ៥៥០ម. | |
| | ស្តារអាងស្តុកមាត់ទន្លេ | | ៤កន្លែង | ២ ១១៣ម.$^{៣}$ |
| | ស្តារលូបង្គន់អនាម័យតាមមណ្ឌលព្យាបាលអ្នកជំងឺកូវីដ | | ៩១បន្ទប់ | ៤១,៦០ម.$^{៣}$ |
| | ការងារលាបស្តេគ្រួស | | ៣ ៥១០ម. | |
| | ការងារលាបកំបោរស | | | ៨ ២៨០ម.$^{៣}$ |
| | ការងារបូមទឹកបញ្ចេញក្រៅក្រុង | | ២៥ ៨២៨ម៉ ៣០នាទី | ២២៣ ៩៤៩ ១៨០ម.$^{៣}$ |
| | កាមេរ៉ាសុវត្ថិភាពសាធារណៈដែលបំពាក់តាមដងផ្លូវក្នុងរាជធានី ភ្នំពេញ រហូតមកដល់ឆ្នាំ២០២១ | | ១ ១៨៦គ្រឿង | |
| | **ការងារធនធានទឹក** | | | |
| | ស្តារប្រឡាយរំដោះទឹក | | ១៦ ០៥៧ម. | |
| | សាងសង់ជញ្ជាំងបេតុងការពារទឹកជំនន់ | | ៥០០ម. | |
| | ស្តារប្រឡាយរងស្រោចស្រព | | ៧ ០៦៧ម. | |
| | ជួសជុលទំនប់បាក់ដោយទឹកជំនន់ | | ៣ ១២០ម. | |
| | សាងសង់លូមូល រំដោះទឹក ស្នាក់ទឹកមុខកាត់១,៥០ម. ១ជួរ=២១កង់ | | ២កន្លែង | |
| | ជួសជុលទំនប់កៅស៊ូ | | ៧ ៤៣៥ម. | |
| | ជួសជុលសំណង់ស្នាក់ទឹក | | ១០កន្លែង | |
| | **ការងារអភិវឌ្ឍន៍ជនបទ** | | | |
| | ជួសជុលផ្លូវក្រាលថ្មម៉ិច | | ១ខ្សែ | ១ ១០០ម. |
| | សាងសង់អណ្តូងស្នប់ | | ១០អណ្តូង | |
| | ស្តារស្រះទឹកសហគមន៍ ទំហំ (៤០ម.x៣០ម.x៤ម.) | | ១កន្លែង | |
| | **ការងារផ្គត់ផ្គង់ទឹក** | | | |
| | ផលិតទឹកស្អាតបានចំនួន | | | ២៣៤ ៦១៦ ១០៤ម.$^{៣}$ |
| | ជួសជុលបណ្តាញទឹកធ្លុះធ្លាយបាន | | ២ ៩៩៦កន្លែង | |
| | តបណ្តាញចូលផ្ទះបាន | | ២៥ ៩៤០ បណ្តាញ | |
| | តបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលទាប | | ៩៧៥គ្រួសារ | |
| | ផ្គត់ផ្គង់ទឹកស្អាតជូនបងប្អូនកម្មករ និយោជិត សិស្ស និស្សិតស្នាក់នៅតាមផ្ទះជួល និងបន្ទប់ជួល | | | ១ ៦៧៨បន្ទប់ |
| | អនុវត្តការងារដាក់បំពង់មេបានប្រវែងសរុប | | | ២៩២ ៨៥០ម. |
| | **ការងារទេសចរណ៍** | | | |
| | ភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិចូលទស្សនាតាមទីតាំងសំខាន់ៗ រួមមាន | ទេសចជាតិ | ៦៧៣ ៥៣០នាក់ | ៧៧៦ ៣៩១នាក់ |
| | | ទេសចអន្តរជាតិ | ១០២ ៨៦១នាក់ | |
| | **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី** | | | |
| | ការងាររដ្ឋបាលដែនដី | ចុះបញ្ជីលក្ខណៈជាប្រព័ន្ធ | ២៥ ៥៩៧បណ្ណ | ២៥ ៧១៨បណ្ណ |
| | | ចុះបញ្ជីលក្ខណៈដាច់ដោយដុំ | ១២២បណ្ណ | |

| | | | | |
|---|---|---|---|---|
| | ការងារចុះបញ្ជីដីបន្ត | ចុះបញ្ជីផ្ទេរសិទ្ធិ | ២៥ ២៧៩បណ្ណ | ៤៧ ៧៤០បណ្ណ |
| | | ចុះបញ្ជីប្រាតិភោគ | ២២ ៤៦១បណ្ណ | |
| | ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យសំណង់ | | ១ ០៦០គម្រោង | ៤ ៨៥២ ០៨២ម.[២] |
| | **ការងាររដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ រថយន្តក្រុង** | | | |
| | ការងារដឹកជញ្ជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ប្រជាពលរដ្ឋ កម្មករ កម្មការិនី និងភ្ញៀវជាតិ អន្តរជាតិ ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទៅមណ្ឌលចត្តាឡីស័ក និងពិនិត្យតាមដានជំងឺកូវីដ-១៩ | | ៧៦ ៤៨០នាក់ | |
| | ប្រើប្រាស់រថយន្តក្រុង | | ១២គ្រឿង | ៤ ៨៥៩ជើង |
| | អ្នកជិះរថយន្តក្រុង | អ្នកបង់ប្រាក់ | ១១ ៧៧៦នាក់ | ៣១ ៦៨៦នាក់ |
| | | អ្នកឥតបង់ប្រាក់ | ១៩ ៩១០នាក់ | |
| | អ្នកជិះកាណូត | អ្នកបង់ប្រាក់ | ២០៨នាក់ | ៥៣៩នាក់ |
| | | អ្នកឥតបង់ប្រាក់ | ៣៣១នាក់ | |
| | រដ្ឋាករបានដាក់ឱ្យដំណើរការខ្សែរត់ | | ៤ខ្សែ | ៦០គ្រឿង |
| | កាណូត | | | ២គ្រឿង |

## ការរៀបចំសួនច្បារក្នុងខណ្ឌទាំង១៤ គិតត្រឹមឆ្នាំ២០២១

| ឈ្មោះខណ្ឌ | ចំនួនសួន | ផ្ទៃក្រឡាសួនច្បារគិតជាម៉ែត្រការ៉េ | | | | | សរុបម៉ែត្រការ៉េ |
|---|---|---|---|---|---|---|---|
| | | ស្មៅ | ផ្កា | ការ៉ូឡាផ្ទៃចាក់សាប ថ្មក្រានីត | គ្រួសក្រហម ថ្មភ្នំ ថ្មបាយក្រៀម | សំណង់ផ្សេងៗ | |
| ដូនពេញ | ៤៩ | ១៦២ ៧០៧ | ១៤ ៨៦៧ | ១៥៥ ៥០២ | ៣៥ ២០៨ | ៨ ១៤០ | ៣៧៦ ៤២៤ |
| ចំការមន | ១៣ | ៥៣ ៤៨៩ | ៣ ២៣៦ | ៣៤ ៩២៥ | ៥១២ | ១ ៩៩២ | ៩៤ ១៥៤ |
| ៧មករា | ៨ | ២៤ ៤៩០ | ៤ ៥៣២ | ៦ ០២៧ | ០ | ៦៤ | ៣៥ ១១៣ |
| ទួលគោក | ៩ | ១១ ២៩៩ | ៥៧៥ | ១៥ ៩៣៤ | ០ | ០ | ២៧ ៨០៨ |
| មានជ័យ | ២ | ៩ ៧១៨ | ០ | ២ ២៧៥ | ០ | ០ | ១១ ៩៩៣ |
| ឫស្សីកែវ | ២ | ១១ ២១០ | ០ | ២០ ១៣៥ | ០ | ០ | ៣១ ៣៤៥ |
| ច្បារអំពៅ | ៣ | ៨ ៨២៣ | ២៥ | ៦៧០ | ០ | ០ | ៩ ៥១៨ |
| ពោធិ៍សែនជ័យ | ៨ | ៥១ ៧២៦ | ២ ៣១២ | ២៨ ០១៧ | ០ | ០ | ៨២ ០៥៥ |
| ដង្កោ | ២ | ១២ ២៥២ | ៥២៨ | ៤៥៨ | ០ | ០ | ១៣ ២៣៨ |
| សែនសុខ | ៥ | ៣៨ ៦៩៥ | ៥០០ | ៤ ៤៨៦ | ០ | ០ | ៤៣ ៦៨១ |
| ជ្រោយចង្វា | ១១ | ១៣០ ១៩១ | ៧ ២៦៥ | ២៥ ០៣៥ | ០ | ៩៧៨ | ១៦៣ ៤៦៩ |
| ព្រែកព្នៅ | ២ | ៨០ ៦១៦ | ០ | ០ | ០ | ០ | ៨០ ៦១៦ |
| បឹងកេងកង | ១ | ៣ ៣៦៥ | ៩០ | ១ ០៩២ | ០ | ០ | ៤ ៥៤៧ |
| កំបូល | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **សរុប** | **១១៥** | **៥៩៨ ៥៨១** | **៣៣ ៩៣០** | **២៩៤ ៥៥៦** | **៣៥ ៧២០** | **១១ ១៧៤** | **៩៧៣ ៩៦១** |

## ស្ពានអាកាស និងស្ពានថ្មើរជើងដែលបានស្ថាបនារួច និងដាក់ឱ្យដំណើរការនៅរាជធានីភ្នំពេញ

| ល.រ. | បរិយាយ | បណ្ដោយ | ទទឹង | កាលបរិច្ឆេទ |
|---|---|---|---|---|
| ១ | ស្ពានអាកាសក្បាលថ្នល់ រាជធានីភ្នំពេញ | ៣០៨ម. | ១៤,២០ម. | ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ |

| | | |
|---|---|---|
| ២ | ស្ពានអាកាស៧មករា(ស្តុបពេទ្យលោកសង្ឃ) នៅចំទីតាំងប្រសព្វផ្លូវលេខ២៧១ ផ្លូវលេខ៥៩៨ និងវិថីផ្លូវកម្ពុជាក្រោមប្រវែង៣៤៥ម. ទទឹង១៥,២០ម.(នៅចំពីលើចំណុចប្រសព្វ មានបែកជាចម្លាមមានបណ្តោយប្រវែង១៦០ម. ទទឹង៦,៥០ម. ជាផ្លូវឯកទិសចុះស្ពាន) រាជធានីភ្នំពេញ | ថ្ងៃទី៦ ខែមករា ឆ្នាំ២០១២ |
| ៣ | ស្ពានអាកាសស្ទឹងមានជ័យ រាជធានីភ្នំពេញ<br>- ស្ពានអាកាសធំពីបេតុងអាម៉េស្របពីលើផ្លូវលេខ២៧១ ត្រង់ចំណុចភ្លើងស្តុបមាន ទទឹងប្រវែង១៤,៨០ម. សម្រាប់ចរាចរណ៍ទ្វេទិស ដោយមានពីរខ្សែទៅ និងពីរខ្សែមក<br>- ស្ពានអាកាសតូចពីឯកទិសពីបេតុងអាម៉េមានទទឹងប្រវែង៦,៥០ម. និងសាងសង់ ស្ពានបេតុងមួយទៀត ជំនួសស្ពានបាឡេ ដែលមានទទឹងប្រវែង៨ម.<br>- កម្ពស់សុវត្ថិភាពក្រោមស្ពានមានប្រវែង៥,២០ម.។ | ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ |
| ៤ | ស្ពានអាកាសស្តុកទួលគោក ឬស្តុបតិចណូ សាងសង់ផ្លូវ២ខ្សែ រួមមានៈ<br>-ខ្សែ១ ហោះឡើងលើស្របបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី មានប្រវែង៣៨២ម. ទទឹង១៥,៨ម. កម្ពស់៥,២ម.<br>- ខ្សែ២ តភ្ជាប់ពីមហាវិថី គីម អ៊ីលស៊ុង ទៅមហាវិថី ម៉ៅ សេទុង មុជក្រោម មហាវិថីសហព័ន្ធរុស្ស៊ីមានប្រវែង៣៥៦ម. ទទឹង៦,៨ម.។ | ថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ |
| ៥ | ស្ពានអាកាសផ្សារដើមហុយ ឬស្ពានអាកាស៥មករា ស្ថិតនៅប្រសព្វរវាងមហាវិថី សហព័ន្ធរុស្ស៊ី និងផ្លូវហាណូយ(១០១៩) មានប្រវែង៩០៥ម. ទទឹង១៦,៥០ម. រាជធានីភ្នំពេញ | ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ |
| ៦ | ស្ពានអាកាសចោមចៅ និងផ្លូវក្រោមដី សាងសង់ផ្លូវ៣ខ្សែ រួមមានៈ<br>- ខ្សែ១ ជាស្ពានអាកាសមេ ពីមហាវិថីសហព័ន្ធរុស្ស៊ី មកផ្លូវជាតិលេខ៣ មាន ប្រវែង៤០៨ម. ទទឹង១៥,៨០ម. ជម្រាលស្ពាន៤,៥ម. កម្ពស់អតិបរិមាដែលអាច ចរាចរក្រោមស្ពានបាន៥,៥០ម. សម្រាប់ចរាចរពីរគន្លងទៅ និងពីរគន្លងមក<br>- ខ្សែ២ ជាស្ពានបំបែកចេញពីស្ពានអាកាសមេ បត់ឆ្វេងតភ្ជាប់ចរាចរពីមហាវិថី សហព័ន្ធរុស្ស៊ី ឆ្ពោះទៅផ្លូវវេងស្រេង មានប្រវែង២០២ម.(ស្ពានអាកាស ប្រវែង ៤០ម. ផ្លូវក្រោមដីប្រវែង១១៨ម. ផ្លូវលើដីប្រវែង៤៤ម.) ទទឹង៥,២៥ម. សម្រាប់ ចរាចរឯកទិស ដែលមានមួយគន្លងរថយន្ត និងមួយគន្លងទោចក្រយានយន្ត ។<br>- ខ្សែ៣ ជាស្ពានកោងបត់ឆ្វេងតភ្ជាប់ពីផ្លូវវេងស្រេង មកផ្លូវជាតិលេខ៣ មានប្រវែង ២០៦ម. (ស្ពានអាកាសប្រវែង៦០ម. ផ្លូវក្រោមដីប្រវែង១១៨ម. ផ្លូវលើដីប្រវែង ២៨ម.) ទទឹង៥,២៥ម. សម្រាប់ចរាចរឯកទិស ដែលមានមួយគន្លងរថយន្ត និង មួយគន្លងទោចក្រយានយន្ត<br>- ផ្លូវក្រោមដី ជាផ្លូវតភ្ជាប់ចរាចរពីផ្លូវជាតិលេខ៤ មកមហាវិថីសហព័ន្ធរុស្ស៊ី ដែល មានប្រវែងសរុប៤៧០ម. ទទឹង៨,៥ម. សម្រាប់ចរាចរមួយទិស ដែលមានពីរគន្លង រថយន្ត និងមួយគន្លងទោចក្រយានយន្ត។ | កំពុងស្ថាបនា |
| ៧ | ស្ពានអាកាសថ្មើរជើង មានចំនួន៥កន្លែង ប្រវែងសរុប២៦៧,៥០ម.<br>- ស្ពានអាកាសថ្មើរជើងផ្លូវជាតិលេខ៤ មានចំនួន២កន្លែង មានប្រវែងសរុប៤៨ម.<br>- ស្ពានអាកាសថ្មើរជើងនាងគង្ហីង ចំនួន១កន្លែង មានប្រវែងសរុប១៩២,៥០ម. ទទឹង ៣ម. កម្ពស់៥,៥ម.<br>- ស្ពានអាកាសថ្មើរជើងផ្សារដើមគរ ចំនួន១កន្លែង មានប្រវែងសរុប២៧ម. ទទឹង ៣,៤០ម. ទទឹងផ្លូវដើរផ្នែកខាងក្នុង២,៨០ម. កម្ពស់៥,៥០ម.<br>- ស្ពានអាកាសថ្មើរជើងសន្ធរមុខចំនួន១កន្លែង។ | |

## ស្ថិតិសំណង់អគារខ្ពស់ៗក្នុងរាជធានីភ្នំពេញ(រហូតដល់ឆ្នាំ២០២១)

| ល.រ. | បរិយាយ | រហូតមកដល់ឆ្នាំ២០២១ |
|---|---|---|
| ១ | ៥ជាន់-៩ជាន់ | ៩២១អគារ |
| ២ | ១០ជាន់-១៩ជាន់ | ៤៤៩អគារ |
| ៣ | ២០ជាន់-២៩ជាន់ | ១១៨អគារ |
| ៤ | ៣០ជាន់-៣៩ជាន់ | ៦៥អគារ |
| ៥ | ៤០ជាន់ឡើងទៅ | ៤០អគារ |
| ៦ | បូរី | ៣១០បូរី |

### ២.២- ខេត្តកណ្ដាល

**សមិទ្ធផល និងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកណ្ដាល សម្រេចបាន៖**

**ខេត្តកណ្ដាល** ជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ លាតសន្ធឹងតាមបណ្ដោយដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ មានភូមិសាស្ត្រព័ទ្ធជុំវិញរាជធានីភ្នំពេញ មានព្រំប្រទល់ខាងលិចទល់នឹងខេត្តកំពង់ស្ពឺ ខាងកើតទល់នឹងខេត្តព្រៃវែង ខាងជើងទល់នឹងខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម ខាងត្បូងទល់នឹងខេត្តតាកែវ និងខេត្តអានយ៉ាងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម(មានខ្សែបន្ទាត់ព្រំដែនប្រវែង២៩,៥គ.ម.។

ខេត្តកណ្ដាលមានផ្ទៃដីសរុប៣ ២១១,៧៥គ.ម.$^{២}$ ចែកចេញជា១០ស្រុក និង១ក្រុង មានឃុំចំនួន១១៧ និងសង្កាត់ចំនួន១០ មានចំនួនភូមិសរុប១ ០១០ភូមិ និងមានប្រជាពលរដ្ឋសរុប១ ៣៤៨ ៧៩៧នាក់(ស្រី ៧០១ ៧០២នាក់) ស្មើនឹង៣០៨ ០៣៦គ្រួសារ។

ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា រដ្ឋបាលខេត្តកណ្ដាលយល់ឃើញថា យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ គឺមានគោលដៅ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ដែលដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន៤ គឺទី១- ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយចីរភាព និងសោធននិវត្តន៍ ទី២- បង្កើតការងារឱ្យបានកាន់តែច្រើនទាំងបរិមាណនិងគុណភាព ជូនដល់ប្រជាជនកម្ពុជា ជាពិសេសស្រទាប់យុវជន ទី៣- ការសម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០% និងទី៤- បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាពសេវាសាធារណៈ។

រដ្ឋបាលខេត្តកណ្ដាល បានរៀបចំរបាយការណ៍បូកសរុបតាមសូចនាករ ស្ដីពីសកម្មភាពការងាររយៈពេល៥ឆ្នាំ(២០១៧-២០២១) ដែលជាសមិទ្ធផលសំខាន់ៗទាំងអស់មានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តកណ្ដាល ដូចខាងក្រោមនេះ៖

**១- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិងទីប្រជុំជនសំខាន់ៗ**

| ល.រ. | ការបរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវកៅស៊ូ | គ.ម. | ២០៧,០២ | ៣០,៧៣ | ៦៩,០១ | ១៨,៦៩ | ៧៦,៤៦ | ៤០១,៩០ |
| ២ | ផ្លូវបេតុង | គ.ម. | ៩៧,១២ | ១៥១,២៧ | ១៩៣,៨៥ | ២០០,១៤ | ១៥៨,៦៥ | ៨០១,០៥ |
| ៣ | ផ្លូវក្រាលគ្រួស | គ.ម. | ១៣៣,៤៤ | ១៣៣,៩៨ | ៨៤,៥២ | ៩៦,៧៨ | ១៦២,០៩ | ៦១០,៨៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | ផ្លូវទឹក | គ.ម. | ៧៥,៥០ | ១,៥៤ | - | - | ៥៨,៦៦ | ១៣៤,៧០ |
| ៥ | ប្រព័ន្ធលូ | គ.ម. | ២៩០,២៩ | ១០២,២៤ | ៧៥៩,១១ | ១៣០,១៣ | ១៤២,៨៤ | ១៤២៤,៦៣ |
| ៦ | ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី | ចំនួន | ៦៣ | -១ | - | ១ | ១ | ៦៤ |
| ៧ | ទឹកស្អាត | ស្ថានីយ | ៤៦ | ៣ | - | ១ | ៣ | ៥៣ |

## ២- ការពង្រឹងសោភ័ណភាព សេវាទីក្រុងទីប្រជុំជន

| ល.រ. | ការបរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការគ្រប់គ្រង ការប្រមូលសំរាម | កន្លែង | ៣ | - | ២ | ៤ | ២ | ១១ |
| ២ | ទីលានចាក់សំរាម | កន្លែង | ៤ | ១ | ១ | ៣ | ១ | ១០ |
| ៣ | ការរៀបចំផ្លូវថ្មើរជើង | គ.ម. | ១៩,១០ | - | - | - | - | ១៩,១០ |
| ៤ | ស្ពានអាកាស | កន្លែង | ១ | - | - | - | ១០ | ១១ |
| ៥ | ទីធ្លាចំណត | កន្លែង | ១ | - | - | - | ២ | ៣ |
| ៦ | សួនច្បារសាធារណៈ | កន្លែង | ៣ | ១ | - | - | ១ | ៥ |
| ៧ | កសាង និងការពារច្រាំងទន្លេ និងទំនប់ | ម. | - | - | ៤ ០០៩ | ១០ ១៥០ | ៦ ៣៣៥ | ២០ ៩៣៥ |
| ៨ | ការរៀបចំសណ្តាប់ធ្នាប់ | កន្លែង | ៣៣ | ២០ | ២២ | ២៨ | ៩ | ១១២ |
| ៩ | ភ្លើងបំភ្លឺនៅក្នុងក្រុង និងទីប្រជុំជន | បង្គោល | ៨៩៤ | - | ៣៥២ | ២៤០០ | ៥៣២៣ | ៨៩៦៩ |
| ១០ | ភ្លើងស្តុប | បង្គោល | ២ | ១ | ៦ | ២ | ២ | ១៣ |
| ១១ | ផ្សារធំៗ | ផ្សារ | ២១ | ១ | - | ១ | ១ | ២៤ |
| ១២ | សេវាដឹកជញ្ជូនសាធារណៈ | កន្លែង | - | - | - | ៣ | ២ | ៧ |
| ១៣ | សាងសង់ទំនប់ | ម. | ៣០ ៧៤០ | - | ១៥ ៩០៨ | ៤ ៤០០ | ៣៥ ៣៤២ | ៨៦ ៣៩០ |

## ៣- ការសាងសង់អគារចាប់ពី៥ជាន់ឡើង( សណ្ឋាគារ ខុនដូរ ផ្ទះសំណាក់...)

| ល.រ. | ការបរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | សណ្ឋាគារ | ខ្នង/បន្ទប់ | ២ | ១ | ៣ | - | - | ៦ |
| ២ | ខុនដូ | ខ្នង/បន្ទប់ | - | - | - | ១ | - | ១ |
| ៣ | ផ្ទះសំណាក់ | ខ្នង/បន្ទប់ | ១៥ | ៩ | ១៩ | ២០ | ១ | ៦៤ |
| ៤ | សំណង់អគារផ្សេងៗ | ខ្នង/បន្ទប់ | ៦ | ៣ | ៨ | ៥ | ៦ | ២៨ |
| ៥ | រមណីយដ្ឋានទេសចរធម្មជាតិកែច្នៃ | កន្លែង | ១ | - | ២ | ២ | ៣ | ៨ |

## ២.៣- ខេត្តកំពង់ឆ្នាំង

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រេចបាន៖

ខេត្តកំពង់ឆ្នាំង ស្ថិតនៅភូមិភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ៩១គ.ម. ពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតទល់នឹងខេត្តកំពង់ចាម កំពង់ធំ ខាងលិចទល់នឹងខេត្តពោធិ៍សាត់ ខាងត្បូងទល់នឹងខេត្តកំពង់ស្ពឺ កណ្តាល ខាងជើងទល់នឹងខេត្តកំពង់ធំ បឹងទន្លេសាប។ រចនាសម្ព័ន្ធរដ្ឋបាលខេត្តចែកចេញជា

១ក្រុង ៧ស្រុក មាន៧១ឃុំ សង្កាត់ ចែកជា៥៦៩ភូមិ មានប្រជាជនចំនួន១៣៧ ៧៥២គ្រួសារ មនុស្សសរុប ៥៧៣ ២៣៤នាក់។

ខេត្តកំពង់ឆ្នាំង មានប្រព័ន្ធផ្លូវគមនាគមន៍សំខាន់ៗ ចំនួន៣ខ្សែ ឆ្លងកាត់ គឺកំណាត់ផ្លូវជាតិលេខ៥ ប្រវែង៩៤គ.ម. ផ្លូវរថភ្លើងប្រវែង៧៣គ.ម. និងផ្លូវទឹក(ទន្លេសាប) ប្រវែង១១០គ.ម. ហូរឆ្លងកាត់។

**ក- ការងារសាធារណការនិងដឹកជញ្ជូន និងអភិវឌ្ឍន៍ជនបទ**

ក្នុងឆ្នាំ២០២១នេះ ខេត្តបានជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ មានជាអាទិ៍ ផ្លូវក្រាលកៅស៊ូ ប្រវែង១៥១,៥៨គ.ម. ផ្លូវក្រាលក្រួសក្រហមប្រវែង៤,២០គ.ម. ស្ពានគ្រប់ប្រភេទចំនួន៥កន្លែង។ អាទិភាពសំខាន់ របស់ខេត្តរួមមានការជួសជុល ថែទាំ និងការកែលម្អបណ្តាញផ្លូវថ្នល់ពីថ្នាក់ខេត្តរហូតដល់ជនបទ ខេត្តមានផ្លូវ សំខាន់ៗ ឆ្លងកាត់ដូចជាផ្លូវជាតិលេខ៥ ប្រវែង៩៣,៩គ.ម.(ភ្នំពេញ-កំពង់ឆ្នាំង៩១គ.ម.) ផ្លូវជាតិលេខ៥២ ប្រវែង ៨គ.ម. ផ្លូវជាតិលេខ៥៣ ប្រវែង៧៣,៥៥០គ.ម. ផ្លូវជាតិលេខ៥៣A ប្រវែង៣០គ.ម. ផ្លូវជាតិលេខ៥០C ប្រវែង ៥៧,៤០គ.ម. ផ្លូវដែកប្រវែង៧៣គ.ម. ផ្លូវទឹកប្រវែង១១០គ.ម.(ភ្នំពេញ-កំពង់ឆ្នាំង១០០គ.ម.)។ ក្រៅពីនោះ ខេត្ត មានផ្លូវខេត្តក្រាលកៅស៊ូ ផ្លូវបេតុង ផ្លូវក្រាលក្រួសក្រហម និងផ្លូវលំជីសយ៉ាងច្រើន កាត់ខ្វាត់ខ្វែងភ្ជាប់ពីជនបទមក ទីប្រជុំជនក្រុង ស្រុក ខេត្ត សម្រាប់សកម្មភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រជាជន។ វឌ្ឍនភាពនៃការកសាងហេដ្ឋា- រចនាសម្ព័ន្ធគមនាគមន៍ ខេត្តបានកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ទាំងផ្លូវទីប្រជុំជន និងផ្លូវ ជនបទកាន់តែប្រសើរឡើង ដោយបានកសាងផ្លូវគមនាគមន៍ក្នុងទីប្រជុំជននិងផ្លូវជនបទជាជំហានៗ ពីផ្លូវក្រាល ក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង ដែលបានអនុវត្តដោយមន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរ អភិវឌ្ឍន៍ជនបទ និងគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់។ ខេត្តបានយកចិត្តទុកដាក់ពង្រឹងសុវត្ថិភាពចរាចរណ៍ ផ្លូវគោក ជំរុញការពាក់មួកសុវត្ថិភាព ពាក់ខ្សែក្រវ៉ាត់ពេលបើកបរ និងមានវិធានការចំពោះអ្នកបើកបរពេលស្រវឹង ព្រមទាំងបានចុះបញ្ជីរថយន្ត និងប្រឡងផ្តល់បណ្ណបើកបររថយន្តគ្រប់ប្រភេទ។

ជំរុញការងារអភិវឌ្ឍន៍ជនបទ ការបង្កើនលទ្ធភាព និងសមត្ថភាពដល់សហគមន៍មូលដ្ឋាន លើ ការរៀបចំផែនការ ការគ្រប់គ្រងលើការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ សមិទ្ធផលជាច្រើនដែលសម្រេចបាន គឺបាន ថែទាំផ្លូវជាប្រចាំ ថែទាំផ្លូវខួប សហការសាងសង់អណ្តូងស្នប់ អណ្តូងលូ បង្គន់អនាម័យតាមផ្ទះ បង្គន់សាធារណៈ ពាងត្រងទឹកភ្លៀងតាមផ្ទះ អាងចម្រោះទឹកសាធារណៈ ដោយសហការជាមួយអង្គការស្បៀងអាហារពិភពលោក អនុវត្តគម្រោងស្បៀងពលកម្ម និងសាច់ប្រាក់ពលកម្ម។

**តារាងទី៥ លទ្ធផលការងារតាមបណ្តាឆ្នាំវិស័យសាធារណៈការ និងដឹកជញ្ជូន**

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ថែទាំជាប្រចាំផ្លូវកៅស៊ូ | ខ្សែ/គ.ម. | ១៣/១៨៤,៨៧ | ១៤/១៩១,១៤ | ១០/២៤៨,៧៥ | ៩/១៤៧,៦៨ | ១៣/១៧០ |
| ជួសជុល សាងសងផ្លូវកៅស៊ូ | ខ្សែ/គ.ម. | 0 | ៣/៦,៧៦០ | ៣/៥,៤៩៥ | ២/៤,០៥០ | ៦/១៦,៩៩៧ |
| ថែទាំជាប្រចាំផ្លូវក្រាលក្រួសក្រហម | ខ្សែ/គ.ម. | ១០/១៧០,៣០ | ១០/១៦០,៧៥ | ៩/១៤៧,៤១០ | ៧/១៥០,៧៤ | ៨/១៧៦,៦៤ |
| ជួសជុល សាងសង់ផ្លូវក្រាលក្រួសក្រហម | ខ្សែ/គ.ម. | ៣/១០,៨៥ | ២/៩,៩៧៥ | ២/៦,១៥០ | ៧/២៥,៤៤០ | ១/២,៣២៥ |
| ជួសជុល សាងសង់ស្ពានបេតុង | កន្លែង/ម. | 0 | 0 | 0 | ២/៧២ | 0 |
| ជួសជុល សាងសង់ស្ពានបេឡត៍ | កន្លែង/ម. | ១/៤៥ | ១/២៤ | 0 | ១/៩០ | 0 |
| ជួសជុល សាងសង់លូសងខាងផ្លូវ | កន្លែង/ម. | ១/១៦០ | 0 | ១/២៣០ | 0 | 0 |
| ជួសជុល សាងសង់លូកាត់ផ្លូវ | កន្លែង/ម. | ២/២០,៥ | ១/៨ | 0 | ២/៤៩ | 0 |

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| សាងសង់រ៉ឺហ្គា | រ៉ឺហ្គា | ៧ | ៧ | ១០ | ០ | ០ |
| ផ្តល់បណ្ណបើកបរយានយន្តផ្លូវគោកគ្រប់ប្រភេទ | បណ្ណ | ១ ៣៩៩ | ២ ១៤១ | ២ ៥០៧ | ៦ ៥៨៤ | ១៣ ៨០៧ |
| ចុះបញ្ជីយានយន្ត និងត្រីចក្រយានយន្ត | គ្រឿង | ៧ ៨៦៤ | ៥ ៣០៤ | ៤ ៨៦៩ | ៥ ១១៣ | ២ ៤១៦ |
| រៀបចំការ៉ូឡាចិញ្ចើមផ្លូវ | ម. | ០ | ០ | ៤៧០ | ១ ៨៤៥ | ០ |

**តារាងទី៦ វឌ្ឍនភាពវិស័យសាធារណការ និងដឹកជញ្ជូនរបស់ខេត្ត**

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ប្រវែងផ្លូវក្រាលកៅស៊ូសរុប(ផ្លូវជាតិ) | គ.ម. | ១៤៩,៨០ | ១៨៨,១០ | ១៨៨,៩១ | ១៨៨,៩១ | ១៤,១៨០ |
| ប្រវែងផ្លូវក្រាលកៅស៊ូសរុប(ផ្លូវខេត្ត) | គ.ម. | ២៨,៦៦ | ២៨,៦៦ | ១៧៨,៧៩ | ១៦៩,២២ | ២,៣៦៧ |
| ប្រវែងផ្លូវក្រាលកៅស៊ូ និងបេតុង(ផ្លូវក្រុង) | គ.ម. | ៥៣,០៨ | ៥៣,០៨ | ៦៣,៥៤ | ៦៣,៨៨ | ០ |
| កំពង់ផែ | ផែ | ៤ | ៥ | ៧ | ៧ | ៧ |

**តារាងទី៧ ចំណុចដៅនៃវិស័យអភិវឌ្ឍន៍ជនបទ**

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| គ្រួសារប្រើប្រាស់ទឹកបានឆ្លងកាត់ពីប្រព័ន្ធធ្វើទឹកឱ្យស្អាត | ភាគរយ | ៧៤ | ៧៥,៩០ | ៧៧,៥០ | ៨០ | ៨៥ |
| គ្រួសារទទួលទានទឹកស្អាត | ភាគរយ | ៧៧,៨០ | ៧៩,៧០ | ៨២,៤០ | ៨៦,១០ | ៧៥ |
| គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ភាគរយ | ៥២,៤០ | ៥៧,៣០ | ៦៧,៨០ | ៦៧,៤០ | ៧៨ |
| គ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស | ភាគរយ | ៤៦,៤០ | ៥០,៤០ | ៦១,៦០ | ៦៥,៦០ | ៨០ |

សាងសង់អគាររដ្ឋបាលឃុំ២១ខ្នង ឃុំក្រាំងស្គារ ស្រុកទឹកផុស ឃុំកំពង់អុស ស្រុកជលគិរី ឃុំពាម ឃុំស្វាយជុក និងឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ សង្កាត់ខ្សាម សង្កាត់ផ្សារឆ្នាំង សង្កាត់កំពង់ឆ្នាំង និងសង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ឃុំអណ្តូងស្នាយ បន្ទាយព្រាល ក្រាំងលាវ ឃុំព្រៃមូល ឃុំស្រែថ្មី ឃុំលោឡៀរ និងឃុំប្រស្នឹប ស្រុករលាប្អៀរ ឃុំលង្វែក ស្រុកកំពង់ត្រឡាច ឃុំខ្លុងពពក ស្រុកទឹកផុស ឃុំពេល ឃុំពេជចង្វារ និងឃុំចក ស្រុកបរិបូណ៌។

សាងសង់អគារការិយាល័យច្រកចេញចូលតែមួយស្រុកកំពង់ត្រឡាច១ខ្នង អគារសាលប្រជុំសាលាខេត្ត១ខ្នង មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ខេត្ត១ខ្នង សួនច្បារក្នុងក្រុងកំពង់ឆ្នាំង៣កន្លែង(សួនសម្តេចចៅហ្វាវាំង **គង់ សំអុល** ខាងមុខមជ្ឈមណ្ឌលកម្ទាត់មីនស៊ីម៉ាក់ និងសួនសម្តេច ជួន ណាត មុខវិទ្យាល័យក្រុងកំពង់ឆ្នាំង សួនរង្វង់មូលទូកមាស សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង) និងវិមានយុទ្ធជន២ផ្ទ ក្នុងបរិវេណមណ្ឌលកុមារកំព្រាខេត្ត។

ជួសជុលនិងថែទាំបង្គោលភ្លើងបំភ្លឺក្នុងក្រុងកំពង់ឆ្នាំង ក្លោងទ្វារចូលសាលាខេត្ត អគារច្រកចេញចូលតែមួយសាលាខេត្ត១ខ្នង អគារបម្រើការងាររបស់រដ្ឋបាលខេត្ត១ខ្នង សួនច្បារក្នុងសាលាខេត្ត និងក្នុងក្រុងកំពង់ឆ្នាំង របងជុំវិញសាលាខេត្តប្រវែង៤៨២ម. និងអាសនដ្ឋានលោកយាយទេព១កន្លែង។

ជួសជុលផ្លូវនៅសង្កាត់ផ្សារឆ្នាំង ដោយចាក់ដីល្បាយថ្មក្នុំលើខ្នងទំនប់ទទឹង១៩ម. ប្រវែង៦៦០ម. និងផ្លូវក្រាលក្រួសក្រហម៦ខ្សែ ប្រវែង៣ ០០០ម. និង៦ ៦៣០ម.២ និងប្រព័ន្ធលូក្នុងសង្កាត់កំពង់ឆ្នាំង ប្រវែង៣ ១២០ម.។ បានជួសជុលផ្លូវបេតុងនៅសង្កាត់ខ្សាម ជុំវិញរង្វង់មូលទូកមាស(ជំហានទី១,ទី២) ទំហំ១៨ ៥៤០ម.២ ផ្លូវបេតុងក្នុងសាលាខេត្ត១ខ្សែ ប្រវែង៧៣៥ម. និងជួសជុលដោយចាក់ដីពង្រីករង្វង់មូលទូកមាសទំហំ១២ ៦៥២ម.២។

**ខ- ការងារបរិស្ថាន អនាម័យ និងសោភ័ណភាពទីក្រុង**

ខេត្តមានទីលាននិងរណ្ដៅចាក់សំរាមចំនួន១២កន្លែង សម្រាប់ទុកដាក់សំណល់សំរាមប្រមាណ២៥០តោនក្នុងមួយថ្ងៃ។ បានចុះត្រួតពិនិត្យការបំពុលបរិស្ថានតាមរោងចក្រ សហគ្រាស ទីលាន និងរណ្ដៅចាក់សំរាម ការបង្ហូរសំណល់រឹងរាវ និងបានយកទឹកតាមដងទន្លេ បឹង ទៅពិនិត្យនៅមន្ទីរពិសោធន៍អំពីគុណភាពទឹកសាធារណៈនៅក្រសួងបរិស្ថានជារៀងរាល់ខែ។

រដ្ឋបាលក្រុងកំពង់ឆ្នាំង បានជ្រើសរើសក្រុមអ្នកទទួលការប្រមូលទុកដាក់សំរាមចំនួន៣ក្រុម ៖

- ក្រុមលោក ស្រីប៉ាម៉ារ៉ាឌី ប្រមូលនិងសម្អាតសំរាមតាមសួនសាធារណៈ គ្រឹះស្ថានរដ្ឋ ឯកជន ទីតាំងអាជីវកម្មគ្រប់ប្រភេទ និងតាមផ្ទះប្រជាពលរដ្ឋក្នុងសង្កាត់កំពង់ឆ្នាំងនិងសង្កាត់ផ្សារឆ្នាំង

- ក្រុមលោក ប៉ិច ហុក ប្រមូល និងសម្អាតសំរាមតាមសួនសាធារណៈ គ្រឹះស្ថានរដ្ឋ ឯកជន ទីតាំងអាជីវកម្មគ្រប់ប្រភេទ និងតាមផ្ទះប្រជពលរដ្ឋក្នុងសង្កាត់ខ្សាម និងសង្កាត់ប្អេរ

- ក្រុមលោក សេង ប៊ុនលី ប្រមូលបោសសម្អាតសំរាមលើការ៉ូឡា និងសង្ខាងផ្លូវសំខាន់ៗក្នុងក្រុង ៦ខ្សែ ស្មើនឹង១៥,៩២គ.ម.

- អប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមលំនៅឋានឱ្យធ្វើអាងសិបទិច ទុកដាក់កាកសំណល់រាវចៀសវាងការបំពុលទឹកក្នុងដី និងក្លិនស្អុយ។ រដ្ឋបាលក្រុងបានទទួលអនុវត្តអនុគម្រោងចំនួន២ នៃគម្រោងគ្រប់គ្រងកែលម្អបរិស្ថានជុំវិញបឹងទន្លេសាប ដំហាន១៖

១- អនុគម្រោងសាងសង់ប្រព័ន្ធលូនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ក្រុងទំហំ១៥ហ.ត. សាងសង់នៅភូមិដំណាក់ពពូល ភូមិកណ្ដាល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង។

២-អនុគម្រោងសាងសង់ទីលានចាក់សំរាមទំហំ១២ហ.ត. ស្ថិតនៅចម្ងាយ១៣គ.ម. ពីក្រុងកំពង់ឆ្នាំង មានទីតាំងនៅភូមិត្រពាំងស្បូវ ឃុំស្រែថ្មី ស្រុករលាប្អៀរ

រៀបចំផ្លូវថ្មើរជើងដោយរៀបប័រឡៀរ និងក្រាលការ៉ូឡានៅក្នុងភូមិធម្មយុត្តិ សង្កាត់ផ្សារឆ្នាំង និងសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ប្រវែង៤ ១៧២,៥៤ម.$^{២}$ និងជួសជុល កែលម្អរៀបប័រឡៀរ និងក្រាលការ៉ូឡាក្នុងសង្កាត់ខ្សាម និងសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ប្រវែង៤ ០៩១,៣៣ម.$^{២}$។

ប្រជាជនដែលកំពុងចាប់យកចំណែកដីច្រាំងទន្លេ បឹង និងព្រែក ដើម្បីធ្វើជាកន្លែងប្រកបរបរអាជីវកម្មលក់ដូរដែលមាននៅជួរដើមស្រល់២០៣តូប អាជីវករជិតស្ថានីយប្រេង២៣តូប អាជីវករលក់ឈើ២៨រោង និងតូបអាជីវកម្មប្រជាជនលក់កសិផល៨០រោង។ ប្រជាជនប្រភេទនេះ រដ្ឋបាលខេត្តមានគម្រោងរៀបចំទីតាំងសម្រាប់បន្លាស់ទីពួកគាត់ទៅលក់ដូរនៅកន្លែងថ្មី។ រដ្ឋបាលខេត្តបានរៀបចំទីតាំងសម្រាប់អាជីវករ ក្រោមគម្រោងវិនិយោគរបស់វិស័យឯកជន។ អាជីវករមានភារកិច្ចជួល ឬទិញទីតាំងនោះ ដើម្បីធ្វើអាជីវកម្មរបស់ខ្លួន។

**គ- ការងារទេសចរណ៍**

ខេត្តកំពង់ឆ្នាំង មានតំបន់សក្ដានុពលទេសចរណ៍២៣កន្លែង ក្នុងនោះរមណីដ្ឋានទេសចរណ៍ ធម្មជាតិ ១៣កន្លែង និងរមណីយដ្ឋានទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ១០កន្លែង។ សណ្ឋាគារមាន៩កន្លែង ផ្ទះសំណាក់ ៤៤កន្លែង ភោជនីយដ្ឋាន និងអាហារដ្ឋានមាន៧៧កន្លែង។

កន្លងទៅការងារទេសចរណ៍បានចុះធ្វើការអប់រំណែនាំ ស្ដីពីការរៀបចំតុបតែងលម្អនៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ដូចជាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន និងកន្លែងលក់ស៊ុប បាន

ចេញច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងចុះផ្សព្វផ្សាយអំពីច្បាប់ស្តីពីទេសចរណ៍ ពីការប្រើប្រាស់ឯកសណ្ឋាន ការធ្វើបដិសណ្ឋារកិច្ចភ្ញៀវទេសចរ ការធ្វើអនាម័យចំណីអាហារ និងឱ្យចូលរួមអនុវត្ត វិធានការរបស់ក្រសួងសុខាភិបាល។

**តារាងទី៨ វឌ្ឍភាពនៃវិស័យទេសចរណ៍**

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| សណ្ឋាគារ | កន្លែង | ៨ | ៩ | ៩ | ៩ | ១០ |
| ចំនួនបន្ទប់ | បន្ទប់ | ២៨០ | ២៨០ | ៣០០ | ៣០០ | ៣៣០ |
| ផ្ទះសំណាក់ | កន្លែង | ២១ | ៣៦ | ៥៧ | ៤៤ | ៤៧ |
| ចំនួនបន្ទប់ | បន្ទប់ | ៣៦៥ | ៤៥២ | ៥៦៨ | ៥៦៦ | ៥០៤ |
| ខារ៉ាអូខេ | កន្លែង | ១១ | ២១ | ២៣ | ២០ | ២០ |
| ភោជនីយដ្ឋាន/អាហារដ្ឋាន | កន្លែង | ៣៧ | ៤៣ | ៧២ | ៧៧ | ១០០ |
| ចំនួនភ្ញៀវទេសចរសរុប | នាក់ | ៦៨ ៥២៥ | ៣៧ ៣៥១ | ១ ២៨៥ ៨៧២ | ៥ ៨២២ | ៥៩ ៩៦១ |
| - ភ្ញៀវទេសចរជាតិ | នាក់ | ៦៤ ០៤៨ | ៣២ ៣០០ | ១ ១៥៧ ៨៥៥ | ៥ ៨១១ | ៥៩ ៩៣៣ |
| - ភ្ញៀវទេសចរអន្តរជាតិ | នាក់ | ៤ ៤៧៧ | ៥ ០៩១ | ១២៨ ០១៧ | ១១ | ២៨ |

## ២.៤- ខេត្តកំពង់ស្ពឺ

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ សម្រេចបាន៖

ខេត្តកំពង់ស្ពឺ គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តសរុប២៥ ដែលមានសណ្ឋានខ្ពង់រាបកណ្តាល និងមានព្រំប្រទល់ខាងលិចជាប់ខេត្តកោះកុងនិងខេត្តព្រះសីហនុ ខាងកើតជាប់ខេត្តកណ្តាលនិងខេត្តតាកែវខាង ជើងជាប់ខេត្តកំពង់ឆ្នាំងនិងខេត្តពោធិ៍សាត់ ខាងត្បូងជាប់ខេត្តតាកែវនិងខេត្តកំពត។ ខេត្តចែកចេញជា៧ស្រុក ១ក្រុង ៨២ឃុំ និង៥សង្កាត់ ភូមិមានចំនួន១ ៣៧៩ភូមិ ក្នុងនោះ ភូមិមានក្របខ័ណ្ឌចំនួន១ ៣៦៨ភូមិ និងភូមិ អត់ក្របខ័ណ្ឌមានចំនួន១១ភូមិ មានគ្រួសារសរុប១៨០ ៨៣៨គ្រួសារ មានប្រជាពលរដ្ឋសរុប៨៥០ ៤៧២នាក់ (ស្រី៤៣៣ ៧២០នាក់)។

### ១- ការកសាងផែនការអភិវឌ្ឍននិងកម្មវិធីវិនិយោគ

**លទ្ធផលនៃការអនុវត្តគម្រោងខេត្តរយៈពេល៥ឆ្នាំ(២០១៧-២០២១)**

| ខេត្ត | គម្រោង | ចំនួនគម្រោង | លទ្ធផលគម្រោង | តម្លៃ (រៀល) |
|---|---|---|---|---|
| កំពង់ស្ពឺ | គម្រោងជួសជុលផ្លូវកាលគ្រួសថ្មភ្នំ | ១ | ៨ ៨៧៧ម. | ១ ៩៩៩ ៦៨៦ ៩០០ |
| | គម្រោងជួលជុលកែលម្អអគារសាលប្រជុំសាលាខេត្ត | ១ | ២អគារ | ៤៩៩ ៨៩៧ ៦០០ |
| | គម្រោងជួសជុលផ្លូវកាលគ្រួសក្រហម | ១ | ១ ៨០០ម. | ៨០០ ០០០ ០០០ |
| | គម្រោងសាងសង់សួនពុះទ្រូងផ្លូវ | ៤ | ៥ ៩៦៤ម. | ៥ ៧៦៥ ៩៦៣ ១០០ |
| | គម្រោងជួសជុលរបងរៀបបិកឌា និងក្រាលការ៉ូឡា | ១ | ១៩០ម. | ២៨០ ០០០ ០០០ |
| | គម្រោងជួសជុលកែលម្អប្រឡាយបង្ហូរទឹកកខ្វក់ខាងកើតផ្សារកំពង់ស្ពឺ | ១ | ៧៨០ម. | ១ ៥៨៩ ០០០ ០០០ |
| | គម្រោងជួសជុលអគារស្នាក់នៅមណ្ឌលកុមារកំព្រា | ១ | ១កន្លែង | ២០០ ០០០ ០០០ |
| | គម្រោងសាងសង់អគាររដ្ឋបាលសាលាខេត្តជំហានទី១,២,៣,៤ | ១ | ១កន្លែង | ១៤ ៥១៥ ៩០១ ៨០០ |

| | | | | |
|---|---|---|---|---|
| | គម្រោងសាង់សង់អគារការិយាល័យច្រកចេញចូលតែមួយ | ១ | ៤កន្លែង | ១ ៨៥៨ ០០០ ០០០ |
| | គម្រោងសាងសង់រង្វង់មូលនិងរូបសំណាកផ្សេងៗ | ២ | ២កន្លែង | ៨៥៥ ៧១៨ ២០០ |
| | គម្រោងបំពាក់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈនិងភ្លើងស្តុប | ៧ | ៦០បង្គោល | ២ ៤៧៦ ៩៤១ ៥០០ |
| | គម្រោងបំពាក់ស្លាកសញ្ញាសម្គាល់ឈ្មោះផ្លូវ | ១ | ៤៦កន្លែង | ១០០ ០០០ ០០០ |
| | គម្រោងចាក់ដីប្រាំងស្ទឹងព្រែកត្នោតជាប់ស្ពានថ្មី | ១ | ១០៦,៥០ម. | ១១៣៥ ០០០ ០០០ |
| | គម្រោងរៀបចំប្រព័ន្ធលូរីហ្គានិងរៀបចំខឿនសងខាងលើកំណាត់ផ្លូវលេខ១០៤ | ១ | ១កន្លែង | ៣៧៨ ០០០ ០០០ |
| | គម្រោងផ្លូវអ៊ុតកៅស៊ូបេទីម | ២ | ៤ ៤៩១ម.$^{២}$ | ១ ៧១០ ០០០ ០០០ |
| | **សរុប** | **៣២** | | **៣៤ ១៦៤ ១០៩ ១០០** |

**២- ការងារទឹកស្អាត**

- សហគ្រាសផលិតនិងផ្គត់ផ្គង់ទឹកស្អាតឯកជន សរុបចំនួន៤៨មូលដ្ឋាន ដែលប្រកាសក្រសួងចំនួន២៨មូលដ្ឋាន មានគោលការណ៍អនុញ្ញាតពីក្រសួងចំនួន២០មូលដ្ឋាន

- ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់សរុបចំនួន៤៥ ៥៤៩គ្រួសារ ស្មើនឹង២៥,៩២%នៃចំនួនគ្រួសារប្រជាពលរដ្ឋសរុបទូទាំងខេត្ត ដោយឡែកទីប្រជុំជន ក្រុងច្បារមន ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ចំនួន៧ ៦៣៦ គ្រួសារ ស្មើនឹង៨០,៦០%។

**៣- ការងារថាមពល**

- វិស័យថាមពល អគ្គិសនី បច្ចុប្បន្នទូទាំងខេត្តកំពង់ស្ពឺមាន៖
  - បន្ទុកអគ្គិសនីប្រើប្រាស់សរុបទូទាំងខេត្ត មាន១២២MW
  - ក្រុមហ៊ុនផ្គត់ផ្គង់និងចែកចាយអគ្គិសនី(រដ្ឋនិងឯកជន)ចំនួន២១ក្រុមហ៊ុន
  - មានបណ្តាញអគ្គិសនីចូលដល់ភូមិ១ ២៧៥ភូមិ/១ ៣៧៩ភូមិ ស្មើនឹង៩២,៤៦%
  - ទូទាំងខេត្តប្រជាជនមានអគ្គីសនីប្រើប្រាស់១៥១ ១៤៧/១៨០ ១៩៦គ្រួសារ ស្មើនឹង៨៣,៨៨%
  - ក្រុងច្បារមនប្រជាជនមានអគ្គិសនីប្រើប្រាស់១០ ៦៦៤/១០ ៧៧២គ្រួសារ ស្មើនឹង៩៩%
- ប្រភពថាមពលអគ្គិសនី

  \+ អនុស្ថានីយ៖

  ១- អនុស្ថានីយ នៅសង្កាត់រកាធំ ក្រុងច្បារមន ៥០MW

  ២- អនុស្ថានីយ នៅឃុំព្រះនិព្វាន្ត ស្រុកគងពិសី ២០០MW

  ៣- អនុស្ថានីយ នៅឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ២០០MW
- ខ្សែបណ្តាញអគ្គិសនី៖

  HV= ៨៨,១៤គ.ម.(កំពុងសាងសង់)

  HV= ១៩៦គ.ម.

  MV= ១ ៧៣៧គ.ម.

  LV= ២ ០០២គ.ម.
- វារីអគ្គិសនី : គីរីរម្យ(I.II.III) ៣០MW
- ម៉ាស៊ីនដើរដោយថាមពលជីវម៉ាស់ (រោងចក្រស្ករអំពៅ) ៣៤MW
- ស្ថានីយផលិតថាមពលដោយពន្លឺព្រះអាទិត្យ៨០MW

- វិស័យប្រេងកាត ស្ថានីយប្រេងឥន្ធនៈចំនួន២០៧ទីតាំង ស្ថានីយ្យរួមប្រេង និងឧស្ម័នឥន្ធនៈចំនួន ២០ទីតាំង អាជីវកម្មឧស្ម័នឥន្ធនៈ(ហ្គាស) ខ្នាតតូចចំនួន៤៨ទីតាំង សេវាកម្មប្តូរប្រេងម៉ាស៊ីន។

**៤- ការងារទេសចរណ៍**

- រមណីយដ្ឋានមាន១០កន្លែង រួមមានរមណីយដ្ឋានប្រភេទកែច្នៃមាន២កន្លែងគឺ អំពែភ្នំ វីគីរីរម្យ ផាញរីសត(A2A ឋេាន) រមណីយដ្ឋានប្រភេទអេកូទេសចរណ៍ជីវៈចម្រុះមាន៤កន្លែង គឺទឹកធ្លាក់ចំបក់ ទឹកធ្លាក់ភ្នំជ្រាវ ក្នុងនោះឧទ្យានជាតិគិរីរម្យត្រូវបានបែងចែកជា១ប្រភេទគឺមជ្ឈមណ្ឌលសាសនា និងរមណីយដ្ឋានគីរីរម្យក្រោម (អូសំបត)

- រមណីយដ្ឋានប្រភេទបុរាណវិទ្យាមាន២កន្លែងគឺ ភ្នំចាស់ ភ្នំព្រះ

- រមណីយដ្ឋានប្រភេទប្រវត្តិសាស្ត្រនិងធម្មជាតិមាន១កន្លែងគឺ តេទឹកពុះ

- រមណីយដ្ឋានកែច្នៃប្រភេទកីឡាមាន១កន្លែងគឺ កីឡាវាយកូនហ្គោល

- ចុះត្រួតពិនិត្យទីតាំងនិងពង្រឹងការគ្រប់គ្រងមូលដ្ឋានអាជីវកម្ម សេវាកម្សាន្ត សេវាស្នាក់នៅក្នុងស្រុកគងពិសី៣០លើក ស្រុកឧដុង្គ២៦លើក ស្រុកភ្នំស្រួច៤៣លើក ស្រុកសំរោងទង៤៦លើក ស្រុកបសេដ្ឋ១៥លើក ស្រុកឱរ៉ាល់២៦លើក ស្រុកថ្ពង២០លើក និងក្រុងច្បារមន៦០លើក

- ចេញអាជ្ញាបណ្ណទេសចរណ៍ចំនួន១៨៦មូលដ្ឋាន ដែលរកចំណូលបានចំនួន២៦ ៩០៥ ០០០រៀល (ម្ភៃប្រាំមួយលានប្រាំបួនរយប្រាំពាន់រៀលគត់) និងចំណូលជួលទីតាំងរមណីយដ្ឋានអំពែភ្នំ សម្រាប់ឆ្នាំ២០១៨ គឺ ២ ៤៨០ ០០០រៀលគត់(ពីរលានបួនរយប៉ែតសិបប្រាំបីពាន់រៀលគត់)។

**+ អំពីស្ថិតិអាជីវកម្ម-សេវាកម្មទេសចរណ៍នានាក្នុងខេត្តកំពង់ស្ពឺ**

- សេវាស្នាក់នៅសរុបទូទាំងខេត្តចំនួន១២៨កន្លែង ក្នុងនោះ សណ្ឋាគារចំនួន៥កន្លែង ស្មើនឹង១៥៦បន្ទប់ ផ្ទះសំណាក់ចំនួន៣៥កន្លែង ស្មើនឹង៣១៣បន្ទប់ ផ្ទះជួលចំនួន៨៨កន្លែង ស្មើនឹង៥៥៣បន្ទប់

- មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យៈ មានចំនួន៣៧កន្លែង ស្មើនឹង៩៤បន្ទប់

- ក្លិបចំនួន៣កន្លែង ស្មើនឹង៣បន្ទប់ សេវាម្ហូបអាហារនិងភេសជ្ជៈ ភោជនីយដ្ឋាន អាហារដ្ឋាន ចំនួន ៨០កន្លែង ស្មើនឹង៤ ៤០៦កៅអី ស្នាកយ៉ា២០កន្លែង

- សេវាសុខភាព : ម៉ាស្សាសុខភាពចំនួន២០កន្លែង ស្មើនឹង៤០គ្រែ

- កម្លាំងពលកម្មក្នុងវិស័យទេសចរណ៍សរុបចំនួន២ ៨៣០នាក់(ស្រី៩៨០នាក់)។

**+ ស្ថិតិភ្ញៀវទេសចរ**

ក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) ភ្ញៀវទេសចរសរុប១ ៣១៨ ៨៧៦នាក់ បើធៀបនឹងឆ្នាំ២០១៧ កើនឡើង២២ ៦៥០នាក់ ស្មើនឹង២២៦,៥%។

ភ្ញៀវទេសចរជាតិ មានចំនួន១ ២៣៥ ៩៩០នាក់ បើធៀបនឹងឆ្នាំ២០១៧ កើនឡើង២០ ៣៥៥នាក់ ស្មើនឹង២០៣,៥៥%។

ភ្ញៀវអន្តរជាតិមានចំនួន៦៦ ៨៤៣នាក់ បើធៀបនឹងឆ្នាំ២០១៧ កើនឡើង២ ២៩៥នាក់ ស្មើនឹង ២២,៩៥%។

## ២.៥- ខេត្តព្រះសីហនុ

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តព្រះសីហនុ សម្រេចបាន៖**

ខេត្តព្រះសីហនុ ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា ជាប់នឹងតំបន់ឆ្នេរសមុទ្រមានចម្ងាយ២៣០គ.ម. ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៤ និងមានចម្ងាយ២៦០គ.ម. តាមផ្លូវជាតិលេខ៣ និងផ្លូវដែក(ភ្នំពេញ ខេត្តព្រះសីហនុ) មានអាកាសយានដ្ឋាននិងកំពង់ផែអន្តរជាតិទឹកជ្រៅ។ ខេត្តមានព្រំប្រទល់ខាងកើតជាប់ខេត្តកំពត និងខេត្តកំពង់ស្ពឺ ខាងលិចនិងខាងត្បូងជាប់ឈូងសមុទ្រថៃ និងខាងជើងជាប់ខេត្តកោះកុង។

ចំពោះការគ្រប់គ្រងរដ្ឋបាលដែនដី ខេត្តចែកចេញជា២ក្រុង ៣ស្រុក ២៣ឃុំ និង៦សង្កាត់ មានភូមិចំនួន១១១ភូមិ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន៤៨ ៣៧២គ្រួសារ ស្មើនឹងមនុស្សសរុបចំនួន២២៣ ២៨៦នាក់(ទិន្នន័យមូលដ្ឋានឃុំ សង្កាត់)។ ផ្អែកតាមទិន្នន័យជំរឿនឆ្នាំ២០១៩ មានប្រជាពលរដ្ឋសរុប៣០២ ៨៨៧នាក់ មានដង់ស៊ីតេប្រជាជន៨៣,២៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។

**១- ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៧ខ្សែ**

គិតចាប់ពីថ្ងៃបើកសម្ពោធការដ្ឋាននាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១ គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៧ខ្សែ ប្រវែងសរុប៨៤ ០៦៥ម. ចំណាយអស់ទឹកប្រាក់សរុប ៣២៤ ០៧៩ ៩៦៤ដុល្លារអាម៉េរិក ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលចំនួន៣១០ ៤៦៦ ២៧៦ដុល្លារអាម៉េរិក ក្រុមហ៊ុនVINCI ចំនួន១០ ១៦៣ ៥៩៣ដុល្លារអាម៉េរិក និងឯកឧត្តមអ្នកឧកញ៉ា លី យ៉ុងផាត់ ចំនួន៣ ០០០ ០០០ ដុល្លារអាម៉េរិក។ រចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៧ខ្សែ រួមមានមហាវិថីចំនួន៣ខ្សែ ប្រវែង២០ ៨៦៤ម. វិថីចំនួន១៥ខ្សែ ប្រវែង៥០ ៣៣៤ម. និងអនុវិថីចំនួន១៩ខ្សែ ប្រវែង១២ ៨៦៧ម. មានដូចខាងក្រោម៖

- **ចិញ្ចើមផ្លូវ** បានរៀបចំខឿនថ្មក្រានីតប្រវែង២១៣ ៤០៨ម. និងកម្រាលថ្មក្រានីតចំនួន៥៣៩ ៦៨៦ម.$^2$ ដោយមានការរៀបចំផ្លូវថ្មើរជើង ផ្លូវកង់ ផ្លូវសម្រាប់ជនមានពិការភាព ជាដើម
- **ដើមឈើ ដើមផ្កា និងស្មៅ** បានដាំដើមឈើចំនួន៨ប្រភេទ លម្អតាមដងផ្លូវទាំង៣៧ខ្សែ សរុបចំនួន ១២ ៦១៨ដើម ផ្កាក្រដាស៦០ ២០០គុម្ព នៅតាមមេដ្យាននៃមហាវិថីទាំង៣ និងដាំស្មៅ២៩៦ ៧៧១ម.$^2$
- **បង្គោលភ្លើងបំភ្លឺផ្លូវ និងអំពូលឆ្លាតវៃ** បានដំឡើងបង្គោលភ្លើងបំភ្លឺផ្លូវចំនួន៤ ៦២៨បង្គោល និងបំពាក់អំពូលឆ្លាតវៃចំនួន៥ ៣០០អំពូល
- **កាមេរ៉ាសុវត្ថិភាព** បានបំពាក់កាមេរ៉ាសុវត្ថិភាពចំនួន៥៣៣គ្រឿង និងមានចំនួន៤៣៣ទីតាំង
- **សញ្ញាចរាចរណ៍** បានដំឡើងភ្លើងសញ្ញា(ភ្លើងស្តុប) ចំនួន៣៤ទីតាំង បំពាក់ស្លាកសញ្ញា១ ១៧៧ស្លាក គំនូសសញ្ញាចរាចរណ៍ចំនួន៩០ ៦៤០ម.$^2$ និងដាក់ភ្នែកឆ្មា(Road Stud) ចំនួន៩ ១៥៥គ្រាប់
- **ប្រព័ន្ធបណ្តាញលូ** បានសាងសង់លូប្រអប់កាត់ទទឹងថ្នល់ចំនួន៤១ទីតាំង ប្រវែង១ ៤៤៣ម. លូមូលកាត់ទទឹងថ្នល់ចំនួន៧៦ទីតាំង ប្រវែង២ ០៣១ម. លូទឹកភ្លៀងអង្កត់ផ្ចិត១ម. ប្រវែង៨៨ ៨៩៧ម. លូទឹកកខ្វក់អង្កត់ផ្ចិត១ម. ប្រវែង៨១ ៦៥៣ម. ប្រឡាយរាងអក្សរអ៊ីយប្រវែង៧ ៤០៦ម. និងប្រឡាយអក្សរវី ប្រវែង៦ ៧៨៤ម.
- **ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់** បានសាងសង់ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ចំនួន៣កន្លែង ក្នុងនោះស្ថានីយទី១ និងស្ថានីយទី២ បានដាក់ឱ្យដំណើរការជាស្ថាពររួចរាល់ ដែលស្ថានីយទី១ មានសមត្ថភាពប្រព្រឹត្តិកម្ម ៥ ២០០ម.$^3$/ថ្ងៃ ស្ថានីយទី២ មានសមត្ថភាពប្រព្រឹត្តិកម្ម៧ ២០០ម.$^3$/ថ្ងៃ និងស្ថានីយទី៣ កំពុងដំណើរការសាងសង់ មានសមត្ថភាពប្រព្រឹត្តិកម្ម២០ ០០០ម.$^3$/ថ្ងៃ

- **សំណង់ស្ពាន** បានសាងសង់ស្ពានសរុបចំនួន៩ទីតាំង ប្រវែងសរុប២៩៦ម. ដែលក្នុងនោះមានស្ពានចំនួន៦ទីតាំង មានទទឹង២៥,៧៥ម. ប្រវែង២០២ម. និងស្ពានចំនួន៣ទីតាំង ទទឹងពី១១,៥៦ម. ដល់២០,៥០ម. មានប្រវែង៩៤ម.

- **រង្វង់មូលនិងត្រីកោណប្រសព្វ** បានរៀបចំរង្វង់មូលចំនួន៤ទីតាំង រួមមាន រង្វង់មូលកងកេង រង្វង់មូលព្រះឧមា-មហេសូរ រង្វង់មូលព្រះថោងនាងនាគ និងរង្វង់មូលសីហរាជមុខបី និងត្រីកោណប្រសព្វចំនួន២ទីតាំង មានត្រីកោណប្រសព្វមហាវិថីជំទាវម៉ៅ និងត្រីកោណប្រសព្វព្រះស្តុន្ទ ដែលទីតាំងនីមួយៗមានលម្អដោយបដិមាធ្វើពីស្ពាន់ និងកម្រាលថ្មក្រានីត និងកម្រាលសួនស្មៅជាដើម

- **ចំណតរថយន្ត** បានរៀបចំចំណតរថយន្ត ដែលមានចំនួនសរុបប្រមាណ៧២៤ចំណត នៅតាមទីតាំងសំខាន់ៗ ជាពិសេសនៅតាមទីតាំងដែលមានសក្តានុពលផ្នែកទេសចរណ៍

- **បន្ទប់ទឹកសាធារណៈប្រណីត** បានសាងសង់បន្ទប់ទឹកសាធារណៈប្រកបដោយភាពប្រណីតចំនួន១១ទីតាំង នៅតាមដងវិថីតេជោបណ្តោយឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះនិងឆ្នេរពយជំទាវម៉ៅសម្រាប់បម្រើដល់សាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ

- **សួន ទីលាន និងទីសាធារណៈសំខាន់ៗ** បានរៀបចំស្ថាបនាសួន និងទីធ្លាសាធារណៈដែលមានដូចជាសាងសង់ទីលានតេជោទំហំ២៣ ៥៩៣ម.² ទីអង្គុយកម្សាន្តពយអូរឈើទាល សួនសាធារណៈពយអូរឈើទាល ខ្មែរធ្វើបាន សិលាចាំស្នេហ៍ ដើមឈើចាំស្នេហ៍ ថ្មបីដុំ សួនឆ្នេរពយជំទាវម៉ៅ សួនកូនសោរ និងសួនរង្វង់មូលកងកេងជាដើម

- **ការស្តារអូរ ប្រឡាយ និងប្រព័ន្ធរំដោះទឹក** បានស្តារអូរ ប្រឡាយធម្មជាតិចំនួន៦ខ្សែ ប្រវែងសរុប២៧ ១១៧ម. ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធរំដោះទឹកភ្លៀងក្នុងក្រុង

- **ការពង្រីក កែលម្អ និងតភ្ជាប់ឆ្នេរ** បានពង្រីកនិងកែលម្អឆ្នេរសមុទ្រមានការកែលម្អចិញ្ចើមផ្លូវ ការកែលម្អដីចំណីឆ្នេរសមុទ្រ និងការចាក់បំពេញខ្សាច់សជាដើម។ ការកែលម្អឆ្នេរចាប់ពីឆ្នេរសុខាដល់ឆ្នេររាម ប្រវែងសរុប១៨,៨៨គ.ម. បានរៀបចំផ្លូវថ្មើរជើងតាមបណ្តោយឆ្នេរប្រវែង៩,៣២គ.ម. ពីវិថីតេជោ ដល់វិថីឆ្នេរពយជំទាវម៉ៅ ព្រមទាំងបានរៀបចំកែលម្អទីតាំងទេសចរណ៍សំខាន់ៗជាច្រើនទៀត។ ត្រូវបានភ្ជាប់ឆ្នេរសុខានឹងឆ្នេរអូរឈើទាល តាមរយៈការស្ថាបនាវិថីតេជោ តភ្ជាប់ឆ្នេរអូរឈើទាល និងឆ្នេរអូរត្រេះ តាមរយៈការស្ថាបនាវិថីពយអូរឈើទាល តភ្ជាប់ឆ្នេរអូត្រេះ នឹងឆ្នេរពយជំទាវម៉ៅ តាមរយៈការស្ថាបនាស្ពានសែនត្រជាក់ចិត្ត និងការតភ្ជាប់ឆ្នេរពយជំទាវម៉ៅនឹងឆ្នេររាម តាមរយៈការស្ថាបនាមហាវិថីជំទាវម៉ៅ នឹងមហាវិថីរាម

- **ការរៀបចំខ្ទមនិងខ្លោងទ្វារឆ្នេរតាមមាត់សមុទ្រ** បានរៀបចំខ្ទមចំនួន៤៤ នៅឆ្នេរអូរឈើទាល និង៨ នៅឆ្នេរឯករាជ្យសម្រាប់សាធារណជន និងភ្ញៀវទេសចរ និងខ្លោងទ្វារឆ្នេរចំនួន១១ទីតាំង

- **ការរៀបចំស្ថានីយបូមទឹកកខ្វក់** បានរៀបចំស្ថានីយបូមទឹកកខ្វក់ចំនួន៤ទីតាំង មានទីតាំងស្ថានីយទី១ នៅឆ្នេរឯករាជ្យ ទី២ នៅអូរសម្អាតឆ្នេរសុខា ទី៣ នៅអូរសម្អាត និងទី៤ នៅឆ្នេរអូរឈើទាល

- **ការស្តារអូរ ប្រឡាយ** បានស្តារអូរ និងប្រឡាយប្រវែង៦ខ្សែ ដែលមានប្រវែងសរុប២៧ ១១៧ម.

- **ការស្ថាបនាវិថីតេជោ** បានស្ថាបនាវិថីតេជោ ដែលជាវិថីដ៏មានសារៈសំខាន់ និងជាវិថីបើកថ្មីភ្ជាប់ពីផ្លូវលេខ៥០២ ទៅវិថី២ធ្នូ ដោយក្នុងនោះការងារចាក់បំពេញតួផ្លូវចូលសមុទ្រប្រវែង១ ០៣៤ម. ដែលមានជម្រៅជាមធ្យមពី៤ទៅ៦ម. បានប្រើប្រាស់មាឌថ្មប្រមាណជា៣៦៤ ៤៩៦ម.។ វិថីតេជោ ក៏បានស្ថាបនា ជាពិសេស ដែលមានចំណតរថយន្តសាធារណៈ ដែលអាចចតរថយន្តធុនធំទេសចរណ៍១០ចំណត និងរថយន្តធុនតូច១១៤ចំណត។

មិនត្រឹមតែប៉ុណ្ណោះថែមទាំងមានការស្ថាបនារូបបដិមាព្រះស្តន្ធធ្វើពីស្ពាន់មានកម្ពស់៦,១៨ម. និងមានកម្ពស់សរុបរួមទាំងខឿនបដិមា១២,៣៦ម. និងបានស្ថាបនាទីលានតេដោទំហំ២៣ ៥៩៣ម.[២] ជាទីលានសាធារណៈ សម្រាប់លម្ហែកម្សាន្ត និងប្រារព្ធពិធីផ្សេងៗតាមតម្រូវការ។

**២- ការងារអគ្គិសនី**

អគ្គិសនីខេត្តព្រះសីហនុ មានប្រភពផ្គត់ផ្គង់សំខាន់ៗចំនួន៩ ដែលកំពុងដំណើរការដូចជា៖

- អង្គភាពអគ្គិសនីខេត្តព្រះសីហនុ ផ្គត់ផ្គង់ថាមពលដំណើរការដោយម៉ាស៊ីន Wartsila ចំនួន៤មេហ្គាវ៉ាត់
- អនុស្ថានីយស្ទឹងហាវ ផ្គត់ផ្គង់ថាមពលបាន៥០មេហ្គាវ៉ាត់
- អនុស្ថានីយឃ្លាំងលើ ផ្គត់ផ្គង់ថាមពលបាន១៥០មេហ្គាវ៉ាត់
- អនុស្ថានីយតាតៃ ផ្គត់ផ្គង់ថាមពលបាន៦០មេហ្គាវ៉ាត់
- រោងចក្រColben ផ្គត់ផ្គង់ថាមពលបាន១០មេហ្គាវ៉ាត់
- ប្រភពពីខេត្តកំពត ផ្គត់ផ្គង់ថាមពលបាន៧មេហ្គាវ៉ាត់
- អនុស្ថានីយចំការហ្លួង ផ្គត់ផ្គង់ថាមពលបាន៤០មេហ្គាវ៉ាត់
- អនុស្ថានីយបុទមសាគរ ផ្គត់ផ្គង់ថាមពលបាន៥០មេហ្គាវ៉ាត់
- អនុស្ថានីយរាម ផ្គត់ផ្គង់ថាមពលបាន៥០មេហ្គាវ៉ាត់។

ក្នុងឆ្នាំ២០១៧ អគ្គិសនីខេត្តព្រះសីហនុ បានទទួលការផ្គត់ផ្គង់ពីបណ្តាញជាតិប្រមាណ៩០មេហ្គាវ៉ាត់ និងពីផលិតកម្មដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត ប្រមាណ២០មេហ្គាវ៉ាត់ ដែលនាំឱ្យមានការកើនឡើងនូវលទ្ធភាពផ្គត់ផ្គង់របស់ប្រព័ន្ធទៅតំបន់ផ្សេងទៀត និងសេវាករជាច្រើននៅក្នុងខេត្តព្រះសីហនុ។ រយៈពេល៥ឆ្នាំនេះ អគ្គិសនីខេត្តព្រះសីហនុ បានដំណើរប្រតិបត្តិការ ដោយទទួលបានសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| **សមិទ្ធផលសំខាន់ៗ សម្រេចបានរយៈពេល ៥ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១) របស់អគ្គិសនីខេត្តព្រះសីហនុ** | | | | | | |
|---|---|---|---|---|---|---|
| **ទិន្នផលប្រចាំឆ្នាំ** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **គិតជា** |
| ថាមពលផលិត និង ផ្គត់ផ្គង់ពីបណ្តាញជាតិ | ៣១៧ ០៦៩ ២៤៧ | ៥១៤ ៧២៨ ៦១១ | ៨៩៩ ៧១០ ១១៩ | ៧៤៦ ៩១២ ៧៩៧ | ៥៤៧ ៩៣៨ ៥៨៥ | KWh |
| អានុភាពអតិបរមា | ៦៨ | ១២០ | ១៧៥ | ១៥៤ | ១៤៣ | MW |
| ខ្សែបណ្តាញ តង់ស្យុងមធ្យម | ៩៩២,៩៦ | ១ ០២៤,២១ | ១ ១៧២,៩៦ | ១ ២៤៩,៩៦ | ១ ៤៦៥,២១ | Km |
| ខ្សែបណ្តាញ តង់ស្យុងទាប | ១៣២,៣ | ១៦២,៩ | ១៧៨,៥៦ | ២០៣,១៥ | ២៤៦,៩៨ | Km |
| ចំនួនត្រង់ស្វូ | ៣២៧ | ៤៨៦ | ១ ១៣៣ | ១ ៦៨៧ | ១ ៩៩៤ | គ្រឿង |
| **ចំនួនអតិថិជនសរុប** | **២០ ១៥៧** | **២៣ ២៧៧** | **២៩ ៩៦៦** | **៣១ ៦៧៨** | **៣២ ០៤៣** | **អតិថិជន** |

**៣- ការងារបរិស្ថាន**

**+ ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន**

- បរិមាណសំរាមនៅឆ្នាំ២០១៧ ក្រុមហ៊ុនស៊ិនទ្រី ជាអ្នកប្រមូលនិងដឹកជញ្ជូនទៅកាន់ទីលាន។ ក្នុងកំឡុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ បរិមាណសំរាមចន្លោះពី៥៩០តោន/ថ្ងៃ ទៅដល់៩២០តោន/ថ្ងៃ។ ចំណែកក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ បរិមាណសំរាមចន្លោះពី៣០០តោន/ថ្ងៃ ទៅ៥០០តោន/ថ្ងៃ។ ចាប់ពីឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន ក្រុមហ៊ុន ខេអេស ដាប់ប៊ែលយូអឹម ខូអិលធីឌី ជាអ្នកប្រមូលនិងដឹកជញ្ជូនទៅកាន់ទីលាន ស្ថិត

នៅភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់។ ទីលានទុកដាក់សំរាម សំណល់រឹង ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ស្របតាមលក្ខណៈបច្ចេកទេស បទដ្ឋានអនាម័យ បរិស្ថានល្អ មានសមត្ថភាពគ្រប់គ្រងសំណល់រឹងទំហំ១៧ហ.ត. ដំណាក់កាល៥ឆ្នាំដំបូង ក្នុងផ្ទៃដីសរុប៥០ហ.ត. ត្រូវបានសាងសង់ដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រោមការចំណាយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បច្ចុប្បន្នទីលានបានដំណើរការសាងសង់រួចរាល់១០០ភាគរយ និងបានដាក់ឱ្យដំណើរការក្រោមការគ្រប់គ្រងរបស់សហគ្រាសគ្រប់គ្រងទីលានទុកដាក់សំណល់រឹងខេត្តព្រះសីហនុ

- បច្ចុប្បន្ននេះខេត្តព្រះសីហនុ មានឡដុតសំរាមចំនួន៦ទីតាំង ក្នុងនោះនៅក្រុងកោះរ៉ុង៣ទីតាំង ស្រុកស្ទឹងហាវ២ទីតាំង និងព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ១ទីតាំង ដែលឡនីមួយៗ មានសមត្ថភាពដុតសំរាមបានប្រមាណពី២តោន/ថ្ងៃ ទៅដល់៤តោន/ថ្ងៃ។

**+ ការគ្រប់គ្រងសំណល់រាវ**

ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ ក្រុងព្រះសីហនុ មានស្ថានីយចម្រោះទឹកកខ្វក់មួយ ដែលមានសមត្ថភាពសម្អាតទឹកបានត្រឹមតែ៦ ៩០០ម.៣/ថ្ងៃ តែប៉ុណ្ណោះ។ អាងប្រព្រឹត្តិកម្មនេះ មិនអាចសម្អាតទឹកឆ្លើយតបទៅនឹងបរិមាណទឹកកខ្វក់ដែលបានបញ្ចេញនៅក្នុងក្រុងទាំងមូលនោះទេ។

រដ្ឋបាលខេត្តព្រះសីហនុ បានសហការជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា សម្រេចសាងសង់ស្ថានីយប្រព្រឹត្តិកម្មទី១ ទី២ និងទី៣ ក្នុងគោលបំណងដើម្បីបន្សុតទឹកកខ្វក់ទឹកស្អុយ ឱ្យក្លាយជាទឹកដែលស្អាតស្របតាមស្តង់ដាបរិស្ថានមុននឹងបញ្ចេញចោលទៅសមុទ្រ ដោយប្រើបច្ចេកវិទ្យាចុងក្រោយរបស់MABR ដែលត្រូវបានគេទទួលស្គាល់ថាជាបច្ចេកវិទ្យាដែលមានស្ថិរភាព ប្រសិទ្ធភាពខ្ពស់ សន្សំសំចៃថាមពលគ្មានសំឡេងរំខាន និងគ្មានក្លិនប៉ះពាល់ដល់អ្នករស់នៅជុំវិញ ក្នុងនោះ៖

- ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ទី១ មានសមត្ថភាពប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងបរិមាណ៥ ២០០ម.៣ ក្នុងមួយថ្ងៃ ទទួលរងទឹកកខ្វក់ពីតំបន់ទី៣ ដែលមានផ្ទៃដី៣៦៤ហ.ត. និងមានប្រជាជន១៤ ៩៩២នាក់(គិតក្នុងឆ្នាំ២០៣០)

- ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ទី២ មានសមត្ថភាពប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងបរិមាណ៧ ២០០ម.៣ ក្នុងមួយថ្ងៃ ទទួលរងទឹកកខ្វក់ពីតំបន់ទី៤ ដែលមានផ្ទៃដី៤៨៦ហ.ត. និងមានប្រជាជន២៣ ៣៩១នាក់(គិតក្នុងឆ្នាំ២០៣០)

- ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣ មានសមត្ថភាពប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងបរិមាណ២០ ០០០ម.៣ ក្នុងមួយថ្ងៃ ទទួលរងទឹកកខ្វក់ពីតំបន់ទី៥ និងតំបន់ទី៦ ដែលមានផ្ទៃដី២ ៦៩០ហ.ត. និងមានប្រជាជន១៣៣ ៨១១នាក់(គិតក្នុងឆ្នាំ២០៣០)

- សាងសង់ស្ថានីយបូមដោយគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរ៣ទីតាំង និងមន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្ត ចំនួន៤ទីតាំង។

**+ ការងារគ្រប់គ្រងការបំពុល**

- ចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ បានចុះត្រួតពិនិត្យការគ្រប់គ្រងបរិស្ថាន តាមរោងចក្រសហគ្រាស ក្រុមហ៊ុន សណ្ឋាគារ ផ្ទះសំណាក់ ដោយតម្រូវឱ្យម្ចាស់ប្រភពបំពុលទាំងនោះ រៀបចំអាងប្រព្រឹត្តិកម្មសម្អាតទឹកកខ្វក់ ស្របតាមស្តង់ដាដែលក្រសួងបរិស្ថានបានកំណត់ មុននឹងបញ្ចេញទៅក្នុងប្រព័ន្ធលូ ឬប្រភពទឹកសាធារណៈ។

- សហការជាមួយនាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង នៃក្រសួងបរិស្ថាន ចុះត្រួតពិនិត្យតាមដានគុណភាពខ្យល់ តាមរោងចក្រ សហគ្រាសជាប្រចាំ ក្នុងគោលបំណងកាត់បន្ថយការបំពុលខ្យល់ ក្នុងនោះក្រសួងបរិស្ថានបាននឹងកំពុងតម្លើងស្ថានីយពិនិត្យគុណភាពខ្យល់ ស្ថិតនៅសាលាបឋមសិក្សា **ហ៊ុន សែន** ក្រុង។

- ក្នុងរយៈពេល៥ឆ្នាំ ក្រុមការងារមន្ទីរបរិស្ថាន បានធ្វើការផាកពិន័យអន្តរការណ៍ ដល់ម្ចាស់ទីតាំងប្រភពបំពុលទាំងឡាយណា ដែលមិនអនុវត្តន៍តាមការណែនាំ និងបង្កឱ្យមានការបំពុលបរិស្ថាន តាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**៤- ការងារសាងសង់អគារចាប់ពី៥ជាន់ឡើង(សណ្ឋាគារ ខុនដូ ផ្ទះសំណាក់..)**

| ចំនួនជាន់ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (គិតត្រឹមខែវិច្ឆិកា) |
|---|---|---|---|---|
| -ពី៥ ទៅ៩ជាន់ | ៣៩គម្រោង | ១០៨គម្រោង | ៦៦គម្រោង | ២៩គម្រោង |
| -ពី១០ ទៅ១៩ជាន់ | ២៥គម្រោង | ១២៩គម្រោង | ៥៥គម្រោង | ១៦គម្រោង |
| -ពី២០ ទៅ២៩ជាន់ | ៦គម្រោង | ៣៧គម្រោង | ១៧គម្រោង | ២គម្រោង |
| -ពី៣០ ទៅ៣៩ជាន់ | ៣គម្រោង | ១៦គម្រោង | ៩គម្រោង | គ្មាន |
| -ពី៤០ ឡើងទៅ | ២គម្រោង | ៣គម្រោង | ១គម្រោង | គ្មាន |
| **សរុបក្នុងឆ្នាំ** | **៧៥គម្រោង** | **២៩៣គម្រោង** | **១៤៨គម្រោង** | **៤៧គម្រោង** |

## ២.៦- ខេត្តកោះកុង

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកោះកុង សម្រេចបាន៖**

ខេត្តកោះកុង មានទីតាំងស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ចម្ងាយ២៩០គ.ម. ពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងលិចនិងខាងត្បូងជាប់នឹងឈូងសមុទ្រថៃ និងប្រទេសថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ និងមានផ្ទៃដីសរុប១០ ០៤៥,៥៨គ.ម.[២] ចែកជា០១ក្រុង ៦ស្រុក ត្រូវជា២៦ឃុំ ៣សង្កាត់ និង១១៩ភូមិ។ ខេត្តមានគ្រួសារសរុបចំនួន៣២ ០០១គ្រួសារ មានប្រជាជនសរុប ១៤១ ៨៣៦នាក់(ស្រី៧០ ៧៣១នាក់) មានប្រជាជនចម្រុះជាតិសាសន៍ដូចជាខ្មែរ ចិន ថៃ ចាម និងវៀតណាម។

**១- វិស័យសាធារណការ និងដឹកជញ្ជូន អភិវឌ្ឍន៍ជនបទ និងធនធានទឹក និងឧតុនិយម**

**- គម្រោងរបស់រដ្ឋបាលខេត្ត**

០គម្រោងសាងសង់ផ្លូវបេតុងអាមេចំនួន៧៤ខ្សែ ប្រវែង២៩,៥១គ.ម.

០គម្រោងសាងសង់ផ្លូវក្រាលកៅស៊ូអាសេចំនួន៨ខ្សែ ប្រវែង១០,០៧គ.ម.

០គម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហមចំនួន៦ខ្សែ ប្រវែង៧,៥០គ.ម.

០ថែទាំផ្លូវក្រាលកៅស៊ូ DBSTចំនួន២៨ខ្សែ ប្រវែង៣៩៨,០៥គ.ម.

០ថែទាំផ្លូវក្រាលក្រួសក្រហមចំនួន៣៣ខ្សែ ប្រវែង១៤៧,១២គ.ម.

០គម្រោងសាងសង់លូដោះទឹកចំនួន១១ខ្សែ ប្រវែង៣,៧៩គ.ម.

០គម្រោងប្រឡាយ និងស្តារលូដោះទឹកចំនួន៣ខ្សែ ប្រវែង៣,៩៥គ.ម.

០ស្ថាបនាលូកាត់ផ្លូវចំនួន៨កន្លែង

០សាងសង់ស្ពានចំនួន១កន្លែង

០សាងសង់អណ្តូងស្នប់ចំនួន២៩កន្លែង

០សាងសង់ស្រះចំនួន២កន្លែង

○ទំនប់ការពារទឹកប្រៃចំនួន២៩ខ្សែ ប្រវែង៦៩,៤២គ.ម.

○សាងសង់អគាររដ្ឋបាលខេត្តចំនួន១កន្លែង

○ជួសជុលអគារសាលមហោស្រពចំនួន១កន្លែង

○សាងសង់អគារការិយាល័យច្រកចេញចូលតែមួយចំនួន៣កន្លែង

○សាងសង់អគាររដ្ឋបាលឃុំចំនួន៤កន្លែង

○ស្ថាបនាសួនច្បារចំនួន៣កន្លែង ប្រវែង១,៣គ.ម.។

**- រដ្ឋបាលក្រុង ស្រុក**

រដ្ឋបាលក្រុង ស្រុក បានទទួលថវិកាពីរាជរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងអភិវឌ្ឍន៍របស់ខ្លួន និងក្រោមការគាំទ្រ និងសម្របសម្រួលរបស់រដ្ឋបាលខេត្ត រួមមាន៖

○សាងសង់ផ្លូវបេតុងអាមេចំនួន៤២ខ្សែ ប្រវែង៨,៧៣គ.ម.

○សាងសង់ផ្លូវក្រាលក្រួសក្រហមចំនួន៥ខ្សែ ប្រវែង១៤,៩៤គ.ម.

○សាងសង់លូកាត់ផ្លូវចំនួន៨កន្លែង

○សាងសង់លូដោះទឹកចំនួន៨០០ម.

○សាងសង់ទំនប់បង្វៀរ២កន្លែង។

**- រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលខេត្តបានគាំទ្រ និងសម្របសម្រួលលើការអនុវត្តគម្រោងរបស់រដ្ឋបាលឃុំ សង្កាត់សម្រាប់រយៈពេល៥ឆ្នាំ រួមមាន៖

○សាងសង់ផ្លូវបេតុងអាមេចំនួន៨២ខ្សែ ប្រវែង២១,៧៤គ.ម.

○សាងសង់ផ្លូវក្រាលគ្រួសក្រហមចំនួន៦៥ខ្សែ ប្រវែង១២៩,០៤គ.ម.

○សាងសង់លូកាត់ផ្លូវចំនួន៣៥កន្លែង

○ស្តារប្រឡាយចំនួន២ខ្សែ ប្រវែង១ ៣៧៧ម.

○សាងសង់លូដោះទឹកចំនួន៥ខ្សែ ប្រវែង៦០៩ម.

○សាងសង់សំណង់ការពារការហូរច្រោះចំនួន២កន្លែង

○សាងសង់ទំនប់បង្វៀរចំនួន២កន្លែង

○សាងសង់អណ្តូងចំនួន២៥កន្លែង

○សាងសងស្រះចំនួន៩កន្លែង

○សាងសង់ស្ពាន១កន្លែង

○សាងសង់កំពង់ផែចំនួន១កន្លែង

○សាងសង់សាលាមត្តេយ្យសហគមន៍ចំនួន១កន្លែង។

- ផ្លូវជាតិលេខ៤៨ និងស្ពានធំៗចំនួន៤ ជាសរសៃឈាមដ៏សំខាន់តភ្ជាប់ពីតំបន់នានាទូទាំងប្រទេស

- ស្ពានកោះកុង ត្រូវបានសាងសង់លើផ្ទៃសមុទ្រ ចាប់ពីចំណុចសួនច្បារសាធារណៈនៃក្រុងខេមរភូមិន្ទតភ្ជាប់ស្រុកមណ្ឌលសីមា មានប្រវែង១ ៩០០ម.

- ផ្លូវក្រុងលេខ៩០០ ត្រូវបានអ៊ុតកៅស៊ូAC ក្នុងក្រុងខេមភូមិន្ទ មានប្រវែង២ ២២០ម.

- ផ្លូវក្រុងលេខ៩៨៩ ត្រូវបានអ៊ុតកៅស៊ូAC ក្នុងក្រុងខេមរភូមិន្ទ មានប្រវែង១ ៥០០ម.

- វិថីព្រឹទ្ធាចារ្យ **សាយ ភូថង** ត្រូវបានកសាងឡើងពីចំណុចផ្លូវបំបែកផ្លូវជាតិលេខ៤៨ ស្ថិតក្នុងឃុំ អណ្តូងទឹក ស្រុកបូទុមសាគរ ឆ្ពោះទៅក្រុមហ៊ុន យូញៀន (UNION DEVELOPMENT Co., Ltd) ស្ថិតក្នុងឃុំកោះកុង ស្រុកគិរីសាគរ មានប្រវែង៥៥គ.ម.

- ផ្លូវក្រាលក្រួសក្រហមបំបែកពីផ្លូវជាតិលេខ៤៨ ស្ថិតក្នុងឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង មានប្រវែង២៣ ០០០ម.

- ផ្លូវជាតិលេខ១០ ពីក្រុងខេមរភូមិន្ទ តភ្ជាប់ទៅអូរសោម វាលវែង(ខេត្តពោធិ៍សាត់) និងសំឡូត ខេត្តបាត់ដំបង មានប្រវែង១៩៧គ.ម.

- សាងសង់ស្ពានបេតុង ប្រវែង៣២ម. ទទឹង៨ម. ស្ថិតក្នុងភូមិចម្លងគោ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង

- ស្ថាបនាលូប្រអប់ចំនួន២កន្លែង ប្រវែង៣២ម. ស្ថិតនៅលើផ្លូវខេត្តលេខ១៤៨៥អា ភូមិចំលងគោ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង

- កែលម្អផ្លូវពីក្រួសក្រហម មកជាផ្លូវបេតុងមានប្រវែង៤៥៣ម. ទទឹង៥ម. និងកម្រាស់០,១៥ម. ក្នុងឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង

- កែលម្អផ្លូវពីក្រួសក្រហម មកជាផ្លូវបេតុងមានប្រវែង៧៥០ម. ទទឹង៥ម. និងកម្រាស់០.១៥ម. ក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង

- ថែទាំផ្លូវជាតិនិងផ្លូវខេត្តក្រាលកៅស៊ូ DBST ចំនួន៣កំណាត់ ប្រវែងសរុប១៦៩,១៤គ.ម.

- ថែទាំផ្លូវជាតិនិងផ្លូវខេត្តក្រាលក្រួសក្រហមចំនួន៣កំណាត់ ប្រវែងសរុប៤៤,១០គ.ម.

- ថែទាំផ្លូវក្នុងក្រុងដោយក្រាលកៅស៊ូ DBST ចំនួន៧កំណាត់ ប្រវែងសរុប១៧ ១៨៧គ.ម.

- ថែទាំផ្លូវក្នុងក្រុងខេមរភូមិន្ទចំនួន១២ខ្សែ ប្រវែងសរុប២៥,០៤គ.ម.

- ថែទាំស្ពានបេតុងប្រវែងសរុប២ ៥៦៥ម.

- ថែទាំស្ពានបេឡេត៍ចំនួន២កន្លែង ប្រវែងសរុប១២២ម.

- ថែទាំលូគ្រប់ប្រភេទប្រវែងសរុប២ ០៣៨ម.

- ថែទាំប្រឡាយប្រវែងសរុប១៧ ៦២៨ម.

- ជួសជុលផ្លូវជាតិលេខ៤៨ មានប្រវែង៦,៧០គ.ម. ទទឹង១០ម. ដោយក្រាលកៅស៊ូ DBST ព្រមទាំងប្រឡាយ៤៥៥ម.

- ចុះបញ្ជីយានយន្តចំនួន៣ ៦៧៧គ្រឿង

- ផ្ទេរកម្មសិទ្ធិយានយន្តក្នុង និងក្រៅខេត្ត បានចំនួន៦២៣គ្រឿង

- ថែទាំផ្លូវជនបទជាលក្ខណៈខួប ចំនួន១២ខ្សែ ប្រវែងសរុប៥៨ ៥៥០ម.

- ជួសជុលផ្លូវជនបទជាលក្ខណៈបន្ទាន់ចំនួន៦ខ្សែ ប្រវែង១៥ ៧០០ម.

- ថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ បានចំនួន៤២ខ្សែ ប្រវែងសរុប១៧៩ ១១០ម.

- ដាំកូនឈើតាមសងខាងផ្លូវជនបទ បានចំនួន២០ ៦៥០ដើម

- សាងសង់លូមូលបានចំនួន៤កន្លែង និងជញ្ជាំងទប់ទឹក១កន្លែង

- ជីកស្រះសហគមន៍ បានចំនួន៣កន្លែង ទំហំ(៥០ម. X ៣០ម. X ៣ម.)
- ស្តារស្រះសហគមន៍ បានចំនួន១កន្លែង ទំហំ(៥០ម. X ៣០ម. X ៣ម.)
- សាងសង់អណ្តូងស្នប់ Afridev បានចំនួន២៤អណ្តូង
- ជួសជុលទំនប់ការពារទឹកប្រៃជីត្រេះ ប្រវែង៧ ៨០០ម. ផ្ទៃដីស្រោចស្រព៥០៨ហ.ត.
- ជួសជុលទំនប់ការពារទឹកប្រៃដងពែង១ ប្រវែង៤ ១០០ម. ផ្ទៃដីស្រោចស្រព៣៥១ហ.ត.
- ជួសជុលទំនប់ការពារទឹកប្រៃតាំកន់ ប្រវែង៦ ៦៥០ម. ផ្ទៃដីស្រោចស្រព៥៤២ហ.ត.
- ជួសជុលទំនប់ការពារទឹកប្រៃត្រៀក ប្រវែង៤ ៦០០ម. ផ្ទៃដីស្រោចស្រព១ ៦៥០ហ.ត.។

**២- វិស័យទេសចរណ៍**

- មានតំបន់វិស្សមកាល តំបន់អេកូទេសចរណ៍ធម្មជាតិ ព្រៃកោងកាង ទឹកធ្លាក់ តំបន់ឆ្នេរ តំបន់ផ្កាថ្ម និងតំបន់កោះមួយចំនួន និងមានសេវាកម្មទេសចរណ៍ ដូចជាសណ្ឋាគារ១២កន្លែង(ស្មើនឹង៤៤០បន្ទប់) ផ្ទះភ្ញៀវ ១១២កន្លែង(ស្មើនឹង១ ២២០បន្ទប់) ភោជនីយដ្ឋាន អាហារដ្ឋាន១៤៥កន្លែង(ស្មើនឹង៥ ៣៣១កៅអី) សហគមន៍ទេសចរណ៍៥កន្លែង រមណីយដ្ឋានទេសចរណ៍៤កន្លែង(ស្មើនឹង១៤៤បន្ទប់) ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក ៣កន្លែង ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវគោក២កន្លែង កីឡាមុជទឹក១កន្លែង
- មានឆ្នេរសមុទ្រប្រវែងប្រមាណ២១៥គ.ម. នៃប្រវែងឆ្នេរសមុទ្រសរុប៤៤០គ.ម. នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានជាប់ជាសមាជិកក្លឹបឆ្នេរសមុទ្រស្អាតបំផុតនៅលើពិភពលោក និងត្រូវបានប្រសិទ្ធនាមថាតារារះនាទិសនិរតី ក្នុងនោះ ឆ្នេរតារាសាគរ ទទួលបានចំណាត់ថ្នាក់លេខ២ និងឆ្នេរចាំយាម ទទួលបានចំណាត់ថ្នាក់លេខ៣ នៃជ័យលាភីប្រឡងឆ្នេរស្អាត ខេត្តតំបន់មាត់សមុទ្រ
- មានតំបន់អេកូទេសចរណ៍ធម្មជាតិព្រៃកោងកាងទំហំសរុប៦២ ០០០ហ.ត. នៅទូទាំងខេត្ត និងតំបន់អេកូទេសចរណ៍ធម្មជាតិ នៅតាមបណ្តាក្រុង ស្រុកមួយចំនួនទៀត ដូចជានៅតាមដងផ្លូវជាតិលេខ៤៨ នៅជីផាត តំបន់អារ៉ែង ជាដើម។ល។
- មានឡដុតសំរាម (សហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប)
- មានអគារផលិតផលិតផលសហគមន៍(មានបំពាក់សម្ភារៈឧបករណ៍សម្រាប់ផលិត ផលិតផលសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប)
- មានមណ្ឌលព័ត៌មានសហគមន៍(សហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប)
- មានកំពង់ផែខ្នាតតូចសម្រាប់ភ្ញៀវទេសចរចុះទូក នៅសហគមន៍អេកូទេសចរណ៍តាតៃក្រោម
- បានធ្វើប៉ាណូតំបន់សក្តានុពលទេសចរណ៍ចំនួន៣ផ្ទាំង
- ដាក់ស្លាកសញ្ញាចង្អុលបង្ហាញគោលដៅទេសចរណ៍ចំនួន២១ស្លាក(៦០ស.ម. x ១២០ស.ម.)
- ស្លាកចង្អុលបង្ហាញមណ្ឌលព័ត៌មានទេសចរណ៍ចំនួន៥ស្លាក(៦០ស.ម. x ១២០ស.ម.)
- ស្លាកសញ្ញាបង្ហាញអំពីតំបន់ទាក់ទាញក្នុងសហគមន៍ទេសចរណ៍៤ស្លាក(១០០ស.ម. x ១២០ស.ម.)
- បដាស័ង្កសីស្តីពីតំបន់សក្តានុពលនៃសហគមន៍ទេសចរណ៍ចំនួន២ស្លាក មុខសងខាង(១២០ស.ម. x ៨០ស.ម.)
- ថ្មម៉ាបមុខមណ្ឌលព័ត៌មានចំនួន១ស្លាក(១ម. x ២ម.)
- ចែកធុងសំរាមទូទាំងខេត្តកោះកុងចំនួន១១០ធុង(៩០ស.ម. x ៦០ស.ម.)

- ស្លាកសញ្ញាប្រុងប្រយ័ត្ន និងគ្រោះថ្នាក់ដាក់តាមតំបន់គោលដៅទេសចរណ៍ ដែលងាយរងគ្រោះ ចំនួន ២០ស្លាក (៣០ស.ម x ៦០ស.ម.)

- រូបភាពមានស៊ុមផ្សព្វផ្សាយពីតំបន់សក្តានុពលទេសចរណ៍ទូទាំងខេត្តកោះកុង ដាក់នៅតាមតំបន់គោលដៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ ចំនួន២០០រូប ខ្នាត A3

- ទង់សញ្ញាសុវត្ថិភាពដាក់នៅឆ្នេរប៉ាក់ខ្លង ចំនួន១៥ទង់

- ប៉ាណូផែនទីទេសចរណ៍ និងតំបន់សក្តានុពលទេសចរណ៍ចំនួន៦ផ្ទាំង

- ដាក់ស្លាកសញ្ញាអប់រំការប្រើប្រាស់គ្រឿងញៀន និងជួញដូរមនុស្សក្នុងវិស័យទេសចរណ៍ចំនួន១៥ស្លាក (៨០ស.ម. x ១២០ស.ម.)

- ដាក់ស្លាកសញ្ញាអប់រំការគ្រប់គ្រងសំណល់រឹង រាវមានចំនួន៧៥ស្លាក

- បានធ្វើ sticker ផ្សព្វផ្សាយអប់រំស្តីពីការចោលសំរាមក្នុងធុងបានចំនួន៤០០សន្លឹក(ខ្នាត A3)

- បានធ្វើ video ផ្សព្វផ្សាយសក្តានុពលទេសចរណ៍ទូទាំងខេត្តចំនួន១(៤នាទី)

- បានធ្វើ និងបោះពុម្ពសៀវភៅផ្នត់ថ្មី ស្តីពីសក្តានុពលទេសចរណ៍ទូទាំងខេត្តចំនួន១៦ ៥០០ច្បាប់

- បានចងក្រង និងបោះពុម្ពសៀវភៅប្រវត្តិ និងសក្តានុពលទេសចរណ៍ខេត្តចំនួន១០០ក្បាល។

**៣- វិស័យធនធានរ៉ែនិងថាមពល**

បច្ចុប្បន្នវិស័យរ៉ែ និងថាមពលក្នុងខេត្ត មានវារីអគ្គិសនីចំនួន៣កន្លែងធំៗ និងមានថាមពលសរុបចំនួន ៦០២មេហ្គាវ៉ាត់ និងផ្ទាំងសូឡានៅតាមតំបន់មួយចំនួន។ វារីអគ្គិសនីទាំង៣ទីតាំងមាន៖

១- **វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម** មានអនុភាព៣៣៨មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន Huadian Lower Stung Russei Chrum Hydro-Electric Project (Cambodia) Company នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

២- **វារីអគ្គិសនីរីម្យេ៣** មានអនុភាព១៨មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន CETIC International Hydropower Development Co., Ltd នៅឃុំជងពែង ស្រុកស្រែអំបិល ខេត្តកោះកុង។

៣- **វារីអគ្គិសនីស្ទឹងតាតៃ** មានអនុភាព២៤៦មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន Cambodia Tatay Hydropower Limited (CTHL) នៅឃុំឫស្សីជ្រុំ និងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង។

## ២.៧- ខេត្តកែប

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកែបសម្រេចបាន៖

ខេត្តកែបស្ថិតនៅភាគនិរតីនិងមានចម្ងាយប្រមាណ១៧៥គ.ម. ពីរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា តាមផ្លូវលេខជាតិលេខ៣និងលេខ៣៣ និងមានផ្លូវរថភ្លើងឆ្លងកាត់១ខ្សែ។ ខេត្តមានព្រំប្រទល់ ខាងកើត ខាងជើង ខាងលិច ជាប់នឹងខេត្តកំពត និងខាងត្បូងជាប់ដែនទឹកប្រវត្តិសាស្ត្រកម្ពុជា វៀតណាម។ ទំហំផ្ទៃដីគោកសរុប១៨៧,២៤គ.ម.² កោះចំនួន១២ ថ្មប៉ប្រះទឹក១កន្លែង និងមានផ្ទៃសមុទ្រចំនួនក្រុង១ និងស្រុក១ មាន៥ឃុំសង្កាត់ ស្មើនឹង១៨ភូមិ ប្រជាពលរដ្ឋចំនួន៩ ៦៤៥គ្រួសារ មនុស្សសរុប៤២ ២៣១នាក់(ស្រី២១ ៧៣១នាក់)។ គិតជាដង់ស៊ីតេប្រជាពលរដ្ឋស្មើនឹង២២៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ មុខរបរចម្បងរបស់ប្រជាពលរដ្ឋគឺធ្វើស្រែចំការ នេសាទសមុទ្រ ផលិតអំបិល និងលក់ដូរបម្រើសេវាកម្មទេសចរណ៍។

### ១- ការកែលម្អសោភ័ណភាពខេត្ត

បានបន្តជំរុញយ៉ាងសកម្មក្នុងការកែលម្អសោភ័ណភាពតាមដងផ្លូវ គេហដ្ឋាន ទីសាធារណៈ រមណីយដ្ឋានទេសចរណ៍ ឆ្នេរកម្សាន្ត និងសាងសង់កែលម្អនូវសមិទ្ធផលសំខាន់ៗ ការសាងសង់អគាររដ្ឋបាល សួនច្បារ ដាក់បង្គោលភ្លើងបំភ្លឺតាមផ្លូវសាធារណៈ និងទីប្រជុំជន ដាក់រូបសំណាកថ្មីៗ ការបង្កើតកន្លែងហាត់ប្រាណ ស្ថាបនាកែលម្អផ្លូវក្រាលកៅស៊ូAC ផ្លូវកៅស៊ូDBST និងសំណង់សិល្បការចាំបាច់មួយចំនួន។ល។ ព្រមជាមួយនេះ យើងបានបណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ច អនាម័យម្ហូបអាហារជូនដល់ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ បង់ហ្គាឡូរីសត ភោជនីយដ្ឋាន អាហារដ្ឋាន និងប្រតិបត្តិករទេសចរណ៍ ការរៀបចំទិវាអនាម័យបរិស្ថាន និងបានដឹកនាំមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ សិស្ស និស្សិត និងបំផុសប្រជាពលរដ្ឋ អាជីវករធ្វើអនាម័យបរិស្ថាន ការដាំដើមឈើ ដើម្បីបំពេញសម្បទាទេសចរណ៍ ស័ក្តិសមជាទីក្រុងទេសចរណ៍ធម្មជាតិ ដែលមានបរិស្ថានបៃតងគ្រប់ទីកន្លែង និងគ្រប់រដូវកាល។

#### ១.១- គម្រោងកែលម្អសោភ័ណភាពទាំងនោះរួមមាន៖

- សាងសង់របងសាលាខេត្ត បញ្ជរព័ត៌មាន និងប៉ុស្តិ៍យាមមុខសាលាខេត្ត
- គម្រោងរៀបខឿនប្រាំងសមុទ្រអំពីថ្មភ្នំ និងចាក់ខ្សាច់ពង្រីកឆ្នេរសមុទ្រ
- គម្រោងសាងសង់ស្តូបតម្កល់រូបសំណាកព្រះបាទជ័យវរ្ម័នទី៧ ចំនួន២ទីតាំង
- គម្រោងដាំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ
- គម្រោងសាងសង់សាលប្រជុំស្តង់ដា១ខ្នង
- គម្រោងសាងសង់អគារការិយាល័យច្រកចេញចូលតែមួយសាលាស្រុកដំណាក់ចង្អើរ
- គម្រោងជួសជុលអគារការិយាល័យច្រកចេញចូលតែមួយសាលាខេត្តកែប និងបន្ទប់រង់ចាំ
- គម្រោងតបណ្តាញអគ្គិសនី និងដាក់ដងគោមភ្លើង អំពូលភ្លើងបំភ្លឺផ្លូវសាធារណៈ
- គម្រោងសាងសង់រូបសំណាកមច្ឆានុ(សួន)នៅក្នុងសមុទ្រ(ជំហានទី១)
- គម្រោងដាក់បង្គោលភ្លើង បំភ្លឺផ្លូវសាធារណៈ៦៩បង្គោល ដងគោមអំពូលភ្លើងចំនួន២១៣ដងគោម
- សាងសង់ឈាបនដ្ឋាន១កន្លែង ទីតាំងស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប។

#### ១.២- វិស័យគមនាគមន៍

បានសាងសង់ផ្លូវលំដីសចំនួន២៥ខ្សែ ប្រវែង៤៤ ០៦៦ម. ផ្លូវលំក្រួសក្រហមចំនួន១១ខ្សែ ប្រវែង២០ ៦៧៥ម. សាងសង់ផ្លូវបេតុងចំនួន៧ខ្សែ ប្រវែង២ ២៣២ម. ជួសជុលផ្លូវបេតុងចំនួន៨ខ្សែ ប្រវែង៨ ៥០៤ម. សាងសង់ផ្លូវDBST ចំនួន៣៥ខ្សែ ប្រវែង២៩ ៦៩៤ម. ផ្លូវបេតុងAC ចំនួន១៥ខ្សែ ប្រវែង៥ ៤៦៥ម. ជួសជុល ថែទាំផ្លូវលក្ខណៈខួប ចំនួន២១ខ្សែ ប្រវែង៦៩ ៨៨០ម. ជួសជុល ថែទាំផ្លូវលក្ខណៈប្រចាំចំនួន៥៨ខ្សែ ប្រវែង១៧០ ០១០ម. និងជួសជុលផ្លូវអន្តរាគមន៍បន្ទាន់ ចំនួន៩ខ្សែ ប្រវែង១៦ ១០០ម. ដាក់លូ១៤កន្លែង បានសាងសង់កំពង់ផែទេសចរណ៍(ផែកោះទន្សាយ) ១កន្លែងទំហំ៣ ៤៧០ម.[២] ដំណើរការសាងសង់បាន៨០% នៅពេលសាងសង់រួចរាល់ កំពង់ផែអាចឱ្យនាវាប្រភេទ១ និងប្រភេទ២ ចូលចតបាន។

## ២- វិស័យទេសចរណ៍៖

| ល.រ. | បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប៥ឆ្នាំ |
|---|---|---|---|---|---|---|---|
| ក- ការងារឧស្សាហកម្មទេសចរណ៍ | | | | | | | |
| ១ | សណ្ឋាគារ | ១០កន្លែង | ១២កន្លែង | ១៣កន្លែង | ១៤កន្លែង | ១៥កន្លែង | ១៥កន្លែង |
| ២ | ផ្ទះសំណាក់ | ៥៦កន្លែង | ៦១កន្លែង | ៥៧កន្លែង | ៥៧កន្លែង | ៥៩កន្លែង | ៥៩កន្លែង |
| ៣ | បឹងហ្គាឡូរីសែត | ៣១កន្លែង | ២៥កន្លែង | ២២កន្លែង | ២៧កន្លែង | ២៧កន្លែង | ២៧កន្លែង |
| ៤ | អាហារដ្ឋាន និង ភោជនីយដ្ឋាន | ៣៦កន្លែង | ៣៦កន្លែង | ៣០កន្លែង | ៣៩កន្លែង | ៣៩កន្លែង | ៣៩កន្លែង |
| ៥ | ស្ប៉ាសូណា និងម៉ាស្សា | ៨កន្លែង | ៤កន្លែង | ៤កន្លែង | ៤កន្លែង | ៣កន្លែង | ៣កន្លែង |
| ៦ | ខារ៉ាអូខេ | ១៣កន្លែង | ៨កន្លែង | ៨កន្លែង | ៨កន្លែង | ៦កន្លែង | ៦កន្លែង |
| ៧ | ក្លិបកម្សាន្ត | ១កន្លែង | ១កន្លែង | ០ | ០ | ០ | ០ |
| ៨ | ខ្សុស | ៣៧កន្លែង | ៣៩កន្លែង | ៤៦កន្លែង | ៤៦កន្លែង | ៤៦កន្លែង | ៤៦កន្លែង |
| ៩ | ម៉ូតូរ៉ឺម៉កដឹកភ្ញៀវ | ៥៨គ្រឿង | ៥៨គ្រឿង | ៥៨គ្រឿង | ៥៨គ្រឿង | ៥៨គ្រឿង | ៥៨គ្រឿង |
| ១០ | មណ្ឌលព័ត៌មាន ទេសចរណ៍ | ១ខ្នង | ១ខ្នង | ២ខ្នង | ២ខ្នង | ៣ខ្នង | ៣ខ្នង |
| ១១ | ទូកដឹកភ្ញៀវទេសចរ | ១៦គ្រឿង | ១៦គ្រឿង | ១៦គ្រឿង | ១៦គ្រឿង | ១៦គ្រឿង | ១៦គ្រឿង |
| ១២ | ភ្នាក់ងារទេសចរ | ៦កន្លែង | ៦កន្លែង | ៦កន្លែង | | | ៦កន្លែង |
| ១៤ | បានផ្តល់អាជ្ញាបណ្ណ ទេសចរណ៍ | ៦៩ អាជ្ញាបណ្ណ | ១០៨ អាជ្ញាបណ្ណ | ៩៨ អាជ្ញាបណ្ណ | ៨៤ អាជ្ញាបណ្ណ | ៨១ អាជ្ញាបណ្ណ | ៤៤០ អាជ្ញាបណ្ណ |

| ខ- ការងារប្រឡងប្រណាំងនិងការទទួលពានរង្វាន់ | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ. | បរិយាយ | ឆ្នាំ | | | | | ផ្សេងៗ |
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១ | ពានរង្វាន់ទីក្រុងនិរន្តរភាព បរិស្ថានអាស៊ាន | √ | | | | | ទទួលនៅប្រទេស ប្រ៊ុយណេ |
| ២ | ជ័យលាភី«ទីក្រុងទេស ចរណ៍ស្អាតអាស៊ាន» | | √ | | | | ទទួលនៅទីក្រុង ឈាងម៉ៃប្រទេសថៃ |
| ៣ | ពានរង្វាន់ សណ្ឋាគារ បៃតងអាស៊ាន | | √ | | | | ទទួលនៅទីក្រុង ឈាងម៉ៃប្រទេសថៃ |
| ៤ | ពានរង្វាន់ទេសចរណ៍ប្រកប ដោយនិរន្តរភាពអាស៊ាន | | √ | | | | ទទួលនៅទីក្រុង ឈាងម៉ៃប្រទេសថៃ |
| ៥ | ជ័យលាភីផ្កាវិជ្ជលពាទង លើកទី២ | | √ | | | | ទទួលនៅរាជធានី ភ្នំពេញ |
| ៦ | ជ័យលាភី ឆ្នេរខ្សាច់ស្អាត | | √ | | | | ទទួលនៅរាជធានី ភ្នំពេញ |
| ៧ | ជ័យលាភីទីក្រុងដែល មានពិធីបុណ្យឆ្លងឆ្នាំ សកលល្អជាងគេប្រចាំឆ្នាំ «២០១៨-២០១៩» | | √ | √ | | | ទទួលនៅរាជធានី ភ្នំពេញ |
| ៨ | ជ័យលាភីស្នាមញញឹម៣ និងស្នាមញញឹម២ | | √ | | | | ទទួលនៅរាជធានី ភ្នំពេញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩ | រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ «ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍»លើកទី៣ | | | √ | | | ទទួលនៅរាជធានីភ្នំពេញ |
| ១០ | ពានរង្វាន់ខ្យល់ស្អាតទីក្រុងនិរន្តរភាពអាស៊ាន | | | | | √ | ទទួលនៅប្រទេសឥណ្ឌូណេស៊ី |

**៣- វិស័យធនធានធម្មជាតិនិងបរិស្ថាន**

ខេត្តមានព្រៃកោងកាងចំនួន៣កន្លែង មានផ្ទៃក្រឡា១ ០០៥ហ.ត. ស្មៅសមុទ្រ៣ ០៩៥ហ.ត. ផ្កាថ្ម ៥២,៥ហ.ត. និងមានធនធានធម្មជាតិមានត្រីផ្សោត ជ្រូកទឹក អណ្តើកសមុទ្រ ត្រីសេះ ក្តាមសេះដែលមានរសជាតិឆ្ងាញ់ ក្តាមថ្ម និងឧទ្យានជាតិកែបមានទំហំ១ ៩៥២ហ.ត.។ ធនធានធម្មជាតិទាំងនេះ ត្រូវបានអភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាព។ បានបោះបង្គោលព្រំឧទ្យានជាតិកែប ចំនួន៩៣បង្គោល ដាំផ្កាធ្វើសួនច្បារគំរូមុខសាលាក្រុង និងការថែទាំ៦០០ម. ធ្វើអាងប្រព្រឹត្តកម្មសាធារណៈ៤គម្រោង បំពាក់ឡដុតសំរាមសំណល់រឹងវេជ្ជសាស្ត្រ និងសំណល់គ្រោះថ្នាក់ផ្សេងៗ១គម្រោង ដាំកូនឈើបាន៥១ ០៨៦ដើម ដាក់ធុងសំរាមនៅតាមទីសាធារណៈ និងសួនច្បារនានាក្នុងខេត្ត៥៣៤ធុង ដាក់ស្លាកប៉ាណូអប់រំផ្សព្វផ្សាយបរិស្ថាន៩៥ស្លាក។

## ២.៨- ខេត្តកំពត

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកំពត សម្រេចបាន៖**

ខេត្តកំពត ស្ថិតនៅប៉ែកនិរតីជាប់នឹងតំបន់ឆ្នេរសមុទ្រកម្ពុជា មានចម្ងាយ១៤៨គ.ម. ពីរាជធានីភ្នំពេញ ភ្ជាប់ដោយផ្លូវជាតិលេខ៣ លេខ៣១ និងលេខ៣៣ និងផ្លូវរថភ្លើងមកកាន់ក្រុងកំពតហើយមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងកើតជាប់នឹងខេត្តតាកែវ ខាងត្បូងជាប់នឹងខេត្តកែបនិងប្រទេសវៀតណាម ខាងលិចជាប់នឹងខេត្តព្រះសីហនុនិងឈូងសមុទ្រថៃ។ ខេត្តមានផ្ទៃដីសរុប៤ ៨៧៣,២គ.ម.$^{២}$ បែងចែកជាដែនដីរដ្ឋបាលចំនួន៧ស្រុក និង២ក្រុង មានចំនួន៨៥ឃុំ ៨សង្កាត់ និង៤៨៨ភូមិ។ មានសណ្ឋានដី និងលក្ខណៈភូមិសាស្ត្រផ្សេងៗគ្នា ប៉ែកខាងកើតមានផ្ទៃដីរាបស្មើ ទទួលរងឥទ្ធិពលទឹកទន្លេមេគង្គ និងមានបណ្តាញផ្លូវទឹកហូរស្រោចស្រព សម្រាប់ដំណាំស្រូវ ម្រេច និងដំណាំផ្សេងៗទៀត។ ប៉ែកខាងជើងជាតំបន់ខ្ពង់រាប មានព្រៃរបោះមានផ្ទៃដីធ្វើស្រែចម្ការហើយតំបន់មួយចំនួនជាតំបន់ថ្មកំបោរ សម្រាប់បម្រើការផលិតស៊ីម៉ង់ត៍និងកំបោរ។ ប៉ែកខាងលិចជាតំបន់ភ្នំខ្ពស់ៗដែលមានឧទ្យានជាតិព្រះមុនីវង្សបូកគោជាតំបន់ការពារអភិរក្សធម្មជាតិមានផ្ទៃដីសរុប ១៥៤ ៤៥៨ហ.ត.។ ប៉ែកខាងត្បូងជាផ្ទៃដីជាប់សមុទ្រ ដែលលាតសន្ធឹងតាមបណ្តោយឆ្នេរមានប្រវែង៦៦,៥គ.ម. ដែលមានសក្តានុពលផលិតអំបិលលើផ្ទៃដី(ស្រែអំបិល) សរុប៣ ៦៧៥,៩៤ហ.ត.។

**១- ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់៖**

| ល.រ. | ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ធ្វើការថែទាំជាប្រចាំលើផ្លូវក្រាលកៅស៊ូ(AC/DBST) | គ.ម. | ២៦៧,៩៥ | ២៧៤,៣២ | ១៥០,០៨ | ១៥០,៣២ | ១៨៣,៣៤ | ១០២៦,០១ |
| ២ | សាងសង់ផ្លូវក្រាលកៅស៊ូ(AC/DBST) | គ.ម. | ១០,២៩ | ៥,៨០ | ២៨,៥១ | ២,៤៨ | ៨,៩០ | ៥៥,៩៨ |
| ៣ | ជួសជុលបន្ទាន់លើផ្លូវក្រាលកៅស៊ូ(AC/DBST) | ម.$^{២}$ | ១៨ ៤៦០ | 0.00 | 0.00 | 0.00 | ១៥ ៦២០ | ៣៤ ០៨០ |

| ល.រ. | ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ៤ | ស្ថាបនាគម្រោងផ្លូវកៅស៊ូ (AC) | ម.$^{២}$ | គ្មាន | ៤៣ ០៥៧ | ១៤ ៩៣៣ | គ្មាន | គ្មាន | ៥៧ ៩៩០ |
| ៥ | គម្រោងក្រាលផ្លូវកៅស៊ូ (AC/DBST) | គ.ម. | ២,០៤ | ២,៨០ | ០,៨០ | គ្មាន | គ្មាន | ៥,៦៣ |
| ៦ | ស្ថាបនាផ្លូវបេតុងសរសៃដែក | គ.ម. | ២,១៩ | ៦,៧៥ | ៦,៥០ | ១២,១៩ | ១៣,៩២ | ៤១,៥៦ |
| ៧ | ស្ថាបនាផ្លូវបេតុងសរសៃដែក | ម.$^{២}$ | គ្មាន | គ្មាន | គ្មាន | ១៧ ៨៦៤ | គ្មាន | ១៧ ៨៦៤ |
| ៨ | ថែទាំជាប្រចាំលើផ្លូវដីល្បាយថ្មក្រួស | គ.ម. | ១១៦,០៥ | ១២៤,៨៧ | ១២៥,៤១ | ១៣៤,៣២ | ១៣២ | ៦៣២,៦៥ |
| ៩ | សាងសង់ផ្លូវដីល្បាយថ្មក្រួស | គ.ម. | ១៨,៥៩ | ២០,៤១ | ៦,៧៨ | ៩,៣២ | ១,៦៩ | ៥៦,៧៨ |
| ១០ | ជួសជុលផ្លូវដីល្បាយថ្មក្រួស | គ.ម. | ២១,៤០ | ៣៣ | ៣៤ | ២១,៥០ | ៣៨ | ១៤៧,៩០ |
| ១១ | សាងសង់ផ្លូវក្រាលក្រួសក្រហម | គ.ម. | ៤៤,៣៦ | ៦០,២៣ | ១០៥,៥៨ | ៧២,៤៣ | ១១០,០៩ | ៣៩២,៦៩ |
| ១២ | ជួសជុលផ្លូវលំជនបទ | គ.ម. | ៧៨ | ១១២ | ១៥០ | ៧៨ | ៨៥ | ៥០៣ |
| ១៣ | ជួសជុលបន្ទាន់ផ្លូវក្រាលថ្មម៉ិច | គ.ម. | គ្មាន | គ្មាន | គ្មាន | ២ | គ្មាន | ២ |
| ១៤ | លូមូលទទឹងផ្លូវ | កន្លែង | ១៩ | ២៩ | ២១ | ១៥ | ២៦ | ១១០ |
| ១៥ | ជួសជុលបន្ទាន់លូមូលទទឹងផ្លូវ | កន្លែង | ១ | ៣ | គ្មាន | គ្មាន | គ្មាន | ៤ |
| ១៦ | លូប្រអប់ទទឹងផ្លូវ | កន្លែង | ៣ | ៣ | ២ | ៣ | គ្មាន | ១១ |
| ១៧ | ជួសជុលបន្ទាន់ លូប្រអប់ទទឹងផ្លូវ | កន្លែង | ៦ | គ្មាន | គ្មាន | គ្មាន | គ្មាន | ៦ |
| ១៨ | ស្ពានបេតុង | កន្លែង | ៤ | ៣ | គ្មាន | ២ | ១ | ១០ |
| ១៩ | ការងារជួសជុលស្ពានបេឡេត៍ | ម. | ១០៥ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១០៥ |

### ២- ការរៀបចំប្រព័ន្ធរំដោះទឹកនិងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់

- ស្ពានព្រែកធម្មជាតិមួយខ្សែមានប្រវែង២ ០០០ម. ធ្វើជាផ្លូវដោះទឹកចេញពីក្រុងកំពត ស្ថិតក្នុងសង្កាត់កំពង់កណ្ដាល ក្រុងកំពត និងស្ពានប្រឡាយទឹកស្អុយទីប្រជុំជនផ្សារឈូកប្រវែង១ ៤៥០ម.

- កំពុងដំណើការសាងសង់គម្រោងអាងប្រមូលទឹកភ្លៀង ស្ពានប្រព័ន្ធលូបង្ហូរទឹកកខ្វក់ អាងចម្រោះទឹកស្អុយ របស់គម្រោងធនាគារអភិវឌ្ឍន៍អាស៊ីADB នៃគម្រោងអភិវឌ្ឍន៍ក្រុងរបៀងនៃមហាអនុតំបន់មេគង្គទី២ ដែលជាជំនួយធនាគារអភិវឌ្ឍន៍អាស៊ីADB។

| ល.រ. | សមិទ្ធផលសម្រេចបាន | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | សាងសង់ លូមូលឃណ្ដោយផ្លូវ | ម. | ៤០០ | គ្មាន | ១ ២៨០ | ១ ០៤០ | ១ ៨១១ | ៤ ៥៣១ |
| ២ | ជួសជុលបន្ទាន់ លូមូលតាមបណ្ដោយផ្លូវ | ម. | គ្មាន | ៧១៧ | ៥៨១ | គ្មាន | គ្មាន | ១ ៣០៩ |
| ៣ | រៀបចំកសាងប្រព័ន្ធលូអង្កត់ផ្ចិត និងដាក់រ៉ឺហ្កា | ម. | ៦ ៤៣៣ | ៣ ៥៥៧ | ៧៥០ | ១៩០ | ៣៣៥ | ១១ ២៦៥ |
| ៤ | ជួសជុលរ៉ឺហ្កា | កន្លែង | គ្មាន | គ្មាន | ៩០ | ២៣៨ | គ្មាន | ៣២៨ |
| ៥ | ជួសជុលរ៉ឺហ្កា | ម. | គ្មាន | គ្មាន | ២ ៦៤០ | ២ ៣៧៣ | គ្មាន | ៥ ០១៣ |
| ៦ | សាងសង់ប្រព័ន្ធលូទឹកស្អុយ | កន្លែង | ១ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ |
| ៧ | ស្ដារប្រព័ន្ធលូក្នុងទីប្រជុំជន | ម. | ១២១ | គ្មាន | ៧១៣ | គ្មាន | គ្មាន | ៨៣៤ |
| ៨ | ស្ដារប្រឡាយទឹកស្អុយនៅទីប្រជុំជនផ្សារ | ម. | ១ ៤៥០ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ ៤៥០ |

### ៣- ការរៀបចំប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី

គ្រួសារសរុបក្នុងខេត្តកំពតមាន១៦៤ ៩៣២គ្រួសារ និងគ្រួសារប្រជាពលរដ្ឋដែលមានអគ្គិសនីប្រើប្រាស់មានចំនួន១៣៦ ៨៧៥គ្រួសារ ស្មើនឹង៨៥,៨១%នៃគ្រួសារសរុប គិតក្នុងរយៈពេល៥ឆ្នាំ មានការកើនឡើងចំនួន៤០ ២៣៤គ្រួសារ ស្មើនឹង៨២,៩៨%។

អ្នកកាន់អាជ្ញាបណ្ណផ្គត់ផ្គង់អគ្គិសនីមាន១០អាជ្ញាបណ្ណ ក្នុងនោះ អាជ្ញាបណ្ណផលិតវារីអគ្គិសនីកំចាយចំនួន១អាជ្ញាបណ្ណ(អ្នកកាន់អាជ្ញាបណ្ណ )។ អង្គភាពអគ្គិសនីកំពតស្វយ័តចំនួន១( សម្រាប់ផ្គត់ផ្គង់ក្រុងកំពត និងសាខាស្រុកកំពង់ត្រាច)។ ក្រុមហ៊ុនសេវាករអគ្គិសនី ឯកជនចំនួន៨អាជ្ញាបណ្ណ សម្រាប់ផ្គត់ផ្គង់តាមទីប្រជុំជនស្រុក និងតាមគោលដៅឃុំ ក្នុងស្រុក។

| ល.រ. | សេចក្ដីបរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|
| ១ | ការពង្រីកបណ្ដាញអគ្គិសនី | ភូមិ | ៤៧៣ | ៤៧៨ | ៤៨១ | ៤៨៥ | ៤៨៥ |
| ២ | ប្រជាពលរដ្ឋបានតបណ្ដាញប្រើប្រាស់ | គ្រួសារ | ៩៤ ៦៨៧ | ១០៣ ២៧៩ | ១១៣ ៥៤៨ | ១២១ ៣១៩ | ១៣៦៨៧៥ |

### ៤- ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ខេត្តកំពត មានស្ថានីយផលិតទឹកស្អាតចំនួន១៦កន្លែង ដែលមានសមត្ថភាពផលិតទឹកស្អាត៤៤ ១០០ ម$^{៣}$/ថ្ងៃ មានអង្គភាពផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋមួយ គឺអង្គភាពរដ្ឋាករទឹកខេត្តកំពត និងសេវាកម្មផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន១៨មូលដ្ឋានគ្រប់ដណ្ដប់លើ២ក្រុង និង៧ស្រុក ស្មើនឹង៤១ឃុំ សង្កាត់។ ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ចំនួន២៨ ៨៧៧គ្រួសារ ស្មើនឹង៥៤,៨២%នៃគ្រួសារសរុបចំនួន៥២ ២៧១គ្រួសារក្នុងតំបន់សេវា។ បើគិតក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់កើនឡើងចំនួន១៥ ១៣២គ្រួសារ ស្មើនឹង២៨,៩៥%។

លទ្ធផលក្នុងរយៈពេល៥ឆ្នាំមានបង្ហាញក្នុងតារាងទិន្នន័យផលិតកម្មដូចខាងក្រោម៖

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|
| ១ | ចំនួនស្ថានីយផលិតទឹកស្អាត | កន្លែង | ១២ | ១២ | ១៤ | ១៦ | ១៦ |
| ២ | ទំហំផលិតទឹកស្អាតក្នុង១ថ្ងៃ | ម$^{៣}$ | ៨ ៩០៦ | ៩ ៣៥០ | ១៨ ១២២ | ១៩ ៧៨៤ | ២២ ៣៤២ |
| ៣ | ចំនួនក្រុង ស្រុក បានតបណ្តាញទឹកស្អាត | ក្រុង ស្រុក | ៩ | ៩ | ៩ | ៩ | ៩ |
| ៤ | ចំនួនឃុំ សង្កាត់ បានតបណ្តាញទឹកស្អាត | ឃុំ សង្កាត់ | ៣៩ | ៤០ | ៤១ | ៥១ | ៥៥ |
| ៥ | ចំនួនភូមិ បានតបណ្តាញទឹកស្អាត | ភូមិ | ៨៤ | ៨៧ | ៩៨ | ១០៧ | ១២៨ |
| ៦ | ចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់ | គ្រួសារ | ១៥ ១១៩ | ១៧ ០៥៦ | ២១ ៦០៤ | ២៥ ៧២៩ | ២៨ ៨៧៧ |

**៥- ការផ្តល់សេវាទេសចរណ៍**

- រៀបចំសោភ័ណភាពទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ចំនួន២១កន្លែង សហគមន៍ទេសចរណ៍ចំនួន៤កន្លែង គោលដៅទាក់ទាញទេសចរណ៍ចំនួន៤កន្លែង និងបោះតង់ចំនួន៥កន្លែង

- កំពុងដំណើរការរៀបចំឆ្នេរសមុទ្រសិប្បនិម្មិតមួយកន្លែង ស្ថិតនៅភូមិកែបថ្មី សង្កាត់បឹងទូក ក្រុងបូកគោ

- កំពុងដំណើរការសាងសង់កំពង់ផែទេសចរណ៍អន្តរជាតិ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍអាស៊ី(ADB) ស្ថិតនៅស្រុកទឹកឈូ ខេត្តកំពត

- កែលម្អសួនច្បារតាមដងព្រែកកំពតមានប្រវែងប្រមាណ៦០០ម. រៀបចំចិញ្ចើមផ្លូវប្រវែង៧១០ម. និងក្រាលក្បឿឡា៥ ២៨០ម.$^{២}$

- សាងសង់បន្ទប់ទឹកនិងបង្គន់អនាម័យស្តង់ដាអាស៊ាន តាមទីសាធារណៈក្នុងក្រុងកំពត មានចំនួន៤កន្លែង

- ផលិតផលទេសចរណ៍ថ្មីៗដែលទើបតែសម្រេចបានមាន វិថីម្ហូបអាហារ(Food Street)កញ្ចប់ខ្សែទស្សនកិច្ចចំនួន៤ និងសេវារ៉ឺម៉កកង់ទេសចរណ៍

**ស្ថិតិរមណីយដ្ឋាននិងសហគមន៍ទេសចរណ៍ ឆ្នាំ២០១៧-២០២១**

| ល.រ. | សេចក្តីបរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|
| ១ | រមណីយដ្ឋានទេសចរណ៍ | កន្លែង | ១៧ | ១៧ | ១៧ | ១៧ | ២១ |
| ២ | សហគមន៍ទេសចរណ៍ | កន្លែង | ៤ | ៤ | ៤ | ៤ | ៤ |

ស្ថានភាពភ្ញៀវទេសចរ ពីឆ្នាំ២០១៧-២០២១

| ឆ្នាំ | ចំនួនភ្ញៀវសរុប | សរុបគិត% | ភ្ញៀវក្នុងស្រុក | គិត% | ភ្ញៀវអន្តរជាតិ | គិត% |
|---|---|---|---|---|---|---|
| ២០១៧ | ១ ៦០០ ៦២០ | ១,៤៧% | ១ ៤៣៨ ៤៤៩ | ១,៥២% | ១៦២ ១៧១ | ១,២០% |
| ២០១៨ | ១ ៦២៩ ៥៣០ | ១,៨១% | ១ ៤៦១ ៧៩៥ | ១,៦២% | ១៦៧ ៧៣៥ | ៣,៤៣% |
| ២០១៩ | ១ ៦៦៥ ០០២ | ២,១៨% | ១ ៤៨៤ ៥៣៩ | ១,៥៦% | ១៨០ ៤៦៣ | ៧,៥៩% |
| ២០២០ | ១ ៦៧៧ ៥៩៦ | ០,៧៦% | ១ ៦១០ ៩៤៥ | ៨,៥១% | ៦៦ ៦៥១ | ១៧០,៧៦% |
| ២០២១ | ៨៧៧ ២៦០ | -៤៧,៧១ | ៨៦៧ ៣៨៥ | -៨៥,៧២ | ៩ ៨៧៥ | -៥៧៤,៩៥ |

## ទីផ្សារទេសចរណ៍សំខាន់ៗទាំង១០ មកខេត្តកំពត

| | |
|---|---|
| Vietnam | 180,083 |
| France | 27,193 |
| United Kingdom | 25,450 |
| Germany | 24,560 |
| America | 21,732 |
| China (RPC) | 21,603 |
| Canada | 19,389 |
| Russia | 18,168 |
| Australia | 16,912 |
| Italy | 16,258 |




## ៦- ការកសាងនិងការរៀបចំប្រាំងព្រែក

ធ្វើការជួសជុលឃឿនថ្មការពារការបាក់ច្រាំងដៃព្រែកនិងបូមខ្សាច់ដាក់ឆ្នេរព្រែកកំពត ប្រវែង១២៧ម.។

## ៧- ការគ្រប់គ្រងសំរាមនិងការរៀបចំទីលានចាក់សំរាម

- កំពុងដំណើរការសាងសង់ទីលានចាក់សំរាមសម្រាប់ទីក្រុងកំពត ស្ថិតនៅក្នុងឃុំថ្មី ស្រុកទឹកឈូ លើផ្ទៃដីប្រមាណជាង១០ហ.ត. ក្រោមគម្រោងអភិវឌ្ឍន៍ក្រុងរបៀង២ ក្រោមកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ គម្រោងនេះ ផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ រួមមានទីលានចាក់សំរាម២ថត ចំនួន២ ស្រះទឹកសម្អាតទឹកកខ្វក់ចេញពីសំរាមចំនួន២ ទីលានត្រង់ទឹកកខ្វក់និងលំហួត អគាររដ្ឋបាល និងប៉ុស្តិ៍យាម អណ្តូងទឹកសម្រាប់ត្រួតពិនិត្យគុណភាពទឹក ជួសជុលផ្លូវចូលទីលានកប់សំរាម កន្លែងថ្លឹងរថយន្ត កន្លែងស្តុក និងញែកសំរាមនិងធ្វើរបងព័ទ្ធជុំវិញទីលានចាក់សំរាម
- រៀបចំទីលានចាក់សំរាម១កន្លែង មានទំហំ២ហ.ត. នៅស្រុកកំពង់ត្រាច។

## ៨- ការរៀបចំសណ្តាប់ធ្នាប់និងភ្លើងបំភ្លឺក្នុងទីក្រុង

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងមន្ទីរអង្គភាពជំនាញ បានរៀបចំដាក់បង្គោលភ្លើង និងភ្លើងបំភ្លឺតាមផ្លូវសាធារណៈក្នុងទីក្រុង

- រៀបចំភ្លើងស្តុបសម្រួលចរាចរចំនួន២កន្លែង
- ដាំបង្គោលភ្លើងនិងតបណ្តាញភ្លើងបំភ្លឺតាមដងផ្លូវ និងទីសាធារណៈ នៅតាមទីរួមខេត្ត និងតាមទីប្រជុំជនក្រុង ស្រុកចំនួន១៩១ដើម
- ឧបត្ថម្ភអំពូលភ្លើងដើរដោយពន្លឺព្រះអាទិត្យ(សូឡា) ជូនប្រជាពលរដ្ឋដែលមិនទាន់មានចរន្តអគ្គិសនីប្រើប្រាស់ចំនួន១៦៥គ្រឿង
- ដាក់កាមេរ៉ាសុវត្ថិភាពចំនួន៨៩គ្រាប់ នៅតាមក្រុង ស្រុកទាំង៩
- រៀបចំក្រុមការងារ ថែទាំ ជួសជុលបណ្តាញអគ្គិសនី តាមដងផ្លូវ និងទីធ្លាសាធារណៈសំខាន់ៗ ស្ថិតនៅក្រុងកំពត។

### ៩- ការសាងសង់អគារចាប់ពី៥ជាន់ឡើង

| ល.រ. | សេចក្តីបរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្ទះសំណាក់ | កន្លែង | ៤ | ២ | ៣ | ៥ | ៩ | ២៣ |
| ២ | សណ្ឋាគារ | កន្លែង | គ្មាន | ៦ | ២ | ៥ | គ្មាន | ១៣ |
| ៣ | ខុនដូរ ៤២ជាន់ | កន្លែង | គ្មាន | ១ | គ្មាន | គ្មាន | គ្មាន | ១ |
| ៤ | បឹងកាឡូជាន់ផ្ទាល់ដី | កន្លែង | គ្មាន | ១១ | គ្មាន | គ្មាន | គ្មាន | ១១ |

## ២.៩- ខេត្តតាកែវ

### សមិទ្ធផល និងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តតាកែវ សម្រេចបាន៖

ខេត្តតាកែវ គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ស្ថិតនៅប៉ែកនិរតីនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ៧៧គ.ម. តាមផ្លូវជាតិលេខ២ ប្រវែង៨៧គ.ម. តាមផ្លូវជាតិលេខ៣ មានប្រវែង៧៥គ.ម. តាមផ្លូវដែកពីរាជធានីភ្នំពេញ។ មានព្រំប្រទល់ខាងជើងនិងខាងកើតជាប់ខេត្តកណ្តាល ខាងលិចជាប់ខេត្តកំពង់ស្ពឺ និងខេត្តកំពត និងខាងត្បូង ខាងកើតជាប់និងប្រទេសវៀតណាម។ ស្ថានភាពផ្ទៃដីមានលក្ខណៈវាលទំនាប និងដីខ្ពស់ជាប់ជួរភ្នំ មានផ្ទៃដីសរុប៣ ៦៨០,១៥គ.ម.$^{2}$ មាន១០ក្រុង ស្រុក ១០០ឃុំ សង្កាត់ ភូមិមាន១ ១២១ភូមិ មានគ្រួសារចំនួន២២៧ ៧១៧គ្រួសារ មានប្រជាពលរដ្ឋសរុបចំនួន១ ០៤២ ១២៤នាក់(ស្រី៥៣៥ ៦៩៩នាក់)។

### ១.វិស័យសាធារណការ

| ល.រ. | ឆ្នាំ | ឈ្មោះផ្លូវ | ប្រភេទកម្រាល | ប្រវែង(គ.ម) | ប្រវែងសរុប(គ.ម) |
|---|---|---|---|---|---|
| ១ | ២០១៧ | ផ្លូវជាតិ ផ្លូវខេត្តចំនួន១២ខ្សែ និងផ្លូវក្រុងចំនួន១៨ខ្សែ | ក្រាលកៅស៊ូគ្រប់ប្រភេទ | ២៧១,០៤ | **៣៣៥,១១** |
| | | ផ្លូវខេត្តចំនួន៤ខ្សែ | ក្រាលដីល្បាយថ្ម | ៦៤,០៧ | |
| ២ | ២០១៨ | ផ្លូវជាតិ ផ្លូវខេត្តចំនួន១៣ខ្សែ និងផ្លូវក្រុងចំនួន២២ខ្សែ | ក្រាលកៅស៊ូគ្រប់ប្រភេទ | ២៨១,២៥ | **៣៤៩,៣០** |
| | | ផ្លូវខេត្តចំនួន៥ខ្សែ | ក្រាលដីល្បាយថ្ម | ៦៨,០៥ | |
| ៣ | ២០១៩ | ផ្លូវជាតិ ផ្លូវខេត្តចំនួន១២ខ្សែ | ក្រាលកៅស៊ូគ្រប់ប្រភេទ | ២៤៦,៣៩ | **២៨៥,៥៤** |
| | | ផ្លូវខេត្តចំនួន ៣ខ្សែ | ក្រាលដីល្បាយថ្ម | ៣៩,១៥ | |
| ៤ | ២០២០ | ផ្លូវជាតិ និងផ្លូវខេត្តចំនួន១០ខ្សែ | ក្រាលកៅស៊ូគ្រប់ប្រភេទ | ១៩៣,៩២ | **២៥៣,១៧** |
| | | ផ្លូវខេត្តចំនួន១ខ្សែ | កម្រាលបេតុង | ១៧,៨០ | |
| | | ផ្លូវខេត្តចំនួន៣ខ្សែ | ក្រាលដីល្បាយថ្ម | ៤១,៤៥ | |
| ៥ | ២០២១ | ផ្លូវជាតិ និងផ្លូវខេត្តចំនួន១១ខ្សែ | ក្រាលកៅស៊ូគ្រប់ប្រភេទ | ១៨៨,៨២ | **២៥១,០២** |
| | | ផ្លូវខេត្ត១ខ្សែ | កម្រាលបេតុង | ១៧,៨០ | |
| | | ផ្លូវខេត្ត២ខ្សែ | ក្រាលដីល្បាយថ្ម | ៤៤,៤០ | |
| | | | | **សរុប** | **១ ៤៧៤,១៤** |

## ២- ការងារថែទាំខួប

| លរ. | ឆ្នាំ | ឈ្មោះផ្លូវ | ប្រភេទកម្រាល | ប្រវែង | | សរុប |
|---|---|---|---|---|---|---|
| | | | | គ.ម. | ម.² | |
| ១ | ២០១៧ | ផ្លូវខេត្តចំនួន៣ខ្សែ | ក្រាលកៅស៊ូDBST | ១១,០៤ | | ១៦,០៤ |
| | | ផ្លូវខេត្តលេខ១៣២ | ក្រាលដីល្បាយថ្ម | ៥ | | |
| ២ | ២០១៨ | ផ្លូវជាតិ និងផ្លូវខេត្តចំនួន៤ខ្សែ | ក្រាលកៅស៊ូDBST | ១១,៨ | | ២០,៤២ |
| | | ផ្លូវខេត្តចំនួន២ខ្សែ | ក្រាលដីល្បាយថ្ម | ៨,៦២ | | |
| ៣ | ២០១៩ | ផ្លូវជាតិ និងផ្លូវខេត្តចំនួន៣ខ្សែ | ក្រាលកៅស៊ូគ្រប់ប្រភេទ | ៧,៨០ | ៧៩៥,៩០ | ៩,៨០ |
| | | ផ្លូវខេត្តលេខ១តេក១ | រៀបជើងទេផ្លូវ | ២ | | |
| ៤ | ២០២០ | ផ្លូវខេត្តចំនួន៣ខ្សែ | ក្រាលកៅស៊ូDBST | ១៩,៣១ | | ១៩,៣១ |
| ៥ | ២០២១ | ផ្លូវជាតិលេខ២ | អ៊ុតកៅស៊ូAC | | ១៦ ៣៥៧ | ២០,៦៧ |
| | | ផ្លូវជាតិ និងផ្លូវខេត្តចំនួន៥ខ្សែ | ក្រាលកៅស៊ូគ្រប់ប្រភេទ | ២០,៦៧ | | |
| សរុប | | | | | ១៧ ១៥២,៩០ | ៨៦,២៦ |

## ២- ការងាររ៉ែនិងថាមពល៖

- ក្រសួងបានចេញអាជ្ញាបណ្ណអណ្តូងរ៉ែ និងការដ្ឋានវាយថ្មឱ្យក្រុមហ៊ុនអាជីវករធ្វើរ៉ែសំណង់គ្រប់ប្រភេទសរុបចំនួន ២៣អាជ្ញាបណ្ណ មន្ទីរចេញអាជ្ញាបណ្ណសិប្បកម្មចំនួន១៧អាជ្ញាបណ្ណ និងតាមរយៈការិយាល័យចក្រចេញ ចូលតែមួយសរុបចំនួន២០៥អាជ្ញាបណ្ណ។ រីឯចំណូលសួយសារធនធានរ៉ែគ្រប់ប្រភេទបង់ចូលថវិការដ្ឋសរុបចំនួន៥៩ ៦០០ ០០០រៀលនិងប្រាក់ដុល្លារសរុបចំនួន១ ០២៨ ៣៩៩,២៦ដុល្លារអាម៉េរិក

- សហការជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា ចុះត្រួតពិនិត្យការរៀបចំខ្សែបណ្តាញអគ្គិសនី និងថ្លៃសេវាផ្សេងៗ របស់សេវាករចំនួន២៩អាជ្ញាបណ្ណ ទាំង១០ក្រុង ស្រុក ចំនួនភូមិផ្គត់ផ្គងជាក់ស្តែង១ ១១២ភូមិ គ្រួសារដែលភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ចំនួន១៨៩ ២៥៧គ្រួសារ ចំនួនគ្រួសារសរុបទាំង៩ស្រុក និង១ក្រុង ចំនួន២២១ ៧៣៦ គ្រួសារ ស្មើនឹង៨៥,៣០% ចំនួនភូមិដែលត្រូវបានផ្គត់ផ្គង់ថាមពលអគ្គិសនីឆ្នាំ២០២១ ស្មើនិង៩៩,៣៧%

- ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះក្នុងវិស័យបរិស្ថានគឺមានសកម្មភាព និងសម្រេចលទ្ធផលសំខាន់ៗមានដូចខាងក្រោម៖

## ៣- ការងារបរិស្ថាននិងអនាម័យ

- ធ្វើការផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋដែលប្រកបរបរលក់ដូរនិងរស់នៅតាមដងផ្លូវជាតិក្នុងទូទាំងខេត្តស្តីពីការគ្រប់គ្រងវេចខ្ចប់និងទុកដាក់សំណល់គ្រប់ប្រភេទ និងការប្រែប្រួលអាកាសធាតុបានចំនួន២៧៨លើក
- ដាំកូនឈើនៅតាមសាលារៀននិងនៅក្នុងតំបន់ការពារ បានចំនួន៤ ៤៤៩ដើម
- លើកស្លាកសញ្ញាពាក្យស្លោកបរិស្ថាននិងហាមចាក់សំរាមនៅតាមបណ្តាក្រុង ស្រុកទាំង១០ បានចំនួន៣៤ស្លាក
- លើកស្លាកប៉ាណូរូបភាពសត្វក្រៀលបានចំនួន១០ផ្ទាំង
- ដាក់ស្លាកសញ្ញាហាមឃាត់ក្របីចូលក្នុងតំបន់ការពារបានចំនួន៤ស្លាក
- ធុងសំរាមជូនរដ្ឋបាលក្រុង ស្រុក សហគមន៍ សាលារៀន ដងផ្លូវ និងសួនច្បារបានចំនួន៥០ធុង
- ឡដុតសំរាមជូនរដ្ឋបាលស្រុកសំរោងចំនួន១គ្រឿង និងស្រុកបាទីចំនួន១គ្រឿង សរុប២គ្រឿង
- រថយន្តបែនសម្រាប់ដឹកសំរាមជូនរដ្ឋបាលស្រុកសំរោងចំនួន១គ្រឿង និងស្រុកគីរីវង់ចំនួន១គ្រឿង សរុប២គ្រឿង

- រ៉ឺម៉ក់កង់បីសម្រាប់ដឹកសំរាមជូនរដ្ឋបាលស្រុកព្រៃកប្បាស ស្រុកបាទី ស្រុកត្រាំកក់ និងស្រុកទ្រាំងក្នុងមួយស្រុក១ គ្រឿង ស្រុកសំរោង៣គ្រឿង សរុប៧គ្រឿង

- ធុងចម្រោះទឹកស្អាតទៅសាលាបឋមសិក្សា ហ៊ុន សែន អនុវត្តន៍១គ្រឿង និងរដ្ឋបាលស្រុកព្រៃកប្បាសចំនួន១គ្រឿង សរុប២គ្រឿង

- ចុះត្រួតពិនិត្យផលិតផលតែបៃតង ដែលហួសកាលបរិច្ឆេទប្រើប្រាស់របស់ក្រុមហ៊ុន ផេស៊ីអរអោយចំនួន១ ៥៥០កេះ ដែលយកមកចាក់ចោលក្នុងភូមិដំណាក់ខ្លុង ឃុំអូរសោចាយ ស្រុកត្រាំកក់។ ជាលទ្ធផល សមត្ថកិច្ចចម្រុះ បានតម្រូវឱ្យក្រុមហ៊ុនប្រមូលផលិតផលទាំងអស់នោះត្រឡប់ទៅវិញ

- ចុះពិនិត្យសិប្បកម្ម អាជីវកម្ម និងរោងចក្រ ដែលមានការប៉ះពាល់បរិស្ថាន ដោយការគ្រប់គ្រងទុកដាក់សំណល់រឹង រាវមិនបានត្រឹមត្រូវ បានចំនួន១៥១ទីតាំង ស្មើនឹង១៧៤លើក។ ជាលទ្ធផល ម្ចាស់សិប្បកម្ម អាជីវកម្ម និងរោងចក្រ បានធ្វើកិច្ចសន្យា ហើយកែលម្អតាមការណែនាំរបស់មន្ត្រីជំនាញ

**៤- ការងារទេសចរណ៍៖**

រមណីយដ្ឋានទេសចរណ៍ មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ និងស្ថិតិភ្ញៀវទេសចរចូលមកទស្សនាសម្រាក ស្នាក់នៅ លំហែ កម្សាន្ត និងចុះសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រក្នុងខេត្តតាកែវ មានដូចខាងក្រោម៖

| ល.រ | បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុបរួម |
|---|---|---|---|---|---|---|---|
| ក- សម្បទាទេសចរណ៍ក្នុងខេត្ត | | | | | | | |
| ១ | រមណីយដ្ឋាន | ០៨ | ០៩ | ០៩ | ០៩ | ១០ | ៤៥ |
| ២ | សណ្ឋាគារ | ០២ | ០២ | ០២ | ០២ | ០២ | ១០ |
| | ចំនួនបន្ទប់ | ៤០ | ៤០ | ៤០ | ៦០ | ៦០ | ២៤០ |
| ៣ | ផ្ទះសំណាក់ | ៧៩ | ៨៤ | ១០០ | ១០៦ | ១០៥ | ៤៧៤ |
| | ចំនួនបន្ទប់ | ៨១៧ | ៨៧៣ | ១ ០០៧ | ១ ០៧២ | ៨១៥ | ៤ ៥៨៤ |
| ៤ | ភោជនីយដ្ឋាន | ៧៤ | ៨២ | ៩៤ | ១០៦ | ១០៦ | ៤៦២ |
| | ចំនួនកៅអី | ២ ៩២០ | ៣ ១៩២ | ៣ ៨២៥ | ៤ ៣១៣ | ៤ ៣១៣ | ១៨ ៥៦៣ |
| ៥ | ខារ៉ាអូខេ | ៥៣ | ៦៧ | ៦៧ | ៦៤ | ៦៣ | ៣១៤ |
| | ចំនួនបន្ទប់ | ១៧៨ | ២៣៥ | ២៣៨ | ២៣២ | ២៣០ | ១ ១១៣ |
| ៦ | ក្លឹបកម្សាន្ត | ០២ | ០២ | ០២ | ០១ | ០១ | ០៨ |
| | ចំនួនកៅអី | ២២៦ | ១៤១ | ១៧២ | ១០០ | ១០០ | ៧៣៩ |
| ៧ | ម៉ាស្សា | ០២ | ០៣ | ០៤ | ០៤ | ០៤ | ១៧ |
| | ចំនួនបន្ទប់ | ០៨ | ១០ | ១៩ | ១៩ | ១៩ | ៧៥ |
| ៨ | ហាងកាហ្វេ | - | ១១ | ១០ | ២០ | ២០ | ៦១ |
| | ចំនួនកៅអី | - | ១៨១ | ១៧៩ | ៤០៧ | ៤០៧ | ១ ១៧៤ |
| ៩ | បន្ទប់ជួល | - | ០២ | ០៣ | ៤២ | ៤២ | ៨៩ |
| | ចំនួនបន្ទប់ | - | ១០ | ២២ | ៣៨៤ | ៣៨៤ | ៨០០ |
| ១០ | ប៉ៀរហ្គាដិន | ០១ | - | - | - | - | ០១ |
| | ចំនួនកៅអី | ៤៨ | - | - | - | - | ៤៨ |
| ខ- ស្ថិតិភ្ញៀវទេសចរ | | | | | | | |
| ១១ | ភ្ញៀវទេសចរជាតិ | ៨៨២ ៥៩៨ | ៨១២ ៩៧៧ | ១ ២៥៩ ៨៩១ | ៦៨៩ ៥១៩ | ១៣៨ ៧៨៦ | ៣ ៧៨៣ ៧៧១ |
| ១២ | ភ្ញៀវអន្តរជាតិ | ១៣ ៩៤៩ | ១៥ ០១១ | ១៤ ៧៥៩ | ៤ ៦៥៦ | ៦៦៥ | ៤៩ ០៤០ |

បុរាណដ្ឋានសរុបដែលបានកំណត់ទំហំដែនរក្សាការពាររួចរាល់មានចំនួន១៨៨ស្ថានីយបុរាណ និងបុរាណដ្ឋានដែលបានបោះបង្គោលការពាររួចរាល់មានចំនួន៨កន្លែង ស្មើនឹង៩៨បង្គោល ក្នុងនោះ ប្រាសាទភ្នំជីសូរ្យចំនួន៣៩បង្គោល ប្រាសាទភ្នំដាចំនួន១០បង្គោល ទួលអ្នកតាទទឹង ស្រុកបាទីចំនួន៥បង្គោល ទួលអង្គជំរំស្រុកកោះអណ្តែកចំនួន២៥បង្គោល ទួលអង្គស្លែង ស្រុកត្រាំកក់ចំនួន៦បង្គោល ទួលអង្គរមាស ស្រុកត្រាំកក់ចំនួន៤បង្គោល ទួលអង្គភោគ ស្រុកទ្រាំងចំនួន៤បង្គោល និងទួលអង្គតាវិទូ(ថ្មស)ស្រុកបូរីជលសារចំនួន៥កន្លែង។

## ២.១០- ខេត្តសៀមរាប

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តសៀមរាប សម្រេចបាន៖

ខេត្តសៀមរាបជាខេត្តមួយក្នុងចំណោមរាជធានី ខេត្ត ទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា មានទីតាំងស្ថិតនៅប៉ែកពាយ័ព្យនៃប្រទេសមានចម្ងាយ៣១៤គ.ម. ពីរាជធានីភ្នំពេញ ដោយមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យ ខាងត្បូងជាប់នឹងខេត្តបាត់ដំបងនិងបឹងទន្លេសាប ខាងកើតជាប់នឹងខេត្តព្រះវិហារ និងខេត្តកំពង់ធំ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ លាតសន្ធឹងលើផ្ទៃដីសរុប១០ ២៩៩គ.ម.ក្រឡា ចែកជា១១ស្រុក ១ក្រុង មាន៨៨ឃុំ ១២សង្កាត់ និង៩១០ភូមិ ចំនួនគ្រួសារសរុប២៤៥ ៥០៧គ្រួសារ ចំនួនប្រជាជនសរុប ១ ១៣៧ ៦៧៦នាក់(ស្រី៥៤៥ ៧៧០នាក់)។

### ១- ការងារកែលម្អអភិវឌ្ឍន៍ក្រុង

### ក- ការងារសាងសង់-ជួសជុល-ថែទាំផ្លូវថ្នល់(ថវិកាគុណប្រយោជន៍ខេត្ត)

ក្នុងរយៈពេលប្រាំឆ្នាំ(២០១៧-២០២១) ខេត្តបានអភិវឌ្ឍន៍គម្រោង ដែលបានប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត មានដូចខាងក្រោម៖

| ឆ្នាំ | ផ្លូវដែលបានសាងសង់និងជួសជុល | ប្រវែង | ផ្សេងៗ |
|---|---|---|---|
| ២០១៧ | ជួសជុលផ្លូវប៉ះសំបុកមាន់ផ្លូវDBSTក្នុងក្រុង | ២២ ២០០ម.$^2$ | |
| | ជួសជុលផ្លូវប្រភេទDBST | ៣១ ៤១៥ម.$^2$ | |
| | សាងសង់ផ្លូវបេតុង | ១១ ១៣០ម.$^2$ | |
| | ជួសជុលផ្លូវក្រាលគ្រួសក្រហម | ៤៧ ៥៤៣ម.$^2$ | |
| | សាងសង់ផ្លូវក្រាលគ្រួសក្រហម | ៨ ៣៥០ម.$^2$ | |
| | ជួសជុលកែលម្អផ្លូវបេតុងអ៊ិតកៅស៊ូ | ១៦ ៨០០ម.$^2$ | |
| | សាងសង់ដាឡូរំដោះទឹកភ្លៀង | ៤ ១៨៧ម. | |
| | សាងសង់លូជ្រុង | ១០កន្លែង | |
| | សាងសង់បង្គោលភ្លើងបំភ្លឺសាធារណៈ | ៩២៥ដើម | |
| | ជួសជុលបង្គោលភ្លើងបំភ្លឺសាធារណៈ | ៣០ដើម | |
| | បោះបង្គោលព្រំដី | ៣០០បង្គោល | |
| | សាងសង់អគារសាលាឃុំ | ៤កន្លែង | |
| | សាងសង់បង្គោលភ្លើងបំភ្លឺសាធារណៈ | ១១៧ដើម | |

| | | | |
|---|---|---|---|
| ២០១៨ | ប៉ះសំបុកមាន់ផ្លូវក្នុងក្រុង | ២ ៣៨៣ម.$^{២}$ | |
| | សាងសង់ផ្លូវក្រាលគ្រួសក្រហម | ២៤ ៧៥០ម.$^{២}$ | |
| | សាងសង់ផ្លូវបេតុង | ៣០ ៨៦២ម.$^{២}$ | |
| | សាងសង់ផ្លូវ DBST | ៣៦ ៩០០ម.$^{២}$ | |
| | សាងសង់ផ្លូវអ៊ុតបេតុងកៅស៊ូ | ១១ ៧៦០ម.$^{២}$ | |
| | ជួសជុលផ្លូវDBST | ១២ ៤០០ម.$^{២}$ | |
| | ជួសជុលផ្លូវក្រាលគ្រួសក្រហម | ៦២ ៥១០ម.$^{២}$ | |
| | ជួសជុលផ្លូវដីស | ៥១ ៧៧២ម.$^{២}$ | |
| | សាងសង់ស្ពានបេតុង | ៨៤ម.$^{២}$ | |
| | ជួសជុលស្ពារប្រឡាយ | ៧ ៧០៦ម. | |
| | លូកាត់ទឹកភ្លៀងកាត់ទទឹងផ្លូវ | ៤កន្លែង | |
| | លូកាត់ទឹកភ្លៀងកាត់ទទឹងផ្លូវ | ១៨៨ម. | |
| | សាងសង់លូទឹកភ្លៀង | ៥ ៣២៨ម. | |
| | សាងសង់អគារសាលាឃុំ | ៨កន្លែង | |
| | សាងសង់ទំនប់បង្ហៀរទឹក | ១កន្លែង | |
| | សាងសង់ទ្វារទឹក និងលូជ្រុង | ២កន្លែង | |
| | ស្តារព្រែក | ២៩៨ ១២៥ម.$^{៣}$ | |
| | សាងសង់អគារច្រកចេញចូលតែមួយ | ២អគារ | |
| | សាងសង់សាលាបឋមសិក្សា | ១អគារ | |
| | សាងសង់បង្គោលភ្លើងស្តុប | ៤កន្លែង | |
| | សាងសង់បង្គោលភ្លើង និងទូបញ្ជា | ៤២៨ដើម | |
| | បោះបង្គោលព្រំដី (រដ្ឋបាលខេត្តគ្រប់គ្រង) | ៥២ទីតាំង | |
| ២០១៩ | ជួសជុល និងប៉ះសំបុកមាន់ក្នុងក្រុងសៀមរាប | ៧ ២៨៤ម.$^{២}$ | |
| | ជួសជុលផ្លូវកៅស៊ូបេទីប | ១២ ៨៤៥ម.$^{២}$ | |
| | ជួសជុលផ្លូវDBST | ៤ ៦២០ម.$^{២}$ | |
| | ជួសជុលផ្លូវបេតុង | ៣ ៥០០ម.$^{២}$ | |
| | ជួសជុលផ្លូវក្រាលបេតុងកៅស៊ូប្រភេទAC | ៦ ៩៣០ម.$^{២}$ | |
| | ជួសជុលផ្លូវក្រាលបេតុងសសៃដែក RC | ២៨ ៣២៥ម.$^{២}$ | |
| | ជួសជុលពង្រីកតួផ្លូវអ៊ុតកៅស៊ូ | ៣៤ ៨៦០ម.$^{២}$ | |
| | សាងសង់ផ្លូវអ៊ុតកៅស៊ូបេទីម | ៦ ២០០ម.$^{២}$ | |

| | | | |
|---|---|---|---|
| | សាងសង់ផ្លូវបេតុង | ២៥ ៣១៥ម.២ | |
| | សាងសង់ផ្លូវ DBST | ១៧ ៧១០ម.២ | |
| | សាងសង់លូកាត់ទទឹងផ្លូវ | ១៩៦ម.២ | |
| | សាងសង់លូប្រអប់ | ៤ ០៧៥ម.២ | |
| | សាងសង់លូរំដោះទឹកភ្លៀង | ៨ ៤៦៧ម.២ | |
| | គំនូសចរាចរណ៍ ក្នុងក្រុងសៀមរាបដែលមានទំហំ | ៨ ៩៨៨ម.២ | |
| | ជួសជុលភ្លើងស្តុប | ១១កន្លែង | |
| | សាងសង់អគារសាលាឃុំ | ១៤កន្លែង | |
| | សាងសង់បង្គោលភ្លើងបំភ្លឺសាធារណៈ | ៥២៣ដើម | |
| | សាងសង់អគាររដ្ឋបាលច្រកចេញចូលតែមួយ | ២កន្លែង | |
| | សាងសង់របងអគាររបស់រដ្ឋបាលខេត្តសៀមរាប | ១ ៤១០ម.២ | |
| | សាងសង់ពេងឡានអំពីដែកប្រក់សង្ក័សីថ្លា | ៨០០ម.២ | |
| | សាងសង់ឃ្លាំងរបស់រដ្ឋបាលខេត្តសៀមរាប | ១ ២០០ម.២ | |
| ២០២០ | សាងសង់ផ្លូវបេតុង | ៧ ០២៨ម.២ | |
| | សាងសង់លូរំដោះទឹកភ្លៀងកាត់ទទឹងផ្លូវ | ១៦០ម.២ | |
| | សាងសង់ភ្លើងស្តុប | ២កន្លែង | |
| | សាងសង់លូរំដោះទឹក | ១០ ៩១២ម. | |
| | សាងសង់អគាររដ្ឋបាលច្រកចេញចូលតែមួយ | ៥កន្លែង | |
| | សាងសង់អាហារដ្ឋានក្នុងបរិវេណសាលាខេត្ត | ១កន្លែង | |
| | សាងសង់អគារមត្តេយ្យសហគមន៍ | ១២កន្លែង | |
| | សាងសង់ផ្លូវRC | ១ ៥៦០ម.២ | |
| | សាងសង់អាងស្តុកទឹកស្អាតដល់សាលារៀន | ៤កន្លែង | |
| | សាងសង់អណ្តូងទឹកស្អាតដល់គ្រួសារងាយរងគ្រោះ | ៥៥អណ្តូង | |
| | សាងសង់សួនកុមារ | ១២កន្លែង | |
| | ជួសជុលផ្លូវបេតុង | ៥៩ ១៥៨ម.២ | |
| | ជួសជុលប៉ះសំបុកមាន់ គូសគំនូសចរាចរ និង ស្លាកសញ្ញាផ្សេងៗទៀតក្នុងក្រុង | ១១ ១៩០ម.២ | |
| ២០២១ | សាងសង់អគាររដ្ឋបាលឃុំ សង្កាត់ | ១២កន្លែង | |
| | ជួសជុលភ្លើងសញ្ញាចរាចរ | ៥កន្លែង | |
| | ជួសជុល និងផ្លាស់ប្តូរទីតាំងបង្គោលភ្លើងបំភ្លឺសាធារណៈ ផ្លូវជាតិលេខ៦ ក្នុងក្រុងសៀមរាប | ១៣៥ទីតាំង | |

| | | | |
|---|---|---|---|
| | ជួសជុលប៉ះសំបុកមាន់ គូសគំនូសចរាចរ និងស្លាកសញ្ញា ផ្ទាំងអក្សរផ្សេងៗទៀតក្នុងក្រុងសៀមរាប | ៩ ០១៧ម.² | |
| | សាងសង់ភ្លើងសញ្ញាចរាចរចំនួន១ទីតាំង ក្នុងក្រុងសៀមរាប | ១កន្លែង | |
| | ជួសជុលផ្លូវបេតុង | ៣៩ ៨១០ម.² | |
| | សាងសង់លូរំដោះទឹក | ៣ ៣៩០ម. | |
| | សាងសង់លូរំដោះកាត់ទទឹងផ្លូវ | ១ ៨៦៤ម. | |
| | ស្តារប្រឡាយរំដោះទឹកនៅស្រុកជីក្រែង | ៦០ ៦០០ម.² | |

### ខ- អំពូលភ្លើងបំភ្លឺសាធារណៈ

ដើម្បីសន្សំសំចៃថាមពលនិងការតុបតែងលម្អក្រុង ខេត្តបានសហការជាមួយក្រុមហ៊ុនវីសាន់ និងក្រុមហ៊ុនមីនីបៀ បានធ្វើការផ្លាស់ប្តូរនិងបន្ថែមទីតាំងបំពាក់ភ្លើងបំភ្លឺសាធារណៈប្រភេទLED តាមផ្លូវសំខាន់ៗក្នុងក្រុងសៀមរាប សរុបចំនួន៤ ៦២៩អំពូល។ ជាមួយគ្នានេះ ក្រុមហ៊ុនមីនីបៀក៏បានផ្តល់នូវអំពូលថ្មីបន្ថែមទៀតចំនួន១ ២៨០អំពូល ដើម្បីត្រៀមតម្លើងលើហេដ្ឋារចនាសម្ព័ន្ធផ្លូវទាំង៣៨ខ្សែ និងផ្លូវតាមបណ្តោយផ្លូវជាតិលេខ៦ ពីស្តុបសណ្ឋាគារសុខា ដល់រង្វង់មូលជ័យវ្រ្មនទី៧។

### គ- គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ៣៨ខ្សែ ក្នុងក្រុងសៀមរាប

គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវ៣៨ខ្សែ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប មានប្រវែងសរុប ១០៤,៤២គ.ម. ប្រើប្រាស់កញ្ចប់ថវិការបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន១៤៩ ២១៦ ៥៩៥ដុល្លារអាម៉េរិក ដែលគ្រោងនឹងបញ្ចប់ការសាងសង់ក្នុងរយៈពេល១៣ខែ ដោយក្នុងនោះមានក្រុមការងារត្រួតពិនិត្យបច្ចេកទេសអន្តរក្រសួងចំនួន៩ក្រុម និងអនុវត្តដោយអង្គភាពរដ្ឋចំនួន៨អង្គភាព។ គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវ៣៨ខ្សែ ក្នុងក្រុងសៀមរាប ខេត្តសៀមរាប មានប្រវែងសរុប១០៦,៤២គ.ម. សម្រេចបាន ៩២,៧២%នៃទំហំការងារសរុប។

**គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ៣៨ខ្សែ ក្នុងក្រុងសៀមរាប**

| ប្រភេទ | ឯកតា | ២០២១ | ទំហំការងារ | ភាគរយ |
|---|---|---|---|---|
| ការងារចាក់បេតុងកម្រាលផ្លូវ | គ.ម. | ៥០ ៥០២ | ៥០ ៨៦២ | ៩៩% |
| ការងារអ៊ុតបេតុងកៅស៊ូ AC | គ.ម. | ២៧ ៩៨០ | ៥៣ ៣៧២ | ៥២% |
| ការងារប្រព័ន្ធបណ្តាញបង្ហូរ | គ.ម. | ២៤៨ ៧២៤ | ២៤៨ ៧២៤ | ១០០% |
| ការងាររៀបចំខឿនចិញ្ចើមផ្លូវ | គ.ម. | ១៨២ ៥៨០ | ១៩០ ៤៨៤ | ៩៦% |
| ការងាររៀបចំកម្រាលផ្លូវថ្មើរជើង | ម.² | ១៩៦ ៨៥០ | ២៣៦ ៤៥៥ | ៨៣% |

### ២- ការងារទឹកស្អាត

ទឹកស្អាតក្នុងក្រុងសៀមរាប មានតម្រូវការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកំណើនប្រជាជន និងការរីកចម្រើននៅក្នុងទីក្រុង ដើម្បីបំពេញតម្រូវការបន្ថែមនេះ ខេត្តបានសហការពង្រីកសមត្ថភាពផលិត និងចែកចាយ ដូចខាងក្រោម៖

- រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតថ្មីមួយ ស្ថិតក្នុងភូមិសណ្តាន់ សង្កាត់ទឹកវិល និងមានសមត្ថភាពផលិតទឹកស្អាតចំនួន១៥ ០០០ម៉ែត្រគ្រីគុណក្នុងមួយថ្ងៃ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីខែធ្នូ ឆ្នាំ២០១៩ ក្រោយពីបានបើកការដ្ឋានសាងសង់នៅក្នុងខែកក្កដា ឆ្នាំ២០១៧ ដោយប្រើរយៈពេលសាងសង់ចំនួន២ឆ្នាំ ៦ខែ ក្រោមហិរញ្ញប្បទានឥណទានរបស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD)។ តាមរយៈសមិទ្ធផលថ្មីនេះ

សមត្ថភាពផ្គត់ផ្គង់ទឹកស្អាតរបស់រ.ស.ស បានកើនដល់៣០ ០០០ម៉ែត្រគ្រីគុណក្នុងមួយថ្ងៃ(ម.៣/ថ្ងៃ) បើធៀបនឹងសមត្ថភាពផលិតមុនឆ្នាំ២០១៩ ដែលមានតែ១៥ ០០០ម.៣/ថ្ងៃ ពោលគឺកើនឡើងក្នុងចំនួនទ្វេដង

- បច្ចុប្បន្ន រដ្ឋាករទឹកស្វយ័តសៀមរាប មានរោងចក្រផលិតទឹកស្អាតសរុបចំនួន២ ដែលកំពុងដំណើរការផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋក្នុងក្រុងសៀមរាបគឺ រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតទឹកវិលទី១ ដែលបានដាក់ឱ្យដំណើរការជាផ្លូវការនាឆ្នាំ២០០៦ ក្រោមគម្រោងហិរញ្ញប្បទានឥតសំណងរបស់JICA មានសមត្ថភាពផលិតទឹកស្អាត ១៥ ០០០ម.៣/ថ្ងៃ និងរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតទឹកវិលទី២ ក្រោមហិរញ្ញប្បទានឥណទានរបស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD)

- ការពង្រីកផ្ទៃសេវាត្រូវបានធ្វើឡើងតាមរយៈការដាក់បំពង់មេបញ្ជូនទឹកស្អាត ដែលមានទំហំចាប់ពី ២៥០មីល្លីម៉ែត្រ(ម.ម.) និងបំពង់ចែកចាយទឹកស្អាតមានទំហំក្រោម២៥០ម.ម. ក្រោមថវិកាវិនិយោគផ្ទាល់របស់រដ្ឋាករទឹកស្វយ័តសៀមរាប រួមជាមួយគម្រោងឥណទានពីដៃគូអភិវឌ្ឍន៍ មាន AFD, ADB, JICA

- ការងារផ្តល់បណ្តាញចូលផ្ទះថ្មីជូនប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់ទទួលបានសេវាទឹកស្អាត ក៏ត្រូវបានអនុវត្តស្របនឹងផែនការដែលបានដាក់ចុះដោយរដ្ឋបាលខេត្តសៀមរាប ជាពិសេសការងារនេះបានដើរទន្ទឹមគ្នាជាមួយគម្រោងស្តាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចំនួន៣៨ខ្សែ និងគម្រោងរៀបចំប្រព័ន្ធលូទឹកសំណល់ក្នុងក្រុងសៀមរាបផងដែរ។ ជាលទ្ធផលក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ចំនួនគ្រួសារប្រជាពលរដ្ឋដែលទទួលបានសេវាទឹកស្អាតពីរដ្ឋាករទឹកស្វយ័តសៀមរាប បានកើនឡើងក្នុងចំនួនទ្វេដងបើធៀបនឹងឆ្នាំ២០១៦

- គម្រោងសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតថ្មី ស្ថិតក្នុងសង្កាត់ជ្រាវ ក្រុងសៀមរាប កំពុងស្ថិតក្នុងដំណាក់កាលសាងសង់ ក្រោមឥណទានរបស់JICA លើសមត្ថភាពផលិត៦០ ០០០ម៉ែត្រគ្រីគុណ/ថ្ងៃ ដោយយកប្រភពទឹកចេញពីបឹងទន្លេសាប។ គម្រោងសាងសង់រោងចក្រនេះ សម្រេចបានលទ្ធផលជារួមប្រមាណ៨០% ក្នុងឆ្នាំ២០២១ និងគ្រោងបញ្ចប់ជាស្ថាពរនៅដើមឆ្នាំ២០២៣ខាងមុខ។

វឌ្ឍនភាពនៃការចែកចាយទឹកស្អាតនៅក្នុងក្រុងសៀមរាប ក្នុងរយៈពេលប្រាំឆ្នាំ(២០១៧-២០២១) មានដូចខាងក្រោម៖

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|
| បំពង់ចែកចាយទឹកស្អាត (ម៉ែត្រ) | ១៦១ ១៦៩ | ១៨៣ ៧២៦ | ២៤០ ២៥៨ | ៣០១ ១៩៧ | ៣០២ ៤៩៣ | ១ ១៨៨ ៨៤៣ |
| ចំនួនប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាត(តំណ) | ៧ ៩៦៧ | ៨ ៧៩៧ | ១១ ០៣៣ | ១៣ ០១៩ | ១៥ ៣២៨ | ៥៦ ១៤៤ |

**៣- ការងារអគ្គិសនី(ថាមពល និងEDC)**

តម្រូវការថាមពលមានការកើនឡើងឥតឈប់ឈរ ដោយសារកត្តាជីវភាពប្រជាពលរដ្ឋនិងកំណើនសេដ្ឋកិច្ចជាតិ តាមរយៈនេះ ក្នុងរយៈពេលប្រាំឆ្នាំនេះឃើញថា ពីមួយឆ្នាំទៅមួយឆ្នាំ មានការកើនឡើងជាពិសេសនៅក្នុងឆ្នាំ២០២១។ គិតត្រឹមចុងឆ្នាំ២០២១អតិថិជនសរុបមានចំនួន៩២ ៦០១អតិថិជននិងអតិថិជនជាវថ្មីកើនឡើងក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) ចំនួន៤៤ ១១៩អតិថិជន។ ជាមួយគ្នានេះការពង្រីកខ្សែបណ្តាញ និងការបំពាក់ឧបករណ៍នានា ត្រូវបានរៀបចំដើម្បីបំពេញតម្រូវការខាងលើ និងដើម្បីសម្រេចបាននូវទិសដៅរបស់រាជរដ្ឋាភិបាល ក្នុងការពង្រីកបណ្តាញអគ្គិសនីដល់គ្រប់ភូមិ នៅឆ្នាំ២០២០។




## ស្ថានភាពប្រវែងខ្សែបណ្តាញ MV - LV និងចំនួនត្រង់ស្វូ




## ៤- ការងារទេសចរណ៍

### - ស្ថានភាពទេសចរជាតិ និងអន្តរជាតិ រយៈពេល៥ឆ្នាំ(២០១៧-២០២១)

| ឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ភ្ញៀវសរុប | ៥ ៥៤៣ ៤៣៤នាក់ | ៦ ១២៨ ២៣០នាក់ | ៤ ២៦២ ៣០៦នាក់ | ១ ១០៤ ០៣៦នាក់ | ៣៦៧ ៨៧៣នាក់ |
| ភ្ញៀវជាតិ | ៣ ០៨៦ ១៥២នាក់ | ៣ ៥១១ ១៧៥នាក់ | ២ ០៥៦ ៦០៩នាក់ | ៧០៣ ១៤៧នាក់ | ៣៥៦ ៩៨៧នាក់ |
| ភ្ញៀវអន្តរជាតិ | ២ ៤៥៧ ២៨២នាក់ | ២ ៦១៧ ០៥៥នាក់ | ២ ២០៥ ៦៩៧នាក់ | ៤០០ ៨៨៩នាក់ | ១០ ៨៨៦នាក់ |
| អត្រា% | +៩,៩៣% | +១០,៥៥% | -៣០,៤៥% | -៧៤,១០២% | -៦៦,៦៨% |

- ស្ថានភាពទីតាំងអាជីវកម្មដ្ឋានទេសចរណ៍រយៈពេល៥ឆ្នាំ(២០១៧-២០២១)

| ប្រភេទ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | បន្ទប់ | ចំនួន | បន្ទប់ | ចំនួន | បន្ទប់ | ចំនួន | បន្ទប់ | ចំនួន | បន្ទប់ |
| សណ្ឋាគារ | ២២០ | ១៣៤៦០ | ២៦០ | ១៤៤៥៦ | ២២៨ | ១៤៥៩៩ | ២២៨ | ១៤៥៩៩ | ២២៨ | ១៤៥៩៩ |
| ផ្ទះភ្ញៀវ | ២៩៦ | ៤៨១១ | ៣៥១ | ៤៩១០ | ៣១០ | ៤៦៧៩ | ៣១០ | ៤៦៧៩ | ២៦១ | ៤៦៧៩ |
| ភោជនីយដ្ឋាន | ១៧១ | ៤៤៧២តុ | ១៨៣ | ៣១៤៣តុ | ១៩៦ | ៤៦២១តុ | ១៩៦ | ៤៦២១តុ | ១៩៦ | ៤៦២១តុ |
| ម៉ាស្សា | ៥០ | ៦៣០គ្រែ | ៥០ | ៩១៤គ្រែ | ៥០ | ៩១៤គ្រែ | ៥០ | ៩១៤គ្រែ | ៥០ | ៩១៤គ្រែ |
| ការ៉ាអូខេ | ១៧ | ២៧២ | ១៦ | ២៦១ | ១៤ | ២៥២ | ១៤ | ២៥២ | ១៤ | ២៥២ |
| មគ្គុទ្ទេសក៍ | ៤៦១៩ | ស្រី៦៦២ | ៥១៧២ | ស្រី៧៥៧ | ៥១៧២ | ស្រី៧៥៧ | ៥១៧២ | ស្រី៧៥៧ | ៥១៧២ | ស្រី៧៥៧ |
| ទីភ្នាក់ងារទេសចរណ៍ | ២៩៦ | | ៣១៦ | | ៣២៧ | | ៣២៧ | | ៣២១ | |

ក្នុងឆ្នាំ២០២០-២០២១ ដោយមាន បញ្ហាកូវីដ-១៩ មានអាជីវកម្មទេសចរណ៍៖
- សណ្ឋាគារចំនួន២៥កន្លែង
- ភោជនីយដ្ឋានចំនួន១៤កន្លែង

## ២.១១- ខេត្តកំពង់ធំ

### សមិទ្ធផល និងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកំពង់ធំសម្រេចបាន៖

### ១- ការកែលម្អសោភ័ណភាព សោភាទីក្រុង និងទីប្រជុំជន

### ១.១- ការគ្រប់គ្រងការប្រមូលសម្រាម និងទីលានចាក់សម្រាម

| ក្រុង/ស្រុក | ភ្នាក់ងារគ្រប់គ្រង | ទំហំទីលាន | ទីតាំងទីលាន | ស្ថានភាពទីលាន |
|---|---|---|---|---|
| **ស្ទឹងសែន** | ក្រុមហ៊ុនហ្គាអ៊ីយ៉ា | ១ហ.ត. | ភូមិកំពង់ធំ សង្កាត់កំពង់រទេះ | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **សន្ទុក** | ភាស៊ីផ្សារ | ៣០ម. x ២៥ម. | ភូមិសង់ឃ្លាំង ឃុំតាំងក្រសាំង | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **កំពង់ស្វាយ** | ភាស៊ីផ្សារ | ៣០ម. x ៥០ម. | ភូមិវល្លិយាវ ឃុំត្រពាំងឫស្សី | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **បារាយណ៍** | កួយ គឹមសាយ | ៦០ម. x ៦០ម. | ភូមិបារាយណ៍ជាន់ដែក ឃុំបល្ល័ង្ក | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **ស្ទោង** | ព្រំ ពិសិដ្ឋ | ២,១៥ហ.ត. | ភូមិបុស្សតាឯក ឃុំទ្រា | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **សណ្តាន់** | ទី ថាវី | ៣០អារ | ព្រៃសហគមន៍ត្រកក្រូច | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **ប្រាសាទសំបូរ** | ជួន ចូត | ២ហ.ត. | ភូមិសំរិត ឃុំសំបូរណ៍ | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **តាំងគោក** | ភាស៊ីផ្សារ | ១២ម. x ១០ម. | ភូមិរំចេក ឃុំទ្រៀល | មិនទាន់មានលក្ខណៈស្តង់ដានៅឡើយ |
| **ប្រាសាទបល្ល័ង្ក** | គ្មាន | គ្មាន | គ្មាន | គ្មាន |

## ១.២- ការរៀបចំផ្លូវថ្មើរជើង ទីធ្លាចំណត សួនច្បារសាធារណៈ

កន្លងមករដ្ឋបាលខេត្ត ក្រុង ស្រុក បានរៀបចំជួសជុល និងសាងសង់ថ្មីនូវសួនច្បារសាធារណៈ និងទីធ្លាសម្រាប់កម្សាន្តដូចខាងក្រោម៖

| ល.រ. | ឈ្មោះ | ទីតាំង |
|---|---|---|
| ១ | សួនច្បារនិងរូបសំណាកលោកតាក្រហមក | ក្រុងស្ទឹងសែន |
| ២ | សួនច្បារនិងវិមានឯករាជ្យ | ក្រុងស្ទឹងសែន |
| ៣ | សួនច្បារសម្ដេចហ៊ុនសែននិងនិមិត្តសញ្ញាខេត្ត | ក្រុងស្ទឹងសែន |
| ៤ | សួនច្បារស្ទឹងសែននិងរូបផែនទីខេត្តកំពង់ធំ | ក្រុងស្ទឹងសែន |
| ៥ | សួនច្បារដំរីជាន់ខ្លា | ក្រុងស្ទឹងសែន |
| ៦ | សួនច្បារនិងរូបសំណាកលោកតាអាចារ្យលាក់ | ក្រុងស្ទឹងសែន |
| ៧ | សួនច្បារនិងរូបសំណាកដាវដែកកំពង់ស្វាយ | ស្រុកកំពង់ស្វាយ |
| ៨ | សួនច្បារកំពង់ក្របៅ | ក្រុងស្ទឹងសែន |
| ៩ | កែលម្អនិងរៀបខឿនតាមបណ្ដោយមាត់ស្ទឹងសែននៅសងខាងគល់ស្ពានកំពង់ធំ | ក្រុងស្ទឹងសែន |
| ១០ | សួនអនុស្សាវរីយ៍មិត្តភាពកម្ពុជា ឥណ្ឌូណេស៊ី | ស្រុកបារាយណ៍ |
| ១១ | សួនច្បារមុខសាលាស្រុកបារាយណ៍និងភ្លើងបំភ្លឺសួនចំនួន៥បង្គោល | ស្រុកបារាយណ៍ |
| ១២ | សួនច្បារមុខសាលាស្រុកសន្ទុក | ស្រុកសន្ទុក |

## ១.៣- ការរៀបចំសណ្ដាប់ធ្នាប់និងភ្លើងបំភ្លឺនៅក្នុងក្រុង

| ក្រុងស្រុក | សកម្មភាព |
|---|---|
| ស្ទឹងសែន | - បំពាក់ភ្លើងបំភ្លឺសាធារណៈតាមផ្លូវនិងសួនច្បារចំនួន១ ១៩៥គ្រឿង<br>- តម្លើងភ្លើងចរាចរណ៍ចំនួន៣កន្លែង ក្នុងភូមិក្ដី សង្កាត់ព្រៃតាហ៊ូ និងចុងសងខាងស្ពានកំពង់ធំ<br>- តម្លើងអំពូលភ្លើងសញ្ញាប្រុងប្រយ័ត្នចំនួន១៩គ្រឿង តាមដងផ្លូវជាតិលេខ៦ ក្នុងស្រុក<br>- តម្លើងអំពូលសូឡាបំភ្លឺផ្លូវ២៤០បង្គោល<br>- តម្លើងក្បាលពន្លត់អគ្គីភ័យចំនួន៧កន្លែង |
| តាំងគោក | - តម្លើងអំពូលសូឡាបំភ្លឺផ្លូវ ចំនួន៤៤២គ្រឿង ក្នុងឃុំស្វាយភ្លើង និងឃុំប្រនាង<br>- តម្លើងអំពូលភ្លើងសញ្ញាប្រុងប្រយ័ត្នចំនួន៨គ្រឿង តាមដងផ្លូវជាតិលេខ៦ ក្នុងស្រុក<br>- តម្លើងក្បាលពន្លត់អគ្គីភ័យចំនួន២កន្លែង |
| បារាយណ៍ | - តម្លើងអំពូលសូឡាបំភ្លឺផ្លូវ ចំនួន៣៧៦គ្រឿង ក្នុងឃុំឈូកខ្សាច់ បល្ល័ង្ក បឹង បារាយណ៍ និងឃុំត្នោតជុំ<br>- តម្លើងអំពូលភ្លើងសញ្ញាប្រុងប្រយ័ត្នចំនួន១២គ្រឿង តាមដងផ្លូវជាតិលេខ៦ ក្នុងស្រុក<br>- តម្លើងក្បាលពន្លត់អគ្គីភ័យចំនួន៣កន្លែង |
| កំពង់ស្វាយ | - បំពាក់អំពូលសូឡាបំភ្លឺផ្លូវតាមដងផ្លូវជាតិលេខ៦ នៅភូមិព្រៃព្រាល(ខ) ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ចំនួន២៤បង្គោល និងភ្លើងចរាចរណ៍ចំនួន៤ផ្ទាំង<br>- តម្លើងអំពូលសូឡាបំភ្លឺផ្លូវ២៦បង្គោល ក្នុងឃុំក្ដីដូង<br>- តម្លើងអំពូលភ្លើងសញ្ញាប្រុងប្រយ័ត្នចំនួន១គ្រឿង តាមដងផ្លូវជាតិលេខ៦ ក្នុងស្រុក |
| ប្រាសាទបល្ល័ង្ក | - បំពាក់អំពូលភ្លើងសូឡាបំភ្លឺ តាមផ្លូវសាធារណៈនិងសួនច្បារចំនួន២៧គ្រឿងក្នុងឃុំសាលាវិស័យ (អំពូលសូឡាខ្នាតធំ១៤គ្រឿង អំពូលសូឡាខ្នាតតូច១៣គ្រឿង) |
| ស្ទោង | - បំពាក់អំពូលសូឡាបំភ្លឺផ្លូវតាមដងផ្លូវចំនួន១៣៦ដើម ក្នុងឃុំម្សាក្រង<br>- តម្លើងអំពូលភ្លើងសញ្ញាប្រុងប្រយ័ត្នចំនួន១១គ្រឿង តាមដងផ្លូវជាតិលេខ៦ ក្នុងស្រុក<br>- តម្លើងក្បាលពន្លត់អគ្គីភ័យចំនួន៤កន្លែង |

| | |
|---|---|
| សន្ទុក | - ដាក់ភ្លើងបំភ្លឺផ្លូវសាធារណៈចាប់ពីច្រមុះជ្រូកអាងទឹកភូមិ៧មករា ដល់ច្រមុះជ្រូកមុខអធិការដ្ឋាន នគរបាលស្រុកចំនួន៣៧អំពូល<br>- តម្លើងក្បាលពន្លត់អគ្គីភ័យចំនួន២កន្លែង |
| សណ្ដាន់ | - តម្លើងក្បាលពន្លត់អគ្គីភ័យចំនួន១កន្លែង |
| ប្រាសាទសំបូរ | - តម្លើងអំពូលសូឡាបំភ្លឺផ្លូវចំនួន៥០បង្គោល |

## ២- ការសាងសង់ប្រព័ន្ធធារាស្ត្រ

| ល.រ. | ឈ្មោះប្រព័ន្ធ | ស្រុក | ទំនប់ (ម.) | ប្រឡាយ (ម.) | ប្រភេទសំណង់ | | | លទ្ធភាពស្រោចស្រព(ហ.ត.) | |
|---|---|---|---|---|---|---|---|---|---|
| | | | | | បង្ហៀរ | សំណង់សិល្បៈការ | លូ | វស្សា | ប្រាំង |
| ការសាងសង់ប្រព័ន្ធធារាសាស្ត្រឆ្នាំ២០១៧ | | | | | | | | | |
| ១ | ទំនប់អូរមាន | សណ្ដាន់ | ៣៨៤ | ១០ ៥០៥ | ១ | ៩ | ៤៥ | ៧៩២ | ២៥០ |
| ២ | ទំនប់អូរទក់ | សណ្ដាន់ | ៣ ០០០ | ៩ ២០១ | ១ | ២ | ០ | ៩២៧ | ៥០ |
| ៣ | ទំនប់អូរអណ្ដែង | ប្រាសាទសំបូរ | ១ ០២៧ | ៦ ០៦៩ | ១ | ៩ | ២៥ | ៥២៦ | ៦០ |
| ៤ | ទំនប់អូរអ្នកតាកែ | ប្រាសាទសំបូរ | ៣៦៥ | ៣ ២៩៨ | ១ | ៥ | ១៥ | ២៩០ | ២០ |
| ៥ | ទំនប់អូរជីក | ប្រាសាទសំបូរ | ២ ១១៨ | | ១ | ២ | ០ | ០ | ២៤០ |
| ៦ | ទំនប់ក្រហមក | សណ្ដាន់ | ៣០០ | ៥ ០៥៥ | ១ | ៨ | ២១ | ៥២៥ | ១២០ |
| សរុបឆ្នាំ២០១៧ | | | ៧ ១៩៤ | ៣៤ ១២៨ | ៦ | ៣៥ | ១០៦ | ៣ ១៦០ | ៧៤០ |
| ការសាងសង់ប្រព័ន្ធធារាសាស្ត្រឆ្នាំ២០១៨ | | | | | | | | | |
| ៧ | យាយណៃ | ស្ទោង | | ១៤ ៨៨៦ | | ២៣ | ៨៧ | ៣៥០ | |
| ៨ | ឈូកខ្សាច់ | បារាយណ៍ | | ៩ ០៧២ | | ១២ | ២៤ | ៨០០ | ៣០០ |
| ៩ | តាំងក្រសាំង | សន្ទុក | ១៤១១០ | ៦៣៨៤៨ | ១ | ៣១២ | ១៣៥ | ១៥ ០០០ | ៤ ២០០ |
| ១០ | អូរលើ | ប្រាសាទសំបូរ | ៥៤៥ | ៣៤០២ | ១ | ៨ | ១២ | ៦១០ | ២០០ |
| សរុបឆ្នាំ២០១៨ | | | ១៤៦៥៥ | ៩១២០៨ | ២ | ៣៥៥ | ២៥៨ | ១៦ ៧៦០ | ៤ ៧០០ |
| ការសាងសង់ប្រព័ន្ធធារាសាស្ត្រឆ្នាំ២០១៩ | | | | | | | | | |
| ១១ | អូរក្រញ៉ាក | សណ្ដាន់ | ៤ ២០០ | ១៥ ០៤៥ | | ១០៥ | ៤៦ | ៦៦៨ | ២៩២ |
| ១២ | បត់ត្រង់ | ស្ទោង | ២៦៨ | ៣ ៩២០ | ១ | ៦ | ១ | ៣ ០០០ | ៤ ០០០ |
| សរុបឆ្នាំ២០១៩ | | | ៤ ៤៦៨ | ១៨ ៩៦៥ | ១ | ១១១ | ៤៧ | ៣ ៦៦៨ | ៤ ២៩២ |
| សរុបរួម | | | **២៦៣១៧** | **១៤៤៣០១** | **៩** | **៥០១** | **៤១១** | **២៣ ៥៨៨** | **៩ ៧៣២** |

## ៣- ការសាងសង់អគារចាប់ពី៥ជាន់ឡើង សណ្ឋាគារ និងផ្ទះសំណាក់

### ៣.១- អគារចាប់ពី៥ជាន់ឡើងមានចំនួន៤កន្លែង៖

| ល.រ. | ឈ្មោះ | ចំនួនជាន់ |
|---|---|---|
| ១ | ភោជនីយដ្ឋាននិងសណ្ឋាគារអរុណរះ | ៩ |
| ២ | សណ្ឋាគារកំពង់ធំរ៉ូយ៉ាល់ | ១០ |
| ៣ | អគារធនាគារវឌ្ឍនៈ | ១០ |
| ៤ | ផ្ទះសំណាក់ ទង់ គឹមឡា | ៦ |

៣.២- ស្ថិតិសណ្ឋាគារនិងផ្ទះសំណាក់

| ក្រុង/ស្រុក | សណ្ឋាគារ | ផ្ទះសំណាក់ | ភោជនីយដ្ឋាន/អាហារដ្ឋាន |
|---|---|---|---|
| ស្ទឹងសែន | ៩ | ៣៥ | ៣៩ |
| សន្ទុក | ០ | ១ | ១២ |
| បារាយណ៍ | ០ | ១០ | ៥ |
| តាំងគោក | ០ | ៣ | ៤ |
| កំពង់ស្វាយ | ១ | ២ | ៩ |
| ស្ទោង | ០ | ១០ | ៨ |
| ប្រាសាទបល្ល័ង្គ | ០ | ១ | ២ |
| ប្រាសាទសំបូរ | ០ | ២ | ៤ |
| សណ្តាន់ | ០ | ២ | ១ |
| សរុប | ១០ | ៦៦ | ៨៤ |

៤- ការរៀបចំប្រព័ន្ធព្រឹត្តិកម្មទឹកកខ្វក់

| ល.រ. | សកម្មភាពការងារ | លទ្ធផលសម្រេចបាន |
|---|---|---|
| ១ | ការងារចាក់បេតុងលូអ៊ុយ | ៥ ៣៣៩ម. |
| ២ | ការងារចាក់គម្របលូ | ៤ ២៤៥,៦៤ម. |
| ៣ | ការងារចាក់លុបខ្សាច់ | ៥ ៣៣៩ម. |
| ៤ | ការងារតំឡើងប្រព័ន្ធទុយោទឹកកខ្វក់មុខកាត់២០cm | ៥ ៦០៤ម. |
| ៥ | ការងារតំឡើងប្រព័ន្ធទុយោទឹកកខ្វក់មុខកាត់២០cm | ៧១៥ម. |
| ៦ | ការតម្លើងប្រព័ន្ធទុយោទឹកកខ្វក់មុខកាត់៣៦cm | ១ ៦៧៧ម. |

## ២.១២- ខេត្តបាត់ដំបង

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តបាត់ដំបង សម្រេចបាន៖

ជាខេត្តមួយក្នុងចំណោមរាជធានី ខេត្ត សរុបចំនួន២៥ ដែលមានទីតាំងស្ថិតនៅភូមិភាគពាយព្យនៃព្រះរាជាណាចក្រកម្ពុជា តាមបណ្តោយផ្លូវជាតិលេខ៥ និងមានចម្ងាយ២៩១គ.ម. ពីរាជធានីភ្នំពេញ។ ខេត្តបាត់ដំបងមានព្រំប្រទល់ខាងលិចទល់នឹងខេត្តប៉ៃលិននិងព្រះរាជាណាចក្រថៃ ខាងកើតទល់នឹងខេត្តពោធិ៍សាត់និងបឹងទន្លេសាប ខាងជើងទល់នឹងខេត្តបន្ទាយមានជ័យនិងខេត្តសៀមរាប ខាងត្បូងទល់នឹងខេត្តពោធិ៍សាត់។ ខេត្តបាត់ដំបងមានផ្ទៃដីសរុប១១ ៧៤៨គ.ម.$^2$ និងមានសណ្ឋានដីចែកចេញជាបីតំបន់សំខាន់ៗ រួមមានតំបន់ខ្ពស់ (ខ្ពង់រាបនិងតំបន់ព្រៃភ្នំ) ដែលជាតំបន់ចំការឈើហូបផ្លែនិងដំណាំឧស្សាហកម្ម តំបន់វាលរាប(វាលស្រែលាតសន្ធឹងតាមបណ្តោយផ្លូវជាតិលេខ៥) និងតំបន់ទំនាបជាប់បឹងទន្លេសាប។ ខេត្តបាត់ដំបងមានស្រុក ក្រុង១៤ ឃុំ សង្កាត់ ១០៣ ភូមិ៨៣០ ចំនួនគ្រួសារ២៩០ ១១៩ មានប្រជាពលរដ្ឋ១ ៣៣៨ ៥៥៤នាក់(ស្រី៦៧១ ០២៤នាក់)។

### ១- ការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការពង្រឹងសោភ័ណភាពសោភាទីក្រុង និងទីប្រជុំជន

១.១- គម្រោងអភិវឌ្ឍន៍ខេត្ត

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការងារជួសជុលផ្លូវបេតុង | ម. | ២ ២១០ | ១ ៨៣២ | ៣ ៩៩២ | ៥ ១៦៣ | ៤៨០ | ១៣ ៦៧៧ |
| ២ | ការងារជួសជុលផ្លូវកៅស៊ូ | ម. | ២ ៦៦៥ | ៣ ៥៦៦ | ១៩,២៥ | ១០ ៤០៣ | ១ ៤៥២ | ៣៧ ៣២៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | ការងារជួសជុលផ្លូវលុបសំបុកមាន់ | ម.$^{២}$ | ១៥ | ១៣,៥០ | គ្មាន | ២០ ០០០ | គ្មាន | ៤៨ ៥០០ |
| ៤ | ការងារជួសជុលផ្លូវក្រាលក្រួសក្រហម | ម. | ៤ ៨៤៩ | ១១,៧៩ | ៧ ៥២១ | គ្មាន | ៨ ៣៦៤ | ៣២ ៥២៤ |
| ៥ | ការងារដាក់លូ | ម. | ៥ ៥៥៨ | ៦ ៤៨១ | ១ ៧៦៣ | ៩៣៩ | ២៨៨ | ១៥ ០២៩ |
| ៦ | រ៉ឺហ្កា | កន្លែង | ២៣៥ | ២៧៥ | ៦២ | ៤៣ | គ្មាន | ៦១៥ |
| ៧ | ការងារស្តារប្រឡាយ | ម. | ១៤,៣១ | ៨ ៦៥០ | ២ ៨២០ | ៦ ៥០០ | ១ ៣៩០ | ៣៣ ៦៧៧ |
| ៨ | បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ | ដើម | ១៤៥ | ៨៦ | គ្មាន | ៦៤ | គ្មាន | ២៩៥ |
| ៩ | បណ្តាញខ្សែភ្លើងបំភ្លឺផ្លូវសាធារណៈ | ម. | ១១,២៧ | ៩ ៣២០ | គ្មាន | ២ ១០០ | គ្មាន | ២២ ៦៩៨ |
| ១០ | បង្គោលភ្លើងផ្កាលម្អតាមសួនច្បារ | ដើម | គ្មាន | ១២០ | គ្មាន | គ្មាន | គ្មាន | ១២០ |
| ១១ | ការបំពាក់ភ្លើងស្តុបក្នុងក្រុងបាត់ដំបង | ទីតាំង | ៥ | គ្មាន | គ្មាន | ១ | គ្មាន | ៦ |
| ១ | សាងសង់អគារច្រកចេញចូលតែមួយក្រុង ស្រុក | កន្លែង | ២ | ៣ | ៦ | គ្មាន | គ្មាន | ១១ |
| ១ | សាងសង់អគារសាលាឃុំ សង្កាត់ | កន្លែង | ៧ | ១៦ | ៨ | ៦ | គ្មាន | ៣៧ |
| ១៤ | ការងារកែលម្អសួនច្បារ | លើក | គ្មាន | ១ | ១ | ១ | ១ | ៤ |
| ១៥ | សាងសង់បណ្ណាល័យសម្តេចក្រឡាហោម | កន្លែង | គ្មាន | គ្មាន | ១ | គ្មាន | គ្មាន | ១ |
| ១៦ | សាងសង់រ៉េវ៉េងដារច្រាំងស្ទឹង | ម. | គ្មាន | គ្មាន | គ្មាន | ៥៩៨ | គ្មាន | ៥៩៨ |
| ១៧ | សាងសង់ច្រាំងស្ទឹងដោយចាក់បេតុង | ម. | គ្មាន | គ្មាន | គ្មាន | ១៨៦ | ១១២ | ២៩៨ |
| ១៨ | សាងសង់ខឿនពុះទ្រូងផ្លូវ | ម. | គ្មាន | គ្មាន | គ្មាន | ៧៦៦ | គ្មាន | ៧៦៦ |

### ១.២- ការងារអភិវឌ្ឍន៍ជនបទ

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការកសាងផ្លូវជនបទ | គ.ម. | ១១៣ | ១៤៣ | ១៣៧ | ២៤៦ | ៣១៤ | ៩៥២ |
| ២ | ការជួសជុលផ្លូវជនបទ | គ.ម. | ១០ | ៦ | ៩ | ១១ | ៣ | ៣៩ |
| ៣ | ការកសាងបង្គន់សាធារណៈ | បង្គន់ | ១០ | ១០ | គ្មាន | ៦ | ១៦ | ៤២ |
| ៤ | ការកសាងបង្គន់អនាម័យគ្រួសារ | បង្គន់ | ១ ៥១៥ | ១ ៩៧៥ | គ្មាន | ២៦៣ | គ្មាន | ៣ ៧៥៣ |
| ៥ | ការកសាងអណ្តូងស្នប់ | អណ្តូង | ៧៣ | ៤១ | ១៣ | ៨២ | ១៨១ | ៣៩០ |
| ៦ | ការកសាងស្រះសហគមន៍ | ស្រះ | ១ | ២ | គ្មាន | ៧ | គ្មាន | ១០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៧ | ការកសាងអាងត្រងទឹកភ្លៀង | អាង | ១០ | ១០ | គ្មាន | គ្មាន | ១៦ | ៣៦ |
| ៨ | ការផ្តល់ពាងត្រងទឹកភ្លៀង | ពាង | ៤ ៧៥២ | ៧ ៨៣៦ | គ្មាន | ៣ ២៣៧ | ៨ ៧៩៣ | ២៤ ៦១៨ |

## ១.៣- ការងារសាធារណការនិងដឹកជញ្ជូន

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| **ការងារវិស័យសាធារណការ** | | | | | | | | |
| **ក- ការងារសាងសង់** | | | | | | | | |
| ១ | ការងារកសាងផ្លូវកៅស៊ូ | ម. | ៣ ៨០០ | ៤ ៣០០ | ៤ ០០០ | ១០ ៨០០ | ៩ ៦០០ | ៣២ ៥០០ |
| ២ | ការងារកសាងផ្លូវបេតុងកៅស៊ូAC | ម. | គ្មាន | គ្មាន | គ្មាន | ៨ ៨៧១ | ២ ០០០ | ១០ ៨៧១ |
| ៣ | ការងារកសាងផ្លូវបេតុង | ម. | ៣៥០ | គ្មាន | គ្មាន | គ្មាន | គ្មាន | ៣៥០ |
| ៤ | ការងារសាងសង់ស្ពានថ្ម និងដែក | កន្លែង | គ្មាន | គ្មាន | ១ | ៣ | គ្មាន | ៤ |
| | | ម. | គ្មាន | គ្មាន | ១៥ | ៣៦ | គ្មាន | ៥១ |
| ៥ | ការងារសាងសង់ប្រាំងស្ទឹង | ម. | គ្មាន | ៥០ | គ្មាន | គ្មាន | គ្មាន | ៥០ |
| ៦ | ការងារសាងសង់លូកាត់ទទឹងផ្លូវ | កន្លែង | គ្មាន | គ្មាន | គ្មាន | ៨ | ១១ | ១៩ |
| **ខ- ការងារជួសជុល** | | | | | | | | |
| ១ | ការងារជួសជុលផ្លូវកៅស៊ូ | ម. | ៦ ២២០ | ១២ | ៦ ១៨០ | ៤៧ | ៧៣០ | ៧៣ ៥៨០ |
| ២ | ការងារជួសជុលផ្លូវក្រួស | ម. | ១៨ ០៧០ | ២០ ៦០០ | ២១ | ៣១ ៨៥០ | ៩ ៣៥០ | ១០១ ០៧០ |
| ៣ | ការងារជួសជុលក្បាល | កន្លែង | គ្មាន | ១ | គ្មាន | ១ | គ្មាន | ២ |
| ៤ | ការងារជួសជុលលូប្រអប់ | ម. | គ្មាន | គ្មាន | គ្មាន | ១ | គ្មាន | ១ |
| **គ- ការងារថែទាំងជាប្រចាំ** | | | | | | | | |
| ១ | ការងារថែទាំផ្លូវកៅស៊ូ | គ.ម. | ៥៦៥,១២ | ៥៧៨,៤៩ | ៨៤៥,៤៦ | ៥៥០,២៨ | ៥២៥,៧៥ | ៣ ០៦៥,១ |
| ២ | ការងារថែទាំផ្លូវក្រួស | គ.ម. | ២៧៧,៨ | ២៧៩,៣ | ៣៣៦,៤ | ៣២៨ | ៣០២,៦ | ១ ៥២៤,១ |
| **ឃ- ការងារប្រព័ន្ធលូទឹកភ្លៀង** | | | | | | | | |
| ១ | ការងារសាងសង់លូទឹកភ្លៀង | ម. | ៣៥០ | គ្មាន | គ្មាន | គ្មាន | ២ ៥០០ | ២ ៨៥០ |
| ២ | ប្រព័ន្ធលូរំដោះទឹកភ្លៀង (ADB) | | | | | | | |
| | លូប្រអប់ | ម. | គ្មាន | គ្មាន | ៥ ៤៨០ | គ្មាន | គ្មាន | ៥ ៤៨០ |
| | លូមូល | ម. | គ្មាន | គ្មាន | ៦ ១៦៦ | គ្មាន | គ្មាន | ៦ ១៦៦ |
| | ប្រឡាយចំហ | ម. | គ្មាន | គ្មាន | ៣ ៦៤៨ | គ្មាន | គ្មាន | ៣ ៦៤៨ |
| | រ៉ឺហ្គា(MH, CB1, CB2) | កន្លែង | គ្មាន | គ្មាន | ៥១០ | គ្មាន | គ្មាន | ៥១០ |
| ៣ | ជួសជុលលូទឹកភ្លៀង | | | | | | | |
| | ជួសជុលរ៉ឺហ្គាលូ | បន្ទប់ | ៥០ | ៥១ | ៤៥ | ៥៩ | គ្មាន | ២០៥ |
| | ស្តារទរតាមចិញ្ចើមផ្លូវ | ម. | ៦ ៦១១ | ៥ ១៩២ | ៣ ១៧៨ | ២ ៤០១ | គ្មាន | ១៧ ៣៨២ |
| | ស្តារបន្ទប់លូ | បន្ទប់ | ១ ០៦២ | ១ ០១០ | ១ ០២១ | ៧៣៦ | គ្មាន | ៣ ៨២៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ស្តារប្រឡាយមេ | ម. | ៣ ៣៥៤ | ៧៥០ | ៩៣ | គ្មាន | គ្មាន | ៤ ១៩៧ |
| | ស្តារប្រព័ន្ធលូ | ម. | គ្មាន | គ្មាន | ៣៦៩ | ១១៦ | គ្មាន | ៤៨៥ |
| | សាងសង់ទរចិញ្ចើមផ្លូវ | ម. | គ្មាន | គ្មាន | គ្មាន | ៦៥១ | គ្មាន | ៦៥១ |
| | ជួសជុលទរប្រអប់ | ម. | គ្មាន | គ្មាន | គ្មាន | ៨២ | គ្មាន | ៨២ |
| **ង- ការងារប្រព័ន្ធចម្រោះទឹកកខ្វក់** | | | | | | | | |
| ១ | ប្រព័ន្ធចម្រោះទឹកកខ្វក់ត្រើយខាងកើត (ADB) អនុវត្តបាន១០,២% | | | | | | | |
| | សាងសង់ស្ថានីយចម្រោះទឹកកខ្វក់ | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | ស្ថានីយបូមបញ្ជូន (ខាងជើង និងត្បូង) | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ២ | ២ |
| | ស្ថានីយរង | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ៤ | ៤ |
| | លូទឹកកខ្វក់(ប្រព័ន្ធមេ) | ម. | គ្មាន | គ្មាន | គ្មាន | គ្មាន | ៥៥ ០០០ | ៥៥ ០០០ |
| | លូប្រអប់ទឹកកខ្វក់តាមផ្ទះ | ម. | គ្មាន | គ្មាន | គ្មាន | គ្មាន | ៦០ ០០០ | ៦០ ០០០ |
| | ចំនួនតំណតាមផ្ទះ | ខ្នងផ្ទះ | គ្មាន | គ្មាន | គ្មាន | គ្មាន | ៥ ៦១៨ | ៥ ៦១៨ |
| ២ | ប្រព័ន្ធចម្រោះទឹកកខ្វក់ត្រើយខាងលិច (ADB) អនុវត្តបាន៨,៨៥% | | | | | | | |
| | សាងសង់ស្ថានីយចម្រោះទឹកកខ្វក់ | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | ស្ថានីយបូមបញ្ជូន | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | លូមេ (បំពង់ខ្លួង) | ម. | គ្មាន | គ្មាន | គ្មាន | គ្មាន | ៤ ៤៨០ | ៤ ៤៨០ |
| | លូខ្មែង | ម. | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៣ ៦៥០ | ១៣ ៦៥០ |
| | លូប្រមូលពីផ្ទះ | ម. | គ្មាន | គ្មាន | គ្មាន | គ្មាន | ៥០ ៩៥០ | ៥០ ៩៥០ |
| | ចំនួនតំណតាមផ្ទះ | ខ្នងផ្ទះ | គ្មាន | គ្មាន | គ្មាន | គ្មាន | ៤ ២០០ | ៤ ២០០ |
| | លូបញ្ចូលស្ថានីយ | ម. | គ្មាន | គ្មាន | គ្មាន | គ្មាន | ៧ ៧២០ | ៧ ៧២០ |
| **ច- ការងារសាងសង់ទីលានកប់សំរាម** | | | | | | | | |
| ១ | ការងារសាងសង់ទីលានកប់សំរាមថ្មី(ADB) អនុវត្តបាន៦៥% | | | | | | | |
| | ផ្ទៃដី | ហ.ត. | គ្មាន | គ្មាន | គ្មាន | គ្មាន | ២០,៨ | ២០,៨ |
| | អគារស្នាក់នៅ | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | ការិយាល័យ | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | ជញ្ជីងថ្លឹង | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | រោងញែកសំរាម | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | រោងជាង | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | រោងសំណល់គ្រោះថ្នាក់ | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |
| | រណ្តៅកប់សំរាមទី១ | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ | ១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | អាងប្រព្រឹត្តិកម្មទឹកកខ្វក់ចេញពីសំរាម | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ៤ | ៤ |
| | បម្រុងសម្រាប់រណ្ដៅសំរាម | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ៣ | ៣ |

## ១.៤- ការងារធនធានទឹកនិងឧតុនិយម

### ១.៤.១- ការងារសាងសង់និងស្ដារឡើងវិញប្រព័ន្ធជាពសាស្ត្រ

| ល.រ | ឈ្មោះប្រព័ន្ធ | ថវិកាអនុវត្ត | ឆ្នាំសាងសង់ | ប្រវែងប្រឡាយ(ម) | ប្រវែងទំនប់(ម) | ផ្ទៃដីស្រោចស្រព(ហ.ត.) | | ទីតាំង | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | វស្សា | ប្រាំង | ឃុំ | ស្រុក | |
| ១ | ប្រឡាយស្ទឹងត្រប់ | ក្រសួងធនធានទឹក | មុន២០១៧ | ២៨ ៥០០ | គ្មាន | ៤ ២៧៥ | គ្មាន | តាប៉ុន-កំពង់ព្រៀង | សង្កែ | |
| ២ | ប្រឡាយលេខ១ | ក្រសួងធនធានទឹក | មុន២០១៧ | ២៥ ២០០ | គ្មាន | ១១ ៦០០ | ១ ០០០ | ខ្នាចរមាស-អូរតាគី | បវេលថ្មគោល | |
| ៣ | ប្រឡាយឃោជា | ស្ថានទូតជប៉ុន | មុន២០១៧ | ១ ៤០០ | គ្មាន | ២៨០ | ៨០ | អន្លង់វុន | ថ្មគោល | |
| ៤ | ប្រឡាយអឹម៩ | JIID ជប៉ុន | មុន២០១៧ | ៤ ០៣០ | គ្មាន | ៣២០ | ៣២០ | តាក្រាម | បាណន់ | |
| ៥ | អាងទឹកបាសាក់ | ធនាគារអាស៊ី | ២០១៥-២០១៧ | ១០ ៦០០ | គ្មាន | ៧ ១០០ | គ្មាន | បាសាក់ | រុក្ខគិរី | អាងទឹក |
| ៦ | ប្រឡាយព្រែកជីក | ធនាគារអាស៊ី | ២០១៥-២០១៧ | ២៧ ៧០០ | គ្មាន | ១១ ៦៤៧ | ១ ០០០ | ព្រែកជីក | រុក្ខគិរី-មោង | |
| ៧ | សំណង់ស្ទាក់ទឹកព្រែខ្ពស់ | ធនាគារអាស៊ី | ២០១៥-២០១៧ | គ្មាន | គ្មាន | គ្មាន | គ្មាន | ព្រែកខ្ពស់ | បវេល | សំណង់ស្ទាក់ទឹកបញ្ចូលប្រឡាយព្រែខ្ពស់ |
| ៨ | ប្រឡាយព្រែខ្ពស់ | ធនាគារអាស៊ី | ២០១៥-២០១៧ | ៩ ២០០ | គ្មាន | ២ ៥៤៦ | ១ ៤៧០ | ព្រែកខ្ពស់ | បវេល | |
| ៩ | ប្រឡាយជីម៉ក់ | ក្រសួងធនធានទឹក | ២០១៧ | ៨ ៨០០ | គ្មាន | ៣ ៧៥០ | គ្មាន | គាស់ក្រឡ | គាស់ក្រឡ | |
| ១០ | អាងជ្រៃ | ក្រសួងធនធានទឹក | ២០១៧ | ៣ ៦០០ | គ្មាន | ១៥០ | ២០ | ជ្រៃ | ថ្មគោល | អាងទឹក |
| ១១ | ស្ទឹងចាស់ | ក្រសួងធនធានទឹក | ២០១៧ | ៣ ៧០០ | គ្មាន | ៥៦៥ | គ្មាន | តាប៉ុន | សង្កែ | ស្រោចស្រពនិងប្រើ |
| ១២ | ប្រព័ន្ធសាលាតាអន | កូរ៉េ | ២០១៧-២០២១ | គ្មាន | គ្មាន | គ្មាន | គ្មាន | | ឯកភ្នំ | |
| ១៣ | ប្រព័ន្ធរាមគន់ | JICAជប៉ុន | ២០១៦-២០២១ | ១២ ០០០ | គ្មាន | ១ ៩៦៩ | ៣៥០ | គារ | មោងឫស្សី | |
| ១៤ | ប្រឡាយពោធិ៍ | JICA ជប៉ុន | ២០១៦-២០២១ | ៧ ៥០០ | គ្មាន | ១ ៩៧៩ | ៣០០ | ជ្រៃ | មោងឫស្សី | |
| ១៥ | ប្រឡាយពុកឆ្មា | ក្រសួងធនធានទឹក | ២០១៨ | ៩ ៥០០ | គ្មាន | ១ ៥៦០ | គ្មាន | អន្លង់វិល | សង្កែ | |
| ១៦ | ពហុបំណងបាត់ដំបង | ចិន | ២០១៤-២០១៨ | គ្មាន | ៣ ៣២៥ | គ្មាន | គ្មាន | ផ្លូវមាស | រតនមណ្ឌល | អាងស្តុកទឹក |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៧ | ប្រឡាយ ព្រៃសង្ហា | ADB | ២០១៨ | ៤ ២០០ | គ្មាន | ១ ៥១០ | ១០០ | ខ្នាចរមាស | បវេល | |
| ១៨ | ប្រឡាយតាម៉ៅ | ADB | ២០១៨ | ១១ ៥៥០ | គ្មាន | ៦៥០ | ១៥០ | អូរតាគី | ថ្មគោល | |
| ១៩ | ប្រឡាយ អន្លង់រុន | ADB | ២០១៨ | ១៦ ៥៦៥ | គ្មាន | ១ ៥០០ | ២០០ | អន្លង់រុន | ថ្មគោល | |
| ២០ | ទំនប់ដូនទ្រី | កូរ៉េ | ២០១៨-២០២៣ | គ្មាន | គ្មាន | គ្មាន | គ្មាន | បាសាក់ | រុក្ខគីរី | អាងស្តុកទឹក |
| ២១ | ប្រឡាយរាមចក្រី | ក្រសួងធនធានទឹក | ២០១៩ | ៦ ៣០០ | គ្មាន | គ្មាន | គ្មាន | កំពង់ព្រះ | សង្កែ | |
| ២២ | ប្រឡាយ នាងលក្ខិ | ក្រសួងធនធានទឹក | ២០១៩ | ៧ ៥០០ | គ្មាន | គ្មាន | គ្មាន | ក្តុលតាហែន | បវេល | |
| ២៣ | អំពិលប្រាំដើម | ក្រសួងធនធានទឹក | ២០១៩ | ៤ ៥០០ | គ្មាន | គ្មាន | គ្មាន | អំពិលប្រាំដើម | បវេល | |
| ២៤ | ទួលញៅ | ក្រសួងធនធានទឹក | ២០២០ | 8 000 | គ្មាន | គ្មាន | គ្មាន | តាប៉ុន | សង្កែ | |
| ២៥ | ប្រឡាយ N4 | ក្រសួងធនធានទឹក | ២០២០ | ៦ ៤០០ | គ្មាន | គ្មាន | គ្មាន | បឹងព្រីង | ថ្មគោល | |
| ២៥ | ប្រឡាយ តាសុវណ្ណ | ក្រសួងធនធានទឹក | ២០២១ | ១០ ៧០០ | គ្មាន | គ្មាន | គ្មាន | កំពង់ព្រៀង | សង្កែ | |
| ២៧ | ប្រឡាយទ្វារ៨ | ក្រសួងធនធានទឹក | ២០២១ | ៩ ៦០០ | គ្មាន | គ្មាន | គ្មាន | តាគ្រាម | បាណន់ | |

### ១.៤.២- កិច្ចដំណើរការ និងការថែទាំប្រចាំ

| លរ. | ឈ្មោះប្រព័ន្ធ | ថវិកាអនុវត្ត | ឆ្នាំថែទាំ | ប្រវែងប្រឡាយ (ម) | ប្រវែងទំនប់ (ម) | ផ្ទៃដីស្រោចស្រព (ហ.ត) | | គ្រួសារទទួលផល | ទីតាំង | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | វស្សា | ប្រាំង | | ឃុំ | ស្រុក | |
| ១ | ប្រឡាយបឹងថ្កូវ | ក្រសួងធនធានទឹក | ២០១៥-២០២១ | ៧ ១០០ | គ្មាន | ១២០០ | ៣០០ | ២ ៣៥៨ | តាពូង | ថ្មគោល | |
| ២ | អាងដង្កោ | ក្រសួងធនធានទឹក | ២០១៥-២០២១ | ២ ៣០០ | ២៥០០ | ៣០០ | ១២០ | ៨៨៧ | ភ្នំសំពៅ | បាណន់ | |
| ៣ | ក្លីអាងទី២ កំពីងពួយ | ក្រសួងធនធានទឹក | ២០១៥-២០២១ | គ្មាន | ៧២០០ | ២៦២៥ | ៣៨៥ | ១ ២៨១ | ស្ទឹង-តាគ្រាម | បាណន់ | |
| ៤ | អាងភាស | ក្រសួងធនធានទឹក | ២០១៥-២០២១ | គ្មាន | ១១៦០០ | ៣២៥០ | ៩៨៥ | ១ ៦៨៦ | ពាមឯក | ឯកភ្នំ | |
| ៥ | ប្រឡាយចបកាប់ | ក្រសួងធនធានទឹក | ២០១៦-២០២១ | ២ ៦០០ | គ្មាន | ១២០០ | ៥០០ | ១ ៦៦៥ | អូរតាគី | ថ្មគោល | |
| ៦ | ប្រឡាយមុខ៤ | ក្រសួងធនធានទឹក | ២០១៦-២០២១ | ១ ៩០០ | គ្មាន | ២៦៥ | ២០០ | ១៧០ | អូរតាគី | ថ្មគោល | |
| ៧ | ប្រឡាយ TC1&TC2 | ក្រសួងធនធានទឹក | ២០១៦-២០២១ | ២ ២០០ | គ្មាន | ២២០ | ១៦៣ | ១៧៨ | អូរតាគី | ថ្មគោល | |
| ៨ | អាងបាដាក | ក្រសួងធនធានទឹក | ២០១៦-២០២១ | ១ ៨០០ | ៩០០ | ៣០៨ | ២០០ | ៦០២ | តាប៉ុន | សង្កែ | |
| ៩ | ប្រឡាយទួលស្វាយ | ក្រសួងធនធានទឹក | ២០១៦-២០២១ | ២ ៤០០ | គ្មាន | ១៥៩ | ១០០ | ៥៦ | អូរតាគី | ថ្មគោល | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១០ | ប្រឡាយទួលបល្ល័ង្គ | ក្រសួងធនធានទឹក | ២០១៦-២០២១ | ២ ៤៥០ | គ្មាន | ២៨០ | ២៣០ | ១៤៣ | អូរតាគី | ថ្មគោល | |
| ១១ | ប្រឡាយស្វាយអា | ក្រសួងធនធានទឹក | ២០១៦-២០២១ | ៤ ០០០ | គ្មាន | ១១៦៥ | ៦០០ | ៥១៣ | ខ្នាចរមាស | បវេល | |
| ១២ | ប្រឡាយយោធា | ក្រសួងធនធានទឹក | ២០១៧-២០២១ | ១ ៤០០ | គ្មាន | ២៨០ | ៨០ | ២២៣ | អន្លង់វុន | ថ្មគោល | |
| ១៣ | ប្រឡាយអឹម៩ | ក្រសួងធនធានទឹក | ២០១៧-២០២១ | ២ ៥៣០ | គ្មាន | ៣២០ | ៣២០ | ១៩០ | តាគ្រាម | បាណន់ | |
| ១៤ | ប្រព័ន្ធប្រឡាយកង្ហត | ក្រសួងធនធានទឹក | ២០១៦-២០២១ | ១៩៨២៥០ | គ្មាន | ៥០៥៤៣ | ១០ ០០០ | ៦៣ ១៧៩ | ១ក្រុង-១៧ឃុំ | ៤ស្រុក-១សង្កាត់ | ប្រព័ន្ធកង្ហត |
| ១៥ | ភ្លឺអាង និង ប្រឡាយមេ កំពីងពួយ | ក្រសួងធនធានទឹក | ២០១៨-២០២១ | ៩ ៦០០ | ៦០០០ | ២២០០០ | ១២ ០០០ | ១៨ ៥០០ | តាគ្រាម | បាណន់ | ប្រព័ន្ធកំពីងពួយ |
| ១៦ | ប្រឡាយបឹងខ្នុំ | ក្រសួងធនធានទឹក | ២០១៩-២០២១ | ១ ៦៥០ | គ្មាន | ១៤៧ | ១១០ | ៦៦ | អូរតាគី | ថ្មគោល | |
| ១៧ | ទ្វារទឹកសំណង់តាហែន | ក្រសួងធនធានទឹក | ២០១៩-២០២១ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | |
| ១៨ | ទ្វារទឹកទំនបពហុបំណងបាត់ដំបង | | ២០១៩-២០២១ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | |

### ១.៤.៣- ការងារជួសជុលបន្ទាន់

| ល.រ. | ឈ្មោះប្រព័ន្ធ | ថវិកាអនុវត្ត | ឆ្នាំសាងសង់ | ប្រវែង (ម) | ផ្ទៃដីស្រោចស្រព (ហ.ត) | | ទីតាំង | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | វស្សា | ប្រាំង | ឃុំ | ស្រុក | |
| ១ | ប្រឡាយមេលេខ៥ | ក្រសួងធនធានទឹក | មុន២០១៧ | ៥០០ | ៦៥០ | | ឈើទាល | បាណន់ | ប្រព័ន្ធកង្ហត |
| ២ | ប្រឡាយរងលេខ៣, ៩, ១៣, ១៤, និងលេខ១៧ | ក្រសួងធនធានទឹក | មុន២០១៧ | ៧ ២០០ | ២ ៧៥០ | | ឈើទាល បាយដំរាំ កន្ទឺ២ រាំងកេសី | បាណន់ និង សង្កែ | ប្រព័ន្ធកង្ហត |
| ៣ | ប្រឡាយទួលពង្រ+ល្វា | ក្រសួងធនធានទឹក | មុន២០១៧ | ៣ ៩០០ | ៧៨០ | | ព្រៃខ្ពស់និងល្វា | បវេល | |
| ៤ | ប្រឡាយមេកំពីងពួយ | ក្រសួងធនធានទឹក | មុន២០១៧ | ២៦០ | - | | តាគ្រាម | បាណន់ | សំណង់បង្ហៀរ១កន្លែង |
| ៥ | ប្រឡាយអូរខ្ចាយ | ក្រសួងធនធានទឹក | មុន២០១៧ | ១ ០០០ | ២២៣ | - | អូរដំបង១ | សង្កែ | |
| ៦ | អាងបាដាក | ក្រសួងធនធានទឹក | មុន២០១៧ | ១២០ | ៣០៨ | | តាប៉ុន | សង្កែ | |
| ៧ | សំណង់ព្រែកអាំ | ក្រសួងធនធានទឹក | មុន២០១៧ | ១ | - | | របស់មង្គល | | ១កន្លែង |
| ៨ | ក្បាលប្រឡាយលេខ១ | ក្រសួងធនធានទឹក | មុន២០១៧ | ១២០ | ១ ៨៥៦ | | ខ្នាចរមាស | បវេល | |
| ៩ | ប្រឡាយគោកពន្លៃ | ក្រសួងធនធានទឹក | មុន២០១៧ | ៧៥០ | ១០៦ | | អូរម៉ាល់ | ក្រុងបាត់ដំបង | |
| ១០ | ប្រឡាយទួលព្រំ | ក្រសួងធនធានទឹក | មុន២០១៧ | ២ ៣៥០ | ៤៧២ | | កកោះ | មោងឫស្សី | |
| ១១ | ប្រឡាយបឹងទឹម | ក្រសួងធនធានទឹក | មុន២០១៧ | ៥០០ | ៣៤០ | | តាប៉ុន | សង្កែ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១២ | ស្ពានបើកមុខទឹកកាយដាក់លូតាមស្ទឹងចាស់ | ក្រសួងធនធានទឹក | មុន២០១៧ | ១០០ | ៦២០ | | តាប៉ុន | សង្កែ | |
| ១៣ | ទប់ទំនប់បត់ត្រង់ | ក្រសួងធនធានទឹក | មុន២០១៧ | ១០០ | - | | បត់ត្រង់ | មង្គលបូរី | |
| ១៤ | ស្ពានស្ទឹងស្វាយចេក | ក្រសួងធនធានទឹក | មុន២០១៧ | ៨ ០០០ | - | | | | |
| ១៥ | ប្រឡាយកុមារ | ក្រសួងធនធានទឹក | មុន២០១៧ | ១ ៥០០ | ៥ ២០០ | | អូរម៉ាល់ | ក្រុងបាត់ដំបង | |
| ១៦ | ប្រឡាយដីម៉ក់ | ក្រសួងធនធានទឹក | មុន២០១៧ | ៦ ៧០០ | ៣ ៧៥០ | | គាស់ក្រឡ | គាស់ក្រឡ | |
| ១៧ | ប្រឡាយទួលភ្នៅ | ក្រសួងធនធានទឹក | មុន២០១៧ | ៨ ០០០ | ៦២០ | | តាប៉ុន | សង្កែ | |
| ១៨ | ប្រឡាយស្វាយស | ក្រសួងធនធានទឹក | ២០១៧ | ៤ ០០០ | ៣៤០ | | តាប៉ុន | សង្កែ | |
| ១៩ | ប្រឡាយមេបវេល | ក្រសួងធនធានទឹក | ២០១៧ | ៣ ២០០ | - | | បវេល | បវេល | |
| ២០ | សំណង់ស្ពាក់ទឹកបវេល | ក្រសួងធនធានទឹក | ២០១៧-២០១៨ | ៩៥ | - | | បវេល | បវេល | ៣កន្លែង |
| ២១ | ប្រឡាយមេអូរដូនពៅ | ក្រសួងធនធានទឹក | ២០១៧ | ១០០០០ | ៤ ៤០០ | ៥០ | ឃ្លាំងមាស | បវេល | |
| ២២ | ស្ពានបឹងបួរខ្លា | ក្រសួងធនធានទឹក | ២០១៧ | ១ ២០០ | - | - | វត្តតាមិម | សង្កែ | ស្តុកទឹកសម្រាប់ប្រជាពលរដ្ឋប្រើ |
| ២៣ | សំណង់តាហែន | ក្រសួងធនធានទឹក | ២០១៧ | ៦៣ | - | - | ក្តុលតាហែន | បវេល | ៤ កន្លែង |
| ២៤ | សំណង់ស្ពាក់ទឹកស្ពានកណ្តាល និងប្រឡាយមេបវេល | ក្រសួងធនធានទឹក | ២០១៨ | ៦០០ | - | - | បវេល | បវេល | ប្រព័ន្ធបវេល |

## ១.៥- ការងាររ៉ែ និងថាមពល

ក្នុងរយៈពេល៥ឆ្នាំនេះ មន្ទីររ៉ែ និងថាមពលខេត្តបានផ្តោតការយកចិត្តទុកដាក់អនុវត្តជាប្រចាំនូវការងារ ធនធានរ៉ែ និងថាមពលជាចំបង ដែលបានសម្រេចសមិទ្ធផលដូចខាងក្រោម៖

**ការងារធនធានរ៉ែ**

| ល.រ. | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ក- អាជ្ញាបណ្ណចេញដោយក្រសួង | | | | | | | | |
| ១ | ថ្មសំណង់ | អាជ្ញាបណ្ណ | ៧ | ៧ | ៦ | ៧ | ៧ | ៣៤ |
| ២ | អាជីវកម្មថ្មអារ | អាជ្ញាបណ្ណ | ២ | ២ | ២ | ១ | ៤ | ១១ |
| ៣ | ការស្វែងរុករកថ្មលោហៈ | អាជ្ញាបណ្ណ | ១ | ១ | ២ | ២ | ២ | ៨ |
| ៤ | ឧស្សាហកម្មអាជីវកម្មរ៉ែ | អាជ្ញាបណ្ណ | ២ | ២ | ២ | ២ | ២ | ១០ |
| ៥ | អាជីវកម្ម ដីក្រហម | អាជ្ញាបណ្ណ | ២ | ២ | ២ | ២ | ២ | ១០ |
| សរុប | | **អាជ្ញាបណ្ណ** | **១៤** | **១៤** | **១៤** | **១៤** | **១៧** | **៧៣** |
| ខ- ចំណូលសម្បទានរ៉ែតាមបណ្តាឆ្នាំ | | | | | | | | |
| ១ | សួយសារធនធានរ៉ែ | ដុល្លារ | | ១ ៣៧៣ ៤៥៨,១៩ | | ២ ០៨៩ ៥២៦,៩១ | | ៨ ០១៩ ៧៧៧,០២ |

- **ការងារថាមពល**

| ល | បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ចំនួនថាមពលដែលបានប្រើប្រាស់ | Kwh | ២៨២២៦៥៧០៤ | ២៩២២៤១៧២៨ | ៣៩១៨១៦៨៧ | ៤៨២២១១០៣ | ២៩៩៧០៦២៧៩ | ៩៦១៦១៦៥០១ |
| ២ | ប្រវែងបណ្ដាញខ្សែតុងស្យុងមធ្យម | Kwh | ២ ៨៣៥,៥០ | ២ ៩៤៣,៣៤ | ៣ ៤៦៥,៥០ | ៣ ៥២៧,៦៥ | ៤ ៦២៦,៨៧ | ១៧ ៣៩៨,៨៦ |
| ៣ | ប្រវែងបណ្ដាញខ្សែតុងស្យុងមទាប | Kwh | ១ ៧៥០,៥០ | ១ ៧៧០,៣០ | ១ ៦៦០,២០ | ១ ៨៤០,៣៥ | ២ ២៨៣,៦៨ | ៩ ៣០៥,០៣ |
| ៤ | ភាគរយនៃចំនួនគ្រួសារដែលមានអគ្គិសនីប្រើ | % | ៨០ | ៨៥ | ៩០ | ៩៣ | ៩៥ | ៨៨,៦ |

## ១.៦- ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| ល | បរិយាយ | ឯក | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|---|
| ក- ការងារទឹកស្អាតឯកជន | | | | | | | | |
| ១ | បរិមាណផលិតទឹកស្អាត | ម.៣ | ២០២២៥៦៤ | ២៤៧២២០៥ | ៣១៦១៦៩២ | ២៩៦១៨៤០ | ២៧៩៦៣១៧ | ១៣៤១៤៦១៨ |
| ២ | ប្រវែងបណ្ដាញទឹកស្អាត | ម. | ៥៣៩ ៨៨១ | ៥៨៩ ០៧៧ | ៦៥៧ ១៤៩ | ៧២៩ ៤០០ | ៨៦៧ ៤២០ | ៣ ៣៨២ ៩២៧ |
| ៣ | ភាគរយនៃចំនួនគ្រួសារដែលមានទឹកស្អាតប្រើ | % | ២០,៨១ | ២២,៧៧ | ២៥,១៥ | ២៧,៦៩ | ៣១,៣៣ | ២៥,៥៥ |
| ខ- ការងាររដ្ឋាករទឹកបាត់ដំបង | | | | | | | | |
| ១ | បរិមាណផលិតទឹកស្អាត | ម.៣ | ៦ ៥២៧ ៧៦៩ | ៧ ៧១០ ៣៦២ | ៩ ១០៥ ១៩៦ | ៩ ៩៥៦ ២៧០ | ៨ ៩៦២ ៧៦៦ | ៤៧ ១៨៧ ៧១៦ |
| ២ | ប្រវែងបណ្ដាញទឹកស្អាត | ម. | ៤៩៤ ៦៨៩,១ | ៥៦៤ ២០៦,៩ | ៦០៥ ៥០១,៩ | ៦៥១២៦៤,៩ | ៦៨៤ ៥២៧ | ៣៤៣៧៣៩៦,៨ |
| ៣ | ភាគរយនៃចំនួនគ្រួសារដែលមានទឹកស្អាតប្រើ | % | ៤៣,០៤ | ៤៧,៦៣ | ៥៧,២៥ | ៦៣,៩៧ | ៦៥,២៩ | ៥៥,៤៣ |

## ២- ការសាងសង់អគារចាប់ពី៥ជាន់ឡើង (សណ្ឋាគារ ខុនដូរ ផ្ទះសំណាក់...)

| ល.រ. | បរិយាយ | ឯកតា | មុនឆ្នាំ ២០១៧ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|---|
| ១ | ចំនួនសណ្ឋាគារ | អគារ | ៦ | គ្មាន | គ្មាន | ១ | គ្មាន | គ្មាន |
| ២ | ចំនួនធនាគារ | អគារ | គ្មាន | គ្មាន | ១ | ១ | គ្មាន | គ្មាន |
| ៣ | ចំនួនអគារពាណិជ្ជកម្ម | អគារ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ៤ | ចំនួនផ្ទះសំណាក់ | អគារ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ៥ | ចំនួនខុនដូរ | អគារ | ១ | គ្មាន | ១ | គ្មាន | គ្មាន | គ្មាន |

## ២.១៣- ខេត្តប៉ៃលិន

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តប៉ៃលិន សម្រេចបាន៖**

ខេត្តប៉ៃលិន គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ដែលមានព្រំប្រទល់ខាងលិចទល់នឹងខេត្តចន្ទបុរីនៃព្រះរាជាណាចក្រថៃ ខាងកើតទល់នឹងស្រុករតនៈមណ្ឌល ខាងជើងទល់នឹងស្រុកកំរៀង និងខាងត្បូងទល់នឹងស្រុកសំឡូតនៃខេត្តបាត់ដំបង ដែលមានផ្ទៃដីសរុបចំនួន១ ០៦២គ.ម.$^{២}$ ចែកចេញជា១ក្រុង ១ស្រុក និងមាន ៨ឃុំ សង្កាត់ និងភូមិចំនួន៩០ភូមិ។ ខេត្តប៉ៃលិន មានប្រជាពលរដ្ឋសរុបចំនួន១៦ ៩០៦គ្រួសារ មានប្រជាពលរដ្ឋសរុប៨១ ១១៣នាក់(ស្រី៣៦ ២៣៧នាក់)(ឆ្នាំ២០២១)។

**១- ការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងបាន៖**

- ថែទាំជួសជុលផ្លូវខេត្តលេខ១ ៥៧៩(ភូមិក្រចាប់) ប្រវែង៧គ.ម.
- ថែទាំផ្លូវខួប ផ្លូវជាតិលេខ៥៧ លេខ៥៩ ផ្លូវខេត្តនិងផ្លូវក្រុង ស្រុក ប្រវែង១៨៦,០៥គ.ម.
- ជួសជុលផ្លូវបន្ទាន់(ផ្លូវខេត្តលេខ1PL1) ប្រវែង៥,៧គ.ម. និងស្ពានបាឡេត៍ ប្រវែង២១ម.
- ថែទាំជួសជុលផ្លូវខេត្តលេខ ១៥៧៩ (ភូមិក្រចាប់) ប្រវែង៤,៥គ.ម.
- ស្ថាបនាប្រព័ន្ធលូបង្ហូរទឹក(លូអ៊ុយ)៤កន្លែង
- ថែទាំផ្លូវជាតិលេខ៥៧ និងលេខ៥៩ ផ្លូវខេត្ត DBST ២ខ្សែ ផ្លូវខេត្ត ក្រួសល្បាយថ្ម៧ខ្សែ ផ្លូវក្នុងក្រុង៧ខ្សែ
- ជួសជុលបន្ទាន់ផ្លូវក្រាលក្រួសល្បាយថ្មភ្នំលើកំណាត់ផ្លូវខេត្ត១៥៧៩អា សាងសង់ស្ពានបេឡេត៍ (អូរខ្ទឹង) លើកំណាត់ផ្លូវខេត្ត១៥៧៩អា ការងារស្ថាបនាប្រព័ន្ធលូមូលបណ្ដោយផ្លូវមុខកាត់០,៨០ម. លើកំណាត់ផ្លូវជាតិលេខ៥៩ ការងារស្ថាបនាប្រព័ន្ធលូបង្ហូរទឹក(លូអ៊ុយ) តាមបណ្ដោយផ្លូវជាតិលេខ៥៩ ការងារជួសជុលផ្លូវក្នុងក្រុងលេខ១០៦សេ ជាប្រភេទបេតុងសរសៃដែកការងារស្ថាបនាប្រព័ន្ធលូមូលបណ្ដោយផ្លូវមុខកាត់០,៨០ម. លើកំណាត់ផ្លូវក្នុងក្រុងលេខ១០៦ ការងារជួសជុលផ្លូវក្រាលក្រួសល្បាយថ្មភ្នំ(គម្រោងបន្ទាន់ កំណាត់ទី១)ការងារជួសជុលផ្លូវក្រាលក្រួសល្បាយថ្មភ្នំ(គម្រោងបន្ទាន់ កំណាត់ទី២) ការងារជួសជុលផ្លូវក្រាលក្រួសល្បាយថ្មភ្នំ(គម្រោងបន្ទាន់ កំណាត់ទី៣)រួចរាល់ស្អាត
- សាងសង់ផ្លូវដោយក្រាលកៅស៊ូ DBST ប្រវែង៤ ៥០០ម.
- ការងារស្ថាបនាលូមូល ៣ម. x ២,៥ម. x ១២ម. ចំនួន៣កន្លែង។ ស្ថាបនាលូកាត់ទទឹងផ្លូវ១ជួរ ១២ម. ប្រវែង១២ម. (លូ៦កង់) ចំនន្ទ៨កន្លែង។ ស្ថាបនាលូកាត់ទទឹងផ្លូវ ២ជួរ ១២ម. ប្រវែង១២ម.(លូ៦កង់)ចំនួន១កន្លែង
- ជួសជុលផ្លូវក្រាលកៅស៊ូជាប្រភេទ(DBST) ផ្លូវខេត្តលេខ១៥៧៩ ប្រវែង២ ៦៣០ម.
- ស្ថាបនាប្រព័ន្ធលូបង្ហូរទឹក(លូអ៊ុយ) តាមបណ្ដោយផ្លូវជាតិលេខ៥៧ ប្រវែង៩៩៥ម. ទទឹង១,០៤ម. និងកម្ពស់១,៣២ម.។ ស្ថាបនាប្រព័ន្ធលូបង្ហូរទឹក(លូមូល) មុខកាត់០,៨០ម. ប្រវែង១៣០ម. និងអណ្ដូងលូរៀបឥដ្ឋចំនួន៤កន្លែង
- ជួសជុលក្រាលកៅស៊ូជាប្រភេទ(DBST) ផ្លូវខេត្តលេខ១៥៧៩F ប្រវែង១ ៣១៥ម.
- ជួសជុលផ្លូវក្រាលក្រួសល្បាយថ្មភ្នំ ស្ថិតលើផ្លូវខេត្តលេខ១៥៧៦B1 ប្រវែង៤ ៥៦២ម.
- ថែទាំផ្លូវជាតិ២ខ្សែ ៥៧និង៥៩ ប្រវែង៥៣,៧៥គ.ម.។ ផ្លូវខេត្តក្រាលកៅស៊ូជាប្រភេទ(DBST) ៣ខ្សែ (១៥៧៦B ១៥៧៩F និង១៥៧៩) ប្រវែង២៧,៨២គ.ម.។ ផ្លូវខេត្តក្រួសល្បាយថ្មភ្នំ៧ខ្សែ(១៥៧៦ ១៥៧៨ ១៥៧៩ ១៥៩៣ ១៥៩៤ ១PL១ ១ PL៣) ប្រវែង១៣៧,៤៨គ.ម. ផ្លូវក្នុងក្រុង១ខ្សែ ចំនួន១០គ.ម.

- ជួសជុលកំណាត់ផ្លូវជាតិលេខ៥៧ ក្រាលកៅស៊ូប្រភេទDBST និងស្រោចកៅស៊ូពីរជាន់

- ជួសជុលផ្លូវក្រាលកៅស៊ូប្រភេទDBST ប្រវែង៤,១៥០ម. ទទឹង៧ម.

- ថែទាំផ្លូវថ្នល់ជាប្រចាំកំណាត់ផ្លូវជាតិ និងផ្លូវខេត្ត(ផ្លូវក្រាលកៅស៊ូ) ៧៥,៨៨គ.ម. និងផ្លូវក្រាលដីក្រួសក្រហម ឬដីល្បាយថ្មភ្នំ១៤៩,៦៤គ.ម. និងផ្លូវឆ្លងកាត់ក្រុង(ផ្លូវក្រាលកៅស៊ូ) ១ខ្សែ ប្រវែង១០គ.ម.

- ជួសជុលផ្លូវក្រាលក្រួសល្បាយថ្មភ្នំ ចំនួន៤ខ្សែ ប្រវែង១២ ១២២ម. ទទឹង៧ម.

- ស្ថាបនាលូប្រព័ន្ធលូបង្ហូរទឹក(លូអ៊ុយ) ទំហំ១,០៤ម. x ១,៣២ម. ប្រវែង៣ ៩៤៦ម. ឱបឺអេសជី៧៤០ម. ទទឹង១០ម. ៥៥២ម. ទទឹង១០ម. នៅលើកំណាត់ផ្លូវជាតិលេខ៥៧

- ស្ថាបនាលូប្រព័ន្ធលូបង្ហូរទឹក(លូអ៊ុយ) ទំហំ១,០៤ម. x ១,៣២ម. ប្រវែង១ ៥៦៥ម.

- ស្ថាបនាប្រព័ន្ធបង្ហូរទឹក(លូមូល) អង្កត់ផ្ចិត១ម. ពីរជួរប្រវែង៨០ម. នៅលើកំណាត់ផ្លូវជាតិលេខ៥៩

- ជួសជុលលូប្រអប់កាត់ទទឹងថ្នល់មុខមួយ មុខកាត់៣ម.×២,៥ម. ប្រវែង១២ម. ចំនួន១កន្លែង លូមូលកាត់ទទឹងថ្នល់មុខពីរ អង្កត់ផ្ចិត១ម. ប្រវែង១២ម. ចំនួន៤កន្លែង លូមូលកាត់ទទឹងថ្នល់មុខមួយ អង្កត់ផ្ចិត១ម. ប្រវែង១២ម. ចំនួន១កន្លែង ប្រឡាយបេតុង រាងចតុកោណញាយ មុខកាត់ក្នុង(បាតធំ១,៥ម. បាតតូច០,៥ម. ជម្រៅ១ម.) ប្រវែង១៦៣ម. លូមូលរំដោះទឹកមុខពីរ អង្កត់ផ្ចិត១ម. ប្រវែង៥០ម. លូមូលរំដោះទឹកមុខមួយ អង្កត់ផ្ចិត១ម. ប្រវែង៤៣ម. អណ្តូងលូទំហំ២,៥០ម.× ៣,៧៤ម.×២,៦៥ម. ចំនួន២កន្លែង និងអណ្តូងលូទំហំ២,៥០ម.× ២,០២ម.× ២,៧៦ម. ចំនួន២កន្លែង លើកំណាត់ផ្លូវខេត្តលេខ១៥៩៣។

**២- ការងារផ្គត់ផ្គង់ប្រព័ន្ធថាមពលនិងអគ្គិសនីបាន៖**

- ធ្វើសម្រុះសម្រួលរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនអគ្គិសនីក្នុងការពង្រីកបណ្តាញភ្លើងអគ្គិសនីនៅភូមិអូរប្រើសចំនួន១លើក

- ត្រួតពិនិត្យទីតាំងដាក់បង្គោលភ្លើងអគ្គិសនីបំភ្លឺផ្លូវសាធារណៈចំនួន២លើក

- ពង្រីកបណ្តាញអគ្គិសនីទៅតាមក្នុងភូមិចំនួន៦ភូមិ ក្នុងស្រុកសាលាក្រៅ និងភូមិមួយចំនួនក្នុងសង្កាត់អូរតាវៅ ក្រុងប៉ៃលិន

- សហការជាមួយអ្នកពាក់ព័ន្ធដើម្បីដោះស្រាយ និងវាយតម្លៃផលប៉ះពាល់គម្រោងខ្សែបញ្ជូនអគ្គិសនី១១៥គីឡូវ៉ុល ពីខេត្តបាត់ដំបង មកខេត្តប៉ៃលិន

- សាងសង់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន៦០ដើម

- ដោះស្រាយបញ្ហាកុងទ័រដើរលឿនខុសប្រក្រតីចំនួន១លើក

- ស្រាយបញ្ហាតម្លៃអគ្គិសនីចំនួន៣លើក

- ដោះស្រាយរំកិលបង្គោលភ្លើងអគ្គិសនី១ដើម

- ត្រួតពិនិត្យកុងទ័រភ្លើង របស់ប្រជាពលរដ្ឋនៅឃុំសាលាក្រៅចំនួន១៩គ្រឿង

- សាងសង់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន៦០ដើម

- ពង្រីកបណ្តាញអគ្គិសនី ទៅដល់ចំនួន៤ភូមិបន្ថែម

- ចុះពិនិត្យមើលការដាក់បង្គោលភ្លើងអគ្គិសនី ស្រុកសាលាក្រៅ

- ធ្វើការពង្រីកបណ្តាញអគ្គិសនីក្នុងឃុំ សង្កាត់ទាំង៨ នៃខេត្តប៉ៃលិន

- វាស់វែងកំណត់ទីតាំងសាងសង់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ នៅក្រោយបេនឡានថ្មី

- សហការជាមួយមន្ត្រីជំនាញនាយកដ្ឋានថាមពល ធ្វើការស្រង់ស្ថិតិការប្រើប្រាស់ថាមពល អគ្គិសនីតាមសណ្ឋាគារ ផ្ទះសំណាក់ សហគ្រាស ពាណិជ្ជកម្ម ក្នុងខេត្តប៉ៃលិន

- ត្រួតពិនិត្យបច្ចេកទេសនៃការភ្ជាប់បណ្តាញភ្លើងបំភ្លឺផ្លូវសាធារណៈបានចំនួន២លើក។

**៣- ការងារផ្គត់ផ្គង់ទឹកស្អាត**

- ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន៣ក្រុមហ៊ុន ដែលបណ្តាញចែកចាយទឹកសរុបមានចំនួន ១១៤គ.ម. ដែលអាចធ្វើផលិតទឹកស្អាតបានចំនួន៧០៧ ៧៨៩ម.៣ ក្នុងមួយឆ្នាំសម្រាប់ផ្គត់ផ្គង់ទឹកស្អាតនៅ៧ឃុំសង្កាត់ ស្មើនឹង៥២ភូមិ ហើយប្រជាពលរដ្ឋទទួលសេវាទឹកស្អាតមានចំនួនសរុប៧ ៥៥០គ្រួសារ

- សាងសង់អាងត្រងទឹកភ្លៀងទំហំ៤ម៉ែត្រគូបចំនួន១៥កន្លែង

- ជីកស្រះសហគមន៍ទំហំ៣០ម. x ៤០ម. x ៣ម. ចំនួន១ស្រះ

- ពង្រីកបណ្តាញការផ្គត់ផ្គង់ទឹកស្អាតបានចំនួន៥៨ភូមិ ដែលមានបណ្តាញចែកចាយទឹកសរុប១៣០ គ.ម. ដែលអាចផលិតទឹកបានចំនួន១ ០២៣ ៨៧៣ម.៣ ហើយប្រជាពលរដ្ឋទទួលសេវាទឹកស្អាតមានចំនួនសរុប ៦ ៦៨២គ្រួសារ

- ពង្រីកបណ្តាញចែកចាយទឹកសរុប១៤១,៩គ.ម. ដែលអាចផលិតទឹកចំនួន១ ៤៩២ ៥៧៧ម.៣ ហើយប្រជាពលរដ្ឋទទួលសេវាទឹកស្អាតមានចំនួនសរុប១២ ៤៤៦គ្រួសារ

- ពង្រីកបណ្តាញចែកចាយទឹកសរុបប្រវែង១៤៣,៥គ.ម. ដែលអាចផលិតទឹកបានចំនួន១ ១៤៧ ៨៣៨ ម.៣ ហើយប្រជាពលរដ្ឋទទួលសេវាទឹកស្អាតមានចំនួនសរុប៩ ៧៥៦គ្រួសារ

- តបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋចំនួន៣ភូមិ(ភូមិ បុស្ព៌ ភូមិដូង និងភូមិអូរអណ្តូង) ក្នុងស្រុកសាលាក្រៅ ស្មើនឹង៦៤ខ្នងផ្ទះ។

**៤- ការសាងសង់អគារ**

| ល.រ. | បរិយាយ | ចំនួន | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | សណ្ឋាគារ | ១ | ១ | ២ | គ្មាន | ១ |
| ២ | មីក្រូហិរញ្ញវត្ថុ | គ្មាន | គ្មាន | ១ | គ្មាន | គ្មាន |
| ៣ | ធនាគារ | ១ | គ្មាន | គ្មាន | គ្មាន | ១ |
| ៤ | មន្ទីរសម្រាកព្យាបាល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ |
| ៥ | ផ្សារទំនើប | គ្មាន | គ្មាន | គ្មាន | គ្មាន | ១ |
| ៦ | បន្ទប់ជួល | គ្មាន | គ្មាន | ២ | គ្មាន | |

## ២.១៤- ខេត្តបន្ទាយមានជ័យ

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ សម្រេចបាន៖**

ខេត្តបន្ទាយមានជ័យ ជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ទូទាំងប្រទេស មានចម្ងាយ ៣៦០គ.ម.ពីរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងលិចជាប់នឹងព្រះរាជាណាចក្រថៃ ប្រវែង១៥៣គ.ម.មាន

ខេត្តស្រះកែវចំនួន៤ស្រុកគឺស្រុកអារញ្ញប្រាថេត គោកឈូង តាបាយ៉ា និងស្រុកខ្លងហាត ខេត្តពុរីរាំចំនួន១ស្រុកគឺស្រុកឡាក់ហានសៃ ខាងកើតទល់នឹងខេត្តសៀមរាប ខាងត្បូងទល់នឹងខេត្តបាត់ដំបង និងខាងជើងទល់នឹងខេត្តឧត្តរមានជ័យ និងប្រទេសថៃ។ មានច្រកទ្វារព្រំដែន អន្តរជាតិប៉ោយប៉ែត ច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន និងច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ហើយមានផ្ទៃដីសរុប៦ ៦៧៩គ.ម.$^{២}$ មានស្រុក៧ គឺស្រុកមង្គលបូរី ស្រុកអូរជ្រៅ ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ស្រុកស្វាយចេក ស្រុកម៉ាឡៃ និងស្រុកថ្មពួក មានក្រុង២ ក្រុងសិរីសោភ័ណ និងក្រុងប៉ោយប៉ែត ឃុំ៥៥ សង្កាត់១០ ភូមិទទួលស្គាល់ដោយក្រសួងមហាផ្ទៃ៦៥៨ភូមិ មានប្រជាជនចំនួន ១៩៤ ៨៦៨គ្រួសារ មនុស្សសរុប៨១៥ ៥២២នាក់ ក្នុងនោះស្រី៤០៦ ៤៨១នាក់។

**១- ការអនុវត្តសកម្មភាពការងារនិងសមិទ្ធផលសំខាន់ៗ ២០១៧-២០២១**

១- ការងារជួសជុលនិងស្ថាបនាលើកកម្ពស់ផ្លូវដីស ដោយមានក្រាលគ្រួសក្រហម ក្រាលកៅស៊ូ DBST និងមានដាក់លូជ្រុងចំនួន១០គម្រោង សរុបប្រវែង៤៦ ៦៣០ម. មានចំនួន១០ខ្សែ ស្ថិតក្នុងស្រុកស្វាយចេក ស្រុកម៉ាឡៃ ស្រុកព្រះនេត្រព្រះ ក្រុងប៉ោយប៉ែត និងក្រុងសិរីសោភ័ណ សរុបទឹកប្រាក់៧១ ០៦១ ៥៥០ ០០០រៀល។

២- ការងារជួសជុលផ្លូវក្រាលគ្រួសក្រហមសរុបប្រវែង២៩ ៧៨៤ម. មានចំនួន៦ខ្សែ ចំនួន៦គម្រោង ស្ថិតក្នុងស្រុកម៉ាឡៃ ស្រុកអូរជ្រៅ ស្រុកមង្គលបូរី និងក្រុងសិរីសោភ័ណដែលមានទឹកប្រាក់សរុបចំនួន១២ ៣៩១ ០៣៦ ០០០ រៀល។

៣- ការងារជួសជុលផ្លូវក្រាលកៅស៊ូDBST និងសាងសង់ស្ពានមួយកន្លែងនិងលូប្រអប់ចំនួន១កន្លែង សរុបប្រវែង១៨ ២១៩ម. មានចំនួន១៣ខ្សែ ចំនួន១២គម្រោង ស្ថិតក្នុងស្រុកព្រះនេត្រព្រះ ស្រុកមង្គលបូរី ស្រុកថ្មពួក និងក្រុងសិរីសោភ័ណ សរុបទឹកប្រាក់១៧ ៣៨០ ០០០ ០០០រៀល។

៤- ការងារជួសជុលនិងស្ថាបនាផ្លូវបេតុងកម្រាស់១៥សង់ទីម៉ែត្រនិងលូប្រអប់ជ្រុងបេតុងសសៃដែក ១កន្លែងសរុបប្រវែង៣៥ ៧៥៤ម. មានចំនួន៤១ខ្សែ ចំនួន២៩គម្រោង ស្ថិតក្នុងស្រុកព្រះនេត្រព្រះ ស្រុកមង្គលបូរី ស្រុកអូរជ្រៅ ស្រុកស្វាយចេក និងក្រុងសិរីសោភ័ណ សរុបទឹកប្រាក់៣៩ ២៤៨ ៧៦០ ០០០រៀល។

៥- ការងារជួសជុលដាក់លូØ១២០ កាត់ទទឹងផ្លូវចំនួន២០កន្លែង ការងារដាក់លូØ១០០ ចំនួន៤៣០កង់ កាត់ទទឹងផ្លូវចំនួន៦កន្លែង និងចាក់បេតុងដៃលូសងខាង ការងារដាក់លូØ៨០ ចំនួន៤ ៥០០កង់ ការងារដាក់លូØ៦០ ចំនួន១២៤កង់ ការងារដាក់លូប្រអប់ជ្រុង ចំនួន៨៦កង់ និងរ៉េហ្គាចំនួន៧៧រ៉ឺហ្គា ក្នុងក្រុងសិរីសោភ័ណ សរុបចំនួន៩គម្រោង ដែលមានទឹកប្រាក់សរុបចំនួន៣ ៤៣១ ៥០០ ០០០រៀល។

៦- ការងារស្តារលូក្នុងទីរួមខេត្តប្រវែង១ ០០០ម. ចំនួន១គម្រោង សរុបទឹកប្រាក់៥០ ០០០ ០០០រៀល។

៧- ការងារថែទាំអាងចំរោះទឹកស្អាតក្នុងក្រុងសិរីសោភ័ណចំនួន៤លើក ចំនួន២គម្រោងសរុបទឹកប្រាក់ ១២១ ០០០ ០០០រៀល។

៨- ការងារជួសជុលកែលម្អរស្តួនច្បារមានជ័យ ដំហានទី២ ទី៣ និងទី៤ ទំហំ២៦ ៤៧០ម.$^{២}$ ចំនួន ៣គម្រោង ដែលមានទឹកប្រាក់សរុបចំនួន៧ ១២២ ០០០ ០០០រៀល។

៩- ការងារជួសជុលសួនច្បារមុខសាលាខេត្ត ដំហានទី១ ទី២ និងដំហានទី៣បញ្ចប់ ទំហំ១២ ២០៩ម.$^{២}$ និងធ្វើដងទង់ជាតិ ធ្វើពីអ៊ីណុក៣កន្លែង ចំនួន៣គម្រោង សរុបទឹកប្រាក់៣ ២៨០ ០០០ ០០០រៀល។

១០- ការងាររៀបចំការ៉ូឡា និងដុំចិញ្ចើមក្នុងបរិវេណសាលាខេត្ត ចំនួន១គម្រោងសរុបទឹកប្រាក់ ២៤០ ០០០ ០០០រៀល។

១១- ការងាររៀបចំចាក់ដីបំពេញនិងចាក់បេតុងប្រាំងមាត់ស្ទឹងនៅក្រោយសាកលវិទ្យាល័យមានជ័យ ប្រវែង១៩៥ម. ជម្រេល៨,៩ម. និងកាំជណ្តើរ១កន្លែងមុខវេទិកាអុំទូក សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ជំហានទី១ ជំហានទី២ ចំនួន២គម្រោង សរុបទឹកប្រាក់ចំនួន៣ ២០០ ០០០ ០០០រៀល។

១២- ការងាររៀបចំចាក់ដីលុបប្រឡាយទំហំ១ ៧៦០ម.[៣] និងដាក់លូ០១ម. ប្រវែង២០៨ម. និងរ៉ឺហ្គា ១២កន្លែង នៅភូមិប្រជាធម្ម ក្រុងប៉ោយប៉ែត ចំនួន១គម្រោង សរុបទឹកប្រាក់ចំនួន៣២០ ០០០ ០០០រៀល។

១៣- ការងាររៀបចំចាក់ដីលុបស្រះ និងបំពេញទីធ្លា(មណ្ឌលសំចត) នៅភូមិប្រជាធម្ម ក្រុងប៉ោយប៉ែត ទំហំ៤ ០៥៧ម.[២] ចំនួន១គម្រោង សរុបទឹកប្រាក់ចំនួន១៦០ ០០០ ០០០រៀល។

១៤- ការងាររៀបចំបណ្តាញអគ្គិសនីបំភ្លឺសាធារណៈ និងបង្គោលភ្លើងបភ្លឺផ្លូវសារធារណៈក្នុងក្រុង សិរីសោភ័ណ សរុបចំនួន៤០១ដើម ចំនួន៥គម្រោង សរុបទឹកប្រាក់ចំនួន៥ ២៤១ ០០០ ០០០រៀល។

១៥- ការងាររៀបចំបណ្តាញអគ្គិសនីបំភ្លឺសាធារណៈនិងបង្គោលភ្លើងបភ្លឺផ្លូវសារធារណៈ(សូឡា) ក្នុងក្រុងសិរីសោភ័ណ សរុបចំនួន១១០ដើម ចំនួន១គម្រោង សរុបទឹកប្រាក់ចំនួន៨៨០ ០០០ ០០០រៀល។

១៦- ការងារជួសជុលរៀបចំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈស្ថិតក្នុងសង្កាត់ព្រះពន្លាចំនួន១៣២ដើម និងសង្កាត់កំពង់ស្វាយចំនួន២៩ដើម V សរុបចំនួន១៦១ដើម ក្រុងសិរីសោភ័ណចំនួន១គម្រោង សរុបទឹកប្រាក់ចំនួន២ ០៨៥ ៨០០០ ០០០រៀល។

១៧- ការងាររៀបចំតម្លើងភ្លើងស្តុបផ្លូវរង្វង់មូលដៃសាមពីរ១កន្លែង ផ្លូវសាមគ្គីមានជ័យ១ កន្លែង ផ្លូវចូលផ្សាររាត្រី១កន្លែង ផ្លូវបំបែក៧មករា សង្កាត់ទឹកថ្លា១កន្លែង ប្តូរនៅកន្លែងស្តុបចាស់១កន្លែង ចំនួន១គម្រោង សរុបទឹកប្រាក់ចំនួន១ ៤៤៨ ៨០០ ០០០រៀល។

១៨- ការងារជួសជុលបំពាក់សំភារៈសាលប្រជុំក្រុមប្រឹក្សាខេត្តនិងអគារផ្ទះភ្ញៀវខេត្តនិងបំពាក់សម្ភារៈខេត្តលាបរបងចំនួន១គម្រោង សរុបទឹកប្រាក់ចំនួន៥៥៨ ០០០ ០០០រៀល។

១៩- ការងារសាងសង់បញ្ជរតាំងរូបព្រះឆាយល័ក្ខខាងមុខសាលាខេត្ត ប្រវែង៦.៦ម. X កម្ពស់៥.៥ម. សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ចំនួន១គម្រោង ទឹកប្រាក់ចំនួន១៧៦ ០០០ ០០០រៀល។

២០- រៀបចំជួសជុលភ្លើងស្តុបនិងអ៊ុតគំនូសចរាចរណ៍តាមដងផ្លូវបំបែកស្តុប ក្នុងក្រុងសិរីសោភ័ណ ចំនួន១គម្រោង ទឹកប្រាក់ចំនួន១៦០ ០០០ ០០០រៀល។

២១- ការងារបំពាក់ជណ្តើរយន្តចំនុះ៧៥០គ.ក្រ. ប្រវែង២,៤ម. កម្ពស់១២,៣ម. សាលប្រជុំ(ធំ) អគារសាលាខេត្តបន្ទាយមានជ័យចំនួន១គម្រោង ទឹកប្រាក់ចំនួន៣១៧ ៨០០ ០០០រៀល។

**២- ការងារទឹកស្អាត**

- ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជនក្នុងខេត្តបន្ទាយមានជ័យ បានកើនឡើងគួរឱ្យកត់សម្គាល់ពិសេសក្នុងកំឡុង៥ឆ្នាំនេះ អត្រាគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាតតាមប្រព័ន្ធបណ្តាញ ក្នុងទីប្រជុំជនបានកើនឡើងពី១២ឃុំ/សង្កាត់ និង៦៧ភូមិ នៅឆ្នាំ២០១៧ ដល់២៨ឃុំ/សង្កាត់ និង១៩១ភូមិ ក្នុងឆ្នាំ២០២១ និងមានប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតចំនួន៤១ ៩៦៤គ្រួសារ ស្មើនឹង៨០%នៃចំនួនគ្រួសារសរុបក្នុងទីប្រជុំជន។

- ការធ្វើវិនិយោគលើវិស័យផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករឯកជនដែលមានអាជ្ញាបណ្ណ នៅក្នុងខេត្តបន្ទាយមានជ័យ មានចំនួន១២ក្រុមហ៊ុន និងប្រតិបត្តិករ៤កំពុងសិក្សាសមិទ្ធិលទ្ធភាព មាននៅ៤ស្រុក។ សរុបបរិមាណផលិតទឹកទូទាំងខេត្តរយៈពេលប្រាំឆ្នាំផលិតទឹកបានចំនួន១១ ៦៨៧ ៨៧២ម.[៣] កើនឡើង១៨,២% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

### ៣- ការងារបរិស្ថាន អនាម័យ និងសោភ័ណភាពទីក្រុង

ខេត្តមានទីលាន និងរណ្ដៅចាក់សំរាមចំនួន៦កន្លែង សម្រាប់ទុកដាក់សំណល់សំរាមប្រមាណ២៨១តោនក្នុងមួយថ្ងៃ ក្រុមហ៊ុនប្រមូលសំរាមចំនួន២ក្រុមហ៊ុន និងរដ្ឋបាលស្រុកជាអ្នកប្រមូលចំនួន៣ស្រុក ក្រុមការងារប្រមូលសំរាមចំនួន២ស្រុក។ បានចុះត្រួតពិនិត្យការបំពុលបរិស្ថាន តាមរោងចក្រ សហគ្រាស ទីលាន និងរណ្ដៅចាក់សំរាម ការបង្ហូរសំណល់រឹងរាវ និងបានយកទឹកតទៅពិនិត្យនៅមន្ទីរពិសោធន៍អំពីគុណភាពទឹកសាធារណៈនៅក្រសួងបរិស្ថានជារៀងរាល់ខែ។

### ៤- ការងារទេសចរណ៍

ខេត្តបន្ទាយមានជ័យ មានតំបន់សក្ដានុពលទេសចរណ៍ចំនួន៩កន្លែង ក្នុងនោះរមណីដ្ឋានទេសចរណ៍ធម្មជាតិចំនួន៥កន្លែង និងកែច្នៃចំនួន២កន្លែង និងរមណីយដ្ឋានទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រចំនួន២កន្លែង។ សណ្ឋាគារមាន២៦កន្លែង ផ្ទះសំណាក់៨៧កន្លែង ភោជនីយដ្ឋាន និងអាហារដ្ឋានមានចំនួន១១៤កន្លែង។

កន្លងទៅការងារទេសចរណ៍បានចុះធ្វើការអប់រំណែនាំ ស្ដីពីការរៀបចំតុបតែងលម្អនៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ដូចជាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន និងកន្លែងលក់ស៊ុបបានចេញច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងចុះផ្សព្វផ្សាយអំពីច្បាប់ស្ដីពីទេសចរណ៍ពីការប្រើប្រាស់ឯកសណ្ឋាន ការធ្វើបដិសណ្ឋារកិច្ចភ្ញៀវទេសចរ ការធ្វើអនាម័យចំណីអាហារ និងឱ្យចូលរួមអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល។

**វឌ្ឍភាពនៃវិស័យទេសចរណ៍**

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| សណ្ឋាគារ | កន្លែង | ១៧ | ២២ | ២៥ | ២៥ | ២៦ |
| ចំនួនបន្ទប់ | បន្ទប់ | ៦១១ | ៨៣៧ | ៩៤២ | ១ ០០១ | ១ ០០៣ |
| ផ្ទះសំណាក់ | កន្លែង | ៧៥ | ៧៧ | ៨៣ | ៧៨ | ៨៧ |
| ចំនួនបន្ទប់ | បន្ទប់ | ១ ៥២៣ | ១ ៤១៥ | ១ ៥២៥ | ១ ៣០៨ | ១ ៤១០ |
| ខារ៉ាអូខេ | កន្លែង | ១៩ | ២២ | ២៤ | ២៧ | ២៧ |
| ភោជនីយដ្ឋាន/អាហារដ្ឋាន | កន្លែង | ៩៥ | ៨៤ | ៩៩ | ៩០ | ១១៤ |

## ២.១៥- ខេត្តពោធិ៍សាត់

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តពោធិ៍សាត់ សម្រេចបាន៖

ខេត្តពោធិ៍សាត់ គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ស្ថិតនៅភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ១៨៦គ.ម. ពីរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ឆ្នាំង ខាងលិចជាប់នឹងខេត្តបាត់ដំបងនិងប្រទេសថៃ(ខ្សែបន្ទាត់ព្រំដែនប្រវែងប្រមាណ៨០គ.ម.) ខាងជើងទល់នឹងបឹងទន្លេសាប(ប្រវែងប្រមាណ៨៦គ.ម.) និងខាងត្បូងជាប់នឹងខេត្តកំពង់ស្ពឺនិងខេត្តកោះកុង។ មានផ្លូវគមនាគមន៍សំខាន់ៗ រួមមានផ្លូវជាតិលេខ៥ លេខ៥៥ និងផ្លូវជាតិលេខ១០ ផ្លូវដែក(រថភ្លើង) និងផ្លូវទឹក(បឹងទន្លេសាប) មានផ្ទៃដីសរុបចំនួន១២ ៦៩២គ.ម.$^{២}$ ត្រូវបែងចែកចេញជា១រដ្ឋបាលក្រុង ៦រដ្ឋបាលស្រុក៧សង្កាត់៤២ឃុំ និង៥១១ភូមិ។

មានប្រជាជនសរុបចំនួន៥០៦ ០៩៩នាក់(ស្រី២៥៧ ០៧៥នាក់) ស្មើនឹង១៣១ ៣៥២គ្រួសារ និងអាយុ១៨ឆ្នាំឡើង មានចំនួន២៩៨ ៦៥៤នាក់ មានមុខរបរជាកសិករ៧៥,៨% សេវាករ២៣,៥% និងសិប្បករ០,៧%។

**១- ការងារសាធារណការ**

- ស្ថាបនាផ្លូវជាតិនិងផ្លូវខេត្ត ដោយក្រាលកៅស៊ូ DBST បានប្រវែងសរុប២១,៧២គ.ម.
- ស្ថាបនាផ្លូវក្រាលគ្រួសក្រហមបានប្រវែងសរុប១២,១០គ.ម.
- ជួសជុលផ្លូវក្រាលគ្រួសក្រហមឡើងវិញបានប្រវែងសរុប១២,៧០គ.ម.
- ស្ថាបនាស្ពានបេតុងបានប្រវែងសរុប៧៨ម.
- ស្ថាបនាលូបណ្តោយនិងលូទទឹងផ្លូវបានប្រវែងសរុប១៦ ២៤១ម.
- ថែទាំជាប្រចាំកំណាត់ផ្លូវជាតិនិងផ្លូវខេត្តក្រាលកៅស៊ូបានប្រវែង២៩៦,៣០គ.ម. និងថែទាំប្រចាំកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលក្រួសក្រហមបានប្រវែង៦៣,២៨គ.ម.។

វិស័យសាធារណការ និងដឹកជញ្ជូនខេត្ត មានបណ្តាញផ្លូវចំនួន៥៥ខ្សែ ប្រវែងសរុប១ ០៨៨,១០គ.ម. រួមមានផ្លូវជាតិ១លេខ ចំនួន១ខ្សែ ប្រវែង៨៦,៣០គ.ម. ផ្លូវជាតិ២លេខ ចំនួន៤ខ្សែ ប្រវែង២៩៤,២៨គ.ម. ផ្លូវខេត្តចំនួន៥០ខ្សែ ប្រវែង៧០៧,៥២គ.ម. និងស្ពានសរុបចំនួន១៦៨កន្លែង ប្រវែង៤ ៣៨០ម. លូគ្រប់ប្រភេទប្រវែង១០៤ ៨១២ម.។ ផ្លូវក្នុងក្រុងពោធិ៍សាត់មានចំនួន៧៦ខ្សែ ប្រវែង៥៧,៥៥គ.ម.(ក្រាលកៅស៊ូប្រវែង៣៥,៣៧គ.ម) និងលូគ្រប់ប្រភេទចំនួន២០ ២៦០ម.។

**២- ការងារធនធានទឹក**

**ក- ការងារសាងសង់ ជួសជុលស្តារប្រឡាយមេ ប្រឡាយរង និងប្រឡាយជើងក្អែប៖**

- សាងសង់សំណង់ទ្វារទឹកកាត់ស្ទឹងធំ ដំណាក់ឈើក្រំចំនួន១កន្លែង មានប្រវែងសរុប៥៧ម.
- សាងសង់សំណង់បង្ហៀរកាត់ស្ទឹង ព្រៃខ្លុងចំនួន១កន្លែង
- ស្តារប្រឡាយមេចំនួន៨ខ្សែ មានប្រវែងសរុបចំនួន៥៤ ៩៤០ម.(ចាក់បេតុងប្រវែង២០ ៦៨៧ម.)
- ស្តារប្រឡាយរងចំនួន៣៥ខ្សែ មានប្រវែងរុបចំនួន១៨៥ ៧០០ម.(ចាក់បេតុងប្រវែង១៤ ៣០៤ម.)
- ស្តារប្រឡាយជើងក្អែបចំនួន៩១៣ខ្សែ មានប្រវែងសរុប៧៦៤ ៨៩៩ម.
- ជួសជុលប្រឡាយមេចំនួន៥ ខ្សែ មានប្រវែងសរុប១៧ ៧៣០ម.
- ជួសជុលប្រឡាយរងចំនួន១៤ខ្សែ មានប្រវែងសរុប២២ ១៩២ម.
- ស្តារប្រឡាយដោះទឹកចំនួន៤ខ្សែ មានប្រវែងសរុប៤១ ០១០ម.
- ជួសជុលទំនប់ចំនួន៥កន្លែង មានប្រវែងសរុប១៤ ៨៤១ម.
- ក្រាលក្រួសក្រហមលើភ្លឺប្រឡាយមេ មានប្រវែងសរុប២ ០០០ម.
- ស្តារស្ទឹងស្វាយដូនកែវ ព្រំប្រទល់ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង សរុបមានប្រវែង៥ ១៩០ម.

**ខ- ការងារសាងសង់ និងជួសជុលសំណង់សិល្បការដែលមាន**(សំណង់បង្ហៀរ សំណង់លូទឹក សំណង់ស្នាក់ទឹក សំណង់ទ្វារទឹក សំណង់យកទឹក សំណង់សម្រួលចរន្តទឹក សំណង់បង្វែរចរន្តទឹក សំណង់បញ្ចេញទឹក សំណង់លូចម្លងទឹកសំណង់លូដោះទឹក លូបំពង់ដោះទឹក ស្ពានឆ្លងកាត់ប្រឡាយមេ និងប្រឡាយរង) សរុបជារួមមានចំនួន៨១៨កន្លែង។

៣- ការងារទេសចរណ៍

**ក- ការរៀបចំតុបតែងរមណីយដ្ឋាន មន្ទីរទេសចរណ៍ខេត្ត** បានធ្វើសេចក្តីណែនាំជារៀងរាល់ឆ្នាំចង្អុលការដល់បណ្តាម្ចាស់និងអ្នកទទួលខុសត្រូវតាមរមណីយដ្ឋាននិងតាមបណ្តាសេវាកម្ម អាជីវកម្មទេសចរណ៍ ព្រមទាំងបានផលិតបដា«**កម្ពុជា ព្រះរាជាណាចក្រកអច្ឆរិយៈ**» និងចលនាប្រឡងប្រណាំង«**ទីក្រុងស្អាត រមណីយដ្ឋាន សេវាល្អ បដិសណ្ឋារកិច្ចល្អ**» ជាផ្ទាំងតូចធំចងតាមរមណីយដ្ឋាននិងតាមទីតាំងអាជីវកម្មទេសចរណ៍។ ខេត្តមានរមណីយ-ដ្ឋានជាច្រើនបម្រើឱ្យភ្ញៀវជាតិ និងអន្តរជាតិ មានជាអាទិ៍ រមណីយដ្ឋានទឹកធ្លាក់ច្រកល្មៀង សក្តានុពលទឹកជ្រោះចំការតាវ៉ែន រមណីយដ្ឋានភ្នំលាំងត្រាច សហគមន៍ទេសចរណ៍កំពង់លួង រមណីយដ្ឋានភ្នំបាយឃ្លះ រមណីយដ្ឋានល្បាក់កំពោញ ជំរំសត្វស្លាបបឹងព្រះពន្លៃ បូជនីយដ្ឋានឧកញ៉ាឃ្លាំងមឿង រមណីយដ្ឋានថ្មដាតូច សហគមន៍ទេសចរណ៍រាំងទិលគ្រួសារខ្ញុំ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រធម្មជាតិភ្នំនាគស សហគមន៍តំបន់ការពារធម្មជាតិភ្នំរាំងខ្វាវ សហគមន៍តំបន់ការពារធម្មជាតិភូមិទំព័រ។

**ខ- សេវាកម្មក្នុងខេត្តមានៈ**

\+ សណ្ឋាគារ៦ មាន៣៦៣បន្ទប់ មានអាជ្ញាបណ្ណពីថ្នាក់ក្រសួង៤ ថ្នាក់ខេត្ត២

\+ អនុវត្តអនុក្រឹត្យស្តីពីចំណាត់ថ្នាក់សណ្ឋាគារនិងសេវាស្នាក់នៅទេសចរ និងតាមយន្តការគណៈកម្មា-ធិការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ យើងរកឃើញសណ្ឋាគារ៣ ត្រូវបានទទួលចំណាត់ថ្នាក់គឺៈ

- ចំណាត់ថ្នាក់ផ្កាយបី សណ្ឋាគារខេអឹម
- ចំណាត់ថ្នាក់ផ្កាយពីរ សណ្ឋាគារពោធិ៍សាត់សេនជូរី
- ចំណាត់ថ្នាក់ផ្កាយមួយ សណ្ឋាគារឋានសួគ៌ថ្មី។

\+ ផ្ទះសំណាក់សរុប៤៩ មាន៥៧១បន្ទប់ មានអាជ្ញាបណ្ណចេញដោយច្រកចេញចូលសាលាខេត្ត។

\+ ភោជនីយដ្ឋាន សរុប៤៣ មានតុ៤៧៤ និងកៅអី១ ៨០៣ មានអាជ្ញាបណ្ណចេញដោយច្រកចេញចូលសាលាខេត្ត។

\+ រមណីយដ្ឋាន និងតំបន់ទេសចរណ៍សរុប៣៤កន្លែង។

- សេវាលក់វត្ថុអនុស្សាវរីយ៍មាន២០កន្លែង ដែលបានដាក់លក់វត្ថុអនុស្សាវរីយ៍អំពីថ្មកែវ ក្នុងក្រុងពោធិ៍សាត់។ ក្រៅពីកន្លែងលក់ក៏មានកន្លែងសិប្បកម្មចម្លាក់ជាង១០០កន្លែង។

## ២.១៦- ខេត្តឧត្តរមានជ័យ

### សមិទ្ធផលនិងស្នាដៃការងារសំខាន់របស់រដ្ឋបាលខេត្តឧត្តរមានជ័យ សម្រេចបានៈ

ខេត្តឧត្តរមានជ័យជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ដែលមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា មានចម្ងាយ៤៦៩គ.ម. ពីរាជធានីភ្នំពេញ ធ្វើដំណើរតាមផ្លូវជាតិលេខ៥ ឆ្លងកាត់ខេត្តចំនួន៦ គឺខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ និងមានចម្ងាយ៤៤៧គ.ម. ពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ ឆ្លងកាត់ខេត្តចំនួន៤ គឺខេត្តកណ្តាល កំពង់ចាម កំពង់ធំ និងខេត្តសៀមរាប កាត់តាមស្រុកក្រឡាញ់ឆ្ពោះមកកាន់ទីរួមខេត្តឧត្តរមានជ័យ ដែលមានព្រំប្រទល់ខាងកើតជាប់និងខេត្តព្រះវិហារ ខាងលិចជាប់និងខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់និងខេត្តសៀមរាប និងខាងជើងជាប់ជាមួយខេត្តចំនួន៣របស់ថៃ គឺមានខេត្តសុរិន្ទ ខេត្តបុរីរ៉ាំ និងខេត្តស៊ីសាកេត មានប្រវែងសរុប២២៤គ.ម.។ គ្រួសារសរុប៥៨ ២៧៤ មានប្រជាពលរដ្ឋសរុប២៥៥ ១៧៩នាក់។

## ១- សាធារណការ និងការកែលម្អសោភ័ណភាព

| ល.រ. | ឈ្មោះគម្រោង | សម្រាប់ទុនវិនិយោគ (លានរៀល) | បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| ១ | ជួសជុលរបងក្រុមប្រឹក្សាខេត្ត | ៩៣ ៤០០ | បញ្ចប់ | |
| ២ | ប្រមូលសំរាម | ២០ ០០០ | បញ្ចប់ | |
| ៣ | ជួសជុលក្រាលសាប និងប្រព័ន្ធលូក្នុងទីផ្សារតាកែវ | ៣៣៨ ៥០០ | បញ្ចប់ | |
| ៤ | ជួសជុលកែលម្អសួនច្បារជាប់មាត់បឹងតាកែវ | ៨៨៥ ០០០ | បញ្ចប់ | |
| ៥ | ជួសជុលបង្គោលដងគោម បណ្ដាញខ្សែអគ្គិសនី ផ្លូវលេខ១២អា ប្រវែង៣៦០ម. បន្តដល់ស្ពាន ចុងថ្នល់ | ៥១ ២០០ | បញ្ចប់ | |
| ៦ | ជួសជុលផ្លូវលេខ១៤ ក្រាលកៅស៊ូ DBST ចាប់ពីផ្លូវលេខ២១ ដល់ផ្លូវលេខ២៥ | ៣៣៨ ៥០០ | បញ្ចប់ | |
| ៧ | ជួសជុលផ្លូវលេខ២៣ ក្រាលកៅស៊ូ DBST ចាប់ពីផ្លូវលេខ២៨ ដល់ផ្លូវលេខ១២ | ៦៩៧ ២០០ | បញ្ចប់ | |
| ៨ | ជួសជុលផ្លូវលេខ៣៣ ក្រាលក្រួសក្រហម ចាប់ពីផ្លូវលេខ១៣ ដល់ផ្លូវលេខ១២៩អា | ១៥៧ ៥២០ | បញ្ចប់ | |
| ៩ | ជួសជុលផ្លូវលេខ១៤ ក្រាលក្រួសក្រហម ចាប់ពីផ្លូវលេខ២៥ ដល់ផ្លូវលេខ២៧ | ៨២ ៧៨០ | បញ្ចប់ | |
| ១០ | ធ្វើប្រព័ន្ធលូមុខកាត់១ម. សងខាងផ្លូវលេខ១៤ និងរៀបប៊័រឌ័រ ចាប់ពីផ្លូវលេខ២១ ដល់ផ្លូវលេខ២៦ | ៨៥០ ០០០ | បញ្ចប់ | |
| ១១ | ធ្វើប្រព័ន្ធលូមុខកាត់០,៦០ម. កាត់ផ្លូវលេខ៣៣ = ៤៨ម. ផ្លូវលេខ១៤=២១ម. និងផ្លូវលេខ២៤ = ១១ម. | ៣៥ ៤២០ | បញ្ចប់ | |
| ១២ | ធ្វើប្រព័ន្ធលូមុខកាត់១,២០ម. កាត់ផ្លូវលេខ៣១ = ២២ | ២២ ០០០ | បញ្ចប់ | |
| ១៣ | ធ្វើប្រព័ន្ធលូមុខកាត់០,៦០ម. សងខាងផ្លូវលេខ២៥ និងរៀបប៊័រឌ័រ ចាប់ពីផ្លូវលេខ២៨ ដល់PKO+១ ៤៣៦ | ៦៨៩ ១៨០ | បញ្ចប់ | |
| ១៤ | ធ្វើប្រព័ន្ធលូមុខកាត់០,៦០ម. សងខាងផ្លូវលេខ២៦ និងរៀបប៊័រឌ័រ ចាប់ពីផ្លូវលេខ២៨ ដល់PKO+៥៩៨ | ៥៧៤ ១០០ | បញ្ចប់ | |
| ១៥ | ធ្វើប្រព័ន្ធលូមុខកាត់០,៦០ម តាមបណ្ដោយផ្លូវលេខ៨ និងរៀបប៊័រឌ័រ ចាប់ពីផ្ទះសំណាក់មិត្តភាព ដល់ផ្លូវលេខ១២៩អា | ១៩១ ០០០ | បញ្ចប់ | |
| ១៦ | ជួសជុលផ្លូវខេត្តលេខ១២៩ E(DBST) ដាក់លូកាត់ផ្លូវ f1m | ៦ ៥៣០ | បញ្ចប់ | |
| ១៧ | ជួសជុលផ្លូវខេត្តលេខ១២៩ D(Laterite) | ៧ ១៥៥ | បញ្ចប់ | |
| ១៨ | ជួសជុលផ្លូវខេត្តលេខ១២៤B(Laterite) | ៣ ៦៨៥ | បញ្ចប់ | |
| ១៩ | ជួសជុលផ្លូវខេត្តលេខ១២៥(DBST) ដាក់លូកាត់ផ្លូវ f1m | ៤ ៣២៩,១០ | បញ្ចប់ | |
| ២០ | ជួសជុលផ្លូវខេត្តលេខ 1TK4 (Laterite) | ៣ ៥២៥ | បញ្ចប់ | |
| ២១ | ជួសជុលផ្លូវជាតិលេខ២២(DBST) សាងសង់លូបណ្ដោយផ្លូវខេត្តលេខ១៣២ f0.60m | ៤ ៩៣០ | បញ្ចប់ | |
| ២២ | ជួសជុលផ្លូវក្រុង២ខ្សែ(DBST) | ១ ៦១០ | បញ្ចប់ | |
| ២៣ | ជួសជុលផ្លូវក្រុង២ខ្សែ(ក្រាលខ្សាច់ភ្នំ) | ១ ៨៨២,៥០ | បញ្ចប់ | |
| ២៤ | ថែទាំផ្លូវជាតិលេខ២(DBST) | ៦៧៨,៩៦ | បញ្ចប់ | |
| ២៥ | ថែទាំផ្លូវជាតិលេខ៣(DBST) | ៣៦៩ | បញ្ចប់ | |

| | | | | |
|---|---|---|---|---|
| ២៦ | ថែទាំផ្លូវខេត្តលេខ១២៩(DBST) | ៤៣៥,០៥ | បញ្ចប់ | |
| ២៧ | ថែទាំផ្លូវខេត្តលេខ១៣២(DBST) | ៦៤៥,៧៥ | បញ្ចប់ | |
| ២៨ | ថែទាំផ្លូវខេត្តលេខ១២៩A(DBST) | ៨៣,៦៤ | បញ្ចប់ | |
| ២៩ | ថែទាំផ្លូវខេត្តលេខ១២៦(DBST) | ១១៧,៤៧ | បញ្ចប់ | |
| ៣០ | ថែទាំផ្លូវក្រុងដូនកែវ១៨ខ្សែ(DBST) | ១៥០,៦១ | បញ្ចប់ | |
| **សរុប វិស័យសាធារណៈការ និងកែលម្អសោភ័ណភាព** | | **៥ ០៦១ ៩២៧** | | |

**២- ការងារធនធានទឹកនិងឧតុនិយម**

- ខេត្តមានប្រព័ន្ធធារាសាស្ត្រកសិកម្មសរុបចំនួន៨ប្រព័ន្ធ ក្នុងនោះ ប្រឡាយមេនិងប្រឡាយរងមានចំនួន២៦ ២៨៣ម.
- សំណង់ទ្វារសំណង់ស្នាក់ទឹកនិងសំណង់លូសរុបមានប្រវែង៤៩កន្លែង សំណង់បង្ហៀសរុបមានប្រវែង២៩៣ម.
- ការស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រ លទ្ធផលស្តារនិងជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រសម្រេចបានរួមមានការងារស្តារឡើងវិញនិងកែលម្អថែទាំប្រព័ន្ធធារាសាស្ត្រចំនួន៤០កន្លែង ក្នុងនោះ ជួសជុលនិងសាងសង់ទំនប់ទំនប់ ជុសជុលនិងសាងសង់ប្រឡាយមេនិងប្រឡាយរង ជួសជុលសាងសង់ទ្វាទឹកចំនួន៥៦កន្លែង សាងសង់លូលើប្រឡាយមេចំនួន៣។

**៣- ការងាររ៉ែនិងថាមពលៈ**

- ក្រុមហ៊ុនដែលមានអាជ្ញាបណ្ណអាជីវកម្មចំនួន៤២ក្រុមហ៊ុន
- ក្រសួងបានចេញអាជ្ញាបណ្ណអណ្តូងរ៉ែ និងការដ្ឋានវាយថ្មឱ្យក្រុមហ៊ុនអាជីវករធ្វើរ៉ែសំណង់គ្រប់ប្រភេទសរុបចំនួន៦៨អាជ្ញាបណ្ណ មន្ទីរចេញអាជ្ញាបណ្ណសិប្បកម្មចំនួន៨អាជ្ញាបណ្ណ
- សហការជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា ចុះត្រួតពិនិត្យការរៀបចំខ្សែបណ្តាញអគ្គិសនី និងថ្លៃសេវាផ្សេងៗ របស់សេវាករចំនួន២៥អាជ្ញាបណ្ណ ទាំង៥ក្រុង ស្រុក គ្រួសារដែលភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ចំនួន១៦ ២៣៩គ្រួសារ។

**៤- ការងារទេសចរណ៍ៈ**

រមណីយដ្ឋានទេសចរណ៍ មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ និងស្ថិតិភ្ញៀវទេសចរចូលមកទស្សនាសម្រាកស្នាក់នៅលំហែកម្សាន្ត និងចុះសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រក្នុងខេត្តតាកែវ មានដូចខាងក្រោមៈ

| ល.រ. | បរិយាយ | ២០១៧ | ០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ១ | រមណីយដ្ឋាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ២ | សណ្ឋាគារ | ៤ | | ៥ | ៥ | ៥ |
| | ចំនួនបន្ទប់ | គ្មាន | ២៤៤ | ៣២២ | ២៧៩ | ២៧៩ |
| ៣ | ផ្ទះសំណាក់ | ២៨ | ២៧ | ៣៧ | ៤២ | ៤១ |
| | ចំនួនបន្ទប់ | គ្មាន | ៤១០ | ៤១០ | ៥៤៧ | ៥៧៩ |
| ៤ | ភោជនីយដ្ឋាន | ១១ | ៨ | ៨ | ៣៩ | ៣៨ |
| | ចំនួនកៅអី | គ្មាន | ៣៦៣ | ៣៧៧ | ១ ៦៨៨ | ៣១៧ |
| ៥ | ខារ៉ាអូខេ | ១០ | ១០ | ២៤ | ១៩ | ២៣ |
| | ចំនួនបន្ទប់ | គ្មាន | ៣៤ | ៦៨ | ៨១ | ១៩៦ |
| ៦ | ក្លឹបកម្សាន្ត | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

| | | | | | | |
|---|---|---|---|---|---|---|
| | ចំនួនកៅអី | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ៧ | ម៉ាស្សា | ១១ | ១២ | ២៤ | ២០ | ១៨ |
| | ចំនួនបន្ទប់ | គ្មាន | ៣០ | ៧១ | ៦៧ | ៦១ |
| ៨ | ហាងកាហ្វេ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| | ចំនួនកៅអី | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ៩ | បន្ទប់ជួល | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| | ចំនួនបន្ទប់ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ១១ | ភ្ញៀវទេសចរជាតិ | ១២៦ ៩៨៣ | ១២៦ ៨១៦ | ១៨២ ២៨១ | ៤២ ៥៦៩ | ១២ ៤០៦ |
| ១២ | ភ្ញៀវអន្តរជាតិ | ៣ ៥០៨ | ៥ ០២៧ | ៥ ០២៧ | ៣១០ | ៤ |

## ២.១៧- ខេត្តមណ្ឌលគិរី

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តមណ្ឌលគិរី សម្រេចបាន៖**

មណ្ឌលគិរី គឺជាខេត្តមួយស្ថិតនៅភូមិភាគឥសាន្ត នៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយផ្លូវប្រវែង **៣៨២គ.ម.** ពីរាជធានីភ្នំពេញ។ មានក្រុងសែនមនោរម្យ ជាទីរួមខេត្ត និងស្រុកចំនួន៤ ចែកចេញជា៤សង្កាត់ ១៧ឃុំ និង៩២ភូមិ។ ខេត្តមានផ្ទៃដីសរុបចំនួន១៤ ២៨៨គ.ម.$^{២}$ ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ប្រជុំភ្នំ និងខ្ពង់រាប សំបូរដោយជ្រលងជងអូរជាច្រើន។ មានព្រំប្រទល់ជាប់ជាមួយនឹងប្រទេសវៀតណាម ប្រវែង៣១៤ ៦៦៤គ.ម. ព្រំប្រទល់ខាងកើត និងខាងត្បូងជាប់ជាមួយខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្ត ប៊ិញភឿកនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងជើងជាប់នឹងខេត្តស្ទឹងត្រែង និងខេត្តរតនគិរី និងខាងលិចជាប់នឹងខេត្តក្រចេះ។ បច្ចុប្បន្ន ខេត្តមានប្រជាពលរដ្ឋសរុបចំនួន៩៣ ៤៤១នាក់(ស្រី៤៥ ៤២៥នាក់) ស្មើនឹង២២ ២២០គ្រួសារប្រជាពលរដ្ឋ អាយុ១៨ឆ្នាំឡើង មានចំនួន៥១ ៤៣១នាក់ និងមានដង់ស៊ីតេប្រជាពលរដ្ឋស្មើនឹង៧នាក់/គីឡូម៉ែត្រក្រឡា កំណើនប្រជាពលរដ្ឋប្រចាំឆ្នាំប្រមាណ២,៧៤%។ ប្រជាពល រដ្ឋជាជនជាតិដើមភាគតិចរស់នៅក្នុងខេត្តចំនួន៨ជនជាតិ ក្នុងនោះមានព្នង ក្រោល គ្រឹង ស្មៀង ថ្មូន ទំពួន ចារាយ និងគួយ។

### ១- សាធារណការ និងការកែលម្អសោភ័ណភាព

#### ក- ការកែលម្អសោភ័ណភាព

- ផ្លូវជាតិលេខ៧៦ តភ្ជាប់ពីស្រុកស្នួល ខេត្តក្រចេះ មកដល់ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ប្រវែង១២៧គ.ម. បានសាងសង់រួចរាល់ជាស្ថាពរ និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ កំណាត់ផ្លូវជាតិលេខ៧៦ ពីក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ទៅដល់តាអង្គ ស្រុកលំផាត់ ខេត្តរតនគិរីប្រវែង១៧២គ.ម. បានសាងសង់រួចរាល់១០០% និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួចរាល់ ហើយផងដែរ។ ផ្លូវលេខ៧៥ ពីស្រុកកោះញែក ទៅស្រុកចិត្របុរី ខេត្តក្រចេះ មានប្រវែង១៥០គ.ម.(ផ្លូវដី) បានសិក្សារួចរាល់ហើយ

- ប្រវែងផ្លូវក្នុងខេត្តសរុប៨៥១ ៣៧៦គ.ម.(សរុបទាំងផ្លូវជាតិ ផ្លូវសំខាន់ៗក្នុងខេត្ត ផ្លូវនៅក្នុងក្រុងសែនមនោរម្យ និងផ្លូវលំជនបទ) ក្នុងនោះ ផ្លូវក្នុងខេត្តមានចំនួន៨ខ្សែ ប្រវែង៥៣០,៥គ.ម.(ផ្លូវចាក់កៅស៊ូDBST ១២៣គ.ម. ផ្លូវចាក់កៅស៊ូម៉ាកាដាម៧គ.ម. ផ្លូវក្រួសក្រហម១៦១,៥គ.ម. និងផ្លូវដី២៣៩គ.ម.) ផ្លូវក្នុងក្រុងសែនមនោរម្យមានចំនួន៥៩ខ្សែ ប្រវែង៦៥,៨៧៦ម.(ផ្លូវចាក់កៅស៊ូ ម៉ាកាដាម៣៤ ៧៩៣ម. ផ្លូវក្រួសក្រហម ១ ៦៦៩ម. និងផ្លូវដី២៩ ៤១៤ម.) និងផ្លូវលំក្នុងខេត្តសរុប៣២ខ្សែ ប្រវែង២៥៥គ.ម.។

ក្រៅពីនេះ ខេត្តក៏មានផ្លូវទៅកាន់ច្រកទ្វារព្រំដែនចំនួន៣ខ្សែផងដែរ សម្រាប់ការធ្វើដំណើរនិងទំនាក់ទំនងការងារកិច្ចសហប្រតិបត្តិការជាមួយបណ្ដាខេត្តរបស់ប្រទេសវៀតណាម។

ការអនុវត្តគម្រោងគុណប្រយោជន៍ខេត្ត ក្នុងនោះ មានការសាងសង់សំណង់និងហេដ្ឋារចនាសម្ព័ន្ធផ្សេងជាច្រើន ដូចជាផ្លូវភ្លោះ ផ្លូវទំនប់លើក្រោម ផ្លូវវាងក្រុង និងផ្លូវខេត្តជាច្រើនទៀត រួមទាំងការសាងសង់ និងដាក់លូ មានលូមូល លូជ្រុង លូប្រអប់ ផ្លូវបេតុង ផ្លូវចាក់កៅស៊ូ បណ្ដាញអគ្គិសនី ផ្សារថ្មីក្រុងសែនមនោរម្យ ចំណតរថយន្ត អគាររដ្ឋបាលសាលាខេត្ត សាលប្រជុំសាលាខេត្ត អគារធ្វើការងារផ្សេងៗនៅក្នុងសាលាខេត្ត សួនច្បារសាធារណៈ សួនច្បារក្នុងសាលាខេត្ត និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាច្រើនទៀត ដែលសរុបចំនួន១២០គម្រោង ដែលមានទឹកប្រាក់សរុបចំនួន១៦ ៣៧៩ ៦០៨ ៣២២ ០០០រៀល។

**ខ- ការងារសាងសង់និងជួសជុល**

- ការងារសាងសង់និងជួសជុលផ្លូវកៅស៊ូ ផ្លូវខេត្ត និងផ្លូវជាតិសរុបចំនួន២០ខ្សែ មានប្រវែង៤១ ៨៨០ម. ថែទាំជាប្រចាំផ្លូវចំនួន៣៨ខ្សែ ប្រវែង១ ០៩៦,៩៤គ.ម. សាងសង់លូមូល លូជ្រុង លូអ៊ុយ ជាឡូចំនួន១៤កន្លែង និងប្រឡាយសរុបប្រវែង១ ៩៤០ម. និងសាងសង់ស្ពានបេតុងចំនួន២កន្លែង ប្រវែង៦៣ម.

- ការងារសាងសង់និងជួសជុលផ្លូវលំជនបទក្នុងខេត្ត(ផ្លូវក្រួសក្រហមនិងល្បាយថ្មភ្នំ) អនុវត្តបានចំនួន៣៤០គ.ម. ស្ពានបេតុងចំនួន៨កន្លែង ប្រវែង៣១២ម. សាងសង់និងជួសជុលស្ពានឈើចំនួន៤កន្លែង ប្រវែង៦៥ម.។ ការងារសាងផ្លូវចាក់កៅស៊ូពីរជាន់ប្រវែង៨គ.ម. សាងសង់ផ្លូវចាក់បេតុងអាមេប្រវែង១,៨៥០ម. នៅក្នុងក្រុងសែនមនោរម្យនិងបានសាងសង់លូប្រអប់ លូមូល និងសំណង់ បង្ហៀរជាច្រើនកន្លែងទៀត សម្រាប់រំដោះទឹកនៅតាមដងផ្លូវជនបទជាច្រើនកន្លែង។ ជួសជុលថែទាំផ្លូវលំជនបទសម្រេចបានចំនួន៣៤០គ.ម. និងសង់អណ្ដូងស្នប់សរុបបានចំនួន៦០អណ្ដូង។

**២- ការងារធនធានទឹកនិងឧតុនិយម**

ការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្នុងនោះ ការងារជួសជុលថែទាំទំនប់ដីចំនួន២១ខ្សែ ប្រវែង៤៨ ២៣៦ម. ការងារជួសជុលថែទាំប្រឡាយមេចំនួន៣៨ខ្សែ ប្រវែង៦១ ២២៥ម. ការងារសាងសង់ ទំនប់ដី១ខ្សែ ប្រវែង៤៥០ម. ការងារសាងសង់ប្រឡាយមេ១ខ្សែ ប្រវែង៨០០ម. ការងារសាងសង់ស្ថានីយឧតុនិយម១កន្លែង និងការងារជួសជុលសំណង់សិល្បៈការចំនួន១៧កន្លែង។

**៣- ការងាររ៉ែនិងថាមពល**

ខេត្តមានស្ថានីយ៍វារីអគ្គិសនីខ្នាតតូចចំនួន២កន្លែងគឺ ស្ថានីយអូររមីសនិងស្ថានីយអូរម្លែង សម្រាប់ផ្គត់ផ្គង់ថាមពលដល់ប្រជាពលរដ្ឋក្នុងក្រុងសែនមនោរម្យ ដែលមានថាមពលផ្គត់ផ្គង់ចំនួន៣៧០Kwh ម៉ាស៊ីនភ្លើងកម្លាំង៣០០Kwh បណ្ដាញអគ្គិសនី២២Kv តភ្ជាប់ពីខេត្តដាក់ណុង ប្រទេសវៀតណាម មកក្រុងសែនមនោរម្យ និងបណ្ដាញអគ្គិសនី២២Kv បានតភ្ជាប់ពីខេត្តប៊ិញភឿក ប្រទេសវៀតណាម មកស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ទន្ទឹមនឹងនោះដែរ បច្ចុប្បន្ននេះ ខេត្តក៏បានទទួលការផ្គត់ផ្គង់អគ្គិសនីមួយផ្នែកមកពីស្ថានីយវារីអគ្គិសនីសេសាន ក្រោម២ដល់ខេត្តមណ្ឌលគិរីផងដែរ។

បណ្ដាញផ្គង់ផ្គង់អគ្គិសនីបានគ្របដណ្ដប់ស្ទើរគ្រប់ភូមិនៅទូទាំងខេត្ត លើកលែងតែភូមិមួយចំនួនតូចដែលស្ថានភាពផ្លូវមានការលំបាកធ្វើដំណើរចូលទៅដល់ និងភូមិនៅតំបន់ដាច់ស្រយ៉ាលនៅក្នុងព្រៃជ្រៅ។ ជាក់ស្ដែងរហូតមកដល់បច្ចុប្បន្ននេះបណ្ដាញអគ្គិសនីផ្គត់ផ្គង់ទូទាំងខេត្តក្នុងនោះ ការតភ្ជាប់បណ្ដាញMV បានប្រវែង៦១០,២៨

គ.ម. បណ្ដាញLV បានប្រវែង៣៣២,១៥គ.ម. និងផ្គត់ផ្គង់ថាមពលប្រើប្រាស់ជូនប្រជាពលរដ្ឋប្រមាណ១២ ២៨៤ ខ្នងផ្ទះ។ អនុស្ថានីយបណ្ដាញចែកចាយអគ្គិសនីពីស្ថានីយសេសានពីរ បាននិងកំពុងដំណើរការសាងសង់ នៅក្នុងភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

**៤- ការងារទេសចរណ៍**

ខេត្តមានតំបន់រមណីយដ្ឋានទេសចរណ៍សរុបចំនួន១០៥កន្លែង ក្នុងនោះ រមណីយដ្ឋានទេសចរណ៍ទាក់ទាញ ដែលអាចធ្វើដំណើរទៅដល់មានចំនួន៣៧កន្លែង ដែលមានដូចជាទឹកជ្រោះ កំពូលភ្នំ វាលស្មៅ មានអាកាសធាតុត្រជាក់ស្រួល និងមានសេវាកម្មទេសចរណ៍ ក្នុងនោះ សណ្ឋាគារ៦កន្លែង ផ្ទះសំណាក់៣៦កន្លែង ម៉ូតែល១០កន្លែង ភោជនីយដ្ឋាន និងអាហារដ្ឋាន៣៦កន្លែង និងមានក្រុមហ៊ុនវិនិយោគលើវិស័យទេសចរណ៍ ដោយឯកជនសរុបមានចំនួន៤ទីតាំង។ ទន្ទឹមនឹងនោះដែរ ស្ថានភាពភ្ញៀវទេសចរណ៍មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ លើកលែងតែប៉ុន្មានឆ្នាំចុងក្រោយនេះដោយសារស្ថានភាពការរាលដាលជំងឺកូវីដ-១៩ ធ្វើឱ្យទេសចរណ៍ មានការថយចុះ។

## ២.១៨- ខេត្តរតនគិរី

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តរតនគិរី សម្រេចបាន៖**

| ល.រ. | សមិទ្ធផល |
|---|---|
| **វិស័យព័ត៌មាន ទេសចរណ៍ វប្បធម៌ និងវិចិត្រសិល្បៈ ធម្មការ និងសាសនា** | |
| ១ | **ការងារទេសចរណ៍** ឧស្សាហកម្មទេសចរណ៍(សេវាកម្ម) មានចំនួន១២៨ទីតាំង បម្រើឱ្យភ្ញៀវជាតិ-អន្តរជាតិ និងបានផ្តល់ការងារ ចំនួន៨២២កន្លែង មានរមណីយដ្ឋានទេសចរណ៍ ចំនួន២០កន្លែង |
| ២ | **ការងារធម្មការ និងសាសនា** វត្តបង្កើតថ្មីចំនួន៥វត្ត(គណៈមហានិកាយ៣វត្ត គណៈធម្មយុត្តិនិកាយ២វត្ត) សរុបវត្តអារាមទូទាំងខេត្តចំនួន៣៩វត្ត និងបានសាងសង់ព្រះពុទ្ធបដិមាកម្ពស់១៥,៥ម. ស្ថិតនៅលើភ្នំឥសីបតមៈ(ភ្នំស្វាយ) ប្រែទៅជាមណ្ឌលទេសចរណ៍វប្បធម៌ និងសាសនា |
| **វិស័យកសិកម្ម រុក្ខាប្រមាញ់ នេសាទ ធនធានទឹក និងឧតុនិយម** | |
| ១ | **ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ផ្ទៃដីដំណាំកសិឧស្សាហកម្មរួមមានផ្ទៃដីកៅស៊ូ៦៥ ០៧១,៣ហ.ត.(កៅស៊ូឧស្សាហកម្មគ្រួសារ៣៨ ០០៨,៥៤ហ.ត. កៅស៊ូក្រុមហ៊ុនវិនិយោគ២៤ ៤៧៥ ៧៦ហ.ត. និងក្រុមហ៊ុនស៊ីប៉ាប់បើរ ២៥៨៧,៩៣ហ.ត.) គិតមកទល់ពេលនេះ ផ្ទៃដីចៀរជ័រកៅស៊ូ លើផ្ទៃដីសរុបចំនួន៤១ ៧៩៤,១៨ហ.ត. ផ្ទៃដីដំណាំចន្ទីសរុបចំនួន៤៥ ០៦៨,១៦ហ.ត. និងដំណាំឈើហូបផ្លែគ្រប់ប្រភេទសរុបចំនួន១៦ ០៩៤ហ.ត.<br>- ក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ច នៅក្នុងខេត្តរតនគិរី សរុបចំនួន ២៧ក្រុមហ៊ុន(ក្រុមហ៊ុន ដែលបានចុះបញ្ជីដីរួចចំនួន ២១ក្រុមហ៊ុន និងកំពុងដំណើរការចុះបញ្ជីដី ចំនួន៦ក្រុមហ៊ុន) មានផ្ទៃដី អាជីវកម្ម សរុប៨៩ ៧១៩,៥៧ហ.ត. លើផ្ទៃដីវិនិយោគ សរុប១០២ ៨៦១,៥០ហ.ត. ដែលបានធ្វើការឈូសឆាយរួចរាល់៥៨ ១៥៩ហ.ត. ដោយធ្វើការដាំដុះដំណាំ រួមមានកៅស៊ូ២៤ ៦៧៤,៨៣ហ.ត. ដំណាំឈើហូបផ្លែ១៤ ២៣១ហ.ត. និងដំណាំផ្សេងទៀត៤៥៩ហ.ត. |
| ២ | - ការងារធនធានទឹក និងឧតុនិយម បានតម្លើងស្ថានីយឧតុនិយមស្វ័យប្រវត្តិចំនួន៥កន្លែង អាងតម្រង់ទឹកភ្លៀងចំនួន៣កន្លែង ស្ថានីយជលសាស្ត្រ៥កន្លែង មានទំនប់អាងស្តុកទឹកសរុប៧ ៨៣៧ម. មានប្រឡាយទឹកសរុប៣៧ ៦៧០ម. និងប្រឡាយបេតុង៨៩ម. |
| **វិស័យពាណិជ្ជកម្ម រ៉ែ ថាមពល ឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ នវានុវត្តន៍ ប្រៃសណីយ៍ និងទូរគមនាគមន៍** | |
| ១ | **ការងារឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ នវានុវត្តន៍** មានរោងចក្រ សហគ្រាសធុនតូច និងមធ្យម មានចំនួន១៩៦មូលដ្ឋាន |
| ២ | **ការងារទឹកស្អាត** មានការវិនិយោគពីក្រុមហ៊ុនឯកជនចំនួន៥មូលដ្ឋាន ដែលបានតភ្ជាប់បណ្តាញជូនពលរដ្ឋប្រើប្រាស់បានចំនួន១ ៦៨៦គ្រួសារ។ |

| | |
|---|---|
| ៣ | **ការងាររ៉ែ និងថាមពល** អាជ្ញាបណ្ណវិស័យរ៉ែមាន៤ប្រភេទ រួមមានអាជ្ញាបណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ(រ៉ែមាស) អាជ្ញាបណ្ណសិក្សាស្រាវជ្រាវស្វែងរុករករ៉ែលោហៈ អាជ្ញាបណ្ណអាជីវកម្ម ធនធានរ៉ែថ្មសម្ភារៈសំណង់(ថ្មសំណង់ ថ្មអារ និងខ្សាច់សំណង់) និងអាជ្ញាបណ្ណអាជីវកម្មសិប្បកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច(សិប្បកម្មបូមខ្សាច់ និងរ៉ែត្បូងថ្មមានតម្លៃ) មានទុនវិនិយោគសរុប៣៣,៥៧លានដុល្លារសហរដ្ឋអាម៉េរិក ស្ថានីយប្រេងឥន្ធៈចំនួន៩០ស្ថានីយ និងបានតបណ្តាញអគ្គិសនីបញ្ជូនតភ្ជាប់ចូលដល់ភូមិ១៩៤ភូមិ ស្មើនឹង៧៩,៨៣% |
| ៤ | **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍** ក្រុមហ៊ុនបម្រើសេវាបញ្ញើឆាប់រហ័សសរុបចំនួន៨ក្រុមហ៊ុន ក្រុមហ៊ុនបម្រើសេវាទូរសព្ទ៤ក្រុមហ៊ុន មានបង្គោល១៧៨បង្គោល និងម៉ៃក្រូវេវសរុប២៣១ មានប្រតិបត្តិករទូរគមនាគមន៍ អ៊ីនធឺណិតចល័ត និងអចល័តចំនួន២ក្រុមហ៊ុន មានប្រតិបត្តិករទូរគមនាគមន៍ខ្សែកាបអុបទិកឆ្លងកាត់ខេត្ត២ក្រុមហ៊ុន |
| **វិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ រតនាគារ ធនាគារ ពន្ធដារ** | |
| ១ | **ការងារធនាគារ** គិតត្រឹមឆ្នាំ២០២១ នៅក្នុងខេត្តរតនគិរី មានគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សរុបចំនួន១៨ កំពុងធ្វើប្រតិបត្តិការ ក្នុងនោះមានធនាគារពាណិជ្ជចំនួន១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំនួន២។ |
| ២ | **ការងារពន្ធដារ** បានប្រមូលចំណូលសារពើពន្ធសរុប៤៩ ៦៦២ ៣៩៣ ១៨៥រៀល។ |
| **វិស័យសង្គមកិច្ច អប់រំ សុខាភិបាល** | |
| ១ | **ការងារអប់រំ** គ្រឹះស្ថានសិក្សាទូទាំងខេត្តសរុបចំនួន៤៣៦ទីតាំង សិស្សសរុបចំនួន១៧ ៤២៤នាក់ ក្នុងនោះ មានវិស័យឯកជនចំនួន១២ទីតាំង |
| ២ | **ការងារសុខាភិបាល** ក្នុងខេត្តមានស្រុកប្រតិបត្តិ២កន្លែង មន្ទីរពេទ្យបង្អែកចំនួន២(មន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យបង្អែកបរកែវ) គ្រែសម្រាកព្យាបាល ចំនួន២៣៣គ្រែ(គ្រែរបេងចំនួន៤១គ្រែ) មណ្ឌលសុខភាព ចំនួន២៧មណ្ឌល និងប៉ុស្តិ៍សុខភាព ចំនួន៨ប៉ុស្តិ៍ |
| **វិស័យមនុស្សធម៌និងការឆ្លើយតបនឹងគ្រោះមហន្តរាយ** | |
| ១ | ផ្តល់អំណោយដល់ពលរដ្ឋក្រីក្រ ជនងាយរងគ្រោះ និងទារក អ្នករស់នៅជាមួយជំងឺអេដស៍ចំនួន៥ ០៩៥គ្រួសារ |
| ២ | សាងសង់ផ្ទះជូនអតីតយុទ្ធជន និងទុគ៌តជនចំនួន៩ខ្នង |
| ការងារកសាងហេដ្ឋានរចនាសម្ព័ន្ធ | |
| ១ | ផ្លូវកៅស៊ូDBST សរុបចំនួន៤៥ខ្សែ មានប្រវែងសរុបចំនួន២១ ១២៧ម. |
| ២ | ផ្លូវកៅស៊ូ AC សរុបចំនួន២ខ្សែ មានប្រវែងសរុបចំនួន១ ៣២០ម. |
| ៣ | ផ្លូវបេតុងអាមេចំនួន៩៥ខ្សែ មានប្រវែងសរុបចំនួន១៨ ០៩៣,៩៥៦គ.ម. |
| ៤ | ផ្លូវគ្រួសក្រហមចំនួន២១១ខ្សែ មានប្រវែងសរុបចំនួន៤៩៤ ៥៤៩,២១៦គ.ម. |
| ៥ | លូរំដោះទឹកចំនួន១៩ខ្សែ មានប្រវែងសរុបចំនួន១៥ ៦៩៩ម. |
| ៦ | ការ៉ូឡូចិញ្ចើមផ្លូវចំនួន២១ខ្សែ មានទំហំសរុបចំនួន៣២ ៣៣១ម.[២] |
| ៧ | ភ្លើងបំភ្លឺសាធារណៈចំនួន៨ខ្សែ ស្មើនឹង១៦៧បង្គោល |
| ៨ | សួនច្បារចំនួន១០ទីតាំង |
| ៩ | អគាររដ្ឋបាល(សាលាស្រុក សាលាឃុំ សង្កាត់ និងមន្ទីរ អង្គភាព) សរុបចំនួន៣២អគារ |
| ១០ | ស្ពានដែកបេឡេតឺចំនួន១កន្លែង |
| ១១ | ស្ពានឈើ២៨កន្លែង |
| ១២ | លូទោល លូភ្លោះកាត់ផ្លូវ១៩៦កន្លែង |
| ១៣ | ស្រះទឹក សរុបចំនួន៤កន្លែង |
| ១៤ | ប្រឡាយទឹក៣ ៩០០ម. |
| ១៥ | រង្វង់មូល ចំនួន១កន្លែង |
| ១៦ | អណ្តូងទឹក សរុបចំនួន២៩៥អណ្តូង |

| | |
|---|---|
| ១៧ | បង្គន់អនាម័យ សរុបចំនួន១៦៥បង្គន់ |
| ១៨ | របងបេតុង សរុបចំនួន៩៩៨ម.។ |

## ២.១៩- ខេត្តស្ទឹងត្រែង

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តស្ទឹងត្រែង សម្រេចបាន៖**

ខេត្តស្ទឹងត្រែង ស្ថិតនៅភាគឦសាននៃប្រទេស មានចម្ងាយ៤៥៥គ.ម. ពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងជើងជាប់ខេត្តចាំប៉ាសាក់ និងខេត្តអត្តពឺនៃប្រទេសឡាវ ខាងកើតជាប់ខេត្តរតនគិរី ខាងត្បូងជាប់ខេត្តក្រចេះនិងខេត្តមណ្ឌលគិរី ខាងលិចជាប់នឹងខេត្តព្រះវិហារ និងខេត្តកំពង់ធំ។ ខេត្តមានផ្ទៃដី១២ ០១៦គ.ម.$^{2}$ ចែកជា៦ក្រុង ស្រុក ៣៤ឃុំ សង្កាត់ ១២៨ភូមិ បច្ចុប្បន្នខេត្តមានប្រជាជន១៦៤ ៥៩៨នាក់(ស្រី៨២ ៣១៨នាក់) ស្មើនឹង៣៩ ៣៨៧គ្រួសារ ក្នុងនោះ ប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង មានចំនួន៩៣ ៧០៤នាក់ អត្រាកំណើនប្រជាជន៣,៨% គិតជាដង់ស៊ីតេប្រជាជន ស្មើនឹង១៣នាក់ក្នុង១គីឡូម៉ែត្រក្រឡា។

សមិទ្ធផលជាប្រវត្តិសាស្ត្រ ជាមរតកនិងមានតម្លៃយ៉ាងធំធេងក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងទឹកដីនៃខេត្តស្ទឹងត្រែង រួមមាន៖

- ទំនប់វារីអគ្គិសនីសេសានក្រោម២ មានអនុភាព៤០០មេហ្គាវ៉ាត់ ដែលបានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨
- ស្ពានឆ្លងកាត់ទន្លេសេកុង លើកំណាត់ផ្លូវជាតិលេខ៧ ឆ្ពោះទៅព្រំដែនឡាវ មានប្រវែង១ ០៥៧ម.
- ស្ពានឆ្លងកាត់ទន្លេមេគង្គលើកំណាត់ផ្លូវជាតិលេខ៩ ភ្ជាប់ទៅខេត្តព្រះវិហារ មានប្រវែង១ ៧៣១ម.
- ស្ពានឆ្លងកាត់ទន្លេកុងផ្នែកខាងលើ មានឈ្មោះទន្លេកុងសែនជ័យ មានប្រវែង២៦០ម.
- ស្ពានឆ្លងកាត់ទន្លេកុងផ្នែកខាងលើ មានឈ្មោះកោះទន្សាយសែនជ័យ មានប្រវែង២៤០ម.
- ផ្លូវជាតិសំខាន់ៗកាត់ខេត្តចំនួន៣ គឺផ្លូវជាតិលេខ៧ លេខ៩ និងលេខ៧៨ បម្រើការធ្វើចរាចរណ៍ភ្ជាប់ទៅកាន់រាជធានីភ្នំពេញ ប្រាសាទអង្គរវត្ត តំបន់មាត់សមុទ្រ និងទៅកាន់បណ្តាខេត្តផ្សេងៗទៀត
- ផ្លូវក្រវាត់ព្រំដែនដែលមានប្រវែងជាង២០០គ.ម.
- ផ្សារសាមគ្គីស្ទឹងត្រែង ជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលមានចំនួន១ ២៨៦តូប រាន សម្រាប់អាជីវករលក់ដូរ។

**១- ការងារហេដ្ឋារចនាសម្ព័ន្ធ**

- ការអនុវត្តគម្រោងក្រុង ស្រុក សម្រេចបាន ផ្លូវបេតុងប្រវែង៤ ២៦៧ម. ផ្លូវក្រួសក្រហមប្រវែង២៨ ០២២គ.ម. ស្ពានឈើក្បាលបេតុង៧កន្លែង ដាក់លូកាត់ផ្លូវ១២កន្លែង រៀបចំសួនច្បារចំនួន៩កន្លែង និងគម្រោងឃុំ សង្កាត់ សម្រេចបានផ្លូវបេតុងប្រវែង៣ ៤៥៧ម. ផ្លូវក្រួសក្រហមប្រវែង១០៨គ.ម. ស្ពានឈើក្បាលបេតុង១៥កន្លែង និងលូកាត់ផ្លូវ៨៨កន្លែង
- គម្រោងផ្លូវថ្នល់អនុវត្តដោយមន្ទីរជំនាញ ដែលមានការស្ថាបនាផ្លូវកៅស៊ូ២២គ.ម. ផ្លូវបេតុង៦ខ្សែប្រវែងសរុប១ ២០០ម. ស្ពានបេតុង៩កន្លែង ប្រវែង៣៤៨ម.។ ផ្លូវលំជនបទ២៦ខ្សែ ប្រវែងសរុប៣១២គ.ម. ស្ពានឈើក្បាលបេតុង១០កន្លែង
- ការអភិវឌ្ឍគម្រោងផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន ក្រោមហិរញ្ញប្បទានឥណទាន ធនាគារអភិវឌ្ឍន៍អាស៊ី មានសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត១២ ០០០ម.$^{3}$ក្នុង១ថ្ងៃ និងបណ្តាញចែកចាយទឹកស្អាតថ្មី២៨៥គ.ម.

- អភិវឌ្ឍគម្រោងស្ថានីយស្រាវជ្រាវ និងផលិតពូជត្រី តាមបទដ្ឋានបច្ចេកទេសថ្មី ដែលអនុវត្តរួមគ្នារវាងក្រសួងធនធានទឹកនិងរដ្ឋបាលជលផលនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រោមគម្រោងហិរញ្ញប្បទានធនាគារពិភពលោកចំនួន១កន្លែង

- គម្រោងស្ដាបនាផ្លូវបេតុងប្រវែងជាង២២គ.ម. ស្ពានបេតុង១១កន្លែង ប្រវែង៣៨០ម. និងលូប្រអប់លូមូលចំនួន៥៧កន្លែង ជាគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអគ្នេយ៍ ក្នុងគម្រោងជំនួយរបស់ធនាគារពិភពលោក

- ការពង្រីក និងភ្ជាប់បណ្ដាញអគ្គិសនីគ្របដណ្ដប់ស្ទើរគ្រប់ភូមិទាំង១២៨ ក្នុងឃុំ សង្កាត់ទាំង៣៤ ក្នុងនោះ គ្រួសារប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់ជាង៨០% និងមូលដ្ឋានប្រជាពលរដ្ឋរស់នៅតាមបណ្ដាជីកោះមួយចំនួន ត្រូវបានផ្ដល់ជូននូវផ្ទាំងថាមពលអគ្គិសនីស៊ុលឡាប្រើពន្លឺព្រះអាទិត្យ។ ក្នុងនោះបានសាងសង់បណ្ដាញខ្សែបញ្ជូន LV ប្រវែង១៧០គ.ម. ខ្សែបណ្ដាញMV ប្រវែង១៦៩គ.ម. និងដាំបង្គោល LV LV បាន១ ០៧៤ដើម។

**២- ការគ្រប់គ្រងធនធានធម្មជាតិ ផ្សារភ្ជាប់នឹងវិស័យទេសចរណ៍**

- រៀបចំចងក្រងនិងបង្កើតសហគមន៍ទេសចរណ៍៦កន្លែង រម្មណីយដ្ឋានអេកូទេសចរណ៍១១កន្លែង សហគមន៍នេសាទ៥២ សហគមន៍ព្រៃឈើ២១ សហគមន៍តំបន់ការពារធម្មជាតិ៧សហគមន៍

- ពង្រឹងអភិបាលកិច្ចនិងកិច្ចការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ តាមរយៈការអនុវត្តតួនាទីរបស់មន្ត្រីបរិស្ថាននុរក្ស មន្ត្រីជំនាញក្នុងវិស័យព្រៃឈើ ជលផល និងសហគមន៍មូលដ្ឋាន។

| បរិយាយ | ឯកតា | លទ្ធផលសម្រេចបាន | |
|---|---|---|---|
| | | គិតត្រឹមឆ្នាំ ២០១៦ | ក្នុង/ត្រឹមឆ្នាំ ២០២១ |
| រម្មណីយ៍ទេសចរណ៍ធម្មជាតិនិងវប្បធម៌ | កន្លែង | ៩ | ១១ |
| សហគមន៍ទេសចរណ៍ | កន្លែង | ៤ | ៦ |
| ផ្ទះស្នាក់សគមន៍ទេសចរណ៍ | កន្លែង | ២៩ | ២៣ |
| សណ្ឋាគារ | កន្លែង | ៤ | ៦ |
| ផ្ទះសំណាក់ | កន្លែង | ៣៦ | ៤២ |
| ភោជនីយដ្ឋាន | កន្លែង | ៣ | ៣ |
| អាហារដ្ឋាន | កន្លែង | ៥២ | ៤៩ |
| មណ្ឌលកម្សាន្តមនុស្សពេញវ័យ | កន្លែង | ៩ | ១២ |
| កម្លាំងពលកម្មក្នុងវិស័យទេសចរណ៍ | នាក់ | ៦១៣ | ៥៨៧ |
| គណៈកម្មការសហគមន៍ទេសចរណ៍ | គណៈកម្មការ | ៤២ | ៥៦ |

## ២.២០- ខេត្តក្រចេះ

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តក្រចេះ សម្រេចបាន៖

ខេត្តក្រចេះ ស្ថិតនៅភាគប៉ែកឦសាននៃប្រទេសកម្ពុជា មានស្ថានភាពដីជាពីរប្រភេទគឺ តំបន់ខ្ពង់រាប និងតំបន់វាលទំនាប មានចម្ងាយ៣៤០គ.ម. ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៧ ឆ្លងកាត់ស្រុកស្នួល ចម្ងាយ២៥០ គ.ម. ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៧៣ ឆ្លងកាត់តាមស្រុកគំបែរ និងស្រុកឆ្លូង និងចម្ងាយ២២០គ.ម. តាមផ្លូវទឹកទន្លេមេគង្គ។ ទន្លេមេគង្គហូរកាត់ក្រុង១ និងស្រុក៤ ក្នុងចំណោមក្រុងនិងស្រុកទាំង៦របស់ខេត្ត ដែលមាន

ប្រវែង១៤០គ.ម. មានព្រែកធំៗចំនួន៥ស្ថិតនៅខាងកើតទន្លេមេគង្គ។ ខេត្តក្រចេះមានផ្ទៃដីធម្មជាតិសរុប ១១ ០៩៤គ.ម.២ ចែកជាក្រុង១ ស្រុក៥ មាន៥សង្កាត់ ៤៣ឃុំ និង២៩៥ភូមិ។ ចំនួនប្រជាពលរដ្ឋសរុប ៤២៩ ៩០៨នាក់(ស្រី២១៦ ៣៨៥នាក់) ស្មើនឹង៩៧ ៣១៦គ្រួសារ ដង់ស៊ីតេប្រជាជន៣៧នាក់/គ.ម.២ ដែលប្រមាណ៨១% ជាកសិករ។ ខេត្តមានជនជាតិដើមភាគតិចចំនួន៧រស់នៅក្នុងនោះ ជនជាតិព្នង កួយ ស្ទៀង មិល ក្រោល ថ្មូន និងជនជាតិខោល។

### ១- វិស័យទេសចរណ៍៖

#### ក- ស្ថិតិមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍

សរុបឆ្នាំ២០១៧ មានចំនួន១១១កន្លែង ឆ្នាំ២០១៨មានចំនួន១៤៩កន្លែង ឆ្នាំ២០១៩មានចំនួន ១៥២កន្លែង ឆ្នាំ២០២០មានចំនួន១៥១កន្លែង និងឆ្នាំ២០២១ មានចំនួន១៤១កន្លែង៖

| ល.រ. | ប្រភេទ អាជីវកម្ម | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ |
|---|---|---|---|---|---|---|
| ១ | សណ្ឋាគារ | ១៤កន្លែង= ៥៦២បន្ទប់ | ១៥កន្លែង= ៦២១បន្ទប់ | ១៦កន្លែង = ៦៥២បន្ទប់ | ១៦កន្លែង = ៦៥២បន្ទប់ | ១៥កន្លែង = ៥៩៣បន្ទប់ |
| ២ | ផ្ទះសំណាក់ | ៣៦កន្លែង= ៣២០បន្ទប់ | ៤៨កន្លែង= ៤៥០បន្ទប់ | ៤៨កន្លែង= ៤៥០បន្ទប់ | ៤៧កន្លែង= ៤៣៥បន្ទប់ | ៤១កន្លែង= ៣៦បន្ទប់ |
| ៣ | ភោជនីដ្ឋាន អាហារដ្ឋាន | ៣៩កន្លែង | ៥៨កន្លែង | ៥៨កន្លែង | ៦០កន្លែង | ៦០កន្លែង |
| ៤ | ខារ៉ាអូខេ | ១២កន្លែង | ១៨កន្លែង | ២១កន្លែង | ១៨កន្លែង | ១៥កន្លែង |
| ៥ | ម៉ាស្សា | ៩កន្លែង | ៩កន្លែង | ៩កន្លែង | ១០កន្លែង | ១០កន្លែង |
| ៦ | ក្លិបកម្សាន្ត | ១កន្លែង | ១កន្លែង | _ | _ | - |
| **សរុបរួម** | | **១១១កន្លែង** | **១៤៩កន្លែង** | **១៥២កន្លែង** | **១៥១កន្លែង** | **១៤១កន្លែង** |

#### ខ- ស្ថិតិរមណីយដ្ឋានទេសចរណ៍និងសហគមន៍ទេសចរណ៍ក្នុងខេត្ត៖

រមណីយដ្ឋានទេសចរណ៍ក្នុងខេត្តក្រចេះសរុបចំនួន១៩កន្លែង ក្នុងនោះរួមមាន រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រចំនួន៥កន្លែង រមណីយដ្ឋានធម្មជាតិចំនួន១១កន្លែង រមណីយដ្ឋានវប្បធម៌ធម្មជាតិចំនួន១កន្លែង និងកែច្នៃចំនួន២កន្លែង។

| បរិយាយ | តារាងស្ថិតិរមណីយដ្ឋាន និងសហគមន៍ទេសចរណ៍ | | | | |
|---|---|---|---|---|---|
| | **ឆ្នាំ២០១៧** | **ឆ្នាំ២០១៨** | **ឆ្នាំ២០១៩** | **ឆ្នាំ២០២០** | **ឆ្នាំ២០២១** |
| រមណីយដ្ឋាន | ១៤កន្លែង | ១៣កន្លែង | ១៥កន្លែង | ១៥កន្លែង | ១៥កន្លែង |
| សហគមន៍ | ៣កន្លែង | ៣កន្លែង | ៣កន្លែង | ៣កន្លែង | ៤កន្លែង |
| **សរុប** | **១៧កន្លែង** | **១៦កន្លែង** | **១៨កន្លែង** | **១៨កន្លែង** | **១៩កន្លែង** |

### ២- ការងារសាធារណការ និងដឹកជញ្ជូន

| ល.រ. | ផ្លូវជាតិ-ផ្លូវខេត្ត-ទីប្រជុំជន | ប្រភេទ កម្រាល | ទំហំការងារ (ម.) | | ទីតាំងភូមិសាស្ត្រ | កាល បរិច្ឆេទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ប្រវែង | ទទឹង | | | |
| ក- ការងារស្ថាបនានិងលើកកម្រិតផ្លូវថ្នល់ | | | | | | | |
| ១ | ផ្លូវខេត្តលេខ២៧៩ | ក្រួសក្រហម | ៨០០ | ៩,៧ | ឃុំតាម៉ៅ ស្រុក ព្រែកប្រសព្វ | ២០១៧ | |
| ២ | ផ្លូវទទឹងលេខ៧ ៣០១ | បេតុង | ១៥២ | ៨ | ទីរួមខេត្តក្រចេះ | ២០១៧ | ថ្នាក់ខេត្ត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ផ្លូវខេត្តលេខ២៧៩ | ក្រួសក្រហម | ៣ ៤៥០ | ៩,៧ | ឃុំតាម៉ៅ ស្រុកព្រៃកប្រសព្វ | ២០១៨ | ថ្នាក់ខេត្ត |
| ៤ | ផ្លូវក្នុងវិមាន២ធ្នូ | បេតុង | ២៣៨ | ៧,៥ | ឃុំ២ធ្នូ ស្រុកស្នួល | ២០១៨ | |
| ៥ | ផ្លូវខេត្តលេខ៣៧៧ | ក្រួសក្រហម | ២ ៣៧០ | ១០,៧ | ស្រុកចិត្របុរី និងស្រុកសំបូរ | ២០១៩ | |
| ៦ | ផ្លូវទទឹងលេខ៨-១៥ | បេតុង | ២០៨ | ៨ | សង្កាត់ក្រចេះ ក្រុងក្រចេះ | ២០១៩ | ថ្នាក់ខេត្ត |
| ៧ | ផ្លូវក្នុងទីរួមស្រុកស្នួល | កៅស៊ូ២ជាន់ | ២១០ | ៦ | ឃុំស្នួល ស្រុកស្នួល | ២០១៩ | ថ្នាក់ខេត្ត |
| ៨ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ២ ៨០០ | ១០ | ឃុំបុសលាវ ស្រុកចិត្របុរី | ២០២០ | |
| ៩ | ផ្លូវជាតិលេខ៧៦ | កៅស៊ូ២ជាន់ | ៣០០០ | ១០ | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២០ | |
| ១០ | ផ្លូវខេត្តលេខ២៧៩ | កៅស៊ូ២ជាន់ | ៣ ៨០០ | ៧ | ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ | ២០២០ | |
| ១១ | ផ្លូវខេត្តលេខ៣៧១ | កៅស៊ូ២ជាន់ | ៣ ៥០០ | ៧ | ឃុំហាន់ជ័យ ស្រុកឆ្លូង | ២០២០ | |
| ១២ | ផ្លូវសងខាងសាលាខេត្ត | បេតុង | ៣១៧ | ៦ | សង្កាត់ក្រចេះ ក្រុងក្រចេះ | ២០២០ | ថ្នាក់ខេត្ត |
| ១៣ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ១ ៨៥០ | ១០ | ឃុំបុសលាវ ស្រុកចិត្របុរី | ២០២១ | |
| ១៤ | ផ្លូវខេត្តលេខ៣៧១ | កៅស៊ូ២ជាន់ | ១ ៧០០ | ៧ | ឃុំពង្រ ស្រុកឆ្លូង | ២០២១ | |
| ១៥ | ផ្លូវខេត្តលេខ២៧៩ | កៅស៊ូ២ជាន់ | ៣ ១៥០ | ៧ | ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ | ២០២១ | |
| **ខ- ការងារស្តារបនាសំណង់សិល្បការ្យ(ស្ពាន+លូគ្រប់ប្រភេទ)** | | | | | | | |
| ១ | ស្ពានអូរក្រូច ផ្លូវខេត្តលេខ៣៧៥ | បេតុង | ៣៦ | ៨ | ឃុំកំផុងដំរីស្រុកឆ្លូង | ២០១៧ | |
| ២ | ដាឡូ ផ្លូវខេត្តលេខ៣៧៥ | បេតុង | ៨ | ៦ | ឃុំកញ្ជរ ស្រុកឆ្លូង | ២០១៧ | |
| ៣ | ស្ពានព្រែកតាអឿផ្លូវខេត្តលេខ ២៧៩ | បេតុង | ៤០ | ១០,១២ | ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ | ២០១៧ | |
| ៤ | រង្វង់មូល បំបែកផ្លូវជាតិលេខ ៧-៧៦ | ម៉ាប | | | ទីរួមស្រុកស្នួល | ២០១៧ | |
| ៥ | ស្ពានព្រែកកំបុត ផ្លូវខេត្តលេខ ២៧៩ | បេឡេត៍ | ៣៦ | ៤ | ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ | ២០១៧ | |
| ៦ | ស្ពានដៃឃ្លាំង ផ្លូវខេត្តលេខ ៣៧៦២ | បេឡេត៍ | ១២ | ៤ | ឃុំក្រញូងសែនជ័យ ស្រុកស្នួល | ២០១៧ | ថ្នាក់ខេត្ត |
| ៧ | ស្ពានកូនអក ផ្លូវខេត្តលេខ៣៧៥ | បេឡេត៍ | ៩ | ៤ | ឃុំកញ្ជរ ស្រុកឆ្លូង | ២០១៨ | |
| ៨ | ស្ពានកំពង់រាំង ផ្លូវជាតិលេខ៧៣ | បេតុង | ១៥២ | ១២ | ព្រំប្រទល់ត្បូងឃ្មុំ-ក្រចេះ | ២០១៩ | វិស្វកម្ម |
| ៩ | ស្ពានតាលា ផ្លូវខេត្តលេខ៣៧៧ | បេតុង | ២៤ | ៨,២ | ឃុំសណ្តាន់ ស្រុកសំបូរ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | លូជ្រុង+មូល ផ្លូវជាតិលេខ៧៣ | បេតុង | ១ ២២៤ | | សង្កាត់កោះកណ្ដាល ក្រុងក្រចេះ | ២០១៩ | |
| ១១ | ដាឡ ២កន្លែង និងលូទទឹងផ្លូវ ១១កន្លែង ផ្លូវខេត្តលេខ៣៧៥-៨ | បេតុង | ៨០ | | ឃុំបុសលាវ ស្រុកចិត្របុរី | ២០១៩ | |
| ១២ | លូមូល ផ្លូវជាតិលេខ៧៦ | បេតុង | ២ ២០០ | | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២០ | |
| ១៣ | លូមូល ផ្លូវខេត្តលេខ៣៧១ | បេតុង | ២ ០០០ | | ឃុំហាន់ជ័យ ស្រុកឆ្លូង | ២០២០ | |
| ១៤ | លូជ្រុង ផ្លូវក្នុងក្រុងក្រចេះ | បេតុង | ៣៧០ | | សង្កាត់ក្រចេះ ក្រុងក្រចេះ | ២០២០ | |
| ១៥ | ស្ពានព្រែកគ្រៀង ផ្លូវខេត្តលេខ ២៧៩ | បេតុង | ៦០ | ១០ | ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ | ២០២០ | វិស្វកម្ម |
| ១៦ | លូមូល ផ្លូវខេត្តលេខ៣៧១ | បេតុង | ១ ៧០០ | | ឃុំពង្រ ស្រុកឆ្លូង | ២០២១ | |
| ១៧ | លូជ្រុង+មូល ផ្លូវជាតិលេខ៧៣ | បេតុង | ៣ ២៨៦ | | សង្កាត់កោះកណ្ដាល | ២០២១ | |
| ១៨ | ស្ពានសណ្ដាយរង ផ្លូវខេត្តលេខ២៧៩ | បេតុង | ៣០ | ១០ | ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ | ២០២១ | វិស្វកម្ម |
| | **គ- ការងារជួសជុលផ្លូវថ្នល់** | | | | | | |
| ១ | ផ្លូវជាតិលេខ៧៤ | កៅស៊ូ២ជាន់ | ១ ៤២០ | ៧-១៥ | ឃុំ២ធ្នូ ស្រុកស្នួល | ២០១៧ | |
| ២ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ២ ២០០ | ៧ | ឃុំហាន់ជ័យ ស្រុកឆ្លូង | ២០១៨ | |
| ៣ | ផ្លូវជាតិលេខ៧៤ | កៅស៊ូ២ជាន់ | ២ ២០០ | ៧-១៥ | ឃុំ២ធ្នូ ស្រុកស្នួល | ២០១៩ | |
| ៤ | ផ្លូវជាតិលេខ៧៦ | កៅស៊ូ២ជាន់ | ៩ ៩៧០ | ១០ | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២០ | |
| ៥ | ផ្លូវខេត្តលេខ៣៧៧ | កៅស៊ូ២ជាន់ | ៥០០ | ១០ | សង្កាត់ក្រគរ ក្រុងក្រចេះ | ២០២០ | |
| ៦ | ផ្លូវជាតិលេខ៧៦ | កៅស៊ូ២ជាន់ | ២ ៦០០ | ១០ | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២១ | |
| ៧ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ២ ៧៧០ | ១០ | ឃុំកញ្ជរ ស្រុកឆ្លូង | ២០២១ | |

ជាសរុបរួម(ក+ខ+គ) សមិទ្ធផលការងារវិស័យសាធារណការរយៈពេល៥ឆ្នាំ(២០១៧-២០២១) សម្រេចបាន រួមមានស្ថាបនានិងលើកកម្រិតផ្លូវដោយក្រាលកៅស៊ូ២ជាន់(DBST) ប្រវែង២០,០១គ.ម. ផ្លូវបេតុងប្រវែង៩១៥ម. ផ្លូវក្រួសក្រហម ប្រវែង៦,៦២គ.ម. ស្ថាបនាសំណង់សិល្បការ្យ រួមមានស្ពានបេតុង ចំនួន ៦កន្លែង សរុបប្រវែង៣៤២ម. ស្ពានបេឡេត៍ ចំនួន៣កន្លែង ប្រវែង៤៦ម. ដាឡ៣កន្លែង+លូជ្រុង+មូល សរុបប្រវែង ១០,៨៧គ.ម. និងរង្វង់មូលទីរួមស្រុកស្នួល ចំនួន១កន្លែងជួសជុលផ្លូវដោយក្រាលកៅស៊ូ២ជាន់(DBST) ប្រវែង ២១ ៦៦០គ.ម.។

### ៣- ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

ខេត្តក្រចេះមានប្រព័ន្ធធារាសាស្ត្រចំនួន១៨១ប្រព័ន្ធ ហើយក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) មន្ទីរបានជួសជុលស្តារឡើងវិញ ប្រព័ន្ធធារាសាស្ត្របាន៦ប្រព័ន្ធ និងជួសជុលថែទាំបាន២០ប្រព័ន្ធ ហើយគិតដល់បច្ចុប្បន្ន មន្ទីរបានជួសជុលស្តារឡើងវិញ ប្រព័ន្ធធារាសាស្ត្រសរុបបានចំនួន៧៤ប្រព័ន្ធ លើ១៨១ប្រព័ន្ធ ដែលមាននៅក្នុងខេត្ត។ ការអនុវត្តការងាររបស់មន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ក្រចេះ លើផ្នែកធារាសាស្ត្រទទួលបានលទ្ធផលដូចខាងក្រោម៖

#### ក- ការស្តារនិងសាងសង់ធារាសាស្ត្រកសិកម្ម

| បរិយាយ | ដំណាំផ្សេងៗ (ហ.ត.) | កំណើនលទ្ធភាពស្រោចស្រព(ហ.ត.) | | |
|---|---|---|---|---|
| | | ស្រូវវស្សា | ស្រូវប្រាំង | សរុប |
| ២០១៧ | ៧០ | ៣៣ | ៦ | ៣៩ |
| ២០១៨ | ៤៥ | ២០ | ៥១ | ៧១ |
| ២០១៩ | ២០ | ៧០ | ៦២ | ១៥២ |
| ២០២០ | ៦០ | ៥ | ៧៦ | ១៤១ |
| ២០២១ | ៣០ | ៤១០ | ៣០ | ៤៧០ |
| **សរុប** | **២២៥** | **៥៣៨** | **២២៥** | **៩៨៨** |

#### ខ- ការជួសជុលនិងសាងសង់សំណង់សិល្បការ

| ឆ្នាំ | ទ្វារទឹក(កន្លែង) | លូទឹក (កន្លែង) | សំណង់ស្នាក់ទឹក(កន្លែង) | សំណង់បង្ហៀរ(កន្លែង) |
|---|---|---|---|---|
| ២០១៧ | ៤ | ២ | ០ | ១ |
| ២០១៨ | ១ | ២ | ០ | ២ |
| ២០១៩ | ០ | ០ | ០ | ៣ |
| ២០២០ | ១ | ៣ | ៣ | ១ |
| ២០២១ | ០ | ៣ | ២ | ២ |
| **សរុប** | **៦** | **១០** | **៥** | **៩** |

#### គ- ការជួសជុលនិងថែទាំទំនប់

| ឆ្នាំ | ចំនួនកន្លែង | ប្រវែង(ម.) | សាច់ដី(ម.$^{៣}$) | សំបកបាវ | ពលករ(នាក់) |
|---|---|---|---|---|---|
| ២០១៧ | ៣ | ២ ៨២៦ | ១៤ ១៣០ | ១០ ០០០ | |
| ២០១៨ | ៤ | ១ ៥០០ | ៥ ៤២០ | ១៥ ០០០ | |
| ២០១៩ | ៣ | ២ ០៥០ | ១៩ ២៤៨ | ១០ ០០០ | |
| ២០២០ | ២ | ១ ៥០០ | ១៤ ៤៣៤ | ១០ ០០០ | |
| ២០២១ | ៤ | ២ ៤៤០ | ៣១ ៦៧៤ | ១០ ០០០ | |
| **សរុប** | **១៦** | **១០ ៣១៦** | **៨៤ ៩០៦** | **៥៥ ០០០** | |

ឃ- ការងារជីកនិងស្តារប្រឡាយ

| ឆ្នាំ | ចំនួនខ្សែ | ប្រវែង(ម.) | សាច់ដី(ម.៣) | ពលករ(នាក់) |
|---|---|---|---|---|
| ២០១៧ | ១ | ២ ៣០០ | ១១ ៥០០ | |
| ២០១៨ | ២ | ២ ៩០០ | ១៦ ៥០០ | |
| ២០១៩ | ១ | ១ ០០០ | ៣ ៦០៨ | |
| ២០២០ | ៣ | ៩ ៨៥០ | ៥៤ ២៧៥ | |
| ២០២១ | ៦ | ៥ ២៥០ | ២៧ ១៥១ | |
| សរុប | ១៣ | ២១ ៣០០ | ១១៣ ០៣៤ | |

## ២.២១- ខេត្តព្រះវិហារ

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តព្រះវិហារ សម្រេចបាន៖**

ខេត្តព្រះវិហារស្ថិតនៅភាគឧត្តរនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចម្ងាយផ្លូវប្រវែង៣០០គ.ម. ពីរាជធានីភ្នំពេញកាត់តាមផ្លូវជាតិលេខ៦ និងលេខ៦២។ មានព្រំប្រទល់ខាងជើងជាប់ជាប់នឹងប្រទេសថៃប្រវែង១២៩គ.ម. និងជាប់ប្រទេសឡាវប្រវែង១៤០គ.ម. ដែលមានលក្ខណៈជាជួរភ្នំព្រៃនិងទន្លេ។ រីឯខាងត្បូងទល់នឹងខេត្តកំពង់ធំ ខាងកើតទល់នឹងខេត្តស្ទឹងត្រែង និងខាងលិចទល់នឹងខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ហើយមានស្ទឹងសែន១ខ្សែហូរកាត់ភូមិសាស្ត្រខេត្តព្រះវិហារប្រវែង២១៣គ.ម. ដែលមានប្រភពមកពីស្រុកជាំក្សាន្ត និងមានទន្លេរមេគង្គហូរកាត់ប្រវែង២៤គ.ម. ក្នុងភូមិសាស្ត្រស្រុកឆែប(ជាប់ព្រំដែនឡាវ)។

ខេត្តមានផ្ទៃដីសរុប១៣ ៨២១,៧៦គ.ម.២ ប្រជាពលរដ្ឋសរុបទូទាំងខេត្តចំនួន៦២ ៩៤៥គ្រួសារ ស្មើនឹងចំនួនមនុស្ស២៥២ ៧៩៥នាក់(ស្រី១២៧ ០១៥នាក់) ដង់ស៊ីតេប្រជាពលរដ្ឋប្រមាណ១៨នាក់ ក្នុង១គ.ម.២ ចែកជា៧ស្រុក ១ក្រុង ៤៩ឃុំ ២សង្កាត់ និង២៣២ភូមិ។

**១- ការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជនសម្រាប់គាំទ្រការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹកក៏ដូចជាប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត និងជាពិសេសការរៀបចំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់៖**

- រៀបចំក្រាលការ៉ូឡាខាងមុខ និងខាងក្រោយអគារបណ្ណាល័យ និងធ្វើសួនច្បាររង្វង់មូលក្នុងបរិវេណសាលាខេត្តព្រះវិហារ
- សាងសង់អគារច្រកចេញចូលតែមួយស្រុកជាំក្សាន្ត ស្រុករវៀង
- ជួសជុលសួនច្បារផ្លូវភ្លោះទំហំ៧០ម.២ និងក្រាលការូឡា ទីរួមខេត្ត ប្រវែង៨ ៩២១,៨ម.២
- សាងសង់អគារសាលាឃុំសរុបចំនួន១៧កន្លែង ក្នុងនោះ ស្រុកឆែប៧កន្លែង ស្រុករវៀង៤កន្លែង ស្រុកជ័យសែន១កន្លែង ស្រុកគូលែន
- ជួសជុលផ្លូវក្រាលក្រួសក្រហម ផ្លូវក្រាលកៅស៊ូDBST និងផ្លូវចាក់បេតុងចំនួន១០ខ្សែ ប្រវែង៨៩ ០៩៥ម. ដាក់លូភ្លោះ៣៤កន្លែង និងលូទោល១ ០២២កន្លែង
- ស្ថាបនាផ្លូវបេតុងភូមិថ្មីនិងទីរួមខេត្តព្រះវិហារ ប្រវែង៨៩១ម.
- ជួសជុលអគារច្រកចេញចូល ឃ្លាំងដាក់សម្ភារៈ អគារក្រុមប្រឹក្សាខេត្ត និងអគារទីចាត់ការផែនការ និងវិនិយោគខេត្តចំនួន២ខ្នង

- បន្តពង្រឹងសោភ័ណភាព សេវាទីក្រុង ទីប្រជុំជន តាមរយៈការគ្រប់គ្រង ការប្រមូលសំរាម ទីលានចាក់សំរាម ការរៀបចំផ្លូវថ្មើរជើង ស្ពានអាកាស ទីធ្លាចំណត ការរៀបចំសួនច្បារសាធារណៈ ការកសាង ការការពារប្រាំងទន្លេនិងទំនប់ ការរៀបចំសណ្តាប់ធ្នាប់ និងភ្លើងបំភ្លឺនៅក្នុងទីក្រុង ភ្លើងស្តុប ផ្សារធំៗ និងការរៀបចំអនុវត្តគម្រោងខេត្ត

- ស្តាបនាបង្គោលភ្លើងបំភ្លឺសាធារណៈ ទីរួមខេត្តចំនួន៣១៩ដើម
- ជួសជុលបង្គោលភ្លើងសូឡា ទីរួមខេត្តចំនួន១០០ដើម
- ជួសជុលបណ្តាញខ្សែភ្លើង ទីរួមខេត្តចំនួន៥១ដើម

**២- វិស័យធនធានទឹក និងឧតុនិយម**

+ អំពីប្រព័ន្ធធារាសាស្ត្រ៖

- ប្រព័ន្ធធារាសាស្ត្រដែលបានកសាងរួចរាល់មានចំនួន៣១អាងទឹក
- ការងារកិច្ចដំណើរការជួសជុល និងថែទាំប្រចាំមានចំនួន៧គម្រោង

+ គម្រោងអភិវឌ្ឍន៍អាងទឹករក្សា៖

គម្រោងអភិវឌ្ឍន៍អាងទឹករក្សា មានទីតាំងស្ថិតនៅតាមបណ្តោយស្ទឹងសែន ដែលទំនប់ខាងឆ្វេងស្ថិតនៅក្នុងឃុំពុទ្រា ស្រុកជ័យសែន និងទំនប់ខាងស្តាំ ស្ថិតនៅក្នុងឃុំរក្សា ស្រុករវៀង។ គម្រោងនេះចាប់ផ្តើមសាងសង់កាលថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយសម្ព័ន្ធក្រុមហ៊ុន ហ្គួងដុង បរទេសសាងសង់ ខូអិលធីឌី និង ហ្គួងដុង យូវៀន វិស្វកម្ម ខូអិលធីឌី(Guangdong Foreign Construction Co.,Ltd. & Guangdong Yuantian Engineering Co., Ltd.) រហូតមកដល់ពេលនេះ សម្រេចបានប្រមាណ៨៧%។ ក្រោយពីសាងសង់រួច ទំនប់អាងទឹករក្សា អាចស្តុកទឹកបានចំនួនប្រមាណ២៥៦,៩លានម៉ែត្រគូប និងអាចផ្គត់ផ្គង់ទឹកស្រោចស្រពសម្រាប់បង្កបង្កើនផលិតផលកសិកម្ម លើផ្ទៃដីទំហំប្រមាណ១៤៣ ៣២៣(មួយរយសែសិបបីពាន់បីរយម្ភៃបីហ.ត. នៅរដូវវស្សា និងប្រមាណ២២ ៨៧៨(ម្ភៃពីរពាន់ប្រាំបីរយចិតសិបប្រាំពីហ.ត. នៅរដូវប្រាំង)។ ទំនប់អាងទឹករក្សាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយនូវគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត(ខ្វះទឹក) និងអាចផ្គត់ផ្គង់ទឹកស្អាតតាមតំបន់មួយ ចំនួននៅផ្នែកខាងក្រោម ព្រមទាំងបម្រើដល់វិស័យទេសចរណ៍ផងដែរ។ គម្រោងអភិវឌ្ឍន៍អាងទឹករក្សានេះ ជាសមិទ្ធផលថ្មីមួយទៀតរបស់ខេត្តព្រះវិហារ ដែលកើតឡើងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គ មហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**។

**៣- ការងារផ្គត់ផ្គង់ទឹកជនបទ**

- ជីក ជួលជុលអណ្តូងស្នប់ អណ្តូងលូ និងអណ្តូងចម្រុះសាងសង់ថ្មីបានចំនួន១ ៧២១អណ្តូង
- ស្តារស្រះសហគមន៍ទំហំ៤០ម. X ៣០ម. X ៣ម. = ៥កន្លែង និងស្រះទំហំ៧០ម. X ៥០ម. X ៦ម. = ៣កន្លែង
- ផ្តល់ពាងត្រងទឹកភ្លៀងចំនួន១ ៥៣៩ពាង និងកសាងអាងត្រងទឹកភ្លៀងបានចំនួន១៦៥អាង
- តបណ្តាញប្រព័ន្ធចែកចាយទឹកស្អាតតាមទុយោនៅជនបទបានចំនួន៣៦កន្លែង
- កសាងស្ថានីយផលិតទឹកពិសាចំណុះ២០លីត្រ បានចំនួន៩កន្លែង
- ផ្តល់ធុងចម្រោះទឹកស្អាតបានចំនួន២ ៧០៤ធុង
- ប្រជាពលរដ្ឋជនបទទទួលបានសេវាទឹកស្អាត មានចំនួន២៨ ៤៨៤គ្រួសារ ស្មើនឹង៤៧%។

### ៤- វិស័យទេសចរណ៍

គោលដៅទេសចរណ៍សំខាន់ៗ ដែលភ្ញៀវទេសចរណ៍អាចមកទស្សនាកម្សាន្តមានចំនួន២៧កន្លែង ក្នុងនោះ រមណីយដ្ឋានប្រវត្តិសាស្ត្រ និងធម្មជាតិ៥កន្លែង សារៈមន្ទីរ១កន្លែង សហគមន៍១០កន្លែង វត្តគោលដៅទេសចរណ៍៣កន្លែង និងកន្លែងសក្តានុពលទេសចរណ៍៨កន្លែង។ ក្នុងឆ្នាំ២០២១ ខេត្តទទួលបានភ្ញៀវទេសចរសរុបចំនួន១៨៣ ៩៤០នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិមានចំនួន១៨២ ៨០៨នាក់ ភ្ញៀវទេសចរអន្តរជាតិមានចំនួន១ ១៣២នាក់។

ស្ថិតិអាជីវកម្មទេសចរណ៍៖

- សណ្ឋាគារមានចំនួន៤កន្លែង ស្មើនឹង១៨៤បន្ទប់ មានបុគ្គលិក៥៥នាក់(ស្រី២៦នាក់)
- ម៉ូតែលមានចំនួន៣កន្លែង ស្មើនឹង៤០បន្ទប់ មានបុគ្គលិក១៦នាក់(ស្រី១១នាក់)
- ផ្ទះភ្ញៀវមានចំនួន៣៨កន្លែង ស្មើនឹង៥០៦បន្ទប់ មានបុគ្គលិកចំនួន១១១នាក់(ស្រី៧០នាក់)
- មគ្គុទ្ទេសក៏ទេសចរសរុបចំនួន១១នាក់(ស្រី៥នាក់)
- ភោជនីយដ្ឋាន អាហារដ្ឋាន ចំនួន៦៦កន្លែង ចំនួន២ ៧៨២កៅអី មានបុគ្គលិក២០៨នាក់(ស្រី១៥៦នាក់)
- បៀរហ្គាឌិន(ពុំមាន)
- ខារ៉ាអូខេចំនួន១៩កន្លែង ស្មើនឹង៧៨បន្ទប់ មានបុគ្គលិកចំនួន៧៩នាក់(ស្រី៥៧នាក់)
- ម៉ាស្សាសុខភាពចំនួន៦កន្លែង មាន៣០គ្រែ មានបុគ្គលិក៣១នាក់(ស្រី២២នាក់)។

### ៥- វិស័យរ៉ែនិងថាមពល

ខេត្តព្រះវិហារសម្បូរទៅដោយធនធានរ៉ែគ្រប់ប្រភេទ រួមមានរ៉ែដែក រ៉ែស្ពាន់ រ៉ែមាស រ៉ែប្រេងកាត និងរ៉ែលោហៈផ្សេងៗទៀត ដែលគ្រប់ដណ្តប់ស្ទើរទូទាំងខេត្ត ហើយមកទល់ពេលនេះ មានក្រុមហ៊ុនចំនួន២២ ដែលបានកំពុងធ្វើអាជីវកម្ម និងសិក្សាស្រាវជ្រាវ ក្នុងនោះមាន៖

- ក្រុមហ៊ុនមានអាជ្ញាបណ្ណចំនួន៣ក្រុមហ៊ុន
- ក្រុមហ៊ុនមានអាជ្ញាបណ្ណសិក្សាស្រាវជ្រាវចំនួន៩ក្រុមហ៊ុន
- ក្រុមហ៊ុនមានអាជ្ញាបណ្ណអណ្តូងរ៉ែ និងការដ្ឋានវាយថ្មចំនួន១០ក្រុមហ៊ុន។

## ២.២២- ខេត្តត្បូងឃ្មុំ

### សមិទ្ធផលនិងស្នាដៃការងារសំខាន់របស់រដ្ឋបាលខេត្តត្បូងឃ្មុំ សម្រេចបាន៖

ខេត្តត្បូងឃ្មុំគឺជាខេត្តមួយដែលមានព្រំប្រទល់ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងលិចជាប់ខេត្តកំពង់ចាម ខាងជើងជាប់ខេត្តក្រចេះ ខាងត្បូងជាប់ខេត្តព្រៃវែងនិងប្រទេសវៀតណាម ហើយមានផ្ទៃដីសរុប ៥ ២៥០,៥១គ.ម.$^{២}$ មានក្រុងចំនួន១ និងស្រុក៦ គឺស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកតំបែរ ស្រុកពញាក្រែក ស្រុកមេមត់ និងស្រុកក្រូចឆ្មារ ដែលមាន ២សង្កាត់ ៦២ឃុំ និង៨៧៣ភូមិ។

ប្រជាពលរដ្ឋសរុបមានចំនួន១៩៨ ៤៩០គ្រួសារ ស្មើនឹង៨៥៧ ៨៤៤នាក់(ស្រី៤៣៧ ៥៤៦នាក់) និងអាយុ១៨ឆ្នាំឡើង មានចំនួន៥២៦ ៥៥១នាក់។

### ១- ការងារសាធារណការនិងដឹកជញ្ជូន

អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន លូទូទាំងខេត្តឱ្យបានល្អប្រសើរ និងបំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមប្រើប្រាស់និងថែទាំផ្លូវលំមានស្រាប់និងទប់ស្កាត់ការដឹកធ្ងន់លើស ចំណុះដែលនាំឱ្យខូចខាតបណ្តាញគមនាគមន៍នានា។

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ការងារសាងសង់ផ្លូវជាតិនិងផ្លូវខេត្ត | គ.ម. | - | ១,៤០ | ៥,៤០ | ២២,៣០ | ៤,២០ |
| ការងារថែទាំផ្លូវជាតិនិងផ្លូវខេត្ត | គ.ម. | ២០២,៩៣ | ២៨០,៥៨ | ២៧៥,៣៨ | ២៦៨,០២ | ២៣៧,៤៦ |
| ការងារថែទាំផ្លូវក្រួសក្រហម | គ.ម. | - | ៤៨,៧០ | ៤៨,៧០ | ៤១ | ៤១ |
| ការងារជួសជុលបន្ទាន់ផ្លូវជាតិនិងផ្លូវខេត្ត | គ.ម. | - | ១,៩៣ | ០,៦ | ២,៩៦ | ១ |
| ការងារសាងសង់ស្ពាន | ម. | - | - | - | - | - |
| ការងារថែទាំស្ពាន | ម. | ៣៥៤ | ៩៤២ | ៩៤២ | ១ ០០៤ | ៩៨៧ |
| ការងារជួសជុលបន្ទាន់ស្ពាន | ម. | - | - | - | - | - |
| ការងារសាងសង់លូគ្រប់ប្រភេទ | ម. | - | ៧៣០ | ៣.២០០ | ៧៦០ | ២ ១០០ |
| ការងារថែទាំលូ | ម. | ៧៨៨ | ១ ៥៦៧ | ១ ៥៦៧ | ១ ៧៨៦ | ១ ៨៨៣ |
| ការងារជួសជុលបន្ទាន់លូ | ម. | - | - | - | - | - |
| ការងារថែទាំប្រឡាយ | ម. | ៣៧ ០២០ | ៣២ ២៩៤ | ៣២ ៦២៤ | ៣២ ៧៨៩ | ៣០ ៦០៩ |

### ២- ការងារធនធានទឹកនិងឧតុនិយម

ជំរុញការគ្រប់គ្រងការងារឧតុនិយម ជលសាស្ត្រ និងតាមដានអាកាសធាតុប្រែប្រួលទឹកភ្លៀង

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| សាងសងប្រាំងទន្លេ | ម. | - | - | - | - | - |
| ស្តាប្រឡាយ | ម. | - | ១ ៥០០ | ២ ៥០០ | ១ ៨០០ | ២ ១០០ |
| ដាក់លូ | កន្លែង | - | ២០ | ៣៥ | ៤០ | ៥៥ |
| ថែទាំលូ | កន្លែង | - | - | - | - | - |
| ជួសជុលទំនប់ | ម. | - | ៥៥០ | ៣ ៩០០ | ២ ២០០ | ៣ ៤០០ |
| ថែទាំសំណង់បង្ហៀរ | កន្លែង | - | - | - | - | ២ |
| ថែទាំសំណង់ស្ទាក់ទឹក | កន្លែង | - | ២៥ | ២៥ | ២៥ | ២៥ |
| ថែទាំសំណង់ទ្វារទឹក | កន្លែង | - | ៣៩ | ៣៩ | ៣៩ | ៣៩ |
| ថែទាំទំនប់ | ម. | - | ៣៨ ៤៥០ | ៣៨ ៤៥០ | ៣៨ ៤៥០ | ៣៨ ៤៥០ |
| ជួសជុលទំនប់ស្ទាក់ទឹក | កន្លែង | - | ២ | - | - | - |
| សាងសង់សំណងទ្វាទឹក | កន្លែង | - | - | ៣ | ៣ | ៣ |
| ថែទាំសំណង់ទ្វារទឹក | កន្លែង | - | ៦ | - | - | - |
| ជួសជុលសំណង់ទ្វារទឹក | កន្លែង | - | - | - | ២ | - |
| ស្តារអាងទឹក | ម.៣ | - | - | - | - | - |

### ៣- ការងាររ៉ែនិងថាមពល

ពង្រឹងការគ្រប់គ្រងផលិតផលឧស្សាហកម្ម សិប្បកម្ម និងការផលិតទឹកស្អាតរដ្ឋ ឱ្យមានគុណភាព ព្រមទាំងពង្រីកបណ្តាញអគ្គិសនីដល់ជនបទ។

### ក- តារាងស្ថិតិទិន្នន័យថាមពលអគ្គិសនី

| ល.រ. | បរិយាយ | ឯកតា | ឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| ១ | ចំនួនក្រុមហ៊ុន/សហគ្រាស/សេវាករ | មូលដ្ឋាន | ០ | ០ | ១៧ | ១៧ | ១៧ |
| ២ | ចំនួនភូមិដែលបានភ្ជាប់បណ្តាញអគ្គិសនីប្រើប្រាស់ | ភូមិ | ០ | ០ | ០ | ៧៩៩ | ៨៦៣ |
| ៣ | ចំនួនខ្នងផ្ទះដែលបានភ្ជាប់បណ្តាញអគ្គិសនីប្រើប្រាស់ | ខ្នងផ្ទះ | ០ | ០ | ១០៨ ០៣២ | ១១១ ៦៥៣ | ១២១ ៤៩៦ |
| ៤ | បរិមាណថាមពលអគ្គិសនីប្រើប្រាស់សរុប | KWH | ០ | ០ | ១៥ ១០៥ ៥៣៥ | ១៥៦ ៧៩៩ ៣១២ | ២៦២ ០៧៤ ៦០៨ |

### ខ- ការងារទឹកស្អាត

| បរិយាយ | ឯកតា | ឆ្នាំ | | | | |
|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| **ក្រុមហ៊ុនអាជីវកម្មទឹកស្អាត** | មូលដ្ឋាន | - | ១១ | ១០ | ១៦ | ១៨ |
| អាជីវកម្មមានប្រកាសអនុញ្ញាត | មូលដ្ឋាន | - | ៤ | ៤ | ៧ | ៧ |
| អាជីវកម្មកំពុងស្នើសុំធ្វើអាជីវកម្ម | មូលដ្ឋាន | - | - | ៥ | ៨ | ១០ |
| អាជីវកម្មកំពុងសិក្សាសមិទ្ធិលទ្ធភាព | មូលដ្ឋាន | - | ៧ | ១ | ១ | ១ |
| អាជីវកម្មបានដាក់ស្នើសុំសិក្សាសមិទ្ធិលទ្ធភាព | មូលដ្ឋាន | - | - | - | ៤ | ៥ |

### ៤- ការងារទេសចរណ៍

ពង្រឹងវិស័យទេសចរណ៍ដើម្បីបង្កើនចំណូលសេដ្ឋកិច្ចខេត្តដោយពង្រីក និងរៀបចំតំបន់ទេសចរណ៍ធម្មជាតិនិងសហគមន៍ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិឱ្យចូលទស្សនារមណីយដ្ឋានក្នុងខេត្ត ពង្រឹងសេវាកម្ម តម្លៃនិងរៀបចំបរិស្ថានជុំវិញឱ្យបានល្អនិងរៀបចំបណ្តុះបណ្តាលអំពីមគ្គុទ្ទេសទេសចរណ៍ និងការបដិសណ្ឋារកិច្ចភ្ញៀវដល់ភ្នាក់ងារទេសចរណ៍ និងអ្នកប្រកបអាជីវកម្ម។

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| សរុបចំនួនភ្ញៀវទេសចរណ៍មកទស្សនាក្នុងខេត្តត្បូងឃ្មុំ | នាក់ | ២១៣ ៣៧១ | ១៩៥ ០៦០ | ១៦៨ ១២០ | ១០ ២៨៤ | ១៨៩ ៥៥៦ |
| ក្នុងនោះភ្ញៀវជាតិ | នាក់ | ៦៧ ៨៦៥ | ១៤៨ ៨៩០ | ១៤២ ៧៩៧ | ៥ ៥៥៩ | ១៤២ ១៣៤ |
| ភ្ញៀវអន្តរជាតិ | នាក់ | ១៤៥ ៥០៦ | ៤៦ ១៧០ | ២៥ ៣២៣ | ៤ ៧២៥ | ៤៧ ៤២២ |
| រមណីយដ្ឋានក្នុងខេត្តត្បូងឃ្មុំ | កន្លែង | ៤ | ៥ | ៥ | ៥ | ៦ |
| ក្នុងនោះគ្រប់គ្រង់ដោយរដ្ឋ | កន្លែង | ៤ | ៤ | ៤ | ៤ | ៤ |
| គ្រប់គ្រង់ដោយឯកជន | កន្លែង | ០ | ១ | ១ | ១ | ១ |
| រមណីយដ្ឋានប្រវត្តិសាស្រ្ត | កន្លែង | ២ | ២ | ២ | ២ | ២ |
| រមណីយដ្ឋានធម្មជាតិ | កន្លែង | ២ | ២ | ២ | ២ | ៣ |
| រមណីយដ្ឋាបកែច្នៃ | កន្លែង | ០ | ១ | ១ | ១ | ១ |

| បរិយាយ | ឯកតា | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|
| ផ្នែកសណ្ឋាគារ | កន្លែង | ៤ | ២ | ៦ | ៥ | ៥ |
| ផ្ទះសំណាក់ | កន្លែង | ២៤ | ២២ | ៤៥ | ៤៣ | ៥១ |
| ភោជនីយដ្ឋាន | កន្លែង | ៩ | ៣ | ៧ | ៧ | ៦ |
| អាហារដ្ឋាន | កន្លែង | ៣៣ | ១៤ | ៥៧ | ៣០ | ២១ |
| ខារ៉ាអូខេ | កន្លែង | ២១ | ១១ | ២០ | ២៤ | ២៥ |
| បៀហ្គាឌិន | កន្លែង | ២ | ១ | ០ | ០ | ០ |
| ឌីស្កូតែក | កន្លែង | ០ | ០ | ០ | ០ | ០ |
| កាស៊ីណូ | កន្លែង | ៤ | ៤ | ៣ | ៣ | ៣ |
| ម៉ាស្សា | កន្លែង | ៤ | ២ | ៣ | ៥ | ៧ |
| ផ្សាររាត្រី | កន្លែង | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

## ២.២៣- ខេត្តកំពង់ចាម

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកំពង់ចាម សម្រេចបាន៖**

ខេត្តកំពង់ចាម គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ធំ ខាងត្បូងជាប់ខេត្តកណ្តាល និងខេត្តព្រៃវែង ខាងកើតជាប់ខេត្តក្រចេះ និងត្បូងឃ្មុំ និងខាងលិចជាប់ខេត្តកំពង់ឆ្នាំង។ ខេត្តកំពង់ចាម ស្ថិតនៅប៉ែកខាងកើតនៃប្រទេសកម្ពុជា មានចម្ងាយ១២៤គ.ម. ពីរាជធានីភ្នំពេញ មានផ្លូវជាតិឆ្លងកាត់ចំនួន២ខ្សែ គឺផ្លូវជាតិលេខ៦ និងផ្លូវជាតិលេខ៧។ ស្ថានដីខេត្តកំពង់ចាម ចែកជាបីតំបន់ តំបន់ដងទន្លេ វាលទំនាប និងខ្ពង់រាប។ ខេត្តកំពង់ចាម មានសក្តានុពលចម្បងលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម ដែលមានប្រជាពលរដ្ឋប្រកបរបរកសិកម្មជាចម្បងស្មើនឹង៦៦,២% របរឧស្សាហកម្មនិងសិប្បកម្ម០,៧០% និងរបរសេវាកម្ម៣៣,១%។ ខេត្តមានផ្ទៃដីសរុប៤ ៥៤៨,០៩គ.ម.$^{២}$ ចែកជាក្រុង និងស្រុក ចំនួន១០(៩ស្រុក-១ក្រុង) ឃុំ សង្កាត់ចំនួន១០៩(១០៥ឃុំ ៤សង្កាត់) ភូមិចំនួន៩១៦ គ្រួសារមានចំនួន២៨៣ ២៥៩ ប្រជាពលរដ្ឋសរុប ១ ១០៥ ១៤៨នាក់(ស្ត្រី៥៧០ ៥៤៥នាក់)។

**១- ការកសាងហេដ្ឋារចនាសម្ព័ន្ធខេត្ត រួមមាន៖**

សមិទ្ធផលសំខាន់ៗ ជាប្រវត្តិសាស្ត្រ ដែលប្រជាពលរដ្ឋខេត្តកំពង់ចាម ទទួលបានពីរាជរដ្ឋាភិបាលកម្ពុជា រួមមាន ស្ពានកោះប៉ែន(ឆ្នាំ២០១៨) ផ្លូវបេតុង៧0B(ឆ្នាំ២០១៨) ស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រង់ ក្រូចឆ្មារ (ឆ្នាំ២០២១) ប្រព័ន្ធធារាសាស្ត្រ ព្រែកពោធិ៍(ឆ្នាំ២០២១)។ ទន្ទឹមនេះ ខេត្តបានកសាង នូវហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តបានមួយចំនួន ដូចជា៖

- ផ្លូវកៅស៊ូ DBST មានប្រវែងសរុប៤៩ ២៥១ម.
- ផ្លូវកៅស៊ូ AC មានប្រវែងសរុប៨ ៥១៤ម.
- ផ្លូវបេតុងអាមេ មានប្រវែងសរុប២៦,៥៧៩គ.ម.
- ផ្លូវក្រួសក្រហម មានប្រវែងសរុប៧៨,៨២៧គ.ម.
- លូរំដោះទឹក មានប្រវែងសរុប៨ ៥៥៣ម.
- ស្ពានដែកបេឡេត៍ មានប្រវែងសរុប២២០,៥០ម.
- ស្នាប្រឡាយទឹក មានប្រវែងសរុប៦ ៤៥០ម.
- សាងសង់ប្រាំងទន្លេ មានប្រវែងសរុប១១៥ម.។

**២- ការងារធនធានទឹក**

- បានដំឡើងស្ថានីយឧតុនិយមស្វ័យប្រវត្តិ៤កន្លែង គឺក្រុងកំពង់ចាម ស្រុកព្រៃឈរចំនួន២ ស្រុកស្ទឹងត្រង់ ស្ថានីយជលសាស្ត្រស្វ័យប្រវត្តិមាន១កន្លែង នៅក្រុងកំពង់ចាម

- ស្ថានីយបូមទឹកមាន៣កន្លែង គឺនៅស្ថានីយបូមទឹកទន្លេរ៉ែកូ ស្ថានីយបូមទឹកហ៊ុន សែនទី១៥ សំពោង និងស្ថានីយបូមទឹកក្ដីបឹង និងមានអាងស្តុកទឹកចំនួន២៦១កន្លែង

- ប្រព័ន្ធធារាសាស្ត្រ មានប្រឡាយមេ-រងសរុប១៩ ៣៦១ម. ប្រឡាយបេតុងមានប្រវែង៤៤ ០៤៥ម. និងប្រឡាយជើងក្អែកមានប្រវែង២១៥ ៨០០ម.

- ប្រព័ន្ធទឹកស្អាត មានចំនួន៦១មូលដ្ឋាន ក្នុងនោះផ្នែកសាធារណៈ១មូលដ្ឋាន និងផ្នែកឯកជន៦០មូលដ្ឋាន មានវិសាលភាពគ្របដណ្តប់នៅទូទាំងខេត្តចំនួន១០៧/១០៩ ឃុំ សង្កាត់ ស្មើនឹង៩៨,១៦% និងគ្របដណ្តប់ភូមិចំនួន៨៧០ ស្មើនឹង៩៤,៩៨%។

**៣- ការងាររ៉ែ និងថាមពល**

- ស្ថិតិថាមពលអគ្គិសនីមានចំនួន៣៨ក្រុមហ៊ុន/សេវករ បានតភ្ជាប់បណ្តាញអគ្គិសនីប្រើប្រាស់៩១៤ភូមិ ដែលមានប្រជាពលរដ្ឋប្រើប្រាស់ចំនួន១៩០ ១៤៧គ្រួសារ

- មានស្ថានីយប្រេងឥន្ធនៈចំនួន២៦០ ស្ថានីយឧស្ម័នឥន្ធនៈ៣ ស្ថានីយប្រេងនិងស្ថានីយឧស្ម័នឥន្ធនៈមាន១៨។

**៤- ការងារទេសចរណ៍**

នៅក្នុងខេត្ត មានរមណីយដ្ឋាន៦៤៩កន្លែង ហើយមានហាងគ្រប់គ្រងដោយរដ្ឋ៤កន្លែងគឺ តូបផ្សារ រាត្រី អាហារដ្ឋានមេគង្គក្រូស៊ីង អាហារដ្ឋានស្មៅទន្លេ និងភោជនីយដ្ឋានស្វាយល័។ ក្នុងរយៈពេល៥ឆ្នាំនេះ ទេសចរដែលមកទស្សនាសរុប២ ១៦២ ៦៧១នាក់ ក្នុងនោះ ទេសចរជាតិ២ ១០០ ៨៣៥នាក់ និងទេសចរបរទេស៦១ ៨៣៦នាក់។ ទន្ទឹមនេះ បានថែរក្សា គាំពារ អភិរក្សប្រាសាទបុរាណចំនួន១៦កន្លែង។

## ២.២៤- ខេត្តព្រៃវែង

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តព្រៃវែង សម្រេចបាន៖**

ខេត្តព្រៃវែង គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្ត២៥ ដែលមានព្រំប្រទល់ខាងលិចទល់នឹងខេត្តកណ្ដាល ខាងកើតទល់នឹងខេត្តស្វាយរៀងនិងខេត្តតៃនិញនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងជើងទល់នឹងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ និងខាងត្បូងទល់នឹងខេត្តឡុងអាន និងខេត្តដុងថាប់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ខេត្តព្រៃវែង ស្ថិតនៅប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា មានចម្ងាយ៩៤គ.ម. ពីរាជធានីភ្នំពេញ មានផ្លូវជាតិឆ្លងកាត់ចំនួន៣ខ្សែ គឺផ្លូវជាតិលេខ១ លេខ១១ និងលេខ៨។ ជាតំបន់វាលរាប និងវាលទំនាប ស្របតាមដងទន្លេមេគង្គ និងមានទន្លេតូចចំនួន៣ខ្សែ។ ខេត្តមានសក្តានុពលចម្បងលើវិស័យកសិកម្ម ដែលមានប្រជាពលរដ្ឋភាគច្រើន ជាកសិករ។ ផ្ទៃដីសរុប៤ ៨៨៣ម.$^{២}$ ចែកជា១៣ ក្រុង ស្រុក ខណ្ឌ១១៦ឃុំ សង្កាត់ មានភូមិ១ ១៤៩ ចំនួនគ្រួសារសរុប១៩១ ១៥២ ចំនួនប្រជាពលរដ្ឋ សរុប១ ២៥៩ ៥៦០នាក់(ស្រី៦៥០ ៥៥៤នាក់)។

**១- ការងារសាធារណការ និងកែលម្អសោភ័ណភាព**

- បានថែទាំផ្លូវជាតិក្រាលកៅស៊ូ ប្រវែង៣១១,៨៧០គ.ម. ផ្លូវក្នុងខេត្ត

- ផ្លូវខេត្តក្រាលគ្រួសក្រហមឬដីល្បាយថ្មភ្នំ ប្រវែង១១៧,៦៥០គ.ម. ផ្លូវក្នុងខេត្ត

- ផ្លូវក្នុងក្រុងព្រៃវែង ការថែទាំផ្លូវជាប្រចាំ ប្រវែង៥,៧៨០គ.ម.

- បានជួសជុលផ្លូវលេខ៣១១១ ជួសជុលបន្ទាន់ដោយក្រាលគ្រួសក្រហម ប្រវែង៣,២៥០គ.ម. ទទឹង ៧ម ត្រង់គ.ម០៧+ ៥០០ដល់គ.ម១០+៧៥០ស្ថិតនៅក្នុងឃុំឫស្សីសាញ់ ស្រុកស៊ីធរកណ្តាល

- ជួសជុលដោយក្រាលគ្រួសក្រហម ផ្លូវខេត្ត៤ខ្សែ ប្រវែង២,៤៧០គ.ម. ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ

- ជួសជុលផ្លូវលេខ៣៨៧A ដោយក្រាលកៅស៊ូ DBST ប្រវែង៥,៧៥គ.ម. ទទឹង៧ម. ចាប់ពីគ.ម. ១១+៩០០ដល់គ.ម ១៧+៦៥០ ស្ថិតនៅក្នុងកញ្ជៀច

- ផ្លូវខេត្ត ជួសជុលដោយក្រាលកៅស៊ូDBST និងប្រវែង៣០០០គ.ម. ទទឹង៧ម ចន្លោះពីគ.ម. ០០+ ០០០ដល់គ.ម. ០៣+០០០ពីឃុំកំពង់ពពិល ស្រុកពារាំង ទៅឃុំព្រែកតាសរ ស្រុកពោធិ៍រៀងខេត្ត ព្រៃវែង

- ផ្លូវក្រុងលេខ២០ ការងារស្ថាបនាលូបេតុងសរសៃដែក១,២ម. ប្រវែង៥០០ម. ស្ថិតនៅសង្កាត់កំពង់លាវ ក្នុងក្រុងព្រៃវែង សម្រេចបាន១០០%

- ផ្លូវខេត្ត3PV7 ជួសជុលដោយក្រាលកៅស៊ូDBST និងសំណង់សិល្បការ្យ ប្រវែង២,៨៥៩គ.ម. ទទឹង ៧ម. ចន្លោះពីគ.ម. ០៣+០០០ដល់គ.ម.០៥+៨៥០ពីឃុំកំពង់ពពិល ស្រុកពារាំង ទៅឃុំព្រែកតាសរ ស្រុកពោធិ៍រៀង សម្រេចបាន២៥%

- ជួសជុលក្បាលស្ពានខ្សោក ដោយចាក់បេតុងទទឹង៥ម. នៅគ.ម. ០២+៩៥០ ឃុំពពឹស ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង សម្រេចបាន១០០%

- ស្ថាបនាលូមូលផ្លូវមុខកាត់០,៦ម និង០,៨ម. និងដាក់រ៉ឺហ្គា៣៨កន្លែង ៩៣០ម. ចាប់ពីចំណុចគ.ម. ៣៤ + ៥០០នៅ ផ្សារចំណុចផ្សារស្នេហ៍ ស្ថិតនៅឃុំជាយ ស្រុកបាភ្នំ និងពីចំណុចគ.ម.០០+៥២០នៅស្រុកស្វាយអន្ទរ សម្រេចបាន១០០%

- ជួសជុលដោយក្រាលកៅស៊ូDBST ប្រវែង៣ ៣៩០ម. ចាប់ពីចំណុចគ.ម.០០+០០០ ដល់ចំណុចគ.ម. ០៤+៥០០ ស្ថិតនៅឃុំស្វាយអន្ទរ សម្រេចបាន១០០%

- ជួសជុលដោយក្រាលកៅស៊ូDBST ប្រវែង៣ ៩៣០ម. ចាប់ពីចំណុចគ.ម.២០+៦០០ដល់ចំណុចគ.ម. ២១+១០០ស្ថិតនៅឃុំឈើកាច់ និងប្រវែង៣.៧៧០មចាប់ពីចំណុចគ.ម.៣៤+០០០ដល់ចំណុចគ.ម ៣៥+៦០០ ស្ថិតនៅឃុំជាយស្រុកបាភ្នំ សម្រេចបាន១០០%

- ជួសជុលដោយក្រាលគ្រួសក្រហមប្រវែង១០ ៩០០ម. ទទឹង៧ម. ចាប់ពីចំណុចគ.ម.០០ + ៨០០ ដល់ចំណុចគ.ម. ១១ + ៧០០ចាប់ពីឃុំក្រញូង ស្រុកកំចាយមារ ទៅឃុំព្រាល ស្រុកកញ្ជៀច សម្រេចបាន១០០%

- ជួសជុលផ្លូវ៣PV7 ដោយក្រាលកៅស៊ូDBST ប្រវែង២,៨៥០គ.ម. ទទឹង៧ម. ចន្លោះគ.ម. ០៣ + ០០០ ដល់គ.ម. ០៥+៨៥០ ស្រុកពារាំង និង ស្រុកពោធិ៍រៀង លទ្ធផលសម្រេចបាន១០០%

- ផ្លូវខេត្ត ជួសជុលដោយក្រាលកៅស៊ូDBST និងប្រវែង២,៩០០គ.ម. ទទឹង៧ម. ចន្លោះពីគ.ម. ០៥+៨៥០ដល់គ.ម ០៨+៧៥០ នៅក្នុងស្រុកពារាំង និងស្រុកពោធិ៍រៀង សម្រេចបាន៧៥%

- ផ្លូវខេត្ត370Bជួសជុលដោយក្រាលកៅស៊ូDBSTប្រវែង២,៦០០គ.ម. ទទឹង៧ម. ចន្លោះពីគ.ម.១៣ +០៣០ដល់គ.ម១៥+៦៣០ពីព្រំប្រទល់ខេត្តត្បូងឃ្មុំ ដល់ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែងសម្រេចបាន៨៧%

- ជួសជុលដោយក្រាលកៅស៊ូDBST ប្រវែង៣,៤០០គ.ម. ទទឹង៦ម ចន្លោះពីគ.ម.០០+០០០ដល់គ.ម. ០៩+០០០ពីឃុំកំពង់សឹង ស្រុកព្រះស្តេច ដល់ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង សម្រេចបាន៧៥%

- ជួសជុលដោយក្រាលកៅស៊ូDBST ប្រវែង១,៨០០គ.ម. ទទឹង៧ម ចន្លោះពីគ.ម.០០+០០០ ដល់គ.ម ០១+៨០០ស្ថិតនៅភូមិបារាយណ៍កើត សង្កាត់បារាយណ៍ ខេត្តព្រៃវែង សម្រេចបាន៤៥%

- ផ្លូវខេត្តលេខ៣PV7ជួសជុលដោយក្រាលកៅស៊ូDBST ប្រវែង២,៥០០គ.ម. ទទឹង៧ម. ចន្លោះពីគ.ម. ០៨+៧៥០ ដល់គ.ម.១១+២៥០ ស្ថិតនៅឃុំកំពង់ប្រាំង ស្រុកពារាំង សម្រេចបាន៩៨%

- ផ្លូវខេត្ត៣១១Aជួសជុលដោយក្រាលកៅស៊ូDBSTនិងដាក់លូទទឹងផ្លូវ មុខកាត់១ម. ចំនួន១កន្លែង ប្រវែង១,៩៣០គ.ម. ទទឹង៧ម. ចន្លោះគ.ម.០៣+២០០ ដល់គ.ម.០៥+១៣០ ស្ថិតក្នុងឃុំជើងភ្នំ ស្រុកបាភ្នំ សម្រេចបាន៩៩%

- ផ្លូវខេត្តលេខ៣៧០Bជួសជុលដោយក្រាលកៅស៊ូDBSTប្រវែង១,៩០០គ.ម. ទទឹង៧ម. ចន្លោះពី គ.ម.១៩+០០០ ដល់គ.ម.២២+០០០ស្ថិតក្នុងស្រុកកំចាយមារ សម្រេចបាន៩៩%

- ផ្លូវខេត្តលេខ៣១១ ជួសជុលដោយក្រាលកៅស៊ូDBSTប្រវែង៣,៦០០គ.ម. ទទឹង៧ម. ចន្លោះពី គ.ម.១០+៤០០ដល់គ.ម.១៤+០០០ស្ថិតនៅក្នុងស្រុកស៊ីធរកណ្ដាល សម្រេចបាន៩៨%

- ផ្លូវខេត្តលេខ៣១១ ជួសជុលដោយក្រាលកៅស៊ូDBSTប្រវែង២,១០០គ.ម. ទទឹង៧ម. ចន្លោះពី គ.ម.០៤+៦០០ដល់គ.ម.០៧+២០០ស្ថិតនៅក្នុងស្រុកបាភ្នំ សម្រេចបាន៩៩%

- ធ្វើការថែទាំផ្លូវជាតិនិងផ្លូវខេត្ត ផ្លូវក្រាលកៅស៊ូប្រវែង២៤៣,១៣គ.ម. សម្រេចបាន៨២%

- ផ្លូវថែទាំជាប្រចាំ ក្រាលក្រួសក្រហមឬដីល្បាយថ្មភ្នំ ប្រវែង១៦៦,៨៤គ.ម. សម្រេចបាន៨៣% (ក្នុងខេត្តព្រៃវែង)

- ជួសជុលផ្លូវខេត្តលេខ3PV7 ដែលបាក់ស្រុតដោយសារចាក់និងកិនបង្ហាប់ស្រទាប់គ្រឹះ ឡើងវិញ និងជួសជុលចិញ្ចើមផ្លូវ២កន្លែងប្រវែង២៤០ម.(ទទឹង៦ម.) នៅស្រុកពារាំងខេត្តព្រៃវែង

- ជួសជុលផ្លូវខេត្តលេខ387A ដោយជួសជុលក្រាលដីល្បាយថ្ម ប្រវែង៣ ៧០០ម.(ទទឹង៧ម.) ក្នុងឃុំក្រញូង ស្រុកកំចាយមារ

- ជួសជុលផ្លូវខេត្តលេខ3PV7 ជួសជុលដោយក្រាលដីល្បាយថ្ម ប្រវែង៥ ០០០ម.(ទទឹង៧ម.) ក្នុងឃុំព្រែកតាសរ ស្រុកពោធិ៍រៀង

- ជួសជុលផ្លូវខេត្តលេខ384B ជួសជុលដោយក្រាលដីល្បាយថ្ម ប្រវែង៣ ៣០០ម.(ទទឹង៧ម.) ក្នុងឃុំទឹកថ្លា ស្រុកស្វាយអន្ទរ

- ជួសជុលផ្លូវខេត្តសម្ដេច ជា ស៊ីម ប្រវែង៧៦០ម. ជួសជុលដោយអ៊ិតកៅស៊ូACកម្រាស់0,០៣ម. (ទទឹង៥ម.) និងជួសជុលដោយក្រាលកៅស៊ូDBSTប្រវែង១ ៨៣៥ម.(ទទឹង៥ម.)នៅឃុំក្រពៅ ស្រុកកំចាយមារ

- ជួសជុលផ្លូវខេត្តលេខ387A ជួសជុលដោយក្រាលដីល្បាយថ្ម ប្រវែង៣ ៣០០ម.(ទទឹង៧ម.) នៅឃុំព្រាល ស្រុកកញ្ជ្រៀច សម្រេចបាន១០០%

- ជួសជុលផ្លូវខេត្ត311A ជួសជុលដោយក្រាលដីល្បាយថ្មប្រវែង១ ៤៩៣ម.(ទទឹង៦ម.) នៅឃុំជើងភ្នំ ស្រុកបាភ្នំ សម្រេចបាន១០០%

- ជួសជុលដោយក្រាលកៅស៊ូDBST ផ្លូវខេត្តលេខ៣PV៧ ប្រវែង៤,៥០០គ.ម. ទទឹង៧ម. ចន្លោះពី គ.ម១១+២៥០ដល់គ.ម១៥+៧៩០ស្ថិតក្នុងឃុំកំពង់ប្រាំង ស្រុកពារាំង សម្រេចបាន៩៨%

- ជួសជុលដោយក្រាលកៅស៊ូDBST និងស្ថាបនាលូមូលបណ្ដោយផ្លូវមុខកាត់ ផ្លូវខេត្តលេខ៣១១ ប្រវែង២,៩០០គ.ម. ទទឹង៧ម. និងលូប្រវែង១ ០០០ម. ចន្លោះពីគ.ម.៧+៥០០ដល់គ.ម.១០+៤០០ស្ថិតនៅក្នុងស្រុកស៊ីធរកណ្ដាល សម្រេចបាន៩៨%

- ជួសជុលដោយក្រាលកៅស៊ូDBST ផ្លូវខេត្តលេខ៣៧០B ប្រវែង៣,៣០០គ.ម. ទទឹង៧ម. ចន្លោះពី គ.ម. ១៥+៧០០ដល់គ.ម.១៩+០០០ស្ថិតក្នុងស្រុកកំចាយមារ លទ្ធផលសម្រេចបាន៩៩%

- ជួសជុលផ្លូវខេត្តលេខ៣១១ កាត់ជួសជុលដោយក្រាលកៅស៊ូDBST និងស្ថាបនាផ្លូវបេតុងសរសៃដែក ក្នុងស្រុកបាភ្នំ សម្រេចបាន៩៩%

- ជួសជុលផ្លូវខេត្តលេខ313 កាត់ជួសជុលដោយក្រាលកៅស៊ូDBST ប្រវែង៣ ៤០០ម.(ទទឹង៧ម.) នៅស្រុកកំពង់ត្របែក និងស្រុកបាភ្នំសម្រេចបាន៦៦%

- ជួសជុលផ្លូវខេត្តលេខ8 ក្រាលបេតុងកៅស៊ូ ប្រវែង៦ ២០០ម.(ទទឹង១០ម.) នៅស្រុកស្វាយអន្ទរ និងស្រុកកំចាយមារ

- ផ្លូវជាតិនិងផ្លូវខេត្ត ការងារថែទាំផ្លូវថ្នល់ជាប្រចាំ(ក្រាលកៅស៊ូ) ២៧៩,៤០០គ.ម. ផ្លូវក្នុងខេត្តព្រៃវែង

- ផ្លូវខេត្តការងារថែទាំថ្នល់ជាប្រចាំ(ផ្លូវក្រាលគ្រួសក្រហមឬដីល្បាយថ្នល់ភ្នំ) ១១៩,៦៥០គ.ម. ផ្លូវក្នុងខេត្ត

- ជួសជុលផ្លូវខេត្តលេខ3PV7 ជួសជុលដោយក្រាលកៅស៊ូDBFT ប្រវែង៤,១៥០គ.ម.(ទទឹង៧ម.) នៅស្រុកពោធិ៍រៀង

- ជួសជុលផ្លូវខេត្តលេខ៣៨៧A ជួសជុលដោយក្រាលកៅស៊ូ DBFT និងសំណង់សិល្បការ ប្រវែង ៤,២០០គ.ម.(ទទឹង៧ម.) នៅស្រុកកកញ្ច្រៀច

- ជួសជុលផ្លូវខេត្តលេខ៣១១A ជួសជុលដោយក្រាលកៅស៊ូDBFT ប្រវែង១,១៧០គ.ម.(ទទឹង៧ម.) និងស្ថាបនាលូមូលបណ្តោយផ្លូវមុខកាត់០,៨ម. ប្រវែង៩៦០ម. នៅស្រុកបាភ្នំ

- ជួសជុលផ្លូវខេត្តលេខ៣៧០B ជួសជុលដោយក្រាលកៅស៊ូDBFT ប្រវែង២,៤០០គ.ម.(ទទឹង៧ម.) ក្នុងស្រុកកំចាយមារ

- ជួសជុលផ្លូវខេត្តលេខ៨ជួសជុលដោយក្រាលកៅស៊ូAC ប្រវែង១,៣០០គ.ម.(ទទឹង១០ម.) និងស្ថាបនាលូមូលបណ្តោយមុខកាត់០,៨០ម. និងដាក់រីហ្គាចំនួន៤កន្លែង ប្រវែង១០០ម. ក្នុងស្រុកកំចាយមារ

- ជួសជុលផ្លូវខេត្ត៣១០ កាត់ជួសជុលដោយក្រាលកៅស៊ូDBFT ប្រវែង៣,០៧០គ.ម.(ទទឹង៧ម.) ស្រុកពាមជរ

- ជួសជុលផ្លូវជាតិលេខ៨ ការងារជួសជុលផ្លូវដោយអ៊ុតកៅស៊ូ(OverayAC) កម្រាស់០,០៥ម. ប្រវែង ២,១៥០គ.ម.(ទទឹង១០ម.) នៅស្រុកស្វាយអន្ទរ។

**២- ការងារទេសចរណ៍**

ក្នុងខេត្ត មានរមណីយដ្ឋានទេសចរណ៍ចំនួន៨កន្លែង រួមមាន(១) រមណីយដ្ឋាននគរភ្នំ(ប្រវត្តិសាស្ត្រ និងធម្មជាតិ) (២) រមណីយដ្ឋានបារាយណ៍អណ្តែត(ប្រវត្តិសាស្ត្រ) (៣) រមណីយដ្ឋានសត្វស្លាបទួលព័ន្ធតាឡី បឹងស្នេហ៍(ធម្មជាតិ) (៤) រមណីយដ្ឋានប្រាសាទព្រៃដើមស្រុក(ប្រវត្តិសាស្ត្រនិងធម្មជាតិ) (៥) ទីលំហែកម្សាន្តចុងប៉ម (៦) តំបន់ដីដុះ(ធម្មជាតិ) (៧) តំបន់អូរចារ(ធម្មជាតិកែច្នៃ) និង(៨) សារមន្ទីរប្រវត្តិសាស្ត្រកម្ពុជាតិ។

ក្នុងរយៈពេល៥ឆ្នាំនេះ ភ្ញៀវទេសចរណ៍ដែលបានមកទស្សនាកម្សាន្តតាមបណ្តារមណីយដ្ឋាននានាក្នុងខេត្តរួមមាន៖

- ឆ្នាំ២០១៧ ភ្ញៀវទេសចរណ៍សរុប២៦៤ ១៨៥នាក់ ក្នុងនោះ ភ្ញៀវអន្តរជាតិមាន២ ៥៦២នាក់

- ឆ្នាំ២០១៨ ភ្ញៀវទេសចរណ៍សរុប៣៦៧ ៤២២នាក់ ក្នុងនោះ អន្តរជាតិមាន៥ ៦០៨នាក់
- ឆ្នាំ២០១៩ ភ្ញៀវទេសចរណ៍៥២៧ ៩១៦នាក់ ក្នុងនោះ ភ្ញៀវទេសចរណ៍អន្តរជាតិ៣ ៦៨២នាក់
- ឆ្នាំ២០២០ ភ្ញៀវទេសចរណ១៩៦ ៩៤២នាក់ ក្នុងនោះ ភ្ញៀវទេសចរណ៍អន្តរជាតិ១ ៧៩៩នាក់

ស្ថិតិឧស្សាហកម្មទេសចរណ៍ រួមមានឆ្នាំ២០១៧ សណ្ឋាគារ៧កន្លែង ផ្ទះសំណាក់៤៥កន្លែង បឹងហ្គាឡូ១ ភោជនីយដ្ឋាន២កន្លែង អាហារដ្ឋាន៣៤កន្លែង ខារ៉ាអូខេ៤៣កន្លែង កន្លែងម៉ាស្សា២កន្លែង ហាងគុយទាវគ្រឿងក្លែម៦១កន្លែង។ ឆ្នាំ២០១៨ សណ្ឋាគារ៧កន្លែង ផ្ទះសំណាក់៥៣កន្លែង បឹងហ្គាឡូ១ ភោជនីយដ្ឋាន២កន្លែង អាហារដ្ឋាន៣៦កន្លែង ខារ៉ាអូខេ៥០កន្លែង កន្លែងម៉ាស្សា១កន្លែង ក្លិបកម្សាន្ត១កន្លែង ហាងគុយទាវគ្រឿងក្លែម ៥៩កន្លែង។ ឆ្នាំ២០១៩ សណ្ឋាគារមានចំនួន៦កន្លែង១៣៩បន្ទប់ បឹងហ្គាឡូដ៏មានចំនួន១កន្លែង២០បន្ទប់ ផ្ទះសំណាក់មានចំនួន៧១កន្លែង៦៧០បន្ទប់ ផ្ទះជួលមានចំនួន០៧កន្លែង២៨បន្ទប់ ភោជនីយដ្ឋានមានចំនួន ៣កន្លែង អាហារដ្ឋានមានចំនួន៥២កន្លែង ខារ៉ាអូខេមានចំនួន៦២កន្លែង ហាងម៉ាស្សាមានចំនួន១០កន្លែង និង ហាងគុយទាវ កាហ្វេ គ្រឿងក្លែមមានចំនួន៣៧កន្លែង។ ឆ្នាំ២០២០ សណ្ឋាគារមានចំនួន៥កន្លែង៤កន្លែង ផ្អាក ១កន្លែង មាន១០៩បន្ទប់ បឹងហ្គាឡូមានចំនួន១កន្លែង មាន២០បន្ទប់ ផ្ទះភ្ញៀវមានចំនួន៨៧កន្លែង មាន៨១៧ បន្ទប់ ផ្ទះជួលមានចំនួន១២កន្លែង មាន៥៣បន្ទប់ ភោជនីយដ្ឋានមានចំនួន៤កន្លែង អាហារដ្ឋានចំនួន៧៨កន្លែង អាហារគុយទាវ កាហ្វេ គ្រឿងក្លែម មានចំនួន៤២កន្លែង កម្លាំងពលកម្មសរុបចំនួន១ ១៧៧នាក់ ស្រី៨៨២នាក់។ ឆ្នាំ២០២១ ឆ្នាំ២០២០ សណ្ឋាគារមានចំនួន៥កន្លែង ផ្អាក១កន្លែង មាន១០៩បន្ទប់ បឹងហ្គាឡូមានចំនួន១កន្លែង មាន២០បន្ទប់ ផ្ទះភ្ញៀវមានចំនួន៨៧កន្លែង មាន៨១៧បន្ទប់ ផ្ទះជួលមានចំនួន១២កន្លែង មាន៥៣បន្ទប់ ភោជនីយដ្ឋានមានចំនួន៤កន្លែង អាហារដ្ឋានចំនួន៧៨កន្លែង អាហារគុយទាវ កាហ្វេ គ្រឿងក្លែម មានចំនួន៤២ កន្លែង កម្លាំងពលកម្មសរុប ចំនួន១ ១៧៧នាក់(ស្រី៨៨២នាក់)។

**៣- អគ្គិសនី**

ថាមពលផលិតទិញ និងលក់ ឆ្នាំ២០១៧-២០២១(គីឡូវ៉ាត់ម៉ោង)

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| ថាមពលផលិត | ៤៩ ០១៤ | ៩ ៦៩០ | ៣១០ ០១៦ | ៨ ០៨៨ | - |
| សរបថាមពលទិញ | ៩១ ៧៨៣ ៤២៤ | ១១១ ២៦៧ ១២៥ | ៩៩ ២៥៧ ៣២៦ | ១០៨ ០៩២ ៥៥២ | - |
| សរុបថាមពល ផលិត និងទិញ | ៩១ ៨៣២ ៤៣៨ | ១១១ ២៧៦ ៨១៥ | ៩៩ ៥៦៧ ៣៤២ | ១០៨ ១០០ ៦៤០ | - |
| សរុបបរិមាណ ថាមពលលក់ | ៨៨ ២៥៧ ៣១៥ | ១០៥ ៥៨៣ ៩៥៨ | ៩៣ ៥៥២ ៥៤៣ | ១០៣ ៨៣៧ ៩៩១ | - |

## ២.២៥- ខេត្តស្វាយរៀង

### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តស្វាយរៀង សម្រេចបាន៖

ខេត្តស្វាយរៀង គឺខេត្តមួយដែលស្ថិតនៅប៉ែកអាគ្នេយ៍នៃព្រះរាជាណាចក្រកម្ពុជានិងមានចម្ងាយ ប្រមាណ១២៥គ.ម. ពីរាជធានីភ្នំពេញ ដែលមានផ្លូវជាតិលេខ១ឆ្លងកាត់ប្រវែង៦៤,៨៤គ.ម. និងមានព្រំប្រទល់ ខាងលិចនិងខាងជើងទល់នឹងខេត្តព្រៃវែង ខាងកើតនិងខាងត្បូងទល់នឹងខេត្តតៃនិញនិងខេត្តឡុងអាន ប្រទេស វៀតណាម។ ខេត្តស្វាយរៀង ស្ថិតនៅតំបន់វាលរាប មានផ្ទៃដីសរុប២ ៩៦៦,៤០គ.ម. ចែកចេញជា៦ស្រុក ២ក្រុង ៦៨ឃុំ ១២សង្កាត់ និង៦៩០ភូមិ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន៦៣៤ ៦៣៦នាក់ ស្មើនឹង១៤៩ ៨៩១គ្រួសារ ក្នុងនោះស្ត្រីមាន៣២៦ ៣២៩នាក់។

**១- ការងារហេដ្ឋារចនាសម្ព័ន្ធ**

**ក- នៅក្នុងឆ្នាំ២០១៧** រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម៖

- ជួសជុលផ្លូវអ៊ុតកៅស៊ូបេទីមAC កម្រាស់៥០ម.ម. លើកំណាត់ផ្លូវក្នុងក្រុងចំនួន៥ខ្សែ ប្រវែង៣,៦៤ គ.ម. សរុបទឹកប្រាក់ចំនួន៣ ៤១៩ ៦៦៩ ០០០រៀល

- ឡើងអាណត្តិទូទាត់គ្រឿងសង្ហារិមសម្រាប់ឆ្នាំ២០១៧ ជូនសាលាខេត្ត សរុបទឹកប្រាក់ចំនួន ៤៤ ៦០០ ០០០រៀល

- ឡើងអាណត្តិទូទាត់សម្ភារៈការិយាល័យសម្រាប់ឆ្នាំ២០១៧ ជូនសាលាខេត្ត សរុបទឹកប្រាក់ចំនួន ៥៦០ ០០០ ០០០រៀល

- សាងសង់បង្គោលភ្លើងស្តុបនិងភ្លើងប្រុងប្រយ័ត្ន ក្នុងក្រុងស្វាយរៀង ចំនួន៣កន្លែង សរុបទឹកប្រាក់ ចំនួន២២៤ ៨៩២ ៧០០រៀល

- ជួសជុលផ្លូវក្រាលគ្រួសក្រហមប្រវែង៤,១៥គ.ម. នៅឃុំសម្បត្តិមានជ័យ ស្រុករមាសហែក សរុបទឹកប្រាក់ចំនួន២ ០០០ ០០០ ០០០រៀល

- សាងសង់សាលាឃុំចំនួន៤ឃុំ សង្កាត់ សរុបទឹកប្រាក់ ចំនួន១ ៤០០ ០០០ ០០០រៀល។

**ខ- នៅក្នុងឆ្នាំ២០១៨** រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម៖

- ជួសជុលការ៉ូឡាអមសងខាងផ្លូវ និងទីធ្លាសាលាខេត្តទំហំ៩ ៩០៤ម.$^2$ ដែលមានទឹកប្រាក់សរុប ១ ៥២៧ ៥៧៧ ១០០រៀល

- ជួសជុលលូទឹកស្អុយ លូមូល និងជ្រុងចំនួន៧ខ្សែ ប្រវែង៣ ២៥៥ម. និងរ៉ឺហ្គាចំនួន១០០កន្លែង នៅសង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ដែលមានទឹកប្រាក់១ ០៩៧ ៦៨៣ ៧០០រៀល

- សាងសង់សាលាឃុំចំនួន៨កន្លែង នៅឃុំបន្ទាយក្រាំង ស្រុកកំពង់រោទិ៍ ឃុំសំបួរ និងឃុំចន្ទ្រី ស្រុករមាសហែក ឃុំជ្រុងពពេល ស្រុករំដួល ឃុំព្រៃតាអី ស្រុកស្វាយទាប និងសង្កាត់ព្រៃឆ្លាក់ សង្កាត់សង្ឃរ័ និងសង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ដែលមានទឹកប្រាក់សរុបចំនួន២ ៧៩៨ ២៦០ ៦០០រៀល

- ដាក់ភ្លើងស្តុបចំនួន២កន្លែង ក្នុងក្រុងស្វាយរៀង ដែលមានទឹកប្រាក់១៧០ ០០០ ០០០រៀល

- ជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន២ខ្សែ ប្រវែង៤ ២០៧ម. នៅឃុំបាសាក់ ស្រុកស្វាយជ្រុំ និងសង្កាត់ព្រៃឆ្លាក់ ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៤ ០០០ ០០០ ០០០រៀល

- ជួសជុលផ្លូវអ៊ុតបេទីមAC ចំនួន៦ខ្សែ មានក្រឡាផ្ទៃសរុប២០ ១២២,៥ម.$^2$ នៅក្រុងស្វាយរៀង បាន ជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន៤ខ្សែ នៅក្រុងស្វាយរៀង និងក្រុងបាវិត ដែលមានទឹកប្រាក់៥ ៩៥០ ០០០ ០០០រៀល។

**គ- នៅក្នុងឆ្នាំ២០១៩** រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម៖

- កែលម្អច្រាំងទន្លេវ៉ៃគោប្រវែង២០៥ម. ទទឹង៣,២ម. ស្ថិតនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ដែលមានទឹកប្រាក់សរុប១ ៩៩៨ ០០០ ០០០រៀល

- ជួសជុលប័រឡៀចិញ្ចើមផ្លូវប្រវែង១ ១០៦ម. និងក្រាលឥដ្ឋការ៉ូឡាចំនួន៣ ៧២០ម.$^2$ ស្ថិតនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៥៩០ ៥៤០ ០០០រៀល

- ជួសជុលកោសលាបជញ្ជាំងខាងក្រោយអគារសាលាខេត្ត របងសួនកុមារ និងរបងស្នាក់ការរដ្ឋសភាខេត្តទំហំ២ ១៦៥ម.$^2$ ដែលមានទឹកប្រាក់សរុបចំនួន៦៧ ៥០០ ០០០រៀល

- ជួសជុលផ្លូវបេតុង ឆ្អឹងដែក និងចាក់សាបបេតុងឆ្អឹងដែកដែលមានផ្ទៃក្រឡាសរុប១ ៨១៦ម.$^2$ ស្ថិតនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ដែលមានទឹកប្រាក់២៣៧ ៤០០ ០០០រៀល

- ជួសជុលក្លោងទ្វារសាលាខេត្តប្រវែង១២ម. ទទឹង២,២ម. កម្ពស់៦,៨៦ម. និងជួសជុលរបងជុំវិញសាលាខេត្ត ប្រវែង៤៣២ម.២កម្ពស់៣,៤០ម. ស្ថិតនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ដែលមានទឹកប្រាក់១ ០៧៩ ០៩៨ ០០០រៀល

- ជួសជុលលូរំដោះទឹកមុខកាត់០,៤ម. ប្រវែង៣៥៨ម. និងរ៉ឺហ្គាចំនួន៣៥កន្លែង និងលូមុខកាត់០,៦ម. ប្រវែង១ ៣៩៨ម. រ៉ឺហ្គា៧២កន្លែង នៅភូមិស្រះវង់ និងភូមិកៀនសាំង សង្កាត់ស្វាយរៀង និងភូមិរាបជោ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៦១៣ ៦៥៧ ០០០រៀល

ជួសជុលផ្លូវខ្សាច់ភ្នំប្រវែង៦ ៨៥០ម. ទទឹង៥ម. ស្ថិតនៅភូមិកក់ ឃុំស្វាយរំពារ ស្រុកស្វាយទាប និងភូមិត្រពាំងថ្កូវ និងភូមិព្រៃតាយន្ត ឃុំពងទឹក ស្រុករំដួល ដែលមានទឹកប្រាក់៣ ៩៣២ ០០០ ០០០រៀល

- សាងសង់សាលាឃុំ សង្កាត់ចំនួន១០ខ្នង គឺសាលាសង្កាត់បាវិត ក្រុងបាវិត សាលាឃុំញរ សាលាឃុំព្រៃធំ និងសាលាឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ សាលាឃុំស្វាយធំ និងសាលាឃុំស្វាយអង្គ ស្រុកស្វាយជ្រំ សាលាឃុំសង្កែ និងសាលាឃុំម៉ឺនជ័យ ស្រុករំដួល សាលាឃុំគគីរសោម ស្រុកស្វាយទាប និងសាលាសង្កាត់គយត្របែក ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៣ ៥០០ ០០០ ០០០រៀល

- ជួសជុលស្ពានបាឡេចំនួន៣កន្លែង ប្រវែង៧៥ម. ទទឹង៤ម. គឺនៅឃុំគោកព្រីង ស្រុកស្វាយជ្រំ ឃុំសំបួរ ស្រុកស្វាយទាប និងសង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៤៤៤ ៦០០ ០០០រៀល

- ជួសជុលបណ្ដាញអគ្គិសនីសាធារណៈដោយប្ដូរចង្កៀងគោម កូនជ្រូក ខ្សែភ្លើង និងអំពូលភ្លើងពណ៌លម្អក្នុងក្រុងស្វាយរៀង ដែលមានទឹកប្រាក់៩៣ ៣៨៧ ០០០រៀល

- ជួសជុលអគារអង្គភាពច្រកចេញចូលតែមួយសាលាខេត្ត និងការយាល័យក្រុមប្រឹក្សាខេត្ត ដែលមានទឹកប្រាក់១៨៩ ០៤៧ ០០០រៀល

-ជួសជុលបន្ទប់សាលប្រជុំព្រៃបាសាក់និងជួសជុលបន្ទប់ទឹក ដែលមានទឹកប្រាក់៦១ ៧៦៣ ០០០រៀល

- ជួសជុលជួសផ្សារកំពង់រោទិ៍ដោយប្ដូរដំបូល ដែរណែង ទរទឹកថ្មី និងលាបថ្នាំ ដែលមានទឹកប្រាក់១៨៩ ៧០០ ០០០រៀល

- ជួសជុលកំណាត់ផ្លូវលេខ១០៥ ដោយក្រាលខ្សាច់ភ្នំនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៣៥២ ៣៥៦ ០០០រៀល

- ជួសជុលលូរំដោះទឹក ដោយដាក់រ៉ឺហ្គាតូច៣៥កន្លែង និងរ៉ឺហ្គាធំ៣៤កន្លែង ដែលមានទឹកប្រាក់១០៣ ៤៨៤ ០០០រៀល

- ជួសជុលផ្លូវលេខ១០៥ ប្រវែង១៨០ម. ទទឹង៦ម. និងដាក់លូមុខកាត់៤,៤ម. នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៤៥៥ ៨៤០ ០០០រៀល

- ជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន២ខ្សែ ប្រវែង១ ៦១០ម. ស្ថិតនៅសង្កាត់ព្រៃឆ្លាក់ ក្រុងស្វាយរៀង ដែលមានទឹកប្រាក់៩៧០ ៥០០ ០០០រៀល

- ជីកស្រះ ធ្វើស្ពានឆ្លងស្រះ និងរៀបការីឡា នៅរមណីយដ្ឋានប្រសាទព្រៃបាសាក់ ដែលមានទឹកប្រាក់៣ ៩៤២ ០០០ ០០០រៀល

- សាងសង់អគារច្រកចេញចូលតែមួយក្នុងសាលាស្រុករមាសហែក ដែលមានទឹកប្រាក់៤១៨ ៦៧៨ ៤០០រៀល

- ជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន៥ខ្សែ ប្រវែង៥ ៨២៦ម. ស្ថិតនៅសង្កាត់បាវិត ក្រុងបាវិត ដែលមានទឹកប្រាក់៧ ៩៨០ ០០០ ០០០រៀល

- ជួសជុលស្ពានបាឡេចំនួន៣កន្លែង នៅឃុំគោកព្រីង ស្រុកស្វាយជ្រំ ឃុំសំបួរ ស្រុកស្វាយទាប និង សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ប្រវែងសរុប៧៥ម. ដែលមានទឹកប្រាក់សរុបចំនួន៤៤៤ ៦០០ ០០០រៀល

- ជួសជុលស្ពានបេតុងពោធិ៍តាហោ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ប្រវែង៧២ម. ដែលមាន ទឹកប្រាក់សរុបចំនួន៥ ៤៨៥ ០០០ ០០០រៀល

**ឃ- នៅក្នុងឆ្នាំ២០២០** រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម៖

- ជួសជុលច្រាំងទន្លេដោយបុកគ្រឹះចាក់បេតុងធ្វើច្រាំងប្រវែង៥៤០ម. ស្មើនឹងទឹកប្រាក់៦ ៤៧២ ៦០០ ០០០ រៀល នៅក្រុងស្វាយរៀង

- ជួសជុលផ្លូវបេតុងឆ្អឹងដែកខាងត្បូង ខាងជើង និងខាងលិចផ្សារពោធិ៍តាហោប្រវែង១៨០ម

- ជួសជុលរបងខាងកើតពន្ធនាគារខេត្ត ប្រវែង៨៧ម. កម្ពស់២,៣០ម. ក្នុងសង្កាត់ស្វាយរៀង

- ជួសជុលថែទាំអគារ ក្នុងបរិវេណសាលាខេត្ត ស្មើនឹងទឹកប្រាក់១៧៣ ០០០ ០០០រៀល

- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែកប្រវែង៩៧០ម. ស្មើនឹងទឹកប្រាក់៥៧២ ០០០ ០០០រៀល នៅសង្កាត់ ស្វាយរៀង ក្រុងស្វាយរៀង

- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែកប្រវែង២៣២ម. ស្មើនឹងទឹកប្រាក់៣១៨ ១០០ ០០០រៀល ខាងកើត ការិយាល័យនគរបាលចរាចរណ៍ខេត្ត នៅសង្កាត់ស្វាយរៀង

- ជួសជុលលូជ្រុងរំដោះទឹកភ្លៀងស្របច្រាំងទន្លេវៃគោប្រវែង១ ០១៥ម. ស្មើនឹងទឹកប្រាក់៥៩១ ៥០០ ០០០ រៀល នៅសង្កាត់ស្វាយរៀង

- ដាក់លូមុខកាត់០,៦០ម. ប្រវែង២៣០ម. ខាងកើតរបងនគរបាលចរាចរណ៍ ចាប់ពីផ្លូវ១០៥ ទៅទល់ផ្លូវ ១០៧ ស្មើនឹងទឹកប្រាក់១១១ ០០០ ០០០រៀល នៅសង្កាត់ស្វាយរៀង

- ជួសជុលលូមុខកាត់០,៦០ម. ប្រវែង៦០០ម. ស្មើនឹងទឹកប្រាក់២៨៤ ៤០០ ០០០រៀល សងខាងផ្លូវ ១០១ ចាប់ពីផ្លូវជាតិលេខ១ ទៅលិចទល់ផ្លូវលេខ២១៩ (ខាងជើងរបងមន្ទីរអប់រំខេត្ត)

- ជួសជុលលូមុខកាត់០,៦០ម ប្រវែង៦៣២ម. ដាក់រ៉េហ្គា៣២កន្លែង ស្មើនឹងទឹកប្រាក់២៩២ ៧០០ ០០០ រៀល នៅសង្កាត់សង្ឃ័រ

- ជួសជុលលូមុខកាត់០,៦០ម. ប្រវែង៧៨ម. ដាក់រ៉េហ្គា៩កន្លែង ស្មើនឹងទឹកប្រាក់៨៤ ៣០០ ០០០រៀល

- ជួសជុលលូមុខកាត់០,៦០ម. ប្រវែង៥៩ម. ដាក់រ៉េហ្គា២កន្លែង ស្មើនឹងទឹកប្រាក់២៩ ៨០០ ០០០រៀល បណ្តោយផ្លូវលេខ២១៤

- ចាក់ដីបំពេញ និងរៀបការ៉ូឡាសួនរមណីយដ្ឋានព្រៃបាសាក់ ស្ថិតនៅឃុំបាសាក់ ស្រុកស្វាយជ្រំ ស្មើនឹងទឹកប្រាក់៣ ៦៨០ ០០០ ០០០រៀល

- ជួសជុលផ្លូវបេតុងឆ្អឹងដែក រៀបខឿន និងប្រព័ន្ធលូ ក្នុងរមណីយដ្ឋានព្រៃបាសាក់ ស្ថិតនៅឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ស្មើនឹង៣២០ ០០០ ០០០រៀល។

**២- ការងារទេសចរណ៍**

នៅទូទាំងខេត្ត មានសណ្ឋាគារចំនួន២៦កន្លែង ផ្ទះសំណាក់មានចំនួន៧១កន្លែង ភោជនីយដ្ឋាន អាហារដ្ឋាន៧៨កន្លែង ឌីស្កូតែកមានចំនួន៤កន្លែង ខារ៉ាអូខេចំនួន៣១កន្លែង និងផ្ទះជួលចំនួន៦៧កន្លែង ព្រមទាំង មានរមណីយដ្ឋានចំនួន៣កន្លែង ធម្មជាតិ២កន្លែង និងវប្បធម៌១កន្លែង។ បានផ្សព្វផ្សាយនូវវិធានសុវត្ថិភាពទេសចរណ៍

ជូនដល់ម្ចាស់មូលដ្ឋានអាជីវកម្មទេសចរណ៍ក្នុងខេត្តស្វាយរៀងសរុបចំនួន១៤៨ទីតាំង រួមមានសណ្ឋាគារ៩កន្លែង ផ្ទះភ្ញៀវ៧៣កន្លែង ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍៦៣កន្លែង និងរមណីយដ្ឋានទេសចរណ៍៣កន្លែង។ មូលដ្ឋានអាជីវកម្ម ដែលបានទទួលបាននូវឡាបិលវិធានសុវត្ថិភាពទេសចរណ៍ក្នុងខេត្តស្វាយរៀងសរុបចំនួន៥៥កន្លែង រួមមានសណ្ឋាគារ៩កន្លែង ផ្ទះភ្ញៀវ២៩កន្លែង ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍១៥កន្លែង រមណីយដ្ឋាន២កន្លែង និងបានចុះផ្សព្វផ្សាយនូវសេចក្តីណែនាំ សារាចរណែនាំ សេចក្តីជូនដំណឹង និងលិខិតបទដ្ឋានគតិយុត្តផ្សេងរបស់រដ្ឋបាលខេត្ត ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ និងរាជរដ្ឋាភិបាលកម្ពុជា ជូនដល់ម្ចាស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ដែលមាននៅក្នុងខេត្តស្វាយរៀងសរុបចំនួន៤៧លើក ស្មើនឹង២៨០ទីតាំង។

### ៣- ការបែងចែកដីក្នុងគោលដៅសម្បទានដីសង្គមកិច្ចនិងប្រទានកម្ម

**ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**

| ឆ្នាំ | ទំហំផ្ទៃដីបានបែងចែក (ហ.ត.) | ចំនួនគ្រួសារ | ចំនួនផ្ទះបាន សាងសង់ | ចំនួនបណ្ណកម្មសិទ្ធិ |
|---|---|---|---|---|
| ២០១៧ | ១ ៥០០ | - | ៣៦៧ | - |
| ២០១៨ | ២៤០,១៥ | ១៨៦ | ៥៣៧ | ៤ ៨០៤ |
| ២០១៩ | ៤ ១២៣,៨៩ | ២ ៣១៧ | ៥៣៧ | ៣ ៥៣១ |
| ២០២០ | ៦ ៨៣២,៧៧ | ៤ ២០៩ | ៥៣៣ | - |
| ៩ខែ ឆ្នាំ២០២១ | ១ ៧៦០,៥៨ | ១ ២២៦ | ៣៦ | - |
| **សរុប** | **១៤ ៤៥៧,៣៩** | **៧ ៩៣៨** | **២ ០១០** | **៨ ៣៣៥** |

គិតពីចាប់ផ្តើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានចែកដីជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ គ្រួសារយោធិននិងនគរបាលនៅតាមបណ្តោយព្រំដែន និងប្រជាពលរដ្ឋក្រីក្រស៊ីវិលសរុបចំនួន៤៨៦ ២៩៧គ្រួសារ ទំហំដី១ ៣៥៣ ៤៨២,៨៦ហ.ត. និងបានសាងសង់ផ្ទះជូនគ្រួសារកងទ័ពនិងនគរបាលជាតិនៅតាមបណ្តោយព្រំដែននិងគ្រួសារ អតីតកងកម្លាំងប្រដាប់អាវុធចំនួន៧ ៧៦៩ខ្នង។ បច្ចុប្បន្នសម្បទានិកបានចូលស្នាក់នៅចំនួន៦ ៨០៥ខ្នង ស្មើនឹង៨៧,៥៩%។

### ៤- ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យសំណង់

**១- ទិន្នន័យសំណង់**

| ឆ្នាំ | ចំនួនគម្រោង | ផ្ទៃក្រឡាសំណង់ (ម.²) | តម្លៃប៉ាន់ស្មាន (ដុល្លារអាមេរិក) | ប្រៀបធៀបទុនវិនិយោគ(%) |
|---|---|---|---|---|
| ២០១៧ | ៣ ៤១៨ | ១១ ៣៨១ ៨៨៣ | ៦ ៧៩៨ ៦៦៣ ១២៥ | +២១,៨៤% |
| ២០១៨ | ៣ ២៩០ | ១២ ៣៧៨ ១១៩ | ៥ ៧៥៥ ០៧០ ១២០ | -១៥,៣៥% |
| ២០១៩ | ៤ ៨៨៨ | ២៣ ២៥៧ ៤១៤ | ១១ ៤៣៧ ២៦៧ ១៤៦ | +៩៨,៧៣% |
| ២០២០ | ៤ ៨៤១ | ១៦ ៩៦៥ ៧៥១ | ៧ ៧៥៣ ៣៤៩ ២៨៩ | -៣២,២១% |
| ៩ខែ ឆ្នាំ២០២១ | ៣ ២៦៣ | ១០ ៧០៧ ២៧៧ | ៤ ៤១០ ៨៤២ ៣១៤ | -២៤,៨៣% |
| **សរុប** | **១៩ ៧០០** | **៧៤ ៦៩០ ៤៤៤** | **៣៦ ១៥៥ ១៩១ ៩៩៤** | |

គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០០០ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ បានចេញលិខិតអនុញ្ញាតសាងសង់នៅទូទាំងប្រទេសចំនួន៥៦ ៥៥០គម្រោង ផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន១៦៤ ៣៣៣ ០៩៦ម.² និងតម្លៃប៉ាន់ស្មានទុនវិនិយោគសរុបប្រមាណ៦៥ ២៨២ ៨៨៥ ៧២៥ដុល្លារអាមេរិក។

២- គម្រោងអគារខ្ពស់ៗចាប់ពី៥ជាន់ឡើង

| ឆ្នាំ | ៥ជាន់ទៅ៩ជាន់ | ១០ជាន់ទៅ១៩ជាន់ | ពី២០ជាន់ទៅ២៩ជាន់ | ពី៣០ជាន់ទៅ៣៩ជាន់ | ៤០ជាន់ឡើង |
|---|---|---|---|---|---|
| ២០១៧ | ៦៤ | ២៩ | ១៣ | ១០ | ៤ |
| ២០១៨ | ៧៨ | ២៧ | ១០ | ៥ | ៩ |
| ២០១៩ | ២០៨ | ១៣៥ | ៥៧ | ២៣ | ១៣ |
| ២០២០ | ៣២០ | ១១១ | ៣៩ | ១៨ | ៨ |
| ៩ខែ ឆ្នាំ ២០២១ | ១១៧ | ៤២ | ១១ | ១ | - |
| **សរុប** | **៧៨៧** | **៣៤៤** | **១៣០** | **៥៧** | **៣៤** |

គិតពីចាប់ផ្ដើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ គម្រោងអគារខ្ពស់ៗ ចាប់ពី៥ជាន់ឡើងនៅទូទាំងប្រទេសមានចំនួន២ ៣៥១អគារ(ខេត្តព្រះសីហនុមានចំនួន៦៦៤អគារ) ក្នុងនោះអគារខ្ពស់ៗ ចាប់ពី៥ជាន់ទៅ៩ជាន់ មានចំនួន១ ២៩៣អគារ អគារចាប់ពី១០ជាន់ទៅ១៩ជាន់ មានចំនួន៦៦៧អគារ អគារចាប់ពី២០ជាន់ទៅ២៩ជាន់ មានចំនួន២១៨អគារ អគារចាប់ពី៣០ជាន់ទៅ៣៩ជាន់ មានចំនួន១២៣អគារ អគារចាប់ពី៤០ជាន់ឡើង មានចំនួន៥០អគារ។

៣- ទិន្នន័យអគារស្នាក់នៅរួមនិងបុរី

| ឆ្នាំ | អគារស្នាក់នៅរួម | បុរីលំនៅឋាននិងលំនៅឋានមានលក្ខណៈបុរី |
|---|---|---|
| ២០១៧ | - | - |
| ២០១៨ | - | ៥៤ |
| ២០១៩ | ១៧៣ | ៤០ |
| ២០២០ | ១២៦ | ៧៩ |
| ៩ខែ ឆ្នាំ២០២១ | ៦៩ | ៦៣ |
| **សរុប** | **៣៦៨** | **២៣៦** |

គិតពីចាប់ផ្ដើមអនុវត្តដល់រយៈពេល៩ខែ ឆ្នាំ២០២១ (១) អគារស្នាក់នៅរួមសរុបចំនួន៣៦៨ និង (២) បុរីលំនៅឋាននិងលំនៅឋានមានលក្ខណៈបុរីសរុបចំនួន៤៥៦គម្រោង។

## មុំទី៤- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

### ១- ការធានាចីរភាពបរិស្ថាន

ក្រសួងបរិស្ថាន សម្រេចការងារបានដូចខាងក្រោម៖

- ផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹង ប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងក្របខ័ណ្ឌនៃគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ដល់រដ្ឋបាលក្រុង ស្រុកមួយចំនួន និងបានជួយអន្តរាគមន៍ដល់ក្រុងស្រុកមួយចំនួន ដែលប្រឈមនឹងកំណើនសំរាមសំណល់រឹងច្រើន តាមរយៈការផ្ដល់ឡជុតសំរាមនៅតាមទីតាំងគោលដៅសំខាន់ៗ

- ពង្រឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់តាមរយៈការអនុវត្តវិធានការច្បាប់ ចំពោះទីតាំងបង្កការបំពុលការគ្រប់គ្រង និងការសម្អាតសំណល់គ្រោះថ្នាក់ដែលបង្កដោយសំណល់យុទ្ធភណ្ឌមិនទាន់ផ្ទុះ

- ដំណើរការស្ថានីយតាមដានគុណភាពខ្យល់និងទឹក ព្រមទាំងធ្វើការតាមដានគុណភាពប្រភពទឹកសាធារណៈនៅរាជធានីភ្នំពេញនិងខេត្តគោលដៅហើយកំពុងជំរុញការបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យនិងរាយការណ៍អំពីការបញ្ចេញនិងការបំភាយសារធាតុពុលទៅក្នុងបរិស្ថាន ទឹក ដី ខ្យល់ ចំពោះទីតាំងគម្រោងដែលអាចបង្កហានិភ័យបរិស្ថានខ្ពស់។

## ២- ការរៀបចំលំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សម្រេចការងារដូចខាងក្រោម៖**

| ឆ្នាំ | ចំនួនគម្រោង | ចំនួនលំនៅឋានសាងសង់ថ្មី | ចំនួនលំនៅឋានជួសជុលពង្រឹង |
|---|---|---|---|
| ២០១៧ | - | - | - |
| ២០១៨ | ១ | ១០ | ១២ |
| ២០១៩ | ១ | ១០៤ | ៩៨ |
| ២០២០ | - | - | - |
| ៩ខែ ឆ្នាំ២០២១ | ១ | ១៥ | - |
| **សរុប** | **៣** | **១២៩** | **១១០** |

គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០១៧ ដល់រយៈពេល៩ខែ ឆ្នាំ២០២១ មានគម្រោងលំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុមានចំនួន៣គម្រោង សាងសង់លំនៅឋានថ្មីចំនួន១២៩ខ្នង និងជួសជុលពង្រឹងចំនួន១១០ខ្នង។

## ៣- ការសាងសង់ទីលានកប់សំរាម ការសាងសង់ប្រព័ន្ធលូចម្រោះទឹកកខ្វក់ និងទឹកភ្លៀង

**ក្រសួងសាធារណការនិងដឹកជញ្ជូន សហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) អនុវត្ត(គិតត្រឹម៩ខែ ឆ្នាំ២០២១) សម្រេចការងារបានដូចខាងក្រោម៖**

១- គម្រោងសាងសង់ទីលានកប់សំរាមនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ សម្រេចបាន១០០%។

២- គម្រោងអភិវឌ្ឍក្រុងរបៀងជំហាន២(សាងសង់ប្រព័ន្ធលូចម្រោះទឹកកខ្វក់ ស្ថានីយបូម ប្រព័ន្ធលូរំដោះទឹកកខ្វក់និងទឹកភ្លៀង) ក្រុងកំពត ខេត្តកំពត សម្រេចបាន៦៧% និង(សាងសង់ទីលានកប់សំរាម) ក្រុងកំពត ខេត្តកំពត សម្រេចបាន៥៩,៥០%។

៣- គម្រោងកែលម្អគ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាបជំហាន២(សាងសង់ប្រព័ន្ធលូរំដោះទឹកកខ្វក់និងស្ថានីយចម្រោះទឹកកខ្វក់) ក្រុងបាត់ដំបង ខេត្តបាត់ដំបង សម្រេចបាន៦៩%(សាងសង់ទីលានកប់សំរាម) ក្រុងបាត់ដំបង ខេត្តបាត់ដំបង សម្រេចបាន៦០%(សាងសង់ប្រព័ន្ធលូរំដោះទឹកកខ្វក់ ប្រព័ន្ធលូរំដោះទឹកភ្លៀង និងស្ថានីយចម្រោះទឹកកខ្វក់) ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ សម្រេចបាន៥២% សាងសង់ទីលានកប់សំរាម ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ សម្រេចបាន៣៩%(សាងសង់ប្រព័ន្ធលូរំដោះទឹកកខ្វក់ ប្រព័ន្ធលូរំដោះទឹកភ្លៀង និងស្ថានីយចម្រោះទឹកកខ្វក់) ក្រុងស្ទឹងសែន ខេត្តកំពង់ធំ សម្រេចបាន៦៥% និងសាងសង់ទីលានកប់សំរាម ក្រុងស្ទឹងសែន ខេត្តកំពង់ធំ សម្រេចបាន៥២,៥២%។

៤- គម្រោងផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យតាមបណ្តាខេត្ត(សាងសង់បណ្តាញលូប្រមូលទឹកកខ្វក់) ក្រុងសៀមរាប ខេត្តសៀមរាប សម្រេចបាន៨៨% និងសាងសង់បណ្តាញលូប្រមូលទឹកកខ្វក់និងស្ថានីយចម្រោះទឹកកខ្វក់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង សម្រេចបាន៣៩%។

៥- គម្រោងស្តារស្ទឹងសៀមរាបដំណាក់កាលទី២ សម្រេចបាន៣៨%។

៦- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់កំណើនប្រកបដោយបរិយាបន្នក្នុងមហាអនុតំបន់ទន្លេមេគង្គដំណាក់កាល២(អនុគម្រោងធ្វើឱ្យប្រសើរឡើងទីលានកប់សំរាម) ក្រុងកែប ខេត្តកែប សម្រេចបាន៧៧% និង(អនុគម្រោងសាងសង់ផ្លូវថ្មើរជើងប្រវែង៨៥០ម.និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងវិស័យទេសចរណ៍នៅកោះទន្សាយ) ក្រុងកែប ខេត្តកែប សម្រេចបាន៤៥%។







# ហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពានអាកាស ស្ពានអាកាសថ្មើរជើង
# និងលូទឹកស្អុយ នៅរាជធានីភ្នំពេញ
# ខែមករា ឆ្នាំ២០២២









# លំនៅឋាន និងអគារខ្ពស់ៗនៅរាជធានីភ្នំពេញ

## ខែមករា ឆ្នាំ២០២២










ពិធីសម្ពោធហេដ្ឋារចនាសម្ព័ន្ធផ្លូវ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់
និងសមិទ្ធផលនានា ក្នុងខេត្តព្រះសីហនុ
ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១

# សកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងកម្មវិធីសំខាន់ៗ ដូចតទៅ៖

## ឆ្នាំ២០១៧

១- ពិធីប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស«**ផ្នែកអក្សរសាស្ត្រ**» ជូនសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជាពីសាកលវិទ្យាល័យក្វាងស៊ីនៃសាធារណរដ្ឋប្រជាមានិតចិននៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០១៧។

២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ រវាងព្រះរាជាណាចក្រកម្ពុជា(ត្រពាំងក្រៀល ខេត្តស្ទឹងត្រែង) និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ណងណុកខៀន ខេត្តចំប៉ាសាក់) ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម**ថងលួន ស៊ីសុលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

៣- ពិធីជួបជុំលើកទី១ ជាមួយអ្នកសារព័ត៌មានកម្ពុជា នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧។

៤- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៥ ៥១០នាក់ (ស្រី២ ៨២៩នាក់) នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧។

៥- ពិធីពិសារអាហារសាមគ្គីជាមួយសមាគមខ្មែរ ចិននៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៧។

៦- ពិធីកាត់ឫសសីមាព្រះវិហារវត្តព្រែកប្រានិងឆ្លងសមិទ្ធផលនានា នៅវត្តព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧។

៧- ពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង ខេត្ត មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ នៅសាលាខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧។

៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានមិត្តភាពកម្ពុជា ចិន កោះធំ(ឆ្លងកាត់ទន្លេបាសាក់) ប្រវែង៤១៥ម. ទទឹង១៣,៥ម. ចំណាយថវិកា១៩,៣៩លានដុល្លារអាម៉េរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅស្រុកកោះធំ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧។

៩- ពិធីបើកកិច្ចប្រជុំធុរកិច្ចអន្តរជាតិកម្ពុជា ឆ្នាំ២០១៧ នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧។

១០- ពិធីបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។

១១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត ១ ៤៣១នាក់(ស្រី៦២៤នាក់)នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧។

១២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧។

១៣- ពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី៥ ឆ្នាំ២០១៧ ក្រោមប្រធានបទ«**ទីក្រុង ស្អាត ទីក្រុងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧។

១៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាថ្មី នៃវិទ្យាល័យតេជោ**ហ៊ុន សែន ចឹងក្រុក** នៅសង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧។

១៥- ពិធីបើកសន្និសីទអន្តរជាតិថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកស្តីពីការអភិវឌ្ឍកុមារតូច នៅសណ្ឋាគារអង្គរអេរា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧។

១៦- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧។

១៧- ពិធីបើកសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០១៧ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧។

១៨- ពិធីអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៩ ក្រោមប្រធានបទ«**យុវជនដើម្បីវប្បធម៌ជាតិ**» និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសលើកទី៣ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៧។

១៩- ពិធីបើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី២ កំណាត់ទី២ និងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវាត់ក្រុងខ្សែទី២ កំណាត់ទី១(មហាវិថីមិត្តភាពភ្នំពេញ-ហាណូយ) ពីផ្លូវទំនប់កប់ស្រូវមហាវិថីសហព័ន្ធរុស្ស៊ី នៅសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧។

២០- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត ៣ ១៥០នាក់(ស្រី២៦៩នាក់)នៃវិទ្យាស្ថានវ៉ាន់ដា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧។

២១- ពិធីសម្ពោធគម្រោងពង្រីករោងចក្រផលិតស្រាបៀរកម្ពុជា នៅសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧។

២២- ពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១០៦ ឆ្នាំ២០១៧ ក្រោមប្រធានបទ «**ស្ត្រីដើម្បីសុខសន្តិភាព និងវឌ្ឍនភាព**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៧។

២៣- ពិធីកាត់ឫសសីមាព្រះវិហារវត្តសិរីសាគរ(ហៅវត្តកំពង់ត្របែក) និងឆ្លងសមិទ្ធផលនានា នៅឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧។

២៤- ពិធីដង្ហែសពសម្តេចវិបុលបញ្ញា **សុខ អាន** ពីទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន មកកាន់ព្រះរាជាណាចក្រកម្ពុជា កាលពីព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧។

២៥- ពិធីគោរពវិញ្ញាណក្ខន្ធសពសម្តេចវិបុលបញ្ញា **សុខ អាន** នៅភូមិគ្រឹះក្នុងសង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧។

២៦- ពិធីបូជាសពសម្តេចវិបុលបញ្ញា **សុខ អាន** នៅមុខវត្តបុទុមវតី រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧។

២៧- ពិធីបើកកិច្ចប្រជុំតុមូលចិន លើកទី៥ ស្តីពីការចូលជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោក (WTO) នៅសណ្ឋាគារសុខាអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧។

២៨- ពិធីប្រគល់សញ្ញាបត្រជូនគ្រូឧទ្ទេសអធិការអប់រំ និស្សិតអធិការអប់រំ និស្សិតថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៣ គរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២១ និងគរុសិស្សកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ(១២+២) ជំនាន់ទី១៨ សរុប៩៨៤នាក់(ស្រី ៣៩០នាក់) នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧។

២៩- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៥-២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៦-២០១៧ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧។

៣០- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា៣ខ្នង កម្ពស់៣ជាន់ ស្មើនឹង៤៨បន្ទប់ នៅវិទ្យាល័យសម្តេចតេជោ **ហ៊ុន សែន** ក្រុងក្រចេះ ខេត្តក្រចេះ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧។

៣១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**«មហាវិថីសម្តេចតេជោ ហ៊ុន សែន»** (ឬហៅផ្លូវ៦០ម៉ែត្រ) ប្រវែង៩ ១៦០ម. តភ្ជាប់ពីផ្លូវលេខ២៧១ នៅភាគខាងជើង ទៅផ្លូវជាតិលេខ២ នៅភាគខាងត្បូង នៅសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០១៧។

៣២- ពិធីសម្ពោធមណ្ឌលកីឡាហែលទឹកនៃពហុកីឡដ្ឋានជាតិមរតកតេជោ និងបើកការដ្ឋានសាងសង់កីឡដ្ឋានធំ ចំណាយថវិកា១៥៧លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅសង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧។

៣៣- ពិធីពិសារអាហារសាមគ្គីជាមួយក្រុមកីឡាករ កីឡាការិនី នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧។

៣៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតនិរោធ ជំហានទី២ អាចផលិតទឹកស្អាតបាន១៣០ពាន់ម៉ែត្រគូបក្នុងមួយថ្ងៃ ចំណាយថវិកាប្រមាណជាង៦០លានដុល្លារអាម៉េរិក ដែលជាគម្រោងហិរញ្ញប្បទានរបស់រដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ នៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧។

៣៥- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៦ ប្រវែង៤០,៤៩គ.ម. ពីសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ទៅដល់ថ្នល់កែង ឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម ចំណាយថវិកា៧០,២៥លានដុល្លារអាម៉េរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧។

៣៦- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦-២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៧-២០១៨របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧។

៣៧- ពិធីផ្សព្វផ្សាយលើកដំបូងនូវសៀវភៅជាខេមរភាសាស្ដីពី«**ស៊ី ជីនភីង : អភិបាលកិច្ចប្រទេសចិន**» នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៧។

៣៨- ពិធីបើកការប្រកួតកីឡាវាយកូនហ្គោលពានរង្វាន់សម្ដេចតេជោ នៅទីលានវាយកូនហ្គោល ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧។

៣៩- ពិធីប្រកាសជ័យលាភីកីឡាវាយកូនហ្គោលពានរង្វាន់សម្ដេចតេជោ នៅសណ្ឋាគារអង្គរប៉ាឡេស ក្រុងសៀមរាប ខេត្តសៀមរាប កាលពីល្ងាចថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧។

៤០- ពិធីសំណេះសំណាលនិងសួរសុខទុក្ខយុទ្ធជនពិការ នៅមជ្ឈមណ្ឌល៣១៧គូលែន ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧។

៤១- ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្តលើកទី៥ ឆ្នាំ២០១៧ នៅមណីយដ្ឋានអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៧។

៤២- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត១ ៨៨៥នាក់(ស្រី៧១៩នាក់)នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧។

៤៣- ពិធីប្រគល់រង្វាន់និងគ្រឿងឥស្សរិយយសជូនកីឡាការិនី **អ៊ុក ស្រីមុំ** ដែលបានទទួលមេដាយមាសប្រភេទកីឡាប៉េតង់ពិភពលោកនៃទីក្រុងកេន ប្រទេសបែលហ្សិក នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧។

៤៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវនិងស្ពានឆ្លងកាត់ព្រំដែនកម្ពុជា វៀតណាម ជ្រៃធំ-ឡុងប៊ិញ នៃខេត្តកណ្ដាល និងខេត្តអាងយ៉ាង ចំណាយថវិកា៣៦,៥៦លានដុល្លារអាម៉េរិក ដែលជាកម្ចីសម្បទានពីសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយមានការអញ្ជើញចូលរួមពីឯកឧត្ដម **ង្វៀន សួនហ្វ៊ុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧។

៤៥- ពិធីប្រគល់វិញ្ញាបនបត្រនិងសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត១ ៥២៦នាក់(ស្រី៦៦២នាក់)នៃសាកលវិទ្យាល័យធនធានមនុស្ស នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧។

៤៦- ពិធីប្រារព្ធខួបទី១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ ២០១៧ ក្រោមប្រធានបទ "**កាកបាទក្រហមកម្ពុជា មានគ្រប់ទីកន្លែងសម្រាប់គ្រប់ៗគ្នា**" នៅទីស្នាក់ការកណ្ដាលកាកបាទក្រហមកម្ពុជា កាលពីព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៧។

៤៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសាលាខេត្ត អគាររដ្ឋបាល និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៃខេត្តត្បូងឃ្មុំ នៅក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧។

៤៨- ពិធីប្រារព្ធខួបលើកទី១០ នៃទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧។

៤៩- ពិធីបើកវេទិកាសេដ្ឋកិច្ចពិភពលោកស្ដីពីអាស៊ាន ឆ្នាំ២០១៧ ក្រោមប្រធានបទ«**យុវជន បច្ចេកវិទ្យា និងកំណើន**» នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១៧។

៥០- ពិធីបិទវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧ ក្រោមប្រធានបទ«**យុវជន បច្ចេកវិទ្យា និងកំណើន**» នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០១៧។

៥១- ពិធីគោរពវិញ្ញាណក្ខន្ធសពកងកម្លាំងមួកខៀវ៤នាក់ ដែលបានពលីជីវិត នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីរាត្រីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៧។

៥២- ពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍នៃដៃគូសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ និងសន្និសីទអន្តរជាតិ លើកទី១ ស្តីពីទេសចរណ៍ ប្រកបដោយនិរន្តរភាព និងទីក្រុងបេតិកភណ្ឌ នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧។

៥៣- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត ៩១៥នាក់(ស្រី៤២១នាក់)នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧។

៥៤- ពិធីពិសាអាហារស្រាយបួសរ៉ាម៉ាដន ជាមួយសាសនិកអ៊ិស្លាម នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧។

៥៥- ពិធីរម្លឹកខួប៤០ឆ្នាំ នៃទិវាចងចាំដំណើរឆ្ពោះទៅកាន់ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅសាលាបឋមសិក្សា **ហ៊ុន សែន អោះថ្មី** ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧។

៥៦- ពិធីពិសាអាហារស្រាយបួសរ៉ាម៉ាដន ជាមួយសាសនិកអ៊ិស្លាម នៅវិហារធំ គីឡូម៉ែត្រ លេខ៩ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។

៥៧- ពិធីបិទវគ្គប្រគល់វិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីមធ្យម ឆ្នាំ២០១៦ និងសិក្ខាកាមវគ្គគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សារាជធានីភ្នំពេញនៃក្រសួងអប់រំ យុវជន និងកីឡាសរុប៧៥១នាក់(ស្រី ៩៨នាក់) និងពិធីបើកវគ្គបណ្តុះបណ្តាលមន្ត្រីក្រមការជំនាន់ទី៧ វគ្គវិក្រឹតការកម្មសិក្សាការី មន្ត្រីជាន់ខ្ពស់ មន្ត្រីមធ្យម ឆ្នាំ២០១៧ នៅសាលាភូមិន្ទរដ្ឋបាល កាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧។

៥៨- ពិធីអបអរសាទរការដាក់តំបន់ប្រាសាទសំបូរព្រៃគុកជាសម្បត្តិបេតិកភណ្ឌពិភពលោក នៅទីក្រុងក្រាកូវ ប្រទេសប៉ូឡូញ នាថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧ នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧។

៥៩- ពិធីចុះហត្ថលេខាលើក្របខ័ណ្ឌកិច្ចព្រមព្រៀងរួម ស្តីពីការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា វៀតណាម នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧។

៦០- ពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧។

៦១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត៣ ៥៧៩ នាក់(ស្រី១ ៦៦៥នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧។

៦២- ពិធីសំណេះសំណាលជាមួយគណៈប្រតិភូ គ្រូបង្វឹក កីឡាករ និងកីឡាការិនី២៧៤នាក់ មុនចេញទៅប្រកួតកីឡាស៊ីហ្គេម លើកទី២៩ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៧។

៦៣- ពិធីប្រកាសចូលកាន់តំណែងប្រធានរាជបណ្ឌិត្យសភាកម្ពុជា ការប្រកាសគោរមងារ បណ្ឌិតសភាចារ្យ៤នាក់ និងសមាសភាពថ្នាក់ដឹកនាំក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា៣នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧។

៦៤- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត៣ ៥០២នាក់ (ស្រី១ ៤៥២នាក់)នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧។

៦៥- ពិធីបំពាក់មេដាយ និងជូនរង្វាន់ដល់កីឡាករជ័យលាភីក្នុងការប្រកួតកីឡាប៉ារ៉ាឡាំពិកយុវជនជនពិការរជូវក្តៅ២នាក់ នៅសាធារណរដ្ឋកូរ៉េ និងពិធីសំណេះសំណាលជាមួយគណៈប្រតិភូកីឡា ប៉ារ៉ាឡាំពិកកម្ពុជាទៅចូលរួមប្រកួតកីឡាជនពិការអាស៊ាន លើកទី៩ នៅប្រទេសម៉ាឡេស៊ី១០១នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។

៦៦- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧។

៦៧- វេទិកាជាតិលើកទី២ ស្តីពី«**ការការពារនិងអភិរក្សធនធានធម្មជាតិ**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧។

៦៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ និងកម្មការិនី ជាង១០ ០០០នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស រាជធានីភ្នំពេញ សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧។

៦៩- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០ពាន់នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៧។

៧០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ និងកម្មការិនី ជាង១០ ០០០នាក់ នៅសួនឧស្សាហកម្មវឌ្ឍនៈ២ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧។

៧១- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧។

៧២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការវិហារអ៊ិស្លាមដើមៀក នៅសង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧។

៧៣- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ និងកម្មការិនី ជិត១០ ០០០នាក់ នៅតំបន់សួនឧស្សាហកម្មកាណាឌីយ៉ា សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧។

៧៤- ពិធីសម្ពោធសួនមិត្តភាពកម្ពុជា ថៃ ចាប់ពីរង្វង់មូលវត្តភ្នំ រហូតដល់មហាវិថីព្រះមុនីវង្ស ក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ កាលពីរសៀលថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៧។

៧៥- ពិធីចូលរួមទស្សនារឿងមហាវេស្សន្តរជាតក នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៧។

៧៦- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧។

៧៧- ពិធីប្រគល់សញ្ញាបត្រថ្នាក់វេជ្ជបណ្ឌិតឯកទេសទន្តបណ្ឌិត ឱសថការី គិលានុបដ្ឋាក ឆ្មប មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងព្យាបាលដោយចលនា ដល់និស្សិត៣ ៩៨៦នាក់(ស្រី២ ៦១១នាក់)នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧។

៧៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ និងកម្មការិនី ជាង១០ ០០០នាក់ នៅសួនឧស្សាហកម្មវឌ្ឍនៈ១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧។

៧៩- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការវារីអគ្គិសនីសេសានក្រោម២ មានអានុភាព៤០០មេហ្គាវ៉ាត់ នៅឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧។

៨០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ និងកម្មការិនី ជាង១០ ០០០នាក់ នៅតំបន់ចាក់អង្រែលើ(ផ្លូវ៦០ម.) ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧។

៨១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត២ ៨៣៨នាក់(ស្រី១ ៥៨៧នាក់) នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រចេនឡា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧។

៨២- ពិធីសំណេះសំណាលបំពាក់គ្រឿងឥស្សរិយយសនិងផ្តល់នូវការលើកទឹកចិត្តដល់ព្រឹទ្ធាចារ្យកោសល្យវោហារ **គង់ ណៃ** ដែលបានទទួលពានរង្វាន់សិល្បៈវប្បធម៌ ក្រុងហ្វុគុអូកា ប្រទេសជប៉ុន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧។

៨៣- ពិធីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **អ៊ុំ ម៉ាន្ធារិន** សមាជិកព្រឹទ្ធសភា នៅវត្តបុទុមវតី សង្កាត់ចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧។

៨៤- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែតុលា ឆ្នាំ២០១៧។

៨៥- ពិធីសម្ពោធសណ្ឋាគារកម្រិតផ្កាយ៥ សុខាសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប មានសមាសភាពចូលរួមជាង៣ ០០០នាក់ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧។

៨៦- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅតំបន់កំបូលផ្លូវជាតិលេខ៤ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៧។

៨៧- ពិធីអបអរទិវាគ្រូបង្រៀន ៥តុលា ឆ្នាំ២០១៧ ក្រោមប្រធានបទ«**គ្រូបង្រៀនជាវិស្វករ ព្រលឹងនៃយុវជនជំនាន់ក្រោយ**» នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧។

៨៨- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៧។

៨៩- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត៥ ៨០៨នាក់(ស្រី២ ១៣៤នាក់)នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៧។

៩០- ពិធីផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧។

៩១- ពិធីសំណេះសំណាលជាមួយប្រតិភូកម្មវិធីនាវាយុវជនកម្ពុជាអាស៊ីអាគ្នេយ៍-ជប៉ុន២៩នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧។

៩២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅតំបន់ផ្លូវវែងស្រេង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧។

៩៣- ពិធីសំណេះសំណាលនិងផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់សិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៧ ទទួលបាននិទ្ទេសA មាន៤២៤នាក់(ស្រី២០១នាក់) នាយកសាលា លោកគ្រូ អ្នកគ្រូ ដែលមានសិស្សជាប់និទ្ទេសA នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៧។

៩៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅតំបន់កំបូល ផ្លូវជាតិលេខ៤ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧។

៩៥- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក និងមេក្រុមជំនួយការ មកពីរោងចក្រផ្សេងៗគ្នានៃខេត្តកណ្តាលជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៧។

៩៦- ពិធីបើកការដ្ឋានស្ថាបនាស្ពានបេតុងអាមេ ខ្សែកាប ឆ្លងកាត់ទន្លេសាប ប្រវែង៩២២ម. ទទឹង ២០,៥ម. តភ្ជាប់ពីទីក្រុងរណបជ្រោយចង្វា មកផ្លូវជាតិលេខ៥ ត្រង់ចំណុចប្រសព្វផ្លូវលេខ៣៦ សង្កាត់ ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧។

៩៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅតំបន់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧។

៩៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅតំបន់ចំការដូង ក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៧។

៩៩- ពិធីសំណេះសំណាលជាមួយប្រតិភូយុវជននៃកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុន លើកទី៤៤ ចំនួន៣៧០នាក់ មកពី១០ប្រទេស នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧។

១០០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង២០ ០០០នាក់ នៅតំបន់ឧស្សាហកម្មសេវិនអិនជី(7NG) ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។

១០១- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៧។

១០២- ពិធីសំណេះសំណាលសាកសួរសុខទុក្ខ និងពិនិត្យមើលចង្វាក់ផលិតកម្មផលិតផលសម្លៀកបំពាក់ ដែលកំពុងដំណើរការផលិតនៅរោងចក្រ **ជិន សុវណ្ណ ហ្វេសសិន ខេមបូឌា លីមីតធីត** (Gin Sovan Fashion Cambodia Limited) នៅផ្លូវសម្ដេច **ជា ស៊ីម** ភូមិព្រៃស សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧។

១០៣- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅមជ្ឈមណ្ឌលពាណិជ្ជកម្មបៃតង តំបន់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។

១០៤- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់នៃរាជធានីភ្នំពេញនិងខេត្តកណ្ដាល នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៧។

១០៥- ពិធីក្រុងពាលីនិងសូត្រមន្តបួងសួងចម្រើនសេចក្ដីសុខ ដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីរសៀលថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៧។

១០៦- ពិធីរាប់បាត្រព្រះសង្ឃ៥ ០០០អង្គ បួងសួងចម្រើនសេចក្ដីសុខ ដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៧។

១០៧- ពិធីចុះហត្ថលេខាលើឯកសារ១១ ជាមួយលោកជំទាវ **សេក ហាស៊ីណា** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧។

១០៨- ពិធីបិទមហាសន្និបាតវិសាមញ្ញកាយវិទ្ធជាតិកម្ពុជា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៧។

១០៩- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅតំបន់អូរឡឹម ផ្លូវជាតិលេខ៤ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧។

១១០- ពិធីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **អ៊ឹម សិទ្ធី** សមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា នៅភូមិគ្រឹះក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៧។

១១១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធ អគារហ្វឹកហ្វឺនជំនាញចារកម្ម និងបើកការដ្ឋានសាងសង់សាលាហ្វឹកហ្វឺនចារកម្ម នៅតំបន់ទំនប់កប់ស្រូវ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧។

១១២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ជាង១០ ០០០នាក់ នៅតំបន់ទំនប់កប់ស្រូវ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧។

១១៣- ពិធីប្រគល់ប្រាក់រង្វាន់របស់រាជរដ្ឋាភិបាលជូនកីឡាករ កីឡាការិនី ជ័យលាភីមេដាយមាសក្នុងការប្រកួតស៊ីហ្គេមលើកទី២៩ និងការប្រកួតជើងឯកគ្រប់កម្រិតជាលក្ខណៈអន្តរជាតិ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧។

១១៤- ពិធីសម្ពោធពិព័រណ៍ផលិតផលនាំចេញ នាំចូល និងខេត្តមួយ ផលិតផលមួយកម្ពុជា លើកទី១២ ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀល ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧។

១១៥- ពិធីបើកការប្រកួតកីឡាវាយកូនហ្គោលពានរង្វាន់«**សម្តេចតេជោ ហ៊ុន សែន**» លើកទី២ នៅទីលានវាយកូនហ្គោលហ្គ្រេនភ្នំពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧។

១១៦- ពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីរោងចក្រផ្សេងៗគ្នាជាង៤ ០០០នាក់នៃខេត្តកំពង់ស្ពឺ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧។

១១៧- ពិធីបិទការប្រកួតកីឡាវាយកូនហ្គោលពានរង្វាន់«**សម្តេចតេជោ ហ៊ុន សែន**» លើកទី២ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧។

១១៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនីជាង១០ ០០០នាក់ នៅតំបន់ទួលពង្រ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧។

១១៩- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ **ប៊ុនរ៉ានី ហ៊ុនសែន ចរិយាវង្ស** នៅសង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប កាលពីព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧។

១២០- ពិធីបើកបុណ្យសមុទ្រឆ្នាំ២០១៧ លើកទី៦«**ឆ្នេរសមុទ្របៃតង : អនាគតគឺបច្ចុប្បន្ន**» ក្រោមពាក្យស្លោក«**និរន្តរភាពទេសចរណ៍សម្រាប់ការអភិវឌ្ឍ**» នៅក្រុងកែប ខេត្តកែប កាលពីរសៀលថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧។

១២១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនីជាង១០ ០០០នាក់ នៅតំបន់វត្តអង្គគ្រគៀត ផ្លូវជាតិលេខ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧។

**ទូលព្រះបង្គំជាខ្ញុំ៖**

- បានទទួលពានរង្វាន់«**ប្រធានគណៈកម្មាធិការអូឡាំពិកអន្តរជាតិ/IOC President's Trophy**» ពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧។

- ត្រូវបានជ្រើសតាំងជាឯកអគ្គរាជទូតសុច្ឆន្ទៈទេសចរណ៍អន្តរជាតិ និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងជ័យលាភីភ្នំពេញជា«**រាជធានីនៃវប្បធម៌ និងទេសចរណ៍ពិភពលោកសម្រាប់ឆ្នាំ២០១៧-២០១៨**» របស់ក្រុមប្រឹក្សាទេសចរណ៍និងពាណិជ្ជកម្មអឺរ៉ុប នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៧។

**ក្រៅពីនេះ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់ទូលព្រះបង្គំជាខ្ញុំ៖**

ក- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីសំណេះសំណាលសួរសុខទុក្ខសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧។

២- ពិធីកាត់ឫសសីមាព្រះវិហារវត្តចន្ទ្ររង្សីសាមគ្គី នៅឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧។

៣- ពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ៥១ ប្រវែង៣៧,៩៥គ.ម. ពីឧដុង្គ (ចំណុចប្រសព្វ) ផ្លូវជាតិលេខ៥១ ដល់ថ្នល់ទទឹង(ចំណុចប្រសព្វ) ផ្លូវជាតិលេខ៤ ចំណាយថវិកា៤០,៨៨លានដុល្លារអាម៉េរិក ដែលជា

កម្ចីសម្បទានពីសាធារណរដ្ឋប្រជាមានិតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧។

៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធខ្សែកាបអុបទិក ក្រោមបាតសមុទ្រ ម៉ាឡេស៊ី កម្ពុជា ថៃ ប្រវែង១ ៣០០គ.ម. ចំណាយទុនវិនិយោគប្រមាណ១០០លានដុល្លារអាមេរិក នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧។

៥- ពិធីប្រកាសផ្សព្វផ្សាយ**«ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦»** នៅសាលប្រជុំក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧។

៦- ពិធីកាត់ឫសសីមាព្រះវិហារវត្តជ្រោយមានជ័យ នៅឃុំព្រែកតាសរ ស្រុកពោធិ៍រៀង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧។

៧- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ នៅសាលប្រជុំក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧។

៨- ពិធីសម្ពោធសាលាធម្មសភានិងសមិទ្ធផលនានានៅវត្តតេនសិលា និងបើកការដ្ឋានសាងសង់ផ្លូវ នៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧។

៩- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពាននិងផ្លូវ១ខ្សែ នៅឃុំល្វេ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧។

១០- ពិធីកាត់ឫសសីមាព្រះវិហារវត្តសុវណ្ណសាមគ្គី នៅឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧។

១១- ពិធីទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០១៧ នៅអាងទឹកពហុបំណង ឬអាងទឹកសេកសក ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៧។

១២- ពិធីបិទការប្រកួតពានរង្វាន់ជើងឯកកីឡាប៉េតង់កម្ពុជា នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧។

១៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសណ្ឋាគារហ្គាឌិនស៊ីធី សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

ខ- សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីទទួលដំណើរនិវត្តន៍នៃកងកម្លាំងវិស្វកម្មលេខ៩៣៦ ចំនួន១៨៤នាក់ និងកងពេទ្យកម្រិត២ លេខ៩០៨ ចំនួន៧៩នាក់ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋលីបង់ និងសាធារណរដ្ឋស៊ូដង់ខាងត្បូង នៅមូលដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានី ភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ២០១៧។

២- ពិធីបូកសរុបលទ្ធផលការងារសាងសង់វិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា រយៈពេល១ឆ្នាំ**«២៥ កុម្ភៈ ២០១៦ - ២៥ កុម្ភៈ ២០១៧»** នៅតំបន់ អភិវឌ្ឍន៍ឧកញ៉ា លី យ៉ុងផាត់ នៅសង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧។

៣- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរណ៍ស៊ីវិលរបស់រដ្ឋលេខាធិការ-ដ្ឋានអាកាសចរណ៍ស៊ីវិល ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋកូរ៉េ នៅសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧។

៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារមណ្ឌលរដ្ឋបាលមន្ទីរខេត្តសៀមរាប នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៧។

៥- ពិធីផ្ទេរ ប្រគល់ជំនួយសម្ភារៈបច្ចេកទេសបោសសម្អាតមីន ដំណាក់កាលទី៧ និងសម្ពោធសារមន្ទីរសន្តិភាពសកម្មភាពកំចាត់មីនស៊ីម៉ាក់ នៅឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៧។

៦- ពិធីអបអរសាទរទិវាជនពិការជាតិលើកទី១៩ និងអន្តរជាតិលើកទី៣៥ ក្រោមប្រធានបទ«**ធ្វើឱ្យមានភាពរឹងមាំស្របនឹងសង្គមមួយមានសន្តិភាពសម្រាប់ទាំងអស់គ្នា**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧។

គ- ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីសំណេះសំណាលជាមួយកម្មករ និយោជិត នៃកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ ដើម្បីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា លើកទី១៣១ នៅកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧។

២- ពិធីជប់លៀងជូនគណៈប្រតិភូវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧ ក្រោមប្រធានបទ«**យុវជន បច្ចេកវិទ្យា និងកំណើន**» នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីល្ងាចថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០១៧។

៣- ពិធីសំណេះសំណាលនិងផ្តល់ប្រាក់រង្វាន់ជ័យលាភីជូនកីឡាការិនីដែលទទួលបានមេដាយប្រាក់ ១គ្រឿង គ្រូបង្វឹក និងគ្រូជំនួយ ដែលបានចូលរួមហ្វឹកហាត់ និងត្រឡប់មកពីការប្រកួតកីឡាជើងឯក ពិភពលោក រដូវរងាប៉ារ៉ាឡាំពិក ក្នុងខែមករា ឆ្នាំ២០១៧ នៅសាធារណរដ្ឋកូរ៉េ នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧។

៤- ពិធីសម្ពោធ ពិព័រណ៍ពាណិជ្ជកម្ម ផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ និងពិព័រណ៍ពាណិជ្ជកម្ម ផលិតផលនាំចេញ នាំចូល និងខេត្ត១ ផលិតផល១ កម្ពុជាលើកទី២ នៅមជ្ឈមណ្ឌល វិមានសុភមង្គល សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧។

៥- កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីប្រៃសណីយ៍និងព័ត៌មានវិទ្យាអាស៊ាន លើកទី១៧ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសណ្ឋាគារអេប្សារាប៉ាលេស ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។

៦- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងបរិស្ថាន នៅសាលប្រជុំ**ម៉ុក ម៉ារ៉េត** ទីស្តីការក្រសួងបរិស្ថាន កាលពីរសៀលថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧។

៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធស្ថានីយអ្នកដំណើរក្នុងស្រុកថ្មី និងកន្លែងសម្រាប់ទទួលការមកដល់នៃអ្នកដំណើរអន្តរជាតិ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧។

៨- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៦ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧។

៩- ពិធីសម្ពោធអគារសិក្សានិងសមិទ្ធផលនានា នៅវិទ្យាល័យសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** ពោធិ៍អណ្តែតដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧។

ឃ- លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបការងារវប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពី ព្រឹកថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧។

២- ពិធីសម្ពោធសាលាមធ្យមសិក្សា NEESON CRIPS នៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧។

៣- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឧស្សាហកម្មនិងសិប្បកម្ម ឆ្នាំ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម នៅទីស្តីការក្រសួងឧស្សាហកម្មនិងសិប្បកម្ម កាលពីព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧។

៤- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានុការីមទូទាំងប្រទេស ឆ្នាំ២០១៧ នៅបរិវេណវិហារអ៊ិស្លាម ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីរសៀលថ្ងៃទី២ ខែមេសា ឆ្នាំ២០១៧។

៥- ពិធីបញ្ចុះបឋមសិលាកសាងចូឡាមណីចេតិយ សម្រាប់តម្កល់ព្រះសារីរិកធាតុ នៅមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា នៅឧទ្យានជាតិគិរីរម្យ ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧។

៦- មិទ្ទីញអបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧។

៧- ពិធីសំណេះសំណាលជាមួយអាចារ្យ អាចារិនី មកពីទូទាំងប្រទេស នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧។

៨- ទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៧ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧។

៩- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តព្រះពុទ្ធមណ្ឌលគិរី នៅឃុំជ្រៃសែន សង្កាត់មនោរម្យ ក្រុងមនោរម្យ ខេត្តមណ្ឌលគិរី កាលពីព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧។

ង- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបើកជាផ្លូវការបុណ្យទន្លេ លើកទី៣ ឆ្នាំ២០១៧ នៅក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីរសៀលថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។

២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧។

៣- សិក្ខាសាលា ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧។

៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា កូរ៉េ នៅសង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០១៧។

៥- ពិធីលៀងសាយភោជន៍ជូនគណៈប្រតិភូ ដែលអញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកទី២ របស់រដ្ឋមន្ត្រីកសិកម្មមហាអនុតំបន់មេគង្គ នៅសណ្ឋាគារអេប្សូរ៉ាផាឡេស រីសត ខនហ្វរិន សិនធី ក្រុងសៀមរាប ខេត្តសៀមរាប កាលពីរាត្រីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៧។

៦- ពិធីបើកកិច្ចប្រជុំលើកទី២ របស់រដ្ឋមន្ត្រីកសិកម្មមហាអនុតំបន់មេគង្គ ក្រោមប្រធានបទ**«មហាអនុតំបន់មេគង្គ ឆ្ពោះទៅកាន់ខ្សែសង្វាក់តម្លៃផលិតកម្មកសិកម្ម ប្រកបដោយចីរភាព សុវត្ថិភាព និងបរិយាបន្ន»** នៅសណ្ឋាគារអេប្សូរ៉ាផាឡេស រីសត ខនហ្វរិន សិនធី ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៧។

៧- ទិវាជាតិលើកកម្ពស់អនាម័យជនបទលើកទី៨ និងពិធីបើកវេទិកាថ្នាក់ជាតិលើកទី២ ស្តីពីអនាម័យជនបទ ក្រោមប្រធានបទ**«ការស្រាវជ្រាវ និងការបង្កើតថ្មី ដើម្បីឆ្ពោះទៅរកភាពជោគជ័យ»** នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។

៨- ពិធីបើកវេទិកាទេសចរណ៍វប្បធម៌អាស៊ាន ចិន ក្រោមប្រធានបទ**«ការការពារមរតក វប្បធម៌ និងការអភិវឌ្ឍទេសចរណ៍»** នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹក ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧។

ច- ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ មិថុនា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧។

## ឆ្នាំ២០១៨

១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៣ ៥៤៦នាក់ នៅតំបន់ទួលសង្កែ (ផ្សារសំហាន់) ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨។

២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ«**អគារសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**» នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅសង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨។

៣- ពិធីគោរពវិញ្ញាណក្ខន្ធសពមហាឧបាសក **គង់ ខាត់** បិតាក្មេកសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នៅគេហដ្ឋានសង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨។

៤- ពិធីទស្សនាការតាំងពិព័រណ៍សម្ភារៈយោធានិងសព្វាវុធ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៨។

៥- ពិធីសំណេះសំណាល និងពិសាអាហារជាមួយបងប្អូនអ្នកជាក់ស៊ីក្លូ ៣០៨នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៨។

៦- ពិធីសំណេះសំណាលជាមួយបងប្អូនសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធនៃសមាគមរួបរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជា៤ ៦៨៥នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៨។

៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារព្យាបាលជំងឺមហារីកនិងសម្ភព«**អគារសម្ដេចតេជោសន្តិភាព**» នៅមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨។

៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៦ ៩០៩នាក់ នៅតំបន់ព្រៃទា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨។

៩- ពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារ«**ក្របខ័ណ្ឌគោលនយោបាយជាតិ ស្ដីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧-២០៣០**» នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៨ខែមករា ឆ្នាំ២០១៨។

១០- ពិធីសំណេះសំណាលជាមួយអ្នកសារព័ត៌មានទូទាំងប្រទេស ជាង៣ ៤០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨។

១១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទេពកោសល្យវិស្វកម្មនិងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររងវិស្វកម្ម បរិញ្ញាបត្រវិស្វកម្ម វិស្វករ និងបរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត២ ៣២៨នាក់(ស្រី ៥១២នាក់)នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៨។

១២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ១០៩នាក់ នៅតំបន់ទំនប់កប់ស្រូវ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨។

១៣- ពិធីសម្ពោធដាក់ឱ្យដំណើរការរោងចក្រផលិតស៊ីម៉ង់ត៍ របស់ក្រុមហ៊ុនជីបម៉ុង អ៊ិនស៊ីស៊ីមេនឧបតើរសិន ចំណាយថវិកា៦២លានដុល្លារអាម៉េរិក នៅឃុំស្ដេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត កាលពីព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨។

១៤- ពិធីបើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ទៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និងផ្លូវតភ្ជាប់មានប្រវែង១ ១៣១ម. ទទឹង១៣,៥៦ម. ចំណាយថវិកា៥៧លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨។

១៥- ពិធីបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨។

១៦- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត៤ ១៥៨នាក់(ស្រី២ ១២៥នាក់)នៃសាកលវិទ្យាល័យវេស្ទើន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨។

១៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ១៩៧នាក់ នៅតំបន់វត្តទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨។

១៨- ពិធីបិទសន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ«**មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត**» នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨។

១៩- ពិធីគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ឃុន ឈី** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅគេហដ្ឋានសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។

២០- ពិធីចូលជួបសម្តែងការគួរសមនិងពិភាក្សាជាមួយសមាគមខ្មែរ ចិន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨។

២១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៨២៨នាក់ នៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨។

២២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងទេសចរណ៍ ពិធីអបអរសាទរទិវាទីក្រុងស្អាតក្រោមប្រធានបទ«**ទីក្រុងស្អាតដើម្បីទាំងអស់គ្នា**» និងពិធីចែកជ័យលាភីទីក្រុងស្អាតលើកទី២ សម្រាប់ឆ្នាំ២០១៨-២០២១ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨។

២៣- ពិធីកាត់ឫសសីមាព្រះវិហារវត្តជ័យមង្គល(ហៅវត្តជ្រៃ) និងសម្ពោធសមិទ្ធផលនានា នៅឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨។

២៤- ពិធីសំណេះសំណាលជាមួយគ្រូពេទ្យស្ម័គ្រចិត្តយុវជន**សម្តេចតេជោ** ៣ ៦០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០១៨។

២៥- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ២១ ១៩១នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨។

២៦- ពិធីសម្ពោធឧបដ្ឋានសាលា និងសមិទ្ធផលនានា នៅវត្តឈូករ៉ា សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៨។

២៧- ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ក្រោមប្រធានបទ«**យុវជន ដើម្បីវប្បធម៌ជាតិ**» និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសលើកទី៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨។

២៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៣ ៩៧១នាក់ នៅក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨។

២៩- ពិធីអបអរសាទរទិវានារីអន្តរជាតិ ៨មីនា ខួបលើកទី១០៧ ក្រោមប្រធានបទ«**ស្ត្រីរួមគ្នារក្សាសន្តិភាពដើម្បីអភិវឌ្ឍន៍ជាតិ**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៨។

៣០- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៤ ក្រោមប្រធានបទ«**ទន្លេនៃសន្តិភាព មិត្តភាព និងនិរន្តរភាពទេសចរណ៍**» នៅក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីរសៀលថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨។

៣១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ១ ដំណាក់កាលទី៤ ចំណាយថវិកា ២៣លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់ប្រទេសជប៉ុន នៅសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨។

៣២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានកោះប៉ែន(ស្ពានកំពង់ត្រុំ ឆ្លងកាត់ទន្លេមេគង្គ) ប្រវែង ៧៧៩ម. ទទឹង៩,២០ម. ចំណាយថវិកាជាតិ១៣,៤៥លានដុល្លារអាម៉េរិក សាងសង់ដោយកងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ នៅឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨។

៣៣- ពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៨ ក្រោមប្រធានបទ«**វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាសម្រាប់ឧស្សាហូបនីយកម្មកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជា**» នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨។

៣៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ៧៦៣នាក់ នៅផ្លូវវេងស្រេង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨។

៣៥- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា២០១៧-២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨។

៣៦- ពិធីប្រគល់សញ្ញាបត្រជូនអធិការអប់រំជំនាន់ទី២ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៤ គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+១) ជំនាន់ទី២២ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រជំនាន់ទី១ សរុប១ ៦៣០នាក់(ស្រី៥៥០នាក់) នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

៣៧- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៧ និងលើកទិសដៅការងារ ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

៣៨- ពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១១ និងផ្លូវវាងប្រវែង៩៦,៤៨គ.ម. ពីអ្នកលឿង (ចំណុចប្រសព្វផ្លូវជាតិលេខ១) ខេត្តព្រៃវែង ដល់ថ្នល់ទទឹង(ចំណុចប្រសព្វផ្លូវជាតិលេខ៧) ខេត្តត្បូងឃ្មុំ ចំណាយថវិកា៩៤,១៥លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និង

ថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំព្រែកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។

៣៩- ពិធីបើកការដ្ឋានសាងសង់កំណាត់ផ្លូវជាតិលេខ៥ ពីបាត់ដំបង ទៅសិរីសោភ័ណ ប្រវែង ៨៤,៧៤គ.ម. ចំណាយថវិកា១៨៥លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុន នៅស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨។

៤០- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត២ ១២៥នាក់(ស្រី៧៥៩នាក់)នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨។

៤១- ពិធីបិទសន្និបាតសុខាភិបាលលើកទី៣៩ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨។

៤២- ពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ៣ ៤០១នាក់ ក្នុងរាជធានីភ្នំពេញ នៅមជ្ឈ-មណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០១៨។

៤៣- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត២ ៨៦០នាក់(ស្រី២ ៣២៣នាក់)នៃវិទ្យាស្ថានវ៉ាន់ដា នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨។

៤៤- ពិធីបើកកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គ លើកទី៣ នៅខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨។

៤៥- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត៣ ១៨៧នាក់(ស្រី១ ៥៧៨នាក់)នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។

៤៦- ពិធីពិសាបាយសាមគ្គីជាមួយសមាគមខ្មែរ-ចិន ចំនួន៥ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។

៤៧- ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវមូលនិធិគន្ធបុប្ផា នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨។

៤៨- ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត លើកទី៦ ក្រោមប្រធានបទ«**សាទរមរតកដូនតា**» នៅបរិវេណប្រាសាទអង្គរធំ ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨។

៤៩- ពិធីបើកកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨។

៥០- ពិធីសំណេះសំណាលជាមួយតំណាងសហជីព តាមរោងចក្រ សហគ្រាស គ្រឹះស្ថានសិក្សា តំណាងសមាគមបុគ្គលិកសិក្សា នៅរាជធានីភ្នំពេញ និងមកពីតាមខេត្ត ប្រមាណជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨។

៥១- ពិធីសម្ពោធដាក់ឱ្យដំណើរការសណ្ឋាគារ**ផ្កាយ៥ រ៉ូយ៉ាល់ សេន កោះរ៉ុង** នៅសង្កាត់កោះរ៉ុង ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨។

៥២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សាកលវិទ្យាល័យ ក្រចេះ នៅសង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨។

៥៣- ពិធីប្រគល់វិញ្ញាបនបត្រដល់សិស្សថ្នាក់វិជ្ជាជីវៈ និងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត១ ៩៦៣នាក់(ស្រី៨៧៣នាក់) នៃសាកលវិទ្យាល័យធនធានមនុស្ស នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

៥៤- ពិធីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៨ លើកទី១៣២ ជាមួយនិយោជិត កម្មករ កម្មការិនី ៥ ៥១៥នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ក្នុងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨។

៥៥- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៨-២០១៩ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីរសៀលថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨។

៥៦- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីជាមួយថ្នាក់ដឹកនាំគ្រិស្តបរិស័ទ៣ ៥០០នាក់ ក្រោមប្រធានបទ«**ដើម្បីសុខដុមនីយកម្ម វិស័យគ្រិស្តសាសនានៅកម្ពុជា**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៨។

៥៧- ពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ៣ ៩០០នាក់ មកពីខណ្ឌទួលគោក ព្រែកព្នៅ ពោធិ៍សែនជ័យ និងខណ្ឌសែនសុខ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៨។

៥៨- ពិធីបើកការដ្ឋានគម្រោងពង្រីកនិងលើកកម្រិតកំណាត់ផ្លូវជាតិលេខ៣ ប្រវែង១៣៤,៨២គ.ម. ចាប់ពីភ្នំពេញ(ចោមចៅ) ដល់ក្រុងកំពត ខេត្តកំពត ចំណាយថវិកា២១៩,៩១១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅសង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨។

៥៩- ពិធីប្រារព្ធទិវាកាកបាទក្រហមពិភពលោក អឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០១៨ លើកទី១៥៥ ក្រោមប្រធានបទ«**កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែងសម្រាប់គ្រប់ៗគ្នា ដោយមិនទុកនរណាម្នាក់ចោល**» នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា កាលពីព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨។

៦០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៨ ៤៨៤នាក់ នៅសង្កាត់ប្រេកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង កាលពីព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨។

៦១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៩ ៤៨៩នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ក្រុងបាវិត ខេត្តស្វាយរៀង កាលពីព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨។

៦២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារមិត្តភាព កម្ពុជា កូរ៉េ នៃមន្ទីរពេទ្យកុមារជាតិ ចំណាយថវិកា៧,២៨លានដុល្លារអាម៉េរិក ដែលជាអំណោយរបស់រដ្ឋាភិបាល និងប្រជាជនកូរ៉េ នៅមន្ទីរពេទ្យកុមារជាតិ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨។

៦៣- ពិធីបិទសន្និបាតជាតិវិស័យសកម្មភាពមីន និងការប្រកាសដាក់ឱ្យដំណើរការផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ឆ្នាំ២០១៨-២០២៥ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨។

៦៤- ពិធីដាំកូនឈើនៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា **តេជោសែន ឫស្សីត្រឹប** នៅឃុំឆែប១ និងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨។

៦៥- ពិធីបើកការដ្ឋានសាងសង់កំណាត់ផ្លូវជាតិលេខ៥ ប្រវែង១៣៥,២៤គ.ម. ចាប់ពីព្រែកក្ដាម ស្រុកពញាឮ ខេត្តកណ្ដាល ដល់ថ្លាម្អម ស្រុកក្រគរ ខេត្តពោធិ៍សាត់ ចំណាយថវិកា២៦១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលជប៉ុននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨។

៦៦- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ៣៥៩នាក់ (ស្រី១ ៤៩៤នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។

៦៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៩ ៩៤៩នាក់ នៅភូមិបុរីកម្មករ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨។

៦៨- ពិធីថ្វាយគោរមងារនិងពិធីស្រោចស្រពព្រះសុគន្ធវារី ប្រគេនព្រះពុទ្ធវង្ស **ខាង សំអាង** ព្រះមេគណខេត្តកណ្ដាល ជាសម្ដេចព្រះឧត្ដមមុនី ព្រះមុនីកោសល **ឃឹម សន** ព្រះមេគណរាជធានីភ្នំពេញ ជាសម្ដេចព្រះពុទ្ធជ័យមុនី និងព្រះសាក្យវង្ស **រ័ត្ន សារឿន** ព្រះអនុគណខណ្ឌសែនសុខ ជាសម្ដេចព្រះសាក្យមុនី ដែលបានប្រារព្ធធ្វើនៅវត្តបទុមវតី រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨។

៦៩- ពិធីបើកការប្រកួតកីឡាជាតិលើកទី២ នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨។

៧០- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារវឌ្ឍនៈ កាពីតាល់ និងរ៉ូសវូដ មានកម្ពស់៣៩ ជាន់ នៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨។

៧១- ពិធីស្រាយបួសខែ រ៉ាម៉ាឌន នៃសាសនាអ៊ិស្លាមកម្ពុជា លើកទី៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨។

៧២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៦ ៤៧៤នាក់ នៅឃុំសិត្បូ ស្រុកស្អាង និងស្រុកកោះធំ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨។

៧៣- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតស៊ីម៉ងត៍បាត់ដំបង ខនស៍ស៊ីមេន លីមីធីត នៅឃុំស្ដៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។

៧៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្រុកត្បូងឃ្មុំ នៅឃុំដីពៅទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៨។

៧៥- ពិធីប្រារព្ធខួបលើកទី១១ ទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ឆ្នាំ២០១៨ ចំនួន២ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨។

៧៦- ពិធីបិទការប្រកួតកីឡាជាតិលើកទី២ នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨។

៧៧- ពិធីបិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ កម្មសិក្សាការី ឆ្នាំ២០១៧ សរុប៥៦៧នាក់ និងពិធីបើកវគ្គបណ្ដុះបណ្ដាលឆ្នាំ២០១៨ របស់សាលាភូមិន្ទរដ្ឋបាល នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៨។

៧៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២១ ៩៧០នាក់ នៅឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨។

៧៩- ពិធីស្រាយបួស ខែរ៉ាម៉ាឌន នៃសាសនាអ៊ិស្លាមកម្ពុជា៤ ៧៥០នាក់ នៅវិហារអាល់សាកាល់ (បឹងកក់) សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨។

៨០- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៦ ប្រវែង២៤៨,៥៣គ.ម. ចាប់ពីថ្នល់កែង ខេត្តកំពង់ចាម ដល់អង្គរ ខេត្តសៀមរាប ចំណាយថវិកា២៥៥,០២លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨។

៨១- ពិធីប្រកាសគោរមងារវិទ្យាសាស្ត្រ គោរមងារកិត្តិយសនិងការតែងតាំងសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជាជូនឥស្សរជន៨នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨។

៨២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៧៦៧នាក់ នៅសង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

៨៣- ពិធីសម្ពោធសមិទ្ធផលនានា ក្នុងទីបញ្ជាការដ្ឋានអង្គរក្ស នៅទីបញ្ជាការដ្ឋានអង្គរក្ស ទួលក្រសាំង ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨។

៨៤- ពិធីបិទសន្និសីទជាតិលើកទី២ ស្តីពី«**កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក លើអ្នកជំនាញទេសចរណ៍អាស៊ាន**» ចំនួន១ ០០០នាក់ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨។

៨៥- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត៣ ២៣៣នាក់ (ស្រី១ ៥០៨នាក់) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨។

៨៦- ពិធីសម្ពោធដាក់ឱ្យដំណើរការសួនសត្វភ្នំពេញ សាហ្វារី នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨។

៨៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការចំណតកំពង់ផែពហុបំណង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ចំណាយថវិកា៧៤លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលជប៉ុននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨។

៨៨- ពិធីកាត់ឫសសីមាព្រះវិហារ សម្ពោធសមិទ្ធផលនានាក្នុងវត្តព្រះឥន្ទសាមគ្គីធម៌ និងពិធីស្រោចស្រពព្រះសុគន្ធវារី ប្រគេនសម្តេចព្រះសង្ឃនាយករង២ព្រះអង្គនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រារព្ធធ្វើនៅវត្តព្រះឥន្ទសាមគ្គីធម៌ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។

៨៩- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៤ ៣៧៥នាក់ នៅឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

៩០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ២១ ៤៦៥នាក់ នៅឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

៩១- ពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសនិងផ្លូវក្រោមដីរង្វង់មូលចោមចៅ ចំណាយថវិកាជាតិ ២២លានដុល្លារអាម៉េរិក នៅសង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨។

៩២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានអាកាសមិត្តភាពកម្ពុជា ចិន សែនសុខ ប្រវែង ៩៤២ម. ទទឹង១៦,៥០ម. ចំណាយថវិកា១៧លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨។

៩៣- ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា ចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨។

៩៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៧ ៤២៧នាក់ នៅឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៨។

៩៥- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៧ ៥២៩នាក់ នៅឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨។

៩៦- ពិធីអបអរសាទរខួប ១០ឆ្នាំ នៃប្រាសាទព្រះវិហារ និងខួប១ឆ្នាំ នៃតំបន់ប្រាសាទសំបូរព្រៃគុក ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ប្រារព្ធធ្វើនៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៨។

៩៧- ពិធីចុះទស្សនកិច្ចចង្វាក់ផលិតកម្មរោងចក្រ ថប សាមីត ហ្គាមេន អ៊ីន ដែលមានកម្មករ កម្មការិនីបម្រើការងារ៣ ៨៧២នាក់ នៅសង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨។

៩៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការចំណតនាវាដឹកជញ្ជូនអ្នកដំណើរ ពីខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទៅដល់ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨។

៩៩- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៤ ៩៧៧នាក់ នៅតំបន់លូប្រាំ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០១៨។

១០០- ពិធីសំណេះសំណាលជាមួយអត្តពលិក កីឡាករ កីឡាការិនី គ្រូបង្វឹក និងប្រតិភូកីឡា៧១ នាក់ មុននឹងទៅចូលរួមការប្រកួតកីឡាអាស៊ីលើកទី១៨ នៅប្រទេសឥណ្ឌូណេស៊ី ប្រារព្ធធ្វើនៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៨។

១០១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៨ ៤៦៧នាក់ នៅតំបន់ផ្លូវជាតិលេខ៤ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨។

១០២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ៣៦៨នាក់ នៅតំបន់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨។

១០៣- ពិធីពិគ្រោះនិងផ្តល់យោបល់លើកដំបូងជាមួយប្រធាន និងតំណាងគណបក្សនយោបាយ ចំនួន១៦ គណបក្សនយោបាយ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨។

១០៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៥០៣នាក់ នៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។

១០៥- ពិធីពិភាក្សាការងារជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា២៨នាក់ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨។

១០៦- ពិធីសំណេះសំណាលនិងសម្ដែងការគួរសមរបស់គណៈប្រតិភូសហព័ន្ធពាណិជ្ជករចិនទាជីវសកលលោកនិងសមាគមសម្ព័ន្ធខ្មែរ-ចិន នៅកម្ពុជា៧២នាក់ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨។

១០៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៤ ៧៩៩នាក់ នៅតំបន់ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨។

១០៨- ពិធីស្វាគមន៍អបអរកីឡាករ សាលី អ៊ូមើត ដែលទទួលបានមេដាយមាស១គ្រឿង សំរឹទ្ធ១គ្រឿង និងកីឡាការិនី ខាន់ ចេសា ទទួលបានមេដាយមាស១គ្រឿង ពីការប្រកួតកីឡាអាស៊ីលើកទី១៨ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ប្រារព្ធធ្វើនៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨។

១០៩- ពិធីបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកដំបូង នីតិកាលទី៦នៃរដ្ឋសភា នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨។

១១០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៧ ៤៤៤នាក់ នៅឃុំពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨។

១១១- ពិធីគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **នៃ ប៉េណា** អនុប្រធានទី១ ព្រឹទ្ធសភា នៃព្រះ-រាជាណាចក្រកម្ពុជា នៅភូមិគ្រឹះបុរី ប៉េង ហួត សង្កាត់និរោធន៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨។

១១២- ពិធីអបអរសាទរទិវាគ្រូបង្រៀន ៥តុលា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨។

១១៣- ពិធីចូលជួបសម្ដែងការគួរសមនិងផ្ដល់អនុសាសន៍ដល់ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា២៩នាក់ មុននឹងទៅចូលរួមកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុនលើកទី៤៥ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨។

១១៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី៦ ៧៨៥នាក់ នៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។

១១៥- ពិធីបើកសន្និសីទអន្តរជាតិថ្នាក់តំបន់ស្ដីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយនិងអន់គុណភាព នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៦- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៣ ០០០នាក់ នៅឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៧- ពិធីសំណេះសំណាលនិងផ្ដល់ប្រាក់រង្វាន់ លើកទឹកចិត្តដល់សិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៨ ទទួលបាននិទ្ទេសA មាន៤០៨នាក់(ស្រី១៩៤នាក់) នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៨- ពិធីចុះសួរសុខទុក្ខនិងសំណេះសំណាលជាមួយកុមារពិការភ្នែក គ ថ្លង់ នៅអង្គការគ្រួសារថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៩- ពិធីបិទមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី៤ របស់សហភាពសហព័ន្ធយុវជនកម្ពុជា នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

១២០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៩១២នាក់ នៅឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១២១- ពិធីអបអរសាទរខួបលើកទី២៥ឆ្នាំ នៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(ICC) នៅសណ្ឋាគារសុខាអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨។

១២២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៦២១នាក់ នៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

១២៣- ពិធីបើកបុណ្យសមុទ្រឆ្នាំ២០១៨ លើកទី៧ ក្រោមប្រធានបទ«**ឆ្នេរស្អាត ពលរដ្ឋរមណីយ**» នៅខេត្តកោះកុង កាលពីល្ងាចថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨។

១២៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការវារីអគ្គិសនីសេសានក្រោម២ មានអានុភាព៤០០ មេហ្គាវ៉ាត់ នៅឃុំស្រែគ និងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨។

១២៥- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ១៥ ៦០៦នាក់ នៅឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨។

១២៦- ពិធីសម្ពោធវិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ និងខួបលើកទី២០ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨។

១២៧- ពិធីប្រគល់ពានរង្វាន់ដល់ជ័យលាភីកីឡាវាយកូនហ្គោល នៅសណ្ឋាគារហ្គាឌិនស៊ីធី សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។

១២៨- ពិធីអបអរសាទរបុណ្យចូលឆ្នាំសកលឆ្នាំ២០១៩ នៅវិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

**ក្រៅពីនេះ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់ទូលព្រះបង្គំជាខ្ញុំ៖**

ក- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨។

២- ពិធីបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨។

៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារគ្រឿងញៀនឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨។

៤- ពិធីបញ្ចុះបឋមសិលាសាងសង់អគារថ្មីនៃមន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង ចំណាយថវិកា១៥លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់ប្រទេសជប៉ុន នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨។

៥- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវលេខ១៥៧៧ ប្រវែងសរុប៥១,៨០គ.ម. ចាប់ពីភូមិភ្នាវ ឃុំត្រែង ស្រុករតនមណ្ឌល ដល់ភូមិធករកា ឃុំសំឡូត ស្រុកសំឡូត(ប្រកទ្វារព្រំដែន៤០០) ខេត្តបាត់ដំបង ចំណាយថវិកា៣៨,២១១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រារព្ធនៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨។

៦- ពិធីកាត់ឫសសីមាព្រះវិហារវត្តសិរីវឌ្ឍ(ហៅវត្តព្រែកផ្តៅ) នៅឃុំព្រែកអន្ទះ ស្រុកពោធិ៍រៀង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៨។

៧- ពិធីកាត់ឫសសីមាព្រះវិហារវត្តសិរីសារពេជ្ជ ហៅវត្តតាគោក នៅឃុំល្វា ស្រុកព្រះស្ដេច ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៨។

៨- ពិធីកាត់ឫសសីមាព្រះវិហារវត្តកណ្តាលមានជ័យ ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

៩- ពិធីឆ្លងមហាកុដិនិងសមិទ្ធផលនានា ក្នុងវត្តពារាណសី សិរីមង្គល នៅឃុំពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៨។

ខ- សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីជូនដំណើរកងវិស្វកម្មលេខ៩៦៣ ចំនួន១៨៤នាក់ ចូលរួមបេសកកម្មរក្សាសន្តិភាពក្រោមឆត្ររបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋលីបង់ និងទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៣៦៩ ចំនួន១៨៤នាក់ និងកងវិស្វកម្មលេខ៤៥៩ ចំនួន២១៦នាក់ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋលីបង់និងអាហ្វ្រិកខាងត្បូង នៅមូលដ្ឋានកងទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨។

២- ពិធីកាត់ឫសសីមាព្រះវិហារវត្តបឹងខ្នារ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨។

៣- ពិធីប្រារព្ធខួប៤១ឆ្នាំ«**ទិវាចងចាំដំណើរឆ្ពោះទៅការផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត**» នៅសាលាបឋមសិក្សា **ហ៊ុន សែន កោះថ្ម** ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

៤- ពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៣០ ថ្ងៃបង្កើតយោធភូមិភាគទី៥«**២៨-៦-១៩៨៨/ ២៨-៦-២០១៨**» នៅសង្កាត់ព្រែកព្រះស្ដេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

៥- ពិធីប្រារព្ធទិវាមច្ចុជាតិ ១កក្កដា ឆ្នាំ២០១៨ លើកទី១៦ នៅកសិណអង្គរវត្ត សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨។

៦- ពិធីទទួលដំណើរនិវត្តន៍កងកម្លាំងវិស្វកម្មព្រលានយន្តហោះលេខ១៨៩ កងកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ១២៣ និងកងរាជអាវុធហត្ថលេខ៦១៩ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋម៉ាលីនិងសាធារណរដ្ឋស៊ូដង់ខាងត្បូង ប្រារព្ធធ្វើនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨។

៧- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៩៥៤ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅអាកាសយានដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

៨- ពិធីហោះហើរបង្ហាញឧទ្ធម្ភាគចក្រ នៅអាកាសយានដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨។

គ- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីជួបសំណេះសំណាលនិងផ្តល់រង្វាន់ជ័យលាភីជូនអត្តពលិកជនពិការដែលទទួលបានមេដាយប្រាក់២១គ្រឿង មេដាយសំរឹទ្ធិ៥គ្រឿង និងគ្រូបង្វឹក គ្រូជំនួយ ត្រឡប់មកពីការប្រកួតអាស៊ាន ប៉ារ៉ាហ្គេម លើកទី៩ នៅប្រទេសម៉ាឡេស៊ី នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨។

២- ពិធីប្រកាសចូលកាន់តំណែងអនុប្រធានទី១ និងអគ្គលេខាធិការរងនៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨។

៣- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអាកាសចរណ៍ស៊ីវិលឆ្នាំ២០១៣-២០១៧ និងលើកទិសដៅការងារ ឆ្នាំ២០១៨-២០២៣ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨។

៤- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម កាលពីព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨។

៥- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា២០១៧-២០១៨ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា កាលពីព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨។

៦- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សារមន្ទីរធម្មជាតិសកល **សម្តេចតេជោ ហ៊ុន សែន ព្រះវិហារ** នៅឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨។

៧- ពិធីបើកនិងបិទកិច្ចប្រជុំស្តីពីការគ្រប់គ្រងប្រព័ន្ធចរាចរនាំផ្លូវអាកាសអាស៊ីខាងត្បូង-តណ្ណាលើកទី៨ និងកិច្ចប្រជុំស្តីពីក្រុមការងារសម្របសម្រួលប្រព័ន្ធត្រួតពិនិត្យចរាចរនាំផ្លូវអាកាសក្នុងតំបន់អាស៊ីអាគ្នេយ៍ លើកទី២៥ នៅសណ្ឋាគារសុខាល័យអង្គរ រីសត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨។

៨- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ៥ឆ្នាំ និងលើកទិសដៅការងាររបស់វិស័យមុខងារសាធារណៈ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨។

៩- ពិធីទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងជនមានពិការភាពអន្តរជាតិលើកទី៣៦ ឆ្នាំ២០១៨ ក្រោមប្រធានបទ«**លើកកម្ពស់សិទ្ធិជនមានពិការភាពធានាដល់ការធ្វើបរិយាបន្ននិងសមភាព**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨។

១០- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៧ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨។

ឃ- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញចូលរួមជាអធិបតីក្នុងៈ

១- ពិធីសំពះគ្រូនិងការតាំងពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពីគ្រឿងអលង្ការ និងការតុបតែងលម្អខ្មែរសម័យបុរាណ នៅសារមន្ទីរជាតិ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨។

២- ពិធីសម្ពោធឆ្លងប្រាសាទ "**នាគរាជតេជោមរតក**" និងសមិទ្ធផលនានា ក្នុងវត្តប្រាសាទ ត្រាំនាគ នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨។

៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨។

៤- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានុការីមថ្នាក់ជាតិទូទាំងប្រទេសលើកទី២៧ ឆ្នាំ២០១៨ នៅវិហារអ៊ិស្លាម ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត កាលពីរសៀលថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៨។

៥- ពិធីអបអរសាទរខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨ ចំនួន២ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។

៦- ពិធីសំណេះសំណាលជាមួយអាចារ្យ អាចារិនី១ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨។

ង- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុងៈ

១- ពិធីប្រកាសជាផ្លូវការកម្មវិធីលុបបំបាត់ភាពងងឹតភ្នែកដោយសារជំងឺភ្នែកឡើងបាយ ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅមន្ទីរពេទ្យខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨។

២- ពិធីបញ្ចុះបឋមសិលាសាងសង់អគារមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ ចំណាយថវិកា ៥៥០លានយ័ន ស្មើនឹងប្រមាណ៨០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមា-និតចិន នៅក្នុងបរិវេណមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។

៣- ទិវាពិភពលោកប្រយុទ្ធប្រឆាំងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៨ ក្រោមប្រធានបទ«**យើងប្តេជ្ញារួមគ្នាបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥**» នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨។

## ឆ្នាំ២០១៩

១- ពិធីចូលជួបសម្តែងការគួរសមនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា១០៥នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០១៩។

២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៨ ២៧៣នាក់ នៅឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩។

៣- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីលើកទី៣ ជាមួយអ្នកសារព័ត៌មានប្រមាណ៤ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩។

៤- ពិធីបើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣(ផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ១)ប្រវែង៥០,៩៧ គ.ម. ចំណាយថវិកាប្រមាណ២៧៣លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមា-និតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅផ្លូវជាតិលេខ២ សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩។

៥- ពិធីប្រកាសជាផ្លូវការក្រុមប្រឹក្សាវប្បធម៌អាស៊ី នៅទីលានជល់ដំរី ក្រុងសៀមរាប ខេត្តសៀមរាប កាលពីរាត្រីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩។

៦- ពិធីប្រារព្ធខួប២០ឆ្នាំនៃថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ នៅបញ្ជាការដ្ឋានកងទ័ពជើងគោក សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩។

៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១១ ៧៣៨នាក់ នៅឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត កាលពីព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩។

៨- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩។

៩- កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩។

១០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១១ ២២៧នាក់ នៅឃុំចក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

១១- ពិធីអបអរសាទរទិវាទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ«**ទីក្រុងស្អាត ទីក្រុងផ្តល់ភាពកក់ក្តៅ**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

១២- ពិធីបើកកិច្ចប្រជុំឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់លើកទី១ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

១៣- ពិធីបញ្ចុះបឋមសិលាសាងសង់មន្ទីរពេទ្យមិត្តភាពកម្ពុជា ចិន ត្បូងឃ្មុំ ចំណាយថវិកាប្រមាណ៥០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩។

១៤- ពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៧ ស្តីពីកិច្ចព្រមព្រៀង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០១៩។

១៥- ពិធីបើកការដ្ឋានសាងសង់សំណង់ផ្សេងៗក្នុងគម្រោងការពារទឹកជំនន់និងកែលម្អប្រព័ន្ធប្រឡាយ លូ ក្នុងរាជធានីភ្នំពេញដំហានទី៤ ចំណាយថវិកាប្រមាណ៣០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន នៅខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៩។

១៦- ពិធីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៨ ក្រោមប្រធានបទ«**លើកកម្ពស់យេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩។

១៧- ពិធីអបអរសាទរទិវាវប្បធម៌ជាតិ៣មីនា លើកទី២១ ក្រោមប្រធានបទ«**យុវជនដើម្បីវប្បធម៌ជាតិ**» និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៥ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩។

១៨- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារការបរទេសឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កាលពីព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩។

១៩- ពិធីសំណេះសំណាលនិងពិសាអាហារជាមួយអ្នកប្រកបមុខរបរជាក់ស៊ីក្លូ៣២០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩។

២០- ពិធីសំណេះសំណាលសួរសុខទុក្ខជាមួយគ្រូ យុវនារី និងកុមារីរងគ្រោះនៅ«**មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី អាហ្វេស៊ីប (AFESIP) ទុំទី**» នៅសង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩។

២១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ០៤៣នាក់ (ស្រី១ ៤១២នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩។

២២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសុខាភិបាលឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩។

២៣- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៣ ៨៦៦នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩។

២៤- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។

២៥- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៥ ក្រោមប្រធានបទ«**ទន្លេផ្សារភ្ជាប់សន្តិភាព ប្រជាជន និងទេសចរណ៍**» នៅខេត្តកំពង់ឆ្នាំង កាលពីល្ងាចថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩។

២៦- ពិធីប្រគល់វិញ្ញាបនបត្រ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត១ ៧០៩អង្គ/នាក់(ស្រី៦៧៦នាក់)នៃវិទ្យាស្ថានខ្មែរជំនាន់ថ្មី នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩។

២៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១០ ៦៨៩នាក់ នៅឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

២៨- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត**១ ៥៧៨នាក់**(ស្រី៦៤០នាក់)នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។

២៩- ពិធីបើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ ក្រុងព្រះសីហនុ មានប្រវែង១៩០,០១គ.ម. តភ្ជាប់ពីភូមិ១ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដល់ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចំណាយថវិកាប្រមាណ២ ០០០លានដុល្លារអាម៉េរិក ក្រោមរូបភាពសាងសង់ ធ្វើអាជីវកម្មផ្ទេរ (BOT) ដែលជាទុនវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មស្ពាននិងថ្នល់ចិន នៅឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

៣០- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **១ ២៤៥នាក់**(ស្រី៥៧២នាក់)នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។

៣១- ពិធីបើកសន្និសីទចក្ខុវិស័យកម្ពុជាលើកទី១៣ ឆ្នាំ២០១៩ ក្រោមប្រធានបទ«**ការប្រែក្លាយផ្នែកឌីជីថលឆ្ពោះទៅកាន់ឧស្សាហកម្មទី៤.០**» នៅសណ្ឋាគារហ្រ្វេត ឌូក រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។

៣២- ពិធីប្រគល់សញ្ញាបត្រដល់គរុនិស្សិតនិងគរុសិស្ស**១ ៩១៨នាក់**(ស្រី៧១៣នាក់) នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩។

៣៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៨-២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩។

៣៤- ពិធីអបអរសាទរខួប១០០ឆ្នាំ(១៩១៩-២០១៩)របស់អង្គការអន្តរជាតិខាងការងារ(ILO) និងខួប៥០ឆ្នាំ(១៩៦៩-២០១៩)នៃសមាជិកភាពរបស់កម្ពុជា នៅអង្គការអន្តរជាតិខាងការងារ ក្រោមប្រធានបទ **«បង្កើនយុត្តិធម៌សង្គម លើកកម្ពស់ការងារសមរម្យ»** នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

៣៥- វេទិការាជរដ្ឋាភិបាលនិងផ្នែកឯកជន លើកទី១៨ ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

៣៦- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **៣ ២១៣នាក់**(ស្រី២ ៧០៤នាក់)នៃវិទ្យាស្ថានវ៉ាន់ដា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩។

៣៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពត ចំណាយថវិកាប្រមាណ**២៧លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន នៅសង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត កាលពីព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩។

៣៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ឡើងវិញស្ពានមិត្តភាពកម្ពុជា ជប៉ុន(ស្ពានជ្រោយចង្វាទី១) ចំណាយថវិកាប្រមាណជាង៣០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន កាលពីព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។

៣៩- ពិធីពិសាបាយសាមគ្គីឆ្នាំ២០១៩ ជាមួយកីឡាករ កីឡាការិនី គ្រូបង្វឹក**៤ ០៩៦នាក់** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩។

៤០- ពិធីសម្ពោធជាផ្លូវការសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ**«ព្រះស្រីឦសានវរ្ម័ន»** នៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

៤១- ពិធីពិសាបាយសាមគ្គីជាមួយសមាគមសម្ព័ន្ធខ្មែរ ចិន៥ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩។

៤២- ពិធីចាក់បេតុងតភ្ជាប់ស្ពានមិត្តភាពកម្ពុជា ថៃ(ស្ទឹងបត់-បានណងអៀង) ចំណាយថវិកាជាង**១៩ លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលថៃនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា និងពិធីបើកការដ្ឋានសាងសង់អគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៥ ចំណាយថវិកា**២៦,៤២លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានសម្បទានពីរាជរដ្ឋាភិបាលថៃ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ កាលពីព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។

៤៣- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**២ ២៨៧នាក់** (ស្រី១ ១៩៤នាក់)នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

៤៤- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីជាមួយនិយោជិត កម្មករ កម្មការិនី**៣ ៧០០នាក់** ដើម្បីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៩ លើកទី១៣៣ នៅឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩។

៤៥- កិច្ចពិភាក្សាការងារជាមួយគណៈប្រតិភូនៃក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិនៅកម្ពុជា ២០នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩។

៤៦- ពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌននៃសាសនិកអិស្លាមកម្ពុជា៤ ៧៥០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩។

៤៧- ពិធីប្រារព្ធទិវាកាកបាទក្រហមពិភពលោក អឌ្ឍចន្ទក្រហម៨ឧសភា ឆ្នាំ២០១៩ លើកទី១៥៦ ក្រោមប្រធានបទ**«ខ្ញុំស្រឡាញ់កាកបាទក្រហមកម្ពុជា»** នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៩។

៤៨- វេទិកាធុរកិច្ចកម្ពុជា-នេប៉ាល់ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩។

៤៩- ពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌននៃសាសនិកអិស្លាមកម្ពុជា៧២៥នាក់ នៅវិហារបឹងកក់ សង្កាត់បឹងកក់១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៩។

៥០- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ១៦១នាក់ (ស្រី១ ៤៨៥នាក់)នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៩។

៥១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត ១ ៣៥៦នាក់(ស្រី៨៧១នាក់)នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៩។

៥២- សន្និសីទកំពូលសារព័ត៌មានអាស៊ីឆ្នាំ២០១៩ លើកទី១៦ នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩។

៥៣- ការចុះពិនិត្យការដ្ឋានផ្ទាល់និងជួបសំណេះសំណាលសួរសុខទុក្ខជាមួយជនរងគ្រោះក្នុងឧបទ្ទវហេតុបាក់រលំអគារកម្ពស់៧ជាន់ នៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីរាត្រីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩។

៥៤- ពិធីផ្ទេរការគ្រប់គ្រងសាលាកុមារពិការភ្នែកនិងកុមារគថ្លង់នៃអង្គការគ្រួសារថ្មីឱ្យស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡា និងការដាក់ឱ្យដំណើរការវិទ្យាស្ថានជាតិអប់រំពិសេស នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

៥៥- ពិធីសំណេះសំណាលជាមួយកម្មករ កម្មការិនី កីឡាករ កីឡាការិនី ក្នុងឱកាសចុះពិនិត្យការដ្ឋានសាងសង់**ពហុកីឡដ្ឋានជាតិមរតកតេជោ** ដែលបាននិងកំពុងសាងសង់ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩។

៥៦- ពិធីប្រគល់សញ្ញាបត្រវិទ្យាសាស្ត្រនគរបាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រដល់និស្សិតនាយនគរបាលបន្តវេននិងសិក្ខាកាមថ្នាក់វិញ្ញាបនបត្រសរុប១ ៤៦៥នាក់(ស្រី១០២នាក់) នៃបណ្ឌិត្យសភានគរបាលកម្ពុជា នៅបណ្ឌិត្យសភានគរបាលកម្ពុជា ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៩។

៥៧- វេទិកាធុរកិច្ចកម្ពុជា ស្រីលង្កា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩។

៥៨- ពិធីបើកកិច្ចប្រជុំជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់ប្រចាំឆមាសលើកទី២ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

៥៩- ពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្ដីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម(CLMTV) នៅសណ្ឋាគារអប្សរាផាលេសក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

៦០- ពិធីអបអរសាទរខួប៧០ឆ្នាំ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩។

៦១- ពិធីប្រគល់វិញ្ញាបនបត្រនិងសញ្ញាបត្រដល់សិស្សថ្នាក់វិជ្ជាជីវៈគរុកោសល្យ និងនិស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់១ ១៨៣នាក់(ស្រី៦៣៥នាក់)នៃសាកលវិទ្យាល័យប៊ែលធីអន្តរជាតិ និងប្រកាសផ្សព្វផ្សាយជាផ្លូវការសៀវភៅ**«ហ៊ុន សែន កម្ពុជា»** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩។

៦២- ពិធីសំណេះសំណាលជាមួយបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**«និទ្ទេសA»** ៤៤៣នាក់(ស្រី២២៣នាក់) សម័យប្រឡងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩។

៦៣- ពិធីចូលជួបសម្តែងការគួរសម និងពិភាក្សាការងាររបស់គណៈប្រតិភូសហគ្រិនចិនដែលដឹកនាំដោយលោក **ហ៊ុន ខឹជូ** ប្រធានសហគ្រិនចិន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

៦៤- ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ(១០ តុលា ១៩៧៩-១០ តុលា ២០១៩) នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

៦៥- ពិធីចូលជួបសម្តែងការគួរសមរបស់ប្រតិភូយុវជនកម្ពុជា២៩នាក់ នៃកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុនលើកទី៤៦ ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

៦៦- ពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋខ្មែរជាគ្រិស្តបរិស័ទ ដើម្បីសុខដុមនីយកម្មវិស័យគ្រិស្តសាសនានិងពិសាភោជនាហារ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩។

៦៧- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៤ ០៣៨នាក់ (ស្រី១ ៣៤៤នាក់)នៃសាកលវិទ្យាល័យបៀលប្រាយ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។

៦៨- ពិធីបើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២ ក្រោមប្រធានបទ«**តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់**» នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦៩- ពិធីផ្សព្វផ្សាយនិងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ«**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧០- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតស៊ីម៉ងត៍របស់ក្រុមហ៊ុន ថៃ ប៊ុនរ៉ុង ចំណាយថវិកាប្រមាណ១១០លានដុល្លារអាមេរិក នៅឃុំល្អាង ស្រុកដងទង់ ខេត្តកំពត កាលពីព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧១- ពិធីបើកការដ្ឋានស្ថាបនាផ្លូវចំនួន៣៤ខ្សែ ប្រវែង៨៤,៥០គ.ម. នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចំណាយថវិកាជាតិប្រមាណជិត៣០០លានដុល្លារអាមេរិក កាលពីព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧២- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញារង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **១ ៩៥៨នាក់**(ស្រី៤៤៧នាក់)នៃសាកលវិទ្យាល័យធនធានមនុស្ស នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៣- ពិធីសំណេះសំណាលជាមួយអត្តពលិក និងប្រតិភូកីឡាកម្ពុជា ដែលត្រូវទៅចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣០ នៅប្រទេសហ្វីលីពីន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៤- ពិធីបើកកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកលើកទី២ ក្រោមប្រធានបទ«**ការឆ្លើយតបចំពោះបញ្ហាប្រឈមគន្លឹះនាពេលបច្ចុប្បន្ន: សន្តិភាព ការបង្រួបបង្រួមជាតិ ការពឹងពាក់គ្នាទៅវិញទៅមក វិបុលភាពទៅវិញទៅមក និងគុណតម្លៃសកល**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៥- ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះសពសម្តេចរាជបុត្រីព្រះរាម**នរោត្តម ប៊ុប្ផាទេវី** ទេពនាដវរជ្ជី ឯកឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ នៅវត្តបទុមវតី រាជវរារាម សង្កាត់ចតុមុខ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៦- ពិធីសម្ពោធ«**អគារឥន្ទ្រទេវី**» របស់រាជបណ្ឌិត្យសភាកម្ពុជា និងអបអរសាទរខួប២០ឆ្នាំ នៃការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា នៅរាជបណ្ឌិត្យសភាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៧- ពិធីបើកមហាសន្និបាតសហព័ន្ធអតីតយុទ្ធជនអាស៊ានលើកទី១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩។

៧៨- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត **៦ ៧៦២នាក់**( ស្រី២ ៧៦១នាក់ )នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩។

៧៩- ពិធីសម្ពោធពិព័រណ៍ផលិតផលខ្មែរនិងទំនិញនាំចេញ នាំចូលកម្ពុជាលើកទី១៤ កម្រិតអន្តរជាតិ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩។

៨០- ពិធីប្រគល់សញ្ញាបត្រដល់និស្សិត២ ៥៨៨នាក់( ស្រី១ ៥២២នាក់ )នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។

៨១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាជាន់ខ្ពស់ ដល់និស្សិត ២ ៨៣១នាក់( ស្រី១ ៦១៤នាក់ )នៃសាកលវិទ្យាល័យវេស្ទើន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

៨២- ពិធីជួបសំណេះសំណាលជាមួយប្រតិភូសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

៨៣- ពិធីបើកបុណ្យសមុទ្រលើកទី៨ ជុំទី២ នៅខេត្តកំពត កាលពីល្ងាចថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៩។

៨៤- ពិធីសម្ពោធផ្សារគំរូព្រំដែន ចំណាយថវិកាប្រមាណ២លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលវៀតណាម នៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩។

៨៥- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត២ ៧៩០នាក់ (ស្រី១ ៣៨០នាក់ )នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

៨៦- ពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

៨៨- ពិធីបើកការប្រកួតវាយកូនគោល«**ពានរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រីលើកទី៤**» នៅទីលានវាយកូនគោលវ៉ឌ្ឍនហ្គោលរីសត ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩។

៨៩- ពិធីបិទការប្រកួតវាយកូនគោល «**ពានរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រីលើកទី៤**» នៅទីលានវាយកូនគោលវ៉ឌ្ឍនហ្គោលរីសត ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីល្ងាចថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩។

**ទូលព្រះបង្គំជាខ្ញុំបាន៖**

១- ទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកទំនាក់ទំនងនយោបាយពីសាកលវិទ្យាល័យគ្រើកនៃព្រះរាជាណាចក្រថៃ ប្រារព្ធធ្វើនៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩។

២- ទទួលគោរមងារជាសាស្ត្រាចារ្យកិត្តិយសផ្នែកទំនាក់ទំនងអន្តរជាតិ ពីសាកលវិទ្យាល័យប៉េកាំងនៅទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

៣- ទទួលពានរង្វាន់ «**ភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចល្អ**» ពីសហព័ន្ធសន្តិភាពសកល (UPF) នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

**ក្រៅពីនេះ សម្តេច ឯកឧត្តម និងលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់ទូលព្រះបង្គំជាខ្ញុំ៖**

ក- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តអង្គរជ័យ នៅឃុំអង្គររាជ្យ ស្រុកព្រះស្តេច ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩។

២- ពិធីប្រកួតកីឡាវាយកូនគោល«**ពានរង្វាន់សម្តេចក្រឡាហោម ស ខេង**» នៅទីលានហ្គ្រេនភ្នំពេញ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩។

៣- ពិធីជប់លៀងប្រកាសជ័យលាភីការប្រកួតកីឡាវាយកូនគោល«**ពានរង្វាន់សម្តេចក្រឡាហោម ស ខេង**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩។

៤- ពិធីបញ្ចុះខណ្ឌសីមានិងសម្ពោធសមិទ្ធផលនានា ក្នុងវត្តនទីជោត្តនារាម (ហៅវត្តខ្សោកជើង) នៅឃុំពពឺស ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩។

៥- ពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩។

៦- ពិធីអបអរសាទរទិវាគ្រូបង្រៀន ក្រោមប្រធានបទ«**គុណភាពគ្រូជាមូលដ្ឋានគ្រឹះនៃយុគសម័យឌីជីថល**» នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩។

៧- ពិធីបើកវេទិកាជាតិអេកូទេសចរណ៍លើកទី១ នៅសណ្ឋាគារហ្គាឌិនស៊ីធី សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៨- ពិធីបើកសន្និបាតបូកសរុបការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ព្រមទាំងទិវាជនមានពិការភាពកម្ពុជាលើកទី២១និងអន្តរជាតិលើកទី៣៧ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩។

៩- ពិធីប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩។

ខ- សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានគម្រោងឈូងសមុទ្រតារា នៅតំបន់អភិវឌ្ឍន៍តារាសាគរ ស្រុកគិរីសាគរ ខេត្តកោះកុង កាលពីល្ងាចថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

២- ពិធីទទួលដំណើរនិវត្តន៍កងកម្លាំងវិស្វកម្មលេខ៩៦៣ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋលីបង់ ប្រារព្ធធ្វើនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។

៣- ពិធីខួប៤២ឆ្នាំ **«ទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០-៦-១៩៧៧/២០-៦-២០១៩»** នៅសាលាបឋមសិក្សា **ម៉ុន រ៉ានី ហ៊ុន សែន** កោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩។

៤- ពិធីបើកជាផ្លូវការកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានលើកទី១៤ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសណ្ឋាគារសុខាសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។

៥- ពិធីអបអរសាទរខួបអនុស្សាវរីយ៍២៥ឆ្នាំ ថ្ងៃបង្កើតកងពលតូចលេខ៧០(១៥ តុលា ១៩៩៤-១៥ តុលា ២០១៩) នៅបញ្ជាការដ្ឋានកងពលតូចលេខ៧០ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩។

៦- ពិធីសម្ពោធអគារបឋមសិក្សា១ខ្នង អគារអនុវិទ្យាល័យ១ខ្នង និងទីចាត់ការ១ខ្នង ក្នុងអនុវិទ្យាល័យស្ពានត្នោត នៅឃុំត្នោត ស្រុកជីក្រែង ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

៧- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៥៩៤ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ប្រារព្ធនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

គ- ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកមហាសន្និបាតលើកទី៣៩ របស់សមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩។

ឃ- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៨-២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។

២- ពិធីសម្ពោធសមិទ្ធផលនានានិងកាត់ឫសសីមាព្រះវិហារវត្តអង្គនិស្សយ៍ នៅសង្កាត់ឪឡោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

៣- ពិធីវប្បធម៌និងទេសចរណ៍កម្ពុជា-ចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩។

៤- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

ង- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានទូទាំងប្រទេសលើកទី២៨ ឆ្នាំ២០១៩ នៅវិហារជំគីឡូម៉ែត្រលេខ៩ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩។

២- ទិវាជាតិអំណានឆ្នាំ២០១៩ ក្រោមប្រធានបទ«**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត**» នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩។

៣- ពិធីបិទមហោស្រពសិល្បៈចម្រៀងខ្មែរជាសកលលើកទី៥ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៩។

៤- ពិធីចូលជួបសម្តែងការគួរសមរបស់លោក **រ៉ុសែល អឹម ណិលសុន** (Russel M. Nelson) ប្រធានសាសនាចក្រនៃព្រះយេស៊ូគ្រិស្តនៅទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កាលពីល្ងាចថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- ពិធីសំណេះសំណាលជាមួយតំណាងអាចារ្យ អាចារិនី មកពីទូទាំងប្រទេស នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- ពិធីប្រគេននិងប្រគល់សញ្ញាបត្រដល់សមណនិស្សិតនិងនិស្សិត**១ ១០៦អង្គ/នាក់** នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩។

ច- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទបានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអភិវឌ្ឍន៍ជនបទឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

២- ប្រារព្ធទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០១៩ នៅអាងទឹកបឹងស្នោ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

៣- ពិធីបិទបញ្ចប់គម្រោងការលុបបំបាត់ភាពពិការភ្នែកដោយសារជំងឺភ្នែកឡើងបាយ ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

ឆ- ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីប្រារព្ធខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១មិថុនា និងខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩។

២- ពិធីប្រារព្ធខួបលើកទី១២ ទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩។

៣- ប្រារព្ធទិវាពិភពលោកប្រយុទ្ធប្រឆាំងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៩ លើកទី២៦ ក្រោមប្រធានបទ **«ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍»** នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩។

ជ- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសាធារណការនិងដឹកជញ្ជូន ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

២- ពិធីអបអរសាទរទិវាពលកម្មអន្តរជាតិ១ឧសភា ឆ្នាំ២០១៩ លើកទី១៣៣ ជាមួយនិយោជិត កម្មករ កម្មការិនីនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩។

៣- ពិធីបើកកិច្ចប្រជុំលើកទី១៥ រដ្ឋមន្ត្រីបរិស្ថានអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធឆ្នាំ២០១៩ នៅសណ្ឋាគារសូហ្វីតែល អង្គរភូគីត្រា ហ្គោហ្វ និងស្ប៉ារីហ្សត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

៤- ពិធីសម្ពោធរោងចក្រផលិតផល មីជាតិ នៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- ពិធីចូលជួបសម្តែងការគួរសមរបស់គណៈប្រតិភូនៃសហព័ន្ធពាណិជ្ជករចិនទាជីវសកល និងថ្នាក់ដឹកនាំសមាគមសម្ព័ន្ធខ្មែរ ចិន នៅកម្ពុជា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាច ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងពាណិជ្ជកម្ម នៅទីស្តីការក្រសួងពាណិជ្ជកម្ម កាលពីល្ងាចថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

ឈ- ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តរតនមុនីតាប៉ាវ(ហៅវត្តពងទឹក) នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩។

២- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តគិរីគង្គា(ហៅវត្តប្រផាត់) នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩។

៣- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តបន្ទាយជ័យមង្គល នៅឃុំកំពង់ទ្រាស ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

៤- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តសារពេជ្រពណ្ណរាយ នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩។

៥- ពិធីស្រោចសុគន្ធវារីព្រះចៅអធិការវត្តនិងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តពាមមង្គល នៅឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។

៦- ពិធីសម្ពោធអគារសិក្សា១ខ្នង មាន៣ជាន់ ១៥បន្ទប់ និងឆ្លងសមិទ្ធផលនានាក្នុងសាលាបឋមសិក្សាភាសាខ្មែរ ចិន សេង ម៉េង នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។

៧- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារនិងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តច័ន្ទរង្សី (ហៅវត្តព្រះអង្គ) នៅឃុំរការពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩។

៨- ពិធីសម្ពោធឆ្លងកុដិថ្មនិងសមិទ្ធផលនានាក្នុងវត្តព្រះពុទ្ធមហាសាស្ត្រារាម នៅឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីល្ងាចថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩។

៩- ពិធីសម្ពោធឆ្លងឧបដ្ឋានសាលានិងសមិទ្ធផលនានាក្នុងវត្តពោធិ៍សាល (ហៅវត្តអំពិល) នៅឃុំប៊ុស២ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

១០- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តគិរីវណ្ណារាម នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

១១- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តជ័យមុនី នៅឃុំទួលស្នួល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។

១២- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តបទុមរង្សី នៅឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។

១៣- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តពោធិ៍គយា (ហៅវត្តវិហារខ្ពស់) នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩។

## ឆ្នាំ២០២០

១- ការចុះដឹកនាំកិច្ចប្រតិបត្តិការរុករកសង្គ្រោះជនរងគ្រោះនិងបានជួបសួរសុខទុក្ខ ជនរងគ្រោះនៅពេលអគារប្រភេទបេតុងកម្ពស់៦ជាន់ ដែលកំពុងសាងសង់ ត្រូវបានបាក់ស្រុតនៅភូមិកែប សង្កាត់កែប ខេត្តកែប កាលពីព្រឹកថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែមករា ឆ្នាំ២០២០។

២- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីលើកទី៤ ជាមួយអ្នកសារព័ត៌មានប្រមាណជាង ៥ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០។

៣- ពិធីលៀងសាយភោជន៍អបអរសាទរបុណ្យចូលឆ្នាំប្រពៃណីជនជាតិវៀតណាម ឆ្នាំ២០២០ ជាមួយសហគមន៍និងធុរកិច្ចវៀតណាមនៅកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០។

៤- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារការបរទេសនិងសហប្រតិបត្តិការអន្តរជាតិឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងពិធីប្រកាសជាផ្លូវការនូវការធ្វើម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុបលើកទី១៣ ឆ្នាំ២០២០ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

៥- ពិធីបើកការដ្ឋានគម្រោងធ្វើឱ្យប្រសើរឡើងវិញកំណាត់ផ្លូវជាតិលេខ២ (ពីរង្វង់មូលតាខ្មៅ ដល់អូរចំបក់) និងផ្លូវជាតិលេខ២២ (ពីអូរចំបក់ ដល់អង្គតាសោម) ប្រវែង៧២,១៧គ.ម. ចំណាយថវិកាប្រមាណ ៥៦,១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីសាធារណរដ្ឋកូរ៉េនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០។

៦- ពិធីទទួលស្វាគមន៍អ្នកទេសចររបស់នាវា Westerdam នៅកំពង់ផែក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

៧- កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

៨- ពិធីប្រគល់សញ្ញាបត្រដល់អធិការកិច្ចអប់រំនិងនិស្សិត គរុសិស្ស១ ៩៧៧នាក់(ស្រី៨១៥នាក់) របស់វិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

៩- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីល្ងាចថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០។

១០- ពិធីបើកកិច្ចប្រជុំប្រចាំឆមាសលើកទី៣នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

១១- ពិធីបិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ដល់សិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ និងកម្មសិក្សាការី ឆ្នាំ២០១៨ ចំនួន៥៧៥នាក់(ស្រី១០៥នាក់) និងពិធីបើកវគ្គបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១១ ឆ្នាំ២០២០ របស់សាលាភូមិន្ទរដ្ឋបាល នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០។

១២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥៨ ប្រវែង១៧៤,១៦គ.ម. ចាប់ពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដល់ក្រុងសំរោង ខេត្តឧត្តរមានជ័យ ចំណាយថវិកាប្រមាណ១២២,៩៨លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០។

១៣- ពិធីស្រោចស្រពព្រះសុគន្ធវារី ប្រគេនសម្តេចព្រះសង្ឃនាយករងបីព្រះអង្គ មានសម្តេចព្រះពោធិវ័ង្ស **អ៊ំ លឹមហេង** សម្តេចព្រះសង្ឃនាយករងទី១ សម្តេចព្រះវនរ័ត **ណយ ជ្រឹក** សម្តេចព្រះសង្ឃនាយករងទី២ និងសម្តេចព្រះឧត្តមវង្សា **មួង រ៉ា** សម្តេចព្រះសង្ឃនាយករងទី៣ នៅវត្តមុនីសុវណ្ណ (ហៅវត្តចំពុះក្អែក) ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។

១៤- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត ១ ៥៨៩នាក់(ស្រី៦១៦នាក់) នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២០។

១៥- ពិធីអបអរសាទរទិវា**«វប្បធម៌ជាតិ៣មីនា»** លើកទី២២ ឆ្នាំ២០២០ និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៦ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។

១៦- ពិធីបិទសន្និបាតការងារសុខាភិបាលឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល នៅសណ្ឋាគារសុខាភ្នំពេញ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០។

១៧- ពិធីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៩ ក្រោមប្រធានបទ**«មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ»** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០។

១៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥៥ ប្រវែង**១៨២,១៦គ.ម.** ចាប់ពីពោធិ៍សាត់ វាលវែង ដល់ថ្មដា(ព្រំដែនកម្ពុជា ថៃ) និងពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១០ ប្រវែង១៩៧,៣៦គ.ម. ចាប់ពីសំឡូត-វាលវែង អូរសោម ដល់កោះកុង ចំណាយថវិកាប្រមាណ១៨៨,៣៨លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅសាលាបឋមសិក្សា **ហ៊ុន សែន ប្រមោយ** ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០។

១៩- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ៤៥៨នាក់(ស្រី២ ៩៥៤នាក់) នៃវិទ្យាស្ថានវ៉ាន់ដា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០។

២០- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៦ ឆ្នាំ២០២០ ក្រោមប្រធានបទ**«ទន្លេនៃសន្តិភាព ទន្លេនៃវិបុលភាព»** នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីល្ងាចថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០។

២១- ពិធីចុះហត្ថលេខាលើលិខិតប្តូរសារ ស្តីពីការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការជប៉ុនជូនចំពោះរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានមានទឹកប្រាក់៣៤ ១៣៨លានយ៉េន ស្មើនឹង៣១០

លានដុល្លារអាម៉េរិក  សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានឥតសំណង៣គម្រោងនិងឥណទានសម្បទាន២គម្រោង នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០។

២២- ពិធីសំណេះសំណាលជាមួយគ្រូពេទ្យសម្តេចតេជោប្រឆាំងកូវីដ-១៩ ចំនួន៤២២នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

២៣- ចុះពិនិត្យដំណើរការស្ថាបនាផ្លូវក្រុង៣៤ខ្សែ ប្រវែង៨៤,៥០គ.ម. សម្រេចបាន៩៤% នៅខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០។

២៤- ពិធីជួបសំណេះសំណាលជាមួយមន្ត្រីរាជការនិងក្រុមការងារបច្ចេកទេសស្ថាបនា ផ្លូវក្រុង៣៤ខ្សែ នៅខេត្តព្រះសីហនុ កាលពីល្ងាចថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០។

២៥- ចុះពិនិត្យការដ្ឋានសាងសង់អគារថ្មីនៃទីស្នាក់ការគណបក្សប្រជាជនកម្ពុជា«**វិមាន ៧មករា**» សម្រេចបាន៩៥% នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០។

២៦- ចុះពិនិត្យការដ្ឋានសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មីសម្រេចបាន៣០% នៅឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០។

២៧- ពិធីប្រកាសអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងកំឡុងពេលប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។

២៨- ពិធីក្រុងពាលីសូត្រមន្តសម្ពោធអគារថ្មីទីស្នាក់ការគណបក្សប្រជាជនកម្ពុជា«**វិមាន ៧មករា**» នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០។

២៩- ការចុះពិនិត្យវឌ្ឍនភាពនៃការងារវារីវប្បកម្ម នៅមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប និងសំណេះសំណាលជាមួយប្រជាកសិករ នៅឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

៣០- ការចុះពិនិត្យវឌ្ឍនភាពនៃការងារបង្កបង្កើនផលស្រូវ និងជួបសំណេះសំណាលជាមួយប្រជាកសិករ នៅឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០។

៣១- ពិធីសម្ពោធសួនទឹកហ្គាឌិនស៊ីធី នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០។

៣២- ពិធីបើកកិច្ចប្រជុំជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ប្រចាំឆមាសលើកទី៤ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

៣៣- ពិធីសម្ពោធមជ្ឈមណ្ឌលកម្សាន្តព្រីនស៍ ម៉ាណ័រ នៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០។

៣៤- ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **វ៉ាង យី** ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០។

៣៥- ការចុះពិនិត្យស្ថានភាពទឹកជំនន់និងសួរសុខទុក្ខប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀង នៅខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីយប់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០។

៣៦- ការចុះសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ នៅឃុំបត់ត្រង់និងឃុំឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០។

៣៧- ការចុះសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ នៅឃុំគំរូ ស្រុកថ្មពួក និងសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០។

៣៨- ការចុះសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ នៅស្រុកអូរជ្រៅនិងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០។

៣៩- ពិធីបើកការដ្ឋានសាងសង់ស្ពានបេតុងខ្សែកាបឆ្លងកាត់ទន្លេបាសាក់ ពីទីក្រុងរណបកោះពេជ្រទៅកាន់តំបន់អភិវឌ្ឍន៍កោះនរា និងពីតំបន់អភិវឌ្ឍន៍កោះនរា ទៅផ្លូវជាតិលេខ១ និងពិធីប្រកាសឱ្យបើកដំណើរការជាបណ្តោះអាសន្នផ្លូវក្រោមដី ស្ពានអាកាសរង្វង់មូលចោមចៅ ប្រព្រឹត្តទៅនៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០។

៤០- ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនិងអនុស្សរណៈនៃការយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋហុងគ្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០។

៤១- ពិធីសំណេះសំណាលនិងពិនិត្យលទ្ធផលការងាររបស់សមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល និងមេធាវីស្ម័គ្រចិត្តសម្តេចតេជោ១៥៣នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០។

៤២- ពិធីបើកការដ្ឋានសាងសង់ផ្លូវ៣៨ខ្សែ ប្រវែង១០៨,៧៤គ.ម. ចំណាយថវិកាប្រមាណ១៤០ លានដុល្លារអាម៉េរិក នៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។

**ទន្ទឹមនេះ ទូលព្រះបង្គំជាខ្ញុំបានអនុញ្ញាតឱ្យ៖**

១- ឯកឧត្តម Muhammad Faruk Khan ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការបរទេសនៃសភាបង់ក្លាដែស ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៦ ខែមករា ឆ្នាំ២០២០។

២- ឯកឧត្តមសាស្ត្រាចារ្យ Jeffrey D. Sachs ទីប្រឹក្សាពិសេសរបស់ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

៣- ឯកឧត្តម Yamoto Kozo សមាជិកសភាជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០។

៤- ឯកឧត្តម Imamura Masahiro ប្រតិភូសភាជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០។

៥- ឯកឧត្តម ឧត្តមសេនីយ៍ទោ Goh Si Hou មេបញ្ជាការកងទ័ពជើងគោកនៃប្រទេសសិង្ហបុរី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

៦- លោកជំទាវ Liurka Rodriquez Barrias ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសគុយបា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

៧- ឯកឧត្តម Pablo Chiho Kang ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

៨- ឯកឧត្តម Bounnhang Vorachith អគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវនិងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២០។

៩- ឯកឧត្តម Mikami Masahiro ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០។

១០- ឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

១១- លោក Orlando Ashford ប្រធានក្រុមហ៊ុន Holland America Line ដែលជាម្ចាស់នាវា Westerdam ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

១២- ឯកឧត្តម នាយឧត្តមសេនីយ៍ Goro Yuasa មេបញ្ជាការកងទ័ពជើងគោក ប្រទេសជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។

១៣- ឯកឧត្តម Takahashi Fumiaki ប្រធានសមាគមកម្ពុជា ជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

១៤- ឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

១៥- ឯកឧត្តម Ermenegildo Kupa Lopes ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើតតែងតាំងថ្មី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០។

១៦- ឯកឧត្តម Panyarak Poolthup ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ព្រះរាជាណាចក្រថៃ ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងប្រគល់ថវិការបស់រដ្ឋាភិបាលថៃចំនួន**២លានបាត** ជូនរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០។

១៧- ឯកឧត្តម Motegi Toshimitsu រដ្ឋមន្ត្រីការបរទេសជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០។

១៨- លោកជំទាវ Manika Jain ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម ពិភាក្សាការងារនិងជម្រាបលា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០។

១៩- ឯកឧត្តម Anatoly Borovik ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីតែងតាំងថ្មីប្រចាំព្រះរាជាណាចក្រ-កម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០។

**ក្រៅពីនេះ សម្តេច ឯកឧត្តម និងលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់ទូលព្រះបង្គំជាខ្ញុំ៖**

ក- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញចូលរួមក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ និងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តន៍ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីល្ងាចថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

២- ពិធីបិទសិក្ខាសាលាជាតិស្តីពីការពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់រៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីល្ងាចថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០។

៣- ពិធីសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយជូនប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀង នៅអាកាសយានដ្ឋានបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២០។

ខ- សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៦៩៣ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋលីបង់ ប្រារព្ធធ្វើនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០។

២- ពិធីរំលឹកខួបលើកទី៤៣ ទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០មិថុនា ១៩៧៧ - ២០មិថុនា ២០២០ នៅចំណុចអាងដាច់«**ដើមត្រយឹង**» ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។

៣- ពិធីប្រកាសទទួលស្គាល់ឯកឧត្តមអនុប្រធាន អគ្គលេខាធិការរង សមាជិកគណៈកម្មាធិការកណ្តាល និងសមាជិកគណៈអចិន្ត្រៃយ៍សមាគមអតីតយុទ្ធជនកម្ពុជា នៅឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០។

៤- ពិធីប្រគល់ ទទួលផែនទីឋានលេខាព្រំដែនគោកខ្នាត១/២៥ ០០០ រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។

៥- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការឡើងវិញអាងហែលទឹក នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០។

៦- ពិធីប្រគល់អំណោយរបស់រាជរដ្ឋាភិបាលកម្ពុជា មានម៉ាស់២,១លានម៉ាស់ និងបរិក្ខារពេទ្យចំនួន **១២មុខ** ជូនដល់រដ្ឋាភិបាលឡាវ នៅអាកាសយានដ្ឋានអន្តរជាតិក្រុងវៀងចន្ទន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កាលពីព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០។

គ- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានុលការីមទូទាំងប្រទេស លើកទី២៩ នៅវិហារធំគីឡូម៉ែត្រលេខ៩ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០២០។

២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌និងវិចិត្រសិល្បៈឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

៣- ពិធីសម្ពោធអគារហង្សមាសគ្រុបនិងស្ទូឌីយ៉ូភ្លោះរបស់ទូរទស្សន៍ហង្សមាស និងរស្មីហង្សមាស HDTV នៅសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០។

៤- ទិវាជាតិអំណាន«**១១មីនា**» លើកទី៥ ឆ្នាំ២០២០ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

ឃ- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម នៅទីស្តីការក្រសួងឧស្សាហកម្មនិងសិប្បកម្ម កាលពីព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

២- ពិធីប្រទានភ្លើងបូជាសពឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស នៅមុខវត្តបទុមវតី រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។

ង- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអភិវឌ្ឍជនបទឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។

២- ពិធីបើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី២ (២០១៩-២០២៣) នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០។

ច- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសាធារណការនិងដឹកជញ្ជូនឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី៩ ខែមករា ឆ្នាំ២០២០។

២- ពិធីបិទសន្និបាតបូកសរុបការងារទេសចរណ៍ឆ្នាំ២០១៩និងទិសដៅអនុវត្តបន្តឆ្នាំ២០២០ អមជាមួយពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតក្រោមប្រធានបទ«**ទីក្រុងស្អាត ទីក្រុងដែលមានវិធីម្ហូបអាហារស្អាត**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។

៣- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៧ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី១៥ តាមរយៈប្រព័ន្ធបញ្ជូនរូបភាពនិងសំឡេង(Video Conference) នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០។

ឆ- ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីសម្ពោធឆ្លងសាលាធម្មសភា សាលាពុទ្ធិកបឋមសិក្សា កុដិធំ ចាក់សាបទីធ្លា និងសមិទ្ធផលនានាក្នុងវត្តពោធិ៍រង្សី ហៅវត្តត្រពាំងឫស្សី នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០។

២- ពិធីសម្ពោធឆ្លងសាលាធម្មសភានិងសមិទ្ធផលនានាក្នុងវត្តគិរីទក្ខិណារាម ហៅវត្តក្បាលបឹងសេះ នៅឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០។

៣- ពិធីសម្ពោធឆ្លងកុដិធំ សាលាបុណ្យ និងឧបដ្ឋានសាលាក្នុងវត្តអង្គនារាម ហៅវត្តស្រែសៀម នៅឃុំដីពោធិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០។

៤- ពិធីសម្ពោធឆ្លងរបង កុដិ ប្រព័ន្ធលូទឹក និងសមិទ្ធផលនានានៅវត្តព្រះពន្លៃ ហៅវត្តពន្លៃ នៅឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០។

៥- ពិធីកាត់ឫសសីមានិងសម្ពោធសមិទ្ធផលនានា នៅវត្តព្រះពុទ្ធមហាស្រ្តារាម ហៅវត្តគីឡូ៣៧ នៅឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០។

## ឆ្នាំ២០២១

១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្ដីការថ្មី ក្រសួងសាធារណការនិងដឹកជញ្ជូន និងវិទ្យាស្ថាន«**តេជោ សែន សាធារណការនិងដឹកជញ្ជូន**» នៅសង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នាថ្ងៃសុក្រ ៩កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០២១។

២- ពិធីបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតបាក់ខែង និងសម្ពោធរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតចំការមន ប្រព្រឹត្តទៅនៅខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ នាថ្ងៃចន្ទ ៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១។

៣- ពិធីប្រគល់ ទទួលវ៉ាក់សាំងស៊ីណូហ្វាម(SARS-COV-2 Sinopharm) ចំនួន៦០ម៉ឺនដូសពីរដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់រាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃអាទិត្យ ១០រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងល្ងាចថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២១។

៤- ពិធីប្រគល់ ទទួលអំណោយដ៏ថ្លៃថ្លា វ៉ាក់សាំងកូវីដ-១៩(AstraZeneca) ចំនួន៣៣២ ០០០ដូស ពីរដ្ឋាភិបាលនិងប្រជាជននៃប្រទេសជប៉ុន ជូនរាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃសុក្រ ១៤កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងរាត្រីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១។

៥- ពិធីបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់កុមារនិងយុវវ័យ ពីអាយុ១២ឆ្នាំដល់ក្រោម១៨ឆ្នាំ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី នាថ្ងៃអាទិត្យ ៨រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២១។

៦- ពិធីប្រគល់ ទទួលវ៉ាក់សាំងកូវីដ-១៩(AstraZeneca) ចំនួន៤១៥ ០០០ដូស ពីចក្រភពអង់គ្លេស ជូនរាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃព្រហស្បតិ៍ ១២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១។

៧- ពិធីប្រគល់ទទួលវិមានកីឡដ្ឋាននៃពហុកីឡដ្ឋានជាតិមរតកតេជោ ជាជំនួយហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **វ៉ាង យី** ទីប្រឹក្សារដ្ឋនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា នាថ្ងៃអាទិត្យ ៦កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១។

៨- ពិធីចុះហត្ថលេខាលើឯកសាចំនួន៦ រវាងកម្ពុជា-ចិន ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **វ៉ាង យី** ទីប្រឹក្សារដ្ឋនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី នាថ្ងៃអាទិត្យ ៦កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១។

៩- ពិធីបើកយុទ្ធនាការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ សម្រាប់កុមារចាប់ពីអាយុ៦ឆ្នាំ ដល់ក្រោម១២ឆ្នាំ ចាប់ផ្ដើមពីថ្ងៃសុក្រទី១៧ ខែកញ្ញា ឆ្នាំ២០២១ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ១១កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១។

១០- ពិធីប្រកាសបិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទី១ សម្រាប់ក្រុមចាប់ពីអាយុ៦ឆ្នាំឡើង ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារដល់

អាយុ៥ឆ្នាំ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវព្រឹកនឹងថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។

១១- ពិធីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ខួន ញឹុល** អនុប្រធានទី១ នៃរដ្ឋសភា ដែលបានទទួលមរណភាពកាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅភូមិគ្រឹះសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃសៅរ៍ ២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២១។

១២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្តីការថ្មីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១។

១៣- ពិធីអបអរសាទរការផ្តល់វ៉ាក់សាំងរបស់រដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋប្រជា-មានិតចិនចំនួន**២លានដូស** ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃពុធ ១៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១។

១៤- ពិធីសម្ពោធស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រង់ ក្រូចឆ្មារ ឬស្ពានភ្ជាប់និស្សិយ ប្រវែង១ ១៣១ម. ទទឹង១៣,៥ម. ចំណាយថវិកាប្រមាណ៥៦លានដុល្លារអាម៉េរិក និងពិធីប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ ៧១C ប្រវែង១១៤,៦២គ.ម. ចំណាយថវិកាប្រមាណ១៣០លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅខេត្តកំពង់ចាម កាលពីថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១។

១៥- ពិធីជប់លៀងផ្លូវការជាមួយឯកឧត្តមបណ្ឌិត **ផនខាំ វីផាវ៉ាន់** (Phankham Viphavanh) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតឡាវ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១។

១៦- ពិធីសម្ពោធហេដ្ឋារចនាសម្ព័ន្ធផ្លូវ**៣៧ខ្សែ** ប្រវែងជាង**៨៤គ.ម.** ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ២កន្លែង និងសមិទ្ធផលនានា ក្នុងខេត្តព្រះសីហនុ ចំណាយថវិកាជាតិប្រមាណ៣២៤លានដុល្លារអាម៉េរិក នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១។

១៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ១១ និងផ្លូវក្នុងក្រុងព្រៃវែង សរុបប្រវែង**៩៦,៤៨គ.ម.** ចាប់ពីអ្នកលឿងចំណុចប្រសព្វផ្លូវជាតិលេខ១ ខេត្តព្រៃវែងដល់ថ្នល់ទទឹង ចំណុចប្រសព្វផ្លូវជាតិលេខ៧ ខេត្តត្បូងឃ្មុំ ចំណាយថវិកាប្រមាណ៩៨,៣៨លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តព្រៃវែង កាលពីថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២១។

១៨- ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះសពសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ នៅព្រះរាជដំណាក់ សង្កាត់បឹងរាំង ខណ្ឌដូនពេញរាជធានីភ្នំពេញ កាលពីថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២១។

១៩- ការចុះត្រួតពិនិត្យវឌ្ឍនភាពនៃការសាងសង់ព្រលានយន្តហោះអន្តរជាតិថ្មី(អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ) និងសំណេះសំណាលជាមួយក្រុមការងារសាងសង់ ចំណាយថវិកាប្រមាណ១ ៥០០

លានដុល្លារអាម៉េរិក នៅឃុំព្រែកស្លែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១។

២០- ពិធីក្រុងពាលី និងសំណេះសំណាលជាមួយក្រុមការងារថតខ្សែភាពយន្តរឿងភាគ«**កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរមី**» នៅភូមិគ្រឹះក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។

២១- ពិធីសម្ពោធសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ របស់ក្រុមហ៊ុនជីប ម៉ុង ចំណាយថវិកាប្រមាណ១៨០លានដុល្លារអាម៉េរិក នៅសង្កាត់ជ័យជំនះ ខណ្ឌដូនពេញរាជធានីភ្នំពេញ កាលពីថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

២២- ពិធីសម្ពោធវិមានកីឡដ្ឋាននៃពហុកីឡដ្ឋានជាតិមរតកតេជោ រាប់ថយក្រោយ**៥០២ថ្ងៃ** ចំណាយថវិកាប្រមាណ១៥០លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងបើកយុទ្ធនាការផ្សព្វផ្សាយស៊ីហ្គេម អាស៊ាន ប៉ារ៉ាស៊ីហ្គេម ២០២៣ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា កាលពីថ្ងៃសៅរ៍ ១៤កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១។

២៣- ពិធីចុះហត្ថលេខាលើឯកសារចំនួន៧ ជាមួយឯកឧត្តម **ង្វៀន សួនហ្វ៊ុក** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

២៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាលគយ អគារសាលាជាតិគយ និងអគារសារមន្ទីរគយនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅខណ្ឌដូនពេញ កាលពីថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១។

២៥- ពិធីប្រកាសបើកការប្រកួតវាយកូនហ្គោល«**ពានរង្វាន់សម្ដេចតេជោ នាយករដ្ឋមន្ត្រីលើកទី៥**» នៅទីលានកូនហ្គោលវឌ្ឍនៈ ហ្គោលរីសត នៅក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃសៅរ៍ ៦រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១។

២៦- ពិធីប្រគល់«**ពានរង្វាន់សម្ដេចតេជោ នាយករដ្ឋមន្ត្រី លើកទី៥**» នៅទីលានកូនហ្គោលវឌ្ឍនៈ ហ្គោលរីសត នៅក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃសៅរ៍ ៦រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១។

២៧- ពិធីប្រគល់ទទួលវ៉ាក់សាំងកូវីដ-១៩ Pfizer ចំនួន២,៣៥លានដូស ពីរដ្ឋាភិបាលនិងប្រជាជនប្រទេសអូស្ត្រាលី ជូនរាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃអាទិត្យ ៧រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងរាត្រីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១។

២៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាលនិងសាលប្រជុំ ក្រសួងការពារជាតិ នៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១។

**ទន្ទឹមនេះ ទូលព្រះបង្គំជាខ្ញុំបានអនុញ្ញាតឱ្យ៖**

១- លោកជំទាវ Devi Uttamkhobragade ឯកអគ្គរដ្ឋទូតឥណ្ឌាថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃចន្ទ ៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

២- លោកជំទាវ Maria Amelita C. Aquino ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋហ្វីលីពីនថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ៦កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។

៣- លោកជំទាវ Tep Lay Cheang ឯកអគ្គរដ្ឋទូតថ្មីសិង្ហបុរីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអង្គារ ១០កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១។

៤- លោកជំទាវ Wendy Ruth Sherman អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិកចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១។

៥- ឯកឧត្តម Martin Vavra ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋឆែកតែងតាំងថ្មី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១។

៦- លោកជំទាវ Eva Nguyen Binh ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ចប់អាណត្តិចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ៩កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១។

៧- ឯកឧត្តម **វ៉ូ ក្វាង មិញ** (Vu Quang Minh) ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសៅរ៍ ៩រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២១។

៨- លោកជំទាវ **ម៉ារីស ផេន** (Marise Payne) រដ្ឋមន្ត្រីការបរទេសនិងជារដ្ឋមន្ត្រីកិច្ចការនារីនៃប្រទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១។

៩- ឯកឧត្តម **ង្វៀន ហ៊ុយតាំង** (Nguyen Huy Tang) ឯកអគ្គរដ្ឋទូតវៀតណាមថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។

១០- ឯកឧត្តម **ហ្សាក់ ប៉ឺឡេ** (Jacques Pellet) ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណៈរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។

១១- លោកជំទាវ **រ៉េតណូ អិល ភី ម៉ារស៊ូឌី** ( Retno L.P.Marsudi ) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១។

១២- ឯកឧត្តម **វុនណា ម៉ោងល្វីន** ( Wunna Maung Lwin ) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអង្គារ ៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២១។

១៣- ឯកឧត្តម **នីកូឡាយ ប៉ាទ្រូឆេហ្វ** ( Nikolai Patrushev ) លេខាធិការនៃក្រុមប្រឹក្សាសន្តិសុខនៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

១៤- ឯកឧត្តម **ដន ប្រាម៉ាត់វីណៃ** ( Don Pramudwinai ) ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនៃព្រះរាជាណាចក្រថៃ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។

**ក្រៅពីនេះ សម្តេច ឯកឧត្តម និងលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់ទូលព្រះបង្គំជាខ្ញុំ៖**

ក- សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីប្រគល់វ៉ាក់សាំងស៊ីណូហ្វាម( SARS-COV-2 Sinopharm ) ចំនួន៧០ម៉ឺនដូសពីរដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់រាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃពុធ ៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងរាត្រីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។

២- ពិធីអបអរសាទរខួប២៣ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះឈ្នះរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានឈ្នះឈ្នះ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។

ខ- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៩ នៅសាលសន្និសីទចតុមុខ កាលពីថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

២- ពិធីរំលឹកគុណអង្គរ នៅស្ពានហាលប្រាសាទអង្គរវត្ត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

គ- ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមជាអធិបតីក្នុងពិធីប្រារព្ធ ខួបលើកទី៣០នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃសៅរ៍ ២រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១។

ឃ- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០និងលើកទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅទីស្តីការក្រសួងសាធារណការនិងដឹកជញ្ជូន កាលពីថ្ងៃពុធ ៦កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងល្ងាចថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។

- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងពាណិជ្ជកម្ម តាមកម្មវិធីZoom កាលពីថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១។

ង- ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីកាត់ឫសសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានា នៅក្នុងវត្តជោតិរង្សី ហៅវត្តបុស្ស ឃុំរូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃសៅរ៍ ៩កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១

២- ពិធីបញ្ចុះបឋមសិលាសាងសង់អគារទី២ នៃមន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃចន្ទ ៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១។

រៀបចំចងក្រង និងបោះពុម្ពផ្សាយ

នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

លេខទូរស័ព្ទលេខ : ០១២ ៧៩១ ៨៨៨/០១២ ៩០៨ ៥៥២

ទូរសារ : ០២៣ ២១២ ៤២៣

Email : monisovan@yahoo.com




# ផែនទីបណ្តាញផ្លូវជាតិនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២